# ព្រះត្រៃបិដក

## ប្រែរួមនឹង ព្រះអដ្ឋកថា

## ភាគ៤៨

បាលីប្រែ ៥៩

ពុទ្ធសករាជ ២៥៥៣

ច្បាប់ពិនិត្យ លើកទី២

# ព្រះ

# សុត្តន្តបិដក

## និង

## ជាតកដ្ឋកថា

### សេចក្តីប្រែជាភាសាខ្មែរ

## ខុទ្ទកនិកាយ ជាតក

## អដ្ឋមភាគ

## ៤៨

## បាលីប្រែ ៥៩



*បោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៥៣*

# ក្បាលទី ៤៨

# សុត្តន្តបិដក អដ្ឋកនិបាត ជាតក

## កច្ចានិវគ្គ

## កច្ចានិជាតក

[ ៤១៩ ] ( ព្រះឥន្ទ្រពោធិសត្វបានពោលថា ) ម្នាលនាងកច្ចានី ប្ដីក៏បានជានាងស្លៀកដណ្ដប់សំពត់សស្អាត មានសក់ទទឹក ហើយដាំឆ្នាំង លាងមេ្សៅល្ង និងអង្ករ បាយលាយដោយល្ង កើតមានឡើង តើព្រោះហេតុដូចម្ដេច ។

[ ៤២០ ] ( នាងកច្ចានីបានពោលថា ) ម្នាលព្រាហ្មណ៍ បាយលាយដោយល្ងដែលខ្ញុំចម្អិនដោយប្រពៃនេះ មិនមែនបម្រុងនឹងបរិភោគខ្លួនឯងទេ ( ព្រោះថា ) ធម៌ស្លាប់បាត់ទៅហើយ ថ្ងៃនេះខ្ញុំនឹងធ្វើការបូជាចំពោះធម៌នោះ ក្នុងកណ្ដាលព្រៃស្មសាន ។

[ ៤២១ ] ( ព្រះឥន្ទ្រពោលថា ) ម្នាលនាងកច្ចានី នាងចូរពិចារណាសិន ហើយសឹមធ្វើនូវកិច្ចដែលត្រូវធ្វើចុះ អ្នកណាប្រាប់នាងថា ធម៌ស្លាប់ទៅហើយ ព្រះសហស្សនេត្ត គឺព្រះឥន្ទ្រមានអានុភាពរកអ្វីថ្លែងថ្លឹកពុំបាន ជាបុគ្គលមានធម៌ដ៏ប្រសើរមិនដែលស្លាប់ក្នុងកាលណាម្ដងឡើយ ។

[ ៤២២ ] ( នាងកច្ចានីពោលថា ) ម្នាលព្រហ្ម ការណ៍ប្រមាណដ៏មាំរបស់ខ្ញុំក្នុងហេតុនេះ ធម៌ស្លាប់បាត់ទៅហើយ ខ្ញុំមិនមានសង្ស័យក្នុងហេតុនេះទេ ឥឡូវនេះ ពួកជនណាៗ ដែលជាបុគ្គលលាមក ពួកជននោះៗ បែរជាបានសុខក្នុងកាលឥឡូវនេះ ។

ត្បិតកូនប្រសាស្រីខ្ញុំ ជាស្រីអារ វាបណ្ដេញខ្ញុំហើយ សម្រាលកូនប្រុស ឥឡូវនេះ វាបានជាធំលើត្រកូលទាំងអស់ ខ្ញុំជាស្ត្រីមិនមានទីពឹង នៅតែម្នាក់ឯង ។

[ ៤២៣ ] ( ព្រះឥន្ទ្រពោលថា ) យើងនៅរស់ យើងមិនទាន់ស្លាប់នៅឡើយ យើងមកក្នុងទីនេះ ក៏ដើម្បីជាប្រយោជន៍ដល់នាងឯង កូនប្រសាស្រីណា ដែលបានបណ្ដេញនាង ហើយបានកូនប្រុស យើងនឹងធ្វើកូនប្រសានោះឲ្យខ្ទេចជាផេះ ព្រមទាំងកូនប្រុសមិនខាន ។

[ ៤២៤ ] ( នាងកច្ចានីពោលថា ) បពិត្រទេវរាជ លោកគាប់ចិត្តយ៉ាងនេះ លោកអញ្ជើញមកក្នុងទីនេះ ដើម្បីប្រយោជន៍ដល់ខ្ញុំ តែសូមឲ្យខ្ញុំ និងកូនប្រុស កូនប្រសាស្រី ចៅ ជាបុគ្គលមានសេចក្ដីរីករាយរកគ្នា ហើយនៅគ្រប់គ្រងផ្ទះវិញ ។

[ ៤២៥ ] ( ព្រះឥន្ទ្រពោលថា ) ម្នាលនាងកច្ចានី បើនាងគាប់ចិត្តយ៉ាងនេះ នាងសូម្បីកូនប្រសាស្រីបៀតបៀនហើយ ក៏នៅតែមិនលះបង់នូវធម៌ឡើយ ( ហេតុនេះ ) សូមឲ្យនាង និងកូន

ប្រុស កូនប្រសាស្រី ចៅ ចូរជាបុគ្គលមានសេចក្តីរីករាយរកគ្នា ហើយនៅគ្រប់គ្រងផ្ទះចុះ ។

[ ៤២៦ ] ( ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា ) នាងកច្ចានីមានសេចក្តីរីករាយរកគ្នា ជាមួយនឹងកូនប្រសាស្រី ហើយនៅគ្រប់គ្រងផ្ទះ ទាំងកូនប្រុស និងចៅ ត្រូវព្រះឥន្ទ្រជាធំជាងពួកទេវតា ជួយអនុគ្រោះហើយ ក៏បាននាំគ្នាបម្រើមាតានោះវិញ ។

**កច្ចានិជាតកទី ១ ចប់**

# អដ្ឋកថា
# អដ្ឋកនិបាត ជាតក

## កច្ចានិវគ្គ
### កច្ចានិជាតក

[ ៤១៩-៤២៦ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធឧបាសកអ្នកចិញ្ចឹមមាតាម្នាក់ ទើបត្រាស់រឿងនេះ មានពាក្យផ្តើមថា **ឱទាតវត្ថា សុចិ អល្លកេសា** ដូច្នេះជាដើម ។

បានឮថា ឧបាសកអ្នកចិញ្ចឹមមាតានោះ ជាកូនដែលល្អក្នុងក្រុងសាវត្ថី ជាបុគ្គលមានមារយាទល្អ កាលបិតាស្លាប់ហើយ គេបូជាមាតាដូចទេវតា ទំនុកបម្រុងមាតា ដោយការខ្វល់ខ្វាយ រៀបចំទឹកលុបមុខ ទឹកខ្ពុរមាត់ ឈើស្ទន់ ទឹកងូត ទឹកលាងជើង បបរ និងភត្តជាដើម ។ សម័យមួយ មាតាពោលថា នែកូន ឯងមានការងារដែលជារឿងរបស់យកវាសច្រើន ចូរនាំស្រីដែលមានត្រកូលស្មើគ្នាម្នាក់មកធ្វើករិយា នាងនឹងចិញ្ចឹមម៉ែ ចំណែកឯងនឹងបានធ្វើការងាររបស់ខ្លួន ។ បុរសនោះពោលថា បពិត្រអ្នកម៉ែ ខ្ញុំបំណងប្រយោជន៍សម្រាប់ខ្លួន ទើបទំនុកបម្រុងអ្នកម៉ែ អ្នកដទៃឯណានឹងទំនុកបម្រុងបានយ៉ាងនេះ ។ មាតាពោលថា កូនជាទីស្រឡាញ់ ឯងគួរធ្វើការងារដែលឲ្យត្រកូលចម្រើន បុរសនោះពោលថា ខ្ញុំមិនត្រូវការគ្រប់គ្រងផ្ទះ ខ្ញុំនឹងចិញ្ចឹម

អ្នកម៉ែ ត្រាតែម៉ែអស់ជីវិត ហើយខ្ញុំនឹងបួស ។ លំដាប់នោះ មាតារបស់បុរសនោះអង្វររឿយៗ ក៏មិនបានដូចចិត្ត ទើបមិនកាន់យកការពេញចិត្តរបស់បុរសនោះជាគោលសំខាន់ នាំស្រីដែលមានជាតិត្រកូលស្មើគ្នាមកឲ្យដល់កូននោះ ។ គេមិនបានជំទាស់ដល់បំណងមាតា បាននៅរួមជាមួយស្រីនោះ ។ សូម្បីស្រីនោះក៏គិតថា ស្វាមីរបស់អញចិញ្ចឹមមាតាដោយឧស្សាហ៍ដ៏ក្រៃលែង សូម្បីអញ ក៏គួរទំនុកបម្រុងលោក កាលអញធ្វើយ៉ាងនេះ ក៏នឹងជាទីស្រឡាញ់របស់ប្ដី គិតដូច្នេះហើយ ក៏ទំនុកបម្រុងម្ដាយក្មេកដោយគោរព ។ ឧបាសកចិញ្ចឹមមាតា គិតថា ស្រីនេះ បម្រើម្ដាយរបស់អញដោយគោរពរាប់តាំងអំពីនោះមក បុរសនោះ បានឲ្យរបស់បរិភោគដែលមានរសឆ្ងាញ់ដែលបានមកហើយដល់នាងនោះឯង ។ ក្នុងកាលតមក ស្រីនោះគិតថា បុរសនេះឲ្យរបស់ស៊ីដែលមានរសឆ្ងាញ់ ដែលបានមកដល់អញប៉ុណ្ណោះ បុរសនេះគង់ត្រូវការបណ្ដេញមាតា ដោយពិត អញនឹងធ្វើឧបាយបណ្ដេញដល់គាត់ទើបក្លែចខ្លួន គិតទៅដោយមិនពិចារណាយ៉ាងនេះ ។ ថ្ងៃមួយ ទើបប្រាប់ប្ដីថា នែអ្នក កាលអ្នកចេញទៅខាងក្រៅ ម្ដាយរបស់អ្នកជេរខ្ញុំ ។ បុរសនោះបាននៅស្ងៀម ស្រីនោះគិតថា អញនឹងឲ្យដាក់ទោសដល់ស្រីចាស់នេះ ហើយធ្វើឲ្យស្រីនេះស្អប់កូនប្រុស ។ តាំងអំពីនោះមក កាលនាងឲ្យបបរ ក៏ឲ្យបបរក្ដៅពេកខ្លះ ត្រជាក់ពេកខ្លះ សាបខ្លះ ប្រៃខ្លះ កាលម្ដាយក្មេកប្រាប់ថា នែនាង បបរក្ដៅពេក ឬត្រជាក់ពេក នាងក៏ចាក់ទឹកត្រជាក់ចូល កាលម្ដាយក្មេកប្រាប់ថា ត្រជាក់ពេក ប្រៃពេក នាងក៏បញ្ចេញសំឡេងឡើងថា អម្បាញ់មិញ

ម៉ែប្រាប់ថា ក្ដៅពេក ប្រែពេក អ្នកណាអាចធ្វើឲ្យត្រូវចិត្តម៉ែបាន សូម្បីទឹកសម្រាប់ងូត នាងក៏ដាំទាល់តែក្ដៅ ហើយស្រោចលើខ្នង កាលម៉ែក្មេកប្រាប់ថា នែនាង ខ្នងម៉ែឆេះហើយ នាងក៏យកទឹកត្រជាក់ចាក់រហូតពេញ កាលម្ដាយក្មេកប្រាប់ថា ត្រជាក់ណាស់កូន នាងក៏ដើរប្រាប់អ្នកស្រុកថា ម៉ែក្មេកខ្ញុំពោលថា ទឹកសម្រាប់ងូតក្ដៅខ្លាំង ឥឡូវនេះ ក៏បែរជាស្រែកឡើងថា ត្រជាក់ពេក នរណាអាចតម្រូវចិត្តស្រីចាស់នេះបាន ។ កាលម៉ែក្មេកប្រាប់ថា នែនាង ទីដេករបស់ម៉ែមានសង្អើច នាងក៏នាំចេញមក ហើយយកគ្រែរបស់ខ្លួនគោះដាក់លើគ្រែនោះ ប្រាប់ថា ខ្ញុំគោះហើយ ហើយនាំទៅតម្កល់នៅកន្លែងដើម ។ ម៉ែក្មេកជាឧបាសិកាត្រូវសង្អើចខាំ ក៏អង្គុយទល់ភ្លឺ លុះព្រឹកឡើងពោលថា នែនាង ម៉ែត្រូវសង្អើចខាំមួយយប់ទល់ភ្លឺ ។ កូនប្រសាក៏ប្រកែកថា ម្សិលមិញ ខ្ញុំបានគោះគ្រែរបស់ម៉ែហើយ នរណាអាចជួយការងាររបស់មនុស្សបែបនេះបាន ហើយគិតថា ពេលនេះ អញនឹងឲ្យកូនប្រុសរបស់គាត់ដាក់ទោស ទើបក្អែងស្ដោះទឹកមាត់ ញើសសម្បោរដាក់ក្នុងទីនោះៗ កាលប្ដីសួរថា អ្នកណាធ្វើផ្ទះនេះឲ្យស្មោកគ្រោក នាងក៏ពោលថា ម្ដាយរបស់អ្នកធ្វើយ៉ាងនេះ ខ្ញុំប្រាប់ថា កុំធ្វើ ក៏មានទូវជម្លោះ ខ្ញុំមិនអាចនៅរួមផ្ទះជាមួយស្រីកាឡកិណីបែបនេះបានឡើយ ផ្ទះរបស់អ្នក ឲ្យម្ដាយរបស់អ្នកនៅ ឬឲ្យខ្ញុំនៅ ។ ឧបាសកអ្នកចិញ្ចឹមមាតា បានស្ដាប់ពាក្យរបស់នាងហើយ បានពោលថា អើនាង នាងនៅក្មេង រស់នៅទីណាក៏បាន ចំណែកម្ដាយរបស់ខ្ញុំជាមនុស្សចាស់ទុព្វលភាព ខ្ញុំប៉ុណ្ណោះជាទីពឹងរបស់គាត់ ចូរនាងចេញអំពីផ្ទះ

នេះ ទៅកាន់ត្រកូលរបស់ខ្លួនចុះ ។ នាងបានស្ដាប់ពាក្យរបស់ប្ដីហើយ ភិតភ័យ គិតថា អញមិនអាចបំបែកប្ដីរបស់អញ ចេញពីមាតាបាន មាតាជាទីស្រឡាញ់របស់គាត់តែម្យ៉ាង បើអញទៅកាន់ផ្ទះត្រកូល អញនឹងនៅមេម៉ាយបានទទួលតែសេចក្ដីទុក្ខប៉ុណ្ណោះ អញនឹងបដិបត្តិម៉ែក្មេកឲ្យដូចក្នុងកាលមុន តាំងពីនោះមក នាងបានបដិបត្តិម៉ែក្មេកដូចកាលពីមុន ។

ថ្ងៃមួយ ឧបាសកចិញ្ចឹមមាតានោះ ទៅកាន់វត្តជេតពនដើម្បីស្ដាប់ធម៌ ថ្វាយបង្គំព្រះសាស្ដាហើយ អង្គុយក្នុងទីសមគួរនាចំណែកម្ខាង ។ ព្រះបរម-សាស្ដាត្រាស់សួរថា ឧបាសកអ្នកមិនប្រមាទក្នុងបុញ្ញកម្មទេឬ អ្នកបំពេញមាតាបិតុបដ្ឋានកិច្ចឬ បុរសនោះ ក្រាបទូលរឿងទាំងអស់ដល់ព្រះមុនីថា បពិត្រព្រះអង្គដ៏ចម្រើន មាតារបស់ខ្ញុំព្រះអង្គ នាំស្រីក្នុងត្រកូលម្នាក់មកដើម្បីខ្ញុំព្រះអង្គ ដោយខ្ញុំព្រះអង្គមិនពេញចិត្តឡើយ ស្រីនោះ បានធ្វើអនាចារផ្សេងៗ បពិត្រព្រះមានព្រះភាគ តែទោះជាយ៉ាងនេះ នាងក៏មិនអាចបំបែកខ្ញុំព្រះអង្គអំពីមាតាបាន ឥឡូវនេះ នាងបានចិញ្ចឹមមាតាដោយគោរព ។

ព្រះសាស្ដាស្ដាប់ពាក្យរបស់ឧបាសកនោះហើយ មានព្រះតម្រាស់ថា ម្នាលឧបាសក ឥឡូវនេះ អ្នកមិនធ្វើតាមពាក្យរបស់ស្រីនោះ តែក្នុងកាលមុន អ្នកបានបណ្ដេញម្ដាយរបស់អ្នកតាមពាក្យរបស់នាង តែបានអាស្រ័យតថាគត ទើបនាំមាតាមកកាន់ផ្ទះ ទំនុកបម្រុងទៀត ឧបាសកទូលអារាធនា ទើបទ្រង់នាំរឿងក្នុងអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិក្នុងនគរពារាណសី

កុលបុត្រនៃត្រកូលមួយ កាលបិតាស្លាប់ហើយ គេបូជាមាតាដូចទេវតា បដិបត្តិមាតាដោយទំនងដូចពោលហើយ រឿងទាំងអស់ មានអត្ថពិស្តារតាមទំនងដែលពោលខាងដើមនោះឯង ។ ឯសេចក្តីដ៏សេស នឹងពណ៌នាដូចតទៅ កាលស្រីនោះពោលនឹងប្តីថា ខ្ញុំមិនអាចនៅរួមជាមួយស្រីកាឡកិណីបែបនេះបាន ផ្ទះនេះ អ្នកឲ្យម្តាយរបស់អ្នកនៅ ឬឲ្យខ្ញុំនៅ កុលបុត្រនោះ ជឿពាក្យរបស់ស្រីនោះ គិតថា នេះជាកំហុសរបស់ម៉ែអញតែម្នាក់ ទើបពោលនឹងមាតាថា ម៉ែ ម៉ែបង្កជម្លោះក្នុងផ្ទះនេះជានិច្ច សូមម៉ែចេញអំពីផ្ទះនេះ ទៅនៅទីដទៃតាមគាប់ចិត្តចុះ ។ មាតាពោលថា សាធុ យំហើយ ចេញអំពីផ្ទះ ទៅអាស្រ័យត្រកូលដែលជាសម្លាញ់មួយ ធ្វើការស៊ីឈ្នួលគេចិញ្ចឹមជីវិត ដោយសេចក្តីលំបាក កាលកូនប្រសាធ្វើនូវជម្លោះជាមួយម៉ែក្មេកក្នុងផ្ទះ រហូតដល់ម៉ែក្មេកចេញអំពីផ្ទះទៅហើយ នាងក៏មានទម្ងន់ នាងប្រាប់ប្តី និងដើរពោលប្រាប់អ្នកស្រុកថា កាលស្រីកាឡកិណីនោះនៅក្នុងផ្ទះ ខ្ញុំមិនមានគភ៌ ឥឡូវនេះ ខ្ញុំមានគភ៌ហើយ ។

តមក នាងប្រសូតបុត្រ ហើយពោលនឹងប្តីជាទីស្រឡាញ់ថា កាលមាតារបស់បងនៅក្នុងផ្ទះ ខ្ញុំមិនមានកូន ឥឡូវនេះ ខ្ញុំមានហើយ សូមបងដឹងថា មាតារបស់បង ជាកាឡកិណី ដោយហេតុនេះចុះ ។ ចំណែកស្ត្រីជាមាតាបានឮថា កូនប្រសាបានបុត្រក្នុងកាលដែលខ្លួនត្រូវដេញចេញពីផ្ទះ នាងគិតថា ក្នុងលោកនេះ ធម៌ពិតជាស្លាប់ទៅហើយ បើធម៌មិនទាន់សាបសូន្យ អ្នកដែលវាយមាតា ហើយបណ្តេញចេញអំពីផ្ទះ មិនគួរបានកូនឡើយ មិន

គួររស់នៅយ៉ាងសប្បាយ អញនឹងថ្វាយមតកភត្តដល់ធម៌ ។ ថ្ងៃមួយ នាងកាន់ល្ង ម្សៅ អង្ករ ថាសមួយ និងវែក ទៅកាន់ព្រៃខ្មោច យកលលាដ៍ក្បាលខ្មោចមកធ្វើជើងក្រាន បង្កាត់ភ្លើងហើយ ចុះទឹកស្រះ ឲ្យសើមក្បាលខ្លួនមាត់ហើយ ឡើងមកដុតភ្លើង រំសាយសក់ ហើយលាងអង្ករ ។

សម័យនោះ ព្រះពោធិសត្វសោយព្រះជាតិជាសក្កទេវរាជ ធម្មតា ព្រះពោធិសត្វទាំងឡាយ រមែងជាសត្វមិនប្រមាទ ។ ខណៈនោះ លោកប្រមើលមើលសត្វលោក ឃើញស្ត្រីនោះកំពុងមានទុក្ខ បំណងនឹងថ្វាយមតកភត្តដល់ធម៌ ព្រោះយល់ថា ធម៌ស្លាប់ទៅហើយ ទើបទ្រង់ត្រិះរិះថា ថ្ងៃនេះ អញនឹងបង្ហាញកម្លាំងរបស់អញ កាឡាខ្លួនជាព្រាហ្មណ៍ ធ្វើជាដើរទៅ លុះឃើញស្រីនោះ ទើបចូលទៅឈរជិត ពោលថា នែអ្នកម៉ែ មានរឿងអ្វី ទើបមកចម្អិនអាហារក្នុងព្រៃខ្មោច នាងយកបាយលាយល្ងដែលធ្វើឲ្យឆ្អិនក្នុងព្រៃខ្មោចទៅធ្វើអ្វី ដូច្នេះ កាលនឹងផ្តើមសន្ទនា ទើបពោលគាថាទី ១ ថា

ម្នាលនាងកច្ចានី ប្តីក៏បានជានាងស្លៀកដណ្តប់សំពត់សស្អាត
មានសក់ទទឹក ហើយដាំឆ្នាំង លាងម្សៅល្ង និងអង្ករ បាយ
លាយដោយល្ង កើតមានឡើង តើព្រោះហេតុដូចម្តេច ដូច្នេះ ។

គប្បីជ្រាបអធិប្បាយក្នុងគាថានោះដូចតទៅនេះ សក្កទេវរាជហៅស្ត្រីនោះដោយគោត្រថា **កច្ចានី** ។

បទថា **កុម្ភិមធិស្សយិត្វា** សេចក្តីថា លើកថាសសម្រាប់ដាំដាក់លើជើងក្រានដែលធ្វើដោយក្បាលមនុស្ស ។

បទថា **ហោហិតិ** សេចក្តីថា បាយល្វនេះមានដើម្បីអ្វី គឺនាងបរិភោគដោយខ្លួនឯង ឬមានហេតុដទៃទៀតលាក់បាំង ។

លំដាប់នោះ កាលប្រាប់សេចក្តីនោះដល់សក្កទេវរាជ បានពោលគាថាទី ២ ថា

ម្នាលព្រាហ្មណ៍ បាយ លាយដោយល្វ ដែលខ្ញុំចម្អិនដោយ
ប្រពៃនេះ មិនមែនបម្រុងនឹងបរិភោគខ្លួនឯងទេ ( ព្រោះថា )
ធម៌ស្លាប់បាត់ទៅហើយ ថ្ងៃនេះ ខ្ញុំនឹងធ្វើការបូជាចំពោះធម៌នោះ
ក្នុងកណ្តាលព្រៃស្មសាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ធម្មោ** បានដល់ ធម៌ គឺការគោរពឱនលំទោនចំពោះបុគ្គលចម្រើនដោយវ័យ និងធម៌ គឺសុចរិត ៣ ប្រការ ។

បទថា **តស្ស បហូនមជ្ជ** សេចក្តីថា ខ្ញុំនឹងធ្វើមតកកត្ត គឺកត្តដើម្បីអ្នកស្លាប់នេះដល់ធម៌នោះ ។

លំដាប់នោះ សក្កទេវរាជបានត្រាស់គាថាទី ៣ ថា

ម្នាលនាងកច្ចានី នាងចូរពិចារណាសិន ហើយសឹមធ្វើនូវកិច្ច
ដែលត្រូវធ្វើចុះ អ្នកណាប្រាប់នាងថា ធម៌ស្លាប់ទៅហើយ ព្រះ
សហស្សនេត្ត គឺព្រះឥន្ទ្រ មានអានុភាពរកអ្វីថ្លឹងថ្មឹកពុំបាន
ជាបុគ្គលមានធម៌ដ៏ប្រសើរ មិនដែលស្លាប់ក្នុងកាលណាម្តង
ឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អនុវិច្ច** សេចក្តីថា ចូរនាងត្រិះរិះ គឺដឹងឲ្យ

ជាក់ច្បាស់សិន ។

បទថា **កោ នុ តវេតសំសិ** សេចក្តីថា នរណាហ្ន៎ប្រាប់សេចក្តីនេះដល់នាង ។

សក្កទេវរាជកាលទ្រង់សម្តែងខ្លួនរបស់ទ្រង់ ប្រៀបដូចធម៌ដ៏ប្រសើរ គឺធម៌ដ៏ឧត្តម ទើបត្រាស់យ៉ាងនេះថា **សហស្សនេត្តោ**។

នាងបានស្តាប់ដូច្នោះហើយ បានពោលគាថា ២ ថា

ម្នាលព្រហ្ម ការណ៍ប្រមាណដ៏មាំរបស់ខ្ញុំ ក្នុងហេតុនេះ ធម៌
ស្លាប់បាត់ទៅហើយ ខ្ញុំមិនមានសង្ស័យក្នុងហេតុនេះទេ ឥឡូវ
នេះ ពួកជនណាៗ ដែលជាបុគ្គលលាមក ពួកជននោះៗ បែរ
ជាបានសុខក្នុងកាលឥឡូវនេះ ។

ត្បិតកូនប្រសាស្រីខ្ញុំ ជាស្រីអារ វាបណ្តេញខ្ញុំហើយ
សម្រាលកូនប្រុស ឥឡូវនេះ វាបានជាធំលើត្រកូលទាំងអស់
ខ្ញុំជាស្ត្រីមិនមានទីពឹង នៅតែម្នាក់ឯង ។

បណ្តាបទទាំងនោះ បទថា **ទឡ្ហប្បមាណំ** សេចក្តីថា ស្ត្រីនោះពោលថា បពិត្រព្រាហ្មណ៍ ក្នុងបទដែលថា ធម៌សូន្យហើយនេះ ខ្ញុំគិតយ៉ាងពិតប្រាកដ មិនមានសង្ស័យឡើយ ។

បទថា **យេ យេ** សេចក្តីថា កាលស្ត្រីនោះសម្តែងហេតុ ក្នុងការដែលធម៌នោះជារបស់សូន្យហើយ ទើបពោលយ៉ាងនេះ ។

បណ្តាបទទាំងនោះ បទថា **វជិត្វាន** សេចក្តីថា នាងវាយបណ្តេញ ។

បទថា **អបវិដ្ឋា** សេចក្ដីថា ខ្ញុំត្រូវគេបោះបង់មិនមានទីពឹង ត្រូវនៅម្នាក់ឯង ។

បន្ទាប់អំពីនោះ សក្កៈបានពោលគាថាទី ៦ ថា

យើងនៅរស់ យើងមិនទាន់ស្លាប់នៅឡើយ យើងមកក្នុងទីនេះ
ក៏ដើម្បីជាប្រយោជន៍ដល់នាងឯង កូនប្រសាស្រីណា ដែល
បានបណ្ដេញនាង ហើយបានកូនប្រុស យើងនឹងធ្វើកូនប្រសា
នោះ ឲ្យខ្ទេចជាផេះ ព្រមទាំងកូនប្រុសមិនខាន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វោ** ត្រឹមតែជានិបាត ។ នាងបានស្ដាប់ដូច្នោះហើយ គិតថា អញនឹងពោលថ្វី អញនឹងធ្វើអាការដែលចៅរបស់អញមិនស្លាប់ ហើយពោលគាថាទី ៧ ថា

បពិត្រទេវរាជ លោកគាប់ចិត្តយ៉ាងនេះ លោកអញ្ជើញមកក្នុងទី
នេះ ដើម្បីប្រយោជន៍ដល់ខ្ញុំ តែសូមឲ្យខ្ញុំ និងកូនប្រុស កូន
ប្រសាស្រី ចៅ ជាបុគ្គលមានសេចក្ដីរីករាយរកគ្នា ហើយនៅ
គ្រប់គ្រងផ្ទះវិញ ដូច្នេះ ។

លំដាប់នោះ សក្កទេវរាជបានត្រាស់គាថាទី ៨ ថា

ម្នាលនាងកច្ចានី បើនាងគាប់ចិត្តយ៉ាងនេះ នាង សូម្បីកូនប្រសា
ស្រីបៀតបៀនហើយ ក៏នៅតែមិនលះបង់នូវធម៌ឡើយ ( ហេតុ
នេះ ) សូមឲ្យនាង និងកូនប្រុស កូនប្រសាស្រី ចៅ ចូរជាបុគ្គល
មានសេចក្ដីរីករាយរកគ្នា ហើយនៅគ្រប់គ្រងផ្ទះចុះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ហនាមិ សន្តា** សេចក្ដីថា ទោះបីត្រូវគេវាយ ទោះបីត្រូវគេបណ្ដេញ ក៏មិនលះបង់ធម៌ គឺមេត្តាក្នុងទារក កាលបើដូច្នោះ នាងប្រាថ្នាយ៉ាងណា ចូរសមបំណងយ៉ាងនោះចុះ យើងជ្រះថ្លាក្នុងគុណរបស់នាង ។

កាលសក្កទេវរាជ ទ្រង់ត្រាស់យ៉ាងនេះហើយ ក៏ប្រដាប់តាក់តែងព្រះកាយ ប្រថាប់ឈរលើអាកាសដោយអានុភាពរបស់ខ្លួន ហើយត្រាស់ថា នែកច្ចានី នាងកុំខ្លាចឡើយ កូនប្រុសក្ដី កូនប្រសារបស់នាងក្ដី នឹងមកដោយអានុភាពរបស់យើង សូមខមាទោសនាងក្នុងចន្លោះផ្លូវ ហើយនឹងនាំនាងទៅចូរនាងកុំប្រមាទ ដូច្នេះហើយ ទើបទៅកាន់វិមានរបស់ខ្លួន ។

ដោយអានុភាពរបស់សក្កទេវរាជ បណ្ដាលឲ្យជនទាំងនោះរឭកដល់គុណរបស់មាតា នាំគ្នាសួរមនុស្សក្នុងស្រុកថា មាតារបស់ខ្ញុំទៅណា កាលបានដឹងថា ទៅកាន់ព្រៃខ្មោច ទើបនាំគ្នាដើរទៅកាន់ព្រៃខ្មោចបណ្ដើរ ហៅបណ្ដើរថា ម៉ែ ! ម៉ែ ! លុះឃើញមាតា ក៏ក្រាបចុះទៀបជើងទាំងទ្វេ ហើយសូមខមាទោសថា បពិត្រអ្នកម៉ែ សូមម៉ែមេត្តាអត់នូវទោសដល់កូនចុះ កុំកាន់យកទោសពៃរ៍ឡើយ មាតាក៏លើកចោល ជនទាំងអស់ មានសេចក្ដីត្រេកអរ នាំគ្នាត្រឡប់មកផ្ទះដោយការសាមគ្គី តាំងអំពីនោះមក ដោយប្រការដូច្នេះ ។

ព្រះសាស្ដា ទ្រង់បានត្រាស់អភិសម្ពុទ្ធគាថាដូច្នេះថា

នាងកច្ចានីមានសេចក្តីរីករាយរកគ្នា ជាមួយនឹងកូនប្រសាស្រី ហើយនៅគ្រប់គ្រងផ្ទះ ទាំងកូនប្រុស និងចៅ ត្រូវព្រះឥន្ទ្រជាធំជាងពួកទេវតាជួយអនុគ្រោះហើយ ក៏បាននាំគ្នាបម្រើមាតានោះវិញ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សា កាតិយានី** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ នាងកច្ចានី ជាកច្ចាយនគោត្រ ។

បទថា **ទេវានមិន្ទេន អធិគ្គហីតា** សេចក្តីថា មនុស្សទាំងនោះ ដែលសក្កទេវរាជ ស្តេចទេវតា ទ្រង់អនុគ្រោះហើយ ទើបនៅរួមគ្នាដោយការស្ម័គ្រស្មាគម ដោយអានុភាពរបស់ទ្រង់ ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកត្រាស់ហើយ ទ្រង់ក៏ប្រកាសសច្ចៈទាំងឡាយ ក្នុងកាលចប់សច្ចធម៌ ឧបាសកអ្នកចិញ្ចឹមមាតានោះបានជាព្រះសោតាបន្ន ហើយទ្រង់សមោធានជាតកថា ឧបាសកចិញ្ចឹមមាតាក្នុងកាលនោះ បានមកជាឧបាសកចិញ្ចឹមមាតាក្នុងកាលឥឡូវនេះ ភរិយាក្នុងកាលនោះ បានមកជាភរិយាក្នុងកាលឥឡូវនេះ ឯសក្កទេវរាជក្នុងកាលនោះ គឺតថាគតនេះឯង ។៚

**អដ្ឋកថា កច្ចានិជាតក ចប់**

# សុត្តន្តបិដក

## អដ្ឋសទ្ទជាតក

[ ៤២៧ ] ( តាបសពោធិសត្វទូលព្រះរាជា អំពីពាក្យកុកថា ) ស្រះបោក្ខរណីនេះ ពីដើមជាទីទំនាប មានត្រីច្រើន មានទឹកច្រើន ជាទីលំនៅរបស់ស្ដេចកុក ជាកេរដំណែលខាងបិតា ជាទីលំនៅរបស់យើង ថ្ងៃនេះ ពួកយើងនោះ ចិញ្ចឹមជីវិតដោយសត្វកង្កែប នៅតែមិនលះបង់ទីលំនៅចោលឡើយ ។

[ ៤២៨ ] ( ទូលអំពីពាក្យក្អែកថា ) អ្នកណាហ្ន៎ បំបែកក្អែកជាគម្រប់ពីររបស់ទម័កជីរ ឈ្មោះពន្ទុរៈ ជាបុគ្គលទ្រុស្តសីល អ្នកណាហ្ន៎ នឹងធ្វើនូវកូនទាំងឡាយ និងសម្បុករបស់យើង ព្រមទាំងយើង ឲ្យមានសួស្តី ។

[ ៤២៩ ] ( ទូលអំពីពាក្យដង្កូវដួងថា ) ការប្រព្រឹត្តទៅនៃឈើស្រោយនោះ មាននៅត្រឹមណា ឈើស្រោយទាំងអស់ អស់រលីងហើយ បពិត្រមហារាជ ដង្កូវដួងអស់អាហារហើយ លែងត្រេកអរក្នុងឈើខ្ទឹម ។

[ ៤៣០ ] ( ទូលអំពីពាក្យមេតាវៅថា ) លុះអាត្មាអញនោះ បានទៅផុតអំពីព្រះរាជនិវេសន៍នេះហើយ នឹងតាំងទីលំនៅលើមែកឈើ ធ្វើខ្លួនឲ្យរីករាយ ។

[ ៤៣១ ] ( ទូលអំពីពាក្យម្រឹគថា ) លុះអាត្មាអញនោះ បានទៅផុតអំពីព្រះរាជនិវេសន៍នេះហើយ នឹងដើរមុខហ្វូង ហើយផឹក

នូវទឹកទាំងឡាយដ៏ប្រសើរ ។

[ ៤៣២ ] ( ទូលអំពីពាក្យស្វាថា ) ព្រានព្រៃឈ្មោះភរតៈ អ្នកនៅក្នុងដែនពាហិកៈ បាននាំយើងដែលកំពុងស្រវឹងដោយកាមទាំងឡាយ ត្រេកត្រអាល ជ្រប់នៅក្នុងកាមទាំងឡាយនោះមក សូមសេចក្តីចម្រើន ចូរមានដល់អ្នក ។

[ ៤៣៣ ] ( ទូលអំពីពាក្យកិន្នរថា ) ខាងលើបពិតមានថ្មស្រួចៗ មានផងផឹតចុះអ័ព្ទ ប្រពន្ធរបស់យើងនោះ បាននិយាយនឹងយើងដោយពាក្យដ៏ទន់ពីរោះថា អ្នកប្រយ័ត្នកុំឲ្យជំពប់ជើងលើថ្ម ។

[ ៤៣៤ ] ( ទូលអំពីឧទ្ទានព្រះបច្ចេកពុទ្ធថា ) អាត្មាអញជាអ្នកឃើញនូវទីបំផុត គឺព្រះនិព្វាន ជាទីអស់ទៅនៃជាតិដោយមិនមានសង្ស័យ នឹងមិនវិលត្រឡប់មកដេកនៅក្នុងគភ៌ទៀត ការដេកនៅក្នុងគភ៌នេះ ជាទីក្រោយបំផុតត្រឹមនេះហើយ ការវង្គាត់ទៅក្នុងភពថ្មីទៀតរបស់អាត្មាអញអស់ហើយ ។

## អដ្ឋសទ្ទជាតកទី ២ ចប់

# អដ្ឋកថា

## អដ្ឋសទ្ទជាតក

[ ៤២៧-៤៣៤ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធសំឡេងអាថ៌កំបាំង សម្តែងនូវការតក់ស្លុត គួរខ្លាច ដែលព្រះបាទកោសលទ្រង់បានស្តាប់ក្នុងពេលរាត្រី ទើបត្រាស់រឿងនេះ មានពាក្យផ្តើមថា **ឥទំ បុរេ និន្នមាហុ** ដូច្នេះជាដើម ។

ផ្ទៃរឿងដូចគ្នានឹងលោហកុម្ភិជាតកដែលពោលមកហើយក្នុងចតុក្កនិបាតនោះឯង ។ ឯក្នុងរឿងនេះ កាលព្រះបាទកោសលទូលថា បពិត្រព្រះអង្គដ៏ចម្រើន តើមានហេតុអ្វីកើតឡើង ព្រោះសំឡេងដែលខ្ញុំព្រះអង្គបានស្តាប់នេះ ។ ព្រះបរមសាស្តាត្រាស់ថា សូមមហាបពិត្រកុំខ្លាចឡើយ មិនមានអន្តរាយណាមួយដល់ទ្រង់ ព្រោះហេតុដែលបានឮសំឡេងទាំងនោះឡើយ ទ្រង់បានឮសំឡេងអាថ៌កំបាំងដែលគួរតក់ស្លុតបែបនេះ តែមួយព្រះអង្គឯង ក៏មិនមែន សូម្បីព្រះរាជាអង្គមុនៗ ក៏បានស្តាប់សំឡេងបែបនេះ ជឿពាក្យរបស់ពួកព្រាហ្មណ៍ បំណងនឹងបូជាយញ្ញ ដោយសត្វមួយមុខ ៤ កាលបានស្តាប់ពាក្យនៃបណ្ឌិត ទើបឲ្យលែងសត្វដែលចាប់មកដើម្បីសម្លាប់បូជាយញ្ញ ហើយឲ្យវាយស្គរប្រកាសហាមនូវការសម្លាប់សត្វពេញព្រះនគរ ។ ព្រះបាទកោសលទូលអារាធនាឲ្យត្រាស់រឿង ( នោះ ) ទើបទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ មានសម្បត្តិ ៨០ កោដិ កាលចម្រើន

វ័យ បានសិក្សាសិល្បវិជ្ជា ក្នុងនគរតក្កសិលា កាលមាតាបិតាស្លាប់ទៅហើយ ទើបពិនិត្យមើលទ្រព្យសម្បត្តិ ហើយលះទ្រព្យសម្បត្តិ ឲ្យជាទាន លះកាមារម្មណ៍ ចូលទៅកាន់ព្រៃហិមពាន្ត បួសជាឥសី ធ្វើឈាន និងអភិញ្ញាឲ្យកើតហើយ លុះត្រូវការបរិភោគរស់ជូរប្រៃ ទើបមកកាន់ដែនដីមនុស្សដល់នគរពារាណសីហើយ ស្នាក់នៅក្នុងព្រះរាជឧទ្យាន ។ ក្នុងកាលនោះព្រះបាទពារាណសីប្រថាប់លើទែនសិរីសេយ្យាសនៈ ក្នុងវេលាទៀបភ្លឺ ទ្រង់បានស្តាប់សំឡេង ៨ យ៉ាង គឺសំឡេងកុកក្នុងព្រះរាជឧទ្យាន ក្បែរព្រះរាជវាំងយំ ១ សំឡេងរបស់កុកយំមិនទាន់ដាច់ មេក្អែកដែលអាស្រ័យក្នុងសសរបង្គោលរោងដំរីក៏យំបន្ត ១ កន្ទង់នៅអាស្រ័យត្រង់ហោជាងព្រះរាជ-វាំងយំ ១ សត្វតាវ៉ៅដែលចិញ្ចឹមក្នុងវាំងយំ ១ ម្រឹគដែលចិញ្ចឹមក្នុងវាំងយំ ១ ពានរដែលចិញ្ចឹមក្នុងវាំងយំ ១ កិន្នរដែលចិញ្ចឹមក្នុងវាំងយំ ១ កាលសំឡេងយំមិនដាច់របស់កិន្នរ ព្រះបច្ចេកពុទ្ធមកដល់ព្រះរាជឧទ្យាន ខាងចុងព្រះរាជវាំង កាលបន្លឺឧទាន បានបន្លឺសំឡេងឡើង ១ ។

ព្រះបាទពារាណសីទ្រង់ស្តាប់សំឡេង ៨ យ៉ាងនោះហើយ ទ្រង់តក់ស្លុត ភ័យខ្លាច ស្អែកឡើង ទើបសួរពួកព្រាហ្មណ៍ ។ ពួកព្រាហ្មណ៍ក្រាបទូលថា បពិត្រមហារាជ អន្តរាយប្រាកដដល់ព្រះអង្គ ពួកទូលបង្គំនឹងបូជាយញ្ញដើម្បីព្រះអង្គ ដោយសត្វមួយមុខ ៤ កាលព្រះរាជាទ្រង់អនុញ្ញាតថា អ្នកទាំងឡាយ ចូរធ្វើតាមគាប់ចិត្ត នាំគ្នាត្រេកអរ ចេញអំពីរាជសម្នាក់ ចាប់ផ្តើមធ្វើយញ្ញកម្ម ។

កាលនោះ មាណពជាសិស្សរបស់ព្រាហ្មណ៍ជាប្រធាន ខាងបូជាយញ្ញ-កម្ម ជាអ្នកមានបញ្ញាឈ្លាសវៃ ពោលនឹងអាចារ្យថា បពិត្រអាចារ្យ យញ្ញ-កម្មយ៉ាងនេះ ជាកម្មទារុណពន់ពេក មិនជាទីត្រេកអរ បង្កនូវវិនាសកម្មដល់សត្វជាច្រើន សូមលោកកុំធ្វើឡើយ អាចារ្យពោលថា នែបា ឯងមិនដឹងអ្វីសោះ បើមិនមានប្រយោជន៍ ពួកយើងក៏នឹងបានស៊ីត្រី និងសាច់ជាច្រើនសិនដែរ ។ មាណពពោលថា បពិត្រលោកអាចារ្យ សូមលោកអាចារ្យកុំធ្វើកម្មដែលនាំឲ្យកើតក្នុងនរក ព្រោះអាស្រ័យតែផ្ទៃឡើយ ពួកព្រាហ្មណ៍ដ៏សេសបានស្តាប់ដូច្នោះ ខឹងសម្បា ពោលថា មាណពធ្វើអន្តរាយដល់លាភរបស់ពួកយើង ។ ព្រោះខ្លាចព្រាហ្មណ៍ទាំងនោះ ទើបមាណពពោលថា បើដូច្នោះសូមពួកលោកធ្វើឧបាយស៊ីត្រី និងសាច់ចុះ ហើយចេញទៅក្រៅព្រះនគរពិចារណាមើលសមណៈអ្នកមានធម៌ ដែលអាចហាមព្រះរាជាបាន ទៅកាន់ព្រះរាជឧទ្យាន ឃើញព្រះពោធិសត្វ ថ្វាយបង្គំហើយ ពោលថា បពិត្រលោកម្ចាស់ៗ មិនមានសេចក្តីអនុគ្រោះក្នុងសត្វទាំងឡាយខ្លះទេឬ ព្រះរាជាត្រាស់ឲ្យសម្លាប់សត្វជាច្រើនបូជាយញ្ញ ការដែលលោកម្ចាស់ធ្វើឲ្យមហាជនផុតចាកចំណង មិនសមគួរឬ ព្រះពោធិសត្វឆ្លើយថា អើ ត្រូវហើយមាណពតែអាត្មានៅទីនេះ ព្រះរាជាក៏មិនស្គាល់អាត្មាៗ ក៏មិនស្គាល់ព្រះរាជា មាណពសួរថា បពិត្រលោកម្ចាស់ៗ ដឹងការសម្រេចផលនៃសំឡេង ដែលព្រះរាជាទ្រង់ស្តាប់ដែរឬ ព្រះពោធិសត្វពោលថា អើ អាត្មាដឹង មាណពពោលថា បើដឹង ហេតុអ្វីមិនក្រាបទូលព្រះរាជា តាបសពោលថា នែមាណព យើង

ចង់ស្អែងសត្វត្រង់ថ្វាស ( អួតអាង ) ដោយការប្រាប់ថា យើងដឹងឬ បើព្រះរាជាយាងមកទីនេះ ហើយត្រាស់សួរ យើងនឹងក្រាបទូលឲ្យទ្រង់ជ្រាប ។

មាណព ក៏ប្រញាប់ទៅកាន់ព្រះរាជសម្នាក់ដោយរហ័ស កាលព្រះរាជាត្រាស់សួរថា មានរឿងអ្វីបា ក៏ក្រាបទូលថា បពិត្រមហារាជ មានតាបសមួយអង្គ ដឹងការសម្រេចផលនៃសំឡេងដែលទ្រង់បានឮ អង្គុយលើមង្គលសិលាក្នុងព្រះរាជឧទ្យានរបស់ព្រះអង្គពោលថា បើព្រះរាជាត្រាស់សួរយើង យើងនឹងក្រាបទូលឲ្យទ្រង់ជ្រាប ទ្រង់គួរយាងទៅសួរតាបសនោះ ។

ព្រះរាជាយាងទៅទីនោះមួយរំពេច ថ្វាយបង្គំតាបសហើយ គង់ប្រថាប់ កាលតាបសធ្វើបដិសណ្ឋារៈហើយ ក៏ត្រាស់សួរថា បានឮថា លោកម្ចាស់ដឹងការសម្រេចផលនៃសំឡេងដែលខ្ញុំបានស្តាប់ពិតឬ តាបសទូលថា បពិត្រមហារាជ ត្រឹមត្រូវហើយ ព្រះរាជាត្រាស់ថា បើដូច្នោះ សូមលោកម្ចាស់ប្រាប់នូវការសម្រេចផលនៃសំឡេងដែលខ្ញុំបានឮនោះ ដល់ខ្ញុំចុះ ។

តាបសពោលថា មហាបពិត្រ មិនមានអន្តរាយណាមួយដល់ព្រះអង្គឡើយ ព្រោះទ្រង់បានស្តាប់សំឡេងទាំងនោះ សត្វកុកមួយ មាននៅត្រង់ឧទ្យានចាស់ សត្វកុកនោះកាលមិនបានចំណី ត្រូវសេចក្តីស្រេកឃ្លានគ្របសង្កត់ បានយំឡើងមុនគេ តាបសក្រាបទូលដូច្នេះហើយ ព្រោះកំណត់ដឹងកិរិយារបស់កុកដោយញាណរបស់ខ្លួន ទើបពោលគាថាទី ១ ថា

ស្រះបោក្ខរណីនេះ ពីដើមជាទីទំនាប មានត្រីច្រើន មានទឹកច្រើន
ជាទីលំនៅរបស់ស្តេចកុក ជាកេរដំណែលខាងបិតា ជាទីលំនៅ

របស់យើង ថ្ងៃនេះ ពួកយើងនោះ ចិញ្ចឹមជីវិតដោយសត្វកង្កែប នៅតែមិនលះបង់ទីលំនៅចោលឡើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឥធំ** តាបសពោលសំដៅដល់ស្រះបោក្ខរណី ដែលជាមង្គលនោះ ។ ស្រះនោះ កាលមុនមានទឹកហូរទៅតាមគុម្ពឈើដែលនៅក្នុងទឹក ទើបមានទឹកច្រើន មានត្រីច្រើន តែឥឡូវនេះ ក្លាយជាស្រះមានទឹកតិច ព្រោះទឹករីងស្ងួតហើយ ។

បទថា **ត្យជ្ជ ភេកេន** សេចក្ដីថា ថ្ងៃនេះ ពួកយើងមិនបានត្រីទាំងនោះជាអាហារ ទើបនាំគ្នាចិញ្ចឹមជីវិតដោយកង្កែប ។

បទថា **ឱកំ** សេចក្ដីថា ទោះបីពួកយើងត្រូវសេចក្ដីស្រេកឃ្លានគ្របសង្កត់ដល់ម្ល៉េះ ក៏មិនព្រមលះបង់ទីលំនៅ តាបសក្រាបទូលបន្តថា មហាបពិត្រ ហេតុដូចទូលមកនេះ កុកនោះត្រូវសេចក្ដីស្រេកឃ្លានគ្របសង្កត់ ទើបយំ បើទ្រង់បំណងដោះកុកនោះឲ្យផុតចាកការស្រេកឃ្លាន សូមជម្រះឧទ្យានឲ្យស្អាត ហើយបង្ហូរទឹកចូលឲ្យពេញស្រះបោក្ខរណី ។ ព្រះរាជាត្រាស់ឲ្យអមាត្យម្នាក់ធ្វើតាមនោះ ។

តាបសក្រាបទូលតទៅថា មហាបពិត្រ ក្អែកមួយ ដែលនៅត្រង់សសរបង្គោលរោងដំរីរបស់ទ្រង់សោយសោកដល់កូនរបស់ខ្លួន ទើបយំជាសំឡេងទី ២ ព្រោះហេតុនោះ ភ័យមិនមានដល់ទ្រង់ឡើយ ដូច្នេះហើយ ក៏ពោលគាថាទី ២ ថា

អ្នកណាហ្ន៎ បំបែកក្អែកជាគម្រប់ពីររបស់ទមកដំរី ឈ្មោះពន្ធុរៈ

ជាបុគ្គលទ្រុស្តសីល អ្នកណាហ្ន៎ នឹងធ្វើនូវកូនទាំងឡាយ និង
សម្បុករបស់យើង ព្រមទាំងយើងឲ្យមានសួស្តី ដូច្នេះ ។

កាលពោលដូច្នេះ បានទូលសួរថា មហាបពិត្រ ហ្វូងដំរីត្រង់រោងដំរីរបស់ព្រះអង្គឈ្មោះអ្វី ព្រះរាជាត្រាស់ថា ឈ្មោះពន្ធុរៈ ឥសីពោលថា មហាបពិត្រ បុរសនោះខ្វាក់ភ្នែកម្ខាងឬ ព្រះរាជាត្រាស់ថា ត្រូវហើយ ឥសីពោលថា មហាបពិត្រ ក្អែកមួយធ្វើសម្បុក ត្រង់សសរបង្គោលរោងដំរីដើម្បីពង ពងហើយកូនក៏ញាស់ ហ្វូងដំរីជិះដំរីចូលមក យកកន្ត្រវាយមេក្អែកផង កូនក្អែកផង បាសម្បុកចោលផង មេក្អែកបានទទួលសេចក្ដីលំបាកបែបនោះ ទើបស្រែកបន់ឲ្យភ្នែកហ្វូងដំរីនោះខ្វាក់ទាំងសងខាង ។ បើទ្រង់មានព្រះហឫទ័យមេត្តាដល់មេក្អែក សូមហៅពន្ធុរៈនោះមកហាមឃាត់ កុំឲ្យបាសម្បុកក្អែកទៀត ព្រះរាជាឲ្យហៅពន្ធុរៈមក ទ្រង់បរិភាសហើយ បណ្ដេញចេញ ហើយតាំងអ្នកដទៃជាហ្វូងជំនួស ។ តាបសទូលបន្តថា មហាបពិត្រ កន្ធង់[១] មួយនៅត្រង់ជហ្វាមហាប្រាសាទ ស៊ីឈើស្រោយអស់ហើយ មិនអាចទំពាឈើខ្ទឹមបាន កាលមិនបានអាហារ ក៏មិនអាចចេញទៅ ទើបកន្ទក់កន្ទេញជាសំឡេងទី ៣ ព្រោះហេតុនោះ ភ័យមិនមានដល់មហាបពិត្រឡើយ ដូច្នេះហើយ កំណាត់ដឹងកិរិយារបស់កន្ធង់នោះ ដោយញាណរបស់ខ្លួន ទើបពោលគាថាទី ៣ ថា

ការប្រព្រឹត្តទៅនៃឈើស្រោយនោះ មាននៅត្រឹមណា ឈើស្រោយ
ទាំងអស់ អស់រលីងហើយ បពិត្រមហារាជ ដង្កូវដួងអស់អាហារ

---

១- បិដកខ្មែរ ជាដង្កូវដួង ។

ហើយ លែងត្រេកអរក្នុងឈើខ្ទឹម ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យាវ តស្សា គតី អហុ** សេចក្ដីថា ឈើស្រោយនោះ បានឲ្យនូវការសម្រេចប្រយោជន៍មកហើយដរាបណា ឈើស្រោយនោះ កន្ធង់ក៏កកេរស៊ីអស់ត្រឹមនោះ ។

បទថា **ឆ រមតី** សេចក្ដីថា តាបសទូលថា មហាបពិត្រ កន្ធង់នោះ ចេញអំពីទីនោះហើយ កាលមិនឃើញផ្លូវដែលហើរទៅបាន ទើបយំសោក សូមទ្រង់ឲ្យមនុស្សយកកន្ធង់នោះចេញអំពីហោជាងចុះ ព្រះរាជាទ្រង់ត្រាស់ឲ្យបុរសម្នាក់ យកកន្ធង់ចេញបានដោយឧបាយ ។

តាបសទូលបន្តថា បពិត្រមហារាជ ក្នុងព្រះរាជវាំងរបស់ទ្រង់ មានចិញ្ចឹមសត្វតាវ៉ៅមួយឬ ព្រះរាជាត្រាស់ថា មានលោកម្ចាស់ តាបសក្រាបទូលថា បពិត្រមហារាជ តាវ៉ៅនោះ នឹកដល់ដងព្រៃដែលធ្លាប់នៅ រើបម្រះគិតថា កាលណាហ្ន៎ ទើបអញផុតពីទ្រុងនេះ ទៅកាន់ដងព្រៃ ដែលគួរជាទីត្រេកអរ ទើបបានយំជាសំឡេងទី ៤ ព្រោះហេតុនោះ ភ័យមិនមានដល់ទ្រង់ឡើយ ហើយពោលគាថាទី ៤ ថា

លុះអាត្មាអញនោះ បានទៅផុតអំពីព្រះរាជនិវេសន៍នេះហើយ នឹង

តាំងទីលំនៅលើមែកឈើ ធ្វើខ្នងឲ្យរីករាយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឧុមសាខានិកេតិនី** សេចក្ដីថា ធ្វើសម្បុកអាស្រ័យនៅយ៉ាងសប្បាយត្រង់មែកឈើដែលមានផ្ការីកស្គុសស្គាយ ។

កាលក្រាបទូលយ៉ាងនេះហើយ ក៏ទូលបន្តថា បពិត្រមហារាជ តាវ៉ៅ

នោះរើបម្រះ សូមទ្រង់លែងតាវៅនោះចុះ ។ ព្រះរាជាត្រាស់ឲ្យធ្វើយ៉ាងនោះ តាបសក្រាបទូលបន្តថា ក្នុងព្រះរាជវាំងរបស់ទ្រង់មានចិញ្ចឹមម្រឹគមួយមិនមែន ឬ ព្រះរាជាត្រាស់ថា មាន លោកម្ចាស់ តាបសក្រាបទូលថា ម្រឹគនោះ ជាមេហ្វូង គិតដល់ម្រឹគញីរបស់ខ្លួន លោតកន្ទ្រោងព្រោះអំណាចកិលេស ក៏ស្រែកឡើងជាសំឡេងគម្រប់ ៥ ព្រោះហេតុនោះ ភ័យមិនមានដល់ទ្រង់ទេ ដូច្នេះហើយ ពោលគាថាទី ៥ ថា

លុះអាត្មាអញនោះ បានទៅផុតអំពីព្រះរាជនិវេសន៍នេះហើយ នឹង

ដើរមុខហ្វូង ហើយផឹកនូវទឹកទាំងឡាយដ៏ប្រសើរ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អគ្គោទកានិ** សេចក្តីថា កាលណាហ្ន៎ អញនឹងនាំហ្វូងទៅផឹកទឹកដ៏ប្រសើរ ដែលម្រឹគដទៃមិនធ្លាប់ផឹកមកអំពីមុន គឺមិនមែនជាទឹកសល់ដែល ។

ព្រះមហាសត្វជាតាបស បានក្រាបទូលឲ្យព្រះរាជាទ្រង់លែងម្រឹគនោះទៅ ហើយទូលបន្តថា បពិត្រមហារាជ ក្នុងព្រះរាជវាំងរបស់ទ្រង់មានចិញ្ចឹមស្វាមួយមិនមែនឬ កាលព្រះរាជាត្រាស់ថា មាន លោកម្ចាស់ តាបសបានក្រាបទូលថា ស្វានោះ តម្រេកដោយកាមជាមួយស្វាញីទាំងឡាយ ក្នុងព្រៃហិមពាន្ត ត្រូវព្រានឈ្មោះភរតៈនាំមកទីនេះ ឥឡូវនេះ ចំប្រាវចង់ទៅទីនោះ ទើបយំជាសំឡេងគម្រប់ ៦ ព្រោះហេតុនោះ ភ័យក៏មិនមានដល់ទ្រង់ឡើយ ហើយក៏ពោលគាថាទី ៦ ថា

ព្រានព្រៃឈ្មោះភរតៈ អ្នកនៅក្នុងដែនពាហិកៈ បាននាំយើងដែល

កំពុងស្រវឹងដោយកាមទាំងឡាយ ត្រេកត្រអាល ជ្រប់នៅក្នុងកាមទាំងឡាយនោះមក សូមសេចក្តីចម្រើន ចូរមានដល់អ្នកដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ពាហិកោ** បានដល់ ព្រានឈ្មោះភរតៈ អ្នកពាហិករដ្ឋ ។ បទថា **ភទ្ទមត្ថុ តេ** សេចក្តីថា ពានរនោះ ពោលសេចក្តីនេះថា សូមសេចក្តីចម្រើនមានដល់លោក សូមលោកដោះលែងខ្ញុំចុះ ។

ព្រះមហាសត្វសូមឲ្យព្រះរាជាលែងស្វានោះ ហើយទូលបន្តថា ក្នុងព្រះរាជវាំងរបស់ទ្រង់មានចិញ្ចឹមកិន្នរមិនមែនឬ កាលព្រះរាជាត្រាស់ថា មានលោកម្ចាស់ ទើបក្រាបទូលថា បពិត្រមហារាជ កិន្នរនោះ គិតដល់គុណដែលកិន្នរីធ្វើដល់ខ្លួន ក្តៅក្រហាយព្រោះកិលេស ទើបស្រែកយំជាសំឡេងគម្រប់ ៧ ព្រោះថា ថ្ងៃមួយ កិន្នរនោះ ឡើងទៅកាន់កំពូលភ្នំគុន្ធបពិតជាមួយកិន្នរីនាំគ្នាបេះផ្កាដែលមានពណ៌ស្អាត ក្លិនក្រអូប និងមានរសឆ្ងាញ់ច្រើនប្រភេទប្រដាប់កាយខ្លួន មិនបានកំណត់ព្រះអាទិត្យដែលកំពុងអស្តង្គត កាលព្រះអាទិត្យអស្តង្គតហើយ ងងឹតក៏មានដល់កិន្នរ និងកិន្នរី ដែលកំពុងចុះអំពីកំពូលភ្នំ កិន្នរីពោលនឹងកិន្នរថា បងជាទីស្រឡាញ់ ងងឹតណាស់ សូមបងប្រយ័ត្នឈានចុះកុំឲ្យភ្លាំងភ្លាត់ ហើយចាប់ដៃឈានចុះទៅ កិន្នរគិតដល់វាចារបស់កិន្នរីនោះ ទើបយំ ព្រោះហេតុនោះ ភ័យមិនមានដល់ទ្រង់ឡើយ ដូច្នេះ លុះធ្វើរឿងនោះឲ្យប្រាកដ កំណត់ដឹងបានដោយញាណរបស់ខ្លួន ក៏បានពោលគាថាទី ៧ ថា

ខាងលើបពិតមានថ្មស្រួចៗ មានផងឹតចុះអ័ព្ទ ប្រពន្ធរបស់យើង នោះ បាននិយាយនឹងយើង ដោយពាក្យដ៏ទន់ពីរោះថា អ្នក ប្រយ័ត្ន កុំឲ្យជំពប់ជើងលើថ្ម ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អន្ធការតិមិសាយ** សេចក្ដីថា ការងងឹត ដែលធ្វើនូវការខ្វាក់ប្រាកដ ។ បទថា **តុង្គេ** បានដល់ មុតស្រួច ។ បទថា **សណ្ហេន មុទុនា** សេចក្ដីថា ដោយពាក្យពីរោះផ្អែមស្រទន់ ។

**យ** អក្ខរៈ ក្នុងបទថា **មា ចានំ ខណិយស្មសិ** នេះ លោកកាន់យក ដោយអំណាចនៃព្យញ្ជនៈសន្ធិ ។ មានពាក្យអធិប្បាយដូច្នេះថា កិន្នរីនោះបាន ពោលនឹងអញដោយវាចាដ៏ផ្អែមពីរោះថា បងសម្លាញ់ បងកុំប្រមាទ បងកុំ ជាន់លើដុំថ្ម គឺឈានតិចៗ កុំឲ្យភ្លាំងភ្លាត់ ទៅត្រង់ដុំថ្មបាន ដូច្នេះហើយ ចាប់ ដៃឈានចុះទៅ ។

ព្រះមហាសត្វ បានទូលដល់ហេតុដែលកិន្នរយំ ដូច្នេះហើយ បានទូល សូមឲ្យទ្រង់ដោះលែងកិន្នរនោះ ហើយទូលបន្តទៀតថា បពិត្រមហារាជ សំឡេងទី ៨ ជាសំឡេងបន្ទឺឧទាន បានឮថា ត្រង់ញកក្ដុំនទ្ធមូលកៈ ព្រះ បច្ចេកពុទ្ធមួយអង្គ ពិចារណាឃើញថា អាយុសង្ខាររបស់លោកអស់ហើយ ទើបគិតថា អញនឹងទៅកាន់ទឹកដីមនុស្ស បរិនិព្វានក្នុងព្រះរាជឧទ្យានរបស់ ព្រះបាទពារាណសី ពួកមនុស្សនឹងបូជាសពអាត្មាអញ នឹងលេងសាធុកីឡា បូជាធាតុ បំពេញផ្លូវទៅកាន់ស្ថានសួគ៌ ដូច្នេះហើយ ហោះមកដោយឫទ្ធានុភាព តាមអាកាស លុះមកដល់កំពូលប្រាសាទរបស់ទ្រង់ បានដាក់នូវខន្ធភារៈ បន្ទឺ

ឧទាន សម្តែងការចូលកាន់នគរ គឺព្រះនិព្វាន ដូច្នេះហើយ ពោលគាថាដែល ព្រះបច្ចេកពុទ្ធពោល ដោយសេចក្តីថា

អាត្មាអញ ជាអ្នកឃើញនូវទីបំផុត គឺព្រះនិព្វាន ជាទីអស់ទៅនៃជាតិ ដោយមិនមានសង្ស័យ នឹងមិនវិលត្រឡប់មកដេកនៅក្នុងគភ៌ទៀត ការដេកនៅក្នុងគភ៌នេះ ជាទីក្រោយបំផុតត្រឹមនេះហើយ ការវង្គាត់ទៅក្នុងភពថ្មីទៀតរបស់អាត្មាអញ អស់ហើយដូច្នេះ ។

គាថានោះ មានអធិប្បាយដូច្នេះថា អាត្មាអញឈ្មោះថា ឃើញទីបំផុតនៃការអស់ជាតិ ព្រោះបានឃើញព្រះនិព្វាន ពោល គឺការអស់ទៅនៃជាតិ ហើយមិនវិលមកដេកក្នុងគភ៌ទៀត ដោយឥតសង្ស័យ ការកើតរបស់អញនេះ មានក្នុងទីបំផុតហើយ ការដេកក្នុងគភ៌ ក៏ជាលើកចុងក្រោយហើយ សង្សារ ពោល គឺលំដាប់នៃបញ្ចក្ខន្ធដើម្បីភពថ្មីរបស់អញ ក៏អស់ហើយ ។

ព្រះមហាសត្វពោលថា ព្រះបច្ចេកពុទ្ធពោលគាថានេះ ដោយអំណាចនៃឧទាន ហើយមកកាន់ព្រះរាជឧទ្យាននេះ បរិនិព្វានត្រង់គល់រាំង ដែលមានផ្ការយោនរយោនមួយដើម បពិត្រមហារាជ សូមទ្រង់ទៅបូជាសពព្រះបច្ចេកពុទ្ធនោះចុះ ។

ព្រះមហាសត្វ នាំព្រះរាជាទៅត្រង់ទីព្រះបច្ចេកពុទ្ធបរិនិព្វាន ចង្អុលឲ្យទតសរីរៈនោះ ។ ព្រះរាជាទតឃើញសរីរៈរបស់ព្រះបច្ចេកពុទ្ធនោះហើយ មួយអន្លើដោយពលនិកាយ បូជាដោយគ្រឿងក្រអូបជាដើម ទ្រង់អាស្រ័យពាក្យ

របស់ព្រះពោធិសត្វ ត្រាស់ឲ្យបញ្ឈប់យញ្ញកម្ម ព្រះរាជទានជីវិតដល់សត្វទាំងអស់ បានវាយស្គរប្រកាស ហាមនូវការសម្លាប់សត្វក្នុងព្រះនគរ ឲ្យលេងសាធុកីឡា ៧ ថ្ងៃ ហើយឲ្យបូជាសពព្រះបច្ចេកពុទ្ធ ដោយសក្ការៈធំ លើជើងថ្ករ ដែលធ្វើដោយគ្រឿងក្រអូបគ្រប់យ៉ាង ហើយឲ្យសាងព្រះស្តូប ក្នុងផ្លូវបែកជា ៤ ។

ព្រះពោធិសត្វសម្តែងធម៌ដល់ព្រះរាជាហើយ ទូន្មានថា សូមទ្រង់ជាបុគ្គលមិនប្រមាទចុះ ដូច្នេះហើយ ទៅកាន់ព្រៃហិមពាន្ត ចម្រើនព្រហ្មវិហារ មានឈានមិនសាបសូន្យ ក៏មានព្រហ្មលោកជាទីទៅខាងមុខ ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកសម្តែងហើយ ត្រាស់ថា បពិត្រមហារាជ អន្តរាយណាមួយ មិនមានដល់ទ្រង់ ព្រោះស្តាប់សំឡេងនោះឡើយ សូមទ្រង់វៀរនូវការបូជាយញ្ញនោះ សូមទ្រង់ប្រទាននូវជីវិតដល់មហាជន ដូច្នេះហើយ ឲ្យព្រះរាជាបំពេញជីវិតទាន វាយស្គរប្រកាសឲ្យមកស្តាប់ធម៌ពេញព្រះនគរ ហើយទ្រង់ប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះបានមកជាអានន្ទ ក្នុងកាលឥឡូវនេះ មាណពក្នុងកាលនោះ បានមកជាសារីបុត្រ ឯតាបសក្នុងកាលនោះ គឺតថាគតនេះឯង ៕

**អដ្ឋកថា អដ្ឋសទ្ទជាតកត ចប់**

# សុត្តន្តបិដក

## សុលសាជាតក

[ ៤៣៥ ] ( នាងសុលសាពោលទៅនឹងស្វាមីថា ) គ្រឿងប្រដាប់ជាវិការនៃមាសនេះ និងកែវមុក្តា កែវពិទូរ្យទាំងឡាយជាច្រើន បពិត្រអ្នកដ៏ចម្រើន អ្នកចូរនាំយកនូវកណ្ឌទាំងអស់ចុះ មួយទៀត ចូរហៅរកខ្ញុំថាជាទាសីចុះ ។

[ ៤៣៦ ] ( ចោរឈ្មោះសត្តុកៈជាស្វាមី ពោលនឹងភរិយាថា ) នាងចូរដោះគ្រឿងប្រដាប់ជាលម្អចេញទៅ កុំយំរៀបរាប់ច្រើន ត្បិតអញទើបនឹងមកមិនដែលស្គាល់ទ្រព្យ ដែលនាងនាំមកឡើយ ។

[ ៤៣៧ ] ( នាងសុលសាពោលថា ) តាំងពីកាលដែលខ្ញុំរឭកឃើញខ្លួនដរាបមក តាំងពីខ្ញុំបានដល់នូវភាពជាអ្នកដឹងក្តីដរាបមក ខ្ញុំមិនដែលស្គាល់បុរសដទៃដែលជាទីស្រឡាញ់លើសលុបជាងអ្នកទេ ។

[ ៤៣៨ ] អ្នកចូរអញ្ជើញមក ខ្ញុំនឹងកៀកឱបនូវអ្នក ហើយនឹងធ្វើប្រទក្សិណ ត្បិតតាំងពីថ្ងៃនេះ ខ្ញុំ និងអ្នក លែងបានជួបគ្នាទៀតហើយ ។

[ ៤៣៩ ] ( ទេវតាលើភ្នំពោលថា ) មិនមែនតែបុរសទេដែលជាបណ្ឌិតក្នុងហេតុទាំងពួង សូម្បីស្ត្រីក៏ជាបណ្ឌិត ឃើញច្បាស់ក្នុងហេតុនោះៗ បានដែរ ។

[ ៤៤០ ] មិនមែនតែបុរសទេ ដែលជាបណ្ឌិតក្នុងហេតុទាំងពួង សូម្បីតែស្ត្រីក៏ជាបណ្ឌិត គង់គិតឃើញសេចក្តីរហ័សបានដែរ ។

[ ៤៤១ ] នាងសុលសា បានគិតឃើញឆាប់រហ័ស ក្នុងកាលដែលមានហេតុយ៉ាងកៀកជិត បានសម្លាប់ចោរសត្តុកៈ ដូចជាគេសម្លាប់ម្រឹគនឹងធ្នូ ដែលមានគ្រឿងផ្សំគ្រប់គ្រាន់ ។

[ ៤៤២ ] បុគ្គលណា ក្នុងលោកនេះ មិនដឹងឆាប់នូវហេតុដែលកើតឡើង បុគ្គលអ្នកមានប្រាជ្ញាតិចនោះ រមែងត្រូវគេសម្លាប់ ដូចជាចោរដែលនាងសុលសាច្រានទម្លាក់ក្នុងជ្រោះភ្នំ ។

[ ៤៤៣ ] បុគ្គលណា ក្នុងលោកនេះ ដឹងឆាប់នូវហេតុដែលកើតឡើង បុគ្គលនោះ រមែងរួចចាកការបៀតបៀនរបស់សត្រូវ ដូចជានាងសុលសា រួចអំពីកណ្តាប់ដៃនៃចោរសត្តុកៈ ។

សុលសាជាតកទី ៣ ចប់

# អដ្ឋកថា

## សុលសាជាតក

[ ៤៣៥-៤៤៣ ] ព្រះសាស្តា កាលគង់នៅក្នុងវិហារជេតពន ទ្រង់ប្រារព្ធទាសីរបស់អនាថបណ្ឌិកសេដ្ឋី ទើបត្រាស់រឿងនេះ មានពាក្យផ្តើមថា **ឥទំ សុវណ្ណកាយូរំ** ដូច្នេះជាដើម ។

បានឮថា ក្នុងថ្ងៃដែលមានការលេងមហោស្រពមួយថ្ងៃ ទាសីនោះទៅឧទ្យានជាមួយពួកទាសី បានសូមគ្រឿងតែងខ្លួនជាមួយនាងបុញ្ញលក្ខណាទេវី ជាចៅហ្វាយរបស់ខ្លួន ។ នាងបុញ្ញលក្ខណាទេវី បានឲ្យគ្រឿងតែងខ្លួនរបស់នាង ដែលមានតម្លៃមួយសែនកហាបណៈដល់ទាសីនោះ ។ នាងប្រដាប់គ្រឿងតែងខ្លួននោះហើយ ទៅកាន់ឧទ្យានជាមួយពួកទាសី កាលនោះ ចោរម្នាក់កើតនូវការចង់បានក្នុងគ្រឿងប្រដាប់របស់ទាសីនោះ គិតថា អញនឹងសម្លាប់ស្រីនេះ រួចកាន់យកគ្រឿងតែងខ្លួនទៅ បានដើរចរចាជាមួយទាសីរហូតដល់ឧទ្យាន ហើយបានឲ្យត្រីសាច់ និងសុរាជាដើមដល់ទាសីនោះ ។ ទាសីគិតថា បុរសនេះ ប្រហែលជាឲ្យដោយអំណាចកិលេស ទើបទទួលយក ហើយលេងក្នុងឧទ្យាន ដើម្បីសាកល្បងមើលឲ្យដឹងពិត ក្នុងវេលាល្ងាច បានដាស់ពួកទាសី ដែលដេកលក់ឲ្យក្រោកឡើង ហើយខ្លួនបានទៅកាន់សម្នាក់ចោរនោះ ចោរពោលថា នែនាង ទីត្រង់នេះ មិនមានអ្វីបិទបាំង យើងដើរទៅខាងមុខបន្តិចទៀតចុះ ។ នាងបានស្តាប់ដូច្នោះ គិតថា ទីនេះក៏អាចធ្វើនូវរឿងកំបាំងបាន តែបុរសនេះបំណងនឹងសម្លាប់អញ យកគ្រឿងតែងខ្លួនពិត ណ្ហើយចុះ អញនឹងឲ្យគេសិក្សាឲ្យទាល់តែបាន ទើបពោលថា អ្នក ខ្ញុំអស់កម្លាំង ព្រោះ

ស្រវឹងស្រា សូមអ្នករកទឹកផឹកឲ្យខ្ញុំផឹកសិន ហើយក៏នាំទៅត្រង់អណ្តូងមួយកន្លែង ប្រាប់ថា សូមដងទឹកអំពីអណ្តូងនេះមកឲ្យខ្ញុំ ហើយហុចខ្សែ និងផ្តាំងឲ្យ ។ ចោរយកខ្សែចងផ្តាំហើយ ឱនចុះក្នុងអណ្តូង កាលចោរឱនដងទឹក ទាសីមានកម្លាំងច្រើន ទើបប្រើដៃទាំង ២ ទះត្រគាក ហើយចាប់បោះទៅក្នុងអណ្តូង ពោលថា ប៉ុណ្ណោះឯងមិនទាន់ស្លាប់ ទើបយកដុំឥដ្ឋធំទម្លាក់លើក្បាលមួយដុំទៀត ចោរស្លាប់ក្នុងអណ្តូងនោះឯង ។

ទាសីត្រឡប់ចូលនគរ ប្រគល់គ្រឿងតែងខ្លួនឲ្យដល់ចៅហ្វាយស្រី ហើយពោលថា បពិត្រអ្នកនាងម្ចាស់ ថ្ងៃនេះ ខ្ញុំប៊ិះនឹងស្លាប់ ព្រោះអាស្រ័យគ្រឿងតែងកាយនេះ ហើយតំណាលរឿងទាំងអស់ឲ្យចៅហ្វាយស្តាប់ នាងបុញ្ញលក្ខណាទេវី បានតំណាលប្រាប់ដល់អនាថបិណ្ឌិកសេដ្ឋី ។ អនាថ-បិណ្ឌិកសេដ្ឋី បានក្រាបបង្គំទូលដល់ព្រះតថាគត ព្រះបរមសាស្តាត្រាស់ថា ម្នាលគហបតី មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលទាសីនោះប្រកបដោយបញ្ញាដឹងទាន់នូវហេតុការណ៍ សូម្បីក្នុងកាលមុន នាងក៏ប្រកបដោយបញ្ញាដូចគ្នា មិនមែនក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលទាសីនេះសម្លាប់ចោរ សូម្បីកាលមុនក៏នាងសម្លាប់ចោរដូចគ្នា អនាថបិណ្ឌិកសេដ្ឋីក្រាបទូលឲ្យទ្រង់ត្រាស់រឿងនោះ ទើបទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិក្នុងនគរពារាណសី ស្រីនគរសោភិនីម្នាក់ ឈ្មោះសុលសា មាននាងវណ្ណទាសី ៥០០ ជាបរិវារ

បុរសដែលមករួមគ្នានឹងនាង ត្រូវឲ្យប្រាក់ ១០០០ ។ ក្នុងនគរនោះ មានចោរឈ្មោះសត្តុកៈ មានកម្លាំងដូចដំរីសារ ពេលយប់ ចូលទៅកាន់ផ្ទះរបស់ឥស្សរជន ប្លន់យកតាមគាប់ចិត្ត ។ អ្នកស្រុកប្រជុំគ្នាស្រែកយំ ជាទុក្ខដល់ព្រះរាជា ព្រះរាជាទ្រង់បង្គាប់អ្នករក្សានគរ ឲ្យត្រៀមជាក្រុមៗ តាមទីនោះៗ ត្រាស់ឲ្យជួយគ្នាចាប់ចោរនោះ កាត់ក្បាលចេញ ។ អ្នករក្សានគរចាប់ចោរនោះបាន ចងក្រពាត់ស្ពាយសេក វាយដោយផ្តៅម្តង ៤ នាំទៅកាន់ផ្លូវត្រឡែងកែង មានដំណឹងលិចឮក្នុងព្រះនគរថា ចោរគេចាប់បានហើយ ។

កាលនោះ នាងសុលសាឈរត្រង់បង្អួច ចោលក្អែកមើលមកកាន់ផ្លូវ ឃើញចោរ ក៏មានចិត្តស្នេហា គិតថា បើអញអាចធ្វើបុរសដែលត្រូវចាប់ថាជាចោរនេះឲ្យផុតបាន អញនឹងនៅរួមជាមួយគេតែម្នាក់ ដោយមិនធ្វើកម្មសៅហ្មង ដែលធ្លាប់ធ្វើមកហើយ គិតដូច្នេះហើយ នាងបានឲ្យសំណូក ១០០០ កហាបណៈ ដល់អ្នករក្សានគរ តាមន័យដែលពោលហើយក្នុងកណ្ណវេរជាតកខាងដើមនោះឯង ឲ្យចោររួចផុតហើយ នាងបានរួមអភិរម្យជាមួយចោរនោះ កាលកន្លងមកបានបីបួនខែ ចោរគិតថា អញមិនអាចនៅទីនេះបានទេ ហើយទៅវិញ ក៏មិនត្រូវទៅដោយដៃទទេ គ្រឿងតែងខ្លួនរបស់នាងសុលសានេះ មានតម្លៃមួយសែន អញសម្លាប់នាងហើយ នឹងយកគ្រឿងតែងខ្លួននេះទៅ ។ ថ្ងៃមួយ ចោរពោលនឹងនាងថា នែនាង កាលរាជបុរសចាប់បងនាំមក បងបានបន់ស្រន់ថា នឹងថ្វាយពលីកម្មដល់រុក្ខទេវតា ត្រង់កំពូលភ្នំឈ្មោះនោះ កាលរុក្ខទេវតាមិនបានពលិកម្ម ក៏នឹងមកបៀតបៀនបង

ពួកយើងធ្វើពលិកម្មជាមួយគ្នាចុះ ហើយនាងសុលសាពោលថា សាធុ សូមបងចាត់ចែងបញ្ជូនទៅចុះ ។ ចោរពោលថា នែនាង កាលបញ្ជូនទៅនោះមិនសមគួរ យើងទាំង ២ ត្រូវប្រដាប់តាក់តែងរាងកាយ ដោយអាករណៈសព្វយ៉ាង ទៅថ្វាយពលិកម្មដោយបរិវារធំ ។ នាងពោលថា សាធុ យើងនឹងធ្វើតាមនោះ ។

លំដាប់នោះ ចោរឲ្យនាងរករបស់របរតាមដែលគិតហើយ ក្នុងកាលដែលធ្វើដំណើរទៅដល់ជើងភ្នំ ទើបពោលថា នែនាង រុក្ខទេវតាឃើញមនុស្សម្នាមកច្រើន នឹងមិនទទួលពលិកម្ម យើងឡើងទៅថ្វាយតែ ២ នាក់ចុះ ។ ចោរនោះ កាលនាងទទួលពាក្យថា សាធុ ទើបឲ្យនាងរែកថាសគ្រឿងពលីខ្លួនឯងសៀតអាវុធ ៥ ប្រភេទ ឡើងលើកំពូលភ្នំ ឲ្យនាងដាក់ថាសគ្រឿងពលីត្រង់គល់ឈើ ដែលដុះត្រង់មាត់ជ្រោះ ជម្រៅ ១០០ ជួរបុរស ហើយពោលថា នែនាង អញមិនបានមកដើម្បីពលិកម្ម បំណងនឹងសម្លាប់នាងហើយយកគ្រឿងតែងខ្លួននាងទៅ ទើបមក ចូរនាងដោះគ្រឿងតែងខ្លួនចេញ ហើយខ្ចប់ដោយសំពត់សាដក នាងសួរថា បងសម្លាប់ខ្ញុំធ្វើអ្វី ចោរពោលថា ដើម្បីទ្រព្យ នាងពោលថា សូមបងរឭកដល់គុណដែលខ្ញុំធ្វើ ខ្ញុំដោះបងដែលគេចង នាំមកឲ្យជាកូនសេដ្ឋី ឲ្យទ្រព្យច្រើន ឲ្យបាននូវជីវិត សូម្បីខ្ញុំបាននូវទ្រព្យមួយថ្ងៃមួយពាន់ ក៏មិនសម្លឹងមើលបុរសដទៃ ខ្ញុំមានឧបការដល់បងយ៉ាងនេះ បងកុំសម្លាប់ខ្ញុំឡើយ ខ្ញុំនឹងឲ្យទ្រព្យដល់បងជាច្រើនទៀត ខ្ញុំនឹងធ្វើ

ជាអ្នកបម្រើរបស់បង ដូច្នេះ កាលនឹងអង្វរចោរនោះ បានពោលគាថាទី ១ ថា

គ្រឿងប្រដាប់ជាវិការនៃមាសនេះ និងកែវមុក្តា កែវពិទូរ្យទាំង
ឡាយជាច្រើន បពិត្រអ្នកដ៏ចម្រើន អ្នកចូរនាំយកនូវកណ្ឌទាំង
អស់ចុះ មួយទៀត ចូរហៅរកខ្ញុំថា ជាទាសីចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ការយ្ហំ** បានដល់ កម្រងសម្រាប់ពាក់ត្រង់ក ។ បទថា **សាវយ** សេចក្តីថា ចូរបងប្រកាសក្នុងកណ្តាលមហាជនថា ខ្ញុំជាទាសីរបស់បងចុះ ។

បន្តពីនោះ ចោរសត្តុកៈពោលគាថាទី ២ តាមអធ្យាស្រ័យរបស់ខ្លួនថា
នាងចូរដោះគ្រឿងប្រដាប់ជាលម្អចេញទៅ កុំយំរៀបរាប់ច្រើន
ត្បិតអញទើបនឹងមក មិនដែលស្គាល់ទ្រព្យដែលនាងនាំមកឡើយ
ដូច្នេះ ។

ដូច្នេះហើយ នាងសុលសាគិតដល់ហេតុដែលអាចរួចខ្លួនបានថា ចោរនេះ មិនព្រមលើកលែងជីវិតឲ្យអញ អញនឹងប្រើឧបាយនេះ ប្រានចោរនេះឲ្យធ្លាក់ក្នុងជ្រោះ ឲ្យស្លាប់ ដូច្នេះហើយ ពោលគាថាទី ២ ថា

តាំងពីកាលដែលខ្ញុំរឭកឃើញខ្លួនដរាបមក តាំងពីខ្ញុំបានដល់នូវ
ភាពជាអ្នកដឹងក្តីដរាបមក ខ្ញុំមិនដែលស្គាល់បុរសដទៃ ដែលជា
ទីស្រឡាញ់លើសលុបជាងអ្នកទេ ។

អ្នកចូរអញ្ជើញមក ខ្ញុំនឹងកៀកឱបនូវអ្នក ហើយនឹងធ្វើប្រទក្សិណ
ត្បិតតាំងពីថ្ងៃនេះ ខ្ញុំ និងអ្នកលែងបានជួបគ្នាទៀតហើយ ដូច្នេះ ។

ចោរសត្តុកៈមិនដឹងបំណងរបស់នាង ទើបពោលថា សាធុ ចូរនាងឱបរឹតយើងចុះ ។ នាងសុលសាធ្វើប្រទក្សិណចោរ ៣ ជុំ ឱបរឹតពោលថា នែបង ទីនេះ ខ្ញុំនឹងថ្វាយបង្គំបងក្នុងទិសទាំង ៤ ហើយនាងក៏បង្អោនក្បាលចុះទៀបខ្នងជើង ថ្វាយបង្គំខាងឆ្វេង ខាងស្តាំ ហើយធ្វើជាទៅថ្វាយបង្គំខាងក្រោយ នាងជាស្រីគណិកា មានកម្លាំងដូចដំរីសារ ទើបចាប់ដៃទាំង ២ របស់ចោរ រួចសង្កត់ក្បាលចុះ បោះទៅក្នុងជ្រោះ ១០០ ជួរបុរស ចោរបានបែកខ្ទេចខ្ទីស្លាប់ក្នុងជ្រោះនោះឯង ។ ទេវតាដែលអាស្រ័យលើកំពូលភ្នំ បានឃើញកិរិយាអាការនោះ ក៏ពោលគាថាទាំងនេះថា

មិនមែនតែបុរសទេ ដែលជាបណ្ឌិតក្នុងហេតុទាំងពួង សូម្បីស្ត្រី
ក៏ជាបណ្ឌិត ឃើញច្បាស់ក្នុងហេតុនោះៗ បានដែរ ។
មិនមែនតែបុរសទេ ដែលជាបណ្ឌិតក្នុងហេតុទាំងពួង សូម្បីតែ
ស្ត្រីក៏ជាបណ្ឌិត គន់គិតឃើញសេចក្តីរហ័សបានដែរ ។
នាងសុលសា បានគិតឃើញឆាប់រហ័ស ក្នុងកាលដែលមាន
ហេតុយ៉ាងកៀកជិត បានសម្លាប់ចោរសត្តុកៈ ដូចជាគេសម្លាប់
ម្រឹគនឹងធ្នូ ដែលមានគ្រឿងផ្សំគ្រប់គ្រាន់ ។
បុគ្គលណា ក្នុងលោកនេះ មិនដឹងឆាប់នូវហេតុដែលកើតឡើង
បុគ្គលអ្នកមានប្រាជ្ញាតិចនោះ រមែងត្រូវគេសម្លាប់ ដូចជាចោរ
ដែលនាងសុលសាប្រានទម្លាក់ក្នុងជ្រោះភ្នំ ។
បុគ្គលណា ក្នុងលោកនេះ ដឹងឆាប់នូវហេតុដែលកើតឡើង

បុគ្គលនោះ រមែងរួចចាកការបៀតបៀនរបស់សត្រូវ ដូចជានាងសុលសា រួចអំពីកណ្ដាប់ដៃនៃចោរសត្តុកៈ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បណ្ឌិតា ហោតិ** សេចក្ដីថា សូម្បីស្រ្តីក៏ជាបណ្ឌិតមានបញ្ញាវាងវៃ ក្នុងទីនោះៗ បាន ម្យ៉ាងទៀត សូម្បីស្រ្តីជាបណ្ឌិតផង ជាអ្នកមានបញ្ញាវាងវៃផង ក្នុងទីនោះៗ ដែរ ។

បទថា **លហុមត្ថំ វិចិន្តិកា** សេចក្ដីថា សូម្បីស្រ្តីក៏ជាបណ្ឌិត មានបញ្ញាត្រិះរិះហេតុផលបានរហ័ស ។

បទថា **លហុញ្ច វត** សេចក្ដីថា មិនយឺតយ៉ាវហ្ន៎ ។ បទថា **ខិប្បញ្ច** សេចក្ដីថា ដោយកាលមិនយូរ ។

បទថា **និកដ្ឋេ សមចេតយិ** សេចក្ដីថា នាងសុលសាឈរក្នុងទីជិតចោរ គិតឧបាយឲ្យចោរនោះស្លាប់ បានដោយរហ័ស ។

បទថា **បុណ្ណាយតនេវ** សេចក្ដីថា កាលមានធ្នូបរិបូណ៌ហើយ ។ លោកអធិប្បាយដូច្នេះ ដូចព្រានម្រឹគដែលឈ្លាស កាលមានធ្នូបរិបូណ៌ហើយ រមែងសម្លាប់ម្រឹគបានដោយរហ័ស យ៉ាងណា នាងសុលសាសម្លាប់ចោរសត្តុកៈបាន ក៏ដូច្នោះ ។

បទថា **យោធ** បានដល់ ក្នុងសត្វលោកនេះ ។ បទថា **និពោធតិ** បានដល់ រមែងដឹង ។ បទថា **សត្តុហាមិវ** សេចក្ដីថា បុគ្គលនោះរមែងផុតចាកការបៀតបៀនរបស់សត្រូវ ដូចនាងសុលសា ផុតអំពីដៃចោរសត្តុកៈ ដូច្នោះ ។

នាងសុលសាសម្លាប់ចោរបានហើយ ចុះអំពីភ្នំ ទៅកាន់សម្នាក់ពួកបរិវារជនរបស់ខ្លួន ត្រូវជនទាំងនោះសួរថា អយ្យបុត្រអញ្ជើញទៅណា នាងឆ្លើយថា កុំសួរដល់គេឡើយ ហើយឡើងរថចូលទៅកាន់នគរ ដូច្នេះ ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ក៏ប្រជុំជាតកថា ជនទាំងពីរក្នុងកាលនោះ បានមកជាជនទាំងពីរក្នុងកាលឥឡូវនេះ ឯទេវតា ក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា សុលសាជាតក ចប់

# សុត្តន្តបិដក

## សុមង្គលជាតក

[ ៤៤៤ ] បុគ្គលជាធំ បើបានដឹងថា អាត្មាអញជាអ្នកក្រោធខ្លាំងដូច្នេះហើយ មិនគប្បីដាក់អាជ្ញាតែម្តង ត្បិតបុគ្គលអ្នកក្រោធគប្បី ( ធ្វើ ) ទោសដែលមិនសមគួរដល់ខ្លួនជា ( ស្តេច ) ហើយពោលបន្ទាច់នូវកម្មជាទុក្ខដ៏ខ្លាំងដល់បុគ្គលដទៃ ដោយឥតហេតុ ។

[ ៤៤៥ ] កាលណាបើបុគ្គលគប្បីដឹងនូវសេចក្តីជ្រះថ្លារបស់ខ្លួន ទើបគួរពិចារណានូវសេចក្តី ដែលជាអំពើអាក្រក់របស់ជនដទៃមួយទៀត គួរពិចារណាឲ្យឃើញច្បាស់ខ្លួនឯងថា នេះជាសេចក្តីហើយ សឹមដាក់អាជ្ញាដ៏សមគួរដល់បុគ្គលដទៃនោះ ក្នុងកាលនោះចុះ ។

[ ៤៤៦ ] បុគ្គលណា មិនជ្រប់ដោយកិលេស ( អគតិ ) ពិចារណានូវហេតុដែលជាទំនង និងមិនទំនង បុគ្គលនោះរមែងមិនញុំាងខ្លួន និងមិនញុំាងបុគ្គលដទៃឲ្យក្តៅក្រហាយទេ បុគ្គលជាធំណាក្នុងលោកនេះ ជាអ្នកទ្រទ្រង់នូវអាជ្ញា បុគ្គលនោះរមែងមានគេគ្រប់គ្រងដោយការសរសើរគុណ មិនសាបសូន្យចាកសិរីឡើយ ។

[ ៤៤៧ ] ពួកក្សត្រណាជាបុគ្គលមិនទាន់ពិចារណាសិន ហើយធ្វើ ជាអ្នកជ្រប់នៅដោយកិលេស ប្រញាប់ដាក់អាជ្ញាដល់អ្នកដទៃ

ដោយរួសរាន់ ពួកក្សត្រនោះ រមែងជាអ្នកប្រកបដោយពាក្យតិះដៀល លះបង់ជីវិតចេញផុតអំពីលោកនេះទៅ រមែងទៅកាន់ទុគ្គតិ ។

[ ៤៤៨ ] បុគ្គលពួកណា ត្រេកអរក្នុងធម៌ដែលព្រះអរិយៈសម្តែងហើយ បុគ្គលពួកនោះ ជាអ្នកប្រសើរដោយកាយកម្ម វចីកម្ម និងមនោកម្ម ពួកបុគ្គលបែបនោះ ជាអ្នកឋិតនៅក្នុងខន្តិ សោរច្ចៈ និងសមាធិ រមែងទៅកាន់លោកទាំងពីរ គឺមនុស្ស-លោក និងទេវលោក ។

[ ៤៤៩ ] ខ្ញុំនយើងជាស្តេចធំលើពួកជនប្រុសស្រី បើយើងខឹងយើងទប់ខ្ញុំន យើងហាមឃាត់នូវប្រជុំជនបែបនោះ ហើយដាក់អាជ្ញាដោយឧបាយប្រាជ្ញា ព្រោះអនុគ្រោះ ។

[ ៤៥០ ] ( ឧទ្យានបាលទូលថា ) បពិត្រក្សត្រជាធំជាងជនសិរី គឺបរិវារសម្បត្តិ និងប្រាជ្ញាកុំលះបង់ព្រះអង្គក្នុងកាលណាៗឡើយ សូមព្រះអង្គជាបុគ្គលមិនក្រោធ មានចិត្តជ្រះថ្លាជានិច្ច ជាអ្នកមិនមានទុក្ខ ហើយថែរក្សាផែនដីឲ្យអស់រយឆ្នាំ ។

[ ៤៥១ ] បពិត្រក្សត្រិយ៍ សូមព្រះអង្គទ្រង់ប្រកបដោយគុណទាំងឡាយនុ៎ះ សូមឲ្យព្រះអង្គឋិតនៅមាំក្នុងការប្រព្រឹត្តដ៏ប្រសើរ ជាបុគ្គលប្រដៅងាយ មិនមានសេចក្តីក្រោធ ជាបុគ្គលបានសេចក្តីសុខ កុំបៀតបៀនសត្វ ហើយរក្សាផែនដី លុះព្រះអង្គចេញផុត

អំពីលោកនេះទៅ សូមឲ្យស្តេចយាងទៅកាន់សុគតិ ។

[ ៤៥២ ] ស្តេចទ្រង់ធម៌ រមែងប្រើឧបាយណែនាំពួកជនដោយពាក្យជាសុភាសិត ជាគ្រឿងណែនាំដ៏ល្អតាមហេតុដ៏ប្រកបដោយធម៌ ហើយញ៉ាំងមហាជនដែលរដើបរជោ ឲ្យត្រជាក់ស្រួល ដូចជាមហាមេឃដែលញ៉ាំងផែនដី ឲ្យត្រជាក់ដោយទឹក ។

សុមង្គលជាតកទី ៤ ចប់

# អដ្ឋកថា

## សុមង្គលជាតក

[ ៤៤៤-៤៥២ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធរាជោវាទសូត្រ ទើបត្រាស់រឿងនេះ មានពាក្យផ្តើមថា **កុសទ្ធិ កុទ្ធោ** ដូច្នេះជាដើម ។

ក្នុងគ្រានោះ ព្រះសាស្តា កាលព្រះបាទបសេនទិកោសលទូលអារាធនាឲ្យត្រាស់រឿង ទើបទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិក្នុងនគរពារាណសី ទ្រង់បំពេញមហាទាន ទ្រង់មានអ្នកយាមព្រះរាជឧទ្យានម្នាក់ឈ្មោះសុមង្គល កាលនោះ ព្រះបច្ចេកពុទ្ធមួយអង្គ ចេញអំពីញកភ្នំនន្ទមូលក៍ ចារិកដល់នគរពារាណសី អាស្រ័យនៅក្នុងព្រះរាជឧទ្យាន ស្អែកឡើង ចូលទៅបិណ្ឌបាតក្នុងព្រះនគរ ។ ព្រះរាជាទតឃើញព្រះបច្ចេកពុទ្ធនោះហើយ ទ្រង់ជ្រះថ្លា ថ្វាយបង្គំហើយ និមន្តឲ្យឡើងទៅកាន់ប្រាសាទ គង់លើអាសនៈ ទ្រង់អង្គាសដោយខាទនីយាហារមានរសដ៏ប្រសើរផ្សេងៗ កាលទ្រង់បានស្តាប់អនុមោទនាហើយ ទ្រង់ជ្រះថ្លាក្រៃលែង សូមអារាធនាឲ្យនៅក្នុងឧទ្យានរបស់ទ្រង់ ហើយទ្រង់បញ្ជូនព្រះបច្ចេកពុទ្ធ ទៅកាន់ព្រះរាជឧទ្យាន សូម្បីព្រះអង្គឯង លុះសោយព្រះក្រយាហារព្រឹកហើយ ក៏យាងទៅចាត់ចែងទីសម្រាកពេលយប់ និងទីសម្រាកពេលថ្ងៃជាដើម ឲ្យអ្នកយាមឧទ្យាន ធ្វើនាទីជាវេយ្យាវច្ចករ ហើយយាងចូលព្រះនគរ ។ តាំងពីនោះមក ព្រះបច្ចេកពុទ្ធក៏ឆាន់ត្រង់ព្រះរាជមន្ទីរជានិច្ច នៅត្រង់ព្រះរាជឧទ្យាននោះអស់កាលដ៏យូរ សូម្បីនាយសុមង្គល ក៏

បម្រើព្រះបច្ចេកពុទ្ធដោយគោរព ។

ថ្ងៃមួយ ព្រះបច្ចេកពុទ្ធហៅនាយសុមង្គលមក ប្រាប់ថា អាត្មានឹងអាស្រ័យនៅស្រុកនោះ ២-៣ ថ្ងៃ ទើបមក ចូរអ្នកក្រាបទូលព្រះរាជាផងចុះ ដូច្នេះហើយ ក៏ចៀសចេញទៅ ។ នាយសុមង្គលក៏បានក្រាបទូលព្រះរាជាហើយ ។ ព្រះបច្ចេកពុទ្ធនៅត្រង់ស្រុកនោះ ២-៣ ថ្ងៃ វេលាល្ងាច ព្រះអាទិត្យអស្តង្គតហើយ មកកាន់រាជឧទ្យាន ។ សុមង្គលមិនដឹងថា ព្រះបច្ចេកពុទ្ធនិមន្តមក បានទៅផ្ទះនៃខ្លួន ។ ព្រះបច្ចេកពុទ្ធទុកដាក់បាត្រចីវរ ហើយចុះកាន់ទីចង្ក្រមបន្តិច អង្គុយលើផ្ទាំងថ្ម ។ ក្នុងថ្ងៃនោះ មានភ្ញៀវមកកាន់ផ្ទះរបស់ឧទ្យានបាលច្រើននាក់ នាយសុមង្គលគិតថា អញនឹងសម្លាប់ម្រឹគដែលព្រះរាជាមិនហាមក្នុងព្រះរាជឧទ្យាន ដើម្បីធ្វើសូបព្យញ្ជនៈ លៀងភ្ញៀវ ទើបកាន់ធ្នូទៅកាន់ឧទ្យាន ចោលភ្នែករកមើលម្រឹគ ឃើញព្រះបច្ចេកពុទ្ធ ស្មានថាជាម្រឹគធំ ទើបផ្ទាប់ព្រួញបាញ់ទៅ ព្រះបច្ចេកពុទ្ធបើកសំពត់ដែលទទូរសីសៈ ពោលថា សុមង្គល ។ គាត់មានការភិតភ័យ ពោលថា បពិត្រលោកម្ចាស់ ខ្ញុំមិនដឹងថា លោកម្ចាស់និមន្តមក ស្មានថា ជាម្រឹគ ក៏បាញ់ទៅ សូមលោកម្ចាស់អត់ទោសដល់ខ្ញុំចុះ កាលព្រះបច្ចេកពុទ្ធពោលថា សេចក្តីនេះ ចូរលើកទុកចុះ ឥឡូវនេះ អ្នកនឹងធ្វើដូចម្តេច ចូរមក ដកយកព្រួញទៅចុះ គាត់ថ្វាយបង្គំហើយ ដកព្រួញ វេទនាដ៏មានកម្លាំងកើតឡើងហើយ ព្រះបច្ចេកពុទ្ធបរិនិព្វានក្នុងទីនោះឯង ។ ឧទ្យានបាលគិតថា បើព្រះរាជាទ្រង់ជ្រាប នឹងមិនទុកជីវិតឲ្យអញ ទើបនាំកូនប្រពន្ធគេចទៅ ។ ក្នុងវេលានោះឯង ដោយទេវា-

នុភាព បានបណ្តាលឲ្យកើតកោលាហលពេញព្រះនគរថា ព្រះបច្ចេកពុទ្ធបរិនិព្វានហើយ ។

ស្អែកឡើង ពួកជននាំគ្នាទៅព្រះរាជឧទ្យាន ឃើញព្រះបច្ចេកពុទ្ធហើយក្រាបទូលព្រះរាជាថា នាយឧទ្យានបាលសម្លាប់ព្រះបច្ចេកពុទ្ធហើយ គេចទៅ ។ ព្រះរាជាយាងទៅដោយបរិវារដ៏ច្រើន ទ្រង់បូជាសព ៧ ថ្ងៃ ហើយទ្រង់ធ្វើឈាបនកិច្ចដោយសក្ការៈធំ រក្សាព្រះធាតុ សាងចេតិយបញ្ចុះ បូជាព្រះចេតិយនោះ គ្រប់គ្រងរាជសម្បត្តិដោយធម៌ ចំណែកនាយសុមង្គល លុះកន្លងទៅបានមួយឆ្នាំ គិតថា អញនឹងដឹងវារៈចិត្តរបស់ព្រះរាជា ទើបមករកអមាត្យម្នាក់ពោលថា ចូរអ្នកដឹងថា ព្រះរាជាទ្រង់រឭកក្នុងយើងដូចម្តេច អមាត្យនោះពោលពណ៌នាគុណរបស់នាយសុមង្គល ក្នុងសម្នាក់ព្រះរាជាៗ ធ្វើមិនបានឮ ។ អមាត្យមិនបានពោលពាក្យណាមួយតទៅទៀត ត្រឡប់មកប្រាប់នាយសុមង្គលថា ព្រះរាជាមិនពេញព្រះហឫទ័យ លុះឆ្នាំទី ២ កន្លងទៅ នាយសុមង្គលត្រឡប់មកទៀត ព្រះរាជាទ្រង់បានស្ងៀមដូចមុន លុះឆ្នាំទី ៣ កន្លងទៅ នាយសុមង្គលបាននាំកូនប្រពន្ធមក ។ អមាត្យដឹងថា ព្រះរាជាមានព្រះហឫទ័យទោរទន់ហើយ ទើបនាំនាយសុមង្គលទៅឈរត្រង់ទ្វារព្រះរាជវាំង ហើយក្រាបទូលព្រះរាជាថា នាយសុមង្គលមក ។ ព្រះរាជាត្រាស់ឲ្យហៅនាយសុមង្គលមក ទ្រង់ធ្វើបដិសណ្ឋារៈ ហើយត្រាស់ថា នែសុមង្គល ហេតុអ្វី ទើបអ្នកសម្លាប់ព្រះបច្ចេកពុទ្ធ ដែលជាបុញ្ញក្ខេត្តរបស់យើង នាយសុមង្គលក្រាបទូលថា បពិត្រព្រះសម្មតិទេព ទូលបង្គំមិនមានចេតនាសម្លាប់ព្រះបច្ចេកពុទ្ធ ទូល

បង្គំស្មានថាជាម្រឹគ ទើបបាញ់ ដូច្នេះហើយ បានក្រាបទូលហេតុការណ៍ដែលកើតឡើងនោះឲ្យទ្រង់ជ្រាប ។ លំដាប់នោះ ព្រះរាជាលួងលោមថា បើដូច្នោះ អ្នកកុំខ្លាចឡើយ ហើយតែងតាំងជាឧទ្យានបាលទៀត ។

លំដាប់នោះ អមាត្យបានក្រាបទូលសួរថា បពិត្រព្រះសម្មតិទេព ហេតុអ្វី ទ្រង់បានស្តាប់គុណរបស់នាយសុមង្គលអស់វារៈ ២ ដង ទ្រង់មិនត្រាស់អ្វី តែលុះស្តាប់លើកទី ៣ ហេតុអ្វី ទើបទ្រង់ហៅមកអនុគ្រោះ ។ ព្រះរាជាត្រាស់ថា នែបា ធម្មតាព្រះរាជាកំពុងក្រោធ មិនគួរធ្វើអ្វីដោយការប្រញាប់ប្រញាល់ ដូច្នោះ ទើបក្នុងកាលមុនយើងនៅស្ងៀម លើកទី ៣ យើងដឹងចិត្តរបស់យើងថា ការក្រោធក្នុងនាយសុមង្គលថមថយហើយ ទើបឲ្យហៅមក ដូច្នេះ កាលទ្រង់សម្តែងរាជវត្ត បានត្រាស់គាថាទាំងនេះថា

បុគ្គលជាធំ បើបានដឹងថា អាត្មាអញជាអ្នកក្រោធខ្លាំង ដូច្នេះហើយ មិនគប្បីដាក់អាជ្ញាតែម្តង ត្បិតបុគ្គលអ្នកក្រោធ គប្បី ( ធ្វើ ) ទោសដែលមិនសមគួរដល់ខ្លួនជា ( ស្តេច ) ហើយពោលបន្តាច់នូវកម្មជាទុក្ខដ៏ខ្លាំងដល់បុគ្គលដទៃ ដោយឥតហេតុ ។ កាលណាបើបុគ្គលគប្បីដឹងនូវសេចក្តីជ្រះថ្លារបស់ខ្លួន ទើបគួរពិចារណានូវសេចក្តីដែលជាអំពើអាក្រក់របស់ជនដទៃ មួយទៀត គួរពិចារណាឲ្យឃើញច្បាស់ខ្លួនឯងថា នេះជាសេចក្តីហើយ សឹមដាក់អាជ្ញាដ៏សមគួរដល់បុគ្គលដទៃនោះ ក្នុងកាលនោះចុះ ។ បុគ្គលណាមិនជ្រប់ដោយកិលេស ( អគតិ ) ពិចារណានូវ

ហេតុដែលជាទំនង និងមិនទំនង បុគ្គលនោះ រមែងមិនញុំាងខ្លួន និងមិនញុំាងបុគ្គលដទៃឲ្យក្តៅក្រហាយទេ បុគ្គលជាធំណា ក្នុងលោកនេះ ជាអ្នកទ្រទ្រង់នូវអាជ្ញា បុគ្គលនោះ រមែងមានគេគ្រប់គ្រងដោយការសរសើរគុណ មិនសាបសូន្យចាកសិរីឡើយ ។

ពួកក្សត្រណា ជាបុគ្គលមិនទាន់ពិចារណាសិន ហើយធ្វើ ជាអ្នកជ្រប់នៅដោយកិលេស ប្រញាប់ដាក់អាជ្ញាដល់អ្នកដទៃដោយរួសរាន់ ពួកក្សត្រនោះ រមែងជាអ្នកប្រកបដោយពាក្យតិះដៀល លះបង់ជីវិតចេញផុតអំពីលោកនេះទៅ រមែងទៅកាន់ទុគ្គតិ ។

បុគ្គលពួកណា ត្រេកអរក្នុងធម៌ ដែលព្រះអរិយៈសម្តែងហើយ បុគ្គលពួកនោះ ជាអ្នកប្រសើរដោយកាយកម្ម វចីកម្ម និងមនោកម្ម ពួកបុគ្គលបែបនោះ ជាអ្នកឋិតនៅក្នុងខន្តិ សោរច្ចៈ និងសមាធិ រមែងទៅកាន់លោកទាំងពីរ គឺមនុស្សលោក និងទេវលោក ។

ខ្លួនយើងជាស្តេចធំលើពួកជនប្រុសស្រី បើយើងខឹង យើងទប់ខ្លួន យើងហាមឃាត់នូវប្រជុំជនបែបនោះ ហើយដាក់អាជ្ញាដោយឧបាយប្រាជ្ញា ព្រោះអនុគ្រោះ ។

បណ្តាបទទាំងនោះ បទថា **អបេក្ខិយាន** សេចក្តីថា បានឃើញ គឺដឹង លោកអធិប្បាយដូច្នេះថា នែបា ធម្មតាព្រះរាជា ជាធំក្នុងផែនដី ដឹងថា អញកំពុងក្រោធ គឺត្រូវសេចក្តីក្រោធដែលមានកម្លាំងគ្របសង្កត់ មិនគប្បីប្រញាប់

ប្រញាល់ដាក់នូវអាជ្ញា ដោយអាជ្ញាមានវត្ថុ ៨ ប្រការ ជាដើមចំពោះអ្នកដទៃ គឺមិនគប្បីញ៉ាំងអាជ្ញាឲ្យប្រព្រឹត្តទៅ សេចក្ដីនេះ ព្រោះហេតុអ្វី ព្រោះថា ព្រះរាជាក្រោធហើយ ដាក់អាជ្ញា ៨ យ៉ាង ឬ ១៦ យ៉ាងដោយអឋាន: គឺដោយហេតុមិនសមគួរ ត្រាស់ឲ្យគេនាំសំណូកមកប៉ុណ្ណោះ ឬឲ្យដាក់ទណ្ឌកម្មនេះ ដល់បុគ្គលនោះ ដែលមិនសមគួរដល់ភាពជាព្រះរាជារបស់ខ្លួន ហេតុនោះ ព្រះរាជានោះ ឈ្មោះថា បន្តនូវទុក្ខដ៏ផ្សាក្ដៅ គឺទុក្ខដែលមានកម្លាំងដល់អ្នកដទៃ ។

បទថា **យតោ** បានដល់ ក្នុងកាលណា ។ លោកអធិប្បាយដូច្នេះថា កាលណាព្រះរាជាដឹងនូវការផូរផង់នៃចិត្តរបស់ខ្លួន ដែលកើតឡើងក្នុងអ្នកដទៃ គប្បីប្រកប គឺកំណត់កំហុស គឺក្ដី ដែលអ្នកដទៃធ្វើមួយផ្នែក កាលនោះ ទ្រង់ពិចារណាយ៉ាងនេះហើយ គប្បីធ្វើសេចក្ដីឲ្យជាក់ច្បាស់ដោយខ្លួនឯងថា ក្នុងក្ដីនេះ ជាចំណែកប្រយោជន៍ នេះជាទោសរបស់បុគ្គលនោះ ដូច្នេះហើយ ទើបហៅយកទ្រព្យរបស់បុគ្គលដែលធ្វើខុសនោះ ៨ កហាបណៈ ឬ ១៦ កហាបណៈ ឲ្យសមគួរដល់ ៨ ឬ ១៦ ខ្ទង់ មកតាំងចុះ ហើយពិន័យឲ្យស្មើគ្នានឹងទោស គឺសមគួរដល់ទោសដែលធ្វើ ។

បទថា **អមុច្ឆិតោ** សេចក្ដីថា ម្យ៉ាងទៀត ស្ដេចផែនដីអង្គណាមិនត្រូវកិលេស មានឆន្ទាគតិជាដើមប្រឡាក់ប្រឡូស ឬគ្របសង្កត់ រមែងពិចារណា គឺត្រិះរិះហេតុដែលសមគួរ និងមិនសមគួរ ស្ដេចផែនដីអង្គនោះ ឈ្មោះថា មិនដុតអ្នកដទៃ និងមិនដុតព្រះអង្គឯង ព្រោះថា ស្ដេចផែនដី ដាក់ព្រះរាជអាជ្ញា

ដោយមិនមានហេតុ ដោយអំណាចនៃអគតិ មានឆន្ទាគតិជាដើម ឈ្មោះថា រមែងដុត គឺធ្វើឲ្យឆេះ បានដល់ បៀតបៀនអ្នកដទៃផង ខ្លួនឯងផង ដោយអាជ្ញានោះ ព្រោះបាបកម្ម មានឆន្ទាគតិជាដើមនោះជាហេតុ ព្រះរាជាដែលមានសភាពបែបនេះ ឈ្មោះថា ដុតអ្នកដទៃផង ដុតព្រះអង្គឯងផង ដោយប្រការដូច្នេះ ។

បទថា **យោ ឥណ្ឌធារោ ភវតីធ ឥស្សរោ** សេចក្តីថា ស្តេចផែនដីអង្គណា ក្នុងលោកនេះ ទ្រង់ដាក់អាជ្ញាសមគួរដល់ទោស ក្នុងពួកសត្វលោកនេះ ស្តេចផែនដីអង្គនោះ ឈ្មោះថា **ឥណ្ឌធរ។**

បទថា **ស វណ្ណគុត្តោ** សេចក្តីថា ស្តេចផែនដីអង្គនោះ ជាបុគ្គលដែលគួរសរសើរដល់គុណ និងការសរសើរ គឺយសគ្រប់គ្រងរក្សា រមែងមិនកម្ចាត់ គឺមិនវិនាសចាកសិរីឡើយ ។

បទថា **អវណ្ណសំយុត្តា ជហន្តិ** សេចក្តីថា ក្សត្រទាំងនោះ មិនតាំងនៅក្នុងធម៌ ជាស្តេចផែនដីឡេះឡោះ ជាបុគ្គលប្រកបទៅដោយទោស រមែងលះបង់ជីវិត ។

បទថា **ធម្មេ ច យេ អរិយប្បវេទិតេ** សេចក្តីថា ព្រះរាជាឯណាទ្រង់ត្រេកអរក្នុងទសពិធរាជធម៌ ដែលធម្មិករាជដ៏ប្រសើរដោយអាចារប្រកាស ។

បទថា **អនុត្តរា តេ** សេចក្តីថា ព្រះរាជាទាំងនោះ ជាអ្នកប្រសើរដោយកាយ វាចា ចិត្ត ជាកំពូលក្នុងទ្វារទាំង ៣ ។

បទថា **តេ សន្តិសោរច្ចសមាធិសណ្ឋិតា** សេចក្តីថា ព្រះរាជាទាំងនោះ

តាំងនៅក្នុងការស្ងប់កិលេស ដោយការលះអគតិ ក្នុងសោរច្ចៈ ពោល គឺភាពជាអ្នកមានសីលបរិសុទ្ធ និងក្នុងសមាធិ គឺភាពជាអ្នកមានចិត្តជាឯកគ្គតារម្មណ៍ ជាធម្មិករាជ ។

បទថា **វជន្តិ លោកំ ឧភយំ** សេចក្ដីថា ព្រះរាជាទាំងនោះគ្រងរាជសម្បត្តិដោយយុត្តិធម៌ រមែងដល់នូវលោកទាំង ២ ប៉ុណ្ណោះ គឺចាកមនុស្សលោក ដល់ទេវលោក ចាកទេវលោក ដល់មនុស្សលោក មិនទៅកើតក្នុងទុគ្គតិ មាននរកជាដើមឡើយ ។

បទថា **នរបមុខានំ** សេចក្ដីថា យើងជាព្រះរាជាធំរបស់មនុស្ស និងសត្វទាំងឡាយ ។

បទថា **ឋបេមិ អត្តនំ** សេចក្ដីថា ទោះបីយើងក្រោធ ក៏មិនត្រូវលុះអំណាចសេចក្ដីក្រោធ តាំងខ្លួនក្នុងគំរូដែលព្រះរាជាពីបុរាណទ្រង់បានបញ្ញត្ត មិនទម្លាយនូវគោលធម៌ ដែលជាគ្រឿងវិនិច្ឆ័យរបស់លោកចោល ។

កាលព្រះបាទព្រហ្មទត្ត ត្រាស់សម្ដែងគុណរបស់ទ្រង់ ៦ គាថាយ៉ាងនេះហើយ រាជបរិស័ទទាំងអស់ នាំគ្នាត្រេកអរ ពោលសរសើរគុណនៃព្រះរាជាថា គុណសម្បត្តិ គឺសីល និងអចារនេះ សមគួរដល់ព្រះអង្គនោះឯង ។ ឯនាយសុមង្គល កាលពួកបរិស័ទពោលចប់ហើយ ក៏ក្រោកឡើងថ្វាយបង្គំព្រះរាជា ផ្គងអញ្ជលី ពោលសរសើរព្រះរាជា បានពោល ៣ គាថាថា

បពិត្រក្សត្រជាធំជាងជន សិរី គឺបរិវារសម្បត្តិ និងប្រាជ្ញា កុំលះបង់ព្រះអង្គក្នុងកាលណាៗ ឡើយ សូមព្រះអង្គ ជាបុគ្គល

មិនក្រោធ មានចិត្តជ្រះថ្លាជានិច្ច ជាអ្នកមិនមានទុក្ខ ហើយថែរក្សាផែនដីឲ្យអស់រយឆ្នាំ ។

បពិត្រក្សត្រិយ៍ សូមព្រះអង្គទ្រង់ប្រកបដោយគុណទាំងឡាយនុ៎ះ សូមឲ្យព្រះអង្គឋិតនៅមាំក្នុងការប្រព្រឹត្តដ៏ប្រសើរ ជាបុគ្គលប្រដៅងាយ មិនមានសេចក្ដីក្រោធ ជាបុគ្គលបានសេចក្ដីសុខ កុំបៀតបៀនសត្វ ហើយរក្សាផែនដី លុះព្រះអង្គចេញផុតអំពីលោកនេះទៅ សូមឲ្យស្ដេចយាងទៅកាន់សុគតិ ។

ស្ដេចទ្រង់ធម៌ រមែងប្រើឧបាយណែនាំពួកជន ដោយពាក្យជាសុភាសិត ជាគ្រឿងណែនាំដ៏ល្អតាមហេតុដ៏ប្រកបដោយធម៌ ហើយញុំាងមហាជនដែលរេជើបរេជា ឲ្យត្រជាក់ស្រួល ដូចជាមហាមេឃដែលញុំាងផែនដី ឲ្យត្រជាក់ដោយទឹក ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សិរី ច លក្ខី ច** បានដល់ បរិវារសម្បត្តិនិងបុណ្យ ។ បទថា **អនីឃោ** បានដល់ ជាអ្នកប្រាសចាកទុក្ខ ។ បទថា **ឧបេត ខត្តិយ** សេចក្ដីថា បពិត្របរមក្សត្រ សូមទ្រង់ប្រកបដោយគុណធម៌ទាំងនេះ ។ ព្រះបាលីក៏ដូចគ្នាយ៉ាងនេះឯង ។

បទថា **ឋិតមរិយវត្តិ** សេចក្ដីថា បុរាណរាជវត្ត ពោល គឺទសពិធរាជធម៌ ឈ្មោះថា **ឋិតអរិយវត្ត** សូមទ្រង់តាំងនៅមាំក្នុងរាជធម៌ ព្រោះតាំងមាំក្នុងបុរាណរាជវត្ត គឺទសពិធរាជធម៌នោះ ។

បទថា **អនុប្បីឡ បសាស មេទនី** សេចក្ដីថា សូមទ្រង់គ្រប់គ្រងផែន

ដីមិនឲ្យពលនិករក្តៅក្រហាយ ។ បាលីក៏យ៉ាងនោះដូចគ្នា ។

បទថា **សុនីតេន** សេចក្តីថា ដែលបណ្ឌិតទូន្មានល្អ គឺត្រឹមត្រូវតាមហេតុផល ។ បទថា **ធម្មេន** បានដល់ ធម៌ គឺកុសលកម្មបថ ១០ ។ បទថា **ញាយេន** នេះ ជាវេវចនៈនៃបទដើមនោះឯង ។ បទថា **ឧបាយសោ** បានដល់ ដោយការឈ្លាសក្នុងឧបាយ ។ បទថា **នយំ** សេចក្តីថា ព្រះបាទធម្មិករាជកាលទ្រង់ដឹកនាំ គឺទ្រង់គ្រងរាជសម្បត្តិ ។ បទថា **និព្វាបយេ** សេចក្តីថា កាលនាយសុមង្គលសម្តែងភាពជាព្រះបាទធម្មិករាជ ដើម្បីបំបាត់សេចក្តីខ្វល់ខ្វល់ផ្លូវកាយ និងផ្លូវចិត្តបានដោយបដិបទានេះ ឈ្មោះថា គប្បីធ្វើមហាជនដែលក្តៅក្រហាយ ដោយទុក្ខកាយ ទុក្ខចិត្ត ឲ្យស្ងប់ត្រជាក់បាន ដូចភ្លៀងញុំាងផែនដីឲ្យត្រជាក់ដោយទឹក ដូច្នោះ សូមទ្រង់ធ្វើមហាជនឲ្យត្រជាក់ស្ងប់យ៉ាងនោះចុះ ។

ព្រះសាស្តាកាលទ្រង់នាំព្រះធម្មទេសនានេះមកសម្តែងដោយការប្រទានឱវាទដល់ព្រះបាទកោសលហើយ ទ្រង់ប្រជុំជាតកថា ព្រះបច្ចេកពុទ្ធក្នុងកាលនោះ បានបរិនិព្វានហើយ នាយសុមង្គលឧទ្យានបាលក្នុងកាលនោះ បានមកជាអានន្ទក្នុងកាលឥឡូវនេះ ព្រះរាជាក្នុងកាលនោះ គឺតថាគតនេះឯង ៕

**អដ្ឋកថា សុមង្គលជាតក ចប់**

# សុត្តន្តបិដក

## គង្គមាលជាតក

[ ៤៥៣ ] ( ស្តេចទ្រង់ត្រាស់សួរភតិកបុរសថា ) ប្រឹថពីជាផែនដីក្តៅដូចរងើកភ្លើង ប្រកបដោយដីខ្សាច់ ( ក្តៅ ) ដូចផេះ ( ដែលភ្លើងឆេះ ) អ្នកច្រៀងនូវទំនុកទាំងឡាយ កម្តៅថ្ងៃមិនដុតកម្តៅអ្នកទេឬ ។ ព្រះអាទិត្យក្តៅខាងលើ ដីខ្សាច់ក្តៅខាងក្រោម អ្នកច្រៀងនូវទំនុកទាំងឡាយ កម្តៅថ្ងៃមិនដុតកម្តៅអ្នកទេឬ ។

[ ៤៥៤ ] ( ភតិកបុរសក្រាបទូលថា ) កម្តៅថ្ងៃមិនដុតកម្តៅខ្ញុំព្រះអង្គបានទេ កម្តៅ គឺកាមទាំងឡាយ ទើបញ៉ាំងខ្ញុំព្រះអង្គឲ្យក្តៅបាន បពិត្រព្រះរាជា ប្រយោជន៍ទាំងឡាយមានប្រការផ្សេងៗ ប្រយោជន៍ទាំងនោះ តែងដុតកម្តៅ ឯកម្តៅថ្ងៃមិនដុតកម្តៅទេ ។

[ ៤៥៥ ] ម្នាលកាម យើងបានឃើញឫសគល់របស់អ្នកហើយ ម្នាលកាម អ្នកកើតអំពីសេចក្តីត្រិះរិះ យើងលែងត្រិះរិះអ្នកទៀតហើយ ម្នាលកាម កាលបើយ៉ាងនេះ អ្នកនឹងមិនកើតមាន ( តទៅទៀតទេ ) ។

[ ៤៥៦ ] កាមទាំងឡាយ សូម្បីតិចក៏នៅតែមិនល្មម សូម្បីច្រើនក៏នៅតែមិនស្កប់ស្កល់ ឱមុខគួរសោផ្សេង និងការចរចារបស់ពួកជនពាល បុគ្គលលុះតែប្រឹងប្រកបព្យាយាម ទើបត្រាស់ដឹងបាន ។

[ ៤៥៧ ] ( ព្រះរាជាឧទយៈត្រាស់ថា ) នេះជាផលកម្ម មាន

ប្រមាណតិចរបស់យើង ឧទយៈបានសម្រេចនូវភាពជាធំ ឱហ្ន៎ មាណពណាបានលះនូវតម្រេកក្នុងកាមហើយបួស មាណពនោះឈ្មោះថា បានល្អហើយ ។

[ ៤៥៨ ] ( ព្រះវររាជមាតា ត្រាស់សួរថា ) ពួកសត្វតែងលះបង់នូវបាបកម្ម ( របស់ខ្លួន ) ដោយតបៈ លះបង់នូវការៈនៃខ្លួនជាខ្មាន់ព្រះកេស និងស្នួនឆ្នាំងដោយតបៈ នៃគន្ធមាលថ្ងៃនេះ អ្នកហ៊ានរំលោកហៅព្រហ្មទត្ត ( កូនអញ ) ដោយចំឈ្មោះ ព្រោះអាងមានតបៈឬ ។

[ ៤៥៩ ] ( ព្រះរាជាទ្រង់ត្រាស់ថា ) បពិត្រព្រះមាតា សូមទ្រង់ទតនូវផលនៃខន្តិ និងសោរច្ចៈ ដែលអាចឃើញជាក់ច្បាស់ដោយខ្លួនឯង ( ក្នុងបច្ចុប្បន្ន ) ព្រះគន្ធមាលបច្ចេកពុទ្ធនោះជាបុគ្គលដែលជនទាំងអស់ត្រូវថ្វាយបង្គំ យើង ព្រមទាំងស្ដេចនិងអាមាត្យនាំគ្នាថ្វាយបង្គំនូវព្រះបច្ចេកពុទ្ធនោះ ។

[ ៤៦០ ] អ្នកទាំងឡាយកុំនិយាយពាក្យតិចតួច នឹងព្រះបច្ចេកពុទ្ធឈ្មោះគន្ធមាល ដែលជាអ្នកសិក្សាក្នុងគន្លងនៃប្រាជ្ញារបស់ពួកអ្នកប្រាជ្ញឡើយ ព្រោះថា ព្រះបច្ចេកពុទ្ធនេះ បានឆ្លងនូវអន្លង់គឺវដ្ដសង្សារ ដែលពួកបុគ្គលអ្នកប្រាសចាកសោក តែងឆ្លងហើយ ត្រាច់ទៅ ។

**គន្ធមាលជាតកទី ៥ ចប់**

# អដ្ឋកថា

## គន្ធមាលជាតក

[ ៤៥៣-៤៦០ ] ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធឧបោសថកម្ម ទើបត្រាស់រឿងនេះ មានពាក្យផ្ដើមថា **អង្គារជាតា** ដូច្នេះជាដើម ។

មានសេចក្ដីសង្ខេបថា ថ្ងៃមួយ ព្រះសាស្ដាទ្រង់ហៅអ្នករក្សាឧបោសថមកហើយ ត្រាស់ថា ម្នាលឧបាសកទាំងឡាយ អ្នកទាំងឡាយធ្វើឧបោសថកម្មឲ្យសម្រេចល្អហើយ អ្នករក្សាឧបោសថគួរឲ្យទាន រក្សាសីល មិនក្រោធ ចម្រើនមេត្តា ចូររក្សាឧបោសថ បណ្ឌិតក្នុងកាលមុន បាននូវយសធំ ព្រោះអាស្រ័យឧបោសថកម្មដែលរក្សាពាក់កណ្ដាលថ្ងៃ ដូច្នេះ ពួកឧបាសកទាំងនោះទូលអារាធនា ទើបទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិក្នុងនគរពារាណសី ក្នុងនគរនោះ មានសេដ្ឋីម្នាក់ឈ្មោះសុចិបរិវារ មានសម្បត្តិ ៨០ កោដិ ជាអ្នកត្រេកអរក្នុងបុណ្យកុសល មានការឲ្យទានជាដើម ។ បុត្រក្ដី ភរិយាក្ដី ជនជាបរិវារក្ដី ដោយហោចក្មេងឃ្វាលគោក្នុងផ្ទះនោះក្ដី សុទ្ធតែជាអ្នករក្សាឧបោសថមួយខែ ៦ ថ្ងៃ ។ គ្រានោះ ព្រះពោធិសត្វកើតក្នុងត្រកូលអ្នកក្រីក្រមួយស៊ីឈ្នួលគេចិញ្ចឹមជីវិត រស់នៅដោយសេចក្ដីលំបាក ។ ព្រះពោធិសត្វគិតថា អញនឹងធ្វើការស៊ីឈ្នួល ទើបទៅកាន់ផ្ទះរបស់សុចិបរិវារសេដ្ឋី ថ្វាយបង្គំហើយ ឈរក្នុងទីសមគួរ នាចំណែកម្ខាង កាលលោកសេដ្ឋីសួរថា អ្នកមកធ្វើអ្វី ក៏ពោលថា មកដើម្បីស៊ីឈ្នួលធ្វើការងារក្នុងផ្ទះរបស់លោក ។ សេដ្ឋី

ធ្លាប់ពោលប្រាប់កូនឈ្នួលដទៃៗ ក្នុងថ្ងៃដែលមកដល់ថា បុគ្គលដែលធ្វើការក្នុងផ្ទះនេះ រក្សាសីលគ្រប់ៗគ្នា បើអ្នកអាចរក្សាសីលបាន ក៏ចូរធ្វើការងារចុះ តែសម្រាប់ព្រះពោធិសត្វ សេដ្ឋីមិនបានប្រាប់ឲ្យរក្សាសីល ទទួលព្រះពោធិសត្វថា សាធុ ចូរអ្នកស៊ីឈ្នួលធ្វើការងារចុះ ។

តាំងអំពីនោះមក ព្រះពោធិសត្វជាមនុស្សប្រដៅងាយ លះបង់ជីវិតមិនគិតដល់ការនឿយហត់របស់ខ្លួន ធ្វើការងារគ្រប់យ៉ាងឲ្យលោកសេដ្ឋី ។ ព្រះពោធិសត្វទៅធ្វើការងារអំពីព្រលឹម លុះពេលល្ងាច ទើបត្រឡប់មក ។

ថ្ងៃមួយ មានគេប្រកាសមហោស្រពក្នុងព្រះនគរ ។ មហាសេដ្ឋីហៅទាសីមកប្រាប់ថា ថ្ងៃនេះ ជាថ្ងៃឧបោសថ ចូរនាងចម្អិនបាយឲ្យពួកកម្មករក្នុងផ្ទះ តែក្នុងពេលព្រឹកបានហើយ ដល់ពេលវេលាពួកគេនឹងបានបរិភោគ រួចរក្សាឧបោសថ ។ ព្រះពោធិសត្វក្រោកឡើងអំពីព្រលឹមធ្វើការងារ មិនមានអ្នកណាប្រាប់ដល់ព្រះពោធិសត្វថា ថ្ងៃនេះ អ្នកគប្បីរក្សាឧបោសថ ។ ពួកកម្មករដ៏សេសបរិភោគអាហារអំពីព្រលឹមហើយ រក្សាឧបោសថ លោកសេដ្ឋីមួយអន្លើដោយកូនប្រពន្ធ ជនជាបរិវារ បានអធិដ្ឋានឧបោសថ ពួកជនដែលរក្សាឧបោសថទាំងអស់ បានទៅកាន់លំនៅរបស់ខ្លួន អង្គុយពិចារណាដល់សីល ព្រះពោធិសត្វធ្វើការងារពេញមួយថ្ងៃ ត្រឡប់មកក្នុងកាលដែលព្រះអាទិត្យអស្តង្គតហើយ ។ លំដាប់នោះ អ្នករៀបចំអាហារ បានឲ្យទឹកលាងដៃដល់ព្រះពោធិសត្វ ហើយដួសបាយដាក់ថាសឲ្យ ។ ព្រះពោធិសត្វសួរថា ថ្ងៃដទៃៗ ក្នុងវេលាថ្មើរនេះ មានសំឡេងអឺងកង តែថ្ងៃនេះ ជនទាំងនោះទៅ

ណាអស់ កាលបានស្ដាប់ថា ជនគ្រប់គ្នាសមាទានឧបោសថ ទៅកាន់លំនៅរៀងៗ ខ្លួន គិតថា អញជាអ្នកទ្រុស្ដសីលតែម្នាក់ឯង នឹងនៅបានក្នុងចំណោមអ្នកមានសីលទាំងនេះបានដូចម្ដេច កាលអញអធិដ្ឋានអឌ្ឍឧបោសថឥឡូវនេះឈ្មោះថា ជាអ្នករក្សាឧបោសថដែរឬហ្ន៎ គិតដូច្នេះហើយ ទើបសួរលោកសេដ្ឋី ។ លំដាប់នោះ សេដ្ឋីពោលនឹងព្រះពោធិសត្វថា នែបា នឹងជាឧបោសថកម្មទាំងអស់មិនបានព្រោះមិនបានអធិដ្ឋានអំពីព្រលឹមត្រឹមតែជាឧបោសថកម្មពាក់កណ្ដាលប៉ុណ្ណោះ ។ ព្រះពោធិសត្វពោលថា ត្រឹមប៉ុណ្ណោះក៏ដោយចុះបានសមាទានសីលក្នុងសម្នាក់របស់លោកសេដ្ឋីហើយ អធិដ្ឋានឧបោសថហើយចូលកាន់លំនៅរបស់ខ្លួន ដេកពិចារណាដល់សីល ។ កាលរាត្រីកន្លងចូលបច្ឆិមយាម ខ្យល់ក៏កម្រើកឡើងដល់ព្រះពោធិសត្វ ព្រោះអត់អាហារមកពេញមួយថ្ងៃ ។ លោកសេដ្ឋីបានប្រកបភេសជ្ជៈផ្សេងៗ នាំមកឲ្យបរិភោគព្រះពោធិសត្វក៏ពោលថា ខ្ញុំសមាទានឧបោសថ ដោយព្រមលះបង់ជីវិតដោយគិតថា នឹងមិនទម្លាយឧបោសថ ។ វេទនាដ៏ខ្លាំងក្លាបានកើតឡើងក្នុងពេលអរុណរះ ព្រះពោធិសត្វមិនអាចតម្កល់សតិបាន ។ មនុស្សទាំងឡាយគិតថា ព្រះពោធិសត្វនឹងស្លាប់ក្នុងកាលឥឡូវនេះ ទើបនាំទៅឲ្យដេកក្នុងរោងដាក់អាហារ ។

សម័យនោះ ព្រះបាទពារាណសីទ្រង់គង់រថព្រះទីន័ង ធ្វើប្រទក្សិណព្រះនគរដោយបរិវារធំដល់ទីនោះ ។ ព្រះពោធិសត្វឃើញសិរីរាជសម្បត្តិរបស់ស្ដេចពារាណសី កើតនូវចំណង់ចង់បានរាជសម្បត្តិ ។ កាលចុតិហើយ បាន

បដិសន្ធិក្នុងព្រះគភ៌របស់អគ្គមហេសីនៃព្រះបាទពារាណសី ដោយអានិសង្ស នៃឧបោសថពាក់កណ្ដាល ។ អគ្គមហេសីបានទូវគព្ភបរិហារហើយ លុះគ្រប់ទសមាស ក៏ប្រសូតព្រះរាជឱរស ។ ព្រះញាតិទាំងឡាយនាំគ្នាថ្វាយព្រះនាមថា **ឧទយកុមារ ។** ឧទយកុមារនោះចម្រើនវ័យហើយ សម្រេចការសិក្សានូវសិប្បៈគ្រប់យ៉ាង រឭកដល់បុព្វកម្មរបស់ខ្លួនបាន ដោយញាណជាគ្រឿងរឭកជាតិ ទើបបន្លឺឧទានរឿយៗ ថា នេះជាផលនៃកម្មបន្តិចបន្តួចរបស់អញដូច្នេះ កាលព្រះរាជបិតាសោយទិវង្គតហើយ បានគ្រងរាជសម្បត្តិ ទតសិរីរាជសម្បត្តិដ៏ក្រៃលែងរបស់ព្រះអង្គហើយ បន្លឺឧទានបែបនោះទៀត ។

ថ្ងៃមួយ អ្នកស្រុកត្រៀមការលេងមហោស្រពក្នុងព្រះនគរ ។ មហាជននាំគ្នាជាក់ចិត្តក្នុងការលេង ។ គ្រានោះ បុរសអ្នកស៊ីឈ្នួលម្នាក់ នៅក្បែរទ្វារទិសឧត្តរ ក្រុងពារាណសី រក្សាទ្រព្យកន្លះមាសក ដែលបានមកដោយការស៊ីឈ្នួល ដងទឹកទុកត្រង់កំពែងក្រុង បាននៅរួមជាមួយស្រីកំព្រាម្នាក់ ដែលចិញ្ចឹមជីវិតដោយការស៊ីឈ្នួលដងទឹកដូចគ្នាក្នុងព្រះនគរនោះ ។ ស្រីនោះបានពោលនឹងបុរសនោះថា នែអ្នក ក្នុងព្រះនគរមានមហោស្រព បើអ្នកមានទ្រព្យខ្លះ យើងទាំង ២ ទៅលេងជាមួយគ្នា ។ បុរសនោះឆ្លើយថា អើនាង ទ្រព្យខ្ញុំមាន ស្រីនោះសួរថា មានប៉ុន្មាន ក៏ប្រាប់ថា មានកន្លះមាសក ស្រីនោះសួរថា ទ្រព្យនោះនៅឯណា បុរសនោះប្រាប់ថា ខ្ញុំលាក់ក្រោមឥដ្ឋ ក្បែរទ្វារទិសខាងជើង ចម្ងាយអំពីទីនេះ ១២ យោជន៍ ចុះទ្រព្យក្នុងដៃរបស់នាងមានខ្លះឬ ស្រីនោះពោលថា អើ មាន បុរសនោះសួរថា មានប៉ុន្មាន ស្រីនោះឆ្លើយថា

កន្ទះមាសកដូចគ្នា ហើយពោលបន្តថា ទ្រព្យរបស់អ្នកកន្ទះមាសក របស់ខ្ញុំ កន្ទះមាសក រួមជា ១ មាសក យើងនឹងយកទ្រព្យនោះទិញផ្កាមួយចំណែក ទិញគ្រឿងក្រអូបមួយចំណែក ទិញស្រាមួយចំណែក ហើយដើរលេងទាំងអស់គ្នា ចូរអ្នកទៅនាំទ្រព្យកន្ទះមាសកដែលទុកមកចុះ ។

បុរសអ្នកស៊ីឈ្នួលត្រេកអរថា ប្រពន្ធជឿពាក្យរបស់អញ ទើបពោលថា នែនាង នាងកុំវិតក្កថ្វីឡើយ ខ្ញុំនឹងនាំទ្រព្យនោះមក ដូច្នេះហើយ ចៀសចេញទៅ ។ បុរសក្រីក្រមានកម្លាំងស្មើនឹងដំរីសារ ដើរឆ្លងមាគ៌ាទៅបាន ៦ យោជន៍ ក៏ដល់ពេលថ្ងៃត្រង់ ហើយដើរជាន់ខ្សាច់ក្ដៅដូចរងើកភ្លើង គាត់ត្រេកអរ ព្រោះចង់បានទ្រព្យ ស្លៀកដណ្ដប់កាសាវពស្ត្រ ប្រដាប់កុណ្ឌលស្លឹកត្នោតត្រង់ត្រចៀក ដើរច្រៀងធ្វើរំកើយទៅម្នាក់ឯង ឆ្លងកាត់តាមលានព្រះរាជវាំង ។

ព្រះបាទឧទយរាជបើកសីហបញ្ជរ ប្រថាប់ឈរ ទតឃើញបុរសកម្មករមកយ៉ាងនោះ ទ្រង់ព្រះតម្រិះថា ហេតុអ្វីហ្ន៎ ដែលធ្វើបុរសនេះ ឲ្យមិនលំបាកដោយខ្យល់ និងកម្ដៅថ្ងៃបែបនេះ មានសេចក្ដីត្រេកអរ ដើរច្រៀង អញនឹងសួរបុរសនេះមើល ដូច្នេះហើយ ទ្រង់បញ្ជូនបុរសម្នាក់ទៅឲ្យហៅមក ។ លុះបុរសនោះទៅប្រាប់ថា ព្រះរាជាត្រាស់ហៅអ្នក បុរសនោះឆ្លើយថា ព្រះរាជាជាអ្វីនឹងយើង យើងមិនធ្លាប់ស្គាល់ព្រះរាជាឡើយ ដូច្នេះ ។ ទើបបុរសនោះនាំទៅដោយការប្រើកម្លាំង ឈរក្នុងចំណែកម្ខាង ។ លំដាប់នោះ កាលព្រះរាជាត្រាស់សួរ ទើបត្រាស់ ២ គាថាថា

ប្រឹថពី ជាផែនដីក្តៅដូចរងើកភ្លើង ប្រកបដោយដីខ្សាច់ ( ក្តៅ ) ដូចផេះ ( ដែលភ្លើងឆេះ ) អ្នកច្រៀងនូវទំនុកទាំងឡាយ កម្តៅថ្ងៃមិនដុតកម្តៅអ្នកទេឬ ។ ព្រះអាទិត្យក្តៅខាងលើ ដីខ្សាច់ក្តៅខាងក្រោម អ្នកច្រៀងនូវទំនុកទាំងឡាយ កម្តៅថ្ងៃមិនដុតកម្តៅអ្នកទេឬ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អង្គារជាតា** សេចក្តីថា នៃបុរសដ៏ចម្រើន ផែនដីនេះក្តៅគគុក ដូចរងើកភ្លើង ។

បទថា **កុក្កុឡានុគតា**[១] សេចក្តីថា ដេរដាសទៅដោយខ្សាច់ក្តៅ ដូចផេះក្តៅ ពោល គឺផេះដែលក្តៅសព្វហើយ ។

បទថា **វត្តានិ** សេចក្តីថា លើករឿងដែលធ្វើមកច្រៀងជាចម្រៀង ។

បុរសកម្មករនោះស្តាប់ព្រះតម្រាស់របស់ព្រះរាជាហើយ បានទូលគាថាទី ៣ ថា

កម្តៅថ្ងៃ មិនដុតកម្តៅខ្ញុំព្រះអង្គបានទេ កម្តៅ គឺកាមទាំងឡាយទើបញ៉ាំងខ្ញុំព្រះអង្គឲ្យក្តៅបាន បពិត្រព្រះរាជា ប្រយោជន៍ទាំងឡាយមានប្រការផ្សេងៗ ប្រយោជន៍ទាំងនោះ តែងដុតកម្តៅ ឯកម្តៅថ្ងៃមិនដុតកម្តៅទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អាតប្បា** បានដល់ វត្ថុកាម និងកិលេសកាម វត្ថុកាម និងកិលេសកាមទាំងនោះ រមែងដុតបុរស ព្រោះហេតុនោះ

---

១- បិដកខ្មែរ ជា កុក្កុលានុគតា ។

ទើបបុរសអ្នកស៊ីឈ្នួលហៅវត្ថុកាម និងកិលេសកាមនោះៗ ថា **អាតប្បា**។

បទថា **អត្ថា ហិ វិវិធា** សេចក្ដីថា បពិត្រមហារាជ ការប៉ុនប៉ងច្រើនយ៉ាង ពោល គឺកិច្ចផ្សេងៗ ដែលត្រូវធ្វើ ព្រោះអាស្រ័យវត្ថុកាម និងកិលេសកាមរបស់ទូលបង្គំមាន វត្ថុកាម និងកិលេសកាមទាំងនេះ ដុតទូលបង្គំ ឯកម្ដៅថ្ងៃ មិនឈ្មោះថា ដុតទូលបង្គំឡើយ ។

លំដាប់នោះ ព្រះរាជាត្រាស់សួរបុរសនោះថា បំណងរបស់អ្នកដូចម្ដេច បុរសនោះក្រាបទូលថា បពិត្រព្រះសម្មតិទេព ទូលបង្គំនៅរួមជាមួយស្រីកំព្រា ក្បែរទ្វារទិសទក្សិណ នាងសួរទូលបង្គំថា នែអ្នក យើងនឹងទៅមើលការលេងមហោស្រព អ្នកមានទ្រព្យក្នុងដៃខ្លះដែរឬទេ ទូលបង្គំបានពោលនឹងនាងថា ទ្រព្យខ្ញុំកប់ទុកត្រង់ញកកំពែងក្បែរទ្វារទិសឧត្តម នាងពោលថា ចូរអ្នកទៅនាំទ្រព្យនោះមក យើងទាំង ២ នឹងទៅមើលការលេងមហោស្រព ហើយបញ្ជូនទូលបង្គំមក ពាក្យរបស់នាង ចាប់ចិត្តទូលបង្គំ កាលទូលបង្គំនឹកដល់ពាក្យរបស់នាង កម្ដៅ គឺកាម រមែងដុតបំណងរបស់ទូលបង្គំយ៉ាងនេះឯង ។ ព្រះរាជាត្រាស់ថា បើឯងមិនរួញរាចំពោះខ្យល់ និងកម្ដៅថ្ងៃបែបនេះ អ្វីជាហេតុឲ្យឯងត្រេកអរ ដើរច្រៀងយ៉ាងនេះ ។ បុរសនោះទូលថា បពិត្រព្រះសម្មតិទេព ទូលបង្គំនាំទ្រព្យដែលកប់នោះមកបានហើយ នឹងអភិរម្យជាមួយស្រីនោះ ដោយហេតុដូចក្រាបទូលមកនេះ ទើបទូលបង្គំត្រេកអរ ហើយច្រៀង ព្រះរាជាត្រាស់សួរថា នែបុរសដ៏ចម្រើន ទ្រព្យដែលកប់ទុកត្រង់ទ្វារទិសឧត្តរ មានប្រមាណបានមួយសែនដែរឬទេ បុរសនោះក្រាបទូលថា បពិត្រ

មហារាជ មិនដល់ប៉ុណ្ណោះទេ ព្រះរាជាត្រាស់សួរដោយលំដាប់ថា បើដូច្នោះ ប្រហែល ៥ ម៉ឺន កហាបណៈ ៤ ម៉ឺនកហាបណៈ ៣ ម៉ឺនកហាបណៈ ២ ម៉ឺនកហាបណៈ ១ ម៉ឺនកហាបណៈ ១ ពាន់កហាបណៈ ៥ រយកហាបណៈ ៤ រយកហាបណៈ ៣ រយកហាបណៈ ២ រយកហាបណៈ ១ រយកហាបណៈ ៥០ កហាបណៈ ៤០ កហាបណៈ ៣០ កហាបណៈ ២០ កហាបណៈ ១០ កហាបណៈ ៥ កហាបណៈ ៤ កហាបណៈ ៣ កហាបណៈ ២ កហាបណៈ ១ កហាបណៈ កន្លះកហាបណៈ ១ បាទ ៤ មាសក ៣ មាសក ២ មាសក ១ មាសក ។ បុរសអ្នកស៊ីឈ្នួល បដិសេធគ្រប់លំដាប់ កាលព្រះរាជាត្រាស់ថា តើទ្រព្យនោះកន្លះមាសកឬ បុរសនោះក្រាបទូលថា ករុណាថ្លៃវិសេស ទ្រព្យរបស់ទូលបង្គំមានប្រមាណប៉ុណ្ណោះ ទូលបង្គំដើរមក ដោយនឹកក្នុងចិត្តថា នាំទ្រព្យមកបានហើយ នឹងអភិរម្យជាមួយនាង ដោយបីតិសោមនស្សនោះ ទើបខ្យល់ និងកម្តៅថ្ងៃមិនដុតទូលបង្គំ ។

សម័យនោះ ព្រះរាជាត្រាស់នឹងបុរសនោះថា នៃបុរសដ៏ចម្រើន កម្តៅថ្ងៃដល់ម្ល៉េះ អ្នកកុំទៅទីនោះឡើយ យើងនឹងឲ្យកន្លះមាសកដល់ឯង បុរសនោះក្រាបទូលថា បពិត្រព្រះសម្មតិទេព ទូលបង្គំនឹងតាំងនៅក្នុងព្រះតម្រាស់របស់ព្រះអង្គ ទទួលយកទ្រព្យកន្លះមាសកនោះផង និងមិនធ្វើទ្រព្យដែលកប់ទុកឲ្យវិនាសទៅផង ទូលបង្គំនឹងទៅយកទ្រព្យនោះ មិនឲ្យវិនាសដោយការដើរផ្លូវ ដែលខំដើរមកផង ។ ព្រះរាជាត្រាស់ថា នៃបុរសដ៏ចម្រើន ចូរឯងត្រឡប់ចុះ យើងនឹងឲ្យទ្រព្យ ១ មាសក ២ មាសក ហើយទ្រង់ត្រាស់ព្រះ

រាជទានបន្ថែមឡើង ដោយទំនងនេះ រហូតដល់មួយកោដិ មួយរយកោដិ និង ទ្រព្យរាប់មិនអស់ ហើយឲ្យបុរសនោះត្រឡប់ បុរសនោះក្រាបទូលថា ទូលបង្គំសូមទទួលទ្រព្យដែលទ្រង់ព្រះរាជទានផង ទ្រព្យដែលកប់ទុកក៏នឹងទៅយកផង ។ បន្ទាប់អំពីនោះ ព្រះរាជាបានលួងលោមដោយឋានន្តរ មានតំណែងសេដ្ឋីជាដើម រហូតឲ្យតាំងនៅក្នុងតំណែងជាឧបរាជ ដោយត្រាស់ថា យើងនឹងឲ្យគ្រងរាជសម្បត្តិពាក់កណ្តាល ចូរត្រឡប់ចុះ ដូច្នេះហើយ ទើបយល់ព្រមទទួលព្រះតម្រាស់ ។

ព្រះរាជាទ្រង់បញ្ជាអមាត្យទាំងឡាយថា ចូរពួកអ្នកទៅកោរពុកមាត់ឲ្យសម្លាញ់របស់យើង ហើយឲ្យងូតទឹក តែងខ្លួន នាំមកជួបយើង ពួកអមាត្យបានធ្វើតាមព្រះតម្រាស់នោះ ។ ព្រះរាជាចែករាជសម្បត្តិជា ២ ចំណែក ឲ្យបុរសស៊ីឈ្នួលនោះ គ្រប់គ្រងរាជសម្បត្តិពាក់កណ្តាល ។ អាចារ្យពួកខ្លះពោលថា បុរសស៊ីឈ្នួលនោះ គ្រងរាជសម្បត្តិនោះហើយ នៅតែទៅកាន់ទិសឧត្តរ ដោយការស្រឡាញ់ក្នុងទ្រព្យកន្លះមាសក ហេតុនោះ ទើបបានឈ្មោះថា អឌ្ឍមាសករាជ ។

ព្រះបាទឧទយរាជ និងព្រះបាទអឌ្ឍមាសករាជ ទ្រង់សាមគ្គីស្និទ្ធស្នាលគ្នាគ្រងរាជសម្បត្តិ ថ្ងៃមួយ យាងទៅព្រះរាជឧទ្យាន ។ ព្រះបាទឧទយរាជទ្រង់លេងកីឡាក្នុងព្រះរាជឧទ្យាននោះ រហូតអស់កម្លាំងហើយ យកសីសៈដាក់លើភ្លៅរបស់ព្រះបាទអឌ្ឍមាសករាជ ផ្ទំលក់ទៅ ។ គ្រាទ្រង់ផ្ទំលក់ហើយពួករាជបរិវារក៏នាំគ្នាទៅលេងកីឡាក្នុងទីនោះៗ ព្រះបាទអឌ្ឍមាសករាជ ទ្រង់

ព្រះតម្រិះថា ប្រយោជន៍អ្វី ដែលអញសោយរាជសម្បត្តិពាក់កណ្តាលជានិច្ច អញនឹងផ្តាច់ព្រះជន្មព្រះបាទឧទយរាជ សោយរាជសម្បត្តិម្នាក់ឯងល្អជាង ដូច្នេះហើយ ទើបហូតដាវចេញអំពីស្រោម គិតនឹងផ្តាច់ព្រះជន្មព្រះបាទឧទយរាជ តែរឭកបានថា ព្រះរាជាអង្គនេះ ធ្វើអញដែលជាជនក្រីក្រកំព្រា ឲ្យមានយសសក្តិស្មើដោយព្រះអង្គ និងតែងតាំងអញក្នុងភាពជាធំក្រៃលែង ការដែលអញបំណងនឹងសម្លាប់អ្នកដែលឲ្យយសដល់អញបែបនេះ ជារឿងដែលមិនសមគួរធ្វើឡើយ ។ រឭកបានដូច្នេះហើយ ស៊កដាវក្នុងស្រោម តែគិតហើយ គិតទៀត អស់ ២ ដង ៣ ដង ដើម្បីសម្លាប់នោះ តែមិនអាចស្ងប់ចិត្តបាន ទើបតាំងព្រះហឫទ័យថា ចិត្តនេះកើតឡើងរឿយៗ គប្បីប្រកបអញក្នុងកម្មលាមក ទើបបោះព្រះខ័នទៅលើផែនដី ដាស់ព្រះបាទឧទយរាជឲ្យភ្ញាក់ពីបន្ទំ ហើយក្រាបចុះទៀបបាតជើង ក្រាបទូលថា បពិត្រព្រះអង្គ សូមទ្រង់ព្រះរាជទានទោសដល់ខ្ញុំចុះ ។ ព្រះបាទឧទយរាជត្រាស់ថា នែសម្លាញ់ ទោសក្នុងរវាងអ្នក និងយើង មិនមានមិនមែនឬ អឌ្ឍមាសករាជ ត្រាស់ថា មានទូលបង្គំបានធ្វើយ៉ាងនេះៗ ព្រះបាទឧទយពោលថា បើដូច្នោះ ខ្ញុំអត់ទោសឲ្យ បើអ្នកចង់គ្រងរាជសម្បត្តិ ក៏ចូរគ្រងសម្បត្តិចុះ ចំណែកខ្ញុំនឹងធ្វើជាឧបរាជទំនុកបម្រុងទ្រង់ ព្រះបាទអឌ្ឍមាសករាជក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំមិនត្រូវការរាជសម្បត្តិ ព្រោះតណ្ហានេះ ធ្វើឲ្យខ្ញុំកើតក្នុងអបាយ សូមទ្រង់គ្រប់គ្រងរាជសម្បត្តិរបស់ទ្រង់មួយអង្គឯងចុះ ខ្ញុំសូមលាទៅបួស ឫសគល់នៃកាមគុណ ខ្ញុំឃើញហើយ ការពិត កាមគុណនេះ ចម្រើនដល់បុគ្គលត្រិះរិះ

ឥឡូវនេះ តអំពីនេះទៅ ខ្ញុំមិនត្រិះរិះដល់ទៀតឡើយ ដូច្នេះ កាលនឹងបន្លឺឧទាន ទើបត្រាស់គាថាទី ៤ ថា

ម្នាលកាម យើងបានឃើញឫសគល់របស់អ្នកហើយ ម្នាលកាម អ្នកកើតអំពីសេចក្ដីត្រិះរិះ យើងលែងត្រិះរិះអ្នកទៀតហើយ ម្នាលកាម កាលបើយ៉ាងនេះ អ្នកនឹងមិនកើតមាន ( តទៅទៀតទេ ) ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឯវំ** សេចក្ដីថា អ្នកមិនមានខាងក្នុងរបស់យើង ដោយអាការយ៉ាងនេះ ។ បទថា **ន ហោហិសិ** សេចក្ដីថា អ្នកនឹងមិនកើតឡើង ។ កាលត្រាស់ដូច្នេះហើយ កាលនឹងសម្ដែងធម៌ដល់មហាជនដែលប្រកបក្នុងកាមតទៅ ទើបត្រាស់គាថាទី ៥ ថា

កាមទាំងឡាយ សូម្បីតិចក៏នៅតែមិនល្មម សូម្បីច្រើន ក៏នៅតែមិនស្កប់ស្កល់ ឱ មុខគួរសង្វេគ និងការចរចារបស់ពួកជនពាល បុគ្គលលុះតែប្រឹងប្រកបព្យាយាម ទើបត្រាស់ដឹងបាន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អហហា** ជាបទសម្ដែងដល់សេចក្ដីសង្វេគ ។ បទថា **ជគ្គតោ** បានដល់ បុគ្គលព្យាយាមបដិបត្តិ ។

លោកអធិប្បាយដូច្នេះថា បពិត្រមហារាជ វត្ថុកាម និងកិលេសកាម សូម្បីតិចតួច ក៏មិនគ្រប់គ្រាន់សម្រាប់មហាជននេះ មហាជន រមែងមិនឆ្អែតដោយវត្ថុកាម និងកិលេសកាម សូម្បីច្រើន គួរសង្វេគ ដែលពួកជនពាល

នាំគ្នារេរីរវាយថា រូប សំឡេងទាំងនេះ ចូរមានដល់អញ កុលបុត្រដែលប្រកបសេចក្តីព្យាយាម ចម្រើនពោធិបក្ខិយធម៌ ញុំាងវិបស្សនាឲ្យចម្រើនហើយ គប្បីដឹងច្បាស់ ចាក់ធ្លុះបាន គឺចាក់ធ្លុះបានដោយការកំណត់ដឹងការលះ និងការត្រាស់ដឹងហើយ លះបង់បាន ។

ព្រះបាទអឌ្ឍមាសករាជ កាលទ្រង់សម្តែងធម៌ដល់មហាជនយ៉ាងនេះហើយ ព្រះបាទឧទយរាជទ្រង់គ្រប់គ្រងរាជសម្បត្តិ លះមហាជនដែលមានមុខជោកដោយទឹកភ្នែក ចូលហិមវន្តប្បទេស បួសហើយ ញុំាងឈាន និងអភិញ្ញាឲ្យកើត ។ កាលព្រះបាទអឌ្ឍមាសករាជបួសហើយ ព្រះបាទឧទយ-រាជ កាលនឹងបន្លឺឧទាន ទើបត្រាស់គាថាទី ៦ ថា

នេះជាផលកម្ម មានប្រមាណតិចរបស់យើង ឧទយៈបានសម្រេច
នូវភាពជាធំ ឱហ្ន៎ មាណពណាបានលះនូវតម្រេកក្នុងកាម
ហើយបួស មាណពនោះ ឈ្មោះថា បានល្អហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧទយោ** ព្រះបាទឧទយរាជត្រាស់សំដៅដល់ព្រះអង្គឯង ។ បទថា **មហត្តបត្តោ** សេចក្តីថា ដល់នូវភាពជាធំ បានដល់សម្រេចនូវឥស្សរិយយសដ៏បរិបូណ៌ ។ បទថា **មាណវស្ស** សេចក្តីថា ព្រះបាទឧទយរាជត្រាស់ ដោយមានបំណងយ៉ាងនេះថា មាណពណា លះកាមរាគចេញបួសហើយ មាណពនោះ គឺសត្វ បានដល់ សម្មាញ់របស់បុគ្គលដែលបានលាភល្អហើយ ។

អត្ថនៃគាថានេះ មិនមានអ្នកណាដឹង ។ ថ្ងៃមួយ ព្រះអគ្គមហេសីទូល

សួរអត្ថនៃព្រះគាថានឹងព្រះរាជា ។ ព្រះរាជាមិនត្រាស់ប្រាប់ ទ្រង់មានជាងកោរកាត់ម្នាក់ ឈ្មោះគន្ធមាលៈ ។ នាយគន្ធមាលៈនោះ កាលនឹងកោរព្រះមស្សុព្រះរាជា បានធ្វើបរិកម្មដោយកាំបិតកោរមុន ហើយទើបដកព្រះលោមាដោយចន្ទុះឯក្រោយ កាលបរិកម្មដោយកាំបិតកោរ ព្រះរាជាទ្រង់មានសេចក្តីសុខ ពេលដែលដកព្រះលោមា ព្រះរាជាទ្រង់មានសេចក្តីទុក្ខ ព្រះរាជានោះបំណងព្រះរាជទានពរដល់ជាងកោរកាត់មុន និងបំណងថា កាត់សក់ជាខាងក្រោយ ។

ថ្ងៃមួយ ព្រះរាជាត្រាស់ប្រាប់រឿងនោះ ដល់ព្រះរាជទេវីថា នាងជាទីស្រឡាញ់ នាយគន្ធមាលៈជាងកោរកាត់របស់យើងជាបុគ្គលល្ងង់ កាលព្រះរាជទេវីទូលសួរថា បពិត្រមហារាជ នាយគន្ធមាលៈជាងកោរកាត់ធ្វើដូចម្តេចទើបគួរ ក៏ត្រាស់ថា គួរដកលោមាមុន ហើយសឹមធ្វើបរិកម្មដោយកាំបិតកោរក្នុងកាលជាក្រោយ ។ ព្រះរាជទេវីហៅជាងកោរកាត់មកត្រាស់ថា ពេលនេះដល់ថ្ងៃដែលសម្អាតព្រះមស្សុថ្វាយព្រះរាជា អ្នកគប្បីដកព្រះលោមាមុន រួចធ្វើបរិកម្មដោយកាំបិតក្នុងកាលជាខាងក្រោយ កាលព្រះរាជាប្រទានពរឲ្យអ្នកគប្បីទូលថា មិនត្រូវការពរដទៃ សូមទ្រង់ប្រាប់អត្ថនៃឧទានគាថារបស់ទ្រង់ យើងនឹងឲ្យទ្រព្យច្រើនដល់អ្នក ។ ជាងកោរកាត់ទទួលព្រះសវនីយ៍ថា សាធុ លុះដល់ថ្ងៃសម្អាតព្រះមស្សុ បានប្រើចន្ទុះដកមុន កាលព្រះរាជាត្រាស់សួរថា នៃគន្ធមាលៈ ហេតុអ្វី ទើបឯងមិនធ្វើដូចសព្វមួយដង គន្ធមាលៈក្រាបទូលថា បពិត្រព្រះសម្មតិទេព ធម្មតាជាងកោរកាត់ រមែងធ្វើវត្ថុដែលមិនធ្លាប់ធ្វើ ទូល

រួច ក៏ដកព្រះលោមាមុន ហើយធ្វើបរិកម្មដោយកាំបិតកោរក្នុងកាលក្រោយ ។ ព្រះរាជាត្រាស់ថា ចូរអ្នកទទួលពរ កាលជាងកោរកាត់ក្រាបទូលថា ទូលបង្គំ មិនត្រូវការពរដទៃ សូមទ្រង់ប្រាប់សេចក្តីនៃឧទានគាថា ។ ព្រះរាជាទ្រង់ខ្មាស ព្រោះជារឿងដែលទ្រង់ក្រីក្រ ទើបត្រាស់ថា ឯងត្រូវការពរនេះធ្វើអ្វី ចូរទទួល ពរដទៃចុះ ។ ជាងកោរកាត់ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ ប្រទានពរនេះដល់ទូលបង្គំចុះ ។ ព្រះរាជាទ្រង់ខ្លាចមុសាវាទកម្ម ទើបទទួល ពាក្យ ហើយបញ្ជាឲ្យបាត់ថែង គាក់តែងវត្ថុទាំងពួង តាមន័យដែលពោល ហើយ ក្នុងកុម្មាសបិណ្ឌជាតក គង់ប្រថាប់លើរតនបល្ល័ង្ក ត្រាស់និទានបុរិម- កិរិយាទាំងពួងថា នៃគង្គមាលៈ ក្នុងកពមុន យើងកើតជាអ្នកក្រីក្រ ត្រង់ នគរនេះ មានសទ្ធារក្សាសីលកន្លះថ្ងៃ ចុតិអំពីអត្តភាពនោះ មកកើតក្នុងត្រកូល ក្សត្រ ឈ្មោះឧទយរាជ ដោយហេតុនេះ ទើបយើងពោលកន្លះគាថាខាងដើម កាលសម្លាញ់របស់យើង លះកាមរាគទៅបួសហើយ យើងជាបុគ្គលប្រមាទ វង្វេង នៅគ្រប់គ្រងរាជសម្បត្តិនេះឯង ដោយហេតុនេះ ទើបយើងពោលកន្លះ គាថាខាងចុង ។ ព្រះរាជាត្រាស់ប្រាប់ន័យឧទាន ដោយប្រការដូច្នេះ ។

ជាងកោរកាត់ស្តាប់រឿងនោះហើយ គិតថា បានឮថា ព្រះរាជាបាន រាជសម្បត្តិនេះ ដោយការរក្សាឧបោសថកន្លះថ្ងៃ ឈ្មោះថា កុសល បុគ្គល គួរតែធ្វើ បើដូច្នោះ អញគប្បីបួស សាងទីពឹងដល់ខ្លួនចុះ គិតហើយ ក៏លះ ពួកញាតិ និងភោគសម្បត្តិ សូមព្រះរាជាបួស ហើយទៅកាន់ហិមវន្តប្បទេស បួសជាឥសី លើត្រៃលក្ខណ៍ឡើងចម្រើនវិបស្សនា ក៏សម្រេចបច្ចេកពោ-

ធិញ្ញាណា ទ្រទ្រង់បាត្រ និងចីវរដែលកើតឡើងដោយឫទ្ធិ ចាំវស្សាត្រង់ភ្នំ គន្ធមាទន៍ បាន ៥ ឆ្នាំ គិតថា នឹងសួរសុខទុក្ខព្រះបាទពារាណសី ទើបហោះ មកគង់លើមង្គលសិលា ក្នុងមង្គលរាជឧទ្យាន ។ អ្នកយាមឧទ្យានចាំបាន ទើបទៅក្រាបទូលព្រះរាជាថា បពិត្រព្រះអង្គ ជាងកោរកាត់គង្គមាលៈជាព្រះ បច្ចេកពុទ្ធ ហោះមកគង់ក្នុងមង្គលរាជឧទ្យាន ។ ព្រះរាជាទ្រង់ស្តាប់ហើយ ប្រញាប់ប្រញាល់ចេញមក ដោយបំណងថា នឹងថ្វាយបង្គំព្រះបច្ចេកពុទ្ធ ។ ព្រះរាជជននីចេញទៅ មួយអន្លើដោយព្រះរាជា ។ ព្រះរាជាយាងទៅកាន់ព្រះ រាជឧទ្យាន ថ្វាយបង្គំព្រះបច្ចេកពុទ្ធហើយ គង់ប្រថាប់ក្នុងទីសមគួរ នាចំណែក ម្ខាង មួយអន្លើដោយបរិស័ទ ។ ព្រះបច្ចេកពុទ្ធ កាលធ្វើបដិសណ្ឋារៈជាមួយ ព្រះរាជា បានហៅព្រះរាជាតាមនាមត្រកូល ធ្វើបដិសណ្ឋារៈថា ម្នាលព្រហ្មទត្ត ទ្រង់មិនប្រមាទ គ្រងរាជសម្បត្តិដោយធម៌ បំពេញបុណ្យ មានឲ្យទានជាដើម ឬ ។ ព្រះរាជជននីបានស្តាប់ដូច្នោះ ព្រះនាងទ្រង់ព្រះពិរោធថា គង្គមាលៈ នេះ មានជាតិថោកទាប លាមក ជាជាងកោរកាត់ មិនស្គាល់ប្រមាណខ្លួន ហៅឱរសរបស់អញដែលជាស្តេចផែនដី ជាស្តេចដោយជាតិ ដោយឈ្មោះថា ព្រហ្មទត្ត ដូច្នេះហើយ ទើបត្រាស់គាថាទី ៧ ថា

> ពួកសត្វ តែងលះបង់នូវបាបកម្ម ( របស់ខ្លួន ) ដោយតបៈ
> លះបង់នូវការៈនៃខ្លួនជាខ្មាន់ព្រះកេស និងស្នូទធ្មាំង ដោយតបៈ
> នៃគង្គមាល ថ្ងៃនេះ អ្នកហ៊ានរំលោក ហៅព្រហ្មទត្ត ( កូន
> អញ ) ដោយចំឈ្មោះ ព្រោះអាងមានតបៈឬ ដូច្នេះ ។

គាថានោះ មានអធិប្បាយដូច្នេះថា ព្រះរាជជននីត្រាស់ថា សត្វទាំងឡាយនេះ រមែងលះបាបកម្មបានដោយតបៈ គឺតបគុណដែលខ្លួនសន្សំ តែតបៈទាំងនោះ នឹងលះភាពជាជាងកោរកាត់ និងស្មូនឆ្នាំងបានដែរឬ នែគន្ធមាលៈ ការដែលអ្នកប្រើតបៈរបស់ខ្លួន សង្កត់សង្កិន ហៅឱរសរបស់យើង ដោយឈ្មោះថា ព្រហ្មទត្ត ក្នុងថ្ងៃនេះ ជាការមិនសមគួរឡើយ ។

ព្រះរាជាត្រាស់ហាមព្រះជននីហើយ កាលប្រកាសគុណរបស់ព្រះបច្ចេកពុទ្ធ ទើបត្រាស់គាថាទី ៨ ថា

បពិត្រព្រះមាតា សូមទ្រង់ទតនូវផលនៃខន្តិ និងសោរច្ចៈ ដែលអាចឃើញជាក់ច្បាស់ ដោយខ្លួនឯង ( ក្នុងបច្ចុប្បន្ន ) ព្រះគន្ធមាលបច្ចេកពុទ្ធនោះ ជាបុគ្គលដែលជនទាំងអស់ ត្រូវថ្វាយបង្គំ យើង ព្រមទាំងស្តេច និងអាមាត្យ នាំគ្នាថ្វាយបង្គំនូវព្រះបច្ចេកពុទ្ធនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ខន្តិ សោរច្ចស្ស** បានដល់ អធិវាសនខន្តិ និងសោរច្ចៈ ។ បទថា **តំ វន្ទាម** សេចក្តីថា បពិត្រព្រះមាតា ឥឡូវនេះ យើងទាំងឡាយ ព្រះរាជាក្តី អមាត្យក្តី ទាំងអស់ ត្រូវនាំគ្នាថ្វាយបង្គំព្រះបច្ចេកពុទ្ធ សូមព្រះមាតាឃើញផលនៃខន្តិ និងសោរច្ចៈចុះ ។

កាលព្រះរាជាត្រាស់ហាមព្រះរាជជននីហើយ មហាជនដ៏សេសក្រោកឡើងពោលថា បពិត្រព្រះសម្មតិទេព ការដែលមនុស្សថោកទាបបែបនេះហៅទ្រង់ដោយឈ្មោះ មិនសមគួរដល់ទ្រង់ឡើយ ព្រះរាជាទ្រង់ហាមមហាជន

ហើយ ដើម្បីសម្តែងគុណរបស់ព្រះបច្ចេកពុទ្ធនោះ ទើបត្រាស់អវសានគាថាថា

អ្នកទាំងឡាយ កុំនិយាយពាក្យតិចតួច នឹងព្រះបច្ចេកពុទ្ធឈ្មោះ
គន្ធមាល ដែលជាអ្នកសិក្សាក្នុងគន្លងនៃប្រាជ្ញារបស់ពួកអ្នកប្រាជ្ញ
ឡើយ ព្រោះថា ព្រះបច្ចេកពុទ្ធនេះ បានឆ្លងនូវអន្លង់ គឺវដ្ត-
សង្សារ ដែលពួកបុគ្គលអ្នកប្រាសចាកសោក តែងឆ្លង ហើយ
ត្រាច់ទៅ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មុនិនំ** បានដល់ អាគារិកមុនី អនាគារិកមុនី សេក្ខមុនី អសេក្ខមុនី និងបច្ចេកមុនី ។ បទថា **មោនបថេសុ សិក្ខមានំ** សេចក្តីថា ដែលសិក្សាក្នុងគន្លងមុនី ពោល គឺពោធិបក្ខិយធម៌ ព្រោះជាបដិបទា ដែលជាបុព្វភាគ ។ បទថា **អណ្ណវំ** បានដល់ សមុទ្រ គឺសង្សារ ។ ព្រះរាជាកាលត្រាស់ដូច្នេះហើយ បាននមស្ការព្រះបច្ចេកពុទ្ធ ត្រាស់ថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់អត់នូវទោសដល់ព្រះរាជជននីផងចុះ ។

ព្រះបច្ចេកពុទ្ធពោលថា ថ្វាយព្រះពរមហាបពិត្រ អាត្មាអត់ទោសឲ្យ ។

ពួករាជបរិស័ទ ក៏នាំគ្នាសូមខមាទោសព្រះបច្ចេកពុទ្ធ ។ ព្រះរាជាសូមប្តេជ្ញាអំពីព្រះបច្ចេកពុទ្ធដើម្បីនៅជាមួយទ្រង់តទៅ ព្រះបច្ចេកពុទ្ធមិនឲ្យនូវប្តេជ្ញា កាលបរិស័ទ មួយអន្លើដោយព្រះរាជាកំពុងមើលនោះឯង បានអណ្តែតទៅក្នុងអាកាស ថ្វាយឱវាទដល់ព្រះរាជា ហើយហោះទៅកាន់ភ្នំគន្ធមាទន៍ ។

ព្រះបរមសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកសម្តែងហើយ ក៏ត្រាស់ថា ម្នាលឧបាសកទាំងឡាយ ឈ្មោះថា ការរក្សាឧបោសថ ជាកិច្ចដែលបុគ្គលគួររក្សា ដោយប្រការដូច្នេះ ហើយទ្រង់ប្រជុំជាតកថា ព្រះបច្ចេកពុទ្ធក្នុងកាលនោះ បានបរិនិព្វានហើយ ព្រះអឡមាសករាជ ក្នុងកាលនោះ បានមកជាអានន្ទ ក្នុងកាលឥឡូវនេះ ព្រះរាជជននីក្នុងកាលនោះ បានមកជាព្រះនាងមហាមាយា អគ្គមហេសី ក្នុងកាលនោះ បានមកជារាហុលមាតា ចំណែកព្រះបាទឧទយរាជ ក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា គណ្ឌមាលជាតក ចប់

# សុត្តន្តបិដក

## ចេតិយរាជជាតក

[ ៤៦១ ] ( តាបសនិយាយថា ) ធម៌ដែលបុគ្គលសម្លាប់ហើយ រមែងសម្លាប់វិញដោយពិត ធម៌ដែលបុគ្គលមិនបានសម្លាប់ រមែងមិនសម្លាប់វិញតិចតួចឡើយ ។ ព្រោះហេតុនោះ ព្រះអង្គមិនត្រូវសម្លាប់ធម៌ ព្រះអង្គកុំឲ្យធម៌ដែលព្រះអង្គសម្លាប់ហើយ ត្រឡប់សម្លាប់ព្រះអង្គវិញបានឡើយ ។

[ ៤៦២ ] កាលបើស្តេចពោលពាក្យកុហក ពួកទេវតារមែងគេចចេញ ( លែងរក្សា ) ស្តេចណាជ្រាបកាលគេសួរប្រស្នា ហើយព្យាករប្រស្នានោះដោយប្រការដទៃវិញ ព្រះឱស្ឋស្តេចនោះ រមែងមានក្លិនស្អុយផ្សាយចេញទៅ ទាំងស្តេចនោះទៀត រមែងឃ្លាតចាកកន្លែងរបស់ខ្លួន បពិត្រព្រះរាជា បើប្រសិនជាព្រះអង្គទ្រង់ពោលពាក្យពិត សូមឲ្យព្រះអង្គឋិតនៅដូចដើម បពិត្រព្រះបាទចេតិយៈ បើព្រះអង្គទ្រង់ពោលពាក្យកុហក សូមឲ្យព្រះអង្គឋិតនៅលើផែនដី ។

[ ៤៦៣ ] ស្តេចណា ជ្រាបកាលគេសួរប្រស្នាហើយ ក៏ព្យាករប្រស្នានោះដោយប្រការដទៃវិញ ភ្លៀងរមែងធ្លាក់ចុះក្នុងកាលមិនគួរ ( ក្នុងដែន ) របស់ស្តេចនោះ ភ្លៀងរមែងមិនធ្លាក់ចុះក្នុងកាលគួរ ( ក្នុងដែនរបស់ស្តេចនោះ ) បពិត្រព្រះរាជា បើព្រះអង្គទ្រង់ពោលនូវពាក្យពិត សូមឲ្យព្រះអង្គទ្រង់ឋិតនៅដូចដើម

បពិត្រព្រះបាទចេតិយៈ បើព្រះអង្គទ្រង់ពោលពាក្យកុហក សូមឲ្យព្រះអង្គចូលទៅកាន់ផែនដី ( ត្រឹមព្រះជានុ ) ។

[ ៤៦៤ ] បពិត្រព្រះអង្គជាធំក្នុងទិស ស្តេចណា ជ្រាបកាលគេសួរប្រស្នាហើយ ក៏ព្យាករប្រស្នានោះដោយប្រការដទៃវិញ អណ្តាតរបស់ស្តេចនោះ រមែងបែកជាពីរ ដូចជាអណ្តាតនៃពស់ បពិត្រព្រះរាជា បើព្រះអង្គទ្រង់ពោលពាក្យពិត សូមឲ្យព្រះអង្គឋិតនៅដូចដើម បពិត្រព្រះបាទចេតិយៈ បើព្រះអង្គទ្រង់ពោលពាក្យកុហក សូមឲ្យព្រះអង្គចូលកាន់ផែនដីក្រៃលែង ( ជាងនេះ គឺត្រឹមចង្កេះ ) ។

[ ៤៦៥ ] បពិត្រព្រះអង្គជាធំក្នុងទិស ស្តេចណា ជ្រាបកាលគេសួរប្រស្នាហើយ ក៏ព្យាករប្រស្នានោះដោយប្រការដទៃវិញ ស្តេចនោះមិនមានអណ្តាតដូចត្រី បពិត្រព្រះរាជា បើព្រះអង្គទ្រង់ពោលពាក្យពិត សូមឲ្យព្រះអង្គទ្រង់ឋិតនៅដូចដើម បពិត្រព្រះបាទចេតិយៈ បើព្រះអង្គទ្រង់ពោលពាក្យកុហក សូមឲ្យព្រះអង្គចូលទៅកាន់ផែនដីក្រៃលែង ( ជាងនេះ គឺត្រឹមផ្ចិត ) ។

[ ៤៦៦ ] ស្តេចណា ជ្រាបកាលគេសួរប្រស្នាហើយ ក៏ព្យាករប្រស្នានោះដោយប្រការដទៃវិញ ក្នុងត្រកូលស្តេចនោះ កើតតែកូនស្រី កូនប្រុសមិនកើតទេ បពិត្រព្រះរាជា បើព្រះអង្គទ្រង់ពោលពាក្យពិត សូមឲ្យព្រះអង្គទ្រង់ឋិតនៅដូចដើម បពិត្រព្រះ

បាទចេតិយៈ បើព្រះអង្គទ្រង់ពោលពាក្យកុហក សូមឲ្យព្រះអង្គ ចូលទៅកាន់ផែនដីក្រៃលែង ( ជាងនេះ គឺត្រឹមដោះ ) ។

[ ៤៦៧ ] ស្តេចណា ជ្រាបកាលគេសួរប្រស្នាហើយ ក៏ព្យាករ ប្រស្នានោះដោយប្រការដទៃវិញ កូនប្រុសរបស់ស្តេចនោះ រមែង មិនមានឡើយ បើជាមាន រមែងគេចចេញទៅកាន់ទិសតូចទិស ធំបាត់អស់ បពិត្រព្រះរាជា បើព្រះអង្គទ្រង់ពោលពាក្យពិត សូមឲ្យព្រះអង្គទ្រង់ឋិតនៅដូចដើម បពិត្រព្រះបាទចេតិយៈ បើ ព្រះអង្គទ្រង់ពោលពាក្យកុហក សូមឲ្យព្រះអង្គចូលទៅកាន់ផែនដី ក្រៃលែង ( ជាងនេះទៅទៀត គឺលិចផុត ) ។

[ ៤៦៨ ] ( អភិសម្ពុទ្ធគាថា ) ស្តេចនោះ កាលពីដើមត្រាច់ ទៅក្នុងអាកាសបាន ( ដល់មកខាងក្រោយ ) ត្រូវឥសីផ្តាសា ហើយ ក៏ប្រែរជាមានសភាពសាបសូន្យដល់វេនរបស់ខ្លួន ចូល ទៅកាន់ផែនដី ព្រោះហេតុនោះ អ្នកប្រាជ្ញទាំងឡាយ ទើបមិន សរសើរនូវការលុះក្នុងអំណាចនៃសេចក្តីប្រាថ្នា បុគ្គលគួរជាអ្នក មានចិត្តមិនប្រទូស្ត ហើយពោលនូវវាចាដ៏ប្រកបដោយសច្ចៈ ។

**ចេតិយរាជជាតកទី ៦ ចប់**

# អដ្ឋកថា

## ចេតិយរាជជាតក

[ ៤៦១-៤៦៨ ] ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធទេវទត្ត ត្រូវផែនដីស្រូប ទើបត្រាស់រឿងនេះ មានពាក្យផ្ដើមថា **ធម្មោ ហវេ ហតោ ហន្តិ** ដូច្នេះជាដើម ។

សេចក្ដីសង្ខេបថា ថ្ងៃនោះ ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងធម្មសភាថា នែអាវុសោទាំងឡាយ ទេវទត្តធ្វើមុសាវាទ ត្រូវផែនដីស្រូប មានអវីចីជាទីទៅខាងមុខ ព្រះសាស្ដាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ កាលភិក្ខុទាំងឡាយទូលឲ្យទ្រង់ជ្រាបហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងឥឡូវនេះប៉ុណ្ណោះទេ ដែលទេវទត្តធ្វើមុសាវាទ ត្រូវផែនដីស្រូប សូម្បីក្នុងកាលមុនទេវទត្តក៏ធ្វើមុសាវាទ ហើយត្រូវផែនដីស្រូបដូចគ្នា ហើយទ្រង់នាំយករឿងក្នុងអតីតមកសាធក:តទៅ

ក្នុងអតីតកាល នាបឋមកប្ប ព្រះរាជាព្រះនាមមហាសម្មត: មានព្រះជន្មាយុមួយអសង្ខេយ្យ ។ ព្រះរាជឱរសរបស់ទ្រង់ព្រះនាមរោជ: ព្រះរាជ-ឱរសរបស់ព្រះបាទរោជ: ព្រះនាមវររោជ: ព្រះរាជឱរសរបស់ព្រះបាទវររោជ: ព្រះនាមកល្យាណ ព្រះរាជឱរសរបស់ព្រះបាទកល្យាណ ព្រះនាមវរកល្យាណ ព្រះរាជឱរសរបស់ព្រះបាទវរកល្យាណ ព្រះនាមឧបោសថ ព្រះរាជឱរសរបស់ព្រះបាទឧបោសថ ព្រះនាមវរឧបោសថ ព្រះរាជឱរសរបស់ព្រះបាទវរ-ឧបោសថ ព្រះនាមមន្ធាតុ ព្រះរាជឱរសរបស់ព្រះបាទមន្ធាតុ ព្រះនាមវរមន្ធាតុ

ព្រះរាជឱរសរបស់ព្រះបាទវរមន្ធាតុ ព្រះនាមវរៈ ព្រះរាជឱរសរបស់ព្រះបាទវរៈ ព្រះនាមឧបវរៈ តែបុគ្គលពួកខ្លះ ហៅថា ឧបរិចរៈ ។

ព្រះបាទឧបរិចរៈនោះ គ្រងរាជសម្បត្តិក្នុងសោត្ថិយនគរ ក្នុងចេតិយរដ្ឋ ទ្រង់ប្រកបដោយឫទ្ធិ ៤ យ៉ាង ទ្រង់តែងយាងទៅខាងលើ គឺទៅតាមអាកាស មានទេវបុត្រ ៤ អង្គ កាន់ព្រះខ័នតាមរក្សាក្នុងទិសទាំង ៤ មានក្លិនចន្ទន៍ក្រអូបផ្សាយចេញអំពីព្រះវរកាយ មានក្លិនឧប្បលផ្សាយចេញអំពីព្រះឱស្ឋ ទ្រង់មានព្រាហ្មណ៍ឈ្មោះកបិលជាបុរោហិត ។ កបិលព្រាហ្មណ៍ មានប្អូនប្រុសឈ្មោះកោរកលម្ពកៈ ជាពាលសហាយ ( សម្លាញ់លេងដី ) ធ្លាប់រៀនសិប្បៈក្នុងសម្នាក់អាចារ្យជាមួយគ្នានឹងព្រះរាជា ។ ក្នុងសម័យដែលព្រះរាជានៅជាព្រះរាជកុមារ ទ្រង់បានប្ដេជ្ញានឹងកោរកលម្ពកព្រាហ្មណ៍ថា កាលយើងបានគ្រងរាជសម្បត្តិហើយ នឹងឲ្យតំណែងបុរោហិតដល់អ្នក ។ កាលទ្រង់ឡើងគ្រងរាជសម្បត្តិហើយ ក៏មិនអាចដកកបិលព្រាហ្មណ៍ដែលជាបុរោហិតរបស់ព្រះជនក អំពីតំណែងបុរោហិតបាន កាលកបិលៈបុរោហិតចូលគាល់ ទ្រង់ក៏សម្ដែងនូវការកោតក្រែងដោយសេចក្ដីគោរពក្នុងបុរោហិតនោះ ។ ព្រាហ្មណ៍សង្កេតអាការនោះហើយ គិតថា ធម្មតាការគ្រងរាជសម្បត្តិ ត្រូវបរិហារជាមួយបុគ្គលដែលមានវ័យស្មើគ្នា ទើបល្អ អញនឹងទូលលាព្រះរាជាបួស ដូច្នេះហើយ ទើបក្រាបទូលថា បពិត្រព្រះសម្មតិទេព ទូលបង្គំជាមនុស្សចាស់ ឯផ្ទះមានកុមារម្នាក់ សូមទ្រង់តាំងកុមារនោះឲ្យជាបុរោហិត ទូលបង្គំនឹងបួស សូមព្រះរាជទានបរមរាជានុញ្ញាតតាំងបុត្រនោះក្នុងតំណែងបុរោហិត ហើយចូល

កាន់ព្រះរាជឧទ្យាន បួសជាឥសី ញុំាងឈាន និងអភិញ្ញាឲ្យកើតហើយ នៅក្នុងព្រះរាជឧទ្យាននោះឯង ដោយអាស្រ័យបុត្រជាអ្នកទំនុកបម្រុង ។ កោរកលម្ពកព្រាហ្មណ៍ ចងអាឃាតនឹងបងប្រុសថា បងប្រុសរបស់អញនេះ សូម្បីបួស ក៏មិនឲ្យឋានន្តរៈដល់អញ ថ្ងៃមួយ ខណៈដែលសន្ទនាជាមួយព្រះរាជា ព្រះរាជាត្រាស់សួរថា កោរកលម្ពកៈ អ្នកមិនបានតំណែងបុរោហិតទេឬ គាត់ក្រាបទូលថា បពិត្រព្រះសម្មតិទេព ទូលបង្គំមិនបានធ្វើ បងប្រុសទូលបង្គំធ្វើ ព្រះរាជាត្រាស់ថា បងប្រុសរបស់អ្នក បួសហើយមិនមែនឬ កោរកលម្ពកៈទូលថា បពិត្រព្រះអង្គ គេបួសហើយ តែគេបានឲ្យទ្រង់ប្រទានឋានន្តរដល់កូនរបស់គេ ព្រះរាជាត្រាស់ថា បើដូច្នោះ អ្នកឲ្យយើងធ្វើដូចម្តេច ។ កោរកលម្ពកៈទូលថា បពិត្រព្រះសម្មតិទេព ទូលបង្គំមិនអាចឲ្យទ្រង់ដកបងប្រុសចាកឋានន្តរដែលបន្តតាមបវេណី ហើយតែងតាំងទូលបង្គំជាបុរោហិតបានទេ ព្រះរាជាត្រាស់ថា បើដូច្នោះ យើងនឹងតែងតាំងអ្នកឲ្យជាធំ ហើយធ្វើបងប្រុសរបស់អ្នកឲ្យជាប្អូនប្រុស ។ កោរកលម្ពកៈទូលថា ទ្រង់ធ្វើបានដូចម្តេច ព្រះរាជាត្រាស់ថា យើងធ្វើបានដោយមុសាវាទ កោរកលម្ពកៈទូលថា បពិត្រព្រះសម្មតិទេព ទ្រង់មិនជ្រាបទេឬ តាំងពីកាលណាមក បងប្រុសរបស់ទូលបង្គំ មានវិជ្ជាប្រកបដោយធម៌ គួរអស្ចារ្យក្រៃលែង គេនឹងបោកបញ្ឆោតទ្រង់ដោយឧបាយដែលមិនពិត ដូចជាធ្វើទេវបុត្រ ៤ អង្គឲ្យបាត់ខ្លួន ធ្វើក្លិនក្រអូបដែលចេញពីព្រះកាយ និងព្រះឱស្ឋ ឲ្យជាក្លិនស្អុយ ធ្វើទ្រង់ឲ្យដូចជាធ្លាក់អំពីអាកាស ឈរលើផែនដី ទ្រង់ដូចជាត្រូវផែនដីស្រូប ក្នុងទីនោះ ទ្រង់មិន

អាចធ្វើវាចាឲ្យតាំងនៅបានទេ ។ ព្រះរាជាត្រាស់ថា អ្នកកុំយល់ដូច្នោះឡើយ យើងអាចធ្វើដូច្នោះបាន កោរកលម្អក:ទូលថា បពិត្រព្រះសម្មតិទេព ទ្រង់ធ្វើក្នុងកាលណា ព្រះរាជាត្រាស់ថា រាប់អំពីនេះទៅ ៧ ថ្ងៃទៀត ។ ព្រះរាជតម្រាស់នោះ បានខ្ចរខ្ចាយទៅពេញព្រះនគរ ។ មហាជនបានកើតបរិវិតក្កឡើងថា បានឮថា ព្រះរាជានឹងធ្វើមុសាវាទ ធ្វើក្មេងឲ្យជាធំ ធ្វើអ្នកធំ ដកឋានន្តរឲ្យដល់ក្មេង ឈ្មោះថា មុសាវាទដូចម្តេចហ្ន៎ មានពណ៌ខៀវ ឬពណ៌លឿង ពណ៌ណាមួយពិត ។ បានឮថា ក្នុងកាលនោះ ជាកាលដែលសត្វលោក ពោលពាក្យសច្ចៈ ទើបមនុស្សទាំងឡាយមិនដឹងថា មុសាវាទនេះដូចម្តេច ។

កូនបុរោហិតបានស្តាប់ពាក្យនោះហើយ ក៏ទៅប្រាប់បិតាថា បានឮថា ព្រះរាជានឹងធ្វើមុសាវាទ ធ្វើលោកឪពុកឲ្យជាក្មេង ហើយព្រះរាជទានឋានន្តររបស់ខ្ញុំឲ្យដល់ឪពុកមា ។ បុរោហិតពោលថា នែកូន ទោះបីព្រះរាជាទ្រង់ធ្វើមុសាវាទ ក៏មិនអាចព្រះរាជទានឋានន្តររបស់យើងដល់មារបស់ឯងបានដែរ ព្រះរាជានឹងធ្វើមុសាវាទក្នុងថ្ងៃណា កូនប្រាប់ថា ក្នុងថ្ងៃទី ៧ រាប់អំពីថ្ងៃនេះ ឪពុកពោលថា បើដូច្នោះ កាលដល់ថ្ងៃនោះ ឯងគប្បីប្រាប់ដល់អញ ។

លុះដល់ថ្ងៃទី ៧ មហាជនគិតថា នឹងមើលមុសាវាទ ទើបទៅប្រជុំគ្នាត្រង់លានព្រះរាជវាំង ចងគ្រែត្រួតលើគ្នា ឡើងឈរមើល កុមារក៏បានទៅប្រាប់ដល់បិតា ។ ព្រះរាជាទ្រង់តែងព្រះកាយហើយ ទ្រង់ប្រថាប់ក្នុងអាកាសខាងមុខលានព្រះរាជវាំង កណ្តាលមហាជន ។ តាបសបានហោះមកហើយ

លាតកម្រាលស្បែក អង្គុយត្រង់ព្រះភក្ត្រព្រះរាជា ពត់ភ្នែនក្នុងអាកាស ទូល ថា បពិត្រមហារាជ បានឮថា ទ្រង់ធ្វើមុសាវាទ ធ្វើក្មេងឲ្យជាមនុស្សធំ រួច ព្រះរាជទានឋានន្តរដល់គេ ពិតឬ ព្រះរាជាត្រាស់ថា ត្រូវហើយលោកម្ចាស់ យើងនឹងពោលយ៉ាងនេះ ។ លំដាប់នោះ តាបសកាលទឹងទូន្មានព្រះរាជា ក៏ ពោលថា បពិត្រមហារាជ ឈ្មោះថា មុសាវាទជាបាបធ្ងន់ កម្ចាត់នូវគុណ ធ្វើ ឲ្យកើតក្នុងអបាយទាំង ៤ ធម្មតាព្រះរាជា កាលទ្រង់ធ្វើមុសាវាទ រមែងឈ្មោះ ថា ទម្លាយធម៌ កាលទម្លាយធម៌ហើយ រមែងបានឈ្មោះថា ទម្លាយខ្លួននោះ ឯង ដូច្នេះហើយ ពោលគាថាទី ១ ថា

ធម៌ដែលបុគ្គលសម្លាប់ហើយ រមែងសម្លាប់វិញដោយពិត ធម៌ ដែលបុគ្គលមិនបានសម្លាប់ រមែងមិនសម្លាប់វិញតិចតួចឡើយ ។ ព្រោះហេតុនោះ ព្រះអង្គមិនត្រូវសម្លាប់ធម៌ ព្រះអង្គកុំឲ្យធម៌ ដែលព្រះអង្គសម្លាប់ហើយ ត្រឡប់សម្លាប់ព្រះអង្គវិញបាន ឡើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ធម្មោ** តាបសសំដៅដល់ជេដ្ឋាបចាយនធម៌ ( ធម៌ គឺការគោរពដល់ត្រកូលរៀមច្បង ) ។

តាបសកាលពោលទូន្មានព្រះរាជាឲ្យក្រៃលែងឡើងទៀត ទើបពោលថា មហាបពិត្រ បើទ្រង់ធ្វើមុសាវាទសោត ឫទ្ធិ ៤ យ៉ាងរបស់ទ្រង់នឹងអន្តរធាន ទៅ ដូច្នេះហើយ ពោលគាថាទី ២ ថា

កាលបើស្តេចពោលពាក្យកុហក ពួកទេវតា រមែងគេចចេញ

( លែងរក្សា ) ស្តេចណា ជ្រាបកាលគេសួរប្រស្នា ហើយ ព្យាករប្រស្នានោះដោយប្រការដទៃវិញ ព្រះឱស្ឋស្តេចនោះ រមែងមានក្លិនស្អុយផ្សាយចេញទៅ ទាំងស្តេចនោះទៀត រមែងឃ្លាតចាកកន្លែងរបស់ខ្លួន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អបក្កមន្តិ ទេវតា** សេចក្តីថា តាបសពោលពាក្យនេះ ដោយបំណងថា មហាបពិត្រ បើទ្រង់ពោលពាក្យកុហកសោត ទេវបុត្រ ៤ អង្គ នឹងលះបង់ទ្រង់គេចចេញទៅ ។

បទថា **បូតិកញ្ច មុខំ វាតិ** សេចក្តីថា តាបសពោលថា ក្លិនស្អុយទាំង ២ គឺក្លិនព្រះឱស្ឋផង ក្លិនព្រះវរកាយផងរបស់ទ្រង់ នឹងផ្សាយទៅ ។

បទថា **សកដ្ឋានា ច ធំសតិ** សេចក្តីថា តាបសកាលសម្តែងថា តែងធ្លាក់ចុះអំពីអាកាស ហើយត្រូវលិចចុះក្នុងផែនដី ទើបពោលយ៉ាងនេះ ។

ព្រះបាទឧបរិចរាជ បានស្តាប់ឱវាទហើយ មានព្រះហឫទ័យភ័យខ្លាចទតកោរកលម្ពកព្រាហ្មណ៍ ។ លំដាប់នោះ កោរកលម្ពកព្រាហ្មណ៍ក្រាបទូលថា បពិត្រមហារាជ សូមទ្រង់កុំខ្លាចឡើយ ទូលបង្គំបានក្រាបទូលរឿងនេះដល់ទ្រង់មុនហើយមិនមែនឬ ។ ព្រះរាជាកាលទ្រង់ស្តាប់ពាក្យកបិលបុរោហិតហើយក៏ដោយ តែដើម្បីរក្សាព្រះតម្រាស់របស់ព្រះអង្គ ទើបត្រាស់ថា នែលោកដ៏ចម្រើន លោកជាប្អូនប្រុស កោរកលម្ពកៈជាបងប្រុស ។ រំពេចនោះទេវបុត្រ ៤ អង្គពោលថា យើងមិនអាចរក្សាមនុស្សពោលកុហកដូចអ្នកបានទេ ហើយបោះព្រះខ័នក្បែរព្រះបាទព្រះរាជា អន្តរធានទៅព្រមគ្នានឹងវាចា

មុសាវាទ ។ ព្រះឱស្ឋក៏មានក្លិនស្អុយ ដូចស៊ុតស្អុយដែលបែក ព្រះវរកាយក៏មានក្លិនស្អុយ ដូចបង្គន់ដែលបើកចំហ ផ្សាយទៅ ។ ព្រះរាជាក៏ធ្លាក់អំពីអាកាស ប្រថាប់លើផែនដី ឫទ្ធិទាំង ៤ បានវិនាសទៅហើយ ។ គ្រានោះមហាបុរោហិតបានក្រាបទូលព្រះរាជាថា បពិត្រព្រះរាជាជាធំ ទ្រង់កុំខ្លាចឡើយ បើទ្រង់ត្រាស់សច្ចវាចាសោត ទូលបង្គំនឹងធ្វើវត្ថុទាំងពួង ឲ្យជាប្រក្រតីដល់ទ្រង់ ហើយពោលគាថាទី ៣ ថា

បពិត្រព្រះរាជា បើប្រសិនជាព្រះអង្គទ្រង់ពោលពាក្យពិត សូមឲ្យព្រះអង្គឋិតនៅដូចដើម បពិត្រព្រះបាទចេតិយៈ បើព្រះអង្គទ្រង់ពោលពាក្យកុហក សូមឲ្យព្រះអង្គ ឋិតនៅលើផែនដីដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ភូមិយំ តិដ្ឋ** សេចក្ដីថា បពិត្រព្រះសម្មតិទេព បើទ្រង់នៅតែមុសាវាទ ទ្រង់នឹងតាំងនៅបានត្រឹមតែលើផែនដី មិនអាចអណ្ដែតឡើងលើអាកាសបាន ។

ព្រះបាទឧបរិចររាជនោះ សូម្បីកបិលតាបសជាស់តឿនថា សូមមហាបពិត្រទតចុះ ត្រឹមតែមុសាវាទម្ដងប៉ុណ្ណោះ ឫទ្ធិ ៤ យ៉ាងរបស់ទ្រង់ក៏អន្តរធានទៅហើយ សូមទ្រង់កំណត់មើលចុះ ឥឡូវនេះ ទូលបង្គំអាចធ្វើឲ្យដូចប្រក្រតីវិញបាន ដូច្នេះហើយ ព្រះបាទឧបរិចររាជត្រាស់ថា កបិលតាបសពោលយ៉ាងនេះ បំណងបញ្ឆោតយើងហើយ ពោលមុសាវាទលើកទី ២ ត្រូវផែនដីស្រូបត្រឹម-កព្រះបាទ លំដាប់នោះ ព្រាហ្មណ៍បានក្រាបទូលព្រះរាជាទៀតថា

សូមទ្រង់កំណត់មើលចុះ ឥឡូវនេះ ទូលបង្គំអាចធ្វើឲ្យត្រឡប់ជាប្រក្រតីបាន ដូច្នេះហើយ ពោលគាថាទី ៤ ថា

ស្ដេចណា ជ្រាបកាលគេសួរប្រស្នាហើយ ក៏ព្យាករប្រស្នានោះ ដោយប្រការដទៃវិញ ភ្លៀងរមែងធ្លាក់ចុះក្នុងកាលមិនគួរ ( ក្នុងដែន ) របស់ស្ដេចនោះ ភ្លៀងរមែងមិនធ្លាក់ចុះក្នុងកាលគួរ ( ក្នុងដែនរបស់ស្ដេចនោះ ) ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **តស្ស** សេចក្ដីថា ព្រះរាជាអង្គណាទ្រង់ជ្រាប ក្លែងពោលកុហក ព្យាករបញ្ហាដែលគេសួរហើយដទៃវិញ ក្នុងដែនរបស់ព្រះរាជាអង្គនោះ ភ្លៀងរមែងមិនធ្លាក់ក្នុងកាលដែលគួរធ្លាក់ តែធ្លាក់ក្នុងកាលដែលមិនគួរធ្លាក់ ។

លំដាប់នោះ កបិលតាបសជាស់តឿនបន្តថា មហាបពិត្រ ដោយផលនៃមុសាវាទ ទ្រង់ត្រូវផែនដីស្រូបត្រឹមព្រះជង្ឃហើយ សូមទ្រង់កំណត់មើលចុះ ហើយពោលគាថាទី ៥ ថា

បពិត្រព្រះរាជា បើព្រះអង្គទ្រង់ពោលនូវពាក្យពិត សូមឲ្យព្រះអង្គទ្រង់ឋិតនៅដូចដើម បពិត្រព្រះបាទចេតិយៈ បើព្រះអង្គទ្រង់ពោលពាក្យកុហក សូមឲ្យព្រះអង្គចូលទៅកាន់ផែនដី ( ត្រឹមព្រះជានុ ) ដូច្នេះ ។

ព្រះបាទឧបរិចររាជ ទ្រង់បានធ្វើមុសាវាទជាគម្រប់ ៣ ដងថា អ្នកដ៏ចម្រើន អ្នកជាប្អូនប្រុស កោរកលម្ពកៈជាបងប្រុស ដូច្នេះហើយ ត្រូវផែនដី

ស្រុបត្រឹមជង្គង់ ។ លំដាប់នោះ កបិលតាបសទូលព្រះរាជាទៀតថា សូមទ្រង់កំណត់មើលចុះ ហើយពោលគាថា ២ ថា

បពិត្រព្រះអង្គជាធំក្នុងទិស ស្តេចណា ជ្រាបកាលគេសួរប្រស្នាហើយ ក៏ព្យាករប្រស្នានោះដោយប្រការដទៃវិញ អណ្តាតរបស់ស្តេចនោះ រមែងបែកជាពីរ ដូចជាអណ្តាតនៃពស់ បពិត្រព្រះរាជា បើព្រះអង្គទ្រង់ពោលពាក្យពិត សូមឲ្យព្រះអង្គឋិតនៅដូចដើម បពិត្រព្រះបាទចេតិយៈ បើព្រះអង្គទ្រង់ពោលពាក្យកុហក សូមឲ្យព្រះអង្គចូលកាន់ផែនដីក្រៃលែង ( ជាងនេះ គឺត្រឹមចង្កេះ ) ដូច្នេះ ។

តាបសកាលពោល ២ គាថានេះហើយ ទូលថា មកទល់ឥឡូវនេះទ្រង់មិនអាចត្រឡប់ធ្វើឲ្យជាប្រក្រតីបាន ។ ព្រះរាជាមិនកាន់យកពាក្យសម្តីរបស់តាបសនោះ នៅតែធ្វើមុសាវាទលើកទី ៤ ថា នៃអ្នកដ៏ចម្រើន អ្នកជាប្អូនប្រុស កោរកលម្ពកៈជាបងប្រុស ដូច្នេះហើយ ត្រូវផែនដីស្រុបត្រឹមផ្ចិត ។ លំដាប់នោះ កបិលព្រាហ្មណ៍បានទូលព្រះរាជាថា សូមទ្រង់កំណត់មើលចុះ ហើយពោលគាថា ២ ថា

បពិត្រព្រះអង្គជាធំក្នុងទិស ស្តេចណា ជ្រាបកាលគេសួរប្រស្នាហើយ ក៏ព្យាករប្រស្នានោះដោយប្រការដទៃវិញ ស្តេចនោះមិនមានអណ្តាតដូចត្រី បពិត្រព្រះរាជា បើព្រះអង្គទ្រង់ពោលពាក្យពិត សូមឲ្យព្រះអង្គទ្រង់ឋិតនៅដូចដើម បពិត្រព្រះបាទ

ចេតិយៈ បើព្រះអង្គទ្រង់ពោលពាក្យកុហក សូមឲ្យព្រះអង្គ
ចូលទៅកាន់ផែនដីក្រៃលែង ( ជាងនេះ គឺត្រឹមផ្ចិត ) ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **មច្ឆស្សេវ** សេចក្ដីថា ព្រះជិវ្ហាដែលធ្វើឲ្យចរចាបាន របស់ព្រះរាជាដែលពោលមុសាវាទ មិនមានក្នុងគ្រប់ៗ ជាតិដូចត្រី គឺជាមនុស្សគរ ។

ព្រះបាទឧបរិចរាជ បានធ្វើមុសាវាទលើកទី ៥ ថា នៃអ្នកដ៏ចម្រើន អ្នកជាប្អូនប្រុស កោរកលម្ពកៈជាបងប្រុស ដូច្នេះហើយ ត្រូវផែនដីស្រូបត្រឹមផ្ចិត ។ លំដាប់នោះ កបិលតាបសបានទូលព្រះរាជាទៀតថា សូមទ្រង់កំណត់មើលចុះ ហើយពោល ២ គាថាទៀតថា

ស្ដេចណា ជ្រាបកាលគេសួរប្រស្នាហើយ ក៏ព្យាករប្រស្នានោះ
ដោយប្រការដទៃវិញ ក្នុងត្រកូលស្ដេចនោះ កើតតែកូនស្រី
កូនប្រុសមិនកើតទេ បពិត្រព្រះរាជា បើព្រះអង្គទ្រង់ពោល
ពាក្យពិត សូមឲ្យព្រះអង្គទ្រង់ឋិតនៅដូចដើម បពិត្រព្រះបាទ
ចេតិយៈ បើព្រះអង្គទ្រង់ពោលពាក្យកុហក សូមឲ្យព្រះអង្គចូល
ទៅកាន់ផែនដីក្រៃលែង ( ជាងនេះ គឺត្រឹមដោះ ) ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ធិយោវ** សេចក្ដីថា ព្រះរាជាមានប្រក្រតីត្រាស់មុសាវាទនោះ ទោះកើតក្នុងកពណា មានតែកូនស្រីប៉ុណ្ណោះ មិនមានកូនប្រុសឡើយ ។

ព្រះរាជាទ្រង់មិនជឿពាក្យ ត្រាស់មុសាវាទដូច្នោះទៀត លើកទី ៦ ត្រូវ

ផែនដីស្រូបត្រឹមដោះ កបិលតាបសទូលព្រះរាជាទៀតថា សូមទ្រង់កំណត់មើលចុះមហាបពិត្រ ហើយពោល ២ គាថាថា

ស្ដេចណា ជ្រាបកាលគេសួរប្រស្នាហើយ ក៏ព្យាករប្រស្នានោះ
ដោយប្រការដទៃវិញ កូនប្រុសរបស់ស្ដេចនោះ រមែងមិនមាន
ឡើយ បើជាមាន រមែងគេចចេញទៅកាន់ទិសតូចទិសធំបាត់
អស់ បពិត្រព្រះរាជា បើព្រះអង្គទ្រង់ពោលពាក្យពិត សូមឲ្យ
ព្រះអង្គទ្រង់ឋិតនៅដូចដើម បពិត្រព្រះបាទចេតិយៈ បើព្រះអង្គ
ទ្រង់ពោលពាក្យកុហក សូមឲ្យព្រះអង្គចូលទៅកាន់ផែនដី
ក្រៃលែង ( ជាងនេះទៅទៀត គឺលិចផុត ) ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បក្កមន្តិ** សេចក្ដីថា បើព្រះរាជាមានប្រក្រតីត្រាស់កុហក មានព្រះរាជឱរសសោត ព្រះរាជឱរសទាំងនោះ ក៏មិនធ្វើឧបការៈដល់ព្រះជនកព្រះជននី នាំគ្នាចៀសចេញទៅកាន់ទិសតូចទិសធំ ។

ព្រះបាទឧបរិចររាជ មិនបានជឿពាក្យរបស់តាបស ព្រោះទោស គឺសេពគប់មិត្រអាក្រក់ ទ្រង់បានធ្វើមុសាវាទបែបនោះទៀតជាគម្រប់ ៣ ដង ។ រំពេចនោះ ផែនដីបានបែកជា ២ មានអណ្ដាតភ្លើងអំពីអវីចីបាញ់ឡើង ចេះព្រះរាជា ។ លុះព្រះសាស្ដាបានត្រាស់ដឹងហើយ ទ្រង់ត្រាស់អភិសម្ពុទ្ធគាថា ២ ថា

ស្ដេចនោះ កាលពីដើម ត្រាច់ទៅក្នុងអាកាសបាន ( ដល់មក
ខាងក្រោយ ) ត្រូវឥសីផ្ដាសាហើយ ក៏បែរជាមានសភាពសាប

សូន្យ ដល់វេនរបស់ខ្លួន ចូលទៅកាន់ផែនដី ព្រោះហេតុនោះ អ្នកប្រាជ្ញទាំងឡាយ ទើបមិនសរសើរនូវការលុះក្នុងអំណាចនៃសេចក្ដីប្រាថ្នា បុគ្គលគួរជាអ្នកមានចិត្តមិនប្រទូស្ត ហើយពោលនូវវាចាដ៏ប្រកបដោយសច្ចៈ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ស រាជា** សេចក្ដីថា ម្នាលភិក្ខុទាំងឡាយ ព្រះបាទចេតិយរាជនោះ ក្នុងកាលមុនធ្លាប់សញ្ចរទៅបានក្នុងអាកាស ក្រោយមក ត្រូវឥសីផ្ដាសាហើយ ក៏សាបសូន្យចាកអំណាច ដល់កំណត់កាល គឺកាលវិប្បយោគរបស់ខ្លួន ក៏ត្រូវផែនដីស្រូប ។ បទថា **តស្មា** សេចក្ដីថា ព្រោះព្រះបាទចេតិយរាជ លុះក្នុងអំណាចអគតិ មានឆន្ទាគតិជាដើម ទើបត្រូវទៅអវិចី ព្រោះហេតុនោះ ។ បទថា **អទុដ្ឋចិត្តោ** សេចក្ដីថា មិនគួរត្រូវឆន្ទាគតិជាដើមប្រទូស្ត គប្បីពោលតែពាក្យសច្ចៈប៉ុណ្ណោះ ។

មហាជននាំគ្នាភិតភ័យ ពោលថា ព្រះបាទចេតិយរាជជេរឥសី ពោលមុសាវាទ ធ្លាក់អវិចីនរកហើយ ។ ព្រះរាជឱរស ៥ អង្គរបស់ព្រះបាទចេតិយរាជ នាំគ្នាក្រាបចុះត្រង់បាតជើងតាបសពោលថា សូមលោកម្ចាស់ជាទីពឹងរបស់ពួកយើងចុះ តាបសទូលថា ព្រះជនករបស់ទ្រង់ ញុំាងធម៌ឲ្យវិនាស ពោលនូវមុសាវាទ ជេរនូវឥសី ទើបធ្លាក់នរក ឈ្មោះថា ធម៌ កាលបុគ្គលទម្លាយហើយ រមែងទម្លាយបុគ្គលនោះ ពួកទ្រង់មិនអាចនាំគ្នានៅក្នុងទីនេះបាន ដូច្នេះហើយ ហៅព្រះរាជឱរសច្បងមកទូលថា សូមទ្រង់ចេញតាមទ្វារទិសខាងកើត យាងទៅឲ្យត្រង់ កាលទ្រង់យាងទៅ នឹងជួបហត្ថីរ័តន៍សសុទ្ធ

៧ ហត្ថ សូមទ្រង់សាងព្រះនគរក្នុងទីនោះ តាមសញ្ញានោះ ព្រះនគរនោះនឹងមានឈ្មោះថា ហត្ថិបុរៈ ។ ហៅព្រះរាជឱរសទី ២ មក ទូលថា សូមទ្រង់ចេញតាមទ្វារទិសទក្សិណ ទ្រង់យាងទៅ ឲ្យត្រង់នោះឯង កាលទ្រង់ជួបអស្សរ័តន៍ពណ៌សសុទ្ធ សូមទ្រង់សាងព្រះនគរក្នុងទីនោះ តាមសញ្ញានោះព្រះនគរនោះនឹងមានឈ្មោះថា អស្សបុរៈ ។ ហៅព្រះរាជឱរសទី ៣ មក ទូលថា សូមទ្រង់ចេញតាមទ្វារទិសខាងលិច យាងទៅត្រង់នោះឯង កាលទ្រង់ជួបកេសរសីហៈ សូមទ្រង់សាងព្រះនគរក្នុងទីនោះ តាមសញ្ញានោះ ព្រះនគរនោះ នឹងមានឈ្មោះថា សីហបុរៈ ។ ហើយហៅព្រះរាជឱរសអង្គទី ៤ មកពោលថា សូមទ្រង់យាងចេញតាមទ្វារទិសឧត្តរ យាងទៅត្រង់នោះឯង កាលទ្រង់ជួបចក្កបញ្ជរ ដែលធ្វើដោយកែវសុទ្ធ សូមទ្រង់សាងព្រះនគរក្នុងទីនោះ តាមសញ្ញានោះ ព្រះនគរនោះនឹងមានឈ្មោះថា ឧត្តរបញ្ជរ ( ឧត្តរ-បញ្ចាល ) ។ ហើយហៅព្រះរាជឱរសអង្គទី ៥ មកទូលថា ទ្រង់មិនអាចនៅក្នុងទីនេះបាន សូមទ្រង់សាងព្រះស្តូបធំ ក្នុងព្រះនគរនេះ ហើយយាងតម្រង់ទៅទិសពាយព្យ កាលទ្រង់ជួបភ្នំ ២ ដែលមានកំពូលឱនរកគ្នា លាន់សំឡេងថា ទទ្ទៈ សូមទ្រង់សាងព្រះនគរក្នុងទីនោះ តាមសញ្ញានោះ ព្រះនគរនោះនឹងមានឈ្មោះថា ទទ្ទបុរៈ ។ ព្រះរាជឱរសទាំង ៥ អង្គ បានសាងនគរក្នុងទីនោះៗ តាមសញ្ញានោះ ។

ព្រះបរមសាស្ដា កាលទ្រង់នាំព្រះធម្មទេសនានេះមកសម្ដែងហើយ ក៏ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលទេវទត្តធ្វើមុសាវាទ ហើយត្រូវផែនដីស្រូប សូម្បីក្នុងកាលមុន ទេវទត្តធ្វើមុសាវាទ ហើយត្រូវផែនដីស្រូបដូចគ្នា ដូច្នេះហើយ ទ្រង់ប្រជុំជាតកថា ព្រះបាទចេតិយរាជក្នុងកាលនោះ បានមកជាទេវទត្ត ក្នុងកាលឥឡូវនេះ ចំណែកកបិលព្រាហ្មណ៍ ក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា ចេតិយរាជជាតក ចប់

# សុត្តន្តបិដក

## ឥន្ទ្រិយជាតក

[ ៤៦៩ ] ( គ្រូឈ្មោះសរភង្គពោលថា ) ម្នាលនារទៈ បុគ្គលណាលុះអំណាចនៃឥន្ទ្រិយទាំងឡាយព្រោះកាម បុគ្គលនោះលះបង់នូវលោកទាំងពីរ ( ហើយកើតក្នុងនរក ) សូម្បីរស់នៅរមែងរីងស្ងួត ។

[ ៤៧០ ] ទុក្ខជាលំដាប់នៃសុខ សុខជាលំដាប់នៃទុក្ខ សូម្បីអ្នកដល់នូវទុក្ខ ព្រោះសាបសូន្យចាកឈានសុខក៏ដោយ អ្នកចូរប្រាថ្នានូវសុខដ៏ប្រសើរវិញចុះ ។

[ ៤៧១ ] បុគ្គលណាជាអ្នកអត់ទ្រាំនូវសេចក្ដីលំបាក ក្នុងវេលាមានលំបាក មិនប្រព្រឹត្តកន្លងនូវសេចក្ដីលំបាក បុគ្គលនោះជាអ្នកប្រាជ្ញ រមែងបាននូវសេចក្ដីសុខជាទីបំផុតនៃសេចក្ដីលំបាកដែលកើតអំពីសេចក្ដីព្យាយាម ។

[ ៤៧២ ] ខ្លួនអ្នកមិនគួរឲ្យឃ្លាតចាកធម៌ ព្រោះការប្រាថ្នាកាម ព្រោះការវិនាស ព្រោះហេតុនៃប្រយោជន៍ ទាំងព្រោះលះបង់ឈានដែលខ្លួនធ្វើបានហើយទេ ។

[ ៤៧៣ ] ( កាលទេវិលតាបសពោលថា ) សេចក្ដីឈ្លាសវៃ ១ ការបែងចែកភោជន ១ មិនរីករាយក្នុងការបាននូវប្រយោជន៍ ១ មិនលំបាកចិត្តក្នុងកាលវិនាសចាកប្រយោជន៍ ១ ( នេះ ) ជាការប្រពៃរបស់គ្រហស្ថ ។

[ ៤៧៤ ] ( អភិសម្ពុទ្ធគាថា ) អសិតទេវិលតាបស បាន ពោលនូវភាពនៃបុគ្គលជាបណ្ឌិតនុ៎ះ ដោយហេតុមានប្រមាណ ប៉ុណ្ណោះថា មិនមានបុគ្គលណាមួយដែលលាមកជាងបុគ្គល ជាអ្នកលុះអំណាចនៃឥន្ទ្រិយទាំងឡាយនេះឡើយ ។

[ ៤៧៥ ] ( មនុស្សប្រេតនិយាយថា ) បពិត្រព្រះបាទសិវិ បុគ្គលប្រាកដស្មើនឹងខ្ញុំ រមែងដល់នូវសេចក្តីវិនាស ( ដោយអំពើរបស់ខ្លួន ) ដូចបុគ្គលដល់នូវសេចក្តីវិនាសក្នុងកណ្តាប់ដៃនៃសត្រូវ ខ្លួនខ្ញុំព្រោះតែញ៉ាំងយសទាំងនុ៎ះ គឺកសិកម្ម វិជ្ជា ភាពជាអ្នកឈ្លាសវៃ វិវាហមង្គល សីល និងភាពនៃចិត្តទន់ឲ្យសាបសូន្យ ទើបមកកើត ( ជាមនុស្សប្រេត ) ដោយអំពើជារបស់ខ្លួន ។

[ ៤៧៦ ] ខ្លួនខ្ញុំនោះ ជាបុគ្គលមិនមានផៅពង្ស មិនមានទីពំនាក់តទៅ ដូចគេសាបសូន្យចាកទ្រព្យរាប់ពាន់ ខ្លួនខ្ញុំជាអ្នកប្រាសចាកអរិយធម៌ដូចប្រេត ។

[ ៤៧៧ ] ខ្លួនខ្ញុំញ៉ាំងពួកសត្វដែលជាអ្នកប្រាថ្នានូវសុខ ឲ្យដល់នូវទុក្ខ ទើបដល់នូវគន្លងនៃទុក្ខនេះ ខ្លួនខ្ញុំនោះមិនបាននូវសេចក្តីសុខឡើយ បិតនៅ ( ទាំងក្តៅក្រហាយ ) ដូចគេពោយដោយរងើកភ្លើង ។

**ឥន្ទ្រិយជាតកទី ៧ ចប់**

# អដ្ឋកថា

## ឥន្ទ្រិយជាតក

[ ៤៦៩-៤៧៧ ] ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុត្រូវភរិយាចាស់លួងលោម ទើបត្រាស់រឿងនេះ មានពាក្យផ្ដើមថា **យោ ឥន្ទ្រិយានំ** ដូច្នេះជាដើម ។

បានឮថា ក្នុងនគរសាវត្ថី មានកុលបុត្រម្នាក់ស្ដាប់ធម្មទេសនារបស់ព្រះសាស្ដាហើយ គិតថា អ្នកនៅគ្រប់គ្រងផ្ទះ មិនអាចប្រព្រឹត្តព្រហ្មចរិយៈឲ្យបរិសុទ្ធបានដោយចំណែកមួយ អញនឹងបួសក្នុងសាសនាដែលនាំសត្វចេញចាកទុក្ខ ហើយនឹងធ្វើទីបំផុតនៃទុក្ខ ដូច្នេះហើយ បានប្រគល់សម្បត្តិក្នុងផ្ទះដល់បុត្រភរិយា ហើយទូលសូមបព្វជ្ជានឹងព្រះសាស្ដា ។ ព្រះបរមសាស្ដាក៏ឲ្យនូវបព្វជ្ជាដល់កុលបុត្រនោះ កាលបព្វជ្ជាហើយ ក៏បំពេញភិក្ខុ ត្រាច់ទៅបិណ្ឌបាតជាមួយអាចារ្យ និងឧបជ្ឈាយ៍ ។ អាសនៈក្នុងផ្ទះនៃត្រកូលក្ដី ក្នុងរោងឆាន់ក្ដី មិនដល់លំដាប់ភិក្ខុនោះ ព្រោះខ្លួនទើបបួសថ្មី និងព្រោះមានភិក្ខុច្រើន ។ តាំង ឬបន្ទះក្ដារ ខាងចុងរបស់ព្រះសង្ឃនវកៈ រមែងដល់លោក ។ សូម្បីអាហារដែលគប្បីបាន ក៏សុទ្ធតែលាយម្សៅ និងជាទឹកបាយដែលជាប់តាម វែកខ្លះ ជាបបរខ្លះ របស់ទំពាដែលផ្អូម ដែលក្រៀមខ្លះ ជាបាយក្ដាំងបាយក្រៀមខ្លះ មិនល្មមនឹងឆ្អែត ។ ភិក្ខុនោះ កាន់យកអាហារដែលខ្លួនបានហើយ ទៅកាន់សម្នាក់របស់ភរិយាចាស់ ។ ភរិយាចាស់ថ្វាយបង្គំហើយទទួលបាត្ររបស់ភិក្ខុនោះ ចាក់កត្តាហារក្នុងបាត្រចោល ហើយប្រគេនបបរភត្ត សូបព្យញ្ជនៈ ដែលខ្លួនធ្វើល្អហើយ ។ ភិក្ខុនោះ ជាប់ក្នុងរសអាហារ

មិនអាចលះបង់កិរិយាចាស់បាន ។ កិរិយាចាស់គិតថា អញនឹងសាកល្បងភិក្ខុនេះមើលថា តើជាប់ក្នុងរសអាហារដែរឬទេ ។ ថ្ងៃមួយ នាងបានឲ្យមនុស្សអ្នកជនបទដួតទឹក ជុសដោយលម្អិត អង្គុយក្នុងផ្ទះ ឲ្យអ្នកបម្រើពីរបីនាក់ដទៃទៀត នាំយកទឹក និងបាយមកឲ្យមនុស្សជនបទនោះបន្តិចបន្តួច ហើយក៏នាំគ្នាអង្គុយទំពាស៊ី ។ នាងឲ្យអ្នកបម្រើចាប់គោ ទឹមរទេះមួយគ្រឿងត្រង់ទ្វារផ្ទះ ខ្លួនឯងក៏គេចទៅអង្គុយចៀននំ ត្រង់បន្ទប់ក្រោយផ្ទះ ។ លំដាប់នោះ ភិក្ខុនោះមកឈរត្រង់ទ្វារ ។ បុរសចាស់ម្នាក់ឃើញភិក្ខុនោះ ពោលថា អើនាង ព្រះថេរៈមួយអង្គមកឈរត្រង់ទ្វារ នាងឆ្លើយថា សូមជួយនិមន្តលោក ឲ្យលោកនិមន្តទៅខាងមុខចុះ បុរសចំណាស់ពោលច្រើនថា សូមនិមន្តលោកម្ចាស់ទៅប្រោសសត្វខាងមុខចុះ ក៏ឃើញលោកនៅតែឈរស្ងៀម ទើបប្រាប់ដល់កិរិយាចាស់ថា អើនាង ព្រះថេរៈមិនទៅទេ ។ កិរិយាចាស់ធ្វើជាទៅបើកវាំងននមើល ពោលថា ឱ ! ព្រះថេរៈជាឪពុករបស់ក្មេង ទើបចេញទៅថ្វាយបង្គំទទួលបាត្រ និមន្តឲ្យចូលទៅក្នុងផ្ទះ និមន្តឲ្យឆាន់ កាលឆាន់ស្រេចហើយនាងពោលថា សូមលោកម្ចាស់ បរិនិព្វានក្នុងទីនេះឯង ខ្ញុំមិនបានកាន់យកត្រកូលដទៃឡើយ អស់កាលមានប្រមាណប៉ុណ្ណោះ ក្នុងផ្ទះដែលប្រាសចាកប្តីនឹងតម្កល់ការគ្រប់គ្រងផ្ទះដោយល្អមិនបាន ខ្ញុំនឹងកាន់យកត្រកូលដទៃ ទៅនៅក្នុងជនបទឆ្ងាយ សូមលោកម្ចាស់កុំប្រមាទ បើខ្ញុំមានទោសសោត សូមអត់ទោសនោះផងចុះ ។ ហទយៈរបស់ភិក្ខុនោះហាក់ដូចពុះ ២ ចម្រៀក ។ គ្រានោះ ភិក្ខុនោះ បានពោលនឹងកិរិយាចាស់ដូច្នេះថា យើងមិនអាចលះបង់នាង

បានទេ នាងកុំទៅឡើយ យើងនឹងសឹក ចូរនាងបញ្ជូនសំពត់សាដកទៅឲ្យយើង ក្នុងទីឈ្មោះនោះ យើងប្រគល់បាត្រ ចីវរហើយ នឹងមក ភរិយានោះទទួលពាក្យសាធុ ។ ភិក្ខុនោះ ទៅវិហារហើយ ឲ្យអាចារ្យ និងឧបជ្ឈាយ៍ទទួលបាត្រ និងចីវរ ។ កាលអាចារ្យ និងឧបជ្ឈាយ៍សួរថា នែអាវុសោ នេះហេតុអ្វី ទើបលោកធ្វើយ៉ាងនេះ ក៏ឆ្លើយថា ខ្ញុំមិនអាចបោះបង់ភរិយាចាស់បានទេ ខ្ញុំនឹងសឹក ។ លំដាប់នោះ ទើបអាចារ្យ និងឧបជ្ឈាយ៍ នាំភិក្ខុដែលមិនប្រាថ្នាទៅកាន់សម្នាក់ព្រះមុនី កាលទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អ្នកនាំភិក្ខុដែលមិនប្រាថ្នានេះមកធ្វើអ្វី ទើបក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុនេះអផ្សុក ។ លំដាប់នោះ ព្រះសាស្តាត្រាស់សួរភិក្ខុនោះថា អើ ភិក្ខុ បានឮថា អ្នកអផ្សុកពិតឬ កាលភិក្ខុនោះក្រាបទូលថា ករុណាព្រះអង្គ ពិតមែន ទើបត្រាស់សួរថា អ្នកណាធ្វើឲ្យអ្នកអផ្សុក ភិក្ខុនោះក្រាបទូលថា ភរិយាចាស់របស់ខ្ញុំព្រះអង្គ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលស្រីនេះ ធ្វើសេចក្តីវិនាសដល់អ្នក សូម្បីក្នុងកាលមុន អ្នកក៏សាបសូន្យចាលឈាន ដល់នូវទុក្ខធំ ព្រោះអាស្រ័យស្រីនេះ តែបានអាស្រ័យតថាគត ទើបផុតចាកទុក្ខ បាននូវឈាន ដែលវិនាសហើយមកវិញ ដូច្នេះហើយ ទើបទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វអាស្រ័យបុរោហិតរបស់ព្រះបាទព្រហ្មទត្តនោះ កើតក្នុងគភ៌របស់ព្រាហ្មណីដែលជាភរិយារបស់បុរោហិតនោះ ។ ក្នុងថ្ងៃដែលព្រះពោធិសត្វកើត

សព្វាវុធទាំងអស់ក្នុងព្រះនគរ ភ្លឺរន្ទាលប្រាលផ្លោ ព្រោះហេតុនោះ ទើបញាតិទាំងឡាយ ដាក់ឈ្មោះព្រះពោធិសត្វថា ជោតិបាល ។ ជោតិបាលកុមារនោះ កាលចម្រើនវ័យហើយ រៀនសិល្បសាស្ត្រគ្រប់យ៉ាង ក្នុងនគរតក្កសិលា រួចត្រឡប់មកសម្តែងសិល្បសាស្ត្រដល់ព្រះរាជា តមក បានឥស្សរិយយស មិនឲ្យអ្នកណាដឹង គេចចេញតាមទ្វារដែលបើកទៅកាន់ព្រៃ បួសជាឥសីក្នុងអាស្រម នាព្រៃខ្វិត ដែលសក្កទេវរាជនិម្មិតថ្វាយ ធ្វើឈាន និងអភិញ្ញាឲ្យកើតឡើងហើយ មានឥសីច្រើនរយចោមរោមជាបរិវារ ជោតិបាលឥសីនៅអាស្រ័យត្រង់អាស្រមនោះ អាស្រមនោះបានជាមហាសមាគម ព្រះពោធិសត្វនោះ មានឈ្មោះថា សរភង្គតាបស មានសិស្សដែលជាប្រធាន ៧ រូប មួយរូប ឈ្មោះសាលិស្សរឥសី បានចេញអំពីព្រៃខ្វិត ទៅកាន់ឆ្នេរស្ទឹងសាតោទកាក្នុងសុរដ្ឋជនបទ មានឥសីច្រើនពាន់ចោមរោមជាបរិវារ ។ ឥសីទី ២ ឈ្មោះមេណ្ឌិស្សរៈ ទៅអាស្រ័យត្រង់កលម្ពមូលកនិគម ក្នុងដែនរបស់ព្រះបាទបជោតករាជ មានឥសីច្រើនពាន់ជាបរិវារ ។ ឥសីទី ៣ ឈ្មោះបព្វតៈ ទៅកាន់អដវីជនបទ មានឥសីច្រើនពាន់ជាបរិវារ ឥសីទី ៤ ឈ្មោះកាឡទេវិលទៅអាស្រ័យត្រង់ឯកឃ្លនសិលា ( ទួលថ្មដា ) មួយកន្លែង ក្នុងទក្ខិណាបថក្នុងដែនអវន្តី មានឥសីច្រើនពាន់ជាបរិវារ ។ តាបសទី ៥ ឈ្មោះកិសវច្ឆៈទៅនៅអាស្រ័យនគរកុម្ភវតីរបស់ស្តេចទណ្ឌកី មួយអន្លើឯង នៅក្នុងព្រះរាជឧទ្យាន ឥសីទី ៦ ឈ្មោះអនុបិយៈ[១] ជាឧបដ្ឋាកព្រះពោធិសត្វ ឥសីទី ៧

១- ក្នុងទីខ្លះ ជាអនុសិស្ស ។

ឈ្មោះនារទៈ ជាប្អូនប្រុសរបស់កាឡទេវិលតាបស ទៅកាន់គុហាពួនសម្ងំ ក្នុងរវាងភ្នំអញ្ជនគីរី ក្នុងព្រៃមជ្ឈិមប្រទេស តែមួយអង្គឯង ។

ក្នុងទីក្បែរអញ្ជនគីរី មាននិគមមួយ មានមនុស្សរស់នៅច្រើន ។ ក្នុងចន្លោះភ្នំអញ្ជនគីរី និងនិគមនោះ មានស្ទឹងធំ ពួកមនុស្សនាំគ្នាទៅប្រជុំត្រង់ស្ទឹងនោះច្រើន ។ ពួកនាងវណ្ណទាសីស្រីស្អាតទាំងឡាយ កាលចែចង់បុរស ក៏នាំគ្នាទៅអង្គុយត្រង់ឆ្នេរស្ទឹង ។ នារទតាបសឃើញស្ត្រីម្នាក់ ក្នុងបណ្តាស្ត្រីទាំងនោះ មានចិត្តប្រតិព័ទ្ធ ឈានក៏សាបសូន្យ ស្គាំងស្គម ធ្លាក់ក្នុងអំណាចកិលេស ដេកអត់អាហារ ៧ ថ្ងៃ ។ លំដាប់នោះ កាឡទេវិលតាបសជាបងប្រុសរបស់នារទតាបសប្រាថ្នានឹងមើល ក៏ដឹងហេតុនោះ ទើបហោះមកហើយចូលទៅកាន់ទីពួនសម្ងំ នារទតាបសឃើញកាឡទេវិល សួរថា លោកម្ចាស់មកធ្វើអ្វី កាលទេវិលឆ្លើយថា ប្អូនមិនសប្បាយ យើងមកដើម្បីរក្សាឯង ។ នារទតាបសពោលសង្កត់សង្កិនកាឡទេវិល ដោយមុសាវាទថា លោកម្ចាស់និយាយមិនដឹងរឿង ពោលពាក្យឡេះឡោះទទេៗ ។ កាឡទេវិលតាបសគិតថា អញមិនគួរលះបង់ ទើបទៅហៅតាបស ៣ អង្គមក គឺសាលិស្សរតាបស ១ មេណ្ឌិស្សរតាបស ១ បព្វតតាបស ១ ។ នារទតាបសក៏ពោលសង្កត់សង្កិនតាបសទាំងនោះដោយមុសាវាទ ។ កាឡទេវិលតាបសគិតថា អញនឹងនាំសរភង្គតាបសមក ទើបហោះទៅនិមន្តសរភង្គតាបសមក ។ សរភង្គតាបសកាលមកឃើញហើយ ក៏ដឹងថា ធ្លាក់នៅក្នុងអំណាចឥន្ទ្រិយ ទើបសួរថា នែនារទៈ អ្នកធ្លាក់ក្នុងអំណាចនៃឥន្ទ្រិយទេដឹង លុះនារទតាបសបានស្តាប់ដូច្នោះ

ក្រោកឡើងថ្វាយអភិវាទ ពោលថា បពិត្រលោកអាចារ្យ ពិតមែនហើយ ទើបសរភង្គតាបសពោលថា នៃនារទៈ ធម្មតាបុគ្គលដែលធ្លាក់ក្នុងអំណាចឥន្ទ្រិយក្នុងអត្តភាពនេះ ក៏ស្គាំងស្គម សោយនូវទុក្ខ ក្នុងអត្តភាពទី ២ រមែងកើតក្នុងនរក ដូច្នេះហើយ ពោលគាថាទី ១ ថា

ម្នាលនារទៈ បុគ្គលណា លុះអំណាចនៃឥន្ទ្រិយទាំងឡាយព្រោះកាម បុគ្គលនោះ លះបង់នូវលោកទាំងពីរ ( ហើយ កើតក្នុងនរក ) សូម្បីរស់នៅ រមែងរីងស្ងួត ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យោ ឥន្ទ្រិយានំ** សេចក្ដីថា នៃនារទៈ បុរសណា កាន់យកអាការក្នុងរូបជាដើមថា ស្អាត ធ្លាក់ក្នុងអំណាចនៃឥន្ទ្រិយ ៦ ដោយអំណាចនៃកិលេសកាម ។ បទថា **ចវិត្វន្ទុភោ** សេចក្ដីថា បុរសនោះលះលោកទាំង ២ គឺមនុស្សលោក និងទេវលោកហើយ រមែងកើតក្នុងអបាយ មាននរកជាដើម ។ បទថា **ជីវន្តោវ វិសុស្សតិ** សេចក្ដីថា កាលរស់នៅ ក៏មិនបានកិលេសវត្ថុដែលខ្លួនប្រាថ្នា រមែងក្រៀមស្ងួតព្រោះសោក ដល់នូវសេចក្ដីទុក្ខធំ ។

នារទតាបសបានស្ដាប់ដូច្នោះ ទើបសួរថា បពិត្រលោកអាចារ្យ ឈ្មោះថា ការសេពកាម រមែងឈ្មោះថាជាសុខ តែលោកមកពោលសេចក្ដីសុខនេះថាជាទុក្ខដូច្នេះ សំដៅដល់អ្វី លំដាប់នោះ សរភង្គតាបសបានពោលថា កាលបើដូច្នោះ ចូរអ្នកស្ដាប់ ហើយពោលគាថាទី ២ ថា

ទុក្ខជាលំដាប់នៃសុខ សុខជាលំដាប់នៃទុក្ខ សូម្បីអ្នកដល់នូវទុក្ខ

ព្រោះសាបសូន្យចាកឈានសុខក៏ដោយ អ្នកចូរប្រាថ្នានូវសុខដ៏ប្រសើរវិញចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សុខស្សានន្តរំ** បានដល់ ទុក្ខ គឺនរកដែលកើតឡើងក្នុងលំដាប់នៃកាមសុខ ។ បទថា **ឧភយស្ស** បានដល់ សុខដែលជាទិព្វ សុខដែលជារបស់មនុស្ស និងសុខ គឺព្រះនិព្វាន ដែលកើតក្នុងលំដាប់នៃសេចក្តីលំបាក គឺត្រូវរក្សាសីល ។

លោកអធិប្បាយដូច្នេះថា ម្នាលនារទៈ សត្វទាំងនេះ ធ្វើកាលកិរិយាក្នុងសម័យដែលសេពកាម រមែងកើតក្នុងនរក ដែលមានទុក្ខដោយចំណែកមួយ ឯបុគ្គលរក្សាសីល និងចម្រើនវិបស្សនា រមែងលំបាក ជនទាំងនោះរក្សាសីលដោយសេចក្តីលំបាកហើយ រមែងបាននូវសេចក្តីសុខ ដូចបានពោលហើយដោយផលនៃសីល អាស្រ័យហេតុនេះ ទើបយើងពោលយ៉ាងនេះ ។ បទថា **សោសិ បត្តោ** សេចក្តីថា នែនារទៈ អ្នកឥឡូវនេះ បានធ្វើឈានសុខឲ្យវិនាស ហើយទើបដល់សេចក្តីទុក្ខផ្លូវចិត្ត ដែលអាស្រ័យកាម ជាហេតុច្រើនជាងសុខនោះ ។ បទថា **ចាជិកន្តុ** សេចក្តីថា ចូរអ្នកបោះបង់កិលេសទុក្ខនេះហើយចូរប្រាថ្នា គឺប្រាថ្នាឈានសុខដ៏ប្រសើរ គឺឧត្តមនោះឯងចុះ ។

នារទតាបសពោលថា បពិត្រលោកអាចារ្យ ទុក្ខនេះ ខ្ញុំមិនអាចអត់សង្កត់បានទេ ។ លំដាប់នោះ ព្រះមហាសត្វពោលនឹងនារទតាបសថា នែនារទៈ ធម្មតាទុក្ខដែលកើតឡើងហើយ បុគ្គលគប្បីអត់សង្កត់បាន ដូច្នេះហើយ ពោលគាថាទី ៣ ថា

បុគ្គលណា ជាអ្នកអត់ទ្រាំនូវសេចក្តីលំបាក ក្នុងវេលាមានលំបាក មិនប្រព្រឹត្តកន្លងនូវសេចក្តីលំបាក បុគ្គលនោះជាអ្នកប្រាជ្ញ រមែងបាននូវសេចក្តីសុខជាទីបំផុតនៃសេចក្តីលំបាក ដែលកើតអំពីសេចក្តីព្យាយាម ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឆាតិវត្តតិ** បានដល់ រមែងមិនប្រព្រឹត្តទៅតាម ។ ព្រះបាលីក៏យ៉ាងនេះដូចគ្នា ។

លោកពាក្យអធិប្បាយថា នៃនារទៈ បុគ្គលណា ក្នុងកាលសេចក្តីលំបាក គឺទុក្ខ ដែលប្រព្រឹត្តទៅតាមកាយ និងចិត្តកើតឡើងហើយ ជាអ្នកមិនប្រមាទ រកឧបាយកម្ចាត់សេចក្តីលំបាកនោះបាន អត់ធ្មត់ចំពោះសេចក្តីលំបាកបាន ឈ្មោះថា មិនប្រព្រឹត្តទៅតាមសេចក្តីលំបាក គឺមិនប្រព្រឹត្តទៅក្នុងអំណាចសេចក្តីលំបាកនោះ ប្រើឧបាយនោះៗ គ្របសង្កត់សេចក្តីលំបាក គឺធ្វើសេចក្តីលំបាកនោះឲ្យអស់ទៅបាន បុគ្គលនោះជាអ្នកប្រាជ្ញ សម្រេចនូវសេចក្តីសុខដែលប្រាសចាកអាមិស គឺសុខដែលមានក្នុងទីបំផុត នៃសេចក្តីលំបាក ឬរមែងជួបនូវសេចក្តីសុខ ដែលកើតអំពីការប្រកប ដែលជាទីបំផុតនៃសេចក្តីលំបាកនោះ គឺជាអ្នកមិនលំបាក រមែងសម្រេចសេចក្តីសុខ ។

នារទតាបសពោលថា បពិត្រលោកអាចារ្យ ឈ្មោះថា កាមសុខ ជាសុខដ៏ឧត្តម ខ្ញុំមិនអាចលះកាមសុខនោះបាន ។ លំដាប់នោះ ទើបព្រះមហាសត្វពោលនឹងនារទតាបសថា នៃនារទៈ ឈ្មោះថា ធម៌ បុគ្គលមិនគួរឲ្យវិនាសដោយហេតុណាមួយ ដូច្នេះហើយ ពោលគាថាទី ៤ ថា

ខ្លួនអ្នកមិនគួរឲ្យឃ្លាតចាកធម៌ ព្រោះការប្រាថ្នាកាម ព្រោះ
ការវិនាស ព្រោះហេតុនៃប្រយោជន៍ ទាំងព្រោះលះបង់ឈាន
ដែលខ្លួនធ្វើបានហើយទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កាមានំ កាមា** បានដល់ ព្រោះពិចារណា
កាម គឺព្រោះប្រាថ្នាវត្ថុកាមទាំងឡាយ ។ បទថា **ឆានត្ថា ឆាត្ថការណា**
សេចក្តីថា អ្នកមិនគួរសាបសូន្យចាកធម៌ ព្រោះហេតុមិនមែនប្រយោជន៍ និង
ព្រោះហេតុជាប្រយោជន៍ ។ បទថា **ឆ កតញ្ច ឆិវត្ថត្វា** សេចក្តីថា ព្រោះ
ធ្វើឈានសុខដែលអ្នកធ្វើហើយ គឺឲ្យសម្រេចហើយ សាបសូន្យទៅ ។

លោកអធិប្បាយថា នៃនារទ: អ្នកមិនគួរឃ្លាតចាកធម៌ ព្រោះប្រាថ្នានូវ
វត្ថុកាមឡើយ កាលវត្ថុមិនមែនប្រយោជន៍ណាមួយកើតឡើង អ្នកបំណងនឹង
កម្ចាត់វត្ថុមិនមែនប្រយោជន៍នោះ កុំឃ្លាតចាកធម៌ ព្រោះវត្ថុមិនមែនប្រយោជន៍
ឡើយ គឺព្រោះវត្ថុមិនមែនប្រយោជន៍នោះ ដែលជាដើមហេតុ ។ អ្នកមិនគួរ
ឃ្លាតចាកធម៌ ព្រោះហេតុដែលជាប្រយោជន៍យ៉ាងនេះថា ប្រយោជន៍យ៉ាង
នោះ កើតដល់អញ អ្នកមិនគួរឃ្លាតចាកធម៌ ព្រោះធ្វើឈានសុខ ដែលធ្វើ
រហូតសម្រេច ហើយឲ្យវិនាសទៅ គឺសាបសូន្យទៅ ។

កាលសរភង្គតាបសសម្តែងធម៌ ៤ គាថា យ៉ាងនេះហើយ កាឡ-
ទេវិលតាបស កាលនឹងទូន្មានប្អូនប្រុសរបស់ខ្លួន ទើបពោលគាថាទី ៥ ថា

សេចក្តីឃ្លាសវៃ ១ ការបែងចែកភោជន ១ មិនរីករាយក្នុង
ការបានទូវប្រយោជន៍ ១ មិនលំបាកចិត្តក្នុងកាលវិនាសចាក

ប្រយោជន៍ ១ ( នេះ ) ជាការប្រពៃរបស់គ្រហស្ថ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ទក្ខំ គហបតំ** សេចក្តីថា នៃនារទៈ គហបតីជាអ្នកគ្រប់គ្រងផ្ទះ ជាអ្នកឧស្សាហ៍ ពោល គឺមិនខ្ជិលច្រអូស ជាអ្នកឈ្លាសវៃ ដើម្បីធ្វើភោគៈឲ្យកើតឡើង គឺភាពជាអ្នកឈ្លាសក្នុងសេចក្តីនេះជាលំដាប់ទី ១ ។ បទថា **សំវិភជ្ជញ្ច ភោជនំ** សេចក្តីថា ការបែងចែកភោគៈ ដែលឲ្យកើតហើយដោយសេចក្តីលំបាក ដល់សមណព្រាហ្មណ៍ អ្នកប្រព្រឹត្តធម៌ហើយ ទើបបរិភោគ សេចក្តីនេះ គឺលំដាប់ទី ២ ។ បទថា **អហាសោ អត្ថលាភេសុ** សេចក្តីថា កាលឥស្សរិយយសធំកើតឡើងហើយ ក៏មិនត្រេកអរដោយចំណាចសេចក្តីស្រវឹង បានដល់ ប្រាសចាកការត្រេកអរ សេចក្តីនេះ ជាលំដាប់ទី ៣ ។ បទថា **អត្ថព្យាបត្តិ** សេចក្តីថា កាលណាមានការសាបសូន្យនូវប្រយោជន៍ គឺយសវិនាស កាលនោះ មិនមានសេចក្តីលំបាក សុបសៅ សេចក្តីនេះ ជាលំដាប់ទី ៤ ។

នៃនារទៈ ព្រោះហេតុនោះ អ្នកកុំសោកឡើយថា ឈានរបស់អញវិនាសទៅហើយ បើអ្នកមិនធ្លាក់នៅក្នុងអំណាចរបស់ឥន្ទ្រិយ សូម្បីឈានដែលអ្នកវិនាសហើយ ក៏នឹងបានមកវិញដូចដើមនោះឯង ។

ព្រះសាស្តា ជាអ្នកត្រាស់ដឹងឯង ដោយព្រះបញ្ញាដ៏ក្រៃលែង ទ្រង់ជ្រាបភាពដែលកាឡទេវិលតាបសពោលទូន្មាននារទតាបសនោះ ទើបត្រាស់អភិសម្ពុទ្ធគាថាទី ៦ ថា

អសិតទេវិលតាបស បានពោលនូវភាពនៃបុគ្គលជាបណ្ឌិតនុ៎ះ ដោយហេតុមានប្រមាណប៉ុណ្ណោះថា មិនមានបុគ្គលណាមួយ ដែលលាមកជាងបុគ្គល ជាអ្នកលុះអំណាចនៃឥន្ទ្រិយទាំងឡាយនេះឡើយ ដូច្នេះ ។

ព្រះគាថានោះ មានអធិប្បាយថា ម្នាលភិក្ខុទាំងឡាយ ទេវិលតាបសជាអ្នកស្ងប់រម្ងាប់ ទូន្មានភាពជាបណ្ឌិតនឹងនារទតាបសនោះ ដោយពាក្យនេះថា បុគ្គលណាធ្លាក់ក្នុងអំណាចនៃឥន្ទ្រិយ ដោយអំណាចនៃកិលេស អ្នកដទៃដែលអាក្រក់ជាងបុគ្គលនោះ មិនមានសូម្បីតែតិចតួច ។

លំដាប់នោះ សរភង្គតាបសហៅនារទតាបសនោះមកពោលថា នែនារទ: ចូរអ្នកស្តាប់ពាក្យនេះសិន បុគ្គលណា មិនធ្វើវត្ថុដែលគួរធ្វើមុន បុគ្គលនោះរមែងសោយសោកយូរអង្វែង ដូចមាណពដែលត្រាច់ទៅក្នុងព្រៃដូច្នោះ ដូច្នេះហើយ បាននាំយករឿងក្នុងអតីតមកសាធក:ដូចតទៅ

ក្នុងអតីតកាល ក្នុងកាសីនិគម មានព្រាហ្មណ៍ម្នាក់រូបស្អាត សម្បូរដោយកម្លាំង មានកម្លាំងប៉ុនដំរីសារ ព្រាហ្មណមាណពនោះគិតថា ប្រយោជន៍អ្វីដែលអញធ្វើកសិកម្មជាដើម ចិញ្ចឹមមាតា ប្រយោជន៍អ្វីដោយបុត្រ ភរិយា ប្រយោជន៍អ្វីដោយកុសល មានទានជាដើម ដែលអញធ្វើ អញនឹងមិនចិញ្ចឹមបុគ្គលណាទាំងអស់ នឹងមិនធ្វើបុណ្យណាមួយ អញនឹងចូលព្រៃសម្លាប់ម្រឹគផ្សេងៗ ចិញ្ចឹមជីវិត ដូច្នេះហើយ ទើបរៀបចំអាវុធ ៥ ប្រភេទ ចូលកាន់ព្រៃហិមពាន្ត សម្លាប់ម្រឹគផ្សេងៗ បរិភោគ ទៅដល់ជើងភ្នំធំ មានភ្នំព័ទ្ធជុំវិញ

ក្បែរប្រាំងវិធិនីនទី ក្នុងហិមវន្តប្បទេសនោះ សម្លាប់ម្រឹគហើយ អាំងលើរងើកភ្លើង បរិភោគក្នុងទីនោះ ។ មាណពនោះគិតថា អញនឹងមានកម្លាំងនៅស្មើជានិច្ចមិនបាន ដល់កាលទុព្វលភាព នឹងមិនអាចត្រាច់ទៅក្នុងព្រៃ ឥឡូវនេះ អញនឹងកៀងម្រឹគច្រើនប្រភេទឲ្យចូលក្នុងរង្វង់ភ្នំ ហើយធ្វើទ្វាររាំង កាលអញទៅព្រៃលែងរួច អញនឹងសម្លាប់ម្រឹគទាំងនេះ បរិភោគតាមគាប់ចិត្ត គិតដូច្នេះហើយ ក៏ធ្វើយ៉ាងនោះ ។ ពេលវេលាកន្លងទៅ កម្មរបស់គាត់ដល់ទីបំផុត ត្រូវឲ្យផលជាទិដ្ឋធម្មវេទនីយកម្ម កាលជើងរបស់គាត់ដើរលែងរួច គាត់មិនអាចដើរទៅមកបាន បរិភោគរបស់ណាមួយមិនបាន ទឹកក៏ផឹកមិនកើត រាងកាយក្រៀមស្ងួត ក្លាយជាមនុស្សប្រេត រាងកាយប្រេះបែក ដូចផែនដីប្រេះក្រហែងក្នុងរដូវប្រាំង ដូច្នោះ ។ គាត់មានរូបរាងគួរខ្ពើម គួរខ្លាចសោយនូវទុក្ខធំ ។

ក្នុងកាលកន្លងទៅមិនយូរប៉ុន្មាន ដោយអាការយ៉ាងនេះ ព្រះបាទសិវិរាជ ក្នុងសិវិរដ្ឋ ទ្រង់ព្រះតម្រិះថា អញនឹងសោយសាច់អាំងក្នុងព្រៃ ក៏ប្រគល់រាជសម្បត្តិឲ្យអមាត្យទាំងឡាយគ្រប់គ្រងជំនួស ទ្រង់ប្រដាប់អាវុធ ៥ យ៉ាង ចូលកាន់ព្រៃសម្លាប់ម្រឹគ សោយសាច់មករឿយៗ រហូតដល់បទេសនោះដោយលំដាប់ ទ្រង់ទតឃើញបុរសនោះ ទ្រង់ភិតភ័យ លុះតាំងសតិបានហើយ ទើបត្រាស់សួរថា នែអ្នកនិទ្ទុក្ខ អ្នកជានរណា បុរសនោះតបថា អើលោក ខ្ញុំជាមនុស្សប្រេត សោយផលកម្មដែលខ្លួនធ្វើ ចុះលោកជានរណា ព្រះរាជាត្រាស់ថា យើងជាស្តេចសិវិរាជ បុរសនោះទូលថា តើទ្រង់យាងមក

ទីនេះដើម្បីអ្វី ព្រះរាជាត្រាស់ថា ដើម្បីសោយសាច់ម្រឹគ ។

លំដាប់នោះ មាណពនោះក្រាបទូលថា បពិត្រមហារាជ ទូលបង្គំក៏មក ដោយហេតុនេះដែរ ទើបក្លាយជាមនុស្សប្រេត ហើយទូលរឿងទាំងអស់ដោយពិស្តារ កាលនឹងក្រាបទូលភាពដែលខ្លួនសោយទុក្ខដល់ព្រះរាជា បានពោលគាថាដ៏សេស ដោយសេចក្តីថា

បពិត្រព្រះបាទសិវិ បុគ្គលប្រាកដស្មើនឹងខ្ញុំ រមែងដល់នូវសេចក្តីវិនាស ( ដោយអំពើរបស់ខ្លួន ) ដូចបុគ្គលដល់នូវសេចក្តីវិនាសក្នុងកណ្តាប់ដៃនៃសត្រូវ ខ្ញុំ ព្រោះតែញុំាងយសទាំងនុ៎ះ គឺកសិកម្ម វិជ្ជា ភាពជាអ្នកឈ្លាសវៃ វិវាហមង្គល សីល និងភាពនៃចិត្តទន់ឲ្យសាបសូន្យ ទើបមកកើត ( ជាមនុស្សប្រេត ) ដោយអំពើជារបស់ខ្លួន ។

ខ្ញុំនោះ ជាបុគ្គលមិនមានផៅពង្ស មិនមានទីពំនាក់តទៅ ដូចគេសាបសូន្យចាកទ្រព្យរាប់ពាន់ ខ្ញុំ ជាអ្នកប្រាសចាកអរិយធម៌ ដូចប្រេត ។

ខ្ញុំ ញុំាងពួកសត្វដែលជាអ្នកប្រាថ្នានូវសុខ ឲ្យដល់នូវទុក្ខ ទើបដល់នូវគន្លងនៃទុក្ខនេះ ខ្ញុំនោះ មិនបាននូវសេចក្តីសុខឡើយ ឋិតនៅ ( ទាំងក្តៅក្រហាយ ) ដូចគេរោយដោយរងើកភ្លើង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អមិត្តានំវ ហត្ថត្តំ** សេចក្តីថា ដូចសេចក្តី

វិនាស គឺការវិនាសក្នុងដៃរបស់សត្រូវ ។

មាណពហៅព្រះរាជាថា **សិវិ** ប្រែថា បពិត្រស្តេចសិវិរាជ ។ បទថា **បប្បោតិ មា មិវ** សេចក្តីថា ដូចខ្ញុំ ត្រូវជួបនូវបាបកម្ម អធិប្បាយថា ត្រូវដល់នូវសេចក្តីវិនាស ដោយកម្មរបស់ខ្លួនឯង ។ បទថា **កម្មំ** បានដល់ កិច្ចកម្មដែលញ៉ាំងជីវិតឲ្យសម្រេច មានកសិកម្មជាដើមជាប្រភេទ ។ បទថា **វិជ្ជំ** បានដល់ សិប្បៈ មានសិប្បៈដំរីជាដើម ដែលមានប្រការផ្សេងៗ គ្នា ។ បទថា **ឧដ្ឋានំ** បានដល់ ភាពជាអ្នកឈ្លាសដោយការញ៉ាំងភោគៈឲ្យកើតឡើងមានប្រការផ្សេងៗ ។ បទថា **វិវាហំ** សេចក្តីថា ការសម្ពន្ធផ្លូវអាវាហមង្គលនិងវិវាហមង្គល ។ បទថា **សីលមទ្ទវំ** បានដល់ សីលមាន ៥ យ៉ាង និងភាពជាអ្នកមានវាចាទន់ភ្លន់ ប្រាថ្នាប្រយោជន៍ ហាមនូវការធ្វើបាប សេចក្តីនោះឯង លោកសំដៅយកថា **មទ្ទវ** ក្នុងគាថានេះ ។ បទថា **ឯតេ ច យសេ ហាបេត្វា** សេចក្តីថា ធ្វើលោកធម៌ដែលជាហេតុឲ្យដល់នូវយសទាំងនេះមានប្រមាណប៉ុណ្ណេះឲ្យវិនាសទៅ ។ បទថា **និព្វត្តោ សេហិ កម្មេហិ** សេចក្តីថា កើតជាមនុស្សប្រេតដោយកម្មរបស់ខ្លួន ។

លោកអធិប្បាយដូច្នេះថា បពិត្រមហារាជ ទូលបង្គំមិនធ្វើកម្មដែលគួរធ្វើ គឺកម្មដែលជាហេតុឲ្យដល់នូវឥស្សរិយយសក្នុងលោកនេះ មិនសិក្សាសិប្បវិជ្ជា មិនខ្វល់ខ្វាយញ៉ាំងភោគៈឲ្យកើតដោយឧបាយ មិនធ្វើនូវអាវាហវិវាហៈ មិនរក្សាសីល មិនគប់រកកល្យាណមិត្រ ដែលអាចហាមឃាត់មិនឲ្យធ្វើបាប ញ៉ាំងលោកធម៌ដែលដល់នូវការរាប់ថា យស ព្រោះជាហេតុឲ្យបាន

យសទាំងនេះ គឺមានប្រមាណប៉ុណ្ណេះ ឲ្យសាបសូន្យទៅ គឺបោះបង់ចោល ចូលមកកាន់ព្រៃនេះ រហូតកើតជាមនុស្សប្រេត ក្នុងឥឡូវនេះ ដោយបាបកម្ម ដែលខ្លួនធ្វើនោះឯង ។

បទថា **សហស្សជិនោវ** សេចក្តីថា ដូចបុរសដែលវិនាសសាបសូន្យ ចាកទ្រព្យរាប់ពាន់ មានអធិប្បាយថា បើទូលបង្គំបដិបត្តិប្រពៃ ធ្វើភោគៈឲ្យ កើតឡើង មាននូវជ័យជម្នះដោយភោគសម្បត្តិទាំងឡាយច្រើនពាន់ ដូច្នេះ ។ បទថា **អបរាយណោ** សេចក្តីថា មិនមានទីពឹង មិនមានទីពំនាក់ ។ បទថា **អរិយធម្មា** សេចក្តីថា ឃ្លាតកន្លងចាកសប្បុរិសធម៌ ។ បទថា **យថា បេតោ** សេចក្តីថា ទោះបីនៅមានជីវិត ក៏ដូចជាស្លាប់ហើយ កើតជាប្រេត អធិប្បាយថា ទូលបង្គំក្លាយជាមនុស្សប្រេត ។ បទថា **សុខកាមេ ទុក្ខា-បេត្វា** សេចក្តីថា ទូលបង្គំបានធ្វើសត្វទាំងឡាយ ដែលប្រាថ្នាសេចក្តីសុខ ឲ្យបានទទួលសេចក្តីទុក្ខ ។ បាឋៈថា **សុខកាមោ** ដូច្នេះក៏មាន សេចក្តីថា ទូលបង្គំប្រាថ្នាសេចក្តីសុខដោយខ្លួនឯង តែញ៉ាំងអ្នកដទៃឲ្យបានទទួលសេចក្តី ទុក្ខ ។ បទថា **អាបន្នោស្មិ បទំ ឥមំ** សេចក្តីថា ទើបទូលបង្គំដល់នូវ ចំណែកនេះ គឺបែបនេះ ។ បាឋៈថា **បថំ** ដូច្នេះក៏មាន សេចក្តីថា ទូលបង្គំ មកដល់អត្តភាពដែលគ្រប់គ្រងនូវសេចក្តីទុក្ខនេះ ។ បទថា **ឋិតោ ភាណុ-មតាមិវ** សេចក្តីថា ភ្លើង លោកហៅថា **ភាណុមា** គឺមាណពក្រាបទូល ថា ទូលបង្គំហាក់បីដូចជាមានគំនរភ្លើងនៅជុំវិញ ត្រូវក្តៅក្រហាយធំ ដែល តាំងឡើងក្នុងរាងកាយដុតបំផ្លាញ មិនបានជួបនូវសេចក្តីសុខកាយ សុខចិត្ត

ឡើយ ។

មាណពនោះកាលពោលយ៉ាងនេះហើយ ក្រាបទូលថា បពិត្រមហារាជ ទូលបង្គំប្រាប្ថាសេចក្តីសុខ តែធ្វើឲ្យអ្នកដទៃបានទទួលសេចក្តីទុក្ខ ទើបកើតជាមនុស្សប្រេតក្នុងបច្ចុប្បន្នទាន់ភ្នែក ព្រោះដូច្នោះ សូមទ្រង់កុំធ្វើអាក្រក់ឡើយ សូមយាងទៅព្រះនគររបស់ទ្រង់ចុះ ហើយទ្រង់បំពេញបុណ្យ មានទានជាដើមចុះ ។ ព្រះបាទសិវិរាជទ្រង់បានធ្វើតាមនោះ ទ្រង់ជម្រះផ្លូវទៅកាន់ស្ថានសួគ៌ឲ្យបរិបូណ៌ហើយ ។

សរភង្គសាស្តា នាំរឿងនេះមកសម្តែងឲ្យតាបសយល់ច្បាស់ដោយល្អ តាបសនោះដល់នូវការសង្វេគ ព្រោះពាក្យរបស់សរភង្គសាស្តា ទើបថ្វាយបង្គំសូមខមាទោស ហើយធ្វើកសិណបរិកម្ម ធ្វើឈានដែលវិនាសហើយ ឲ្យត្រឡប់មកវិញជាប្រក្រតី សរភង្គតាបស មិនឲ្យនារទតាបសនៅក្នុងទីនោះ នាំទៅកាន់អាស្រមរបស់ខ្លួន ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ កាលចប់សច្ចធម៌ ភិក្ខុអផ្សុកតាំងនៅក្នុងសោតាបត្តិផល ហើយទ្រង់ប្រជុំជាតកថា នារទតាបសក្នុងកាលនោះ បានមកជាភិក្ខុអផ្សុកក្នុងកាលឥឡូវនេះ សាលិស្សរតាបស ក្នុងកាលនោះ បានមកជា

សារីបុត្រ មេណ្ឌិស្សរតាបស ក្នុងកាលនោះ បានមកជាកស្សបៈ បព្វត តាបស ក្នុងកាលនោះ បានជាអនុរុទ្ធ កាឡទេវិលតាបស ក្នុងកាលនោះ បានមកជាកច្ចាយនៈ អនុបិយតាបស ក្នុងកាលនោះ បានមកជាអានន្ទ កិសវច្ចតាបសក្នុងកាលនោះ បានមកជាមោគ្គល្លាន ឯសរភង្គតាបស ក្នុង កាលនោះ គឺតថាគតនេះឯង ។ល។

**អដ្ឋកថា ឥន្រ្ទិយជាតក ចប់**

# សុត្តន្តបិដក

## អាទិត្តជាតក

[ ៤៧៨ ] ( ព្រះបច្ចេកពុទ្ធជាសង្ឃត្ថេរសម្តែងថា ) កាលបើផ្ទះត្រូវភ្លើងឆេះហើយ បុគ្គលនាំចេញនូវភាជន៍ណាទាន់ ភាជន៍នោះ រមែងបានជាប្រយោជន៍នៃបុគ្គលនោះ ភាជន៍ណាដែលភ្លើងឆេះក្នុងផ្ទះនោះ ភាជន៍នោះ មិនបានជាប្រយោជន៍នៃបុគ្គលនោះឡើយ ។

[ ៤៧៩ ] សត្វលោកកាលបើត្រូវជរា និងមរណៈឆេះយ៉ាងនេះហើយ បុគ្គលគួរតែនាំចេញនូវទ្រព្យដោយការឲ្យទាន ( ព្រោះ ) ទ្រព្យដែលបុគ្គលបានឲ្យហើយ ឈ្មោះថា នាំចេញហើយដោយប្រពៃ ។

[ ៤៨០ ] ( ព្រះបច្ចេកពុទ្ធដ៏សេសសម្តែងថា ) សត្វណា បានឲ្យទានដល់បុគ្គលអ្នកបានធម៌ បានត្រាស់ដឹងធម៌ដោយសេចក្តីព្យាយាម គឺការប្រឹងប្រែង សត្វនោះ រមែងប្រព្រឹត្តកន្លងនូវវេតរណីរបស់យមៈ ( នរក ) បាន ហើយចូលទៅកាន់ទីទាំងឡាយជាទិព្វ ។

[ ៤៨១ ] អ្នកប្រាជ្ញទាំងឡាយពោលថា ទាន និងចម្បាំងជារបស់ស្មើគ្នា ពួកជនសូម្បីតិចគ្នា តែជាអ្នកស៊ូលះបង់ជីវិត រមែងឈ្នះជនច្រើននាក់បាន បុគ្គលណាកាលបើជឿហើយ ឲ្យទាន សូម្បីបន្តិចបន្តួច បុគ្គលនោះ រមែងបាននូវសេចក្តីសុខក្នុងលោកខាង

មុខ ដោយទេយ្យវត្ថុមានប្រមាណតិចនោះ ។

[ ៤៨២ ] ការពិចារណាសិន ហើយទើបឲ្យ ព្រះសុគតទ្រង់សរសើរហើយ ពួកទក្ខិណេយ្យបុគ្គលណា មាននៅក្នុងជីវលោកនេះ ទានដែលបុគ្គលឲ្យហើយ ដល់ពួកទក្ខិណេយ្យបុគ្គលនុ៎ះ មានផលច្រើន ដូចជាពូជដែលគេសាបព្រោះក្នុងស្រែដ៏ល្អ ។

[ ៤៨៣ ] បុគ្គលណា មិនបៀតបៀននូវពួកសត្វ មិនធ្វើនូវបាប ព្រោះ ( ខ្លាច ) ការតិះដៀលអំពីអ្នកដទៃ អ្នកប្រាជ្ញទាំងឡាយ តែងសរសើរនូវបុគ្គលអ្នកខ្លាចបាប មិនសរសើរនូវបុគ្គលអ្នកក្លៀវក្លាក្នុងការធ្វើបាបនោះឡើយ ដ្បិតសប្បុរសទាំងឡាយតែងមិនធ្វើបាប ព្រោះខ្លាច ( ពាក្យជំណេះជំនៀលនោះ ) ។

[ ៤៨៤ ] បុគ្គលចូលទៅកើតក្នុងពួកក្សត្រិយ៍ ដោយព្រហ្មចរិយធម៌ដ៏ថោកទាប បុគ្គលចូលទៅកាន់ភាពជាទេវតាដោយព្រហ្មចរិយធម៌យ៉ាងកណ្ដាល បុគ្គលបរិសុទ្ធដោយព្រហ្មចរិយធម៌ដ៏ឧត្តម ។

[ ៤៨៥ ] ការឲ្យទាន ពិតជាអ្នកប្រាជ្ញសរសើរដោយចំណែកច្រើន ក៏មែនហើយ តែថា ចំណែកធម៌ប៉ុណ្ណោះ ប្រសើរជាងទាន ព្រោះពួកសប្បុរសអ្នកមានប្រាជ្ញាក្នុងកាលមុន និងកាលមុនទៅទៀត បានត្រាស់ដឹងនូវនិព្វានធម៌ ។

**អាទិត្តជាតកទី ៨ ចប់**

# អដ្ឋកថា

## អាទិត្តជាតក

[ ៤៧៨-៤៨៥ ] *ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធ អសទិសទាន ទើបត្រាស់រឿងនេះ មានពាក្យផ្តើមថា* **អាទិត្តស្មឹ** *ដូច្នេះជាដើម ។*

*រឿងអសទិសទាន មានពិស្តារក្នុងអដ្ឋកថាមហាគោវិន្ទសូត្រហើយ ។*

*ក្នុងថ្ងៃទី ២ បន្ទាប់អំពីថ្ងៃដែលព្រះបាទកោសលថ្វាយអសទិសទានហើយ ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ ព្រះបាទកោសល ទ្រង់ឈ្លាសជ្រើសរើសនូវស្រែបុណ្យដ៏ប្រសើរ ថ្វាយមហាទានដល់អរិយសង្ឃ មានព្រះពុទ្ធជាប្រធាន ។ ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងនោះក្រាបទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គដោយរឿងឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការជ្រើសថ្វាយទានក្នុងស្រែបុណ្យដ៏ឧត្តមក្រៃលែងរបស់ព្រះបាទកោសល មិនជាអស្ចារ្យឡើយ បុរាណកបណ្ឌិតក្នុងកាលមុន ក៏បានជ្រើសរើសហើយ ទើបបានថ្វាយមហាទានដូចគ្នា ដូច្នេះហើយ ទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅ*

*ក្នុងអតីតកាល ព្រះបាទភេរុវមហារាជ សោយរាជសម្បត្តិក្នុងភេរុវនគរ នាសិវិរដ្ឋ ទ្រង់បំពេញទសពិធរាជធម៌ សង្គ្រោះមហាជនដោយសង្គហវត្ថុ ៤ តាំងនៅក្នុងឋានៈជាមាតាបិតារបស់មហាជន បានឲ្យទានដល់មនុស្សកំព្រា វនិព្វក និងយាចកទាំងឡាយជាច្រើន ។ ទ្រង់មានអគ្គមហេសីព្រះនាមថា*

សមុទ្ទវិជយា ជាបណ្ឌិតសម្បូរដោយញាណ ។ ថ្ងៃមួយ ព្រះបាទកេរុរមហារាជ ទ្រង់ទតរោងទាន ទ្រង់ព្រះតម្រិះថា បដិគ្គាហកទាំងឡាយ សុទ្ធតែជាអ្នកទ្រុស្តសីល មិនមានមារយាទ បរិភោគទានរបស់អញ សេចក្តីនោះ មិនធ្វើឲ្យអញត្រេកអរឡើយ អញប្រាថ្នានឹងថ្វាយទានដល់ព្រះបច្ចេកពុទ្ធ ដែលជាអ្នកមានសីល ជាអគ្គទក្ខិណេយ្យបុគ្គលដល់លោកទាំងនោះ ក្នុងហិមវន្តប្បទេស នរណាហ្ន៎ ទៅនិមន្តលោកមកបាន អញនឹងបញ្ជូនអ្នកណាទៅនិមន្តបាន ទ្រង់ត្រិះរិះដូច្នេះហើយ បានត្រាស់សេចក្តីនោះដល់ព្រះទេវី ។ លំដាប់នោះ ព្រះទេវីបានទូលព្រះរាជាថា បពិត្រព្រះអង្គ សូមទ្រង់កុំវិតក្កឡើយ ខ្ញុំម្ចាស់នឹងបញ្ជូនការទៅនិមន្តព្រះបច្ចេកពុទ្ធទាំងឡាយ ដោយកម្លាំងទានដែលគប្បីថ្វាយ កម្លាំងសីល និងកម្លាំងសច្ចៈរបស់យើងទាំងឡាយ កាលព្រះបច្ចេកពុទ្ធទាំងឡាយមកដល់ហើយ សឹមថ្វាយទាន ដែលសម្បូរដោយបរិក្ខារគ្រប់យ៉ាង ។ ព្រះរាជាទ្រង់ត្រាស់ថា សាធុ ដូច្នេះហើយ ត្រាស់ឲ្យវាយស្គរប្រកាសថា អ្នកនគរទាំងមូល ចូរសមាទានសីល ចំណែកទ្រង់ មួយអន្លើដោយរាជបរិវារ ក៏ទ្រង់អធិដ្ឋានអង្គនៃឧបោសថ បំពេញមហាទាន ។ ព្រះទេវីឲ្យរាជបុរសកាន់ជាលមាសដាក់ផ្កាម្លិះពេញ ចុះអំពីប្រាសាទ ប្រថាប់ត្រង់លានព្រះរាជវាំង ព្រះនាងក្រាបថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋានលើផែនដី ហើយបែរព្រះភក្ត្រទៅទិសខាងកើត នមស្ការហើយ ត្រាស់ថា ខ្ញុំសូមនមស្ការព្រះអរហន្តទាំងឡាយ ក្នុងទិសខាងកើត បើគុណឯណានីមួយរបស់ខ្ញុំមានសោត សូមលោកម្ចាស់ទាំងឡាយ អនុគ្រោះពួកខ្ញុំ សូមនិមន្តមកទទួលភិក្ខារបស់ពួកខ្ញុំទាំងឡាយ

ចុះ ប្រកាសដូច្នេះហើយ ព្រះនាងបាចផ្កាម្លិះទៅ ៧ ក្តាប់ ។ ក្នុងថ្ងៃស្អែកឡើង មិនមានព្រះបច្ចេកពុទ្ធនិមន្តមក ព្រោះក្នុងទិសខាងកើតមិនមានព្រះបច្ចេកពុទ្ធ ។ ក្នុងថ្ងៃទី ២ ព្រះនាងនមស្ការទៅទិសទក្សិណ ក៏មិនមានព្រះបច្ចេកពុទ្ធ ថ្ងៃទី ៣ ព្រះនាងនមស្ការទៅទិសបស្ចិម ក៏មិនមានព្រះបច្ចេកពុទ្ធនិមន្តមក ។ ក្នុងថ្ងៃទី ៤ ព្រះនាងនមស្ការទៅទិសឧត្តរ កាលព្រះនាងនមស្ការហើយ ក៏បាចផ្កាម្លិះ ៧ ក្តាប់ អធិដ្ឋានថា សូមព្រះបច្ចេកពុទ្ធទាំងឡាយដែលនៅក្នុងហិមវន្តប្បទេស ទិសឧត្តរ សូមនិមន្តមកទទួលភិក្ខារបស់ខ្ញុំ ។

ផ្កាម្លិះ បានអណ្តែតទៅធ្លាក់ចុះលើព្រះបច្ចេកពុទ្ធទាំងឡាយ ៥០០ អង្គត្រង់ញកភ្នំនន្ទមូលកៈ ។ ព្រះបច្ចេកពុទ្ធទាំងនោះពិចារណាក៏ដឹងថា ព្រះរាជានិមន្ត ។ ស្អែកឡើង ទើបទ្រង់ហៅព្រះបច្ចេកពុទ្ធមក ៧ អង្គ ហើយពោលថា នៃលោកនិទ្ទុក្ខ ព្រះរាជានិមន្តលោកម្ចាស់ទាំងឡាយ សូមលោកម្ចាស់ទាំងឡាយ អនុគ្រោះព្រះរាជាចុះ ។ ព្រះបច្ចេកពុទ្ធទាំងនោះហោះមកចុះត្រង់ទ្វារព្រះរាជវាំង ។ ព្រះបាទកេរុវមហារាជទតឃើញព្រះបច្ចេកពុទ្ធទាំងនោះហើយ ទ្រង់នមស្ការនិមន្តឡើងប្រាសាទ ទ្រង់ធ្វើសក្ការបូជាដោយសក្ការៈធំ ហើយថ្វាយទាន កាលព្រះបច្ចេកពុទ្ធឆាន់ស្រេចហើយ បាននិមន្តឲ្យមកឆាន់ក្នុងថ្ងៃបន្តមកទៀត របូតគ្រប់ ៦ ថ្ងៃ ក្នុងថ្ងៃទី ៧ ទ្រង់ចាត់ចែងទានបរិក្ខារគ្រប់យ៉ាង រៀបចំគ្រែដ៏វិចិត្រ ដោយកែវ ៧ ប្រការ ទ្រង់ដាក់គ្រឿងសមណ-បរិភោគទាំងពួង មានត្រៃចីវរជាដើមក្នុងសម្នាក់របស់ព្រះបច្ចេកពុទ្ធទាំង ៧ អង្គ ធ្វើនមស្ការហើយ ត្រាស់ថា បពិត្រលោកម្ចាស់ ខ្ញុំសូមថ្វាយបរិក្ខារ

ទាំងអស់នេះដល់លោកម្ចាស់ទាំងឡាយ ។ កាលព្រះបច្ចេកពុទ្ធទាំងនោះឆាន់ស្រេចហើយ ព្រះរាជា និងព្រះទេវីទាំង ២ អង្គ ប្រថាប់ឈរនមស្ការ ។

លំដាប់នោះ ព្រះបច្ចេកពុទ្ធដែលជាធំក្នុងគណៈ កាលនឹងអនុមោទនាដល់ព្រះរាជា និងព្រះទេវី ទើបពោល ២ គាថាថា

កាលបើផ្ទះត្រូវភ្លើងឆេះហើយ បុគ្គលនាំចេញនូវភាជន៍ណាទាន់
ភាជន៍នោះ រមែងបានជាប្រយោជន៍នៃបុគ្គលនោះ ភាជន៍ណា
ដែលភ្លើងឆេះក្នុងផ្ទះនោះ ភាជន៍នោះ មិនបានជាប្រយោជន៍នៃ
បុគ្គលនោះឡើយ ។

សត្វលោក កាលបើត្រូវជរា និងមរណៈឆេះយ៉ាងនេះហើយ
បុគ្គលគួរតែនាំចេញនូវទ្រព្យដោយការឲ្យទាន ( ព្រោះ ) ទ្រព្យ
ដែលបុគ្គលបានឲ្យហើយ ឈ្មោះថា នាំចេញហើយដោយប្រពៃ
ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អាទិត្តស្មឹ** សេចក្តីថា ខណៈផ្ទះភ្លើងត្រូវឆេះនោះ ។ បទថា **ភាជនំ** បានដល់ ឧបករណ៍ឯណានីមួយ ។ បទថា **នោ ច យំ តត្ថ** សេចក្តីថា របស់ណាមួយក្នុងផ្ទះនោះ មិនបានជញ្ជូនចេញ តែងត្រូវភ្លើងឆេះមិនសល់សូម្បីត្រឹមតែស្មៅ វត្ថុទាំងអស់នោះ រមែងមិនជាគុណប្រយោជន៍ដល់បុគ្គលនោះឡើយ ។ បទថា **ជរាយ មរណេន ច** នេះ ត្រឹមតែជាមាតិកាទេសនា ។ តែដោយអត្ថ ឈ្មោះថា ត្រូវភ្លើង ១១ កងដុតហើយ ។ បទថា **ទីហរេថេវ** សេចក្តីថា បុគ្គលគប្បីនាំបរិក្ខារទាននោះៗ

មានទានវត្ថុ ១០ យ៉ាងជាដើម ចេញអំពីលោក ដែលត្រូវភ្លើង ១១ កងដុត នោះដោយចេតនា ។ ទានដែលឲ្យហើយ ទោះតិច ឬច្រើនក៏ដោយ ឈ្មោះថា ជាការនាំចេញល្អហើយ ។

ព្រះសង្ឃត្ថេរ អនុមោទនាយ៉ាងនេះហើយ បានឲ្យឱវាទដល់ព្រះរាជាថា បពិត្រមហារាជ ទ្រង់កុំប្រមាទ ហើយហោះឡើងទៅលើអាកាស ធ្វើហោជាងប្រាសាទឲ្យរហែកជា ២ ចំណែក ហើយទៅកាន់ញកភ្នំនន្ទមូលកៈ ។ បរិក្ខារដែលព្រះរាជាថ្វាយដល់ព្រះបច្ចេកពុទ្ធ អណ្តែតតាមក្រោយព្រះបច្ចេក-ពុទ្ធ ទៅចុះត្រង់ញកភ្នំនោះដូចគ្នា ។ សកលកាយរបស់ព្រះរាជា និងព្រះទេវី ពេញទៅដោយបីតិ ។ កាលព្រះបច្ចេកពុទ្ធជាធំក្នុងគណៈនិមន្តទៅយ៉ាងនេះហើយ ព្រះបច្ចេកពុទ្ធដែលនៅសល់ ៦ អង្គ បានអនុមោទនាដោយគាថាមួយអង្គ ១ គាថាថា

សត្វណា បានឲ្យទានដល់បុគ្គលអ្នកបានធម៌ បានត្រាស់ដឹងធម៌
ដោយសេចក្តីព្យាយាម គឺការប្រឹងប្រែង សត្វនោះ រមែងប្រព្រឹត្ត
កន្លងនូវវេតរណីរបស់យមៈ ( នរក ) បាន ហើយចូលទៅ
កាន់ទីទាំងឡាយជាទិព្វ ។

អ្នកប្រាជ្ញទាំងឡាយពោលថា ទាន និងចម្បាំង ជារបស់ស្មើគ្នា
ពួកជនសូម្បីតិចគ្នា តែជាអ្នកស៊ូលះបង់ជីវិត រមែងឈ្នះជនច្រើន
នាក់បាន បុគ្គលណា កាលបើជឿហើយ ឲ្យទាន សូម្បីបន្តិច
បន្តួច បុគ្គលនោះ រមែងបាននូវសេចក្តីសុខក្នុងលោកខាងមុខ

ដោយទេយ្យវត្ថុមានប្រមាណតិចនោះ ។

ការពិចារណាសិនហើយទើបឲ្យ ព្រះសុគតទ្រង់សរសើរហើយ ពួកទក្ខិណេយ្យបុគ្គលណា មាននៅក្នុងជីវលោកនេះ ទានដែលបុគ្គលឲ្យហើយ ដល់ពួកទក្ខិណេយ្យបុគ្គលនុ៎ះ មានផលច្រើន ដូចជាពូជដែលគេសាបព្រោះ ក្នុងស្រែដ៏ល្អ ។

បុគ្គលណា មិនបៀតបៀននូវពួកសត្វ មិនធ្វើនូវបាប ព្រោះ ( ខ្លាច ) ការតិះដៀលអំពីអ្នកដទៃ អ្នកប្រាជ្ញទាំងឡាយ តែងសរសើរនូវបុគ្គលអ្នកខ្លាចបាប មិនសរសើរនូវបុគ្គលអ្នកក្លៀវក្លាក្នុងការធ្វើបាបនោះឡើយ ដ្បិតសប្បុរសទាំងឡាយ តែងមិនធ្វើបាប ព្រោះខ្លាច ( ពាក្យជំណេះជំនៀលនោះ ) ។

បុគ្គលចូលទៅកើតក្នុងពួកក្សត្រិយ៍ ដោយព្រហ្មចរិយធម៌ដ៏ថោកទាប បុគ្គលចូលទៅកាន់ភាពជាទេវតា ដោយព្រហ្មចរិយធម៌យ៉ាងកណ្តាល បុគ្គលបរិសុទ្ធដោយព្រហ្មចរិយធម៌ដ៏ឧត្តម ។

ការឲ្យទាន ពិតជាអ្នកប្រាជ្ញសរសើរដោយចំណែកច្រើន ក៏មែនហើយ តែថា ចំណែកធម៌ប៉ុណ្ណោះ ប្រសើរជាងទាន ព្រោះពួកសប្បុរសអ្នកមានប្រាជ្ញាក្នុងកាលមុន និងកាលមុនទៅទៀត បានត្រាស់ដឹងនូវនិព្វានធម៌ ដូច្នេះ ។

កាលអនុមោទនាយ៉ាងនេះហើយ ក៏ហោះទៅយ៉ាងនោះឯង មួយអន្លើដោយបរិក្ខារទាំងឡាយ ។

បណ្តាបទទាំងនោះ បទថា **ធម្មលទ្ធស្ស** សេចក្តីថា បុគ្គល មានព្រះវីណាស្រពជាដើម រហូតដល់ព្រះយោគាវចរដែលជាសុក្ខវិបស្សកៈ ឈ្មោះថា **ធម្មលទ្ធ** ព្រោះភាពជាអ្នកមានធម៌បានសម្រេចហើយ ។ បុគ្គលប្រភេទនោះឯង ឈ្មោះថា **ឧដ្ឋានវីរិយាធិគត** ព្រោះសម្រេចធម៌នោះ ដោយសេចក្តីព្យាយាម គឺប្រឹងប្រែង ។ អធិប្បាយថា បុគ្គលណា ឲ្យទានដល់បុគ្គលដែលសម្រេចធម្មវិសេសហើយនោះ ។ ន័យម្យ៉ាងទៀត មានអធិប្បាយថា បុគ្គលណា កាន់យកចំណែកដ៏ប្រសើរនៃទេយ្យធម៌ ដែលខ្លួនបានហើយដោយធម៌ គឺបានមកដោយសេចក្តីព្យាយាម ពោល គឺការប្រឹងប្រែង ហើយឲ្យទានក្នុងបុគ្គលអ្នកមានសីលទាំងឡាយ ។ ម្យ៉ាងទៀត សេចក្តីក្នុងគាថានេះបណ្ឌិតគប្បីជ្រាបដោយធ្វើឆដ្ឋីវិភត្តិ ឲ្យជាទុតិយា ។ បទថា **វេតរណឹ** នេះ ជាមាតិកានៃទេសនា ។ អធិប្បាយថា ព្រះវីណាស្រព រហូតដល់ព្រះសុក្ខ-វិបស្សកៈ កន្លងនូវមហានរក ៨ ឧស្សទនរក ១៦ នៃស្តេចយមបានហើយ ។ បទថា **ទិព្វានិ ឋានានិ ឧបេតិ** សេចក្តីថា រមែងទៅកើតក្នុងទេវលោក ។ បទថា **សមានមាហុ** សេចក្តីថា អ្នកប្រាជ្ញពោលថា ដូចគ្នា អធិប្បាយថា អ្នកខ្លាចនូវការអស់ រមែងមិនមានការឲ្យ អ្នកខ្លាចចំពោះភ័យ រមែងមិនមានការតយុទ្ធ គឺអ្នកចម្បាំង លះនូវសេចក្តីអាល័យក្នុងជីវិតបាន ក៏អាចច្បាំងគ្នាបាន ទាយកលះសេចក្តីអាល័យក្នុងភោគៈចេញបាន ក៏អាចបរិច្ចាគបាន ដោយហេតុនោះឯង ទើបអ្នកប្រាជ្ញពោលទាន និងចម្បាំងទាំង ២ នោះ ថាមានសភាពស្មើគ្នា ។ បទថា **អប្បាបិ សន្តា** សេចក្តីថា អ្នកចម្បាំង ទោះបី

មានបក្ខពួកតិច តែស្មគ្រចិត្តលះបង់ជីវិត ក៏អាចផ្ចាញ់បុគ្គលដែលមានគ្នាច្រើន យកជ័យជម្នះបាន យ៉ាងណា ចេតនាគិតបរិច្ចាគ ទោះបីមានតិច ក៏រមែងឈ្នះពួកកិលេសសូម្បីមានច្រើន មានមច្ឆរិយចិត្ត និងលោភៈជាដើមបាន ដូច្នោះ ។ បទថា **អប្បម្បិ ចេ** សេចក្តីថា បើទាយកជឿកម្ម ជឿផលនៃកម្ម រមែងបរិច្ចាគទេយ្យធម៌ សូម្បីតិចតួចបាន ។ បទថា **តេនេវ សោ** សេចក្តីថា មហាបពិត្រ ទាយកនោះ រមែងជាសុខក្នុងលោកខាងមុខ ដោយទេយ្យធម៌តិចតួចនោះ គឺបរិច្ចាគសូម្បីតិចតួច ។ បទថា **វិចេយ្យ ទានំ** បានដល់ ទានដែលបុគ្គលជ្រើសរើសទក្ខិណាទាន និងទក្ខិណេយ្យបុគ្គលសិនហើយ ទើបថ្វាយ ។ ក្នុងទក្ខិណាទាន និងទក្ខិណេយ្យបុគ្គល ២ យ៉ាងនោះ កាលបុគ្គលមិនឲ្យរបស់តាមមានតាមបាន ជ្រើសរើសឲ្យតែទេយ្យធម៌ដ៏ប្រសើរដ៏ប្រណីត ឈ្មោះថា រមែងជ្រើសរើសឲ្យនូវទក្ខិណាទាន កាលមិនឲ្យដល់បុគ្គលទូទៅ ជ្រើសរើសឲ្យតែបុគ្គលដែលសម្បូរដោយគុណធម៌ មានសីលជាដើម ឈ្មោះថា រមែងជ្រើសរើសតែទក្ខិណេយ្យបុគ្គល ។ បទថា **សុគតប្បសត្ថំ** សេចក្តីថា ទានបែបនេះ សូម្បីព្រះពុទ្ធទាំងឡាយ ក៏ទ្រង់សរសើរ ។

ក្នុង ២ យ៉ាងនោះ កាលនឹងសម្តែងដល់ការជ្រើសរើសទក្ខិណេយ្យ-បុគ្គល ទើបលោកពោលពាក្យជាដើមថា **យេ ទក្ខិណេយ្យា** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ទក្ខិណេយ្យា** បានដល់ ព្រះអរិយបុគ្គលទាំងឡាយ មានព្រះពុទ្ធជាដើម ជាអ្នកគួរដល់ទក្ខិណា ។ បទថា **ធាណភូតានិ** បានដល់ វត្ថុមានជីវិត ពោល គឺសត្វដែលមានជីវិតទាំងឡាយ ។

បទថា **អហោឋយំ ចរំ** សេចក្តីថា មានសេចក្តីករុណា មិនបៀតបៀនសត្វឲ្យក្តៅក្រហាយគ្រាប់ទៅ ។ បទថា **បរូបឃាតា** សេចក្តីថា មិនធ្វើបាប ព្រោះខ្លាចអ្នកដទៃតិះដៀល ។ បទថា **ភីរុំ** បានដល់ ដែលខ្លាចនូវការតិះដៀល ។ បទថា **ន តត្ថ សូរំ** សេចក្តីថា ឯបុគ្គលណាមិនខ្លាចការតិះដៀលនោះ ទើបហ៊ានធ្វើបាបកម្មដោយអយោនិសោមនសិការ បណ្ឌិតទាំងឡាយ រមែងមិនសរសើរបុគ្គលនោះៗ ទេ ។ បទថា **ភយា ហិ** សេចក្តីថា ព្រោះថា បណ្ឌិតទាំងឡាយ រមែងមិនធ្វើបាប ព្រោះខ្លាចការតិះដៀល ។ បទថា **ហីនេន ព្រហ្មចរិយេន** សេចក្តីថា នឹងពោលក្នុងលទ្ធិខាងក្រៅសាសនាជាមុនសិន ផលត្រឹមតែមេថុនវិរតិ និងសីល ឈ្មោះថា ព្រហ្មចរិយៈថ្នាក់ទាប បុគ្គលកើតក្នុងខត្តិយត្រកូល ដោយអំណាចព្រហ្មចរិយៈដ៏តូចតាចនោះ ។ ផលត្រឹមឧបចារជ្ឈាន ឈ្មោះថា ព្រហ្មចរិយៈយ៉ាងកណ្តាល បុគ្គលកើតក្នុងទេវលោកដោយព្រហ្មចរិយៈយ៉ាងកណ្តាលនោះ ។ សមាបត្តិ ៨ ជាព្រហ្មចរិយៈយ៉ាងខ្ពស់ បុគ្គលចូលដល់ព្រហ្មលោក ដោយព្រហ្មចរិយៈយ៉ាងខ្ពស់នោះ ឈ្មោះថា រមែងបរិសុទ្ធ ។ ឯក្នុងផ្លូវពុទ្ធសាសនា ការប្រព្រឹត្តព្រហ្មចរិយៈដោយប្រាថ្នាទេវនិកាយរបស់បុគ្គលអ្នកមានសីលនោះឯង ឈ្មោះថា ជាព្រហ្មចរិយៈយ៉ាងទាប ការញុំាងសមាបត្តិឲ្យកើតឡើងនៃអ្នកមានសីលបរិសុទ្ធនោះឯង ឈ្មោះថា ព្រហ្មចរិយៈយ៉ាងកណ្តាល ការដែលភិក្ខុតាំងនៅក្នុងបារិសុទ្ធិសីល ចម្រើនវិបស្សនា ហើយសម្រេចអរហត្ត ឈ្មោះថា ព្រហ្មចរិយៈយ៉ាងខ្ពស់ ។

គាថាចុងក្រោយ មានអធិប្បាយដូច្នេះថា មហាបពិត្រ មានអ្នកសរសើរ គឺលើកតម្កើងទ្រង់ដោយចំណែកច្រើនក៏ពិត តែធម្មបទដែលជាចំណែកនៃធម៌ ពោល គឺសមថវិបស្សនាក្តី ពោល គឺព្រះនិព្វានក្តី ប្រសើរជាងទាន ។ ព្រោះហេតុអ្វី ព្រោះថា សប្បុរសទាំងឡាយក្នុងកាលមុន គឺក្នុងកទ្ទុកប្បនេះ មានព្រះកស្សបទសពលជាដើម ឬក្នុងកាលមុននោះទៀត មានព្រះវេស្សភូទសពលជាដើម ទ្រង់មានបញ្ញា ចម្រើនសមថវិបស្សនា បានសម្រេចដល់ព្រះនិព្វាននោះឯង ។

ព្រះបច្ចេកពុទ្ធ ៧ អង្គ ពណ៌នាអមតមហានិព្វានដល់ព្រះរាជា ដោយអនុមោទនាគាថាយ៉ាងនេះហើយ ពោលទូន្មានព្រះរាជាដោយអប្បមាទធម៌ ក៏ទៅកាន់លំនៅរៀងៗ ខ្លួន តាមន័យដូចពោលហើយនោះឯង ។ ព្រះរាជាមួយអន្លើដោយអគ្គមហេសី បានថ្វាយទានដរាបដល់អស់ព្រះជន្ម លុះឃ្លាតចាកអត្តភាពនោះហើយ ក៏បានទៅកាន់ស្ថានសួគ៌ ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកសម្តែងហើយ ត្រាស់ថា ទោះក្នុងកាលមុន បណ្ឌិតក៏បានជ្រើសរើសក្នុងការថ្វាយទាន ដោយប្រការដូច្នេះ ហើយទ្រង់ប្រជុំជាតកថា ព្រះបច្ចេកទាំងឡាយក្នុងកាលនោះបរិនិព្វានហើយ ព្រះនាងសមុទ្ទវិជយាទេវីក្នុងកាលនោះ បានមកជារាហុលមាតា ព្រះបាទភេរុវៈក្នុងកាលនោះ គឺតថាគតនេះឯង ។៙

**អដ្ឋកថា អាទិត្តជាតក ចប់**

# សុត្តន្តបិដក

## អដ្ឋានជាតក

[ ៤៨៦ ] ( មហាធនតាបសនិយាយថា ) ក្នុងកាលណាទន្លេគង្គាប្រែជាមានផ្កាកុមុទ ទាំងមានទឹកនឹង សត្វតាវ៉ៅប្រែជាមានសម្បុរដូចស័ង្ខ ដើមព្រីងប្រែជាបញ្ចេញផ្លែត្នោត កាលបើយ៉ាងនេះ ទើប ( យើង និងនាង ) បានជួបគ្នាក្នុងកាលនោះដោយពិត ។

[ ៤៨៧ ] ក្នុងកាលណាសំពត់បាវ៉ារ ៣ យ៉ាង គឺសំពត់ដែលធ្វើដោយផ្កាស្រកាអណ្តើក ១ សំពត់ដែលធ្វើដោយប៉ុយ ១ សំពត់ដែលធ្វើដោយលាយគ្នា ទាំងពីរមុខ ១ ប្រែជាសំពត់សម្រាប់ដណ្តប់ក្នុងរដូវរងាបាន កាលបើយ៉ាងនេះ ទើប( យើង និង នាង ) បានជួបគ្នាក្នុងកាលនោះដោយពិត ។

[ ៤៨៨ ] ក្នុងកាលណា គេយកជើងសត្វមូសទាំងឡាយ មកធ្វើជាសើនយ៉ាងល្អឲ្យមាំ មិនឲ្យកក្រើកបាន កាលបើយ៉ាងនេះ ទើប ( យើង និងនាង ) បានជួបគ្នាក្នុងកាលនោះដោយពិត ។

[ ៤៨៩ ] ក្នុងកាលណា គេយកស្នែងទន្សាយ មកធ្វើជាបង្អោងសម្រាប់ឡើងកាន់ឋានសួគ៌បាន កាលបើយ៉ាងនេះ ទើប ( យើង និងនាង ) បានជួបគ្នាក្នុងកាលនោះដោយពិត ។

[ ៤៩០ ]ក្នុងកាលណា ពួកកណ្តុរឡើងតាមបង្អោង ទៅទំពាស៊ីនូវដួងព្រះចន្ទ ទាំងដេញរាហូឲ្យរត់ទៅបាន កាលបើយ៉ាងនេះ

ទើប ( យើង និងនាង ) បានជួបគ្នាក្នុងកាលនោះដោយពិត ។

[ ៤៩១ ] ក្នុងកាលណា ពួករុយហើរទៅទាំងហ្វូង ក្រេបផឹកនូវសុរាក្នុងក្អម ហើយសម្រេចការនៅក្នុងរងើកភ្លើងបាន កាលបើយ៉ាងនេះ ទើប ( យើង និងនាង ) បានជួបគ្នាក្នុងកាលនោះដោយពិត ។

[ ៤៩២ ] ក្នុងកាលណា សត្វលាមានបបូរមាត់ដ៏រលើងល្អ មានមុខដ៏ល្អជាសត្វឈ្លាសវៃ ក្នុងការរាំ និងការច្រៀងបាន កាលបើយ៉ាងនេះ ទើប ( យើង និងនាង ) បានជួបគ្នាក្នុងកាលនោះដោយពិត ។

[ ៤៩៣ ] ក្នុងកាលណា ពួកក្អែក និងមៀម នាំគ្នាទៅក្នុងទីស្ងាត់ ហើយគប្បីប្រឹក្សាគ្នា គប្បីស្រឡាញ់គ្នាទៅវិញទៅមកបាន កាលបើយ៉ាងនេះ ទើប ( យើង និងនាង ) បានជួបគ្នាក្នុងកាលនោះដោយពិត ។

[ ៤៩៤ ] ក្នុងកាលណា ស្លឹកឈូកទាំងឡាយ បែរទៅជាឆ័ត្រយ៉ាងមាំ ដើម្បីការពារភ្លៀងបាន កាលបើយ៉ាងនេះ ទើប ( យើង និងនាង ) បានជួបគ្នាក្នុងកាលនោះដោយពិត ។

[ ៤៩៥ ] ក្នុងកាលណា សត្វបក្សីតូចឈ្មោះកុលកៈ ពាំក្ដាំគន្ធ-មាទន៍ដោយចំពុះបាន កាលបើយ៉ាងនេះ ទើប ( យើង និង នាង ) បានជួបគ្នាក្នុងកាលនោះដោយពិត ។

[ ៤៩៦ ] ក្នុងកាលណា កូនក្មេងតូច អាចកាន់យកសំពៅ សម្រាប់ដើរសមុទ្រ ព្រមទាំងគ្រឿងយន្ត និងចង្កូតទៅបាន កាល បើយ៉ាងនេះ ទើប ( យើង និងនាង ) បានជួបគ្នាក្នុងកាល នោះដោយពិត ។

អដ្ឋានជាតកទី ៩ ចប់

# អដ្ឋកថា

## អដ្ឋានជាតក

[ ៤៨៦-៤៩៦ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអផ្សុកមួយរូប ទើបត្រាស់រឿងនេះ មានពាក្យផ្តើមថា **គង្គា កុមុទិនី** ដូច្នេះជាដើម ។

ព្រះសាស្តាត្រាស់សួរភិក្ខុនោះថា ម្នាលភិក្ខុ បានឮថា អ្នកអផ្សុកពិតឬ កាលភិក្ខុនោះក្រាបទូលថា ករុណាព្រះអង្គ ពិតមែន ទើបត្រាស់សួរថា អ្នកអផ្សុកព្រោះហេតុអ្វី កាលភិក្ខុនោះក្រាបទូលថា ព្រោះអំណាចកិលេស ទើបត្រាស់ថា ម្នាលភិក្ខុ ឈ្មោះថា មាតុគ្រាម ជាអកតញ្ញូ ជាអ្នកទ្រុស្តមិត្ត មិនគួរដាក់ចិត្ត បណ្ឌិតទាំងឡាយក្នុងកាលមុន សូម្បីឲ្យទ្រព្យមួយថ្ងៃ ១០០០ ក៏មិនអាចឲ្យមាតុគ្រាមត្រេកអរបាន ស្រីនោះមិនបានទ្រព្យ ១០០០ តែមួយថ្ងៃប៉ុណ្ណោះ ក៏បានឲ្យមនុស្សអូស-កបណ្ឌិតនោះចេញទៅ មាតុគ្រាមមិនដឹងគុណយ៉ាងនេះ អ្នកកុំធ្លាក់ក្នុងអំណាចកិលេស ព្រោះមាតុគ្រាមនោះឡើយ ដូច្នេះហើយ ទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះរាជឱរសរបស់ព្រះអង្គព្រះនាមព្រហ្មទត្តកុមារ និងបុត្ររបស់សេដ្ឋីម្នាក់ក្នុងនគរពារាណសីឈ្មោះមហាធនកុមារ កុមារទាំង ២ ជាសម្លាញ់នឹងគ្នាតាំងពីនៅតូចៗ រៀនសិប្បៈក្នុងត្រកូលអាចារ្យជាមួយគ្នា ។ ព្រហ្មទត្តកុមារបានគ្រងរាជសម្បត្តិ ក្នុងកាលដែលព្រះបិតាសោយទិវង្គតទៅ ។ កូនសេដ្ឋីបាននៅក្នុងរាជសម្នាក់នោះឯង ។ ក្នុងនគរពារាណសី មានវណ្ណទាសីម្នាក់

ជាស្រីធ្វើឲ្យនគរស្អាត មានរូបរាងល្អត្រកាលពន់ពេក សេដ្ឋីបុត្តបានឲ្យទ្រព្យមួយថ្ងៃ ១០០០ អភិរមជាមួយស្រីនោះសព្វកាល សូម្បីបានតំណែងសេដ្ឋីកាលបិតាអនិច្ចកម្មហើយ ក៏មិនបោះបង់ស្រីនោះ នៅតែឲ្យទ្រព្យមួយថ្ងៃ ១០០០ ហើយអភិរមនោះឯង ។

សេដ្ឋីបុត្រចូលគាល់ព្រះរាជាមួយថ្ងៃ ៣ ដង ។ ថ្ងៃមួយ សេដ្ឋីបុត្រចូលគាល់ព្រះរាជាក្នុងវេលាល្ងាច ប្រាស្រ័យជាមួយព្រះរាជារហូតព្រលប់ ក៏ចេញចាករាជសម្នាក់ គិតថា ឥឡូវនេះ បើអញទៅផ្ទះ ហើយមករកស្រីនគរសោភិនី ពេលវេលាក៏មិនគ្រប់គ្រាន់ អញនឹងទៅផ្ទះស្រីនគរសោភិនីតែម្តងចុះ ហើយបញ្ជូនអ្នកបម្រើឲ្យទៅផ្ទះម្នាក់ឯងប៉ុណ្ណោះ ទៅផ្ទះរបស់ស្រីនគរសោភនី ។ លំដាប់នោះ ស្រីនគរសោភិនីឃើញសេដ្ឋីបុត្រហើយ ពោលថា នែអយ្យបុត្រ អ្នកនាំទ្រព្យ ១០០០ ឬមកដៃទទេ សេដ្ឋីបុត្រពោលថា នែនាងថ្ងៃនេះ ខ្ញុំជ្រុលពេល ព្រោះដូច្នោះ ទើបមិនបានទៅផ្ទះ បញ្ជូនតែអ្នកបម្រើទៅខ្ញុំមកតែម្នាក់ឯង តែថ្ងៃស្អែកនេះ យើងនឹងឲ្យទ្រព្យដល់នាង ២០០០ ។ ស្រីនោះគិតថា បើថ្ងៃនេះអញឲ្យឱកាសសូម្បីថ្ងៃដទៃៗ ក៏នឹងមកដៃទទេទៀត កាលបើដូច្នេះ អញនឹងសាបសូន្យចាកទ្រព្យ អញនឹងមិនឲ្យឱកាសដល់សេដ្ឋីនេះ ។ គិតដូច្នេះហើយ ទើបពោលនឹងសេដ្ឋីបុត្រថា នែអ្នក ពួកយើង ឈ្មោះថា វណ្ណទាសី នឹងឲ្យលេងសើចទទេៗ នោះមិនមាន ចូរអ្នកទៅនាំទ្រព្យ ១០០០ មក ។ សេដ្ឋីបុត្របានសំណូមពរហើយសំណូមពរទៀតថា នែនាងស្អែកនេះ ខ្ញុំនឹងនាំមកឲ្យ ២ ដង ។ ស្រីនគរសោភិនីបង្គាប់ពួកទាសីថា ពួក

នាងកុំឲ្យសេដ្ឋីនេះ មកឈរមើលក្នុងទីនេះ ចូរអូសកគេចេញទៅ ហើយបិទទ្វារ ។ ពួកទាសីបានធ្វើយ៉ាងនោះ ។

សេដ្ឋីនោះគិតថា អញបានឲ្យទ្រព្យដល់ស្រីនេះដល់ទៅ ៨០ កោដិ គ្រាន់តែនាងឃើញអញមានដៃទទេត្រឹមតែមួយថ្ងៃ ក៏ឲ្យអូសកអញចេញទៅ ឱ ! ឈ្មោះថា មាតុគ្រាមជារបស់លាមក មិនមានខ្មាស ជាអកតញ្ញូ ទ្រុស្ត-មិត្រ គិតដូច្នេះ ក៏ឃើញទោសរបស់មាតុគ្រាម ទើបប្រាសចាកតម្រេក បាននូវបដិកូលសញ្ញា នឿយណាយក្នុងឃរាវាស គិតថា ការនៅគ្រប់គ្រងផ្ទះមានប្រយោជន៍អ្វីដល់អញ អញនឹងចេញបួសក្នុងថ្ងៃនេះឯង មិនទៅផ្ទះ និងមិនគាល់ព្រះរាជាទៀតឡើយ ចេញអំពីនគរ ចូលព្រៃ បួសជាឥសី សាងអាស្រមនៅត្រង់ច្នេរស្ទឹងគង្គា ធ្វើឈានអភិញ្ញាឲ្យកើតឡើង មានត្រាវ និងដំឡូង ផ្លៃឈើព្រៃជាអាហារ នៅក្នុងទីនោះ ។

កាលព្រះបាទព្រហ្មទត្ត មិនឃើញមហាធនសេដ្ឋីចូលគាល់ ទើបត្រាស់សួរថា សម្លាញ់យើងទៅឯណា សូម្បីដំណឹងក្នុងការធ្វើរបស់ស្រីនគរសោភិនី ក៏បានល្បីខ្ចរខ្ចាយទៅពេញព្រះនគរ ។ លំដាប់នោះ ពួករាជបុរសបានក្រាបទូលនូវសេចក្តីនោះដល់ព្រះរាជាថា បពិត្រព្រះសម្មតិទេព សម្លាញ់របស់ទ្រង់មានការខ្មាស មិនត្រឡប់ទៅផ្ទះ ចូលព្រៃបួសហើយ ព្រះរាជាត្រាស់ឲ្យហៅស្រីនគរសោភិនីមកហើយ ត្រាស់សួរថា បានឮថា នាងមិនបានទ្រព្យ ១០០០ មួយថ្ងៃប៉ុណ្ណោះ ក៏ឲ្យពួកទាសីអូស-កសម្លាញ់យើងចេញទៅ ពិតឬ ស្រីនោះក៏ទទួលថា ព្រះមេខ្ញុំម្ចាស់ ព្រះរាជាត្រាស់ថា នែស្រីលាមក ចូរហែងទៅកាន់

ទីដែលសម្លាញ់អញទៅ ហើយនាំគេមក បើនាំមកមិនបាន ហងត្រូវស្លាប់ ។ នាងបានស្តាប់ព្រះរាជតម្រាស់ដូច្នោះ មានសេចក្តីខ្លាច ទើបឡើងរថចេញអំពីព្រះនគរទៅ មួយអន្លើដោយបរិវារច្រើន ហើយត្រាស់ស្វែងរកទីលំនៅរបស់ឥសីនោះ បានដឹងដំណឹងថា នៅក្នុងទីឈ្មោះនោះ ក៏បានទៅក្នុងទីនោះ នមស្ការហើយ អង្វរថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់អត់ទោសដល់ខ្ញុំ ដែលធ្វើដោយភាពជាអន្ធពាល ខ្ញុំនឹងមិនធ្វើយ៉ាងនោះទៀតទេ កាលឥសីពោលថា សាធុ យើងនឹងអត់ទោសឲ្យ យើងមិនមានអាឃាតក្នុងនាង ទើបនាងពោលថា បើលោកម្ចាស់អត់ទោសឲ្យខ្ញុំ សូមឡើងរថទៅកាន់នគរជាមួយខ្ញុំចុះ លុះដល់ព្រះនគរហើយ ខ្ញុំនឹងប្រគេនវត្ថុគ្រប់យ៉ាង ដែលមានក្នុងផ្ទះរបស់ខ្ញុំ ។ ឥសីបានស្តាប់ពាក្យរបស់នាងហើយ ពោលថា នែប្អូនស្រី ឥឡូវនេះ យើងមិនអាចទៅជាមួយនាង កាលណាទ្រព្យណាក្នុងលោកនេះ មិនគប្បីមានរបស់នឹងមាន កាលនោះឯង យើងគប្បីទៅជាមួយនាង ហើយពោលគាថាទី ១ ថា

> ក្នុងកាលណា ទន្លេគង្គាប្រែរជាមានផ្កាកុមុទ ទាំងមានទឹកនឹង
> សត្វតាវៅប្រែរជាមានសម្បុរដូចស័ង្ខ ដើមព្រីងប្រែរជាបញ្ចេញ
> ផ្លែត្នោត កាលបើយ៉ាងនេះ ទើប ( យើង និងនាង ) បានជួប
> គ្នាក្នុងកាលនោះដោយពិត ដូច្នេះ ។

គាថានោះមានអធិប្បាយដូច្នេះថា នែនាងដ៏ចម្រើន ក្នុងកាលណា ស្ទឹងមហាគង្គាទាំងអស់ មានគុម្ពកុមុទ ហើយមហានទី ដែលមានខ្សែទឹកហូរខ្ជួលខ្លាញ់ ស្ងប់មិនកម្រើក ដូចស្រះកុមុទ ដេរដាសទៅដោយផ្កាកុមុទ តាំងនៅក្តី

សត្វតាវ៉ៅទាំងអស់ មានពណ៌សដូចសង្ខ័ក្តី ម្យ៉ាងទៀត ដើមព្រីងទាំងអស់ មានផ្លែជាផ្លែត្នោតក្តី ។

បទថា **អថ នូន តទា សិយា** មានអធិប្បាយថា កាលនោះ គឺក្នុងវេលានោះ យើងទាំងពីរ គប្បីនៅរួមគ្នាបានពិត ។

កាលឥសីពោលយ៉ាងនេះហើយ នាងពោលទៀតថា និមន្តលោកម្ចាស់មកក្នុងឥឡូវនេះចុះ ទើបពោលថា អាត្មានឹងទៅ កាលនាងសួរថា លោកម្ចាស់ទៅទីណា ឥសីពោលថា នឹងទៅទីឈ្មោះនោះ ពេលនោះ ដូច្នេះហើយ បានពោលគាថាដ៏សេសថា

> ក្នុងកាលណា សំពត់បាវារ ៣ យ៉ាង គឺសំពត់ដែលធ្វើដោយផ្កាស្រកាអណ្តើក ១ សំពត់ដែលធ្វើដោយប៉ុយ ១ សំពត់ដែលធ្វើដោយលាយគ្នាទាំងពីរមុខ ១ ប្រែជាសំពត់សម្រាប់ដណ្តប់ក្នុងរដូវរងាបាន កាលបើយ៉ាងនេះ ទើប ( យើង និងនាង ) បានជួបគ្នាក្នុងកាលនោះដោយពិត ។
>
> ក្នុងកាលណា គេយកជើងសត្វមូសទាំងឡាយ មកធ្វើជាសើនយ៉ាងល្អឲ្យមាំ មិនឲ្យកក្រើកបាន កាលបើយ៉ាងនេះ ទើប ( យើង និងនាង ) បានជួបគ្នាក្នុងកាលនោះដោយពិត ។
>
> ក្នុងកាលណា គេយកស្នែងទន្សាយ មកធ្វើជាបង្អោង សម្រាប់ឡើងកាន់ឋានសួគ៌បាន កាលបើយ៉ាងនេះ ទើប ( យើង និងនាង ) បានជួបគ្នាក្នុងកាលនោះដោយពិត ។

ក្នុងកាលណា ពួកកណ្ដុរឡើងតាមបង្អោង ទៅទំពាស៊ីនូវដួងព្រះចន្ទ ទាំងដេញរាហូឲ្យរត់ទៅបាន កាលបើយ៉ាងនេះ ទើប ( យើងនិងនាង ) បានជួបគ្នាក្នុងកាលនោះដោយពិត ។

ក្នុងកាលណា ពួករុយហើរទៅទាំងហ្វូង ក្រេបផឹកនូវសុរាក្នុងក្អម ហើយសម្រេចការនៅក្នុងរងើកភ្លើងបាន កាលបើយ៉ាងនេះ ទើប ( យើង និងនាង ) បានជួបគ្នាក្នុងកាលនោះដោយពិត ។

ក្នុងកាលណា សត្វលាមានបបូរមាត់ដ៏រលើងល្អ មានមុខដ៏ល្អ ជាសត្វឈ្លាសវៃក្នុងការរាំ និងការច្រៀងបាន កាលបើយ៉ាងនេះ ទើប ( យើង និងនាង ) បានជួបគ្នាក្នុងកាលនោះដោយពិត ។

ក្នុងកាលណា ពួកក្អែក និងមៀម នាំគ្នាទៅក្នុងទីស្ងាត់ ហើយគប្បីប្រឹក្សាគ្នា គប្បីស្រឡាញ់គ្នាទៅវិញទៅមកបាន កាលបើយ៉ាងនេះ ទើប ( យើង និងនាង ) បានជួបគ្នាក្នុងកាលនោះដោយពិត ។

ក្នុងកាលណា ស្លឹកឈូកទាំងឡាយ ប្រែទៅជាឆត្រយ៉ាងមាំ ដើម្បីការពារភ្លៀងបាន កាលបើយ៉ាងនេះ ទើប ( យើង និងនាង ) បានជួបគ្នាក្នុងកាលនោះដោយពិត ។

ក្នុងកាលណា សត្វបក្សីតូចឈ្មោះកុលកៈ ពាំភ្នំគន្ធមាទន៍ដោយចំពុះបាន កាលបើយ៉ាងនេះ ទើប ( យើង និងនាង ) បានជួបគ្នាក្នុងកាលនោះដោយពិត ។

ក្នុងកាលណា កូនក្មេងតូច អាចកាន់យកសំពៅ សម្រាប់ដើរសមុទ្រ ព្រមទាំងគ្រឿងយន្ត និងចក្តូតទៅបាន កាលបើយ៉ាងនេះ ទើប ( យើង និងនាង ) បានជួបគ្នាក្នុងកាលនោះដោយពិត ។

បណ្តាបទទាំងនោះ បទថា **តិវិធោ** បានដល់ សំពត់ ៣ ប្រភេទយ៉ាងនេះ គឺសំពត់ធ្វើដោយផ្កា ១ សំពត់ធ្វើដោយសំឡី ១ សំពត់ធ្វើដោយរបស់ ២ យ៉ាង រួមចូលគ្នា ១ គប្បីធ្វើឲ្យសម្រេចបានដោយរោមអណ្តើក ( ប្រើរោមអណ្តើកធ្វើជំនួស ) ។ បទថា **ហេមន្តិកំ ចាវុរណំ** សេចក្តីថា អាចប្រើជាគ្រឿងដណ្តប់ការពាររងាក្នុងគ្រាសន្សើមធ្លាក់បាន ។ បទថា **អថ នូន តទា សិយា** សេចក្តីថា កាលនោះ គឺក្នុងកាលនោះ យើងគប្បីនៅរួមគ្នា ជាមួយនាងបានដោយចំណែកមួយ ។

ដោយវិធីនេះ បណ្ឌិតគប្បីយកបទខាងក្រោយ ប្រកបចូលគ្រប់បទផងចុះ ។ បទថា **អដ្ដាលោ សុការោ** សេចក្តីថា ក្នុងកាលណាជើងមូសទាំងឡាយ ត្រូវគេយកធ្វើជាប៉ម ដែលរឹងមាំមិនញាប់ញ័រ ទ្រទ្រង់នូវបុរស ១០០ នាក់ ដែលឡើងច្បាំងបាន ។ បទថា **បរិចារេយ្យុំ** បានដល់ ដេញឲ្យគេចទៅ ។ បទថា **អង្គារេ** បានដល់ ក្នុងរោងដែលប្រាសចាកអណ្តាតភ្លើង ។ បទថា **វាសំ កប្បេយ្យុំ** សេចក្តីថា វុយទាំងឡាយនាំគ្នាផឹកសុរាអស់ទាំងក្អមស្រវឹង ហើយចូលទៅក្នុងគំនររងើកភ្លើង ។ បទថា **ពិម្ពោដ្ឋសម្បន្នោ** សេចក្តីថា ប្រកបដោយបបូរមាត់ទាំង ២ ស្អាតដូចផ្លែបាស់ទុំ ។ បទថា **សុមុខោ**

បានដល់ មានមុខស្អាតដូចកញ្ចក់មាស ។ បទថា **បិហាយេយ្យុំ** សេចក្តីថា គប្បីប្រាថ្នាសម្បត្តិឲ្យដល់គ្នានិងគ្នា បំណងល្អដល់គ្នានិងគ្នា ត្រូវគ្នាបាន ។ បទថា **មុឡាលបត្តានំ** បានដល់ ត្រួយឈើដែលកើតអំពីគុម្ពឈើ ។ បទថា **កុលុង្កោ** បានដល់ បក្សីតូចៗ មួយក្បាល ។ បទថា **សមុទ្ទិកំ** បានដល់ នាវាធំដែលកំពុងត្រាច់ទៅក្នុងសមុទ្រ ។ បទថា **សយន្តំ សវជាករំ** សេចក្តីថា ប្រកបដោយសម្ភារៈគ្រប់គ្រាន់ មួយអន្ទើដោយគ្រឿងយន្ត និងក្តោង ។ បទថា **ចេតោ អានាយ** សេចក្តីថា កាលណា ក្មេងអ្នកស្រុកតូចៗ គប្បីយកដៃលើកសំពៅបែបនេះ ដើរទៅបាន ។

មហាសត្វបានពោលគាថា ១១ គាថា ដោយអដ្ឋានបរិកម្មនេះ ដោយប្រការដូច្នេះ ស្រីនគរសោភិនីបានស្តាប់ដូច្នោះហើយ សូមខមាទោសព្រះមហាសត្វ ទៅកាន់ព្រះនគរ ក្រាបទូលរឿងនោះដល់ព្រះរាជា ហើយទូលសូមជីវិតរបស់ខ្លួន ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ត្រាស់ថា ម្នាលភិក្ខុ ឈ្មោះថា មាតុគ្រាម ជាអកតញ្ញូ ទ្រុស្តមិត្តយ៉ាងនេះ ដូច្នេះហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងកាលចប់សច្ចៈធម៌ ភិក្ខុអផ្សុក តាំងនៅក្នុងសោតាបត្តិផល ហើយទ្រង់ប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទក្នុងកាលឥឡូវនេះ ឯតាបសក្នុងកាលនោះ គឺតថាគតនេះឯង ៕

## អដ្ឋកថា អដ្ឋានជាតក ចប់

# សុត្តន្តបិដក

## ធីបិជាតក

[ ៤៩៧ ] *( មេតាពៃនិយាយនឹងខ្លាថា ) បពិត្រឪពុកធំ លោកល្មមអត់ធន់បាន ល្មមញ៉ាំងអត្តភាព ឲ្យប្រព្រឹត្តទៅបានដែរឬ លោកបានសេចក្តីសុខទេឬ ម្តាយខ្ញុំបាននិយាយសួរសេចក្តីសុខរបស់លោក ព្រោះថា យើងទាំងឡាយជាអ្នកប្រាថ្នាសេចក្តីសុខដល់លោក ។*

[ ៤៩៨ ] *( ខ្លាធ្មៃយតបថា ) ម្នាលមេតាពៃ នាងឯងបានដើរជាន់កន្ទុយរបស់អញ ធ្វើឲ្យអញលំបាក ថ្ងៃនេះ នាងឯងស្មានថាអាត្មាអញនឹងរួចទោស ដោយសារការហៅអញថា ឪពុកធំដូច្នេះឬ ។*

[ ៤៩៩ ] *( មេតាពៃនិយាយថា ) អ្នកអង្គុយបែរមុខទៅទិសខាងកើត ចំណែកខ្ញុំក៏បានដើរមកចំមុខរបស់អ្នក កន្ទុយរបស់អ្នកនៅពីខាងក្រោយទេ ចុះខ្ញុំជាន់កន្ទុយរបស់អ្នក ដោយប្រការដូចម្តេចបាន ។*

[ ៥០០ ] *( ខ្លានិយាយថា ) ទ្វីប ៤ ព្រមទាំងសមុទ្រ និងភ្នំមានទៅត្រឹមណា កន្ទុយរបស់អញ ក៏មានទៅត្រឹមណោះដែរ ហាងឯងនឹងវៀរឲ្យផុត ( ពីកន្ទុយរបស់អញ ) ដូចម្តេចបាន ។*

[ ៥០១ ] *( មេតាពៃនិយាយថា ) អំពីដើមមក មាតាបិតា និងបងឈ្មោលរបស់ខ្ញុំ ក៏បានប្រាប់ហេតុនុ៎ះហើយថា កន្ទុយសត្វ*

សាហាវវែងណាស់ ( ព្រោះហេតុនោះ បានជា ) ខ្ញុំហោះមកតាមអាកាស ។

[ ៥០២ ] ( ខ្លានិយាយថា ) នែមេពពែ ហ្វូងម្រឹគវត់បាត់អស់ទៅ ព្រោះឃើញឯងហោះមកក្នុងអាកាស ឯងបំផ្លាញចំណីរបស់អញអស់ ។

[ ៥០៣ ] ( អភិសម្ពុទ្ធគាថា ) កាលដែលមេពពែកំពុងតែនិយាយរៀបរាប់យ៉ាងនេះ ខ្លាជំបងដែលជាសត្វស៊ីឈាម ក៏ស្ទុះទៅចាប់កាច់កនែពពែសម្លាប់ទៅ ឱ ! សម្ដីល្អ មិនមានក្នុងបុគ្គលអាក្រក់ឡើយ ។

[ ៥០៤ ] ការដឹកនាំ ១ ធម៌ ១ និងសម្ដីល្អ ១ មិនមានក្នុងបុគ្គលអាក្រក់ទេ បុគ្គលគួរគេចវាងពួកបុគ្គលអាក្រក់ ហើយប្រឹងប្រែកបព្យាយាម ព្រោះពួកបុគ្គលអាក្រក់នោះ មិនត្រេកអរនឹងពួកសប្បុរសឡើយ ។

**ទីបិជាតកទី ១០ ចប់**

**កច្ចានិវគ្គ ចប់**

## ឧទ្ទាននៃកច្ចានិវគ្គនោះ គឺ

និយាយអំពីកច្ចានីបរិសុទ្ធ មិនមានមន្ទិល ទ្រទ្រង់សំពត់ ១ សម្រែកស្តេចកុក ១ គ្រឿងប្រដាប់មាស ១ ការទ្រទ្រង់នូវអាជ្ញា ១ ផែនដីដូចរងើកភ្លើង ១ ស្តេចចេតិយៈ ១ កាឡទេវិលតាបស ១ ផ្ទះត្រូវភ្លើងឆេះ ១ ទន្ទេគន្ធា ១ មេពពែ ១ រួមត្រូវជា ១០ ។

**អដ្ឋកនិបាត ចប់**

# អដ្ឋកថា

## ទីបិជាតក

[ ៤៩៧-៥០៤ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធមេពពែមួយក្បាល ទើបត្រាស់រឿងនេះ មានពាក្យផ្ដើមថា **១មនីយំ យាបនីយំ** ដូច្នេះជាដើម ។

សេចក្ដីពិស្ដារថា សម័យមួយ ព្រះមហាមោគ្គល្លាននៅត្រង់គិរិព្វជៈ សេនាសនៈដែលព័ទ្ធដោយភ្នំ មានទ្វារចេញតែម្ខាង ទីចង្រ្កមរបស់លោកមានក្បែរទ្វារភ្នំនោះ ។ ក្នុងកាលនោះ ពួកអ្នកចិញ្ចឹមពពែ គិតថា ពពែត្រាច់ទៅក្នុងទីនេះ ទើបកៀងពពែចូលទៅក្នុងញកភ្នំ ហើយនាំគ្នាលេង ។ ល្ងាចថ្ងៃមួយ កាលពួកអ្នកចិញ្ចឹមពពែ នាំគ្នាកៀងហ្វូងពពែទៅ មេពពែមួយដើរឆ្ងាយអំពីហ្វូង មិនឃើញហ្វូងពពែចេញទៅ ក៏ដើរតែឯង ខ្លាមួយឃើញមេពពែនោះដើរតែឯង ទើបគិតថា អញនឹងស៊ីមេពពែនោះ ហើយទៅឈរខាងស្ដាំទ្វារញកភ្នំ ។ មេពពែសម្លឹងមើលឆ្វេងស្ដាំ ឃើញខ្លាធំនោះ គិតថា ខ្លានេះកំពុងឈរដើម្បីសម្លាប់អញ បើអញត្រឡប់ក្រោយ គេចទៅ ក៏គង់មិនរួចជីវិត អញគួរធ្វើសេចក្ដីក្លាហានក្នុងថ្ងៃនេះ ដូច្នេះហើយ ទើបអើតក្បាលរត់ចូលទៅរកខ្លានោះដោយរហ័ស ខ្លាគេចដោយគិតថា អញនឹងចាប់ខាងនេះ តែមិនទាន់ មេពពែបានចូលដល់ព្រៃស្រុក គេចចូលក្នុងហ្វូងពពែបាន ។

ព្រះមហាមោគ្គល្លាន បានឃើញកិរិយារបស់សត្វទាំង ២ នោះ ស្អែកឡើងទៅក្រាបទូលព្រះសាស្ដាថា បពិត្រព្រះអង្គដ៏ចម្រើន មេពពែនោះបានធ្វើសេចក្ដីព្យាយាម ដោយភាពដែលខ្លួនឈ្លាសក្នុងឧបាយ ទើបរួចអំពីក្រញាំខ្លា

បានយ៉ាងនេះ ព្រះសាស្តាត្រាស់ថា ម្នាលមោគ្គល្លាន ខ្លាមិនអាចចាប់មេពពែនោះបានក្នុងកាលឥឡូវនេះ តែក្នុងកាលមុន ខ្លាបានសម្លាប់មេពពែនោះដែលកំពុងយំសោក ទំពាស៊ីហើយ ដូច្នេះ ។ ព្រះមហាមោគ្គល្លានបានទូលអារាធនាឲ្យត្រាស់រឿង ទើបទ្រង់នាំយករឿងក្នុងអតីតមកសាធក:ដូចតទៅ

ក្នុងអតីតកាល ព្រះពោធិសត្វកើតក្នុងត្រកូលមានភោគ:ច្រើន ក្នុងស្រុកមួយ នាមគធរដ្ឋ ចម្រើនវ័យហើយ បានលះកាមចេញបួសជាឥសី ធ្វើឈាននិងអភិញ្ញាឲ្យកើតហើយ នៅក្នុងហិមវន្តប្បទេសអស់កាលយូរ កាលត្រូវការបរិភោគរសជូរព្រៃ ទើបទៅនគររាជគ្រឹះ សាងបណ្ណសាលាត្រង់ញកភ្នំមួយកន្លែង កាលនោះ ពួកអ្នកចិញ្ចឹមពពែ លែងហ្វូងពពែឲ្យត្រាច់ទៅ ដោយទំនងដូចពោលហើយ ថ្ងៃមួយ ខ្លាបានឃើញមេពពែចេញមកក្រោយគេ គិតថា អញនឹងស៊ីមេពពែនោះ ទើបឈររាំងផ្លូវ មេពពែឃើញដូច្នោះ គិតថា ថ្ងៃនេះ អញនឹងមិនរួចជីវិត អញនឹងប្រាស្រ័យដោយវាចាពីរោះជាមួយខ្លានេះ ដោយឧបាយណាមួយ ធ្វើហទយ:ខ្លាឲ្យទន់ រក្សានូវជីវិត ។ គិតដូច្នេះហើយ ទើបធ្វើបដិសណ្ឋារ:នឹងខ្លានោះពីចម្ងាយ កាលមកដល់ ទើបពោលគាថាទី ១ ថា

បពិត្រឪពុកធំ លោកល្មមអត់ធន់បាន ល្មមញុំាងអត្តភាពឲ្យ
ប្រព្រឹត្តទៅបានដែរឬ លោកបានសេចក្តីសុខទេឬ ម្តាយខ្ញុំបាន
និយាយសួរសេចក្តីសុខរបស់លោក ព្រោះថា យើងទាំងឡាយ
ជាអ្នកប្រាថ្នាសេចក្តីសុខដល់លោក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សុខំ តេ អម្មា** សេចក្តីថា មាតារបស់ខ្ញុំ

បានផ្តាំនឹងខ្ញុំក្នុងថ្ងៃនេះថា នឹងបានទទួលសេចក្តីសុខអំពីលោក ។ បទថា **មយំ** សេចក្តីថា បពិត្រឪពុកធំ សូម្បីខ្លួនខ្ញុំ ក៏ត្រូវការឲ្យឪពុកធំមានសេចក្តីសុខដូចគ្នា

ខ្លាបានស្តាប់ដូច្នោះ គិតថា មេពពៃធបោកនេះបំណងនឹងបញ្ឆោតអញ ដោយគិតថា អញជាឪពុកធំ មិនដឹងថា អញកាច ដូច្នេះហើយ ពោលគាថាទី ២ ថា

ម្នាលមេពពៃ នាងឯងបានដើរជាន់កន្ទុយរបស់អញ ធ្វើឲ្យអញ
លំបាក ថ្ងៃនេះ នាងឯងស្មានថា អាត្មាអញនឹងរួចទោស
ដោយសារការហៅអញថា ឪពុកធំដូច្នេះឬ ដូច្នេះ ។

គាថានោះ មានសេចក្តីថា នែមេពពៃ នាងជាន់កន្ទុយអញ ថ្ងៃនេះ នាងគន់យល់ថា នឹងផុតចាកសេចក្តីស្លាប់ ដោយក្លែងហៅអញថា ឪពុកធំ នាងកុំស្មានយ៉ាងនេះឡើយ ។

មេពពៃបានស្តាប់ដូច្នោះ ទើបពោលថា បពិត្រឪពុកធំ លោកកុំធ្វើយ៉ាងនេះឡើយ ហើយពោលគាថាទី ៣ ថា

អ្នកអង្គុយបែរមុខទៅទិសខាងកើត ចំណែកខ្ញុំក៏បានដើរមកចំមុខ
របស់អ្នក កន្ទុយរបស់អ្នកនៅពីខាងក្រោយទេ ចុះខ្ញុំជាន់កន្ទុយ
របស់អ្នក ដោយប្រការដូចម្តេចបាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មុខំ** ប្រែថា ចំពោះមុខ ។ បទថា **កថំ ខោហំ** សេចក្តីថា ធ្វើម្តេចខ្ញុំនឹងជាន់កន្ទុយរបស់លោកដែលនៅពីខាងក្រោយ

បាន ។ លំដាប់នោះ ខ្លាបានពោលនឹងមេពពែថា នែមេពពែ នាងនិយាយអ្វី ទីដែលផុតចាកកន្ទុយរបស់យើង មិនមាន ដូច្នេះហើយ ពោលគាថាទី ៤ ថា

ទ្វីប ៤ ព្រមទាំងសមុទ្រ និងភ្នំ មានទៅត្រឹមណា កន្ទុយរបស់អញ ក៏មានទៅត្រឹមណោះដែរ ហឯងនឹងវៀរឲ្យផុត ( ពីកន្ទុយរបស់អញ ) ដូចម្ដេចបាន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **តាវតា** សេចក្ដីថា ខ្លាពោលថា អញយកកន្ទុយរបស់អញដាក់ក្នុងទីប្រមាណប៉ុណ្ណោះ ។

មេពពែបានស្ដាប់ដូច្នោះ គិតថា ខ្លានេះលាមក មិនគិតក្នុងពាក្យដែលពីរោះ បែរជាសត្រូវពោលបៀតបៀនអញ ដូច្នេះហើយ ពោលគាថាទី ៥ ថា

អំពីដើមមក មាតា បិតា និងបងឈ្មោលរបស់ខ្ញុំ ក៏បានប្រាប់ហេតុនុ៎ះហើយថា កន្ទុយសត្វសាហាវវែងណាស់ ( ព្រោះហេតុនោះ បានជា ) ខ្ញុំហោះមកតាមអាកាស ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អក្ខំសុ** សេចក្ដីថា កាលមុន មាតាបិតាក្ដី ញាតិបងប្អូនទាំងឡាយក្ដី បានប្រាប់រឿងនេះដល់ខ្ញុំហើយ ។ បទថា **សាធិ** សេចក្ដីថា ខ្ញុំដឹងអំពីសម្នាក់មាតា បិតា ញាតិ បងប្អូនថា កន្ទុយរបស់សត្វសាហាវវែងណាស់ ដើម្បីរក្សាកន្ទុយរបស់លោក ទើបខ្ញុំមកតាមអាកាស ។

លំដាប់នោះ ខ្លាពោលថា អញដឹងថា នាងមកតាមអាកាស តែកាលមក នាងបានធ្វើអាហាររបស់អញឲ្យវិនាស ដូច្នេះហើយ ពោលគាថាទី ៦ ថា

នៃមេពពែ ហ្វូងម្រឹគរត់បាត់អស់ទៅ ព្រោះឃើញហានឯងហោះ មកក្នុងអាកាស ហានឯងបំផ្លាញចំណីរបស់អញអស់ ដូច្នេះ ។

មេពពែបានស្ដាប់ដូច្នោះ ក៏ខ្លាចមរណភ័យ មិនអាចរកឧបាយដទៃ មកកែខៃបាន ទើបយំអង្វរថា បពិត្រឪពុកធំ លោកកុំធ្វើកម្មគ្រោតគ្រាតយ៉ាងនេះឡើយ សូមឲ្យជីវិតដល់ខ្ញុំចុះ ។ ខ្លាបានសង្គ្រុបមេពពែ ដែលកំពុងយំអង្វរ សម្លាប់ស៊ីហើយ ។

ព្រះមានព្រះភាគ កាលទ្រង់បានត្រាស់ជីងហើយ ទើបទ្រង់ត្រាស់អភិសម្ពុទ្ធគាថា ២ គាថាថា

កាលដែលមេពពែកំពុងតែនិយាយរៀបរាប់យ៉ាងនេះ ខ្លាដំបង
ដែលជាសត្វស៊ីឈាម ក៏ស្ទុះទៅចាប់កាច់កនៃពពែសម្លាប់ទៅ
ឱ ! សម្ដីល្អ មិនមានក្នុងបុគ្គលអាក្រក់ឡើយ ។
ការដឹកនាំ ១ ធម៌ ១ និងសម្ដីល្អ ១ មិនមានក្នុងបុគ្គលអាក្រក់
ទេ បុគ្គលគួរគេចវាងពួកបុគ្គលអាក្រក់ ហើយប្រឹងប្រកប
ព្យាយាម ព្រោះពួកបុគ្គលអាក្រក់នោះ មិនត្រេកអរនឹងពួក
សប្បុរសឡើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **រុហគ្ឃសោ** បានដល់ ខ្លាដែលមានលោហិតជាភិក្ខា គឺជាអ្នកស៊ីផឹកនូវឈាម ។ បទថា **គលកំ អក្វាវមទ្ទិ** សេចក្ដីថា ខ្លាដំបងកាច់កហែកសាច់ ផឹកបឺតឈាមបរិភោគ ។ បទថា **ឆយោ** បានដល់ហេតុ ។ បទថា **ឆម្មោ** បានដល់ សេចក្ដីពិត ។ បទថា **សុភាសិតំ** បានដល់

វាចាដែលពោលល្អហើយ អធិប្បាយថា ធម៌ដែលពោលមកហើយទាំងអស់ រមែងមិនមានក្នុងបុគ្គលដែលប្រទូស្តឡើយ ។ បទថា **និក្កមំ ទុដ្ឋេ យុញ្ជេថ** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ បុគ្គលគប្បីធ្វើសេចក្តីព្យាយាម ឈានឲ្យផុតបុគ្គលចិត្តអាក្រក់ ។ បទថា **សោ ច សព្ភិ ន រជ្ជតិ** សេចក្តីថា ព្រោះបុគ្គលចិត្តអាក្រក់នោះ រមែងមិនត្រេកអរ រមែងមិនយកចិត្តទុកដាក់ក្នុងសុន្ទរ-សុភាសិតរបស់សប្បុរសទាំងឡាយឡើយ ។ តាបសបានឃើញកិរិយារបស់សត្វទាំង ២ នោះ គ្រប់យ៉ាង ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រជុំជាតកថា មេពពែក្នុងកាលនោះ បានមកជាមេពពែក្នុងកាលឥឡូវនេះ ខ្លាដំបងក្នុងកាលនោះ បានមកជាខ្លាដំបង ឯតាបសក្នុងកាលនោះ គឺតថាគតនេះឯង ។៚

**អដ្ឋកថា ទីបិជាតក ចប់**

**កច្ចានិវគ្គ ចប់**

**អដ្ឋកនិបាត ចប់**

# សុត្តន្តបិដក

## នវកនិបាត

### គិជ្ឈជាតក

[ ៥០៥ ] ( អភិសម្ពុទ្ធគាថា ) មានផ្លូវលើភ្នំគិជ្ឈបព៌តឈ្មោះបរិសង្កុបថ: ជាផ្លូវមានមកតាំងពីបុរាណ ត្មាតមួយចិញ្ចឹមមាតាបិតាដែលចាស់ជរា នៅក្នុងផ្លូវនោះ ។

[ ៥០៦ ] ត្មាតនោះ បានទៅនាំយកកន្សោមខ្លាញ់ពស់ថ្លាន់មកចិញ្ចឹមមាតាបិតាទាំងនោះដោយច្រើន ចំណែកត្មាតជាបិតា កាលបើដឹងថា ត្មាតឈ្មោះសុបត្ត: ជាកូនមានស្លាបបរិបូណ៌ មានតេជះហើរទៅកាន់ទីខ្ពស់ ទាំងហើរទៅកាន់ទីឆ្ងាយបាន ក៏និយាយជាស់តឿន ។

[ ៥០៧ ] នែបា ( បើ ) អ្នកដឹងនូវផែនដីថា អណ្តែត ( ដូចជាស្លឹកឈូក ) មានសាគរព័ទ្ធជុំវិញ មូលដូចកង់ វេលាណាហើយ នែបា ចូរអ្នកត្រឡប់មកអំពីទីនោះវិញ អ្នកកុំទៅឲ្យហួសទៅនាយ អំពីទីនេះឡើយ ។

[ ៥០៨ ] ( ត្មាតឈ្មោះសុបត្ត: ) ជាបក្សីមានកក្កក់ មានកម្លាំងដ៏ប្រសើរជាងទិជជាតិ ហើរស្ទុះឡើងដោយសម្ទុះដ៏ខ្លាំងរមិលមើលនូវភ្នំ និងព្រៃទាំងឡាយ ។

[ ៥០៩ ] ត្មាត ( ឈ្មោះសុបត្តៈនោះ ) បានឃើញផែនដី មានសាគរព័ទ្ធជុំវិញ មូលដូចជាកង់ សមដូចពាក្យប្រដៅរបស់បិតាដែលខ្លួនបានឮមកហើយ ។

[ ៥១០ ] ត្មាតនោះ ហើររំលងទីនោះ ហួងហួសទៅកាន់ទីខាងនាយ ស្រាប់តែមានខ្យល់ព្យុះយ៉ាងខ្លាំង បក់កួចត្មាតដ៏មានកម្លាំងនោះ ខ្ទេចខ្ទីអស់ទៅ ។

[ ៥១១ ] បក្សីត្មាតនោះ ហើរជ្រុលហួសទៅនាយហើយ ក៏មិនអាចហើរត្រឡប់មកវិញបាន លុះក្នុងអំណាចខ្យល់ព្យុះ ក៏ដល់នូវសេចក្ដីវិនាសទៅ ។

[ ៥១២ ] ពួកកូន និងប្រពន្ធរបស់ត្មាតនោះក្ដី ពួកត្មាតដទៃដែលរស់នៅដោយសារត្មាតនោះ ( បរិវារ ) ក្ដី ក៏ដល់នូវសេចក្ដីវិនាសទាំងអស់គ្នា ព្រោះតែត្មាតសុបត្តៈនោះមិនធ្វើតាមឱវាទ ។

[ ៥១៣ ] ពួកជនណាក្នុងលោកនេះ មិនធ្វើតាមពាក្យប្រដៅរបស់បុគ្គលចាស់ព្រឹទ្ធាចារ្យទាំងឡាយយ៉ាងនេះហើយ ពួកជនទាំងអស់នោះ រមែងដល់នូវសេចក្ដីវិនាស ព្រោះតែមិនធ្វើតាមពាក្យប្រដៅរបស់បុគ្គលចាស់ព្រឹទ្ធាចារ្យ ដូចជាត្មាតដ៏មានកម្លាំងប្រព្រឹត្តល្មើសពាក្យប្រដៅ ហើរហួសទីព្រំប្រទល់ ។

**គិជ្ឈជាតកទី ១ ចប់**

# អដ្ឋកថា
# នវកនិបាត

## គិជ្ឈជាតក

[ ៥០៥-៥១៣ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធ ភិក្ខុប្រដៅក្រមួយរូប ទើបត្រាស់រឿងនេះ មានពាក្យផ្ដើមថា **បរិសង្កុបថោ ឆាម** ដូច្នេះជាដើម ។

បានឮថា ភិក្ខុប្រដៅក្ររូបនោះ ជាកូនរបស់សប្បុរសម្នាក់ បួសក្នុង សាសនាដែលនាំចេញចាកទុក្ខ កាលអាចារ្យ ឧបជ្ឈាយ៍ និងសព្រហ្មចារីមាន បំណងល្អ ពោលទូន្មានថា លោកគប្បីឈានទៅយ៉ាងនេះ គប្បីឈានថយ យ៉ាងនេះ ក្រឡេកមើលទៅមុខយ៉ាងនេះ ក្រឡេកមើលឆ្វេងស្ដាំយ៉ាងនេះ បត់ អង្គុញយ៉ាងនេះ លាតសណ្ដូកយ៉ាងនេះ ស្លៀកយ៉ាងនេះ ដណ្ដប់យ៉ាងនេះ កាន់បាត្រយ៉ាងនេះ គប្បីទទួលភត្តត្រឹមតែល្មមញុំាំងអត្តភាពឲ្យប្រព្រឹត្តទៅបាន ពិចារណាសិនហើយ សឹមឆាន់ គប្បីគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ស្គាល់ ប្រមាណក្នុងភោជន ប្រកបសេចក្ដីព្យាយាមរឿយៗ គប្បីដឹងទំនៀម ទទួល អាគន្តុកៈ គប្បីដឹងគមិកវត្ត គប្បីប្រព្រឹត្តដោយល្អ ក្នុងខន្ធកវត្ត ១៤ និង មហាវត្ត ៨០ គប្បីសមាទានធុតង្គគុណ ១៣ ដូច្នេះ ជាអ្នកប្រដៅក្រ មិនអត់ ធន់ចំពោះឱវាទ មិនគោរពទទួលពាក្យប្រៀនប្រដៅ ពោលតបថា ខ្ញុំមិន បានថាឲ្យពួកលោក ហេតុអ្វី ទើបពួកលោកថាឲ្យខ្ញុំ ខ្ញុំប៉ុណ្ណោះ ធ្វើវត្តជា

ប្រយោជន៍ ឬមិនជាប្រយោជន៍សម្រាប់ខ្លួន ហើយបានធ្វើខ្លួនមិនឲ្យបុគ្គលណាម្នាក់ប្រដៅបាន ។

បានឮថា ពួកភិក្ខុដឹងថា ភិក្ខុរូបនោះជាអ្នកប្រដៅក្រ ទើបបានប្រជុំគ្នាពោលទោសក្នុងធម្មសភា ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកប្រជុំសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើបព្រះសាស្តាឲ្យហៅភិក្ខុនោះមក ត្រាស់ថា បានឮថា អ្នកប្រដៅក្រពិតឬ កាលភិក្ខុនោះទូលថាករុណាព្រះអង្គ ពិតមែន ទើបត្រាស់ថា អ្នកបួសក្នុងសាសនាដែលនាំចេញចាកទុក្ខបែបនេះ ហេតុអ្វី ទើបមិនស្តាប់ពាក្យរបស់បុគ្គលដែលបំណងល្អ សូម្បីក្នុងកាលមុន អ្នកមិនស្តាប់ពាក្យប្រៀនប្រដៅ ត្រូវបែកខ្ទេចខ្ទីក្នុងលម្ហាវេរម្ភវាតមកហើយ ទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះពោធិសត្វសោយព្រះជាតិជាសត្វត្មាត ត្រង់ភ្នំគិជ្ឈ-កូដ ស្តេចត្មាតនោះមានកូនឈ្មោលមួយ ឈ្មោះសុបត្តៈ ជាសត្វមានកម្លាំងច្រើន មានត្មាតច្រើនពាន់ជាបរិវារ ស្តេចត្មាតនោះជាសត្វចិញ្ចឹមមាតាបិតា តែព្រោះខ្លួនមានកម្លាំងច្រើន ទើបហើរទៅឆ្ងាយហួសដែនដែលគួរ បិតាបានពោលទូន្មានស្តេចត្មាតនោះថា នែកូនជាទីស្រឡាញ់ បាមិនគួរទៅហួសទីប្រមាណប៉ុណ្ណោះឡើយ ។ ស្តេចត្មាតនោះ សូម្បីទទួលពាក្យថា សាធុក៏ពិត តែថ្ងៃមួយកាលភ្លៀងធ្លាក់ថ្មីៗ បានហើរទៅជាមួយត្មាតទាំងឡាយ ចោលពួកត្មាតទាំងឡាយ ខ្លួនឯងហើរខ្ពស់ជាងលំដាប់របស់បក្សី ដល់ខ្យល់វេរម្ភវាត ក៏ដល់នូវ

កាលបែកខ្ទេចខ្ទី ព្រះសាស្តាកាលទ្រង់ប្រកាសសេចក្តីនោះ ទ្រង់ជាអ្នកត្រាស់ដឹងហើយ បានត្រាស់គាថាទាំងឡាយថា

មានផ្លូវលើគិជ្ឈបព៌ត ឈ្មោះបរិសន្ទបថៈ ជាផ្លូវមានមកតាំងពីបុរាណ ត្មាតមួយចិញ្ចឹមមាតា បិតា ដែលចាស់ជរា នៅក្នុងផ្លូវនោះ ។

ត្មាតនោះ បានទៅនាំយកកន្ត្រាមខ្លាញ់ពស់ថ្លាន់ មកចិញ្ចឹមមាតាបិតាទាំងនោះដោយច្រើន ចំណែកត្មាតជាបិតា កាលបើដឹងថាត្មាតឈ្មោះសុបត្តៈជាកូន មានស្លាបបរិបូណ៌ មានតេជះ ហើរទៅកាន់ទីខ្ពស់ ទាំងហើរទៅកាន់ទីឆ្ងាយបាន ក៏និយាយជាស់តឿន ។

នែបា ( បើ ) អ្នកដឹងនូវផែនដីថា អណ្តែត ( ដូចជាស្លឹកឈូក ) មានសាគរព័ទ្ធជុំវិញ មូលដូចកង់ វេលាណាហើយ នែបា ចូរអ្នកត្រឡប់មកអំពីទីនោះវិញ អ្នកកុំទៅឲ្យហួសទៅនាយ អំពីទីនេះឡើយ ។

ជាបក្សីមានកក្លក់មាន កម្លាំងដ៏ប្រសើរជាងទិជជាតិ ហើរស្ទុះឡើងដោយសម្ទុះដ៏ខ្លាំង រមិលមើលនូវភ្នំ និងព្រៃទាំងឡាយ ។

ត្មាត ( ឈ្មោះសុបត្តៈនោះ ) បានឃើញផែនដី មានសាគរព័ទ្ធជុំវិញ មូលដូចជាកង់ សមដូចពាក្យប្រដៅរបស់បិតា ដែលខ្លួនបានឮមកហើយ ។

ត្មាតនោះ ហើររំលងទីនោះ ហ្វាងហួសទៅកាន់ទីខាងនាយ ស្រាប់តែមានខ្យល់ព្យុះយ៉ាងខ្លាំង បក់ក្លួចត្មាតដ៏មានកម្លាំងនោះ ខ្ទេចខ្ទី

អស់ទៅ ។

បក្សីត្មាតនោះ ហើរជ្រុលហួសទៅនាយហើយ ក៏មិនអាចហើរត្រឡប់មកវិញបាន លុះក្នុងអំណាចខ្យល់ព្យុះ ក៏ដល់នូវសេចក្តីវិនាសទៅ ។

ពួកកូន និងប្រពន្ធរបស់ត្មាតនោះក្តី ពួកត្មាតដទៃដែលរស់នៅដោយសារត្មាតនោះ ( បរិវារ ) ក្តី ក៏ដល់នូវសេចក្តីវិនាសទាំងអស់គ្នា ព្រោះតែត្មាតសុបត្តៈនោះ មិនធ្វើតាមឱវាទ ។

ពួកជនណា ក្នុងលោកនេះ មិនធ្វើតាមពាក្យប្រដៅ របស់បុគ្គលចាស់ព្រឹទ្ធាចារ្យទាំងឡាយ យ៉ាងនេះហើយ ពួកជនទាំងអស់នោះ រមែងដល់នូវសេចក្តីវិនាស ព្រោះតែមិនធ្វើតាមពាក្យប្រដៅរបស់បុគ្គលចាស់ព្រឹទ្ធាចារ្យ ដូចជាត្មាតដ៏មានកម្លាំងប្រព្រឹត្តល្មើសពាក្យប្រដៅ ហើរហួសទីព្រំប្រទល់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បរិសង្កុបថោ** គឺមានឈ្មោះថា **សង្កុបថ** មនុស្សទៅរកប្រាក់មាស ត្រូវបោះបង្គោលចងខ្សែឡើងទៅលើទឹកដីនោះ ព្រោះហេតុនោះ ផ្លូវថ្មើរជើងលើគិជ្ឈបព្វតនោះ ទើបលោកហៅថា **សង្កុបថ**។

ផ្លូវលើកំពូលភ្នំគិជ្ឈកូដ ឈ្មោះថា **គិជ្ឈបថោ** ។ បទថា **សនន្តនោ** បានដល់ មានមកតាំងអំពីយូរលង់ ។ បទថា **តត្រាសិ** សេចក្តីថា ក្បែរផ្លូវដើរ ឈ្មោះសង្កុបថៈ លើកំពូលភ្នំគិជ្ឈកូដនោះ មានត្មាតមួយនៅអាស្រ័យ ត្មាតនោះចិញ្ចឹមមាតាបិតាដែលជរាហើយ ។ ពីរបទថា **អជគរំ មេទំ** កែជា

**អជគរមេធំ** សេចក្តីថា កន្ទ្យាមខ្លាញ់ពស់ថ្លាន់ ។ បទថា **អច្ចហាសិ** គឺនាំមកហើយសន្ទឹកសន្ធាប់ ។ បទថា **ពហុត្តតោ** កែជា **ពហុត្តសោ** ប្រែថា ដោយច្រើន ។ បទថា **ជានំ ឧច្ចំ បចាតិនំ** សេចក្តីថា បិតាបានឮថា បុត្ររបស់លោកហើរឡើងទៅកាន់ទីខ្ពស់ពេក ដឹងថា ត្មាតសុបត្តៈនេះ នឹងធ្លាក់អំពីទីខ្ពស់ ។ បទថា **តេជសី** បានដល់ ដល់ព្រមដោយតេជះរបស់បុរស ។ បទថា **ទូរគាមិនំ** បានដល់ ទៅឆ្ងាយដោយតេជះនោះឯង ។ បទថា **បរិប្ល-វន្តំ** បានដល់ លិចអណ្តែតៗ ដូចស្លឹកឈូកអណ្តែតក្នុងទឹក ។ បទថា **វិជា-នហិ** កែជា **វិជានាសិ** ប្រែថា ដឹង ។ បទថា **ចក្កំវ បរិមណ្ឌលំ** សេចក្តីថា បិតាពោលទូន្មានយ៉ាងនេះថា កាលណា ជម្ពូទ្វីបដែលព័ទ្ធជុំវិញដោយសាគរ ប្រាកដដល់ឯង ដែលតាំងនៅក្នុងបទេសនោះ ហាក់បីដូចជាកង់ចក្រ ចូរឯងប្រញាប់ត្រឡប់អំពីទីនោះ ។ បទថា **ឧទបត្តោសិ** សេចក្តីថា ត្មាតឈ្មោះសុបត្តៈ មិនធ្វើតាមឱវាទរបស់បិតា ។ ថ្ងៃមួយ បានហើរទៅជាមួយត្មាតទាំងឡាយ ក៏ហើរបោលត្មាតទាំងនោះទៅ បានហើរឡើងដល់ទីដែលបិតាប្រាប់ហើយ ។ បទថា **ឱលោកយន្តោ** គឺកាលដល់ទីត្រង់នោះ ហើយសម្លឹងមើលខាងក្រោម ។ បទថា **វង្កង្គោ** កែជា **វង្កគីវោ** ប្រែថា បក្សីមានកក្ងក់ ។ បទថា **យថស្សាសិ បិតុស្សុតំ** សេចក្តីថា បានឃើញដូចគ្នានឹងពាក្យដែលខ្លួនបានស្តាប់មកអំពីសម្នាក់របស់ត្មាតជាបិតានោះ បាលីថា **យថា-ស្សាសិ** ដូច្នេះក៏មាន ។ បទថា **បរមេវ បវត្តថ** សេចក្តីថា ហើររំលងចាកទីដែលបិតាបានប្រាប់ហើយ ទៅខាងលើទៀត ។ បទថា **តញ្ច វាតសិខា**

**តិក្ខា** សេចក្តីថា ខ្យល់វេរម្ភាគដ៏ខ្លាំងក្លា បានប្រហារ គឺកម្ចាត់ត្មាតឈ្មោះសុបត្តៈដែលមិនធ្វើតាមឱវាទ សូម្បីជាសត្វមានកម្លាំងច្រើននោះហើយ បានដល់ បានធ្វើឲ្យបែកល្អិតខ្ទេចខ្ទីហើយ ។ បទថា **ឆាសក្ខាតិគតោ** កាត់បទជា **ឆាសក្ខិ អតិគតោ** ប្រែថា មិនអាចត្រឡប់អំពីទីនោះបាន ។

សត្វឈ្មោះ **ចោសោ** ។ បទថា **អនោវាទករេ** សេចក្តីថា កាលត្មាតឈ្មោះសុបត្តៈនោះ មិនធ្វើតាមឱវាទរបស់បណ្ឌិតទាំងឡាយ សត្វទាំងអស់នោះនាំគ្នាជួបនូវទុក្ខដ៏ធំ ។ បទថា **អកត្វា វុឌ្ឍសាសនំ** បានដល់ ជាអ្នកមិនធ្វើតាមពាក្យទូន្មានបុគ្គលដែលជាធំ ដែលប្រាថ្នាប្រយោជន៍ រមែងដល់នូវសេចក្តីវិនាស គឺទុក្ខធំយ៉ាងនោះដូចគ្នា ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ ដូច្នោះ ចូរអ្នកកុំធ្វើដូចត្មាត ចូរស្តាប់ពាក្យរបស់បុគ្គលដែលប្រាថ្នាប្រយោជន៍ ភិក្ខុនោះកាលព្រះសាស្តាទូន្មានយ៉ាងនេះហើយ ក៏ជាអ្នកប្រដៅងាយតាំងអំពីនោះមក ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា ស្តេចត្មាតដែលប្រដៅក្រក្នុងកាលនោះ បានមកជាភិក្ខុប្រដៅក្រក្នុងកាលឥឡូវនេះ ចំណែកត្មាតជាបិតាក្នុងកាលនោះ គឺតថាគតនេះឯង ៕

## អដ្ឋកថា គិជ្ឈជាតក ចប់

# សុត្តន្តបិដក

## កោសម្ពិយជាតក

[ ៥១៤ ] ( ព្រះសាស្តាត្រាស់ថា ) ជនសុទ្ធតែមានសំឡេងខ្លាំងស្មើគ្នា មិនមានជនណាមួយដឹងថា អាត្មាអញជាបុគ្គលពាលឡើយ កាលបើសង្ឃកំពុងបែកគ្នា ក៏មិនមានជនណាមួយដឹងនូវហេតុដទៃឲ្យក្រៃលែងជាងនេះទៅទៀត ។

[ ៥១៥ ] ពួកជនអ្នកភ្លេចស្មារតី មានអាការស្រដៀងនឹងបណ្ឌិត មានវាចាជាអារម្មណ៍ ចេះតែល្មោកនិយាយ តាមដែលខ្លួនចង់និយាយឲ្យតែរួចពីមាត់ មានគេដឹកនាំដោយជម្លោះណា ក៏នៅតែមិនស្គាល់នូវជម្លោះនោះឡើយ ។

[ ៥១៦ ] ពួកជនណាចងសេចក្តីក្រោធនោះទុក ដោយគិតថា ជនឯណោះបានជេរអញ បានវាយអញ បានផ្ចាញ់អញ បានលួចយក ( ទ្រព្យ ) អញដូច្នេះ ពៀររបស់ជនទាំងនោះ រមែងមិនស្ងប់រម្ងាប់បានឡើយ ។

[ ៥១៧ ] លុះតែពួកជនណា មិនចងសេចក្តីក្រោធនោះទុក ដោយគិតថា ជនឯណោះបានជេរអញ បានវាយអញ បានផ្ចាញ់អញ បានលួចយក ( ទ្រព្យ ) អញដូច្នេះ ទើបពៀររបស់ជននោះស្ងប់រម្ងាប់បាន ។

[ ៥១៨ ] ពៀរទាំងឡាយ ក្នុងលោកនេះ មិនស្ងប់រម្ងាប់ដោយពៀរ ក្នុងកាលណាមួយឡើយ មានតែស្ងប់រម្ងាប់ដោយមិនមាន

ពៀរ នេះជាធម៌មានមកតាំងអំពីដើម ។

[ ៥១៩ ] ពួនជនក្រៅពីបណ្ឌិត មិនដឹងច្បាស់ថា ពួកយើងនឹងដល់នូវសេចក្ដីវិនាសក្នុងកណ្ដាលសង្ឃនេះទេ បណ្ដាជនទាំងនោះលុះតែពួកជនណាដឹងច្បាស់ ( យ៉ាងនេះថា ពួកយើងនឹងដល់នូវសេចក្ដីវិនាស ) ទើបកលហធម៌ គឺការឈ្លោះប្រកែកទាំងឡាយ ស្ងប់រម្ងាប់អំពីសម្នាក់ពួកជននោះទៅបាន ។

[ ៥២០ ] អំបាលពួកជនដែលបានកាត់ឆ្អឹងគ្នា បានសម្លាប់គ្នា បានលួចយកគោ សេះ និងទ្រព្យ ប្លន់យកទាំងដែន គេគង់រួមគ្នាបាន ហេតុអ្វី ក៏ពួកអ្នករួមគ្នាមិនបាន ។

[ ៥២១ ] បើបុគ្គលបានសម្លាញ់ដែលមានប្រាជ្ញា ជាគ្រឿងរក្សាខ្លួន ជាអ្នកប្រាជ្ញត្រាច់ទៅជាមួយ មានវិហារធម៌ដ៏ប្រពៃ គប្បីគ្របសង្កត់នូវសេចក្ដីអន្តរាយទាំងឡាយទាំងពួង ហើយមានចិត្តត្រេកអរ មានស្មារតី ត្រាច់ទៅជាមួយនឹងសម្លាញ់នោះចុះ ។

[ ៥២២ ] បើបុគ្គលមិនបានសម្លាញ់ ដែលមានប្រាជ្ញាជាគ្រឿងរក្សាខ្លួន ជាអ្នកប្រាជ្ញត្រាច់ទៅជាមួយគ្នា មានវិហារធម៌ដ៏ល្អទេ គប្បីត្រាច់ទៅតែម្នាក់ឯង ដូចជាព្រះរាជាលះបង់ដែន ដែលឈ្នះហើយ ( ពុំនោះសោត ) ដូចដំរីដ៏ប្រសើរ ដែលត្រាច់ទៅ តែម្នាក់ឯង ក្នុងព្រៃ ។

[ ៥២៣ ] ការត្រាច់ទៅម្នាក់ឯង ប្រសើរជាង ( ព្រោះ ) សហាយតាគុណ មិនមានក្នុងបុគ្គលពាលទេ បុគ្គលគួរត្រាច់ទៅតែម្នាក់ឯង តែថា ត្រូវជាអ្នកខ្វល់ខ្វាយតិច កុំធ្វើបាបទាំងឡាយឡើយ ដូចជាដំរីដ៏ប្រសើរ ដែលត្រាច់ទៅក្នុងព្រៃ ។

**កោសម្ពិយជាតកទី ២ ចប់**

# អដ្ឋកថា

## កោសម្ពិយជាតក

[ ៥១៤-៥២៣ ] ព្រះសាស្ដា កាលទ្រង់អាស្រ័យនៅក្នុងនគរកោសម្ពី នាឃោសិតារាម ទ្រង់ប្រារព្ធពួកភិក្ខុដែលឈ្លោះគ្នា ក្នុងនគរកោសម្ពីនោះ ទើបត្រាស់រឿងនេះ មានពាក្យផ្ដើមថា **បុថុសទ្ទោ** ដូច្នេះជាដើម ។

ផ្ទៃរឿងមានមកហើយ ក្នុងកោសម្ពិកក្ខន្ធកៈ ក្នុងទីនេះ មានសេចក្ដីសង្ខេបដូច្នេះ

បានឮថា គ្រានោះ ភិក្ខុ ២ រូប គឺវិនយធរមួយរូប ធម្មកថិកមួយរូប នៅក្នុងអាវាសជាមួយគ្នា ។ ភិក្ខុទាំង ២ រូបនោះ ថ្ងៃមួយ ព្រះធម្មកថិកបន្ទោបង់ឧច្ចារៈ បន្សល់ទឹកជម្រះទុកខាងក្នុងភាជនៈ ត្រង់ទីសម្រាប់ដាក់ទឹក ហើយចេញទៅ ព្រះវិនយធរចូលទៅក្នុងទីនោះតាមក្រោយ ឃើញនូវទឹកនោះ ហើយ ចេញមកសួរព្រះធម្មកថិកថា អាវុសោ លោកបន្សល់ទឹកទុកឬ ព្រះធម្មកថិក ឆ្លើយថា អើ ខ្ញុំបន្សល់ទុក ព្រះវិនយធរសួរថា លោកមិនដឹងថា ត្រូវអាបត្តិក្នុងសេចក្ដីនេះទេឬ ព្រះធម្មកថិកឆ្លើយថា ខ្ញុំមិនដឹង ព្រះវិនយធរពោលថា អាវុសោ ការដែលលោកបន្សល់ទឹកទុកក្នុងភាជនៈនោះ ជាអាបត្តិ ព្រះធម្មកថិកពោលថា បើដូច្នោះ ខ្ញុំនឹងសម្ដែងអាបត្តិ ព្រះវិនយធរពោលថា អាវុសោ បើលោកមិនក្លែងធ្វើ គឺធ្វើដោយភ្លេចស្មារតី ក៏មិនត្រូវអាបត្តិទេ ។ ព្រះធម្មកថិកយល់អាបត្តិនោះថា មិនជាអាបត្តិ ព្រះវិនយធរបានប្រាប់សិស្សរបស់ខ្លួនថា ធម្មកថិកនេះសូម្បីត្រូវអាបត្តិ ក៏មិនដឹង ពួកសិស្សរបស់ព្រះវិនយធរ ឃើញពួកសិស្សរបស់ព្រះធម្មកថិក ពោលថា ឧបជ្ឈាយ៍របស់ពួក

លោក ត្រូវអាបត្តិហើយ ក៏មិនដឹងថា ត្រូវអាបត្តិ ពួកសិស្សរបស់ព្រះធម្ម-កថិកបាននាំគ្នាទៅប្រាប់ដល់ឧបជ្ឈាយ៍របស់ខ្លួន ព្រះធម្មកថិកពោលយ៉ាងនេះថា ព្រះវិនយធរនេះ ដំបូងប្រាប់ថា មិនជាអាបត្តិ ឥឡូវនេះ ប្រាប់ថាជាអាបត្តិ នេះលោកនិយាយកុហក ពួកសិស្សរបស់ព្រះធម្មកថិកនាំគ្នាទៅពោលថា ឧបជ្ឈាយ៍របស់ពួកលោកនិយាយកុហក ហើយបានឈ្លោះគ្នា ដោយប្រការដូច្នេះ តាំងអំពីនោះមក ព្រះវិនយធរបានឱកាស ទើបធ្វើឧក្ខេបនីយកម្ម លើកទោសក្នុងការមិនឃើញអាបត្តិនោះ តាំងអំពីនោះមក ឧបាសកឧបាសិកាដែលថ្វាយបច្ច័យដល់ភិក្ខុទាំងនោះ បានបែកគ្នាជា ២ ពួក ភិក្ខុនីដែលទទួលឱវាទក្តី អារក្ខទេវតាក្តី អាកាសដ្ឋកទេវតាដែលធ្លាប់ស្និទ្ធស្នាលជាមួយអារក្ខទេវតាក្តី រហូតដល់ព្រហ្មលោកដែលជាបុថុជ្ជន បានបែកគ្នាជា ២ ពួក កើតនូវកោលាហល រហូតដល់អកនិដ្ឋកៈ ។

សម័យនោះ ភិក្ខុមួយរូបចូលទៅគាល់ព្រះតថាគត ក្រាបទូលការយល់ឃើញរបស់ពួកភិក្ខុ ដែលលើកទោសថា ព្រះធម្មកថិកនេះ ពួកយើងលើកទោសដោយកម្មដែលជាធម៌នោះឯង និងលទ្ធិរបស់ពួកភិក្ខុ ដែលប្រព្រឹត្តតាមព្រះធម្មកថិកដែលត្រូវលើកទោសថា អាចារ្យរបស់ពួកយើង ត្រូវលើកទោសដោយកម្មដែលមិនជាធម៌ និងការៈដែលពួកភិក្ខុទាំងនោះ សូម្បីពួកភិក្ខុដែលលើកទោសឃាត់ ក៏នៅតែត្រាច់តាមចោមរោមព្រះធម្មកថិកនោះ ឲ្យព្រះសាស្តាទ្រង់ជ្រាប ។ ព្រះមានព្រះភាគទ្រង់បញ្ជូនភិក្ខុទៅ ២ ដង ដោយមានព្រះពុទ្ធតម្រាស់ថា ចូរសង្ឃសាមគ្គីគ្នាចុះ ទ្រង់ជ្រាបថា ភិក្ខុទាំងនោះមិនប្រាថ្នានឹងសាមគ្គីគ្នា ក្នុងលើកទី ៣ ទ្រង់ជ្រាបថា ភិក្ខុសង្ឃបែកគ្នាហើយ ទើបយាង

ទៅកាន់សម្នាក់របស់ភិក្ខុទាំងនោះ ត្រាស់ទោសក្នុងការលើកទោសរបស់ពួកភិក្ខុដែលលើកទោស និងក្នុងការមិនឃើញអាបត្តិរបស់ពួកភិក្ខុក្រៅអំពីនោះ ហើយចៀសចេញទៅ ។ ព្រះសាស្តាទ្រង់បញ្ញត្តវត្តក្នុងរោងកត្តថា គប្បីអង្គុយក្នុងអាសនៈដែលមានអាសនៈដទៃខណ្ឌក្នុងចន្លោះដល់ភិក្ខុទាំងនោះ ដែលជាអ្នកធ្វើ ឧបោសថកម្មជាដើម ក្នុងសីមាជាមួយគ្នា ក្នុងឃោសិតារាមនោះឯង ហើយក៏កើតការប្រេះឆាគ្នាទៀត ក្នុងរោងកត្តជាដើម ទ្រង់បានឮថា ឥឡូវនេះ ពួកភិក្ខុនៅតែប្រេះឆានឹងគ្នា ក៏ទ្រង់យាងទៅជាស់តឿនថា ម្នាលភិក្ខុទាំងឡាយ កុំឡើយ កុំប្រេះឆាគ្នាឡើយ ដូច្នេះជាដើម ។ កាលព្រះធម្មវាទីមួយរូបមិនប្រាថ្នានឹងឲ្យព្រះមានព្រះភាគលំបាក ក៏ក្រាបទូលថា បពិត្រព្រះអង្គជាធម្មសាមី សូមទ្រង់ឈប់ចុះ សូមទ្រង់ខ្វល់ខ្វាយតិច សូមទ្រង់នៅជាសុខក្នុងទិដ្ឋធម៌ ពួក ខ្ញុំព្រះអង្គនឹងប្រាកដដោយជម្លោះ វិវាទ ដល់គ្នានិងគ្នា ទើបព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ រឿងធ្លាប់មានមកហើយ ក្នុងនគរពារាណសី មានព្រះរាជាគ្រងរាជ្យ ព្រះនាមព្រហ្មទត្ត ដូច្នេះ ។ ហើយត្រាស់រឿងដែលព្រះបាទព្រហ្មទត្តដណ្តើមរាជសម្បត្តិ របស់ព្រះបាទទីឃីតិកោសល ចាប់ព្រះបាទទីឃីតិកោសលដែលបន្លំលាក់ខ្លួន ឲ្យផ្តាច់ព្រះជន្មចោល និងរឿងដែលទីឃាវុកុមារថ្វាយជីវិតដល់ព្រះបាទព្រហ្មទត្ត ហើយក្សត្រទាំង ២ សាមគ្គីដល់គ្នានិងគ្នា បន្ទាប់អំពីនោះ ក៏ត្រាស់ទូន្មានថា ម្នាលភិក្ខុទាំងឡាយ ព្រះរាជាទ្រង់មានអាជ្ញា មានសស្ត្រា គង់មានខន្តិសោរច្ចៈដល់ម៉្លេះ ពួកអ្នកសុទ្ធតែជាអ្នកបួសក្នុងធម្មវិន័យ ដែលតថាគតពោលល្អហើយយ៉ាងនេះ គប្បីមានខន្តិ

សោរច្ចៈ សេចក្តីនេះ ជាលម្អក្នុងធម្មវិន័យនេះពិត ត្រាស់ហាមពីរបីដងថា ម្នាលភិក្ខុទាំងឡាយ កុំឡើយ កុំប្រេះឆាគ្នាឡើយ ទ្រង់ឃើញថា មិនអាចចុះសម្រុងគ្នាបាន ទើបទ្រង់ត្រិះរិះថា ពួកមោឃបុរសទាំងនេះ ត្រូវកិលេសរឹតរុំលំបាកនឹងឲ្យសិក្សា ទើបទ្រង់ចៀសចេញទៅ ។ ស្អែកឡើង ទ្រង់ត្រឡប់អំពីបិណ្ឌបាត ទ្រង់សម្រាកក្នុងព្រះគន្ធកុដិបន្តិច ទ្រង់រៀបចំសេនាសនៈ ទ្រង់កាន់បាត្រ និងចីវររបស់ទ្រង់ គង់នៅក្នុងអាកាសកណ្តាលជំនុំសង្ឃ ត្រាស់ព្រះគាថាទាំងឡាយនេះថា

ជនសុទ្ធតែមានសំឡេងខ្លាំងស្មើគ្នា មិនមានជនណាមួយ ដឹងថាអាត្មាអញជាបុគ្គលពាលឡើយ កាលបើសង្ឃកំពុងបែកគ្នា ក៏មិនមានជនណាមួយដឹងនូវហេតុដទៃ ឲ្យក្រៃលែងជាងនេះទៅទៀត ។

ពួកជនអ្នកភ្លេចស្មារតី មានអាការស្រដៀងនឹងបណ្ឌិត មានវាចាជាអារម្មណ៍ ចេះតែល្មោភនិយាយ តាមដែលខ្លួនចង់ និយាយឲ្យតែរួចពីមាត់ មានគេដឹកនាំដោយជម្លោះណា ក៏នៅតែមិនស្គាល់នូវជម្លោះនោះឡើយ ។

ពួកជនណា ចងសេចក្តីក្រោធនោះទុក ដោយគិតថា ជនឯណោះបានជេរអញ បានវាយអញ បានផ្ចាញ់អញ បានលួចយក ( ទ្រព្យ ) អញ ដូច្នេះ ពៀររបស់ជនទាំងនោះ រមែងមិនស្ងប់រម្ងាប់បានឡើយ ។

លុះតែពួកជនណា មិនចងសេចក្ដីក្រោធនោះទុក ដោយគិតថា ជនឯណោះបានជេរអញ បានវាយអញ បានផ្ចាញ់អញ បានលួចយក ( ទ្រព្យ ) អញ ដូច្នេះ ទើបពៀររបស់ជននោះ ស្ងប់រម្ងាប់បាន ។

ពៀរទាំងឡាយ ក្នុងលោកនេះ មិនស្ងប់រម្ងាប់ដោយពៀរក្នុងកាលណាមួយឡើយ មានតែស្ងប់រម្ងាប់ដោយមិនមានពៀរ នេះជាធម៌មានមកតាំងអំពីដើម ។

ពួនជនក្រៅពីបណ្ឌិត មិនដឹងច្បាស់ថា ពួកយើងនឹងដល់នូវសេចក្ដីវិនាស ក្នុងកណ្ដាលសង្ឃនេះទេ បណ្ដាជនទាំងនោះ លុះតែពួកជនណាដឹងច្បាស់ ( យ៉ាងនេះថា ពួកយើងនឹងដល់នូវសេចក្ដីវិនាស ) ទើបកលហធម៌ គឺការឈ្លោះប្រកែកទាំងឡាយស្ងប់រម្ងាប់អំពីសម្នាក់ពួកជននោះទៅបាន ។

អម្បាលពួកជនដែលបានកាត់ឆ្អឹងគ្នា បានសម្លាប់គ្នា បានលួចយកគោ សេះ និងទ្រព្យ ប្លន់យកទាំងដែនគេ គង់រួមគ្នាបានហេតុអ្វី ក៏ពួកអ្នករួមគ្នាមិនបាន ។

បើបុគ្គលបានសម្លាញ់ដែលមានប្រាជ្ញា ជាគ្រឿងរក្សាខ្លួន ជាអ្នកប្រាជ្ញត្រាច់ទៅជាមួយ មានវិហារធម៌ដ៏ប្រពៃ គប្បីគ្របសង្កត់នូវសេចក្ដីអន្តរាយទាំងឡាយទាំងពួង ហើយមានចិត្តត្រេកអរ មានស្មារតី ត្រាច់ទៅជាមួយនឹងសម្លាញ់នោះចុះ ។

បើបុគ្គលមិនបានសម្លាញ់ ដែលមានប្រាជ្ញាជាគ្រឿងរក្សាខ្លួន ជា

អ្នកប្រាជ្ញត្រាច់ទៅជាមួយគ្នា មានវិហារធម៌ដ៏ល្អទេ គប្បីត្រាច់ទៅតែម្នាក់ឯង ដូចជាព្រះរាជាលះបង់ដែន ដែលឈ្នះហើយ ( ពុំនោះសោត ) ដូចដំរីដ៏ប្រសើរ ដែលត្រាច់ទៅតែម្នាក់ឯងក្នុងព្រៃ ។

ការត្រាច់ទៅម្នាក់ឯង ប្រសើរជាង ( ព្រោះ ) សហាយតាគុណមិនមានក្នុងបុគ្គលពាលទេ បុគ្គលគួរត្រាច់ទៅតែម្នាក់ឯង តែថាត្រូវជាអ្នកខ្វល់ខ្វាយតិច កុំធ្វើបាបទាំងឡាយឡើយ ដូចជាដំរីដ៏ប្រសើរ ដែលត្រាច់ទៅក្នុងព្រៃ ដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទាំងនោះថា បុគ្គលពាល ឈ្មោះថា សុទ្ធតែមានសំឡេងខ្លាំង ព្រោះវិគ្គហៈថា មានសំឡេងអឺងកងគឹខ្លាំង ។ បទថា **សមជនោ** បានដល់ ជាបុគ្គលដូចគ្នាទាំងអស់ មានពាក្យដែលលោកអធិប្បាយថា បុគ្គលដែលធ្វើនូវជម្លោះទាំងអស់ មានសំឡេងអឺងកងស្មើគ្នា ព្រោះបន្លឺសំឡេងដោយជុំវិញ ។

បទថា **ន ពាលោ កោចិ មញ្ញថ** សេចក្តីថា បណ្តាបុគ្គលពាលទាំងនោះ បុគ្គលណាម្នាក់ ក៏មិនដឹងខ្លួនថា ជាបុគ្គលពាល សុទ្ធតែសម្គាល់ខ្លួនថា ជាបណ្ឌិត អធិប្បាយថា បុគ្គលដែលធ្វើនូវជម្លោះទាំងអស់នោះឯងរមែងមិនដឹងថា ខ្លួនជាបុគ្គលពាល ។ បទថា **នាញ្ញំ ភិយ្យោ អមញ្ញរុំ** សេចក្តីថា បុគ្គលណាម្នាក់ក៏មិនដឹងខ្លួនថា ជាបុគ្គលពាល កាលសង្ឃបែកគ្នាអ្នកដទៃសូម្បីតែម្នាក់ ក៏មិនដឹងហេតុនេះថា សង្ឃបែកគ្នា ព្រោះហេតុតែអញ ។

បទថា **បរិមុដ្ឋា** បានដល់ បុគ្គលមិនមានស្មារតី ។ បទថា **បណ្ឌិតាភាសា** សេចក្តីថា ឈ្មោះថា ដូចគ្នានឹងបណ្ឌិត ព្រោះសម្គាល់ខ្លួន ថាជាបណ្ឌិត ។ លោកអាទេស **វា** អក្ខរៈ ឲ្យជាវស្សរៈថា **វាចាគោចរ ភាណិនោ** ដូច្នេះ អធិប្បាយថា មានវាចាជាអារម្មណ៍ មិនមានអរិយធម៌ មានសតិប្បដ្ឋានជាដើមជាអារម្មណ៍ឡើយ និងជាបុគ្គលនិយាយច្រើន គឺច្រើនដោយពាក្យសម្តី ។ បទថា **យាវិច្ឆន្តិ មុខាយាមំ** សេចក្តីថា រមែងប្រាថ្នានឹងឲ្យសំឡេងចេញពីមាត់ដរាបណា ក៏ឈរជំទែងជើង ស្រែកចន្ទាលចេញទៅដរាបនោះ អធិប្បាយថា សូម្បីបុគ្គលម្នាក់ ក៏មិនធ្វើការបិទមាត់ ព្រោះគោរពក្នុងសង្ឃ ។ បទថា **យេន នីតា** សេចក្តីថា បុគ្គលនោះត្រូវការជម្លោះណា នាំទៅហើយកាន់ភាពជាអ្នកមិនមានការខ្មាសនេះ ។ បទថា **ន តំ វិទូ** សេចក្តីថា បុគ្គលនោះ មិនដឹងនូវជម្លោះនោះថា ការឈ្លោះនេះ មានទោសយ៉ាងនេះ ។ បទថា **យេ ចតំ ឧបនយ្ហន្តិ** សេចក្តីថា ជនពួកណាចូលទៅចងសេចក្តីក្រោធនោះ គឺដែលមានអាការថា បុគ្គលឯណោះបានជេរអញ ដូច្នេះជាដើម ។ បទថា **សនន្តនោ** បានដល់ ជារបស់ពីដើម ។ បទថា **បរេ** ជាដើម សេចក្តីថា បុគ្គលដែលធ្វើនូវជម្លោះក្រៅអំពីពួកបណ្ឌិត គឺពួកជនដទៃៗ ក្រៅអំពីពួកបណ្ឌិតនោះ ឈ្មោះថា **បរេ** ។ បរេជនទាំងនោះ ញុំាងការវិកវរឲ្យកើតឡើងក្នុងកណ្តាលសង្ឃនេះ រមែងមិនដឹងថា ពួកយើងនាំគ្នាលំបាក គឺពួកយើងនាំគ្នាវិនាស បានដល់ ពួកយើងនាំគ្នាទៅកាន់ទីជិត គឺកាន់សម្នាក់នៃមច្ចុរាជរឿយៗ ។ បទថា **យេ ច តត្ថ វិជានន្តិ** សេចក្តីថា ចំណែកជនទាំងឡាយ

ណា ក្នុងពួកជននោះ ដែលជាបណ្ឌិត រមែងដឹងបានថា ពួកយើងនឹងនាំគ្នាទៅកាន់ទីជិតនៃមច្ចុរាជ ។ បទថា **តតោ សម្មន្តិ មេធគា** សេចក្ដីថា ម្នាលភិក្ខុទាំងឡាយ ជនទាំងនោះកាលដឹងយ៉ាងនេះ ញ៉ាំងការធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញាឲ្យកើតឡើងហើយ ។ រមែងបដិបត្តិដើម្បីការចូលទៅស្ងប់នូវប្រកាន់ខ្ជាប់នៃជម្លោះបាន ។ បទថា **អដ្ឋិច្ឆិន្នា** សេចក្ដីថា ព្រះមានព្រះភាគត្រាស់ព្រះគាថានេះ ទ្រង់សំដៅដល់ព្រះបាទព្រហ្មទត្ត និងទីឃាវុកុមារទាំង ២ អង្គនោះ ក៏គង់ព្រមព្រៀងគ្នាបាន ហេតុអ្វី ពួកអ្នកមិនបានកាត់ឆ្អឹងរបស់មាតាបិតា មិនបានផ្ដាច់ជីវិតគ្នា មិនបានដណ្ដើមគោ សេះ និងទ្រព្យសម្បត្តិគ្នា ទើបមិនសាមគ្គីគ្នាទៅវិញ សេចក្ដីនេះ មានព្រះបរមពុទ្ធាធិប្បាយថា ម្នាលភិក្ខុទាំងឡាយ ព្រះរាជាទ្រង់កាន់យកអាជ្ញា និងសស្ត្រាគង់សាមគ្គីគ្នា សមាគមគ្នា ធ្វើសម្ពន្ធមេត្រីគ្នា ដោយអាវាហៈ និងវិវាហមង្គល ទ្រង់ផឹក ទ្រង់សោយរួមគ្នាបាន ពួកអ្នកបួសក្នុងសាសនាបែបនេះ មិនអាចរលាស់ត្រឹមតែពៀររបស់ខ្លួនបាន អ្វីជាភារៈនៃភិក្ខុរបស់អ្នក ។

ព្រះគាថាថា **សចេ លភេថ** ដូច្នេះជាដើម ព្រះមានព្រះភាគត្រាស់ដើម្បីទ្រង់សម្ដែងដល់គុណរបស់សម្លាញ់ជាបណ្ឌិត និងទោសរបស់សម្លាញ់ដែលជាបុគ្គលពាល ។ បទថា **អភិភុយ្យ សព្វានិ បរិស្សយានិ** សេចក្ដីថា គួរសរសើរជនមានសតិត្រាច់ទៅជាមួយសម្លាញ់នោះ និងគ្របសង្កត់អន្តរាយដែលប្រាកដ និងអន្តរាយដែលបិទបាំងទាំងពួងបាន ។ បទថា **រាជាវ រដ្ឋំ វិជិតំ** សេចក្ដីថា គប្បីត្រាច់ទៅតែម្នាក់ឯង ដូចព្រះរាជាមហាជនក និងអរិន្ទ-

មកជា ទ្រង់លះបង់នូវដែន យាងទៅមួយអង្គឯង ដូច្នោះ ។ បទថា **មាតង្គ-រញ្ញេវ នាគោ** សេចក្តីថា ព្រះមានព្រះភាគត្រាស់ហៅដំរីថា **មាតង្គ** ពាក្យថា **នាគ** នោះ ជាឈ្មោះនៃដំរីធំ លោកអធិប្បាយថា គួរត្រាច់ទៅតែម្នាក់ឯង និងមិនគួរធ្វើបាប ដូចដំរីមាតង្គៈអ្នកចិញ្ចឹមមាតា ដូចដំរីសេីលវហត្ថិ និងដូចដំរីបារិលេយ្យកៈ ត្រាច់ទៅក្នុងព្រៃតែម្នាក់ឯង និងមិនធ្វើបាប ដូច្នោះ ។

ព្រះសាស្តា កាលត្រាស់យ៉ាងនេះហើយ ក៏នៅតែមិនអាចឲ្យភិក្ខុទាំងនោះ ស្រុះស្រួលគ្នាបាន ទើបយាងទៅកាន់ពាលកលោណការាមគ្រាម ទ្រង់សម្តែងនូវអានិសង្សក្នុងការនៅតែម្នាក់ឯងដល់ព្រះភគុត្ថេរ បន្ទាប់អំពីនោះ បានយាងទៅដល់លំនៅរបស់កុលបុត្រ ៣ រូប ទ្រង់សម្តែងអានិសង្សក្នុងសាមគ្គីរសដល់កុលបុត្រទាំងនោះ បន្ទាប់អំពីនោះ ទ្រង់យាងដល់ដងព្រៃឈ្មោះបារិលេយ្យកៈ នៅក្នុងទីនោះអស់ ៣ ខែ ទ្រង់មិនយាងមកកាន់ក្រុងកោសម្ពីទៀតទេ ទ្រង់យាងទៅក្រុងសាវត្ថីតែម្តង ។

ពួកឧបាសកអ្នកក្រុងកោសម្ពី ប្រឹក្សាគ្នាថា លោកម្ចាស់អ្នកកោសម្ពីនេះធ្វើនូវសេចក្តីវិនាសឲ្យដល់ពួកយេីងច្រេីន ព្រះមានព្រះភាគ ទ្រង់ខ្ពើមពួកភិក្ខុទាំងនេះចៀសចេញទៅ ពួកយេីងមិនគួរធ្វើសាមីចិកម្ម មានការក្រោកទទួលជាដើមដល់ភិក្ខុទាំងនេះឡើយ និងកុំឲ្យបិណ្ឌបាតដល់លោកដែលចូលមកបិណ្ឌ-បាត កាលធ្វើយ៉ាងនេះ ភិក្ខុទាំងនេះ នឹងចៀសចេញទៅខ្លះ នឹងសឹកទៅខ្លះ នឹងឲ្យព្រះសាស្តាទ្រង់ជ្រះថ្លាខ្លះ ដូច្នេះហើយ ក៏ធ្វើតាមដែលប្រឹក្សាគ្នានោះ ភិក្ខុទាំងនោះ ត្រូវពួកឧបាសកដាក់ទណ្ឌកម្មបែបនោះ ទើបនាំគ្នាទៅកាន់ក្រុងសាវត្ថី

ទូលសូមខមាទោសនឹងព្រះមានព្រះភាគ ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតក ថា ព្រះរាជបិតាក្នុងកាលនោះ បានមកជាព្រះបាទសុទ្ធោទនមហារាជក្នុងកាល ឥឡូវនេះ ព្រះមាតាក្នុងកាលនោះ បានមកជាព្រះមហាមាយា ឯទីឃាវុកុមារ ក្នុងកាលនោះ គឺតថាគតនេះឯង ។ល។

## អដ្ឋកថា កោសម្ពិយជាតក ចប់

# សុត្តន្តបិដក

## មហាសុវរាជជាតក

[ ៥២៤ ] ( ស្តេចហង្ស និយាយនឹងស្តេចសេកថា ) កាលណាឈើមានផ្លែបរិបូណ៌ ពួកសត្វស្លាបក៏ហើរសំដៅទៅបរិភោគផ្លែឈើនោះ លុះពួកសត្វស្លាបបានដឹងថា ឈើអស់ផ្លែហើយក៏ហើរចេញអំពីដើមឈើនោះ ទៅកាន់ទិសផ្សេងៗ ក្នុងវេលាជាទីអស់ទៅនៃផ្លែ ។

[ ៥២៥ ] ម្នាលសេកមានចំពុះក្រហម អ្នកចូរត្រាច់ទៅកាន់ចារិក កុំឲ្យខ្លួនអ្នកស្លាប់ឡើយ ម្នាលសេក ម្តេចក៏អ្នកនៅសញ្ចប់សញ្ចឹងលើដើមឈើងាប់ ( នេះ ) ម្នាលសេកមានសម្បុរខៀវ ស្រដៀងនឹងឈើក្នុងវស្សន្តរដូវ យើងសូមជាស់តឿនអ្នក អ្នកចូរថាមកមើល ព្រោះហេតុអ្វី ក៏បានជាអ្នកមិនលះបង់នូវឈើងាប់នេះ ។

[ ៥២៦ ] ( ស្តេចសេកបតថា ) ម្នាលហង្ស ពួកសប្បុរសណាៗពួកវៀយៗ នូវធម៌របស់ពួកសប្បុរស លោកជាសម្លាញ់នឹងពួកសម្លាញ់ ( ទៅវិញទៅមកហើយ ) ពួកសប្បុរសនោះសូម្បីដល់នូវការអស់ទៅនៃជីវិត ក៏មិនលះបង់សម្លាញ់នោះចោលដោយគិតថា អស់ ឬមិនអស់ក្នុងកាលដែលបានសុខ និងទុក្ខឡើយ ។

[ ៥២៧ ] ម្នាលហង្ស ខ្ញុំជាសប្បុរសដែរ ដើមឈើនេះទុកជា

ញាតិ ឬជាសម្លាញ់របស់ខ្ញុំក៏បាន ខ្ញុំជាអ្នកត្រូវការដោយជីវិត ក៏មិនអាចនឹងលះបង់នូវដើមឈើនោះចោលឡើយ ( បើខ្ញុំដឹងថាឈើនោះអស់ហើយៗ លះបង់ចោល ) នុ៎ះ មិនមែនជាធម៌របស់សប្បុរសទេ ។

[ ៥២៨ ] ( ស្តេចហង្ស ... ) ម្នាលបក្សី សេចក្តីមេត្រី សេចក្តីជួបជុំ និងសេចក្តីស្និទ្ធស្នាលដែលអ្នកបានធ្វើហើយ ជាការប្រពៃណាស់ បើអ្នកពេញចិត្តនឹងធម៌នោះ អ្នកនឹងបានជាទីសរសើរនៃពួកវិញ្ញូជន ។

[ ៥២៩ ] ម្នាលសេក អ្នកមានស្លាបជាយាន ហើរទៅក្នុងអាកាស យើងឲ្យពរដល់អ្នក ម្នាលបក្សី បើអ្នកមានចិត្តប្រាថ្នានូវពរណាមួយ ចូរទទួលយកនូវពរនោះចុះ ។

[ ៥៣០ ] ( ស្តេចសេក ... ) ម្នាលហង្ស អ្នកគប្បីឲ្យនូវពរដល់ខ្ញុំ សូមឲ្យដើមឈើនេះត្រឡប់មានអាយុរស់វិញ សូមឲ្យដើមឈើនោះ មានមែក មានផ្លែលូតលាស់ល្អ មានផ្លែមានរសផ្អែមល្អ ។

[ ៥៣១ ] ( ស្តេចហង្ស ... ) ម្នាលសម្លាញ់ អ្នកចូរមើលដើមឈើដែលមានផ្លែដ៏លើសលុបនេះចុះ ទីលំនៅរបស់អ្នក ចូរកើតជាមួយនឹងដើមល្វា ដើមល្វានោះ ចូរមានមែក មានផ្លែ លូតលាស់ល្អ មានផ្លែ មានរសផ្អែមល្អ ។

[ ៥៣២ ] ( ស្តេចសោក ... ) បពិត្រសក្កៈ កាលបើយ៉ាងនេះ សូមឲ្យព្រះអង្គបានសេចក្ដីសុខ ព្រមទាំងពួកញាតិទាំងអស់ ឲ្យដូចខ្ញុំដែលបានសេចក្ដីសុខ ព្រោះបានឃើញដើមឈើ ប្រកបដោយផ្លែក្នុងថ្ងៃនេះឯង ។

[ ៥៣៣ ] ( អភិសម្ពុទ្ធគាថា ) ព្រះឥន្ទ្របានឮពាក្យសោកហើយ ក៏ធ្វើនូវដើមឈើនោះឲ្យមានផ្លែ រួចចៀសចេញទៅកាន់នន្ទនវនឧទ្យានរបស់ពួកទេវតា ជាមួយនឹងប្រពន្ធ ។

មហាសុវរាជជាតកទី ៣ ចប់

# អដ្ឋកថា

## មហាសុវរាជជាតក

[ ៥២៨-៥៣៣ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុមួយរូប ទើបត្រាស់រឿងនេះ មានពាក្យផ្តើមថា **ទុមោ យទា ហោតិ** ដូច្នេះ ។

បានឮថា ភិក្ខុរូបនោះ រៀនកម្មដ្ឋានក្នុងសម្នាក់ព្រះសាស្តាហើយ ទៅក្នុងព្រៃ អាស្រ័យស្រុកចុងកាត់មាត់ញកមួយកន្លែង ក្នុងដែនកោសលជនបទ ពួកអ្នកស្រុកនាំគ្នាសង់ទីសម្រាកពេលយប់ និងពេលថ្ងៃជាដើម ហើយធ្វើសេនាសនៈក្នុងទីដើរងាយស្រួលទៅមកប្រគេនដល់ភិក្ខុនោះ ទំនុកបម្រុងភិក្ខុនោះដោយគោរព កាលភិក្ខុនោះចាំវស្សាខែទី ១ ភ្លើងឆេះស្រុកនោះ សូម្បីតែគ្រាប់ពូជរបស់ពួកមនុស្សក៏មិនមានសល់ ទើបមិនអាចប្រគេនបិណ្ឌបាតដែលប្រណីតដល់ភិក្ខុនោះបាន លោកសូម្បីនៅក្នុងសេនាសនៈដែលជាសប្បាយ តែលំបាកដោយបិណ្ឌបាត ទើបមិនអាចឲ្យមគ្គ ឬផលកើតឡើងបាន កាលកន្លងទៅបាន ៣ ខែ លោកមកគាល់ព្រះសាស្តាៗ ធ្វើបដិសណ្ឋារៈ ហើយត្រាស់សួរថា ម្នាលភិក្ខុ អ្នកមិនលំបាកដោយបិណ្ឌបាតទេឬ សេនាសនៈជាទីសប្បាយដែរឬ ភិក្ខុរូបនោះបានទូលសេចក្តីនោះឲ្យទ្រង់ជ្រាប ព្រះសាស្តាកាលទ្រង់ជ្រាបថា លោកមានសេនាសនៈជាទីសប្បាយ ទើបត្រាស់ថា ម្នាលភិក្ខុ ធម្មតាសមណៈ គ្រាមានសេនាសនៈជាទីសប្បាយហើយ ក៏គួរលះនូវសេចក្តីលោភក្នុងអាហារចេញ ឆាន់តាមមានតាមបាននោះឯង ធ្វើសមណ-

ធម៌ បុរាណកបណ្ឌិតទាំងឡាយ សូម្បីកើតជាសត្វតិរច្ឆាន ទំពាលម្អិតនៃដើមឈើដែលខ្លួននៅអាស្រ័យ គង់លះនូវសេចក្តីលោភក្នុងអាហារ មានសេចក្តីសន្តោស មិនទម្លាយមិត្តធម៌ មិនទៅកាន់ទីដទៃ ហេតុអ្វី ទើបអ្នកគិតថាបិណ្ឌបាតតិច មិនឆ្ងាញ់ លះនូវសេនាសនៈដ៏សប្បាយចោល ភិក្ខុនោះទូលអារាធនាឲ្យត្រាស់រឿង ទើបទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល ត្រង់ព្រៃល្វាមួយកន្លែង ដែលតាំងនៅប្របមាត់ស្ទឹងគង្គាក្នុងហិមវន្តប្បទេស មានសត្វសេកអាស្រ័យនៅរាប់សែន បណ្តាសេកទាំងនោះ ស្តេចសេកមួយ កាលផ្លែរបស់ដើមឈើដែលខ្លួនអាស្រ័យនៅ អស់ហើយ របស់ឯណាទីមួយនៅសល់ ទោះបីជាពន្លក ស្លឹក សម្បក ឬស្រាយក៏ដោយ ក៏ស៊ីវត្ថុនោះ ហើយផឹកទឹកក្នុងស្ទឹងគង្គា មានការប្រាថ្នាតិច សន្តោសយ៉ាងក្រៃលែង មិនទៅទីដទៃឡើយ ដោយគុណ គឺការប្រាថ្នាតិច សន្តោសយ៉ាងក្រៃលែងរបស់ស្តេចសេកនោះ បានបណ្តាលឲ្យសក្កពិភពញាប់ញ័រ ។ សក្កទេវរាជពិចារណាមើល ក៏ឃើញហេតុនោះ កាលសាកល្បងស្តេចសេកទើបបណ្តាលឲ្យដើមឈើនោះរីងស្ងួតទៅ ដោយអានុភាពរបស់ទ្រង់ ដើមឈើនោះ សល់តែដង្គត់ ដែលមានប្រហោងតូចធំ កាលត្រូវខ្យល់បក់ ក៏មានសំឡេងប្រាកដ ដូចមានអ្នកណាមកជំ មានអាចម៍ខ្ទុតហូរចេញតាមប្រហោងដើមឈើនោះ ស្តេចសេកចឹកលម្អិតទាំងនោះបរិភោគ ហើយទៅផឹកទឹកក្នុងស្ទឹងគង្គា មិនទៅទីដទៃ ទំត្រង់កំពូលដើមល្វា ដោយមិនរួញរាចំពោះខ្យល់និងកម្តៅថ្ងៃ ។

សក្កទេវរាជ ទ្រង់ជ្រាបភាពដែលស្តេចសេកនោះ មានការប្រាថ្នាតិចក្រៃលែង ទ្រង់ត្រិះរិះថា អញនឹងឲ្យស្តេចសេកសម្តែងគុណក្នុងមិត្តធម៌ ហើយនឹងឲ្យពរដល់សេកនោះ ធ្វើដើមល្វាឲ្យមានផ្លែរឿយៗ ទៅ ហើយត្រឡប់មក កាលទ្រង់ត្រិះរិះដូច្នេះហើយ ទើបទ្រង់កាឡាខ្លួនជាស្តេចហង្សមួយ នាំនាងសុជាតាអសុរកញ្ញា ឲ្យធ្វើជាហង្សញីនៅអំពីខាងមុខ ហើរទៅដល់ព្រៃល្វានោះ ទំត្រង់មែកល្វាមួយដើមដែលនៅក្បែរគ្នា កាលផ្តើមចរចាជាមួយស្តេចសេកនោះ បានត្រាស់គាថាទី ១ ថា

កាលណាឈើមានផ្លែបរិបូណ៌ ពួកសត្វស្លាបក៏ហើរសំដៅទៅ
បរិភោគផ្លែឈើនោះ លុះពួកសត្វស្លាបបានដឹងថា ឈើអស់ផ្លែ
ហើយ ក៏ហើរចេញអំពីដើមឈើនោះ ទៅកាន់ទិសផ្សេងៗ ក្នុង
វេលាជាទីអស់ទៅនៃផ្លែ ដូច្នេះ ។

បណ្ឌិតគប្បីជ្រាបអត្ថនៃគាថានោះថា នៃស្តេចសេក កាលណា ដើមឈើមានផ្លែបរិបូណ៌ កាលនោះ ហ្វូងវិហគៈទាំងឡាយ រមែងនាំគ្នាមកចោមរោមបរិភោគផ្លែឈើនោះអំពីមែកនោះ មកកាន់មែកនេះ តែកាលដឹងថា ដើមឈើនោះអស់ផ្លែហើយ ហ្វូងវិហគៈទាំងឡាយ ក៏នាំគ្នាចេញពីដើមឈើនោះទៅកាន់ទិសតូចធំ ។

កាលត្រាស់យ៉ាងនេះហើយ កាលទ្រង់អញ្ជើញស្តេចសេកឲ្យចេញអំពីទីនោះ ទើបត្រាស់គាថាទី ២ ថា

ម្នាលសេកមានចំពុះក្រហម អ្នកចូរត្រាច់ទៅកាន់ចារិក កុំឲ្យខ្លួនអ្នកស្លាប់ឡើយ ម្នាលសេក ម្តេចក៏អ្នកនៅសញ្ជប់សញ្ជឹងលើដើមឈើឆាប់ ( នេះ ) ម្នាលសេក មានសម្បុរខៀវ ស្រដៀងនឹងឈើក្នុងវស្សន្តរដូវ យើងសូមដាស់តឿនអ្នក អ្នកចូរថាមកមើល ព្រោះហេតុអ្វី ក៏បានជាអ្នកមិនលះបង់នូវឈើឆាប់នេះដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឈាយសិ** សេចក្តីថា ហេតុអ្វី ទើបអ្នកសញ្ជប់សញ្ជឹង គឺសោកសៅ នៅត្រង់ចុងឈើឆាប់ ។ សព្ទថា **ឥង្ឃ** ត្រឹមតែជានិបាត ចុះក្នុងអត្ថថា ដាស់តឿន ។

បទថា **វស្សន្តសន្និភ** សេចក្តីថា ក្នុងរដូវភ្លៀង ដងព្រៃមានពណ៌ខៀវស្រងាត់ ដូចជេរជាសទៅដោយលម្អ និងភាពបរិបូណ៌ ព្រោះហេតុនោះស្តេចហង្សសរសើរស្តេចសេកនោះថា ម្នាលសេកមានសម្បុរខៀវ ស្រដៀងនឹងឈើ ក្នុងវស្សន្តរដូវ ។ បទថា **ន វិញ្ចសិ** បានដល់ មិនលះបង់ទៅ ។

លំដាប់នោះ ស្តេចសេកពោលនឹងស្តេចហង្សថា នែស្តេចហង្ស យើងលះបង់ដើមឈើនេះមិនបានទេ ព្រោះយើងមានកតញ្ញូកតវេទី ហើយបានពោល ២ គាថាថា

ម្នាលហង្ស ពួកសប្បុរស ណាព្រេករឿយៗ នូវធម៌របស់ពួកសប្បុរស លោកជាសម្លាញ់នឹងពួកសម្លាញ់ ( ទៅវិញទៅមកហើយ ) ពួកសប្បុរសនោះ សូម្បីដល់នូវការអស់ទៅនៃជីវិតក៏មិនលះបង់សម្លាញ់នោះចោល ដោយគិតថា អស់ ឬមិនអស់

ក្នុងកាលដែលបានសុខ និងទុក្ខឡើយ ។

ម្នាលហង្ស ខ្ញុំជាសប្បុរសដែរ ដើមឈើនេះទុកជាញាតិ ឬជាសម្លាញ់របស់ខ្ញុំក៏បាន ខ្ញុំជាអ្នកត្រូវការដោយជីវិត ក៏មិនអាចនឹងលះបង់នូវដើមឈើនោះចោលឡើយ ( បើខ្ញុំដឹងថា ឈើនោះអស់ហើយៗ លះបង់ចោល ) នុ៎ះ មិនមែនជាធម៌របស់សប្បុរសទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យេ វេ សខីនំ សខារោ ភវន្តិ** បានដល់ជនពួកណាជាសម្លាញ់របស់សម្លាញ់ទាំងឡាយ ។ បទថា **ខីណាំ អខីណាំ** សេចក្តីថា ធម្មតាបណ្ឌិតទាំងឡាយ រមែងមិនលះបង់សម្លាញ់ដែលអស់ទ្រព្យព្រោះរបស់ខ្លួនអស់ភោគទ្រព្យ ។ បទថា **សតំ ធម្មមនុស្សរន្តា** បានដល់រឭកដល់បវេណីរបស់បណ្ឌិតទាំងឡាយ ។ បទថា **ញាតី ច មេ** សេចក្តីថា បពិត្រស្តេចហង្ស ដើមឈើនេះ ឈ្មោះថា ជាញាតិរបស់យើង ព្រោះអត្ថថា ជាទីស្រឡាញ់ស្និទ្ធស្នាលផង ឈ្មោះថា ជាសម្លាញ់របស់យើង ព្រោះនៅរួមព្រៃជាមួយយើងផង ។ បទថា **ជីវិកត្ថោ** សេចក្តីថា យើងមិនអាចលះបង់ទៅ គ្រាន់តែដើម្បីចង់មានជីវិត ។

សក្កទេវរាជទ្រង់ស្តាប់ពាក្យរបស់ស្តេចសេកនោះហើយ ទ្រង់ត្រេកអរត្រាស់សរសើរ បំណងនឹងប្រទានពរ ទើបត្រាស់ ២ គាថាថា

ម្នាលបក្សី សេចក្តីមេត្រី សេចក្តីជួបជុំ និងសេចក្តីស្និទ្ធស្នាលដែលអ្នកបានធ្វើហើយ ជាការប្រពៃណាស់ បើអ្នកពេញចិត្តនឹង

ធម៌នោះ អ្នកនឹងបានជាទីសរសើរនៃពួកវិញ្ញូជន ។

ម្នាលសេក អ្នកមានស្លាបជាយាន ហើរទៅក្នុងអាកាស យើង
ឲ្យពរដល់អ្នក ម្នាលបក្សី បើអ្នកមានចិត្តប្រាថ្នានូវពរណាមួយ
ចូរទទួលយកនូវពរនោះចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សាធុ** សេចក្តីថា អ្នកបានធ្វើជាសាក្សី
ល្អហើយ ដោយការត្រេកអរ ។ បទថា **មេត្តិ សំសតិ សន្ថវោ** បានដល់
ភាពជាសម្លាញ់ មេត្រីភាព ការស្និទ្ធស្នាលក្នុងកណ្តាលបរិស័ទ ការមាន
មេត្រីដូចពោលមកនេះ អ្នកបានធ្វើល្អហើយ គឺធ្វើល្អពេកហើយ បានដល់
ធ្វើប្រសើរហើយ ។ បទថា **សចេតំ ធម្មំ** សេចក្តីថា បើអ្នកគាប់ចិត្តធម៌ គឺ
ការមេត្រីនោះ ។ បទថា **វិជានតំ** សេចក្តីថា កាលបើដូច្នោះ អ្នកក៏ជាបុគ្គល
គួរវិញ្ញូជនទាំងឡាយគប្បីសរសើរ ។ បទថា **សោ តេ** បានដល់ ខ្ញុំឲ្យពរ
ដល់អ្នក ។ បទថា **វរស្សុ** បានដល់ ចូរប្រាថ្នា ។ បទថា **មនសិច្ឆសិ**
សេចក្តីថា អ្នកប្រាថ្នាពរយ៉ាងណាមួយដោយចិត្ត ខ្ញុំនឹងឲ្យពរទាំងអស់ដល់
អ្នក ។ ស្តេចសេកកាលជ្រើសរើសពរ បានពោលគាថាទី ៧ ថា

ម្នាលហង្ស អ្នកគប្បីឲ្យនូវពរដល់ខ្ញុំ សូមឲ្យដើមឈើនេះ
ត្រឡប់មានអាយុរស់វិញ សូមឲ្យដើមឈើនោះ មានមែក មាន
ផ្លែលូតលាស់ល្អ មានផ្លែ មានរសផ្អែមល្អ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សាខវា** បានដល់ ចូរសម្បូរដោយមែក ។
បទថា **ផលិមា** បានដល់ ប្រកបដោយមែកដែលមានផ្លែ ។ បទថា **សំវិរុឡ្ហោ**

បានដល់ ចូរមានស្លឹកដុះដាលដោយជុំវិញ គឺចូរសម្បូរដោយស្លឹកខ្ចី ។ បទថា **មធុត្ថិកោ** បានដល់ ចូរមានផ្លែមានរសផ្អែមដូចទឹកឃ្មុំ និងផ្លែស្រគំដែលមានដោយធម្មជាតិ ដូច្នោះ ។ លំដាប់នោះ សក្កទេវរាជ កាលនឹងប្រទានពរដល់ស្តេចសេកនោះ បានពោលគាថាទី ៨ ថា

ម្នាលសម្លាញ់ អ្នកចូរមើលដើមឈើ ដែលមានផ្លែដ៏លើសលុបនេះចុះ ទីលំនៅរបស់អ្នក ចូរកើតជាមួយនឹងដើមល្វា ដើមល្វានោះ ចូរមានមែក មានផ្លែ លូតលាស់ល្អ មានផ្លែ មានរសផ្អែមល្អ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សហាវ តេ ហោតុ ឧទុម្ពរេន** សេចក្តីថា ការនៅរួមដោយភាពតែមួយជាមួយគ្នា ដោយដើមល្វា ចូរមានដល់អ្នក ។

កាលសក្កទេវរាជត្រាស់យ៉ាងនេះហើយ ក៏បាត់ភេទជាហង្ស ត្រឡប់ទៅជាសក្កទេវរាជវិញ សម្តែងអានុភាពរបស់ទ្រង់ និងនាងសុជាតា យកព្រះហស្តក្បង់ទឹកពីស្ទឹងគង្គា មកប្រោះព្រំដើមល្វា រំពេចនោះ ដើមល្វាដែលសម្បូរដោយមែក និងប្រគាប មានផ្លែឆ្ងាញ់ ក៏តាំងឡើងយ៉ាងស្រស់ត្រកាលដូចមុណ្ឌមណីបពិត ដូច្នោះ ស្តេចសេកឃើញដូច្នោះហើយ កើតសោមនស្សកាលសរសើរសក្កទេវរាជ បានពោលគាថាទី ៩ ថា

បពិត្រសក្កៈ កាលបើយ៉ាងនេះ សូមឲ្យព្រះអង្គបានសេចក្តីសុខព្រមទាំងពួកញាតិទាំងអស់ ឲ្យដូចខ្ញុំដែលបានសេចក្តីសុខ ព្រោះបានឃើញដើមឈើ ប្រកបដោយផ្លែក្នុងថ្ងៃនេះឯង ដូច្នេះ ។

ឯសក្កទេវរាជ កាលប្រទានពរដល់ស្តេចសេកនោះហើយ ទ្រង់ធ្វើដើមល្វាឲ្យមានផ្លែជានិច្ច ហើយត្រឡប់ទៅកាន់វិមានរបស់ទ្រង់ មួយអន្លើដោយនាងសុជាតា ។

ព្រះសាស្តាទ្រង់ត្រាស់អភិសម្ពុទ្ធគាថា ដែលសម្តែងដល់ន័យនោះខាងចុងថា

ព្រះឥន្ទបានឮពាក្យសេកហើយ ក៏ធ្វើនូវដើមឈើនោះឲ្យមានផ្លែ
រួចចៀសចេញទៅកាន់នន្ទនវនឧទ្យានរបស់ពួកទេវតា ជាមួយនឹង
ប្រពន្ធ ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ត្រាស់ថា នែភិក្ខុ បុរាណកបណ្ឌិតកើតជាសត្វតិរច្ឆាន គង់មិនល្មោភក្នុងអាហារ អ្នកបួសក្នុងសាសនាបែបនេះ ហេតុអ្វី ទើបល្មោភក្នុងអាហារ ចូរអ្នកនៅក្នុងទីនោះឯង ដូច្នេះហើយ ទ្រង់បង្រៀនកម្មដ្ឋានដល់ភិក្ខុនោះ កាលលោកទៅនៅទីនោះហើយចម្រើនវិបស្សនា បានសម្រេចអរហត្ត ហើយទ្រង់ប្រជុំជាតកថា សក្កទេវរាជក្នុងកាលនោះ បានមកជាអនុរុទ្ធក្នុងកាលឥឡូវនេះ ចំណែកស្តេចសេកក្នុងកាលនោះ គឺតថាគតនេះឯង ។ល។

**អដ្ឋកថាមហាសុវរាជជាតក ចប់**

# សុត្តន្តបិដក

## ចុល្លសុវកោរាជជាតក

[ ៥៣៤ ] ( ស្តេចហង្ស និយាយនឹងស្តេចសេកថា ) ដើមឈើទាំងឡាយច្រើនណាស់ ដែលមានស្លឹកខៀវ មានផ្លែជាអនេក ព្រោះហេតុអ្វីហ្ន៎ បានជាសេកនេះមានចិត្តរីករាយជានិច្ច តែនឹងដង្គត់ឈើពុកស្ងួត ។

[ ៥៣៥ ] ( ស្តេចសេក និយាយតបវិញថា ) យើងបានចូលទៅបរិភោគផ្លែឈើនោះ រាប់ដោយឆ្នាំច្រើនជាអនេក ទោះបីយើងដឹងថា ឈើនោះ មិនមានផ្លែហើយ ការមេត្រីនោះ ក៏នៅដូចដើម ។

[ ៥៣៦ ] ( ស្តេចហង្ស និយាយថា ) សត្វស្លាបទាំងឡាយ តែងលះបង់នូវដើមឈើដែលពុកស្ងួត ជ្រុះស្លឹកអស់មិនមានផ្លែហើយហើរទៅ ម្នាលអ្នកជាទ្វិជាតិ អ្នកសម្គាល់ឃើញទោស ( ក្នុងការលះបោលនោះ ) ដូចម្តេច ។

[ ៥៣៧ ] ( ស្តេចសេក និយាយថា ) ពួកសត្វណា មានសេចក្តីត្រូវការដោយផ្លែ ហើយគប់រកនូវដើមឈើ លុះដឹងថាមិនមានផ្លែ ក៏លះបោលនូវដើមឈើនោះ ពួកសត្វស្លាបនោះ

ឈ្មោះថា មានប្រាជ្ញា គិតតែប្រយោជន៍ផ្ទាល់ខ្លួន មានប្រាជ្ញាមិនល្អ រមែងញុំាងចំណែកនៃសេចក្តីរាប់អានឲ្យវិនាស ។

[ ៥៣៨ ] ( ស្តេចហង្ស និយាយថា ) ម្នាលបក្សី សេចក្តីមេត្រី សេចក្តីជួបជុំ និងសេចក្តីស្និទ្ធស្នាល ដែលអ្នកបានធ្វើហើយ ជាការប្រពៃណាស់ បើអ្នកពេញចិត្តនឹងធម៌នេះ អ្នកនឹងបានជាទីសរសើរនៃពួកវិញ្ញូជន ។

[ ៥៣៩ ] ម្នាលសេក អ្នកមានស្លាបជាយាន ហើរទៅតាមអាកាស យើងឲ្យពរដល់អ្នក ម្នាលបក្សី បើអ្នកមានចិត្តប្រាថ្នានូវពរណាទីមួយ ចូរទទួលយកពរនោះចុះ ។

[ ៥៤០ ] ( ស្តេចសេក និយាយថា ) ខ្ញុំសូមឲ្យបានឃើញនូវដើមឈើនោះ មានស្លឹក និងផ្លែឡើងវិញដូចដើម ខ្ញុំគប្បីរីករាយរឿយៗ ដូចមនុស្សក្រមុំបានកំណប់ទ្រព្យ ។

[ ៥៤១ ] ( អភិសម្ពុទ្ធគាថា ) លំដាប់នោះ ព្រះឥន្ទបានយកទឹកអម្រឹតមកស្រោចនូវឈើដុះលើផែនដី ដើមឈើនោះ មានមែកលូតលាស់ត្រសាយត្រសុំ មានម្លប់ដ៏ត្រជាក់ ជាទីរីករាយនៃចិត្ត ។

[ ៥៤២ ] ( ស្តេចសេក និយាយថា ) បពិត្រសក្កៈ កាលបើយ៉ាងនេះ សូមឲ្យព្រះអង្គបានសេចក្ដីសុខ ព្រមទាំងពួកញាតិទាំងអស់ ឲ្យដូចជាខ្ញុំដែលបានសេចក្ដីសុខ ព្រោះឃើញនូវដើមឈើដ៏ប្រកបដោយផ្លែក្នុងថ្ងៃនេះ ។

[ ៥៤៣ ] ( អភិសម្ពុទ្ធគាថា ) ព្រះឥន្ទ្របានឮពាក្យសេកហើយក៏ធ្វើនូវឈើនោះឲ្យមានផ្លែ រួចក៏ចៀសចេញទៅកាន់នន្ទនវនឧទ្យាន នៃទេវតាទាំងឡាយ ជាមួយនឹងភរិយា ។

ចុល្លសុវករាជជាតកទី ៤ ចប់

# អដ្ឋកថា

## ចុល្លសុវកោរាជជាតក

[ ៥៣៤-៥៤៣ ] ព្រះសាស្តា កាលគង់នៅក្នុងនគរសាវត្ថីត្រង់វត្តជេតពន ទ្រង់ប្រារព្ធវេរញ្ជកណ្ឌទើបត្រាស់រឿងនេះ មានពាក្យផ្តើមថា **សន្តិ រុក្ខា** ដូច្នេះជាដើម ។

កាលព្រះសាស្តាទ្រង់ចាំវស្សាក្នុងក្រុងវេរញ្ជាហើយ ទ្រង់យាងដល់នគរសាវត្ថីដោយលំដាប់ ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ ព្រះតថាគតជាក្សត្រសុខុមាលជាតិ ជាពុទ្ធសុខុមាលជាតិ ប្រកបដោយឥទ្ធានុភាពដ៏ធំ ។ វេរញ្ជព្រាហ្មណ៍និមន្តហើយ បានចាំវស្សាអស់កាល ៣ ខែ មិនបានភិក្ខាអំពីសម្នាក់វេរញ្ជព្រាហ្មណ៍សូម្បីតែមួយថ្ងៃ ព្រោះត្រូវមារបណ្តាលចិត្ត ទ្រង់លះនូវចំណង់ក្នុងអាហារ បានតម្កល់ព្រះជន្មដោយបាយសម្រាប់សេះដែលឈ្មួញសេះថ្វាយមួយថ្ងៃមួយកំបង់អស់កាល ៣ ខែ មិនបានយាងទៅកាន់ទីដទៃ ភាពដែលព្រះតថាគតប្រាថ្នាតិច សន្តោសនេះគួរសរសើរពន់ពេក ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយអម្បាញ់មិញនេះ ពួកអ្នកប្រជុំសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គដោយរឿងឈ្មោះនេះទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការលះលោភៈក្នុងអាហាររបស់តថាគតក្នុងកាលឥឡូវនេះ មិនគួរជាអស្ចារ្យទេ សូម្បីក្នុងកាលមុន តថាគតកើតជាសត្វតិរច្ឆានក៏បានលះលោភៈក្នុងអាហារមកហើយ ដូច្នេះហើយទ្រង់នាំយករឿងក្នុងអតីតមកសាធកៈ ដូចតទៅនេះថា

ផ្ទៃរឿងទាំងមូល គប្បីជ្រាបដោយពិស្ដារ តាមទំនងដែលពោលមកហើយខាងដើម តែក្នុងទីនេះ មានសេចក្ដីថា សក្កទេវរាជទ្រង់កាឡាខ្លួនជាស្ដេចហង្ស សន្ទនាជាមួយសេក ទើបត្រាស់គាថាទាំងនេះថា

ដើមឈើទាំងឡាយច្រើនណាស់ ដែលមានស្លឹកខៀវ មានផ្លែជាអនេក ព្រោះហេតុអ្វីហ្ន៎ បានជាសេកនេះ មានចិត្តរីករាយជានិច្ចតែនឹងដង្គត់ឈើពុកស្ងួត ។

យើងបានចូលទៅបរិភោគផ្លែឈើនោះ រាប់ដោយឆ្នាំ ច្រើនជាអនេក ទោះបីយើងដឹងថា ឈើនោះ មិនមានផ្លែហើយ ការមេត្រីនោះ ក៏នៅដូចដើម ។

សត្វស្លាបទាំងឡាយ តែងលះបង់នូវដើមឈើដែលពុកស្ងួត ជ្រុះស្លឹកអស់មិនមានផ្លែ ហើយហើរទៅ ម្នាលអ្នកជាទ្វិជាតិ អ្នកសម្គាល់ឃើញទោស ( ក្នុងការលះចោលនោះ ) ដូចម្ដេច ។

ពួកសត្វណា មានសេចក្ដីត្រូវការដោយផ្លែ ហើយគប់រកនូវដើមឈើ លុះដឹងថា មិនមានផ្លែ ក៏លះចោលនូវដើមឈើនោះ ពួកសត្វស្លាបនោះ ឈ្មោះថា មានប្រាជ្ញា គិតតែប្រយោជន៍ផ្ទាល់ខ្លួន មានប្រាជ្ញាមិនល្អ រមែងញ៉ាំងចំណែកនៃសេចក្ដីរាប់អានឲ្យវិនាស ។

ម្នាលបក្សី សេចក្ដីមេត្រី សេចក្ដីជួបជុំ និងសេចក្ដីស្និទ្ធស្នាលដែលអ្នកបានធ្វើហើយ ជាការប្រពៃណាស់ បើអ្នកពេញចិត្តនឹង

ធម៌នេះ អ្នកនឹងបានជាទីសរសើរនៃពួកវិញ្ញូជន ។

ម្នាលសេក អ្នកមានស្លាបជាយាន ហើរទៅតាមអាកាស យើងឲ្យពរដល់អ្នក ម្នាលបក្សី បើអ្នកមានចិត្តប្រាថ្នា នូវពរណានីមួយ ចូរទទួលយកពរនោះចុះ ។

ខ្ញុំសូមឲ្យបានឃើញនូវដើមឈើនោះ មានស្លឹក និងផ្លែឡើងវិញដូចដើម ខ្ញុំគប្បីរីករាយរឿយៗ ដូចមនុស្សកម្សត់ បានកំណប់ទ្រព្យ ។

លំដាប់នោះ ព្រះឥន្ទបានយកទឹកអម្រឹតមកស្រោចនូវឈើដុះលើផែនដី ដើមឈើនោះ មានមែកលូតលាស់ ត្រសាយត្រសុំ មានម្លប់ដ៏ត្រជាក់ ជាទីរីករាយនៃចិត្ត ។

បពិត្រសក្កៈ កាលបើយ៉ាងនេះ សូមឲ្យព្រះអង្គបានសេចក្តីសុខព្រមទាំងពួកញាតិទាំងអស់ ឲ្យដូចជាខ្ញុំដែលបានសេចក្តីសុខព្រោះឃើញនូវដើមឈើដ៏ប្រកបដោយផ្លែ ក្នុងថ្ងៃនេះ ។

ព្រះឥន្ទបានឮពាក្យសេកហើយ ក៏ធ្វើនូវឈើនោះ ឲ្យមានផ្លែ រួចក៏ចៀសចេញទៅកាន់នន្ទនវនឧទ្យាន នៃទេវតាទាំងឡាយ ជាមួយនឹងភរិយា ដូច្នេះ ។

គប្បីជ្រាបសេចក្តីដោយអំណាចនៃពាក្យដែលមានពីមុននោះឯង ខ្ញុំនឹងពណ៌នាចំពោះបទដែលលំបាកប៉ុណ្ណោះ ។

បទថា **ហរិតបត្តា** បានដល់ ស្រស់បំព្រងទៅដោយស្លឹកពណ៌ខៀវ ។

បទថា **កោលាបេ** បានដល់ ដែលមិនមានខ្លឹម កាលខ្យល់បក់ ក៏បន្លឺសំឡេង ដូចមានអ្នកណាមកវាយឲ្យឮ ដូច្នោះ ។ បទថា **សុវស្ស** សេចក្ដីថា ហេតុអ្វី ទើបស្ដេចសេកមានចិត្តត្រេកអរក្នុងដើមឈើបែបនេះ ។ បទថា **ផលស្ស** បាន ដល់ ផលរបស់ដើមឈើនោះ ។ បទថា **នេកវស្សគណោ** កែជា **អនេក-វស្សគណោ** ប្រែថា រាប់ដោយឆ្នាំជាច្រើនមកហើយ ។ បទថា **ពហូ** សេចក្ដី ថា ច្រើនរយ មាន ២ ឆ្នាំក៏មិនមែន ៣ ឆ្នាំក៏មិនមែន ដោយពិត គឺច្រើន ឆ្នាំមកហើយ ។ បទថា **វិទិត្វាន** សេចក្ដីថា ស្ដេចសេកកាលប្រកាសថា បពិត្រស្ដេចហង្ស ឥឡូវនេះ ពួកយើងសូម្បីដឹងថា ដើមឈើនេះមិនមានផ្លែ ក៏នៅតែរក្សាមេត្រីដូចមុន មេត្រីមានដរាបណា ពួកយើងក៏មិនទម្លាយនូវ មេត្រីដរាបនោះ ព្រោះបុគ្គលទម្លាយមេត្រី មិនមែនជាបុគ្គលល្អ មិនឈ្មោះថា សប្បុរស ។ បទថា **ឱបត្តំ** សេចក្ដីថា អស់ទៅ គឺមិនមានស្លឹក បានដល់ មានស្លឹកជ្រុះហើយ ។ បទថា **កឹ ទោសំ បស្សសេ** សេចក្ដីថា បក្សីដទៃនាំ គ្នាលះដើមឈើនោះទៅក្នុងទីដទៃ អ្នកឃើញទោសអ្វី ក្នុងការទៅយ៉ាងនេះ ។ បទថា **យេ ផលត្ថា** សេចក្ដីថា បក្សីពួកណាគប់រក គឺចូលទៅរក ព្រោះ ត្រូវការផ្លែឈើ គឺព្រោះផ្លែឈើជាហេតុ កាលដឹងថា ដើមឈើនោះមិនមាន ផ្លែ ក៏លះដើមឈើនោះទៅ ។ បទថា **អត្តត្ថបញ្ញា** សេចក្ដីថា សត្វទាំង នោះ ឈ្មោះថា មានបញ្ញាឃើញតែប្រយោជន៍ខ្លួន ព្រោះមានបញ្ញាដើម្បី ប្រយោជន៍របស់ខ្លួន គឺមានបញ្ញាតាំងនៅក្នុងខ្លួនប៉ុណ្ណោះ ដោយមិនពិចារណា ដល់អ្នកដទៃ ។ បទថា **បក្ខបាតិនោ** សេចក្ដីថា បក្សីទាំងនោះ កាលបំណង

សេចក្ដីចម្រើនដើម្បីខ្លួនប៉ុណ្ណោះ រមែងញុំាងចំណែកនៃមិត្តភាពឲ្យធ្លាក់ទៅ គឺឲ្យវិនាសទៅ ព្រោះហេតុនោះ ទើបឈ្មោះថា ជាអ្នកធ្វើចំណែកនៃមិត្តភាពឲ្យធ្លាក់ទៅ ម្យ៉ាងទៀត ឈ្មោះថា ជាអ្នកធ្វើចំណែកមិត្តភាពឲ្យធ្លាក់ទៅ ព្រោះអត្ថថា ធ្លាក់ទៅក្នុងចំណែករបស់ខ្លួនប៉ុណ្ណោះ ដូច្នេះក៏បាន ។ បទថា **អបិ ឆាម នំ** សេចក្ដីថា បពិត្រស្ដេចហង្ស បើមនោរថរបស់ខ្ញុំគប្បីសម្រេច និងពរដែលលោកឲ្យហើយ គប្បីសម្រេចសោត ធ្វើម្ដេច ខ្ញុំគប្បីឃើញដើមឈើនេះ ត្រឡប់មានស្លឹក មានផ្លែបានទៀត បន្ទាប់អំពីនោះ ខ្ញុំនឹងត្រេកអរក្នុងដើមឈើនេះ គឺគ្រាន់តែឃើញដើមនេះប៉ុណ្ណោះ ក៏ត្រេកអរបំផុត ដូចអ្នកក្រីក្របានកំណប់ទ្រព្យ ដូច្នោះ ។ បទថា **អមតមាធាយ** បានដល់ តាំងនៅហើយដោយអានុភាពរបស់សក្កៈ ដែលទ្រង់ក្បង់ទឹកពីស្ទឹងគង្គា មកប្រោះព្រំហើយ ក្នុងជាតកនេះ មានអភិសម្ពុទ្ធគាថា ២ គាថា នឹងគាថានេះ ។

ព្រះសាស្ដា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា សក្កទេវរាជក្នុងកាលនោះ បានមកជាអនុរុទ្ធក្នុងកាលឥឡូវនេះ ស្ដេចសេកក្នុងកាលនោះ គឺតថាគតនេះឯង ។៚

## អដ្ឋកថា ចុល្លសុវរាជជាតក ចប់

# សុត្តន្តបិដក

## ហារិតជាតក

[ ៥៤៤ ] *( ព្រះបាទព្រហ្មទត្ត ទ្រង់ត្រាស់សួរតាបសថា ) បពិត្រមហាព្រហ្ម ខ្ញុំបានឮថា ព្រះហារិតតាបសបរិភោគកាម ពាក្យនុ៎ះទទេទេឬ លោកជាបុគ្គលបរិសុទ្ធទេឬ ។*

[ ៥៤៥ ] *( ហារិតតាបសពោធិសត្វតបថា ) បពិត្រមហារាជ ពាក្យដែលទ្រង់បានព្រះសណ្តាប់មកយ៉ាងណា ពាក្យនុ៎ះពិតយ៉ាងនោះហើយ អាត្មាភាពជាបុគ្គលបានដើរទៅកាន់ផ្លូវខុស ជ្រប់នៅក្នុងអារម្មណ៍ដែលជាទីតាំងនៃសេចក្តីវង្វេង ។*

[ ៥៤៦ ] *( ព្រះរាជា ... ) បើបុគ្គលមិនអាចដើម្បីបន្ទោបង់នូវគំនិតមិនល្អ គឺរាគៈដែលកើតឡើងដោយប្រាជ្ញាណាបានទេ ប្រាជ្ញានោះ នឹងចាត់ថាមានប្រយោជន៍ ជាគុណជាតដ៏ល្អិត អាចគិតឃើញនូវរបស់ល្អដូចម្តេចបាន ។*

[ ៥៤៧ ] *( តាបស ... ) បពិត្រមហារាជ ធម៌ទាំង ៤ ប្រការនេះ គឺរាគៈ ទោសៈ មទៈ និងមោហៈ ជាកិលេសមានកម្លាំងក្លៀវក្លាបំផុតក្នុងលោក ប្រាជ្ញាមិនបានទីពំនាក់ ព្រោះតែកិលេសទាំងនោះ ។*

[ ៥៤៨ ] *( ព្រះរាជា ... ) លោកដ៏ចម្រើន ពួកយើងសន្មតថា ព្រះហារិតតាបស ជាព្រះអរហន្តបរិបូណ៌ដោយសីល ជាបុគ្គលបរិសុទ្ធ ជាអ្នកប្រាជ្ញ មានប្រាជ្ញាសម្រាប់ទម្លុះទម្លាយកិលេស ។*

[ ៥៤៩ ] ( តាបស ... ) បពិត្រព្រះរាជា វិតក្កទាំងឡាយ ដ៏លាមក ប្រកបដោយសុភនិមិត្ត និងប្រកបដោយរាគៈ តែងបៀតបៀនអ្នកប្រាជ្ញ ដែលជាអ្នកត្រេកអរក្នុងគុណធម៌របស់ឥសី ។

[ ៥៥០ ] ( ព្រះរាជា ... ) រាគៈនេះ ជាសភាពកើតអំពីសរីរៈ តែកើតឡើងហើយ រមែងប្រទូស្តនូវគុណឲ្យខូច សូមលោកលះរាគៈរបស់លោកនោះចេញ សេចក្តីចម្រើន ទើបកើតមានដល់លោក ត្បិតជនច្រើននាក់ សន្មតលោកថាជាអ្នកប្រាជ្ញ ។

[ ៥៥១ ] ( តាបស ... ) កាមទាំងឡាយនោះ ជាគ្រឿងធ្វើឲ្យងងឹត នាំមកនូវទុក្ខច្រើន មានពិសច្រើន អាត្មាភាពនឹងស្វែងរកនូវឫសនៃកាមទាំងឡាយនោះ នឹងកាត់ផ្តាច់នូវរាគៈ ព្រមទាំងចំណង ។

[ ៥៥២ ] ( អភិសម្ពុទ្ធគាថា ) ឥសីឈ្មោះហារិតៈ ជាអ្នកខំប្រឹងព្យាយាមដោយសច្ចៈ លុះពោលពាក្យនេះរួច ក៏លះបង់កាមរាគ ហើយបានចូលទៅកើតក្នុងព្រហ្មលោក ។

**ហារិតចជាតកទី ៥ ចប់**

# អដ្ឋកថា

## ហារិតចជាតក

[ ៥៤៤-៥៥២ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអផ្សុក ទើបត្រាស់រឿងនេះ មានពាក្យផ្តើមថា **សុតមេតំ មហាព្រហ្មេ** ដូច្នេះជាដើម ។

សេចក្តីសង្ខេបថា ភិក្ខុរូបនោះ ឃើញមាតុគ្រាមម្នាក់ តែងខ្លួនស្អាតបាត កើតនូវការអផ្សុក ទុកសក់ ក្រចក និងពុកមាត់វែង បំណងនឹងសឹក ឧបជ្ឈាយ៍អាចារ្យ ប្រៀនប្រដៅក៏មិនពេញចិត្ត ព្រះសាស្តាត្រាស់សួរថា ពិតឬភិក្ខុ បានឮថា អ្នកអផ្សុក កាលភិក្ខុនោះទូលថា ករុណាព្រះអង្គ ពិតហើយ ទើបត្រាស់សួរថា អ្នកអផ្សុកព្រោះហេតុអ្វី កាលភិក្ខុនោះក្រាបទូលថា អផ្សុកដោយអំណាចកិលេស ព្រោះបានឃើញមាតុគ្រាមតែងខ្លួនយ៉ាងស្អាត ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ ធម្មតាកិលេស រមែងមិនមានសេចក្តីត្រេកអរ ព្រោះកម្ចាត់នូវគុណ មានតែឲ្យធ្លាក់នរក កិលេសនោះ រឿងអ្វីដែលមិនធ្វើឲ្យអ្នកលំបាកនោះ ខ្យល់ខ្លាំងដែលអាចបក់ភ្នំសិនេរុឲ្យកម្រើក រឿងអ្វីដែលថា មិនបក់ស្លឹកឈើចាស់ៗ ឲ្យខ្ចាត់ខ្ចាយបាននោះ សូម្បីមហាបុរសវិសុទ្ធិជាតិ បានអភិញ្ញា ៥ សមាបត្តិ ៨ ដើរតាមគន្លងពោធិញ្ញាណ ព្រោះអាស្រ័យកិលេសនេះ ក៏មិនអាចតម្កល់សតិបាន សាបសូន្យចាកឈាន នឹងពោលទៅថ្វីដល់អ្នក ដូច្នេះហើយ ទើបទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ មានសម្បត្តិ ៨០ កោដិ ក្នុងនិគមមួយ

ឪពុកម្ដាយបានដាក់ឈ្មោះឲ្យថា ហារិតកុមារ ព្រោះលោកមានពណ៌សម្បុរដូចមាស ។ កាលកុមារចម្រើនវ័យហើយ សម្រេចការសិក្សាក្នុងនគរតក្កសិលា ប្រមូលទ្រព្យ កាលមាតាបិតាអនិច្ចកម្មទៅហើយ បានពិនិត្យមើលទ្រព្យសម្បត្តិ កើតគំនិតឡើងថា ទ្រព្យប៉ុណ្ណោះដែលនៅប្រាកដ ឯអ្នកដែលធ្វើទ្រព្យឲ្យកើតឡើង មិនប្រាកដ អាត្មាអញក៏ត្រូវបែកខ្ទេចខ្ទីក្នុងមាត់នៃមច្ចុរាជដូច្នេះ ខ្លាចចំពោះមរណភ័យ បានឲ្យទានដ៏ធំ ហើយចូលទៅកាន់ហិមវន្តប្បទេស បួសជាឥសី ក្នុងថ្ងៃទី ៧ បានអភិញ្ញា ៥ និងសមាបត្តិ ៨ មានត្រាវដំឡូង និងផ្លែឈើក្នុងព្រៃជាអាហារ តម្កល់ជីវិតក្នុងទីនោះអស់កាលយូរ ត្រូវការបរិភោគអាហារដែលមានរសជូរប្រៃ ទើបចុះអំពីភ្នំ ទៅដោយលំដាប់ ដល់នគរពារាណសី ចូលទៅក្នុងរាជឧទ្យាន ស្អែកឡើង ត្រាច់ភិក្ខាចារក្នុងនគរពារាណសី ដល់លានព្រះរាជវាំង ព្រះរាជាទ្រង់ឃើញតាបសនោះ មានព្រះហឫទ័យជ្រះថ្លា និមន្តឲ្យគង់លើរាជបល្ល័ង្ក ខាងក្រោមស្វេតច្ឆត្រ ឲ្យឆាន់ភោជនដែលមានរសដ៏ប្រសើរផ្សេងៗ លុះតាបសឆាន់ហើយ អនុមោទនា គ្រាចប់អនុមោទនា ព្រះរាជាត្រេកអរក្រៃលែងឡើង ត្រាស់សួរថា លោកម្ចាស់គិតនិមន្តទៅឯណាទៀត តាបសថ្វាយព្រះពរថា មហាបពិត្រ អាត្មាភាពរកទីចាំវស្សា ។ ព្រះរាជាត្រាស់ថា សាធុ លោកម្ចាស់ ។ កាលសោយព្រះក្រយាហារស្រេចហើយ ទ្រង់នាំតាបសទៅព្រះរាជឧទ្យាន ឲ្យគេសាងទីសម្រាកពេលយប់ និងទីសម្រាក់ពេលថ្ងៃជាដើមប្រគេនតាបស ឲ្យអ្នករក្សាឧទ្យានចាំប្រណិប័តន៍ ទ្រង់អភិវាទហើយ យាងត្រឡប់ ។ តាំងអំពីនោះមក

ព្រះមហាសត្វ បានឆាន់ត្រង់ព្រះរាជមន្ទីរជានិច្ច អស់កាល ១២ ឆ្នាំ ។

ថ្ងៃមួយ ព្រះរាជាយាងទៅបង្ក្រាបជាយដែន ដែលបង្កនូវការបះបោរ ទ្រង់ទុកដាក់ព្រះមហាសត្វដល់ព្រះរាជទេវីថា នែនាង នាងកុំភ្លេចបុញ្ញក្ខេត្ត របស់យើង ហើយទ្រង់យាងទៅ ។ តាំងអំពីនោះ ព្រះរាជទេវីបានអង្គាស ព្រះមហាសត្វផ្ទាល់ព្រះហស្ត ថ្ងៃមួយ ព្រះនាងរៀបចំភោជនស្រេចបាច់ហើយ កាលតាបសមិនទាន់មក ព្រះនាងស្រពស្រង់ដោយទឹកក្រអូប ហើយទ្រទ្រង់ នូវសំពត់ដែលមានសាច់ម៉ដ្ឋ បើកសីហបញ្ជរ ប្រថាប់លើគ្រែតូច ឲ្យខ្យល់ បក់ត្រូវព្រះវរកាយ ។ ព្រះមហាសត្វស្លៀកដណ្តប់ស្រេចបាច់ហើយ កាន់នូវ ភាជនៈសម្រាប់ភិក្ខា ហោះមកដល់សីហបញ្ជរ ព្រះរាជទេវីបានស្តាប់សំឡេង សំពត់ស្បូវក្លាំងរបស់ព្រះមហាសត្វ ក៏ក្រោកឡើងដោយរហ័ស ព្រះភូសាក៏ រអិលចុះ វិសភាគារម្មណ៍បានប៉ះចក្ខុព្រះមហាសត្វ រំពេចនោះឯង កិលេស ដែលដេកត្រាំខាងក្នុងមហាសត្វនោះ ច្រើនសែនកោដិឆ្នាំ មានអាការដូចជា អាសិរពិស ដេកក្នុងត្រក ក៏កម្រើកឡើង ធ្វើឈានឲ្យអន្តរធានទៅ ។ ព្រះ មហាសត្វមិនអាចទប់ស្មារតីបាន ទើបចូលទៅចាប់ព្រះហស្តព្រះទេវីទាំង ២ ក៏ទម្លាក់វាំងននចុះ ហើយសេពលោកធម៌ជាមួយគ្នា ។ កាលមហាសត្វឆាន់ កត្តាហារហើយ ក៏ទៅដោយជើង ទៅកាន់ព្រះរាជឧទ្យាន តាំងអំពីថ្ងៃនោះមក បានធ្វើយ៉ាងនោះរាល់ៗ ថ្ងៃ ។

ដំណឹងដែលព្រះមហាសត្វសេពលោកធម៌ជាមួយព្រះរាជទេវី បានផ្សព្វ ផ្សាយទៅពេញព្រះនគរ ពួកអមាត្យបានបញ្ជូនលិខិត ទៅក្រាបទូលដល់ព្រះ

រាជាថា ហារិតចតាបសបានធ្វើយ៉ាងនេះ ។ ព្រះរាជាមិនជឿ ដោយទ្រង់ត្រិះរិះថា ពួកអមាត្យបំណងនឹងបំបែកយើង ទើបពោលយ៉ាងនេះ ។ កាលទ្រង់បង្រ្កាបជាយដែនឲ្យរាបទាបហើយ ក៏ត្រឡប់មកកាន់នគរពារាណសី ធ្វើប្រទក្សិណនគរហើយ យាងទៅកាន់សម្នាក់ព្រះរាជទេវី មានព្រះតម្រាស់សួរថា បានឮថា ហារិតចតាបស លោកម្ចាស់របស់យើងសេពលោកធម៌នឹងនាងពិតឬ ព្រះទេវីក្រាបទូលថា ពិតព្រះអង្គ ។ ព្រះរាជាមិនទាន់ជឿព្រះរាជទេវី ទ្រង់ត្រិះរិះថា អញនឹងសួរតាបស ។ ទើបយាងទៅព្រះរាជឧទ្យាន នមស្ការហើយ ក៏ប្រថាប់គង់ក្នុងទីសមគួរនាចំណែកម្ខាង កាលត្រាស់សួរសេចក្តីនោះ បានត្រាស់គាថាទី ១ ថា

បពិត្រមហាព្រហ្ម ខ្ញុំបានឮថា ព្រះហារិតតាបស បរិភោគកាម

ពាក្យនុ៎ះទទេទេឬ លោកជាបុគ្គលបរិសុទ្ធទេឬ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កច្ចេតំ** កាត់បទជា **កច្ចិ ឯតំ** សេចក្តីថា ពាក្យដែលញោមបានឮថា ហារិតចតាបសបរិភោគកាមដូច្នេះនោះ ជាពាក្យទទេ គឺជាពាក្យមិនពិតទេដឹង លោកនៅជាអ្នកបរិសុទ្ធទេឬ ។

តាបសគិតថា បើអញទូលថា មិនបានបរិភោគកាម ព្រះរាជាក៏ជឿអញប៉ុណ្ណោះ តែក្នុងលោកនេះ ឈ្មោះថា ទីពឹង ដូចគ្មានឹងសច្ចៈមិនមាន ព្រោះថា អ្នកដែលលះបង់ពាក្យសច្ចៈចោលហើយ មិនអាចអង្គុយត្រង់ពោធិបល្ល័ង្កសម្រេចពោធិញ្ញាណបានឡើយ អញគួរពោលតែសច្ចៈប៉ុណ្ណោះ ។ ពិតហើយ បាណាតិបាតក្តី អទិន្នាទានក្តី កាមេសុមិច្ឆាក្តី សុរាបានក្តី រមែងមានដល់ព្រះ

ពោធិសត្វខ្វះៗ ក្នុងឋានៈណាមួយ តែមុសាវាទដែលពោលឲ្យឃ្លៀងឃ្លាត កាច់បំបាក់នូវប្រយោជន៍ មិនមានដល់ព្រះពោធិសត្វឡើយ ដូច្នោះ កាលតាបសពោលនូវពាក្យសច្ចៈ ទើបពោលគាថាទី ២ ថា

បពិត្រមហារាជ ពាក្យដែលទ្រង់បានព្រះសណ្ដាប់មក យ៉ាងណា ពាក្យនុ៎ះ ពិតយ៉ាងនោះហើយ អាត្មាភាពជាបុគ្គលបានដើរទៅកាន់ផ្លូវខុស ជ្រប់នៅក្នុងអារម្មណ៍ដែលជាទីតាំងនៃសេចក្ដីវង្វេង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **មោហនេយ្យេសុ** បានដល់ ក្នុងកាមគុណ ។ ពិតហើយ សត្វលោកទាំងឡាយ រមែងវង្វេងក្នុងកាមគុណ ព្រោះហេតុនោះទើបកាមគុណ ហៅថា **មោហនេយ្យ** ។ ព្រះរាជាទ្រង់បានស្ដាប់ដូច្នោះ ទើបត្រាស់គាថាទី ៣ ថា

បើបុគ្គលមិនអាច ដើម្បីបន្ទោបង់នូវគំនិតមិនល្អ គឺរាគៈដែលកើតឡើងដោយប្រាជ្ញាណាបានទេ ប្រាជ្ញានោះ នឹងចាត់ថា មានប្រយោជន៍ ជាគុណជាតដ៏ល្អិត អាចគិតឃើញនូវរបស់ល្អដូចម្ដេចបាន ដូច្នេះ ។

សព្ទថា **អទុ** ក្នុងគាថានោះត្រឹមតែជានិបាត ។ លោកអធិប្បាយពាក្យនេះថា បពិត្រលោកម្ចាស់ ធម្មតាភេសជ្ជៈ ជាទីពឹងរបស់អ្នកជំងឺ ទឹកផឹកជាទីពឹងរបស់អ្នកស្រេក បញ្ញាដ៏ល្អិតដែលគិតនូវរបស់ល្អ គឺដែលជាប្រយោជន៍ជាគ្រឿងបន្ទោបង់រាគៈដែលកើតឡើងហើយរបស់លោក តើមានប្រយោជន៍

អ្វី ។

បទថា **កឹមនោ ឯ វិនោទយេ** សេចក្តីថា ហេតុអ្វី ទើបលោកមិនអាចប្រើបញ្ញានោះបន្ទោបង់នូវការគិតបាន ។

លំដាប់នោះ ហរិតចតាបស កាលនឹងសម្តែងកម្លាំងរបស់កិលេសដល់ព្រះរាជា បានពោលគាថាទី ៤ ថា

បពិត្រមហារាជ ធម៌ទាំង ៤ ប្រការនេះ គឺរាគៈ ទោសៈ មទៈ
និងមោហៈ ជាកិលេសមានកម្លាំងក្លៀវក្លាបំផុត ក្នុងលោក
ប្រាជ្ញាមិនបានទីពំនាក់ ព្រោះតែកិលេសទាំងនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យត្ថ** ជាដើម សេចក្តីថា កាលកិលេសទាំងឡាយណាចាក់ដោតហើយ បញ្ញារមែងឈមចុះមិនដល់ គឺតាំងនៅដូចបុគ្គលធ្លាក់ក្នុងជំនន់ទឹកធំ ដូច្នោះ ។ ព្រះរាជាបានស្តាប់ដូច្នោះ ទើបត្រាស់គាថាទី ៥ ថា

លោកដ៏ចម្រើន ពួកយើងសន្មតថា ព្រះហរិតតាបស ជាព្រះ
អរហន្តបរិបូណ៌ដោយសីល ជាបុគ្គលបរិសុទ្ធ ជាអ្នកប្រាជ្ញ មាន
ប្រាជ្ញាសម្រាប់ទម្លុះទម្លាយកិលេស ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឥតិ នោ សម្មតោ** សេចក្តីថា ញោមបានលើកតម្កើង គឺបានសរសើរលោកហើយយ៉ាងនេះ ។ ហរិតចតាបសបានស្តាប់ដូច្នេះហើយ ក៏ពោលគាថាទី ៦ ជាបន្តថា

បពិត្រព្រះរាជា វិតក្កទាំងឡាយដ៏លាមក ប្រកបដោយសុក-

និមិត្ត និងប្រកបដោយរាគៈ តែងបៀតបៀនអ្នកប្រាជ្ញ ដែលជា
អ្នកត្រេកអរក្នុងគុណធម៌របស់ឥសី ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សុភា** គឺប្រព្រឹត្តទៅហើយ ដោយការប្រកាន់និមិត្តថាស្អាត ។

លំដាប់នោះ ព្រះរាជាកាលឲ្យហរិតចតាបសកើតឧស្សាហៈ ក្នុងការលះកិលេស ទើបត្រាស់គាថាទី ៧ ថា

រាគៈនេះ ជាសភាពកើតអំពីសរីរៈ តែកើតឡើងហើយ រមែង
ប្រទូស្តនូវគុណឲ្យខូច សូមលោកលះរាគៈរបស់លោកនោះចេញ
សេចក្ដីចម្រើន ទើបកើតមានដល់លោក ត្បិតជនច្រើននាក់
សន្មតលោកថាជាអ្នកប្រាជ្ញ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វណ្ណវិទូសនោ តវ** បានដល់ ជារបស់ទម្លាយនូវពណ៌សម្បុរកាយ និងគុណរបស់លោក ។ បទថា **ពហុនាសិ** សេចក្ដីថា លោកជាបុគ្គលដែលជនច្រើនសន្មតហើយថាជាអ្នកមានបញ្ញា ។

កាលនោះ ព្រះមហាសត្វបានស្ដាប់ដូច្នេះហើយ បែរជាបានសតិកំណត់ទោសក្នុងកាមទាំងឡាយហើយ ពោលគាថាទី ៨ ថា

កាមទាំងឡាយនោះ ជាគ្រឿងធ្វើឲ្យងងឹត នាំមកនូវទុក្ខច្រើន
មានពិសច្រើន អាត្មាភាពនឹងស្វែងរកនូវឫសនៃកាមទាំងឡាយ
នោះ នឹងកាត់ផ្ដាច់នូវរាគៈ ព្រមទាំងចំណង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អន្ធការណោ** បានដល់ ឈ្មោះថា អន្ធករណៈ

ព្រោះធ្វើបញ្ញាចក្ខុឲ្យវិនាស ។ បទថា **ពហុទុក្ខេ** នេះ បណ្ឌិតគប្បីនាំសូត្រ ( ក្នុងមជ្ឈិមនិកាយ មូលបណ្ណាសក ) ថា កាមទាំងឡាយ មានសេចក្ដីសុខតិចដូច្នេះជាដើម មកសម្ដែងដល់ភាពដែលកាមទាំងនោះមានទុក្ខច្រើន ។ បទថា **មហាវិសេ** បានដល់ ឈ្មោះថា **មហាវិស** ព្រោះពិស គឺសម្បយុត្តក្កិលេស និងពិស គឺវិបាក ជារបស់ធំក្រៃលែង ។

បទថា **តេសំ មូលំ** សេចក្ដីថា អាត្មានឹងជញ្ជឹងគិត គឺនឹងស្វែងរកមូលនៃកាមទាំងនោះ ដើម្បីលះកាមដែលមានប្រការដូចពោលហើយនោះចេញ ។

សួរថា អ្វីជាឫសគល់នៃកាមទាំងនោះ ឆ្លើយថា អយោនិសោមនសិការ ។

បទថា **ឆេជ្ជំ រាគំ សពន្ធនំ** សេចក្ដីថា មហាបពិត្រ ឥឡូវនេះ អាត្មានឹងកាត់នូវតម្រេកដែលជាគ្រឿងចង ព្រោះចំណង គឺសុភនិមិត្ត ដោយប្រហារដោយដាវ គឺបញ្ញា កាលពោលដូច្នេះហើយ បានសូមព្រះរាជទានឱកាសថា មហាបពិត្រ សូមទ្រង់ប្រទានឱកាសដល់អាត្មាបន្តិច ហើយចូលទៅកាន់បណ្ណសាលា ពិចារណាកសិណ ញុំាងឈានដែលវិនាសហើយ ឲ្យកើតឡើងជាថ្មី ចេញអំពីបណ្ណសាលា អង្គុយពត់ភ្នែនក្នុងអាកាស ថ្វាយព្រះធម្មទេសនាដល់ព្រះរាជា ហើយទូលថា មហាបពិត្រ អាត្មាត្រូវតិះដៀលក្នុងកណ្ដាលមហាជន ព្រោះមកក្នុងទីមិនសមគួរ សូមទ្រង់កុំប្រមាទ ឥឡូវនេះ អាត្មានឹងទៅកាន់ដងព្រៃ ឲ្យផុតអំពីក្លិនស្ត្រី កាលព្រះរាជាទ្រង់កំពុងបរិទេវនា បានទៅកាន់ហិមវន្តប្បទេស មិនសាបសូន្យចាកឈាន ចូលដល់ព្រហ្មលោក ។

ព្រះសាស្តាទ្រង់ត្រាស់ដឹងហើយ ទ្រង់ជ្រាបរឿងនោះ ទើបត្រាស់អភិសម្ពុទ្ធគាថានេះថា

ឥសីឈ្មោះហារិតៈ ជាអ្នកខំប្រឹងព្យាយាមដោយសច្ចៈ លុះ
ពោលពាក្យនេះរួច ក៏លះបង់កាមរាគ ហើយបានចូលទៅកើត
ក្នុងព្រហ្មលោក ដូច្នេះ ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងកាលចប់សច្ចៈ ភិក្ខុអផ្សុកតាំងនៅក្នុងអរហត្តផល ហើយព្រះទសពលទ្រង់សមោធានជាតកថា ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទ ក្នុងកាលឥឡូវនេះ ឯហារិតតាបស ក្នុងកាលនោះ គឺតថាគតនេះឯង ។ល។

## អដ្ឋកថា ហារិតជាតក ចប់

# សុត្តន្តបិដក

## បទកុសលមាណវកជាតក

[ ៥៥៣ ] ( ករិយានិយាយថា ) ទឹកទន្លេគង្គាក្តួចយកទៅនូវបុរសឈ្មោះបាដលិ ជាអ្នកចេះដឹងច្រើន ពោលនូវពាក្យដ៏វិចិត្រ នៃអ្នកដ៏ចម្រើនដែលទឹកក្តួចយកទៅ សូមអ្នកឲ្យនូវចម្រៀងយ៉ាងខ្លីមួយដល់ខ្ញុំ ។

[ ៥៥៤ ] ( ស្វាមីនិយាយតបថា ) ពួកជនតែងស្រោចនូវបុគ្គលមានទុក្ខដោយទឹកណា តែងស្រោចនូវបុគ្គលដែលមានសេចក្តីក្រវល់ក្រវាយដោយទឹកណា យើងគង់នឹងស្លាប់ ក្នុងកណ្តាលទឹកនោះ ភ័យកើតមកអំពីវត្ថុជាទីពឹងហើយ ។

[ ៥៥៥ ] ( នាយស្មូនឆ្នាំងនិយាយថា ) ពូជទាំងឡាយ តែងដុះឡើងលើផែនដីណា ពួកសត្វឋិតនៅលើផែនដីណា ផែនដីនោះបៀតបៀននូវក្បាលអញ ភ័យកើតអំពីវត្ថុជាទីពឹងហើយ ។

[ ៥៥៦ ] ( បុរសម្នាក់និយាយថា ) ពួកជនគេចម្អិនបាយដោយភ្លើងណា គេកម្ចាត់បង់នូវរងាដោយភ្លើងណា ភ្លើងនោះឆេះនូវកាយរបស់អញ ភ័យកើតអំពីវត្ថុជាទីពឹងហើយ ។

[ ៥៥៧ ] ( បុរសម្នាក់និយាយថា ) ពួកព្រាហ្មណ៍ និងក្សត្រិយ៍ជាច្រើន តែងញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយកត្តណា កត្តនោះដែលអាត្មាអញបរិភោគហើយនោះ សម្លាប់នូវអញ ភ័យកើតអំពីវត្ថុជាទីពឹងហើយ ។

[ ៥៥៨ ] ( បុរសម្នាក់និយាយថា ) ពួកអ្នកប្រាជ្ញ តែងប្រាថ្នាខ្យល់ ក្នុងខែជាទីបំផុតនៃគិម្ហរដូវ ( ឥឡូវ ) ខ្យល់នោះ កាច់បំបាក់ខ្លួនខ្ញុំ ភ័យកើតអំពីវត្ថុជាទីពឹងហើយ ។

[ ៥៥៩ ] ( បក្សីជាធំ និយាយថា ) ពួកបក្សីតែងអាស្រ័យដើមឈើណា ដើមឈើនោះបញ្ចេញនូវភ្លើង បក្សីទាំងឡាយ ចូរគប់នូវទិសទាំងឡាយផ្សេងៗ ភ័យកើតអំពីវត្ថុជាទីពឹងហើយ ។

[ ៥៦០ ] ( មាតានិយាយថា ) អញមានចិត្តសោមនស្សហើយនាំមកនូវកូនប្រសាស្រីណា ដែលប្រដាប់ដោយកម្រងផ្កា និងប្រោះព្រំដោយខ្លឹមច័ន្ទន៍ ( ឥឡូវ ) កូនប្រសាស្រីនោះ បណ្តេញអញ ចេញអំពីផ្ទះ ភ័យកើតអំពីវត្ថុជាទីពឹងហើយ ។

[ ៥៦១ ] ( បុរសម្នាក់និយាយថា ) អញត្រេកត្រអាលនឹងកូនប្រុសណា ដែលកើតហើយ នឹងប្រាថ្នាសេចក្តីចម្រើនដល់កូន

ប្រុសណា ( ឥឡូវ ) កូនប្រុសនោះ បណ្តេញអញចេញអំពីផ្ទះ ភ័យកើតអំពីវត្ថុជាទីពឹងហើយ ។

[ ៥៦២ ] ( ពោធិសត្វពោលថា ) សូមឲ្យពួកអ្នកជនបទ និងអ្នកនិគមដែលបានមកប្រជុំស្តាប់ខ្ញុំ ( ឥឡូវ ) វត្ថុណាជាទឹក វត្ថុនោះក្លាយទៅជាភ្លើងហើយ សេចក្តីក្សេមកើតមកអំពីព្រះរាជាណា ភ័យកើតមកអំពីព្រះរាជានោះហើយ ព្រះរាជា និងព្រាហ្មណ៍បុរោហិត ប្លន់ជនអ្នកនៅក្នុងដែន អ្នកទាំងឡាយចូររក្សាខ្លួន ត្បិតភ័យកើតអំពីវត្ថុជាទីពឹងហើយ ។

## បទកុសលមាណវកជាតកទី ៦ ចប់

# អដ្ឋកថា

## បណ្ឌកុសលមាណវកជាតក

[ ៥៥៣-៥៦២ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធទារកម្នាក់ ទើបត្រាស់រឿងនេះ មានពាក្យផ្តើមថា **ពហុស្សុតំ** ដូច្នេះ ។

បានឮថា ទារកនោះ ជាកូនរបស់កុដុម្ពិកៈ ក្នុងនគរសាវត្ថី ជាអ្នកឈ្លាសក្នុងការមើលស្នាមជើង ក្នុងកាលដែលខ្លួនមានអាយុ ៧ ឆ្នាំប៉ុណ្ណោះ ។ គ្រានោះ បិតារបស់កុមារគិតថា នឹងសាកល្បងកូននេះ ទើបទៅផ្ទះរបស់សម្លាញ់ មិនឲ្យទារកនោះដឹងឡើយ ទារកនោះមិនបានសួរទីទៅរបស់បិតា ដើរទៅតាមស្នាមជើងរបស់បិតា បានទៅឈរត្រង់សម្នាក់បិតា ។

ថ្ងៃមួយ បិតាបានសួរទារកនោះថា កូនសម្លាញ់ ឪពុកទៅមិនឲ្យឯងដឹង ឯងដឹងទីទៅរបស់ឪពុកបានដូចម្តេច ទារកឆ្លើយថា បពិត្រឪពុក ខ្ញុំស្គាល់ស្នាមជើងរបស់ពុកបាន ខ្ញុំឈ្លាសក្នុងការសង្កេតស្នាមជើង ។ លំដាប់នោះ បិតារបស់ទារកត្រូវការសាកល្បងទៀត កាលបរិភោគអាហារព្រឹកហើយ ក៏ចេញអំពីផ្ទះ ទៅកាន់ផ្ទះអ្នកស្និទ្ធស្នាល ដែលនៅជាប់គ្នា ហើយចេញអំពីផ្ទះនោះ ទៅកាន់ផ្ទះទី ៣ ចេញអំពីផ្ទះទី ៣ មកកាន់ផ្ទះរបស់ខ្លួន ចេញអំពីផ្ទះរបស់ខ្លួន ទៅកាន់ទ្វារនគរទិសខាងជើង ចេញអំពីទ្វារនោះ បត់ទៅខាងឆ្វេង ដល់ជេតវនវិហារ ថ្វាយបង្គំព្រះសាស្តាហើយ អង្គុយស្តាប់ធម៌ ។ ទារកសួរអ្នកផ្ទះថា ឪពុករបស់ខ្ញុំទៅណា កាលបានទទួលពាក្យថា មិនដឹង ទើបសង្កេតគន្លងជើងបិតា តាំងអំពីផ្ទះរបស់អ្នកស្និទ្ធស្នាលដែលជាប់គ្នា ទៅតាមផ្លូវដែលបិតាទៅនោះឯង រហូតដល់ជេតវនវិហារ ថ្វាយបង្គំព្រះសាស្តាហើយ

ឈរក្បែរបិតា កាលបិតាសួរថា កូនសម្លាញ់ ឯងដឹងថា អញមកក្នុងទីនេះឬ ទារកឆ្លើយថា ខ្ញុំស្គាល់ស្នាមជើងពុក ទើបមក ដោយសង្កេតគន្លងជើង ។ ព្រះសាស្តាត្រាស់សួរថា ម្នាលឧបាសក អ្នកនិយាយអ្វី កាលកុដុម្ពិកៈក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ទារកនេះឈ្លាសក្នុងការសង្កេតស្នាមជើង ខ្ញុំព្រះអង្គពិសោធក្មេងនេះ ទើបមកដោយឧបាយនេះ ទារកនេះ កាលមិនឃើញខ្ញុំព្រះអង្គក្នុងផ្ទះ បានមកដោយសង្កេតស្នាមជើងខ្ញុំព្រះអង្គ ។ ព្រះសាស្តាត្រាស់ថា ម្នាលឧបាសក ការចាំស្នាមជើងលើផែនដី មិនគួរអស្ចារ្យទេ បណ្ឌិតក្នុងកាលមុន ចាំស្នាមជើងក្នុងអាកាសបាន កុដុម្ពិកៈនោះក្រាបទូលអារាធនាឲ្យត្រាស់រឿង ទើបទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិក្នុងនគរពារាណសី អគ្គមហេសីរបស់ទ្រង់ប្រព្រឹត្តក្រៅចិត្ត កាលព្រះរាជាត្រាស់សួរ ក៏ស្បថថា បើខ្ញុំម្ចាស់ប្រព្រឹត្តក្រៅចិត្តទ្រង់ សូមឲ្យខ្ញុំម្ចាស់កើតជាយក្ខិនី មានមុខដូចសេះ ។ បន្ទាប់អំពីនោះ ព្រះនាងបានអស់ព្រះជន្មកើតជាយក្ខិនី មានមុខដូចសេះ ត្រង់ជើងភ្នំមួយកន្លែង នៅក្នុងគុហា ចាប់មនុស្សដែលធ្វើដំណើរទៅមកក្នុងព្រៃធំក្នុងផ្លូវដែលកាត់តាមព្រៃនោះ បរិភោគជាអាហារ ។ បានឮថា យក្ខិនីនោះបម្រើព្រះបាទវេស្សវ័ណ ៣ ឆ្នាំ ទទួលពរ ឲ្យស៊ីមនុស្សបាន ក្នុងទីចម្ងាយបណ្តោយ ៣០ យោជន៍ និងទទឹង ៥ យោជន៍ ។

ថ្ងៃមួយ ព្រាហ្មណ៍រូបស្អាតម្នាក់ ជាអ្នកស្តុកស្តម្ភដោយភោគទ្រព្យ ចោមរោមទៅដោយមនុស្សជាច្រើន ធ្វើដំណើរតាមផ្លូវនោះ យក្ខិនីឃើញព្រាហ្មណ៍

នោះ មានចិត្តត្រេកអរក៏រត់ទៅ ពួកមនុស្សជាបរិវារនាំគ្នារត់អស់ យក្ខិនីរត់លឿនដូចខ្យល់ ចាប់ព្រាហ្មណ៍បានហើយ ដាក់ឲ្យដេកក្នុងគុហា កាលពាល់ត្រូវជាមួយបុរស នាងក៏កើតស្នេហាក្នុងព្រាហ្មណ៍នោះដោយអំណាចកិលេស ក៏មិនបានទំពាស៊ីព្រាហ្មណ៍ ទុកធ្វើជាប្តីរបស់ខ្លួន ជនទាំង ២ នៅរួមគ្នាដោយសាមគ្គីភាព ។ តាំងពីនោះមក យក្ខិនីចាប់មនុស្សគ្រាន់យកសំពត់ អង្ករ និងប្រេងជាដើម មកចម្អិនជាអាហារ មានរសប្រសើរផ្សេងៗ ឲ្យប្តី ខ្លួនឯងទំពាស៊ីសាច់មនុស្ស មុនពេលនាងចេញទៅណាមកណា បានលើកដុំថ្មធំ បិទទ្វារគុហាជាមុន ហើយចេញទៅ ព្រោះខ្លាចព្រាហ្មណ៍រត់ ។ កាលជនទាំង ២ នៅរួមគ្នាដោយសេចក្តីត្រេកអរយ៉ាងនេះ ព្រះពោធិសត្វចុតិចាកស្ថានដែលទ្រង់កើត មកបដិសន្ធិក្នុងគភ៌របស់យក្ខិនីនោះ ព្រោះអាស្រ័យព្រាហ្មណ៍ ។ លុះកន្លងទៅបាន ១០ ខែ យក្ខិនីក៏ប្រសូតបុត្រ នាងមានសេចក្តីស្រឡាញ់ក្នុងបុត្រ និងព្រាហ្មណ៍ជាខ្លាំង បានចិញ្ចឹមជនទាំង ២ យ៉ាងល្អ កាលបុត្រចម្រើនវ័យហើយ បានឲ្យចូលទៅខាងក្នុងគុហាជាមួយបិតា ហើយបិទទ្វារ ។ ថ្ងៃមួយ ព្រះពោធិសត្វដឹងថា យក្ខិនីនោះទៅហើយ ទើបគាស់ថ្មចេញ នាំបិតាទៅខាងក្រៅ យក្ខិនីមកទាន់ សួរថា អ្នកណាយកថ្មចេញ ព្រះពោធិសត្វឆ្លើយថា បពិត្រអ្នកម៉ែ គឺខ្ញុំ ព្រោះខ្ញុំមិនអាចអង្គុយក្នុងទីងងឹត នាងក៏មិនថាអ្វី ព្រោះស្រឡាញ់កូន ។ ថ្ងៃមួយ ព្រះពោធិសត្វសួរបិតាថា បពិត្រលោកឪពុក ហេតុអ្វី មុខរបស់ម៉ែ មិនដូចមុខរបស់ពុក ព្រាហ្មណ៍ជាបិតាពោលថា កូនសម្លាញ់ ម៉ែរបស់ឯងជាយក្ខិនី ស៊ីសាច់មនុស្ស យើងទាំង ២ ជា

មនុស្ស ។ ព្រះពោធិសត្វពោលថា បពិត្រលោកឪពុក បើដូច្នោះ យើងនៅក្នុងទីនេះធ្វើអ្វី មកយើងទៅទឹកដីមនុស្សជាមួយគ្នា ។ ព្រាហ្មណ៍ជាបិតាពោលថា កូនសម្លាញ់ បើយើងរត់គេច ម៉ែរបស់ឯង នឹងសម្លាប់យើងទាំង ២ ចោល ព្រះពោធិសត្វពោលលួងលោមបិតាថា កុំខ្លាចឡើយ ខ្ញុំទទួលភារៈនាំពុកទៅដល់ដែនដីមនុស្ស ។ ស្អែកឡើង កាលមាតាចេញទៅហើយ ក៏បាននាំបិតារត់ យក្ខិនីត្រឡប់មក មិនឃើញជនទាំង ២ ក៏រត់ទៅដោយរហ័សដូចខ្យល់ចាប់ជនទាំង ២ បាន រួចពោលថា នែព្រាហ្មណ៍ អ្នកគេចធ្វើអ្វី អ្នកនៅទីនេះ អត់ឃ្លានឬ ព្រាហ្មណ៍ក៏ពោលថា នែនាង នាងកុំខឹងនឹងខ្ញុំឡើយ កូនរបស់នាងនាំខ្ញុំរត់ ដូច្នោះ នាងក៏មិនបានថាអ្វី ព្រោះស្រឡាញ់ក្នុងកូន លួងលោមជនទាំង ២ ហើយនាំទៅកាន់លំនៅរបស់ខ្លួន យក្ខិនីបាននាំជនទាំង ២ ដែលគេចទៅក្នុងថ្ងៃទី ៣ យ៉ាងនោះ ត្រឡប់មកទៀត ។

ព្រះពោធិសត្វគិតថា ម៉ែរបស់អញ គង់មានដែនកំណត់ បើដូច្នោះ អញនឹងសួរដល់ដែនកំណត់ក្នុងអាណាខេត្តរបស់គាត់ កាលសួរបានដឹង អញនឹងគេចទៅឲ្យផុតដែននោះ ។ ថ្ងៃមួយ ព្រះពោធិសត្វឱបមាតាអង្គុយចុះក្នុងទីមួយកន្ទែង ហើយពោលថា បពិត្រមាតា ធម្មតាទ្រព្យដែលជារបស់ម៉ែរមែងធ្លាក់ដល់កូន សូមម៉ែប្រាប់ដែនកំណត់ ដែលជាទឹកដីរបស់ម៉ែដល់ខ្ញុំ យក្ខិនីប្រាប់ទីដែលមានបណ្តោយ ៣០ យោជន៍ ទទឹង ៥ យោជន៍ មានភ្នំជាដើមជាគ្រឿងសម្គាល់ក្នុងទិសទាំងពួងដល់បុត្រ ហើយពោលថា នែកូន ចូរឯងកំណត់នូវទីដែលមានប្រមាណប៉ុណ្ណេះ ។ លុះកន្លងទៅបានពីរបីថ្ងៃ កាលមាតា

ទៅព្រៃហើយ ព្រះពោធិសត្វបានបញ្ជិះបិតាដាក់លើ-ក រត់ទៅដោយរហ័សដូចខ្យល់ តាមសញ្ញាដែលមាតាកំណត់ ដល់ឆ្នេរស្ទឹងដែលជាដែនកំណត់ យក្ខិនីត្រឡប់មក កាលមិនឃើញជនទាំង ២ ក៏ដេញតាម ព្រះពោធិសត្វនាំបិតាដល់កណ្តាលស្ទឹង យក្ខិនីក៏មកដល់ឆ្នេរស្ទឹង ដឹងថា ជនទាំង ២ កន្លងហួសដែនរបស់ខ្លួនទៅហើយ ឈរត្រង់ច្រាំងនោះឯង អង្វរបុត្រ និងស្វាមីថា កូនជាទីស្រឡាញ់ ចូរឯងនាំបិតាត្រឡប់មក ម៉ែមានកំហុសអ្វី អ្វីគ្រប់យ៉ាងមិនសម្បូរដល់ពួកអ្នកព្រោះអាស្រ័យយើងឬ ត្រឡប់មកចុះប្តីជាទីស្រឡាញ់ដូច្នេះ ។ លំដាប់នោះ ព្រាហ្មណ៍បានឆ្លងស្ទឹងទៅហើយ យក្ខិនីអង្វរបុត្រថា កូនជាទីស្រឡាញ់ បាកុំធ្វើយ៉ាងនេះ ចូរបាត្រឡប់មកចុះ ។ ព្រះពោធិសត្វពោលថា បពិត្រអ្នកម៉ែ ខ្ញុំ និងបិតាជាមនុស្ស ម៉ែជាយក្ខិនី ខ្ញុំមិនអាចនៅក្នុងសម្នាក់ម៉ែបានរហូតទេ ដូច្នោះ ខ្ញុំ និងពុកមិនត្រឡប់ឡើយ ។ យក្ខិនីសួរថា កូនសម្លាញ់ឯងមិនត្រឡប់ឬ ព្រះពោធិសត្វឆ្លើយថា ពិតហើយ កូនមិនអាចត្រឡប់បានទេ យក្ខិនីពោលថា កូនជាទីស្រឡាញ់ បើឯងមិនត្រឡប់ក៏ហីទៅចុះ ឈ្មោះថា ការតម្កល់ជីវិតក្នុងលោកនេះ ជារបស់កម្រ បុគ្គលដែលមិនចេះសិប្បៈ មិនអាចធ្វើជីវិតឲ្យតាំងនៅបាន ម៉ែចេះវិជ្ជាម្យ៉ាង ឈ្មោះចិន្តាមណីដោយអានុភាពរបស់មន្តនេះ អាចដើរតាមស្នាមជើងរបស់បុគ្គលដែលបាត់ទៅអស់ ១២ ឆ្នាំ វិជ្ជានេះ ជាគ្រឿងចិញ្ចឹមជីវិតរបស់ឯង ចូរឯងរៀនមន្តដែលកាត់ថ្លៃមិនបាននេះ ពោលដូច្នោះហើយ ទាំងដែលសេចក្តីទុក្ខកំពុងគ្រប់សង្កត់នោះឯង នាងក៏បានបង្រៀនមន្តដោយស្រឡាញ់កូន ។ ព្រះពោធិសត្វឈរក្នុង

ស៊ីងនោះឯង ថ្វាយបង្គំមាតា ឈរប្រណម្យដៃរៀនមន្ត កាលរៀនបានហើយ បានថ្វាយបង្គំមាតាម្តងទៀត ហើយពោលថា បពិត្រអ្នកម៉ែ សូមម៉ែទៅចុះ យក្ខិនីពោលថា កូនជាទីស្រឡាញ់ បើឯង និងបិតារបស់ឯងមិនត្រឡប់ ជីវិតរបស់ម្តាយក៏មិនមាន ហើយពោលគាថានេះថា

កូនជាទីស្រឡាញ់ ចូរកូនមករកម៉ែ ចូរត្រឡប់ទៅជាមួយម៉ែចុះ កុំធ្វើឲ្យម្តាយមិនមានទីពឹងឡើយ កាលម្តាយមិនបានឃើញកូន ក៏ត្រូវស្លាប់ក្នុងថ្ងៃនេះ ។

កាលពោលហើយ យក្ខិនីបានបោកក្បាលខ្លួនឯង ។ រំពេចនោះ ហទយៈរបស់នាងបានបែកធ្លាយ ព្រោះសោកសង្រែងដល់បុត្រ នាងដួលចុះស្លាប់ក្នុងទីនោះឯង ។ ខណៈនោះ ព្រះពោធិសត្វជ្រាបថា មាតាស្លាប់ ទើបហៅបិតាចូលទៅជិត ហើយធ្វើជើងថ្ករបូជាសព កាលដុតស្រេចហើយ បានបូជាដោយផ្កាច្រើនប្រភេទ ទ្រហោយំ នាំបិតាទៅកាន់នគរពារាណសី ឈរត្រង់ទ្វារព្រះរាជនិវេសន៍ បានក្រាបទូលដល់ព្រះបាទពារាណសីថា មានមាណពឈ្លាសវៃក្នុងការសង្កេតស្នាមជើង មកឈរត្រង់ទ្វារសូមចូលគាល់ កាលបានទទួលអនុញ្ញាតថា បើដូច្នោះ ចូលមកចុះ បានចូលទៅថ្វាយបង្គំព្រះបាទពារាណសី កាលព្រះរាជាត្រាស់សួរថា នៃបា បាចេះសិប្បវិជ្ជាណាមួយឬ ទើបក្រាបទូលថា បពិត្រព្រះអង្គ ទូលបង្គំចេះវិជ្ជាដែលអាចទៅតាមស្នាមជើង ហើយចាប់មនុស្សដែលលួចរបស់ទៅហើយ ក្នុងកាល ១២ ឆ្នាំបាន ។ ព្រះបាទពារាណសីត្រាស់ថា បើដូច្នោះ ចូរអ្នកទទួលរាជការ ហើយនៅជាមួយយើង ព្រះពោធិ-

សត្វទូលថា កាលទូលបង្គំបានទទួលព្រះរាជទានទ្រព្យ មួយថ្ងៃមួយពាន់ ទើបទទួលរាជការ ព្រះបាទពារាណសីទទួលថា សាធុ ចូរបាទទួលរាជការចុះ ហើយត្រាស់ឲ្យព្រះរាជទានទ្រព្យមួយថ្ងៃ ១០០០ រាល់ថ្ងៃ ។

ថ្ងៃមួយ បុរោហិតក្រាបទូលព្រះបាទពារាណសីថា បពិត្រមហារាជ យើងទាំងឡាយមិនដឹងថា មាណពនោះមានសិប្បៈ ឬមិនមានទេ ព្រោះគេមិនបានធ្វើកម្មឯណានីមួយ ដោយអានុភាពនៃសីលវិជ្ជា គួរសាកល្បងមាណពនោះសិន ព្រះរាជាត្រាស់ថា សាធុ ទើបជនទាំង ២ ឲ្យសញ្ញាដល់ក្នាក់ងាររក្សារតនៈកាន់យកកែវមួយដួង ចុះអំពីប្រាសាទ ដើរប្រទក្សិណព្រះរាជនិវេសន៍ ៣ ជុំ ហើយដាក់ជណ្តើរចុះទៅខាងក្រៅកំពែង ចូលទៅកាន់សាលាក្តីអង្គុយក្នុងសាលានោះហើយ ត្រឡប់មកតាមជណ្តើរនោះ ចូលទៅខាងក្នុងព្រះរាជានិវេសន៍តាមផ្លូវខាងចុងកំពែង ដើរទៅកាន់ស្រះបោក្ខរណីខាងក្នុងរាជវាំង ប្រទក្សិណស្រះបោក្ខរណី ៣ ជុំ ហើយចុះទៅទុកទ្រព្យនោះក្នុងស្រះបោក្ខរណី ហើយឡើងទៅលើប្រាសាទ ។ ស្អែកឡើង បានកើតកោលាហលថា ពួកចោរលួចកែវអំពីព្រះរាជនិវេសន៍ ព្រះរាជាធ្វើជាទ្រង់មិនជ្រាប ឲ្យហៅព្រះពោធិសត្វមក ត្រាស់ថា នែបា កែវដ៏មានតម្លៃត្រូវចោរលួចទៅអំពីព្រះរាជនិវេសន៍ ណ្ហើយចុះ បាគួរដេញតាម ហើយយកកែវនោះមកឲ្យបាន ព្រះពោធិសត្វក្រាបទូលថា បពិត្រមហារាជ ទ្រព្យដែលចោរលួចទៅអស់ ១២ ឆ្នាំ គង់ទូលបង្គំអាចដើរតាមស្នាមជើងចោរ នាំយកមកវិញបាន នឹងពោលថ្វីទ្រព្យដែលត្រូវលួចកាលពីយប់មិញនេះ ទូលបង្គំនឹងនាំមកក្នុងថ្ងៃនេះពិត សូម

ទ្រង់កុំបរិវិតក្កថ្វីឡើយ ។ ព្រះរាជាត្រាស់ថា បើយ៉ាងនោះ ចូរបាំនាំមកចុះ ។ ព្រះពោធិសត្វក្រាបទូលថា សាធុ ហើយឡើងកាន់ប្រាសាទ ថ្វាយបង្គំមាតា រាយចិន្តាមណីមន្ត ហើយក្រាបទូលថា ស្នាមជើង ២ នាក់ ប្រាកដដល់ទូលបង្គំ ហើយតាមស្នាមជើងរបស់ព្រះរាជា និងបុរោហិត ចូលទៅកាន់បន្ទប់ដ៏មានសិរី ចេញពីបន្ទប់នោះ ចុះអំពីប្រាសាទ ដើរប្រទក្សិណក្នុងព្រះរាជ-និវេសន៍ ៣ ជុំ ហើយទៅក្បែរកំពែង តាមស្នាមជើងនោះឯង ឈរលើកំពែង ហើយពោលថា បពិត្រមហារាជ ផុតអំពីកំពែងនេះទៅ ស្នាមជើងប្រាកដក្នុងអាកាស សូមទ្រង់ព្រះរាជទានជណ្ដើរ ហើយដាក់ជណ្ដើរចុះទៅខាងចុងកំពែង ទៅកាន់សាលាវិនិច្ឆ័យ តាមស្នាមជើងនោះឯង ហើយដើរមកកាន់ព្រះរាជនិ-វេសន៍វិញ ឲ្យដាក់ជណ្ដើរចុះតាមផ្លូវខាងចុងកំពែង ទៅកាន់ស្រះបោក្ខរណី ដើរវៀល ៣ ជុំ ហើយទូលថា បពិត្រមហារាជ ពួកចោរចុះខាងក្នុងស្រះបោក្ខរណីនេះ ហើយចុះទៅនាំរបស់ ដូចជាខ្លួនទុកឯង មកថ្វាយព្រះបាទពារាណសី ហើយក្រាបទូលថា បពិត្រមហារាជ ចោរ ២ នាក់នោះ ជាមហាចោរដែលទ្រង់ស្គាល់ច្បាស់ ទើបឡើងព្រះរាជនិវេសន៍តាមផ្លូវនេះ មហាជននាំគ្នាត្រេកអរទះដៃសរសើរ លើកសំពត់ឡើងគ្រវី ។

ព្រះរាជាទ្រង់ព្រះតម្រិះថា មាណពនេះ ដើរទៅដោយសង្កេតស្នាមជើង ប្រហែលជាដឹងតែកន្លែងទ្រព្យដែលចោរទុកប៉ុណ្ណោះ តែមិនអាចចាប់ចោរបាន ទើបត្រាស់នឹងព្រះពោធិសត្វថា ឯងនាំទ្រព្យដែលពួកចោរលួចទៅមកឲ្យយើងបាន តែមិនអាចចាប់ចោរឲ្យយើងបាន ព្រះពោធិសត្វក្រាបទូលថា បពិត្រ

មហារាជ ពួកចោរនៅក្នុងទីនេះឯង មិនមែននៅឆ្ងាយឡើយ ព្រះរាជាមានព្រះតម្រាស់ថា នរណាជាចោរ នរណាជាចោរ ព្រះពោធិសត្វក្រាបទូលថា បពិត្រមហារាជ អ្នកណាចង់បាន អ្នកនោះឯងជាចោរ កាលបានទ្រព្យរបស់ទ្រង់មកហើយ ប្រយោជន៍អ្វីដោយពួកចោរទៀត សូមទ្រង់កុំសួរដល់ឡើយ ។ ព្រះរាជាមានព្រះតម្រាស់ថា នែបា យើងឲ្យទ្រព្យមួយថ្ងៃ ១០០០ រាល់ថ្ងៃ ចូរឯងចាប់ចោរឲ្យយើង ។ ព្រះពោធិសត្វក្រាបទូលថា បពិត្រមហារាជ ទ្រព្យដែលបាត់ទៅ ទ្រង់ក៏បានមកហើយ ប្រយោជន៍អ្វីដោយពួកចោរទៀត ។ ព្រះរាជាត្រាស់ថា នែបា យើងបានពួកចោរ គួរជាងបានទ្រព្យ ព្រះពោធិសត្វក្រាបទូលថា បពិត្រមហារាជ បើដូច្នោះ ទូលបង្គំមិនក្រាបទូលដល់ទ្រង់ថា នេះជាចោរ តែនឹងនាំរឿងក្នុងអតីតមកក្រាបទូលទ្រង់ បើទ្រង់មានបញ្ញាទ្រង់នឹងជ្រាបរឿងនោះ កាលក្រាបទូលដូច្នេះហើយ បាននាំយករឿងក្នុងអតីតមកដូច្នេះ

បពិត្រមហារាជ ក្នុងអតីតកាល មានអ្នករបាំម្នាក់ ឈ្មោះបាដលិ នៅក្នុងស្រុកតូច ក្បែរឆ្នេរស្ទឹង មិនឆ្ងាយអំពីនគរពារាណសី ថ្ងៃមួយ មានមហោស្រព គាត់នាំភរិយាទៅនគរពារាណសី ច្រៀងរាំបានទ្រព្យ កាលមហោស្រពឈប់សម្តែងហើយ បានទិញស្រា និងអាហារជាច្រើន ត្រឡប់មកផ្ទះរបស់ខ្លួន ដល់ច្រាំងស្ទឹង ឃើញទឹកថ្មីកំពុងហូរមក ទើបអង្គុយបរិភោគអាហារ ផឹកស្រាស្រវឹង រហូតមិនដឹងកម្លាំងខ្លួន យកពិណាធំចងត្រង់ក ចុះក្នុងទឹក ចាប់ដៃភរិយាពោលថា មកយើងទៅជាមួយគ្នា ហើយហែលទឹកទៅ ។

ទឹកបានចូលទៅក្នុងស្នុកពិណ ពិណនោះ ក៏បានទាញបុរសនោះលិចចូលទៅក្នុងទឹក ឯភរិយាដឹងថា ប្ដីលិចទឹក ទើបរលាស់ដៃ ហើយឡើងទៅឈរលើប្រាំង មាណពអ្នកលេងតន្ត្រី លិចងើបៗ ផឹកទឹករហូតពេញពោះ លំដាប់នោះភរិយាគិតថា ប្ដីរបស់អញ នឹងស្លាប់ក្នុងឥឡូវនេះ អញនឹងសូមបទចម្រៀងមួយបទ យកបទនេះទុកច្រៀងកណ្ដាលបរិស័ទចិញ្ចឹមជីវិត គិតដូច្នេះហើយទើបពោលថា នែអ្នកកំពុងលិចទឹក សូមអ្នកឲ្យបទចម្រៀងមួយបទដល់ខ្ញុំគ្រាន់នឹងចិញ្ចឹមជីវិតដោយចម្រៀងនោះ ហើយពោលគាថានេះថា

ទឹកទន្លេគង្គា កួចយកទៅនូវបុរសឈ្មោះបាដលិ ជាអ្នកចេះដឹងច្រើន ពោលនូវពាក្យដ៏វិចិត្រ នែអ្នកដ៏ចម្រើន ដែលទឹកកួចយកទៅ សូមអ្នកឲ្យនូវចម្រៀងយ៉ាងខ្លីមួយដល់ខ្ញុំ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **គាថកំ** បានដល់ បទចម្រៀងខ្លីៗ ។ គ្រានោះ បាដលិអ្នករបាំពោលនឹងភរិយាថា នាងជាទីស្រឡាញ់ អញនឹងឲ្យចម្រៀងដល់នាងដូចម្ដេចបាន ទឹកជាទីពឹងអាស្រ័យរបស់មហាជន ឥឡូវនេះកំពុងសម្លាប់អញហើយ ក៏ពោលគាថាថា

ពួកជន តែងស្រោចនូវបុគ្គលមានទុក្ខដោយទឹកណា តែងស្រោចនូវបុគ្គលដែលមានសេចក្ដីក្រវល់ក្រវាយ ដោយទឹកណា យើងគង់នឹងស្លាប់ ក្នុងកណ្ដាលទឹកនោះ ភ័យកើតមកអំពីវត្ថុជាទីពឹងហើយ ដូច្នេះ ។

ព្រះពោធិសត្វសម្ដែងគាថានេះហើយ ក្រាបទូលថា បពិត្រមហារាជ ទឹកដែលជាទីពឹងរបស់មហាជន យ៉ាងណា ព្រះរាជាទាំងឡាយក៏ជាទីពឹងនៃ

មហាជនយ៉ាងនោះ កាលភ័យកើតអំពីសម្នាក់របស់ព្រះរាជាទាំងនោះហើយ អ្នកណានឹងការពារភ័យនោះបាន ដូច្នេះហើយ ទូលបន្តថា បពិត្រមហារាជ រឿងចោរលួចព្រះរាជទ្រព្យនេះ ជារឿងសម្ងាត់ តែទូលបង្គំក្រាបទូលតាមលំនាំ ដែលបណ្ឌិតអាចដឹងបាន សូមទ្រង់ជ្រាបចុះ ។ ព្រះរាជាត្រាស់ថា នែបា យើង ដឹងរឿងសម្ងាត់បែបនេះបានដូចម្តេច ចូរឯងចាប់ចោរនោះមកឲ្យយើងចុះ គ្រា នោះ ព្រះមហាសត្វក៏ក្រាបទូលព្រះរាជាថា បពិត្រមហារាជ បើដូច្នោះ សូម ទ្រង់ស្តាប់រឿងនេះ ហើយទ្រង់នឹងជ្រាប ទើបនាំយករឿងមួយមកតំណាល ជាបន្តទៅទៀត

បពិត្រព្រះអង្គ កាលពីព្រេងនាយ ក្នុងស្រុកមួយ ជិតទ្វារនគរពារាណសី នេះ មានស្មូនឆ្នាំងម្នាក់ កាលនាំដីឥដ្ឋមកដើម្បីស្មូនភាជនៈ បានជីកដីស្អិត ក្នុងទីមួយកន្លែងមកជានិច្ច រហូតក្លាយជារណ្តៅធំ ខាងក្នុងជាក្អេង ។ ថ្ងៃមួយ ស្មូនឆ្នាំងនោះកំពុងជីកដីឥដ្ឋ មហាមេឃបានតាំងឡើងពុំដូកាល ភ្លៀងធំក៏ធ្លាក់ ចុះមក ទឹកហូរចូលរណ្តៅ ដីក៏បាក់ សង្កត់ក្បាលស្មូនឆ្នាំងនោះរហូតបែក ស្មូនឆ្នាំងទ្រហោយំ ពោលគាថាថា

ពូជទាំងឡាយ តែងដុះឡើងលើផែនដីណា ពួកសត្វឋិតនៅលើ
ផែនដីណា ផែនដីនោះ បៀតបៀននូវក្បាលអញ ភ័យកើតអំពី
វត្ថុជាទីពឹងហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឆិបីឡេតិ** បានដល់ បាក់សង្កត់ គឺ បែកធ្លាយ ។

ព្រះមហាសត្វក្រាបទូលបន្តថា បពិត្រមហារាជ ផែនដីធំជាទីពឹងអាស្រ័យរបស់មហាជន បានបៀតបៀនអំបែងក្បាលស្នូនថ្នាំង យ៉ាងណា កាលព្រះរាជាជាធំនៃនរជន ជាទីពឹងអាស្រ័យនៃសត្វលោក ដូចផែនដីធំ មកធ្វើចោរកម្មយ៉ាងនេះ អ្នកណានឹងការពារបាន បពិត្រមហារាជ ទ្រង់អាចជ្រាបខ្លួនចោរ ដែលទូលបង្គំក្រាបទូលដោយសម្គាល់បានដោយឧបមាយ៉ាងនេះ ។ ព្រះបាទពារាណសីត្រាស់ថា នែបា ហេតុដែលយើងបិទបាំងនោះ មិនមាន ចូរឯងចាប់ចោរឲ្យដល់យើង ដោយឈ្មោះថា អ្នកនេះជាចោរដូច្នេះ ។ ព្រះពោធិសត្វ កាលរក្សាព្រះកិត្តិគុណរបស់ព្រះរាជា មិនបានពោលថា ទ្រង់ជាចោរ បាននាំរឿងមួយទៀតមកឧបមាថា

បពិត្រមហារាជ កាលពីព្រេងនាយ កាលភ្លើងឆេះផ្ទះបុរសម្នាក់ ក្នុងព្រះនគរនេះឯង គាត់ប្រើបុរសម្នាក់ថា ចូរឯងទៅខាងក្នុងជញ្ជូនទ្រព្យចេញ កាលបុរសនោះកំពុងចូលទៅជញ្ជូន របស់ដែលនៅត្រង់ទ្វារផ្ទះក៏បិទ ភ្នែកគេមើលអ្វីមិនឃើញ ព្រោះត្រូវផ្សែង រកផ្លូវចេញមិនបាន កើតទុក្ខព្រោះកម្ដៅឈរយំកន្ទក់កន្ទេញខាងក្នុង ពោលថា

ពួកជន គេចម្អិនបាយដោយភ្លើងណា គេកម្ចាត់បង់នូវរងាដោយ
ភ្លើងណា ភ្លើងនោះ ឆេះនូវកាយរបស់អញ ភ័យកើតអំពីវត្ថុ
ជាទីពឹងហើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សោ មំ ឌហតិ** សេចក្ដីថា ភ្លើងនោះឆេះអញ ។ ម្យ៉ាងទៀត បាលីក៏យ៉ាងនេះដូចគ្នា ។

ព្រះមហាសត្វក្រាបទូលថា បពិត្រមហារាជ មនុស្សម្នាក់ជាទីពឹងអាស្រ័យនៃមហាជន បើដូចភ្លើងជាទីពឹងអាស្រ័យដូច្នោះ បានលួចរបស់ គឺរតនៈទៅ សូមទ្រង់កុំត្រាស់សួរដល់ចោរនឹងទូលបង្គំឡើយ ។ ព្រះរាជាត្រាស់ថា នែបា ចូរឯងប្រាប់ចោរដល់យើងចុះ ។ ព្រះពោធិសត្វមិនបានក្រាបទូលថា ទ្រង់ជាចោរ បាននាំឧបមាដោយរឿងមួយទៀតថា

បពិត្រមហារាជ កាលពីព្រេងនាយ បុរសម្នាក់ក្នុងនគរនេះឯង បរិភោគអាហារច្រើនពេក មិនអាចរលួយបាន ទទួលនូវទុក្ខវេទនា ទូញយំពោលគាថានេះថា

ពួកព្រាហ្មណ៍ និងក្សត្រិយ៍ជាច្រើន តែងញុំាំងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយភត្តណា ភត្តនោះ ដែលអាត្មាអញបរិភោគហើយ
នោះ សម្លាប់នូវអញ ភ័យកើតអំពីវត្ថុជាទីពឹងហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សោ មំ ភុត្តោ ព្យាធាធិ** សេចក្តីថា បាយនោះ អញបរិភោគហើយ នាំឲ្យអញដល់នូវសេចក្តីវិនាស គឺឲ្យស្លាប់ ។

ព្រះមហាសត្វក្រាបទូលបន្តថា បពិត្រមហារាជ បុរសម្នាក់ជាទីអាស្រ័យរបស់មហាជន ដូចបាយ បានលួចទ្រព្យទៅ កាលបានរបស់នោះមកវិញ ទ្រង់នឹងសួរដល់ចោរធ្វើអ្វី ។ ព្រះរាជាត្រាស់ថា នែបា បើបាអាច ក៏ចូរនាំចោរមកឲ្យយើង ព្រះពោធិសត្វបាននាំរឿងមួយមកជាឧបមាទៀតថា

បពិត្រមហារាជ ក្នុងកាលមុន ខ្យល់បានតាំងឡើង បក់ប្រហាររាងកាយនៃបុរសម្នាក់ ក្នុងនគរនេះឯង បុរសនោះខ្សឹកខ្សួល ពោលគាថានេះថា

ពួកអ្នកប្រាជ្ញ តែងប្រាថ្នាខ្យល់ ក្នុងខែជាទីបំផុតនៃគិម្ហរដូវ ( ឥឡូវ ) ខ្យល់នោះ កាច់បំបាក់ខ្លួនខ្ញុំ ភ័យកើតអំពីវត្ថុជាទីពឹងហើយ ដូច្នេះ ។

ព្រះមហាសត្វទូលបន្តថា បពិត្រមហារាជ ភ័យកើតឡើងអំពីទីពឹងដោយប្រការដូច្នេះ សូមទ្រង់ជ្រាបរឿងនេះចុះ ។ ព្រះរាជាត្រាស់ថា នៃបា ចូរបាចាប់ចោរចុះ ។ ដើម្បីឲ្យព្រះរាជាទ្រង់ជ្រាប ព្រះពោធិសត្វបាននាំឧបមាមកក្រាបទូលដោយរឿងមួយទៀតថា

បពិត្រមហារាជ ក្នុងអតីតកាល នាហិមវន្តប្បទេស មានដើមឈើធំសម្បូរដោយមែក និងប្រគាប ជាទីនៅអាស្រ័យនៃបក្សីច្រើនពាន់ មែក ២ របស់ដើមឈើនោះ បានសង្កៀតគ្នា រហូតចេញជាផ្សែងឡើង ភ្លើងក៏ឆាបឆេះ បក្សីមេហ្វូងឃើញដូច្នោះ ពោលគាថានេះថា

ពួកបក្សី តែងអាស្រ័យដើមឈើណា ដើមឈើនោះ បញ្ចេញនូវភ្លើង បក្សីទាំងឡាយ ចូរគប់នូវទិសទាំងឡាយផ្សេងៗ ភ័យកើតអំពីវត្ថុជាទីពឹងហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឆគតិរុហំ** ប្រែថា ដុះអំពីផែនដី ។

ព្រះមហាសត្វទូលបន្តថា បពិត្រមហារាជ ដើមឈើជាទីពឹងអាស្រ័យនៃបក្សីទាំងឡាយ យ៉ាងណា ព្រះរាជាក៏ជាទីពឹងអាស្រ័យរបស់មហាជនយ៉ាងនោះដែរ កាលព្រះរាជានោះធ្វើចោរកម្ម អ្នកណានឹងការពារបាន សូមទ្រង់ជ្រាបចុះ ព្រះរាជាត្រាស់ថា នៃបា ចូរបាចាប់ចោរមកឲ្យយើងចុះ ។ លំដាប់

នោះ ព្រះពោធិសត្វបាននាំឧបមាមកទូលព្រះរាជាដោយរឿងមួយទៀតថា

បពិត្រមហារាជ ត្រង់ស្រុករបស់អ្នកកាសីមួយកន្លែង មានស្ទឹងដែលមានក្រពើមួយក្បាលអាស្រ័យនៅ ត្រកូលនោះ មានកូនប្រុសម្នាក់ប៉ុណ្ណោះ កាលឪពុកស្លាប់ទៅ កូននោះក៏បានបជិបត្តិមាតា មាតាបាននាំកុលធីតាម្នាក់មកឲ្យបុរសនោះ ដោយគាត់មិនប្រាថ្នាសោះ ដំបូង នាងកុលធីតានោះ ក៏ស្រឡាញ់ម្ដាយក្មេក ក្រោយមក ចម្រើនដោយកូនប្រុស និងកូនស្រី ទើបចង់បណ្ដេញម្ដាយក្មេកចេញ សូម្បីម្ដាយរបស់នាង ក៏នៅក្នុងផ្ទះនោះដូចគ្នា ។ គ្រានោះ នាងពោលទោសម្ដាយក្មេក មានប្រការផ្សេងៗ ចំពោះមុខប្ដី ហើយពោលថា ខ្ញុំមិនអាចចិញ្ចឹមមាតារបស់លោកបានទេ សូមសម្លាប់គាត់ចោល កាលប្ដីពោលថា ការសម្លាប់មនុស្សជាកម្មធ្ងន់ ខ្ញុំនឹងសម្លាប់ម៉ែបានដូចម្ដេច ទើបពោលថា ក្នុងកាលដែលគាត់ដេកលក់ យើងនាំគ្នាសែងគាត់ទៅទាំងគ្រែនោះឯង បោះក្នុងស្ទឹងដែលមានក្រពើ ហើយក្រពើនឹងត្របាក់គាត់ស៊ី ។ ប្ដីសួរថា ម្ដាយរបស់នាងដេកឯណា នាងឆ្លើយថា ដេកជិតមាតារបស់លោកនោះឯង ប្ដីពោលថា បើដូច្នោះ ចូរនាងយកខ្សែចងគ្រែដែលមាតារបស់ខ្ញុំដេក ធ្វើជាគ្រឿងចំណាំ ។ គ្រានោះ នាងបានធ្វើយ៉ាងនោះ ហើយប្រាប់ថា ខ្ញុំបានធ្វើគ្រឿងសម្គាល់ហើយ ។ ប្ដីពោលថា រង់ចាំបន្តិចឲ្យជនទាំងឡាយដេកលក់សិន ខ្លួនឯងក៏ដេកធ្វើជាលក់ ហើយទៅស្រាយខ្សែនោះ មកចងត្រង់គ្រែម្ដាយភរិយា ដាស់ភរិយាឡើង ជនទាំង ២ ក៏នាំគ្នាលើកគ្រែឡើងសែងទៅបោះក្នុងទឹក ក្រពើទាំងឡាយបានចំណី ក៏ដណ្ដើមគ្នាទំពាស៊ីមាតា

របស់ស្រីនោះក្នុងស្ទឹងនោះ ។

ស្អែកឡើង នាងដឹងថា មាតាត្រូវប្តីរខូន ទើបពោលថា នែលោក មាតារបស់ខ្ញុំត្រូវសម្លាប់ហើយ បន្ទាប់អំពីនេះទៅ អ្នកគប្បីសម្លាប់មាតារបស់អ្នក កាលប្តីឆ្លើយថា បើដូច្នោះ យើងយល់ព្រម ទើបពោលថា យើងនាំគ្នាធ្វើជើងថ្ករក្នុងព្រៃខ្មោច ហើយចាប់គាត់ដាក់ចូលក្នុងភ្លើងឲ្យស្លាប់ លំដាប់នោះ ជនទាំង ២ បាននាំមាតាដែលកំពុងដេកលក់ទៅទុកត្រង់ព្រៃខ្មោច ប្តីពោលនឹងភរិយាក្នុងព្រៃខ្មោចនោះថា នាងនាំភ្លើងមកហើយឬ ភរិយាឆ្លើយថា មិនបាននាំមក ព្រោះភ្លេច ស្វាមីពោលថា បើដូច្នោះ ចូរនាងទៅនាំមក ភរិយាពោលថា ខ្ញុំមិនអាចទៅតែម្នាក់ឯង ទោះបីអ្នកទៅ ខ្ញុំក៏មិនហ៊ានទៅតែម្នាក់ឯង យើងទៅ ២ នាក់ចុះ ។ កាលប្តីប្រពន្ធទាំង ២ ត្រឡប់ទៅហើយ ស្រីនោះភ្ញាក់ឡើង ព្រោះខ្យល់រងា ដឹងថា ទីនោះជាព្រៃខ្មោច ពិចារណាថា ប្តីប្រពន្ធ ២ នាក់នេះ បំណងនឹងសម្លាប់អញ ពួកគេប្រហែលជាទៅយកភ្លើងមកដុតអញពិត គិតថា ពួកគេមិនស្គាល់កម្លាំងរបស់អញ ដូច្នេះហើយ ទើបបានយកសាកសពមួយដាក់ឲ្យដេកលើគ្រែ យកសំពត់ចាស់ដណ្តប់ពីខាងលើ ខ្លួនឯងក៏ចៀសចូលគុហា ពួនសម្ងំក្បែរព្រៃខ្មោចនោះឯង ។ ប្តីប្រពន្ធ ២ នាក់នាំភ្លើងមកហើយ ដុតសាកសព ដោយយល់ថា ជាស្រីចាស់ ហើយចៀសចេញទៅ ។

សម័យនោះ ក្នុងគុហាដែលគាត់ពួននោះ ចោរម្នាក់យកទ្រព្យទៅលាក់ទុកមុន ចោរនោះគិតថា អញនឹងទៅយកទ្រព្យនោះ ក៏មកឃើញស្រីចាស់

យល់ថា ជាយក្ខិនី គិតថា ទ្រព្យរបស់អញមានអមនុស្សហួងហែង ទើបទៅនាំគ្រូខ្មោចម្នាក់មក កាលគ្រូខ្មោចដើររាយមន្តចូលទៅក្នុងគុហា ស្រីចាស់ក៏ពោលនឹងគ្រូខ្មោចនោះថា ខ្ញុំមិនមែនយក្ខិនី អញ្ជើញអ្នកចូលមកចុះ យើងទាំង ២ នឹងបរិភោគទ្រព្យនេះ គ្រូខ្មោចពោលថា យើងជឿបានដូចម្ដេច ដូនចាស់ពោលថា សូមលោកយកអណ្ដាតរបស់លោកដាក់លើអណ្ដាតរបស់ខ្ញុំ គ្រូខ្មោចបានធ្វើយ៉ាងនោះ រំពេចនោះ ដូនចាស់បានខាំអណ្ដាតគ្រូខ្មោចដាច់ធ្លាក់ទៅ គ្រូខ្មោចមានឈាមហូរចេញពីអណ្ដាត គិតថា ស្រីចាស់នេះ ជាយក្ខិនីពិត ទើបស្រែករត់ទៅ ឯស្រីចាស់ កាលថ្ងៃរះឡើង ក៏ស្លៀកសំពត់សាច់ល្អ កាន់យករតនៈផ្សេងៗ ទៅផ្ទះ ។ លំដាប់នោះ ស្រីកូនប្រសាឃើញទើបសួរថា ម៉ែបានរបស់នេះពីណាមក ស្រីចាស់ឆ្លើយថា នែកូន ជនដែលត្រូវដុតលើជើងថ្ករក្នុងព្រៃនោះ រមែងបានទ្រព្យបែបនេះ ស្រីកូនប្រសាសួរថា បើដូច្នោះ មនុស្សដូចខ្ញុំនេះ អាចបានដែរឬទេ ស្រីចាស់ឆ្លើយថា បើដូចយើងពិតជាបាន ។ កាលនោះ ដោយការចង់បានក្នុងទ្រព្យ និងគ្រឿងប្រដាប់នាងក៏បានប្រាប់ដល់ប្ដីឲ្យដុតខ្លួនក្នុងព្រៃខ្មោចនោះ ។ ក្នុងថ្ងៃស្អែកឡើង ប្ដីមិនឃើញភរិយាត្រឡប់មក ទើបពោលនឹងម្ដាយថា បពិត្រអ្នកម៉ែ ម៉ែមកក្នុងពេលនេះ តែកូនប្រសា ហេតុអ្វី មិនឃើញមក ។ ស្រីចាស់បានស្ដាប់ដូច្នោះទើបប្រាប់កូនប្រុសថា វ៉ឺយ មនុស្សអាក្រក់ ឈ្មោះថា អ្នកដែលស្លាប់ហើយនឹងមកបានដូចម្ដេច ហើយពោលគាថានេះថា

អញមានចិត្តសោមនស្ស ហើយនាំមកនូវកូនប្រសាស្រីណា ដែលប្រដាប់ដោយកម្រងផ្កា និងប្រោះព្រំដោយខ្លឹមច័ន្ទន៍ ( ឥឡូវ ) កូនប្រសាស្រីនោះ បណ្តេញអញចេញអំពីផ្ទះ ភ័យកើតអំពីវត្ថុជាទីពឹងហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សោមនស្សំ** គឺធ្វើសោមនស្សឲ្យកើតឡើងម្យ៉ាងទៀត បាលីថា **សោមនស្សា** សេចក្តីថា ជាអ្នកត្រេកអរក្នុងសោមនស្ស ដូច្នេះក៏មាន ។

សេចក្តីនេះអធិប្បាយថា យើងយល់ថា កូនរបស់យើងនឹងចម្រើនដោយបុត្រធីតាទាំងឡាយ ព្រោះអាស្រ័យស្រីនេះ យើងនាំស្រីណា ដែលមានសោមនស្ស ឲ្យទ្រទ្រង់នូវកម្រងផ្កា មានកាយប្រោះព្រំដោយខ្លឹមចន្ទន៍មក ប្រដាប់តាក់តែងឲ្យជាកូនប្រសា សង្ឃឹមថា នឹងមើលថែយើង ក្នុងកាលឯចាស់ ស្រីនោះបណ្តេញយើងចេញអំពីផ្ទះ ក្នុងថ្ងៃនេះ ភ័យកើតអំពីទីពឹងហើយ ដូច្នេះ ។

ព្រះមហាសត្វទូលបន្តថា បពិត្រមហារាជ ព្រះរាជាជាទីពឹងរបស់មហាជន ដូចស្រីកូនប្រសាជាទីពឹងរបស់ម្តាយក្មេក កាលភ័យកើតអំពីព្រះរាជានោះហើយ អ្នកណាអាចនឹងធ្វើអ្វីបាន សូមទ្រង់ជ្រាបចុះ ។ ព្រះរាជាបានស្តាប់ដូច្នោះហើយ ត្រាស់ថា នែបា ហេតុការណ៍ដែលបានាំមកពោលនេះយើងមិនដឹង ចូរឯងចាប់ចោរឲ្យយើងចុះ ព្រះពោធិសត្វគិតថា អញនឹងរក្សាកិត្តិគុណព្រះរាជា ទើបបាននាំយករឿងមកក្រាបទូលបន្តទៀតថា

បពិត្រមហារាជ ក្នុងកាលមុន បុរសម្នាក់ក្នុងព្រះនគរនេះឯង តាំងនូវសេចក្តីប្រាថ្នាហើយ ក៏បានកូនប្រុស ក្នុងវេលាដែលកូនកើត គាត់ក៏មានបីតិសោមនស្សថា អញបានកូនប្រុសហើយ ចិញ្ចឹមកូននោះយ៉ាងល្អ កាលចម្រើនវ័យហើយ បានរកកិរិយាឲ្យ ។ ក្នុងកាលក្រោយមក គាត់ក៏ចាស់ជរា មិនអាចធ្វើការងារឲ្យសម្រេចបាន កាលនោះ កូននោះបានពោលនឹងគាត់ថា ពុកមិនអាចធ្វើការងារបានទេ សូមពុកចេញអំពីផ្ទះនេះ ហើយបណ្តេញចេញអំពីផ្ទះ គាត់ដើរសូមទានចិញ្ចឹមជីវិតដោយសេចក្តីលំបាក ខ្សឹកខ្សួលពោលគាថានេះថា

អញត្រេកត្រអាលនឹងកូនប្រុសណា ដែលកើតហើយ នឹងប្រាថ្នាសេចក្តីចម្រើនដល់កូនប្រុសណា ( ឥឡូវ ) កូនប្រុសនោះបណ្តេញអញចេញអំពីផ្ទះ ភ័យកើតអំពីវត្ថុ ជាទីពឹងហើយដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សោ មំ** សេចក្តីថា កូនប្រុសនោះបណ្តេញអញចេញអំពីផ្ទះ អញដើរសុំទានចិញ្ចឹមជីវិតដោយលំបាក ភ័យកើតឡើងដល់អាត្មាអញអំពីទីពឹងនោះឯង ។

ព្រះមហាសត្វ ក្រាបទូលបន្តថា បពិត្រមហារាជ ឈ្មោះថា បិតាអ្នកចាស់ជរា បុត្រដែលមានកម្លាំង មានសមត្ថភាព គួរថែរក្សា យ៉ាងណា ជនបទទាំងអស់ ព្រះរាជាគួររក្សា ដូច្នោះ ភ័យនេះកើតឡើង បានកើតឡើងហើយអំពីសម្នាក់របស់ព្រះរាជាដែលរក្សាសត្វទាំងពួង សូមទ្រង់ជ្រាបថា បុគ្គល

ឈ្មោះនោះជាចោរ ដោយហេតុនេះឯង ។ ព្រះរាជាទ្រង់ស្តាប់ដូច្នោះ ទើបត្រាស់ថា នែបា យើងមិនជ្រាបហេតុដែលគួរ និងមិនគួរ ចូរបាបង្ហាញចោរផងចុះ ឬខ្លួនបាជាចោរ ព្រះរាជារុកកួនមាណពរឿយៗ ដោយប្រការដូចពោលមកនេះ ។

លំដាប់នោះ ព្រះពោធិសត្វបានក្រាបទូលព្រះរាជាយ៉ាងនេះថា បពិត្រមហារាជ ទ្រង់ឲ្យទូលបង្គំបង្ហាញខ្លួនចោរតែម្យ៉ាងប៉ុណ្ណោះមិនមែនឬ ព្រះរាជាត្រាស់ថា ត្រូវហើយ ព្រះពោធិសត្វទូលថា បើដូច្នោះ ទូលបង្គំនឹងប្រកាសកណ្តាលបរិស័ទថា បុគ្គលនោះផង បុគ្គលនោះផងជាចោរ ព្រះរាជាត្រាស់ថា ចូរធ្វើយ៉ាងនោះចុះ ។ ព្រះពោធិសត្វបានស្តាប់រាជតម្រាស់ហើយ គិតថា ព្រះរាជានេះមិនឲ្យអញរក្សាទ្រង់ ដូច្នោះ អញនឹងចាប់ចោរក្នុងកាលឥឡូវនេះ គិតដូច្នេះហើយ ទើបប្រកាសហៅអ្នកនិគមជនបទមកប្រជុំគ្នា ហើយពោល ២ គាថាថា

សូមឲ្យពួកអ្នកជនបទ និងអ្នកនិគមដែលបានមកប្រជុំ ស្តាប់ខ្ញុំ ( ឥឡូវ ) វត្ថុណាជាទឹក វត្ថុនោះក្លាយទៅជាភ្លើង ហើយ សេចក្តីក្សេម កើតមកអំពីព្រះរាជាណា ភ័យកើតមកអំពីព្រះរាជានោះហើយ ព្រះរាជា និងព្រាហ្មណបុរោហិត ប្លន់ជនអ្នកនៅក្នុងដែន អ្នកទាំងឡាយ ចូររក្សាខ្លួន ត្បិតភ័យ កើតអំពីវត្ថុជាទីពឹងហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យតោ ឧកំ តទាទិត្តំ** សេចក្តីថា ទឹកមាន

ទីណា ភ្លើងក៏មានទីនោះ ។ បទថា **យតោ ខេមំ** សេចក្តីថា សេចក្តីក្សេមគប្បីមានដល់ព្រះរាជាអង្គណា ភ័យកើតឡើងហើយដល់ព្រះរាជាអង្គនោះ ។ បទថា **អត្តគុត្តា វិហរថ** សេចក្តីថា ឥឡូវនេះ អ្នកទាំងឡាយមិនមានទីពឹងហើយ ចូរកុំញុំាងខ្លួនឲ្យវិនាស ចូរអ្នកទាំងឡាយគ្រប់គ្រងខ្លួនឯង រក្សាទ្រព្យនិងស្រូវដែលជារបស់ខ្លួនចុះ ធម្មតាព្រះរាជាជាទីពឹងនៃមហាជន ភ័យកើតឡើងហើយដល់អ្នកទាំងឡាយអំពីព្រះរាជាអង្គនេះឯង ព្រះរាជានិងព្រាហ្មណបុរោហិតជាចោរ រកស៊ីដោយការប្លន់ បើអ្នកទាំងឡាយបំណងនឹងចាប់ចោរក៏ចូរចាប់ព្រះរាជា និងព្រាហ្មណបុរោហិត ទាំង ២ នាក់នេះដាក់ទោសចុះ ។

លំដាប់នោះ មហាជនទាំងនោះ បានស្តាប់ពាក្យរបស់ព្រះពោធិសត្វនោះហើយ នាំគ្នាពោលថា ព្រះរាជាអង្គនេះ គួរមានតួនាទីគ្រប់គ្រងរក្សាឥឡូវនេះ ទ្រង់បែរជាដាក់ទោសអ្នកដទៃ យកទ្រព្យរបស់ខ្លួនទៅទុកក្នុងស្រះបោក្ខរណី ដោយព្រះអង្គឯង ហើយស្វែងរកចោរ ឥឡូវនេះ ពួកយើងនឹងសម្លាប់ព្រះរាជាលាមកនេះចោល ដើម្បីកុំឲ្យធ្វើចោរកម្មតទៅទៀត ។ លំដាប់នោះ មហាជនទាំងនោះ ក៏នាំគ្នាក្រោកឡើង កាន់កំណាត់ឈើខ្លះ ដំបងខ្លះវាយព្រះរាជា និងព្រាហ្មណបុរោហិតឲ្យស្លាប់ ហើយអភិសេកព្រះមហាសត្វឲ្យគ្រងរាជសម្បត្តិតទៅ ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះ មកសម្តែងដូច្នេះហើយត្រាស់ថា ម្នាលឧបាសក ការចាំស្នាមជើងលើផែនដីបាន មិនគួរអស្ចារ្យទេបណ្ឌិតកាលមុន ចាំស្នាមជើងក្នុងអាកាសបានយ៉ាងនេះ ហើយទ្រង់ប្រកាស

សង្ឃ:ទាំងឡាយ ក្នុងកាលចប់សច្ចៈ ឧបាសក និងបុត្រតាំងនៅក្នុងសោតា-
បត្តិផល ហើយទ្រង់ប្រជុំជាតកថា បិតាក្នុងកាលនោះ បានមកជាកស្សប:
ក្នុងកាលឥឡូវនេះ មាណពអ្នកឈ្លាសក្នុងការសង្កេតស្នាមជើងក្នុងកាលនោះ
គឺតថាគតនេះឯង ៕ល៚

**អដ្ឋកថា បទកុសលមាណវកជាតក ចប់**

# សុត្តន្តបិដក

## លោមសកស្សបជាតក

[ ៥៦៣ ] ( ព្រះឥន្ទនិយាយនឹងព្រះបាទព្រហ្មទត្តថា ) បពិត្រព្រះរាជា បើព្រះអង្គញុំាងឥសីឈ្មោះលោមសកស្សបៈឲ្យបូជាយញ្ញ ព្រះអង្គនឹងបានទៅជាបុគ្គលមិនចាស់ មិនស្លាប់ ស្មើនឹងព្រះឥន្ទ ដោយពិត ។

[ ៥៦៤ ] ( តាបសពោធិសត្វពោលនឹងអាមាត្យថា ) បុគ្គលមិនគួរប្រាថ្នានូវផែនដីដែលមានសមុទ្រព័ទ្ធជុំវិញ ដូចកុណ្ឌលក្នុងសាគរ ព្រមទាំងពាក្យតិះដៀលទេ ម្នាលសេយ្ហាមាត្យ អ្នកចូរដឹងយ៉ាងនេះចុះ ។

[ ៥៦៥ ] ម្នាលព្រាហ្មណ៍ ការប្រព្រឹត្ត ( ចិញ្ចឹមជីវិត ) ណាដោយកិរិយាបំផ្លាញជីវិតគេ ឬដោយការប្រព្រឹត្តមិនត្រូវតាមធម៌ មុខគួរឲ្យតិះដៀលនូវការបានយស និងការបាននូវទ្រព្យដោយការប្រព្រឹត្តនោះ ។

[ ៥៦៦ ] បុគ្គលបួសដើរបិណ្ឌបាត ការចិញ្ចឹមជីវិតនោះ ប្រសើរជាងការស្វែងរកខុសធម៌ ។

[ ៥៦៧ ] បុគ្គលបួសដើរបិណ្ឌបាត មិនបៀតបៀនជនដទៃក្នុងលោក ការនោះប្រសើរជាងរាជសម្បត្តិទៅទៀត ។

[ ៥៦៨ ] ( មហាជននិយាយថា ) ព្រះចន្ទមានកម្លាំង ព្រះអាទិត្យមានកម្លាំង ពួកសមណព្រាហ្មណ៍មានកម្លាំង ប្រាំងសមុទ្រ

មានកម្លាំង ឯពួកស្ត្រីមានកម្លាំងលើសលុបជាងកម្លាំង ( នោះៗទៅទៀត ) ។

[ ៥៦៩ ] ដូចជារាជធីតាឈ្មោះចន្ទវតី បានញ៉ាំងឥសីឈ្មោះលោមសកស្សបៈ មានតបៈដ៏ខ្ពង់ខ្ពស់ ឲ្យបូជានូវការបូជាឈ្មោះវាជបេយ្យៈ គឺបូជាដោយការសម្លាប់សត្វចិញ្ចឹមដើម្បីប្រយោជន៍ដល់បិតា ។

[ ៥៧០ ] ( តាបស ... ) អំពើដែលធ្វើដោយសេចក្តីលោភនោះ ជាអំពើក្តៅក្រហាយ មានកាមជាហេតុ អាត្មានឹងស្វែងរកឫសនៃអំពើនោះ នឹងកាត់នូវរាគៈ ព្រមទាំងចំណង ។

[ ៥៧១ ] មុខគួរតិះដៀលនូវកាមទាំងឡាយ ដ៏ច្រើនក្រៃពេកក្នុងលោក បពិត្រព្រះរាជា ការព្យាយាមដុតបំផ្លាញកិលេសប្រសើរបំផុតជាងកាមគុណទាំងឡាយ អាត្មានឹងលះបង់កាមហើយធ្វើព្យាយាមបំផ្លាញកិលេស ឯដែន និងនាងចន្ទវតី ចូរជារបស់ព្រះអង្គវិញចុះ ។

**លោមសកស្សបជាតកទី ៧ ចប់**

# អដ្ឋកថា

## លោមសកស្សបជាតក

[ ៥៦៣-៥៧១ ] ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអផ្សុកមួយរូប ទើបត្រាស់រឿងនេះ មានពាក្យផ្ដើមថា **អស្ស ឥន្ទសមោ រាជា** ដូច្នេះ ។

មានសេចក្ដីសង្ខេបថា ព្រះសាស្ដាត្រាស់សួរភិក្ខុនោះថា ម្នាលភិក្ខុ បានឮថា អ្នកអផ្សុកពិតឬ កាលភិក្ខុរូបនោះទូលថា ករុណាព្រះអង្គ ទើបត្រាស់ថា ម្នាលភិក្ខុ ខ្យល់ដែលផាត់ភ្នំសិនេរុឲ្យកម្រើកញាប់ញ័រ រឿងអ្វី ដែលថាមិនបក់ស្លឹកឈើចាស់ៗ ឲ្យកម្រើកនោះ បុគ្គលដល់ព្រមដោយយសទូទៅគង់វិនាសយសបាន ឈ្មោះថា កិលេស រមែងធ្វើសត្វដែលបរិសុទ្ធឲ្យសៅហ្មងបាន នឹងពោលថ្វីដល់មនុស្សដូចអ្នក ដូច្នេះហើយ ទ្រង់នាំយករឿងក្នុងអតីតមកសម្ដែងដូចតទៅ

ក្នុងអតីតកាល ឱរសរបស់ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះនាមព្រហ្មទត្តកុមារ និងកូនរបស់បុរោហិត ឈ្មោះកស្សបៈ ជាសម្លាញ់នឹងគ្នា រៀនសិប្បៈគ្រប់យ៉ាង ក្នុងត្រកូលអាចារ្យតែមួយសម័យតមក កាលព្រះរាជាបិតាសោយទិវង្គត ព្រហ្មទត្តកុមារបានគ្រងរាជ-សម្បត្តិ ។ កាលនោះ កស្សបកុមារគិតថា សម្លាញ់របស់អញជាព្រះរាជាដូច្នេះ គង់ព្រះរាជទានភាពជាធំ ប្រយោជន៍អ្វីដោយភាពជាធំសម្រាប់អញ អញលាមាតាបិតា និងព្រះរាជា ហើយបួស លុះគិតដូច្នេះហើយ ទើបថ្វាយបង្គំលាព្រះរាជា និងលាមាតាបិតា ទៅកាន់ដែនដីហិមពាន្ត បួសជាឥសី ក្នុង

ថ្ងៃទី ៧ បានអភិញ្ញា និងសមាបត្តិ ចិញ្ចឹមជីវិតដោយការស្វែងរកផ្លែឈើ មនុស្សទាំងឡាយនាំគ្នាហៅលោកដែលជាបព្វជិតថា លោមសកស្សបៈ ។ លោកជាតាបសមានឥន្ទ្រិយស្ងប់រម្ងាប់ក្រៃលែង មានតបៈខ្លាំងក្លា សក្កពិភពញាប់ញ័រដោយតេជះនៃតបៈរបស់តាបសនោះ ។ គ្រានោះ សក្កទេវរាជទ្រង់បានពិចារណាឃើញហេតុ ដូច្នោះហើយ ទ្រង់ត្រិះរិះថា តាបសនេះមានតេជះខ្លាំងក្លា ធ្វើអញឲ្យឃ្លាតចាកភាពជាសក្កៈ អញនឹងសហការជាមួយនឹងព្រះបាទពារាណសី ទម្លាយតបៈរបស់តាបសនេះចេញ ។ គ្រានោះ សក្កទេវរាជបានចូលទៅកាន់បន្ទប់ដ៏មានសិរី របស់ព្រះបាទពារាណសីទាំងកណ្តាលយប់ សម្តែងនូវអានុភាពរបស់សក្កៈ ធ្វើបន្ទប់ទាំងមូលឲ្យភ្លឺដោយរស្មី ព្រះសរីរៈអណ្តែតនៅក្នុងអាកាស ក្នុងសម្នាក់របស់ព្រះរាជា ដាស់ព្រះរាជាថា តើនឡើងមហារាជ កាលព្រះរាជាត្រាស់សួរថា លោកជានរណា ក៏ត្រាស់ថា យើង គឺសក្កៈ ព្រះរាជាត្រាស់សួរថា ទ្រង់មកដើម្បីអ្វី សក្កទេវរាជត្រាស់ឆ្លើយថា មហារាជ ទ្រង់ប្រាថ្នាភាពជាធំក្នុងជម្ពូទ្វីបទាំងមូល ឬមិនប្រាថ្នាទេ ព្រះរាជាបានត្រាស់ឆ្លើយថា រឿងអ្វីថា មិនប្រាថ្នានោះ ។ លំដាប់នោះ សក្កទេវរាជក៏ត្រាស់នឹងព្រះរាជាថា បើដូច្នោះ សូមទ្រង់នាំលោមសកស្សបតាបសមកបូជាបសុឃាតយញ្ញ ទ្រង់នឹងស្មើដោយសក្កទេវរាជ មិនចាស់ មិនស្លាប់ នឹងបានគ្រងរាជសម្បត្តិក្នុងជម្ពូទ្វីបទាំងមូល ដូច្នេះហើយ ត្រាស់គាថាទី ១ ថា

បពិត្រព្រះរាជា បើព្រះអង្គញ៉ាំងឥសីឈ្មោះលោមសកស្សបៈ
ឲ្យបូជាយញ្ញ ព្រះអង្គនឹងបានទៅជាបុគ្គលមិនចាស់ មិនស្លាប់

ស្មើនឹងព្រះឥន្ទដោយពិត ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អស្ស** បានដល់ នឹងបានជា ។ បទថា **យជេយ្យ** សេចក្ដីថា បើទ្រង់នាំឥសីលោមសកស្សបៈមកអំពីលំនៅក្នុងព្រៃឲ្យមកបូជាយញ្ញបាន ។

លំដាប់នោះ ព្រះរាជាទ្រង់បានស្ដាប់ព្រះតម្រាស់នៃសក្កទេវរាជហើយ ទ្រង់ទទួលពាក្យថា សាធុ ។ គ្រានោះ សក្កទេវរាជដាស់តឿនថា បើដូច្នោះ សូមទ្រង់កុំយឺតយ៉ាវ ហើយចៀសចេញទៅ ។

ស្អែកឡើង ព្រះរាជាឲ្យហៅសេយ្យាមាត្យមក ត្រាស់ថា នែសម្លាញ់ ចូរឯងទៅកាន់សម្នាក់លោមសកស្សបៈ ជាសម្លាញ់ជាទីស្រឡាញ់របស់យើង ចូរនិយាយតាមពាក្យយើងយ៉ាងនេះថា ព្រះរាជាឲ្យលោកម្ចាស់បូជាបសុឃាតយញ្ញ ហើយនឹងបានជាឯករាជ្យក្នុងជម្ពូទ្វីប លោកម្ចាស់ប្រាថ្នាប្រទេសណា ព្រះរាជានឹងព្រះរាជទានប្រទេសប្រមាណប៉ុណ្ណោះដល់លោកម្ចាស់ សូមលោកម្ចាស់មកដើម្បីបូជាយញ្ញជាមួយយើង ។ សេយ្យាមាត្យស្ដាប់ពាក្យដូច្នោះហើយ ក្រាបទូលថា សាធុ ហើយឲ្យវាយស្គរប្រកាសក្នុងព្រះនគរ ដើម្បីដឹងលំនៅរបស់តាបស កាលថ្មើរព្រៃម្នាក់ប្រាប់ថា ខ្ញុំស្គាល់ បានឲ្យបុរសនោះ ជាមគ្គុទ្ទេសក៍ ធ្វើដំណើរទៅទីនោះដោយបរិវារធំ ថ្វាយបង្គំឥសីហើយ អង្គុយក្នុងទីសមគួរនាចំណែកម្ខាង ប្រាប់ដំណឹងនោះ ។ លំដាប់នោះ តាបសបានស្ដាប់ពាក្យរបស់សេយ្យាមាត្យហើយ ពោលថា នែសេយ្យៈ ឯងនិយាយអ្វី កាលបដិសេធនូវពាក្យរបស់សេយ្យាមាត្យ បានពោលគាថា ៤ គាថាថា

បុគ្គល មិនគួរប្រាថ្នានូវផែនដីដែលមានសមុទ្រព័ទ្ធជុំវិញ ដូចកុណ្ឌលក្នុងសាគរ ព្រមទាំងពាក្យតិះដៀលទេ ម្នាលសេយ្យាមាត្យ អ្នកចូរដឹងយ៉ាងនេះចុះ ។

ម្នាលព្រាហ្មណ៍ ការប្រព្រឹត្ត ( ចិញ្ចឹមជីវិត ) ណា ដោយកិរិយាបំផ្លាញជីវិតគេ ឬដោយការប្រព្រឹត្តមិនត្រូវតាមធម៌ មុខគួរឲ្យតិះដៀលនូវការបានយស និងការបាននូវទ្រព្យដោយការប្រព្រឹត្តនោះ ។

បុគ្គលបួសដើរបិណ្ឌបាត ការចិញ្ចឹមជីវិតនោះ ប្រសើរជាងការស្វែងរកខុសធម៌ ។

បុគ្គលបួសដើរបិណ្ឌបាត មិនបៀតបៀនជនដទៃ ក្នុងលោក ការនោះប្រសើរជាងរាជសម្បត្តិទៅទៀត ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សសមុទ្ទបរិយាយំ** បានដល់ មានសមុទ្រព័ទ្ធដោយជុំវិញ ។ បទថា **សាគរកុណ្ឌលំ** បានដល់ ដែលប្រកបដោយសាគរដែលព័ទ្ធជុំវិញទ្វីបទាំង ៤ ដូចកុណ្ឌលដែលគេពាក់ត្រង់ត្រចៀកដូច្នោះ ។ បទថា **សហ និន្ទាយ** សេចក្ដីថា លោមសកស្សបតាបសពោលថា អាត្មាមិនប្រាថ្នាសូម្បីមហាប្រឹថពី ដែលមានចក្រវាលជាទីបំផុត មួយអន្លើដោយពាក្យនិន្ទានេះថា លោមសកស្សបតាបសនេះ បានធ្វើបសុឃាតកម្មហើយ ។ បទថា **យា វុត្តិ វិនិបាតេន** លោមសកស្សបតាបសសម្ដែងថា យើងតិះដៀលការប្រព្រឹត្តទៅនៃជីវិត ដោយកម្ម ដែលឲ្យធ្លាក់ទៅក្នុងនរក គឺ

យើងតិះដៀលការប្រព្រឹត្តទៅនោះ ។ បទថា **សាយេវ ជីវិកា** សេចក្ដីថា ការរស់នៅដោយវិធីឱបបាត្រដី ដើរចូលទៅកាន់ផ្ទះរបស់អ្នកដទៃ ស្វែងរកអាហាររបស់បព្វជិតនោះឯង ល្អជាងការបានយស ទ្រព្យ និងលាភរាប់រយរាប់ពាន់ទ្វេគុណ ។ បទថា **អបិ រជ្ជេន តំ វរំ** សេចក្ដីថា ការវៀរនូវអំពើអាក្រក់របស់បព្វជិត ដែលមិនបៀនអ្នកដទៃនោះ ប្រសើរជាងភាពជាព្រះរាជាក្នុងជម្ពូទ្វីបទាំងមូល ។

អមាត្យស្ដាប់ពាក្យរបស់តាបសនោះ បានមកក្រាបទូលដល់ព្រះរាជាៗ បានស្ដាប់ដូច្នោះ ត្រាស់ថា កាលបើលោកម្ចាស់មិនមក យើងក៏មិនអាចធ្វើអ្វីបាន ទើបទ្រង់នៅស្ងៀម ។ លំដាប់នោះ សក្កទេវរាជបានយាងមកក្នុងកណ្ដាលរាត្រីទៀត ប្រថាប់នៅក្នុងអាកាសត្រាស់ថា នែមហារាជ ហេតុអ្វីទើបមិនបង្គាប់លោមសកស្សបតាបសឲ្យបូជាយញ្ញ ព្រះរាជាត្រាស់ថា ខ្ញុំបញ្ជូនអមាត្យឲ្យទៅប្រាប់ហើយ តែលោកមិនមក សក្កៈត្រាស់ថា នែមហារាជ បើដូច្នោះ សូមទ្រង់ស្អិតស្អាងចន្ទវតីកុមារី ដែលជារាជធីតារបស់ទ្រង់ ហើយប្រគល់ឲ្យសេយ្យាមាត្យនាំទៅ ប្រាប់ថា បើលោកម្ចាស់មកបូជាយញ្ញ ព្រះរាជានឹងព្រះរាជទានព្រះរាជកុមារីនេះដល់លោកម្ចាស់ តាបសនោះ នឹងមានចិត្តប្រតិព័ទ្ធក្នុងកុមារី នឹងមកពិត ។ ព្រះរាជាទ្រង់ស្ដាប់ដូច្នោះ ទ្រង់ទទួលថា សាធុ ។ ស្អែកឡើង ទ្រង់ប្រគល់រាជធីតារបស់ទ្រង់ដល់សេយ្យាមាត្យបញ្ជូនទៅហើយ សេយ្យាមាត្យនាំព្រះរាជធីតាទៅទីនោះ ថ្វាយបង្គំឥសី ធ្វើបដិសណ្ឋារៈហើយ ឈរក្នុងទីសមគួរនាចំណែកម្ខាង បង្ហាញរាជធីតាដែលស្អាត

ដូចទេពអប្សរដល់ឥសី ។ លំដាប់នោះ តាបសទម្លាយឥន្រ្ទិយ ហើយសម្លឹង មើលរាជធីតា ជំណាលគ្នានឹងការមើលនោះឯង ក៏កើតចិត្តប្រតិព័ទ្ធ ហើយ ក៏សាបសូន្យចាកឈាន ។ អមាត្យដឹងថា តាបសមានចិត្តប្រតិព័ទ្ធ ទើបពោល ថា បពិត្រលោកម្ចាស់ បើលោកម្ចាស់បូជាយញ្ញ ព្រះរាជានឹងឲ្យព្រះរាជធីតា នេះ ជាបាទបរិចារិកាសម្រាប់លោកម្ចាស់ ។ តាបសនោះ កំពុងញាប់ញ័រ ដោយអំណាចកិលេស ទើបសួរថា បានឮថា ព្រះរាជានឹងព្រះរាជទានព្រះ រាជធីតានេះដល់យើងឬ អមាត្យឆ្លើយថា ត្រូវហើយ ព្រះរាជានឹងព្រះរាជទាន ដល់លោកម្ចាស់ដែលបូជាយញ្ញ តាបសពោលថា សាធុ បើយើងបានព្រះ រាជធីតានេះ នឹងបូជាយញ្ញ ហើយពាក់ជដា នាំព្រះរាជធីតាឡើងរថ ដែល ប្រដាប់តាក់តែងស្អាត ទៅកាន់នគរពារាណសី ។

ព្រះរាជាបានឮថា តាបសអញ្ជើញមក ក៏ត្រាស់ឲ្យរៀបចំពិធីកម្មឡើង ត្រង់រណ្តៅបូជាយញ្ញសម្រាប់តាបសនោះ ។ កាលបានទតឃើញតាបសមក ក៏ត្រាស់ថា សូមលោកបូជាយញ្ញក្នុងថ្ងៃស្អែកនេះ យើងនឹងស្មើដោយព្រះឥន្ទ្រ ពេលចប់ការបូជាយញ្ញ យើងនឹងឲ្យធីតាដល់លោក ។ កស្សបតាបសទទួល ពាក្យថា សាធុ ។ ក្នុងថ្ងៃស្អែកឡើង ព្រះរាជានាំតាបសទៅឯរណ្តៅបូជាយញ្ញ មួយអន្លើដោយនាងចន្ទវតី ។ ក្នុងរណ្តៅនោះ មានសត្វចតុបាទគ្រប់យ៉ាង ដូច ជាដំរី សេះ គោជាដើម ប្រតិស្ឋានជាលំដាប់ តាបសផ្តើមនឹងសម្លាប់សត្វ ទាំងនោះឲ្យស្លាប់ ហើយបូជាយញ្ញ ។ មហាជនដែលមកប្រជុំគ្នាក្នុងទីនោះ ឃើញដូច្នោះ ពោលថា បពិត្រលោមសកស្សបៈ កម្មនេះ មិនសមគួរដល់

លោកទេ លោកធ្វើកម្មនោះដើម្បីអ្វី ហើយយំសោក ពោល ២ គាថាថា

ព្រះចន្ទមានកម្លាំង ព្រះអាទិត្យមានកម្លាំង ពួកសមណព្រាហ្មណ៍
មានកម្លាំង ប្រាំងសមុទ្រ មានកម្លាំង ឯពួកស្ត្រីមានកម្លាំង
លើសលុបជាងកម្លាំង ( នោះៗ ទៅទៀត ) ។

ដូចជារាជធីតាឈ្មោះចន្ទវតី បានញុំាងឥសីឈ្មោះលោមសកស្សបៈ
មានតបៈដ៏ខ្ពង់ខ្ពស់ ឲ្យបូជានូវការបូជាឈ្មោះវាជបេយ្យៈ គឺបូជា
ដោយការសម្លាប់សត្វចិញ្ចឹមដើម្បីប្រយោជន៍ដល់បិតា ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ពលំ ចន្ទោ ពលំ សុរិយោ** សេចក្ដីថា ក្នុងការកម្ចាត់ងងឹត កម្លាំងដទៃ រមែងមិនមានក្នុងការកម្ចាត់ងងឹតនេះ ព្រះចន្ទ និងព្រះអាទិត្យប៉ុណ្ណោះមានកម្លាំង ។ បទថា **សមណព្រាហ្មណា** សេចក្ដីថា ក្នុងការអត់ធន់ចំពោះកម្លាំងនៃឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ សមណព្រាហ្មណ៍ដែលប្រកបដោយកម្លាំង គឺខន្តី និងកម្លាំង គឺញាណ ដែលមានបាបស្ងប់រម្ងាប់ និងមានបាបបន្សាត់ហើយ មានកម្លាំង ។ បទថា **ពលំ វេលា សមុទ្ទស្ស** សេចក្ដីថា ប្រាំងនៃមហាសមុទ្រ ឈ្មោះថា មានកម្លាំង ព្រោះអាចមិនឲ្យទឹកឡើងមក និងការពារទឹកឲ្យវិនាសបាន ។ បទថា **ពលាតិ ពលមិត្ថិយោ** សេចក្ដីថា ឯស្រីទាំងឡាយ ជាអ្នកមានកម្លាំងក្រៃលែងជាងកម្លាំងទាំងអស់នោះ ព្រោះអាចនាំបុរសដែលមានប្រាជ្ញាល្អ តែមានតម្រេកមកកាន់អំណាចខ្លួន រួចឲ្យវិនាសបាន អធិប្បាយថា កម្លាំងនៃស្រីប៉ុណ្ណោះ មានច្រើនជាងកម្លាំងទាំងឡាយ ។ សព្ទថា **យថា** ស្មើគ្នានឹង **យស្មា** ប្រែថា ព្រោះហេតុ

ណា ។ បទថា **បិតុ អត្ថា** បានដល់ ដើម្បីជាប្រយោជន៍នៃសេចក្ដីចម្រើនដល់បិតា ។

សេចក្ដីនេះមានអធិប្បាយថា ព្រោះនាងចន្ទវតី ធ្វើលោមសកបស្សបៈដែលមានតបៈខ្លាំងក្លា ឈ្មោះថា ជាឥសី ព្រោះជាអ្នកស្វែងគុណទាំងឡាយមានសីលជាដើម ឲ្យជាអ្នកមិនមានសីល ហើយឲ្យបូជា **វាជបេយ្យ** គឺយញ្ញដើម្បីជាប្រយោជន៍ដល់ព្រះរាជបិតាបាន ដូច្នោះ សេចក្ដីនេះ បណ្ឌិតគប្បីជ្រាបថា ស្រីមានកម្លាំងក្រៃលែងជាងកម្លាំងទាំងឡាយ ។

ខណៈនោះ កស្សបតាបសឆ្លាព្រះខ័នកែវឡើង ដោយគិតថា នឹងកាត់ក្បាលមង្គលហត្ថី ដើម្បីបូជាយញ្ញ ដំរីឃើញដូច្នោះ ភ័យខ្លាចចំពោះមរណភ័យទើបស្រែកដោយសំឡេងខ្លាំង សូម្បីពួកសត្វក្រៅអំពីនេះ គឺដំរី សេះ គោជាដើម បានស្ដាប់សំឡេងស្រែករបស់មង្គលហត្ថីនោះ ក៏នាំគ្នាតក់ស្លុតចំពោះមរណភ័យ ទើបស្រែកកងរំពងដោយសេចក្ដីខ្លាច សូម្បីមហាជនក៏នាំគ្នាស្រែកកស្សបតាបសបានឮសំឡេងស្រែកដ៏ធំ ដូច្នោះ ក៏សង្វេគ ក្រឡេកមើលជដារបស់ខ្លួនជាដើម លំដាប់នោះ ជដា ពុកមាត់ ពុកចង្កា រោមក្លៀក រោមទ្រូងបានប្រាកដដល់តាបសនោះ តាបសមានចិត្តក្ដៅក្រហាយ គិតថា អញបានធ្វើកម្មលាមក មិនសមគួរសោះ កាលនឹងប្រកាសសេចក្ដីសង្វេគ បានពោលគាថាទី ៨ ថា

អំពើដែលធ្វើដោយសេចក្ដីលោភនោះ ជាអំពើក្ដៅក្រហាយ មាន
កាមជាហេតុ អាត្មានឹងស្វែងរកឫសនៃអំពើនោះ នឹងកាត់នូវ

ភាគៈ ព្រមទាំងចំណាង ដូច្នេះ ។

គប្បីជ្រាបអត្ថ នៃពាក្យដែលជាគាថានោះថា បពិត្រព្រះរាជាជាធំ កម្ម ណាដែលទូលបង្គំកើតនូវសេចក្តីលោភ ក្នុងនាងចន្ទវតី ហើយធ្វើដោយសេចក្តី លោភនោះ កម្មនោះ មានកាមជាហេតុ កម្មដែលធ្វើហើយនោះ ជាកម្មក្តៅ ក្រហាយ មានវិបាកខ្លាំងក្លា ទូលបង្គំនឹងស្វែងរកឫសគល់ ពោល គឺអយោ-និសោមនសិការរបស់កម្មនោះសមគួរហើយ ដោយដាវនេះ ទូលបង្គំនឹងដក ដាវ គឺបញ្ញាចេញមក កាត់នូវភាគៈ មួយអន្លើដោយចំណាង គឺសុភនិមិត្ត ។

លំដាប់នោះ ព្រះរាជាត្រាស់នឹងតាបសថា នែសម្លាញ់ លោកកុំខ្លាច ឡើយ យើងនឹងឲ្យនាងចន្ទវតីកុមារី និងគំនរកែវ ៧ ប្រការដល់លោក ក្នុង កាលឥឡូវនេះ ចូរលោកបូជាយញ្ញចុះ ។ កស្សបតាបសបានស្តាប់ដូច្នោះ ទើបពោលថា បពិត្រមហារាជ ទូលបង្គំមិនត្រូវការដោយកិលេសនេះ ហើយ ក៏ពោលគាថាចុងក្រោយថា

មុខគួរតិះដៀលនូវកាមទាំងឡាយ ដ៏ច្រើនក្រៃពេក ក្នុងលោក
បពិត្រព្រះរាជា ការព្យាយាមដុតបំផ្លាញកិលេស ប្រសើរបំផុត
ជាងកាមគុណទាំងឡាយ អាត្មានឹងលះបង់កាម ហើយធ្វើព្យា-
យាមបំផ្លាញកិលេស ឯដែន និងនាងចន្ទវតី ចូរជារបស់
ព្រះអង្គវិញចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សុពហូបិ** បានដល់ សូម្បីមានច្រើន ក្រៃលែង ។ បទថា **តចោ ករិស្សាមិ** បានដល់ នឹងបំពេញសីលសំវរៈ

ប៉ុណ្ណោះ ។

តាបស កាលទូលដូច្នេះហើយ បានប្រមូលកសិណបរិកម្ម ធ្វើគុណវិសេស ដែលវិនាសទៅឲ្យកើតឡើង អង្គុយពត់ភ្នែនក្នុងអាកាសសម្តែងធម៌ដល់ព្រះរាជាថា សូមទ្រង់កុំប្រមាទ ហើយទម្លាយរណ្តៅបូជាយញ្ញ ឲ្យអភ័យដល់មហាជន កាលព្រះរាជាកំពុងអង្វរ បានហោះទៅក្នុងលំនៅរបស់ខ្លួន ចម្រើនព្រហ្មវិហារធម៌ ដរាបដល់អស់ជីវិត មានព្រហ្មលោកជាទីទៅខាងមុខ ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកសម្តែងដូច្នេះហើយ ក៏ទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងកាលចប់សច្ចៈ ភិក្ខុអផ្សុក តាំងនៅក្នុងអរហត្ត ហើយទ្រង់ប្រជុំជាតកថា សេយ្យាមាត្យ ក្នុងកាលនោះ បានមកជាសារីបុត្រ ក្នុងកាលឥឡូវនេះ ឯលោមសកស្សបតាបស ក្នុងកាលនោះ គឺតថាគតនេះឯង ។ល។

## អដ្ឋកថា លោមសកស្សបជាតក ចប់

# សុត្តន្តបិដក

## ចក្កវាកជាតក

[ ៥៧២ ] ( ក្អែកនិយាយនឹងចាក្រពាកថា ) ខ្ញុំសូមសួរនូវពួកសត្វបក្សីមានសម្បុរដូចសំពត់ ដែលជ្រលក់ដោយទឹកអម្ចត់ ជាសត្វមានចិត្តរីករាយ ត្រាច់ទៅទាំងគូៗ ចុះក្នុងពួកកំណើតជាអណ្ឌជៈ និងមនុស្សទាំងឡាយ តើគេសរសើរនូវកំណើតអណ្ឌជៈណា អ្នកចូរពោលនូវហេតុនោះមកមើល ។

[ ៥៧៣ ] ( ចាក្រពាកតបថា ) ម្នាលក្អែក ជាសត្វបៀតបៀនមនុស្ស ពួកគេតែងពោលសរសើរយើងជាចាក្រពាកថា ជាសត្វប្រព្រឹត្តសមគួរក្នុងចំណោមនៃមនុស្សទាំងឡាយ ទាំងគេបានសន្មតយើងថា ជាសត្វមានភាពល្អ ក្នុងចំណោមនៃសត្វស្លាបទាំងឡាយ ( ពួកយើងមានសភាពជាសត្វឥតភ័យ ត្រាច់ទៅផ្សេងៗក្នុងស្រះឈូក ) ពួកយើងមិនធ្វើបាបព្រោះហេតុតែចំណីឡើយ ។

[ ៥៧៤ ] ( ក្អែក ... ) ម្នាលចាក្រពាកទាំងឡាយ ជាអ្នកមិនថោកទាប អ្នកទាំងឡាយបរិភោគផ្លែឈើអ្វី ទំពាស៊ីសាច់អ្វី បរិភោគភោជនអ្វីក្នុងស្រះ បានជាកម្លាំង និងសម្បុរមានសភាពមិនតិច ។

[ ៥៧៥ ] ( ចាក្រពាក ... ) ម្នាលក្អែក ផ្លែឈើទាំងឡាយមិនមានក្នុងស្រះទេ ពួកចាក្រពាកបានសាច់បរិភោគអំពីណា ពួកយើងជាអ្នកបរិភោគសារាយ បរិភោគតែទឹកមិនល្អក់ ( ពួកយើង

មិនធ្វើបាបព្រោះហេតុតែចំណីឡើយ ) ពួកយើងមានសភាពជាអ្នកឥតភ័យ ត្រាច់ទៅផ្សេងៗ ក្នុងស្រះ ។

[ ៥៧៦ ] ( ក្អែក ... ) ម្នាលចាក្រពាក ភោជនទេះមិនគាប់ចិត្តយើងទេ ខ្លួនអ្នកមានសភាពប្រហែលនឹងភោជនក្នុងលំនៅនេះ កាលដើម ខ្ញុំមានសេចក្តីត្រិះរិះ ( យ៉ាងនេះ ) ខាងក្រោយមកខ្ញុំមានសេចក្តីត្រិះរិះផ្សេង សេចក្តីសង្ស័យរបស់ខ្ញុំក៏កើតមានក្នុងហេតុនុ៎ះ ដោយប្រការដូច្នេះឯង ។

[ ៥៧៧ ] ឯខ្លួនយើងតែងបានបរិភោគសាច់ និងផ្លែឈើទាំងឡាយផង នូវចំណីអាហារដែលលាយអំបិល និងប្រេងទាំងឡាយផង ខ្លួនយើងតែងបានបរិភោគនូវរសក្នុងពួកមនុស្ស ដូចបុគ្គលក្លៀវក្លាបានឈ្នះនូវប្រធាននៃសង្គ្រាម ម្នាលចាក្រពាក ឯសម្បុររបស់ខ្ញុំ មិនដូចជាសម្បុររបស់អ្នកទេ ។

[ ៥៧៨ ] ( ចាក្រពាក ... ) អ្នកជាសត្វមានអាហារមិនស្អាត តែងលបចក់ក្នុងខណៈ ( ដែលគេធ្វេសប្រហែស ) អ្នកឯងតែងបាននូវចំណីអាហារ និងទឹកផឹកដោយលំបាក ម្នាលក្អែក អ្នកឯងមិនត្រេកអរដោយផ្លែឈើទាំងឡាយ មួយទៀត សាច់ទាំងឡាយណាដែលមាននៅក្នុងកណ្តាលនៃព្រៃស្មសាន អ្នកមិនត្រេកអរនិងសាច់នោះឡើយ ។

[ ៥៧៩ ] ម្នាលក្អែក បុគ្គលណាជាអ្នកលបចក់ក្នុងខណៈ ( ដែល

គេធ្វេសប្រហែស ) បានទូវភោគៈទាំងឡាយ ដោយអំពើដ៏អាក្រក់ហើយបរិភោគ ដល់មកខាងក្រោយ អ្នកផងទាំងតិះដៀលបុគ្គលនោះ បុគ្គលដែលត្រូវគេតិះដៀលនោះ រមែងសាបសូន្យចាកសម្បុរ និងកម្លាំង ។

[ ៥៨០ ] បុគ្គលបើទុកជាបរិភោគរបស់ត្រជាក់ ( ឥតទោស ) សូម្បីតិចតួច តែជាអ្នកមិនបៀតបៀនជនដទៃ ដោយអំពើអាក្រក់ កម្លាំង និងសម្បុរ រមែងកើតមានដល់បុគ្គលនោះ ព្រោះថាសម្បុរទាំងអស់ មិនមែនសុទ្ធតែសម្រេចមកអំពីអាហារទេ ។

## ចក្កវាកជាតកទី ៨ ចប់

# អដ្ឋកថា

## ចក្កវាកជាតក

[ ៥៧២-៥៨០ ] ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុលោភលន់មួយរូប ទើបត្រាស់រឿងនេះ មានពាក្យផ្ដើមថា **កាសាយវត្ថេ** ដូច្នេះជាដើម ។

បានឮថា ភិក្ខុនោះ ជាអ្នកឡេះឡោះ ល្មោភក្នុងបច្ច័យ លះបង់អាចរិយវត្ត និងឧបជ្ឈាយវត្តជាដើម ចូលនគរសាវត្ថីអំពីព្រលឹម ឆាន់បបរ ដែលមានរបស់ទំពាច្រើនយ៉ាងជាបរិវារ ហើយឆាន់នូវបាយស្រូវសាលី សាច់ដែលមានរសប្រសើរផ្សេងៗ ត្រង់ផ្ទះនាងវិសាខាប៉ុណ្ណោះ ក៏មិនទាន់ស្កប់ស្កល់ ចេញអំពីទីនោះ ទៅកាន់និវេសន៍របស់ជននោះៗ មានចូឡអនាថបិណ្ឌិកសេដ្ឋី មហាអនាថបិណ្ឌិកសេដ្ឋី និងព្រះបាទកោសលជាដើម ។

ថ្ងៃមួយ ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងធម្មសភា ប្រារព្ធការលោភលន់របស់ភិក្ខុនោះ ព្រះសាស្ដាយាងមក ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយអង្គុយសន្ទនាគ្នាដោយរឿងអ្វី ភិក្ខុទាំងឡាយទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើបត្រាស់ឲ្យហៅភិក្ខុនោះមក សួរថា ម្នាលភិក្ខុ បានឮថា អ្នកឡេះឡោះពិតឬ ភិក្ខុនោះទូលថា ករុណា ពិតហើយព្រះអង្គ ដូច្នេះ ។ ព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុ ហេតុអ្វី ក៏អ្នកជាបុគ្គលឡេះឡោះ ក្នុងកាលមុន អ្នកមិនឆ្អែតដោយសាកសពដំរីជាដើម ក្នុងនគរពារាណសី ព្រោះភាពជាអ្នកឡេះឡោះ ចេញអំពីទីនោះហើយ ត្រាច់ទៅតាមច្រាំងស្ទឹងគង្គា ចូលទៅកាន់ហិមវន្តប្បទេស ដូច្នេះហើយ ទ្រង់នាំយករឿង

ក្នុងអតីតមកសាធក:ដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិក្នុងនគរពារាណសី មានក្អែកឡេះឡោះមួយក្បាល ត្រាច់ស៊ីសាកសពដំរីជាដើមក្នុងនគរពារាណសី មិនឆ្អែតដោយសាកសពទាំងនោះ គិតថា អញនឹងទំពាស៊ីត្រីត្រង់ច្រាំងស្ទឹងគង្គា ទៅរកស៊ីត្រីងាប់ត្រង់ច្រាំងស្ទឹងគង្គា ២-៣ ថ្ងៃ ក៏ចូលទៅកាន់ព្រៃហិមពាន្ត ទំពាស៊ីផ្លែឈើតូចធំច្រើនប្រភេទ ទៅកាន់ស្រះឈូកធំ ដែលមានត្រី និងអណ្តើកច្រើន ឃើញសត្វចាក្រពាកមួយគូ មានពណ៌ដូចមាស កំពុងទំពាស៊ីសារាយក្នុងស្រះនោះ គិតថា ចាក្រពាកពីរនេះ មានពណ៌ល្អពន់ពេកបក្សីនេះ គង់មានភោជនីយាហារជាទីគាប់ចិត្ត អញនឹងសួរដល់ភោជនាហាររបស់បក្សីទាំងនេះ ហើយនឹងទំពាស៊ីដូច្នោះដែរ អញនឹងមានពណ៌ដូចមាស ហើយចូលទៅកាន់សម្នាក់របស់បក្សីទាំងនោះ ធ្វើបដិសណ្ឋារៈ ហើយទំត្រង់មែកឈើមួយកន្ទែង ពោលគាថាដំបូងដោយការសរសើរបក្សីទាំងនោះថា

ខ្ញុំសូមសួរនូវពួក សត្វបក្សីមានសម្បុរដូចសំពត់ ដែលជ្រលក់ដោយទឹកអម្ចត់ ជាសត្វមានចិត្តរីករាយ ត្រាច់ទៅទាំងគូៗ ចុះក្នុងពួកកំណើតជាអណ្ឌជ: និងមនុស្សទាំងឡាយ តើគេសរសើរនូវកំណើតអណ្ឌជ:ណា អ្នកចូរពោលនូវហេតុនោះមកមើលដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កាសាយវត្ថេ** បានដល់ មានពណ៌ដូចមាស ដូចដណ្តប់ដោយសំពត់ជ្រលក់ដោយទឹកអម្ចត់ ។ បទថា **ធុវេ ធុវេ**

បានដល់ ទាំង ២ ។ បទថា **ឆន្ទមេនេ** បានដល់ មានចិត្តត្រេកអរ ។ បទថា **កំ អណ្ឌជំ អណ្ឌជា មានុសេសុ ជាតឹ បសំសន្តិ** សេចក្តីថា អ្នកដ៏ចម្រើនទាំងឡាយ បក្សីទាំងឡាយ កាលសរសើរពួកអ្នក រមែងពោលសរសើរក្នុងពួកមនុស្សទាំងឡាយថា បក្សីមួយណា គឺបក្សីឈ្មោះអ្វី អធិប្បាយថា បក្សីទាំងឡាយ រមែងសរសើរអ្នកទាំងឡាយ ក្នុងរវាងមនុស្សទាំងឡាយប្រារព្ធថាឈ្មោះបក្សីអ្វី ។ បាលីថា **កំ អណ្ឌជំ អណ្ឌជមានុសេសុ** ដូច្នេះក៏មាន បាលីនោះ មានអធិប្បាយថា បក្សីទាំងឡាយ ពោលសរសើរពួកអ្នកក្នុងពួកបក្សីទាំងឡាយ និងក្នុងពួកមនុស្សទាំងឡាយថា បក្សីប្រភេទណា ។ សត្វចាក្រពាកបានស្តាប់ដូច្នោះ ក៏ពោលគាថាទី ២ ថា

*ម្នាលក្អែក ជាសត្វបៀតបៀនមនុស្ស ពួកគេតែងពោលសរសើរយើង ជាចាក្រពាកថា ជាសត្វប្រព្រឹត្តសមគួរ ក្នុងចំណោមនៃមនុស្សទាំងឡាយ ទាំងគេបានសន្មតយើងថា ជាសត្វមានភាពល្អក្នុងចំណោមនៃសត្វស្លាបទាំងឡាយ ( ពួកយើង មានសភាពជាសត្វឥតភ័យ ត្រាច់ទៅផ្សេងៗ ក្នុងស្រះឈូក ) ពួកយើងមិនធ្វើបាប ព្រោះហេតុតែចំណីឡើយ ដូច្នេះ ។*

បណ្តាបទទាំងនោះ បទថា **មនុស្សហឹស** សេចក្តីថា ក្អែកបៀតបៀនគឺរុកកួនមនុស្សទាំងឡាយ ព្រោះហេតុនោះ ទើបចាក្រពាកពោលនឹងក្អែកនោះយ៉ាងនេះ ។ បទថា **អនុព្វតេ** សេចក្តីថា ទៅតាម គឺត្រេកអរ បានដល់ដោយសេចក្តីស្រឡាញ់នូវគ្នានិងគ្នា ។ បទថា **ចក្កវាកេ** សេចក្តីថា បក្សី

ទាំងឡាយរមែងសរសើរ គឺលើកតម្កើង បានដល់ ពោលសរសើរថា ជាតិបក្សីនោះ ឈ្មោះថា ចាក្រពាក ។ បទថា **ធិជេសុ** សេចក្តីថា ឈ្មោះថាបក្សីទាំងឡាយមានប្រមាណប៉ុនណា បណ្តាបក្សីទាំងឡាយ មានប្រមាណប៉ុណ្ណោះ គេដឹងទូទៅក្នុងមនុស្សថា ពួកខ្ញុំជាអ្នកមានភាវៈគួររាប់អាន ។ គប្បីជ្រាបវិនិច្ឆ័យ ក្នុងអត្ថវិកប្បទី ២ ថា ក្នុងពួកមនុស្ស បក្សីទាំងឡាយ រមែងពោលដល់យើងទាំងឡាយថា ចាក្រពាក តែក្នុងពួកបក្សីដូចគ្នា បក្សីទាំងឡាយរមែងពោលដល់ពួកខ្ញុំថា យើងខ្ញុំទាំងឡាយ ជាអ្នកមានភាវៈគួររាប់អាន ។ បទថា **អណ្ណវេ** សេចក្តីថា ក្នុងទីនេះ ចាក្រពាកហៅស្រះថា អន្លង់ទឹក អធិប្បាយថា ពួកខ្ញុំទាំងពីរប៉ុណ្ណោះ ឈ្មោះថា ជាអ្នកមានរូបស្អាត ព្រោះមិនបៀតបៀនសត្វដទៃ ត្រាច់ទៅក្នុងទីជិតស្រះឈូកនេះ ។

ឯបទទី ៤ នៃគាថានេះ អាចារ្យពួកខ្លះពោលថា **ន ឃាសហេតុ** ដូច្នេះ ពាក្យនេះមានអធិប្បាយថា ព្រោះពួកខ្ញុំមិនធ្វើបាប ព្រោះហេតុត្រឹមតែស៊ី ព្រោះដូច្នោះ ទើបពួកជនទាំងនោះលើកតម្កើងពួកខ្ញុំ ទាំងក្នុងពួកមនុស្ស និងក្នុងពួកបក្សីថា ជាអ្នកមានភាវៈគួររាប់អាន ។

ក្អែកបានឮដូច្នោះ ក៏បានពោលគាថាទី ៣ ថា

ម្នាលចាក្រពាកទាំងឡាយ ជាអ្នកមិនថោកទាប អ្នកទាំងឡាយ
បរិភោគផ្លែឈើអ្វី ទំពាស៊ីសាច់អ្វី បរិភោគភោជនអ្វី ក្នុងស្រះ
បានជាកម្លាំង និងសម្បុរមានសភាពមិនតិច ដូច្នេះ ។

សព្ទថា **កឹ** ក្នុងគាថានោះ ជាអាលបនៈ ដោយអំណាចនៃពាក្យសួរ

អធិប្បាយថា នែចាក្រពាក អ្នកទាំងឡាយបរិភោគភោជនាហារអ្វី ។ បទថា **អណ្ណវេ** បានដល់ ក្នុងស្រះនេះ ។ បទថា **ភុញ្ជេ** ស្មើគ្នានឹង **ភុញ្ជថ** ប្រែថា ស៊ី ម្យ៉ាងទៀត ស្មើគ្នានឹង **ភុញ្ជិត្ថ** ប្រែថា ស៊ីហើយ ។ បទថា **មំសំ កុតោ ខាទថ** បានដល់ អ្នកទាំងឡាយស៊ីសាច់របស់សត្វប្រភេទណា ។

**វោ** សព្ទ ក្នុងពាក្យថា **ភុញ្ជថ វោ** ត្រឹមតែជានិបាត ។ សព្ទថា **វោ** នោះ សម្ពន្ធចូលជាមួយបទខាងមុខថា **ពលញ្ច វោ វណ្ណោ ច អនប្បរូបោ** ដូច្នេះ បន្ទាប់ពីនោះ សត្វចាក្រពាកពោលគាថាទី ៤ ថា

ម្នាលក្អែក ផ្លែឈើទាំងឡាយ មិនមានក្នុងស្រះទេ ពួកចាក្រពាក

បានសាច់បរិភោគអំពីណា ពួកយើង ជាអ្នកបរិភោគសារាយ

បរិភោគតែទឹកមិនល្អក់ ( ពួកយើង មិនធ្វើបាប ព្រោះហេតុតែ

ចំណីឡើយ ) ពួកយើងមានសភាពជាអ្នកឥតភ័យ ត្រាច់ទៅ

ផ្សេងៗ ក្នុងស្រះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ចក្កវាកេ** ស្មើគ្នានឹង **ចក្កវាកស្ស** ។ បទថា **អចាណភោជនា** បានដល់ ផឹកទឹកដែលប្រាសចាកភាពខុសប្រក្រតី ( ទឹកដែលមិនមានសត្វល្អិត ) សត្វចាក្រពាកសម្ដែងថា ពួកយើងមានសារាយនិងទឹកប៉ុណ្ណោះជាអាហារ ។ បទថា **ឩ ឃាសហេតុ** សេចក្ដីថា ពួកយើងមិនធ្វើបាប ព្រោះតែរឿងបរិភោគ ដូចពួកអ្នកឡើយ ។ បន្ទាប់អំពីនោះ ក្អែកពោល ២ គាថាថា

ម្នាលចាក្រពាក ភោជននេះ មិនគាប់ចិត្តយើងទេ ខ្លួនអ្នកមាន

សភាពប្រហែលនឹងភោជនក្នុងលំនៅនេះ កាលដើម ខ្ញុំមានសេចក្តីត្រិះរិះ ( យ៉ាងនេះ ) ខាងក្រោយមក ខ្ញុំមានសេចក្តីត្រិះរិះផ្សេង សេចក្តីសង្ស័យរបស់ខ្ញុំ ក៏កើតមានក្នុងហេតុនុ៎ះ ដោយប្រការដូច្នេះឯង ។

ឯខ្លួនយើង តែងបានបរិភោគសាច់ និងផ្លែឈើទាំងឡាយផង នូវចំណីអាហារដែលលាយអំបិល និងប្រេងទាំងឡាយផង ខ្លួនយើង តែងបានបរិភោគនូវសេក្នុងពួកមនុស្ស ដូចបុគ្គលក្លៀវក្លា បានឈ្នះនូវប្រធាននៃសង្គ្រាម ម្នាលចាក្រពាក ឯសម្បុររបស់ខ្ញុំ មិនដូចជាសម្បុរបស់អ្នកទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឥធំ** សេចក្តីថា អាហារដែលអ្នកបរិភោគខ្ញុំមិនចូលចិត្ត ។ បទថា **អស្មិំ ភវេ ភោជនសន្និកាសោ** សេចក្តីថា ជាអ្នកដូចគ្នានឹងអាហារនោះ គឺអាហារណា ដែលអ្នកបរិភោគក្នុងកពដែលជាសត្វចាក្រពាកនេះ អ្នកក៏ជាបុគ្គលដូចគ្នានឹងអាហារនោះ គឺជាបុគ្គលដូចគ្នានឹងអាហារនោះ បានដល់ ជាអ្នកដូចគ្នានឹងអាហារនោះ អធិប្បាយថា អ្នកជាបុគ្គលមានសរីរកាយបរិបូណ៌យ៉ាងក្រៃលែង ។

បទថា **តតោ មេ អញ្ញថា** សេចក្តីថា កាលមុន ការយល់ដូច្នេះមានដល់ខ្ញុំ ព្រោះឃើញពួកអ្នក ខ្ញុំគិតថា សត្វចាក្រពាកទាំងនេះ ទំពាស៊ីផ្លែឈើគ្រប់ប្រភេទ និងទំពាស៊ីត្រី និងសាច់ក្នុងស្រះនេះ ព្រោះហេតុនោះ ទើបមានរូបរាងស្អាតក្រៃលែងយ៉ាងនេះ តែឥឡូវនេះ បែរជាដទៃទៅវិញ ។

បទថា **តេនេវ** មេ សេចក្ដីថា ដោយហេតុនេះឯង ទើបយើងកើតសេចក្ដីសង្ស័យ ក្នុងពណ៌សម្បុរកាយរបស់អ្នកថា ហេតុអ្វីហ្ន៎ សត្វចាក្រពាកទាំងនេះ ស៊ីអាហារដែលសៅហ្មងបែបនេះ បែរជាមានពណ៌ដូចមាស ។ បទថា **អហាម្បិ** កែជា **អហំ ហិ** ម្យ៉ាងទៀត បាលីក៏យ៉ាងនេះដូចគ្នា ។ បទថា **ភញ្ជេ** ស្មើគ្នានឹង **ភុញ្ជាមិ** គឺបរិភោគ ។ បទថា **អន្នានិ** ច បានដល់ភោជនទាំងឡាយ ។ បទថា **លោណិយតេលិយានិ** បានដល់ ដែលផ្សំដោយអំបិល លាយដោយប្រេង ។ បទថា **រសំ** គឺមានរសប្រណីត ដែលមនុស្សបរិភោគក្នុងពួកមនុស្ស ។ បទថា **វិជេត្វា** បានដល់ អ្នកចម្បាំងដែលក្លាហានឈ្នះសង្គ្រាមហើយ ក៏មកចោមរោមបរិភោគអាហារទាំងនោះ យ៉ាងណា ខ្ញុំក៏មកចោមរោមបរិភោគអាហារដូច្នោះដូចគ្នា ។

ដោយពាក្យថា **យថា តវ** នេះ ក្អែកចង់លបង្ហាញថា ពណ៌របស់យើងសូម្បីបរិភោគអាហារប្រណីតយ៉ាងនេះ ក៏មិនបានដូចពួកអ្នកឡើយ ទើបយើងមិនជឿពាក្យរបស់អ្នក ។

លំដាប់នោះ សត្វចាក្រពាកកាលពោលដល់ហេតុ ដែលមិនចម្រើននៃវណ្ណសម្បត្តិរបស់ក្អែក និងហេតុដែលចម្រើននៃវណ្ណសម្បត្តិរបស់ខ្លួន បានពោលគាថាដ៏សេសថា

អ្នកជាសត្វមានអាហារមិនស្អាត តែងលបចក់ក្នុងខណៈ ( ដែលគេធ្វេសប្រហែស ) អ្នកឯងតែងបាននូវចំណីអាហារ និងទឹកផឹកដោយលំបាក ម្នាលក្អែក អ្នកឯងមិនត្រេកអរ ដោយផ្លែឈើ

ទាំងឡាយ មួយទៀត សាច់ទាំងឡាយណា ដែលមាននៅក្នុង
កណ្តាលនៃព្រៃស្មសាន អ្នកមិនត្រេកអរនឹងសាច់នោះឡើយ ។
ម្នាលក្អែក បុគ្គលណា ជាអ្នកលបធក់ក្នុងខណៈ ( ដែលគេ
ធ្វេសប្រហែស ) បាននូវភោគៈទាំងឡាយ ដោយអំពើដ៏អាក្រក់
ហើយបរិភោគ ដល់មកខាងក្រោយ អ្នកផងនឹងតិះដៀលបុគ្គល
នោះ បុគ្គលដែលត្រូវគេតិះដៀលនោះ រមែងសាបសូន្យចាក
សម្បុរ និងកម្លាំង ។

បុគ្គល បើទុកជាបរិភោគរបស់ត្រជាក់ ( ឥតទោស ) សូម្បីតិច
តួច តែជាអ្នកមិនបៀតបៀនជនដទៃ ដោយអំពើអាក្រក់ កម្លាំង
និងសម្បុរ រមែងកើតមានដល់បុគ្គលនោះ ព្រោះថា សម្បុរទាំង
អស់ មិនមែនសុទ្ធតែសម្រេចមកអំពីអាហារទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អសុទ្ធភក្ខោសិ** សេចក្តីថា អ្នកឈ្មោះថា ជាអ្នកបរិភោគអាហារមិនបរិសុទ្ធ ព្រោះលួចគេបរិភោគ ។ បទថា **ខណា-នុបាតី** បានដល់ ធក់ក្នុងខណៈដែលគេប្រហែស ។ បទថា **កិច្ឆេន តេ** សេចក្តីថា អ្នកបានបរិភោគបាយ និងទឹកដោយលំបាក ។ បទថា **មំសានិ វា** សេចក្តីថា ឬសាច់ពួកណាដែលមានកណ្តាលព្រៃខ្មោច សាច់ទាំងនោះ អ្នកក៏មិនត្រេកអរ ។ បទថា **តតោ** ស្មើគ្នានឹង **បច្ឆា** ប្រែថា ខាងក្រោយ ។ បទថា **ឧបក្កោសតិ ឆំ សភាវោ** បានដល់ ខ្លួននោះឯង រមែងតិះដៀលបុគ្គលនោះ ។ បទថា **ឧបក្កុដ្ឋោ** សេចក្តីថា បុគ្គលនោះ ត្រូវខ្លួនឯងខ្លះ អ្នក

ដទៃខ្វះ តិះដៀលហើយ គឺតិះដៀលហើយ រមែងលះនូវពណ៌សម្បុរ និងកម្លាំង ព្រោះជាអ្នកមានការក្តៅក្រហាយ ។ បទថា **ឆិត្វាន កុញ្ជតិ យទិ** សេចក្តីថា បើបុគ្គលណាបរិភោគអាហារសូម្បីតិចតួច ដែលបានមកដោយធម៌ ឈ្មោះថា ជារបស់ត្រជាក់ មិនបៀតបៀនអ្នកដទៃ ។ បទថា **តទស្ស ហោតិ** សេចក្តីថា ក្នុងកាលនោះ កម្លាំងកាយ និងពណ៌សម្បុរក្នុងសរីរៈ រមែងមានដល់បុគ្គលនោះ ដែលជាបណ្ឌិត ។ បទថា **អាហារមយេន** បានដល់ដោយអាហារមានប្រការផ្សេងៗ ប៉ុណ្ណោះ មានអធិប្បាយថា នៃក្អែក ឈ្មោះថា ពណ៌សម្បុរនោះ មានសមុដ្ឋាន ៤ ប្រការ មិនមែនព្រោះអាហារតែម្យ៉ាង ពណ៌សម្បុរនោះ រមែងមានដោយឧតុ ចិត្ត និងកម្ម ( ផងដែរ ) ។

សត្វចាក្រពាកតិះដៀលក្អែកដោយបរិយាយមិនមែនតិចយ៉ាងនេះ ក្អែកកើតនូវការស្អប់សត្វចាក្រពាក គិតថា អញមិនត្រូវការពណ៌សម្បុររបស់ឯងទេ ហើយក៏ស្រែកឡើងថា ខ្វក ខ្វក ហើយហើរទៅ ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ កាលចប់សច្ចៈ ភិក្ខុឡេះឡោះតាំងនៅក្នុងអនាគាមិផល ទ្រង់សមោធានជាតកថា ក្អែកក្នុងកាលនោះ បានមកជាភិក្ខុឡេះឡោះក្នុងកាលឥឡូវនេះ ចាក្រពាកញី ក្នុងកាលនោះ បានមកជារាហុលមាតា ឯចាក្រពាកឈ្មោលក្នុងកាលនោះ គឺតថាគតនេះឯង ៕

**អដ្ឋកថា ចក្កវាកជាតក ចប់**

# សុត្តន្តបិដក

## ហលិទ្ទភាគជាតក

[ ៥៨១ ] ( នាងកុមារិកានិយាយនឹងតាបសកុមារថា ) ការដែលលោកអត់ទ្រាំក្នុងព្រៃ ជាសេចក្តីសុខៈដ៏ស្ងាត់ ជាការប្រពៃហើយ តែថា ពួកជនណា អត់ទ្រាំនៅក្នុងស្រុក ពួកជននោះឈ្មោះថា ប្រសើរលើសលុបជាងលោកទៅទៀត ។

[ ៥៨២ ] ( តាបសកុមារ សួរតាបសពោធិសត្វជាបិតាថា ) បពិត្របិតា លុះដល់ខ្ញុំចេញអំពីព្រៃមកកាន់ស្រុក តើគួរសេពគប់បុរសមានសីលដូចម្តេច មានវត្តដូចម្តេច ខ្ញុំសួរហើយ សូមបិតាប្រាប់ហេតុនោះ ។

[ ៥៨៣ ] ( តាបសពោធិសត្វ ... ) នែបា បើបុគ្គលណាស្និទ្ធស្នាលនឹងអ្នក ថែមទាំងគាប់ចិត្តនឹងសេចក្តីស្និទ្ធស្នាលរបស់អ្នក ហើយស្តាប់បង្គាប់ និងអត់ទ្រាំ ( នូវពាក្យសម្តី ) អ្នកចេញអំពីព្រៃនេះទៅ ចូរសេពគប់បុគ្គលនោះចុះ ។

[ ៥៨៤ ] បុគ្គលណា មិនមានអំពើអាក្រក់ ដោយកាយវាចាចិត្ត អ្នកចេញអំពីព្រៃនេះទៅ ចូរតាំងខ្លួនដូចជាកូន ហើយសេពគប់បុគ្គលនោះចុះ ។

[ ៥៨៥ ] មួយទៀត បុគ្គលណា ប្រព្រឹត្តតាមធម៌ ទោះបីកំពុងប្រព្រឹត្ត ក៏មិនប្រកាន់ខ្លួន លុះដល់អ្នកចេញអំពីព្រៃនេះទៅ ចូរ

សេពគប់នូវបុគ្គលដែលជាអ្នកធ្វើអំពើដ៏បរិសុទ្ធ ប្រកបដោយប្រាជ្ញា នោះចុះ ។

[ ៥៨៦ ] នែបា បុគ្គលណា មានចិត្តដូចជាសំពត់ជ្រលក់រមៀត មានចិត្តដូចស្វា ត្រេកអរហើយ បែរជាមិនត្រេកអរវិញ បើទុកជា ( ក្នុងជម្ពូទ្វីបនេះ ) មិនមានមនុស្សសោះ អ្នកកុំគប់រកបុរសបែបនោះឡើយ ។

[ ៥៨៧ ] អ្នកចូរចៀសវាង ( បុគ្គលបែបនោះ ) អំពីចម្ងាយឲ្យដូចបុគ្គលចៀសវាងអាសីពិសដែលក្រោធ ឬចៀសវាងផ្លូវធំដែលប្រឡាក់ដោយលាមក ឬដូចបុគ្គលទៅដោយយាន ចៀសវាងផ្លូវមិនស្មើ ។

[ ៥៨៨ ] នែបា អំពើមិនជាប្រយោជន៍ទាំងឡាយ តែងចម្រើនដល់បុគ្គល ដែលគប់រកបុគ្គលពាល អ្នកកុំគប់រកបុគ្គលពាលដែលដូចជាសត្រូវ សព្វៗ កាលឡើយ ។

[ ៥៨៩ ] នែបា ព្រោះហេតុនោះហើយ បានជាយើងសូមអង្វរអ្នក ចូរអ្នកធ្វើតាមពាក្យយើង ចូរអ្នកកុំគប់រកបុគ្គលពាលឡើយ ( ព្រោះ ) ការគប់រកនូវបុគ្គលពាលទាំងឡាយ តែងនាំមកនូវសេចក្តីទុក្ខ ។

ហលិទ្ទរាគជាតកទី ៩ ចប់

# អដ្ឋកថា

## ហារិទ្ធកាគជាតក

[ ៥៨១-៥៨៩ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការលួងលោមរបស់ថុល្លកុមារី ទើបត្រាស់រឿងនេះ មានពាក្យផ្តើមថា **សុតីតិក្ខំ** ដូច្នេះជាដើម ។ រឿងដែលជាបច្ចុប្បន្ន មានច្បាស់ក្នុងចូឡនារទ-ជាតក ក្នុងតេរសកនិបាត ។

ឯរឿងដែលជាអតីត មានដូច្នេះ កុមារិកានោះ ទម្លាយសីលរបស់តាបសកំលោះនោះហើយ ដឹងថា តាបសធ្លាក់នៅក្នុងអំណាចរបស់ខ្លួន គិតថា អញនឹងបញ្ឆោតតាបសកំលោះនេះ នាំទៅកាន់ដែនដីមនុស្ស គិតដូច្នេះហើយ ពោលថា ឈ្មោះថា សីល ដែលរក្សាក្នុងព្រៃ ដែលវៀរចាកកាម-គុណ មានរូបជាដើម រមែងមានផលធំមិនបាន សីលដែលរក្សាក្នុងដែនដីមនុស្ស ដែលជាទីតាំងនៃកាមគុណ មានរូបជាដើម រមែងមានផលធំ មកលោក យើងទៅរក្សាសីលក្នុងដែនដីមនុស្ស ព្រៃនឹងបានជាប្រយោជន៍អ្វីដល់លោក ដូច្នេះហើយ ពោលគាថាទី ១ ថា

ការដែលលោកអត់ទ្រាំក្នុងព្រៃ ជាសេនាសនៈដ៏ស្ងាត់ ជាការ
ប្រពៃហើយ តែថា ពួកជនណា អត់ទ្រាំនៅក្នុងស្រុក ពួកជន
នោះ ឈ្មោះថា ប្រសើរលើសលុបជាងលោកទៅទៀត ដូច្នេះ ។

ការអត់ធន់ដោយល្អ ឈ្មោះថា **សុតីតិក្ខំ** ក្នុងគាថានោះ ។ បទថា **តិតិក្ខន្តិ** គឺអត់ធន់ក្នុងភ័យធម្មជាតិទាំងឡាយ មានត្រជាក់ជាដើម ។ តាបសកំលោះបានស្តាប់ដូច្នោះហើយ ពោលថា ឪពុករបស់យើងទៅព្រៃ កាលលោក

មកហើយ យើងនឹងលាលោកជាមុនហើយ សឹមទៅ ។

កុមារិកាគិតថា បានឮថា តាបសកំលោះនេះមានបិតា បើលោកឃើញអញ នឹងវាយអញឲ្យដល់នូវសេចក្តីវិនាស ដោយដងរែក អញគួរទៅមុនចុះ ។ ហើយក៏ពោលនឹងតាបសកំលោះថា បើដូច្នោះ ខ្ញុំធ្វើគ្រឿងចំណាំតាមផ្លូវ ហើយទៅមុន សូមលោកមកតាមក្រោយ ។ តាបសកំលោះ កាលកុមារិកាទៅហើយ ក៏មិនបានរកឧស មិនបានដងទឹកប្រើ ទឹកឆាន់ អង្គុយសញ្ជប់សញ្ជឹងតែម្យ៉ាងប៉ុណ្ណោះ លុះបិតាមក ក៏មិនបានចេញទៅទទួល គ្រានោះ បិតាដឹងថា កូនរបស់អញនេះធ្លាក់ក្នុងអំណាចរបស់ស្រីហើយ ទើបសួរតាបសកំលោះនោះថា នែបា ហេតុអ្វី ទើបបាមិនរកឧស មិនដងទឹកប្រើ ទឹកឆាន់ បានតែអង្គុយស្ងប់សៅតែម្យ៉ាងប៉ុណ្ណោះ តាបសកំលោះសួរថា បពិត្រលោកឪពុក បានឮថា សីលដែលរក្សាក្នុងព្រៃ មិនមានផលច្រើន សីលដែលរក្សាក្នុងស្រុក មានផលច្រើនជាង ខ្ញុំនឹងទៅរក្សាសីលក្នុងដែនដីមនុស្ស សម្លាញ់របស់ខ្ញុំប្រាប់ថា សូមមកតាមក្រោយ ហើយគេទៅមុន ខ្ញុំនឹងទៅជាមួយសម្លាញ់ កាលខ្ញុំនៅក្នុងដែនដីមនុស្សហើយ គួរសេពគប់បុគ្គលដូចម្តេច ទើបពោលគាថាទី ២ ថា

បពិត្របិតា លុះដល់ខ្ញុំចេញអំពីព្រៃមកកាន់ស្រុក តើគួរសេព
គប់បុរសមានសីលដូចម្តេច មានវត្តដូចម្តេច ខ្ញុំសួរហើយ សូម
បិតាប្រាប់ហេតុនោះ ដូច្នេះ ។

លំដាប់នោះ តាបសជាបិតាកាលនឹងប្រាប់តាបសកំលោះ ទើបពោល

គាថាដ៏សេសថា

នៃបា បើបុគ្គលណាស្និទ្ធស្នាលនឹងអ្នក ថែមទាំងគាប់ចិត្តនឹងសេចក្តីស្និទ្ធស្នាលរបស់អ្នក ហើយស្តាប់បង្គាប់ និងអត់ទ្រាំ ( នូវពាក្យសម្តី ) អ្នកចេញអំពីព្រៃនេះទៅ ចូរសេពគប់បុគ្គលនោះចុះ ។

បុគ្គលណា មិនមានអំពើអាក្រក់ ដោយកាយវាចាចិត្ត អ្នកចេញអំពីព្រៃនេះទៅ ចូរតាំងខ្លួនដូចជាកូន ហើយសេពគប់បុគ្គលនោះចុះ ។

មួយទៀត បុគ្គលណា ប្រព្រឹត្តតាមធម៌ ទោះបីកំពុងប្រព្រឹត្ត ក៏មិនប្រកាន់ខ្លួន លុះដល់អ្នកចេញអំពីព្រៃនេះទៅ ចូរសេពគប់នូវបុគ្គលដែលជាអ្នកធ្វើអំពើដ៏បរិសុទ្ធ ប្រកបដោយប្រាជ្ញានោះចុះ ។

នៃបា បុគ្គលណា មានចិត្តដូចជាសំពត់ជ្រលក់រមៀត មានចិត្តដូចស្វា ត្រេកអរហើយ បែរជាមិនត្រេកអរវិញ បើទុកជា ( ក្នុងជម្ពូទ្វីបនេះ ) មិនមានមនុស្សសោះ អ្នកកុំគប់រកបុរសបែបនោះឡើយ ។

អ្នកចូរចៀសវាង ( បុគ្គលបែបនោះ ) អំពីចម្ងាយ ឲ្យដូចបុគ្គលចៀសវាងអាសិរពិសដែលក្រោធ ឬចៀសវាងផ្លូវធំ ដែលប្រឡាក់ដោយលាមក ឬដូចបុគ្គលទៅដោយយាន ចៀសវាងផ្លូវមិនស្មើ ។

នែបា អំពើមិនជាប្រយោជន៍ទាំងឡាយ តែងចម្រើនដល់បុគ្គល ដែលគប់រកបុគ្គលពាល អ្នកកុំគប់រកបុគ្គលពាល ដែលដូចជាសត្រូវ សព្វៗ កាលឡើយ ។

នែបា ព្រោះហេតុនោះហើយ បានជាយើងសូមអង្វរអ្នក ចូរអ្នកធ្វើតាមពាក្យយើង ចូរអ្នកកុំគប់រកបុគ្គលពាលឡើយ ( ព្រោះ ) ការគប់រកនូវបុគ្គលពាលទាំងឡាយ តែងនាំមកនូវសេចក្តីទុក្ខដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យោ តេ វិស្សាសយេ** ស្មើគ្នានឹង **យោ តវ វិស្សាសេយ្យ** ប្រែថា បុគ្គលណាគប្បីស្និទ្ធស្នាលនឹងអ្នក ។ បទថា **ខមេយ្យ តេ** សេចក្តីថា បុគ្គលណាគប្បីអត់ធន់ចំពោះសេចក្តីស្និទ្ធស្នាលដែលអ្នកធ្វើហើយក្នុងខ្លួន ។ បទថា **សុស្សូសី ច តិតិក្ខី ច** សេចក្តីថា បុគ្គលណា គប្បីជាអ្នកប្រកបដោយការស្តាប់ដោយល្អនូវវាចារបស់អ្នក និងអត់ធន់ចំពោះពាក្យសម្តីរបស់អ្នក ។ បទថា **ឱរសីវ បតិដ្ឋាយ** តាបសជាឪពុកពោលថា អ្នកគប្បីតាំងខ្លួន គប្បីតម្កល់ខ្លួន ដូចបុត្រកើតអំពីទ្រូងរបស់មាតា ដូច្នោះហើយ ដឹងថា ដូចមាតារបស់ខ្លួន គប្បីសេពគប់បុគ្គលនោះ ។ បទថា **យោ ច ធម្មេន ចរតិ** សេចក្តីថា បុគ្គលណាប្រព្រឹត្តសុចរិតធម៌ ៣ នោះឯង ។ បទថា **ន មញ្ញតិ** សេចក្តីថា កាលប្រព្រឹត្តយ៉ាងនោះ ក៏មិនប្រកាន់ខ្លួនថា អញប្រព្រឹត្តធម៌ ។ បទថា **វិសុទ្ធការី** បានដល់ជាអ្នកធ្វើកម្មបថ ១០ ប្រការដ៏បរិសុទ្ធ ។ បទថា **ភាគវិភាគិតំ** បានដល់

ស្រឡាញ់ឆាយ និងនឿយណាយរហ័ស គឺមានការស្រឡាញ់ហើយ នឿយណាយក្នុងខណៈនោះជាសភាវៈ ។ បទថា **និម្មនុស្សម្បិ ចេ សិយា** សេចក្ដីថា បើផ្ទៃជម្ពូទ្វីបមិនមានមនុស្សសោត មានតែបុគ្គលនោះតែម្នាក់ ទោះជាដូច្នោះ ក៏កុំគប់រកបុគ្គលនោះ ។ បទថា **មហាបថំ** បានដល់ ដូចបុគ្គលដែលវៀរផ្លូវប្រឡាក់ដោយលាមក ដូច្នោះ ។ បទថា **យានីវ** បានដល់ ដូចបុគ្គលដែលទៅដោយយាន ។ បទថា **វិសមំ** បានដល់ មិនរាបស្មើ ដូចជារណ្ដៅ ទីទួល ទីមានជង្គត់ និងថ្មជាដើម ។ បទថា **ពាលំ អច្ចុបសេវតោ** បានដល់ បុគ្គលគប់រកបុគ្គលពាល គឺបុគ្គលមិនមានបញ្ញា ។ បទថា **សព្ទទា** សេចក្ដីថា នៃបា ឈ្មោះថា ការនៅរួមជាមួយបុគ្គលពាលជាទុក្ខសព្វកាល គឺអស់កាលជានិច្ច ដូចនៅរួមជាមួយសត្រូវ ដូច្នោះ ។ បទថា **តំ តាហំ** សេចក្ដីថា ព្រោះហេតុនោះ ទើបឪពុកសំណូមពរឯង ។

តាបសកំលោះបានស្ដាប់ពាក្យទូន្មានរបស់បិតាយ៉ាងនេះហើយ ពោលថា បពិត្រលោកឪពុក ខ្ញុំទៅកាន់ដែនដីមនុស្ស នឹងមិនបានបណ្ឌិត ដូចជាលោកឪពុក ខ្ញុំខ្លាចការទៅក្នុងដែនដីមនុស្សនោះ ខ្ញុំនៅក្នុងសម្នាក់របស់បិតានេះឯង ។ លំដាប់នោះ តាបសដែលជាបិតាបានឲ្យឱវាទដល់តាបសកំលោះក្រៃលែងឡើងទៀត ហើយបង្រៀនឲ្យបរិកម្មក្នុងកសិណ មិនយូរប៉ុន្មានតាបសក៏បានអភិញ្ញា និងសមាបត្តិ ជាអ្នកមានព្រហ្មលោកជាទីទៅខាងមុខ មួយអន្លើដោយតាបសជាបិតា ។

*ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងកាលចប់សច្ចៈ ភិក្ខុអផ្សុក តាំងនៅក្នុងសោតាបត្តិផល ហើយទ្រង់ប្រជុំជាតកថា តាបសកំលោះក្នុងកាលនោះ បានមកជាភិក្ខុអផ្សុកក្នុងកាលឥឡូវនេះ កុមារិកាក្នុងកាលនោះ បានមកជានាងថុល្លកុមារិកា ឯតាបសជាបិតាក្នុងកាលនោះ គឺតថាគតនេះ ។ល។*

**អដ្ឋកថា ហលិទ្ទរាគជាតក ចប់**

# សុត្តន្តបិដក

## សមុគ្គជាតក

[ ៥៩០ ] ( តាបសពោធិសត្វ សួរអារក្សទឹកថា ) នែអ្នកទាំងឡាយដ៏ចម្រើន ចុះអ្នកទាំង ៣ នាក់មកអំពីទីណា អ្នកមកស្រួលហើយ ចូរមកអង្គុយលើអាសនៈទៅ នែអ្នកដ៏ចម្រើន អ្នកមានសេចក្តីសុខស្រួលមិនមានជំងឺជម្ងាត់ទេឬ ព្រោះយូរណាស់ហើយ អ្នកទាំងឡាយ ទើបមកក្នុងទីនេះ ។

[ ៥៩១ ] ( ទានវៈ[1] តបនឹងតាបសថា ) ខ្ញុំមកក្នុងទីនេះតែម្នាក់ឯងទេ ខ្ញុំមិនមានអ្នកណាមួយជាគម្រប់ពីរទេ បពិត្រឥសី លោកសំដៅហេតុអ្វី បានជាពោលថា នែអ្នកដ៏ចម្រើន ចុះអ្នកទាំង ៣ នាក់ មកអំពីទីណា ។

[ ៥៩២ ] ( តាបស ... ) ខ្លួនអ្នកឯងម្នាក់ផង ភរិយាជាទីស្រឡាញ់របស់អ្នក ដែលអ្នកដាក់ក្នុងស្មុគ្រ ហើយលេបចូលទៅក្នុងពោះផង ភរិយានោះ ដែលអ្នករក្សាហើយ នៅក្នុងពោះសព្វកាល ត្រេកអរជាមួយនឹង ( វិជ្ជាធរ ) ជាវាយុបុត្រក្នុងស្មុគ្រនោះផង ។

[ ៥៩៣ ] ទានវៈនោះ លុះឥសីព្យាករហើយ ក៏មានសភាពតក់ស្លុតហើយ ខ្ជាក់ស្មុគ្រចេញក្នុងទីនោះ ក៏បានឃើញភរិយាមានរូបយ៉ាងស្អាត ទ្រទ្រង់នូវផ្កាកម្រង ត្រេកអរជាមួយនឹងវិជ្ជាធរជាវាយុបុត្រក្នុងស្មុគ្រនោះ ។

---

១- អសុរសាមញ្ញ ។

[ ៥៩៤ ] ព្រះករុណាដែលជាអ្នកប្រព្រឹត្តតបៈដ៏ខ្ពង់ខ្ពស់ បាន ឃើញហេតុត្រឹមត្រូវមែនហើយ ពួកជនណា ជាបុគ្គលថោកទាប ពួកជននោះ រមែងលុះអំណាចស្រ្តី ដូចខ្ញុំដែលបានរក្សាទុកនូវ ស្រ្តី ដូចជាជីវិតក្នុងទីនេះ ស្រ្តីនោះ ប្រទូស្តនឹងខ្ញុំ ហើយរីករាយ នឹងបុរសដទៃវិញ ។

[ ៥៩៥ ] ខ្ញុំបានទំនុកបម្រុងស្រ្តីនោះ ទាំងយប់ ទាំងថ្ងៃ ដូចជា ភ្លើងដែលលោកមានតបៈនៅក្នុងព្រៃ បូជាហើយ ស្រ្តីនោះប្រព្រឹត្ត កន្លងធម៌ ហើយប្រព្រឹត្តអធម៌វិញ ការស្និទ្ធស្នាលជាមួយនឹងពួក ស្រ្តី ជាសភាពមិនគួរធ្វើសោះឡើយ ។

[ ៥៩៦ ] ខ្ញុំសម្គាល់ស្រ្តីដែលជាអសប្បុរស មិនសង្រួមថា ( ស្រ្តី នេះ ) ឋិតនៅក្នុងកណ្តាលសរីរៈ ស្រ្តីនេះ ជារបស់អញ ដូច្នេះ ស្រ្តីនោះ ប្រព្រឹត្តកន្លងធម៌ ហើយប្រព្រឹត្តអធម៌វិញ ការស្និទ្ធ ស្នាលជាមួយនឹងពួកស្រ្តី ជាសភាពមិនគួរធ្វើសោះឡើយ ។

[ ៥៩៧ ] ចុះបុគ្គលគួរទុកចិត្តថា អាត្មាអញបានរក្សាស្រ្តីទុកល្អ ហើយ ដូច្នេះ ដោយបការដូចម្តេចបាន ព្រោះមិនមានវិធីរក្សា ទុកនូវពួកស្រ្តី ដែលមានចិត្តរាយមាយនេះបានទេ ត្បិតពួកស្រ្តី ទាំងនុ៎ះ ប្រហែលនឹងអន្លង់ក្នុងបាតសមុទ្រ បុគ្គលតែប្រហែស ក្នុងពួកស្រ្តីទាំងនោះហើយ រមែងដល់នូវសេចក្តីវិនាស ។

[ ៥៩៨ ] ព្រោះហេតុនោះឯង បុគ្គលពួកណា ជាអ្នកប្រព្រឹត្ត វលាស់ខ្លួនចេញចាកពួកមាតុគ្រាម បុគ្គលពួកនោះ តែងបានសុខ ប្រាសចាកសេចក្ដីសោក បុគ្គល កាលបើប្រាថ្នាសេចក្ដីក្សេមដ៏ឧត្ដមនុ៎ះ មិនគួរធ្វើនូវសេចក្ដីស្និទ្ធស្នាលនឹងពួកមាតុគ្រាមឡើយ ។

## សមុគ្គជាតកទី ១០ ចប់

# អដ្ឋកថា

## សមុគ្គជាតក

[ ៥៩០-៥៩៨ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអផ្សុក ទើបត្រាស់រឿងនេះ មានពាក្យផ្តើមថា **កុតោ នុ អាគច្ឆថ** ដូច្នេះជាដើម ។

សេចក្តីសង្ខេបថា ព្រះសាស្តាត្រាស់សួរភិក្ខុអផ្សុកនោះថា ម្នាលភិក្ខុ បានឮថា អ្នកអផ្សុកពិតឬ កាលភិក្ខុនោះក្រាបថា ករុណាព្រះអង្គ ពិតមែន ដូច្នេះ ទើបត្រាស់ថា ម្នាលភិក្ខុ អ្នកប្រាថ្នាមាតុគ្រាម ព្រោះហេតុអ្វី ឈ្មោះថា មាតុគ្រាម មិនមែនសប្បុរស ជាអកតញ្ញូ សូម្បីទានវយក្ខក្នុងកាលមុន លេបមាតុគ្រាមទុកក្នុងពោះ ត្រាច់ទៅ ក៏នៅតែមិនអាចរក្សាមាតុគ្រាម ធ្វើឲ្យនាងមានប្តីតែម្នាក់បាន អ្នកនឹងរក្សាបានដូចម្តេច ដូច្នេះហើយ ទ្រង់នាំយករឿងក្នុងអតីតមកសាធក:ដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វលះកាមចូលទៅដែនដីព្រៃហិមពាន្ត បួសជាឥសី បានអភិញ្ញានិងសមាបត្តិហើយ ធ្វើជីវិតឲ្យតាំងនៅដោយផ្លែឈើតូចធំ ក្នុងទីមិនឆ្ងាយអំពីបណ្ណសាលារបស់ព្រះពោធិសត្វនោះ មានទានវយក្ខព្រៃមួយ ចូលទៅរកព្រះពោធិសត្វ ស្តាប់ធម៌ជានិច្ចកាល ។ ម្យ៉ាងទៀត យក្ខនោះតែងតែទៅកាន់ផ្លូវដែលមនុស្សទាំងឡាយធ្វើដំណើរទៅមកក្នុងព្រៃ ឃើញមនុស្សអ្នកដំណើរមក ក៏ចាប់បរិភោគ ។

សម័យនោះ ក្នុងដែនកាសី មានកុលធីតាម្នាក់ មានរូបស្អាតក្រៃលែង

អាស្រ័យបច្ចន្តគាមមួយកន្លែង ។ ថ្ងៃមួយ នាងមកសួរសុខទុក្ខមាតាបិតា ក្នុងគ្រាត្រឡប់ ទានវៈនោះឃើញពួកបរិវាររបស់នាង ទើបរត់ដេញដោយរូបដែលគួរខ្លាច ។ ពួកបរិវារកាន់របស់របរ នាំគ្នាចោលរបស់របរ រត់គេចទៅ ទានវៈឃើញមាតុគ្រាមរូបស្អាតអង្គុយក្នុងយាន កើតចិត្តប្រតិព័ទ្ធ ទើបនាំទៅគុហារបស់ខ្លួន ធ្វើជាភរិយា ។ តាំងអំពីនោះមក ទានវៈបាននាំសប្បិ អង្ករ ត្រីសាច់ជាដើម និងផ្លែឈើដែលឆ្ងាញ់មកឲ្យភរិយា និងឲ្យតាក់តែងដោយគ្រឿងអលង្ការ គឺសំពត់ ឲ្យនាងដេកក្នុងស្មុគ មានសណ្ឋានដូចកំប្រោង រាង ៤ ជ្រុងមានគម្រប ហើយលេបស្មុគនោះទុកក្នុងពោះ ថែរក្សាភរិយាដោយពោះ ។

ថ្ងៃមួយ ទានវៈនោះ ទៅកាន់ស្រះមួយកន្លែងដើម្បីងូតទឹក ខ្ជាក់ស្មុគចេញហើយ យកនាងចេញអំពីស្មុគនោះ ឲ្យងូតទឹក លាបម្សៅ តែងកាយហើយពោលថា ចូរនាងអាំងថ្ងៃមួយស្របក់ ឲ្យនាងឈរក្បែរស្មុគនោះ ខ្លួនឯងក៏ចុះទៅត្រង់កំពង់ទឹក មិនមានសេចក្តីសង្ស័យក្នុងភរិយា បានទៅងូតឆ្ងាយបន្តិច ខណៈនោះ វិទ្យាធរ ឈ្មោះវាយុបុត្ត កាន់ដាវហោះមក ស្រីនោះឃើញវិទ្យាធរហើយ លើកដៃជាសញ្ញាឲ្យដឹងថា មកនេះ វិទ្យាធរក៏ចុះមកមួយរំពេចលំដាប់នោះ នាងយកវិទ្យាធរនោះដាក់ក្នុងស្មុគ រង់ចាំការមករបស់ទានវៈ នាងអង្គុយលើស្មុគ កាលឃើញទានវៈមក ក៏បង្ហាញខ្លួនដល់ទានវៈនោះ កាលទានវៈមិនទាន់មកដល់ស្មុគ នាងក៏បើកស្មុគ ហើយចូលទៅខាងក្នុងដេកលើវិទ្យាធរ ហើយយកសំពត់ដណ្តប់ ទានវៈមកមិនបានពិនិត្យមើលស្មុគឲ្យហ្មត់ចត់

ជាមុន លេបស្មុគចូលទៅ ដោយយល់ថា ប្របពន្ធអញតែម្នាក់ ទៅកាន់គុហា របស់ខ្លួន ក្នុងវេលាផ្សេង គិតថា អញខានសួរសុខទុក្ខតាបសយូរហើយ ថ្ងៃនេះ អញនឹងនមស្ការលោកសិន ទើបទៅកាន់សម្នាក់តាបសៗ ឃើញទានវៈនោះ មកអំពីចម្ងាយ ដឹងថា មានមនុស្ស ២ នាក់ ដេកនៅក្នុងពោះ កាលនឹង ចរចា ទើបពោលគាថាទី ១ ថា

នៃអ្នកទាំងឡាយដ៏ចម្រើន ចុះអ្នកទាំង ៣ នាក់មកអំពីទីណា អ្នកមកស្រួលហើយ ចូរមកអង្គុយលើអាសនៈទៅ នៃអ្នកដ៏ ចម្រើន អ្នកមានសេចក្តីសុខស្រួល មិនមានជំងឺតម្កាត់ទេឬ ព្រោះយូរណាស់ហើយ អ្នកទាំងឡាយ ទើបមកក្នុងទីនេះ ដូច្នេះ ។

សព្ទថា **ភោ** ក្នុងគាថានោះ ជាអាលបនៈ ។ បទថា **កច្ចិន្នុ** ស្មើគ្នា នឹង **កច្ចិ ហោថ ភវថ វិជ្ជថ** សេចក្តីថា អ្នកទាំងឡាយ ចម្រើនល្អហើយឬ តាបសកាលនឹងរាក់ទាក់បន្ត ទើបពោលថា **ភោន្តោ** ប្រែថា អ្នកដ៏ចម្រើន ទាំងឡាយ ។ បទថា **កុសលំ អនាមយំ** សេចក្តីថា អ្នកទាំងឡាយ ប្រហែលជាសុខសប្បាយល្អ មិនមានរោគទេឬ ។ បទថា **ចិរស្សមព្ភាគមនំ ហិ វោ ឥធ** សេចក្តីថា យូរហើយអ្នកទាំងឡាយ ទើបតែមកទីនេះ ថ្ងៃនេះ ។

ទានវៈបានស្តាប់ដូច្នោះ គិតថា អញមកកាន់សម្នាក់តាបសតែម្នាក់ឯង ប៉ុណ្ណោះ តែតាបសពោលថា អ្នកទាំង ៣ តាបសពោលដូច្នោះ ព្រោះហេតុ អ្វីហ្ន៎ តាបសនេះដឹងតាមសេចក្តីពិត ទើបពោល ឬក៏ពោលផ្តេសផ្តាស ចូល ទៅរកតាបស នមស្ការហើយ អង្គុយក្នុងទីសមគួរ នាចំណែកម្ខាង កាល

ចរចាជាមួយតាបសនោះ ទើបបានពោលគាថាទី ២ ថា

ខ្ញុំមកក្នុងទីនេះ តែម្នាក់ឯងទេ ខ្ញុំមិនមានអ្នកណាមួយ ជាគម្រប់ពីរទេ បពិត្រឥសី លោកសំដៅហេតុអ្វី បានជាពោលថា នែអ្នកដ៏ចម្រើន ចុះអ្នកទាំង ៣ នាក់មកអំពីទីណា ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឥធមជ្ជ** កាត់បទជា **ឥធ អជ្ជ**។ បទថា **កិមេវ សន្ធាយ តេ ភាសិតំ ឥសេ** សេចក្ដីថា បពិត្រឥសីដ៏ចម្រើន ពាក្យដែលលោកពោលនោះសំដៅដល់អ្វី សូមលោកប្រាប់ឲ្យជាក់ច្បាស់ដល់ខ្ញុំចុះ ។ តាបសសាកសួរថា អាវុសោ អ្នកត្រូវការស្ដាប់មែនឬ កាលទានវៈឆ្លើយថា ពិតហើយ លោកម្ចាស់ ទើបពោលថា បើដូច្នោះ ចូរអ្នកស្ដាប់ដូច្នេះហើយ ទើបពោលគាថាទី ៣ ថា

ខ្លួនអ្នកឯងម្នាក់ផង ភរិយាជាទីស្រឡាញ់របស់អ្នក ដែលអ្នកដាក់ក្នុងស្នូក្រ ហើយលេបចូលទៅក្នុងពោះផង ភរិយានោះដែលអ្នករក្សាហើយ នៅក្នុងពោះសព្វកាល ត្រេកអរជាមួយនឹង (វិជ្ជាធរ) ជាវាយុបុត្រក្នុងស្នូក្រនោះផង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **តុវញ្ច ឯកោ** គឺដំបូងខ្លួនអ្នកម្នាក់ ។ បទថា **បក្ខិត្តនិកិណ្ណមន្តរេ** សេចក្ដីថា អ្នកដាក់ស្នូគទុកខាងក្នុង គឺអ្នកត្រូវរក្សាភរិយានោះសព្វកាល ទើបដាក់ក្នុងស្នូគនោះ រក្សាទុកខាងក្នុង គឺទុកខាងក្នុងពោះ មួយអន្ទើដោយស្នូគ ។ បទថា **វាយុស្ស បុត្តេន សហា** បានដល់រួមត្រេកអរជាមួយវិទ្យាធរដែលមានឈ្មោះយ៉ាងនេះ ។ បទថា **តហឹ រតា**

បានដល់ រួមត្រេកអរដោយសេចក្តីត្រេកអរ ដោយអំណាចកិលេសខាងក្នុងផ្ទៃរបស់អ្នកនោះឯង ។ តាបសនោះពោលថា ឥឡូវនេះ អ្នកគិតថា អញនឹងធ្វើមាតុគ្រាមឲ្យមានប្តីតែមួយ ទើបរក្សាដោយផ្ទៃ តែនាងបានឱបសហាយរបស់នាង នៅខាងក្នុង ។

ទានវៈបានស្តាប់ដូច្នោះ ក៏គក់ស្មុគ គិតថា ធម្មតាវិទ្យាធរ រមែងមានមាយាច្រើន បើវិទ្យាធរនោះ មានដាវក្នុងដៃ នឹងទម្លុះពោះអញគេចទៅ ទើបខ្ទាក់ស្មុគទុកក្នុងទីចំពោះមុខមួយរំពេច ។

ព្រះសាស្តា កាលទ្រង់ត្រាស់ដឹងហើយ ដើម្បីប្រកាសការប្រព្រឹត្តទៅនោះ ទើបទ្រង់ត្រាស់អភិសម្ពុទ្ធគាថាទី ៤ ថា

ទានវៈនោះ លុះឥសីព្យាករហើយ ក៏មានសភាពគក់ស្មុគហើយ
ខ្ទាក់ស្មុគចេញក្នុងទីនោះ ក៏បានឃើញកិរិយាមានរូបយ៉ាងស្អាត
ទ្រទ្រង់នូវផ្កាកម្រង ត្រេកអរជាមួយនឹងវិជ្ជាធរ ជាវាយុបុត្រក្នុង
ស្មុគនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អទ្ទក្ខិ** បានដល់ បើកស្មុគហើយ ក៏បានឃើញ ។ លុះទានវៈបើកស្មុគឡើងប៉ុណ្ណោះ វិទ្យាធរក៏រាយមន្ត កាន់ដាវហោះទៅក្នុងអាកាស ទានវៈឃើញដូច្នោះ មានចិត្តត្រេកអរចំពោះព្រះមហាសត្វ បានពោលគាថាដ៏សេស មានការសរសើរជាខាងដើមថា

ព្រះករុណាដែលជាអ្នកប្រព្រឹត្តតបៈដ៏ខ្ពង់ខ្ពស់ បានឃើញហេតុ
ត្រឹមត្រូវមែនហើយ ពួកជនណា ជាបុគ្គលថោកទាប ពួកជន

នោះ រមែងលុះអំណាចស្ត្រី ដូចខ្ញុំដែលបានរក្សាទុកនូវស្ត្រី ដូចជាជីវិតក្នុងទីនេះ ស្ត្រីនោះ ប្រទូស្តនឹងខ្ញុំ ហើយរីករាយនឹងបុរសដទៃវិញ ។

ខ្ញុំបានទំនុកបម្រុងស្ត្រីនោះ ទាំងយប់ ទាំងថ្ងៃ ដូចជាភ្លើងដែលលោកមានតបៈនៅក្នុងព្រៃ បូជាហើយ ស្ត្រីនោះ ប្រព្រឹត្តកន្លងធម៌ ហើយប្រព្រឹត្តអធម៌វិញ ការស្និទ្ធស្នាលជាមួយនឹងពួកស្ត្រី ជាសភាពមិនគួរធ្វើសោះឡើយ ។

ខ្ញុំសម្គាល់ស្ត្រីដែលជាអសប្បុរស មិនសង្ស័យថា ( ស្ត្រីនេះ ) ឋិតនៅក្នុងកណ្តាលសរីរៈ ស្ត្រីនេះ ជារបស់អញ ដូច្នេះ ស្ត្រីនោះប្រព្រឹត្តកន្លងធម៌ ហើយប្រព្រឹត្តអធម៌វិញ ការស្និទ្ធស្នាលជាមួយនឹងពួកស្ត្រី ជាសភាពមិនគួរធ្វើសោះឡើយ ។

ចុះបុគ្គលគួរទុកចិត្តថា អាត្មាអញបានរក្សាស្ត្រីទុកល្អហើយដូច្នេះ ដោយបការដូចម្តេចបាន ព្រោះមិនមានវិធីរក្សាទុក នូវពួកស្ត្រីដែលមានចិត្តរាយមាយនេះបានទេ ត្បិតពួកស្ត្រីទាំងនុ៎ះ ប្រហែលនឹងអន្លង់ក្នុងបាតសមុទ្រ បុគ្គលតែប្រហែសក្នុងពួកស្ត្រីទាំងនោះហើយ រមែងដល់នូវសេចក្តីវិនាស ។

ព្រោះហេតុនោះឯង បុគ្គលពួកណា ជាអ្នកប្រព្រឹត្តវៀរលាស់ខ្លួនចេញចាកពួកមាតុគ្រាម បុគ្គលពួកនោះ តែងបានសុខ ប្រាសចាកសេចក្តីសោក បុគ្គល កាលបើប្រាថ្នាសេចក្តីក្សេមដ៏ឧត្តមនុ៎ះ

មិនគួរធ្វើនូវសេចក្តីស្និទ្ធស្នាលនឹងពួកមាតុគ្រាមឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សុចិណ្ណព្រហ្មចរិយា** សេចក្តីថា បពិត្រឥសី ហេតុនេះ លោកអ្នកដែលប្រព្រឹត្តតបៈខ្ពង់ខ្ពស់ ឃើញល្អហើយ ។ បទថា **ហីនា** គឺជាបុគ្គលថោកទាប ។ បទថា **យថា ហរេ ចាណាវិរេត្ត រក្ខិតា** សេចក្តីថា កិរិយានេះ ដែលខ្ញុំថែរក្សាទុកក្នុងទីនេះ គឺខាងក្នុងផ្ទៃនេះ ស្មើនឹងជីវិតរបស់ខ្លួន ។ បទថា **ទុដ្ឋា មយិ** សេចក្តីថា ឥឡូវនេះ ត្រឡប់មកធ្វើកម្មរបស់បុគ្គលទ្រុស្តមិត្ត ប្រទូស្តខ្ញុំ ត្រេកអរនឹងប្រុសដទៃ ។ បទថា **ជោតិរិវា វនេ វសំ** សេចក្តីថា ខ្ញុំទំនុកបម្រុង គឺបម្រើកិរិយានោះ ដូចជាឥសីអ្នកមានតបៈនៅក្នុងព្រៃ បម្រើភ្លើង ដូច្នោះ ។ បទថា **សា ធម្មមុក្កម្ម** សេចក្តីថា កិរិយានោះគង់ឈានកន្លង គឺកន្លងនូវធម៌ ។ បទថា **អក្រិយរូបោ** ស្មើគ្នានឹង **អកត្តព្វរូបោ** ប្រែថា មិនគួរធ្វើ ។ បទថា **សរីរមជ្ឈម្ហិ ឋិតាតិ មញ្ញហំ មយ្ហំ អយន្តិ អសតំ អសញ្ញតំ** សេចក្តីថា ខ្ញុំសម្គាល់ស្រីនេះដែលមិនមានសេចក្តីស្ងប់ គឺបុគ្គលប្រកបដោយធម៌អសប្បុរសដែលមិនសង្រួម គឺជាបុគ្គលទ្រុស្តសីលថា នៅត្រង់កណ្តាលសរីរៈរបស់ខ្ញុំ និងសម្គាល់ថា ស្រីនេះជាកិរិយារបស់ខ្ញុំ ។ បទថា **សុរក្ខិតម្មេតិ កថន្នុ វិស្សសេ** សេចក្តីថា បណ្ឌិត គប្បីដាក់ចិត្តបានថា ស្រីនេះ អញរក្សាទុកល្អហើយ តែមនុស្សដូចអញ រក្សាកិរិយាទុកក្នុងពោះរបស់ខ្លួនពិត នៅតែមិនអាចរក្សាបាន ។ បទថា **បាតាល បចាតសន្និភា** សេចក្តីថា ឈ្មោះថា មានអាការដូចគ្នានឹងជ្រោះជ្រៅដែលហៅថា បាតាល ក្នុងមហាសមុទ្រ ព្រោះស្រីទាំងនោះ បុគ្គលលំបាកឲ្យ

ពេញ ដោយការត្រេកអរក្នុងលោកបាន ។ បទថា **ឯត្ថប្បមត្តោ** សេចក្ដីថា បុរសអ្នកប្រមាទក្នុងស្រីដែលមិនមានគុណបែបនេះប៉ុណ្ណោះ តែងដល់នូវសេចក្ដីវិនាសធំ ។ បទថា **តស្មា ហិ** សេចក្ដីថា ព្រោះធ្លាក់នៅក្នុងអំណាចរបស់មាតុគ្រាម រមែងដល់នូវការវិនាសធំ ដូច្នោះ ជនណាមិនច្រឡូកច្រឡំជាមួយមាតុគ្រាម ជនទាំងនោះ រមែងមានសេចក្ដីសុខ ។ បទថា **ឯតំ សិវំ** សេចក្ដីថា ការប្រព្រឹត្តរបស់បុគ្គលដែលមិនច្រឡូកច្រឡំ គឺមិនទាក់ទងជាមួយមាតុ-គ្រាម នេះជាហេតុឲ្យបានសុខក្នុងឈាន គឺជាសេចក្ដីល្អ បានដល់ ជាការក្សេមដ៏ឧត្ដម ដែលបុគ្គលគប្បីប្រាថ្នា បុគ្គលប្រាថ្នាសេចក្ដីក្សេមដ៏ឧត្ដមនោះមិនគួរធ្វើការស្និទ្ធស្នាលជាមួយមាតុគ្រាមឡើយ ។

កាលពោលដូច្នេះហើយ ទានវៈបានក្រាបចុះទៀបបាតជើងព្រះពោធិសត្វពោលសរសើរព្រះមហាសត្វថា ខ្ញុំមានជីវិតព្រោះអាស្រ័យលោកម្ចាស់ ព្រោះខ្ញុំមិនត្រូវស្រីលាមកនេះ ប្រើឲ្យវិទ្យាធរសម្លាប់ ។ ព្រះពោធិសត្វកាលសម្ដែងធម៌ដល់ទានវៈនោះហើយ ពោលថា អ្នកកុំធ្វើកម្មអាក្រក់ណាមួយដល់ស្រីនេះឡើយ ចូរទទួលសីល ឲ្យទានវៈតាំងនៅក្នុងសីល ៥ ។ ទានវៈគិតថា ទោះបីអញរក្សាដោយពោះ ក៏នៅតែមិនអាចរក្សាស្រីនេះបាន អ្នកដទៃណានឹងរក្សាបាន ទើបបញ្ជូនស្រីនោះទៅ ខ្លួនឯងក៏ចូលព្រៃ ដែលជាលំនៅរបស់ខ្លួន ។

*ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់បាន ប្រកាសសច្ចៈទាំងឡាយ ក្នុងកាលចប់សច្ចៈ ភិក្ខុអផ្សុកតាំងនៅក្នុងសោតា-បត្តិផល ហើយទ្រង់ប្រជុំជាតកថា តាបសអ្នកមានទិព្វចក្ខុក្នុងកាលនោះ គឺ តថាគតនេះឯង ៕*

**អដ្ឋកថា សមុគ្គជាតក ចប់**

# សុត្តន្តបិដក

## បូតិមំសជាតក

[ ៥៩៩ ] ( មេពពៃនិយាយនឹងមេចចកថា ) នៃសម្លាញ់ ការក្រឡេកមើល នៃចចកឈ្មោះបូតិមំសៈ មិនគាប់ចិត្តយើងទេ បុគ្គលគួរវៀរឲ្យឆ្ងាយ អំពីសម្លាញ់បែបនេះ ។

[ ៦០០ ] ( ចចកឈ្មោះបូតិមំសៈ ពោលតិះដៀលមេចចកជាប្រពន្ធខ្លួនថា ) មេចចកឈ្មោះវេណិនេះជាសត្វឆ្កួត ពោលសរសើរនូវសម្លាញ់ប្រាប់ដល់អញជាប្តី ហើយបែរជាសោកស្រណោះនូវមេពពៃដែលទើបនឹងមក ហើយត្រឡប់ថយទៅវិញ ។

[ ៦០១ ] ( មេចចកនិយាយតបថា ) នៃសម្លាញ់ អ្នកឯងទេតើ ជាសត្វឆ្កួតខ្លៅ មិនចេះពិចារណាអ្វីសោះ អ្នកឯងធ្វើពុតជាស្លាប់ ហើយក្រឡេកមើលខុសកាល ។

[ ៦០២ ] ( អភិសម្ពុទ្ធគាថា ) អ្នកប្រាជ្ញមិនគប្បីក្រឡេកមើលក្នុងកាលមិនគួរទេ គប្បីក្រឡេកមើលតែក្នុងកាលដ៏គួរ បុគ្គលណាក្រឡេកមើលក្នុងកាលមិនគួរ បុគ្គលនោះ រមែងសោកស្រណោះ ដូចចចកឈ្មោះបូតិមំសៈ ។

[ ៦០៣ ] ( មេចចកនិយាយនឹងមេពពៃថា ) ម្នាលសម្លាញ់ សេចក្តីស្រឡាញ់របស់យើង សូមឲ្យមានទៅដដែល សូមនាងឲ្យរង្វាន់ដល់យើង ប្តីរបស់យើងរស់ដោយខ្លួនឯងវិញហើយ កាលបើខ្ញុំសួរអំពីសេចក្តីស្រឡាញ់ហើយ ( គប្បីមកជាមួយនឹងយើង ) ។

[ ៦០៤ ] ( មេពពៃ ... ) នែសម្លាញ់ របស់ជាទីស្រឡាញ់ ចូរមានដល់នាងដូចដែលចុះ ឥឡូវ យើងឲ្យស្ងោន់ដល់នាងហើយ ( តែថា ) យើងនឹងមកជាមួយនឹងបរិវារច្រើន ( បើដូច្នោះ ) នាងចូររៀបកោជនទទួលផង ។

[ ៦០៥ ] ( មេចចក ... ) បរិវាររបស់នាងដូចម្ដេចទៅ ខ្ញុំនឹងរៀបកោជនចាំទទួលពួកបរិវាររបស់នាង បរិវារនាងទាំងអស់នោះតើមានឈ្មោះដូចម្ដេច យើងសួរ នាងចូរប្រាប់នូវបរិវារនោះ ។

[ ៦០៦ ] ( មេពពៃ ... ) ( ឆ្កែ ៤ ពួក ) គឺឆ្កែឈ្មោះមាលិយៈ ១ ឆ្កែឈ្មោះចតុរក្ខៈ ១ ឆ្កែឈ្មោះបិង្គិយៈ ១ ឆ្កែឈ្មោះជម្ពុកៈ ១ ឆ្កែបែបនេះ ជាបរិវាររបស់យើង នាងចូររៀបកោជនបម្រុងឆ្កែទាំងនោះចុះ ។

[ ៦០៧ ] ( មេចចក ... ) កាលបើនាងចេញទៅអំពីផ្ទះ ទ្រព្យរបស់ មុខជាវិនាសមិនខាន ចាំយើងប្រាប់សេចក្ដីមិនមានរោគដល់សម្លាញ់ នាងចូរនៅក្នុងទីនេះចុះ នាងកុំបាច់ទៅឡើយ ។

**បូតិមំសជាតកទី ១១ ចប់**

# អដ្ឋកថា

## ឫតិមំសជាតក

[ ៥៩៩-៦០៧ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការមិនសង្រួម ទើបត្រាស់រឿងនេះ មានពាក្យផ្តើមថា **ន ខោ មេ រុច្ចតិ** ដូច្នេះជាដើម ។

មានសេចក្តីសង្ខេបថា ថ្ងៃមួយ ភិក្ខុជាច្រើនមិនគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ព្រះសាស្តាត្រាស់នឹងព្រះអានន្ទថា គួរនឹងពោលទូន្មានភិក្ខុទាំងនេះ ត្រាស់ឲ្យប្រជុំភិក្ខុសង្ឃ ជាពិសេស យាងទៅក្នុងកណ្តាលភិក្ខុទាំងនោះ គង់លើបល្ល័ង្កដ៏ប្រសើរដែលគេរៀបចំ ត្រាស់ហៅភិក្ខុទាំងឡាយមកហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឈ្មោះថា ភិក្ខុ មិនគួរកាន់យកនិមិត្តក្នុងរូបជាដើមដោយអំណាចសុភនិមិត្ត ព្រោះបើស្លាប់ក្នុងខណៈនោះ នឹងកើតក្នុងអបាយមាននរកជាដើម ដូច្នោះ កុំកាន់យកសុភនិមិត្តក្នុងរូបជាដើម ដែលឈ្មោះថា ភិក្ខុ មិនគួរកាន់យករូបជាដើមជាអារម្មណ៍ ព្រោះបុគ្គលដែលកាន់យករូបជាដើមជាអារម្មណ៍ រមែងដល់នូវមហាវិនាសក្នុងបច្ចុប្បន្ននេះឯង ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ចក្ខុន្ទ្រិយដែលត្រូវចាក់ដោយដែកស្រួច ក្រហមដោយភ្លើង ប្រសើរជាងការមើលសុភនិមិត្តក្នុងរូប វេលាដែលពួកអ្នកគួរសម្លឹងមើលរូបមានក្នុងកាលខ្លះ វេលាដែលពួកអ្នកមិនគួរសម្លឹងមើលរូបមានក្នុងកាលខ្លះ ក្នុងវេលាមើលមិនគួរមើលដោយអំណាចនៃសុភនិមិត្ត គួរមើលដោយអំណាចនៃអសុភនិមិត្តប៉ុណ្ណោះ បើធ្វើបានយ៉ាងនេះ ក៏នឹងមិនវិនាសចាកអារម្មណ៍របស់ខ្លួន ។ អ្វីជាអារម្មណ៍របស់ពួកអ្នក គឺសតិប្បដ្ឋាន ៤

អរិយមគ្គមានអង្គ ៨ លោកុត្តរធម៌ ៩ កាលពួកអ្នកគោចរក្នុងអារម្មណ៍បែបនេះ មារក៏មិនបាននូវឱកាសប្រទូស្ត តែបើពួកអ្នកធ្លាក់ក្នុងអំណាចកិលេស មើលដោយអំណាចសុភនិមិត្ត ក៏នឹងវិនាសចាកអារម្មណ៍របស់ខ្លួន ដូចចចកឈ្មោះបូតិមំសៈសាបសូន្យចាកអាហារ ដូច្នោះហើយ ទ្រង់បាននាំយករឿងក្នុងអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិក្នុងនគរពារាណសី មានពពែច្រើនរយ នៅក្នុងគុហាក្បែរជើងភ្នំ នាដែនដីព្រៃហិមពាន្ត ក្នុងទីជិតលំនៅរបស់ពពែទាំងនោះ មានចចកឈ្មោះបូតិមំសៈ និងភរិយា ឈ្មោះវេណិ នៅក្នុងគុហាមួយ ។ ថ្ងៃមួយ ចចកត្រាច់ទៅជាមួយភរិយាឃើញពពែទាំងនោះ គិតថា យើងគួរស៊ីសាច់ពពែទាំងនេះ ដោយឧបាយណាមួយ ហើយបានប្រើនូវឧបាយសម្លាប់ពពែមួយថ្ងៃមួយ ។ ចចកទាំង ២ ស៊ីសាច់ពពែរហូតមានកម្លាំង រាងកាយធាត់បរិបូណ៌ ។ ពពែក៏ថយចុះជាលំដាប់ ក្នុងក្រុមពពែទាំងនោះ មានពពែញីមួយឈ្មោះមេណ្ឌិកមាតា ជាពពែឈ្លាសវៃ ដឹងទាន់នូវឧបាយ ។ ចចកមិនអាចសម្លាប់មេពពែនោះបាន ។ ថ្ងៃមួយ ទើបប្រឹក្សាជាមួយភរិយាថា នាងជាទីស្រឡាញ់ ពពែទាំងឡាយអស់ហើយ យើងគួរប្រើឧបាយស៊ីពពែញីមួយនេះ ហើយក្នុងរឿងនេះ មានឧបាយដូច្នេះ គឺខ្លួននាងចូរទៅធ្វើជាសម្លាញ់ជាមួយពពែនោះ កាលពពែញីស្និទ្ធស្នាលនឹងនាង អញនឹងដេកធ្វើជាស្លាប់ ហើយចូរនាងបបួលមេពពែនោះថា នែសម្លាញ់ ប្តីរបស់ខ្ញុំស្លាប់ហើយ ខ្ញុំមិនមានទីពឹងក្រៅអំពីនាង ញាតិដទៃរបស់ខ្ញុំមិនមាន មកចុះ

ពួកយើងនឹងនាំគ្នាយំ បូជាសពប្តីរបស់ខ្ញុំ ដូច្នេះហើយ ចូរនាំពពែនោះមក ហើយខ្ញុំនឹងស្ទុះឡើងខាំកសម្លាប់មេពពែនោះ ។ ចចកញីទទួលពាក្យថា សាធុ ទើបទៅសេពគប់ធ្វើជាសម្លាញ់ លុះស្និទ្ធស្នាលហើយ ក៏បានពោលនឹងមេពពែយ៉ាងនោះ ។ មេពពែពោលថា នែសម្លាញ់ ការដែលយើងទៅទីនោះ មិនគួរ ប្តីរបស់នាងស៊ីញាតិរបស់ខ្ញុំអស់ ខ្ញុំខ្លាច ខ្ញុំមិនអាចទៅបានទេ ។ ចចកញីក៏ពោលថា នែសម្លាញ់ កុំខ្លាចឡើយ អ្នកដែលស្លាប់ហើយ នឹងធ្វើអ្វីបាន ពពែញីក៏ពោលឆ្លើយយ៉ាងនេះថា ប្តីនាងមានតេជះច្រើន ខ្ញុំខ្លាចពិតៗ ដូច្នេះ ត្រូវចចកអង្វររឿយៗ គិតថា ចចកឈ្មោលគង់ស្លាប់ពិត ទើបទទួលពាក្យ ហើយទៅជាមួយចចកញី កាលទៅ ពពែគិតថា អ្នកណាដឹងថា មានហេតុអ្វីកើតឡើង ទើបឲ្យចចកញីទៅខាងមុខ ហើយខ្លួនដើរពីក្រោយ ចាំកំណាត់មើលចចកឈ្មោល ព្រោះសង្ស័យក្នុងចចកឈ្មោលនោះ ។

ចចកឈ្មោលបានឮសំឡេងជើងសត្វទាំង ២ គិតថា មេពពែមកដល់ហើយនៅ ទើបអើតក្បាលឡើងសម្លឹងមើល ពពែញីឃើញចចកធ្វើដូច្នោះ គិតថា ចចកនេះលាមក បំណងបោកអញមកសម្លាប់ ដេកធ្វើជាស្លាប់ ទើបត្រឡប់ទៅ ចចកញីសួរថា ហេតុអ្វី ទើបនាងគេចទៅ កាលនឹងប្រាប់ហេតុនោះ បានពោលគាថាទី ១ ថា

នែសម្លាញ់ ការក្រឡេកមើល នៃចចកឈ្មោះបូតិមំសៈ មិនគាប់ចិត្តយើងទេ បុគ្គលគួរវៀរឲ្យឆ្ងាយ អំពីសម្លាញ់បែបនេះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អាឡិ** ជាអាលបនៈ សេចក្តីថា នែ

សម្លាញ់ ។ បទថា **ឯតាទិសា សខារស្មា** សេចក្តីថា បុគ្គលចៀសចេញពីសម្លាញ់បែបនេះ ហើយគប្បីវៀរឲ្យឆ្ងាយសម្លាញ់នោះ ។

កាលពោលដូច្នេះហើយ ពពែញីបានត្រឡប់ទៅកាន់លំនៅរបស់ខ្លួន ចចកញីកាលមិនអាចហៅពពែញីមកបាន ក៏ខឹងសម្បានឹងចចកឈ្មោល ទៅកាន់សម្នាក់ប្តីរបស់ខ្លួន អង្គុយសញ្ជប់សញ្ជឹង ។ លំដាប់នោះ ចចកឈ្មោលគ្រានឹងតិះដៀលចចកញី ទើបពោលគាថាទី ២ ថា

មេចចកឈ្មោះវេណិនេះ ជាសត្វឆ្កួត ពោលសរសើរនូវសម្លាញ់
ប្រាប់ដល់អញជាប្តី ហើយបែរជាសោកស្រណោះ នូវមេពពែ
ដែលទើបនឹងមក ហើយត្រឡប់ថយទៅវិញ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វេណិ** ជាឈ្មោះរបស់ចចកញីនោះ ។ បទថា **វណ្ណេតិ បកតិនោ សខឹ** សេចក្តីថា ជាបឋម ចចកញីឈ្មោះវេណិនេះពណ៌នាដល់ពពែញីជាសម្លាញ់របស់ខ្លួន ក្នុងសម្នាក់ប្តីថា មេពពែមានសេចក្តីស្និទ្ធស្នាលជាមួយខ្លួន នឹងនាំមកកាន់សម្នាក់របស់ប្តី ឲ្យប្តីពុតធ្វើជាស្លាប់ ឥឡូវនេះ កាលមេពពែត្រឡប់ទៅ មកអង្គុយសញ្ជប់សញ្ជឹង សោយសោកដល់មេពពែ ឈ្មោះមេណ្ឌិកមាតានោះ ដែលមកហើយ តែមិនដល់សម្នាក់ប្តី ។ មេចចកបានស្តាប់ដូច្នោះហើយ ទើបពោលគាថាទី ៣ ថា

នែសម្លាញ់ អ្នកឯងទេតើ ជាសត្វឆ្កួតខ្លៅ មិនចេះពិចារណាអ្វី
សោះ អ្នកឯងធ្វើពុតជាស្លាប់ ហើយក្រឡេកមើលខុសកាល
ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អវិចក្ខណោ** បានដល់ វៀរចាកបញ្ញាជាគ្រឿងពិចារណា ។ បទថា **អាកាលេន វិបេក្ខសិ** សេចក្ដីថា កាលមេពពែមិនទាន់មកដល់សម្នាក់របស់ខ្លួន អើតមើលក្នុងកាលដែលមិនគួរ ។

ព្រះសាស្ដា កាលទ្រង់បានត្រាស់ដឹងហើយ ទើបទ្រង់ត្រាស់អភិសម្ពុទ្ធគាថានេះថា

អ្នកប្រាជ្ញមិនគប្បីក្រឡេកមើល ក្នុងកាលមិនគួរទេ គប្បីក្រឡេក
មើលតែក្នុងកាលដ៏គួរ បុគ្គលណា ក្រឡេកមើលក្នុងកាលមិន
គួរ បុគ្គលនោះ រមែងសោកស្រណោះ ដូចចចកឈ្មោះបូតិមំសៈ
ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អកាលេ** បានដល់ ក្នុងកាលដែលចិត្តុប្បាទកើតឡើង ដោយអំណាចសុភនិមិត្ត ព្រោះប្រារព្ធកាមគុណ កាលនេះឯងឈ្មោះថា កាលដែលមិនគួរ ភិក្ខុគប្បីក្រឡេកមើលនូវរូប ។ បទថា **កាលេ** បានដល់ ក្នុងកាលដែលកំណត់កាន់យករូបដោយអំណាចនៃអសុភនិមិត្ត ដោយអំណាចនៃអនុស្សតិ ឬដោយអំណាចនៃកសិណ កាលនេះឯង ឈ្មោះថា កាលគួរ ដែលភិក្ខុគប្បីមើលរូប ។

ក្នុងកាលទាំង ២ នោះ ជនទាំងឡាយ ដែលសម្លឹងមើលរូប ក្នុងកាលដែលមានតម្រេក រមែងដល់នូវមហាវិនាស ដូច្នេះ ។ ពាក្យថា ក្នុងកាលដែលមិនគួរ បណ្ឌិតគប្បីប្រៀបធៀបដោយជាតកទាំងឡាយ មានហរិតចជាតក និងលោមសកស្សបជាតកជាដើម បុគ្គលដែលសម្លឹងមើលរូប ដោយអំណាចនៃ

អសុភនិមិត្ត រមែងតាំងនៅក្នុងអរហត្តផល ដូច្នោះ ពាក្យថា ក្នុងកាលដែលគួរ បណ្ឌិតគប្បីប្រៀបធៀបដោយរឿងព្រះតិស្សត្ថេរ អ្នកចម្រើនអសុភកម្មដ្ឋាន ។ បទថា **បូតិមំសោវ បជ្ឈាយិ** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ចចកឈ្មោះបូតិមំសៈក្រឡេកមើលមេពពែ ក្នុងកាលដែលមិនគួរ ទើបសាបសូន្យចាកចំណីរបស់ខ្លួន សុបសៅ យ៉ាងណា ភិក្ខុសម្លឹងមើលរូបដោយអំណាចសុភនិមិត្ត ក្នុងកាលដែលមិនគួរ ក៏វិនាសចាកអារម្មណ៍ មានសតិប្បដ្ឋានជាដើម សុបសៅ គឺលំបាកទាំងក្នុងទិដ្ឋធម៌ និងសម្បរាយភព ដូច្នោះ ។

មេចចកឈ្មោះវេណិ បានពោលលួងលោមចចកឈ្មោលឈ្មោះបូតិមំសៈថា បពិត្រស្វាមី អ្នកកុំទោមនស្សឡើយ ខ្ញុំនឹងប្រើឧបាយនាំមេពពែនោះមកទៀត ពេលពពែញីមក អ្នកកុំប្រមាទ ចូរចាប់ឲ្យបាន ហើយទៅកាន់សម្នាក់ពពែញី ពោលថា នែសម្លាញ់ ការដែលនាងត្រឡប់មកនោះឯង ប្រយោជន៍បានកើតដល់ខ្ញុំ ព្រោះគ្រាន់តែនាងមកប៉ុណ្ណោះ ប្តីរបស់ខ្ញុំ ក៏ត្រឡប់បានស្មារតី គឺរស់ឡើងវិញ ឥឡូវនេះ ចូរនាងមក ទៅធ្វើបដិសណ្ឋារៈជាមួយប្តីរបស់ខ្ញុំចុះ ដូច្នេះហើយ ពោលគាថាទី ៥ ថា

> ម្នាលសម្លាញ់ សេចក្តីស្រឡាញ់របស់យើង សូមឲ្យមាននៅដដែល សូមនាងឲ្យរង្វាន់ដល់យើង ប្តីរបស់យើង រស់ដោយខ្លួនឯងវិញហើយ កាលបើខ្ញុំសួរអំពីសេចក្តីស្រឡាញ់ ហើយ ( គប្បីមកជាមួយនឹងយើង ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បុណ្ណាបត្តំ ទទាហិ មេ** សេចក្តីថា ចូរនាង

ឲ្យនូវការត្រេកអរដល់ខ្ញុំដែលមកហើយ ដើម្បីជនជាទីស្រឡាញ់ទាំងឡាយ ។ បទថា **បតិសញ្ញីវិតោ** សេចក្តីថា ប្តីរបស់យើងដឹងខ្លួនមកហើយ គឺក្រោកឡើងមកហើយ ជាអ្នកមិនមានរោគ ។ បទថា **ឯយ្យាសិ** សេចក្តីថា ចូរនាងមកជាមួយយើងចុះ ។

មេពពែគិតថា ចចកចោកទាបនេះ បំណងនឹងបោកអញ ធ្វើខ្លួនបដិបក្ខមិនសមគួរឡើយ អញនឹងប្រើឧបាយបញ្ឆោតចចកញីវិញ ដូច្នេះហើយពោលគាថាទី ៦ ថា

នែសម្លាញ់ របស់ជាទីស្រឡាញ់ ចូរមានដល់នាងដូចដែលចុះ
ឥឡូវ យើងឲ្យរង្វាន់ដល់នាងហើយ ( តែថា ) យើងនឹងមក
ជាមួយនឹងបរិវារច្រើន ( បើដូច្នោះ ) នាងចូររៀបភោជនទទួល
ផង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឯស្សំ** សេចក្តីថា ខ្ញុំនឹងមក កាលមក នឹងមកដោយបរិវារជាច្រើន សម្រាប់រក្សាខ្លួន ។ លំដាប់នោះ ទើបមេចចកសួរដល់បរិវាររបស់មេពពែ បានពោលគាថាទី ៧ ថា

បរិវាររបស់នាងដូចម្តេចទៅ ខ្ញុំនឹងរៀបភោជន ចាំទទួលពួកបរិវារ
របស់នាង បរិវារនាងទាំងអស់នោះ តើមានឈ្មោះដូចម្តេច
យើងសួរ នាងចូរប្រាប់នូវបរិវារនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តេ មេ** សេចក្តីថា ចូរនាងប្រាប់បរិវារទាំងនោះដល់យើង ។

កាលមេពពៃប្រាប់ បានពោលគាថាទី ៨ ថា

( ក្អែក ៤ ពួក ) គឺក្អែកឈ្មោះមាលិយៈ ១ ក្អែកឈ្មោះចតុរក្ខៈ ១ ក្អែកឈ្មោះបិដ្ឋិយៈ ១ ក្អែកឈ្មោះជម្ពុកៈ ១ ក្អែកបែបនេះ ជាបរិវារ របស់យើង នាងចូររៀបភោជនបម្រុងក្អែកទាំងនោះចុះ ដូច្នេះ ។

បទថា **មាលិយោ** ជាដើម ជាឈ្មោះរបស់ក្អែក ៤ ។ មេពពៃពោល ដូច្នេះហើយ ពោលបន្តថា បណ្តាក្អែកទាំងនោះ ក្អែកនីមួយៗ មានបរិវារ ៥០០ កាលបើដូច្នេះ ខ្ញុំមានសុខន ២០០០ ចោមរោមមក ដូច្នេះហើយ ពោលថា បើក្អែកទាំងនោះមិនបានភោជនាហារ ក៏នឹងសម្លាប់អ្នកទាំង ២ ស៊ីជាអាហារ ចចកបានស្តាប់ដូច្នោះហើយក៏ខ្លាច គិតថា មិនជាការសមគួរដែលមេពពៃនេះ ទៅក្នុងសម្នាក់របស់ប្តីអញ អញនឹងប្រើឧបាយធ្វើឲ្យមេពពៃនេះកុំទៅ ដូច្នេះ ហើយ ពោលគាថាទី ៩ ថា

កាលបើនាងចេញទៅអំពីផ្ទះ ទ្រព្យរបស់ មុខជាវិនាសមិនខាន ចាំយើងប្រាប់សេចក្តីមិនមានរោគដល់សម្លាញ់នាង ចូរនៅក្នុងទី នេះចុះ នាងកុំបាច់ទៅឡើយ ដូច្នេះ ។

អធិប្បាយអត្ថនៃគាថានោះដូច្នេះថា នែសម្លាញ់ ក្នុងផ្ទះរបស់នាង មាន ទ្រព្យច្រើន បើនាងចេញអំពីផ្ទះទៅ ទ្រព្យនោះ មិនមានអ្នកណាមើលថែ នឹង វិនាស ខ្ញុំនេះឯងនឹងប្រាប់វាចារបស់នាង ដែលជាសម្លាញ់ គឺជាមិត្រ មិនមាន សេចក្តីរង្កៀស ចូរនាងនៅទីនេះឯង កុំទៅឡើយ ។

កាលពោលយ៉ាងនេះហើយ មេចចកខ្លាចចំពោះមរណភ័យ ប្រញាប់ទៅកាន់សម្នាក់របស់ប្តី នាំប្តីគេចទៅទីដទៃ សត្វទាំង ២ មិនអាចមកទីនោះទៀត ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រជុំជាតកថា ក្នុងកាលនោះ តថាគតកើតជាទេវតាត្រង់ដើមឈើធំក្នុងទីនោះបានឃើញហេតុការណ៍នោះឯង ។៙

## អដ្ឋកថា បូតិមំសជាតក ចប់

# សុត្តន្តបិដក

## ឧច្ឆុរជាតក

[ ៦០៨ ] ( រុក្ខទេវតានិយាយនឹងមេទន្សេងថា ) តាបសណា ដែលនាងបានឲ្យអាហារ ហើយស៊ីកូនតូចៗ ដែលមិនបានប្រទូស្ត ( ដល់ខ្លួន ) នាងចូរខាំនូវតាបសនោះនឹងចង្កូម កុំឲ្យតាបសនោះរួច ( អំពីដៃ ) នាងមានជីវិតតទៅឡើយ ។

[ ៦០៩ ] ( មេទន្សេងតបនឹងទេវតាថា ) បុរសដែលមានសេចក្តីល្មោភខ្លាំង ដ៏ប្រឡាក់ប្រឡូសដូចជាកំណាត់សំពត់របស់មេនំ ខ្ញុំរមែងមិនឃើញនូវប្រទេសដ៏គួរ ហើយខាំដោយចង្កូមនោះបានឡើយ ។

[ ៦១០ ] បុគ្គលបើទុកជាឲ្យនូវសម្បត្តិលើផែនដីទាំងអស់ ដល់បុរសអកតញ្ញូ ដែលសម្លឹងឃើញទោសជានិច្ច ក៏នៅតែធ្វើបុរសនោះ ឲ្យត្រេកអរមិនបាន ។

[ ៦១១ ] ( សីហៈសួរថា ) នែអ្នកមានដើមដៃល្អ ចុះដូចម្តេចបានជាអ្នកប្រញាប់ប្រញាល់ ត្រឡប់មកជាមួយនឹងមាណពនេះ អ្នកមានកិច្ចជាប្រយោជន៍ ( ដោយមាណពនេះ ) ដូចម្តេចក្នុងទីនេះ ខ្ញុំសួរហើយ អ្នកចូរប្រាប់សេចក្តីនុ៎ះ ។

[ ៦១២ ] ( ខ្វា ... ) ទទាណាដែលជាសម្លាញ់របស់លោក មានសភាពជាសប្បុរស ខ្ញុំថប់តែបុរសនេះ សម្លាប់ទទានោះក្នុងថ្ងៃនេះឯង ខ្ញុំធ្លាប់បានឮអំពើរបស់បុរសនេះហើយ ទើបមិនសម្គាល់ថា ទទាបានសេចក្ដីសុខក្នុងថ្ងៃនេះឡើយ ។

[ ៦១៣ ] ( សីហៈ ... ) អ្នកធ្លាប់បានឮអំពើសម្រាប់ផ្គុំនូវជីវិតឲ្យប្រព្រឹត្តទៅរបស់បុរសនេះដូចម្ដេច មួយទៀត អ្នកធ្លាប់បានឮនូវពាក្យប្ដេជ្ញារបស់បុរសនេះដូចម្ដេច បានជាអ្នកថប់ក្រែងតែមាណពនេះសម្លាប់ទទា ។

[ ៦១៤ ] ( ខ្វា ... ) បុរសនេះធ្លាប់សន្សំធ្វើជំនួញក្នុងដែនកលិង្គៈ ទាំងធ្លាប់ដើរទៅមក តាមផ្លូវមានជន្លត់សម្រាប់ចរទៅមកតាមខ្សែផ្ដៅ ធ្លាប់សន្សំជាមួយនឹងពួករបាំ នឹងដាក់បង្កាត់ធ្លាប់លេងគុណដំបងក្នុងកណ្ដាលមហោស្រព ។

[ ៦១៥ ] បុរសនេះធ្លាប់ទាក់ពួកសត្វបក្សី ធ្លាប់វាល់ដោយរង្វាល់អាឡ្ហកៈ ធ្លាប់ដាក់ខ្នាច់ ( ឲ្យអ្នកលេងស្កា ) មានកិរិយាជាអ្នកសង្រួម តែប្រព្រឹត្តកន្លងនូវសីល ធ្លាប់ ( រកស៊ីសម្លាប់អ្នកទោស ) ធ្វើមិនឲ្យឈាមហូរចេញមួយតំណក់ ក្នុងកណ្ដាលរាត្រី

មានដៃរលាកដោយការទទួលនូវបិណ្ឌបាតដ៏ក្តៅ ( ក្នុងកាលដែលខ្វទនូវបួស ) ។

[ ៦១៦ ] ខ្ញុំបានឮនូវអំពើសម្រាប់ផ្គុំជីវិតឲ្យប្រព្រឹត្តទៅរបស់បុរសនេះ ( បែបនេះឯង ) នេះដូចជាដុំនៃរោម ( ទទានៅលើក្អួងសក់បុរសនេះ ) បុរសនេះ សម្លាប់នូវគោទាំងឡាយបានទៅហើយ ណាក៏មិនហ៊ានសម្លាប់នូវសត្វទទា ។

**ទទ្ទរជាតកទី ១២ ចប់**

## ឧទ្ទាននៃនវកនិបាតនោះ គឺ

និយាយអំពីត្មាតដ៏ប្រសើរ ១ ជនស្មើគ្នា ១ ហង្សដ៏ប្រសើរ ១ កំណប់ទ្រព្យ ១ ហរិតចកុមារ ១ អ្នករបាំឈ្មោះបាតលិកៈ ១ បុគ្គលមិនចាស់មិនស្លាប់ ១ ក្អែក ១ ការអត់ទ្រាំ ១ ( អ្នកទាំង ៣ នាក់មក ) ពីណា ១ ការក្រឡេកមើល ១ ទទា ១ រួមត្រូវជា ១២ ។

**នវកនិបាត ចប់**

# អដ្ឋកថា

## ឧច្ឆុរជាតក

[ ៦០៨-៦១៦ ] ព្រះសាស្តា កាលគង់នៅនាភ្នំគិជ្ឈកូដ ទ្រង់ប្រារព្ធទេវទត្ត ព្យាយាមផ្តាច់ព្រះជន្មព្រះអង្គ ទើបត្រាស់រឿងនេះ មានពាក្យផ្តើមថា **យោ តេ បុត្តកេ** ដូច្នេះជាដើម ។

មានសេចក្តីសង្ខេបថា សម័យនោះ ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ ទេវទត្តមិនមានខ្មាស មិនមែនជាសប្បុរស សេពគប់ព្រះបាទអជាសត្តុ ធ្វើឧបាយដើម្បីផ្តាច់ព្រះជន្មព្រះសម្មាសម្ពុទ្ធ ដែលទ្រទ្រង់នូវគុណដ៏ឧត្តម ដោយវិធីប្រកបនាយខ្មាន់ធ្នូ ប្រមៀលដុំថ្ម លែងដំរីនាឡាគិរី ។ ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដល់រឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងឥឡូវនេះប៉ុណ្ណោះទេ ដែលទេវទត្ត ព្យាយាមសម្លាប់តថាគត សូម្បីក្នុងកាលមុន ទេវទត្តក៏ព្យាយាមសម្លាប់តថាគតដូចគ្នាដូច្នេះហើយ ទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិក្នុងនគរពារាណសី អាចារ្យទិសាបាមោក្ខម្នាក់ បង្រៀនសិប្បៈដល់មាណព ៥០០ នៅក្នុងនគរពារាណសី ថ្ងៃមួយ គិតថា អញនៅក្នុងទីនេះ មាននូវកង្វល់ច្រើន មាណពទាំងឡាយ ក៏មិនសម្រេចការសិក្សា អញនឹងចូលព្រៃហិមពាន្ត នៅទីនោះបង្រៀនសិប្បៈ ។ អាចារ្យទិសាបាមោក្ខនោះប្រាប់ដល់មាណព ហើយឲ្យជញ្ជូន

ល្ង អង្ករ ប្រេង និងសំពត់ជាដើមចូលព្រៃ ឲ្យធ្វើបណ្ណសាលាក្នុងទីមិនឆ្ងាយអំពីផ្លូវ ពួកមាណពក៏ធ្វើតូបរៀងខ្លួន ពួកញាតិរបស់មាណពទាំងឡាយ ក៏បញ្ជូនប្រេង និងអង្ករជាដើម ឯអ្នកដែនក៏ពោលថា បានឮថា អាចារ្យទិសាបាមោក្ខនៅក្នុងព្រៃនោះ ឲ្យមាណពរៀនសិប្បៈ ដូច្នេះ ក៏នាំគ្នាដឹកអង្ករជាដើមទៅឲ្យ សូម្បីអ្នកដើរផ្លូវក៏នាំទៅឲ្យ បុរសម្នាក់បានឲ្យមេគោទឹកដោះ មួយអន្ទើដោយកូនគោ ដើម្បីជាប្រយោជន៍ដល់អាចារ្យទិសាបាមោក្ខបានផឹកទឹកដោះ ។ ក្នុងទីជិតបណ្ណសាលារបស់អាចារ្យ មានទន្សោងមួយ និងកូនខ្ទិមួយ ។ សូម្បីរាជសីហ៍ និងខ្លាធំ ក៏មកកាន់ទីបម្រើអាចារ្យនោះ ។ សត្វទទាមួយបានមកទីនោះជាប្រចាំ សត្វទទាបានឮសំឡេងអាចារ្យកំពុងប្រាប់មន្តដល់មាណពទាំងឡាយ ទើបរៀនវេទបានទាំង ៣ មាណពទាំងឡាយ ក៏បានស្និទ្ធស្នាលនឹងសត្វទទានោះ ។

ក្នុងកាលក្រោយមក មាណពទាំងឡាយ មិនទាន់សម្រេចការសិក្សា អាចារ្យបានស្លាប់ចោលទៅ ពួកមាណពនាំគ្នាបូជាសពអាចារ្យហើយ ពូនស្តូបដោយខ្សាច់ យកផ្កាផ្សេងៗ មកបូជា ហើយទ្រហោយំ ។ លំដាប់នោះ ទទាសួរមាណពទាំងនោះថា ពួកលោកយំអ្វី មាណពពោលថា ពួកយើងមិនទាន់សម្រេចការសិក្សា អាចារ្យក៏ស្លាប់ទៅ ដូច្នោះ ទើបពួកខ្ញុំយំ ទទាពោលថា បើដូច្នោះ ពួកលោកកុំទោមនស្សឡើយ ខ្ញុំនឹងប្រាប់សិប្បៈដល់ពួកលោក មាណពទាំងឡាយសួរថា អ្នកចេះអ្វីខ្លះ ទទាឆ្លើយថា កាលអាចារ្យកំពុងបង្រៀនដល់ពួកលោក ខ្ញុំបានស្តាប់ហើយ បានធ្វើត្រៃវេទឲ្យស្ទាត់ជំនាញហើយ

មាណពទាំងឡាយ បើដូច្នោះ ចូរអ្នកឲ្យពួកយើងដឹងនូវភាពដែលខ្លួនជាអ្នកស្ទាត់ជំនាញចុះ សត្វទទាពោលថា បើដូច្នោះ សូមពួកលោកស្តាប់ ហើយសូមឲ្យត្រៃវេទដែលពួកមាណពទាំងនោះមិនស្ទាត់ជំនាញ ដូចខ្សែទឹកដែលធ្លាក់ចុះមកអំពីកំពូលភ្នំ ដូច្នោះ មាណពទាំងឡាយក៏ត្រេកអរ រៀនសិប្បៈក្នុងសម្នាក់ទទាដែលជាបណ្ឌិតនោះ សត្វទទាបានតាំងនៅក្នុងឋានៈជាអាចារ្យទិសាបាមោក្ខប្រាប់សិប្បៈដល់មាណពទាំងនោះ ពួកមាណពបានធ្វើទ្រុងមាសដល់សត្វទទាចងពិតានខាងលើ នាំទឹកឃ្មុំ និងលាជជាដើម ដាក់ចានមាសឲ្យសត្វទទាបូជាដោយផ្កាច្រើនប្រភេទ ធ្វើមហាសក្ការៈ ដំណឹងសត្វទទាប្រាប់មន្តដល់មាណព ៥០០ ក្នុងព្រៃ ល្បីសុសសាយពេញជម្ពូទ្វីប ។

កាលនោះ មហាជនក្នុងជម្ពូទ្វីប បានប្រកាសលេងមហោស្រពដ៏ធំ ដូចមហោស្រពដែលលេងលើកំពូលភ្នំ ។ ឪពុកម្តាយរបស់មាណពទាំងឡាយ បានបញ្ជូនដំណឹងដល់កូនថា ចូរមកមើលមហោស្រព មាណពទាំងឡាយលាទទាហើយនាំគ្នាបិទបាំងសត្វទទាដែលជាបណ្ឌិត ទន្សង និងសត្វទាំងអស់ មិនឲ្យអ្នកណាឃើញ ហើយទៅកាន់នគររៀងៗ ខ្លួន ។ ក្នុងកាលនោះ មានតាបសអាក្រក់ មិនមានករុណាម្នាក់ ត្រាច់ទៅកាន់ទីផ្សេងៗ មកដល់ទីនោះ ទន្សងឃើញតាបស ក៏ចេញមកធ្វើបដិសណ្ឋារៈ ពោលថា អង្ករមានក្នុងទីនោះ ប្រេងនៅក្នុងទីនោះជាដើម សូមលោកម្ចាស់ចម្អិនឆាន់ចុះ ដូច្នេះហើយ ក៏ទៅរកអាហារ តាបសដាំបាយអំពីព្រលឹម សម្លាប់កូនទទ្សងពីរធ្វើម្ហូប លុះដល់ពេលថ្ងៃត្រង់ សម្លាប់ទទាដែលជាបណ្ឌិត និងកូនគោបរិភោគ ពេលល្ងាច ឃើញ

មេគោដើរមក ក៏សម្លាប់មេគោនោះស៊ីសាច់ ហើយទៅដេកលក់ស្រមុកត្រង់ដើមឈើ ។ ទន្សោងមកក្នុងវេលាល្ងាច មិនឃើញកូនទាំង ២ ក៏ដើររក រុក្ខទេវតាសម្លឹងមើលទន្សោង ដែលមិនបានជួបកូន មានការញាប់ញ័រ ទើបបង្ហាញកាយឲ្យប្រាកដត្រង់ព្រង់ឈើ ដោយទិព្វានុភាព ហើយពោលថា នែទន្សោងអ្នកកុំញាប់ញ័រឡើយ កូនតូចរបស់នាង ទទា កូនគោ និងមេគោ ត្រូវបុរសអាក្រក់នេះសម្លាប់ហើយ ចូរនាងខាំកវាឲ្យស្លាប់ ដូច្នេះហើយ ពោលគាថាទី ១ ថា

តាបសណា ដែលនាងបានឲ្យអាហារ ហើយស៊ីកូនតូចៗ ដែលមិនបានប្រទូស្ត ( ដល់ខ្លួន ) នាងចូរខាំនូវតាបសនោះនឹងចង្កូមកុំឲ្យតាបសនោះរួច ( អំពីដៃ ) នាង មានជីវិតតទៅឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ទិន្នភត្តោ** បានដល់ បុគ្គលដែលនាងឲ្យភត្តដោយពោលថា សូមលោកម្ចាស់ជាំភត្តឆាន់ចុះ ដូច្នេះ ។ បទថា **អទូសកេ** បានដល់ ដែលមិនមានទោស គឺប្រាសចាកកំហុស ។ បទថា **តស្មឹ ទាឋា** អធិប្បាយថា ចូរនាងដាក់ចង្កូមទាំង ៤ លើ-កបុគ្គលអាក្រក់ ។ បទថា **មា តេ មុញ្ចិត្ថ ជីវតោ** សេចក្តីថា នាងកុំដោះលែងបុគ្គលអាក្រក់នោះ ឲ្យផុតពីកណ្តាប់ដៃ ឲ្យវារស់នៅ គឺឲ្យមានជីវិតឡើយ អធិប្បាយថា ឥសីនេះកុំបីផុត ចូរនាងឲ្យវាដល់នូវការអស់ជីវិតទៅ ។ លំដាប់នោះ ទន្សោងបានពោលគាថា ២ ថា

បុរសដែលមានសេចក្តីល្មោភខ្លាំង ដ៏ប្រឡាក់ប្រឡូស ដូចជា
កំណាត់សំពត់របស់មេទំ ខ្ញុំរមែងមិនឃើញនូវប្រទេសដ៏គួរ
ហើយខាំដោយចង្កូមនោះបានឡើយ ។

បុគ្គល បើទុកជាឲ្យនូវសម្បត្តិលើផែនដីទាំងអស់ ដល់បុរស
អកតញ្ញូ ដែលសម្លឹងឃើញទោសជានិច្ច ក៏នៅតែធ្វើបុរសនោះ
ឲ្យត្រេកអរមិនបាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អាកិណ្ណលុទ្ធោ** បានដល់ ដែលមានភាព
អាក្រក់ដ៏ខ្លាំងក្លា ។ បទថា **វិវរេសិនោ** បានដល់ អ្នកស្វែងរកឱកាស គឺ
ទោស ។ ដោយបទថា **នេវ នំ អភិរាធយេ** ទន្សោងសម្តែងថា ទោះបីឲ្យនូវ
សម្បត្តិទាំងផែនដី ក៏មិនអាចឲ្យបុគ្គលបែបនេះត្រេកអរបាន នឹងពោលថ្វីដល់
ខ្ញុំ ដែលឲ្យត្រឹមតែកត្តាហារ ។

ទន្សោងពោលយ៉ាងនេះហើយ គិតថា បុរសនេះភ្ញាក់ឡើង គង់នឹងសុីអញ
ដើម្បីរក្សាជីវិតរបស់ខ្លួន ទើបគេចទៅ ។ រាជសីហ៍ និងខ្លាធំ ក៏ជាសម្លាញ់
របស់សត្វទោ ជួនកាល សត្វទាំងនោះ ក៏នាំគ្នាមកសួរសុខទុក្ខសត្វទោ ជួន
កាល សត្វទោក៏ទៅសម្តែងធម៌ដល់សត្វទាំង ២ ហើយត្រឡប់មក ក្នុងថ្ងៃ
នោះ រាជសីហ៍ពោលនឹងខ្លាធំថា នែសម្លាញ់ អញខានសួរសុខទុក្ខសត្វទោ
យូរហើយ មកដល់នឹងថ្ងៃនេះ ៧-៨ ថ្ងៃហើយ ចូរឯងទៅស្តាប់ដំណឹងរបស់
សត្វទោនោះសិន ហើយសឹមមក ។ ខ្លាធំទទួលពាក្យថា សាធុ ហើយទៅ
ដល់ទីនោះ ក្នុងកាលដែលទន្សោងគេចទៅហើយ ឃើញឥសីនោះកំពុងដេកលក់

រោមរបស់ទេវតាដែលជាបណ្ឌិត ជាប់ក្នុងរវាងជដារបស់បុរសនោះ ឆ្អឹងមេគោនិងកូនគោ ក៏នៅប្រាកដ ស្តេចខ្លាឃើញហេតុការណ៍ទាំងអស់នោះ មិនឃើញសត្វទេវតាដែលជាបណ្ឌិតក្នុងទ្រុងមាស គិតថា បុរសនេះគង់សម្លាប់សត្វទាំងនោះ ទើបដាស់បុរសនោះឲ្យក្រោកឡើង តាបសអាក្រក់ឃើញដូច្នោះហើយមានការភិតភ័យក្រៃលែង ។ លំដាប់នោះ ខ្លាធំសួរតាបសនោះថា លោកសម្លាប់សត្វទាំងនេះបរិភោគឬ កាលបានទទួលពាក្យថា យើងមិនបានសម្លាប់ យើងមិនបានទំពាស៊ីទេ ដូច្នេះ ទើបពោលថា នែបុរសលាមក បើឯងមិនសម្លាប់ អ្នកដទៃណានឹងសម្លាប់ ចូរប្រាប់មកចុះ បើមិនប្រាប់ ឯងនឹងស្លាប់ តាបសនោះខ្លាចមរណភ័យ ទើបពោលថា ត្រូវហើយ ខ្ញុំសម្លាប់កូនទទន្សង កូនគោ និងមេគោ បរិភោគហើយ តែមិនបានសម្លាប់សត្វទេវតា ទោះជាតាបសនោះពោលច្រើនយ៉ាងណា ខ្លាធំក៏មិនជឿ ទើបសួរថា ឯងមកពីណា កាលតាបសនោះប្រាប់កម្មដែលខ្លួនធ្វើទាំងអស់ថា ខ្ញុំនាំទំនិញរបស់ពួកឈ្មួញអ្នកកលិង្គរដ្ឋ ទៅធ្វើការងារយ៉ាងនេះខ្លះ យ៉ាងនោះខ្លះ ដើម្បីចិញ្ចឹមជីវិត ឥឡូវនេះមកដល់ទីនេះ ដូច្នេះ ទើបពោលថា នែមនុស្សលាមក បើឯងមិនសម្លាប់សត្វទេវតា អ្នកដទៃណានឹងសម្លាប់ មកយើងនាំឯងទៅកាន់សម្នាក់រាជសីហ៍ ដែលជាស្តេចសត្វ ហើយឲ្យតាបសនោះដើរពីមុខ ដើរបណ្តើរសម្លុតបណ្តើរទៅ ។

ស្តេចរាជសីហ៍ ឃើញស្តេចខ្លានាំតាបសនោះមក កាលនឹងសាកសួរស្តេចខ្លា ទើបពោលគាថាទី ៤ ថា

នៃអ្នកមានដើមដៃល្អ ចុះដូចម្ដេច បានជាអ្នកប្រញាប់ប្រញាល់
ត្រឡប់មកជាមួយនឹងមាណពនេះ អ្នកមានកិច្ចជាប្រយោជន៍
( ដោយមាណពនេះ ) ដូចម្ដេចក្នុងទីនេះ ខ្ញុំសួរហើយ អ្នកចូរ
ប្រាប់សេចក្ដីនុ៎ះ ដូច្នេះ ។

ក្នុងគាថានោះ ស្ដេចរាជសីហ៍រាក់ទាក់ស្ដេចខ្លាធំ ដោយឈ្មោះថា នៃសុពាហុ ។ ឈ្មោះថា **សុពាហុ** ព្រោះកាយខាងមុខរបស់ស្ដេចខ្លា ជាទីពេញចិត្ត ដូច្នោះ ទើបស្ដេចរាជសីហ៍ពោលយ៉ាងនោះនឹងស្ដេចខ្លាធំនោះ ។ បទថា **កឹ កិច្ចមត្ថំ ឥធមត្ថិ តុយ្ហំ** សេចក្ដីថា ករណីយកិច្ចដែលប្រកបដោយប្រយោជន៍ មានជាមួយមាណពនេះ ក្នុងទីនេះឬ ។ បាឋៈថា **តុយ្ហំ កឹ កិច្ចមត្ថំ** ក៏មាន អត្ថក៏យ៉ាងនោះដូចគ្នា ។ ស្ដេចខ្លាបានស្ដាប់ដូច្នោះ បានពោលគាថាទី ៥ ថា

ទទាណាដែលជាសម្លាញ់របស់លោក មានសភាពជាសប្បុរស
ខ្ញុំថប់តែបុរសនេះ សម្លាប់ទទានោះ ក្នុងថ្ងៃនេះឯង ខ្ញុំធ្លាប់បានឮ
អំពើរបស់បុរសនេះហើយ ទើបមិនសម្គាល់ថា ទទាបានសេចក្ដី
សុខក្នុងថ្ងៃនេះឡើយ ដូច្នេះ ។

សត្វទទាឈ្មោះថាទទ្ទរក្នុងគាថានោះ ។ បទថា **តស្ស វធំ** សេចក្ដីថា ខ្ញុំសង្ស័យថា សត្វទទាជាបណ្ឌិតនោះ ត្រូវបុរសនេះសម្លាប់ ក្នុងថ្ងៃនេះឯង ។ បទថា **ជាហំ សុខឹ** សេចក្ដីថា ខ្ញុំមិនបានសម្គាល់ថា សត្វទទាមានសេចក្ដីសុខ គឺមិនមានរោគក្នុងថ្ងៃនេះ ។

ស្ដេចរាជសីហ៍កាលសួរស្ដេចខ្លា បានពោលគាថាទី ៦ ថា អ្នកធ្លាប់បានឮអំពើសម្រាប់ផ្គុំនូវជីវិត ឲ្យប្រព្រឹត្តទៅរបស់បុរសនេះដូចម្ដេច មួយទៀត អ្នកធ្លាប់បានឮនូវពាក្យប្ដេជ្ញារបស់បុរសនេះដូចម្ដេច បានជាអ្នកថប់ក្រែងតែមាណពនេះសម្លាប់ទទា ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អស្សុ** ស្មើគ្នានឹង **អស្សោសិ** ប្រែថា បានស្ដាប់ ។ បទថា **វុត្តិសមោធានតាយ** បានដល់ ក្នុងការប្រព្រឹត្តចិញ្ចឹមជីវិត អធិប្បាយថា បុរសនេះ បានប្រាប់ការងារអ្វីរបស់ខ្លួនដល់អ្នក ។ បទថា **មាណវេន** សេចក្ដីថា អ្នកបានស្ដាប់ប្ដេជ្ញាដូចម្ដេច ទើបសង្ស័យថា សត្វទទាត្រូវមាណពនេះសម្លាប់នោះ ។

លំដាប់នោះ ស្ដេចខ្លា កាលពោលដល់ស្ដេចរាជសីហ៍ បានពោលគាថាដ៏សេសថា

បុរសនេះ ធ្លាប់សន្សំធ្វើជំនួញក្នុងដែនកលិង្គៈ ទាំងធ្លាប់ដើរទៅមក តាមផ្លូវ មានជន្លត់សម្រាប់ចរទៅមកតាមខ្សែផ្ដៅ ធ្លាប់សន្សំជាមួយនឹងពួករបាំ និងដាក់បង្ហាត់ ធ្លាប់លេងគុណដំបងក្នុងកណ្ដាលមហោស្រព ។

បុរសនេះ ធ្លាប់ទាក់ពួកសត្វបក្សី ធ្លាប់វាល់ដោយរង្វាល់អាឡ្ហកៈ ធ្លាប់ដាក់ខ្នាច់ ( ឲ្យអ្នកលេងស្កា ) មានកិរិយាជាអ្នកសង្រួម តែប្រព្រឹត្តកន្លងនូវសីល ធ្លាប់ ( រកស៊ីសម្លាប់អ្នកទោស ) ធ្វើមិនឲ្យឈាមហូរចេញមួយតំណក់ ក្នុងកណ្ដាលរាត្រី

មានដៃរលាកដោយការទទួលនូវបិណ្ឌបាតដ៏ក្ដៅ ( ក្នុងកាលដែលខ្ញុំនៅបួស ) ។

ខ្ញុំបានឮនូវអំពើសម្រាប់ផ្គុំជីវិតឲ្យប្រព្រឹត្តទៅ របស់បុរសនេះ ( បែបនេះឯង ) នេះដូចជាដុំនៃរោម ( ទទានៅលើក្នុងសក់បុរសនេះ ) បុរសនេះ សម្លាប់នូវគោទាំងឡាយបានទៅហើយ ណាក៏មិនហ៊ានសម្លាប់នូវសត្វទទា ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ចិណ្ណា កលិង្គា** សេចក្ដីថា បានឮថា ការលក់ដូរក្នុងកលិង្គរដ្ឋ បុរសនេះជញ្ជូនទំនិញរបស់ឈ្មួញទៅ បានសន្សំប្រព្រឹត្តមកហើយ គឺធ្វើមកហើយ ។ បទថា **វេត្តាចរោ** បានដល់ ត្រាច់ទៅដោយការផ្ដៅ ។ បទថា **សង្កុបថោបិ ចិណ្ណោ** បានដល់ សូម្បីផ្លូវដែលមានជង្គត់គេក៏បានប្រើមកហើយ ។ បទថា **នដេហិ** បានដល់ រួមជាមួយអ្នករបាំទាំងឡាយ ដើម្បីចិញ្ចឹមជីវិត ។ បទថា **ចិណ្ណំ សហ វាកុរេហិ** សេចក្ដីថា គាត់នាំអន្ទាក់ទៅប្រព្រឹត្តជាមួយអ្នកមានអន្ទាក់ ។ បទថា **ទណ្ឌេន យុទ្ធំ** សេចក្ដីថា បានឮថា សូម្បីការវាយគ្នាដោយដំបង គេក៏ធ្លាប់ច្បាំងមកហើយ ។ បទថា **ពទ្ធា កុលិកា** សេចក្ដីថា បានឮថា សូម្បីបក្សីទាំងឡាយ គេក៏ធ្លាប់ទាក់មកហើយ ។ បទថា **មិតមាឡ្ហកេន** សេចក្ដីថា សូម្បីការវាល់ស្រូវគេក៏ធ្លាប់ធ្វើមកហើយ ។ បទថា **អក្ខា ជិតា** សេចក្ដីថា សូម្បីការលេងបាស្កា គេក៏បានតាំងឲ្យអ្នកលេងបាស្កាលេងជាមួយគ្នា ។ បទថា **សញ្ញមោ អព្ភតីតោ** សេចក្ដីថា ការសង្រួមក្នុងសីល ដែលគេបួសចិញ្ចឹមជីវិតឈាន

កន្ទុងហើយ ។ បទថា **អប្បហិតំ** បានដល់ ឃាត់ហើយ គឺធ្វើមិនឲ្យហូរចេញ ។ លោហិត ឈ្មោះថា **ពុប្ផក។** សេចក្តីនេះ មានអធិប្បាយថា បានឮថា បុរសនេះកាត់ដៃ និងជើងរបស់អ្នកទោសដែលខុស ចំពោះព្រះរាជាអាស្រ័យចិញ្ចឹមជីវិត ហើយនាំមនុស្សទាំងនោះមកឲ្យដេក នៅត្រង់សាលាលុះពេលយប់ ទើបទៅត្រង់សាលានោះ ហើយដាក់ ថ្នាំឈ្មោះ កណ្ឌធូម ឃាត់ ឈាមដែលហូរឲ្យឈប់បាន ។ បទថា **ហត្ថា ទឌ្ឍា** សេចក្តីថា បានឮថា ក្នុងកាលដែលបុរសនេះបួសជាអាជីវក ដៃទាំង ២ របស់គេក៏ក្តៅ ព្រោះទទួលដុំបាយដែលក្តៅ ។ បទថា **តានិស្ស កម្មាយតនានិ** បានដល់ ហេតុទាំងនោះ ដែលទាក់ទងដោយការធ្វើរបស់បុរសនោះ ។ បទថា **អស្ស** ស្មើគ្នានឹង **អស្សោសិ** ប្រែថា បានស្តាប់ហើយ ។ បទថា **យថា អយំ** សេចក្តីថា សូម្បីសំណុំរោមនៃសត្វទទានោះ គង់ប្រាកដក្នុងជដារបស់បុរសនេះ ដោយហេតុនេះ ទើបខ្ញុំដឹងសេចក្តីនោះថា បុរសនេះឯង សម្លាប់សត្វទទានោះ ។ បទថា **គាវោ ហនា កឹ បន ឧទ្ធរស្ស** សេចក្តីថា សូម្បីគោទាំងឡាយ បុរសនេះ ក៏បានសម្លាប់ហើយ តើសត្វទទា មិនត្រូវបុរសនេះសម្លាប់ នឹងមានដូចម្តេច ព្រោះដូច្នោះ បុរសនេះ ពិតជាសម្លាប់សត្វទទា ។

រាជសីហ៍សួរបុរសនោះថា ឯងសម្លាប់ទទាដែលជាបណ្ឌិតឬ បុរសនោះឆ្លើយថា ពិតហើយ រាជសីហ៍បានស្តាប់ពាក្យតាបសទទួលតាមពិត ក៏គិតនឹងដោះលែងតាបសនោះទៅ តែស្តេចខ្លាពោលថា មនុស្សអាក្រក់បែបនេះ គួរឲ្យស្លាប់សិន ហើយក៏ខាំតាបសនោះដោយចង្កូមឲ្យស្លាប់ ហើយកាយជីកប់

ក្នុងទីនោះឯង ។ មាណពទាំងឡាយមក មិនឃើញទេវតាដែលជាបណ្ឌិត ក៏នាំគ្នាទ្រហោងយំ ហើយត្រឡប់ទៅ ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងកាលមុនទេវទត្ត ក៏ព្យាយាមសម្លាប់តថាគតយ៉ាងនេះ ទ្រង់ប្រជុំជាតកថា ជដិលលាមកក្នុងកាលនោះ បានមកជាទេវទត្តក្នុងកាលឥឡូវនេះ ទន្សេញបានមកជាកិសាគោតមី ខ្លាធំបានមកជាមោគ្គល្លាន រាជសីហ៍បានមកជាសារីបុត្រ អាចារ្យទិសាមោក្ខបានមកជាកស្សបៈ ឯទេវតាដែលជាបណ្ឌិត គឺតថាគតនេះឯង ៗ៚

**អដ្ឋកថា ឧទ្ទុរជាតក ចប់**

**នវកនិបាត ចប់**

# សុត្តន្តបិដក

# ទសកនិបាត

## ចតុទ្វារជាតក

[ ៦១៧ ] ( មិត្តវិន្ទុកៈ សួររុក្ខទេវតាថា ) ក្រុងនេះមានទ្វារ ៤ ជាវិការនៃដែក មានកំពែងដ៏មាំ ខ្ញុំត្រូវកំពែងព័ទ្ធជាប់ជុំវិញ តើខ្ញុំបានធ្វើបាបអ្វី ។

[ ៦១៨ ] ទ្វារទាំងអស់បិទជិត ខ្ញុំក៏ជាប់នៅដូចជាសត្វស្លាប ( ជាប់នៅក្នុងទ្រុង ) បពិត្រយក្ខ ហេតុដូចម្តេច ទើបខ្ញុំត្រូវចក្រវិលសង្កិន ។

[ ៦១៩ ] ( រុក្ខទេវតា ... ) អ្នកបានទ្រព្យជាង ២០ សែន មិនធ្វើតាមពាក្យរបស់ញាតិទាំងឡាយ ដែលជាអ្នកជួយអនុគ្រោះដោយល្អ ។

[ ៦២០ ] អ្នកស្ទុះលឿនទៅកាន់ទូកដែលអណ្តែតទៅកាន់សមុទ្រសាគរ ជាទីសម្រេចប្រយោជន៍តិច បាននាងវេមានិកប្រេត ៤ នាក់ នាងវេមានិកប្រេត ៨ នាក់ លុះចេញអំពីវេមានិកប្រេត

៨ នាក់ ក៏បាននាងវេមានិកប្រេត ១៦ នាក់ ។

[ ៦២១ ] អ្នកចេញអំពីនាងវេមានិកប្រេត ១៦ នាក់ ក៏បាននាងវេមានិកប្រេត ៣២ នាក់ អ្នកជាមនុស្សមានសេចក្តីប្រាថ្នាដ៏លើសលុប បានមកប្រទះនឹងចក្រ ទាំងចក្រក៏វិលកិននូវអម្បែងក្បាលនៃបុរសដែលមានសេចក្តីប្រាថ្នាគ្របសង្កត់ ។

[ ៦២២ ] សេចក្តីប្រាថ្នា ជាធម្មជាតដ៏ទូលាយលើសលុប ដែលគេបំពេញបានដោយក្រ ជាផ្លូវដល់នូវសេចក្តីវិបត្តិ ព្រោះសេចក្តីប្រាថ្នា ពួកជនណា ត្រេកអរតាមសេចក្តីប្រាថ្នានោះ ពួកជននោះ រមែងជាអ្នកទ្រទ្រង់នូវចក្រ ។

[ ៦២៣ ] ពួកជនណា មិនពិចារណានូវផ្លូវនេះ ដូចជាអ្នកលះបង់នូវទ្រព្យច្រើន មិនពិចារណានូវផ្លូវ ( ដែលខ្លួនត្រូវដើរទៅ ) ពួកជននោះ រមែងជាអ្នកទ្រទ្រង់នូវចក្រ ។

[ ៦២៤ ] បុគ្គលគប្បីពិចារណា នូវកិច្ចការដែលត្រូវធ្វើ និងភោគៈដ៏ច្រើន ហើយមិនគប្បីគប់រកនូវសេចក្តីប្រាថ្នា ដែលមិនប្រកបដោយប្រយោជន៍ ធ្វើតាមពាក្យរបស់ពួកជនអ្នកអនុគ្រោះ ចក្រមិនគប្បីវិលសង្កិនបុគ្គលបែបនោះបាន ។

[ ៦២៥ ] ( មិត្តវិន្ទុកៈ ... ) បពិត្រយក្ខ ចក្រនឹងបិតនៅលើក្បាលរបស់ខ្ញុំអស់កាលយូរប៉ុន្មានឆ្នាំ ប៉ុន្មានពាន់ឆ្នាំ ខ្ញុំសួរហើយ សូមលោកប្រាប់ហេតុនោះ ។

[ ៦២៦ ] ( រុក្ខទេវតា ... ) ម្នាលមិត្តវិន្ទុកៈ អ្នកចូរនឹករឭកឲ្យក្រៃលែង នឹករឭកឲ្យខ្ជាប់ ហើយចូរស្តាប់នូវពាក្យយើង ចក្រ ( នេះ ) វិលកិនក្បាលរបស់អ្នក អ្នកកាលរស់នៅ រមែងមិនទាន់រួចទេ ។

**បតុទ្វារជាតកទី ១ ចប់**

# អដ្ឋកថា
# ទសកនិបាត

## ចតុទ្វារជាតក

[ ៦១៧-៦២៦ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុប្រដៅក្រមួយរូប ទើបត្រាស់រឿងនេះ មានពាក្យផ្តើមថា **ចតុទ្វារមិទំ នគរំ** ដូច្នេះជាដើម ។

រឿងក្នុងបច្ចុប្បន្ន បណ្ឌិតគប្បីឲ្យពិស្តារក្នុងជាតករឿងទី ១ ក្នុងនវកនិបាត សម្រាប់ក្នុងទីនេះ មានសេចក្តីថា ព្រះសាស្តាកាលសួរដល់ភិក្ខុរូបនោះថា ម្នាលភិក្ខុ បានឮថា អ្នកប្រដៅក្រពិតឬ កាលភិក្ខុនោះក្រាបទូលថា ករុណាព្រះអង្គ ពិតមែន ទើបត្រាស់ថា ម្នាលភិក្ខុ ក្នុងកាលមុន អ្នកក៏មិនស្តាប់ពាក្យរបស់បណ្ឌិត ទៅត្រេកអរនឹងខុរចក្រ ព្រោះជាអ្នកប្រដៅក្រដូច្នេះហើយ ទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល ក្នុងសាសនាព្រះកស្សបទសពល ក្នុងនគរពារាណសី សេដ្ឋីមានទ្រព្យ ៨០ កោដិ មានកូនប្រុសម្នាក់ ឈ្មោះមិត្តវិន្ទុកៈ មាតាបិតារបស់មិត្តវិន្ទុកៈនោះ ជាព្រះសោតាបន្ន តែមិត្តវិន្ទុកៈជាបុគ្គលទ្រុស្តសីល មិនមានសទ្ធា ។

តមក កាលបិតាស្លាប់ហើយ មាតាសម្លឹងមើលទ្រព្យសម្បត្តិ ថ្ងៃមួយ

ពោលនឹងបុរសនោះថា កូនជាទីស្រឡាញ់ ភាពជាមនុស្ស ជារបស់បានដោយកម្រ ឯងក៏បានហើយ ចូរឯងធ្វើទានរក្សាសីល ធ្វើឧបោសថកម្ម ស្តាប់ធម៌ចុះ ។ មិត្តវិន្ទុកៈពោលថា បពិត្រអ្នកម៉ែ ទានជាដើម មិនជាប្រយោជន៍ដល់ខ្ញុំទេ ម៉ែកុំពោលនឹងខ្ញុំ ខ្ញុំនឹងទៅតាមយថាកម្ម ។ ថ្ងៃមួយ ជាថ្ងៃបុណ្ណមីឧបោសថ មាតាបានពោលនឹងបុរសនោះថា កូនជាទីស្រឡាញ់ ថ្ងៃនេះ ជាថ្ងៃអភិលក្ខិតសមយមហាឧបោសថ ចូរបាសមាទានឧបោសថ ទៅវិហារស្តាប់ធម៌មួយរាត្រី ហើយសឹមមក ម៉ែនឹងឲ្យទ្រព្យដល់ឯង ១០០០ បុរសនោះទទួលពាក្យថា សាធុ ហើយសមាទានឧបោសថ ព្រោះចង់បានទ្រព្យ លុះបរិភោគអាហារព្រឹកហើយ ទៅកាន់វិហារអស់មួយថ្ងៃ ហើយដេកលក់ក្នុងទីមួយអស់មួយយប់ ដោយអាការនៃធម៌ សូម្បីតែមួយបទ មិនបានប៉ះដល់ត្រចៀក ។ ស្អែកឡើង បុរសនោះលុបមុខ ទៅអង្គុយត្រង់ផ្ទះ អំពីព្រលឹមនោះឯង ឯមាតារបស់បុរសនោះ គិតថា ថ្ងៃនេះ កូនរបស់អញស្តាប់ធម៌ នឹងនាំព្រះថេរៈដែលជាធម្មកថិក មកអំពីព្រលឹមនោះឯង ទើបតាក់តែងបបរជាដើម ហើយក្រាលអាសនៈរង់ចាំ កាលឃើញបុរសនោះមកតែឯង ទើបសួរថា កូនជាទីស្រឡាញ់ ឯងមិនបាននាំព្រះធម្មកថិកមកទេឬ កាលបុរសនោះពោលថា ខ្ញុំមិនត្រូវការព្រះធម្មកថិក ទើបពោលថា បើដូច្នោះ ចូរកូនបរិភោគបបរចុះ បុរសនោះពោលថា ម៉ែទទួលថា ឲ្យទ្រព្យ ១០០០ ដល់ខ្ញុំ សូមម៉ែឲ្យទ្រព្យ ១០០០ ដល់ខ្ញុំសិន ខ្ញុំនឹងបរិភោគក្នុងកាលជាក្រោយ មាតាពោលថា កូនជាទីស្រឡាញ់ ចូរអ្នកបរិភោគសិនចុះ ម៉ែនឹងឲ្យក្នុងកាលជា

ក្រោយ បុរសនោះពោលថា បានទ្រព្យសិន ទើបខ្ញុំបរិភោគ ។ លំដាប់នោះ មាតាបានយកកញ្ចប់ទ្រព្យ ១០០០ ដាក់ពីមុខបុរសនោះៗ បរិភោគបបរហើយ កាន់យកកញ្ចប់ទ្រព្យ ១០០០ ទៅធ្វើជំនួញ មិនយូរប៉ុន្មានទ្រព្យក៏កើនឡើង ដល់មួយសែនពីរម៉ឺន ។ លំដាប់នោះ គាត់មានគំនិតដូច្នេះថា អញនឹងចុះសំពៅ ធ្វើនូវការជួញដូរ ។ កាលបុរសនោះកក់ថ្លៃសំពៅហើយ បានពោលនឹងមាតា ថា បពិត្រអ្នកម៉ែ ខ្ញុំនឹងធ្វើការជួញដូរតាមសំពៅ គ្រានោះ មាតាឃាត់ថា នែ កូន ឯងជាកូនតែមួយរបស់ម៉ែ ហើយក្នុងផ្ទះនេះ ទ្រព្យក៏មានច្រើន សមុទ្រ មានទោស មិនមែនតិច ឯងកុំទៅឡើយ ។ បុរសនោះពោលថា ខ្ញុំនឹងទៅ ឲ្យបាន ម៉ែមិនមានអំណាចនឹងឃាត់ខ្ញុំឡើយ កាលមាតាពោលថា នែកូន ម៉ែ ត្រូវហាមកូន ហើយចាប់ដៃ បុរសនោះក៏រលាស់មាតាឲ្យដួល ហើយលោត កន្លងទៅ ចុះទូកទៅកាន់មហាសមុទ្រ ។

លុះដល់ថ្ងៃទី ៧ សំពៅបានកឿងនៅកណ្ដាលសមុទ្រ ព្រោះមិត្តវិន្ទុកៈ ជាហេតុ ។ ស្លាកកាឡកិណីដែលឲ្យចាប់ បានធ្លាក់ក្នុងដៃមិត្តវិន្ទុកៈរហូតដល់ ៣ ដង កាលនោះ ជនដែលទៅជាមួយគ្នា ចងក្បូនឲ្យមិត្តវិន្ទុកៈ ហើយបោះ ទៅក្នុងសមុទ្រ ដោយគិតឃើញរួមគ្នាថា ជនជាច្រើន កុំបីវិនាស ព្រោះអា-ស្រ័យមិត្តវិន្ទុកៈនេះតែម្នាក់ឡើយ រំពេចនោះឯង សំពៅក៏បានរសាត់ទៅក្នុង មហាសមុទ្រដោយរហ័ស ។ មិត្តវិន្ទុកៈដេកក្នុងក្បូន អណ្ដែតទៅដល់កោះ មួយ ។ លើកោះតូចនោះ គេបានជួបស្រី គឺវេមានិកប្រេត ៤ នាក់ នៅក្នុង វិមានកែវផលិក ប្រេតទាំងនោះសោយទុក្ខ ៧ ថ្ងៃ សោយសុខ ៧ ថ្ងៃ មិត្ត-

វិន្ទុកៈបានសោយទិព្វសម្បត្តិជាមួយវេមានិកប្រេតទាំងនោះ ៧ ថ្ងៃ ក្នុងវារៈដែលសុខ លុះដល់វារៈដែលស្រីនោះត្រូវទៅទទួលទុក្ខ ស្រីទាំង ៤ បានប្រាប់ថា នែអ្នក ពួកខ្ញុំនឹងមកក្នុងថ្ងៃទី ៧ អ្នកកុំអផ្សុកឡើយ ចូរនៅក្នុងទីនេះទម្រាំពួកខ្ញុំមក ដូច្នេះហើយ នាំគ្នាទៅ ។ មិត្តវិន្ទុកៈ ជាបុគ្គលធ្លាក់នៅក្នុងអំណាចនៃតណ្ហា ចុះដេកលើក្បូននោះ អណ្តែតទៅតាមផ្ទៃសមុទ្រទៀត ដល់កោះតូចមួយកន្លែង បានជួបនឹងវេមានិកប្រេត ៨ នាក់ ក្នុងវិមានប្រាក់ លើកោះនោះ ។ បានជួបនាងវេមានិកប្រេត ១៦ នាក់ ក្នុងវិមានកែវមណី លើកោះមួយកន្លែងទៀត បានជួបវេមានិកប្រេត ៣២ នាក់ ក្នុងវិមានមាស លើកោះមួយទៀត ដោយឧបាយនេះឯង បានសោយទិព្វសម្បត្តិជាមួយវេមានិក-ប្រេតទាំងនោះគ្រប់ៗ កោះ ដូចពោលហើយ លុះដល់នាងវេមានិកប្រេតទាំងនោះទៅទទួលទុក្ខ បានដេកលើក្បូន អណ្តែតទៅតាមសមុទ្រទៀត បានជួបនឹងនគរមួយដែលមានកំពែងព័ទ្ធជុំវិញ មានទ្វារ ៤ បានឮថា ទីនោះជាឧស្សុ-ទនរក ជាទីសោយទារុណកម្មរបស់ពួកសត្វនរកជាច្រើន តែបានប្រាកដដល់មិត្តវិន្ទុកៈ ដូចនគរដែលប្រដាប់តាក់តែង គាត់គិតថា អញនឹងធ្វើព្រះរាជាក្នុងនគរនេះ ហើយចូលទៅ បានឃើញសត្វនរកមួយទូលខ្មុរចក្រ ដែលវិលនៅលើក្បាល ខណៈនោះ ចក្រដែលវិលលើក្បាលសត្វនរកនោះ បានប្រាកដដល់មិត្តវិន្ទុកៈជាផ្កាឈូក ចំណង ៥ ប្រការត្រង់ទ្រូង ប្រាកដដូចជាសង្វារជាគ្រឿងប្រដាប់ទ្រូង លោហិតដែលហូរចេញអំពីក្បាល ដូចចន្ទន៍ក្រហមដែលលាប សំឡេងទ្រហោយំ ដូចសំឡេងច្រៀងដ៏ពីរោះ ។ មិត្តវិន្ទុកៈចូល

ទៅជិតសត្វនរកនោះហើយ ពោលសុំថា បពិត្រសប្បុរសដ៏ចម្រើន លោកបានទ្រទ្រង់នូវកម្រងផ្កាមកយូរហើយ ចូរឲ្យដល់ខ្ញុំចុះ សត្វនរកពោលថា នែសម្លាញ់ នេះមិនមែនផ្កាឈូកទេ គឺខុរចក្រ មិត្តវិន្ទុកៈពោលថា លោកពោលយ៉ាងនេះ ព្រោះមិនចង់ឲ្យដល់ខ្ញុំ ។ សត្វនរកគិតថា បាបរបស់អញអស់ហើយ បុរសនេះ ប្រហែលជាវាយមាតា ហើយមកដូចអញ អញនឹងឲ្យខុរចក្រដល់បុរសនេះ គ្រានោះ សត្វនរកបានពោលនឹងមិត្តវិន្ទុកៈថា មកសម្លាញ់ ចូរអ្នកទទួលផ្កាឈូកនេះចុះ ហើយដាក់ខុរចក្រលើក្បាលរបស់មិត្តវិន្ទុកៈ ខុរចក្របានធ្លាក់ចុះវិលក្បាលរបស់មិត្តវិន្ទុកៈ ខណៈនោះ ទើបមិត្តវិន្ទុកៈដឹងថា ផ្កាឈូកនោះ គឺខុរចក្រ បានទទួលទុក្ខវេទនាជាកម្លាំង ទ្រហោយំពោលថា សូមលោកយកខុរចក្ររបស់លោកទៅវិញចុះ សត្វនរកនោះបានបាត់ទៅហើយ ។ គ្រានោះ ព្រះពោធិសត្វសោយព្រះជាតិជារុក្ខទេវតា មួយអន្លើដោយបរិវារធំត្រាច់ចារិកទៅក្នុងឧស្សុទនរក បានទៅដល់ទីនោះ មិត្តវិន្ទុកៈឃើញរុក្ខទេវតាកាលសួរថា បពិត្រទេវរាជ ខុរចក្រនេះធ្លាក់លើក្បាល ហាក់ដូចធ្វើឲ្យល្អិតដូចគ្រាប់ល្ង ខ្ញុំបានធ្វើបាបកម្មអ្វីហ្ន៎ ដូច្នេះ ទើបពោល ២ គាថាថា

ក្រុងនេះ មានទ្វារ ៤ ជាវិការនៃដែក មានកំពែងដ៏មាំ ខ្ញុំត្រូវកំពែងព័ទ្ធជាប់ជុំវិញ តើខ្ញុំបានធ្វើបាបអ្វី ។

ទ្វារទាំងអស់ បិទជិត ខ្ញុំក៏ជាប់នៅដូចជាសត្វស្លាប ( ជាប់នៅក្នុងទ្រុង ) បពិត្រយក្ខ ហេតុដូចម្តេច ទើបខ្ញុំត្រូវចក្រវិលសង្កិនដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឧទ្ធដ្ឋាការំ** បានដល់ មានកំពែងមាំទាំ បាលីថា **ឧទ្ធដ្ឋតោរណំ** ដូច្នេះក៏មាន សេចក្ដីថា មានទ្វារមាំទាំ ។ បទថា **ឱរុទ្ធបដិរុទ្ធោស្មិ** សេចក្ដីថា ខ្ញុំត្រូវព័ទ្ធដោយកំពែងជុំវិញ ជាប់នៅខាងក្នុងទី សម្រាប់គេចទៅមិនប្រាកដ ។ បទថា **កឹ បាបំ បកតំ** សេចក្ដីថា ខ្ញុំបានធ្វើបាបអ្វីហ្ន៎ ។ បទថា **អបិហិតា** បានដល់ ដែលគេបិទហើយ ។ បទថា **យថា ទិជោ** បានដល់ ដូចបក្សីដែលឃាំងក្នុងទ្រុង ។ បទថា **កិមាធិករណំ** សេចក្ដីថា មូលហេតុដូចម្ដេច គឺដូចម្ដេច ។ បទថា **ចក្កាភិនិហតោ** បានដល់ ត្រូវខ្សែចក្រកិនហើយ ។ លំដាប់នោះ ទេវរាជ កាលប្រាប់ហេតុដល់បុរសនោះ បានពោល ៦ គាថាថា

អ្នកបានទ្រព្យជាង ២០ សែន មិនធ្វើតាមពាក្យរបស់ញាតិទាំងឡាយ ដែលជាអ្នកជួយអនុគ្រោះដោយល្អ ។

អ្នកស្ទុះលឿនទៅកាន់ទូកដែលអណ្ដែតទៅកាន់សមុទ្រសាគរ ជាទីសម្រេចប្រយោជន៍តិច បាននាងវេមានិកប្រេត ៤ នាក់ នាងវេមានិកប្រេត ៨ នាក់ លុះចេញអំពីវេមានិកប្រេត ៨ នាក់ ក៏បាននាងវេមានិកប្រេត ១៦ នាក់ ។

អ្នកចេញអំពីនាងវេមានិកប្រេត ១៦ នាក់ ក៏បាននាងវេមានិក-ប្រេត ៣២ នាក់ អ្នកជាមនុស្សមានសេចក្ដីប្រាថ្នាដ៏លើសលុប បានមកប្រទះនឹងចក្រ ទាំងចក្រក៏វិលកិននូវអំបែងក្បាលនៃបុរសដែលមានសេចក្ដីប្រាថ្នាគ្របសង្កត់ ។

សេចក្ដីប្រាថ្នា ជាធម្មជាតដ៏ទូលាយលើសលុប ដែលគេបំពេញបានដោយក្រ ជាផ្លូវដល់នូវសេចក្ដីវិបត្តិ ព្រោះសេចក្ដីប្រាថ្នា ពួកជនណា ត្រេកអរតាមសេចក្ដីប្រាថ្នានោះ ពួកជននោះ រមែងជាអ្នកទ្រទ្រង់នូវចក្រ ។

ពួកជនណា មិនពិចារណានូវផ្លូវនេះ ដូចជាអ្នកលះបង់នូវទ្រព្យច្រើន មិនពិចារណានូវផ្លូវ ( ដែលខ្លួនត្រូវដើរទៅ ) ពួកជននោះ រមែងជាអ្នកទ្រទ្រង់នូវចក្រ ។

បុគ្គល គប្បីពិចារណានូវកិច្ចការដែលត្រូវធ្វើ និងភោគៈដ៏ច្រើន ហើយមិនគប្បីគប់រកនូវសេចក្ដីប្រាថ្នា ដែលមិនប្រកបដោយប្រយោជន៍ ធ្វើតាមពាក្យរបស់ពួកជនអ្នកអនុគ្រោះ ចក្រមិនគប្បីវិលសង្កិនបុគ្គលបែបនោះបាន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **លទ្ធា សតសហស្សានិ អតិរេកានិ វីសតិ** សេចក្ដីថា អ្នកធ្វើឧបោសថបានទ្រព្យ ១០០០ អំពីសម្នាក់មាតា កាលធ្វើការលក់ដូរ ទើបបានទ្រព្យអំពីដើមទុន ១០០០ និងទ្រព្យដែលចំណេញមួយសែនពីរម៉ឺនហើយ ។ ដោយបទថា **ញាតកា** នេះ ទេវរាជសម្ដែងថា អ្នកមិនត្រេកអរដោយទ្រព្យនោះ ចេញជំណើរទៅក្នុងសមុទ្រ ត្រូវមាតាពោលដល់ទោសក្នុងសមុទ្រ ហើយឃាត់ ក៏នៅតែមិនជឿពាក្យជាស់តឿនរបស់ញាតិដែលជាអ្នកករុណា បែរជាប្រទូស្តមាតាជាសោតាបន្ន ហើយធ្មៀតយកឱកាសគេចចេញទៅ ។ បទថា **លង្ឃី** បានដល់ ដែលអាចធ្វើឲ្យសំពៅទៅមុខបាន ។

បទថា **បក្កន្តិ** បានដល់ អ្នកជាបុគ្គលចេញសំពៅទៅហើយ ។ បទថា **អប្ប-សិទ្ធិកំ** បានដល់ ដែលមានការសម្រេចតិចតួច ច្រើនដោយសេចក្តីវិនាស ។ បទថា **ចតុព្ភិ អដ្ឋ** សេចក្តីថា កាលសំពៅកៀងហើយ ព្រោះអាស្រ័យអ្នកជាហេតុ សូម្បីត្រូវពួកដែលទៅជាមួយគ្នាចងក្បូន ហើយបោះចូលក្នុងសមុទ្រ អ្នកបានស្រី ៤ នាក់ ក្នុងវិមានកែវផលិក ព្រោះអានិសង្សនៃឧបោសថកម្ម ដែលខ្លួនបានធ្វើមួយថ្ងៃ ព្រោះអាស្រ័យមាតា បន្ទាប់អំពីនោះបានស្រី ៨ នាក់ ក្នុងវិមានប្រាក់ ១៦ នាក់ក្នុងវិមានកែវមណី និង ៣២ នាក់ក្នុងវិមានមាស ។ បទថា **អត្រិច្ឆំ ចក្កមាសទោ** សេចក្តីថា ទោះជាដូច្នោះ អ្នកក៏មិនត្រេកអរដោយបច្ច័យតាមមានតាមបាន ឈ្មោះថា ជាអ្នកប្រាថ្នាច្រើន ព្រោះជាអ្នកប្រកបដោយការប្រាថ្នា កើតនូវការចាំបាច់ ពោល គឺចំណង់ក្រៃលែង ដែលជាគ្រឿងកន្លងវត្ថុដែលខ្លួនបានមកហើយយ៉ាងនេះថា អញនឹងបានក្រៃលែងជាងនេះ ក្នុងវត្ថុនេះ ដូច្នេះ ឈ្មោះថា ជាបុគ្គលថោកទាប ព្រោះភាពដែលឧបោសថកម្មនោះអស់ហើយ ទើបបានឆ្លងផុតនូវស្រី ៣២ នាក់ ហើយមកកាន់បេតនគរនេះ ព្រោះវិបាកនៃអកុសលកម្ម គឺការប្រទូស្តមាតានោះ ទើបជួបនូវចក្រនេះ ។ បាលីថា **អត្រិច្ឆំ** ដូច្នេះក៏មាន សេចក្តីថា ប្រាថ្នាក្នុងវត្ថុនេះខ្លះ វត្ថុនោះខ្លះ ។ បាលីថា **អត្រិច្ឆា** ដូច្នេះក៏មាន សេចក្តីថា ព្រោះប្រាថ្នាហួសព្រំដែន ។ បទថា **ភមតិ** សេចក្តីថា ឥឡូវនេះ ចក្រនេះកិននូវអំបែងក្បាលរបស់អ្នក ឈ្មោះថា វិលលើក្បាលរបស់អ្នកដែលត្រូវចំណង់គ្របសង្កត់ហើយ ដូចចក្ររបស់ស្មូនឆ្នាំង ដូច្នោះ ។ បទថា **យេ ច តំ អនុគិជ្ឈន្តិ**

សេចក្តីថា ឈ្មោះថា ចំណង់នោះ កាលផ្សាយទៅ រមែងជារបស់ធំវិសាល លំបាកបំពេញឲ្យពេញ ដូចសមុទ្រ ឈ្មោះថា តែងឲ្យដល់នូវវិបត្តិ ព្រោះការប្រាថ្នាដែលជាគ្រឿងប្រាថ្នាអារម្មណ៍នោះៗ ក្នុងបណ្តាអារម្មណ៍ មានរូបជាដើម ជនពួកណា រមែងត្រេកអរ ទៅតាមចំណង់បែបនេះ គឺជាអ្នកត្រេកត្រអាលជាប់ជំពាក់រឿយៗ ។ បទថា **តេ ហោន្តិ ចក្កធារិនោ** សេចក្តីថា ជនទាំងនោះទៅយ៉ាងនេះ ឈ្មោះថា រមែងទ្រទ្រង់នូវខុរចក្រ ។ បទថា **ពហុភណ្ឌំ** បានដល់ ទ្រព្យជាច្រើន ដែលជារបស់មាតាបិតា ។ បទថា **មគ្គំ** សេចក្តីថា ជនដទៃណាមិនពិចារណា គឺមិនគិតហេតុការណ៍នោះឲ្យពិតប្រាកដ ដូចអ្នកមិនបានពិចារណាផ្លូវក្នុងសមុទ្រ ដែលមានការសម្រេចតិចតួច ដែលខ្លួនត្រូវទៅហើយ ធ្វើដំណើរទៅ ជនទាំងនោះ ជាអ្នកធ្លាក់ក្នុងអំណាចសេចក្តីលំបាក លះទ្រព្យហើយ មិនពិចារណាផ្លូវដែលទៅ ហើយធ្វើដំណើរទៅ រមែងទ្រទ្រង់នូវខុរចក្រ ដូចរូបអ្នក ។ បទថា **កម្មំ សមេក្ខេ** សេចក្តីថា ព្រោះហេតុនោះ បុរសជាបណ្ឌិត គប្បីពិនិត្យពិច័យ គឺគប្បីពិចារណាដល់កិច្ចដែលខ្លួនត្រូវធ្វើថា មានទោស ឬមិនមានទោសហ្ន៎ ។ បទថា **វិបុលញ្ច ភោគំ** បានដល់ គប្បីសម្លឹងពិនិត្យគំនរទ្រព្យដែលបានមក ប្រកបដោយធម៌របស់ខ្លួន ។ បទថា **នាតិវត្តេយ្យ** សេចក្តីថា បុគ្គលបែបនោះ នឹងមិនត្រូវខុរចក្រនេះវៃ គឺសង្កត់សង្កិន ។ បាលីថា **នាតិវត្តតិ** ដូច្នេះក៏មាន សេចក្តីថា រមែងសង្កត់សង្កិន ។

មិត្តវិន្ទុកៈបានស្តាប់ដូច្នោះហើយ គិតថា ទេវបុត្រនេះ ដឹងកម្មដែលអញ

ធ្វើពិត ទេវបុត្រនេះ នឹងដឹងកំណត់កាលដែលអញចេះក្នុងនរកនេះ អញនឹងសាកសួរ ដូច្នេះហើយ ក៏ពោលគាថាទី ៩ ថា

បពិត្រយក្ខ ចក្រនឹងបិតនៅលើក្បាលរបស់ខ្ញុំ អស់កាលយូរ
ប៉ុន្មានឆ្នាំ ប៉ុន្មានពាន់ឆ្នាំ ខ្ញុំសួរហើយ សូមលោកប្រាប់ហេតុនោះ
ដូច្នេះ ។

លំដាប់នោះ ព្រះមហាសត្វ កាលនឹងប្រាប់មិត្តវិន្ទុកៈនោះ ក៏ពោលគាថាទី ១០ ថា

ម្នាលមិត្តវិន្ទុកៈ អ្នកចូរនឹករឭកឲ្យក្រៃលែង នឹករឭកឲ្យខ្ជាប់
ហើយចូរស្តាប់នូវពាក្យយើង ចក្រ ( នេះ ) វិលកិនក្បាល
របស់អ្នក អ្នកកាលរស់នៅ រមែងមិនទាន់រួចទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អតិសរោ** មានវិគ្គហៈថា ឈ្មោះថា **អតិសរោ** ព្រោះអត្ថថា ប្រព្រឹត្តទៅយូរដូច្នេះខ្លះ ព្រោះអត្ថថា រឹងរឹតតែប្រព្រឹត្តទៅយូរដូច្នេះខ្លះ ។ បទថា **អច្ចសរោ** ជាវេវចនៈនៃបទថា **អតិសរោ** នោះឯង សេចក្តីនេះ មានអធិប្បាយថា ម្នាលមិត្តវិន្ទុកៈដ៏ចម្រើន ចូរអ្នកស្តាប់ពាក្យរបស់យើង អ្នក ឈ្មោះថា នឹងត្រូវទទួលទុក្ខទារុណកម្មអស់កាលយូរ ព្រោះកម្មដ៏ខ្លាំងក្លា ជាកម្មដែលអ្នកធ្វើហើយ ម្យ៉ាងទៀត អ្នកនឹងត្រូវអត់ធន់នឹងទុក្ខអស់កាលយូរ ព្រោះវិបាកនៃកម្មនោះ បុគ្គលណាម្នាក់ មិនអាចនឹងប្រាប់ឲ្យដឹងបាន ដោយការរាប់ឆ្នាំ ព្រោះអ្នកត្រូវទទួលទុក្ខ គឺត្រូវដល់នូវវិបាកទុក្ខដ៏ធំក្រៃលែង ប្រមាណមិនបាន ព្រោះហេតុនោះ យើងមិនអាចប្រាប់

ដល់អ្នកបានថា ប៉ុណ្ណោះពាន់ឆ្នាំ ប៉ុណ្ណោះសែនឆ្នាំបានឡើយ ។

បទថា **សិរស្មិមាវិទ្ធំ** សេចក្តីថា ខុរចក្រនេះបានវិខ គឺវិលទៅលើអំបែងក្បាលរបស់អ្នក ដូចចក្ររបស់ស្មូនឆ្នាំង ដូច្នោះ ។ បទថា **ឆ តំ ជីវំ បមោក្ខសិ** សេចក្តីថា ជរាបណាដែលវិបាកកម្មរបស់អ្នកមិនទាន់អស់ទៅ ជរាបនោះកាលអ្នកនៅមានជីវិត នឹងផុតខុរចក្រនោះទៅមិនបាន តែបើវិបាកកម្មអស់ទៅហើយ អ្នកក៏នឹងលះខុរចក្រនេះ ទៅតាមយថាកម្ម ។

កាលទេវបុត្រពោលគាថានេះហើយ បានទៅកាន់ទេវវិមានរបស់ខ្លួន ឯមិត្តវិន្ទុកៈ ក៏បានប្រព្រឹត្តទៅកាន់ទុក្ខធំ ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា មិត្តវិន្ទុកៈក្នុងកាលនោះ បានមកជាភិក្ខុប្រដៅក្រក្នុងកាលឥឡូវនេះ ឯទេវរាជក្នុងកាលនោះ គឺតថាគតនេះឯង ។ល។

**អដ្ឋកថា ចតុទ្វារជាតក ចប់**

# សុត្តន្តបិដក

## កណ្ហជាតក

[ ៦២៧ ] ( សក្កទេវរាជពោលថា ) ឱហ្ន៎ បុរសនេះ មានសម្បុរខ្មៅ បរិភោគភោជនខ្មៅ នៅក្នុងភូមិប្រទេសក៏ខ្មៅ មិនជាទីពេញចិត្តរបស់យើងឡើយ ។

[ ៦២៨ ] ( កណ្ហតាបសពោធិសត្វពោលថា ) ម្នាលសុជម្បតិ មនុស្សមិនឈ្មោះថាខ្មៅដោយតបធម៌ទេ ព្រោះថាមនុស្សមានធម៌ជាខ្លឹមខាងក្នុង ឈ្មោះថាជាព្រាហ្មណ៍ ឯបាបកម្មមាននៅក្នុងមនុស្សណា មនុស្សនោះឯង ឈ្មោះថា ខ្មៅ ។

[ ៦២៩ ] ( សក្កទេវរាជ ... ) ពាក្យនោះ អ្នកពោលល្អហើយ ជាសុភាសិតដ៏គួរ លោកប្រាថ្នាក្នុងចិត្តចំពោះពរណាមួយ ខ្ញុំនឹងឲ្យពរ ( នោះ ) ដល់លោក ។

[ ៦៣០ ] ( កណ្ហតាបស ... ) បពិត្រសក្កៈ ជាធំជាងពួកភូតទាំងពួង បើព្រះអង្គនឹងឲ្យពរដល់អាត្មា អាត្មាប្រាថ្នានូវសេចក្ដីប្រព្រឹត្តចំពោះខ្លួន គឺការមិនមានកោធៈ ១ មិនមានទោសៈ ១ មិនមានលោភៈ ១ មិនមានស្នេហា ១ សូមព្រះអង្គឲ្យនូវពរ ៤ នេះដល់អាត្មា ។

[ ៦៣១ ] ( សក្កទេវរាជ ... ) បពិត្រព្រាហ្មណ៍ លោកពិចារណាឃើញច្បាស់នូវទោសដូចម្ដេចក្នុងកោធៈ ទោសៈ លោភៈ និងស្នេហា ខ្ញុំសួរហើយ លោកចូរប្រាប់ហេតុនោះ ។

[ ៦៣២ ] ( កណ្ហផសី ... ) សេចក្តីក្រោធមានប្រមាណតិច រមែងទៅជាច្រើន សេចក្តីក្រោធនោះ ដែលកើតអំពីសេចក្តីមិនអត់ធន់ រមែងចម្រើន សេចក្តីក្រោធ ជាហេតុឲ្យជាប់ជំពាក់ ឲ្យមានសេចក្តីចង្អៀតចង្អល់ច្រើន ព្រោះហេតុនោះ អាត្មាមិនពេញចិត្តនឹងសេចក្តីក្រោធឡើយ ។

[ ៦៣៣ ] វាចារបស់អ្នកប្រកបដោយទោសៈ ជាវាចាអាក្រក់ ការប្រចាប់ ( ប្រទាញទៅមកក៏កើតឡើង ) ជាលំដាប់ បន្ទាប់អំពីនោះ ដៃ បន្ទាប់អំពីដៃ ដំបង មានដំណើរនៃគ្រឿងសស្ត្រាជាទីបំផុត ទោសៈកើតអំពីសេចក្តីក្រោធ ព្រោះហេតុនោះ អាត្មាមិនពេញចិត្តនឹងទោសៈទេ ។

[ ៦៣៤ ] ការប្ញូន់ និងអាការកំហែង ការបោកប្រាស និងការបញ្ឆោត រមែងប្រាកដក្នុងពួកបុគ្គល អ្នកមានសេចក្តីលោភជាធម្មតា ព្រោះហេតុនោះ អាត្មាមិនពេញចិត្តនឹងលោភៈទេ ។

[ ៦៣៥ ] កិលេសគ្រឿងចាក់ស្រែះ ដែលសេចក្តីស្នេហារួបរឹតជាកិលេសក្រាស់ កើតអំពីចិត្ត រមែងដេកនៅ ( ក្នុងអារម្មណ៍នោះៗ ) កិលេសទាំងនោះ រមែងធ្វើបុគ្គលឲ្យក្តៅក្រហាយដោយក្រៃលែង ព្រោះហេតុនោះ អាត្មាមិនពេញចិត្តនឹងសេចក្តីស្នេហាទេ ។

[ ៦៣៦ ] ( សក្កៈ ... ) ពាក្យនោះ លោកពោលល្អហើយ ជា

សុភាសិតដ៏គួរ ម្នាលព្រាហ្មណ៍ លោកប្រាថ្នាក្នុងចិត្តចំពោះពរណាមួយ ខ្ញុំនឹងឲ្យពរ ( នោះ ) ដល់លោក ។

[ ៦៣៧ ] ( កណ្ហ ... ) បពិត្រសក្កៈ ជាធំជាងពួកភូតទាំងពួង បើព្រះអង្គនឹងឲ្យពរដល់អាត្មាៗ សូមកុំឲ្យអាពាធដ៏ក្លៀវក្លា ធ្វើអន្តរាយកើតឡើងដល់អាត្មា ដែលនៅក្នុងព្រៃតែម្នាក់ឯងជានិច្ចឡើយ ។

[ ៦៣៨ ] ( សក្កៈ ... ) ពាក្យនោះ លោកពោលល្អហើយ ជាសុភាសិតដ៏គួរ លោកប្រាថ្នាក្នុងចិត្តចំពោះពរណាមួយ ម្នាលព្រាហ្មណ៍ យើងនឹងឲ្យពរ ( នោះ ) ដល់លោក ។

[ ៦៣៩ ] ( កណ្ហ ... ) បពិត្រសក្កៈ ជាធំជាងពួកភូតទាំងពួង បើព្រះអង្គនឹងឲ្យពរដល់អាត្មាៗ សូមកុំឲ្យចិត្ត ឬសរីរៈ ( របស់អាត្មា ) បៀតបៀនចំពោះអ្នកណាមួយ ព្រោះហេតុនៃអាត្មាក្នុងកាលណាឡើយ បពិត្រសក្កៈ សូមព្រះអង្គឲ្យនូវពរនេះ ។

**កណ្ហជាតកទី ២ ចប់**

# អដ្ឋកថា

## កណ្ហជាតក

[ ៦២៧-៦៣៩ ] ព្រះសាស្តា កាលចូលទៅអាស្រ័យនគរកបិលពស្តុ គង់នៅក្នុងនិគ្រោធារាម ទ្រង់ប្រារព្ធការញញឹម ទើបត្រាស់រឿងនេះ មានពាក្យផ្តើមថា **កណ្ហោ វតាយំ បុរិសោ** ដូច្នេះជាដើម ។

បានឮថា គ្រានោះ ពេលល្ងាច ព្រះសាស្តាចោមរោមទៅដោយពួកភិក្ខុសង្ឃ ទ្រង់យាងទៅតាមបរិវេណវិហារនិគ្រោធារាម ទ្រង់បានញញឹមក្នុងទីមួយ ព្រះអានន្ទគិតថា អ្វីហ្ន៎ជាហេតុ ជាបច្ច័យ ឲ្យព្រះសាស្តាញញឹម ព្រះតថាគតទាំងឡាយ ទ្រង់ញញឹមដោយអត់ហេតុមិនមាន អញនឹងទូលសួរសិន ហើយផ្គងអញ្ជលី ទូលសួរហេតុដែលទ្រង់ញញឹម ។ លំដាប់នោះ ព្រះសាស្តាត្រាស់ហេតុដែលទ្រង់ញញឹមដល់ព្រះអានន្ទថា ម្នាលអានន្ទ រឿងធ្លាប់មានមកហើយ មានឥសីមួយអង្គ ឈ្មោះថា កណ្ហៈ ឥសីនោះនៅក្នុងទីនេះ ជាអ្នកបានឈាន ត្រេកអរក្នុងឈាន ដោយតេជះនៃសីលរបស់លោក បណ្តាលឲ្យសក្កពិភពញាប់ញ័រ ដូច្នេះ ។ ដោយរឿងនោះមិនប្រាកដ ព្រះថេរៈក៏ទូលអារាធនាឲ្យទ្រង់ត្រាស់សម្តែង ព្រះសាស្តាទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិក្នុងនគរពារាណសី មានព្រាហ្មណ៍ម្នាក់ មានសម្បត្តិ ៨០ កោដិ មិនមានបុត្រ បានសមាទានសីលប្រាថ្នាបុត្រ ព្រះពោធិសត្វក៏កើតក្នុងគភ៌របស់ព្រាហ្មណីជាភរិយានៃព្រាហ្មណ៍នោះ ។ ក្នុងថ្ងៃដាក់ឈ្មោះព្រះពោធិសត្វ ពួកញាតិឲ្យឈ្មោះថា **កណ្ហកុមារ**

ព្រោះមានសម្បុរខ្មៅ ។ កណ្ហកុមារនោះ លុះមានអាយុ ១៦ ឆ្នាំ មានរូបស្អាត ដូចធ្វើដោយកែវមណី បិតាបញ្ជូនទៅរៀនសិល្បសាស្ត្រក្នុងនគរតក្កសិលា កាលរៀនស្រេចហើយ ក៏ត្រឡប់មក ។ កាលនោះ បិតាក៏បានឲ្យមាណពមានកិរិយា ដែលសមគួរដល់គ្នានិងគ្នា ចំណេរតមក កាលមាតាបិតាអនិច្ចកម្មទៅហើយ មាណពក៏បានភាពជាធំ គ្រប់គ្រងសម្បត្តិទាំងអស់ ។

ថ្ងៃមួយ កណ្ហកុមារបានពិនិត្យឃ្លាំងរតនៈទាំងឡាយ ហើយឡើងអង្គុយលើបល្ល័ង្ក ឲ្យយកក្រាំងមាសមក ឃើញអក្ខរៈដែលញាតិក្នុងកាលមុនចារឹកក្នុងក្រាំងមាសថា ទ្រព្យប៉ុណ្ណេះ ញាតិឈ្មោះនោះ ធ្វើឲ្យកើតឡើង ទ្រព្យប៉ុណ្ណេះ ញាតិឈ្មោះនោះ ធ្វើឲ្យកើតឡើង ទើបគិតថា បុគ្គលដែលធ្វើទ្រព្យនេះឲ្យកើតឡើងមិនប្រាកដ ស្លាប់ទៅអស់ហើយ ប្រាកដនៅត្រឹមតែទ្រព្យតែម្យ៉ាង បុគ្គលដែលកាន់យកទ្រព្យនេះទៅសូម្បីតែម្នាក់ ក៏មិនមាន សេចក្តីពិតមិនមាននរណា អាចយកបង្វេចទ្រព្យទៅកាន់បរលោកបានឡើយ ទ្រព្យជារបស់មិនមានសារៈ ព្រោះត្រូវដល់នូវភ័យ ៥ គឺរាជភ័យ ១ ចោរភ័យ ១ អគ្គិភ័យ ១ ឧទកភ័យ ១ អប្បិយទាយាទភ័យ ១ ។ ការឲ្យទ្រព្យជាទានជាសារៈ រាងកាយមិនជាសារៈ ព្រោះជាសាធារណៈ ដោយរោគច្រើន បុគ្គលធ្វើសេចក្តីល្អ មានថ្វាយបង្គំអ្នកមានសីលជាដើមជាសារៈ ជីវិតមិនជាសារៈ ព្រោះមិនទៀងពិតប្រាកដ ការប្រកបសេចក្តីព្យាយាមចម្រើនវិបស្សនា ដោយអំណាចនៃត្រៃលក្ខណ៍ជាសារៈ ព្រោះហេតុនោះ អញនឹងឲ្យទាន ដើម្បីកាន់យកសារៈអំពីភោគៈដែលមិនជាសារៈ ។ ដូច្នេះហើយ ទើបក្រោកចាក

អាសនៈ ទៅគាល់ព្រះរាជា រួចថ្វាយបង្គំលាព្រះរាជា មកបំពេញទានដ៏គគ្រឹកគគ្រេង អស់ ៧ ថ្ងៃ ឃើញទ្រព្យនៅតែមិនអស់ គិតថា ប្រយោជន៍អ្វីដោយទ្រព្យសម្រាប់អញ ខណៈដែលមិនទាន់ជរាគ្របសង្កត់នេះ អញនឹងបួសធ្វើអភិញ្ញា និងសមាបត្តិឲ្យកើត ហើយនឹងមានព្រហ្មលោកជាទីទៅខាងមុខ គិតហើយ ឲ្យបើកទ្វារផ្ទះគ្រប់ទ្វារ ប្រកាសថា ទ្រព្យរបស់យើងទាំងអស់បានឲ្យហើយ អ្នកណាត្រូវការ ចូរយកទៅចុះ មាណពស្អប់ខ្ពើមទ្រព្យសម្បត្តិដូចរបស់ស្មោកគ្រោក លះវត្ថុកាមចោល កាលមហាជនកំពុងយំ បានចេញអំពីនគរ ចូលទៅកាន់ហិមវន្តប្បទេស បួសជាឥសី សម្លឹងមើលទីកន្លែងដែលគួរត្រេកអរ ដើម្បីជាលំនៅរបស់ខ្លួន បានមកដល់ទីដែលតថាគតឈរនេះ គិតថា អញនឹងនៅទីនេះ ។ ដូច្នេះហើយ ក៏អធិដ្ឋានយកដើមឥន្ទវារុណព្រឹក្សមួយដើម ជាលំនៅ ជាទីបរិភោគ ត្រង់គល់ឈើនោះ បានលះសេនាសនៈខាងក្នុងស្រុកចោល សមាទានការនៅព្រៃជាវត្ត មិនសាងបណ្ណសាលា សមាទានការនៅគល់ឈើជាវត្តខ្លះ នៅទីកណ្តាលវាលជាវត្តខ្លះ មិនដេកជាវត្តខ្លះ បើដេកក៏ដេកលើផែនដីប៉ុណ្ណោះ ។ សមាទានការប្រើធ្មេញជាអង្រែ ប្រើធ្មេញទំពាតែម្យ៉ាង ទំពាស៊ីតែរបស់មិនចម្អិនដោយភ្លើង មិនទំពាស៊ីរបស់ណាមួយដែលមានសម្បកស្រោប បរិភោគអាហារមួយថ្ងៃម្តងប៉ុណ្ណោះ សម្រាកលើផែនដី ធ្វើខ្លួនឲ្យស្មើដោយដី ទឹក ភ្លើង ខ្យល់ សមាទានធុតង្គគុណ មានប្រមាណប៉ុណ្ណោះ បានឮថា ក្នុងជាតកនេះ ព្រះពោធិសត្វប្រាថ្នាតិចក្រៃលែង មិនយូរប៉ុន្មានក៏បានអភិញ្ញា និងសមាបត្តិ ជាអ្នកលេងឈានក្នុងទីនោះ សូម្បី

ត្រូវការផលាហារ ក៏មិនទៅកាន់ទីដទៃ គ្រាដើមឈើចេញផ្លែ ក៏មិនបរិភោគផ្លែ កាលចេញផ្កា ក៏មិនបរិភោគផ្កា កាលមានស្លឹក ក៏បរិភោគស្លឹក បើមិនមានស្លឹក ក៏បរិភោគក្រម៉ លោកជាអ្នកសន្តោសក្រៃលែងយ៉ាងនេះ នៅក្នុងទីនេះអស់កាលយូរ ព្រឹកមួយ លោកក៏បេះផ្លែឈើមិនទុំ កាលបេះ ក៏មិនមានសេចក្តីលោភ ទៅបេះក្នុងទីដទៃ អង្គុយត្រង់ដើមនោះឯង លាដៃទៅបេះផ្លែឈើដែលល្មមដៃបេះដល់ បណ្តាផ្លែឈើទាំងនោះ ក៏មិនបានជ្រើសរើសថា ពេញចិត្ត ឬមិនពេញចិត្ត ស្រេចហើយតែដៃបេះមក ដោយតេជះនៃសីលដែលលោកសន្តោសក្រៃលែងយ៉ាងនេះ បណ្ឌុកម្ពលសិលាអាសនៈនៃសក្កទេវរាជបានបញ្ចេញចំហាយក្តៅខុសប្រក្រតី ។

បានឮថា អាសនៈនោះក្តៅដោយហេតុ ៤ ប្រការ គឺសក្កទេវរាជអស់អាយុ ១ អស់បុណ្យ ១ សត្វមានអានុភាពធំដទៃប្រាថ្នាទីនោះ ១ ដោយតេជះនៃសីលរបស់សមណព្រាហ្មណ៍ដែលតាំងនៅក្នុងធម៌មានឫទ្ធិច្រើន ១ ។

សក្កទេវរាជទ្រង់ពិចារណាថា អ្នកណាហ្ន៎ បំណងឲ្យអញឃ្លាតចាកទី បានទតឃើញកណ្ហឥសីកំពុងបេះផ្លែឈើក្នុងទីនេះ ទើបទ្រង់ព្រះតម្រិះថា ឥសីនេះមានតបៈខ្លាំងក្លា ឈ្នះនូវឥន្ទ្រិយយ៉ាងក្រៃលែងហើយ អញនឹងឲ្យលោកបន្លឺនូវសីហនាទដោយធម្មកថា បានស្តាប់ហេតុល្អហើយ នឹងទំនុកបម្រុងឲ្យឆ្អែតដោយពរ ធ្វើដើមឈើឲ្យមានផ្លែជានិច្ចសម្រាប់ឥសីនេះហើយ នឹងត្រឡប់មក កាលទ្រង់ត្រិះរិះដូច្នេះហើយ ក៏ចុះមកដោយរហ័ស ដោយអានុភាពធំប្រថាប់ឈរត្រង់គល់ឈើ ក្រោយខ្នងឥសី កាលសាកល្បង ទើបពោល

ទោស ដើម្បីដឹងថា ឥសីនេះក្រោធដែរឬទេ ដោយគាថាទី ១ ថា

ឱហ្ន៎ បុរសនេះ មានសម្បុរខ្មៅ បរិភោគភោជនខ្មៅ នៅក្នុង
ភូមិប្រទេសក៏ខ្មៅ មិនជាទីពេញចិត្តរបស់យើងឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កណ្ហោ** បានដល់ មានពណ៌ខ្មៅ ។ បទថា
**ភោជនំ** បានដល់ ភោជន គឺផ្លែឈើ ។

កណ្ហឥសីបានស្តាប់ពាក្យរបស់សក្កៈហើយ ពិចារណាមើលដោយទិព្វ
ចក្ខុថា នរណាហ្ន៎ មកនិយាយនឹងអញ ដឹងថា ជាសក្កទេវរាជ ទើបពោល
គាថាទី ២ ដោយមិនងើបមើលថា

ម្នាលសុជម្បតិ មនុស្ស មិនឈ្មោះថា ខ្មៅ ដោយតបធម៌ទេ
ព្រោះថា មនុស្សមានធម៌ជាខ្លឹមខាងក្នុង ឈ្មោះថា ជាព្រាហ្មណ៍
ឯបាបកម្មមាននៅក្នុងមនុស្សណា មនុស្សនោះឯង ឈ្មោះថា
ខ្មៅ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តបសា** អធិប្បាយថា បុគ្គល មិនឈ្មោះ
ថា ខ្មៅ ព្រោះមានតបៈ ។ បទថា **អន្តោសារោ** សេចក្តីថា ព្រោះថា បុគ្គល
ដែលប្រកបដោយខ្លឹម គឺសីល សមាធិ បញ្ញា វិមុត្តិ វិមុត្តិញ្ញាណទស្សនៈ
ខាងក្នុងបែបនេះ ឈ្មោះថា ជាព្រាហ្មណ៍ ព្រោះមានបាបបន្សាត់ហើយ ។
បទថា **ស វេ** សេចក្តីថា ចំណែកបាបកម្ម មានក្នុងបុគ្គលណា បុគ្គលនោះ
ទោះកើតក្នុងត្រកូលណាក៏ដោយ ទោះប្រកបដោយពណ៌នៃសរីរៈយ៉ាងណា
ក៏ដោយ ក៏ឈ្មោះថា ជាបុគ្គលខ្មៅទាំងអស់ ។

កាលឥសីពោលយ៉ាងនេះហើយ ទើបចែកប្រភេទបាបកម្ម ដែលធ្វើសត្វទាំងនេះ ឲ្យជាខ្មៅដោយពិស្តារ តិះដៀលនូវបាបទាំងនោះ សរសើរនូវគុណមានសីលជាដើម សម្ដែងធម៌ដល់សក្កៈ ប្រៀបដូចឲ្យព្រះចន្ទរះឡើងក្នុងអាកាស សក្កទេវរាជទ្រង់ស្ដាប់ធម្មកថារបស់កណ្ហឥសីហើយ មានចិត្តត្រេកអរ កើតនូវសោមនស្ស កាលនិមន្តព្រះមហាសត្វដោយពរ បានត្រាស់គាថាទី ៣ ថា

ពាក្យនោះ អ្នកពោលល្អហើយ ជាសុភាសិតដ៏គួរ លោកប្រាថ្នា
ក្នុងចិត្តចំពោះពរណាមួយ ខ្ញុំនឹងឲ្យពរ ( នោះ ) ដល់លោក
ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឯតស្មឹ** ជាដើម សេចក្ដីថា ពាក្យនេះ ដែលលោកពោលដូចជាសព្វញ្ញុពុទ្ធពោលល្អហើយ ពាក្យនោះ លោកពោលល្អហើយ ជាសុភាសិត ឈ្មោះថា សមគួរ ព្រោះជាពាក្យដែលសមគួរដល់លោក លោកប្រាថ្នាពរណាមួយដោយចិត្ត គឺពរណា ដែលចង់បានហើយ ប្រាថ្នាហើយ ខ្ញុំនឹងឲ្យពរទាំងនោះ ដល់លោក ។

ព្រះមហាសត្វបានស្ដាប់ដូច្នោះហើយ គិតថា សក្កទេវរាជនេះ គ្រានឹងសាកល្បងអញថា កាលពោលទោសរបស់អញ នឹងក្រោធ ឬមិនក្រោធហ្ន៎ បានជាក្លែងតិះដៀលពណ៌សម្បុរ ភោជន ទីលំនៅរបស់អញ ឥឡូវនេះ ដឹងថាអញមិនក្រោធ ក៏មានចិត្តជ្រះថ្លា ហើយឲ្យពរ គង់សម្គាល់នូវអញថា ប្រព្រឹត្តព្រហ្មចរិយៈ ដើម្បីភាពជាធំ ជាសក្កៈ ជាព្រហ្មពិត អញនឹងកាត់សេចក្ដីសង្ស័យរបស់សក្កៈក្នុងរឿងនេះចេញ គួរទទួលពរ ៤ ប្រការ គឺកុំឲ្យសេចក្ដី

ក្រោធចំពោះអ្នកដទៃកើតឡើងដល់អញ ១ កុំឲ្យទោសៈចំពោះអ្នកដទៃកើតឡើងដល់អញ ១ កុំឲ្យសេចក្តីលោភក្នុងសម្បត្តិរបស់អ្នកដទៃកើតឡើងដល់អញ ១ កុំឲ្យសេចក្តីស្រឡាញ់ក្នុងអ្នកដទៃកើតឡើងដល់អញ ១ អញគប្បីនៅជាកណ្តាលប៉ុណ្ណោះ កាលទទួលពរ ៤ ប្រការ ដើម្បីកាត់សេចក្តីសង្ស័យរបស់សក្កៈ ក៏បានពោលគាថាទី ៤ ថា

បពិត្រសក្កៈ ជាធំជាងពួកភូតទាំងពួង បើព្រះអង្គនឹងឲ្យពរដល់អាត្មា អាត្មាប្រាថ្នានូវសេចក្តីប្រព្រឹត្តចំពោះខ្លួន គឺការមិនមានក្រោធៈ ១ មិនមានទោសៈ ១ មិនមានលោភៈ ១ មិនមានស្នេហា ១ សូមព្រះអង្គឲ្យនូវពរ ៤ នេះ ដល់អាត្មា ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វរញ្ចេ មេ អទោ សក្ក** សេចក្តីថា បើទ្រង់ប្រទានពរដល់អាត្មាសោត ។ បទថា **សុនិក្កោធំ** បានដល់ កុំមានសេចក្តីក្រោធ ដោយអំណាចការមិនក្រោធតប ។ បទថា **សុនិទ្ទោសំ** បានដល់ កុំឲ្យមានទោសៈ ដោយការមិនប្រទូស្តតប ។ បទថា **និល្លោភំ** បានដល់ កុំឲ្យមានសេចក្តីលោភក្នុងសម្បត្តិអ្នកដទៃ ។ បទថា **វុត្តិមត្តនោ** សេចក្តីថា អាត្មាប្រាថ្នាឲ្យការប្រព្រឹត្តរបស់ខ្លួន មានការៈយ៉ាងនេះ ។ បទថា **និស្នេហំ** បានដល់ កុំឲ្យមានស្នេហា គឺឲ្យប្រាសចាកលោភៈ សូម្បីក្នុងរបស់ខ្លួនឯង គឺក្នុងបុត្រ និងធីតាទាំងឡាយដែលមានវិញ្ញាណ ឬក្នុងទ្រព្យ មានស្រូវជាដើមដែលមិនមានវិញ្ញាណ ។ បទថា **អភិកង្ខាមិ** សេចក្តីថា អាត្មាប្រាថ្នាឲ្យការប្រព្រឹត្តរបស់ខ្លួនប្រកបដោយអង្គ ៤ ប្រការបែបនេះ ។ ដោយបទថា **ឃតេ**

**មេ ចតុរោ វរេ** នេះ ព្រះមហាសត្វពោលថា សូមទ្រង់ប្រទានពរ ៤ ប្រការ មានកុំឲ្យមានសេចក្តីក្រោធជាដើមនោះដល់ខ្ញុំចុះ ។

សួរថា ព្រះមហាសត្វមិនជ្រាបឬថា បុគ្គលណាម្នាក់ មិនអាចទទួលពរក្នុងសម្នាក់របស់សក្កៈ ហើយកម្ចាត់សេចក្តីក្រោធជាដើមបានដោយពរ ។ ឆ្លើយថា មិនមែនមិនជ្រាបទេ តែទទួលពរដោយគិតថា បើសក្កៈប្រទានពរការពោលថា ខ្ញុំមិនទទួល មិនសមគួរ ដើម្បីកាត់សេចក្តីសង្ស័យរបស់សក្កៈនោះ ក៏ទទួលពរ ។

លំដាប់នោះ សក្កទេវរាជទ្រង់ព្រះតម្រិះថា កណ្ហបណ្ឌិតកាលនឹងទទួលពរ ក៏ទទួលតែពរមិនមានទោសទាំងអស់ អញនឹងសួរដល់គុណ និងទោសក្នុងពរទាំងនេះជាមួយឥសីជាមុន ។ គ្រានោះ កាលទ្រង់សួរឥសី បានត្រាស់គាថាទី ៥ ថា

បពិត្រព្រាហ្មណ៍ លោកពិចារណាឃើញច្បាស់នូវទោសដូចម្តេច
ក្នុងកោធៈ ទោសៈ លោភៈ និងស្នេហា ខ្ញុំសួរហើយ លោក
ចូរប្រាប់ហេតុនោះ ដូច្នេះ ។

គប្បីជ្រាបអត្ថក្នុងរឿងនោះថា នៃព្រាហ្មណ៍ លោកឃើញទោសក្នុងសេចក្តីក្រោធ ក្នុងទោសៈ ក្នុងលោភៈ ឬក្នុងស្នេហាដូចម្តេចឬ ខ្ញុំសូមសួរសេចក្តីនោះ សូមលោកប្រាប់ខ្ញុំសិនចុះ ព្រោះថា ខ្ញុំមិនដឹងដល់ទោសក្នុងអកុសលធម៌នោះ ។

លំដាប់នោះ ព្រះមហាសត្វពោលនឹងសក្កៈថា បើដូច្នោះ សូមទ្រង់ស្តាប់

ដូច្នេះហើយ ពោល ៤ គាថាថា

សេចក្តីក្រោធមានប្រមាណតិច រមែងទៅជាច្រើន សេចក្តីក្រោធនោះ ដែលកើតអំពីសេចក្តីមិនអត់ធន់ រមែងចម្រើន សេចក្តីក្រោធជាហេតុឲ្យជាប់ជំពាក់ ឲ្យមានសេចក្តីចង្អៀតចង្អល់ច្រើន ព្រោះហេតុនោះ អាត្មាមិនពេញចិត្តនឹងសេចក្តីក្រោធឡើយ ។

វាចារបស់អ្នកប្រកបដោយទោសៈ ជាវាចាអាក្រក់ ការប្រចាប់ ( ប្រទាញទៅមកក៏កើតឡើង ) ជាលំដាប់ បន្ទាប់អំពីនោះ ដៃ បន្ទាប់អំពីដៃ ដំបង មានដំណើរនៃគ្រឿងសស្ត្រាជាទីបំផុត ទោសកើតអំពីសេចក្តីក្រោធ ព្រោះហេតុនោះ អាត្មាមិនពេញចិត្តនឹងទោសៈទេ ។

ការប្ញន់ និងអាការកំហែង ការបោកប្រាស និងការបញ្ឆោត រមែងប្រាកដក្នុងពួកបុគ្គល អ្នកមានសេចក្តីលោភជាធម្មតា ព្រោះហេតុនោះ អាត្មាមិនពេញចិត្តនឹងលោភៈទេ ។

កិលេសគ្រឿងចាក់ស្រេះ ដែលសេចក្តីស្នេហារួបរឹត ជាកិលេសក្រាស់ កើតអំពីចិត្ត រមែងដេកនៅ ( ក្នុងអារម្មណ៍នោះៗ ) កិលេសទាំងនោះ រមែងធ្វើបុគ្គលឲ្យក្តៅក្រហាយដោយក្រៃលែង ព្រោះហេតុនោះ អាត្មាមិនពេញចិត្តនឹងសេចក្តីស្នេហាទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អខន្តិជោ** សេចក្តីថា សេចក្តីក្រោធនោះ កើតអំពីការមិនអត់ធន់ នៃបុគ្គលមានជាតិមិនអត់ធន់ ដំបូងជារបស់តូច តែ

ក្រោយមកជារបស់ច្រើន រមែងចម្រើនឡើងដោយលំដាប់ សេចក្ដីក្រោធនោះចម្រើនឡើង គប្បីពណ៌នាដោយខន្តិវាទិជាតក និងចូឡធម្មបាលជាតក ។ ម្យ៉ាងទៀត ក្នុងសេចក្ដីនេះ គប្បីនាំរឿងតិស្សអមាត្យសម្លាប់ជនទាំងអស់ តាំងអំពីកិរិយា មួយអន្ទើដោយបរិវារជន ហើយសម្លាប់ខ្លួនឯងក្នុងកាលជាក្រោយ ។ បទថា **អាសង្គិ** សេចក្ដីថា សេចក្ដីក្រោធ រមែងធ្វើនូវការជាប់ជំពាក់ គឺកើតឡើងដល់បុគ្គលណា រមែងធ្វើបុគ្គលនោះឲ្យជាប់ជំពាក់ និងមិនឲ្យលះរឿងនោះបាន ត្រូវឲ្យត្រឡប់មកធ្វើនូវអំពើអាក្រក់ មានការជេរជាដើម ។

បទថា **ពហុចាយាសោ** បានដល់ ប្រកបដោយការចង្អៀតចង្អល់ គឺការលំបាក ពោល គឺសេចក្ដីទុក្ខផ្លូវកាយ និងចិត្តជាច្រើន ពិតហើយ ព្រោះអាស្រ័យសេចក្ដីក្រោធជាហេតុ ជនទាំងឡាយដែលធ្វើការប្រព្រឹត្តកន្លងក្នុងព្រះអរិយបុគ្គលជាដើម ដោយអំណាចសេចក្ដីក្រោធ រមែងសោយទុក្ខដ៏ខ្លាំងក្លា មានការក្ដៅក្រហាយ ព្រោះត្រូវសម្លាប់ និងត្រូវចងជាដើម មានការត្រូវដាក់ទោស ដោយគ្រឿងចង ៥ យ៉ាងជាដើម ទាំងក្នុងភពនេះ និងភពខាងមុខ ព្រោះហេតុនោះ ទើបសេចក្ដីក្រោធ ឈ្មោះថា មានការចង្អៀតចង្អល់ច្រើន ។ បទថា **តស្មា** សេចក្ដីថា ព្រោះសេចក្ដីក្រោធនោះ មានទោសច្រើនដូចពោលមកនេះ ដូច្នោះ ទើបខ្ញុំមិនគាប់ចិត្តក្នុងសេចក្ដីក្រោធ ។

បទថា **ឧដ្ឋស្ស** ជាដើម សេចក្ដីថា ជាដំបូង វាចាគ្រោតគ្រាតរបស់បុគ្គលក្រោធ ដោយកោធៈដែលមានការក្ដៅក្រហាយជាលក្ខណៈ ហើយតមកទើបប្រទូស្តដោយទោសៈ ដែលមានការគិតអាក្រក់ចំពោះអ្នកដទៃជាលក្ខណៈ

រមែងបន្ទឺចេញមក បន្ទាប់អំពីវាចា ក៏កើតការប្រទន់ប្រទាញដោយដៃ ដោយអំណាចនៃការប្រវាយប្រតប់គ្នា បន្ទាប់ពីនោះ ក៏វាយតប់គ្នាដោយដៃ ដោយប្រើកម្លាំង តទៅ ក៏ចាប់ដំបងវាយគ្នា រហូតដល់ចាប់សស្ត្រា ដែលមានមុខតែម្ខាង ឬមានមុខទាំងសងខាង កាប់ចាក់គ្នា ជាទីបំផុត ។ ពិតហើយ ក្នុងកាលណា បុគ្គលប្រើសស្ត្រាសម្លាប់អ្នកដទៃ ខាងក្រោយ ទើបប្រើសស្ត្រានោះឯងសម្លាប់ខ្លួនឯង ក្នុងកាលនោះ ទោសៈ រមែងដល់ទីបំផុត ។

បទថា **ទោសោ កោធសមុដ្ឋានោ** សេចក្ដីថា ប្រៀបដូចតក្កៈ ឬទឹកអន្ករដែលមិនជូរ តែក្លាយជារបស់ជូរ ដោយអំណាចនៃការប្រែប្រួលទៅ វត្ថុដែលជូរ និងមិនជូរទាំងនេះ រមែងមានកំណើតតែមួយ លោកក៏ហៅថា ជូរមិនជូរ យ៉ាងណា ទោសៈក៏ដូច្នោះដូចគ្នា កាលមុនជាកោធៈ លុះកាលក្រោយមក ក៏ក្លាយជាទោសៈ សភាវធម៌ទាំង ២ នោះ មានកំណើតតែមួយ ជាអកុសលមូលជាមួយគ្នា តែលោកហៅផ្សេងគ្នាថា កោធៈ និងទោសៈ ប្រៀបដូចរបស់ដែលមានរសជូរ កើតអំពីវត្ថុដែលមិនមានរសជូរ យ៉ាងណា ទោសៈនោះក៏តាំងឡើងអំពីកោធៈ ដូច្នោះ ព្រោះហេតុនោះ ទើបទោសៈ ឈ្មោះថាមានកោធៈជាសមុដ្ឋាន ។ បទថា **តស្មា** សេចក្ដីថា ព្រោះទោសៈមានទោសជាអនេកយ៉ាងនេះ ដូច្នោះ ទើបខ្ញុំមិនគាប់ចិត្តនឹងទោសៈឡើយ ។

បទថា **អាលោបសាហសាការា** សេចក្ដីថា ឈ្មោះថា ញុំាងឲ្យកើតនូវការគ្រោតគ្រាត ព្រោះប្លន់សម្លាប់អ្នកស្រុករាល់ៗ ថ្ងៃ ដោយការប្រើអាវុធភ្ជង់ត្រង់ដើមទ្រូង ហើយសម្លុតថា ចូរឲ្យវត្ថុនេះ ដល់អញ ។

បទថា **និកតិ វញ្ចនានិ ច** សេចក្តីថា ការសម្តែងរបស់ក្លែងក្លាយ ដូរយករបស់អ្នកដទៃទៅ ឈ្មោះថា ការបន្ទំៗ នោះ គប្បីឃើញគំរូ ក្នុងការឲ្យមាសក្លែងក្លាយ ថាជាមាសពិត និងកហាបណៈក្លែងក្លាយ ថាជាកហាបណៈពិត ហើយកាន់យកទ្រព្យអ្នកដទៃទៅ ឯការកាន់យកទ្រព្យរបស់អ្នកដទៃទៅដោយអំណាចនៃបដិភាណ ព្រោះភាពជាអ្នកឈ្លាសក្នុងឧបាយ ឈ្មោះថា បោកបញ្ឆោត គប្បីជ្រាបរឿងនៃការបោកបញ្ឆោតនោះយ៉ាងនេះថា បុរសអ្នកស្រុកដែលមានភាពស្មោះត្រង់ម្នាក់ នាំទន្សាយមកអំពីព្រៃ ដាក់ត្រង់ឆ្នេរស្ទឹង ហើយចុះងូតទឹក សម័យនោះ អ្នកលេងម្នាក់ យកទន្សាយនោះដាក់លើក្បាល ហើយចុះងូតទឹក បុរសអ្នកស្រុកឡើងមក មិនឃើញទន្សាយ ទើបសម្លឹងមើលឆ្វេងស្តាំ អ្នកលេងឃើញដូច្នោះ សួរបុរសនោះថា អ្នកសម្លឹងរកអ្វី បុរសអ្នកស្រុកឆ្លើយថា ខ្ញុំដាក់ទន្សាយត្រង់នេះ តែមិនឃើញទន្សាយនោះ ។ អ្នកលេងពោលថា នែបុរសល្ងង់ខ្លៅ ឯងមិនដឹងទេឬ ទន្សាយទាំងឡាយ ដែលបុគ្គលដាក់ត្រង់ឆ្នេរស្ទឹង រមែងគេចទៅបាន ឯងមើលនេះ ខ្ញុំចាំបាច់ត្រូវយកទន្សាយរបស់ខ្លួនដាក់លើក្បាល ងូតទឹកដែរ ។ បុរសអ្នកស្រុកយល់ថា ពិតជាយ៉ាងនោះ ព្រោះភាពដែលខ្លួនមិនមានបដិភាណ ទើបចៀសចេញទៅ ។ ក្នុងសេចក្តីនេះ គប្បីនិទានរឿងដែលគេទទួលយកកូនម្រឹគដោយប្រាក់ ១ កហាបណៈ ឲ្យកូនម្រឹគនោះវិញ ហើយទើបទទួលយកមេម្រឹគដែលមានតម្លៃ ២ កហាបណៈ ។

បទថា **និស្សន្តិ លោភធម្មេសុ** សេចក្តីថា បពិត្រសក្កទេវរាជ បាបធម៌ទាំងឡាយ មានលោភៈជាដើមនេះ មានប្រាកដក្នុងសភាវៈ គឺសេចក្តីលោក

ទាំងឡាយ គឺក្នុងសត្វទាំងឡាយ ដែលត្រូវលោភៈគ្រប់សង្កត់ហើយ ព្រោះថា សត្វទាំងឡាយ មិនលោភហើយ រមែងមិនធ្វើកម្មបែបនេះ សេចក្ដីលោភមានទោសច្រើនយ៉ាងនេះ ព្រោះហេតុនោះ ទើបខ្ញុំមិនគាប់ចិត្ត ក្នុងសេចក្ដីលោភ ។

បទថា **សេ្នហសង្គន្ថិតា គន្ថា** សេចក្ដីថា អភិជ្ឈាកាយគន្ថៈ ដែលប្រព្រឹត្តទៅក្នុងអារម្មណ៍ទាំងឡាយ មានប្រការផ្សេងៗ ត្រូវស្នេហាដែលមានការជាប់ក្នុងអារម្មណ៍ទាំងឡាយជាលក្ខណៈ រួបរឹតហើយ គឺបន្តហើយ ដោយអំណាចនៃការកើតឡើងរឿយៗ ដូចផ្កាទាំងឡាយដែលគេក្រងដោយអំបោះដូច្នោះ ។

បទថា **សេន្តិ មនោមយា បុថុ** សេចក្ដីថា អភិជ្ឈាកាយគន្ថៈទាំងឡាយដែលកើតឡើងហើយក្នុងអារម្មណ៍ទាំងនោះ ឈ្មោះថា ជាគ្រឿងសម្រេចដោយចិត្ត ព្រោះជាសភាវៈដែលកើតឡើងផ្លូវចិត្ត ដូចវត្ថុទាំងឡាយ មានគ្រឿងប្រដាប់ជាដើម ដែលកើតហើយអំពីរតនៈទាំងឡាយ មានមាសជាដើម ឈ្មោះថា សម្រេចហើយដោយរតនៈទាំងឡាយ មានមាសជាដើម ដេកត្រាំក្នុងអារម្មណ៍ទាំងនោះ ។

បទថា **តេ ភុសំ ឧបតាបេន្តិ** សេចក្ដីថា កិលេសទាំងនោះបើដេកត្រាំហើយជាច្រើន គឺមានកម្លាំងដឹងច្បាស់ តែងធ្វើបុគ្គលឲ្យក្ដៅក្រហាយ គឺឲ្យលំបាកក្រៃលែង ក្នុងការដែលកិលេសទាំងនោះ ធ្វើឲ្យបុគ្គលក្ដៅក្រហាយដ៏ក្រៃលែង គប្បីនាំរឿងរបស់គាថា ( នៅក្នុងខុទ្ទកនិកាយ សុត្តនិបាត ) ថា

កាលបើសត្វនោះប្រាថ្នា មានឆន្ទៈកើតហើយ កាមនោះសាបសូន្យទៅ សត្វក៏សុបសៅទៅ ដូចជាមុតដោយសរ និងដូចសូត្រ ( ក្នុងមជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក ) ថា យ៉ាងនោះមែនគហបតី ពិតមែន គហបតី សេចក្តីសោកស្តាយ ខ្សឹកខ្សួល សេចក្តីទុក្ខតូចចិត្ត ការចង្អៀតចង្អល់ចិត្ត តែងកើតមកអំពីសេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់ជាដែនកើត និងដូចគាថា ( ខុទ្ទកនិកាយ ធម្មបទ ) ថា សេចក្តីសោក កើតអំពីសេចក្តីស្រឡាញ់ ដូច្នេះជាដើម មកជាឧទាហរណ៍ ។ ម្យ៉ាងទៀត បេះដូងសុមង្គលពោធិសត្វបែកហើយ ព្រោះសេចក្តីសោកដ៏មានកម្លាំង ព្រោះហេតុ ឲ្យកូនទាំងឡាយជាទានទោមនស្សដ៏ខ្លាំងក្លា បានកើតដល់ព្រះវេស្សន្តរពោធិសត្វ សេចក្តីស្រឡាញ់រមែងធ្វើឲ្យព្រះមហាសត្វទាំងឡាយ បំពេញបារមីហើយ ក្តៅក្រហាយបានដោយប្រការដូច្នេះ ។ ព្រោះទោសនេះ មាននៅក្នុងសេចក្តីស្នេហានោះ ទើបខ្ញុំមិនគាប់ចិត្តនូវសេចក្តីស្នេហានោះ ។

សក្កទេវរាជទ្រង់ស្តាប់ពាក្យវិសជ្ជនាបញ្ហាហើយ ទើបត្រាស់ថា បពិត្រកណ្ហបណ្ឌិត ប្រស្នានេះលោកពោលល្អហើយ ប្រៀបដូចពុទ្ធលីលា ខ្ញុំបាននូវការត្រេកអរពន់ពេក ដូច្នោះ សូមលោកទទួលពរដទៃទៀត ហើយត្រាស់គាថាទី ១០ ថា

ពាក្យនោះ លោកពោលល្អហើយ ជាសុភាសិតដ៏គួរ ម្នាលព្រាហ្មណ៍ លោកប្រាថ្នាក្នុងចិត្តចំពោះពរណាមួយ ខ្ញុំនឹងឲ្យពរ ( នោះ ) ដល់លោក ។

លំដាប់នោះ ព្រះពោធិសត្វបានពោលគាថាបន្តថា

បពិត្រសក្កៈ ជាធំជាងពួកភូតទាំងពួង បើព្រះអង្គនឹងឲ្យពរដល់
អាត្មាៗ សូមកុំឲ្យអាពាធដ៏គៀវក្លា ធ្វើអន្តរាយកើតឡើងដល់
អាត្មា ដែលនៅក្នុងព្រៃតែម្នាក់ឯងជានិច្ចឡើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អន្តរាយករា កុសា** បានដល់ ដែលធ្វើអន្តរាយដល់តបកម្មរបស់ខ្ញុំ ។

សក្កៈ ទ្រង់បានស្ដាប់ដូច្នោះហើយ ទ្រង់ព្រះតម្រិះថា កណ្ហបណ្ឌិតកាលទទួលពរដែលមិនអាស្រ័យអាមិស ទទួលពរដែលអាស្រ័យតបកម្មប៉ុណ្ណោះ សក្កទេវរាជរឹងរឹតតែជ្រះថ្លាក្រៃលែងឡើង កាលប្រទានពរដទៃទៀត ទើបត្រាស់ព្រះគាថាក្រៅអំពីនេះថា

ពាក្យនោះ លោកពោលល្អហើយ ជាសុភាសិតដ៏គួរ លោក
ប្រាថ្នាក្នុងចិត្តចំពោះពរណាមួយ ម្នាលព្រាហ្មណ៍ យើងនឹងឲ្យ
ពរ ( នោះ ) ដល់លោក ដូច្នេះ ។

ព្រះពោធិសត្វ កាលសម្ដែងធម៌ដល់សក្កៈ ដោយអាស្រ័យការទទួលពរ ទើបពោលអវសានគាថាថា

បពិត្រសក្កៈ ជាធំជាងពួកភូតទាំងពួង បើព្រះអង្គនឹងឲ្យពរដល់
អាត្មាៗ សូមកុំឲ្យចិត្ត ឬសរីរៈ ( របស់អាត្មា ) បៀតបៀន
ចំពោះអ្នកណាមួយ ព្រោះហេតុនៃអាត្មា ក្នុងកាលណាឡើយ
បពិត្រសក្កៈ សូមព្រះអង្គឲ្យនូវពរនេះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មនោ វា** បានដល់ មនោទ្វារ ។ បទថា **សរីរំ វា** បានដល់ កាយទ្វារ ។ សូម្បីវចីទ្វារ ក៏គប្បីជ្រាបថា លោកកាន់យកហើយ ដោយការកាន់យកទ្វារទាំងនោះដូចគ្នា ។ បទថា **មន្តុតេ** បានដល់ ព្រោះហេតុនៃខ្ញុំ ។ បទថា **ឧបហញ្ញេថ** បានដល់ កុំចូលទៅបៀតបៀន គឺគប្បីជាទ្វារដែលបរិសុទ្ធហើយ ។

សេចក្តីនោះមានអធិប្បាយថា បពិត្រសក្កទេវរាជ សូមកុំឲ្យកម្មដែលប្រព្រឹត្តទៅក្នុងទ្វារទាំង ៣ ចូលទៅបៀតបៀនដល់បុគ្គលណាម្នាក់ គឺដល់សក្កទេវរាជក្នុងកាលណាមួយ ព្រោះហេតុនៃខ្ញុំ គឺព្រោះអាស្រ័យខ្ញុំ បានដល់ព្រោះភាពដែលខ្ញុំជាអ្នកប្រាថ្នាចំពោះសេចក្តីវិនាស គឺសូមកម្មដែលប្រព្រឹត្តទៅក្នុងទ្វារទាំង ៣ នេះ គប្បីជាធម្មជាតដែលរួចផុតហើយ គឺបរិសុទ្ធហើយចាកអកុសលកម្មបថ ១០ ប្រការ មានបាណាតិបាតជាដើមនោះឯង ។

ព្រះមហាសត្វ កាលទទួលពរក្នុងឋានៈ ៦ បានទទួលយកពរ អាស្រ័យនេក្ខម្មៈទាំងនោះ ដោយប្រការដូច្នេះ ។ ពិតហើយ ព្រះពោធិសត្វនោះ តែងដឹងថា នេះឈ្មោះថា សរីរៈ រមែងមានជំងឺជាធម្មតា សក្កទេវរាជមិនអាចធ្វើសរីរៈនោះឲ្យមិនឈឺជាធម្មតាបានឡើយ ម្យ៉ាងទៀត ភាពដែលសត្វទាំងឡាយជាអ្នកមានខ្លួនបរិសុទ្ធហើយ ក្នុងទ្វារទាំង ៣ ដែលសក្កៈក៏មិនអាចធ្វើឲ្យជានិស្ស័យរបស់ខ្លួនបាន កាលបើដូច្នោះ ព្រះមហាសត្វក៏បានទទួលពរទាំងនោះ

ហើយ ដើម្បីសម្តែងធម៌ដល់សក្កៈនោះ សូម្បីសក្កទេវរាជក៏បានធ្វើដើមឈើនោះឲ្យជាឈើមានផ្លែមានរសផ្អែមឆ្ងាញ់ ថ្វាយបង្គំព្រះមហាសត្វ ផ្គងអញ្ជលីដាក់លើសិរសា ត្រាស់ថា សូមលោកនៅទីនេះ ដោយប្រាសចាករោគចុះ ហើយយាងទៅកាន់វិមានរបស់ទ្រង់ ។ ព្រះពោធិសត្វមានឈានមិនសាបសូន្យ បានជាអ្នកមានព្រហ្មលោកជាទីទៅខាងមុខ ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ត្រាស់ថា ម្នាលអានន្ទ នេះជាភូមិប្រទេសដែលតថាគតធ្លាប់នៅមកហើយដូច្នេះហើយ ទ្រង់ប្រជុំជាតកថា សក្កៈក្នុងកាលនោះ បានមកជាអនុរុទ្ធ ក្នុងកាលឥឡូវនេះ ឯកណ្ហបណ្ឌិតក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា កណ្ហជាតក ចប់

# សុត្តន្តបិដក

## ចតុបោសថជាតក

[ ៦៤០ ] ( ព្រះបាទវរុណនាគរាជពោលថា ) បុគ្គលណា ជាសប្បុរស មិនធ្វើនូវសេចក្ដីក្រោធ ក្នុងបុគ្គលគួរក្រោធ និង មិនក្រោធក្នុងកាលណាមួយ បុគ្គលសប្បុរសនោះ បើទុកជា ក្រោធ ក៏មិនធ្វើសេចក្ដីក្រោធឲ្យប្រាកដ បណ្ឌិតទាំងឡាយ ហៅ ជននោះឯងថា ជាសមណៈ ក្នុងលោក ។

[ ៦៤១ ] ( ព្រះបាទសុបណ្ណរាជពោលថា ) ជនណា មាន ពោះធូរ អត់ទ្រាំនូវសេចក្ដីស្រេកឃ្លានបាន ទូន្មាននូវឥន្ទ្រិយ ជា អ្នកមានតបធម៌ មានទឹក និងភោជនល្មមប្រមាណ មិនធ្វើនូវ បាប ព្រោះហេតុនៃអាហារឡើយ បណ្ឌិតទាំងឡាយ ហៅជន នោះថា ជាសមណៈ ក្នុងលោក ។

[ ៦៤២ ] ( សក្កទេវរាជពោលថា ) ជនណា លះបង់នូវល្បែង ( ដោយកាយ និងវាចា ) និងសេចក្ដីត្រេកអរ ( ក្នុងកាមគុណ ) ទាំងពួង ទាំងមិនពោលនូវពាក្យឡេះឡោះតិចតួចក្នុងលោក វៀរ ចាកហេតុជាទីតាំងនៃការស្អិតស្អាង និងមេថុនធម្ម បណ្ឌិតទាំង ឡាយ ហៅជននោះឯងថា ជាសមណៈ ក្នុងលោក ។

[ ៦៤៣ ] ( ព្រះបាទធនញ្ជ័យពោលថា ) ជនណា កំណាត់ដឹង ហើយ លះបង់នូវទ្រព្យសម្បត្តិផង លោភៈទាំងពួងផង បណ្ឌិត ទាំងឡាយ ហៅជនដែលមានខ្លួនទូន្មាន មានសភាពខ្ជាប់ខ្ជួន មិន

មានសេចក្តីប្រកាន់ថា អញមិនមានសេចក្តីប្រាថ្នានោះឯងថា ជាសមណៈ ក្នុងលោក ។

[ ៦៤៤ ] ( ព្រះរាជាទាំង ៤ ព្រះអង្គនោះត្រាស់សួរថា ) ម្នាលអ្នកមានប្រាជ្ញាមិនថោកថយ យើងទាំងឡាយសូមសួរចំពោះអ្នក ជាអ្នកធ្វើ ( នូវហេតុដែលគួរធ្វើ ) ការជជែកចំពោះពាក្យទាំងឡាយកើតមានដល់យើង សូមអ្នកកាត់នូវសេចក្តីងឿងឆ្ងល់ និងសេចក្តីសង្ស័យចេញក្នុងថ្ងៃនេះ យើងទាំងអស់គ្នាគប្បីឆ្លងនូវសេចក្តីសង្ស័យនោះ ក្នុងថ្ងៃនេះ ។

[ ៦៤៥ ] ( វិធុរបណ្ឌិតពោធិសត្វពោលថា ) បណ្ឌិតណាជាអ្នកយល់សេចក្តី បណ្ឌិតនោះ រមែងពោលដោយឧបាយនៃប្រាជ្ញាក្នុងកាលគួរ ក្នុងពាក្យជជែកនោះ បពិត្រព្រះអង្គជាធំជាងជនទាំងឡាយ ពួកជនអ្នកឈ្លាស គប្បីយល់នូវសេចក្តីនៃពាក្យពោលដែលគេមិនទាន់និយាយ ដោយប្រការដូចម្តេចបាន ។

[ ៦៤៦ ] ស្តេចនាគពោលដូចម្តេច ស្តេចគ្រុឌវេនតេយ្យពោលដូចម្តេច ស្តេចគន្ធព្វ ( ព្រះឥន្ទ ) ពោលដូចម្តេច ស្តេចដ៏ប្រសើររបស់អ្នកដែនកុរុពោលដូចម្តេច ។

[ ៦៤៧ ] ( ព្រះរាជាទាំងឡាយនោះឆ្លើយថា ) ស្តេចនាគពោលចំពោះខន្តិធម៌តែម្យ៉ាង ស្តេចគ្រុឌវេនតេយ្យពោលចំពោះអាហារតិច ស្តេចគន្ធព្វពោលចំពោះការលះបង់សេចក្តីត្រេកអរ

ស្តេចដ៏ប្រសើររបស់អ្នកដែនកុរុពោលចំពោះការមិនមានកន្លង់ ។

[ ៦៤៨ ] ( ព្រះពោធិសត្វពោលថា ) ពាក្យទាំងអស់នេះ ជាសុភាសិត ពាក្យជាទុព្ភាសិតសូម្បីបន្តិចបន្តួច ក៏មិនមានក្នុងប្រស្នានេះទេ ម្យ៉ាងទៀត ពាក្យទាំងនេះ តាំងនៅស៊ប់ ប្រជុំចុះដោយល្អក្នុងបុគ្គលណា ដូចជាកាំរទេះដែលគេបញ្ចុះស៊ប់ក្នុងដុំ បណ្ឌិតទាំងឡាយ ហៅបុគ្គលដែលព្រមព្រៀងដោយធម៌ ៤ យ៉ាងនោះឯងថា ជាសមណៈ ក្នុងលោក ។

[ ៦៤៩ ] ( ព្រះរាជាទាំង ៤ ព្រះអង្គ ... ) អ្នកជាបុគ្គលប្រសើរ អ្នកជាបុគ្គលមិនមានអ្នកណាវិសេសជាង អ្នកជាបុគ្គលដល់នូវត្រើយនៃធម៌ ចេះដឹងនូវធម៌ មានយោបល់ដ៏ល្អ កំណាត់ដឹងនូវប្រស្នាដោយប្រាជ្ញា អ្នកជាអ្នកប្រាជ្ញ បានផ្តាច់សេចក្តីសង្ស័យចេញហើយ អ្នកបានកាត់នូវសេចក្តីសង្ស័យ និងសេចក្តីងឿងឆ្ងល់ ដូចជាគេកាត់នូវក្លុកនៃដំរី ដោយរណារ ។

[ ៦៥០ ] ( សក្កទេវរាជ ... ) បពិត្រអ្នកប្រាជ្ញ ខ្ញុំត្រេកអរនឹងការដោះនូវប្រស្នា ហើយជូនសំពត់នេះ មានពន្លឺដូចផ្កាឧប្បលខៀវ មិនមានមន្ទិល ជាសំពត់កាត់ថ្លៃមិនបាន មានពណ៌ស្មើដោយផ្សែង ដើម្បីបូជានូវធម៌របស់អ្នក ។

[ ៦៥១ ] ( សុបណ្ណរាជ ... ) បពិត្រអ្នកប្រាជ្ញ ខ្ញុំត្រេកអរនឹងការដោះនូវប្រស្នា ហើយជូននូវកម្រងផ្កាមាស ដែលរីកសំពោង

ដោយត្របកច្រើនស្រទាប់ ប្រកបដោយលម្អដ៏ប្រដាប់ដោយកែវដ៏ច្រើន ដើម្បីបូជានូវធម៌របស់អ្នក ។

[ ៦៥២ ] ( វរុណនាគរាជ ... ) បពិត្រអ្នកប្រាជ្ញ ខ្ញុំត្រេកអរនឹងការដោះស្រាយនូវប្រស្នា ហើយជូននូវកែវមុនី ដែលកាត់ថ្លៃមិនបាន ជាកែវដ៏រុងរឿង មានពន្លឺផ្ទេកៗ សម្រាប់ពាក់ព្ធដ៏ក ដែលស្អិតស្អាងដោយកែវមុនី ដើម្បីបូជានូវធម៌របស់អ្នក ។

[ ៦៥៣ ] ( ព្រះរាជា ... ) ខ្ញុំត្រេកអរនឹងការដោះស្រាយនូវប្រស្នា ហើយជូននូវគោមួយពាន់ ទាំងគោឧសភផង ដំរីផង រថ ១០ ដែលទឹមដោយសេះអាជានេយ្យនេះផង ស្រុកសួយ ១៦ ផងដល់អ្នក ។

[ ៦៥៤ ] អ្នកទាំងឡាយ ចូរចាំទុកនូវជាតកយ៉ាងនេះថា ស្តេចនាគក្នុងកាលណោះ បានមកជាព្រះសារីបុត្ត ស្តេចគ្រុឌបានមកជាកោលិតភិក្ខុ ( មោគ្គល្លាន ) ស្តេចគន្ធព្វបានមកជាព្រះអនុរុទ្ធ ស្តេចបានមកជាអានន្ទបណ្ឌិត វិធុរពោធិសត្វ គឺតថាគត ។

## ចតុប្បោសថជាតកទី ៣ ចប់

# អដ្ឋកថា

## ចតុប្បោសថជាតក

[ ៦៤០-៦៥៤ ] *ចតុប្បោសថជាតកនេះ មានពាក្យផ្ដើមថា* **យោ កោបនេយ្យេ** *សេចក្ដីមានជាក់ច្បាស់ក្នុងបុណ្ណកជាតក ( វិធុរជាតក )* ។ល។

**អដ្ឋកថា ចតុប្បោសថជាតក ចប់**

# សុត្តន្តបិដក

## សន្ធជាតក

[ ៦៥៥ ] ( អ្នកបម្រើពោលថា ) បពិត្រសន្ធព្រាហ្មណ៍ អ្នកជាពហុស្សូត ធ្លាប់បានស្តាប់ធម៌ ទាំងសមណព្រាហ្មណ៍ អ្នកក៏បានជួបហើយ កាលបើដូច្នេះ ( ហេតុអ្វី ) ទើបអ្នកសម្តែងនូវពាក្យរវើរវាយ ក្នុងកាលមិនមែនជាខណៈ អ្នកណាទៀតហ្ន៎ ជាអ្នកប្រឹក្សាចំពោះអ្នក ក្រៅអំពីខ្ញុំ ។

[ ៦៥៦ ] ( សន្ធព្រាហ្មណ៍ពោលថា ) ទេវធីតាមានមុខល្អ មានរូបល្អ មានមាសពាក់ដោយល្អ កាន់នូវ ( កត្ត ) ដោយកាជន៍មាស មានសទ្ធា មានចិត្តរីករាយ និយាយនឹងយើងថា អ្នកចូរបរិភោគនូវកត្តចុះ យើងនិយាយនឹងទេវតានោះថា យើងមិន ( បរិភោគ ) ទេ ។

[ ៦៥៧ ] ( លំដាប់នោះ អ្នកបម្រើពោលថា ) ម្នាលព្រាហ្មណ៍ ធម្មតាបុរសអ្នកប្រាថ្នាសេចក្តីសុខ កាលបានឃើញយក្ខប្រាកដដូច្នោះហើយ គួរណាស់តែសួរ ( ឲ្យដឹង ) អ្នកចូរក្រោកឡើង ហើយប្រណម្យដៃ សួរយក្ខនោះថា នាងជាទេវធីតា ឬជាមនុស្ស ។

[ ៦៥៨ ] ( សន្ធព្រាហ្មណ៍ពោធិសត្វពោលថា ) នាងបានគយគន់មើលយើងដោយសេចក្តីសុខ និយាយនឹងយើងថា អ្នកចូរបរិភោគនូវកត្តចុះ ម្នាលនាងនារី អ្នកមានអានុភាពធំ យើងសូមសួរនាង តើនាងជាទេវធីតា ឬជាមនុស្ស ។

[ ៦៥៩ ] ( ទេវធីតាពោលថា ) បពិត្រសង្ខព្រាហ្មណ៍ ខ្ញុំជាទេវធីតាមានអានុភាពធំ មកក្នុងកណ្តាលសាគរនេះ ព្រោះខ្ញុំមានសេចក្តីអនុគ្រោះ មិនមែនមានចិត្តប្រទូស្តទេ ទើបមកក្នុងទីនេះ ដើម្បីប្រយោជន៍ចំពោះអ្នកតែម្យ៉ាង ។

[ ៦៦០ ] បពិត្រសង្ខព្រាហ្មណ៍ ក្នុងសមុទ្ទនេះ មានបាយ ទឹក ទីដេក ទីអង្គុយ និងយានផ្សេងៗ ជាច្រើន អ្នកមានចិត្តប្រាថ្នាចំពោះរបស់ណាមួយ ខ្ញុំនឹងប្រគល់ឲ្យរបស់ទាំងអស់នោះដល់អ្នក ។

[ ៦៦១ ] ( ព្រះពោធិសត្វពោលថា ) បពិត្រនាងទេវធីតា មានរាងខ្លួនល្អ មានភ្នៀវល្អ មានវង់ចិញ្ចើមល្អ មានអវយវៈពាក់កណ្តាលខ្លួនល្អ ការបូជាធំក្តី បូជាតូចក្តី ណាមួយរបស់ខ្ញុំ នាងជាឥស្សរៈនៃបុញ្ញកម្ម របស់យើងនោះទាំងអស់ នេះជាផលនៃកម្មរបស់ខ្ញុំដូចម្តេច ។

[ ៦៦២ ] ( នាងទេវធីតាពោលថា ) បពិត្រសង្ខព្រាហ្មណ៍ អ្នកបានប្រគេនស្បែកជើង ចំពោះភិក្ខុ ១ អង្គ ( ព្រះបច្ចេកពុទ្ធ ) ដែលមានជើងកំពុងរលាក ស្រេកឃ្លាន លំបាក ក្នុងផ្លូវដ៏ក្តៅ ទក្ខិណាទាននោះ ឲ្យនូវសេចក្តីប្រាថ្នាដល់អ្នក ក្នុងថ្ងៃនេះ ។

[ ៦៦៣ ] ( ព្រះពោធិសត្វពោលថា ) សូមឲ្យកើតសំពៅដែលពាសដោយផែនក្តារ ជាសំពៅមិនលិចទឹក ប្រកបដោយ

ក្តៅង និងខ្យល់ ព្រោះថា ក្នុងសមុទ្រនេះ មិនមែនជាភូមិនៃយាន ជទៃឡើយ សូមនាងចម្លងខ្ញុំ ឲ្យដល់នូវក្រុងមោលិនី ក្នុងថ្ងៃនេះ ។

[ ៦៦៤ ] ( អភិសម្ពុទ្ធគាថា ) ទេវតានោះ មានចិត្តត្រេកអរ រីករាយសប្បាយ និម្មិតសំពៅដ៏វិចិត្រល្អ ហើយនាំសង្ខព្រាហ្មណ៍ ព្រមទាំងបុរសឧបដ្ឋាក ចូលទៅកាន់ក្រុង ជាទីសុខសាន្ត ។

## សង្ខជាតកទី ៤ ចប់

# អដ្ឋកថា

## សព្វជាតក

[ ៦៥៥-៦៦៤ ] ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការថ្វាយបរិក្ខារទាំងពួង ទើបត្រាស់រឿងនេះ មានពាក្យផ្ដើមថា **ពហុស្សុតោ** ដូច្នេះជាដើម ។

បានឮថា ក្នុងនគរសាវត្ថី មានឧបាសកម្នាក់ ស្ដាប់ធម្មទេសនារបស់ព្រះតថាគតហើយ មានចិត្តជ្រះថ្លាក្នុងព្រះសាស្ដា ទើបចូលទៅនិមន្តដើម្បីឆាន់ក្នុងថ្ងៃស្អែក ហើយឲ្យធ្វើមណ្ឌបក្បែរទ្វារផ្ទះរបស់ខ្លួន ប្រដាប់តាក់តែងយ៉ាងល្អ ស្អែកឡើង ឲ្យមនុស្សទៅក្រាបទូលកត្តកាលដល់ព្រះតថាគត ។ ព្រះសាស្ដា មានភិក្ខុ ៥០០ ជាបរិវារ យាងទៅក្នុងទីនោះ គង់លើបវរ-ពុទ្ធាសនៈ ដែលឧបាសកក្រាល ឧបាសក មួយអន្លើដោយបុត្រភរិយា និងបរិវារជន ថ្វាយមហាទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន បាននិមន្តឆាន់ថ្វាយមហាទានយ៉ាងនេះអស់ ៧ ថ្ងៃ ក្នុងថ្ងៃទី ៧ បានថ្វាយគ្រឿងបរិក្ខារគ្រប់យ៉ាង កាលនឹងថ្វាយនោះ បានរៀបចំស្បែកជើងថ្វាយជាវិសេស គឺថ្វាយដល់ព្រះទសពល ដែលមានតម្លៃ ១០០០ ថ្វាយអគ្គសាវកទាំង ២ មានតម្លៃ ៥០០ ថ្វាយដល់ភិក្ខុ ៥០០ អង្គក្រៅអំពីនោះ មានតម្លៃ ១០០ ។ ឧបាសកនោះ កាលថ្វាយគ្រឿងបរិក្ខារគ្រប់យ៉ាងដូច្នេះហើយ បានទៅអង្គុយក្នុងសម្នាក់ព្រះមានព្រះភាគ ជាមួយរបស់បរិស័ទខ្លួន ។

កាលនោះ ព្រះសាស្ដា កាលទ្រង់អនុមោទនា ដោយព្រះសូរសៀងដ៏

ពីរោះដល់ឧបាសកនោះ បានត្រាស់ថា នែឧបាសក ការថ្វាយគ្រឿងបរិក្ខារគ្រប់យ៉ាងរបស់អ្នកឱឡារក្រៃលែង ចូរអ្នកត្រេកអរចុះ ក្នុងកាលមុនដែលព្រះសម្ពុទ្ធមិនទាន់កើតឡើង ជនទាំងឡាយ ប្រគេនស្បែកជើងមួយគូដល់ព្រះបច្ចេកពុទ្ធ ធ្វើដំណើរតាមសំពៅទៅ សំពៅបែកធ្លាយក្នុងមហាសមុទ្រ មិនមានទីពឹង បុរសនោះ បានទីពឹង ដោយផលានិសង្សដែលប្រគេនស្បែកជើងឯខ្លួនអ្នក បានថ្វាយបរិក្ខារគ្រប់យ៉ាងដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ផលនៃការប្រគេនស្បែកជើងរបស់អ្នកនោះ រឿងអ្វីដែលមិនបានជាទីពឹងនោះ ដូច្នេះហើយ ឧបាសកនោះ ក្រាបទូលអារាធនាឲ្យត្រាស់រឿង ទើបទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចទៅ

ក្នុងអតីតកាល នគរពារាណសី មានឈ្មោះថា មោលិនី ព្រះបាទព្រហ្មទត្ត គ្រងរាជសម្បត្តិក្នុងនគរមោលិនីនោះ ។ មានព្រាហ្មណ៍ម្នាក់ឈ្មោះសង្ខៈ ជាអ្នកស្តុកស្តម្ភ មានភោគៈច្រើន មានគ្រឿងដែលធ្វើឲ្យត្រេកអរ ដូចជាទ្រព្យ ស្រូវ ប្រាក់ និងមាសជាច្រើន ឲ្យធ្វើរោងទាន ៦ កន្លែង គឺត្រង់ទ្វារនគរទាំង ៤ ត្រង់កណ្តាលព្រះនគរ ១ និងត្រង់ទ្វារផ្ទះ ១ លះទ្រព្យមួយថ្ងៃ ៦ សែន ធ្វើនូវមហាទានដល់មនុស្សកំព្រា និងអ្នកធ្វើដំណើរ ដែលជាអាគន្តុកៈរាល់ថ្ងៃ ។ ថ្ងៃមួយ គាត់គិតថា កាលទ្រព្យក្នុងផ្ទះអស់ហើយ អញមិនអាចឲ្យទានបាន កាលទ្រព្យមិនទាន់អស់ទៅនេះ អញនឹងចេញសំពៅទៅសុវណ្ណភូមិ នាំទ្រព្យមក គិតដូច្នេះហើយ ទើបរៀបចំសំពៅ ផ្ទុកទំនិញទាល់តែពេញ ហើយហៅបុត្រភរិយាមកប្រាប់ថា ពួកនាងចូរឲ្យទានរបស់យើង

ប្រព្រឹត្តទៅកុំឲ្យដាច់ ទម្រាំយើងត្រឡប់មក ហើយចោមរោមដោយទាសៈ និង កម្មករ បាំងឆត្រ ពាក់ស្បែកជើង ដើរតម្រង់ទៅកាន់កំពង់ក្នុងពេលថ្ងៃត្រង់ ។ ក្នុងគ្រានោះ នៅឯភ្នំគន្ធមាទន៍ មានព្រះបច្ចេកពុទ្ធមួយអង្គ ពិចារណាមើល ក៏បានឃើញព្រាហ្មណ៍នោះ កំពុងធ្វើដំណើរដើម្បីនាំទ្រព្យមក ទើបពិចារណា មើលថា មហាបុរសនឹងទៅរកទ្រព្យ អន្តរាយមានក្នុងសមុទ្រដែរឬហ្ន៎ ក៏ជ្រាប ថា នឹងមានអន្តរាយ ទើបគិតថា មហាបុរសនេះ ឃើញអាត្មាអញហើយ នឹងប្រគេនឆត្រ ស្បែកជើង ដល់អញ កាលសំពៅបែកធ្លាយកណ្តាលសមុទ្រ បុរសនេះនឹងបាននូវទីពឹង ដោយអានិសង្សដែលប្រគេនស្បែកជើង អញនឹង អនុគ្រោះដល់បុរសនេះ ហើយក៏ហោះមកចុះក្នុងទីជិតសង្ខព្រាហ្មណ៍ និមន្ត ជាន់ដីខ្សាច់ក្តៅ ដូចគ្នានឹងរងើកភ្លើង ព្រោះខ្យល់ និងកម្តៅខ្លាំងក្លា តម្រង់ មកកាន់សង្ខព្រាហ្មណ៍ ។

សង្ខព្រាហ្មណ៍ គ្រាន់តែឃើញព្រះបច្ចេកពុទ្ធប៉ុណ្ណោះ ក៏ត្រេកអរថា បុញ្ញក្ខេត្តរបស់អញមកដល់ហើយ ថ្ងៃនេះ អញគួរព្រោះពូជ គឺទានក្នុងបុញ្ញ-ក្ខេត្តនេះ ទើបប្រញាប់ចូលទៅនមស្ការព្រះបច្ចេកពុទ្ធ ហើយពោលថា បពិត្រ លោកម្ចាស់ ដើម្បីអនុគ្រោះខ្ញុំ សូមលោកម្ចាស់ចុះអំពីផ្លូវបន្តិច ហើយចូល ទៅត្រង់គល់ឈើនេះ លុះព្រះបច្ចេកពុទ្ធចូលទៅត្រង់គល់ឈើ ក៏ពូនខ្សាច់ ឡើង យកសំពត់ដណ្តប់ក្រាល នមស្ការព្រះបច្ចេកពុទ្ធ ហើយលាងជើងដោយ ទឹកដែលអប់ និងត្រងស្អាត លាបជើងដោយប្រេងក្រអូប ដោះស្បែកជើងដែល ខ្លួនពាក់ លាបដោយគ្រឿងក្រអូប ហើយពាក់ត្រង់ជើងព្រះបច្ចេកពុទ្ធ ប្រគេន

ឆត្រ និងស្បែកជើងដោយវាចាថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ពាក់ស្បែកជើង និងបាំងឆត្រចុះ ។

ព្រះបច្ចេកពុទ្ធដើម្បីអនុគ្រោះសង្ខព្រាហ្មណ៍ ទើបទទួលឆត្រ និងស្បែកជើង ដើម្បីឲ្យសេចក្ដីជ្រះថ្លារីងរឹតតែចម្រើនឡើង ទើបហោះទៅភ្នំគន្ធមាទន៍ ឲ្យសង្ខព្រាហ្មណ៍ឃើញនោះឯង ។

សង្ខព្រាហ្មណ៍ពោធិសត្វបានឃើញដូច្នោះហើយ មានចិត្តជ្រះថ្លាក្រៃលែង ដើរទៅកាន់កំពង់ កាលសង្ខព្រាហ្មណ៍កំពុងធ្វើដំណើរកណ្ដាលមហាសមុទ្រ លុះដល់ថ្ងៃទី ៧ សំពៅក៏បានធ្លាយ ទឹកហូរចូល មិនមាននរណាអាចបាចទឹកឲ្យអស់បាន មហាជនខ្លាចចំពោះមរណភ័យ ក៏នាំគ្នានមស្ការទេវតាដែលខ្លួនរាប់អានរៀងៗ ខ្លួន ស្រែកបន់ស្រន់ ។ ព្រះមហាសត្វ និងឧបដ្ឋាក គឺអ្នកបម្រើម្នាក់ លាបសរីរៈដោយប្រេង ទំពាលម្អិតស្ករផែនជាមួយសប្បិ គ្រប់គ្រាន់ដល់សេចក្ដីត្រូវការហើយ ឲ្យឧបដ្ឋាកបរិភោគផងដែរ ឡើងលើសសរក្ដោងជាមួយឧបដ្ឋាក កំណត់ទិសថា នគររបស់យើងនៅទិសនេះ កាលនឹងដោះខ្លួនអំពីអន្តរាយ មានត្រី និងអណ្ដើក ទើបលោតបំផ្លោងទៅក្នុងទីមានប្រមាណមួយឧសភជាមួយឧបដ្ឋាកនោះ ។ មហាជនវិនាសអស់ ចំណែកព្រះមហាសត្វ និងឧបដ្ឋាកព្យាយាមហែលឆ្លងមហាសមុទ្រអស់ ៧ ថ្ងៃ ថ្ងៃនោះ ជាថ្ងៃឧបោសថ ព្រះពោធិសត្វបានខ្ពុរមាត់ដោយទឹកប្រៃ ហើយរក្សាឧបោសថ ។

សម័យនោះ ទេពធីតាឈ្មោះមណីមេខលា បានទទួលការតែងតាំងអំពី

ស្តេចចតុលោកបាលទាំង ៤ ឲ្យជាអ្នករក្សាសមុទ្រ ដោយប្រាប់ថា បើសំពៅបែកធ្លាយ មនុស្សដែលដល់ត្រៃសរណគមន៍ក្តី មានសីលបរិបូណ៌ក្តី បដិបត្តិប្រពៃក្នុងមាតាបិតាក្តី ដែលដល់ហើយនូវសេចក្តីទុក្ខក្នុងសមុទ្រនេះ នាងគប្បីរក្សាបុគ្គលនោះ ។ ទេពធីតាប្រមាទ ដោយភាពជាធំរបស់ខ្លួនអស់ ៧ ថ្ងៃ រហូតដល់ថ្ងៃទី ៧ ទើបនាងមកមើលសមុទ្រ បានឃើញសង្ខព្រាហ្មណ៍ប្រកបដោយសីល និងអាចារ កើតសេចក្តីសង្វេគគិតថា ព្រាហ្មណ៍នេះលំបាកអស់ ៧ ថ្ងៃហើយ បើព្រាហ្មណ៍នេះស្លាប់ អញនឹងបានទទួលនូវការតិះដៀលជាច្រើន ហើយនាងបានរៀបចំថាសមាសមួយ ដែលពេញដោយទិព្វភោជនមានរសប្រសើរផ្សេងៗ ហោះទៅក្នុងទីនោះដោយរហ័ស ឈរលើអាកាស ក្នុងទីចំពោះមុខសង្ខព្រាហ្មណ៍ ពោលថា បពិត្រព្រាហ្មណ៍ លោកអត់អាហារ ៧ ថ្ងៃហើយ ចូរបរិភោគទិព្វភោជននេះចុះ ។ សង្ខព្រាហ្មណ៍សម្លឹងមើលទេពធីតា ហើយពោលថា ចូរនាំភត្តរបស់នាងចេញទៅ យើងរក្សាឧបោសថ ។ គ្រានោះ ឧបដ្ឋាកដែលនៅខាងក្រោយ មិនឃើញទេវតា បានឮតែសំឡេង គិតថា ព្រាហ្មណ៍នេះ ជាសុខុលជាតិដោយប្រក្រតី មកអត់អាហារ លំបាកអស់ ៧ ថ្ងៃ ប្រហែលជារវើរវាយខ្លាចស្លាប់ អញនឹងលួងលោមព្រាហ្មណ៍ គិតដូច្នេះហើយ បានពោលគាថាទី ១ ថា

បពិត្រសង្ខព្រាហ្មណ៍ អ្នកជាពហុស្សូត ធ្លាប់បានស្តាប់ធម៌ ទាំងសមណព្រាហ្មណ៍ អ្នកក៏បានជួបហើយ កាលបើដូច្នេះ ( ហេតុអ្វី ) ទើបអ្នកសម្តែងនូវពាក្យរវើរវាយ ក្នុងកាលមិនមែនជាខណៈ

អ្នកណាទៀតហ្ន៎ ជាអ្នកប្រឹក្សាចំពោះអ្នក ក្រៅអំពីខ្ញុំ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សុតធម្មោសិ** សេចក្តីថា សូម្បីធម៌ លោកបានស្តាប់មកហើយ ក្នុងសម្នាក់របស់សមណព្រាហ្មណ៍ ដែលតាំងនៅក្នុងធម៌ទាំងឡាយ ។ បទថា **ទិដ្ឋា** សេចក្តីថា ទាំងសមណព្រាហ្មណ៍ដែលតាំងនៅក្នុងធម៌ទាំងឡាយ ដែលលោកអ្នកឲ្យបច្ច័យដល់សមណព្រាហ្មណ៍ហើយនោះ ធ្វើនូវសេចក្តីខ្វល់ខ្វាយ ក៏បានឃើញមកហើយ លោកកាលធ្វើយ៉ាងនេះ ក៏ឃើញសមណព្រាហ្មណ៍ទាំងនោះមិនបាន ។ បទថា **អជក្ខណោ** កាត់បទជា **អជ អក្ខណោ** បានដល់ ក្នុងខណៈដែលមិនមែនឱកាសត្រូវនិយាយព្រោះមិនមានបុគ្គលណាម្នាក់ដែលចរចាជាមួយ ។ បទថា **ឧស្សយសេ** សេចក្តីថា លោកកាលពោលថា យើងរក្សាឧបោសថ ឈ្មោះថា ពោលនូវពាក្យផ្តេសផ្តាស ។ បទថា **បដិមន្តកោ** សេចក្តីថា អ្នកដទៃក្រៅអំពីខ្ញុំ អ្នកណាគេនឹងមកចរចា គឺមកឲ្យនូវពាក្យសម្តីជាមួយលោកបាន ព្រោះហេតុអ្វីទើបលោករវើរវាយយ៉ាងនេះ ។

សន្ទព្រាហ្មណ៍បានស្តាប់ពាក្យរបស់ឧបដ្ឋាកហើយ ទើបគិតថា ប្រហែលជាទេវតានោះមិនប្រាកដដល់បុរសនេះ ទើបពោលថា នែសម្លាញ់ អញមិនបានខ្លាចមរណភ័យ អ្នកដទៃដែលមកនិយាយជាមួយអញមាន ហើយពោលនូវគាថាទី ២ ថា

ទេវធីតាមានមុខល្អ មានរូបល្អ មានមាសពាក់ដោយល្អ កាន់នូវ ( ភត្ត ) ដោយភាជន៍មាស មានសទ្ធា មានចិត្តរីករាយ និយាយ

នឹងយើងថា អ្នកចូរបរិភោគនូវកត្តុចុះ យើងនិយាយនឹងទេវតា

នោះថា យើងមិន ( បរិភោគ ) ទេ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សុត្ថា** បានដល់ អ្នកមានមុខល្អ ។ បទថា **សុភា** បានដល់ មានរូបរាងដ៏ស្អាត គួរជ្រះថ្លា ។ បទថា **សុប្បដិមុក្កកម្ពុ** បានដល់ ប្រដាប់ដោយគ្រឿងអលង្ការមាស ។ បទថា **បគយ្ហា** បានដល់ ជាសកត្តាហារលើកឡើង ។ បទថា **សទ្ធា វិត្តា** បានដល់ មានសទ្ធាផង មានចិត្តត្រេកអរផង ។ បាលីថា **សទ្ធា វិត្តំ** ដូច្នេះក៏មាន សេចក្ដីនោះ មានអត្ថថា បទថា **សទ្ធា** បានដល់ ដែលជឿ ។ បទថា **វិត្តំ** បានដល់ មានចិត្តត្រេកអរហើយ ។ បទថា **តមហំ នោ** សេចក្ដីថា កាលយើងបដិសេធព្រោះភាពដែលខ្លួនជាអ្នករក្សាឧបោសថ ទើបឆ្លើយនឹងទេវតានោះថា មិនបរិភោគ យើងមិនរវើរវាយទេ សម្លាញ់ ។

គ្រានោះ អ្នកបម្រើបានពោលគាថាទី ៣ ដល់សន្ធព្រាហ្មណ៍ថា

ម្នាលព្រាហ្មណ៍ ធម្មតាបុរស អ្នកប្រាថ្នាសេចក្ដីសុខ កាលបាន

ឃើញយក្ខប្រាកដដូច្នោះហើយ គួរណាស់តែសួរ ( ឲ្យដឹង ) អ្នក

ចូរក្រោកឡើង ហើយប្រណម្យដៃ សួរយក្ខនោះថា នាងជាទេវធីតា

ឬជាមនុស្ស ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សុខមាសីសានោ** សេចក្ដីថា បុរសជាបណ្ឌិត ដែលប្រាថ្នាសេចក៏សុខដើម្បីខ្លួន បានជួបទេវតាបែបនេះហើយ គួរសាកសួរមើលថា សេចក្ដីសុខនឹងមានដល់ខ្ញុំដែរឬទេ ។ បទថា **ឧដ្ឋេហិ** សេចក្ដី

ថា លោកកាលសម្តែងអាការក្រោកឡើងអំពីទឹក ឈ្មោះថា ចូរក្រោកឡើង ។ បទថា **បញ្ជលិកាភិបុច្ឆ** បានដល់ ចូរជាអ្នកប្រណម្យដៃសួរ ។ បទថា **ឧឧមានុសី** សេចក្តីថា ឬនាងជាមនុស្សមានឫទ្ធិច្រើន ។

ព្រះពោធិសត្វគិតថា ឧបដ្ឋាកនិយាយត្រូវ កាលនឹងសួរទេពធីតានោះ បានពោលគាថាទី ៤ ថា

នាងបានគយគន់ មើលយើងដោយសេចក្តីសុខ និយាយនឹងយើង
ថា អ្នកចូរបរិភោគនូវកត្តុះ ម្នាលនាងនារី អ្នកមានអានុភាពធំ
យើងសូមសួរនាង តើនាងជាទេវធីតា ឬជាមនុស្ស ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យំ ត្វំ** សេចក្តីថា ព្រោះហេតុណា ទើបនាងមកសម្លឹងយើងដោយក្រសែភ្នែកសម្តែងសេចក្តីស្រឡាញ់ ។ បទថា **អភិ-សក្ខេសេ** បានដល់ សម្លឹងមើលដោយចក្ខុដែលសម្តែងសេចក្តីស្រឡាញ់ ។ បទថា **បុច្ឆាមិ តំ** សេចក្តីថា ព្រោះហេតុនោះ ទើបខ្ញុំសូមសួរនាង ។ លំដាប់នោះ ទេពធីតាពោល ២ គាថាថា

បពិត្រសង្ខព្រាហ្មណ៍ ខ្ញុំជាទេវធីតាមានអានុភាពធំ មកក្នុងកណ្តាលសាគរនេះ ព្រោះខ្ញុំមានសេចក្តីអនុគ្រោះ មិនមែនមានចិត្តប្រទូស្តទេ ទើបមកក្នុងទីនេះ ដើម្បីប្រយោជន៍ចំពោះអ្នកតែម្យ៉ាង ។

បពិត្រសង្ខព្រាហ្មណ៍ ក្នុងសមុទ្រនេះ មានបាយ ទឹក ទីដេក ទីអង្គុយ និងយានផ្សេងៗ ជាច្រើន អ្នកមានចិត្តប្រាថ្នាចំពោះរបស់

ណាមួយ ខ្ញុំនឹងប្រគល់ឲ្យរបស់ទាំងអស់នោះដល់អ្នក ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឥធ** បានដល់ ក្នុងមហាសមុទ្រនេះ ។ បទថា **នានាវិធានិ** បានដល់ មានយានពាហនៈ គឺដំរី និងយានពាហនៈ មានសេះជាដើមសន្ធឹកសន្ធាប់ច្រើនយ៉ាង ។ បទថា **សព្វស្ស ត្យាហំ** សេចក្ដីថា ខ្ញុំនឹងឲ្យបាយទឹកជាដើមនោះសម្រេចដល់អ្នក គឺឲ្យអ្នកជាម្ចាស់នៃបាយ និងទឹកជាដើមនោះគ្រប់យ៉ាង ។ បទថា **យំកិញ្ចិ** សេចក្ដីថា ចិត្តរបស់អ្នកចង់បានវត្ថុណាមួយ ខ្ញុំនឹងឲ្យវត្ថុគ្រប់យ៉ាងដល់អ្នក ។

ព្រះមហាសត្វបានស្ដាប់ដូច្នោះហើយ គិតថា ទេវតានេះពោលថា នឹងឲ្យយ៉ាងនោះ យ៉ាងនេះ ដល់អញកណ្ដាលផ្ទៃទឹក នាងប្រាថ្នានឹងឲ្យដោយបុញ្ញកម្ម ដែលអញធ្វើទុក ឬនឹងឲ្យដោយអានុភាពរបស់ខ្លួន អញនឹងសាកសួរមើល កាលនឹងសាកសួរ បានពោលគាថាទី ៧ ថា

បពិត្រនាងទេវធីតា មានរាងខ្លួនល្អ មានភ្នៅល្អ មានវង់ចិញ្ចើមល្អ មានអវយវៈពាក់កណ្ដាលខ្លួនល្អ ការបូជាធំក្ដី បូជាតូចក្ដីណាមួយរបស់ខ្ញុំ នាងជាឥស្សរៈនៃបុញ្ញកម្ម របស់យើងនោះទាំងអស់ នេះជាផលនៃកម្មរបស់ខ្ញុំដូចម្ដេច ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យិដ្ឋំ** បានដល់ បូជាហើយ ដោយអំណាចនៃទាន ។ បទថា **ហុតំ** បានដល់ ឲ្យហើយ ដោយអំណាចនៃអាហុនេយ្យទាន និងបាហុនេយ្យទាន ។ បទថា **សព្វស្ស នោ ឥស្សរា តុំ** សេចក្ដីថា នាងជាឥស្សរៈ គឺជាអ្នកអាចដឹងវិបាកនៃបុញ្ញកម្មរបស់ខ្ញុំនោះគ្រប់

យ៉ាងថា នេះជាវិបាកនៃកម្មនេះ នេះជាវិបាកនៃកម្មនេះ ។ បទថា **សុស្សោណិ** បានដល់ ជាអ្នកមានលក្ខណៈនៃគល់ភ្លៅល្អ ។ បទថា **សុភ្ញា** បានដល់ ជាអ្នកមានចិញ្ចើមល្អ ។ បទថា **សុវិលាកមជ្ឈេ** បានដល់ ត្រង់កណ្ដាលខ្លួនរៀវមូលក្ងំ ។ បទថា **កិស្ស មេ** សេចក្ដីថា បណ្ដាកម្មដែលខ្ញុំធ្វើហើយ ការដែលខ្ញុំបានទីពឹងក្នុងមហាសមុទ្រ ដែលមិនមានទីពឹងនេះ ជាវិបាកនៃកម្មអ្វី ។

នាងទេពធីតាបានស្ដាប់ដូច្នោះ ទើបគិតថា ព្រាហ្មណ៍នេះ ប្រហែលជាសួរដោយសម្គាល់ថា អញដឹងកុសលកម្មដែលគាត់ធ្វើ ឥឡូវនេះ អញនឹងពោលទានរបស់គាត់ ទើបពោលគាថាទី ៨ ថា

បពិត្រសង្ខព្រាហ្មណ៍ អ្នកបានប្រគេនស្បែកជើង ចំពោះភិក្ខុ ១ អង្គ ( ព្រះបច្ចេកពុទ្ធ ) ដែលមានជើងកំពុងរលាក ស្រេកឃ្លាន លំបាក ក្នុងផ្លូវដ៏ក្ដៅ ទក្ខិណាទាននោះ ឲ្យនូវសេចក្ដីប្រាថ្នាដល់អ្នក ក្នុងថ្ងៃនេះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឯកភិក្ខុំ** បានដល់ ទេពធីតាពោលសំដៅយកព្រះបច្ចេកពុទ្ធអង្គនោះ ។ បទថា **ឧគ្ឃដ្ដបាទំ** បានដល់ ដើរដោយចុងម្រាម ព្រោះខ្សាច់ក្ដៅ ។ បទថា **តសិតំ** បានដល់ ជាអ្នកក្រវល់ក្រវាយហើយ ។ បទថា **បដិបាទយិ** សេចក្ដីថា បានប្រគេនហើយ គឺបានប្រកបហើយ ។ បទថា **កាមទុហា** បានដល់ឲ្យ នូវរបស់ដែលគួរប្រាថ្នាគ្រប់យ៉ាង ។

ព្រះមហាសត្វបានស្ដាប់ដូច្នោះហើយ មានចិត្តត្រេកអរ គិតថា ការថ្វាយស្បែកជើងដែលអញបានឲ្យហើយ ឲ្យផលដែលគួរប្រាថ្នាគ្រប់យ៉ាងក្នុងមហា

សមុទ្រ ដែលមិនមានទីពឹងបែបនេះ ឱ ! ការដែលអញថ្វាយទានដល់ព្រះបច្ចេកពុទ្ធ ជាការថ្វាយល្អហើយ ទើបពោលគាថាទី ៩ ថា

សូមឲ្យកើតសំពៅ ដែលពាសដោយផែនក្តារ ជាសំពៅមិនលិច
ទឹក ប្រកបដោយក្តោង និងខ្យល់ ព្រោះថា ក្នុងសមុទ្រនេះ មិន
មែនជាភូមិនៃយានដទៃឡើយ សូមនាងចម្លងខ្ញុំ ឲ្យដល់នូវក្រុង
មោលិនីក្នុងថ្ងៃនេះ ដូច្នេះ ។

គប្បីជ្រាបអត្ថនៃពាក្យដែលជាគាថានោះថា នៃទេពធីតា កាលបើដូច្នោះ សូមនាងនិម្មិតសំពៅមួយដល់ខ្ញុំផងចុះ តែសូមនិម្មិតសំពៅតូចមួយប្រមាណប៉ុនទូកកម្រោល ម្យ៉ាងទៀត សំពៅដែលនាងនិម្មិតឲ្យ ជាសំពៅដែលធ្វើដោយបន្ទះក្តារច្រើនបន្ទះ ដែលបោះភ្ជាប់ល្អហើយ ឈ្មោះថា ទឹកមិនលិច ព្រោះមិនមានប្រហោង ដែលឲ្យទឹកហូរចូលទៅបាន ប្រកបដោយក្តោង ដែលខ្យល់បក់ទៅយ៉ាងស្រួល ព្រោះក្នុងសមុទ្រនេះ ទីដែលប្រើយានពាហនៈដទៃ វៀរសំពៅទិព្វ មិនមាន សូមនាងបញ្ជូនខ្ញុំឲ្យដល់នគរមោលិនីដោយសំពៅនោះ ក្នុងថ្ងៃនេះចុះ ។

ទេពធីតាបានស្តាប់ពាក្យព្រះពោធិសត្វនោះហើយ មានចិត្តត្រេកអរ និម្មិតសំពៅមួយ សម្រេចដោយកែវ ៧ ប្រការ សំពៅនោះបណ្តោយ ៨ ឧសភ ទទឹង ៤ ឧសភ ជម្រៅ ២០ ព្យាម មានសសរក្តោង ៣ សម្រេចដោយកែវឥន្ទនិល មានខ្សែរចងសម្រេចដោយមាស មានខ្សែរ៉ក់សម្រេចដោយប្រាក់ មានកន្ទ្រេសម្រេចដោយមាស ទេវតាយករតនៈ ៧ ប្រការដាក់ពេញទូក ហើយបី

ព្រាហ្មណ៍ឡើង ដាក់លើទូកដែលប្រដាប់ហើយ តែមិនបានក្រឡេកមើលបុរសដែលជាឧបដ្ឋាកព្រះពោធិសត្វឡើយ ព្រាហ្មណ៍បានឲ្យចំណែកបុណ្យដែលខ្លួនធ្វើដល់ឧបដ្ឋាកៗ ក៏ទទួលអនុមោទនា រំពេចនោះ ទេវតាក៏បីឧបដ្ឋាកនោះឡើងលើទូកដែរ ។ លំដាប់នោះ ទេវតាក៏នាំទូកទៅកាន់មោលិនីនគរ ជញ្ជូនទ្រព្យឡើងផ្ទះព្រាហ្មណ៍ ហើយទៅកាន់លំនៅរបស់ខ្លួន ។

ព្រះសាស្តាត្រាស់ដឹងហើយ ទ្រង់ត្រាស់អភិសម្ពុទ្ធគាថាជាចុងក្រោយថា

ទេវតានោះ មានចិត្តត្រេកអរ រីករាយ សប្បាយ និម្មិតសំពៅដ៏
វិចិត្រល្អ ហើយនាំសង្ខព្រាហ្មណ៍ ព្រមទាំងបុរសឧបដ្ឋាក ចូល
ទៅកាន់ក្រុងជាទីសុខសាន្ត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សា** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ទេព-ធីតានោះ បានស្តាប់ពាក្យព្រះពោធិសត្វនោះ ក្នុងកណ្តាលសមុទ្រនោះហើយប្រកបដោយបីតិ ពោល គឺមានចិត្តត្រេកអរ ។ បទថា **សុមនា** ជាដើម គឺជាអ្នកមានចិត្តស្អាត ជាអ្នកមានចិត្តត្រេកអរដោយបាមោជ្ជ និម្មិតសំពៅដ៏វិចិត្រ នាំព្រាហ្មណ៍ និងអ្នកបម្រើទៅហើយ ។ បទថា **សាធុរម្មំ** បានដល់នាំចូលមកដល់ក្រុងដែលជាទីត្រេកអរក្រៃលែង ។

ព្រាហ្មណ៍គ្រប់គ្រងឃរាវាស ដែលមានទ្រព្យប្រមាណមិនបាន ឲ្យទានរក្សាសីលដរាបដល់អស់ជីវិត កាលអស់ជីវិតហើយ មួយអន្លើដោយបរិស័ទបានទៅកើតក្នុងទេវនគរ ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់

ប្រកាសសច្ចៈទាំងឡាយ លុះចប់សច្ចៈ ឧបាសកតាំងនៅក្នុងសោតាបត្តិផល ។ ហើយទ្រង់សមោធានជាតកថា ទេពធីតាក្នុងកាលនោះ បានមកជាឧប្បលវណ្ណាថេរី ក្នុងកាលឥឡូវនេះ ឧបដ្ឋាកក្នុងកាលនោះ បានមកជាអានន្ទ ឯសង្ខព្រាហ្មណ៍ក្នុងកាលនោះ គឺតថាគតនេះឯង ៕

**អដ្ឋកថា សង្ខជាតក ចប់**

# សុត្តន្តបិដក

## ចុល្លពោធិជាតក

[ ៦៦៥ ] ( ព្រះរាជាពារាណសីពោលថា ) បើបុគ្គលណា ចាប់យកនាងបរិព្វាជិកា មានភ្នែកទូលាយ ជាទីស្រឡាញ់ មានមុខញញឹមនេះរបស់អ្នកទៅ ដោយការកំហែង ម្នាលព្រាហ្មណ៍ តើអ្នកនឹងធ្វើអ្វី ( ដល់បុគ្គលនោះ ) ។

[ ៦៦៦ ] ( ព្រះពោធិសត្វពោលថា ) សេចក្តីក្រោធកើតដល់អាត្មា ក៏ចេញមកមិនបាន អាត្មាកាលរស់នៅ ចេញមកមិនបានទេ អាត្មាឃាត់ឆាប់រហ័ស ឲ្យដូចជាភ្លៀងដ៏ធំឃាត់នូវធូលី ។

[ ៦៦៧ ] ( ព្រះរាជា ... ) ក្នុងកាលពីដើម លោកនិយាយអួតឥឡូវនេះ ថ្ងៃនេះ លោកនោះ ដូចអាងកម្លាំង នៅស្ងៀម សម្ងំដេរសង្ឃាដីវិញ ។

[ ៦៦៨ ] ( ព្រះមហាសត្វ ... ) សេចក្តីក្រោធកើតដល់អាត្មា ក៏ចេញមកមិនបាន អាត្មាកាលរស់នៅ ចេញមកមិនបានទេ អាត្មាឃាត់ឆាប់រហ័ស ឲ្យដូចជាភ្លៀងធំឃាត់នូវធូលី ។

[ ៦៦៩ ] ( ព្រះរាជា ... ) អ្វីកើតឡើងដល់លោក ចេញមកមិនបាន លោកកាលរស់នៅ អ្វីចេញមកបាន លោកឃាត់អ្វីដូចភ្លៀងធំឃាត់នូវធូលី ។

[ ៦៧០ ] ( ព្រះពោធិសត្វពោលថា ) កាលសភាវៈណាកើតឡើង បុគ្គលមើលមិនឃើញ កាលមិនកើតឡើង ទើបឃើញងាយ

សភាវៈនោះ គឺសេចក្តីក្រោធ ជាអារម្មណ៍របស់បុគ្គលល្ងង់ កើតឡើងដល់អាត្មា ចេញមកមិនបានទេ ។

[ ៦៧១ ] បុគ្គលទាំងឡាយជាសត្រូវ អ្នកស្វែងរកនូវសេចក្តីទុក្ខ រមែងត្រេកអរដោយសភាវៈណា ដែលកើតហើយ សភាវៈនោះ គឺសេចក្តីក្រោធ ជាអារម្មណ៍របស់បុគ្គលល្ងង់ កើតឡើងដល់អាត្មា ចេញមកមិនបានទេ ។

[ ៦៧២ ] កាលសភាវៈណាកើតឡើង បុគ្គលរមែងមិនយល់នូវប្រយោជន៍របស់ខ្លួន សភាវៈនោះ គឺសេចក្តីក្រោធ ជាអារម្មណ៍របស់បុគ្គលល្ងង់ កើតឡើងដល់អាត្មាមិនបានទេ ។

[ ៦៧៣ ] បពិត្រមហារាជ បុគ្គលត្រូវសេចក្តីក្រោធណា គ្របសង្កត់ហើយ រមែងលះបង់នូវកុសលផង ធ្វើប្រយោជន៍ដ៏ធំទូលាយឲ្យសាបសូន្យផង សេចក្តីក្រោធនោះ មានសេនា គឺកិលេស ដែលគួរខ្លាច មានកម្លាំងអាចញាំញីសត្វបាន សេចក្តីក្រោធ ចេញពីអាត្មាមិនបានទេ ។

[ ៦៧៤ ] ធម្មតាភ្លើង រមែងកើតក្នុងឈើដែលពួត ភ្លើងនោះកើតអំពីឈើណា ឆេះនូវឈើនោះវិញ ។

[ ៦៧៥ ] កាលបុរសល្ងង់ខ្លៅ អាប់ឥតប្រាជ្ញា មិនចេះដឹងយ៉ាងនេះ សេចក្តីក្រោធ រមែងកើតអំពីការប្រណាំងប្រជែង បុរសនោះរមែងត្រូវភ្លើង គឺសេចក្តីក្រោធនោះឆាបឆេះ ។

[ ៦៧៦ ] សេចក្ដីក្រោធ របស់បុគ្គលណាចម្រើនឡើង ដូចភ្លើងកាលចម្រើនឡើង ក្នុងគំនរស្មៅ និងឈើ យសរបស់បុគ្គលនោះ រមែងសាបសូន្យ ដូចព្រះចន្ទ្រក្នុងកាឡបក្ខ ។

[ ៦៧៧ ] សេចក្ដីក្រោធ របស់បុគ្គលណាស្ងប់រម្ងាប់ ដូចភ្លើងមិនមានកំញ៉ម យសរបស់បុគ្គលនោះ រមែងបរិបូណ៌ ដូចព្រះចន្ទ្រក្នុងសុក្កបក្ខ ។

## ចុល្លពោធិជាតកទី ៥ ចប់

# អដ្ឋកថា

## ចុល្លពោធិជាតក

[ ៦៦៥-៦៧៧ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុច្រើនទៅដោយសេចក្តីក្រោធមួយរូប ទើបត្រាស់រឿងនេះ មានពាក្យផ្តើមថា **យោ តេ ឥមំ វិសាលក្ខឹ** ដូច្នេះជាដើម ។

បានឮថា ភិក្ខុនោះ សូម្បីបួសក្នុងព្រះពុទ្ធសាសនា ដែលនាំសត្វចេញចាកទុក្ខ ក៏មិនអាចគ្រាន់តែលះសេចក្តីក្រោធបាន ជាអ្នកច្រើនដោយសេចក្តីក្រោធ និងការអាក់អន់ជានិច្ច កាលត្រូវគេពោលបន្តិចបន្តួច ក៏អាក់អន់ក្រោធខឹងក្រៃលែង ដូច្នេះឯង ។ ព្រះសាស្តាទ្រង់ជ្រាបថា ភិក្ខុរូបនោះច្រើនដោយសេចក្តីក្រោធ ទើបត្រាស់ហៅភិក្ខុនោះមកសួរថា ម្នាលភិក្ខុ បានឮថា អ្នកជាបុគ្គលច្រើនដោយសេចក្តីក្រោធពិតឬ កាលភិក្ខុនោះក្រាបទូលថា ករុណាព្រះអង្គ ពិតមែន ទើបត្រាស់ថា ម្នាលភិក្ខុ ឈ្មោះថា សេចក្តីក្រោធ អ្នកគួរតែហាមឃាត់ សេចក្តីក្រោធបែបនេះ ធ្វើឲ្យមានប្រយោជន៍ ក្នុងលោកនេះ និងលោកខាងមុខ មិនមាន អ្នកបួសក្នុងសាសនារបស់ព្រះពុទ្ធដែលមិនក្រោធ ហេតុអ្វី ទើបក្រោធ បុរាណកបណ្ឌិតទាំងឡាយ ទោះបីបួសក្នុងលទ្ធិខាងក្រៅព្រះពុទ្ធសាសនា ក៏គង់មិនក្រោធ ដូច្នេះហើយ ទ្រង់នាំយករឿងក្នុងអតីតមកសាធក:ដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិក្នុងនគរពារាណសី ក្នុងនិគមរបស់អ្នកកាសីមួយ មានព្រាហ្មណ៍ម្នាក់ ជាអ្នកស្តុកស្តម្ភដោយទ្រព្យ តែមិនមានកូន ព្រាហ្មណីភរិយារបស់គាត់ចង់បានកូន គ្រានោះ ព្រះពោធិសត្វ

ចុតិអំពីព្រហ្មលោក មកកើតក្នុងផ្ទៃព្រាហ្មណី ក្នុងថ្ងៃដាក់ឈ្មោះកុមារនោះ ញាតិទាំងឡាយដាក់ឈ្មោះថា **ពោធិកុមារ** ។ លុះចម្រើនវ័យហើយ ទៅកាន់តក្កសិលានគរ រៀនសិល្បសាស្ត្រគ្រប់យ៉ាងសម្រេចហើយត្រឡប់មក ។ មាតាបិតាបាននាំកុមារិកា ដែលមានត្រកូលស្មើគ្នាមកឲ្យ ទាំងដែលពោធិកុមារមិនប្រាថ្នាសោះ សូម្បីទារិកានោះ ក៏ចុតិមកអំពីព្រហ្មលោកដូចគ្នា មានរូបសម្បត្តិប្រៀបដូចទេពអប្សរ ។ ពោធិកុមារ និងកុមារិកា មិនប្រាថ្នាជាស្វាមីភរិយានឹងគ្នា ញាតិទាំងឡាយ ក៏រៀបចំអាវាហវិវាហមង្គលឲ្យ ។ ជនទាំង ២ នោះ មិនធ្លាប់មានការរាយមាយដោយកិលេស សូម្បីត្រឹមតែសម្លឹងមើលគ្នាដោយអំណាចនៃរាគៈ មិនមាន ឈ្មោះថា មេថុនធម្ម មិនធ្លាប់ជួបសូម្បីត្រឹមតែយល់សប្តិ ជនទាំង ២ ជាអ្នកមានសីលបរិសុទ្ធ ដោយប្រការដូច្នេះ ។

សម័យក្រោយមក កាលមាតាបិតាអនិច្ចកម្មហើយ ព្រះមហាសត្វបានរៀបចំបូជាសពជនទាំងពីរស្រេចបាច់ហើយ ហៅកុមារិកាមកប្រាប់ថា នែសម្ងាញ់ចិត្ត ចូរនាងទទួលយកទ្រព្យ ៨០ កោដិនោះ ចិញ្ចឹមជីវិតជាសុខចុះ កុមារិកាសួរថា ចុះអយ្យបុត្រវិញ ព្រះមហាសត្វឆ្លើយថា ខ្ញុំមិនមានកិច្ចដោយទ្រព្យ ខ្ញុំនឹងទៅកាន់ដែនដីហិមពាន្ត បួសជាឥសី ធ្វើទីពឹងដល់ខ្លួន កុមារិកាសួរថា បពិត្រអយ្យបុត្រ បព្វជ្ជានោះ គួរដល់តែបុរសប៉ុណ្ណោះឬ មហាសត្វឆ្លើយថា នែសម្ងាញ់ចិត្ត ពួកស្ត្រីក៏គួរ ។ កុមារិកាពោលថា បើដូច្នោះ ខ្ញុំមិនទទួលទឹកមាត់ដែលអ្នកស្តោះចោល ខ្ញុំក៏មិនមានកិច្ចដោយទ្រព្យ ខ្ញុំក៏នឹងបួស ព្រះមហាសត្វទទួលថា សាធុ ។ ជនទាំង ២ បានឲ្យមហាទាន ហើយចេញ

ទៅសាងអាស្រមក្នុងភូមិប្រទេសដែលគួរជាទីត្រេកអរ បួសហើយ ស្វែងរកផលាផលចិញ្ចឹមជីវិត រស់នៅទីនោះប្រមាណ ១០ ឆ្នាំ ឈានសមាបត្តិមិនកើតឡើងដល់ជនទាំង ២ ឡើយ ឥសីទាំង ២ នៅក្នុងទីនោះ ១០ ឆ្នាំដោយសេចក្ដីសុខដែលកើតអំពីបព្វជ្ជាប៉ុណ្ណោះ កាលត្រូវការសេពរសជូរប្រៃ ទើបចារិកទៅតាមជនបទ ដល់នគរពារាណសីដោយលំដាប់ អាស្រ័យនៅក្នុងព្រះរាជឧទ្យាន ។

ថ្ងៃមួយ ព្រះរាជាទតឃើញបុរសយាមឧទ្យាន កាន់គ្រឿងបណ្ណាការមក គាល់ក៏ត្រាស់ថា យើងនឹងទៅក្រសាលឧទ្យាន ចូរអ្នកជម្រះឧទ្យានឲ្យស្អាត ដូច្នេះហើយ ទើបយាងទៅកាន់ព្រះរាជឧទ្យាន ដែលឧទ្យានបាលនោះ ជម្រះស្អាតហើយ មួយអន្លើដោយបរិវារជាច្រើន ។ ខណៈនោះ ជនទាំង ២ នោះអង្គុយឲ្យកាលវេលាកន្លងទៅ ដោយសេចក្ដីសុខដែលកើតអំពីបព្វជ្ជា ម្ខាងម្នាក់នៃព្រះរាជឧទ្យាន ។ លំដាប់នោះ ព្រះរាជាយាងប្រពាតឧទ្យាន បានទតឃើញជនទាំង ២ នោះ អង្គុយហើយ កាលទ្រង់ក្រឡេកមើលបរិព្វាជិកាដែលមានរូបស្អាត គួរជ្រះថ្លាក្រៃលែង ក៏មានព្រះហឫទ័យប្រតិព័ទ្ធ ទ្រង់ញាប់ញ័រដោយអំណាចនៃកិលេស ទ្រង់ព្រះតម្រិះថា អញនឹងសាកសួរមើល បរិព្វា-ជិកានេះ ជាអ្វីនឹងតាបសនេះ ហើយចូលទៅរកព្រះពោធិសត្វ ត្រាស់សួរថា បពិត្របព្វជិត បរិព្វាជិកានេះជាអ្វីនឹងលោក តាបសឆ្លើយថា មហាបពិត្រ មិនជាអ្វីនឹងគ្នាឡើយ គ្រាន់តែបួសជាគ្នាប៉ុណ្ណោះ តែកាលនៅជាគ្រហស្ថ ទារិកានេះ ជាបាទបរិចារិការបស់អាត្មា ព្រះរាជាទ្រង់បានស្ដាប់ដូច្នោះហើយ ទ្រង់ព្រះ

តម្រិះថា ស្រីនេះមិនជាអ្វីនឹងតាបសនោះ តែជាបាទបរិចារិកាកាលជាគ្រហស្ថ បើអញនាំយកស្រីនេះទៅ ដោយភាពជាធំសោត តាបសនេះនឹងធ្វើដូចម្ដេចហ្ន៎ អញនឹងសាកសួរតាបសនោះមើល ដូច្នេះហើយ ចូលទៅជិត ពោលគាថាទី ១ ថា

បើបុគ្គលណា ចាប់យកនាងបរិញ្ជិកា មានភ្នែកទូលាយ ជាទី
ស្រឡាញ់ មានមុខញញឹមនេះរបស់អ្នក ទៅដោយការកំហែង
ម្នាលព្រាហ្មណ៍ តើអ្នកនឹងធ្វើអ្វី ( ដល់បុគ្គលនោះ ) ។

បណ្ដាបទទាំងនោះ បទថា **សម្ហិលហាសិនី** បានដល់ មានទឹកមុខញញឹមតិចៗ ។ បទថា **ពលា គច្ឆេយ្យ** បានដល់ នាំយកទៅដោយកម្លាំង ។ បទថា **កឹ នុ កយិរាសិ** សេចក្ដីថា នែព្រាហ្មណ៍ លោកធ្វើដូចម្ដេច ដល់បុគ្គលនោះ ។

លំដាប់នោះ ព្រះមហាសត្វស្ដាប់ព្រះតម្រាស់របស់ព្រះរាជានោះហើយ ពោលគាថាទី ២ ថា

សេចក្ដីក្រោធកើតដល់អាត្មា ក៏ចេញមកមិនបាន អាត្មាកាល
រស់នៅ ចេញមកមិនបានទេ អាត្មាឃាត់ផាប់ហ័ស ឲ្យដូចជា
ភ្លៀងដ៏ធំឃាត់នូវធូលី ដូច្នេះ ។

គប្បីជ្រាបអត្ថនៃគាថានោះដូច្នេះថា មហាបពិត្រ បើបុគ្គលណាម្នាក់នាំស្រីនេះទៅ សេចក្ដីក្រោធគប្បីកើតឡើង ដល់អាត្មាក្នុងខាងក្នុង សេចក្ដីក្រោធនោះ កើតឡើងដល់អាត្មាក្នុងខាងក្នុងហើយ មិនគប្បីវិនាសទៅ គឺមិនគប្បី

វិនាសទៅ ដរាបណាអាត្មានៅមានជីវិត អាត្មាក៏មិនឲ្យសេចក្តីក្រោធនោះតាំងនៅខាងក្នុង ដោយការនៅរួមគ្នាជាដុំជាក្រុមបានដោយពិត អាត្មានឹងសង្កត់សង្កិនឃាត់ដោយមេត្តាភាវនាដោយឆាប់រួសរាន់ ដូចភ្លៀងធំជម្រះនូវធូលីដែលកើតឡើងហើយដោយរួសរាន់ ដូច្នោះ ។

ព្រះមហាសត្វបានបន្លឺសីហនាទយ៉ាងនេះ ។ ឯព្រះរាជាទ្រង់បានស្តាប់ពាក្យរបស់ព្រះមហាសត្វហើយ ក៏មិនអាចឃាត់ព្រះហឫទ័យរបស់ទ្រង់ដែលប្រតិព័ទ្ធបាន ព្រោះជាបុគ្គលពាលល្ងង់ខ្លៅ ទ្រង់បញ្ជាអមាត្យម្នាក់ថា អ្នកចូរនាំបរិព្វាជិកានេះទៅកាន់ព្រះរាជនិវេសន៍ ។ អមាត្យនោះ ទទួលព្រះរាជបញ្ជាហើយបាននាំបរិព្វាជិកា ដែលកំពុងខ្សឹកខ្សួលថា អធម៌កំពុងប្រព្រឹត្តទៅក្នុងលោក មិនសមគួរឡើយ ដូច្នេះជាដើម ។ ព្រះពោធិសត្វស្តាប់សំឡេងយំសោករបស់នាង ក្រឡេកមើលតែម្តងហើយ មិនមើលទៀត ពួករាជបុរសក៏នាំនាងដែលកំពុងយំ ទៅកាន់ព្រះរាជនិវេសន៍ ។ ពាលរាជនោះ មិនបានដំអក់នៅក្នុងព្រះរាជឧទ្យាន ទ្រង់ប្រញាប់យាងទៅកាន់ព្រះរាជវាំង ត្រាស់ឲ្យហៅបរិព្វាជិកានោះមក ហើយប្រទានយសធំ តែនាងបានពណ៌នាទោស និងគុណរបស់បព្វជ្ជារឿយៗ ព្រះរាជាទ្រង់ប្រើវិធីសាស្រ្តផ្សេងៗ ក៏មិនអាចបង្កចិត្តនាងបាន ទើបត្រាស់ឲ្យបង្ខាំងនាងក្នុងបន្ទប់តូច ហើយទ្រង់ព្រះតម្រិះថា បរិព្វាជិកានេះ មានសីល មានកល្យាណធម៌ មិនប្រាថ្នាយសបែបនេះ សូម្បីតាបសនោះ កាលគេនាំស្រ្តីដែលល្អបែបនេះទៅ ក៏មិនសម្លឹងមើលដោយចិត្តក្រោធ តែបព្វជិត រមែងមានមាយាច្រើន ប្រកបអ្វីមួយឡើងហើយ គប្បីធ្វើ

សេចក្ដីវិនាសឲ្យដល់អញ អញទៅមើលឲ្យដឹងសិនថា គាត់អង្គុយធ្វើអ្វី គិតដូច្នេះហើយ មិនអាចតាំងនៅបាន ទើបយាងទៅកាន់ព្រះរាជឧទ្យាន ។

ឯព្រះពោធិសត្វអង្គុយដេរចីវរ ព្រះរាជា មួយអន្ទើដោយបរិវារតិចតួចចូលទៅសន្សឹមៗ មិនឲ្យឮសូរព្រះបាទ ព្រះពោធិសត្វមិនបានសម្លឹងមើលព្រះរាជា ដេរចីវររឿយៗ ទៅ ព្រះរាជាយល់ថា តាបសនេះក្រោធ ទើបមិនប្រាស្រ័យជាមួយអញ ហើយទ្រង់សម្គាល់ថា តាបសកោងនេះ ដំបូងអួតអាងថា នឹងមិនឲ្យសេចក្ដីក្រោធកើតឡើង ទោះបីកើតឡើងហើយ ក៏នឹងហាមឃាត់ដោយរហ័ស ឥឡូវនេះ ជាអ្នករឹងត្អឹងដោយសេចក្ដីក្រោធ មិននិយាយជាមួយអញ ដូច្នេះ ទើបត្រាស់គាថាទី ៣ ថា

ក្នុងកាលពីដើម លោកនិយាយអួត ឥឡូវនេះ ថ្ងៃនេះ លោក
នោះ ដូចអាងកម្លាំង នៅស្ងៀម សម្ងំដេរសង្ឃាដីវិញ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ពលម្ហិវ អបស្សិតោ** បានដល់ ហាក់ដូចជាអាស្រ័យកម្លាំង ។ បទថា **តុណ្ហិកតោ** បានដល់ មិនពោលពាក្យណាមួយ ។ បទថា **សិព្វមច្ឆសិ** ស្មើគ្នានឹង **សិព្វន្តោ អច្ឆសិ** ប្រែថា កំពុងដេរ ។

ព្រះមហាសត្វបានស្ដាប់ដូច្នោះ ទើបគិតថា ព្រះរាជាអង្គនេះយល់ថា អញមិនប្រាស្រ័យ ក៏ដោយអំណាចសេចក្ដីក្រោធ អញនឹងទូលភាពដែលអញមិនលុះអំណាចសេចក្ដីក្រោធដែលកើតឡើង ឲ្យទ្រង់ជ្រាបក្នុងកាលឥឡូវនេះ ហើយពោលគាថាទី ៤ ថា

សេចក្តីក្រោធកើតដល់អាត្មា ក៏ចេញមកមិនបាន អាត្មាកាល
រស់នៅ ចេញមកមិនបានទេ អាត្មាឃាត់ផាប់របស់ ឲ្យដូចជា
ភ្លៀងធំឃាត់នូវធូលី ដូច្នេះ ។

គប្បីជ្រាបអត្ថនៃពាក្យដែលជាគាថានោះថា បពិត្រមហារាជ សេចក្តីក្រោធកើតឡើងហើយដល់អាត្មា សេចក្តីក្រោធនោះ កាលកើតឡើងហើយមិនទាន់វិនាសទៅអំពីអាត្មា អាត្មាមិនបានឲ្យសេចក្តីក្រោធនោះ ចូលទៅតាំងនៅក្នុងហទយៈបាន កាលអាត្មានៅមានជីវិត សេចក្តីក្រោធនោះ ក៏មិនទាន់ស្លាប់ ដោយប្រការដូច្នេះ តែអាត្មាឃាត់ហើយដោយឆាប់រួសរាន់ ប្រៀបដូចភ្លៀងធំជម្រះនូវធូលី ដូច្នោះ ។

ព្រះរាជា ទ្រង់ស្តាប់ដូច្នោះហើយ ទ្រង់ព្រះតម្រិះថា តាបសនេះពោលសំដៅដល់សេចក្តីក្រោធប៉ុណ្ណោះ ឬសំដៅដល់សិប្បៈណាមួយដទៃ អញនឹងសួរលោកមើល កាលនឹងត្រាស់សួរ បានត្រាស់គាថាទី ៥ ថា

អ្វីកើតឡើងដល់លោក ចេញមកមិនបាន លោក កាលរស់នៅ
អ្វីចេញមកបាន លោកឃាត់អ្វីដូចភ្លៀងធំឃាត់នូវធូលី ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កិន្តេ ឧប្បជ្ជិ នោ មុញ្ចិ** សេចក្តីថា សេចក្តីក្រោធកើតឡើងដល់លោកផង មិនទាន់វិនាសទៅហើយផងដូចម្តេច ។

ព្រះពោធិសត្វបានស្តាប់ដូច្នោះហើយ ពោលថា មហាបពិត្រ ការក្រោធមានទោសច្រើនយ៉ាងនេះ ព្រោះប្រកបដោយការវិនាសធំ សេចក្តីក្រោធប្រភេទមួយកើតឡើងហើយដល់អាត្មា តែអាត្មាបានហាមនូវសេចក្តីក្រោធ

ដែលកើតឡើងហើយដោយមេត្តាភាវនា ដូច្នេះហើយ កាលនឹងប្រកាសទោសក្នុងសេចក្ដីក្រោធ ទើបពោលគាថាទាំងនេះថា

កាលសភាវៈណាកើតឡើង បុគ្គលមើលមិនឃើញ កាលមិនកើតឡើង ទើបឃើញងាយ សភាវៈនោះ គឺសេចក្ដីក្រោធ ជាអារម្មណ៍របស់បុគ្គលល្ងង់ កើតឡើងដល់អាត្មា ចេញមកមិនបានទេ ។

បុគ្គលទាំងឡាយ ជាសត្រូវ អ្នកស្វែងរកនូវសេចក្ដីទុក្ខ រមែងត្រេកអរដោយសភាវៈណា ដែលកើតហើយ សភាវៈនោះ គឺសេចក្ដីក្រោធ ជាអារម្មណ៍របស់បុគ្គលល្ងង់ កើតឡើងដល់អាត្មា ចេញមកមិនបានទេ ។

កាលសភាវៈណាកើតឡើង បុគ្គលរមែងមិនយល់នូវប្រយោជន៍របស់ខ្លួន សភាវៈនោះ គឺសេចក្ដីក្រោធ ជាអារម្មណ៍របស់បុគ្គលល្ងង់ កើតឡើងដល់អាត្មា មិនបានទេ ។

បពិត្រមហារាជ បុគ្គលត្រូវសេចក្ដីក្រោធណា គ្របសង្កត់ហើយ រមែងលះបង់នូវកុសលផង ធ្វើប្រយោជន៍ដ៏ធំទូលាយ ឲ្យសាបសូន្យផង សេចក្ដីក្រោធនោះ មានសេនា គឺកិលេសដែលគួរខ្លាច មានកម្លាំងអាចញាំញីសត្វបាន សេចក្ដីក្រោធចេញពីអាត្មា មិនបានទេ ។

ជម្ពូតាភ្លើង រមែងកើតក្នុងឈើដែលពួត ភ្លើងនោះ កើតអំពីឈើណា ឆេះនូវឈើនោះវិញ ។

កាលបុរសល្ងង់ខ្លៅ អាប់ឥតប្រាជ្ញា មិនចេះដឹងយ៉ាងនេះ សេចក្តីក្រោធ រមែងកើតអំពីការប្រណាំងប្រជែង បុរសនោះ រមែងត្រូវភ្លើង គឺសេចក្តីក្រោធនោះឆាបឆេះ ។

សេចក្តីក្រោធរបស់បុគ្គលណា ចម្រើនឡើងដូចភ្លើង កាលចម្រើនឡើងក្នុងគំនរស្មៅ និងឈើ យសរបស់បុគ្គលនោះ រមែងសាបសូន្យ ដូចព្រះចន្ទ្រក្នុងកាឡបក្ខ ។

សេចក្តីក្រោធ របស់បុគ្គលណាស្ងប់រម្ងាប់ ដូចភ្លើង មិនមានកំញ៉ម យសរបស់បុគ្គលនោះរមែងបរិបូណ៌ ដូចព្រះចន្ទ្រក្នុងសុក្កបក្ខ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ន បស្សតិ** បានដល់ រមែងមិនឃើញនូវប្រយោជន៍ខ្លួន នឹងពោលថ្វីដល់ឃើញប្រយោជន៍អ្នកដទៃនោះ ។ បទថា **សាធុ បស្សតិ** បានដល់ រមែងឃើញប្រយោជន៍ទាំង ២ គឺប្រយោជន៍ខ្លួន ប្រយោជន៍អ្នកដទៃបានល្អ ។ បទថា **ទុម្មេធគោចរោ** បានដល់ ជាទីគោចរ ( អារម្មណ៍ ) របស់បុគ្គលអាប់ឥតប្រាជ្ញាទាំងឡាយ ។ បទថា **ទុក្ខមេសិនោ** បានដល់ប្រាថ្នាសេចក្តីទុក្ខ ។

បទថា **សទត្ថំ** បានដល់ វត្ថុដែលជាប្រយោជន៍របស់ខ្លួន គឺសេចក្តីចម្រើនទាំងដោយអត្ថ និងដោយធម៌ ។ បទថា **បរក្ការេ** សេចក្តីថា តាបសពោលថា សេចក្តីក្រោធ ធ្វើប្រយោជន៍ដែលកើតឡើងបរិបូណ៌ឲ្យទៅជាដទៃ អ្នកទាំងឡាយ ចូរនាំចេញទៅ អាត្មាមិនត្រូវការសេចក្តីក្រោធនេះទេ ។

បទថា **ស ភីមសេនោ** សេចក្ដីថា សេចក្ដីក្រោធនោះ ប្រកបដោយសេនា គឺកិលេសធំ ដែលនឹងឲ្យភ័យកើតឡើង ។ បទថា **បមទ្ទិ** បានដល់ ព្រោះសេចក្ដីក្រោធ មានសេនា គឺកិលេសក្រាស់ ទើបអាចចាប់សត្វទាំងឡាយ សូម្បីច្រើន មកបង្ក្រាប ធ្វើឲ្យនៅក្នុងអំណាចរបស់ខ្លួនបាន ។ បទថា **ន មេ អមុច្ចថ** សេចក្ដីថា មិនបានរួចផុតអំពីសម្នាក់របស់អាត្មា ម្យ៉ាងទៀតសេចក្ដីថា មិនតាំងនៅក្នុងហទយៈរបស់អាត្មា ដូចទឹកដោះ មិនតាំងនៅដោយភាពជាទធិ ត្រឹមតែមួយរំពេច ដូច្នោះ យ៉ាងនេះក៏មាន ។ បទថា **កដ្ឋស្មឹ មត្ថមានស្មឹ** បានដល់ ដែលបុគ្គលកួតដោយឈើពំនួត បាលីថា **មន្ថមានស្មឹ** ដូច្នេះក៏មាន ។ បទថា **យស្មា** សេចក្ដីថា ភ្លើងកើតឡើងអំពីឈើណា ក៏ដុតឈើនោះឯង ភ្លើង ឈ្មោះថា **គិនិ**។

បទថា **ពាលស្ស អវិជានតោ** ស្មើគ្នានឹង **ពាលស្ស អវិជានន្តស្ស** ប្រែថា បុគ្គលល្ងង់ខ្លៅ មិនដឹងពិត ។ បទថា **សារម្ភា ជាយតេ** សេចក្ដីថា សេចក្ដីក្រោធ រមែងកើតឡើងដល់បុគ្គល ដែលធ្វើការអូសមក ទាញទៅ ថាឯង ថាអញ ព្រោះការប្រណាំងប្រជែង ដែលមានព្រោះធ្វើឲ្យលើប្រមាណ ជាងហេតុជាលក្ខណៈ ដូចភ្លើងព្រៃកើតឡើង ព្រោះការកួតនៃឈើពំនួត ដូច្នោះ ។

បទថា **សោបិ តេនេវ** សេចក្ដីថា សូម្បីបុគ្គលនោះ គឺបុគ្គលពាល ក៏ត្រូវសេចក្ដីក្រោធនោះឯងដុតរោល ដូចឈើត្រូវភ្លើងឆេះ ដូច្នោះ ។ បាទគាថាថា **អគ្គិនេវ ធូមកេតុនា** បានដល់ ដូចភ្លើងដែលអស់កំញម ដូច្នោះ ។

បទថា **ឥសស្ស** សេចក្តីថា យសដែលបុគ្គលប្រកបដោយអធិវាសនខន្តីបាន ហើយ រមែងពេញដូចព្រះចន្ទខាងខ្នើត ដូច្នោះ ។

ព្រះរាជា ទ្រង់ស្តាប់ធម្មកថារបស់ព្រះមហាសត្វហើយ ទ្រង់ត្រេកអរ ត្រាស់ឲ្យអមាត្យម្នាក់ នាំបរិព្វាជិកាមក ហើយត្រាស់ថា បពិត្រលោកម្ចាស់ ដោយការមិនក្រោធ សូមលោកម្ចាស់ទាំង ២ តាំងនៅដោយសេចក្តីសុខ ដែលកើតអំពីបព្វជ្ជាក្នុងព្រះរាជឧទ្យាននេះចុះ ខ្ញុំនឹងជួយថែរក្សាដោយធម៌ដល់ លោកម្ចាស់ទាំង ២ ហើយបានសូមខមាទោស ថ្វាយបង្គំហើយចៀសចេញ ទៅ ។ បព្វជិតទាំង ២ នោះ នៅក្នុងព្រះរាជឧទ្យាននោះ សម័យក្រោយមក បរិព្វាជិកាក៏ធ្វើមរណកាល ព្រះពោធិសត្វកាលបរិព្វាជិកាធ្វើមរណកាលហើយ ក៏ចូលទៅកាន់ព្រៃហិមពាន្ត ធ្វើអភិញ្ញា និងសមាបត្តិឲ្យកើត ចម្រើនព្រហ្មវិហារ ៤ ហើយទៅកាន់ព្រហ្មលោក ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនាមកសម្តែងហើយ ទ្រង់បាន ប្រកាសសច្ចៈទាំងឡាយ ក្នុងកាលចប់សច្ចៈ ភិក្ខុដែលច្រើនដោយសេចក្តី ក្រោធ តាំងនៅក្នុងអនាគាមិផល ហើយទ្រង់ជាតកថា បរិព្វាជិកាក្នុងកាល នោះ បានមកជារាហុលមាតាក្នុងកាលឥឡូវនេះ ព្រះរាជាក្នុងកាលនោះ បាន មកជាអានន្ទ ឯបរិព្វាជក ក្នុងកាលនោះ គឺតថាគតនេះឯង ។៙

**អដ្ឋកថា ចុល្លពោធិជាតក ចប់**

# សុត្តន្តបិដក

## មណ្ឌព្យជាតក

[ ៦៧៨ ] ( កណ្ហទីបាយនតាបស ធ្វើសច្ចកិរិយាថា ) យើងមានចិត្តជ្រះថ្លា ត្រូវការដោយបុណ្យ បានប្រព្រឹត្តព្រហ្មចរិយៈអស់ ៧ ថ្ងៃគត់ មួយទៀត ព្រហ្មចរិយៈណា លើសទៅទៀត ដែលយើងបានប្រព្រឹត្តហើយ ព្រហ្មចរិយៈនេះជារបស់នៃយើង យើងជាអ្នកមិនប្រាថ្នា ( ចំពោះបព្វជ្ជា ) អស់ជាង ៥០ ឆ្នាំមកហើយ តែឥឡូវនេះ យើងខំប្រព្រឹត្តព្រហ្មចរិយៈ ដោយពាក្យសច្ចៈនេះ សូមសួស្តីកើតមាន ( ដល់យញ្ញទត្តកុមារ ) ពិសចូរសាបរលាបបាត់ទៅ យញ្ញទត្តកុមារ ចូររស់ឡើង ។

[ ៦៧៩ ] ( បិតាយញ្ញទត្តកុមារ ធ្វើសច្ចកិរិយាថា ) ក្នុងកាលខ្លះ ខ្ញុំឃើញភ្ញៀវក្នុងវេលា ដែលមកដល់លំនៅ ក៏មិនត្រេកអរនឹងឲ្យទានទេ តែខ្ញុំមិនឲ្យពួកសមណព្រាហ្មណ៍ ទោះជាពហុស្សូតបានដឹងថា ខ្ញុំមិនស្រឡាញ់ទេ មួយទៀត ខ្ញុំ ទោះបីមិនប្រាថ្នា ( ក្នុងទាន ) ក៏នៅតែឲ្យ ដោយពាក្យសច្ចៈនេះ សូមសួស្តីកើតមាន ( ដល់យញ្ញទត្តកុមារ ) ពិសចូរសាបរលាបបាត់ទៅ សូមយញ្ញទត្តកុមារ រស់ឡើង ។

[ ៦៨០ ] ( មាតាយញ្ញទត្តកុមារពោលថា ) ម្នាលកូន អាសិរពិសណា មានតេជៈច្រើន បានលូនចេញពីរន្ធមកចឹកអ្នក ក្នុងថ្ងៃនេះ ខ្ញុំ និងបិតាអ្នក មិនមានសេចក្តីប្លែកគ្នាណាមួយ ក្នុង

អាសិរពិសនោះទេ ( ព្រោះជាអ្នកមិនស្រឡាញ់អាសិរពិសដូចគ្នា ) ដោយពាក្យសច្ចៈនេះ សូមសួស្តីកើតមាន ពិសចូរសាបរលាបបាត់ទៅ សូមយញ្ញទត្តកុមារ រស់ឡើង ។

[ ៦៨១ ] ( នាយមណ្ឌព្យៈជាសម្លាញ់សួរថា ) ពួកជនណាបួស ជាអ្នកស្ងប់រម្ងាប់ ទូន្មានឥន្ទ្រិយ ពួកជននោះ ប្រាកដជាអ្នកប្រាថ្នា ( នឹងបួស ) មែន វៀរលែងតែកណ្ហទីបាយនតាបសចេញ បពិត្រទីបាយនតាបស លោកស្អប់ខ្ពើមអ្វី បានជាមិនចង់បួស ហើយទ្រាំប្រព្រឹត្តព្រហ្មចារ្យទៅវិញ ។

[ ៦៨២ ] ( ទីបាយនតាបសពោលថា ) បុគ្គលណាចេញ ( ចាកផ្ទះបួស ) ដោយសទ្ធាហើយត្រឡប់មក ( កាន់ផ្ទះ ) វិញ បុគ្គលនោះឯង ឈ្មោះថា ជាមនុស្សល្ងីល្ងើមិននឹងនួន យើងស្អប់ខ្ពើមវាទៈនេះ ( សូម្បី ) ជាអ្នកមិនប្រាថ្នា ( បួស ) ក៏ទ្រាំប្រព្រឹត្តព្រហ្មចារ្យ ដែលវិញ្ញូជនសរសើរផង ជាឋានៈរបស់ពួកសប្បុរសផង យើងជាអ្នកធ្វើនូវបុណ្យយ៉ាងនេះ ។

[ ៦៨៣ ] ចំណែកអ្នកបានញុំាងពួកសមណព្រាហ្មណ៍ និងអ្នកដំណើរឲ្យឆ្អែតស្កប់ស្កល់ ដោយបាយ ទឹក និងកិក្ខាហារ ឯផ្ទះរបស់អ្នកនេះ មានកិក្ខាហារ ( ដ៏សម្បូរ ) ដូចជាស្រះសម្រាប់ជនចុះផឹក កាលបើដូច្នេះទេ ចុះអ្នកស្អប់ខ្ពើមពាក្យអ្វី បានជាអ្នកមិនប្រាថ្នានឹងឲ្យទាន តែនៅតែឲ្យនូវទាននេះវិញ ។

[ ៦៨៤ ] ( មណ្ឌព្យ: ... ) មាតាបិតា និងជីដូនជីតារបស់ខ្ញុំ ជាអ្នកមានសទ្ធា ជាម្ចាស់នៃទាន ជាអ្នកដឹងនូវពាក្យស្នូម ខ្ញុំ ប្រព្រឹត្តតាមវត្តរបស់ត្រកូលនោះ ដោយតាំងចិត្តថា អាត្មាអញ កុំជាអ្នកមានក្នុងទីបំផុត និងជាអ្នកកាត់នូវវង្សត្រកូល ក្នុងត្រកូល ឡើយ អាត្មាអញស្អប់ខ្ពើមចំពោះពាក្យនោះ ( ទោះបី ) ជា អ្នកមិនមានប្រាថ្នានឹងឲ្យទាន ក៏នៅតែឲ្យនូវទាននេះ ។

[ ៦៨៥ ] ម្នាលនាងមានសរីរៈកាយដ៏ល្អ យើងបាននាំនាងមក អំពីត្រកូលនៃញាតិ តាំងពីកាលនាងនៅជាកុមារីក្មេង មានប្រាជ្ញា មិនទាន់អង់អាចម៉្លេះ នាងបម្រើអញទាំងមិនចង់ តែមិនឲ្យដឹងថា មិនស្រឡាញ់អញ ម្នាលនាង កាលបើដូច្នេះ ការនៅរួមជាមួយ យើងមានសភាពយ៉ាងនេះ តើដោយហេតុដូចម្តេច ។

[ ៦៨៦ ] ( ករិយា ... ) យូរណាស់មកហើយ ក្នុងកាលណាក៏ ដោយ ការផ្លាស់ប្តូរប្តី មិនមានក្នុងត្រកូលនេះទេ ខ្ញុំប្រព្រឹត្តតាម វត្តរបស់ត្រកូលនោះ ដោយតាំងចិត្តថា អាត្មាអញ កុំជាអ្នក មានក្នុងទីបំផុត និងជាអ្នកកាត់នូវវង្សត្រកូល ក្នុងត្រកូលឡើយ ខ្ញុំស្អប់ខ្ពើមពាក្យនេះ ទោះបីជាអ្នកមិនមានប្រាថ្នានឹងបម្រើ ក៏ ប្រព្រឹត្តបម្រើមិនដាច់ ចំពោះអ្នក ។

[ ៦៨៧ ] បពិត្រមណ្ឌព្យៈ ខ្ញុំនិយាយនូវពាក្យ ដែលមិនគួរនិយាយ សូមអ្នកអត់ទោសចំពោះពាក្យនោះ ដល់ខ្ញុំក្នុងថ្ងៃនេះ ព្រោះហេតុនៃកូន ចុះរបស់ណាមួយឯទៀតក្នុងលោកនេះ រមែងមិនមានជាងសេចក្តីស្រឡាញ់ ក្នុងកូនឡើយ យញ្ញទត្តកុមាររបស់យើងនេះរស់វិញ ។

មណ្ឌព្យជាតកទី ៦ ចប់

# អដ្ឋកថា

## មណ្ឌព្យជាតក

[ ៦៧៨-៦៨៧ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអផ្សុកមួយរូប ទើបត្រាស់រឿងនេះ មានពាក្យផ្តើមថា **សត្តាហមេវាហំ** ដូច្នេះជាដើម ។

ចំណែករឿងមានច្បាស់ក្នុងកុសរាជជាតក ។

ព្រះសាស្តាត្រាស់សួរភិក្ខុនោះថា ម្នាលភិក្ខុ បានឮថា អ្នកអផ្សុកពិតឬ ភិក្ខុនោះក្រាបទូលថា ករុណាព្រះអង្គ ពិតមែន ដូច្នេះ ទើបត្រាស់ថា ម្នាលភិក្ខុ កាលព្រះពុទ្ធមិនទាន់កើតឡើង បុរាណកបណ្ឌិតបានបួសក្នុងលទ្ធិខាងក្រៅព្រះពុទ្ធសាសនា មិនមានសេចក្តីត្រេកអរ គង់ប្រព្រឹត្តព្រហ្មចរិយៈបានជាង ៥០ ឆ្នាំ មិនសម្តែងភាពដែលខ្លួនអផ្សុកឲ្យប្រាកដដល់បុគ្គលណា ព្រោះខ្លាចហិរិឱត្តប្បៈបែកធ្លាយ ឯអ្នកបួសក្នុងសាសនា ដែលនាំចេញចាកទុក្ខបែបនេះ តាំងនៅចំពោះព្រះភក្ត្ររបស់ព្រះពុទ្ធជាសាស្តាដូចតថាគត ហេតុអ្វី ទើបធ្វើសេចក្តីអផ្សុកឲ្យប្រាកដក្នុងកណ្តាលបរិស័ទ ៤ ហេតុអ្វី ទើបមិនរក្សាហិរិឱត្តប្បៈរបស់ខ្លួន ហើយទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះរាជាព្រះនាមកោសម្ពិកៈ សោយរាជសម្បត្តិនៅក្នុងនគរកោសម្ពី ដែនវង្សៈ ។ ក្នុងកាលនោះ មាននិគមមួយកន្លែង មានព្រាហ្មណ៍ ២ នាក់ មានសម្បត្តិម្នាក់ ៨០ កោដិ ជាសម្លាញ់នឹងគ្នា ឃើញទោសក្នុងកាមគុណ ឲ្យមហាទាន ហើយជនទាំង ២ លះកាម ទាំងដែលមហាជនកំពុងយំ បានចេញទៅសាងអាស្រម បួសក្នុងទឹកដីនៃព្រៃហិមពាន្ត ស្វែងរក

ត្រាវជំឡូង ផ្លែឈើចិញ្ចឹមជីវិត បាន ៥០ ឆ្នាំ មិនអាចធ្វើឈានឲ្យកើតឡើងបាន ។ ៥០ ឆ្នាំក្រោយមក កាលត្រូវការសេពសេជ្ជូវប្រៃ ទើបត្រាច់ទៅតាមជនបទ ដល់ដែនកាសី ។ ក្នុងស្រុកមួយកន្លែង នាដែនកាសីនោះ ទីបាយនតាបស មានសម្លាញ់ជាគ្រហស្ថម្នាក់ឈ្មោះមណ្ឌព្យៈ តាបសទាំង ២ បានទៅសួរសុខទុក្ខបុរសនោះ គាត់ឃើញតាបសនោះហើយ ក៏មានសេចក្ដីត្រេកអរ សាងបណ្ណសាលាប្រគេន ហើយទំនុកបម្រុងដោយបច្ច័យ ៤ តាបសទាំង ២ នៅទីនោះ ៣-៤ វស្សាហើយ លានាយមណ្ឌព្យៈ ត្រាច់ចារិកទៅកាន់នគរពារាណសី នៅក្នុងអធិមុត្តិកស្មសាន ។ ទីបាយនតាបសនៅក្នុងទីនោះ សមគួរដល់អធ្យាស្រ័យហើយ ក៏ត្រឡប់ទៅកាន់សម្នាក់សម្លាញ់នោះទៀត តែមណ្ឌព្យតាបសនៅក្នុងព្រៃខ្មោចនោះឯង ។

ថ្ងៃមួយ ចោរម្នាក់លួចរបស់ខាងក្នុងក្រុង កាន់យកទ្រព្យចេញទៅ កាលម្ចាស់ផ្ទះ និងអាជ្ញាធរដែនដីភ្ញាក់ឡើង ដឹងថា ចោរ ក៏នាំគ្នាតាមចាប់ បានរត់គេចតាមលូទឹក ប្រញាប់រត់ចូលព្រៃខ្មោច បោះបង់ចទ្រព្យចោលត្រង់ទ្វារបណ្ណសាលាកន្លែងតាបស ហើយចៀសចេញទៅ មនុស្សតាមមកឃើញកញ្ចប់ទ្រព្យ ទើបសម្គុតថា វ៉ុយ ជដិលបាប ពេលយប់ធ្វើចោរ ពេលថ្ងៃធ្វើតាបស វាយហើយ ចាប់ខ្លួនបញ្ជូនទៅកាន់សម្នាក់ព្រះរាជា។ ទ្រង់មិនបានពិចារណា បញ្ជាឲ្យរាជបុរសដោតដោយឈើអណ្ដោត ពួករាជបុរសនាំខ្លួនតាបស ទៅដោតដោយឈើគគីរក្នុងព្រៃនោះ តែដោតមិនចូល ទើបដូរឈើអណ្ដោត ដោយប្រើមែកស្ដៅ ក៏ដោតមិនចូលទៀត យកលំពែងដែកដោត

ក៏មិនចូល ។ តាបសពិចារណាមើលបុព្វកម្មរបស់ខ្លួន លំដាប់នោះ លោក ក៏រឭកជាតិបាន ប្រើញាណនោះពិចារណាមើលហើយ ។ សួរថា អ្វីជាបុព្វកម្ម របស់លោក ឆ្លើយថា លោកយកបន្ទារល្ហុសផ្អុងដោតរុយ ជាបុព្វកម្មរបស់ លោក បានឮថា ក្នុងអតីតជាតិ លោកកើតជាកូនជាងឈើ ទៅចាំងឈើជា មួយបិតា ចាប់រុយមួយហើយ យកបន្ទារល្ហុសផ្អុងដោត កម្មនោះឯងតាមមក ទាន់ លោកដឹងថា មិនអាចផុតបាបកម្មនេះបាន ទើបប្រាប់រាជបុរសថា បើ អ្នកចង់ដោតអាត្មា ចូរយកអណ្តោតដើមល្ហុសផ្អុង ពួករាជបុរសក៏ធ្វើហើយ ដោតហើយ ចាត់ឲ្យមនុស្សរក្សាចៀសចេញទៅ ពួកអ្នករក្សាបានចាំមើល បុគ្គលដែលមករកតាបស គ្រានោះ ទីបាយនតាបសគិតថា អញខានជួប សម្លាញ់យូរហើយ ទើបមកកាន់សម្នាក់របស់មណ្ឌព្យតាបស បានស្តាប់ដំណឹង ក្នុងរវាងផ្លូវក្នុងថ្ងៃនោះឯងថា មណ្ឌព្យតាបសត្រូវដោតឆ្កាង ក៏ទៅទីនោះ ហើយឈរក្នុងចំណែកម្ខាង សួរថា នែសម្លាញ់ លោកធ្វើខុសអ្វីឬ កាល តាបសនោះឆ្លើយថា ខ្ញុំមិនបានធ្វើខុស ក៏សួរទៀតថា លោកអាចរក្សាចិត្តមិន ឲ្យមានការអាក់អន់បានដែរឬទេ មណ្ឌព្យតាបសពោលថា សម្លាញ់ អ្នក ដែលចាប់ខ្ញុំបញ្ជូនទៅ និងព្រះរាជា ខ្ញុំមិនមានចិត្តអាក់អន់ឡើយ ទីបាយន-តាបសពោលថា បើដូច្នោះ ម្លប់អ្នកមានសីលដូចលោក ជាសេចក្តីសុខ សម្រាប់ខ្ញុំ ហើយចូលទៅអង្គុយផ្អែកលំពែង តំណក់ឈាមដែលចេញពីខ្លួន មណ្ឌព្យតាបស ក៏ហូរស្រោចលើទីបាយនតាបស តំណក់ឈាមទាំងនោះ ក៏ ហូរប្រឡាក់សរីរៈដែលមានពណ៌ដូចមាស ស្ងួតខ្មៅទៅពេញខ្លួន តាំងពីនោះ

មក ទើបបានឈ្មោះបន្ថែមថា កណ្ហទីបាយនៈ លោកអង្គុយផ្អែកឈើអណ្តោត នោះអស់មួយយប់ទល់ភ្លឺ ។

ស្អែកឡើង ពួកអ្នកយាមក៏ទៅក្រាបទូលហេតុការណ៍នោះដល់ព្រះរាជាៗ ទ្រង់ព្រះតម្រិះថា រឿងនេះ យើងធ្វើដោយមិនពិចារណា ទើបប្រញាប់ទៅទីនោះ ហើយត្រាស់សួរទីបាយនតាបសថា បពិត្របព្វជិត ហេតុអ្វី ទើបលោកអង្គុយផ្អែកឈើអណ្តោត ទីបាយនតាបសតបថា បពិត្រមហារាជ អាត្មាមកអង្គុយរក្សាតាបសនេះ មហាបពិត្រជ្រាបហើយឬថា តាបសនេះធ្វើខុស ឬមិនធ្វើខុស ទើបដាក់អាជ្ញាយ៉ាងនេះ ព្រះរាជាត្រាស់ថា ខ្ញុំដាក់ទោសដោយមិនពិចារណា តាបសក៏ពោលដល់ព្រះរាជាថា បពិត្រមហារាជ ធម្មតាស្តេច គួរពិចារណាសិន សឹមធ្វើ ដូច្នេះហើយ សម្តែងធម៌ថា គ្រហស្ថបរិភោគកាម ខ្ជិលច្រអូសមិនល្អ ដូច្នេះជាដើម ។

ព្រះរាជាទ្រង់ជ្រាបថា មណ្ឌព្យតាបសមិនមានកំហុស ទើបត្រាស់ឲ្យដកឈើចេញ ពួករាជបុរសមិនអាចដកបាន មណ្ឌព្យតាបសទូលព្រះរាជាថា បពិត្រមហារាជ អាត្មាដល់នូវសេចក្តីវិនាសលំបាកយ៉ាងនេះ ដោយអំណាចកម្មដែលធ្វើក្នុងកាលមុន មិនមាននរណាអាចដកអណ្តោតចេញពីខ្លួនអាត្មាបានទេ បើទ្រង់មានបំណងឲ្យជីវិតដល់អាត្មាសោត សូមឲ្យគេយករណារមកកាត់ឈើនេះស្មើស្បែក ព្រះរាជាត្រាស់ឲ្យធ្វើតាមនោះ ។ ខាងក្នុងរាងកាយមានកំណាត់ឈើនោះរហូតមក ។

បានឮថា គ្រានោះ តាបសនោះយកបន្ទារល្អសផ្អុងដោតរុយ បន្ទារល្អស

ជាប់ក្នុងខ្លួនរុយ តែរុយមិនស្លាប់ព្រោះការដោត រុយនោះស្លាប់ក្នុងកាលអស់អាយុរបស់ខ្លួន ដូច្នោះ ទើបតាបសនេះមិនស្លាប់ ។ ព្រះរាជាទ្រង់នមស្ការតាបសទាំង ២ សូមខមាទោសហើយ និមន្តឲ្យនៅក្នុងព្រះរាជឧទ្យាន ទំនុកបម្រុង ហើយតាំងពីនោះមក មណ្ឌព្យតាបស បាននាមបញ្ញត្តិថា អាណិ-មណ្ឌព្យៈ ។ តាបសអាស្រ័យព្រះរាជានៅក្នុងព្រះរាជឧទ្យាននោះ ឯទីបាយ-នតាបសរក្សារបួសមណ្ឌព្យតាបសជាល្អហើយ ទៅកាន់សម្នាក់នាយមណ្ឌព្យៈដែលជាសម្លាញ់គ្រហស្ថនៃខ្លួន ។

បុរសម្នាក់ឃើញទីបាយនតាបសនោះ ចូលទៅកាន់បណ្ណសាលា ទើបប្រាប់ដល់នាយមណ្ឌព្យៈជាសម្លាញ់ ។ នាយមណ្ឌព្យៈនោះ បានដំណឹងក៏ត្រេកអរ នាំបុត្រកភរិយា គ្រឿងសក្ការៈ មានផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាបជាដើម ជាច្រើនមកកាន់បណ្ណសាលា ថ្វាយបង្គំទីបាយនតាបសហើយលាងជើង លាបប្រេង ប្រគេនទឹកបានឲ្យឆាន់ ហើយអង្គុយស្តាប់ដំណឹងអាណិមណ្ឌព្យតាបស ។ កាលនោះ កូនប្រុសរបស់គាត់ឈ្មោះយញ្ញទត្តកុមារលេងវូនៅត្រង់ចុងទីចង្ក្រម ។ ត្រង់ទីចង្ក្រមមានដំបូក ក្បែរបណ្ណសាលានោះមានអាសិរពិសមួយអាស្រ័យនៅ ។ វូដែលកុមារគ្រវែងទៅលើផែនដី បានធ្លាក់ចូលទៅ ត្រូវក្បាលរបស់អាសិរពិសក្នុងដំបូក កុមារនោះមិនដឹង ទើបលូកដៃចូលទៅក្នុងរន្ធ ។ គ្រានោះ អាសិរពិសឆេវឆាវជាខ្លាំង ទើបចឹកដៃកុមារៗ នោះដួលសន្លប់ក្នុងទីនោះដោយកម្លាំងពិស លំដាប់នោះ មាតាបិតាដឹងថា កូនត្រូវអាសិរពិសខាំ ទើបលើកកុមារឡើង ហើយបីមករកតាបស

ដាក់ទៀបបាតជើង ហើយពោលថា បពិត្រលោកម្ចាស់ ធម្មតាបព្វជិត រមែង
ចេះឱសថ ឬព្រះបរិត្ត សូមលោកម្ចាស់ធ្វើកូនរបស់ខ្ញុំឲ្យជាសះស្បើយផងចុះ
តាបសពោលថា អាត្មាមិនចេះថ្នាំ អាត្មាជាបព្វជិត នឹងធ្វើវេជ្ជកម្មមិនបាន
តាបសត្រូវជនទាំង ២ ទទូចអង្វរថា បើដូច្នោះ សូមលោកម្ចាស់តាំងមេត្តា
ក្នុងកុមារ ធ្វើសច្ចាធិដ្ឋានចុះ ក៏ទទួលថា សាធុ ហើយធ្វើសច្ចកិរិយា ដាក់
ដៃចុះត្រង់ក្បាលយញ្ញទត្តកុមារ បានពោលគាថាទី ១ ថា

យើង មានចិត្តជ្រះថ្លា ត្រូវការដោយបុណ្យ បានប្រព្រឹត្តព្រហ្ម-
ចរិយៈអស់ ៧ ថ្ងៃគត់ មួយទៀត ព្រហ្មចរិយៈណា លើស
ទៅទៀត ដែលយើងបានប្រព្រឹត្តហើយ ព្រហ្មចរិយៈនេះ ជា
របស់នៃយើង យើងជាអ្នកមិនប្រាថ្នា ( ចំពោះបព្វជ្ជា ) អស់
ជាង ៥០ ឆ្នាំមកហើយ តែឥឡូវនេះ យើងខំប្រព្រឹត្តព្រហ្មចរិយៈ
ដោយពាក្យសច្ចៈនេះ សូមសួស្តីកើតមាន ( ដល់យញ្ញទត្តកុមារ )
ពិសចូរសាបរលាបបាត់ទៅ យញ្ញទត្តកុមារចូររស់ឡើង[១]
ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អជាបរំ យំ ចរិតំ** សេចក្តីថា ព្រោះដូច្នោះ
បន្ទាប់អំពី ៧ ថ្ងៃនោះមក យើងមិនបានប្រាថ្នា តែទ្រាំប្រព្រឹត្តព្រហ្មចរិយៈ
របស់យើងបាន ។ បទថា **អកាមកោ វាហិ** បានដល់ មិនប្រាថ្នានូវបព្វជ្ជា

---

១- គាថានេះ មានសេចក្តីថា តាបសត្រេកអរក្នុងព្រហ្មចរិយធម៌ ត្រឹម ៧ ថ្ងៃប៉ុណ្ណោះ
ក្រោយមក ក្នុងកាល ៥០ ឆ្នាំជាង ពុំមានសេចក្តីត្រេកអរឡើយ ។

ឡើយ ។ បទថា **ឯតេន សច្ចេន សុវត្ថិ ហោតុ** សេចក្តីថា បើកាលដែលយើងអត់ធន់ ដោយការមិនពេញចិត្តអស់ ៥០ ឆ្នាំថ្វាយ មិនប្រាប់ហើយដល់អ្នកណា ជាសច្ចៈសោត ដោយសច្ចៈនោះ សូមសួស្តីមានដល់យញ្ញទត្តកុមារ ចូរយញ្ញទត្តកុមារត្រឡប់បាននូវជីវិតចុះ ។

ជំណាលគ្នានឹងសច្ចកិរិយា ពិសក្នុងកាយកំណាត់ខាងលើរបស់យញ្ញទត្តកុមារ ក៏ធ្លាក់ចូលកាន់ផែនដីអស់ កុមារបើកភ្នែកឡើង មើលមាតាបិតាហៅថា ម៉ែ ហើយរើបម្រះ លំដាប់នោះ កណ្ហទីបាយនៈពោលនឹងបិតារបស់កុមារនោះថា កម្លាំងរបស់យើងៗ ធ្វើបានប៉ុណ្ណោះ ចូរអ្នកធ្វើកម្លាំងរបស់ខ្លួនចុះ បុរសនោះពោលថា ខ្ញុំនឹងធ្វើសច្ចកិរិយាដែរ ហើយដាក់ដៃត្រង់ទ្រូងកូនបានពោលគាថាទី ២ ថា

> ក្នុងកាលខ្លះ ខ្ញុំឃើញភ្ញៀវ ក្នុងវេលាដែលមកដល់លំនៅ ក៏
> មិនត្រេកអរនឹងឲ្យទានទេ តែខ្ញុំមិនឲ្យពួកសមណព្រាហ្មណ៍ ទោះ
> ជាពហុស្សូត បានដឹងថា ខ្ញុំមិនស្រឡាញ់ទេ មួយទៀត ខ្ញុំ ទោះ
> បីមិនប្រាថ្នា ( ក្នុងទាន ) ក៏នៅតែឲ្យ ដោយពាក្យសច្ចៈនេះ
> សូមសួស្តីកើតមាន ( ដល់យញ្ញទត្តកុមារ ) ពិសចូរសាប
> រលាបបាត់ទៅ សូមយញ្ញទត្តកុមាររស់ឡើង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វាសកាលេ** បានដល់ ក្នុងពេលដែលភ្ញៀវមកដល់ផ្ទះ ដើម្បីការស្នាក់នៅ ។ បទថា **ន ចាបិ មេ អប្បិយតំ អវេទុំ** សេចក្តីថា បិតារបស់កុមារ រមែងសម្តែងថា សូម្បីសមណព្រាហ្មណ៍ដែលជា

ពហុស្សុតក៏មិនជ្រាបហេតុ គឺអាការដែលមិនពេញចិត្តរបស់ខ្ញុំនេះសោះថា បុគ្គលនេះមិនពេញចិត្តនឹងឲ្យទាន បុគ្គលនេះមិនពេញចិត្តក្នុងពួកយើង ព្រោះខ្ញុំនៅតែសម្លឹងមើលដោយភ្នែកដែលសម្តែងសេចក្តីស្រឡាញ់ ។ បទថា **ឯតេន សច្ចេន** អធិប្បាយថា បើយើងឲ្យទាន ក៏មិនជឿផលនៃទាន ឲ្យដោយការមិនពេញចិត្តរបស់ខ្លួន ជនដទៃក៏មិនជ្រាបហេតុ គឺអាការដែលមិនជាទីពេញចិត្តរបស់ខ្ញុំសោត ដោយសច្ចៈនេះ ចូរសួស្តីមានដល់យញ្ញទត្តកុមារចុះ ។

កាលបិតាធ្វើសច្ចកិរិយាយ៉ាងនេះហើយ ពិសលើចង្កេះក៏ធ្លាក់ចូលកាន់ផែនដី កុមារក្រោកឡើងអង្គុយបាន តែឈរមិនបាន លំដាប់នោះ បិតាពោលនឹងមាតាកុមារនោះថា សម្លាញ់ស្មើចិត្ត អញបានធ្វើកម្លាំងរបស់អញហើយ ចូរនាងធ្វើសច្ចកិរិយាឲ្យកូនក្រោកឡើងដើរបាន មាតាពោលថា អើអ្នក សច្ចៈនៃខ្ញុំក៏មានមួយដែរ តែមិនអាចពោលចំពោះមុខអ្នកបាន បិតាពោលថា ទោះជាយ៉ាងណាក៏ដោយ ចូរនាងពោលចុះ ឲ្យតែបុត្ររបស់យើងជាសះស្បើយ នាងទទួលថា សាធុ កាលធ្វើសច្ចកិរិយា បានពោលគាថាទី ៣ ថា

ម្នាលកូន អាសិរពិសណា មានតេជៈច្រើន បានលូនចេញពីរន្ធ
មកចឹកអ្នក ក្នុងថ្ងៃនេះ ខ្ញុំ និងបិតាអ្នក មិនមានសេចក្តីប្លែកគ្នាណា
មួយ ក្នុងអាសិរពិសនោះទេ ( ព្រោះជាអ្នកមិនស្រឡាញ់ អាសិ-
រពិសដូចគ្នា ) ដោយពាក្យសច្ចៈនេះ សូមសួស្តីកើតមាន ពិស
ចូរសាបរលាបបាត់ទៅ សូមយញ្ញទត្តកុមាររស់ឡើង[១] ដូច្នេះ ។

---

១- គាថានេះ មានសេចក្តីថា អាសិរពិស និងបិតារបស់អ្នក មិនប្លែកគ្នាឡើយ ព្រោះមិនជាទីស្រឡាញ់របស់មាតា... ។

មាតាហៅបុត្រថា **តាត** ក្នុងគាថានេះ ។ បទថា **បហូតតេជោ** បាន ដល់ មានពិសដ៏ពន្លឹក ។ បទថា **ពិឡារា** បានដល់ ចេញអំពីរន្ធ ម្យ៉ាង ទៀត បាលីក៏ដូច្នេះដូចគ្នា ។ បទថា **ឧទ្ធច្ច** បានដល់ ចេញហើយ អធិប្បាយ ថា លូនមកអំពីរន្ធក្នុងដំបូក ។ បទថា **បិតរញ្ច តេ** បានដល់ ក្នុងបិតា របស់ឯង ។ ក្នុងអដ្ឋកថា បាលីក៏យ៉ាងនោះដូចគ្នា ។

សេចក្តីនេះ មានអធិប្បាយថា នែយញ្ញទត្តកូន អាសិរពិសនោះ ក៏មិន ប្លែកអ្វីពីបិតារបស់កូន ព្រោះមិនជាទីស្រឡាញ់របស់ម៉ែដូចគ្នា វៀរថ្ងៃនេះ ហើយ ម៉ែមិនធ្លាប់ឲ្យបុគ្គលណាដឹងនូវភាពមិនជាទីស្រឡាញ់នោះឡើយ បើ ពាក្យនេះជាពាក្យពិតសោត ដោយសច្ចៈនេះ ចូរសួស្តីមានដល់កូនចុះ ។ ដំណាលគ្នានឹងសច្ចកិរិយា ពិសទាំងអស់ក៏ធ្លាក់ចូលក្នុងផែនដី យញ្ញទត្ត- កុមារកាលរាងកាយអស់ពិសហើយ ក៏ក្រោកឡើងលែងជាធម្មតា កាលកូន ក្រោកឡើងបានហើយយ៉ាងនេះ នាយមណ្ឌព្យៈ កាលសួរដល់អធ្យាស្រ័យ របស់ទីបាយនតាបស ក៏ពោលគាថាទី ៤ ថា

ពួកជនណា បួស ជាអ្នកស្ងប់រម្ងាប់ ទូន្មានឥន្ទ្រិយ ពួកជននោះ
ប្រាកដជាអ្នកប្រាថ្នា ( នឹងបួស ) មែន វៀរលែងតែកណ្ហ-
ទីបាយនតាបសចេញ បពិត្រទីបាយនតាបស លោកស្អប់ខ្ពើមអ្វី
បានជាមិនចង់បួស ហើយទ្រាំប្រព្រឹត្តព្រហ្មចារ្យទៅវិញ ដូច្នេះ ។

គប្បីជ្រាបពាក្យដែលជាគាថានោះថា ឥស្សរជនទាំងឡាយ មានក្សត្រ ជាដើមពួកណាមួយ លះកាមហើយ ទើបបួសក្នុងលោកនេះ ជនទាំងនោះ

ក្រៅអំពីលោកម្ចាស់កណ្ហៈ គឺជនដទៃ វៀរលោកម្ចាស់កណ្ហៈដែលឈ្មោះថា ជាអ្នកអត់ធន់ ប្រព្រឹត្តព្រហ្មចរិយៈ រមែងមិនមាន ជនទាំងអស់នោះ ឈ្មោះថា **សន្តា** ព្រោះរម្ងាប់កិលេសដោយឈានភាវនា ឈ្មោះថា **ទន្តា** ព្រោះទូន្មានចក្ខុទ្វារជាដើម ឲ្យផុតចាកព្យសន៍កំណាច ត្រេកអរក្រៃលែង ទើបប្រព្រឹត្តព្រហ្មចរិយៈបាន លោកម្ចាស់ទីបាយនៈដ៏ចម្រើន លោកម្ចាស់ស្អប់ខ្ពើមអ្វី ទើបទូន្មានចិត្តប្រព្រឹត្តព្រហ្មចរិយៈបាន ហេតុអ្វី ទើបមិនសឹក មកគ្រប់គ្រងផ្ទះ ។ កាលតាបសប្រាប់រឿងរបស់ខ្លួន ទើបពោលគាថាទី ៥ ថា

បុគ្គលណាចេញ ( ចាកផ្ទះបួស ) ដោយសទ្ធាហើយ ត្រឡប់មក ( កាន់ផ្ទះ ) វិញ បុគ្គលនោះឯង ឈ្មោះថា ជាមនុស្សល្ងីល្ងើ មិននឹងនួន យើងស្អប់ខ្ពើមវាទៈនេះ ( សូម្បី ) ជាអ្នកមិនប្រាថ្នា ( បួស ) ក៏ទ្រាំប្រព្រឹត្តព្រហ្មចារ្យ ដែលវិញ្ញូជនសរសើរផង ជាឋានៈរបស់ពួកសប្បុរសផង យើងជាអ្នកធ្វើនូវបុណ្យយ៉ាងនេះ ដូច្នេះ ។

បណ្ឌិតគប្បីជ្រាបអត្ថនៃគាថានោះថា យើងស្អប់ខ្ពើមនូវពាក្យបែបនេះថា បុគ្គលជឿកម្មខ្លៅ និងផលនៃកម្ម លះសម្បត្តិជាច្រើនចេញបួសហើយ ត្រឡប់មកដើម្បីវត្ថុដែលខ្លួនលះទៀត បុគ្គលនោះ ជាបុគ្គលល្ងីល្ងើហ្ន៎ ជាមនុស្សមិននឹងនួន ដូចក្មេងអ្នកស្រុកហ្ន៎ សូម្បីមិនប្រាថ្នា ក៏ត្រូវអត់ធន់ ប្រព្រឹត្តព្រហ្មចរិយៈ ព្រោះខ្លាចហិរិ និងឱត្តប្បៈរបស់ខ្លួនបែកធ្លាយ ធម្មតា បព្វជ្ជា និងបុណ្យនោះ សូម្បីតិចតួច ក៏ជាឋានៈដែលវិញ្ញូជនទាំងឡាយ មានព្រះពុទ្ធ

ជាដើមសរសើរយ៉ាងក្រៃលែង និងជាឋានៈដែលជាវិហារធម៌របស់សប្បុរស ទាំងឡាយនោះ អាត្មាជាអ្នកធ្វើបុណ្យ ដោយប្រការដូច្នេះ ដោយហេតុនេះ ទោះបីទឹកភ្នែកជោកមុខ ក៏អត់ធន់ប្រព្រឹត្តព្រហ្មចរិយៈរហូតមក ។

តាបសកាលប្រាប់អធ្យាស្រ័យរបស់ខ្លួនយ៉ាងនេះហើយ កាលនឹងសាកសួរនាយមណ្ឌព្យៈ ទើបពោលគាថាទី ៦ ថា

ចំណែកអ្នកបានញុំាងពួកសមណព្រាហ្មណ៍ និងអ្នកដំណើរឲ្យ
ឆ្អែតស្កប់ស្កល់ ដោយបាយ ទឹក និងភិក្ខាហារ ឯផ្ទះរបស់អ្នក
នេះ មានភិក្ខាហារ ( ដ៏សម្បូរ ) ដូចជាស្រះសម្រាប់ជនចុះផឹក
កាលបើដូច្នេះទេ ចុះអ្នកស្អប់ខ្ពើមពាក្យអ្វី បានជាអ្នកមិនប្រាថ្នា
នឹងឲ្យទាន តែនៅតែឲ្យនូវទាននេះវិញ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ភិក្ខុំ** បានដល់ ឲ្យភិក្ខាហារដ៏ឧត្ដមបរិបូណ៌ ដល់សមណព្រាហ្មណ៍ និងអ្នកដំណើរទាំងឡាយដែលត្រាច់ទៅ ។ បទថា **ឱបានភូតំវ** បានដល់ ដូចអណ្ដូងទឹកសាធារណៈ ដែលគេជីកក្នុងផ្លូវធំ ដែលមានមុំ ៤ ។ លំដាប់នោះ នាយមណ្ឌព្យៈកាលនឹងប្រាប់អធ្យាស្រ័យរបស់ខ្លួន ក៏ពោលគាថាទី ៧ ថា

មាតាបិតា និងជីដូនជីតារបស់ខ្ញុំ ជាអ្នកមានសទ្ធា ជាម្ចាស់នៃទាន
ជាអ្នកដឹងនូវពាក្យស្មូម ខ្ញុំប្រព្រឹត្តតាមវត្តរបស់ត្រកូលនោះ ដោយ
តាំងចិត្តថា អាត្មាអញកុំជាអ្នកមានក្នុងទីបំផុត និងជាអ្នកកាត់នូវ
វង្សត្រកូល ក្នុងត្រកូលឡើយ អាត្មាអញ ស្អប់ខ្ពើមចំពោះពាក្យ

នោះ ( ទោះបី ) ជាអ្នកមិនមានប្រាថ្នានឹងឲ្យទាន ក៏នៅតែឲ្យនូវទាននេះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អាសុំ** សម្ពន្ធនឹងបទថា **សទ្ធា** នេះ អធិប្បាយថា ជាអ្នកមានសទ្ធាហើយ ។ បទថា **អហុ** ជាដើម សេចក្ដីថា ជាអ្នកមានសទ្ធាក្រៃលែងជាងនោះ ជាធំដោយទានផង ជាអ្នកយល់អត្ថនៃពាក្យដែលជនពោលថា សូមអ្នកទាំងឡាយឲ្យ ចូរធ្វើដូច្នេះឲ្យជាក់ច្បាស់ផង ។ បទថា **តំ កុលវត្តំ** បានដល់ តាមទំនៀមក្នុងត្រកូលនោះ ទោះបីក្នុងអដ្ឋកថាក៏មានបាលីយ៉ាងនេះដូចគ្នា ។ បទថា **មាហំ កុលេ អន្តិមគន្ធិនោ អហុំ** សេចក្ដីថា នាយមណ្ឌព្យៈសម្ដែងថា ខ្ញុំកំណត់ក្នុងចិត្តថា អាត្មាអញ កុំជាមនុស្សចុងក្រោយបង្អស់ក្នុងត្រកូលរបស់ខ្លួន ដោយការកាត់ផ្ដាច់នូវទំនៀមនៃត្រកូល ដូច្នេះ ។ ស្អប់នូវវាទៈថា កាត់នូវទំនៀមនៃត្រកូលក្រោយគេ ទោះបីមិនបំណងឡើយ ក៏នៅតែឲ្យទានបាន ។

កាលពោលយ៉ាងនេះហើយ នាយមណ្ឌព្យៈ កាលសួរកិរិយារបស់ខ្លួន ទើបពោលគាថាទី ៨ ថា

ម្នាលនាងមានសរីរៈកាយដ៏ល្អ យើងបាននាំនាងមកអំពីត្រកូលនៃញាតិ តាំងពីកាលនាងនៅជាកុមារីក្មេង មានប្រាជ្ញាមិនទាន់អង់អាចម៉្លេះ នាងបម្រើអញទាំងមិនចង់ តែមិនឲ្យដឹងថា មិនស្រឡាញ់អញ ម្នាលនាងកាលបើដូច្នេះ ការនៅរួមជាមួយយើងមានសភាពយ៉ាងនេះ តើដោយហេតុដូចម្ដេច ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អសមត្ថបញ្ញំ** បានដល់ នៅជាកុមារី ដែលមានបញ្ញាមិនអាចចាត់ចែងទ្រព្យបាន ។ បទថា **យន្តានយឹ** កាត់បទជា **យំ តំ អានយឹ** អធិប្បាយថា យើងនាំនាងតាំងពីជាកុមារីមក អំពីត្រកូលនៃញាតិ ។ បទថា **អញ្ញត្រ កាមា បរិចារយន្តា** សេចក្ដីថា នាងមិនមានសេចក្ដីស្រឡាញ់ បដិបត្តិយើងដោយមិនពេញចិត្ត ក៏មិនឲ្យអញដឹងថា នាងមិនមានសេចក្ដីស្រឡាញ់ អស់កាលមានប្រមាណប៉ុណ្ណេះ គឺសម្ដែងសេចក្ដីស្រឡាញ់ ប្រណិប័តន៍អញហើយ ។ បទថា **កេន វណ្ណេន** បានដល់ ដោយហេតុអ្វី ។ នាយមណ្ឌព្យៈហៅភរិយាថា **ភោតិ** ។ បទថា **ឯវំ ភោ** សេចក្ដីថា ការដែលនាងនៅរួមជាមួយយើង ដែលមានការស្អប់ខ្ពើម ស្មើដោយអាសិរពិសបែបនេះបាន គឺហាក់ដូចជានៅរួមនឹងមនុស្សជាទីស្រឡាញ់បានដូចម្ដេច។ គ្រានោះ កាលភរិយាប្រាប់ដល់ស្វាមី បានពោលគាថាទី ៩ ថា

យូរណាស់មកហើយ ក្នុងកាលណាក៏ដោយ ការផ្លាស់ប្ដូរប្ដី មិនមានក្នុងត្រកូលនេះទេ ខ្ញុំប្រព្រឹត្តតាមវត្តរបស់ត្រកូលនោះ ដោយតាំងចិត្តថា អាត្មាអញ កុំជាអ្នកមានក្នុងទីបំផុត និងជាអ្នកកាត់នូវវង្សត្រកូល ក្នុងត្រកូលឡើយ ខ្ញុំស្អប់ខ្ពើមពាក្យនេះ ទោះបីជាអ្នកមិនមានប្រាថ្នានឹងបម្រើ ក៏ប្រព្រឹត្តបម្រើមិនដាច់ចំពោះអ្នកដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អារា ទូរេ** ជាវេវចនៈនៃគ្នានិងគ្នា កាលនាងសម្ដែងទំនៀមថា យូរយារមកហើយ ទើបពោលយ៉ាងនេះ ។ សព្វថា

**៩៨** ត្រឹមតែជានិបាត សេចក្តីថា ក្នុងកាលណាៗ ក៏មិនមាន ។ បទថា **បរម្បរា** បានដល់ ដូរប្រុសរឿយៗ ។

សេចក្តីនេះ មានអធិប្បាយថា នែអ្នក តាំងពីយូរមកហើយ រហូតដល់ ៧ តំណាត្រកូល ដែលភរិយាមានប្តីច្រើន មិនមានក្នុងត្រកូលនៃញាតិរបស់ខ្ញុំឡើយ ទោះបីមានស្រីខ្វះលែងប្តីហើយ ក៏មិនយកប្រុសដទៃជាប្តីឡើយ ។ បទថា **តំ កុលវត្តំ** សេចក្តីថា ខ្ញុំអនុវត្តតាមទំនៀមរបស់ត្រកូល គឺតាមបវេណីរបស់ត្រកូលនោះ កំណត់ថា អញកុំបីជាស្រីមិននឹងនួន គឺជាមនុស្សចុងក្រោយ ក្នុងត្រកូលរបស់ខ្លួន ខ្មើមនូវវាទៈថា ជាស្រីកាត់នូវទំនៀមរបស់ត្រកូល ជាមនុស្សចុងក្រោយក្នុងត្រកូលនោះ ទោះបីមិនពេញចិត្ត ក៏បដិបត្តិអ្នកបាន គឺជាអ្នកធ្វើសេចក្តីខ្វល់ខ្វាយ ជាអ្នកបម្រើទៀបបាតជើងអ្នកបាន ។

កាលនាងពោលយ៉ាងនេះហើយ ទើបគិតថា អាថ៌កំបាំងមិនគួរពោលចំពោះមុខប្តី អញបានពោលហើយ ប្តីគង់នឹងក្រោធ អញនឹងសូមទោសប្តីចំពោះមុខតាបស ដែលចូលដល់ត្រកូលរបស់អញ កាលឲ្យស្វាមីអត់ទោស ទើបពោលគាថាទី ១០ ថា

បពិត្រមណ្ឌព្យៈ ខ្ញុំនិយាយនូវពាក្យដែលមិនគួរនិយាយ សូមអ្នកអត់ទោសចំពោះពាក្យនោះ ដល់ខ្ញុំក្នុងថ្ងៃនេះ ព្រោះហេតុនៃកូនចុះ របស់ណាមួយឯទៀតក្នុងលោកនេះ រមែងមិនមានជាងសេចក្តីស្រឡាញ់ក្នុងកូនឡើយ យញ្ញទត្តកុមាររបស់យើងនេះរស់វិញ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **តំ ខម្សតំ** បានដល់ សូមអត់ទោសនូវពាក្យនោះ ។ បទថា **បុត្តហេតុ មមជ្ជ** សេចក្ដីថា សូមអ្នកអត់ទោសនូវពាក្យ ដែលខ្ញុំពោលហើយនោះ ព្រោះយល់ដល់កូនក្នុងថ្ងៃនេះចុះ ។ បទថា **សោ ហោ អយំ** សេចក្ដីថា ខ្ញុំពោលពាក្យនោះ ព្រោះហេតុនៃកូនណា កូនរបស់យើងនោះ បានរស់រានមានជីវិតហើយ ព្រោះកូននេះរស់រានមានជីវិតហើយនោះឯង សូមអ្នកអត់ទោសដល់ខ្ញុំ តាំងអំពីថ្ងៃនេះទៅ ខ្ញុំនឹងនៅក្នុងអំណាចរបស់អ្នក ។

លំដាប់នោះ នាយមណ្ឌព្យៈបានពោលនឹងភរិយាថា នាងជាទីស្រឡាញ់ ចូរនាងក្រោកឡើង យើងអត់ទោសឲ្យនាង តាំងអំពីនេះទៅ នាងកុំមានចិត្តរឹងត្អឹង សូម្បីយើងក៏មិនស្អប់ខ្ពើមនាង ។ តាបសពោលនឹងនាយមណ្ឌព្យៈថា អាវុសោ កាលដែលអ្នករកទ្រព្យបានមកដោយលំបាក ហើយបរិច្ចាគទានដោយមិនជឿកម្ម និងផលនៃកម្មនោះ ជាការមិនសមគួរ តាំងអំពីនេះទៅ ចូរអ្នកជឿនូវកម្ម និងផលនៃកម្ម ហើយឲ្យទានចុះ នាយមណ្ឌព្យៈទទួលថា សាធុ ហើយពោលនឹងតាបសថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់តាំងនៅក្នុងភាពជាទក្ខិណេយ្យបុគ្គលរបស់ខ្ញុំ ការមិនមានសេចក្ដីត្រេកអរប្រព្រឹត្តព្រហ្មចរិយៈ ជាការមិនសមគួរឡើយ តាំងអំពីនេះទៅ សូមលោកម្ចាស់ធ្វើចិត្តឲ្យជ្រះថ្លា មានចិត្តបរិសុទ្ធ ត្រេកអរក្នុងឈាន ប្រព្រឹត្តព្រហ្មចរិយៈ ដោយលក្ខណៈដែលខ្ញុំធ្វើសក្ការៈដល់លោកម្ចាស់ក្នុងឥឡូវនេះ ហើយនឹងបានទទួលផលច្រើនចុះ ។ ស្វាមីភរិយាទាំង ២ ក៏នមស្ការតាបស ក្រោកអំពីអាសនៈ

ទៅ តាំងពីនោះមក ភរិយាក៏មានចិត្តស្រឡាញ់ក្នុងប្ដីយ៉ាងល្អ នាយមណ្ឌព្យៈក៏មានចិត្តជ្រះថ្លា ថ្វាយទានដោយសទ្ធា តាបសបន្ទោបង់ការអផ្សុកចេញ បានធ្វើឈាន និងអភិញ្ញាឲ្យកើតឡើង មានព្រហ្មលោកជាទីទៅខាងមុខ ។

ព្រះសាស្ដា កាលទ្រង់នាំព្រះធម្មទេសនានេះមកសម្ដែងហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងកាលចប់សច្ចៈ ភិក្ខុអផ្សុកតាំងនៅក្នុងសោតាបត្តិផល ហើយទ្រង់សមោធានជាតកថា នាយមណ្ឌព្យៈក្នុងកាលនោះ បានមកជាអានន្ទក្នុងកាលឥឡូវនេះ ភរិយាក្នុងកាលនោះ បានមកជានាងវិសាខាបុត្រក្នុងកាលនោះ បានជារាហុល អាណិមណ្ឌព្យតាបសក្នុងកាលនោះ បានមកជាសារីបុត្រ ឯកណ្ហទីបាយនតាបសក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា មណ្ឌព្យជាតក ចប់

# សុត្តន្តបិដក

## និគ្រោធជាតក

[ ៦៨៨ ] ( បោតិកបុរសពោលថា ) បពិត្រនិគ្រោធ សាខ-សេនាបតីបាននិយាយថា អញមិនស្គាល់អ្នកនុ៎ះទេ អ្នកនេះជាអ្វីឬជាអ្នកបម្រើរបស់អ្នកណា ( ដូច្នេះ ) យ៉ាងណា តើព្រះអង្គទ្រង់យល់យ៉ាងនោះដែរឬ ។

[ ៦៨៩ ] កាលនោះ ពួកបុរស អ្នកធ្វើតាមពាក្យសាខបុរស ក៏ទះតប់មាត់បណ្តេញខ្ញុំព្រះអង្គ ដោយការអូស-កចេញ ។

[ ៦៩០ ] បពិត្រព្រះអង្គជាធំជាងជន អំពើមិនប្រសើរប្រាកដដូច្នេះ សាខៈជាសម្លាញ់របស់ព្រះអង្គ ជាមនុស្សមានគំនិតអាក្រក់ ជាអកតញ្ញូ ទ្រុស្តមិត្ត បានធ្វើហើយ ។

[ ៦៩១ ] ( ព្រះបាទនិគ្រោធ ... ) ម្នាលសម្លាញ់ អ្នកប្រាប់នូវការទន់ទាញណា ដែលសាខៈធ្វើហើយដល់ខ្ញុំ ខ្ញុំមិនដឹងនូវដំណើរនុ៎ះទេ ទាំងអ្នកណាមួយ ក៏មិនបានប្រាប់ដល់ខ្ញុំដែរ ។

[ ៦៩២ ] អ្នកបានធ្វើនូវការចិញ្ចឹមជីវិតងាយ ដល់សម្លាញ់ទាំង ២ នាក់ គឺខ្ញុំ និងសាខៈ ជាអ្នកឲ្យឥស្សរិយយស គឺភាពជាធំក្នុងមនុស្សដល់យើង យើងបានសេចក្តីសម្រេចក៏ព្រោះអ្នក សេចក្តីសង្ស័យក្នុងហេតុនុ៎ះ មិនមានដល់ខ្ញុំទេ ។

[ ៦៩៣ ] ពូជ ( ដែលដាក់ ) ក្នុងភ្លើង រមែងឆេះ មិនដុះយ៉ាងណាមិញ ឧបការគុណដែលបុគ្គលធ្វើហើយ ក្នុងអសប្បុរស

រមែងវិនាស មិនលូតលាស់យ៉ាងនោះដែរ ។

[ ៦៩៤ ] ឧបការគុណដែលបុគ្គលធ្វើហើយ ក្នុងបុរសជាកតញ្ញូ មានសីលធម៌ មានសេចក្តីប្រព្រឹត្តប្រសើរនោះ រមែងមិនវិនាសទេ ដូចពូជ ( ដែលព្រោះ ) ក្នុងស្រែល្អ ។

[ ៦៩៥ ] រាជបុរសទាំងឡាយ ចូរយកលំពែងសម្លាប់នូវសាខៈនេះ ជាមនុស្សលាមក របិញរបុញ មានគំនិតជាអសប្បុរសចុះ យើងមិនប្រាថ្នាឲ្យវារស់នៅទេ ។

[ ៦៩៦ ] ( បោតិកៈ ... ) បពិត្រមហារាជ សូមព្រះអង្គអត់ទោសចំពោះបុរសនេះ ( ព្រោះថា ) ជីវិត ( របស់សត្វដែលស្លាប់ហើយ ) មិនអាចនាំត្រឡប់មកវិញបានទេ បពិត្រព្រះសម្មតិទេព សូមព្រះអង្គអត់ទោសដល់អសប្បុរស ខ្ញុំព្រះអង្គមិនប្រាថ្នាការសម្លាប់បុរសនេះទេ ។

[ ៦៩៧ ] បុគ្គលគប្បីសេពគប់ នូវស្តេចនិគ្រោធប៉ុណ្ណោះ កុំនៅជាមួយសាខៈឡើយ សេចក្តីស្លាប់ក្នុងសម្នាក់ស្តេចនិគ្រោធប្រសើរជាង ឯការរស់នៅក្នុងសម្នាក់សាខៈ ពុំប្រសើរឡើយ ។

**និគ្រោធជាតកទី ៧ ចប់**

# អដ្ឋកថា

## ឆិគ្រោធជាតក

[ ៦៨៨-៦៩៧ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធទេវទត្តភិក្ខុ ទើបត្រាស់រឿងនេះ មានពាក្យផ្តើមថា **ឆ វាហាមេតំ ជាឆាមិ** ដូច្នេះជាដើម ។

បានឮថា ថ្ងៃមួយ ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងធម្មសភាដល់រឿងទេវទត្តភិក្ខុ កាលភិក្ខុទាំងឡាយជាស់តឿនថា នែទេវទត្ត ព្រះសាស្តាទ្រង់មានឧបការៈដល់លោក ព្រោះលោកបានអាស្រ័យទ្រង់ ទើបបានបព្វជ្ជាឧបសម្បទា បានរៀនព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដក និងបានឈាន សូម្បីលាភសក្ការៈរបស់លោកកើតអំពីព្រះទសពលទាំងអស់ ។ ទេវទត្តលើកស្លាកស្មៅឡើង ប្រកាសថា ឧបការគុណសូម្បីត្រឹមតែប៉ុណ្ណេះ យើងក៏មិនធ្លាប់សម្លឹងមើលឃើញថា ព្រះសមណគោតមធ្វើដល់យើង ដូច្នេះ ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកទាំងឡាយអង្គុយសន្ទនាគ្នាដល់រឿងអ្វី កាលភិក្ខុទាំងឡាយទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះ ដែលទេវទត្តជាអកតញ្ញូ ទ្រុស្តមិត្ត សូម្បីក្នុងកាលមុន ទេវទត្តក៏អកតញ្ញូ ទ្រុស្តមិត្តដូចគ្នា ហើយទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទមគធរាជ សោយរាជសម្បត្តិក្នុងនគររាជគ្រឹះ កាលនោះ សេដ្ឋីក្រុងរាជគ្រឹះ បានស្តីដណ្តឹងធីតាសេដ្ឋីក្នុងជនបទ មកឲ្យជា

កិរិយារបស់បុត្រខ្លួន ។ ស្រីនោះ ជាស្រីអា ក្រោយមក ត្រកូលនោះ ក៏សាបសូន្យលាភសក្ការៈ គេនិយាយឲ្យស្រីនោះឮថា បើស្រីអាមកនៅក្នុងផ្ទះអយ្យបុត្រយើង វង្សត្រកូលចម្រើនបានដូចម្តេច ។ ស្រីនោះ បានស្តាប់ពាក្យនោះ ក៏គិតថា ណ្ហើយចុះ អញនឹងធ្វើជាមានគភ៌ បោកបញ្ឆោតមនុស្សទាំងនេះ ហើយសួរភីលៀងដែលស្និទ្ធស្នាល ដល់វិធីការស្រីមានគភ៌ថា ធម្មតាស្រីមានគភ៌ត្រូវធ្វើដូចម្តេចខ្លះ កាលបានស្តាប់ហើយ ដល់ពេលមានរដូវ ក៏បិទបាំង សម្តែងកិរិយារបស់ស្រីចាញ់ផ្ទៃ មានចូលចិត្តរបស់ជូរជាដើម ក្នុងកាលដែលដៃជើងត្រូវហើម ក៏វាយខ្នងដៃ ខ្នងជើងឲ្យហើម យកកន្ទបរុំពោះឲ្យធំឡើងរាល់ថ្ងៃ ធ្វើចុងដោះឲ្យខ្មៅ ធ្វើសរីរកិច្ច ក៏មិនធ្វើចំពោះមុខអ្នកដទៃក្រៅអំពីស្រីភីលៀងនោះ ស្វាមីប្តីក៏ជួយបរិហារគភ៌ដល់នាងរហូត ៩ ខែដោយអាការយ៉ាងនេះ ទើបនាងលាឪពុកម្តាយទៅប្រសូតបុត្រ ក្នុងផ្ទះបិតាឯជនបទ ហើយក៏ឡើងរថអំពីនគររាជគ្រឹះ ធ្វើដំណើរទៅដោយបរិវារធំ ។

នៅខាងមុខនាងមានពួករទេះមួយក្រុម នាងទៅដល់ទីដែលពួកអ្នករទេះឈប់សម្រាកក្នុងពេលអាហារព្រឹក កាលនោះ មានស្រីទុគ៌តម្នាក់ អាស្រ័យពួករទេះនោះ ប្រសូតបុត្រត្រង់គល់ជ្រៃមួយដើមក្នុងកណ្តាលយប់ លុះព្រឹកឡើង កាលពួកអ្នករទេះចេញដំណើរ គិតថា អញវៀរពួកអ្នករទេះហើយមិនអាចទៅបាន បើអញនៅមានជីវិត នឹងមានកូនទៀត ដូច្នេះ ទើបយកមន្ទិលគភ៌មកស្រោចត្រង់គល់ជ្រៃ ហើយចោលទារកក្នុងទីនោះ ។ ទេវតាក៏បានរក្សាទារកនោះ ព្រោះទារកនោះមិនមែនសត្វសាមញ្ញ គឺព្រះពោធិសត្វ

នោះឯង តែគ្រានោះ ព្រះពោធិសត្វមកបដិសន្ធិ មានសភាពបែបនោះ ។

ពេលព្រឹក ស្រីអានោះបានទៅដល់ទីនោះក្នុងពេលអាហារព្រឹក គិតថា នឹងធ្វើសរីរកិច្ច ទើបទៅត្រង់គល់ជ្រៃជាមួយភីលៀងនោះ ឃើញទារកមាន ពណ៌ដូចមាស ទើបនិយាយនឹងភីលៀងថា កិច្ចរបស់យើងសម្រេចហើយ ទើបដោះសំពត់រុំពោះចេញ យកឈាម និងមន្ទិលគភ៌លាបជើង ហើយប្រាប់ ថា ខ្ញុំនប្រសូតបុត្រ ។ រំពេចនោះ ពួកបរិវារនាំគ្នាត្រេកអរ ជួយគ្នាយក វាំងននបាំងឲ្យនាង ហើយមានលិខិតបញ្ជូនទៅនគររាជគ្រឹះ ។ លំដាប់នោះ ឪពុកក្មេក ម្តាយក្មេករបស់នាង មានសំបុត្របញ្ជូនទៅថា បើប្រសូតហើយ មិនចាំបាច់ទៅត្រកូលបិតា ចូរត្រឡប់មកវិញចុះ ទើបនាងត្រឡប់មកនគរ រាជគ្រឹះវិញ កាលដល់ថ្ងៃដាក់ឈ្មោះទារក ញាតិទាំងឡាយបានឲ្យឈ្មោះថា និគ្រោធកុមារ ព្រោះកើតត្រង់គល់ជ្រៃ ។ ក្នុងថ្ងៃជាមួយគ្នានោះ កូនប្រសា របស់អនុសេដ្ឋីក៏ទៅត្រកូលមាតាបិតា ដើម្បីប្រសូតបុត្រ បានប្រសូតបុត្រ ក្រោមមែកឈើមួយដើម ក្នុងវាងផ្លូវ ពួកញាតិបានដាក់ឈ្មោះទារកនោះថា **សាខកុមារ** ។ ក្នុងថ្ងៃជាមួយគ្នានោះ ភរិយារបស់ជាងកាត់ដេរដែលអាស្រ័យ មហាសេដ្ឋីក៏ប្រសូតបុត្រ ក្នុងរវាងគំនរសំពត់ចាស់ៗ ទើបពួកញាតិដាក់ ឈ្មោះទារកនោះថា **បោត្តិកៈ** ។

មហាសេដ្ឋីជ្រាបថា ទារកទាំង ២ នោះ កើតក្នុងថ្ងៃដែលនិគ្រោធកុមារ កើត ទើបនាំមកចិញ្ចឹមជាមួយនិគ្រោធកុមារ ។ កុមារទាំង ៣ នោះ ចម្រើន ធំធាត់ព្រមគ្នា លុះចម្រើនវ័យហើយ ទើបទៅកាន់នគរតក្កសិលា រៀននូវ

សិប្បៈ ។ កូនសេដ្ឋី ២ នាក់ឲ្យទ្រព្យថ្លៃបង្រៀនដល់អាចារ្យម្នាក់ ១០០០ តែបោតិកកុមារ ចាំរៀនសិល្បៈបន្តក្នុងសម្នាក់និគ្រោធកុមារ ។ កាលកុមារទាំង ៣ សម្រេចការសិក្សាហើយ ទើបលាអាចារ្យត្រាច់ទៅតាមជនបទ ដល់នគរពារាណសីដោយលំដាប់ ដេកត្រង់គល់ឈើមួយកន្លែង ។

សម័យនោះ ជាពេលដែលព្រះបាទពារាណសីទ្រង់សោយទិវង្គត បាន ៧ ថ្ងៃ ពួកសេនាមាត្យវាយស្គរប្រកាសពេញនគរថា ថ្ងៃស្អែកនេះ នឹងផ្សងបុស្សរថ ខណៈដែលសម្លាញ់ទាំង ៣ ដេកលក់ត្រង់គល់ឈើ បោតិកៈក្រោកឡើងក្នុងពេលទៀបភ្លឺ អង្គុយច្របាច់ជើងនិគ្រោធកុមារ លើដើមឈើនោះមានមាន់ ២ ដេក មាន់ដែលដេកលើបន្ទោបង់ឧច្ចារៈដាក់មាន់ដែលដេកក្រោម គ្រានោះ មាន់ខាងក្រោមសួរមាន់ខាងលើថា អ្នកណាជុះអាចម៍ មាន់ខាងលើឆ្លើយថា នែសម្លាញ់ កុំក្រោធឡើយ ខ្ញុំមិនដឹងទើបជុះ មាន់ខាងក្រោមស្តីឲ្យមាន់ខាងលើថា នែសត្វអាក្រក់ ឯងយល់ថា ខ្ញុំជាបង្គន់របស់ឯងឬ ឯងមិនស្គាល់គុណរបស់ខ្ញុំឬ មាន់ដែលដេកខាងលើពោលនឹងមាន់ដែលដេកខាងក្រោមនោះថា នែសត្វអាក្រក់ កាលអញមិនដឹង ព្រមទទួលហើយថា អញបន្ទោបង់ អានៅខឹងក្រោធទៀត អ្វីជាសេចក្តីល្អរបស់អា មាន់ខាងក្រោមឆ្លើយថា អ្នកណាសម្លាប់អញ ហើយស៊ីសាច់ អ្នកនោះនឹងបានទ្រព្យ ១០០០ ទាំងព្រឹក ដូច្នោះ ទើបអញប្រកាន់ខ្លួន មាន់ខាងលើពោលនឹងមាន់ខាងក្រោមនោះថា សត្វអាក្រក់ ដោយហេតុត្រឹមប៉ុណ្ណោះអាប្រកាន់ខ្លួន អញនេះ បើអ្នកណាសម្លាប់ ហើយស៊ីសាច់ចំឡូករបស់អញ នឹងបានជាព្រះរាជាទាំងព្រឹក អ្នកដែល

ស៊ីសាច់កណ្ដាល នឹងបានជាសេនាបតី អ្នកស៊ីសាច់ជាប់ឆ្អឹង នឹងបានជានាយឃ្លាំង ។ បោតិកៈបានឮពាក្យមាន់ទាំង ២ នោះ ទើបគិតថា ប្រយោជន៍អ្វីដោយទ្រព្យ ១០០០ រាជសម្បត្តិប៉ុណ្ណោះប្រសើរ ទើបឡើងដើមឈើសន្ទ្រមចាប់មាន់ដែលដេកខាងលើសម្លាប់ អាំងលើរងើកភ្លើង ហើយហែកសាច់ចំឡែកឲ្យនិគ្រោធកុមារ ឲ្យសាច់កណ្ដាលដល់សាខកុមារ ខ្លួនឯងបរិភោគសាច់ជាប់ឆ្អឹង កាលបរិភោគហើយ បោតិកៈក៏ពោលថា និគ្រោធសម្លាញ់ ថ្ងៃនេះ ឯងនឹងបានជាព្រះរាជា ឯសាខៈ ថ្ងៃនេះឯង នឹងបានជាសេនាបតី ចំណែកខ្ញុំនឹងបានជានាយឃ្លាំង ត្រូវសម្លាញ់ទាំង ២ សួរថា ឯងដឹងបានដូចម្ដេច ទើបនិយាយរឿងឲ្យស្ដាប់គ្រប់ប្រការ ។

សម្លាញ់ទាំង ៣ នោះ កាលដល់ពេលបរិភោគអាហារព្រឹក ក៏នាំគ្នាចូលកាន់នគរពារាណសី បរិភោគបាយាសដែលលាយដោយសប្បិ និងស្ករ ត្រង់ផ្ទះព្រាហ្មណ៍ម្នាក់ ហើយចេញអំពីក្រុងចូលព្រះរាជឧទ្យាន និគ្រោធកុមារ ដេកលើផ្ទាំងថ្ម កុមារទាំង ២ ដេកខាងក្រៅ ខណៈនោះ ពួកសេនាមាត្យទាំងឡាយបានយកគ្រឿងបញ្ចរាជកកុធភណ្ឌដាក់លើបុស្សរថ ហើយលែងទៅ ។ អត្ថពិស្ដារក្នុងការផ្សងបុស្សរថនោះ មានពិស្ដារក្នុងមហាជនកជាតក ។ បុស្សរថទៅដល់ព្រះរាជឧទ្យាន ក៏បែរត្រឡប់ ហើយឈប់ ហាក់បីដូចត្រៀមរង់ចាំអ្នកណាម្នាក់ឲ្យឡើង ។ បុរោហិតគិតថា សត្វមានបុណ្យ ពិតជានៅក្នុងព្រះរាជឧទ្យាន ទើបចូលព្រះរាជឧទ្យាន ឃើញកុមារ ក៏បើកសំពត់ត្រង់ជើងឡើងពិចារណាក្រឡាបាតជើងទាំង ២ ក៏ដឹងច្បាស់ថា រាជសម្បត្តិក្នុងនគរពារាណសី

នឹងគង់វង្សតទៅ កុមារនេះ សមគួរជារាជាធិរាជក្នុងជម្ពូទ្វីប ទើបឲ្យប្រគំតូរ្យតន្ត្រីឡើង ។

និគ្រោធកុមារភ្ញាក់ឡើង បើកសំពត់គ្របមុខចេញ ឃើញមនុស្សប្រជុំគ្នាជាច្រើន ក៏ដេកវិញ ទុកឲ្យពេលវេលាកន្លងទៅមួយស្របក់ ហើយក្រោកឡើង អង្គុយពត់ក្អែនលើផ្ទាំងថ្ម លំដាប់នោះ បុរោហិតលុតជង្គង់ចុះ ពោលនឹងនិគ្រោធកុមារនោះថា បពិត្រព្រះសម្មតិទេព រាជសម្បត្តិធ្លាក់ដល់ទ្រង់ហើយ និគ្រោធកុមារពោលថា សាធុ ក៏រៀបចំពិធីឲ្យគង់លើគំនររតនៈ ក្នុងទីនោះ រួចអភិសេកតាមរាជបវេណី ។ និគ្រោធកុមារនោះគ្រងរាជសម្បត្តិហើយ ព្រះរាជទានតំណែងសេនាបតីដល់សាខកុមារ ហើយយាងចូលនគរដោយសក្ការៈធំ សូម្បីបោតិកៈក៏តាមព្រះរាជាទៅដែរ ។ ចាប់តាំងពីនោះមកមហាសត្វបានគ្រងរាជសម្បត្តិក្នុងនគរពារាណសីដោយធម៌ ថ្ងៃមួយ ទ្រង់រឭកដល់មាតាបិតា ទើបពោលនឹងសាខៈថា នែសម្លាញ់ យើងមិនអាចនៅដោយប្រាសចាកមាតាបិតាបានទេ លោក មួយអន្ទើដោយបរិវារធំ ចូរទៅអញ្ជើញមាតាបិតារបស់យើងមក សាខសេនាបតីទូលទាស់ថា ទូលបង្គំមិនមានកិច្ចដែលត្រូវទៅក្នុងទីនោះ ។ បន្ទាប់អំពីនោះ ព្រះរាជាត្រាស់ប្រើបោតិកៈឲ្យទៅអញ្ជើញ ។ បោតិកកុមារទទួលព្រះរាជបញ្ជាថា សាធុ ហើយក៏ទៅក្នុងទីនោះទៅរកព្រះជនក និងព្រះជននីនៃព្រះបាទនិគ្រោធរាជ ប្រាប់ថា និគ្រោធកុមារបុត្ររបស់អ្នកបានរាជសម្បត្តិហើយ មក យើងនឹងទៅក្នុងទីនោះ ព្រះជនកព្រះជននីឃាត់ថា កុំឲ្យយើងទៅឡើយ សម្បត្តិរបស់យើងក៏មានហើយ ។

បោតិកកុមារក៏ប្រាប់ដល់មាតាបិតារបស់សាខសេនាបតី ជនទាំង ២ ក៏ព្រម ទៅ ទើបទៅរកមាតាបិតារបស់ខ្លួន អង្វរឲ្យទៅជាមួយ ជនទាំង ២ ក៏ឃាត់ថា នែកូន អញសូមរស់នៅដោយការដេរប៉ាក់នេះ កុំចាំបាច់ទៅឡើយ ។ បោតិកកុមារ កាលមិនបានមាតាបិតាទៅហើយ ក៏មកកាន់នគរពារាណសី គិតថា នឹងទៅសម្រាកត្រង់ផ្ទះសេនាបតី ឲ្យបាត់នឿយហត់ សឹមចូលគាល់ព្រះបាទនិគ្រោធរាជឯក្រោយ ទើបទៅកាន់ផ្ទះសេនាបតី ពោលនឹងឆ្មាំទ្វារថា ចូរអ្នកទៅប្រាប់សេនាបតីថា បោតិកៈជាសម្លាញ់លោកមករក អ្នកយាមទ្វារបានធ្វើតាមនោះ ។

ឯសាខសេនាបតី ចងពៀរនឹងបោតិកកុមារថា បោតិកៈនេះមិនឲ្យរាជសម្បត្តិដល់អញ បែរជាឲ្យនិគ្រោធកុមារដែលជាសម្លាញ់ ។ គ្រាន់តែសាខសេនាបតីបានស្តាប់ពាក្យនោះប៉ុណ្ណោះ ក៏ក្រោធខឹងដេរថា អ្នកណាជាសម្លាញ់របស់វានោះ វាជាមនុស្សឆ្កួត ជាកូនទាសី ចូរចាប់វា ហើយឲ្យអ្នកបម្រើយកដៃ និងជើង វាយទាត់ ចាប់កអូសចេញទៅ ។ បោតកកុមារគិតថា ឱ ! សាខៈ ឯងបានតំណែងសេនាបតីក៏ព្រោះអញ នៅមិនដឹងគុណ ជាអ្នកទ្រុស្តមិត្ត ឲ្យអ្នកបម្រើវាយបណ្តេញអញ តែនិគ្រោធជាបណ្ឌិត ជាអ្នកដឹងគុណ ជាសប្បុរស អញនឹងទៅគាល់ទ្រង់ ហើយទៅកាន់ទ្វារព្រះរាជវាំង ឲ្យឆ្មាំទ្វារទៅក្រាបទូលដល់ព្រះរាជាថា សម្លាញ់របស់ទ្រង់ឈ្មោះបោតិកៈនៅត្រង់ទ្វារ ព្រះរាជាត្រាស់ឲ្យចូលមក គ្រាន់តែទតឃើញបោតិកៈមក ក៏ក្រោកអំពីព្រះរាជអាសនៈ ចេញទទួល ទ្រង់ធ្វើបដិសណ្ឋារៈ ត្រាស់ឲ្យជាងកោរកាត់ស្អិតស្អាង

សក់ និងពុកមាត់ ឲ្យប្រដាប់គ្រឿងសព្វាភរណៈ និងឲ្យបរិភោគភោជន ប្រណីត មានរសដ៏ប្រសើរ ហើយត្រាស់សួរដល់ដំណើងព្រះជនកព្រះជននី ទ្រង់ជ្រាបថា មិនព្រមមក ។

សាខសេនាបតីគិតថា បោតិកៈទម្លាយអញក្នុងសម្នាក់ព្រះរាជា តែកាល អញទៅគាល់ គេពិតជាមិនអាចពោលទោសណាមួយ គិតដូច្នេះហើយ ទើប ចូលគាល់ក្នុងព្រះរាជសម្នាក់នោះឯង ។ បោតិកៈបានក្រាបទូលព្រះរាជាចំពោះ មុខសាខសេនាបតីនោះថា បពិត្រព្រះសម្មតិទេព ទូលបង្គំហត់នឿយមកតាម ផ្លូវ គិតថា ទៅផ្ទះលោកសាខសេនាបតី សម្រាកហើយ ទើបចូលគាល់ តែលោកសាខសេនាបតីពោលនឹងទូលបង្គំថា មិនស្គាល់ទូលបង្គំ ឲ្យមនុស្ស វាយចាប់កអូសចេញទៅ សូមទ្រង់ជ្រាបដូច្នេះចុះ ហើយពោល ៣ គាថាថា

បពិត្រនិគ្រោធ សាខសេនាបតីបាននិយាយថា អញមិនស្គាល់ អ្នកនុ៎ះទេ អ្នកនេះជាអ្វី ឬជាអ្នកបម្រើរបស់អ្នកណា ( ដូច្នេះ ) យ៉ាងណា តើព្រះអង្គ ទ្រង់យល់យ៉ាងនោះដែរឬ ។

កាលនោះ ពួកបុរសអ្នកធ្វើតាមពាក្យសាខបុរស ក៏ទះតប់មាត់ បណ្តេញខ្ញុំព្រះអង្គ ដោយការអូស-កចេញ ។

បពិត្រព្រះអង្គជាធំជាងជន អំពើមិនប្រសើរប្រាកដដូច្នេះ សាខៈ ជាសម្លាញ់របស់ព្រះអង្គ ជាមនុស្សមានគំនិតអាក្រក់ ជាអកតញ្ញូ ទ្រុស្តមិត្តបានធ្វើហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កិន្តិ មញ្ញសិ** សេចក្តីថា សាខសេនាបតី

បានពោលនឹងទូលបង្គំយ៉ាងណា ទ្រង់យល់ព្រះហឫទ័យយ៉ាងនោះដែរឬទេ អធិប្បាយថា សាខសេនាបតីពោលយ៉ាងនេះនឹងទូលបង្គំ ទ្រង់ជឿដែរឬទេ ។ បទថា **គលវិនីតេន** បានដល់ ចាប់ត្រង់ក ។ បទថា **ឧត្តិណា** បានដល់ ដែលទ្រុស្តមិត្ត ។ ព្រះបាទនិគ្រោធរាជទ្រង់បានស្តាប់ដូច្នោះ ទើបត្រាស់ ៤ គាថាថា

ម្នាលសម្លាញ់ អ្នកប្រាប់នូវការទង់ទាញណា ដែលសាខៈធ្វើហើយដល់ខ្ញុំ ខ្ញុំមិនដឹងនូវដំណើរនុ៎ះទេ ទាំងអ្នកណាមួយ ក៏មិនបានប្រាប់ដល់ខ្ញុំដែរ ។

អ្នកបានធ្វើនូវការចិញ្ចឹមជីវិតងាយ ដល់សម្លាញ់ទាំង ២ នាក់ គឺខ្ញុំ និងសាខៈ ជាអ្នកឲ្យឥស្សរិយយស គឺភាពជាធំក្នុងមនុស្ស ដល់យើង យើងបានសេចក្តីសម្រេចក៏ព្រោះអ្នក សេចក្តីសង្ស័យក្នុងហេតុនុ៎ះ មិនមានដល់ខ្ញុំទេ ។

ពូជ ( ដែលដាក់ ) ក្នុងភ្លើង រមែងឆេះ មិនដុះ យ៉ាងណាមិញ ឧបការគុណដែលបុគ្គលធ្វើហើយ ក្នុងអសប្បុរស រមែងវិនាស មិនលូតលាស់ យ៉ាងនោះដែរ ។

ឧបការគុណដែលបុគ្គលធ្វើហើយ ក្នុងបុរសជាកតញ្ញូ មានសីលធម៌ មានសេចក្តីប្រព្រឹត្តប្រសើរនោះ រមែងមិនវិនាសទេ ដូចពូជ ( ដែលព្រោះ ) ក្នុងស្រែល្អ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សំសតិ** បានដល់ ប្រាប់ ។ បទថា **កឡូធំ**

**កតំ** បានដល់ ធ្វើនូវការអូស ពោល គឺការអូសមកអូសទៅ ដោយវាយ និងទះ ។ បទថា **សក្ខិនំ សាជីវន្តរោ** សេចក្ដីថា នែបោតិកៈសម្លាញ់ អ្នកជាសម្លាញ់ឲ្យនូវជីវិតរស់នៅជាសុខ គឺជាអ្នកឲ្យនូវការកើតឡើងដល់មិត្រ ។ បទថា **មម សាខស្ស ចូភយំ** បានដល់ ដល់យើង និងសាខសេនាបតី ដែលជាសម្លាញ់ទាំង ២ ។ បទថា **ត្វំ ឆោសិស្សរិយំ** សេចក្ដីថា ម្យ៉ាងទៀត អ្នកជាអ្នកឲ្យនូវឥស្សរិយយសដល់ពួកយើង គឺពួកយើងបានឥស្សរិយយសនេះ ព្រោះអ្នក ។ បទថា **មហាគ្គតំ** បានដល់ ភាពជាអ្នកមានតំណែងធំ ។ កាលព្រះបាទនិគ្រោធរាជកំពុងត្រាស់យ៉ាងនេះ សាខសេនាបតីបានឈរក្នុងទីនោះឯង ។ លំដាប់នោះ ព្រះរាជាក៏ត្រាស់សួរថា នែសាខៈអ្នកចាំបោតិកៈនេះបានឬទេ សាខៈសេនាបតីបាននៅស្ងៀម កាលដាក់ព្រះរាជអាជ្ញាដល់សេនាបតី បានត្រាស់គាថាទី ៨ ថា

រាជបុរសទាំងឡាយ ចូរយកលំពែងសម្លាប់នូវសាខៈនេះ ជាមនុស្សលាមក រេចិញរេចុញ មានគំនិតជាអសប្បុរសចុះ យើងមិនប្រាថ្នាឲ្យវារស់នៅទេ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ជម្មំ** បានដល់ បុគ្គលលាមក ។ បទថា **នេកតិកំ** បានដល់ រេចិញរេចុញ ។

បោតិកៈបានស្ដាប់ដូច្នោះ គិតថា មនុស្សពាលនេះ កុំបីវិនាសព្រោះអញឡើយ ទើបពោលគាថាទី ៩ ថា

បពិត្រមហារាជ សូមព្រះអង្គអត់ទោសចំពោះបុរសនេះ ( ព្រោះ
ថា ) ជីវិត ( របស់សត្វដែលស្លាប់ហើយ ) មិនអាចនាំត្រឡប់
មកវិញបានទេ បពិត្រព្រះសម្មតិទេព សូមព្រះអង្គអត់ទោស
ដល់អសប្បុរស ខ្ញុំព្រះអង្គមិនប្រាថ្នាការសម្លាប់បុរសនេះទេ
ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ខមតស្ស** កាត់បទជា **ខមតំ អស្ស** សេចក្តីថា សូមទ្រង់អត់ទោសដល់អសប្បុរសនេះចុះ ។ បទថា **ឧប្បជិអានយា** បានដល់ ជីវិតរបស់អ្នកដែលស្លាប់ ដែលបុគ្គលណាម្នាក់ មិនអាចនាំត្រឡប់មកបាន ។

ព្រះរាជាបានស្តាប់ពាក្យរបស់បោតិកៈហើយ ទ្រង់ក៏អត់ទោសឲ្យសាខៈ ទ្រង់បំណងនឹងព្រះរាជទានតំណែងសេនាបតីដល់បោតិកៈ តែបោតិកៈមិនត្រូវការ ។ លំដាប់នោះ ទើបទ្រង់ព្រះរាជទានតំណែងនាយឃ្លាំង ឲ្យមាននាទីត្រួតត្រារាជការទាំងអស់ បានឮថា ឋានន្តរបែបនោះ ក្នុងកាលមុនមិនធ្លាប់មាន ទើបតែមានឡើងតាំងអំពីនោះមក ។ សម័យក្រោយមក នាយឃ្លាំងបោតិកៈ ចម្រើនដោយបុត្រធីតា កាលនឹងទូន្មានបុត្រធីតា ទើបពោលគាថាចុងក្រោយថា

បុគ្គលគប្បីសេពគប់ នូវស្តេចនិគ្រោធប៉ុណ្ណោះ កុំនៅជាមួយ
សាខៈឡើយ សេចក្តីស្លាប់ក្នុងសម្នាក់ស្តេចនិគ្រោធ ប្រសើរ
ជាង ឯការរស់នៅក្នុងសម្នាក់សាខៈ ពុំប្រសើរឡើយ ដូច្នេះ ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកសម្តែងហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សូម្បីក្នុងកាលមុន ទេវទត្តក៏ជាអកតញ្ញូយ៉ាងនេះឯង ហើយទ្រង់ប្រជុំជាតកថា សាខសេនាបតីក្នុងកាលនោះ បានមកជាទេវទត្តក្នុងកាលឥឡូវនេះ បោតិកៈនាយឃ្មាំងក្នុងកាលនោះ បានមកជាអានន្ទ ចំណែកនិគ្រោធរាជក្នុងកាលនោះ គឺតថាគតនេះឯង ។ល។

## អដ្ឋកថា និគ្រោធជាតក ចប់

# សុត្តន្តបិដក

## តក្កលជាតក

[ ៦៩៨ ] ( កុមារពោធិសត្វពោលថា ) បពិត្របិតា ជំឡូងឈាមមាន់មិនមាន ជំឡូងជ្វាមិនមាន ជំឡូងដៃខ្លាមិនមាន ជំឡូងត្នោតមិនមាន ( ក្នុងទីនេះទេ ) បិតាមានប្រយោជន៍អ្វីទើបមកជីករណ្តៅ ក្នុងទីកណ្តាលស្មសាន ក្នុងព្រៃតែម្នាក់ឯង ។

[ ៦៩៩ ] ( បិតាពោលថា ) ម្នាលកូន ជីតារបស់អ្នកមានកម្លាំងថមថយណាស់ហើយ ត្រូវព្យាធិទុក្ខច្រើនយ៉ាងប៉ះពាល់ ថ្ងៃនេះ អញនឹងកប់គាត់ចោលក្នុងរណ្តៅ ព្រោះមិនចង់ឲ្យគាត់រស់នៅទេ ។

[ ៧០០ ] ( កុមារ ... ) សេចក្តីត្រិះរិះនោះ ជាអំពើដ៏លាមកដែលបិតាបានធ្វើហើយ បិតាធ្វើនូវកម្មមិនជាប្រយោជន៍ក្រៃពេក ជាអំពើអាក្រក់ បពិត្របិតា អ្នកកាលបើជរាចូលគ្របសង្កត់ រមែងបានទទួលនូវកម្ម ប្រាកដដូច្នេះអំពីខ្ញុំវិញ សូម្បីខ្ញុំ កាលប្រព្រឹត្តតាមវត្តរបស់ត្រកូលនោះ នឹងកប់បិតាក្នុងរណ្តៅវិញ ។

[ ៧០១ ] ( បិតា ... ) ម្នាលកុមារ អ្នកគ្របសង្កត់ និយាយខ្លាំងខ្លួបអញដោយសម្តីអាក្រក់ នៃកូន អ្នកជាកូនកើតអំពីទ្រូងនៃអញ អនុគ្រោះដោយអំពើ មិនមែនជាប្រយោជន៍ដល់អញ ។

[ ៧០២ ] ( កុមារ ... ) បពិត្របិតា ខ្ញុំមិនមែនអនុគ្រោះលោក ដោយឥតប្រយោជន៍ទេ បពិត្របិតា ពិតណាស់ ខ្ញុំអនុគ្រោះដោយប្រយោជន៍ ដល់លោកដោយពិត ប៉ុន្តែខ្ញុំមិនគួរដើម្បីនឹងហាមលោក ដែលកំពុងធ្វើកម្មអាក្រក់ ដោយហេតុនោះទេ ។

[ ៧០៣ ] បពិត្រសវិដ្ឋៈ បុគ្គលណាមានធម៌ដ៏លាមក បៀត-បៀននូវមាតាបិតា ដែលជាអ្នកមិនប្រទូស្ត បុគ្គលនោះ លុះបែកធ្លាយរាងកាយទៅក្នុងភពខាងមុខ រមែងកើតក្នុងនរកឥតសង្ស័យ ។

[ ៧០៤ ] បពិត្រសវិដ្ឋៈ បុគ្គលណាទំនុកបម្រុងមាតាបិតាដោយបាយ និងទឹក បុគ្គលនោះ លុះបែកធ្លាយរាងកាយ ទៅក្នុងភពខាងមុខ រមែងកើតក្នុងសុគតិឥតសង្ស័យ ។

[ ៧០៥ ] ( បិតា ... ) ម្នាលកូន អ្នកមិនមែនអនុគ្រោះដោយឥតប្រយោជន៍ដល់យើងទេ ម្នាលកូន អ្នកអនុគ្រោះដោយប្រយោជន៍ដល់យើងពិត ចំណែកខាងយើង ត្រូវមាតារបស់អ្នកប្រើ ទើបមកធ្វើនូវកម្មអាក្រក់ប្រាកដដូច្នេះ ។

[ ៧០៦ ] ( កុមារ ... ) ស្ត្រីណាជាភរិយារបស់បិតា មានសភាពមិនប្រសើរ ស្ត្រីនោះ ជាមាតាបង្កើតរបស់ខ្លួនខ្ញុំ បិតា

គប្បីបណ្តេញមាតានោះ ចេញចាកផ្ទះរបស់ខ្លួន ព្រោះថា មាតានោះ គង់នឹងនាំទុក្ខឯទៀត មកឲ្យបិតាមិនខាន ។

[ ៧០៧ ] ស្ត្រីណាជាភរិយារបស់បិតា មានសភាពមិនប្រសើរ ស្ត្រីនោះ ជាមាតាបង្កើតរបស់ខ្លួនខ្ញុំ មាតាមានធម៌ដ៏លាមកនោះ បានទូន្មានខ្លួន ចុះអំណាចដូចជាមេដំរី ចូរត្រឡប់មក ( កាន់ផ្ទះ ) វិញ ។

### តក្កលជាតកទី ៨ ចប់

# អដ្ឋកថា

## តក្កលជាតក

[ ៦៩៨-៧០៧ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធបុរសចិញ្ចឹមបិតាម្នាក់ ទើបត្រាស់រឿងនេះ មានពាក្យផ្តើមថា **ឆ តក្កលា សន្តិ** ដូច្នេះជាដើម ។

បានឮថា បុរសនោះជាកូនពៅក្នុងត្រកូលក្រីក្រម្នាក់ កាលមាតាស្លាប់ហើយ គាត់ក្រោកឡើងអំពីព្រលឹមធ្វើកិច្ចបដិបត្តិបិតា មានឲ្យឈើស្ទន់ និងទឹកខ្ពុរមាត់ជាដើម រៀបចំអាហារ មានបាយ បបរ និងកត្តជាដើម ដោយសមគួរដល់ទ្រព្យដែលខ្លួនបានមក ដោយការស៊ីឈ្នួលក្នុងស្រែ ទំនុកបម្រុងបិតា ។ កាលនោះ បិតាពោលនឹងបុរសនោះថា កូនសម្លាញ់ ឯងតែម្នាក់ ធ្វើការខាងក្នុងផង ខាងក្រៅផង ឪពុកនឹងនាំកុលទារិកាមកឲ្យឯងម្នាក់ នាងនឹងបានជួយធ្វើការងារក្នុងផ្ទះ ។ បុរសនោះពោលថា បពិត្រលោកឪពុក ឈ្មោះថា ស្ត្រី មកផ្ទះហើយ មិនធ្វើសេចក្តីសុខដល់ខ្ញុំ និងឪពុកបានឡើយ សូមលោកឪពុកកុំគិតដូច្នោះឡើយ ខ្ញុំនឹងចិញ្ចឹមលោកឪពុកត្រាដល់អស់ជីវិត លុះឪពុកស្លាប់ទៅហើយ ខ្ញុំនឹងបួស ។ លំដាប់នោះ បិតាបាននាំទារិកាម្នាក់មកទាំងដែលបុរសនោះមិនប្រាថ្នា ។ នាងមានឧបការៈ និងគោរពកោតក្រែងចំពោះឪពុកក្មេក ឯប្តីក៏ត្រេកអរចំពោះនាងថា ជាអ្នកមានឧបការៈដល់បិតានៃខ្លួន ទើបនាំរបស់ដែលគាប់ចិត្ត ដែលបានមក ប្រគល់ឲ្យនាង នាងក៏បាននាំបង្អែនចូលទៅឲ្យបិតាទាំងអស់ ។

សម័យតមក នាងគិតថា ប្តីរបស់អញ បានអ្វីមក ក៏មិនបានឲ្យដល់បិតា ឲ្យដល់អញម្នាក់ប៉ុណ្ណោះ គាត់គង់មិនស្រឡាញ់បិតានេះពិត អញនឹងប្រើឧបាយណាមួយ ធ្វើតាចាស់នេះឲ្យជាទីស្អប់ខ្ពើមរបស់ប្តីអញ ហើយឲ្យបណ្តេញចេញពីផ្ទះ ។ តាំងអំពីនោះមក នាងក៏បានធ្វើហេតុ ដែលល្មមឲ្យឪពុកក្មេកក្រោធ ដូចជា កាលនឹងឲ្យទឹក ក៏ឲ្យទឹកត្រជាក់ពេកខ្លះ ក្តៅពេកខ្លះ ឲ្យអាហារប្រៃពេកខ្លះ សាបពេកខ្លះ ឲ្យកត្តធៅខ្លះ ធ្លិនខ្លះ ជ្រាយខ្លះ ដូច្នេះ កាលឪពុកក្មេកក្រោធ នាងក៏ពោលពាក្យគ្រោតគ្រាតថា អ្នកណានឹងអាចបដិបត្តិតាកញ្ចាស់នេះបាន ។ ហើយបង្ហូរជម្លោះ ដោយក្លែងខាកស្តោះទឹកមាត់ជាដើមក្នុងទីទូទៅ ហើយប្រាប់ប្តីថា សូមអ្នកមើលការធ្វើរបស់បិតា កាលខ្ញុំពោលថា សូមលោកឪពុកកុំធ្វើយ៉ាងនេះ គាត់ក៏ខឹង លោកឪពុកនៅក្នុងទីនេះ ឬឲ្យខ្ញុំនៅ បុរសនោះបានពោលថា នាងជាទីស្រឡាញ់ នាងនៅក្មេង នាងនៅទីណាក៏បាន ឪពុករបស់ខ្ញុំចាស់ហើយ បើនាងមិនអាចអត់ទ្រាំបានទេ អញ្ជើញចេញពីផ្ទះនេះទៅ ។ ស្រីនោះមានការខ្លាច ក្រាបចុះទៀបបាតជើងឪពុកក្មេក សូមខមាទោសឪពុកក្មេកថា តាំងអំពីនេះទៅ ខ្ញុំលែងធ្វើយ៉ាងនេះទៀតហើយ នាងក៏ផ្តើមបដិបត្តិតាមប្រក្រតីដូចមុន ។

លំដាប់នោះ ឧបាសក តាំងអំពីថ្ងៃដែលភរិយាបៀតបៀនបិតាឲ្យក្តៅក្រហាយ ក៏ខានបានទៅស្តាប់ធម៌ ក្នុងសម្នាក់ព្រះសាស្តា លុះភរិយាតាំងនៅក្នុងប្រក្រតីហើយ ទើបបានទៅ ។ ពេលនោះ ព្រះសាស្តាត្រាស់សួរថា ម្នាលឧបាសក ហេតុអ្វី ទើបអ្នកខានមកអស់ ៧ ថ្ងៃ គាត់បានក្រាបទូល

ហេតុការណ៍ឲ្យទ្រង់ជ្រាប ព្រះសាស្តាត្រាស់ថា ក្នុងកាលនេះប៉ុណ្ណោះ ដែលអ្នកមិនជឿពាក្យភរិយា មិនបណ្តេញឪពុកចេញអំពីផ្ទះ តែក្នុងកាលមុន អ្នកជឿពាក្យរបស់ភរិយា នាំបិតាទៅកាន់ព្រៃខ្មោច ជីករណ្តៅកប់បិតា តថាគតកើតជាបុត្រ មានអាយុ ៧ ឆ្នាំ សម្តែងគុណរបស់មាតាបិតា ហាមនូវការសម្លាប់ជីតាបាន គ្រានោះ អ្នកស្តាប់ពាក្យតថាគត បដិបត្តិបិតារហូតអស់ជីវិត ហើយទៅកើតក្នុងស្ថានសួគ៌ ឱវាទដែលតថាគតឲ្យនោះ អ្នកទៅកើតភពជាតិ ក៏មិនភ្លេចភ្លាំង ដោយហេតុនេះ ទើបអ្នកមិនជឿពាក្យរបស់ភរិយា មិនបណ្តេញបិតាចេញក្នុងកាលឥឡូវនេះ ឧបាសកនោះទូលអារាធនាឲ្យត្រាស់រឿង ទើបទ្រង់នាំអតីតនិទានមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិក្នុងនគរពារាណសី ក្នុងដែនកាសីនោះ មានត្រកូលមួយ ត្រកូលនោះមានកូនប្រុសម្នាក់ ឈ្មោះ **សវិដ្ឋកៈ** គាត់ជាអ្នកទំនុកមាតាបិតា លុះមាតាអនិច្ចកម្មទៅហើយ ក៏ទំនុកបម្រុងបិតា រឿងទាំងអស់ដូចគ្នានឹងរឿងបច្ចុប្បន្ននេះឯង តែរឿងដែលប្លែកនឹងពោលដូចតទៅ

កាលនោះ ស្រីនោះពោលថា សូមលោកមើលការធ្វើរបស់បិតាចុះ កាលខ្ញុំពោលថា កុំធ្វើយ៉ាងនេះ កុំធ្វើយ៉ាងនេះ គាត់ក៏ក្រោធ ។ ហើយពោលថា នែអ្នក បិតារបស់អ្នកកាចអាក្រក់អាក្រី បន្តជម្លោះរឿយៗ គាត់ចាស់ទ្រុឌទ្រោម ព្យាធិបៀតបៀន មិនយូរមិនឆាប់ក៏នឹងស្លាប់ ខ្ញុំមិនអាចនៅរួមផ្ទះជាមួយគាត់បានទេ ក្នុង ២-៣ ថ្ងៃនេះ គាត់នឹងស្លាប់ពិត សូមអ្នកនាំគាត់ទៅ

កាន់ព្រៃខ្មោច ជីករណ្តៅហើយ យកគាត់ដាក់ចូលក្នុងរណ្តៅ យកចបវាយក្បាលឲ្យស្លាប់ កាយដីកប់ខាងលើហើយ សឹមមក ។ សវិដ្ឋកៈត្រូវកិរិយារំអុករឿយៗ ទើបពោលថា នែនាង ឈ្មោះថា ការសម្លាប់មនុស្សជាកម្មធ្ងន់ អញនឹងសម្លាប់បិតាបានដូចម្តេចកើត ។ នាងពោលថា ខ្ញុំប្រាប់ឧបាយដល់អ្នក សវិដ្ឋកៈពោលថា ចូរនាងប្រាប់មកចុះ ទើបនាងប្រាប់ថា នែអ្នក ចូរអ្នកទៅកាន់ទីដែលបិតាដេកក្នុងពេលងងឹត ធ្វើសំឡេងឲ្យមនុស្សទាំងអស់បានឮពោលថា បពិត្រលោកឪពុក កូនបំណុលរបស់ពុកមាននៅក្នុងស្រុកនោះ កាលខ្ញុំទៅតែឯង គេនឹងមិនឲ្យ កាលពុកស្លាប់ទៅហើយ ប្រាក់នឹងសាបសូន្យ ស្អែកនេះ យើងនឹងអង្គុយលើយាន ទៅជាមួយគ្នាអំពីព្រឹកចុះ ដូច្នេះហើយ ក្រោកឡើងតាមពេលដែលបិតាប្រាប់ ទឹមយាន ឲ្យបិតាអង្គុយលើយានហើយ នាំទៅកាន់ព្រៃខ្មោច ជីកនូវរណ្តៅហើយ ធ្វើជាសំឡេងចោរប្លន់សម្លាប់គាត់ហើយ បោះក្នុងរណ្តៅ វាយក្បាល ហើយងូតទឹកមកផ្ទះ សវិដ្ឋកៈគិតថា ឧបាយនេះល្អ ទើបទទួលពាក្យរបស់នាង ហើយត្រៀមយានគិតនឹងទៅ ។ សវិដ្ឋកៈមានកូនប្រុសម្នាក់ មានអាយុ ៧ ឆ្នាំ ជាក្មេងឈ្លាសវៃបានស្តាប់ពាក្យរបស់ម្តាយ គិតថា ម្តាយរបស់អញមានធម៌លាមក ញុះញង់បិតាអញឲ្យធ្វើបិតុឃាត អញនឹងមិនឲ្យបិតាធ្វើបិតុឃាត ហើយក៏លបៗ ចូលទៅដេកជាមួយជីតា កាលបានវេលាដែលបិតាប្រាប់ សវិដ្ឋកៈទឹមយានហើយពោលថា មកចុះលោកឪពុក យើងទៅទារបំណុលជាមួយគ្នា ហើយឲ្យបិតាអង្គុយលើយាន កុមារបានឡើងយានមុនហើយ សវិដ្ឋកៈមិនអាចហាមកូន

បាន ទើបនាំទៅកាន់ព្រៃខ្មោចដែរ ឲ្យបិតា និងកុមារស្នាក់នៅក្នុងទីមួយកន្លែង ជាមួយយាន ខ្លួនឯងកាន់ចប និងបង្គី ផ្ដើមជីករណ្ដៅ ៤ ជ្រុង ក្នុងទីកំបាំងមួយកន្លែង សូម្បីកុមារក៏ចុះទៅកាន់សម្នាក់បិតា ធ្វើជាមិនដឹង ផ្ដើមពោលគាថាទី ១ ថា

បពិត្របិតា ដំឡូងឈាមមាន់មិនមាន ដំឡូងជ្វាមិនមាន ដំឡូងដៃខ្លាមិនមាន ដំឡូងត្នោតមិនមាន ( ក្នុងទីនេះទេ ) បិតា មានប្រយោជន៍អ្វី ទើបមកជីករណ្ដៅ ក្នុងទីកណ្ដាលស្មសាន ក្នុងព្រៃតែម្នាក់ឯង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ន តក្កលា សន្តិ** បានដល់ ដំឡូងឈាមមាន់ក៏មិនមាន ។ ដំឡូងជ្វា ឈ្មោះថា **អាលុពានិ** ដំឡូងដៃខ្លា ឈ្មោះថា **វិលាលិយោ** ដំឡូងត្នោត ឈ្មោះថា **កលម្ពានិ**។

លំដាប់នោះ បិតាបានពោលគាថាទី ២ ឆ្លើយនឹងបុត្រថា

ម្នាលកូន ជីតារបស់អ្នកមានកម្លាំងថមថយណាស់ហើយ ត្រូវព្យាធិទុក្ខច្រើនយ៉ាងប៉ះពាល់ ថ្ងៃនេះ អញនឹងកប់គាត់ចោលក្នុងរណ្ដៅ ព្រោះមិនចង់ឲ្យគាត់រស់នៅទេ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អនេកព្យាធីហិ** បានដល់ ត្រូវសេចក្ដីទុក្ខដែលកើតអំពីព្យាធិច្រើនយ៉ាងបៀតបៀនហើយ ។ បទថា **ន ហិស្ស តំ** សេចក្ដីថា ព្រោះថា ឪពុកមិនចង់ឲ្យជីតារបស់ឯងនោះ មានជីវិតរស់នៅលំបាកបែបនោះ ឪពុកយល់ថា ការស្លាប់របស់ជីតានោះប្រសើរជាងមានជីវិត រស់នៅ

បែបនេះ ទើបកប់គាត់ក្នុងរណ្ដៅ ។

កុមារបានស្ដាប់ដូច្នោះ ទើបពោលកន្ទះគាថាថា

សេចក្ដីត្រិះរិះនោះ ជាអំពើដ៏លាមក ដែលបិតាបានធ្វើហើយ

បិតាធ្វើនូវកម្មមិនជាប្រយោជន៍ក្រៃពេក ជាអំពើអាក្រក់ដូច្នេះ ។

គប្បីជ្រាបភាពនៃពាក្យដែលជាគាថានោះថា លោកឪពុកគិតថា អញនឹងដោះបិតាឲ្យផុតចាកទុក្ខ ទើបចង់ដោយមរណទុក្ខ ឈ្មោះថា ធ្វើនូវកម្មគ្រោតគ្រាត ដែលកន្ទងបង់ប្រយោជន៍ ព្រោះមានការត្រិះរិះដ៏លាមកនេះ និងព្រោះឈានកន្ទងប្រយោជន៍ ដោយអំណាចនៃការត្រិះរិះនោះ ។

កាលពោលយ៉ាងនេះហើយ ក៏ទាញយកចបអំពីដៃបិតា ធ្វើអាកប្ប-កិរិយា ជីករណ្ដៅមួយក្នុងទីក្បែរគ្នា ។ លំដាប់នោះ បិតាសួរកុមារថា នែកូនឯងជីករណ្ដៅធ្វើអ្វី កាលកុមារឆ្លើយនឹងបិតា បានពោលគាថាទី ៣ ថា

បពិត្របិតា អ្នកកាលបើជរាចូលគ្របសង្កត់ រមែងបានទទួលនូវកម្ម ប្រាកដដូច្នេះអំពីខ្ញុំវិញ សូម្បីខ្ញុំកាលប្រព្រឹត្តតាមវត្តរបស់ត្រកូលនោះ នឹងកប់បិតាក្នុងរណ្ដៅវិញ ដូច្នេះ ។

គប្បីជ្រាបអត្ថនៃពាក្យដែលជាគាថានោះថា បពិត្រលោកឪពុក សូម្បីខ្ញុំក៏នឹងកប់លោកឪពុក ក្នុងរណ្ដៅមួយទៀត ក្នុងកាលឪពុកចាស់ អធិប្បាយថា ដោយហេតុនេះឯង កាលលោកឪពុកចាស់ ក៏នឹងបានទទួលកម្មបែបនេះក្នុងរណ្ដៅដែលជីកនេះអំពីកូនផងដែរ សូម្បីកូនក៏នឹងប្រព្រឹត្តតាមវត្តរបស់ត្រកូល គឺដែលលោកឪពុកឲ្យប្រព្រឹត្តទៅហើយ គឺកាលចម្រើនវ័យហើយ

រកស៊ីជាមួយភរិយា ក៏នឹងកប់លោកឪពុកក្នុងរណ្តៅដែរ ។

លំដាប់នោះ បិតាបានពោលគាថាទី ៤ ដល់កុមារថា

ម្នាលកុមារ អ្នកគ្របសង្កត់ និយាយខ្លាំងខ្លួនអញ ដោយសម្តី អាក្រក់ នៃកូន អ្នកជាកូនកើតអំពីទ្រូងនៃអញ អនុគ្រោះដោយ អំពើមិនមែនជាប្រយោជន៍ដល់អញ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បក្កុព្ភមានោ** បានដល់ សម្លុត ។ បទថា **អាសជ្ជ** បានដល់ ទ្រគោះបោះបោក ។

កាលបិតាពោលយ៉ាងនេះហើយ កុមារដែលជាបណ្ឌិត បានពោល ៣ គាថា គឺគាថាឆ្លើយមួយគាថា គាថាឧទាន ២ គាថា

បពិត្របិតា ខ្ញុំមិនមែនអនុគ្រោះលោក ដោយឥតប្រយោជន៍ទេ បពិត្របិតា ពិតណាស់ ខ្ញុំអនុគ្រោះ ដោយប្រយោជន៍ដល់ លោកដោយពិត ប៉ុន្តែ ខ្ញុំមិនគួរដើម្បីនឹងហាមលោក ដែលកំពុង ធ្វើកម្មអាក្រក់ ដោយហេតុនោះទេ ។

បពិត្រសវិដ្ឋ: បុគ្គលណាមានធម៌ដ៏លាមក បៀតបៀននូវមាតា បិតា ដែលជាអ្នកមិនប្រទូស្ត បុគ្គលនោះ លុះបែកធ្លាយរាង កាយ ទៅក្នុងភពខាងមុខ រមែងកើតក្នុងនរកឥតសង្ស័យ ។

បពិត្រសវិដ្ឋ: បុគ្គលណាទំនុកបម្រុងមាតាបិតា ដោយបាយ និង ទឹក បុគ្គលនោះ លុះបែកធ្លាយរាងកាយ ទៅក្នុងភពខាងមុខ រមែងកើតក្នុងសុគតិឥតសង្ស័យ ដូច្នេះ ។

កាលបិតាស្តាប់ធម្មកថារបស់កូនដូច្នោះហើយ ទើបពោលគាថាទី ៨ ថា

ម្នាលកូន អ្នកមិនមែនអនុគ្រោះ ដោយឥតប្រយោជន៍ដល់យើង ទេ ម្នាលកូន អ្នកអនុគ្រោះដោយប្រយោជន៍ដល់យើងពិត ចំណែកខាងយើង ត្រូវមាតារបស់អ្នកប្រើ ទើបមកធ្វើនូវកម្ម អាក្រក់ ប្រាកដដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អហាញ្ច តេ មាតរា** ស្មើគ្នានឹង **អហំបិ តេ មាតរា**ម្យ៉ាងទៀត បាលីក៏យ៉ាងនេះដូចគ្នា ។

កុមារបានស្តាប់ដូច្នោះហើយ ពោលថា បពិត្រលោកឪពុក ធម្មតាស្រ្តី កាលកើតទោសៈឡើង សង្កត់សង្កិនមិនបានឡើយ ទើបធ្វើអាក្រក់រឿយៗ គួរតែលោកឪពុកបណ្តេញម៉ែរបស់ខ្ញុំចេញ កុំឲ្យធ្វើអាក្រក់បែបនេះទៀត ហើយពោលគាថាទី ៩ ថា

ស្រ្តីណា ជាភរិយារបស់បិតា មានសភាពមិនប្រសើរ ស្រ្តីនោះ ជាមាតាបង្កើតរបស់ខ្លួនខ្ញុំ បិតាគប្បីបណ្តេញមាតានោះ ចេញ ចាកផ្ទះរបស់ខ្លួន ព្រោះថា មាតានោះ គង់នឹងនាំទុក្ខឯទៀត មក ឲ្យបិតាមិនខាន ដូច្នេះ ។

សវិដ្ឋកៈ បានស្តាប់ពាក្យកូនដែលជាបណ្ឌិតហើយ មានសោមនស្ស ពោលថា យើងទៅជាមួយគ្នាចុះ ហើយឡើងអង្គុយលើយានជាមួយកូន និង បិតាត្រឡប់ទៅផ្ទះ ឯស្រីអនាចារនោះ ក៏ត្រេកអរថា មនុស្សកាឡកិណីចេញ អំពីផ្ទះអញទៅហើយ ទើបយកអាចម៍គោស្រស់មកលាបផ្ទះ ចម្អិនបាយាស

ទន្ទឹងមើលផ្លូវប្ដីត្រឡប់មក កាលឃើញមកទាំង ៣ នាក់ ក៏ក្រោធថា នាំមនុស្សកាឡកិណីចេញទៅ ហេតុអ្វីនាំត្រឡប់មកវិញ ទើបផ្ដាសាថា មនុស្សអាក្រក់ អ្នកនាំមនុស្សកាឡកិណីទៅហើយ នាំមកវិញធ្វើអ្វី សវិដ្ឋកៈមិនបាននិយាយអ្វី ដោះយានហើយ ទើបពោលថា នែស្រីអនាចារ ហឯនិយាយអ្វី ហើយវាយស្រីនោះពេញកម្លាំងពោលថា តាំងអំពីនេះទៅ ហឯកុំចូលមកក្នុងផ្ទះនេះ ហើយចាប់ជើងអូសចេញទៅ កាលបណ្ដេញកិរិយាទៅហើយ ក៏ងូតទឹកឲ្យបិតា និងបុត្រ ខ្លួនឯង ក៏ងូត ហើយបរិភោគបាយាសទាំង ៣ នាក់ ស្រីចិត្តបាបនោះ ទៅកាន់ផ្ទះអ្នកដទៃ បាន ២-៣ ថ្ងៃ ។

ក្នុងកាលនោះ កុមារពោលនឹងបិតាថា បពិត្រលោកឪពុក អ្នកម៉ែគង់មិនដឹងខ្លួនដោយការដាក់ទោសមានប្រមាណប៉ុណ្ណេះ សូមលោកឪពុកធ្វើជាពោលថា អញនឹងទៅសូមកូនស្រីឪពុកជំក្នុងត្រកូលនោះ មកប្រណិប័តន៍លោកឪពុក ជីតា និងខ្ញុំ ដើម្បីឲ្យម៉ែខ្មាសអៀន ហើយកាន់យកគ្រឿងក្រអូប និងផ្កាជាដើម ឡើងយានត្រាច់ទៅតាមវាលស្រែ ហើយត្រឡប់មកពេលល្ងាច សវិដ្ឋកៈបានធ្វើតាមគ្រប់ប្រការ ស្ត្រីក្នុងត្រកូលដែលធ្លាប់ស្និទ្ធស្នាលប្រាប់ស្រីនោះថា បានឮថា ប្ដីរបស់ហឯ ទៅស្រុកនោះ ដើម្បីនាំស្រីដទៃមកជាកិរិយា ស្រីនោះ តក់ស្លុត គិតថា វិនាសហើយអញ អញលែងមានឱកាសទៀតពិត គិតថា អញនឹងអង្វរកូនសាកមើលម្ដង ។ ទើបលួចទៅជួបបុត្រ ហើយពោលថា កូនជាទីស្រឡាញ់ វៀរឯងចេញហើយ អ្នកដទៃមិនជាទីពឹងរបស់ម៉ែទេ តាំងអំពីនេះទៅ ម៉ែនឹងបដិបត្តិឪពុក និងជីតារបស់កូន ដូចព្រះចេតិយ

ដែលគេសាង ចូរឯងជួយម៉ែ ឲ្យម៉ែបានចូលមកក្នុងផ្ទះនេះវិញ កុមារពោលថា សាធុ បើម៉ែមិនធ្វើយ៉ាងនេះទៀត ខ្ញុំនឹងជួយ សូមម៉ែកុំប្រមាទ ។ កាលបិតាត្រឡប់មក បានពោលគាថាទី ១០ ថា

ស្ត្រីណា ជាកិរិយារបស់បិតា មានសភាពមិនប្រសើរ ស្ត្រីនោះ
ជាមាតាបង្កើតរបស់ខ្លួនខ្ញុំ មាតាមានធម៌ដ៏លាមកនោះ បាន
ទូន្មានខ្លួន ចុះអំណាចដូចជាមេដំរី ចូលត្រឡប់មក ( កាន់ផ្ទះ )
វិញ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ករេណុវ** សេចក្ដីថា បពិត្រលោកឪពុកឥឡូវនេះ ស្រីមិនប្រសើរជាកិរិយារបស់លោកឪពុក ដែលបង្កហេតុវឹកវរនោះ ត្រូវទូន្មាន ដូចមេដំរីដែលហ្មបង្ខឹកឲ្យនៅក្នុងអំណាច អស់ព្យសន៍ហើយ ។ បទថា **បុនរាវជាតុ** បានដល់ ចូរត្រឡប់មកកាន់ផ្ទះនេះវិញចុះ ។

កុមារនោះ កាលសម្ដែងធម៌ដល់បិតាដូច្នេះហើយ ក៏ទៅនាំមាតាមក នាងសូមខមាទោសប្ដី និងឪពុកក្មេកហើយ តាំងអំពីនោះមក ក៏ប្រកបដោយធម៌ ជាគ្រឿងអប់រំ បដិបត្តិប្ដី និងឪពុកក្មេក មួយអន្លើដោយកូនយ៉ាងល្អ ២ នាក់ប្ដីប្រពន្ធតាំងនៅក្នុងឱវាទរបស់ព្រះពោធិសត្វ ធ្វើបុណ្យ មានទានជាដើម ក៏បានទៅកើតក្នុងសុគតិ ។

*ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងកាលចប់សច្ចៈ បុរសដែលជាអ្នកចិញ្ចឹមបិតាបានតាំងនៅក្នុងសោតាបត្តិផល ហើយទ្រង់ប្រជុំជាតកថា បិតា បុត្រ និងកូនប្រសាស្រីក្នុងកាលនោះ បានមកជាបិតា បុត្រ និងកូនប្រសាស្រីក្នុងកាលឥឡូវនេះ ឯកុមារដែលជាបណ្ឌិតក្នុងកាលនោះ គឺតថាគតនេះឯង ។l៕*

**អដ្ឋកថា តក្កលជាតក ចប់**

# សុត្តន្តបិដក

## មហាធម្មបាលជាតក

[ ៧០៨ ] ( អាចារ្យសួរថា ) អ្វីជាវត្តរបស់អ្នក អ្វីជាព្រហ្មចរិយៈរបស់អ្នក នេះជាផលសុចរិតធម៌ដូចម្តេច ដែលអ្នកសន្សំល្អហើយ ម្នាលព្រាហ្មណ៍ អ្នកចូរប្រាប់សេចក្តីនុ៎ះដល់ខ្ញុំ ព្រោះហេតុអ្វីទើបពួកជននៅក្មេង ( ក្នុងត្រកូល ) របស់អ្នកមិនស្លាប់ ។

[ ៧០៩ ] ( បិតារបស់ធម្មបាលតបថា ) ពួកយើងប្រព្រឹត្តធម៌ មិននិយាយកុហក វៀរនូវអំពើដ៏លាមក វៀរនូវអំពើមិនប្រសើរគ្រប់យ៉ាង ព្រោះហេតុនោះឯង ទើបពួកជននៅក្មេង ( ក្នុងត្រកូល ) របស់ពួកយើង មិនស្លាប់ ។

[ ៧១០ ] ពួកយើង ស្តាប់ធម៌របស់អសប្បុរសផង សប្បុរសផង ប៉ុន្តែ ពួកយើងមិនពេញចិត្ត នឹងធម៌របស់ពួកអសប្បុរសទេ ពួកយើង លះបង់អសប្បុរស មិនលះបង់សប្បុរសទេ ព្រោះហេតុនោះឯង ទើបពួកជននៅក្មេង ( ក្នុងត្រកូល ) របស់ពួកយើង មិនស្លាប់ ។

[ ៧១១ ] ពួកយើង មានចិត្តល្អក្នុងកាលមុនឲ្យ កាលកំពុងឲ្យក៏មានចិត្តត្រេកអរ លុះឲ្យហើយមិនក្តៅក្រហាយក្រោយ ព្រោះហេតុនោះឯង ទើបពួកជននៅក្មេង ( ក្នុងត្រកូល ) របស់ពួកយើង មិនស្លាប់ ។

[ ៧១២ ] ពួកយើង បានញ៉ាំងពួកសមណព្រាហ្មណ៍ អ្នកដំណើរ ស្មូមយាចក និងអ្នកកម្សត់ ឲ្យឆ្អែតស្កប់ស្កល់ ដោយបាយ និងទឹក ព្រោះហេតុនោះឯង ទើបពួកជនទៅក្មេង ( ក្នុងត្រកូល ) របស់យើង មិនស្លាប់ ។

[ ៧១៣ ] ពួកយើង មិនប្រព្រឹត្តកន្លងចិត្តភរិយាទេ ទាំងពួកភរិយា ក៏មិនប្រព្រឹត្តកន្លងចិត្តយើង ពួកយើង ប្រព្រឹត្តនូវព្រហ្មចរិយធម៌ លើកលែងតែភរិយាទាំងនោះចេញ ព្រោះហេតុនោះឯង ទើបពួកជនទៅក្មេង ( ក្នុងត្រកូល ) របស់ពួកយើង មិនស្លាប់ ។

[ ៧១៤ ] យើងទាំងអស់គ្នា វៀរចាកបាណាតិបាត វៀរចាកអទិន្នាទានក្នុងលោក មិនផឹកទឹកស្រវឹង មិននិយាយពាក្យកុហក ព្រោះហេតុនោះឯង ទើបពួកជនទៅក្មេង ( ក្នុងត្រកូល ) របស់ពួកយើង មិនស្លាប់ ។

[ ៧១៥ ] កូនទាំងឡាយ ( របស់យើង ) កើតក្នុងពួកស្ត្រីដ៏ឧត្តម រមែងជាអ្នកប្រាជ្ញ មានប្រាជ្ញាច្រើន ជាពហុស្សូត ដឹងនូវវេទ ព្រោះហេតុនោះឯង ទើបពួកជនទៅក្មេង ( ក្នុងត្រកូល ) របស់យើង មិនស្លាប់ ។

[ ៧១៦ ] មាតាបិតា បងប្អូនស្ត្រី បងប្អូនប្រុស កូន ប្រពន្ធ និងយើងគ្រប់គ្នា ប្រព្រឹត្តធម៌ ដើម្បីជាប្រយោជន៍ក្នុងលោកខាងមុខ ព្រោះហេតុនោះឯង ទើបពួកជនទៅក្មេង ( ក្នុងត្រកូល ) របស់

ពួកយើង មិនស្លាប់ ។

[ ៧១៧ ] ពួកខ្ញុំប្រុស ពួកខ្ញុំស្រី អ្នកចិញ្ចឹមជីវិតដោយសារ អ្នកបម្រើ និងអ្នកធ្វើនូវការងារទាំងអស់ ប្រព្រឹត្តធម៌ដើម្បីប្រ-យោជន៍ក្នុងលោកខាងមុខ ព្រោះហេតុនោះឯង ទើបពួកជននៅក្មេង ( ក្នុងត្រកូល ) របស់យើង មិនស្លាប់

[ ៧១៨ ] ធម៌ រមែងរក្សាអ្នកប្រព្រឹត្តធម៌ដោយពិត ធម៌ដែលសន្សំល្អហើយ រមែងនាំសុខមកឲ្យ នេះជាអានិសង្សក្នុងធម៌ ដែលសន្សំល្អហើយ បុគ្គលអ្នកប្រព្រឹត្តធម៌ រមែងមិនទៅកាន់ទុគ្គតិ ។

[ ៧១៩ ] ធម៌ រមែងរក្សាអ្នកប្រព្រឹត្តធម៌ដោយពិត ដូចឆត្រធំ ( ការពារ ) ក្នុងកាលដែលភ្លៀង ធម្មបាលជាបុត្ររបស់យើង ធម៌គ្រប់គ្រងហើយ ឆ្អឹង ( ដែលអ្នកនាំមកនេះ ) ជាឆ្អឹងសត្វដទៃ កុមារ ( ជាបុត្ររបស់យើង ) មានសេចក្តីសុខនៅឡើយ ។

**មហាធម្មបាលជាតកទី ៩ ចប់**

# អដ្ឋកថា

## មហាធម្មបាលជាតក

[ ៧០៨-៧១៩ ] ព្រះសាស្តា កាលយាងមកនគរកបិលពស្តុជំបូង គង់នៅក្នុងនិគ្រោធារាម ទ្រង់ប្រារព្ធការមិនជឿរបស់ពុទ្ធបិតាក្នុងព្រះរាជនិវេសន៍ ទើបត្រាស់រឿងនេះ មានពាក្យផ្តើមថា **កិរេន្ត វតំ** ដូច្នេះជាដើម ។

សេចក្តីសង្ខេបថា កាលនោះ ព្រះបាទសុទ្ធោទនមហារាជ ទ្រង់ប្រគេនបបរ និងរបស់ទំពាដល់ព្រះមានព្រះភាគ មួយអន្លើដោយភិក្ខុពីរម៉ឺនជាបរិវារក្នុងព្រះរាជនិវេសន៍របស់ព្រះអង្គ កាលទ្រង់ធ្វើសម្មោទនីយកថា ក្នុងរវាងកត្តបានត្រាស់ថា បពិត្រព្រះអង្គ កាលដែលទ្រង់ធ្វើសេចក្តីព្យាយាម មានពួកទេវតាឈរក្នុងអាកាស ប្រាប់ដល់ខ្ញុំព្រះអង្គថា សិទ្ធត្ថកុមារ ឱរសរបស់ទ្រង់អស់ព្រះជន្មហើយ ព្រោះសោយព្រះក្រយាហារតិច កាលព្រះសាស្តាត្រាស់ថា បពិត្រមហារាជ ទ្រង់ជឿឬ ទើបត្រាស់ថា ខ្ញុំព្រះអង្គមិនជឿទេ បានហាមទេវតាដែលឈរក្នុងអាកាសថា ឱរសរបស់ខ្ញុំ បើមិនទាន់បានជាព្រះពុទ្ធត្រង់គល់ពោធិ៍ហើយ គង់មិនបរិនិព្វាន ព្រះសាស្តាត្រាស់ថា បពិត្រមហារាជ ឥឡូវនេះ ទ្រង់នឹងជឿដូចម្តេច សូម្បីក្នុងកាលមុន កាលតថាគតកើតជាមហាធម្មបាល អាចារ្យទិសាបាមោក្ខ យកឆ្អឹងពពែមកប្រាប់ថា កូនរបស់អ្នកស្លាប់ហើយ នេះឆ្អឹងកូនរបស់អ្នក ទ្រង់ក៏មិនជឿ បានពោលនឹងអាចារ្យថា នៅក្នុងត្រកូលរបស់ខ្ញុំ អ្នកស្លាប់ទាំងនៅក្មេងមិនមាន រឿងអ្វីដែលទ្រង់ជឿក្នុងកាលឥឡូវនេះនោះ ព្រះពុទ្ធបិតាទ្រង់ទូលអារាធនាឲ្យត្រាស់រឿងនោះ ទ្រង់ក៏នាំអតីតនិទានមកសាធក:ដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិក្នុងនគរពារាណសី ក្នុងដែនកាសី មានស្រុកមួយឈ្មោះធម្មបាលគ្រាម ស្រុកនោះ បានជាមានឈ្មោះយ៉ាងនោះ ព្រោះជាលំនៅរបស់ត្រកូលធម្មបាល ព្រាហ្មណ៍ដែលនៅអាស្រ័យក្នុងស្រុកនោះ ប្រាកដឈ្មោះថា ធម្មបាល ព្រោះជាអ្នករក្សាធម៌ គឺកុសលកម្មបថ ១០ ក្នុងត្រកូលរបស់ព្រាហ្មណ៍នោះ សូម្បីទាសៈ និងកម្មករក៏ឲ្យទាន រក្សាសីល ធ្វើនូវឧបោសថកម្ម ។

កាលនោះ ព្រះពោធិសត្វកើតក្នុងត្រកូលនោះ ឈ្មោះធម្មបាលកុមារ កាលចម្រើនវ័យហើយ បិតាបានឲ្យទ្រព្យ ១០០០ បញ្ជូនទៅរៀនសិប្បៈក្នុងនគរតក្កសិលា ធម្មបាលកុមារទៅក្នុងទីនោះហើយ រៀនសិប្បៈក្នុងសម្នាក់របស់អាចារ្យទិសាបាមោក្ខ បានជាប្រធានពួកមាណព ដែលជាអន្តេវាសិក ៥០០ នាក់ ។ កាលនោះ កូនច្បងរបស់អាចារ្យស្លាប់ អាចារ្យមានមាណពចោមរោម ព្រមដោយពួកញាតិទ្រហោយំ កន្ទក់កន្ទេញ ធ្វើឈាបនកិច្ចក្នុងព្រៃខ្មោច អាចារ្យក្តី សិស្សក្តី ពួកញាតិក្តី ទ្រហោយំក្នុងទីនោះ ធម្មបាលម្នាក់ឯងប៉ុណ្ណោះមិនយំ មិនកន្ទក់កន្ទេញ កាលមាណព ៥០០ មកអំពីព្រៃខ្មោចហើយ បាននាំគ្នាទៅអង្គុយពណ៌នាក្នុងសម្នាក់អាចារ្យថា គួរឲ្យស្តាយមាណពកំលោះ បរិបូណ៌ដោយមារយាទបែបនេះ ព្រាត់ប្រាសចាកមាតាបិតាស្លាប់ទាំងនៅកំលោះនោះឯង ។ ធម្មបាលកុមារពោលថា អើអ្នកទាំងឡាយអ្នកពោលថា នៅកំលោះ ហេតុអ្វីក៏ស្លាប់តាំងពីនៅកំលោះ ក្នុងកាលដែលជាកំលោះមិនគួរស្លាប់មិនមែនឬ មាណពទាំងនោះ ពោលនឹងធម្មបាលថា អើ

សម្លាញ់ ឯងមិនស្គាល់សេចក្តីស្លាប់របស់សត្វទាំងនេះទេឬ ធម្មបាលកុមារពោលថា ខ្ញុំដឹង តែមិនមាននរណាស្លាប់ទាំងនៅកំលោះ ស្លាប់តែកាលចាស់ប៉ុណ្ណោះ មាណពទាំងឡាយពោលថា សង្ខារទាំងឡាយមិនទៀង មានហើយក៏ទៅជាមិនមាន មិនមែនឬ ធម្មបាលកុមារពោលថា ពិតហើយ សង្ខារមិនទៀង តែសត្វទាំងឡាយ មិនស្លាប់ទាំងក្មេង ស្លាប់តែចាស់ហើយ គឺដល់នូវការមិនទៀង មាណពទាំងឡាយពោលថា នែធម្មបាលសម្លាញ់ ក្នុងផ្ទះរបស់អ្នកមិនមានអ្នកណាស្លាប់ឬ ធម្មបាលពោលថា អ្នកដែលស្លាប់ទាំងកំលោះមិនមានទេ មានតែចាស់ហើយបានស្លាប់ប៉ុណ្ណោះ មាណពទាំងឡាយពោលថា នេះជាបវេណីក្នុងត្រកូលរបស់ឯងឬ ធម្មបាលកុមារពោលថា អើ ជាបវេណីនៃត្រកូលរបស់ខ្ញុំ ។

មាណពទាំងឡាយ បានស្តាប់ពាក្យរបស់ធម្មបាលកុមារដូច្នោះហើយ ក៏បាននាំគ្នាប្រាប់ដល់អាចារ្យៗ ហៅធម្មបាលកុមារមកសួរថា នែបាធម្មបាលបានឮថា ក្នុងត្រកូលរបស់អ្នក មនុស្សមិនស្លាប់ក្នុងវ័យក្មេងពិតឬ ធម្មបាល-កុមារឆ្លើយថា បពិត្រលោកអាចារ្យ ពិតហើយ អាចារ្យស្តាប់ពាក្យរបស់ព្រះពោធិសត្វ គិតថា កុមារនេះនិយាយដូចអស្ចារ្យពន់ពេក អញនឹងទៅកាន់សម្នាក់ឪពុករបស់កុមារនេះសាកសួរមើល បើពិត អញនឹងបំពេញធម៌បែបនោះដែរ ។ អាចារ្យនោះ កាលធ្វើឈាបនកិច្ចកូនស្រេចហើយ កន្លងមកបាន ៧-៨ ថ្ងៃ បានហៅធម្មបាលកុមារមកប្រាប់ថា នែបា អញនឹងចេញទៅ ចូរបាបង្រៀនសិប្បៈដល់មាណពទាំងនេះ ទម្រាំអញត្រឡប់មក ប្រាប់ហើយ ក៏

ដុតឆ្អឹងពពែមួយ លាងដាក់ក្នុងកញ្ចប់ ឲ្យអ្នកបម្រើម្នាក់កាន់តាមទៅ ចេញអំពីនគរតក្កសិលាទៅដោយលំដាប់ ។ ទៅដល់ស្រុកនោះ សួររកផ្ទះរបស់មហាធម្មបាលថា នៅឯណា ស្គាល់ហើយ ក៏ទៅឈរត្រង់ទ្វារ ។

ពួកទាសៈរបស់ព្រាហ្មណ៍ឃើញមុន ក៏នាំគ្នាទទួលឆត្រ ស្បែកជើងអំពីដៃរបស់អាចារ្យ និងទទួលកញ្ចប់អំពីដៃរបស់អ្នកបម្រើ កាលអាចារ្យពោលថា ចូរពួកអ្នកទៅប្រាប់បិតារបស់កុមារថា អាចារ្យរបស់ធម្មបាលកុមារកូនរបស់លោកមកឈរត្រង់ទ្វារ ពួកទាសៈទទួលពាក្យថា សាធុ ហើយនាំគ្នាទៅប្រាប់ ព្រាហ្មណ៍ប្រញាប់ទៅត្រង់ទ្វារ អញ្ជើញថា បពិត្រលោកអាចារ្យអញ្ជើញខាងនេះ ហើយនាំអាចារ្យឡើងលើផ្ទះ ឲ្យអង្គុយលើបល្ល័ង្ក ធ្វើកិច្ចគ្រប់យ៉ាងមានលាងជើងជាដើម អាចារ្យបរិភោគអាហារហើយ ពេលអង្គុយសន្ទនាតាមសប្បាយ ទើបធ្វើជាពោលថា នែព្រាហ្មណ៍ ធម្មបាលកុមារកូនរបស់លោកជាមនុស្សមានសតិ និងបញ្ញា រៀនចប់ត្រៃវេទ និងសិល្បសាស្ត្រ ១៨ ប្រការ តែបានស្លាប់ទៅហើយ ដោយរោគឯណានីមួយ សង្ខារទាំងពួងមិនទៀង លោកកុំសោយសោកឡើយ ។

ព្រាហ្មណ៍ទះដៃសើចខ្លាំងៗ កាលអាចារ្យសួរថា នែព្រាហ្មណ៍ លោកសើចអ្វី ក៏ឆ្លើយថា កូនខ្ញុំមិនស្លាប់ឡើយ អ្នកដែលស្លាប់នោះជាអ្នកដទៃ អាចារ្យពោលថា លោកបានឃើញឆ្អឹងកូនរបស់លោកហើយ ចូរជឿចុះ រួចនាំឆ្អឹងចេញមក ពោលថា នេះឆ្អឹងកូនរបស់លោក ព្រាហ្មណ៍ពោលថា នេះជាឆ្អឹងពពែ ឬឆ្អឹងឆ្កែ កូនខ្ញុំមិនស្លាប់ ព្រោះក្នុងត្រកូលរបស់ខ្ញុំ ៧ តំណមក

ហើយ មិនមានអ្នកធ្លាប់ស្លាប់ក្នុងវ័យក្មេងឡើយ លោកអាចារ្យពោលកុហក ខណៈនោះ មនុស្សទាំងឡាយបានទះដៃសើច អាចារ្យឃើញភាពអស្ចារ្យនោះ មានសេចក្តីសោមនស្ស កាលនឹងសួរថា នែព្រាហ្មណ៍ ក្នុងបវេណីត្រកូលរបស់លោក ដែលមនុស្សក្មេងមិនស្លាប់ បើមិនមានហេតុ គង់មិនអាចប្រព្រឹត្តទៅបាន ព្រោះហេតុអ្វី ទើបក្មេងៗ មិនស្លាប់ដូច្នេះ បានពោលគាថាទី ១ ថា

អ្វីជាវត្តរបស់អ្នក អ្វីជាព្រហ្មចរិយៈរបស់អ្នក នេះជាផលសុចរិតធម៌ដូចម្តេច ដែលអ្នកសន្សំល្អហើយ ម្នាលព្រាហ្មណ៍ អ្នកចូរប្រាប់សេចក្តីនុ៎ះដល់ខ្ញុំ ព្រោះហេតុអ្វី ទើបពួកជននៅក្មេង ( ក្នុងត្រកូល ) របស់អ្នកមិនស្លាប់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វតំ** បានដល់ វត្តសមាទាន ។ បទថា **ព្រហ្មចរិយំ** បានដល់ ជាព្រហ្មចរិយៈដ៏ប្រសើរបំផុត ។ បទថា **កិស្ស សុចិណ្ណស្ស** សេចក្តីថា ការដែលក្មេងៗ ក្នុងត្រកូលរបស់ពួកលោកមិនស្លាប់ ជាផលនៃសុចរិតដូចម្តេច ។

ព្រាហ្មណ៍បានស្តាប់ដូច្នោះហើយ កាលនឹងពណ៌នាគុណានុភាពដែលជាហេតុឲ្យក្មេងៗ ក្នុងត្រកូលនោះមិនស្លាប់ ទើបពោលគាថាទាំងនេះថា

ពួកយើង ប្រព្រឹត្តធម៌ មិននិយាយកុហក វៀរនូវអំពើដ៏លាមក វៀរនូវអំពើមិនប្រសើរគ្រប់យ៉ាង ព្រោះហេតុនោះឯង ទើបពួកជននៅក្មេង ( ក្នុងត្រកូល ) របស់ពួកយើង មិនស្លាប់ ។

ពួកយើង ស្តាប់ធម៌របស់អសប្បុរសផង សប្បុរសផង ប៉ុន្តែ

ពួកយើង មិនពេញចិត្តនឹងធម៌របស់ពួកអសប្បុរសទេ ពួកយើង លះបង់អសប្បុរស មិនលះបង់សប្បុរសទេ ព្រោះហេតុនោះឯង ទើបពួកជននៅក្មេង ( ក្នុងត្រកូល ) របស់ពួកយើង មិនស្លាប់ ។

ពួកយើង មានចិត្តល្អក្នុងកាលមុនឲ្យ កាលកំពុងឲ្យ ក៏មានចិត្តត្រេកអរ លុះឲ្យហើយ មិនក្តៅក្រហាយក្រោយ ព្រោះហេតុនោះឯង ទើបពួកជននៅក្មេង ( ក្នុងត្រកូល ) របស់ពួកយើង មិនស្លាប់ ។

ពួកយើង បានញ៉ាំងពួកសមណព្រាហ្មណ៍ អ្នកដំណើរ ស្មូមយាចក និងអ្នកកម្សត់ ឲ្យឆ្អែតស្កប់ស្កល់ ដោយបាយ និងទឹក ព្រោះហេតុនោះឯង ទើបពួកជននៅក្មេង ( ក្នុងត្រកូល ) របស់យើង មិនស្លាប់ ។

ពួកយើង មិនប្រព្រឹត្តកន្លងចិត្តភរិយាទេ ទាំងពួកភរិយា ក៏មិនប្រព្រឹត្តកន្លងចិត្តយើង ពួកយើង ប្រព្រឹត្តនូវព្រហ្មចរិយធម៌ លើកលែងតែភរិយាទាំងនោះចេញ ព្រោះហេតុនោះឯង ទើបពួកជននៅក្មេង ( ក្នុងត្រកូល ) របស់ពួកយើង មិនស្លាប់ ។

យើងទាំងអស់គ្នា វៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន ក្នុងលោក មិនផឹកទឹកស្រវឹង មិននិយាយពាក្យកុហក ព្រោះហេតុនោះឯង ទើបពួកជននៅក្មេង ( ក្នុងត្រកូល ) របស់ពួកយើង មិនស្លាប់ ។

កូនទាំងឡាយ ( របស់យើង ) កើតក្នុងពួកស្ត្រីដ៏ឧត្តម រមែង
ជាអ្នកប្រាជ្ញ មានប្រាជ្ញាច្រើន ជាពហុស្សូត ដឹងនូវវេទ ព្រោះ
ហេតុនោះឯង ទើបពួកជនទៅក្មេង ( ក្នុងត្រកូល ) របស់
យើង មិនស្លាប់ ។

មាតា បិតា បងប្អូនស្ត្រី បងប្អូនប្រុស កូន ប្រពន្ធ និងយើង
គ្រប់គ្នា ប្រព្រឹត្តធម៌ ដើម្បីជាប្រយោជន៍ក្នុងលោកខាងមុខ ព្រោះ
ហេតុនោះឯង ទើបពួកជនទៅក្មេង ( ក្នុងត្រកូល ) របស់
ពួកយើង មិនស្លាប់ ។

ពួកខ្ញុំប្រុស ពួកខ្ញុំស្រី អ្នកចិញ្ចឹមជីវិតដោយសារអ្នកបម្រើ និង
អ្នកធ្វើនូវការងារទាំងអស់ ប្រព្រឹត្តធម៌ ដើម្បីប្រយោជន៍ក្នុង
លោកខាងមុខ ព្រោះហេតុនោះឯង ទើបពួកជនទៅក្មេង ( ក្នុង
ត្រកូល ) របស់យើង មិនស្លាប់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ធម្មំ ចរាម** បានដល់ ប្រព្រឹត្តធម៌ គឺកុស-លកម្មបថ ១០ ប្រការ កុសលកម្មគ្រប់យ៉ាងមាន ពួកយើងមិនផ្តាច់ជីវិតសត្វ ដោយហោចសូម្បីត្រឹមតែស្រមោចខ្មៅ ស្រមោចក្រហម ឲ្យដាច់ចាកជីវិត ព្រោះហេតុនៃជីវិតខ្លួន និងមិនសម្លឹងមើលទ្រព្យអ្នកដទៃដោយលោភចិត្តជាដើម ឡើយ ។ បណ្ឌិតគប្បីពណ៌នាឲ្យពិស្តារ ក្នុងគាថានេះ ព្រាហ្មណ៍ពោលដល់ ការពោលមុសា តែពោលដោយអំណាចអកុសលកម្មដ៏ក្រៃលែងឡើងថា ឈ្មោះថា បាប ដែលបុគ្គលអ្នកច្រើនដោយការពោលកុហក មិនធ្វើ រមែង

មិនមាន បានឮថា បុគ្គលទាំងនោះ មិនពោលកុហក សូម្បីមានបំណងនឹងសើចលេង ។

បទថា **ធាធានិ** បានដល់ កម្មដ៏លាមក ដែលជាហេតុឲ្យចូលដល់នរកគ្រប់យ៉ាង ។ បទថា **អនរិយំ** បានដល់ វៀរនូវកម្មដែលវៀរចាកកម្មដ៏ប្រសើរ គឺដែលមិនល្អ បានដល់ មិនបរិសុទ្ធទាំងអស់ ។ **ហិ** អក្ខរៈ ក្នុងពាក្យថា **តស្មា ហិ អម្ហំ** នេះ ត្រឹមតែជានិបាត អធិប្បាយថា ព្រោះហេតុនេះ បុគ្គលដែលនៅក្មេងរបស់ពួកយើងមិនស្លាប់ គឺឈ្មោះថា អកាលមរណៈក្នុងចន្លោះ រមែងមិនមានដល់ពួកយើង ។ បាលីថា **តស្មា អម្ហំ** ដូច្នេះក៏មាន ។ បទថា **សុណោម** ជាដើម សេចក្តីថា បានឮថា ធម៌ដែលសម្តែងកុសលរបស់សប្បុរស ពួកយើងក៏ស្តាប់ ធម៌ដែលសម្តែងអកុសលនៃអសប្បុរស ពួកយើងក៏ស្តាប់ តែពួកយើងក៏គ្រាន់តែស្តាប់ធម៌នោះហើយប៉ុណ្ណោះ មិនគាប់ចិត្តក្នុងធម៌របស់អសប្បុរសនោះឡើយ ពួកយើងស្តាប់ដោយគិតថា មិនឲ្យមានការឈ្លោះ ឬវិវាទជាមួយអសប្បុរសទាំងនោះ សូម្បីស្តាប់ហើយ ក៏លះអសប្បុរស ប្រព្រឹត្តតាមសប្បុរស មិនលះសប្បុរស សូម្បីត្រឹមតែមួយខណៈ លះអសប្បុរស គឺបាបមិត្តចេញ ជាអ្នកសេពគប់តែកល្យាណមិត្តប៉ុណ្ណោះ ។

បទថា **សមណោ មយំ ព្រាហ្មណោ** សេចក្តីថា ម្នាលព្រាហ្មណ៍ ពួកយើងផ្គត់ផ្គង់សមណព្រាហ្មណ៍ គឺព្រះបច្ចេកពុទ្ធ ដែលមានបាបស្ងប់រម្ងាប់ហើយ ជាអ្នកបន្សាត់បាបហើយ សមណព្រាហ្មណ៍ដែលតាំងនៅក្នុងធម៌ដ៏

សេសផង ជនដ៏សេស មានអ្នកដើរផ្លូវជាដើមផង ឲ្យឆ្អែតស្កប់ស្កល់ដោយបាយ ទឹក ក្នុងបាលី គាថានេះ ក៏មកតាមក្រោយគាថាថា **បុញ្ញេ ធានា** ដូចគ្នា ។ បទថា **ធាតិក្កមាម** សេចក្តីថា ពួកយើងមិនប្រព្រឹត្តកន្លងចិត្តកិរិយារបស់ខ្លួន ធ្វើនូវមិច្ឆាចារក្នុងស្រីដទៃខាងក្រៅ ។ បទថា **អញ្ញត្រ តាហិ** សេចក្តីថា ពួកយើង ប្រព្រឹត្តព្រហ្មចរិយៈក្នុងស្រីដ៏សេស ក្រៅអំពីកិរិយានៃខ្លួន សូម្បីកិរិយារបស់ពួកយើង ក៏ប្រព្រឹត្តទៅក្នុងប្រុសដ៏សេសយ៉ាងនេះដូចគ្នា ។ បទថា **ជាយរេ** ប្រែថា រមែងកើត ។ បទថា **សុត្តមាសុ** គឺក្នុងស្រីដ៏ឧត្តម មានសីលល្អទាំងឡាយ ។

សេចក្តីនេះ មានអធិប្បាយថា កូនទាំងឡាយណារបស់ពួកយើងកើតក្នុងស្រីដ៏ឧត្តម ជាអ្នកមានសីលបរិបូណ៌ទាំងនោះ កូនទាំងនោះ រមែងជាអ្នកមានប្រការយ៉ាងនេះ គឺជាអ្នកឈ្លាសជាដើម ការស្លាប់ក្នុងវ៉ាង នឹងមានដល់កូនទាំងនោះអំពីណា ព្រោះហេតុនោះ ជនដែលនៅក្មេងក្នុងត្រកូលរបស់ពួកយើង មិនស្លាប់ ។ បទថា **ធម្មំ ចរាម** បានដល់ ប្រព្រឹត្តសុចរិតធម៌ ៣ ប្រការ ដើម្បីជាប្រយោជន៍ដល់បរលោក ។ ស្រីបម្រើទាំងឡាយ ឈ្មោះថាទាសី ។ ក្នុងទីបំផុត ព្រាហ្មណ៍ក៏បានសម្តែងគុណអ្នកប្រព្រឹត្តធម៌ដោយគាថាទាំង ២ នេះថា

> ធម៌រមែងរក្សាអ្នកប្រព្រឹត្តធម៌ដោយពិត ធម៌ដែលសន្សំល្អហើយ
> រមែងនាំសុខមកឲ្យ នេះជាអានិសង្សក្នុងធម៌ ដែលសន្សំល្អហើយ
> បុគ្គលអ្នកប្រព្រឹត្តធម៌ រមែងមិនទៅកាន់ទុគ្គតិ ។

ធម៌រមែងរក្សាអ្នកប្រព្រឹត្តធម៌ដោយពិត ដូចឆត្រធំ ( ការពារ ) ក្នុងកាលដែលភ្លៀង ធម្មបាលជាបុត្ររបស់យើង ធម៌គ្រប់គ្រងហើយ ឆ្អឹង ( ដែលអ្នកនាំមកនេះ ) ជាឆ្អឹងសត្វដទៃ កុមារ ( ជាបុត្ររបស់យើង ) មានសេចក្ដីសុខនៅឡើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **រក្ខតិ** សេចក្ដីថា ធម្មតាធម៌ដែលបុគ្គលរក្សាហើយ រមែងរក្សាបុគ្គលដែលមានធម៌ដែលខ្លួនរក្សាហើយ ។ បទថា **សុខមាវហាតិ** បានដល់ រមែងនាំសុខក្នុងទេវតា និងមនុស្សទាំងឡាយ និងនិព្វានសុខមកឲ្យ ។ បទថា **ន ទុគ្គតឹ** បានដល់ រមែងមិនទៅកាន់ទុគ្គតិ មានទុគ្គតិ គឺនរកជាដើម ។ ព្រាហ្មណ៍នោះសម្ដែងថា បពិត្រលោកអាចារ្យ ពួកយើងរក្សាធម៌យ៉ាងនេះ សូម្បីធម៌ក៏រក្សាពួកយើងដូចគ្នា ។ បទថា **ធម្មេន គុត្តោ** បានដល់ ដែលធម៌ដែលខ្លួនរក្សាដូចគ្នានឹងឆត្រធំគ្រប់គ្រងហើយ ។ បទថា **អញ្ញស្ស អដ្ឋីនិ** សេចក្ដីថា ឆ្អឹងដែលអ្នកនាំមកនេះ ជាឆ្អឹងរបស់សត្វដទៃ គឺរបស់ពពែក្ដី របស់ឆ្កែក្ដី សូមលោកបោះឆ្អឹងទាំងនោះចោល កូនរបស់ខ្ញុំមានសេចក្ដីសុខនៅឡើយ ។

អាចារ្យបានស្ដាប់ដូច្នោះ ក៏ពោលថា ការមករបស់ខ្ញុំជាការមកល្អ មានផល មិនឥតផល ហើយមានសេចក្ដីត្រេកអរ សូមខមាទោសបិតាធម្មបាល ហើយពោលថា នេះជាឆ្អឹងពពែ ខ្ញុំនាំមកដើម្បីសាកល្បងលោក កូនរបស់លោកសុខសប្បាយ សូមលោកឲ្យធម៌ដែលលោករក្សាដល់ខ្ញុំ ដូច្នេះហើយចារឹកសេចក្ដីក្នុងសៀវភៅ នៅទីនោះ ២-៣ ថ្ងៃហើយ ទៅនគរតក្កសិលា ឲ្យ

ធម្មបាលកុមារសិក្សាសិប្បៈគ្រប់យ៉ាង ហើយបញ្ជូនទៅដោយបរិវារធំ ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកសម្តែងដល់ព្រះបាទសុទ្ធោទនមហារាជហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងកាលចប់សច្ចៈ ព្រះបាទសុទ្ធោទនមហារាជ តាំងនៅក្នុងអនាគាមិផល ហើយទ្រង់ប្រជុំជាតកថា មាតាបិតាក្នុងកាលនោះ បានមកជាពុទ្ធមាតា និងពុទ្ធបិតា ក្នុងកាលឥឡូវនេះ អាចារ្យក្នុងកាលនោះ បានជាសារីបុត្រ បរិស័ទក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទក្នុងកាលឥឡូវនេះ ឯធម្មបាលកុមារ ក្នុងកាលនោះ គឺតថាគតនេះឯង ៕

## អដ្ឋកថា មហាធម្មបាលជាតក ចប់

# សុត្តន្តបិដក

## កុក្កុដជាតក

[ ៧២០ ] ( មាន់ពោធិសត្វពោលថា ) បុគ្គលមិនគប្បីស្និទ្ធស្នាល នឹងបុគ្គលដែលធ្វើបាបម្តងហើយ មិនគប្បីស្និទ្ធស្នាលនឹងបុគ្គល ដែលពោលពាក្យឡេះឡោះ មិនគប្បីស្និទ្ធស្នាលនឹងបុគ្គលដែល មានប្រាជ្ញា គិតតែប្រយោជន៍ខ្លួន មិនគប្បីស្និទ្ធស្នាលនឹងបុគ្គល ( មានពុតត្បុត ) ដែលធ្វើហាក់ដូចជាស្ងប់ស្ងាត់ក្រៃលែង ។

[ ៧២១ ] បុរសពួកខ្លះ ប្រកបដោយជាតិ ហាក់ដូចជាគោស្រេក ទឹក ស៊ីនូវមិត្តដោយវាចា តែមិន ( សង្គ្រោះដោយការងារ ) ។

[ ៧២២ ] បុរសពួកខ្លះ ផ្គងអញ្ជលីទទេឡើង ហើយបិទបាំង ដោយវាចា ជាមនុស្សស្រោយ កតញ្ញូតាធម៌ មិនមានក្នុងបុគ្គល ណា សប្បុរសមិនគប្បីចូលទៅជិត នូវបុគ្គលនោះទេ ។

[ ៧២៣ ] បុគ្គលមិនគប្បីស្និទ្ធស្នាលនឹងស្ត្រី ឬបុរស ដែលមាន ចិត្តប្រែប្រួល ( អ្នកណា ) ធ្វើនូវសេចក្តីស្និទ្ធស្នាលឲ្យច្បាស់ ដោយអំពើផ្សេងៗ ( ហើយធ្វើនូវសេចក្តីអន្តរាយ ក្នុងកាលខាង ក្រោយ ) បុគ្គលមិនគប្បីស្និទ្ធស្នាលនឹងបុគ្គលបែបនោះទេ ។

[ ៧២៤ ] អ្នកដែលល្មោភនឹងអំពើមិនប្រសើរ មានវាចាមិនខ្ជាប់ខ្ជួន បៀតបៀននូវជនទាំងពួង ដូចជាដាវដែលសំលៀងហើយ បិទបាំងទុក បុគ្គលមិនគប្បីស្និទ្ធស្នាលនឹងបុគ្គលបែបនោះទេ ។

[ ៧២៥ ] បុគ្គលពួកខ្លះ ក្នុងលោកនេះ ចូលទៅជិតដោយឧបាយផ្សេងៗ គឺដោយអំណាច ធ្វើហាក់ដូចជាមិត្ត ( ដ៏ស្និទ្ធ ) មានពាក្យដ៏ស្អាតផូរផង់ តែមិនមានចិត្ត ( ស្អាតល្អ ) បុគ្គលមិនគប្បីស្និទ្ធស្នាលនឹងបុគ្គលបែបនោះទេ ។

[ ៧២៦ ] ជនឥតប្រាជ្ញាបែបនោះ ឃើញនូវអាមិសៈ ឬទ្រព្យក្នុងផ្ទះសម្លាញ់ណា រមែងធ្វើនូវសេចក្តីប្រទូស្ត បៀតបៀននូវជននោះ ហើយចៀសចេញទៅ ។

[ ៧២៧ ] ( អភិសម្ពុទ្ធគាថា ) សត្រូវច្រើនបិទបាំង ដោយសភាពហាក់ដូចជាមិត្តមកគប់រក បុគ្គលគប្បីលះបង់ នូវបុរសអាក្រក់នោះចោលចេញ ដូចមាន់លះបង់ខ្លែង ។

[ ៧២៨ ] បុគ្គលណា មិនឆាប់យល់នូវហេតុ ដែលកើតឡើងបុគ្គលនោះ រមែងលុះអំណាចសត្រូវ រមែងក្តៅក្រហាយរឿយៗក្នុងកាលជាខាងក្រោយ ។

[ ៧២៩ ] បុគ្គលណា យល់ទាន់នូវហេតុដែលកើតឡើង បុគ្គលនោះ រមែងរួចផុតចាកការបៀតបៀនរបស់សត្រូវ ដូចជាមាន់រួចអំពីខ្លែង ។

[ ៧៣០ ] ជនមានប្រាជ្ញាវាងវៃ គប្បីវៀរអំពីចម្លាយ នូវបុគ្គលមិនប្រកបដោយធម៌ ជាអ្នកកម្ចាត់នូវគុណ របស់បុគ្គលដទៃជានិច្ច ប្រាកដដូចជាអន្ទាក់បញ្ឆោត ដែលគេដាក់ក្នុងព្រៃ ដូចជាមាន់វៀរខ្លែងក្នុងព្រៃឫស្សី ។

**កុក្កុដជាតកទី ១០ ចប់**

# អដ្ឋកថា

## កុក្កុដជាតក

[ ៧២០-៧៣០ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធការព្យាយាមផ្តាច់ព្រះជន្ម ទើបត្រាស់រឿងនេះ មានពាក្យផ្តើមថា **ឆាស្នសេកតចាបម្ហិ** ដូច្នេះជាដើម ។

មានសេចក្តីសង្ខេបថា ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងធម្មសភា ដល់ភាពមិនល្អរបស់ទេវទត្តថា អាវុសោទាំងឡាយ ទេវទត្តធ្វើឧបាយជាគ្រឿងផ្តាច់ព្រះជន្មព្រះទសពល ដោយការរៀបចំនាយខ្មាន់ធ្នូរជាដើម ។ ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដល់រឿងអ្វី កាលភិក្ខុទាំងឡាយទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងឥឡូវនេះប៉ុណ្ណោះទេ ដែលទេវទត្តព្យាយាមសម្លាប់តថាគត សូម្បីក្នុងកាលមុន ទេវទត្តក៏ព្យាយាមសម្លាប់តថាគតដូចគ្នា ហើយទ្រង់បាននាំយករឿងក្នុងអតីតមកសាធក:ដូចតទៅ

ក្នុងអតីតកាល ព្រះរាជាព្រះនាមកោសម្ពិក: សោយរាជសម្បត្តិក្នុងនគរកោសម្ពី កាលនោះ ព្រះពោធិសត្វយោនយកកំណើតជាសត្វមាន់ ក្នុងព្រៃឫស្សីមួយកន្លែង មានមាន់ច្រើនរយជាបរិវារ ក្នុងព្រៃនោះ ។ ខ្លែងមួយនៅក្នុងទីជិតនោះ ប្រើឧបាយចាប់មាន់ ក្រៅអំពីព្រះពោធិសត្វ ស៊ីម្តងមួយៗទាល់តែអស់ ព្រះពោធិសត្វនៅតែម្នាក់ឯង ជាអ្នកមិនប្រមាទ ត្រាច់ស្វែងរកអាហារតាមកាល ហើយចូលទៅក្នុងគុម្ពឫស្សី ។ ខ្លែងនោះ មិនអាចចាប់ព្រះ

ពោធិសត្វនោះបាន ទើបគិតថា អញនឹងប្រើឧបាយណាមួយ បញ្ឆោតចាប់មាន់នោះស៊ីឲ្យបាន ។ ហើយខ្លែងនោះទៅពួនត្រង់មែកឈើក្បែរនោះ ពោលថា នែស្តេចមាន់សម្លាញ់ ឯងខ្លាចខ្ញុំព្រោះហេតុអ្វី ខ្ញុំត្រូវការស្និទ្ធស្នាលនឹងឯង ប្រទេសឈ្មោះនោះ សម្បូរដោយអាហារ យើងទាំង ២ ទៅរកអាហារជាមួយគ្នាក្នុងទីនោះ ហើយនឹងនៅដោយមានសេចក្តីស្រឡាញ់ដល់គ្នានិងគ្នា ។

លំដាប់នោះ ព្រះពោធិសត្វពោលនឹងខ្លែងថា នែសម្លាញ់ ខ្ញុំស្និទ្ធស្នាលនឹងអ្នកមិនបានទេ ឯងទៅចុះ ។ ខ្លែងសួរថា នែសម្លាញ់ អ្នកមិនជឿខ្ញុំ ព្រោះខ្ញុំធ្លាប់ធ្វើអាក្រក់មកហើយ តាំងអំពីនេះទៅ ខ្ញុំមិនធ្វើដូច្នោះទៀតឡើយ ។ ព្រះពោធិសត្វឆ្លើយថា ខ្ញុំមិនត្រូវការសម្លាញ់ដូចឯងទេ ចូរឯងទៅចុះ ព្រះពោធិសត្វឃាត់ខ្លែងទំនងនេះអស់វារៈ ៣ ដង បន្លឺសំឡេងរងាវរំពងព្រៃថា បុគ្គលណាមួយ មិនគួរធ្វើសេចក្តីស្និទ្ធស្នាល ជាមួយនឹងបុគ្គលដែលប្រកបដោយលក្ខណៈដូច្នេះ កាលទេវតាទាំងឡាយ នាំគ្នាឲ្យសាធុការ មាន់កាលនឹងផ្តើមធម្មកថា បានពោលគាថាទាំងនេះថា

បុគ្គលមិនគប្បីស្និទ្ធស្នាល នឹងបុគ្គលដែលធ្វើបាបម្តងហើយ មិនគប្បីស្និទ្ធស្នាល នឹងបុគ្គលដែលពោលពាក្យឡេះឡោះ មិនគប្បីស្និទ្ធស្នាល នឹងបុគ្គលដែលមានប្រាជ្ញា គិតតែប្រយោជន៍ខ្លួន មិនគប្បីស្និទ្ធស្នាល នឹងបុគ្គល ( មានពុតត្បុត ) ដែលធ្វើហាក់ដូចជាស្ងប់ស្ងាត់ក្រៃលែង ។

បុរសពួកខ្លះ ប្រកបដោយជាតិ ហាក់ដូចជាគោស្រេកទឹក ស៊ីនូវ

មិត្តដោយវាចា តែមិន ( សង្គ្រោះដោយការងារ ) ។

បុរសពួកខ្លះ ផ្គងអញ្ជលីទទេឡើង ហើយបិទបាំងដោយវាចា ជាមនុស្សស្រោយ កតញ្ញូតាធម៌ មិនមានក្នុងបុគ្គលណា សប្បុរសមិនគប្បីចូលទៅជិត នូវបុគ្គលនោះទេ ។

បុគ្គលមិនគប្បីស្និទ្ធស្នាល នឹងស្ត្រី ឬបុរស ដែលមានចិត្តប្រែប្រួល ( អ្នកណា ) ធ្វើនូវសេចក្តីស្និទ្ធស្នាលឲ្យច្បាស់ ដោយអំពើផ្សេងៗ ( ហើយធ្វើនូវសេចក្តីអន្តរាយ ក្នុងកាលខាងក្រោយ ) បុគ្គលមិនគប្បីស្និទ្ធស្នាល នឹងបុគ្គលបែបនោះទេ ។

អ្នកដែលល្មោភនឹងអំពើមិនប្រសើរ មានវាចាមិនខ្ជាប់ខ្ជួន បៀតបៀននូវជនទាំងពួង ដូចជាដាវដែលសំលៀងហើយ បិទបាំងទុក បុគ្គលមិនគប្បីស្និទ្ធស្នាល នឹងបុគ្គលបែបនោះទេ ។

បុគ្គលពួកខ្លះ ក្នុងលោកនេះ ចូលទៅជិតដោយឧបាយផ្សេងៗ គឺដោយអំណាចធ្វើហាក់ដូចជាមិត្ត ( ដ៏ស្និទ្ធ ) មានពាក្យដ៏ស្អាតផូរផង់ តែមិនមានចិត្ត ( ស្អាតល្អ ) បុគ្គលមិនគប្បីស្និទ្ធស្នាល នឹងបុគ្គលបែបនោះទេ ។

ជនឥតប្រាជ្ញាបែបនោះ ឃើញនូវអាមិសៈ ឬទ្រព្យក្នុងផ្ទះសម្លាញ់ណា រមែងធ្វើនូវសេចក្តីប្រទូស្ត បៀតបៀននូវជននោះ ហើយចៀសចេញទៅ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឆាស្នសេ** បានដល់ មិនគប្បីស្និទ្ធស្នាល

ម្យ៉ាងទៀត ព្រះបាលីក៏យ៉ាងនោះដូចគ្នា មានពាក្យដែលលោកពោលថា បុគ្គលមិនគួរស្និទ្ធស្នាល ។ បទថា **កតបាបម្ហិ** បានដល់ ក្នុងបុគ្គលអ្នកធ្លាប់ធ្វើបាបមកអំពីមុន ។ បទថា **អលិកវាទិនេ** បានដល់ មិនគប្បីទុកចិត្តក្នុងបុគ្គលដែលច្រើនដោយការពោលកុហក ព្រោះថា ឈ្មោះថា បាប ដែលបុគ្គលច្រើនដោយការនិយាយកុហកនោះ មិនគប្បីធ្វើ រមែងមិនមាន ។

បទថា **ឆាស្មសេ អត្តត្ថបញ្ញម្ហិ** សេចក្តីថា បុគ្គលណាមានបញ្ញាគិតតែប្រយោជន៍ខ្លួនប៉ុណ្ណោះ គឺមិនបានសេពគប់ដោយអំណាចនៃស្នេហា សម្ដីឃើញតែទ្រព្យទាំងនោះ ទើបគប់រក សូម្បីក្នុងបុគ្គលដែលមានបញ្ញាគិតតែប្រយោជន៍ខ្លួននោះ ក៏មិនគួរទុកចិត្ត ។ បទថា **អតិសន្តេ** បានដល់ ក្នុងបុគ្គលដែលពុតធ្វើជាស្ងប់ស្ងៀម ដោយការសម្តែងសេចក្តីស្ងប់ខាងក្រៅ ទាំងដែលសេចក្តីស្ងប់ខាងក្នុងមិនមានសោះ គឺក្នុងបុគ្គលបោកបញ្ឆោត ជាអ្នកបិទបាំងការងារ ដូចអាសិរពិសពួនក្នុងរន្ធ ។ បទថា **គោបិសាចាសិកជាតិកា** បានដល់ ហាក់បីដូចកើតមានការស្រេកទឹកនៃគោទាំងឡាយ អធិប្បាយថា ដូចគ្នានឹងគោដែលស្រេកទឹក ព្រះពោធិសត្វសម្តែងសេចក្តីនេះថា ប្រៀបដូចគោដែលស្រេកទឹកចុះកាន់កំពង់ទឹក ហើយផឹកទាល់តែពេញមាត់ តែមិនធ្វើវត្តដែលគួរធ្វើដល់ទឹក យ៉ាងណា បុគ្គលពួកខ្លះ ក៏ដូច្នោះដូចគ្នា ធ្វើអាកប្បកិរិយា លេបនូវមិត្តដោយពាក្យទន់ផ្អែមថា នឹងធ្វើវត្តឈ្មោះនេះឲ្យ ហើយក៏មិនធ្វើវត្តដែលគួរដល់ពាក្យដែលពីរោះ ការស្និទ្ធស្នាលក្នុងបុគ្គលបែបនោះ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីវិនាសដ៏ធំ ។

បទថា **សុខញ្ជលី បគ្គហិតា** បានដល់ ជាអ្នកផ្គងអញ្ជលីទទេ ។ បទថា **វាចាយ បលិគុណ្ឋិតា** បានដល់ បិទបាំងដោយពាក្យថា នឹងឲ្យ នឹងធ្វើវត្ថុនោះ ។ បទថា **មនុស្សផេគ្គុ** សេចក្ដីថា មនុស្សមិនមានសារៈបែបនេះ ឈ្មោះថា មនុស្សស្រោយ ។ បទថា **នាសិទេ** បានដល់ មិនគួរអង្គុយជិត គឺមិនគួរចូលទៅជិតបុគ្គលបែបនេះ ។

បទថា **យស្មឹ នត្ថិ** សេចក្ដីថា ម្យ៉ាងទៀត កតញ្ញូមិនមានក្នុងបុគ្គលណា សូម្បីក្នុងបុគ្គលនោះ ក៏មិនគួរអង្គុយជិត ។ បទថា **អញ្ញញ្ញចិត្តានំ** បានដល់ ដែលប្រកបដោយចិត្តមិនពិតប្រាកដ អធិប្បាយថា មានចិត្តប្រែប្រួល ។ ព្រះពោធិសត្វសម្ដែងសេចក្ដីនេះថា បុគ្គលមិនគួរស្និទ្ធស្នាលចំពោះបុរស ឬស្ត្រីបែបនេះ ។

បទថា **នានាវិកត្វា សំសគ្គំ** ព្រះពោធិសត្វសម្ដែងថា សូម្បីបុគ្គលណា អាងក្នុងការធ្វើអន្តរាយ គឺអះអាងដោយហេតុផ្សេងៗ ថា ខ្ញុំមិនអាចចូលទៅធ្វើឲ្យបុគ្គលនោះមានអន្តរាយ ដូច្នេះហើយ ធ្វើអន្តរាយក្នុងកាលជាខាងក្រោយ បុគ្គលបែបនោះ ក៏មិនគួរស្និទ្ធស្នាល គឺមិនគួរយកខ្លួនបៀត ។

បទថា **អនរិយកម្មំ ឱក្កន្តំ** បានដល់ ឈមចុះកាន់កម្មរបស់បុគ្គលមិនប្រសើរ គឺអ្នកទ្រុស្តសីលទាំងឡាយតាំងនៅ ។ បទថា **អថេតំ** បានដល់ បុគ្គលមិនមាំទាំ គឺបុគ្គលមានវាចាមិនពិតប្រាកដ ។

បទថា **សព្វឃាតិនំ** បានដល់ ដែលបានឱកាសហើយ ធ្វើនូវការកម្ចាត់បុគ្គលមិនរើសមុខ ។ បទថា **និសិតំវ បដិច្ឆន្នំ** បានដល់ ដូចដាវ

ដែលសំលៀងហើយ បិទបាំងដោយស្រោម ឬកំណាត់សំពត់ ដូច្នោះ ។ បទថា **តាធិសម្បិ** សេចក្ដីថា បុគ្គលមិនគួរស្និទ្ធស្នាល បុគ្គលដែលមិនមែនមិត្រ ជាមិត្រក្លែងក្លាយមានសភាពបែបនេះ ។

បទថា **សាខល្យេន** បានដល់ ដោយពាក្យដែលពីរោះ ។ បទថា **អចេតសា** បានដល់ ដែលមិនត្រូវទឹកចិត្ត ពិតហើយ វាចានៃបុគ្គលនោះប៉ុណ្ណោះពីរោះ តែចិត្តគ្រោតគ្រាត បុគ្គលពួកខ្លះក្នុងលោកនេះ រមែងសម្លឹងទោស ចូលទៅរកដោយឧបាយគ្រប់យ៉ាង ។ បទថា **តាធិសម្បិ** សេចក្ដីថា បុគ្គលណាដូចគ្នានឹងបុគ្គលមិនមែនមិត្រ ជាមិត្របូមទាំងនោះ បុគ្គលបែបនោះក៏មិនគួរស្និទ្ធស្នាល ។

បទថា **អាមិសំ** បានដល់ របស់គួរទំពា និងរបស់គួរបរិភោគ ។ បទថា **ធនំ** បានដល់ របស់ដ៏សេស តាំងអំពីជើងគ្រែឡើងទៅ ។ បទថា **យត្ថ បស្សតិ** បានដល់ ឃើញក្នុងទីណាក្នុងផ្ទះរបស់សម្លាញ់ ។ បទថា **ទុព្ភឹ ករោតិ** បានដល់ ឲ្យចិត្តប្រទូស្តកើតឡើង គឺនាំទ្រព្យនោះទៅ ។ បទថា **តញ្ច ហាត្វាន** បានដល់ លះសម្លាញ់នោះហើយទៅ ។

ស្ដេចមាន់បានពោល ៧ គាថា ដោយប្រការដូច្នេះ ។

ព្រះសាស្ដាជាធម្មរាជា ទ្រង់បានភាសិតអភិសម្ពុទ្ធ ៤ គាថាដូច្នេះថា

សត្រូវច្រើនបិទបាំង ដោយសភាពហាក់ដូចជាមិត្តមកគប់រក
បុគ្គលគប្បីលះបង់នូវបុរសអាក្រក់នោះចោលចេញ ដូចមាន់លះ
បង់ខ្លែង ។

បុគ្គលណា មិនឆាប់យល់នូវហេតុ ដែលកើតឡើង បុគ្គលនោះ រមែងលុះអំណាចសត្រូវ រមែងក្តៅក្រហាយរឿយៗ ក្នុងកាលជាខាងក្រោយ ។

បុគ្គលណា យល់ទាន់នូវហេតុដែលកើតឡើង បុគ្គលនោះ រមែងរួចផុតចាកការបៀតបៀន របស់សត្រូវដូចជាមាន់រួចអំពីខ្សែង ។ ជនមានប្រាជ្ញាវាងវៃ គប្បីវៀរអំពីចម្ងាយ នូវបុគ្គលមិនប្រកបដោយធម៌ ជាអ្នកកម្ចាត់នូវគុណ របស់បុគ្គលដទៃជានិច្ច ប្រាកដដូចជាអន្ទាក់បញ្ឆោត ដែលគេដាក់ក្នុងព្រៃ ដូចជាមាន់ វៀរខ្សែងក្នុងព្រៃឫស្សី ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ជហេ កាបុរិសេ ហេតេ** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ បណ្ឌិតគប្បីលះបុរសអាក្រក់ទាំងនោះចេញ ។ **ហិ** អក្ខរៈក្នុងគាថានេះ ត្រឹមតែជានិបាត ។

បទថា **បច្ឆា ច មនុតប្បតិ** បានដល់ រមែងក្តៅក្រហាយក្នុងកាលជាក្រោយ ។ បទថា **កូដមិវោឌ្ឌិតំ** បានដល់ ដូចអន្ទាក់ដែលគេដាក់ក្នុងព្រៃដើម្បីឲ្យម្រឹគក្នុងព្រៃមកជាប់ ដូច្នោះ ។ បទថា **និច្ចវិធំសការិនំ** បានដល់ អ្នកច្រើនដោយការកម្ចាត់ជានិច្ច ។ បទថា **វំសកាននេ** បានដល់ ក្នុងព្រៃឫស្សី ។ នរជនមានបញ្ញាជាគ្រឿងពិចារណា គួរវៀរបាបមិត្ត ដែលធ្វើនូវការកម្ចាត់ ដូចមាន់ក្នុងព្រៃឫស្សីវៀរនូវខ្សែង ដូច្នោះ ។

*ស្តេចមាន់នោះ កាលពោលគាថាហើយ ហៅខ្លែងមកសម្តែងថា បើយើងនៅក្នុងទីនេះ យើងនឹងតប-**ត**ក្នុងការធ្វើរបស់ឯង សូម្បីខ្លែង ក៏បានគេចអំពីទីនោះទៅកាន់ទីដទៃ ។*

*ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះ មកសម្តែងហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សូម្បីក្នុងកាលមុន ទេវទត្តក៏ព្យាយាមសម្លាប់តថាគតយ៉ាងនេះ ដូច្នេះហើយ ទ្រង់ប្រជុំជាតកថា ខ្លែងក្នុងកាលនោះបានមកជាទេវទត្តក្នុងកាលឥឡូវនេះ ឯស្តេចមាន់ក្នុងកាលនោះ គឺតថាគតនេះឯង ។*

**អដ្ឋកថា កុក្កុដជាតក ចប់**

# សុត្តន្តបិដក

## មដ្ឋកុណ្ឌលិជាតក

[ ៧៣១ ] ( ព្រាហ្មណ៍សួរថា ) អ្នកស្អិតស្អាង ដោយគ្រឿងប្រដាប់ មានកុណ្ឌលដ៏រលីង ទ្រទ្រង់នូវកម្រងផ្កា ប្រោះព្រំដោយខ្លឹមចន្ទន៍ក្រហម ផ្គងដៃកន្ទក់កន្ទេញ ក្នុងកណ្តាលនៃព្រៃស្មសាន តើអ្នកដល់នូវសេចក្តីទុក្ខដូចម្តេច ។

[ ៧៣២ ] ( មាណពឆ្លើយថា ) គ្រោងនៃរថ ធ្វើដោយមាស មានរស្មីភ្លឺផ្លេក កើតឡើងហើយដើម្បីខ្ញុំ ( បើ ) ខ្ញុំមិនបាននូវគូនៃកង់របស់រថនោះទេ ខ្ញុំនឹងលះបង់ជីវិត ព្រោះសេចក្តីទុក្ខនោះ ។

[ ៧៣៣ ] ( ព្រាហ្មណ៍ ... ) អ្នកចូរប្រាប់នូវរថ ដែលធ្វើដោយមាស ធ្វើដោយកែវមណី ធ្វើដោយទង់ដែង ឬធ្វើដោយប្រាក់ចុះ ខ្ញុំនឹងធ្វើរថ ( នោះ ) ឲ្យដល់អ្នក ខ្ញុំនឹងញ៉ាំងអ្នក ឲ្យបាននូវគូនៃកង់ ( នោះ ) ។

[ ៧៣៤ ] លំដាប់នោះ មាណពប្រាប់ព្រាហ្មណ៍នោះថា ព្រះចន្ទ្រ និងព្រះអាទិត្យ រុងរឿងក្នុងវិថីទាំងពីរ រថរបស់ខ្ញុំដែលធ្វើដោយមាស ទើបសមដោយគូនៃកង់ គឺព្រះចន្ទ្រ និងព្រះអាទិត្យនោះ ។

[ ៧៣៥ ] ( ព្រាហ្មណ៍ ... ) ម្នាលមាណព អ្នកណាប្រាថ្នារបស់ដែលមិនគួរប្រាថ្នា អ្នកនោះចំជាល្ងង់មែន ខ្ញុំសម្គាល់ថា អ្នកនឹងស្លាប់ អ្នកពិតជាមិនបាននូវព្រះចន្ទ្រ និងព្រះអាទិត្យឡើយ ។

[ ៧៣៦ ] ( មាណព ... ) ការចរទៅ និងចរមក ( នៃព្រះចន្ទ្រ និងព្រះអាទិត្យទាំងពីរ ) ក៏ប្រាកដវណ្ណធាតុ ( រស្មី ) ក៏ប្រាកដ វិថីទាំងពីរ ឰដ៏អាកាសនុ៎ះក៏ប្រាកដ ចំណែកខាងជនធ្វើមរណ-កាល ទៅកាន់លោកខាងមុខហើយ មិនប្រាកដទេ បណ្ដាយើង ទាំងពីរនាក់ ដែលកំពុងកន្ទក់កន្ទេញ តើអ្នកណាល្ងង់ជាង ។

[ ៧៣៧ ] ( ព្រាហ្មណ៍ ... ) ម្នាលមាណព អ្នកនិយាយត្រូវ មែន បណ្ដាយើងទាំងពីរនាក់ កំពុងកន្ទក់កន្ទេញ ខ្ញុំហ្នឹងឯង ជា បុគ្គលល្ងង់ជាង ខ្ញុំប្រាថ្នានូវកូន ដែលធ្វើមរណកាល ទៅកាន់ លោកខាងមុខ ដូចជាទារកយំទារនូវព្រះចន្ទ្រ ។

[ ៧៣៨ ] អ្នកបានស្រោចស្រពនូវខ្ញុំ ដែលភ្លើង គឺសេចក្ដីសោក កំពុងឆេះ ឲ្យស្ងប់រម្ងាប់ ញុំាងសេចក្ដីក្រវល់ក្រវាយទាំងអស់ ឲ្យរលត់ ដូចបុគ្គលយកទឹកស្រោចនូវភ្លើង ដែលឆេះនូវថ្នាំង ខ្លាញ់ ។

[ ៧៣៩ ] សរ គឺសេចក្ដីសោកណា ដែលអាស្រ័យក្នុងហឫទ័យ សរ គឺសេចក្ដីសោកនោះ ខ្ញុំបានដកចេញហើយ ខ្ញុំកាលត្រូវសេចក្ដី សោកគ្របសង្កត់ អ្នកបានបន្ទោបង់សេចក្ដីសោក ព្រោះបុត្តនោះ ហើយ ។

[ ៧៤០ ] ម្នាលមាណព ខ្ញុំនោះជាអ្នកមានសរ គឺសេចក្តីសោក ដកចេញហើយ ជាអ្នកប្រាសចាកសេចក្តីសោក មានចិត្តមិនល្អក់ ម្នាលមាណព ខ្ញុំលែងសោកស្តាយ លែងយំទួញ ព្រោះបាន ស្តាប់ពាក្យរបស់អ្នក ។

## មដ្ឋកុណ្ឌលិជាតកទី ១១ ចប់

# អដ្ឋកថា

## មដ្ឋកុណ្ឌលិជាតក

[ ៧៣១-៧៤០ ] ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធកុដុម្ពិកៈម្នាក់ ដែលមានកូនប្រុសស្លាប់ ទើបត្រាស់រឿងនេះ មានពាក្យផ្ដើមថា **អលង្កតោ មដ្ឋកុណ្ឌលី** ដូច្នេះជាដើម ។

បានឮថា ក្នុងនគរសាវត្ថី បុត្រជាទីស្រឡាញ់របស់កុដុម្ពិកៈ ដែលជាពុទ្ធុប្បដ្ឋាកម្នាក់បានស្លាប់ ។ កុដុម្ពិកៈពេញទៅដោយសេចក្ដីសោកដល់បុត្រ មិនងូតទឹក មិនបរិភោគអាហារ មិនក្រឡេកមើលការងារ មិនទៅកាន់ទីបម្រើព្រះសម្ពុទ្ធ កន្ទក់កន្ទេញតែម្យ៉ាងថា ឱ ! កូនសម្លាញ់ ឯងបានលាឪពុកទៅមុនហើយ ។

ព្រះសាស្ដាទ្រង់ប្រមើលមើលសត្វលោកក្នុងវេលាទៀបភ្លឺ ទ្រង់ឃើញឧបនិស្ស័យសោតាបត្តិផលរបស់កុដុម្ពិកៈនោះ លុះភ្លឺឡើង ទ្រង់ចោមរោមទៅដោយភិក្ខុសង្ឃ យាងបិណ្ឌបាតក្នុងនគរសាវត្ថី លុះឆាន់ស្រេច ទ្រង់បញ្ជូនភិក្ខុទាំងឡាយត្រឡប់ ទ្រង់មានព្រះអានន្ទជាបច្ឆាសមណៈ បានយាងទៅកាន់ទ្វារផ្ទះកុដុម្ពិកៈនោះ មនុស្សទាំងឡាយប្រាប់កុដុម្ពិកៈថា ព្រះសាស្ដាយាងមកលំដាប់នោះ មនុស្សក្នុងផ្ទះរបស់កុដុម្ពិកៈបានក្រាលអាសនៈ ហើយនិមន្តព្រះសាស្ដាឲ្យគង់ នាំគ្នាគ្រាហ៍កុដុម្ពិកៈមកគាល់ព្រះសាស្ដា កុដុម្ពិកៈថ្វាយបង្គំហើយ អង្គុយនៅក្នុងចំណែកម្ខាង ។ ព្រះសាស្ដាទ្រង់មានព្រះវាចាដ៏ស្រទន់ប្រកបដោយព្រះករុណាថា ឧបាសក អ្នកសោយសោកដល់បុត្រឬ កាលកុដុម្ពិកៈក្រាបទូលថា ករុណាព្រះអង្គ ទើបព្រះសាស្ដាត្រាស់ថា ម្នាល

ឧបាសក បុរាណកបណ្ឌិត កាលកូនស្លាប់ ដល់ព្រមដោយសេចក្ដីសោក ត្រាច់ទៅ លុះបានស្ដាប់ពាក្យរបស់បណ្ឌិតតាមសេចក្ដីពិតថា ជាឋានៈដែលមិនគួរបាន ហើយក៏មិនបានសោយសោកដល់បុត្រឡើយ កុដុម្ពិកៈនោះទូលអារាធនាឲ្យទ្រង់ត្រាស់រឿងនោះ ហើយទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិក្នុងនគរពារាណសី កូនរបស់ព្រាហ្មណ៍អ្នកមានសម្បត្តិច្រើនម្នាក់ កាលអាយុបាន ១៥-១៦ ឆ្នាំ ត្រូវព្យាធិឯណានីមួយបៀតបៀន ស្លាប់ទៅកើតក្នុងទេវលោក តាំងអំពីកូននោះស្លាប់ ព្រាហ្មណ៍ទៅកាន់ឈាបនដ្ឋាន អង្គុយត្អូញគំនរផេះ កន្ទក់កន្ទេញ លះបង់ការងារគ្រប់យ៉ាង មានតែសេចក្ដីសោក ៗ ទេវបុត្រពិចារណាឃើញដូច្នោះ ត្រិះរិះថា អញនឹងធ្វើឧបមាណាមួយ រម្ងាប់នូវសេចក្ដីសោក កាលព្រាហ្មណ៍ទៅព្រៃខ្មោចយំសោក ទើបកាឡាខ្លួនជាកូនរបស់ព្រាហ្មណ៍នោះ ប្រដាប់ដោយអាករណៈគ្រប់យ៉ាង ឈរក្នុងទីមួយកន្លែង យកដៃទាំង ២ ដាក់លើក្បាលទ្រហោយំដោយសំឡេងខ្លាំង ៗ ព្រាហ្មណ៍បានឮសំឡេង ទើបសម្លឹងមើលបុត្រកាឡាខ្លួននោះ ក៏បាននូវសេចក្ដីស្រឡាញ់ដូចបុត្រ ទើបចូលទៅជិតទេវបុត្រ កាលសួរថា នៃមាណព ហេតុអ្វី ទើបឯងមកយំកណ្ដាលព្រៃខ្មោចនេះ ហើយពោលគាថាដំបូងថា

អ្នកស្អិតស្អាង ដោយគ្រឿងប្រដាប់ មានកុណ្ឌលដ៏រលីង ទ្រទ្រង់នូវកម្រងផ្កា ប្រោះព្រំដោយខ្លឹមចន្ទន៍ក្រហម ផ្គងដៃកន្ទក់កន្ទេញ

ក្នុងកណ្តាលនៃព្រៃស្មសាន តើអ្នកដល់នូវសេចក្តីទុក្ខដូចម្តេច ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អលង្កតោ** បានដល់ ប្រដាប់ដោយអាភរណៈផ្សេងៗ ។ បទថា **មដ្ឋកុណ្ឌលី** បានដល់ ប្រកបដោយកុណ្ឌលរលើង ដែលមានរូបរាងសម្រេចហើយ ។ បទថា **មាលធារី** បានដល់ ទ្រទ្រង់នូវកម្រងផ្កាដ៏វិចិត្រ ។ បទថា **ហរិចន្ទនុស្សទោ** បានដល់ លាបដោយខ្លឹមចន្ទន៍ដែលមានពណ៌ដូចមាស ។ បទថា **វនមជ្ឈេ** បានដល់ ក្នុងព្រៃខ្មោច ។ បទថា **កឹ ទុក្ខិតោ តុវំ** សេចក្តីថា ព្រាហ្មណ៍ពោលថា អ្នកមានសេចក្តីទុក្ខអ្វីឬ ចូរប្រាប់មកចុះ យើងនឹងឲ្យវត្ថុដែលឯងត្រូវការ ។ គ្រានោះ ទេវបុត្តមាណព កាលនឹងប្រាប់ដល់ព្រាហ្មណ៍ បានពោលគាថាទី ២ ថា

គ្រោងនៃរថ ធ្វើដោយមាស មានរស្មីភ្លឺផ្លេក កើតឡើងហើយ ដើម្បីខ្ញុំ ( បើ ) ខ្ញុំមិនបាននូវគូនៃកង់របស់រថនោះទេ ខ្ញុំនឹងលះបង់ជីវិត ព្រោះសេចក្តីទុក្ខនោះ ដូច្នេះ ។

កាលព្រាហ្មណ៍ទទួលរកឲ្យ ទើបពោលគាថាទី ៣ ថា

អ្នកចូរប្រាប់នូវរថ ដែលធ្វើដោយមាស ធ្វើដោយកែវមណី ធ្វើដោយទង់ដែង ឬធ្វើដោយប្រាក់ចុះ ខ្ញុំនឹងធ្វើរថ ( នោះ ) ឲ្យដល់អ្នក ខ្ញុំនឹងញ៉ាំងអ្នក ឲ្យបាននូវគូនៃកង់ ( នោះ ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ចាវឧ** សេចក្តីថា អ្នកត្រូវការរថប្រភេទណា ពេញចិត្តរថប្រភេទណា ចូរប្រាប់រថប្រភេទនោះចុះ យើងនឹងធ្វើរថឲ្យ

អ្នក ។ បទថា **បដិចាទយាមិ** បានដល់ យើងនឹងឲ្យអ្នកបានទទួលនូវកង់ទាំងគូដ៏សមគួរដល់គ្រោងរថ ។

ព្រះសាស្តាត្រាស់ដឹងហើយ បានត្រាស់ដោយគាថាដែលមាណពបានស្តាប់បិតាហើយ ពោលគាថានេះថា

លំដាប់នោះ មាណពប្រាប់ព្រាហ្មណ៍នោះថា ព្រះចន្ទ្រ និងព្រះអាទិត្យ រុងរឿងក្នុងវិថីទាំងពីរ រថរបស់ខ្ញុំដែលធ្វើដោយមាស ទើបសមដោយគូនៃកង់ គឺព្រះចន្ទ្រ និងព្រះអាទិត្យនោះ ដូច្នេះ ។

ព្រាហ្មណ៍ក៏ពោលគាថាដ៏សេសបន្ទាប់អំពីនោះថា

ម្នាលមាណព អ្នកណាប្រាថ្នា របស់ដែលមិនគួរប្រាថ្នា អ្នកនោះចំជាល្ងង់មែន ខ្ញុំសម្គាល់ថា អ្នកនឹងស្លាប់ អ្នកពិតជាមិនបាននូវព្រះចន្ទ្រ និងព្រះអាទិត្យឡើយ ដូច្នេះ ។

គប្បីជ្រាបអធិប្បាយក្នុងគាថា ដែលព្រាហ្មណ៍ពោលដូច្នេះថា បណ្តាបទទាំងនោះ បទថា **អបត្ថយំ** បានដល់ ដែលគេមិនគប្បីប្រាថ្នា ។

លំដាប់នោះ មាណពក៏ពោលគាថាបន្ទាប់ថា

ការចរទៅ និងចរមក ( នៃព្រះចន្ទ្រ និងព្រះអាទិត្យទាំងពីរ ) ក៏ប្រាកដវណ្ណធាតុ ( រស្មី ) ក៏ប្រាកដ វិថីទាំងពីរឰដ៏អាកាសទុំះ ក៏ប្រាកដ ចំណែកខាងជនធ្វើមរណកាល ទៅកាន់លោកខាងមុខហើយ មិនប្រាកដទេ បណ្តាយើងទាំងពីរនាក់ ដែលកំពុងកន្ទក់កន្ទេញ តើអ្នកណាល្ងង់ជាង ដូច្នេះ ។

គប្បីជ្រាបអធិប្បាយក្នុងគាថាដែលមាណពពោលដូច្នេះថា ការរះ និងការលិច ឈ្មោះថា **គមនាគមនំ** ក្នុងគាថានោះ ។ ពណ៌នោះឯង ឈ្មោះថា **វណ្ណធាតុ**។ ក្នុងពាក្យថា **ឧភយេត្ថ វីថិយោ** នេះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះថា ភូមិជាទីទៅ និងជាទីមកនៃព្រះចន្ទ និងព្រះអាទិត្យទាំង ២ រមែងប្រាកដក្នុងអាកាសថា នេះជាវិថីរបស់ព្រះចន្ទ នេះជាវិថីរបស់ព្រះអាទិត្យ ។

បទថា **បេតោ បន** សេចក្តីថា ចំណែកសត្វដែលទៅហើយកាន់បរលោករមែងមិនប្រាកដឡើយ ។ បទថា **កោ នុ ខោ** សេចក្តីថា កាលបើដូច្នោះបណ្តាយើង ២ នាក់ អ្នកណាល្ងង់ខ្លៅជាងអ្នកណា កាលមាណពពោលយ៉ាងនេះ ព្រាហ្មណ៍កំណត់មិនបាន ទើបពោលគាថានេះថា

ម្នាលមាណព អ្នកនិយាយត្រូវមែន បណ្តាយើងទាំងពីរនាក់
កំពុងកន្ទក់កន្ទេញ ខ្ញុំហ្នឹងឯង ជាបុគ្គលល្ងង់ជាង ខ្ញុំប្រាថ្នានូវកូន
ដែលធ្វើមរណកាល ទៅកាន់លោកខាងមុខ ដូចជាទារកយំទារនូវ
ព្រះចន្រ្ទ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ចន្ទំ វិយ ទារកោ** សេចក្តីថា ក្មេងអ្នកស្រុកដែលនៅក្មេង គប្បីយំត្រូវការព្រះចន្ទ ដោយពោលថា អ្នកទាំងឡាយចូរឲ្យព្រះចន្ទដល់ខ្ញុំចុះ ដូច្នេះយ៉ាងណា ខ្ញុំក៏ប្រាថ្នាអ្នកស្លាប់ ទៅកាន់បរលោកហើយ ដូច្នោះដូចគ្នា ។

ព្រាហ្មណ៍ស្បើយនូវសេចក្តីសោក ដោយពាក្យរបស់មាណព កាលនឹងពោលសរសើរមាណព ទើបពោលគាថាដ៏សេសថា

អ្នកបានស្រោចស្រពនូវខ្ញុំ ដែលភ្លើង គឺសេចក្តីសោក កំពុងឆេះ ឲ្យស្ងប់រម្ងាប់ ញុំាងសេចក្តីក្រវល់ក្រវាយទាំងអស់ឲ្យរលត់ ដូចបុគ្គលយកទឹកស្រោចនូវភ្លើង ដែលឆេះនូវថ្នាំងខ្លាញ់ ។ សរ គឺសេចក្តីសោកណា ដែលអាស្រ័យក្នុងហឫទ័យ សរ គឺសេចក្តីសោកនោះ ខ្ញុំបានដកចេញហើយ ខ្ញុំកាលត្រូវសេចក្តីសោកគ្របសង្កត់ អ្នកបានបន្ទោបង់សេចក្តីសោក ព្រោះបុត្តនោះហើយ ។

ម្នាលមាណព ខ្ញុំនោះជាអ្នកមានសរ គឺសេចក្តីសោក ដកចេញហើយ ជាអ្នកប្រាសចាកសេចក្តីសោក មានចិត្តមិនល្អក់ ម្នាលមាណព ខ្ញុំលែងសោកស្តាយ លែងយំទួញ ព្រោះបានស្តាប់ពាក្យរបស់អ្នក ដូច្នេះ ។

លំដាប់នោះ មាណពពោលទូន្មានព្រាហ្មណ៍ថា នែព្រាហ្មណ៍ អ្នកយំដើម្បីបុត្រណា បុត្រនោះ គឺខ្លួនខ្ញុំជាបុត្ររបស់អ្នក ខ្ញុំកើតក្នុងទេវលោក តាំងអំពីនេះទៅ អ្នកកុំសោយសោកដល់ខ្ញុំឡើយ ចូរឲ្យទាន រក្សាសីល ធ្វើឧបោសថកម្ម ដូច្នេះហើយ ទៅកាន់វិមានរបស់ខ្លួន ព្រាហ្មណ៍ក៏តាំងនៅក្នុងឱវាទរបស់មាណពនោះ ធ្វើបុណ្យ មានឲ្យទានជាដើម ស្លាប់ហើយ ទៅកើតក្នុងទេវលោក ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះ មកសម្តែងហើយ ទ្រង់ប្រកាសសច្ចធម៌ ក្នុងកាលចប់សច្ចៈ កុដុម្ពិកៈតាំងនៅក្នុងសោតាបត្តិផល ព្រះទសពលទ្រង់សមោធានជាតកថា ទេវបុត្រអ្នកសម្តែងធម៌ក្នុងកាលនោះ គឺតថាគតនេះឯង ។ល។

## អដ្ឋកថា មដ្ឋកុណ្ឌលិជាតក ចប់

# សុត្តន្តបិដក

## ពិលារកោសិយជាតក

[ ៧៤១ ] ( ឥន្ទ្រព្រាហ្មណ៍ពោលថា ) សប្បុរសទាំងឡាយ ទោះបីមិនបានចម្អិន តែបើបានភោជនហើយ ក៏ប្រាថ្នាឲ្យដែរ អ្នកកាលចម្អិន មិនឲ្យភោជនណា ការមិនឲ្យភោជននោះ មិនសមគួរទេ ។

[ ៧៤២ ] បុគ្គលមិនឲ្យទាន ( ដោយហេតុ ២ យ៉ាង គឺ ) សេចក្តីកំណាញ់ ១ សេចក្តីប្រហែស ១ បុគ្គលអ្នកចេះដឹង កាលប្រាថ្នានូវបុណ្យ រមែងឲ្យទាន ។

[ ៧៤៣ ] ( ចន្ទព្រាហ្មណ៍ពោលថា ) បុគ្គលកំណាញ់ ខ្លាចចំពោះសេចក្តីឃ្លាន និងការស្រេកណាហើយ រមែងឲ្យទានមិនកើតទេ សេចក្តីឃ្លាន និងការស្រេកនោះ ជាភ័យរបស់បុគ្គលអ្នកមិនឲ្យ បុគ្គលកំណាញ់ រមែងខ្លាចអំពីសេចក្តីឃ្លាន និងការស្រេកណា សេចក្តីឃ្លាន និងការស្រេកនោះ រមែងប៉ះពាល់នូវបុគ្គលពាលនោះឯង ក្នុងលោកនេះផង ក្នុងលោកខាងមុខផង ។

[ ៧៤៤ ] ព្រោះហេតុនោះ បុគ្គលគប្បីបន្ទោបង់នូវសេចក្តីកំណាញ់ចេញ គប្បីគ្របសង្កត់នូវមន្ទិល គឺសេចក្តីកំណាញ់ ហើយឲ្យនូវទាន ព្រោះថា បុណ្យ រមែងបានជាទីពឹងរបស់សត្វទាំងឡាយ ក្នុងលោកខាងមុខ ។

[ ៧៤៥ ] ( សុរិយព្រាហ្មណ៍ពោលថា ) ពួកជនជាសប្បុរស ឲ្យនូវវត្ថុ ដែលគេឲ្យបានដោយក្រ ធ្វើនូវអំពើដែលគេធ្វើបាន ដោយក្រ ឯពួកអសប្បុរស រមែងមិនធ្វើតាមឡើយ ធម៌របស់ សប្បុរស គឺអសប្បុរសយល់បានដោយក្រ ។

[ ៧៤៦ ] ព្រោះហេតុនោះ គតិរបស់ពួកសប្បុរស និងអសប្បុរស រមែងបែកផ្សេងគ្នាអំពីលោកនេះ គឺពួកអសប្បុរសរមែងទៅកាន់ នរក ពួកសប្បុរសរមែងមានឋានសួគ៌ប្រព្រឹត្តទៅក្នុងខាងមុខ ។

[ ៧៤៧ ] ( មាតលិព្រាហ្មណ៍ពោលថា ) បណ្ឌិតបុរសពួកខ្លះ សូម្បីមានទេយ្យធម៌បន្តិចបន្តួច ក៏រមែងធ្មៀតឲ្យបាន តែបុរសពួក ខ្លះ ( សូម្បីបរិបូណ៌ ) ដោយទេយ្យធម៌ដ៏ច្រើន ក៏ឲ្យមិនបាន ទក្ខិណាទានដែលបុគ្គល ( រំលែក ) អំពីវត្ថុមានប្រមាណតិច ហើយឲ្យ រាប់ស្មើដោយទានមានប្រមាណច្រើន ។

[ ៧៤៨ ] ( បញ្ចសិខព្រាហ្មណ៍ពោលថា ) បុគ្គលណាប្រព្រឹត្ត ស្វែងរកអាហារ មកចិញ្ចឹមនូវកូន និងប្រពន្ធផង ឲ្យទានសូម្បី បន្តិចបន្តួចផង បុគ្គលនោះឈ្មោះថាប្រព្រឹត្តធម៌ បុគ្គលជាឥស្សរៈ ទាំងសែនទាក់ ជាអ្នកបូជាទាំងពាន់នោះ មិនដល់នូវចំណិតរបស់ អ្នកកម្សត់ ដែលឲ្យទានដោយធម៌ មានឧបការដូច្នោះឡើយ ។

[ ៧៤៩ ] ( ពិលារកោសិយសេដ្ឋីសួរថា ) យញ្ញៈ គឺការបូជា នុ៎ះ ជាបូជាដ៏ទូលាយ មានថ្លៃក៏ច្រើន ហេតុអ្វីទើបមិនដល់នូវថ្លៃ

នៃទានដែលបុគ្គលឲ្យហើយតាមធម៌ដ៏ត្រឹមត្រូវ ហេតុអ្វី បុគ្គលជាឥស្សរៈទាំងសែននាក់ ជាអ្នកបូជាទាំងពាន់នោះ មិនដល់នូវចំណិតរបស់អ្នកកម្សត់ដែលឲ្យទានដោយធម៌ មានបការដូច្នោះ ។

[ ៧៥០ ] ( បញ្ចសិខៈ ... ) ព្រោះថា បុគ្គលពួកខ្លះ តាំងនៅក្នុងកាយកម្មជាដើមមិនស្មើគ្នា បៀតបៀន សម្លាប់ ឬក៏ធ្វើគេឲ្យសោកសៅ ហើយទើបឲ្យ ( នូវទក្ខិណាទាន ) ទក្ខិណាទាននោះ ឈ្មោះថា មានមុខជោកដោយទឹកភ្នែក ប្រកបដោយអាជ្ញា រមែងមិនដល់នូវតម្លៃនៃទានដែលបុគ្គលឲ្យ ដោយធម៌ដ៏ត្រឹមត្រូវទេ បុគ្គលជាឥស្សរៈទាំងសែននាក់ ជាអ្នកបូជាទាំងពាន់នោះ មិនដល់នូវចំណិតរបស់អ្នកកម្សត់ ដែលឲ្យទានដោយធម៌ មានបការដូច្នោះ ។

## ពិលារកោសិយជាតកទី ១២ ចប់

# អដ្ឋកថា

## ពិលារកោសិយជាតក

[ ៧៤១-៧៥០ ] ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុ អ្នកមានទានជាគ្រឿងត្រេកអរមួយរូប ទើបត្រាស់រឿងនេះ មានពាក្យផ្ដើមថា **អបចន្តាបិ** ដូច្នេះជាដើម ។

បានឮថា ភិក្ខុនោះ ស្ដាប់ព្រះធម្មទេសនារបស់ព្រះសាស្ដាហើយ បួសក្នុងព្រះសាសនា ចាប់តាំងពីបួសហើយ ជាអ្នកមានទានជាគ្រឿងត្រេកអរ មានអធ្យាស្រ័យត្រេកអរក្នុងការឲ្យទាន បើមិនទាន់ឲ្យបិណ្ឌបាត ដែលធ្លាក់ក្នុងបាត្រដល់អ្នកដទៃជាមុន ក៏មិនឆាន់ ដោយហោចសូម្បីតែទឹកផឹក បើមិនទាន់ឲ្យដល់អ្នកដទៃក៏មិនផឹក ជាអ្នកត្រេកអរក្រៃលែងដោយទាន ដោយអាការយ៉ាងនេះ ។

កាលនោះ ភិក្ខុទាំងឡាយ នាំគ្នាពណ៌នាគុណរបស់ភិក្ខុរូបនោះ ក្នុងធម្មសភា ព្រះសាស្ដាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នា ដោយរឿងអ្វី កាលភិក្ខុនោះក្រាបទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើបទ្រង់ត្រាស់ឲ្យហៅភិក្ខុនោះមក សួរថា ម្នាលភិក្ខុ បានឮថា អ្នកមានទានជាគ្រឿងត្រេកអរ មានអធ្យាស្រ័យត្រេកអរក្នុងការឲ្យទានពិតឬ កាលភិក្ខុនោះក្រាបទូលថា ករុណាព្រះអង្គ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលមុន ភិក្ខុនេះ មិនមានសទ្ធាមិនមានសេចក្ដីជ្រះថ្លា សូម្បីតែតំណក់ប្រេង ក៏មិនយកចុងស្បូវជ្រលក់ឲ្យជាទាន កាលនោះ តថាគតទូន្មានធ្វើឲ្យអស់ព្យសន៍ ឲ្យតាំងនៅក្នុងផលនៃទាន

សូម្បីក្នុងភពបន្តៗ មក ក៏គង់មិនលះទានវត្តនេះបាន ភិក្ខុទាំងឡាយទូល អារាធនា ឲ្យទ្រង់ត្រាស់រឿងនោះ ទើបទ្រង់នាំរឿងក្នុងអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលសេដ្ឋី ចម្រើនវ័យហើយ ប្រមូលទ្រព្យជាច្រើន កាលបិតាអនិច្ចកម្មទៅ ក៏បានតំណែងសេដ្ឋី ថ្ងៃមួយ សម្លឹងមើលទ្រព្យសម្បត្តិហើយ គិតថា ទ្រព្យនៅប្រាកដនៅឡើយ តែអ្នកធ្វើឲ្យទ្រព្យកើតឡើងមិនប្រាកដ អញគួរលះទ្រព្យនេះឲ្យជាទាន ទើបឲ្យសាងរោងទាន បំពេញទានជាធំ ដរាបដល់អស់ជីវិត កាលអស់អាយុ បានឲ្យឱវាទដល់កូនថា ឯងកុំកាត់នូវទានវត្តនេះចោល ហើយស្លាប់ទៅកើតជាសក្កទេវរាជក្នុងតាវត្តិង្សពិភព ។ បុត្ររបស់សេដ្ឋីនោះ ក៏បានឲ្យទានយ៉ាងនោះដូចគ្នា ហើយពោលទូន្មានបុត្រ ក្នុងកាលដែលខ្លួនអស់អាយុ បានកើតជាចន្ទទេវបុត្រ កូនរបស់សេដ្ឋីបន្តមកទៀត បានជាសុរិយទេវបុត្រ កូនសេដ្ឋីបន្តមកទៀត បានជាមាតលិសង្គាហកទេវបុត្រ កូនបន្តមកទៀត បានកើតជាគន្ធព្វទេវបុត្រ ឈ្មោះបញ្ចសិខៈ ។ តែកូនជំនាន់ទី ៦ ជាអ្នកមិនមានសទ្ធា មានចិត្តរឹងត្អឹង មិនស្រឡាញ់ក្នុងការឲ្យទាន ជាអ្នកកំណាញ់ ។ គាត់ឲ្យមនុស្សរើរោងទានដុតចោល ឲ្យវាយពួកស្មូមយាចក សូម្បីតំណក់ប្រេងមួយតំណក់ ដែលជ្រលក់ដោយចុងស្បូវ ក៏មិនឲ្យដល់បុគ្គលណា ។

ក្នុងកាលនោះ សក្កទេវរាជ សម្លឹងមើលបុព្វកម្មរបស់ទ្រង់ ពិចារណា

ថា ទានវង្សរបស់អញ នៅប្រព្រឹត្តទៅដែរឬហ្ន៎ ទ្រង់ជ្រាបថា បុត្ររបស់អញ បំពេញទាន កើតជាចន្ទទេវបុត្រ បុត្ររបស់ចន្ទទេវបុត្រ កើតជាសុរិយទេវ-បុត្រ បុត្ររបស់សុរិយទេវបុត្រ កើតជាមាតលិទេវបុត្រ បុត្ររបស់មាតលិ-ទេវបុត្រ កើតជាបញ្ចសិខទេវបុត្រ តែបុត្រជំនាន់ទី ៦ ក៏បានកាត់ទានវង្ស នោះចោល ។ កាលនោះ សក្កៈទ្រង់ព្រះតម្រិះថា អញទៅទូន្មានសេដ្ឋីដែល មានចិត្តលាមកនេះឲ្យស្គាល់ផលទាន ហើយនឹងមក ទើបទ្រង់ត្រាស់ឲ្យហៅ ចន្ទសុរិយមាតលិ និងបញ្ចសិខទេវបុត្រមកត្រាស់ថា នែសម្លាញ់ សេដ្ឋីទី ៦ ក្នុងវង្សរបស់ពួកយើង កាត់វង្សត្រកូលហើយ ឲ្យដុតរោងទាន ឲ្យបណ្ដេញ ពួកស្មូមយាចក មិនឲ្យរបស់ណាមួយដល់អ្នកដទៃ មកលោកទាំងឡាយ ពួក យើងនឹងទូន្មានសេដ្ឋីនោះ ដូច្នេះហើយ បានយាងទៅកាន់ក្រុងពារាណសី មួយ អន្លើដោយទេវបុត្រទាំង ៤ នោះ ។

ខណៈនោះ សេដ្ឋីទៅគាល់ព្រះរាជា ហើយមកសម្លឹងមើលក្នុងរវាងផ្លូវ ត្រង់ខ្លោងទ្វារទី ៧ ។ សក្កទេវរាជត្រាស់នឹងទេវបុត្រទាំង ៤ ថា ពេលដែល សេដ្ឋីនេះចូលទៅហើយ អ្នកទាំងឡាយ ចូរតាមពីក្រោយទៅតាមលំដាប់ ដូច្នេះហើយ ទៅឈរក្នុងសម្នាក់សេដ្ឋី ពោលថា បពិត្រលោកសេដ្ឋី សូម លោកឲ្យភោជនដល់ខ្ញុំខ្លះ សេដ្ឋីពោលថា នែព្រាហ្មណ៍ ទីនេះ មិនមានភត្ត សម្រាប់លោកទេ សូមលោកទៅកាន់ទីដទៃចុះ សក្កទេវរាជត្រាស់ថា បពិត្រ លោកសេដ្ឋី កាលព្រាហ្មណ៍ទាំងឡាយសូមនូវភត្ត លោកគួរតែឲ្យ សេដ្ឋី ឆ្លើយថា នែព្រាហ្មណ៍ ភត្តចម្អិនហើយក្ដី ដែលនឹងត្រូវចម្អិនក្ដី មិនមានក្នុងផ្ទះ

របស់យើងទេ សូមលោកទាំងឡាយទៅកាន់ទីដទៃចុះ សក្កទេវរាជត្រាស់ថា លោកសេដ្ឋី ខ្ញុំនឹងពោលសរសើរទានម្យ៉ាង សូមលោកស្តាប់ សេដ្ឋីឆ្លើយថា ខ្ញុំមិនត្រូវការសរសើររបស់លោកទេ សូមលោកទៅចុះ កុំឈរក្នុងទីនេះអី សក្កទេវរាជធ្វើជាមិនឮពាក្យរបស់សេដ្ឋី បានត្រាស់ ២ គាថាថា

សប្បុរសទាំងឡាយ ទោះបីមិនបានចម្អិន តែបើបានភោជន
ហើយ ក៏ប្រាថ្នាឲ្យដែរ អ្នកកាលចម្អិនមិនឲ្យភោជនណា ការមិន
ឲ្យភោជននោះ មិនសមគួរទេ ។

បុគ្គលមិនឲ្យទាន ( ដោយហេតុ ២ យ៉ាង គឺ ) សេចក្តីកំណាញ់
១ សេចក្តីប្រហែស ១ បុគ្គលអ្នកចេះដឹង កាលប្រាថ្នានូវបុណ្យ
រមែងឲ្យទាន ដូច្នេះ ។

សេចក្តីនៃគាថាទាំងនោះ ដូច្នេះថា លោកសេដ្ឋីដ៏ចម្រើន សប្បុរសទាំងឡាយស្ងប់ហើយ សូម្បីមិនចម្អិនបរិភោគឯង ក៏ប្រាថ្នាឲ្យភោជនដែលបានមកហើយ ដោយភិក្ខាចារ រមែងមិនបរិភោគម្នាក់ឯង ។

បទថា **កិរមេវ តុំ** សេចក្តីថា ទាំងដែលលោកចម្អិនក៏មិនឲ្យ ។ បទថា **ឆ តំ សមំ** សេចក្តីថា ការដែលលោកមិនឲ្យនោះ មិនសមគួរ គឺមិនសមដល់លោក ។ បុគ្គលឲ្យទានមិនបានដោយហេតុ ២ យ៉ាង គឺសេចក្តីកំណាញ់ ១ សេចក្តីប្រមាទ ១ ។ មនុស្សដែលជាបណ្ឌិត ដែលដឹងច្បាស់ ដូចគ្នានឹងលោក កាលត្រូវការបុណ្យ គួរឲ្យទាននោះឯង ។

សេដ្ឋីបានស្តាប់ពាក្យសក្កៈហើយ ពោលថា បើដូច្នោះ សូមលោកចូលទៅអង្គុយក្នុងផ្ទះចុះ នឹងបានបន្តិចបន្តួច សក្កៈបានចូលទៅអង្គុយ ហើយបានសូធ្យសរសើរ លំដាប់នោះ ចន្ទទេវបុត្រ បានមកសូមកត្តនឹងសេដ្ឋីនោះ កាលសេដ្ឋីពោលថា កត្តសម្រាប់លោកមិនមាន ចូរទៅចុះ ទើបពោលថា លោកសេដ្ឋី ព្រាហ្មណ៍ម្នាក់អង្គុយខាងក្នុងផ្ទះ ប្រហែលជាមានព្រាហ្មណសូត្រទេដឹង ខ្ញុំនឹងទៅសូធ្យដែរ សេដ្ឋីពោលថា មិនមានព្រាហ្មណសូត្រទេ ចូរអ្នកចេញទៅ ចន្ទទេវបុត្រពោលថា បពិត្រមហាសេដ្ឋី សូមលោកស្តាប់បទសរសើរសិន ហើយបានពោល ២ គាថាថា

បុគ្គលកំណាញ់ ខ្លាចចំពោះសេចក្តីឃ្លាន និងការស្រេកណាហើយ រមែងឲ្យទានមិនកើតទេ សេចក្តីឃ្លាន និងការស្រេកនោះជាភ័យរបស់បុគ្គលអ្នកមិនឲ្យ បុគ្គលកំណាញ់ រមែងខ្លាចអំពីសេចក្តីឃ្លាន និងការស្រេកណា សេចក្តីឃ្លាន និងការស្រេកនោះ រមែងប៉ះពាល់នូវបុគ្គលពាលនោះឯង ក្នុងលោកនេះផងក្នុងលោកខាងមុខផង ។

ព្រោះហេតុនោះ បុគ្គលគប្បីបន្ទោបង់នូវសេចក្តីកំណាញ់ចេញ គប្បីគ្របសង្កត់នូវមន្ទិល គឺសេចក្តីកំណាញ់ ហើយឲ្យនូវទាន ព្រោះថា បុណ្យ រមែងបានជាទីពឹងរបស់សត្វទាំងឡាយ ក្នុងលោកខាងមុខ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យស្ស ភាយតិ** សេចក្តីថា រមែងខ្លាចចំពោះការស្រេកឃ្លានណាថា ខ្ញុំឲ្យដល់ជនដទៃហើយ នឹងក្លាយជាបុគ្គល

ស្រេកឃ្លានឯង ។ បទថា **តមេវ** ជាដើម សេចក្តីថា ភ័យ ពោល គឺការស្រេកឃ្លាននោះឯង នឹងត្រឡប់មកពាល់ត្រូវ គឺបៀតបៀនបុគ្គលពាលនោះទាំងក្នុងលោកនេះ និងលោកខាងមុខ ក្នុងទីដែលបុគ្គលនេះកើតហើយ បុគ្គលនោះនឹងដល់នូវការអត់ឃ្លានបំផុត ។ បទថា **មលាភិភូ** សេចក្តីថា គ្របសង្កត់មន្ទិល គឺសេចក្តីកំណាញ់ ។

សេដ្ឋីបានស្តាប់ពាក្យរបស់ចន្ទទេវបុត្រនោះហើយ ពោលថា បើដូច្នោះសូមលោកចូលទៅ នឹងបានបន្តិច ។ ចន្ទទេវបុត្រ ចូលទៅអង្គុយជិតសក្កទេវរាជ បន្ទាប់ពីនោះ សុរិយទេវបុត្រឲ្យពេលវេលាកន្លងទៅបន្តិច ហើយចូលមក កាលសូមនូវភត្តបានពោល ២ គាថាថា

ពួកជនជាសប្បុរសឲ្យនូវវត្ថុ ដែលគេឲ្យបានដោយក្រ ធ្វើនូវអំពើដែលគេធ្វើបានដោយក្រ ឯពួកអសប្បុរស រមែងមិនធ្វើតាមឡើយ ធម៌របស់សប្បុរស គឺអសប្បុរសយល់បានដោយក្រ ។

ព្រោះហេតុនោះ គតិរបស់ពួកសប្បុរស និងអសប្បុរស រមែងបែកផ្សេងគ្នាអំពីលោកនេះ គឺពួកអសប្បុរស រមែងទៅកាន់នរក ពួកសប្បុរស រមែងមានឋានសួគ៌ប្រព្រឹត្តទៅក្នុងខាងមុខ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ទុទ្ទទំ** សេចក្តីថា ឈ្មោះថា ទាន បុគ្គលឲ្យបានដោយលំបាក ព្រោះបុគ្គលដែលឲ្យទាននោះ ត្រូវគ្របសង្កត់នូវសេចក្តីកំណាញ់ជាមុនសិន ទើបឲ្យបាន ។ បទថា **ទុក្ករំ** សេចក្តីថា ការធ្វើទាននោះធ្វើលំបាកពិត ដូចគ្នានឹងការច្បាំង ។ បាទគាថាថា **អសន្តោ នានុកុព្វន្តិ**

សេចក្តីថា ពួកអសប្បុរសមិនដឹងនូវផលនៃទាន ក៏មិនដើរតាមផ្លូវ ដែលពួកសប្បុរសទាំងនោះដើរទៅហើយ ។ បទថា **សតំ ធម្មោ** សេចក្តីថា ធម៌របស់សប្បុរស គឺព្រះពោធិសត្វទាំងឡាយ អ្នកដទៃដឹងបានលំបាក ។ បទថា **អសន្តោ** សេចក្តីថា ពួកអសប្បុរសមិនឲ្យទាន ដោយអំណាចនៃសេចក្តីកំណាញ់ រមែងទៅកាន់នរក ។

សេដ្ឋីមិនឃើញវត្ថុដែលគួរបៀបចឲ្យទៅបាន ទើបពោលថា បើដូច្នោះសូមលោកចូលទៅអន្តុយក្នុងសម្នាក់ព្រាហ្មណ៍ទាំងឡាយ នឹងបានបន្តិច ។ បន្ត អំពីនោះ មាតលិទេវបុត្រឲ្យពេលវេលាកន្លងទៅបានបន្តិចហើយ ចូលមកសូមកត្តក្នុងចន្លោះ កាលសេដ្ឋីឆ្លើយថា មិនមាននោះឯង បានពោលគាថាទី ៧ ថា

បណ្ឌិតបុរសពួកខ្លះ សូម្បីមានទេយ្យធម៌បន្តិចបន្តួច ក៏រមែងធ្វៀតឲ្យបាន តែបុរសពួកខ្លះ ( សូម្បីបរិបូណ៌ ) ដោយទេយ្យធម៌ដ៏ច្រើន ក៏ឲ្យមិនបាន ទក្ខិណាទានដែលបុគ្គល ( រំលែក ) អំពីវត្ថុមានប្រមាណតិច ហើយឲ្យ រាប់ស្មើដោយទាន មានប្រមាណច្រើន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អប្បស្មេកេ បវេច្ឆន្តិ** អធិប្បាយថា បពិត្រលោកសេដ្ឋី បុរសដែលជាបណ្ឌិតពួកខ្លះ រមែងចែករំលែក គឺរមែងឲ្យទេយ្យ-ធម៌សូម្បីតិចតួច ។ បទថា **ពហុនា** សេចក្តីថា សត្វពួកខ្លះ សូម្បីទេយ្យធម៌មានច្រើន ក៏ឲ្យមិនបាន គឺមិនឲ្យសោះ ។ បទថា **ទក្ខិណា** សេចក្តីថា ទានដែលបុគ្គលជឿកម្ម និងផលនៃកម្ម ហើយឲ្យ ។

បទថា **សហស្សេន សមំ មិតា** សេចក្តីថា ទក្ខិណាទាន សូម្បីបាយប្រមាណមួយវែក ដែលបុគ្គលឲ្យហើយយ៉ាងនេះ ក៏រាប់ថា ស្មើគ្នាដោយការឲ្យចំនួនច្រើនរាប់ពាន់ គឺដូចគ្នានឹងការឲ្យរាប់ពាន់នោះឯង ព្រោះមានផលច្រើន ។

សេដ្ឋីពោលនឹងមាតលិទេវបុត្រនោះថា បើដូច្នោះ សូមលោកចូលទៅអង្គុយចុះ បន្ទាប់អំពីនោះ បញ្ចសិខទេវបុត្រ បណ្តាយឲ្យពេលវេលាកន្លងទៅបន្តិច ហើយមកសូមភត្ត កាលសេដ្ឋីពោលថា ភត្តមិនមាន សូមលោកទៅចុះ ទើបពោលថា ខ្ញុំមិនទៅឡើយ ក្នុងផ្ទះនេះ ប្រហែលជាមានព្រាហ្មណសូត្រទេដឹង កាលនឹងផ្តើមធម្មកថាដល់សេដ្ឋី ទើបពោលគាថាទី ៨ ថា

> បុគ្គលណា ប្រព្រឹត្តស្វែងរកអាហារ មកចិញ្ចឹមនូវកូន និងប្រពន្ធផង ឲ្យទានសូម្បីបន្តិចបន្តួចផង បុគ្គលនោះ ឈ្មោះថា ប្រព្រឹត្តធម៌ បុគ្គលជាឥស្សរៈ ទាំងសែននាក់ ជាអ្នកបូជាទាំងពាន់នោះ មិនដល់នូវចំណិតរបស់អ្នកកម្សត់ ដែលឲ្យទានដោយធម៌ មានបការដូច្នោះឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ធម្មំ** បានដល់ ធម៌ គឺសុចរិត ៣ ប្រការ ។ បទថា **សមុច្ចកំ** សេចក្តីថា បុគ្គលណាត្រាច់ទៅសូមអាហារនៅ ធ្និនតាមផ្ទះក្តី នាំផ្លែឈើមកអំពីព្រៃក្តី បុគ្គលនោះ ឈ្មោះថា ប្រព្រឹត្តធម៌នោះឯង ។ បទថា **ទារញ្ច បោសំ** សេចក្តីថា ម្យ៉ាងទៀត បុគ្គលអ្នកចិញ្ចឹមបុត្រ និងភរិយារបស់ខ្លួន ។ បទថា **ទទមប្បកស្មឹ** សេចក្តីថា កាលទេយ្យធម៌មាន

តិច ក៏ធ្មៀតឲ្យដល់សមណៈ និងព្រាហ្មណ៍ ដែលតាំងនៅក្នុងធម៌ ឈ្មោះថា ប្រព្រឹត្តនូវធម៌ ។ បទថា **សតសហស្សានំ សហស្សយាគិនំ** សេចក្តីថា យញ្ញដែលបុគ្គលរាប់សែនសម្លាប់សត្វដទៃ មកបូជាដល់បុគ្គលដែលគួរបូជារាប់ពាន់ គឺកាលឥស្សរជនរាប់សែន បូជាដល់បុគ្គលដែលគួរបូជារាប់ពាន់ ។

បទថា **កលម្បិ នាគ្ឃន្តិ តថាវិធស្ស តេ** សេចក្តីថា ការបូជារបស់ឥស្សរជនទាំងនោះ ដែលបូជាយញ្ញដោយទ្រព្យមួយពាន់ ចំនួនរាប់សែននាក់ រមែងមិនដល់ចម្រៀកទី ១៦ នៃផលទានរបស់បុគ្គលបែបនោះ គឺរបស់ទុគ្គតបុគ្គល ដែលញ៉ាំងទេយ្យធម៌ឲ្យកើតឡើងដោយធម៌ស្មើហើយឲ្យទាន ។

លំដាប់នោះ សេដ្ឋីស្តាប់ពាក្យរបស់បញ្ចសិខទេវបុត្រហើយកំណត់បាន ។ ពេលនោះ សេដ្ឋី កាលនឹងសួរដល់ហេតុនៃការបូជាដែលមានផលគណនាមិនបាន នឹងបញ្ចសិខទេវបុត្រនោះ បានពោលគាថាទី ៩ ថា

*យញ្ញៈ គឺការបូជានុ៎ះ ជាបូជាដ៏ទូលាយ មានថ្លៃក៏ច្រើន ហេតុអ្វីទើបមិនដល់នូវថ្លៃនៃទាន ដែលបុគ្គលឲ្យហើយតាមធម៌ដ៏ត្រឹមត្រូវ ហេតុអ្វី បុគ្គលជាឥស្សរៈទាំងសែននាក់ ជាអ្នកបូជាទាំងពាន់នោះ មិនដល់នូវចំណិតរបស់អ្នកកម្សត់ ដែលឲ្យទានដោយធម៌ មានបការដូច្នោះ ដូច្នេះ ។*

បណ្តាបទទាំងនោះ បទថា **យញ្ញោ** សេចក្តីថា យញ្ញ គឺទាន ឈ្មោះថា **វិបុលោ** ព្រោះអំណាចនៃការបរិច្ចាគទ្រព្យរាប់សែន និងឈ្មោះថា **មហគ្ឃតោ** ព្រោះមានផលបរិបូណ៌ ។ បទថា **សមេន ទិន្នស្ស** សេចក្តី

ថា ព្រោះហេតុអ្វី ទើបមិនស្មើនឹងតម្លៃនៃផលទាន ដែលបុគ្គលឲ្យដោយធម៌ នោះ ។ បទថា **កថំ សហស្សានំ** សេចក្តីថា ម្នាលព្រាហ្មណ៍ ហេតុអ្វី ឥស្សរជនរាប់សែននៃបុគ្គលដែលបូជារាប់ពាន់ គឺរបស់បុគ្គលចំនួនច្រើនពាន់ ទើបមិនដល់ចម្រៀកទី ១៦ នៃផលទានរបស់ទុគ្គតបុគ្គលតែម្នាក់ ដែលញុំាង ទេយ្យធម៌ឲ្យកើតដោយធម៌ហើយឲ្យ ។

លំដាប់នោះ បញ្ចសិខទេវបុត្រ កាលពោលដល់សេដ្ឋីនោះ បានពោល គាថាចុងក្រោយថា

ព្រោះថា បុគ្គលពួកខ្លះ តាំងនៅក្នុងកាយកម្មជាដើមមិនស្មើគ្នា បៀតបៀន សម្លាប់ ឬក៏ធ្វើគេឲ្យសោកសៅហើយ ទើបឲ្យ ( នូវ ទក្ខិណាទាន ) ទក្ខិណាទាននោះ ឈ្មោះថា មានមុខជោកដោយ ទឹកភ្នែក ប្រកបដោយអាជ្ញា រមែងមិនដល់នូវតម្លៃ នៃទានដែល បុគ្គលឲ្យ ដោយធម៌ដ៏ត្រឹមត្រូវទេ បុគ្គលជាឥស្សរៈទាំងសែន នាក់ ជាអ្នកបូជាទាំងពាន់នោះ មិនដល់នូវចំណិតរបស់អ្នកកម្សត់ ដែលឲ្យទានដោយធម៌ មានបការដូច្នោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វិសមេ** បានដល់ តាំងនៅក្នុងកាយកម្ម ដែលជាចំណែកមិនស្មើគ្នា ។ បទថា **ឃត្វា** បានដល់ ធ្វើសត្វឲ្យលំបាក ។ បទថា **វធិត្វា** បានដល់ ធ្វើសត្វឲ្យស្លាប់ ។ បទថា **សោ ច យិត្វា** បានដល់ ធ្វើសត្វ ឲ្យមានសេចក្តីសោក ។

សេដ្ឋីនោះ ស្តាប់ធម្មកថារបស់បញ្ចសិខទេវបុត្រហើយ ពោលថា បើ

ដូច្នោះ សូមលោកចូលទៅក្នុងផ្ទះ នឹងបានបន្តិច ។ បញ្ចសិខទេវបុត្របានទៅអន្តរធានក្នុងសម្នាក់ព្រាហ្មណ៍ទាំងនោះ ។ គ្រានោះ ពិលារកោសិយសេដ្ឋី បានហៅទាសីម្នាក់មកប្រាប់ថា ចូរនាងឲ្យសម្លីស្រូវដល់ព្រាហ្មណ៍ទាំងនេះ ម្នាក់មួយនាឡិ ទាសីកាន់យកនាឡិស្រូវទៅឲ្យព្រាហ្មណ៍ ហើយពោលថា សូមលោកទាំងឡាយយកស្រូវទាំងនេះទៅចម្អិនបរិភោគក្នុងទីណាមួយ ព្រាហ្មណ៍ទាំងឡាយពោលថា ពួកយើងមិនត្រូវការស្រូវ ពួកយើងមិនប៉ះពាល់ស្រូវ ។ ទាសីប្រាប់សេដ្ឋីថា បានឮថា ព្រាហ្មណ៍ទាំងឡាយ មិនប៉ះពាល់ស្រូវ សេដ្ឋីពោលថា បើដូច្នោះ ចូរនាងឲ្យអង្ករដល់ព្រាហ្មណ៍ទាំងនេះ ទាសីកាន់យកអង្ករទៅឲ្យពួកព្រាហ្មណ៍ ហើយពោលថា បពិត្រព្រាហ្មណ៍ទាំងឡាយ សូមពួកលោកទទួលយកអង្ករចុះ ព្រាហ្មណ៍ទាំងឡាយពោលថា ពួកយើងមិនទទួលរបស់ឆៅ ទាសីប្រាប់សេដ្ឋីថា បពិត្រលោកម្ចាស់ ព្រាហ្មណ៍ទាំងឡាយ មិនទទួលរបស់ឆៅ សេដ្ឋីពោលថា បើដូច្នោះ ចូរនាងដួសបាយដែលដាំឲ្យគោស៊ី ដាក់ក្នុងត្រឡោក ឲ្យដល់ពួកព្រាហ្មណ៍ចុះ ទាសីបានដួសបាយសម្រាប់ឲ្យគោ ដាក់ក្នុងត្រឡោក ឲ្យដល់ព្រាហ្មណ៍ទាំងនោះហើយ ។ ព្រាហ្មណ៍ទាំង ៥ ពូតបាយជាពំនូតៗ ញាត់ក្នុងមាត់ ធ្វើឲ្យបាយជាប់ក ក្អែកត្រឡប់ ដេកធ្វើជាស្លាប់ទាំងអស់ មិនដឹងខ្លួន ទាសីឃើញដូច្នោះ គិតថា ព្រាហ្មណ៍នឹងស្លាប់ ទើបខ្លាចរត់ទៅប្រាប់សេដ្ឋីថា បពិត្រលោកម្ចាស់ ព្រាហ្មណ៍ទាំងនោះមិនអាចលេបបាយសម្រាប់គោបានទេ ស្លាប់អស់ហើយ ។

សេដ្ឋីគិតថា ពេលនេះ មនុស្សទាំងឡាយនឹងតិះដៀលអញថា សេដ្ឋី

មានចិត្តអាក្រក់ ឲ្យទាសីដួសបាយសម្រាប់គោ ឲ្យដល់ពួកព្រាហ្មណសុខុមាលជាតិ ពួកព្រាហ្មណ៍ទាំងនោះ មិនអាចលេបបាយទាំងនោះរួច ទើបស្ដោះទាំងអស់ ។ គ្រានោះ សេដ្ឋីពោលនឹងទាសីថា ចូរនាងប្រញាប់ទៅយកបាយសម្រាប់គោក្នុងត្រឡោកទាំងនោះចេញ ហើយដួសបាយស្រូវសាលី ដែលមានឱជារសទៅឲ្យជាថ្មី ទាសីបានធ្វើយ៉ាងនោះហើយ សេដ្ឋីហៅពួកអ្នកដើរតាមថ្នល់ មកប្រាប់ថា យើងឲ្យទាសីនាំអាហារ តាមដែលយើងធ្លាប់បរិភោគឲ្យពួកព្រាហ្មណ៍ទាំងនេះ ព្រាហ្មណ៍ទាំងនេះមានសេចក្ដីលោភ បរិភោគពំនូតបាយធំ ក៏អួលស្លាប់ ចូរអ្នកទាំងឡាយដឹងថា យើងមិនមានកំហុស ហើយឲ្យប្រជុំបរិស័ទ ។

កាលមហាជនប្រជុំគ្នាហើយ ព្រាហ្មណ៍ទាំងឡាយក្រោកឡើង សម្លឹងមើលមហាជន ហើយពោលថា អ្នកទាំងឡាយ ចូរមើលសេដ្ឋីនេះនិយាយកុហក សេដ្ឋីពោលថា បានឲ្យបាយសម្រាប់ខ្លួនដល់ពួកយើង សេចក្ដីពិតសេដ្ឋីបានឲ្យបាយសម្រាប់គោដល់ពួកយើង កាលពួកយើងធ្វើជាដេកស្លាប់ ទើបឲ្យទាសីទៅដួសបាយនេះ បញ្ជូនមកឲ្យ ដូច្នេះហើយ ទើបខ្ជាក់បាយដែលបៀមក្នុងមាត់លើផែនដី បង្ហាញដល់មហាជន មហាជននាំគ្នាតិះដៀលសេដ្ឋីថា នែបុគ្គលអន្ធពាល លោកធ្វើវង្សរបស់ខ្លួនឲ្យវិនាស ឲ្យដុតរោងទានឲ្យចាប់កពួកស្មូមយាចកបណ្ដេញទៅ ឥឡូវនេះ កាលឲ្យបាយដល់ពួកព្រាហ្មណ៍ដែលជាសុខុមាលជាតិទាំងនេះ បានឲ្យបាយសម្រាប់គោ កាលលោកទៅកាន់បរលោកប្រហែលជាយកសម្បត្តិក្នុងផ្ទះ ចងត្រង់កហើយ ទៅ

ទេដឹង ។

ខណៈនោះ សក្កទេវរាជសួរមហាជនថា អ្នកទាំងឡាយដឹងទេថា ទ្រព្យក្នុងផ្ទះនេះជារបស់អ្នកណា មហាជនឆ្លើយថា មិនដឹង សក្កទេវរាជសួរថា ពួកអ្នកធ្លាប់បានឮទេថា ក្នុងកាលឈ្មោះនោះ ក្នុងនគរនេះ មានមហាសេដ្ឋី ក្រុងពារាណសី បានសាងសាលាទាន ហើយបំពេញទានដ៏ធំ មហាជនឆ្លើយថា ត្រូវហើយ ពួកយើងបានឮ សក្កទេវរាជពោលថា យើង គឺសេដ្ឋីនោះ កាលឲ្យទានហើយ ទៅកើតជាសក្កទេវរាជ ឯកូនរបស់យើង ក៏មិនបានទម្លាយវង្សត្រកូល បានឲ្យទានហើយ កើតជាចន្ទទេវបុត្រ បុត្ររបស់ចន្ទទេវបុត្រ កើតជាសុរិយទេវបុត្រ កូនរបស់សុរិយទេវបុត្រ កើតជាមាតលិទេវបុត្រ កូនរបស់មាតលិទេវបុត្រ កើតជាគន្ធព្វទេវបុត្រ ឈ្មោះបញ្ចសិខៈ បណ្ដាទេវបុត្រទាំងនោះ នេះ គឺចន្ទទេវបុត្រ នេះ គឺសុរិយទេវបុត្រ នេះ គឺមាតលិសង្គាហកទេវបុត្រ នេះ គឺគន្ធព្វទេវបុត្រ ឈ្មោះបញ្ចសិខៈ ដែលជាបិតារបស់សេដ្ឋីចិត្តលាមកនេះ កុសលទានដែលមានគុណច្រើនយ៉ាងនេះ បណ្ឌិតគួរធ្វើពិត ខណៈកំពុងពោល ដើម្បីកាត់ការសង្ស័យរបស់មហាជន ទេវបុត្រទាំងឡាយក៏ហោះទៅក្នុងអាកាស ឈរក្នុងអាកាស បញ្ចេញរស្មី មានកាយរុងរឿងដោយអានុភាពធំក្រៃលែង ព្រះនគរទាំងមូលពោរពេញដោយពន្លឺ ។ សក្កទេវរាជហៅមហាជនមក ត្រាស់ថា ពួកយើងលះទិព្វសម្បត្តិរបស់ខ្លួនមក ក៏ព្រោះពិលារកោសិយសេដ្ឋីមានចិត្តអាក្រក់ ដែលបន្តវង្សត្រកូលចុងក្រោយនេះ សេដ្ឋីចិត្តបាបនេះ ទម្លាយវង្សរបស់ខ្លួន ដុតរោងទាន ចាប់កពួកស្មូម

យាចកបណ្តេញទៅ កាត់វង្សនៃពួកយើងចោល មិនឲ្យទាន មិនរក្សាសីល គប្បីកើតក្នុងនរក ពួកយើងមក ដើម្បីអនុគ្រោះសេដ្ឋីនេះ ដើម្បីប្រកាសគុណនៃទាន បានសម្តែងធម៌ដល់ពួកមហាជន ។

ពិលារកោសិយសេដ្ឋី បានផ្គងអញ្ជលីឡើងដាក់លើសិរសា ឲ្យប្តេជ្ញាដល់សក្កទេវរាជថា បពិត្រព្រះអង្គ តាំងអំពីនេះទៅ ខ្ញុំនឹងមិនទម្លាយនូវវង្សត្រកូលដែលមានមកអំពីបុរាណ នឹងបំពេញទានតាំងពីថ្ងៃនេះជាដើម បើមិនទាន់បានឲ្យអាហារដែលបានមក ដោយហោចសូម្បីទឹក និងឈើស្ទន់ ដល់អ្នកដទៃជាមុនទេ ខ្ញុំនឹងមិនបរិភោគឡើយ ។ សក្កទេវរាជទ្រង់ទូន្មានសេដ្ឋីឲ្យអស់ព្យសន៍ហើយ ឲ្យតាំងនៅក្នុងសីល ៥ ហើយនាំទេវបុត្រទាំង ៤ ទៅកាន់វិមានរៀងៗ ខ្លួន សូម្បីសេដ្ឋីនោះ កាលអស់ជីវិតហើយ ក៏បានទៅកើតក្នុងតាវត្តិង្សពិភព ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលមុន ភិក្ខុនេះមិនមានសទ្ធា មិនឲ្យទានដល់បុគ្គលណាឡើយ តែតថាគតបានទូន្មានឲ្យស្គាល់ផលទានយ៉ាងនេះ សូម្បីកើតក្នុងភពតៗ មក ក៏លះការឲ្យទាននោះមិនបាន ហើយទ្រង់ប្រជុំជាតកថា សេដ្ឋីក្នុងកាលនោះ បានមកជាភិក្ខុទានបតី ក្នុងកាលឥឡូវនេះ ចន្ទទេវបុត្រ

ក្នុងកាលនោះ បានមកជាសារីបុត្រ សុរិយាទេវបុត្រ ក្នុងកាលនោះ បានមកជាមោគ្គល្លាន មាតលិទេវបុត្រ ក្នុងកាលនោះ បានមកជាកស្សបៈ បញ្ច-សិខទេវបុត្រ ក្នុងកាលនោះ បានមកជាអានន្ទ ឯសក្កទេវរាជ ក្នុងកាលនោះ គឺតថាគតនេះឯង ។ល។

## អដ្ឋកថា ពិលារកោសិយជាតក ចប់

# សុត្តន្តបិដក

## ចក្កវាកជាតក

[ ៧៥១ ] ( ក្អែកសួរថា ) ម្នាលចាក្រពាក អ្នកមានសរីរៈដ៏មាំមួន មានសម្បុរ និងរូបដ៏ល្អ មានសម្បុរក្រហមអំពីកំណើត មានរូបដ៏សមរម្យ មានឥន្រ្ទិយ គឺមុខថ្លាផូរផង់ ។

[ ៧៥២ ] អ្នកទំនៅឰដ៏ឆ្នេរស្ទឹងគង្គា ប្រហែលជាស៊ីនូវភោជន គឺត្រីក្អែក ត្រីសណ្តាយ ត្រីក្បក ត្រីប្រា និងត្រីឆ្ពិនយ៉ាងនេះឬ ។

[ ៧៥៣ ] ( ចាក្រពាកឆ្លើយថា ) ម្នាលសម្លាញ់ ខ្ញុំមិនបរិភោគនូវសាច់របស់សត្វគោក និងសត្វទឹក វៀរលែងតែសារាយ និងចកចេញ វត្ថុដទៃ ( ក្រៅអំពីសាច់ ) ជាភោជនរបស់ខ្ញុំ ។

[ ៧៥៤ ] ( ក្អែក ... ) ម្នាលសម្លាញ់ ខ្ញុំមិនជឿថា សារាយ និងចកនោះ ជាភោជនរបស់ចាក្រពាកទេ ចំណែកខាងខ្ញុំបរិភោគអាហារភោជនដែលលាយដោយអំបិល និងប្រេងក្នុងស្រុក ។

[ ៧៥៥ ] ( ខ្ញុំបរិភោគ ) នូវបាយលាយដោយសាច់ដ៏ស្អាតដែលគេធ្វើក្នុងពួកមនុស្ស ម្នាលចាក្រពាក អ្នកមានសម្បុរយ៉ាងណា ខ្ញុំមិនមានសម្បុរប្រាកដដូច្នោះទេ ។

[ ៧៥៦ ] ( ចាក្រពាក ... ) អ្នកបៀតបៀននូវពួកមនុស្ស សត្វឃើញនូវពៀរក្នុងខ្លួន ស៊ីទាំងតក់ស្លុត ភិតភ័យ ព្រោះហេតុនោះទើបពណ៌សម្បុររបស់អ្នកប្រាកដដូច្នោះ ។

[ ៧៥៧ ] ម្នាលក្អែក អ្នកត្រូវសត្វលោកទាំងពួងទីង បិណ្ឌាហារដែលអ្នកបានមក ដោយអំពើដ៏អាក្រក់ បានជាមិនស្កប់ស្កល់ ( ដល់អ្នក ) ព្រោះហេតុនោះ ពណ៌សម្បុររបស់អ្នកប្រាកដដូច្នោះ ។

[ ៧៥៨ ] ម្នាលសម្លាញ់ ខ្លួនខ្ញុំមិនបៀតបៀនពួកសត្វទាំងពួងមកស៊ីទេ ខ្ញុំមានសេចក្ដីខ្វល់ខ្វាយតិច ប្រាសចាកសេចក្ដីរង្កៀសមិនមានសេចក្ដីសោកភ័យ អំពីទីណាទេ ។

[ ៧៥៩ ] អ្នកនោះ ចូរធ្វើនូវអានុភាព គឺសេចក្ដីព្យាយាម ចូរផ្លាស់មារយាទចេញ កាលបើអ្នកប្រព្រឹត្តនូវការមិនបៀតបៀនគេនឹងបានជាទីស្រឡាញ់ ( របស់សត្វលោក ) ដូចជាខ្ញុំដែរ ។

[ ៧៦០ ] អ្នកណាមិនបៀតបៀនគេដោយខ្លួនឯង មិនប្រើគេឲ្យបៀតបៀន មិនបំផ្លាញគេដោយខ្លួនឯង មិនប្រើគេឲ្យបំផ្លាញជាបុគ្គលមានចំណែកនៃមេត្រីចិត្ត ក្នុងពួកសត្វទាំងពួង ពៀររបស់អ្នកនោះនឹងមិនមានមួយអន្លើដោយសត្វណានីមួយឡើយ ។

**ចក្កវាកជាតកទី ១៣ ចប់**

# អដ្ឋកថា

## ចក្កវាកជាតក

[ ៧៥១-៧៦០ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុរលារលាំមួយរូប ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **វណ្ណវា អភិរូបោសិ** ដូច្នេះជាដើម ។

បានឮថា ភិក្ខុរូបនោះ មិនឆ្អែតដោយបច្ច័យ មានចីវរជាដើម ដើរស្វែងរកថា សង្ឃភត្តមានក្នុងទីណា និមន្តនភត្តមានក្នុងទីណាជាដើម គាប់ចិត្តនៅក្នុងរឿងអាមិសប៉ុណ្ណោះ កាលនោះភិក្ខុដែលសីលជាទីស្រឡាញ់ បំណងនឹងអនុគ្រោះលោក ទើបទូលព្រះសាស្តា ។ ព្រះសាស្តាឲ្យហៅភិក្ខុនោះមកត្រាស់សួរថា ម្នាលភិក្ខុ បានឮថា អ្នកជាបុគ្គលឡេះឡោះពិតឬ កាលភិក្ខុនោះក្រាបទូលថា ករុណាពិតព្រះអង្គ ទើបត្រាស់ថា ម្នាលភិក្ខុ អ្នកបួសក្នុងសាសនាដែលនាំសត្វចេញចាកទុក្ខបែបនេះ ហេតុអ្វីក៏ឡេះឡោះ ឈ្មោះថាការឡេះឡោះជារឿងលាមក ក្នុងកាលមុនអ្នកអាស្រ័យការឡេះឡោះ មិនឆ្អែតដោយសាកសពដំរីជាដើម ក្នុងក្រុងពារាណសី ត្រូវចូលទៅកាន់ព្រៃធំដូច្នេះហើយ ទ្រង់នាំរឿងក្នុងអតីតមកសាធក:ដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិក្នុងនគរពារាណសី មានក្អែកឡេះឡោះមួយក្បាល មិនឆ្អែតដោយសពដំរីជាដើម ក្នុងនគរពារាណសី ទើបគិតថា ព្រៃដូចម្តេចហ្ន៎ ហើយទៅកាន់ព្រៃ សន្តោសដោយផ្លែឈើក្នុងព្រៃនោះ ត្រាច់ទៅដល់ឆ្នេរស្ទឹងគង្គា ឃើញសត្វចាក្រពាកពីរ ញីឈ្មោលគិតថា បក្សីនេះល្អពន់ពេកណាស់ បក្សីនេះ ប្រហែលជាស៊ីសាច់ និងត្រីច្រើន

ត្រង់ឆ្នេរស្ទឹងគង្គានេះ សូម្បីអញក៏គួរសួរបក្សីទាំងនេះ ហើយស៊ីអាហាររបស់បក្សីទាំងនេះ មុខជាមានពណ៌សម្បុរស្អាត ។ គិតហើយ ក៏ទៅទំក្បែរៗ កាលនឹងសាកសួរសត្វចាក្រពាក ទើបពោល ២ គាថាថា

ម្នាលចាក្រពាក អ្នកមានសរីរៈដ៏មាំមួន មានសម្បុរ និងរូបដ៏ល្អ មានសម្បុរក្រហមអំពីកំណើត មានរូបដ៏សមរម្យ មានឥន្ទ្រិយ គឺមុខថ្លាផូរផង់ ។

អ្នកទំនៅឰដ៏ឆ្នេរស្ទឹងគង្គា ប្រហែលជាស៊ីនូវភោជន គឺត្រីក្អែក ត្រីសណ្តាយ ត្រីក្បក ត្រីប្រា និងត្រីឆ្ពិនយ៉ាងនេះឬ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឃនោ** បានដល់ មានរាងកាយរឹងមាំ ។ បទថា **សញ្ជាតរោហិតោ** បានដល់ មានពណ៌ក្រហមដែលកើតហើយដោយល្អ ដូចពណ៌នៃមាសដ៏បរិសុទ្ធ ។ បទថា **ចាដីនំ** បានដល់ ត្រីក្អែកឈ្មោះថា **ចាដីន** ។ បទថា **ចាវុសំ** បានដល់ ត្រីក្បក បាលីថា **ពាវុសំ** ដូច្នេះក៏មាន ។ បទថា **ពលជ្ជំ** បានដល់ ត្រីសណ្តាយ ។ បទថា **មុញ្ជរោហិតំ** បានដល់ ត្រីប្រា និងត្រីឆ្ពិន ។ ក្អែកសួរថា អ្នកប្រហែលជាបរិភោគអាហារបែបនេះទេដឹង ។ សត្វចាក្រពាក កាលបដិសេធពាក្យរបស់ក្អែកនោះ ទើបពោលគាថាទី ៣ ថា

ម្នាលសម្លាញ់ ខ្ញុំមិនបរិភោគនូវសាច់របស់សត្វគោក និងសត្វទឹក វៀរលែងតែសារាយ និងចកចេញ វត្ថុដទៃ ( ក្រៅអំពីសាច់ ) ជាភោជនរបស់ខ្ញុំ ដូច្នេះ ។

គប្បីជ្រាបអត្ថនៃពាក្យដែលជាគាថានោះថា នែសម្លាញ់ វត្ថុដទៃក្រៅពីសារាយ និងចកហើយ ខ្ញុំមិនបានកាន់យកសាច់សត្វលើគោក ឬក្នុងទឹកមកបរិភោគជាអាហារឡើយ នែសម្លាញ់ សារាយ និងចកប៉ុណ្ណោះ ជាអាហាររបស់ខ្ញុំ ។

លំដាប់នោះ ក្អែកបានពោល ២ គាថាថា

ម្នាលសម្លាញ់ ខ្ញុំមិនជឿថា សារាយ និងចកនោះជាភោជនរបស់

ចាក្រពាកទេ ចំណែកខាងខ្ញុំបរិភោគអាហារភោជនដែលលាយ

ដោយអំបិល និងប្រេងក្នុងស្រុក ។

( ខ្ញុំបរិភោគ ) នូវបាយលាយដោយសាច់ដ៏ស្អាត ដែលគេធ្វើ

ក្នុងពួកមនុស្ស ម្នាលចាក្រពាក អ្នកមានសម្បុរ យ៉ាងណា ខ្ញុំមិន

មានសម្បុរប្រាកដដូច្នោះទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យថា តុវំ** ជាដើម សេចក្តីថា ពណ៌សម្បុររបស់ខ្ញុំមិនដូចអ្នក ដែលដល់ព្រមដោយលម្អដ៏លើស មានពណ៌ដូចមាស ដោយហេតុនោះ កាលអ្នកប្រាប់ថា មានសារាយ និងចកជាអាហារ ទើបខ្ញុំមិនជឿ ។

លំដាប់នោះ ចាក្រពាកកាលប្រាប់ហេតុ ដែលធ្វើឲ្យពណ៌សម្បុរសៅហ្មង សម្តែងធម៌ដល់ក្អែកនោះ ទើបពោលគាថាដ៏សេសថា

អ្នកបៀតបៀននូវពួកមនុស្ស សត្វឃើញនូវពៀរក្នុងខ្លួន ស៊ីទាំង

តក់ស្លុត ភិតភ័យ ព្រោះហេតុនោះ ទើបពណ៌សម្បុររបស់អ្នក

ប្រាកដដូច្នោះ ។

ម្នាលក្អែក អ្នកត្រូវសត្វលោកទាំងពួងខឹង បិណ្ឌាហារដែលអ្នក បានមក ដោយអំពើដ៏អាក្រក់ បានជាមិនស្អប់ស្អល់ ( ដល់អ្នក ) ព្រោះហេតុនោះ ពណ៌សម្បុររបស់អ្នកប្រាកដ ដូច្នោះ ។

ម្នាលសម្លាញ់ ខ្លួនខ្ញុំមិនបៀតបៀនពួកសត្វទាំងពួង មកស៊ីទេ ខ្ញុំមានសេចក្ដីខ្វល់ខ្វាយតិច ប្រាសចាកសេចក្ដីរង្កៀស មិនមាន សេចក្ដីសោកភ័យ អំពីទីណាទេ ។

អ្នកនោះ ចូរធ្វើនូវអានុភាព គឺសេចក្ដីព្យាយាម ចូរផ្លាស់ មារយាទចេញ កាលបើអ្នកប្រព្រឹត្តនូវការមិនបៀតបៀនគេ នឹង បានជាទីស្រឡាញ់ ( របស់សត្វលោក ) ដូចជាខ្ញុំដែរ ។

អ្នកណាមិនបៀតបៀនគេដោយខ្លួនឯង មិនប្រើគេឲ្យបៀតបៀន មិនបំផ្លាញគេដោយខ្លួនឯង មិនប្រើគេឲ្យបំផ្លាញ ជាបុគ្គលមាន ចំណែកនៃមេត្រីចិត្ត ក្នុងពួកសត្វទាំងពួង ពៀររបស់អ្នកនោះ នឹងមិនមាន មួយអន្លើដោយសត្វណានីមួយឡើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សព្វស្សំ** សេចក្ដីថា នៃក្អែកសម្លាញ់ អ្នក បៀតបៀនសត្វទាំងឡាយ ទើបត្រូវគេចងពៀរ គឺមានពៀរក្នុងខ្លួនដែលកើត ឡើងក្នុងអ្នកដទៃ ។ បទថា **មានុសី បជំ** បានដល់ បៀតបៀន គឺប្រទូស្ត សត្វទាំងឡាយ ។ បទថា **ឧត្រស្តោ** បានដល់ ខ្លាចហើយ ។ បទថា **ឃសសី** បានដល់ នឹងស៊ី ព្រោះហេតុនោះ ទើបពណ៌សម្បុររបស់អ្នក គួរ

ទើ្តមដូច្នេះ សត្វចាក្រពាក ហៅក្អែកថា **ធង្ក** កោជនឈ្មោះថា **បិណ្ឌោ** ។ បទថា **អហឹសំ សព្វបាណភិនំ** សេចក្តីថា សត្វចាក្រពាកពោលថា ឯខ្ញុំមិនបានបៀតបៀនសត្វទាំងពួងមកបរិភោគ ។ បទថា **សោ ករស្សុ អានុភាវំ** សេចក្តីថា ចូរអ្នកធ្វើនូវសេចក្តីព្យាយាមរបស់ខ្លួន លះនូវទុស្សីភាវៈ ពោលគឺប្រក្រតីរបស់ខ្លួនចេញ ។ បទថា **អហឹសាយ** បានដល់ ប្រកបដោយអហិង្សា ត្រាច់ទៅក្នុងលោក ។ បទថា **បិយោ ហោហិសិ មម្មិវ** សេចក្តីថា កាលបើដូច្នេះ អ្នករមែងជាទីស្រឡាញ់ នៃសត្វលោកដូចខ្លួនខ្ញុំនេះឯង ។ បទថា **ន ជិនាតិ** បានដល់ មិនធ្វើទ្រព្យឲ្យសាបសូន្យឯង ។ បទថា **ន ជាបយេ** បានដល់ មិនប្រើឲ្យអ្នកដទៃធ្វើទ្រព្យឲ្យវិនាស ។ បទថា **មេត្តំសោ** បានដល់ មានមេត្តាចិត្ត ដែលជាចំណែកនៃការស្រឡាញ់ ។ បទថា **ន កេនចិ** សេចក្តីថា ឈ្មោះថា ពៀររបស់បុគ្គលនោះ មិនមានជាមួយបុគ្គលណាសូម្បីតែម្នាក់ឡើយ ។

ដូច្នោះ អ្នកត្រូវការភាពជាទីស្រឡាញ់របស់សត្វលោក ព្រមទាំងទេវលោក ចូរវៀរចាកពៀរទាំងអស់ ។ ចាក្រពាកសម្តែងធម៌ដល់ក្អែក ដោយប្រការដូច្នេះ ។ ក្អែកពោលថា អ្នកមិនប្រាប់អាហាររបស់ខ្លួនដល់យើង រួចក៏ស្រែកខ្វកៗ ហើរទៅចុះត្រង់គំនរអាចម៍សត្វក្នុងក្រុងពារាណសី ។

ព្រះសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះ មកសម្តែងហើយ ទ្រង់ប្រកាសសច្ចធម៌ ក្នុងកាលចប់សច្ចៈ ភិក្ខុឡេះឡោះតាំងនៅក្នុងអនាគាមិផល ព្រះទសពលទ្រង់សមោធានជាតកថា ក្អែកក្នុងកាលនោះ បានមកជាភិក្ខុឡេះឡោះ ក្នុងកាលឥឡូវនេះ ចាក្រពាកញីក្នុងកាលនោះ បានមកជារាហុលមាតា ចំណែកចាក្រពាកឈ្មោល ក្នុងកាលនោះ គឺតថាគតនេះឯង ។ល។

**អដ្ឋកថា ចក្កវាកជាតក ចប់**

# សុត្តន្តបិដក

## ភូរិបញ្ញាជាតក

[ ៧៦១ ] ( អាមាត្យពួកខាងអាចារ្យសេនកៈ សួរថា ) បពិត្រអ្នកមានបញ្ញាក្រាស់ដូចផែនដី សិរី សេចក្តីព្យាយាម និងប្រាជ្ញាប្រាកដដូច្នោះ រមែងមិនរក្សានូវអ្នកដែលជាមនុស្សធ្លាក់ចុះទៅកាន់អំណាចនៃសេចក្តីមិនចម្រើន ព្រោះហេតុតែអ្នកបរិភោគនូវបាយដំណើបមានសម្ងួតិច តើការណ៍នោះពិតមែនឬ ។

[ ៧៦២ ] ( ព្រះមហោសថពោធិសត្វពោលថា ) ខ្ញុំញុំាងសេចក្តីសុខ ( ចាស់របស់ខ្លួន ) ឲ្យចម្រើនដោយសេចក្តីទុក្ខ ពិនិត្យមើលនូវកាលគួរ និងកាលមិនគួរ ហើយបិទបាំងតាមសេចក្តីពេញចិត្ត ( របស់ខ្លួន ) បើកនូវទ្វារនៃប្រយោជន៍ ព្រោះហេតុនោះ ទើបត្រេកអរដោយបាយដំណើប ។

[ ៧៦៣ ] មួយទៀត ខ្ញុំដឹងនូវកាលគួរ ហើយញុំាងប្រយោជន៍ឲ្យចម្រើនដោយប្រាជ្ញា ( របស់ខ្លួន ) ព្រោះសេចក្តីព្យាយាមដ៏ក្លៀវក្លាដូចសត្វសីហៈ ធ្វើសេចក្តីព្យាយាមដ៏រឹងប៉ឹង អ្នកគង់នឹងឃើញខ្ញុំម្តងទៀត ដោយឫទ្ធិនោះមិនខាន ។

[ ៧៦៤ ] ( ព្រះរាជាត្រាស់សួរថា ) ជនពួកខ្លះជាអ្នកមានសេចក្តីសុខ ទើបមិនធ្វើបាប ជនពួកខ្លះទៀត ( មិនធ្វើបាប ) ព្រោះខ្លាចអំពីការជាប់ចំពាក់ដោយតំណិះដំនៀល អ្នកជាបុគ្គល

អាចមានគំនិត គិតនូវប្រយោជន៍ដ៏ទូលាយបាន ហេតុអ្វីក៏មិនធ្វើសេចក្តីលំបាកដល់យើង ។

[ ៧៦៥ ] ( ព្រះពោធិសត្វ... ) បណ្ឌិតទាំងឡាយរមែងមិនប្រព្រឹត្តនូវអំពើដ៏លាមក ព្រោះហេតុនៃសេចក្តីសុខផ្ទាល់ខ្លួនទេ ទោះបីត្រូវសេចក្តីទុក្ខប៉ះពាល់ ឬឃ្លាតចាក ( សម្បត្តិ ) ក៏រមែងមិនលះបង់នូវធម៌ព្រោះសេចក្តីស្រឡាញ់និងសេចក្តីស្អប់ឡើយ ។

[ ៧៦៦ ] ( ព្រះរាជា... ) បុគ្គលគប្បីលើកតម្កើងនូវខ្លួនដ៏ក្រខ្សត់ ( ឲ្យតាំងនូវក្នុងសម្បត្តិ ) ដោយពាក្យសរសើរ ឬដោយពាក្យដ៏ទន់ ឬក៏ដោយពាក្យទ្រគោះណានីមួយ ហើយសឹមប្រព្រឹត្តធម៌ដោយប្រពៃក្នុងកាលជាខាងក្រោយ ។

[ ៧៦៧ ] ( ពោធិសត្វ... ) បុគ្គលអង្គុយឬដេកក្នុងម្លប់នៃឈើណា មិនត្រូវកាច់នូវមែកនៃឈើនោះទេ ព្រោះបុគ្គលអ្នកទ្រុស្តមិត្ត ជាមនុស្សអាក្រក់ ។

[ ៧៦៨ ] បុរសចេះដឹងនូវធម៌ ( អំពីសម្នាក់ ) នៃអាចារ្យណា មួយទៀត សប្បុរសទាំងឡាយណាបន្ទោបង់នូវសេចក្តីសង្ស័យរបស់អ្នកនោះ ការដឹងនិងការបន្ទោបង់នោះ ឈ្មោះថាជាទីពឹង ជាទីប្រព្រឹត្តទៅរបស់បុរសនោះ បុគ្គលអ្នកមានប្រាជ្ញាមិនត្រូវញ៉ាំងមេត្រីចិត្តឲ្យសាបសូន្យ អំពីអាចារ្យនោះទេ ។

[ ៧៦៩ ] គ្រហស្ថអ្នកបរិភោគកាមខ្ជិលច្រអូសមិនល្អ បព្វជិតមិនសង្រួមមិនល្អ ព្រះរាជាធ្វើការមិនពិចារណាមិនល្អ នរណាជាបណ្ឌិតច្រើនក្រោធ សេចក្តីក្រោធនោះមិនល្អ ។

[ ៧៧០ ] បពិត្រព្រះអង្គជាធំក្នុងទិស ក្សត្រិយ៍គប្បីពិចារណាហើយសឹមធ្វើ មិនគប្បីមិនបានពិចារណាហើយធ្វើទេ បពិត្រព្រះរាជា យសបរិវារក្តី កេរ្តិ៍ឈ្មោះក្តី រមែងចម្រើនដល់ព្រះរាជាអ្នកពិចារណាហើយធ្វើ ។

## កុរុធម្មជាតកទី ១៤ ចប់

# អដ្ឋកថា

## ភូរិបញ្ញាជាតក

[ ៧៦១-៧៧០ ] ភូរិបញ្ញជាតកនេះ មានពាក្យផ្ដើមថា **សច្ចំ កិរ** ដូច្នេះជាដើម ។ ផ្ទៃរឿងមានជាក់ច្បាស់ក្នុងមហាឧម្មគ្គជាតកនោះឯង ៕

**អដ្ឋកថា ភូរិបញ្ញាជាតក ចប់**

# សុត្តន្តបិដក

## មហាមង្គលជាតក

[ ៧៧១ ] ( តាបសជាសិស្សច្បងរបស់ពោធិសត្វសួរថា ) ក្នុងកាល ( ជាទីប្រាថ្នានូវមង្គល ) នរជនសែកមន្តដូចម្ដេច អាស្រ័យនូវវិជ្ជាដូចម្ដេច ឬ ( នូវបរិយត្តិ ) នៃសូត្រទាំងឡាយដូចម្ដេច ជននោះ ទើបឈ្មោះថា គ្រប់គ្រងខ្លួនដោយសួស្ដីក្នុងលោកនេះ និងលោកខាងមុខ ។

[ ៧៧២ ] ( ពោធិសត្វពោលថា ) ពួកទេវតាក្ដី ពួកបិតា ( ព្រហ្ម ) ទាំងអស់ក្ដី ពួកទីឃជាតិក្ដី ពួកសត្វទាំងអស់ក្ដី ដែលបុគ្គលណាកោតក្រែងដោយមេត្តាចិត្ត អស់កាលជានិច្ច បណ្ឌិតទាំងឡាយពោលនូវមេត្តាចិត្ត ក្នុងពួកសត្វនោះ ថាជាសួស្ដីរបស់បុគ្គលនោះ ដោយពិត ។

[ ៧៧៣ ] បុគ្គលណា ប្រព្រឹត្តឱនលំទោនចំពោះសត្វលោកទាំងអស់ ជាអ្នកអត់ទ្រាំនូវពាក្យនៃស្រីប្រុស និងក្មេងទាំងឡាយដែលពោលអាក្រក់ ជាអ្នកពោលពាក្យមិនជាទីខ្ពើម បណ្ឌិតទាំងឡាយពោលនូវការអត់ទ្រាំនោះថាជាសួស្ដី (របស់បុគ្គលនោះ) ។

[ ៧៧៤ ] បុគ្គលណា មានប្រាជ្ញាក្ដីថ្លា មានបញ្ញាវាងវៃក្នុងកាលដែលកើតឡើងនៃហេតុ មិនមើលងាយនូវសម្លាញ់ និងមិត្តដោយសិល្បវិជ្ជា ដោយកុលសម្បត្តិ ដោយទ្រព្យ ដោយជាតិ

បណ្ឌិតទាំងឡាយបានពោលនូវការមិនមើលងាយ ក្នុងពួកសម្លាញ់នោះ ថាជាសួស្តី ( របស់បុគ្គលនោះ ) ។

[ ៧៧៥ ] ពួកជនណា ជាអ្នកមិនពោលបន្ទុស ជាសប្បុរស ជាមិត្តស្និទ្ធស្នាល ជាអ្នកមិនទ្រុស្តមិត្ត ចែករំលែកដោយទ្រព្យ បណ្ឌិតទាំងឡាយបានពោលនូវការស្និទ្ធស្នាល ក្នុងមិត្តទាំងឡាយនោះ ថាជាសួស្តី ( របស់ជននោះ ) ។

[ ៧៧៦ ] បុគ្គលណា មានភរិយា មានវ័យប្រហែលគ្នា មានសេចក្តីព្រមព្រៀងគ្នា ជាអ្នកប្រព្រឹត្តតាម ប្រាថ្នាធម៌ ជាស្រីមានកូន មានសីលធម៌ដោយគួរដល់ត្រកូល មានវត្តដល់ប្តី ពួកបណ្ឌិតបានពោលនូវចរិយានៃភរិយាទាំងឡាយនោះ ថាជាសួស្តី ( របស់ស្វាមីនោះ ) ។

[ ៧៧៧ ] ព្រះរាជាជាម្ចាស់របស់សត្វ មានយស តែងជ្រាបនូវសេចក្តីស្អាត និងសេចក្តីព្យាយាមរបស់រាជសេវកាមាត្យណាថា ( សេវកាមាត្យនោះ ) មិនបែកចិត្ត ( អំពីអញ ) ជាអ្នកមានចិត្តល្អចំពោះអញ បណ្ឌិតទាំងឡាយបានពោលនូវសេចក្តីល្អក្នុងព្រះរាជាទាំងឡាយនោះ ថាជាសួស្តី ( របស់រាជសេវកាមាត្យ ) ។

[ ៧៧៨ ] បុគ្គលណា មានសទ្ធា មានចិត្តជ្រះថ្លា ត្រេកអរ ឲ្យបាយទឹក ផ្កាកម្រង គ្រឿងក្រអូប និងគ្រឿងលាប បណ្ឌិតទាំងឡាយបានពោលនូវសេចក្តីល្អនោះ ថាជាសួស្តី ក្នុងឋានសួគ៌ទាំង

ឡាយ ( របស់បុគ្គលនោះ ) ។

[ ៧៧៩ ] ពួកបុគ្គលណា ដឹងច្បាស់ដោយញាណ រមែងញ៉ាំង បុគ្គលណាឲ្យស្អាតដោយអរិយធម៌ជាអ្នកត្រេកអរក្នុងការប្រព្រឹត្ត ល្អ ជាអ្នករៀនសូត្រច្រើន ជាអ្នកស្វែងរកគុណ ជាអ្នកមានសីល បណ្ឌិតទាំងឡាយបានពោលនូវសេចក្ដីល្អ ក្នុងកណ្ដាលនៃព្រះ អរហន្តនោះ ថាជាសួស្ដី ( របស់បុគ្គលនោះ ) ។

[ ៧៨០ ] សួស្ដីមង្គលទាំងឡាយនេះឯង វិញ្ញូជនតែងសរសើរ មានសេចក្ដីសុខជាកម្រៃក្នុងលោក នរជនអ្នកប្រកបដោយប្រាជ្ញា ក្នុងលោកនេះ គប្បីសេពគប់នូវសួស្ដីមង្គលទាំងឡាយនោះ វត្ថុ ណាមួយ ក្នុងមង្គល ( មានទិដ្ឋមង្គលជាដើម ) មិនឈ្មោះថា ជាសច្ចៈទេ ។

**មហាមង្គលជាតកទី ១៥ ចប់**

# អដ្ឋកថា

## មហាមង្គលជាតក

[ ៧៧១-៧៨០ ] ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធមហាមង្គលសូត្រ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **កឹសុ ឆរោ** ដូច្នេះជាដើម ។

សេចក្ដីពិស្ដារថា ក្នុងនគររាជគ្រឹះ មានបុរសម្នាក់ នៅក្នុងចំណោមមហាជន ដែលប្រជុំគ្នាក្នុងរោងទទួលភ្ញៀវ ដោយករណីឯណានីមួយ ពោលឡើងថា ថ្ងៃនេះ មង្គលកិរិយានឹងមានដល់ខ្ញុំ ដូច្នេះហើយ ក្រោកឡើងដើរទៅ ។ បុរសម្នាក់ទៀត បានស្ដាប់ពាក្យរបស់បុរសនោះហើយ ពោលថា បុរសនេះពោលថា មង្គលហើយ ក៏ទៅបាត់ អ្វីឈ្មោះថា មង្គលហ្ន៎ ។ បុរសម្នាក់ទៀតក្រៅអំពីជនទាំង ២ ដែលពោលហើយ ពោលឡើងថា ការឃើញរូប ជាមង្គលក្រៃលែង សេចក្ដីពិត បុគ្គលពួកខ្លះ ក្រោកឡើងអំពីព្រលឹមបានឃើញគោសសុទ្ធក្ដី ស្រីមានគភ៌ដេកក្ដី ត្រីត្ដិទក្ដី ក្អមពេញដោយទឹកក្ដី នវនីតក្ដី សប្បិក្ដី សំពត់ថ្មីក្ដី បាយាសក្ដី ការឃើញយ៉ាងនេះ ឈ្មោះថា ជាមង្គល ក្រៅអំពីនេះ មិនឈ្មោះថាជាមង្គលឡើយ ជនពួកខ្លះក៏នាំគ្នាត្រេកអរនឹងពាក្យបុរសនោះពោលថា បុរសនេះនិយាយត្រូវ ។

បុរសម្នាក់ទៀតជំទាស់ឡើងថា ទុំះមិនមែនមង្គលទេ ការស្ដាប់ឈ្មោះថាជាមង្គល បុគ្គលខ្លះបានស្ដាប់ពាក្យមនុស្សដែលពោលថា បុណ្ណា ( បរិបូណ៌ ) វឌ្ឍា ( ចម្រើន ) វឌ្ឍមានា ( សប្បាយ ) កុញ្ជា ( បរិភោគ ) ខាទា ( ទំពាស៊ី ) ដូច្នេះ ការបានស្ដាប់យ៉ាងនេះ ឈ្មោះថា មង្គល អ្វីដទៃ

ក្រៅអំពីនោះ មិនឈ្មោះថាជាមង្គលឡើយ បុគ្គលពួកខ្លះ នាំគ្នាត្រេកអរថា បុរសនេះនិយាយត្រូវ ។

បុរសម្នាក់ទៀតជំទាស់ឡើងថា ទុំះមិនមែនជាមង្គល ការប៉ះពាល់ ជាមង្គល សេចក្តីពិត បុគ្គលខ្លះក្រោកឡើងអំពីព្រលឹម បានប៉ះពាល់ផែនដី ស្មៅដែលមានពណ៌ខៀវ អាចម៍គោស្រស់ សំពត់ដែលស្អាត ត្រីឆ្លិន មាស ប្រាក់ ឬភោជន ការប៉ះពាល់របស់ទាំងនេះ ឈ្មោះថា ជាមង្គល ក្រៅអំពីនេះមិនឈ្មោះថា ជាមង្គលឡើយ បុគ្គលពួកខ្លះក៏នាំគ្នាត្រេកអរនឹងពាក្យរបស់បុរសនោះ ពោលថា និយាយត្រូវ ។ មនុស្សទាំងឡាយមានការឃើញផ្សេងគ្នា ជា ៣ ពួកយ៉ាងនេះ គឺពួកទិដ្ឋមង្គលិក ១ ពួកសុតមង្គលិក ១ និងពួកមុតមង្គលិក ១ មិនអាចយល់ឃើញស្របគ្នាបាន ទេវតាទាំងឡាយ តាំងពីភុម្មទេវតា រហូតដល់ព្រហ្មលោក ក៏មិនដឹងពិតថា របស់នេះជាមង្គល ។

សក្កទេវរាជទ្រង់ព្រះតម្រិះថា ក្នុងលោក ព្រមទាំងទេវលោក អ្នកដទៃក្រៅពីព្រះមានព្រះភាគ ឈ្មោះថា អាចពោលស្រាយមង្គលប្បញ្ហានេះបាន មិនមានឡើយ អាត្មាអញនឹងចូលគាល់ព្រះសាស្តាទូលសួរបញ្ហានេះ លុះដល់រាត្រី ទើបទ្រង់ចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំហើយ ផ្គងអញ្ជលីទូលសួរនូវបញ្ហាដោយគាថាដូច្នេះថា **ពហូ ទេវា មនុស្សា ច** ដូច្នេះជាដើម ។ គ្រានោះ ព្រះសាស្តាត្រាស់មង្គល ៣៨ ប្រការ ១២ គាថា ដល់សក្កទេវរាជ កាលមង្គលសូត្រចប់ ទេវតាប្រមាណមួយសែនកោដិ បានសម្រេចអរហត្ត ជាព្រះសោតាបន្នជាដើម រាប់មិនអស់ឡើយ សក្កទេវរាជស្តាប់មង្គលហើយ

យានទៅវិមានរបស់ទ្រង់ ។

កាលព្រះសាស្តាទ្រង់ត្រាស់មង្គលហើយ មនុស្ស ព្រមទាំងទេវតាក៏នាំគ្នាត្រេកអរថា ព្រះសាស្តាមានព្រះតម្រាស់ត្រូវ ។ កាលនោះ ភិក្ខុទាំងឡាយប្រជុំគ្នាសរសើរព្រះគុណរបស់ព្រះសាស្តាក្នុងធម្មសភាថា អាវុសោទាំងឡាយ ព្រះសាស្តាទ្រង់ដោះស្រាយមង្គលប្បញ្ហាផុតវិស័យរបស់អ្នកដទៃ កាត់នូវការសង្ស័យរបស់មនុស្ស និងទេវតាបាន ដូចព្រះចន្ទ ដែលតាំងឡើងក្នុងលម្ហ ដូច្នោះ អាវុសោទាំងឡាយ ព្រះសាស្តាទ្រង់មានព្រះបញ្ញាច្រើនដល់ម៉្លេះ ។ ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងនោះ ក្រាបទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គ ដោយរឿងនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការដោះស្រាយមង្គលប្បញ្ហារបស់តថាគត ដែលសម្រេចសម្ពោធិញ្ញាណហើយក្នុងកាលឥឡូវនេះ មិនជាអស្ចារ្យទេ តថាគតកាលនៅជាពោធិសត្វប្រព្រឹត្តបរិយធម៌ បានពោលស្រាយមង្គលប្បញ្ហា កាត់នូវសេចក្តីសង្ស័យរបស់ទេវតា និងមនុស្សទាំងឡាយបាន ដូច្នេះហើយ ទ្រង់នាំរឿងក្នុងអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ ដែលសម្បូរដោយទ្រព្យ ក្នុងនិគមមួយ មាតាបិតាបានដាក់ឈ្មោះថា **រក្ខិតកុមារ** ។ រក្ខិតកុមារនោះ កាលចម្រើនវ័យ រៀនសិប្បៈក្នុងនគរតក្កសិលាសម្រេចហើយ មានភរិយា កាល

មាតាបិតាអនិច្ចកម្មទៅ ពិនិត្យទ្រព្យសម្បត្តិ កើតនូវមហាសង្វេគ បានឲ្យទានដ៏ធំ លះកាម បួសក្នុងដែនដីហិមពាន្ត ធ្វើឈាន និងអភិញ្ញាឲ្យកើត មានជំទ្បង និងផ្លែឈើក្នុងព្រៃជាអាហារ ក្នុងភូមិប្រទេសមួយកន្លែង មានអន្តេវាសិកជាបរិវារច្រើន រហូត ៥០០ នាក់ ។

ថ្ងៃមួយ តាបសទាំងនោះចូលទៅរកព្រះពោធិសត្វ ថ្វាយបង្គំហើយ ពោលថា បពិត្រលោកអាចារ្យ សម័យនេះជារដូវភ្លៀង យើងទាំងឡាយនឹងចុះអំពីហិមវន្តប្បទេស ចារិកទៅតាមជនបទ ដើម្បីសេពរសជូរប្រៃ ដោយអាការដូច្នេះ រាងកាយរបស់ពួកយើងនឹងរឹងមាំ និងជាការសម្រាកស្មុងផងដែរ កាលព្រះពោធិសត្វពោលថា កាលបើដូច្នោះ ចូរពួកលោកទៅចុះ ខ្ញុំនៅក្នុងទីនេះឯង តាបសទាំងនោះក៏ថ្វាយបង្គំព្រះពោធិសត្វ ហើយចេញអំពីដែនដីហិមពាន្ត ចារិកដល់នគរពារាណសី សម្រាកក្នុងព្រះរាជឧទ្យាន សក្ការៈ និងការរាប់អាន ក៏មានដល់តាបសទាំងនោះដោយច្រើន ។

ថ្ងៃមួយ មហាជនប្រជុំគ្នាត្រង់រោងទទួលភ្ញៀវ ក្នុងនគរពារាណសី តាំងមង្គលបញ្ហាឡើង សេចក្តីទាំងអស់គប្បីជ្រាបតាមន័យក្នុងរឿងបច្ចុប្បន្ននោះឯង ។ ក្នុងគ្រានោះ មហាជនមិនអាចស្រាយមង្គលបញ្ហាកាត់នូវសេចក្តីសង្ស័យរបស់ពួកមនុស្សបាន ទើបនាំគ្នាទៅព្រះរាជឧទ្យាន សួរមង្គលបញ្ហានឹងពួកឥសី ពួកឥសីទាំងឡាយក៏ប្រឹក្សានឹងព្រះរាជាថា បពិត្រមហារាជ អាត្មាទាំងឡាយមិនអាចឆ្លើយមង្គលបញ្ហានេះបាន តែអាចារ្យរបស់ពួកអាត្មា ឈ្មោះរក្ខិតតាបស ជាអ្នកមានបញ្ញាច្រើន ដែលលោកនៅក្នុងដែនដីហិមពាន្ត

លោកនឹងឆ្លើយមង្គលបញ្ហានេះយ៉ាងក្បោះក្បាយដល់មនុស្ស និងទេវតាទាំងឡាយ ព្រះរាជាត្រាស់ថា បពិត្រលោកម្ចាស់ ឈ្មោះថា ដែនដីហិមពាន្តឆ្ងាយណាស់ នឹងទៅក៏លំបាក ពួកខ្ញុំមិនអាចទៅទីនោះបានទេ បើយកល្អលោកម្ចាស់ទាំងឡាយនោះឯង ទៅកាន់សម្នាក់អាចារ្យ សួរប្រស្នាហើយរៀនឲ្យចាំ ត្រឡប់មកប្រាប់ដល់ពួកខ្ញុំ ។

តាបសទាំងនោះទទួលថា សាធុ ហើយទៅកាន់សម្នាក់អាចារ្យ ថ្វាយបង្គំហើយ កាលអាចារ្យធ្វើបដិសណ្ឋារៈ សួរដល់គុណធម៌របស់ព្រះរាជា និងជនបទដែលចារិកទៅ ក៏ប្រាប់ហេតុនៃទិដ្ឋមង្គលជាដើម តាំងអំពីដើមដល់ចប់ ហើយប្រកាសភាពដែលព្រះរាជាអារាធនា និងខ្លួនលំបាកដឹងបញ្ហា ទើបមករកអាចារ្យ អារាធនាថា បពិត្រលោកម្ចាស់ យើងខ្ញុំសូមឱកាស សូមលោកម្ចាស់ ពោលមង្គលបញ្ហាឲ្យជាក់ច្បាស់ដល់យើងទាំងឡាយចុះ ។ លំដាប់នោះ អន្តេវាសិកធំ កាលសួរអាចារ្យ ក៏ពោលគាថាដំបូងថា

ក្នុងកាល ( ជាទីប្រាថ្នានូវមង្គល ) នរជនសែកមន្តដូចម្តេច
អាស្រ័យនូវវិជ្ជាដូចម្តេច ឬ ( នូវបរិយត្តិ ) នៃសូត្រទាំងឡាយ
ដូចម្តេច ជននោះ ទើបឈ្មោះថា គ្រប់គ្រងខ្លួនដោយសួស្តីក្នុង
លោកនេះ និងលោកខាងមុខ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កាលេ** បានដល់ ក្នុងកាលប្រាថ្នាមង្គល ។ បទថា **វិជ្ជំ** បានដល់ វេទ ។ បទថា **សុតានំ** បានដល់ បរិយត្តិដែលខ្លួនគួរសិក្សា ។ សព្ទថា **ច** ក្នុងពាក្យថា **អស្មឹ ច** នេះ ត្រឹមតែជានិបាត ។

បទថា **សោត្ថានេន** បានដល់ មង្គលដែលជាគ្រឿងនាំសួស្ដីមកឲ្យ ។

សេចក្ដីនេះ មានអធិប្បាយថា បពិត្រលោកអាចារ្យ នរជនកាលត្រូវការមង្គល គួររាយវេទបទណា ក្នុងកាលដែលជាមង្គល គឺគួរសែកវេទអ្វី ក្នុងបណ្ដាវេទទាំង ៣ យ៉ាងក្ដី ឬសុត្តបរិយត្តិណា ក្នុងរវាងសុត្តៈទាំងឡាយក្ដី សត្វនោះធ្វើដូចម្ដេច គឺដោយនិយាមដូចម្ដេច ទើបជាបុគ្គលដែលសួរក្ដី គឺដែលមង្គលប្រាសចាកទោស គ្រប់គ្រងហើយ គឺរក្សាហើយ ទាំងក្នុងលោកនេះ និងលោកខាងមុខ សូមលោកឲ្យកាន់យកប្រយោជន៍ក្នុងលោកនេះ និងប្រយោជន៍ក្នុងលោកខាងមុខ សម្ដែងអធិមង្គលដល់យើងខ្ញុំទាំងឡាយចុះ ។

កាលអន្តេវាសិកច្បង សួរមង្គលបញ្ហាយ៉ាងនេះហើយ ព្រះមហាសត្វកាលនឹងកាត់សេចក្ដីសង្ស័យរបស់ទេវតានិងមនុស្សទាំងឡាយ សម្ដែងមង្គលដោយពុទ្ធលីលាថា នេះផង នេះផង ជាមង្គល ទើបពោលគាថាទី ២ ថា

ពួកទេវតាក្ដី ពួកបិតា ( ព្រហ្ម ) ទាំងអស់ក្ដី ពួកទីឃជាតិក្ដី
ពួកសត្វទាំងអស់ក្ដី ដែលបុគ្គលណាកោតក្រែងដោយមេត្តាចិត្ត
អស់កាលជានិច្ច បណ្ឌិតទាំងឡាយពោលនូវមេត្តាចិត្ត ក្នុងពួក
សត្វនោះ ថាជាសួស្ដីរបស់បុគ្គលនោះដោយពិត ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យស្ស** បានដល់ ដែលបុគ្គលណា ។ បទថា **ទេវា** បានដល់ កាមាវចរទេវតាទាំងអស់ ចាប់តាំងអំពីភុម្មទេវតាទៅ ។ បទថា **បិតរោ ច** បានដល់ រូបាវចរព្រហ្មខាងលើ គឺខ្ពស់ជាងភុម្មទេវតានោះ

ទៅ ។ បទថា **សីវសថា** បានដល់ ទីយជាតិទាំងឡាយ ។ បទថា **សព្វ-ភូតានិ ចាបិ** បានដល់ សត្វទាំងឡាយគ្រប់ពួកដ៏សេស ក្រៅអំពីសត្វដែលប្រារព្ធហើយ ។ បទថា **មេត្តាយ និច្ចំ អបចិតានិ ហោន្តិ** សេចក្តីថា សត្វទាំងពួងនោះ ដែលបុគ្គលណាឱនលំទោន គឺគោរពរាប់អានដោយមេត្តាភាវនា ដល់នូវភាពជាអប្បនា ដែលប្រព្រឹត្តទៅហើយ ដោយអំណាចនៃការផ្សាយមេត្តាទៅក្នុងទិសទាំង ១០ ។ បទថា **ភូតេសុ វេ** សេចក្តីថា បណ្ឌិតទាំងឡាយពោលមេត្តាភាវនានោះនៃបុគ្គលនោះថា ជាសុវត្ថិមង្គលក្នុងសព្វសត្វទាំងឡាយ គឺមង្គលដែលប្រាសចាកទោស ដែលប្រព្រឹត្តទៅហើយ អស់កាលជានិច្ច ។

ពិតហើយ បុគ្គលមានប្រក្រតីនៅដោយមេត្តា រមែងជាទីស្រឡាញ់នៃសត្វទាំងឡាយទាំងពួង ជាអ្នកមិនត្រូវបៀតបៀន ដោយសេចក្តីព្យាយាមរបស់អ្នកដទៃ ដោយហេតុដូចពោលនេះ បុគ្គលនោះ ទើបជាបុគ្គលដែលមង្គលនេះរក្សាគ្រប់គ្រង ។

ព្រះមហាសត្វ កាលសម្តែងមង្គលទី ១ ដូច្នេះហើយ កាលនឹងសម្តែងមង្គលទី ២ ជាដើម ទើបពោលគាថាទាំងឡាយថា

> បុគ្គលណា ប្រព្រឹត្តឱនលំទោន ចំពោះសត្វលោកទាំងអស់ ជា
> អ្នកអត់ទ្រាំនូវពាក្យនៃស្រីប្រុស និងក្មេងទាំងឡាយដែលពោល
> អាក្រក់ ជាអ្នកពោលពាក្យមិនជាទីខ្ពើម បណ្ឌិតទាំងឡាយ
> ពោលនូវការអត់ទ្រាំនោះ ថាជាសួស្តី ( របស់បុគ្គលនោះ ) ។

បុគ្គលណា មានប្រាជ្ញាភ្លឺថ្លា មានបញ្ញាវាងវៃ ក្នុងកាលដែលកើតឡើងនៃហេតុ មិនមើលងាយនូវសម្លាញ់ និងមិត្តដោយសិល្បវិជ្ជា ដោយកុលសម្បត្តិ ដោយទ្រព្យ ដោយជាតិ បណ្ឌិតទាំងឡាយ បានពោលនូវការមិនមើលងាយក្នុងពួកសម្លាញ់នោះថាជាសួស្តី ( របស់បុគ្គលនោះ ) ។

ពួកជនណា ជាអ្នកមិនពោលបន្ទុស ជាសប្បុរស ជាមិត្តស្និទ្ធ-ស្នាល ជាអ្នកមិនទ្រុស្តមិត្ត ចែករំលែកដោយទ្រព្យ បណ្ឌិតទាំងឡាយ បានពោលនូវការស្និទ្ធស្នាលក្នុងមិត្តទាំងឡាយនោះថាជាសួស្តី ( របស់ជននោះ ) ។

បុគ្គលណា មានភរិយា មានវ័យប្រហែលគ្នា មានសេចក្តីព្រមព្រៀងគ្នា ជាអ្នកប្រព្រឹត្តតាម ប្រាថ្នាធម៌ ជាស្រីមានកូនមានសីលធម៌ដោយគួរដល់ត្រកូល មានវត្តដល់ប្តី ពួកបណ្ឌិតបានពោលនូវចរិយានៃភរិយាទាំងឡាយនោះថាជាសួស្តី ( របស់ស្វាមីនោះ ) ។

ព្រះរាជាជាម្ចាស់របស់សត្វ មានយស តែងជ្រាបនូវសេចក្តីស្អាត និងសេចក្តីព្យាយាមរបស់រាជសេវកាមាត្យណាថា ( សេវកាមាត្យនោះ ) មិនបែកចិត្ត ( អំពីអញ ) ជាអ្នកមានចិត្តល្អចំពោះអញ បណ្ឌិតទាំងឡាយបានពោលនូវសេចក្តីល្អក្នុងព្រះរាជាទាំងឡាយនោះថាជាសួស្តី ( របស់រាជសេវកាមាត្យ ) ។

បុគ្គលណា មានសទ្ធា មានចិត្តជ្រះថ្លា ត្រេកអរ ឲ្យបាយ ទឹក ផ្កាកម្រង គ្រឿងក្រអូប និងគ្រឿងលាប បណ្ឌិតទាំងឡាយបាន ពោលនូវសេចក្តីល្អនោះ ថាជាសួស្តីក្នុងឋានសួគ៌ទាំងឡាយ ( របស់បុគ្គលនោះ ) ។

ពួកបុគ្គលណា ដឹងច្បាស់ដោយញាណ រមែងញុាំងបុគ្គលណា ឲ្យស្អាតដោយអរិយធម៌ ជាអ្នកត្រេកអរក្នុងការប្រព្រឹត្តល្អ ជាអ្នក រៀនសូត្រច្រើន ជាអ្នកស្វែងរកគុណ ជាអ្នកមានសីល បណ្ឌិត ទាំងឡាយបានពោលនូវសេចក្តីល្អ ក្នុងកណ្តាលនៃព្រះអរហន្ត នោះ ថាជាសួស្តី ( របស់បុគ្គលនោះ ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **និវាតវុត្តិ** បានដល់ ជាបុគ្គលដែលមាន ការប្រព្រឹត្តឱនលំទោនដល់សត្វលោកទាំងពួង ដោយភាពជាអ្នកមានចិត្តទន់ភ្លន់ ។ បទថា **ខន្តា ទុរុត្តានំ** បានដល់ ជាបុគ្គលអត់សង្កត់ចំពោះពាក្យ អាក្រក់ ដែលអ្នកដទៃពោល ។ បទថា **អប្បដិក្កូលវាទី** បានដល់ មិនធ្វើ ការប្រកែកប្រណាំងថា បុគ្គលឈ្មោះនោះ បានជេរអញ បុគ្គលឈ្មោះនោះ បានប្រហារអញ ពោលតែវាចាដែលសមគួរដល់ហេតុប៉ុណ្ណោះ ។ បទថា **អធិវាសនំ** សេចក្តីថា បណ្ឌិតទាំងឡាយ តែងពោលនូវការអត់ធន់នេះ របស់បុគ្គលនោះ ថាជាសុវត្ថិមង្គល គឺជាមង្គលដែលប្រាសចាកទោស ។

បទថា **សហាយមិត្តេ** បានដល់ បុគ្គលជាសម្លាញ់ផង ជាសម្លាញ់នឹង មិត្រផង ក្នុងបុគ្គល ២ ពួកនោះ បុគ្គលដែលលេងដីរួមគ្នាមក ឈ្មោះថា

សម្លាញ់ បុគ្គលដែលនៅរួមគ្នា ១០-១២ ឆ្នាំ ឈ្មោះថា សម្លាញ់ផង មិត្រផង មិនមើលងាយមិត្តសម្លាញ់ទាំងនោះដោយសិប្បៈ យ៉ាងនេះថា អញមានសិប្បៈ ជនទាំងនេះគ្មានសិប្បៈ ឬដោយត្រកូល ពោល គឺកុលសម្បត្តិយ៉ាងនេះថា យើងមានត្រកូល ជនទាំងនេះ មិនមានត្រកូល ឬដោយទ្រព្យ យ៉ាងនេះថា យើងស្តុកស្តម្ភ ជនទាំងនេះជាអ្នកក្រីក្រ ឬដោយជាតិយ៉ាងនេះថា យើងដល់ព្រមដោយជាតិ ជនទាំងនេះ ជាបុគ្គលមានជាតិអាក្រក់ ។ បទថា **រុចិបញ្ញោ** បានដល់ ជាអ្នកមានបញ្ញាល្អ គឺមានបញ្ញាស្អាត ។ បទថា **អត្ថកាលេ** បានដល់ ក្នុងកាលមានសេចក្តីត្រូវការ គឺហេតុណាមួយកើតឡើង ។ បទថា **មតីមា** សេចក្តីថា ឈ្មោះថា ជាអ្នកដឹងធុះធ្លាយ ព្រោះជាអ្នកអាចក្នុងការកំណត់ ពិចារណាប្រយោជន៍ គឺវត្ថុដែលត្រូវបំណាង មិនមើលងាយសម្លាញ់ទាំងនោះ ។ បទថា **សហាយេសុ** សេចក្តីថា បុរាណកបណ្ឌិតទាំងឡាយ ពោលការមិនមើលងាយសម្លាញ់របស់បុគ្គលនោះថា ជាសុវត្ថិមង្គល ក្នុង សម្លាញ់ទាំងឡាយដោយពិត ។

បើដូច្នោះ បុគ្គលនោះ រមែងជាបុគ្គលដែលមង្គលប្រាសចាកទោសគ្រប់គ្រងរក្សាហើយ ទាំងក្នុងលោកនេះ និងលោកខាងមុខ ក្នុងសេចក្តីនោះ បណ្ឌិតគប្បីពោលទទួលសួស្តី ព្រោះអាស្រ័យសម្លាញ់ដែលជាបណ្ឌិត ដោយកុសនាឡិជាតក ។

បទថា **សន្តោ** សេចក្តីថា សប្បុរសទាំងឡាយដែលជាបណ្ឌិត ជាមិត្តពិតនៃបុគ្គលណា ។ បទថា **សារិស្សត្ថា** បានដល់ ជាអ្នកដល់នូវការស្និទ្ធ-

ស្នាល ដោយអំណាចនៃការចូលទៅកាន់ផ្ទះហើយ កាន់យកវត្ថុដែលត្រូវការបាន ។ បទថា **អវិសំវាទកស្ស** បានដល់ ជាអ្នកមានប្រក្រតីពោលមិនឃៀងឃ្លាត ។ បទថា **ន មិត្តទុព្ភី** សេចក្ដីថា ម្យ៉ាងទៀត បុគ្គលណាជាអ្នកមិនទ្រុស្តមិត្រ ។ បទថា **សំវិភាគី ធនេន** បានដល់ ធ្វើការចែករំលែកទ្រព្យរបស់ខ្លួនឲ្យដល់មិត្រ ។ បទថា **មិត្តេសុ** សេចក្ដីថា ការបានប្រយោជន៍ ព្រោះអាស្រ័យមិត្រនោះ របស់បុគ្គលនោះ ឈ្មោះថា ជាសុវត្ថិមង្គលក្នុងមិត្រទាំងឡាយ ពិតហើយ បុគ្គលដែលមិត្រទាំងឡាយបែបនេះរក្សាហើយ រមែងដល់នូវសួស្ដី ។ ក្នុងសេចក្ដីនោះ បណ្ឌិតគប្បីពោលសួស្តី ព្រោះអាស្រ័យមិត្រទាំងឡាយដោយជាតកទាំងឡាយ មានមហាឧក្កុសជាតកជាដើម ។

បទថា **តុល្យវយា** បានដល់ មានវ័យស្មើគ្នា ។ បទថា **សមគ្គា** បានដល់ ដែលនៅរួមគ្នា ដោយព្រមព្រៀងគ្នា ។ បទថា **អនុព្វតា** បានដល់ ប្រព្រឹត្តតាមចិត្តគ្នា ។ បទថា **ធម្មកាមា** បានដល់ ពេញចិត្តនឹងសុចរិតធម៌ ៣ ប្រការ ។ បទថា **បជាតា** បានដល់ មានប្រក្រតីញុំាងបុត្រឲ្យប្រសូតគឺមិនជាស្រីអារ ។ បទថា **ទារេសុ** សេចក្ដីថា បណ្ឌិតទាំងឡាយពោលថា មាតុគ្រាមប្រកបដោយគុណទាំងនេះនៅក្នុងផ្ទះ រមែងជាសុវត្ថិមង្គលរបស់ស្វាមី ក្នុងសេចក្ដីនោះ បណ្ឌិតគប្បីពោលសួស្តី ព្រោះអាស្រ័យមាតុគ្រាមអ្នកមានសីល ដោយមណិចោរជាតក និងសម្ពុលាជាតក និងខណ្ឌហាលជាតក ។ បទថា **សោចេយ្យំ** បានដល់ ភាពជាអ្នកស្អាត ។ បទថា **អទ្វេជ្ឈតា** សេចក្ដី

ថា ទ្រង់ជ្រាបរាជសេវកៈណា ដោយភាពជាបុគ្គលមិនបៀតបៀនទ្រង់ គឺដោយភាពជាអ្នកមិនបែកចិត្តជា ២ ជាមួយទ្រង់យ៉ាងនេះថា រាជសេវកៈនោះមិនធ្លាប់បែកជាមួយអញជា ២ ចំណែក ។ បទថា **សុហាទយំ មមំ** សេចក្តីថា ទ្រង់ជ្រាបរាជសេវកៈណាថា រាជសេវកៈនោះ មានភក្តីចំពោះអញ ។ បទថា **រាជូសុ វេ** សេចក្តីថា កាលបើដូច្នោះ បណ្ឌិតទាំងឡាយពោលគុណយ៉ាងនេះរបស់រាជសេវកៈទាំងនោះថា ជាសុវត្ថិមង្គល ក្នុងព្រះរាជាទាំងឡាយ ។ បទថា **ឧធាតិ សទ្ធោ** បានដល់ ជឿកម្ម និងផលនៃកម្ម ហើយឲ្យ ។ បទថា **សគ្គេសុ វេ** សេចក្តីថា កាលបើដូច្នោះ បណ្ឌិតទាំងឡាយរមែងពោលគុណនោះរបស់បុគ្គលនោះ ថាជាសុវត្ថិមង្គល គឺជាមង្គលដែលប្រាសចាកទោសក្នុងស្ថានសួគ៌ គឺក្នុងទេវលោក បណ្ឌិតគប្បីពោលអាងដល់សេចក្តីនោះ ដោយរឿងប្រេត( បេតវត្ថុ ) និងរឿងវិមាន( វិមានវត្ថុ ) ឲ្យពិស្តារ ។ បទថា **បុនន្តិ វុឌ្ឍា** សេចក្តីថា សប្បុរសទាំងឡាយ ដែលដឹងច្បាស់ដោយញាណ ញុំាងបុគ្គលណាឲ្យបរិសុទ្ធ គឺឲ្យផូរផង់ដោយអរិយធម៌ ។

បទថា **សមចរិយាយ** បានដល់ ក្នុងសម្មាបដិបត្តិ ។ បទថា **ពហុស្សុតា** បានដល់ ដែលស្តាប់ច្រើន ដើម្បីបដិវេធ ។ បទថា **ឥសយោ** បានដល់ អ្នកស្វែងរកគុណ ។ បទថា **សីលវន្តោ** បានដល់ ដែលប្រកបដោយអរិយសីល ។ បទថា **អរហន្តមជ្ឈេ** សេចក្តីថា បណ្ឌិតទាំងឡាយ រមែងសរសើរសេចក្តីល្អនៃសប្បុរសនោះថា ជាសុវត្ថិមង្គល ដែលគប្បីបានក្នុងចំណោមព្រះអរហន្ត ដ្បិតថា ព្រះអរហន្តទាំងឡាយ កាលប្រាប់មគ្គដែលខ្លួនបាន

ហើយ ឲ្យអ្នកដទៃបដិបត្តិ រមែងញុំាងបុគ្គលដែលត្រេកអរឲ្យបរិសុទ្ធដោយអរិយធម៌ សូម្បីបុគ្គលនោះ ក៏ជាព្រះអរហន្តនោះឯង ។

ព្រះមហាសត្វកាន់យកកំពូលនៃទេសនា ដោយព្រះអរហត្ត សម្តែងមង្គល ៨ ដោយគាថា ៨ យ៉ាងនេះហើយ កាលនឹងសរសើរមង្គលទាំងនោះបានពោលគាថាចុងក្រោយថា

សួស្តីមង្គលទាំងឡាយនេះឯង វិញ្ញូជនតែងសរសើរ មានសេចក្តីសុខជាកម្រៃក្នុងលោក នរជនអ្នកប្រកបដោយប្រាជ្ញាក្នុងលោកនេះ គប្បីសេពគប់នូវសួស្តីមង្គលទាំងឡាយនោះ វត្ថុណាមួយក្នុងមង្គល ( មានទិដ្ឋមង្គលជាដើម ) មិនឈ្មោះថាជាសច្ចៈទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ន ហិ មង្គលេ** សេចក្តីថា ក្នុងមង្គល មានប្រភេទ គឺទិដ្ឋមង្គល សុតមង្គល និងមុតមង្គលនោះ សូម្បីមង្គលនោះ ត្រឹមតែបន្តិចបន្តួច ឈ្មោះថា ជាមង្គលពិតៗ មិនមានឡើយ ព្រះនិព្វានតែម្យ៉ាងប៉ុណ្ណោះ ជាបរមត្ថមង្គលពិតៗ ។

ឥសីទាំងឡាយស្តាប់មង្គលទាំងនោះហើយ លុះកន្លងទៅ ៧-៨ ថ្ងៃ ក៏នាំគ្នាលាអាចារ្យទៅក្នុងព្រះរាជឧទ្យាននោះ ព្រះរាជាយាងទៅកាន់សម្នាក់ឥសីទាំងនោះ ហើយសួរបញ្ហា ឥសីទាំងឡាយពោលឆ្លើយនូវមង្គលបញ្ហា តាមទំនងដែលអាចារ្យប្រាប់ដល់ព្រះរាជា ហើយត្រឡប់ទៅកាន់ដែនដីហិមពាន្តតាំងពីនោះមក មង្គលបានប្រាកដក្នុងលោក បុគ្គលដែលប្រព្រឹត្តក្នុងមង្គល

ទាំងឡាយ ស្លាប់ទៅកើតក្នុងស្ថានសួគ៌ ព្រះពោធិសត្វចម្រើនព្រហ្មវិហារ ៤ នាំពួកឥសីទៅកើតក្នុងព្រហ្មលោក ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះ មកសម្តែងហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងឥឡូវនេះទេ ដែលតថាគត ស្រាយនូវមង្គលបញ្ហា សូម្បីក្នុងកាលមុន តថាគតក៏ស្រាយនូវមង្គល-បញ្ហាហើយ ដូច្នេះហើយ ទ្រង់ប្រជុំជាតកថា ពួកឥសីក្នុងកាលនោះ បាន មកជាពុទ្ធបរិស័ទក្នុងកាលឥឡូវនេះ អន្តេវាសិកដែលជាធំអ្នកសួរមង្គល-បញ្ហាក្នុងកាលនោះ បានមកជាសារីបុត្រ ចំណែកអាចារ្យក្នុងកាលនោះ គឺតថាគតនេះឯង ។ល។

**អដ្ឋកថា មហាមង្គលជាតក ចប់**

# សុត្តន្តបិដក

## ឃតបណ្ឌិតជាតក

[ ៧៨១ ] ( អាមាត្យឈ្មោះរោហិនេយ្យពោលថា ) បពិត្រព្រះអង្គជាកណ្ហាយនគោត្រ សូមព្រះអង្គក្រោកឡើង ព្រះអង្គនៅផ្ទំធ្វើអ្វី ប្រយោជន៍អ្វីរបស់ព្រះអង្គដោយការផ្ទំ ក្សត្រិយ៍ណាជាព្រះកនិដ្ឋភាតារបស់ខ្លួនព្រះអង្គ ( ស្មើដោយ ) ហឫទ័យនិងព្រះនេត្រខាងស្ដាំ ខ្យល់ចាប់រួបរឹតនូវហឫទ័យរបស់ក្សត្រិយ៍ជាព្រះកនិដ្ឋភាតានោះ បពិត្រព្រះកេសវៈ ឃតបណ្ឌិតរមែងអំពាវនាវថា ( អ្នកទាំងឡាយ ចូរឲ្យទន្សាយដល់យើង ) ។

[ ៧៨២ ] ( ព្រះសាស្ដាត្រាស់ថា ) ព្រះបាទកេសវៈ ទ្រង់ព្រះសណ្ដាប់ពាក្យរបស់អាមាត្យ ឈ្មោះរោហិនេយ្យនោះហើយ ក៏ទ្រង់ក្រោកឡើងរលះរលាំង ត្រូវសេចក្ដីសោកក្នុងព្រះកនិដ្ឋ-ភាតាគ្របសង្កត់ ។

[ ៧៨៣ ] ( ព្រះបាទកេសវៈសួរថា ) អ្នក ហេតុអ្វីក៏មានសភាពហាក់ដូចជាឆ្កួត ( ត្រាច់ទៅ ) កាន់នគរទ្វារវតីទាំងមូលនេះ និយាយរវើរវាយថា ទន្សាយៗ អ្នកណាលួចយកទន្សាយរបស់អ្នកទៅឬ ។

[ ៧៨៤ ] អ្នកប្រាថ្នានូវទន្សាយមាស កែវមណី ( លោហៈ ) ឬប្រាក់ ឬក៏ទន្សាយធ្វើដោយស័ង្ខ ដោយសិលា ដោយកែវប្រពាល យើងនឹងឲ្យគេធ្វើទន្សាយនោះដល់អ្នក ។ ( បើអ្នកមិន

ពេញចិត្តទន្សាយនោះទេ ) ទន្សាយឯទៀតក្នុងព្រៃ រកស៊ីក្នុងព្រៃ យើងនឹងឲ្យគេនាំទន្សាយទាំងនោះមកឲ្យអ្នក អ្នកត្រូវការទន្សាយបែបណា ( ចូរប្រាប់យើងក្នុងកាលឥឡូវនេះ ) ។

[ ៧៨៥ ] ( ឃតបណ្ឌិតឆ្លើយថា ) ពួកទន្សាយណាដែលអាស្រ័យនៅលើផែនដី ខ្ញុំមិនចង់បានទន្សាយនេះទេ ខ្ញុំចង់បានទន្សាយអំពីដួងព្រះចន្ទ បពិត្រព្រះកេសវៈ សូមព្រះអង្គញ៉ាំងទន្សាយនោះឲ្យចុះមកដើម្បីខ្ញុំ ។

[ ៧៨៦ ] ( ព្រះបាទកេសវៈ ... ) អ្នកណាប្រាថ្នានូវរបស់ដែលមិនគួរប្រាថ្នា ( ដូចជា ) អ្នកប្រាថ្នានូវទន្សាយអំពីដួងព្រះចន្ទ ម្នាលអ្នកជាញាតិ អ្នកនោះនឹងលះបង់ជីវិតជាទីស្រឡាញ់ដោយពិត ( ក៏មិនបានទន្សាយនោះដែរ ) ។

[ ៧៨៧ ] ( ឃតបណ្ឌិត ... ) បពិត្រព្រះកណ្ហាយនគោត្រ បើព្រះអង្គទ្រង់ជ្រាបយ៉ាងនោះ ព្រះអង្គទ្រង់ប្រៀនប្រដៅបុគ្គលដទៃហេតុអ្វី ព្រះអង្គសោកស្ដាយនឹងបុត្រដែលទទួលមរណកាលក្នុងកាលមុនរហូតមកក្នុងថ្ងៃនេះ ។

[ ៧៨៨ ] របស់ណាដែលមនុស្ស ឬអមនុស្សមិនគប្បីបានវិញដោយប្រាថ្នាថា ( ព្រះអង្គប្រាថ្នានូវរបស់នោះថា ) បុត្ររបស់អញកើតហើយកុំស្លាប់ឡើយ ដូច្នេះ ព្រះអង្គនឹងគប្បីបានរបស់ដែលមិនគប្បីបានអំពីទីណាកើត ។ បពិត្រព្រះកណ្ហាយនគោត្រ

ព្រះអង្គសោកស្ដាយនឹងបុត្រណា ដែលទៅកាន់បរលោកហើយ ព្រះអង្គអាចនាំបុត្រនោះមកវិញ ដោយមន្ត ដោយថ្នាំ ដែលធ្វើដោយឫសឈើ ដោយឱសថ ឬក៏ដោយទ្រព្យមិនបានឡើយ ។

[ ៧៨៩ ] ( ព្រះបាទកេសវៈសរសើរថា ) ពួកបុរសជាបណ្ឌិតប្រាកដដូច្នោះ ជាអាមាត្យរបស់ព្រះរាជាណា ដូចយ៉ាងអ្នកជាបណ្ឌិតបុរស ឈ្មោះឃតៈ បានពន្យល់ ( ខ្ញុំ ) ក្នុងថ្ងៃនេះ ( សោករបស់ព្រះរាជានោះ នឹងមានមកពីណា ) ។ អ្នកបានស្រោចស្រពនូវយើង ដែលក្ដៅ គឺសេចក្ដីសោកកំពុងឆេះ ឲ្យស្ងប់រម្ងាប់ ញុំាងសេចក្ដីក្រវល់ក្រវាយទាំងអស់ឲ្យរលត់ ដូចបុគ្គលយកទឹកស្រោចនូវភ្លើង កំពុងឆេះឆ្នាំងខ្លាញ់ ។ សរ គឺសេចក្ដីសោកណា ដែលអាស្រ័យក្នុងហឫទ័យ សរ គឺសេចក្ដីសោកនោះ យើងបានដកចេញហើយ អ្នកឈ្មោះថាបានបន្ទោបង់នូវសេចក្ដីសោកព្រោះបុត្ររបស់យើង ដែលត្រូវសេចក្ដីសោកគ្របសង្កត់ ។ ម្នាលមាណព យើងនោះជាអ្នកមានសរ គឺសេចក្ដីសោកដកចេញហើយ ជាអ្នកប្រាសចាកសេចក្ដីសោក ម្នាលមាណព យើងលែងសោកស្ដាយ លែងយំទួញព្រោះបានស្ដាប់នូវពាក្យរបស់អ្នក ។

[ ៧៩០ ] ( ព្រះសម្ពុទ្ធត្រាស់ថា ) ពួកជនណា ប្រកបដោយប្រាជ្ញា ជាអ្នកអនុគ្រោះ រមែងធ្វើយ៉ាងនេះ ទើបញុំាងជនឲ្យឃ្លាត

ចាកសេចក្តីសោក ដូចយតបណ្ឌិតញុំាងព្រះជេដ្ឋា ( ឲ្យរួចចាកសេចក្តីសោក ) ។

**យតបណ្ឌិតជាតកទី ១៦ ចប់**

## ឧទ្ទាននៃជាតកនោះ គឺ

និយាយអំពីកំពែងនៃនគរដ៏មាំមួន ១ កណ្ហតាបស ១ ស្តេចធនញ្ជ័យ ១ សង្ខព្រាហ្មណ៍ ១ ព្រះរាជាពារាណសី ១ តាបសជ្រះថ្លាចំពោះព្រហ្មចរិយធម៌អស់ ៧ ថ្ងៃ ១ សាខកុមារ ១ តក្កលជាតក ១ មហាធម្មបាលជាតក ១ កុក្កុដជាតក ១ មដ្ឋកុណ្ឌលិជាតក ១ អ្នកឲ្យនូវភោជន ១ ចក្កវាកជាតក ១ ភូរិបញ្ហាជាតក ១ ប្រកបដោយសេចក្តីសួស្តី ១ យតបណ្ឌិតជាតក ១ ។

**ទសកនិបាត ចប់**

# អដ្ឋកថា

## ឃតបណ្ឌិតជាតក

[ ៧៨១-៧៩០ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធកុដុម្ពិកៈកូនស្លាប់ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ឧដ្ឋេហិ កណ្ហ** ដូច្នេះជាដើម ។

ផ្ទៃនៃរឿងដូចគ្នានឹងរឿងមដ្ឋកុណ្ឌលីនោះឯង ឯក្នុងជាតកនេះ មានសេចក្តីសង្ខេបដូច្នេះ

ព្រះសាស្តាយាងចូលទៅរកឧបាសកនោះហើយ ត្រាស់សួរថា ម្នាលឧបាសក អ្នកសោយសោកដល់កូនស្លាប់ឬ កាលឧបាសកទូលថា ករុណាព្រះអង្គ ទើបទ្រង់ត្រាស់ថា ម្នាលឧបាសក បុរាណកបណ្ឌិតស្តាប់ពាក្យរបស់បណ្ឌិតហើយ មិនសោយសោកដល់កូនដែលស្លាប់ទៅហើយឡើយ កាលឧបាសកនោះក្រាបទូលអារាធនាឲ្យត្រាស់រឿង ទើបទ្រង់នាំរឿងក្នុងអតីតមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះរាជាព្រះនាមមហាវង្ស សោយរាជសម្បត្តិក្នុងអសិតញ្ជនគរ ដែនកង្សកូត្រ ជិតឧត្តាបថបទេស ទ្រង់មានព្រះរាជឱរស ២ ព្រះអង្គ មួយអង្គព្រះនាមកង្សៈ មួយអង្គព្រះនាមឧបកង្សៈ មានព្រះធីតាមួយអង្គ ព្រះនាមទេវគព្ភា ក្នុងថ្ងៃដែលព្រះរាជធីតាប្រសូត ព្រាហ្មណ៍អ្នកទាយលក្ខណៈបានព្យាករថា ព្រះឱរសដែលកើតក្នុងព្រះគភ៌របស់ព្រះនាងទេវគព្ភានោះ នឹងធ្វើកង្សកូត្រ កង្សវង្សឲ្យវិនាស ព្រះរាជាមិនអាចឲ្យសម្រេចទោសព្រះរាជធីតាបាន ព្រោះទ្រង់ស្រឡាញ់ក្នុងព្រះរាជធីតាច្រើន សូម្បីព្រះ

រាជជេដ្ឋាទាំង ២ ក៏ទ្រង់ជ្រាបដូចគ្នា ។ ព្រះរាជាទ្រង់តាំងរាជសម្បត្តិ ដរាបដល់អស់ព្រះជន្មាយុហើយ ទ្រង់សោយទិវង្គត ។ កាលទ្រង់សោយទិវង្គតហើយ កង្សរាជឱរសបានជាព្រះរាជា ឧបកង្សរាជឱរសបានជាឧបរាជ ទាំង ២ ព្រះអង្គទ្រង់ព្រះតម្រិះថា បើយើងឲ្យសម្រេចទោសព្រះភគិនី យើងនឹងត្រូវគេតិះដៀល យកល្អ យើងមិនគួរឲ្យព្រះភគិនីនេះដល់បុគ្គលណាឡើយ នឹងមើលថែកុំឲ្យមានស្វាមី ដូច្នេះ ក្សត្រទាំង ២ ព្រះអង្គសាងប្រាសាទសសរមួយ ឲ្យព្រះរាជធីតានៅប្រាសាទនោះ ទាសីម្នាក់ឈ្មោះនន្ទគោបា ជាបរិចារិការបស់ព្រះនាង ទាសៈឈ្មោះអន្ធកវេណ្ហុ ជាប្តីរបស់នាងនន្ទគោបាជាអ្នករក្សាព្រះនាង ។

គ្រានោះ ព្រះបាទមហាសាគររាជ សោយរាជសម្បត្តិក្នុងឧត្តរាបថ-បទេស ទ្រង់មានឱរស ២ អង្គ មួយអង្គព្រះនាមសាគរ មួយអង្គទៀតព្រះនាមឧបសាគរ បណ្តាឱរស ២ អង្គនោះ កាលព្រះជនកសោយទិវង្គតហើយ សាគររាជឱរសបានជាព្រះរាជា ឧបសាគររាជឱរសបានជាឧបរាជ ។ ឧបសាគរឧបរាជនោះ ជាសម្លាញ់របស់ឧបកង្សឧបរាជ សម្រេចការសិក្សាជាមួយគ្នា ក្នុងសម្នាក់អាចារ្យជាមួយគ្នា ។

ឧបសាគរឧបរាជ បានធ្វើមិនល្អក្នុងស្នំជាទីស្រឡាញ់របស់ព្រះជេដ្ឋា-សាគររាជ ខ្លាចព្រះរាជអាជ្ញា ក៏គេចទៅកាន់សម្នាក់ឧបកង្សឧបរាជ ក្នុងដែនកង្សកូត្រ ឧបកង្សឧបរាជនាំមកគាល់ព្រះបាទកង្សរាជ ព្រះបាទកង្សរាជទ្រង់ប្រទានយសធំដល់ឧបសាគរឧបរាជ ឧបសាគរឧបរាជ កាលទៅគាល់ព្រះ

រាជា ឃើញប្រាសាទសសរមួយ ដែលជាទីប្រថាប់របស់ព្រះនាងទេវគព្ភា ទើបសួរថា ទីនោះជាប្រាសាទរបស់អ្នកណា កាលជ្រាបសេចក្តីនោះហើយ ក៏មានចិត្តប្រតិព័ទ្ធក្នុងព្រះនាងទេវគព្ភា ។ ថ្ងៃមួយ ព្រះនាងទេវគព្ភាទតឃើញ ឧបសាគរឧបរាជ ទៅគាល់ព្រះរាជាជាមួយឧបកង្សឧបរាជ ទើបត្រាស់សួរថា នុ៎ះជាអ្នកណា ព្រះនាងជ្រាបអំពីនាងនន្ទគោបាថា ជាឱរសព្រះបាទមហាសាគររាជ ព្រះនាមឧបសាគរ ក៏មានចិត្តប្រតិព័ទ្ធក្នុងឧបសាគរឧបរាជនោះ ។ ឧបសាគរឧបរាជ ឲ្យសំណូកនាងនន្ទគោបាហើយ ពោលថា នែប្អូនស្រី នាងអាចនាំព្រះនាងទេវគព្ភាមកឲ្យជួបយើងបានឬទេ នាងនន្ទគោបាពោលថា សេចក្តីនោះមិនជាលំបាកទេ ហើយប្រាប់រឿងនោះ ដល់ព្រះនាងទេវគព្ភា ។ ជាធម្មតា ព្រះនាងមានចិត្តប្រតិព័ទ្ធក្នុងឧបសាគរឧបរាជស្រាប់ហើយ គ្រាន់តែស្តាប់ដូច្នោះ ក៏ទទួលថា សាធុ ។ នាងនន្ទគោបាឲ្យសញ្ញាដល់ឧបសាគរឧបរាជឲ្យឡើងប្រាសាទក្នុងពេលរាត្រី ។ ឧបសាគរឧបរាជបានរួមសង្វាសជាមួយព្រះនាងទេវគព្ភា ដោយទំនងនោះរឿយៗ ព្រះនាងក៏តាំងគភ៌ ។ តមក ដំណឹងព្រះនាងមានគភ៌ ក៏បានប្រាកដឡើង ទើបព្រះជេដ្ឋាទាំង ២ សួរនាងនន្ទគោបាៗ ក្រាបទូលសូមអភ័យទោសហើយ ទូលរឿងសម្ងាត់នោះឲ្យទ្រង់ជ្រាប ។ ព្រះជេដ្ឋាទាំង ២ ជ្រាបហើយ ប្រឹក្សាគ្នាថា យើងមិនអាចសម្លាប់ប្អូនស្រីបាន បើនាងប្រសូតបុត្រី យើងមិនសម្រេចទោស តែបើប្រសូតព្រះឱរស យើងនឹងសម្រេចទោស ហើយប្រទានព្រះនាងទេវគព្ភាឲ្យដល់ឧបសាគរឧបរាជ ព្រះនាងទេវគព្ភាទ្រង់គភ៌គ្រប់កំណត់ហើយ ក៏ប្រសូត

បុត្រី ។ ព្រះជេដ្ឋាទាំង ២ ជ្រាបហើយ សប្បាយព្រះហឫទ័យ តាំងនាមឲ្យព្រះរាជធីតានោះថា **អញ្ជនទេវី** បានប្រទានស្រុកសួយឈ្មោះកោគវឌ្ឍមានៈដល់ស្តេចទាំង ២ ។ ឧបសាគរឧបរាជ ក៏នាំព្រះនាងទេវគព្ភាទៅប្រថាប់នៅក្នុងកោគវឌ្ឍមានគ្រាម ។ ព្រះនាងទេវគព្ភា ក៏មានគភ៌ទៀត សូម្បីនាងនន្ទគោបាក៏តាំងគភ៌ ក្នុងថ្ងៃនោះដូចគ្នា កាលស្រីទាំង ២ មានគភ៌គ្រប់កំណត់ហើយ ព្រះនាងទេវគព្ភាក៏ប្រសូតព្រះឱរស ឯនាងនន្ទគោបាក៏ប្រសូតកូនស្រីក្នុងថ្ងៃតែមួយនោះឯង ព្រះនាងទេវគព្ភាខ្លាចព្រះឱរសវិនាសដោយរាជភ័យ ទើបបញ្ជូនព្រះឱរសទៅឲ្យនាងនន្ទគោបា ហើយឲ្យនាងនន្ទគោបា នាំកូនស្រីមក ដោះដូរគ្នាចិញ្ចឹមជាសម្ងាត់ ។

អមាត្យទាំងឡាយក្រាបទូលភាព ដែលព្រះនាងទេវគព្ភាប្រសូតហើយឲ្យព្រះជេដ្ឋាទាំង ២ ទ្រង់ជ្រាប ព្រះជេដ្ឋាទាំង ២ អង្គនោះ ត្រាស់សួរថា ប្រសូតឱរស ឬជាធីតា កាលបានទទួលចម្លើយថា ធីតា ទើបត្រាស់ថា បើដូច្នោះ ចូរអ្នកទាំងឡាយចិញ្ចឹមចុះ ។ ព្រះនាងទេវគព្ភាប្រសូតព្រះឱរស ១០ អង្គ ឯនាងនន្ទគោបាក៏កើតកូនស្រី ១០ នាក់ ដូរគ្នាចិញ្ចឹមដោយឧបាយនេះ ។ ឱរសរបស់ព្រះនាងទេវគព្ភាចម្រើននៅក្នុងសម្នាក់របស់នាងនន្ទគោបា កូនស្រីរបស់នាងនន្ទគោបា ចម្រើននៅក្នុងសម្នាក់របស់ព្រះនាងទេវគព្ភា អ្នកណាម្នាក់ ក៏មិនដឹងអាថ៌កំបាំងនោះ ។

ព្រះឱរសច្បងរបស់ព្រះនាងទេវគព្ភា ឈ្មោះវាសុទេព អង្គទី ២ ឈ្មោះពលទេព ទី ៣ ឈ្មោះចន្ទទេព ទី ៤ ឈ្មោះសុរិយទេព ទី ៥ ឈ្មោះអគ្គិទេព

ទី ៦ ឈ្មោះវរុណទេព ទី ៧ ឈ្មោះអជ្ជុនៈ ទី ៨ ឈ្មោះបជ្ជុនៈ ទី ៩ ឈ្មោះឃតបណ្ឌិត ទី ១០ ឈ្មោះថា អង្កុរៈ ។ ឱរសទាំងនោះបានប្រាកដជាបងប្អូន ១០ នាក់ ជាកូនរបស់អន្ធកវេណ្ហុទាសៈ ។

ក្រោយមក ឱរសទាំងនោះចម្រើនវ័យហើយ មានកម្លាំងខ្លាំងក្លា ជាបុគ្គលគ្រោតគ្រាតក្រៃលែង នាំគ្នាត្រាច់ប្លន់មហាជន សូម្បីអ្នកនាំបណ្ណាការទៅថ្វាយព្រះរាជា ក៏នាំគ្នាប្លន់យកអស់ មហាជនប្រជុំគ្នា ស្រែកត្រង់លានព្រះរាជវាំងថា បងប្អូន ១០ នាក់ ដែលជាកូនរបស់អន្ធវេណ្ហុទាសៈប្លន់ស្រុក ព្រះរាជាត្រាស់ឲ្យហៅអន្ធកវេណ្ហុទាសៈ មកគំរាមថា ព្រោះហេតុអ្វី ទើបឯងបណ្ដោយកូនឲ្យធ្វើការប្លន់ ដូច្នេះ ។ កាលមហាជនមកស្រែកទាមទារ អស់វារៈ ២-៣ ដងយ៉ាងនេះ ព្រះរាជាក៏គំរាមអន្ធកវេណ្ហុទាសៈនោះ គាត់ខ្លាចនូវមរណភ័យទូលសូមអភ័យទោសនឹងព្រះរាជា ហើយក្រាបទូលថា បពិត្រព្រះសម្មតិទេព កូនទាំងនោះ មិនមែនកូនទូលបង្គំទេ ជាឱរសរបស់ឧបសាគរឧបរាជ ហើយក្រាបទូលរឿងសម្ងាត់នោះឲ្យទ្រង់ជ្រាប ។ ព្រះរាជាទ្រង់តក់ស្លុត ត្រាស់សួរអមាត្យទាំងឡាយថា យើងប្រើឧបាយដូចម្ដេច ទើបចាប់កុមារទាំងនោះបាន កាលពួកអមាត្យទូលថា បពិត្រព្រះសម្មតិទេព កុមារទាំងនោះ ចូលចិត្តខាងវាយតប់ ទូលបង្គំនឹងធ្វើការប្រកួតក្នុងព្រះនគរ ហើយឲ្យចាប់កុមារទាំងនោះ ដែលមកកាន់ទីប្រកួតសម្លាប់ចោលក្នុងទីនោះ ដូច្នេះ ទើបជ្រើសរើសយកអ្នកប្រដាល់ ២ នាក់ គឺអ្នកប្រដាល់ឈ្មោះវានុរៈ ១ ឈ្មោះមុដ្ឋិកៈ ១ ហើយឲ្យវាយស្គរប្រកាសក្នុងព្រះនគរថា បន្ទាប់អំពីនេះទៅ

៧ ថ្ងៃ នឹងមានការប្រកួត ដូច្នេះហើយ ឲ្យត្រៀមទីលានប្រកួតក្នុងលាន ព្រះរាជវាំង ឲ្យធ្វើវេទិកាសម្រាប់ប្រយុទ្ធ ហើយចងទង់ និងទង់ជ្វាលា ។

ដំណឹងនោះល្បីពេញព្រះនគរ មហាជននាំគ្នាចងកង់រទេះ និងគ្រែតូចធំតម្រួតលើគ្នា ។ វានុរៈ និងមុដ្ឋិកៈ ក៏មកកាន់ទីលានប្រយុទ្ធ ស្រែកគំរាមទះដៃដើរទៅដើរមក កុមារបងប្អូនទាំង ១០ ក៏មកតាមផ្លូវ ដែលលក់អាហារគ្រឿងក្រអូប និងគ្រឿងជ្រលក់ ហើយស្លៀកដណ្ដប់សំពត់ពណ៌ ជណ្ដើមយកគ្រឿងក្រអូប កាន់យកផ្កាតាមរានលក់ផ្កាមកប្រដាប់ខ្លួន ប្រដាប់ត្រចៀកទាំង ២ ស្រែកគំរាមតបទះដៃចូលកាន់លានប្រយុទ្ធ ខណៈនោះ វានុរៈដើរទះដៃ ពលទេពឃើញដូច្នោះ គិតថា អញមិនត្រូវវាយវានុរៈដោយដៃ ហើយទៅយកខ្សែចងដំរីមួយសរសៃធំមកអំពីរោងដំរី ស្រែកឌីដង ហើយបោះខ្សែទៅទាក់ត្រង់ពោះវានុរៈ រុំខ្សែទាំង ២ ចូលគ្នា ស្រែកលើកឡើង គ្រវីលើក្បាល បោះចុះទៅដីខាងក្រៅវេទិកា កាលវានុរៈស្លាប់ហើយ ព្រះរាជាត្រាស់ឲ្យមុដ្ឋិកៈធ្វើការប្រកួតតទៅ មុដ្ឋិកៈចេញទៅស្រែកហ៊ោ ឌីដង ទះដៃ ពលទេពក៏វាយមុដ្ឋិកៈរហូតខ្ទេចឆ្អឹង កាលមុដ្ឋិកៈពោលថា លោកជាអ្នកប្រដាល់ ខ្ញុំមិនមែនជាអ្នកប្រដាល់ទេ ទើបឆ្លើយថា យើងមិនដឹងថា ឯងជាអ្នកប្រដាល់ ឬមិនអ្នកប្រដាល់អីទេ ហើយចាប់ដៃទាំង ២ បោកលើផែនដី ហើយបោះទៅខាងក្រៅវេទិកា មុដ្ឋិកៈកាលស្លាប់ បានចងពៀរថា សូមឲ្យអញកើតជាយក្ខហើយស៊ីពលទេព កាលគាត់ស្លាប់ទៅ ក៏កើតជាយក្ខក្នុងព្រៃ ឈ្មោះកាឡមត្តិកៈ ។

ព្រះរាជាក្រោកឡើងត្រាស់ថា អ្នកទាំងឡាយ ចូរចាប់បងប្អូនទាំង ១០ ឲ្យបាន ខណៈនោះ វាសុទេព គ្រវែងកងចក្រ កាត់សីសៈក្សត្រទាំង ២ អង្គ អស់ព្រះជន្ម មហាជននាំគ្នាតក់ស្លុត ក្រាបទៀបបាទជើងកុមារទាំងនោះពោលថា សូមទ្រង់ជាទីពឹងរបស់ទូលបង្គំចុះ ។ កុមារទាំងនោះ កាលផ្តាច់ព្រះជន្មម្ចាស់អ៊ំទាំង ២ ក៏ដណ្តើមរាជសម្បត្តិក្នុងអសិតញ្ជននគរ លើកមាតាបិតាឲ្យឡើងគ្រងរាជសម្បត្តិ ហើយប្រឹក្សាគ្នាថា យើង ១០ នាក់ នឹងដណ្តើមរាជ-សម្បត្តិក្នុងជម្ពូទ្វីបទាំងមូល ហើយនាំគ្នាចេញទៅដោយលំដាប់ ដល់អយុជ្ឈ-នគរ ដែលជាទីប្រថាប់របស់ព្រះបាទកាលយោនកករាជ ហើយព័ទ្ធនូវព្រះនគរទម្លាយបន្ទាយ បំបាក់កំពែង ចូលទៅចាប់ព្រះរាជាដណ្តើមរាជសម្បត្តិទុកក្នុងកណ្តាប់ដៃរបស់ខ្លួន ទៅដល់នគរទ្វារវតី ។ នគរទ្វារវតីនោះ មានសមុទ្រតាំងនៅម្ខាង មានភ្នំតាំងនៅម្ខាង ។

បានឮថា នគរនោះ មានអមនុស្សរក្សា យក្ខដែលឈររក្សានគរនោះ ឃើញបច្ចាមិត្រហើយ កាឡាខ្លួនជាសត្វលា ស្រែកសំឡេងដូចលា ខណៈនោះ នគរទាំងមូលអណ្តែតនៅលើកោះមួយកណ្តាលសមុទ្រ ដោយអានុភាពយក្ខ ។ កាលបច្ចាមិត្រទៅហើយ នគរក៏មកប្រតិស្ឋានដូចដើមវិញ ។ គ្រានោះ លាយក្ខទាំងនោះដឹងថា កុមារ ១០ នាក់ បងប្អូនមកហើយ ក៏កញ្ជ្រៀវជាសំឡេងលា នគរក៏អណ្តែតទៅប្រតិស្ឋានលើកោះ កុមារទាំងនោះ មិនឃើញនគរ ក៏នាំគ្នាត្រឡប់ នគរក៏ប្រតិស្ឋានដូចដើមវិញ កុមារនោះក៏ត្រឡប់មកទៀត លាយក្ខក៏ធ្វើយ៉ាងនោះទៀត ។ កុមារទាំងនោះ កាលមិនអាច

ដណ្តើមរាជសម្បត្តិ ក្នុងនគរទ្វារវតីបាន ក៏នាំគ្នាទៅរកកណ្ហទីបាយនតាបស នមស្ការហើយ សួរថា បពិត្រលោកម្ចាស់ យើងទាំងឡាយមិនអាចដណ្តើម រាជសម្បត្តិក្នុងទ្វារវតីបាន សូមលោកម្ចាស់ប្រាប់ឧបាយណាមួយដល់ពួកខ្ញុំ កាលតាបសប្រាប់ថា មានលាមួយ ដើរត្រេចខ្ទេចប្រឡាយក្នុងទីនោះ លា ឃើញពួកអមិត្រហើយ ក៏កញ្ជ្រៀវឡើង ខណៈនោះ នគរក៏អណ្តែតទៅ កណ្តាលសមុទ្រ អ្នកទាំងឡាយ ចូរចាប់ជើងរបស់លានោះ នេះជាឧបាយ ដែលឲ្យអ្នកដល់នូវសេចក្តីសម្រេច ដូច្នេះ កុមារទាំង ១០ ថ្វាយបង្គំតាបស ហើយ ទៅក្រាបទៀបជើងលាអង្វរថា បពិត្រលោក អ្នកដទៃក្រៅពីលោក មិនជាទីពឹងរបស់ពួកខ្ញុំបានទេ កាលបើពួកខ្ញុំដណ្តើមព្រះនគរ សូមលោកកុំ ស្រែកឡើយ ។ លាយក្ខពោលថា យើងមិនអាចមិនស្រែកបានទេ តែលោក ៤ នាក់ ចូរមកមុន យកនង្គ័លដែកធំៗ ហើយបោះបង្គោលដែកធំត្រង់ផែនដី នាទ្វារនគរទាំង ៤ ទិស កាលបើនគរចាប់ផ្តើមរំកិល ចូរចាប់នង្គ័ល ហើយ នាំគ្នាយកច្រវាក់ដែកដែលចងត្រង់នង្គ័ល លាមនឹងបង្គោលដែក នគរនឹងមិន អាចអណ្តែតទៅបានទេ ។

កុមារទាំងនោះទទួលថា សាធុ លុះដល់កណ្តាលយប់ ក៏នាំគ្នាកាន់យក នង្គ័ល ហើយបោះបង្គោលលើផែនដី ត្រង់ទ្វារនគរទាំង ៤ ទិស ហើយឈរ ខណៈនោះ លាយក្ខក៏ស្រែកឡើង នគរចាប់ផ្តើមអណ្តែត កុមារទាំងនោះ ឈរត្រង់ទ្វារនគរទាំង ៤ ចាប់នង្គ័លដែកទាំង ៤ យកច្រវាក់ចងនង្គ័លលាម ជាមួយបង្គោលដែក នគរក៏មិនអាចអណ្តែតទៅបាន លំដាប់នោះ កុមារ ១០

នាក់បងប្អូន ក៏ចូលព្រះនគរសម្លាប់ព្រះរាជា ហើយដណ្តើមយករាជសម្បត្តិ ។ កុមារទាំងនោះ ប្រើកងចក្រផ្តាច់ព្រះជន្មព្រះរាជាទាំង ៦៣០០០ នគរ ហើយមកជួបជុំគ្នាត្រង់នគរទ្វារវតី ចែកទ្រព្យសម្បត្តិជា ១០ ចំណែក ដោយមិនបាននឹកដល់ព្រះនាងអញ្ជនទេវី ដែលជាបងស្រីឡើយ បន្ទាប់មកក៏នឹកឃើញ ទើបពិភាក្សាជាថ្មីថា នឹងបែងចែកជា ១១ ចំណែក អង្កុរកុមារពោលឡើងថា អ្នកទាំងឡាយ ចូរឲ្យចំណែកខ្ញុំដល់អញ្ជនទេវី ព្រះជេដ្ឋកគិនីចុះ ខ្ញុំនឹងធ្វើជំនួញចិញ្ចឹមជីវិត តែអ្នកទាំងឡាយត្រូវឲ្យចំណែកសួយក្នុងជនបទរបស់ខ្លួនដល់ខ្ញុំគ្រប់គ្នា បងប្អូនទាំង ៩ អង្គទទួលថា សាធុ ដូច្នេះហើយ ប្រគល់រាជសម្បត្តិដែលត្រូវបានអង្កុរកុមារ ឲ្យដល់ព្រះនាងអញ្ជនទេវីជាបងស្រី ក៏បានជាព្រះរាជា ៩ អង្គ និងជេដ្ឋកគិនី នៅជាមួយគ្នាក្នុងនគរទ្វារវតី ឯអង្កុរកុមារធ្វើនូវការជួញដូរ ។

កាលព្រះរាជាបងប្អូនទាំងនោះ ចម្រើនដោយបុត្រធីតាបន្តៗ មកទៀតយ៉ាងនេះ អស់កាលដ៏យូរ ព្រះរាជមាតាបិតាក៏អស់ព្រះជន្ម បានឮថា អាយុមនុស្សក្នុងកាលនោះ ពីរម៉ឺនឆ្នាំ ។ កាលនោះ ព្រះឱរសជាទីស្រឡាញ់មួយអង្គរបស់ព្រះបាទវាសុទេពមហារាជ បានអស់ព្រះជន្ម ព្រះរាជាទ្រង់គិតតែពីសោយសោក លះកិច្ចការសព្វយ៉ាង ផ្ទុំឱបម៉ែគ្រែ រវើរវាយ កាលនោះយតបណ្ឌិតគិតថា វៀរអាត្មាអញចេញហើយ អ្នកដទៃឈ្មោះថា អាចកម្ចាត់សេចក្តីសោករបស់បងប្រុសអញបាន មិនមាន អញនឹងប្រើឧបាយកម្ចាត់សេចក្តីសោករបស់បងប្រុស គិតដូច្នេះហើយ ទើបធ្វើជាឆ្កួត ដើរមើលមេឃ

មើលផ្កាយ ពេញព្រះនគរថា ចូរអ្នកទាំងឡាយឲ្យទន្សាយដល់យើង អ្នកទាំងឡាយ ចូរឲ្យទន្សាយដល់យើង ហើយក៏ល្បីពេញព្រះនគរថា ឃតបណ្ឌិតឆ្កួតទៅហើយ ។

សម័យនោះ អមាត្យឈ្មោះរោហិណេយ្យ[១] ទៅគាល់ព្រះបាទវាសុទេព កាលផ្តើមសន្ទនាជាមួយព្រះរាជា បានពោលគាថាដំបូងថា

បពិត្រព្រះអង្គ ជាកណ្ហាយនគោត្រ សូមព្រះអង្គក្រោកឡើង
ព្រះអង្គនៅផ្ទុំធ្វើអ្វី ប្រយោជន៍អ្វីរបស់ព្រះអង្គដោយការផ្ទុំ ក្សត្រិយ៍
ណា ជាព្រះកនិដ្ឋភាតារបស់ខ្លួនព្រះអង្គ ( ស្មើដោយ ) ហឫទ័យ
និងព្រះនេត្រខាងស្តាំ ខ្យល់ចាប់រួបរឹតនូវហឫទ័យរបស់ក្សត្រិយ៍
ជាព្រះកនិដ្ឋភាតានោះ បពិត្រព្រះកេសវៈ ឃតបណ្ឌិតរមែង
អំពាវនាវថា ( អ្នកទាំងឡាយ ចូរឲ្យទន្សាយដល់យើង )
ដូច្នេះ ។

រោហិណេយ្យអមាត្យប្រាស្រ័យនឹងព្រះរាជាដោយគោត្រថា បពិត្រព្រះអង្គជាកណ្ហាវង្ស ក្នុងគាថានោះ បានឮថា ស្តេចវាសុទេពនោះ មានគោត្រជាកណ្ហាយនៈ ។ បទថា **កោ អត្ថោ** បានដល់ សេចក្តីចម្រើនអ្វី ។ បទថា **ហទយំ ចក្ខុ ច ទក្ខិណំ** សេចក្តីថា ស្មើដោយហឫទ័យ និងព្រះនេត្រខាងស្តាំ ។ បទថា **តស្ស វាតាពលិយន្តិ** សេចក្តីថា ខ្យល់ពាល់ត្រូវត្រង់

---

១- បិដកខ្មែរជារោហិនេយ្យ ។

ហទយៈរបស់ព្រះភាគានោះ ក្នុងទីនេះ ។ បទថា **ជប្បតិ** បានដល់ ទ្រង់ រវើរវាយថា អ្នកទាំងឡាយ ចូរឲ្យទន្សាយដល់យើង ។ បទថា **កេសវ** សេចក្ដីថា បានឮថា ស្ដេចវាសុទេពនោះ ទ្រង់ប្រាកដនាមថា កេសវៈ ព្រោះ ទ្រង់មានសក់ស្អាត ។ រោហិណេយ្យអមាត្យហៅព្រះបាទវាសុទេពដោយព្រះ នាមនោះ កាលអមាត្យទូលយ៉ាងនេះហើយ ព្រះសាស្ដាទ្រង់ត្រាស់ដឹងហើយ ទ្រង់ជ្រាបការចូលគាល់របស់អមាត្យនោះ ដែលមានចិត្តតាំងមាំ ទើបត្រាស់ អភិសម្ពុទ្ធគាថាទី ២ ថា

*ព្រះបាទកេសវៈ ទ្រង់ព្រះសណ្ដាប់ពាក្យរបស់អាមាត្យ ឈ្មោះ*
*រោហិនេយ្យនោះហើយ ក៏ទ្រង់ក្រោកឡើងរលះរលាំង ត្រូវសេចក្ដី*
*សោកក្នុងព្រះកនិដ្ឋភាតាគ្របសង្កត់ ដូច្នេះ ។*

ព្រះរាជាក្រោកឡើងហើយ ប្រញាប់ចុះពីប្រាសាទ ទៅរកឃតបណ្ឌិត ចាប់ដៃទាំង ២ កាលនឹងចរចានឹងឃតបណ្ឌិត បានពោលគាថាទី ៣ ថា

*អ្នក ហេតុអ្វី ក៏មានសភាពហាក់ដូចជាឆ្កួត ( ត្រាច់ទៅ ) កាន់*
*នគរទ្វារវតីទាំងមូលនេះ និយាយរវើរវាយថា ទន្សាយៗ អ្នក*
*ណា លួចយកទន្សាយរបស់អ្នកទៅឬ ដូច្នេះ ។*

បណ្ដាបទទាំងនោះ បទថា **កោវលំ ទ្វារកំ ឥមំ** សេចក្ដីថា ព្រះរាជា ត្រាស់សួរថា ព្រោះហេតុអ្វី ទើបឯងទៅជាឆ្កួត ត្រាច់រវើរវាយពេញនគរទ្វារ-វតីនេះថា ទន្សាយៗ អ្នកណាលួចទន្សាយរបស់ឯងទៅឬ គឺទន្សាយរបស់ឯង អ្នកណាលួចទៅហើយឬ ។ ព្រះរាជាត្រាស់យ៉ាងនេះហើយ ឃតបណ្ឌិតក៏

ត្រាស់ពាក្យនោះឯងរឿយៗ ទើបព្រះរាជាត្រាស់ ២ គាថាទៀតថា

អ្នកប្រាថ្នានូវទ្រព្យមាស កែវមណី ( លោហៈ ) ឬប្រាក់ ឬក៏ទ្រព្យធ្វើដោយស័ង្ខ ដោយសិលា ដោយកែវប្រពាល យើងនឹងឲ្យគេធ្វើទ្រព្យនោះដល់អ្នក ។ ( បើអ្នកមិនពេញចិត្តទ្រព្យនោះទេ ) ទ្រព្យឯទៀតក្នុងព្រៃ រកស៊ីក្នុងព្រៃ យើងនឹងឲ្យគេនាំទ្រព្យទាំងនោះមកឲ្យអ្នក អ្នកត្រូវការទ្រព្យបែបណា ( ចូរប្រាប់យើងក្នុងកាលឥឡូវនេះ ) ដូច្នេះ ។

គប្បីជ្រាបសេចក្ដីសង្ខេបក្នុងគាថានោះដូច្នេះថា បណ្ដាទ្រព្យទាំងឡាយមានទ្រព្យមាសជាដើមនោះ ចូរឯងប្រាប់ទ្រព្យដែលឯងត្រូវការ បងនឹងឲ្យគេធ្វើឲ្យ បើឯងមិនគាប់ចិត្តនឹងទ្រព្យទាំងនោះ ហ្វូងទ្រព្យព្រៃដទៃៗក៏មាននៅក្នុងព្រៃ បងនឹងឲ្យគេនាំទ្រព្យទាំងនោះមកឲ្យ នែប្អូនមានមុខស្អាត ឯងត្រូវការទ្រព្យបែបណា ចូរប្រាប់មកចុះ យតបណ្ឌិតស្ដាប់ព្រះតម្រាស់របស់ព្រះរាជាហើយ ក៏ពោលគាថាទី ៦ ថា

ពួកទ្រព្យណា ដែលអាស្រ័យនៅលើផែនដី ខ្ញុំមិនចង់បានទ្រព្យនេះទេ ខ្ញុំចង់បានទ្រព្យអំពីដួងព្រះចន្ទ បពិត្រព្រះកេសវៈ សូមព្រះអង្គញុំាងទ្រព្យនោះឲ្យចុះ មកដើម្បីខ្ញុំ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឱហារ** បានដល់ ឲ្យធ្លាក់ចុះ ។ ព្រះរាជាទ្រង់ស្ដាប់ពាក្យរបស់យតបណ្ឌិតហើយ ទ្រង់ទោមនស្សថា ប្អូនប្រុសរបស់អញឆ្កួតមែនទែនហើយ ដោយឥតសង្ស័យ ទើបពោលគាថាទី ៧ ថា

អ្នកណាប្រាថ្នានូវរបស់ដែលមិនគួរប្រាថ្នា ( ដូចជា ) អ្នកប្រាថ្នា
នូវទន្សាយអំពីដួងព្រះចន្ទ ម្នាលអ្នកជាញាតិ អ្នកនោះ នឹងលះបង់
ជីវិតជាទីស្រឡាញ់ ដោយពិត ( ក៏មិនបានទន្សាយនោះដែរ )
ដូច្នេះ ។

ព្រះរាជាកាលទ្រង់ហៅព្រះកនិដ្ឋភាតា ទើបត្រាស់ថា **ញាតិ** ក្នុងគាថានោះ មានអធិប្បាយថា នែបា ឯងប្រាថ្នាវត្ថុដែលមិនគួរប្រាថ្នា ឯងជាប្អូនរបស់យើង នឹងលះបង់ជីវិតរបស់ខ្លួនដែលល្អក្រៃលែងនេះពិត ។

ឃតបណ្ឌិតស្តាប់ព្រះតម្រាស់ហើយ ឈរស្ងៀម ពោលថា បពិត្រព្រះជេដ្ឋៈ បងជ្រាបថា ខ្ញុំប្រាថ្នាទន្សាយអំពីដួងចន្ទមិនបាន ហើយនឹងស្លាប់ ហេតុអ្វី ទើបបងសោយសោកដល់ឱរស ដែលអស់ព្រះជន្មទៅហើយ ក៏ពោលគាថាទី ៨ ថា

បពិត្រព្រះកណ្ហាយនគោត្រ បើព្រះអង្គទ្រង់ជ្រាបយ៉ាងនោះ ព្រះ
អង្គទ្រង់ប្រៀនប្រដៅបុគ្គលដទៃ ហេតុអ្វី ព្រះអង្គសោកស្តាយ
នឹងបុត្រដែលទទួលមរណភាព ក្នុងកាលមុន រហូតមកក្នុងថ្ងៃនេះ
ដូច្នេះ ។

បទថា **ឯវំ** ក្នុងគាថានោះ មានអធិប្បាយថា បើទ្រង់ជ្រាបយ៉ាងនេះថា ឈ្មោះថា របស់ដែលមិនគួរបាន បុគ្គលក៏មិនគួរប្រាថ្នាសោត ។ បទថា **យថញ្ញមនុសាសសិ** សេចក្តីថា បើទ្រង់ជ្រាបយ៉ាងនេះឯង ត្រាស់ទូន្មានអ្នកដទៃ ។ បទថា **បុរេ** សេចក្តីថា ឃតបណ្ឌិតពោលថា បើដូច្នោះ ព្រោះហេតុ

អ្វី ទើបទ្រង់សោយសោកដល់ព្រះឱរសដែលអស់ព្រះជន្មទៅហើយ រាប់តាំងអំពីនេះទៅ អស់ ៤ ខែ មកទល់នឹងថ្ងៃនេះ ។

ឃតបណ្ឌិតឈរក្នុងរវាងវិថី ក្រាបទូលដូច្នេះថា បពិត្រព្រះជេដ្ឋា ទូលបង្គំប្រាថ្នាវត្ថុដែលប្រាកដពិតៗ តែព្រះជេដ្ឋាសោយសោកប្រាថ្នាវត្ថុដែលមិនប្រាកដ កាលសម្តែងធម៌ថ្វាយព្រះរាជា បានពោល ២ គាថាទៀតថា

របស់ណាដែលមនុស្ស ឬអមនុស្សមិនគប្បីបានវិញ ដោយប្រាថ្នាថា ( ព្រះអង្គប្រាថ្នានូវរបស់នោះថា ) បុត្ររបស់អញកើតហើយ កុំស្លាប់ឡើយ ដូច្នេះ ព្រះអង្គនឹងគប្បីបានរបស់ដែលមិនគប្បីបានអំពីទីណាកើត ។ បពិត្រព្រះកណ្ហាយនគោត្រ ព្រះអង្គសោកស្តាយនឹងបុត្រណា ដែលទៅកាន់បរលោកហើយ ព្រះអង្គអាចនាំបុត្រនោះមកវិញ ដោយមន្ត ដោយថ្នាំ ដែលធ្វើដោយឫសឈើ ដោយឱសថ ឬក៏ដោយទ្រព្យមិនបានឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យំ** សេចក្តីថា ឃតបណ្ឌិតសម្តែងថា មនុស្ស ឬទេវតាមិនគប្បីបានវិញ គឺមិនអាចបាននូវឋានៈឯណា គឺការប៉ុនប៉ងយ៉ាងនេះថា កូនរបស់អញដែលកើតមកហើយ កុំស្លាប់ឡើយ ទ្រង់ប្រាថ្នាឋានៈនោះ ទ្រង់គប្បីបានឋានៈដែលមិនគួរបាននោះ គឺព្រះឱរសដែលទៅបរលោកហើយអំពីណា គឺអាចបានដោយហេតុណា បានដល់ មិនអាចបាននូវឋានៈដែលមិនគួរបាននោះ អធិប្បាយថា ព្រោះហេតុនោះ ឈ្មោះថា វត្ថុដែលមិនគួរបាន គឺឋានៈដែលមិនគួរបាននោះ នឹងបានអំពីណា ។

បទថា **មន្តា** បានដល់ ដោយការរាយមន្ត ។ បទថា **មូលភេសជ្ជា** បានដល់ ដោយថ្នាំឫសឈើ ។ បទថា **ឱសធេហិ** បានដល់ ដោយឱសថផ្សេងៗ ។ បទថា **ធនេន វា** បានដល់ ដោយរាជទ្រព្យដែលរាប់បាន ១០០ កោដិក្តី ។

ពាក្យនោះ មានអធិប្បាយថា ទ្រង់សោយសោកដល់បុត្រណា ដែលទៅកាន់បរលោកហើយ ទ្រង់ក៏មិនអាចនាំព្រះឱរសនោះមកបាន ដោយការរាយមន្តជាដើមនោះឡើយ ។

ព្រះរាជាទ្រង់ស្តាប់ដូច្នោះហើយ ត្រាស់ថា នែយតបណ្ឌិត ពាក្យដែលពោលនេះ គួរកំណត់ទុក ឯងបានធ្វើយើងឲ្យប្រាសចាកសោកហើយ កាលសរសើរយតបណ្ឌិត ទើបត្រាស់ ៤ គាថាថា

ពួកបុរសជាបណ្ឌិត ប្រាកដដូច្នោះ ជាអាមាត្យរបស់ព្រះរាជាណា ដូចយ៉ាងអ្នកជាបណ្ឌិតបុរស ឈ្មោះយតៈ បានពន្យល់ ( ខ្ញុំ ) ក្នុងថ្ងៃនេះ ( សោករបស់ព្រះរាជានោះ នឹងមានមកពីណា ) ។ អ្នកបានស្រោចស្រពនូវយើង ដែលភ្លើង គឺសេចក្តីសោកកំពុងឆេះ ឲ្យស្ងប់រម្ងាប់ ញុំាងសេចក្តីក្រវល់ក្រវាយទាំងអស់ឲ្យរលត់ ដូចបុគ្គលយកទឹកស្រោចនូវភ្លើងកំពុងឆេះថ្នាំងខ្លាញ់ ។ សរ គឺសេចក្តីសោកណា ដែលអាស្រ័យក្នុងហឫទ័យ សរ គឺសេចក្តីសោកនោះ យើងបានដកចេញហើយ អ្នកឈ្មោះថាបានបន្ទោបង់នូវសេចក្តីសោកព្រោះបុត្ររបស់យើង ដែលត្រូវសេចក្តីសោក

គ្របសង្កត់ ។ ម្នាលមាណព យើងនោះជាអ្នកមានសរ គឺសេចក្តីសោកដកចេញហើយ ជាអ្នកប្រាសចាកសេចក្តីសោក ម្នាលមាណព យើងលែងសោកស្តាយ លែងយំទួញព្រោះបានស្តាប់នូវពាក្យរបស់អ្នក ដូច្នេះ ។

បណ្តាបទទាំងនោះ គាថាទី ១ មានសេចក្តីសង្ខេបដូច្នេះថា បុរសជាបណ្ឌិតបែបនេះ ជាអមាត្យរបស់ព្រះរាជាអង្គណា ព្រះរាជាអង្គនោះ នឹងមានសេចក្តីសោកមកពីណា ដូចឃតបណ្ឌិត ញុំាងយើងដែលត្រូវសេចក្តីសោកដល់បុត្រគ្របសង្កត់ ឲ្យរលត់ គឺឲ្យត្រជាក់ បានដល់ ឲ្យក្រាក់ ដើម្បីប្រយោជន៍ ដល់ការកម្ចាត់សេចក្តីសោកនោះ ។ គាថាដ៏សេស មានអត្ថដូចពោលហើយនោះឯង ។

ក្នុងអវសាន មានអភិសម្ពុទ្ធគាថា ដែលមានអត្ថងាយយល់ដូច្នេះ

ពួកជនណាប្រកបដោយប្រាជ្ញា ជាអ្នកអនុគ្រោះ រមែងធ្វើយ៉ាងនេះ ទើបញុំាងជនឲ្យឃ្លាតចាកសេចក្តីសោក ដូចឃតបណ្ឌិត ញុំាងព្រះជេដ្ឋា ( ឲ្យរួចចាកសេចក្តីសោក ) ដូច្នេះ ។

កាលព្រះបាទវាសុទេព ដែលឃតបណ្ឌិតធ្វើឲ្យអស់សេចក្តីសោកយ៉ាងនេះ គ្រងរាជសម្បត្តិ ដោយកាលដ៏យូរកន្លងទៅ ព្រះរាជកុមារដែលជាឱរសនៃក្សត្រទាំង ១០ អង្គ ប្រឹក្សាគ្នាថា បានឮថា កណ្ហទីបាយនតាបស មានភ្នែកទិព្វ ពួកយើងនឹងសួរលោកសាកមើល ទើបប្រដាប់តាក់តែងព្រះរាជបុត្រមួយអង្គ សម្តែងអាការដូចជាស្រីមានគភ៌ យកកែវមកិតចងត្រង់ពោះ ហើយ

នាំទៅរកតាបស សួរថា បពិត្រលោកម្ចាស់ ក្មេងស្រីនេះ នឹងប្រសូតឬ ។ តាបសគិតថា កាលវិបត្តិរបស់ស្តេចទាំង ១០ អង្គនេះមកដល់ហើយ អាយុសង្ខាររបស់អញដូចម្តេចហ្ន៎ ក៏ដឹងថា នឹងត្រូវស្លាប់ថ្ងៃនេះពិត ក៏ពោលថា នែកុមារទាំងឡាយ ពួកទ្រង់ត្រូវការអ្វីដោយរឿងឥតប្រយោជន៍នេះ ត្រូវពួកកុមាររំអុកថា សូមលោកម្ចាស់ប្រាប់ដល់ពួកខ្ញុំចុះ តាបសក៏ពោលថា ៧ ថ្ងៃទៀត កុមារិកានេះ នឹងប្រសូតឈើគគីរចេញមក ដោយហេតុនោះ ត្រកូលរបស់វាសុទេពនឹងវិនាស ម្យ៉ាងទៀត អ្នកទាំងឡាយ ចូរកាន់យកដុំឈើគគីរនោះទៅដុត ហើយយកផេះទៅបាចក្នុងស្ទឹង ។ លំដាប់នោះ ព្រះរាជ-កុមារទាំងនោះពោលនឹងតាបសថា នែជដិលកោង ធម្មតាមនុស្សប្រុស កើតកូន មិនមានឡើយ ហើយធ្វើទណ្ឌកម្មឈ្មោះតន្តវជ្ជុកៈ ( ព្យួរក ) ធ្វើឲ្យតាបសអស់ជីវិតក្នុងទីនេះឯង ។

ក្សត្រទាំងឡាយ ហៅកុមារមក ត្រាស់សួរថា ពួកឯងសម្លាប់តាបសព្រោះហេតុអ្វី កាលបានស្តាប់រឿងទាំងអស់ហើយ ទ្រង់តក់ស្លុត កិតភ័យក្រៃលែង ទើបរក្សាក្មេងទាំងនោះ លុះដល់ថ្ងៃទី ៧ ក៏យកដុំគគីរ ដែលចេញអំពីពោះរបស់ក្មេងនោះ ហើយយកផេះទៅចោលក្នុងស្ទឹង ផេះនោះទឹកបន្សាត់ទៅ ជាប់ត្រង់ឆ្នេរសមុទ្រមួយកន្លែង ក៏ដុះជាគុម្ពរំទឹកឡើងក្នុងទីនោះ ។

ថ្ងៃមួយ ក្សត្រទាំងនោះបបួលគ្នាលេងសមុទ្ទកីឡា យាងទៅដល់ឆ្នេរសមុទ្រនោះហើយ ឲ្យធ្វើមហាមណ្ឌប ទ្រង់សោយ ទ្រង់ផឹក ទ្រង់ចំអក

ចំអន់គ្នា ត្រង់មហាមណ្ឌបដែលតាក់តែងស្អាតហើយ ប្រើព្រះហស្ត និងព្រះបាទដាល់តប់គ្នា ប្រព្រឹត្តទៅដោយអំណាចការចំអកចំអន់ ទើបឈ្លោះគ្នាយ៉ាងធំ បែកគ្នាជា ២ ពួក ។ គ្រានោះ ក្សត្រមួយអង្គ កាលមិនបានដំបងដទៃ ក៏កាន់យកស្លឹកវែទឹក អំពីគុម្ពវែទឹកមួយសន្ទឹក ស្លឹកវែទឹកនោះ គ្រាន់តែចាប់ប៉ុណ្ណោះ ក៏ក្លាយជាអង្រែគគីរ ទ្រង់វាយមហាជនដោយអង្រែនោះ វត្ថុដែលមនុស្សទាំងអស់ចាប់ដោយយល់ថា ជារបស់ដទៃ ក៏ក្លាយជាអង្រែទាំងអស់ ជនទាំងនោះប្រហារគ្នានិងគ្នា ដល់នូវសេចក្តីវិនាសអស់ ។ កាលជនទាំងនោះកំពុងវិនាស ក្សត្រ ៤ អង្គ គឺវាសុទេព ពលទេព អញ្ជនទេវី និងបុរោហិត នាំគ្នាគេចរត់ទៅ ពួកជនដ៏សេសស្លាប់អស់ ។ ក្សត្រ ៤ អង្គនេះ ឡើងរថគេចទៅដល់ព្រៃកាឡមត្តិកៈ ។ មុដ្ឋិកៈអ្នកប្រដាល់នោះ បានតាំងសេចក្តីប្រាថ្នា កើតជាយក្ខក្នុងព្រៃនោះ ដឹងថា ពលទេពមក ក៏និម្មិតជាស្រុកក្នុងទីនោះ កាឡាខ្លួនជាអ្នកប្រដាល់ ស្រែកហ៊ោគំរាម ទះដៃ រកអ្នកប្រកួតថា អ្នកណាត្រូវការប្រកួត ពលទេពឃើញបុរសនោះ ក៏ពោលថា បពិត្រព្រះជេដ្ឋា ខ្ញុំនឹងប្រកួតជាមួយបុរសនេះឯង កាលវាសុទេពកំពុងឃាត់នោះឯង ក៏ចុះអំពីរថ ទះដៃ ចូលទៅរកយក្ខនោះ ទើបយក្ខចាប់ដៃដែលលាចេញ ហើយស៊ីពលទេព ដូចក្រអៅឈូក ។ វាសុទេពដឹងថា ពលទេពអស់ជីវិត ទើបនាំព្រះភគិនី និងបុរោហិត គេចចេញទៅអស់មួយយប់ លុះព្រឹកឡើង ដល់បច្ចន្តគ្រាមមួយកន្លែង ប្រាប់បងស្រី និងបុរោហិតឲ្យចូលទៅកាន់ស្រុកថា ចូរចម្អិនអាហារ ហើយនាំមក ឯទ្រង់ក៏ផ្ទំលាក់ខ្លួនត្រង់គុម្ពឈើ

មួយកន្ទែង ។ សម័យនោះ ព្រានព្រៃម្នាក់ឈ្មោះជរា ឃើញគុម្ពឈើកម្រើក យល់ថា ជ្រូកនឹងមានក្នុងទីនោះ ទើបពួយលំពែងទៅ ត្រូវព្រះវាជាវាសុទេព កាលវាសុទេពត្រាស់ថា អ្នកណាចាក់យើង ព្រានដឹងថា ខ្លួនពួយលំពែង ត្រូវមនុស្ស ភិតភ័យ ប្រារព្ធនឹងគេចទៅ ព្រះរាជាតាំងស្មារតីក្រោកឡើង ហៅថា បពិត្រឪពុកធំ អ្នកកុំខ្លាចឡើយ មកចុះ កាលនាយព្រានមកហើយ ទើបត្រាស់សួរថា អ្នកឈ្មោះអ្វី កាលនាយព្រានឆ្លើយថា ខ្ញុំឈ្មោះជរា ទ្រង់ក៏ជ្រាបថា បានឮថា មនុស្សជំនាន់មុន ព្យាករអញថា នឹងត្រូវស្លាប់ក្រោមផ្លែលំពែងនៃបុរសឈ្មោះជរា ថ្ងៃនេះ អញគង់នឹងស្លាប់ដោយឥតសង្ស័យ រួចត្រាស់នឹងនាយជរាថា បពិត្រឪពុកធំ អ្នកកុំខ្លាចឡើយ មកជួយរុំរបួសឲ្យយើង ឲ្យព្រានឈ្មោះជរារុំរបួសហើយ ក៏បញ្ជូនព្រាន ឈ្មោះជរានោះទៅ ។ វេទនាដ៏មានកម្លាំង បានប្រព្រឹត្តទៅយ៉ាងខ្លាំងក្លា ព្រះរាជាមិនអាចសោយព្រះក្រយាហារ ដែលព្រះជេដ្ឋកតិនី និងបុរោហិតនាំមកបាន លំដាប់នោះ ទ្រង់ក៏ហៅជនទាំង ២ មក ត្រាស់ថា យើងនឹងស្លាប់ក្នុងថ្ងៃនេះ អ្នកទាំង ២ ជាសុខុលមាលជាតិ មិនអាចធ្វើការងាររដទៃចិញ្ចឹមជីវិតបាន ចូររៀនវិជ្ជានេះហើយឲ្យសិក្សាវិជ្ជាមួយ ក៏បញ្ជូនទៅ ទ្រង់អស់ព្រះជន្មក្នុងទីនោះឯង ក្សត្របងប្អូនទាំងអស់ ក្រៅអំពីអញ្ជូនទេវី ដល់នូវសេចក្តីវិនាសទាំងអស់ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះ មកសម្តែងហើយ ទ្រង់ត្រាស់ថា ម្នាលឧបាសក បុរាណកបណ្ឌិតស្តាប់ពាក្យរបស់បណ្ឌិតហើយ កម្ចាត់នូវសេចក្តីសោករបស់ខ្លួនបាន អ្នកកុំគិតដល់កូននោះឡើយ ដូច្នេះហើយ

ទ្រង់ប្រកាសសច្ចធម៌ ក្នុងកាលចប់សច្ចៈ ឧបាសកតាំងនៅក្នុងសោតាបត្តិផល ហើយទ្រង់សមោធានជាតកថា រោហិណេយ្យអមាត្យ ក្នុងកាលនោះ បានមកជាអានន្ទ ក្នុងកាលឥឡូវនេះ វាសុទេព ក្នុងកាលនោះ បានមកជាសារីបុត្រ ជនដទៃក្រៅអំពីនេះ ក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទ ក្នុងកាលឥឡូវនេះ ឃតបណ្ឌិត ក្នុងកាលនោះ គឺតថាគតដ៏ជាសម្មាសម្ពុទ្ធ ជាអ្នកមានដំបូល គឺកិលេសបើកហើយក្នុងលោក ដូច្នេះ ។

**អដ្ឋកថា ឃតបណ្ឌិតជាតក ចប់**

**ទសកនិបាតដែលប្រដាប់ដោយរឿង ១៦ ចប់**

# សុត្តន្តបិដក
# ឯកាទសកនិបាត ជាតក

## មាតុបោសកជាតក

[ ៧៩១ ] ( ដំរីជាមាតារបស់ព្រះពោធិសត្វពោលថា ) ដើមពោនស្វាផង ដើមខ្លែងគង់ផង ដើមទទឹម និងស្មៅធំឈ្មោះករវីរៈផង ក្រអៅឈូក និងស្រង៉ែផង ដុះទ្រុបទ្រុលហើយ ទាំងដើមកណិការជិតជើងភ្នំក៏ចេញផ្កាដែរ ព្រោះតែដំរីនោះមិននៅ ។

[ ៧៩២ ] ក្នុងស្រុក ឬក្នុងក្រុងណាមួយ ព្រះរាជា ឬព្រះរាជកុមារណាមួយ មានគ្រឿងអាភរណៈជាវិការនៃមាស រមែងចិញ្ចឹមស្តេចដំរីដោយដុំនៃភោជន ដ្បិតដំរីដែលព្រះរាជា ឬព្រះរាជកុមារ ( គង់ហើយ ) មិនតក់ស្លុត ( ក្នុងសង្គ្រាម ) អាចនឹងទម្លុះទម្លាយនូវក្រោះ ( នៃពួកបច្ចាមិត្តបាន ) ។

[ ៧៩៣ ] ( ព្រះរាជា ... ) ម្នាលដំរី អ្នកចូរទទួលពំនូតភោជនចុះ ម្នាលដំរីអ្នកកុំស្គមឡើយ ម្នាលដំរី រាជកិច្ចទាំងឡាយមានច្រើន អ្នកនឹងធ្វើនូវរាជកិច្ចទាំងនោះ ។

[ ៧៩៤ ] ( ព្រះពោធិសត្វ ... ) មេដំរីនោះជាសត្វកំព្រា ខ្វាក់ភ្នែក មិនមានគេដឹកនាំ ទង្គិចជើងនឹងជន្ទល់ឈើ ហើយបែរមុខទៅរកភ្នំចណ្ឌោរណៈ ដួលនៅ ។

[ ៧៩៥ ] ( ព្រះរាជា ... ) ម្នាលដំរីដ៏ប្រសើរ មេដំរីខ្វាក់ភ្នែក មិនមានគេដឹកនាំ ទន្គិចជើងនឹងជន្លត់ឈើ បែរមុខទៅរកភ្នំចណ្ឌោរណៈ ដួលនៅនោះ តើត្រូវជាអ្វីនឹងអ្នកឯង ។

[ ៧៩៦ ] ( ព្រះពោធិសត្វ ... ) បពិត្រមហារាជ មេដំរីខ្វាក់ភ្នែក មិនមានគេដឹកនាំ ទន្គិចជើងនឹងជន្លត់ឈើ បែរមុខទៅរកភ្នំចណ្ឌោរណៈ ដួលនៅនោះ ត្រូវជាមាតារបស់ទូលព្រះបង្គំជាខ្ញុំ ។

[ ៧៩៧ ] ( ព្រះរាជា ... ) អ្នកទាំងឡាយ ចូរលែងនូវដំរីដ៏ប្រសើរនុ៎ះ ជាសត្វចិញ្ចឹមនូវមាតា ចូរឲ្យដំរីបានជួបជុំនឹងមាតាព្រមទាំងញាតិទាំងពួងចុះ ។

[ ៧៩៨ ] ( អភិសម្ពុទ្ធគាថា ) ដំរីគ្រាន់តែរួចចាកចំណងដែលព្រះរាជាកាសីបានបញ្ជូនទៅ សម្រាកខ្លួនតែមួយរំពេច ក៏ដើរសំដៅទៅរកភ្នំ ដំរីនោះចេញទៅអំពីភ្នំនោះ ដើរទៅកាន់ព្រៃជាទីពួនសម្ងំដ៏ត្រជាក់ ដែលដំរីធ្លាប់សេព ( នៅ ) ហើយដងទឹកដោយប្រមោយ យកមកស្រោចស្រពមាតា ។

[ ៧៩៩ ] ( មាតាពោធិសត្វ ... ) ភ្លៀងអ្វីហ្នឹង ផ្ដេសផ្ដាស បង្អុរចុះពុំជួកាលសោះ កូនបង្កើតរបស់អញដែលជាអ្នកបម្រើអញទៅបាត់ហើយតើ ។

[ ៨០០ ] ( ព្រះពោធិសត្វ ... ) បពិត្រអ្នកមេ សូមអ្នកក្រោកឡើង សម្រាន្តអ្វី ខ្ញុំជាកូនបង្កើតរបស់លោកដែលព្រះរាជាកាសី

ទ្រង់ប្រកបដោយប្រាជ្ញា មានយស បានលែងមកវិញហើយ ។

[ ៨០១ ] ( មាតាពោធិសត្វ ... ) ព្រះរាជាណា បានលែងកូនរបស់ខ្ញុំ ជាអ្នកកោតក្រែងចំពោះបុគ្គលចាស់សព្វៗ កាល សូមព្រះរាជានោះ ញុំាងដែនរបស់ពួកអ្នកកាសីឲ្យចម្រើន គង់ព្រះជន្មនៅអស់កាលយូរអង្វែងចុះ ។

## មាតុបោសកជាតកទី ១ ចប់

# អដ្ឋកថា
# ខុទ្ទកនិកាយ ជាតក

## ឯកាទសកនិបាត

### អដ្ឋកថា មាតុបោសកជាតក

[ ៧៩១-៨០១ ] *ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុចិញ្ចឹមមាតា ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា* **តស្ស នាគស្ស វិប្បវាសេន** *ដូច្នេះជាដើម ។*

*រឿងបច្ចុប្បន្នដូចគ្នានឹងរឿងសាមជាតកនោះឯង ព្រះសាស្តាត្រាស់ហៅភិក្ខុទាំងឡាយមកហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកកុំលើកទោសភិក្ខុនេះឡើយ បោរាណកបណ្ឌិតទាំងឡាយ សូម្បីកើតក្នុងកំណើតតិរច្ឆាន ព្រាត់ប្រាសចាកមាតា មិនបរិភោគអាហារអស់ ៧ ថ្ងៃ សូម្បីបានភោជនដែលសមគួរអំពីព្រះរាជា គិតថា អញវៀរចាកមាតានឹងមិនបរិភោគលុះឃើញមាតាក៏បរិភោគអាហារ ដូច្នេះហើយ កាលភិក្ខុទាំងឡាយទូលអារាធនា ទើបទ្រង់នាំអតីតនិទានមកសាធកៈដូចតទៅ*

*ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសីកាលនោះ ព្រះពោធិសត្វយោនយកកំណើតជាដំរី ក្នុងហិមវន្តប្បទេស ជាសត្វមានសម្បុរសសុទ្ធ មានរូបស្អាតគួរសរសើរ គួរជ្រះថ្លា សម្បុរដោយ*

លក្ខណៈ ធ្វើនូវសេចក្ដីចម្រើនដោយលំដាប់ មានដំរី ៨ ម៉ឺនជាបរិវារ ។ ឯមាតារបស់ដំរីនោះ ជាសត្វខ្វាក់ តែដំរីបានឲ្យផ្លែឈើមានរសឆ្ងាញ់ដល់ដំរីទាំងឡាយ ដើម្បីបញ្ជូនទៅកាន់សម្នាក់របស់មាតា ដំរីទាំងឡាយ មិនបានឲ្យដល់មាតាឡើយ ទំពាស៊ីឯង ដំរីពោធិសត្វកំណត់ដឹងរឿងនោះ គិតថា អញនឹងលះហ្វូង ចិញ្ចឹមតែមាតាប៉ុណ្ណោះ កាលដល់ចំណែកនៃរាត្រី កាលដំរីដទៃមិនដឹង ទើបនាំមាតាទៅកាន់ជើងភ្នំឈ្មោះចណ្ឌោរណៈ ហើយឲ្យមាតាសម្រាកត្រង់គុហាភ្នំ ដែលអាស្រ័យស្រះមួយកន្លែង ហើយថែរក្សា ។ លំដាប់នោះព្រានព្រៃអ្នកក្រុងពារាណសីម្នាក់ ជាមនុស្សវង្វេងផ្លូវ កាលមិនអាចកំណត់ទិសបាន ទើបស្រែកយំដោយសំឡេងខ្លាំង ។ ព្រះពោធិសត្វបានឮសំឡេងរបស់ព្រានព្រៃនោះ គិតថា បុរសនេះជាអ្នកឥតទីពឹង ការដែលបុរសនេះគប្បីវិនាសទៅក្នុងទីនេះ ក្នុងកាលដែលអញនៅ មិនសមគួរដល់អញឡើយ ដូច្នេះហើយ ទើបទៅរកព្រានព្រៃ ឃើញព្រានព្រៃកំពុងរត់ទៅដោយសេចក្ដីខ្លាច ទើបសួរថា នែបុរសដ៏ចម្រើន អ្នកមិនមានភ័យព្រោះអាស្រ័យខ្ញុំឡើយ អ្នកកុំរត់ឡើយ ព្រោះហេតុអ្វី ទើបអ្នកយំយ៉ាងនេះ បុរសនោះពោលថា បពិត្រដំរី ខ្ញុំជាមនុស្សវង្វេងផ្លូវ ថ្ងៃនេះជាថ្ងៃទី ៧ សម្រាប់ខ្ញុំ ដំរីក៏ពោលថា បុរសដ៏ចម្រើន អ្នកកុំខ្លាចឡើយ ខ្ញុំនឹងដាក់អ្នកក្នុងទឹកដីមនុស្ស ដូច្នេះហើយឲ្យព្រានព្រៃអង្គុយលើខ្នងរបស់ខ្លួន នាំចេញអំពីព្រៃហើយ ត្រឡប់ទៅ ។ ឯព្រានព្រៃជាមនុស្សអាក្រក់ គិតថា អញទៅដល់នគរហើយនឹងទូលដល់ព្រះរាជា ដូច្នេះហើយ ទើបធ្វើដើមឈើជាគ្រឿងសម្គាល់ ធ្វើភ្នំជាគ្រឿងសម្គាល់

បានចេញទៅកាន់ក្រុងពារាណសី ។ ក្នុងកាលនោះ ដំរីមង្គលរបស់ព្រះរាជា បានធ្វើកាលកិរិយាទៅ ។ ព្រះរាជាត្រាស់ឲ្យវាយស្គរប្រកាសថា បើបុគ្គលណាមួយ ឃើញដំរីដែលស្អាតសមរម្យ ដែលសមគួរជារាជពាហនៈក្នុងទីណាមួយ បុគ្គលនោះ ចូរប្រាប់ ។ បុរសនោះ ចូលទៅគាល់ព្រះរាជាហើយទូលថា បពិត្រសម្មតិទេព ទូលបង្គំបានឃើញស្តេចដំរីមានពណ៌សសុទ្ធ សមជារាជពាហនៈរបស់ព្រះអង្គ ទូលបង្គំនឹងបង្ហាញផ្លូវ សូមទ្រង់បញ្ជូននាយហត្ថាចារ្យ ទៅជាមួយទូលបង្គំឲ្យចាប់ដំរីនោះចុះ ។ ព្រះរាជាទទួលពាក្យហើយ ទើបត្រាស់ថា ចូរពួកអ្នកធ្វើបុរសនេះឲ្យជាមគ្គុទេសក៍ ទៅកាន់ព្រៃ នាំស្តេចដំរីដែលបុរសនេះនិយាយមក ដូច្នេះហើយ ទើបបញ្ជូននាយហត្ថាចារ្យ មួយអន្លើដោយបរិវារជាច្រើនទៅជាមួយបុរសនោះ ។ នាយហត្ថាចារ្យទៅជាមួយបុរសនោះ ឃើញដំរីពោធិសត្វកំពុងចូលទៅកាន់ស្រះ នាំយកអាហារទៅ ។ ចំណែកព្រះពោធិសត្វឃើញហត្ថាចារ្យហើយ អធិដ្ឋានថា ភ័យនេះមិនបានកើតឡើងអំពីអ្នកដទៃ ប្រហែលជាកើតឡើងអំពីសម្នាក់របស់បុរសអាក្រក់នោះ ចំណែកអញជាអ្នកមានកម្លាំងច្រើន អាចកម្ចាត់ដំរីបានមួយពាន់ កាលក្រោធហើយ ក៏អាចធ្វើពាហនៈរបស់មេទ័ព ព្រមទាំងដែនឲ្យវិនាសទៅបាន បើអញក្រោធ សីលរបស់អញនឹងដាច់ ព្រោះហេតុនោះ ថ្ងៃនេះគេយកលំពែងចាក់អញ អញមិនក្រោធ ដូច្នេះហើយ ទើបឱនក្បាលចុះ បានឈរស្ងៀម ។ នាយហត្ថាចារ្យចុះកាន់ស្រះឈូក ឃើញភាពសម្បូរនៃលក្ខណៈរបស់ព្រះពោធិសត្វនោះ ទើបពោលថា មកចុះបា ហើយចាប់ប្រមោយដែលដូចកម្រង

ប្រាក់ ហើយដឹកទៅ ។ ក្នុងថ្ងៃទី ៧ ទើបដល់ក្រុងពារាណសី ។ ចំណែក មាតាព្រះពោធិសត្វ កាលមិនឃើញកូនមក ទើបខ្សឹកខ្សួលថា ប្រហែលជា ព្រះរាជា និងមហាមាត្យរបស់ព្រះរាជានាំយកកូនអញទៅ ឥឡូវនេះ ពួកព្រៃ ឈើនេះនឹងចម្រើន ព្រោះដីរនោះមិននៅ ដូច្នេះហើយ បានពោល ២ គាថាថា

ដើមពោនស្វាផង ដើមខ្វែងគង់ផង ដើមទទឹម និងស្ទៅធំឈ្មោះ
ករវរៈផង ក្រអៅឈូក និងស្រង៉ែផង ដុះទ្រុបទ្រុលហើយ ទាំង
ដើមកណិការជិតជើងភ្នំក៏ចេញផ្កាដែរ ព្រោះតែដីរនោះមិននៅ ។

ក្នុងស្រុក ឬក្នុងក្រុងណាមួយ ព្រះរាជា ឬព្រះរាជកុមារ ណា
មួយ មានគ្រឿងអាករណៈជាវិការនៃមាស រមែងចិញ្ចឹមស្តេចដីរ
ដោយដុំនៃគោជន ដ្បិតដីរដែលព្រះរាជា ឬព្រះរាជកុមារ ( គង់
ហើយ ) មិនតក់ស្លុត ( ក្នុងសង្គ្រាម ) អាចនឹងទម្លុះទម្លាយនូវ
គ្រោះ ( នៃពួកបច្ចាមិត្តបាន ) ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វិរូឡ្ហា** បានដល់ ឈ្មោះថា ចម្រើនឡើង ហើយ មេដីរពោលយ៉ាងនេះដោយអំណាចការសង្ស័យថា ក្នុងសេចក្តីនេះ ការសង្ស័យកុំបីមានឡើយ ។ បទថា **សល្លកិយោ ច កុដជា** បានដល់ ដើមពោនស្វា និងដើមខ្វែងគង់ ។ បទថា **កុរុវិន្ទករវា ភិសសាមា** សេចក្ដីថា ដើមទទឹម ស្ទៅប្រមោយដីរ ស្ពៅ និងស្លួយ ។ មេដីរខ្សឹកខ្សួលថា ក្នុងព្រៃទាំងអស់នេះ នឹងចម្រើនក្នុងកាលឥឡូវនេះ ។ បទថា **និវាតេ** បានដល់ ត្រង់ជើងភ្នំ ។ បទថា **បុប្ផិតា** លោកអធិប្បាយថា ដើមកណិការដែលបុត្ត

របស់យើង មិនបានកាច់មែកទំពាស៊ី ក៏នឹងចេញផ្កា ។ បទថា **កោចិទេវ** បានដល់ ក្នុងស្រុក ឬក្នុងនគរទីណាមួយ ។ បទថា **សុវណ្ណកាយុរា** បានដល់ ព្រះរាជា និងមហាមាត្យរបស់ព្រះរាជា ដែលមានគ្រឿងប្រដាប់ធ្វើដោយមាស ។ បទថា **ភរន្តិ បិណ្ឌេន** សេចក្ដីថា ក្នុងថ្ងៃនេះ ព្រះរាជា និងមហាមាត្យរបស់ព្រះរាជា នឹងចិញ្ចឹមដំរីដែលចិញ្ចឹមមាតាដោយដុំបាយដែលផ្សំល្អហើយនៃភោជន ដ៏សមគួរដល់ព្រះរាជា ។ បទថា **យត្ថ** សេចក្ដីថា ព្រះរាជាប្រថាប់គង់លើខ្នងស្ដេចដំរីណា ។ បទថា **ករវចមភិហេស្សន្តិ** សេចក្ដីថា ព្រះរាជា ឬព្រះរាជកុមារ ចូលទៅកាន់សង្គ្រាមហើយ នឹងកម្ចាត់ទម្លាយនូវគ្រោះរបស់សត្រូវ លោកអធិប្បាយថា ព្រះរាជា ឬព្រះរាជកុមារ ប្រថាប់គង់ក្នុងទីណា គឺលើខ្នងរបស់កូនយើង មិនមានការតក់ស្លុត នឹងទម្លាយគ្រោះរបស់ពួកសត្រូវ ថ្ងៃនេះ ពួកគេមានអាករណៈ ដែលសម្រេចដោយមាសរមែងចិញ្ចឹមដំរីរបស់យើងនោះ ដោយដុំបាយ ។

ចំណែកនាយហត្ថាចារ្យ ដើរទៅក្នុងរវាងផ្លូវ បញ្ជូនដំណឹងទៅដល់ព្រះរាជាៗ ត្រាស់ឲ្យតាក់តែងព្រះនគរ ។ ចំណែកនាយហត្ថាចារ្យ នាំព្រះពោធិ-សត្វ ដែលគេប្រោះព្រំដោយគ្រឿងក្រអូប ប្រដាប់តាក់តែងចូលទៅកាន់រោងដំរី ឲ្យបាំងដោយរាំងននដ៏វិចិត្រ ឲ្យចងពិដានដ៏វិចិត្រអំពីខាងលើ ហើយឲ្យក្រាបទូលដល់ព្រះរាជា ។ ព្រះរាជាទ្រង់នាំភោជនមានរសដ៏ប្រសើរផ្សេងៗមកឲ្យដល់ព្រះពោធិសត្វ ។ ព្រះពោធិសត្វគិតថា អាត្មាអញ វៀរមាតាចេញនឹងមិនព្រមទទួលអាហារ ដូច្នេះហើយ មិនទទួលអាហារ ។ លំដាប់នោះ ព្រះ

រាជា កាលទ្រង់អង្វរព្រះពោធិសត្វ ទើបត្រាស់គាថាទី ៣ ថា

ម្នាលដំរី អ្នកចូរទទួលពំនូតភោជនចុះ ម្នាលដំរីអ្នកកុំស្គមឡើយ ម្នាលដំរី រាជកិច្ចទាំងឡាយមានច្រើន អ្នកនឹងធ្វើនូវរាជកិច្ចទាំងនោះ ដូច្នេះ ។

ព្រះពោធិសត្វបានស្តាប់ដូច្នោះ ក៏ពោលគាថាទី ៤ ថា

មេដំរីនោះ ជាសត្វកំព្រា ខ្វាក់ភ្នែក មិនមានគេដឹកនាំ ទង្គិចជើងនឹងជន្ទត់ឈើ ហើយបែរមុខទៅរកភ្នំចណ្ឌោរណៈ ដួលនៅ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សា នូន សា** បានដល់ បពិត្រមហារាជ ដំរីញីនោះកំព្រាពិត ។ បទថា **កបណិកា** បានដល់ ជាសត្វកំព្រា ព្រោះព្រាត់ប្រាសចាកកូន ។ បទថា **ខាណុំ** បានដល់ កំណាត់ឈើដែលដួលរលំក្នុងទីនោះៗ ។ បទថា **ឃដ្តេតិ** សេចក្តីថា ដំរីខ្វាក់ខ្វល់ ជើងក៏ចំពប់ត្រង់ជន្ទត់ឈើនោះៗ ដោយពិត ។ បទថា **ចណ្ឌោរណំ បតិ** សេចក្តីថា មេដំរីដើរបែរមុខទៅកាន់ភ្នំឈ្មោះចណ្ឌោរណៈ កន្ទក់កន្ទេញត្រង់ជើងភ្នំ ។

លំដាប់នោះ ព្រះរាជាកាលត្រាស់សួរព្រះពោធិសត្វ ទើបត្រាស់គាថាទី ៥ ថា

ម្នាលដំរីដ៏ប្រសើរ មេដំរីខ្វាក់ភ្នែក មិនមានគេដឹកនាំ ទង្គិចជើងនឹងជន្ទត់ឈើ បែរមុខទៅរកភ្នំចណ្ឌោរណៈ ដួលនៅនោះ តើត្រូវជាអ្វីនឹងអ្នកឯង ដូច្នេះ ។

ព្រះពោធិសត្វពោលគាថាទី ៦ ថា

បពិត្រមហារាជ មេដំរីខ្វាក់ភ្នែក មិនមានគេដឹកនាំ ទង្គិចជើងនឹង

ដង្គត់ឈើ បែរមុខទៅរកភ្នំចណ្ឌោរណៈ ដួលនៅនោះ ត្រូវជា

មាតារបស់ទូលព្រះបង្គំជាខ្ញុំ ដូច្នេះ ។

ព្រះរាជាទ្រង់ស្តាប់អត្ថនៃគាថាទី ៦ នោះ កាលនឹងឲ្យលែងទៅ ក៏ពោលគាថាទី ៧ ថា

អ្នកទាំងឡាយ ចូរលែងនូវដំរីដ៏ប្រសើរនុ៎ះ ជាសត្វចិញ្ចឹមនូវមាតា

ចូរឲ្យដំរីបានជួបជុំនឹងមាតា ព្រមទាំងញាតិទាំងពួងចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យោយំ ភរតិ** សេចក្តីថា ស្តេចដំរីនេះពោលថា បពិត្រព្រះរាជា ខ្ញុំចិញ្ចឹមមាតាខ្វាក់ភ្នែក វៀរខ្ញុំហើយ មាតារបស់ខ្ញុំនឹងដល់នូវការអស់ជីវិត វៀរមាតាហើយ ខ្ញុំមិនមានសេចក្តីត្រូវការដោយភាពជាធំឡើយ ថ្ងៃនេះជាថ្ងៃទី ៧ ដែលមាតារបស់ខ្ញុំមិនបានអាហារ ព្រោះដូច្នោះ ទើបព្រះរាជាត្រាស់ថា អ្នកទាំងឡាយ ចូរលែងនូវដំរីដ៏ប្រសើរនុ៎ះជាសត្វចិញ្ចឹមនូវមាតា ចូរឲ្យដំរីបានជួបជុំនឹងមាតា ព្រមទាំងញាតិទាំងពួងចុះ ដូច្នេះ ។

គាថាទី ៨-៩ ជាអភិសម្ពុទ្ធគាថា មានសេចក្តីដូច្នេះថា

ដំរីគ្រាន់តែរួចចាកចំណង ដែលព្រះរាជាកាសីបានបញ្ជូនទៅ

សម្រាកខ្លួនតែមួយរំពេច ក៏ដើរសំដៅទៅរកភ្នំ ដំរីនោះចេញទៅ

អំពីភ្នំនោះ ដើរទៅកាន់ព្រៃជាទីពួនសម្ងំដ៏ត្រជាក់ ដែលដំរីធ្លាប់

សេព ( ទៅ ) ហើយជន៍ទឹកដោយប្រមោយ យកមកស្រោច
ស្រពមាតា ដូច្នេះ ។

បានឮថា ស្តេចដំរីនោះផុតចាកចំណង សម្រាកមួយស្របក់ ហើយបានសម្តែងធម៌ដល់ព្រះរាជា ដោយទសពិធរាជធម្មគាថា ហើយទូន្មានថា បពិត្រព្រះរាជា សូមទ្រង់កុំជាអ្នកប្រមាទឡើយ កាលមហាជនបូជាដោយគ្រឿងសក្ការៈ មានគ្រឿងក្រអូប និងផ្កាជាដើម ចេញអំពីព្រះនគរដល់ស្រះឈូកនោះ ក្នុងខណៈនោះឯង គិតថា អញមិនឲ្យមាតារបស់អញបរិភោគអាហារហើយ អញនឹងមិនបរិភោគ ដូច្នេះហើយ ទើបកាន់យកក្រអៅឈូកជាច្រើនហើយយកប្រមោយបូមទឹកពេញ ទៅកាន់សម្នាក់មាតាដែលចេញអំពីទីសម្ងំក្នុងគុហា ដេកត្រង់ទ្វារគុហា ស្រោចទឹកលើរាងកាយរបស់មាតា ដើម្បីឲ្យដឹងខ្លួន ព្រោះអត់អាហារមក ៧ ថ្ងៃ ។ ព្រះសាស្តា កាលទ្រង់ធ្វើសេចក្តីនោះឲ្យប្រាកដ ទើបត្រាស់ ២ គាថានេះ ។ ចំណែកមាតារបស់ព្រះពោធិសត្វសម្គាល់ថា ភ្លៀងធ្លាក់ ទើបជេរភ្លៀងនោះ ដោយគាថាទី ១០ ថា

ភ្លៀងអ្វីហ្នឹង ផ្តេសផ្តាស បង្អុរចុះពុំជូកាលសោះ កូនបង្កើតរបស់
អញ ដែលជាអ្នកបម្រើអញ ទៅបាត់ហើយតើ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អត្រជោ** បានដល់ កើតក្នុងខ្លួន ។ លំដាប់នោះ ព្រះពោធិសត្វ កាលឲ្យមាតាសប្បាយចិត្ត ទើបពោលគាថាទី ១១ ថា

បពិត្រអ្នកមេ សូមអ្នកក្រោកឡើង សម្រាន្តអ្វី ខ្ញុំជាកូនបង្កើត
របស់លោកដែលព្រះរាជាកាសី ទ្រង់ប្រកបដោយប្រាជ្ញា មាន

យស បានលែងមកវិញហើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អាគតោ ត្យាហំ** កាត់បទជា **អាគតោ តេ អហំ** ។ បទថា **វេទេហោធ** បានដល់ សម្បូរដោយញាណ ។ បទថា **យសស្សិនា** បានដល់ មានបរិវារច្រើន ។ អធិប្បាយថា ខ្ញុំត្រូវព្រះរាជានោះចាប់ដោយកាលដែលខ្ញុំជាដំរីមង្គលផុតហើយ ឥឡូវនេះ ខ្ញុំមកកាន់សម្នាក់របស់អ្នកមេ សូមអ្នកក្រោកឡើងទទួលអាហារចុះ មេដំរីត្រេកអរទើបធ្វើអនុមោទនាដល់ព្រះរាជា ពោលគាថាចុងក្រោយថា

ព្រះរាជាណា បានលែងកូនរបស់ខ្ញុំ ជាអ្នកកោតក្រែងចំពោះ
បុគ្គលចាស់សព្វៗ កាល សូមព្រះរាជានោះ ញ៉ាំងដែនរបស់ពួក
អ្នកកាសីឲ្យចម្រើន គង់ព្រះជន្មនៅអស់កាលយូរអង្វែងចុះ ដូច្នេះ ។

គ្រានោះ ព្រះរាជាទ្រង់ជ្រះថ្លាក្នុងគុណរបស់ព្រះពោធិសត្វ ទ្រង់ត្រាស់ឲ្យសាងរោងដំរីមិនឆ្ងាយអំពីស្រះឈូក ហើយទ្រង់ផ្ដើមតាំងអាហារទុកជានិច្ចដើម្បីព្រះពោធិសត្វ និងមាតា ។ ក្នុងកាលខាងក្រោយព្រះពោធិសត្វ កាលមាតាបានធ្វើកាលកិរិយាហើយ បានធ្វើការបរិហាររាងកាយរបស់មាតាហើយ បានទៅកាន់អាស្រមឈ្មោះករណ្ឌកៈ ក្នុងទីនោះ ឥសី ៥០០ ចុះអំពីភ្នំហិមពាន្តមក ។ ព្រះពោធិសត្វបានថ្វាយវត្ថុទាននោះ ដល់ឥសីទាំងនោះ ។ ព្រះរាជាទ្រង់ឲ្យសាងរូបបដិមា ដែលសម្រេចដោយថ្ម មានរូបប៉ុនព្រះពោធិសត្វ ហើយបានឲ្យមហាសក្ការៈប្រព្រឹត្តទៅ ។ មហាជនអ្នកជម្ពូទ្វីប ប្រជុំគ្នារៀងរាល់ឆ្នាំ បានធ្វើនូវការឆ្លងដំរី ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រកាសសច្ចៈហើយ ទ្រង់ប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទក្នុងកាលឥឡូវនេះ បុរសអាក្រក់ ក្នុងកាលនោះ បានមកជាទេវទត្ត ហត្ថាចារ្យក្នុងកាលនោះ បានមកជាសារីបុត្ត ដំរីញីក្នុងកាលនោះ បានមកជាព្រះនាងមហាមាយាទេវី ដំរីដ៏ប្រសើរអ្នកចិញ្ចឹមមាតា ក្នុងកាលនោះ គឺតថាគតដ៏ជាសម្មាសម្ពុទ្ធនេះឯង ។ល។

**អដ្ឋកថា មាតុបោសកជាតក ចប់**

# សុត្តន្តបិដក

## ជុណ្ហជាតក

[ ៨០២ ] ( ព្រាហ្មណ៍បានពោលថា ) បពិត្រព្រះអង្គធំជាងជន សូមព្រះអង្គស្តាប់ពាក្យរបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គមកក្នុងទីនេះ ដោយសេចក្តីត្រូវការចំពោះព្រះអង្គ ទ្រង់ព្រះនាមជុណ្ហៈ បពិត្រព្រះអង្គប្រសើរបំផុត ជាងពួកសត្វជើងពីរ បណ្ឌិតទាំងឡាយពោលថា កាលព្រាហ្មណ៍ជាអ្នកដំណើរ កំពុងឈរ ( សូម ) បុគ្គលមិនត្រូវដើរ ( ហួស ) ទេ ។

[ ៨០៣ ] ( ព្រះរាជាទ្រង់ត្រាស់ថា ) ម្នាលព្រាហ្មណ៍ យើងឮ យើងឈប់នៅ អ្នកចូរនិយាយចុះ អ្នកមកក្នុងទីនេះដោយប្រយោជន៍ណា ឬប្រាថ្នានូវប្រយោជន៍អ្វីចំពោះយើង ទើបមកក្នុងទីនេះ ម្នាលព្រាហ្មណ៍ អ្នកចូរប្រាប់នូវប្រយោជន៍នោះចុះ ។

[ ៨០៤ ] ( ព្រាហ្មណ៍ ... ) សូមព្រះអង្គប្រទានស្រុកសួយ ៥ ទាសី ១០០ គោ ៧០០ និងមាសត្មោរជាង ១០០ ដល់ទូលព្រះបង្គំ សូមប្រទានភរិយា ២ នាក់ មានរូបសណ្ឋានដូចគ្នាដល់ទូលព្រះបង្គំផង ។

[ ៨០៥ ] ( ព្រះរាជា ... ) ម្នាលព្រាហ្មណ៍ ក្រែងអ្នកមានតបៈដ៏ខ្លាំងដែរឬ ម្នាលព្រាហ្មណ៍ ក្រែងអ្នកមានមន្តទាំងឡាយ មានសភាពដ៏វិចិត្រដែរឬ ក្រែងអ្នកមានពួកយក្ខខ្លះ ជាអ្នកស្តាប់ដែរ ឬ ម្យ៉ាងទៀត អ្នកដឹងច្បាស់នូវប្រយោជន៍ដែលអ្នកធ្វើហើយ

ចំពោះយើងឬ ។

[ ៨០៦ ] ( ព្រាហ្មណ៍ ... ) ទូលព្រះបង្គំជាខ្ញុំមិនមានតបៈ មិនមានមន្តទេ ទូលព្រះបង្គំជាខ្ញុំមិនមានពួកយក្ខៈ ជាអ្នកស្តាប់ទេ ទូលព្រះបង្គំជាខ្ញុំមិនដឹងច្បាស់នូវប្រយោជន៍ ដែលទូលព្រះបង្គំជាខ្ញុំធ្វើហើយចំពោះព្រះអង្គទេ ក្នុងកាលមុន ( ទូលព្រះបង្គំជាខ្ញុំ និងព្រះអង្គ ) គ្រាន់តែបានជួបគ្នាប៉ុណ្ណោះ ។

[ ៨០៧ ] ( ព្រះរាជា ... ) តាមខ្ញុំដឹង នេះជាការឃើញដំបូង យើងមិនស្គាល់អ្នកមុនអំពីកាលនេះទេ យើងសួរហើយ អ្នកចូរប្រាប់សេចក្តីនុ៎ះ យើងបានជួបគ្នាក្នុងកាលណា ឬក្នុងទីណា ។

[ ៨០៨ ] ( ព្រាហ្មណ៍ ... ) បពិត្រព្រះសម្មតិទេព ពួកយើងនៅក្នុងក្រុងតក្កសិលា ជាបុរីគួរឲ្យត្រេកអរ របស់ស្តេចគន្ធារៈ ក្នុងទីនោះ ពួកយើងខ្ញុំបានទង្គិចស្មានិងស្មាក្នុងទីងងឹត ក្នុងរាត្រីមានអ័ព្ទដ៏ក្រាស បពិត្រព្រះអង្គជាធំជាងជន យើងខ្ញុំទាំងពីរនាក់នោះ ឈរក្នុងទីនោះ បានបញ្ចប់ពាក្យគួរឲ្យរឭកក្នុងទីនោះ នោះឯងឈ្មោះថាការជួបគ្នានៃយើងខ្ញុំ ( ឯការជួបគ្នា ) ខាងក្រោយ និងខាងមុខអំពីកាលនោះ មិនមានឡើយ ។

[ ៨០៩ ] ( ព្រះរាជា ... ) ម្នាលព្រាហ្មណ៍ ការជួបនឹងសប្បុរសក្នុងពួកមនុស្សក្នុងកាលណា ពួកបណ្ឌិតមិនដែលបំបាត់ការជួប និងសេចក្តីស្និទ្ធស្នាល ឬគុណដែលគេធ្វើហើយក្នុងកាលមុនទេ ។

[ ៨១០ ] ចំណែកខាងពួកពាល តែងបំបាត់ការជួប និងសេចក្តីស្និទ្ធស្នាល ឬគុណដែលគេធ្វើហើយក្នុងកាលមុន គុណសូម្បីច្រើនដែលគេធ្វើហើយចំពោះពួកពាល រមែងបាត់ទៅពិតដូច្នោះមែន ពួកពាល មានសភាពជាមនុស្សអកតញ្ញូ ។

[ ៨១១ ] ចំណែកខាងពួកបណ្ឌិត មិនបំបាត់ការជួប និងសេចក្តីស្និទ្ធស្នាល ឬគុណដែលគេធ្វើហើយក្នុងកាលមុនទេ គុណសូម្បីតិចដែលគេធ្វើហើយចំពោះពួកបណ្ឌិត រមែងមិនបាត់ពិតដូច្នោះមែន ពួកបណ្ឌិត មានសភាពជាមនុស្សកតញ្ញូ យើងនឹងឲ្យស្រុកសួយ ៥ ទាសី ១០០ នាក់ គោ ៧០០ មាសត្ថោរ ជាង ១០០០ ដល់អ្នក ម្យ៉ាងទៀត យើងនឹងឲ្យភរិយាពីរ ដែលមានរូបសណ្ឋានដូចគ្នាដល់អ្នក ។

[ ៨១២ ] ( ព្រាហ្មណ៍ ... ) បពិត្រព្រះរាជា ការជួបជុំសប្បុរសតែងមានយ៉ាងនេះ បពិត្រព្រះអង្គជាម្ចាស់នៃដែនកាសី ដូចយ៉ាង ( ព្រះចន្ទឋិតនៅក្នុងកណ្តាល ) នៃពួកផ្កាយ រមែងពេញឡើងយ៉ាងណាមិញ ទូលព្រះបង្គំជាខ្ញុំ ( ពេញប្រៀបដោយស្រុកសួយជាដើម ដែលព្រះអង្គប្រទានក្នុងថ្ងៃនេះ ក៏យ៉ាងនោះដែរ ) ព្រោះការជួបនឹងព្រះអង្គ ខ្ញុំបានហើយក្នុងថ្ងៃនេះ ។

ជុណ្ហជាតកទី ២ ចប់

# អដ្ឋកថា

## ជុណ្ហជាតក

[ ៨០២-៨១២ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធពរដែលព្រះអានន្ទត្ថេរបានហើយ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **សុណោហិ មយ្ហំ វចនំ ជនិន្ទ** ដូច្នេះជាដើម ។

នឹងពោលដោយពិស្តារថា ក្នុងបឋមបោធិកាល ព្រះមានព្រះភាគមិនមានឧបដ្ឋាកជាប្រចាំអស់ ២០ ឆ្នាំ ជួនកាលមានព្រះនាគសមាលត្ថេរជាអ្នកឧបដ្ឋាក ជួនកាលព្រះនាគិតៈ ជួនកាលព្រះឧបវាណ ជួនកាលព្រះសុនក្ខត្តៈ ជួនកាលព្រះចុន្ទ ជួនកាលព្រះសាគតៈ ជួនកាលព្រះមេឃិយៈជាអ្នកឧបដ្ឋាកព្រះមានព្រះភាគ ។

ថ្ងៃមួយ ព្រះសាស្តាត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ តថាគតចាស់ហើយ ភិក្ខុពួកខ្លះ កាលតថាគតពោលថា ទៅផ្លូវនេះ បែរជានាំគ្នាទៅផ្លូវដទៃ ភិក្ខុពួកខ្លះដាក់បាត្រ និងចីវររបស់តថាគតត្រង់ផែនដី ចូរពួកអ្នកដឹងភិក្ខុមួយរូប ដែលជាអ្នកឧបដ្ឋាកជាប្រចាំដល់តថាគត ទ្រង់ឃាត់ព្រះសារីបុត្តត្ថេរជាដើម ដែលនាំគ្នាក្រោកឡើង ធ្វើអញ្ជលីដោយសិរសា គឺតួងថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងឧបដ្ឋាក ខ្ញុំព្រះអង្គនឹងឧបដ្ឋាកដូច្នេះ ដោយព្រះតម្រាស់ថា សេចក្តីប្រាថ្នារបស់ពួកអ្នកដល់ទីបំផុតហើយ ។ លំដាប់នោះ ភិក្ខុទាំងឡាយក៏ពោលនឹងព្រះអានន្ទត្ថេរថា អាវុសោ សូមលោកសូមធ្វើការឧបដ្ឋាកចុះ ។ ព្រះថេរៈសូមពរ ៨ ប្រការ គឺបដិសេធ ៤ សំណូមពរ ៤ ទាំងនេះថា បពិត្រព្រះអង្គ បើទ្រង់មិនឲ្យចីវរដែលទ្រង់បាន

ហើយដល់ខ្ញុំព្រះអង្គ មិនឲ្យបិណ្ឌបាត និងមិនឲ្យនៅក្នុងព្រះគន្ធកុដិជាមួយទ្រង់ មិននាំខ្ញុំព្រះអង្គទៅកាន់ទីនិមន្ត បើទ្រង់ទៅកាន់ទីនិមន្ត ដែលខ្ញុំព្រះអង្គទទួល បើខ្ញុំព្រះអង្គបានដើម្បីឲ្យបរិស័ទដែលមកអំពីក្រៅដែន ក្រៅជនបទគាល់ទ្រង់ សូមឲ្យបានគាល់ក្នុងខណៈដែលមកហើយនោះឯង សូមឲ្យខ្ញុំព្រះអង្គបានគាល់ទ្រង់ ក្នុងខណៈដែលខ្ញុំកើតសង្ស័យ បើទ្រង់សម្តែងធម៌ឯណាក្នុងទីកំបាំង ទ្រង់ត្រឡប់មកហើយ សូមសម្តែងធម៌នោះដល់ខ្ញុំព្រះអង្គទៀត ដោយអាការយ៉ាងនេះ ទើបខ្ញុំព្រះអង្គឧបដ្ឋាកព្រះមានព្រះភាគអង្គនោះ ។ ចំណែកព្រះសាស្តាបានប្រទានដល់អានន្ទហើយ ។ តាំងអំពីនោះមក ព្រះអានន្ទត្ថេរបានជាអ្នកឧបដ្ឋាកជាប្រចាំអស់កាល ២៥ ឆ្នាំ ។ ព្រះថេរៈបានទទួលនូវការស្ថាបនាក្នុងឯតទគ្គៈក្នុងឋានៈ ៥ ប្រកបដោយសម្បទា ៧ គឺអាគមសម្បទា ១ អធិគមសម្បទា ១ បុព្វហេតុសម្បទា ១ អត្តត្ថបរិបុច្ឆាសម្បទា ១ តិដ្ឋវាសសម្បទា ១ យោនិសោមនសិការសម្បទា ១ ពុទ្ធូបនិស្សយសម្បទា ១ បាននូវមត៌ក គឺពរ ៨ ប្រការក្នុងសម្នាក់ព្រះពុទ្ធទាំងឡាយ បានប្រាកដច្បាស់ក្នុងព្រះពុទ្ធសាសនា ដូចព្រះចន្ទប្រាកដកណ្តាលអាកាសដូច្នោះ ។ ថ្ងៃមួយ ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោ ព្រះតថាគតបានឲ្យព្រះអានន្ទត្អែតដោយការប្រទានពរ ព្រះសាស្តាយាងមកហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អំបាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែកាលឥឡូវនេះប៉ុណ្ណោះទេ

សូម្បីក្នុងកាលមុន តថាគតក៏ឲ្យអានន្ទឆ្អែតដោយពរហើយ ក្នុងកាលមុននោះ ឯង តថាគតក៏បានឲ្យវត្ថុដែលអានន្ទសូមដូចគ្នា ដូច្នេះហើយ ទើបទ្រង់នាំអតីតនិទានមកសាធក:ដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វ បានជាព្រះរាជឱរសរបស់ព្រះរាជាអង្គនោះ ព្រះនាមជុណ្ហ-កុមារ ទ្រង់សិក្សាសិប្ប:ក្នុងនគរតក្កសិលា ឲ្យនូវកិច្ចបដិបត្តិរឿយៗ ដល់អាចារ្យក្នុងពេលងងឹត កណ្តាលយប់ ចេញអំពីផ្ទះរបស់អាចារ្យ ប្រញាប់ទៅកាន់លំនៅរបស់ខ្លួន កាលមិនបានឃើញព្រាហ្មណ៍ម្នាក់ ដែលត្រាច់ភិក្ខាចារក្នុងទីលំនៅរបស់ខ្លួន ទើបទង្គិចភាជនភត្តរបស់ព្រាហ្មណ៍នោះបែកទៅ ព្រាហ្មណ៍ដួលចុះស្រែកយំ ។ កុមារបែរជាបាននូវសេចក្តីករុណា ទើបចាប់ដៃព្រាហ្មណ៍នោះឲ្យក្រោកឡើង ព្រាហ្មណ៍ពោលថា អ្នកមកទម្លាយភាជនភិក្ខារបស់យើង ធ្វើអ្វី ចូរឲ្យថ្លៃភត្តាហារដល់យើង ។ កុមារពោលថា នែព្រាហ្មណ៍ ឥឡូវនេះ ខ្ញុំមិនអាចឲ្យតម្លៃភត្តាហារនេះ ដល់អ្នកបានទេ ខ្ញុំជាឱរសរបស់ព្រះបាទកាសី ឈ្មោះជុណ្ហកុមារ កាលខ្ញុំតាំងនៅក្នុងរាជសម្បត្តិ អ្នកគប្បីមកសូមទ្រព្យខ្ញុំបាន ។ ចប់ការសិក្សាហើយ ថ្វាយបង្គំអាចារ្យ លាទៅកាន់នគរពារាណសី សម្តែងសិប្ប:ដល់បិតា ។ ព្រះបិតាគិតថា កាលអញនៅមានជីវិតបានឃើញបុត្រហើយ អញនឹងឃើញបុត្រនោះបានជាព្រះរាជា ដូច្នេះហើយ ទើបអភិសេកក្នុងរាជសម្បត្តិ ។ ព្រះរាជាព្រះនាមជុណ្ហ: គ្រងរាជសម្បត្តិដោយធម៌ ព្រាហ្មណ៍ជ្រាបរឿងនោះ ទើបគិតថា ឥឡូវនេះ អញនឹងឲ្យព្រះរាជាសងតម្លៃភត្តាហារ

មកដល់អញ ទើបទៅកាន់ក្រុងពារាណសី ឃើញព្រះរាជាកំពុងប្រទក្សិណព្រះនគរ ដែលគេបានតាក់តែងនោះ ទើបឈរក្នុងទីខ្ពស់មួយកន្លែង ហើយលាដៃចេញទៅថ្វាយនូវជ័យជម្នះ ។ ព្រះរាជាទ្រង់យានហួសទៅដោយមិនក្រឡេកមើលឡើយ ព្រាហ្មណ៍ដឹងថា ព្រះរាជាមិនបានឃើញ កាលនឹងលើករឿងឡើង ទើបពោលគាថាទី ១ ថា

បពិត្រព្រះអង្គធំជាងជន សូមព្រះអង្គស្តាប់ពាក្យរបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គមកក្នុងទីនេះ ដោយសេចក្តីត្រូវការចំពោះព្រះអង្គ ទ្រង់ព្រះនាមជុណ្ហៈ បពិត្រព្រះអង្គប្រសើរបំផុត ជាងពួកសត្វជើងពីរ បណ្ឌិតទាំងឡាយពោលថា កាលព្រាហ្មណ៍ជាអ្នកដំណើរ កំពុងឈរ ( សូម ) បុគ្គលមិនត្រូវដើរ ( ហួស ) ទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ជុណ្ហាម្ហិ** ព្រាហ្មណ៍សម្តែងថា បពិត្រព្រះរាជាទូលបង្គំមកដល់ទីនេះ ដោយប្រយោជន៍ឯណានីមួយ ក្នុងទ្រង់ដែលព្រះនាមជុណ្ហៈ មិនបានមកដោយឥតហេតុទេ ។ បទថា **អទ្ធិកោ** បានដល់ មកអស់រយៈកាលយូរ ។ បទថា **គន្តព្វំ** សេចក្តីថា បណ្ឌិតទាំងឡាយ មិនបានពោលហើយ នឹងរមែងមិនពោលថា ព្រះរាជាគួរយានហួសទៅ កុំដាក់ចិត្តក្នុងព្រាហ្មណ៍ដែលដើរផ្លូវឆ្ងាយ គឺមកអស់រយៈកាលយូរ ហើយសូម ។

ព្រះរាជា ទ្រង់ស្តាប់ពាក្យរបស់ព្រាហ្មណ៍ហើយ ទើបយកកង្វេរពេជ្រទាញដំរី បានត្រាស់គាថាទី ២ ថា

ម្នាលព្រាហ្មណ៍ យើងព្ញ យើងឈប់នៅ អ្នកចូរនិយាយចុះ អ្នក

មកក្នុងទីនេះដោយប្រយោជន៍ណា ឬប្រាថ្នានូវប្រយោជន៍អ្វីចំពោះយើង ទើបមកក្នុងទីនេះ ម្នាលព្រាហ្មណ៍ អ្នកចូរប្រាប់នូវប្រយោជន៍នោះចុះ ដូច្នេះ ។

សព្ទថា **ឥង្ឃ** ក្នុងគាថានោះ ជានិបាតប្រើក្នុងអត្ថថា ទាមទារ ។ បន្ទាប់អំពីនោះ ព្រះមានព្រះភាគត្រាស់គាថាដ៏សេស ដោយអំណាចការឆ្លើយឆ្លងរបស់ព្រាហ្មណ៍ និងព្រះរាជាថា

សូមព្រះអង្គប្រទានស្រុកសួយ ៥ ទាសី ១០០ គោ ៧០០ និងមាសផ្កាជាង ១០០ ដល់ទូលព្រះបង្គំ សូមប្រទានភរិយា ២ នាក់ មានរូបសណ្ឋានដូចគ្នា ដល់ទូលព្រះបង្គំផង ។

ព្រះរាជាត្រាស់ថា

ម្នាលព្រាហ្មណ៍ ក្រែងអ្នកមានតបៈដ៏ខ្លាំងដែរឬ ម្នាលព្រាហ្មណ៍ ក្រែងអ្នកមានមន្តទាំងឡាយ មានសភាពដ៏វិចិត្រដែរឬ ក្រែងអ្នកមានពួកយក្ខ: ជាអ្នកស្តាប់ដែរឬ ម្យ៉ាងទៀត អ្នកដឹងច្បាស់នូវប្រយោជន៍ដែលអ្នកធ្វើហើយ ចំពោះយើងឬ ។

ព្រាហ្មណ៍ក្រាបទូលថា

ទូលព្រះបង្គំជាខ្ញុំមិនមានតបៈ មិនមានមន្តទេ ទូលព្រះបង្គំជាខ្ញុំមិនមានពួកយក្ខ: ជាអ្នកស្តាប់ទេ ទូលព្រះបង្គំជាខ្ញុំមិនដឹងច្បាស់នូវប្រយោជន៍ ដែលទូលព្រះបង្គំជាខ្ញុំធ្វើហើយចំពោះព្រះអង្គទេ ក្នុងកាលមុន ( ទូលព្រះបង្គំជាខ្ញុំ និងព្រះអង្គ )

គ្រាន់តែបានជួបគ្នាប៉ុណ្ណោះ ។

ព្រះរាជាត្រាស់ថា

តាមខ្ញុំដឹង នេះជាការឃើញដំបូង យើងមិនស្គាល់អ្នកមុនអំពីកាលនេះទេ យើងសួរហើយ អ្នកចូរប្រាប់សេចក្តីនុ៎ះ យើងបានជួបគ្នាក្នុងកាលណា ឬក្នុងទីណា ។

ព្រាហ្មណ៍ក្រាបទូលថា

បពិត្រព្រះសម្មតិទេព ពួកយើង នៅក្នុងក្រុងតក្កសិលា ជាបុរីគួរឲ្យត្រេកអរ របស់ស្តេចគន្ធារៈ ក្នុងទីនោះ ពួកយើងខ្ញុំបានទន្ទិចស្នាទិងស្នាក្នុងទីងងឹត ក្នុងរាត្រីមានអ័ព្ទដ៏ក្រាស់ បពិត្រព្រះអង្គជាធំជាងជន យើងខ្ញុំទាំងពីរនាក់នោះ ឈរក្នុងទីនោះ បានបញ្ចប់ពាក្យគួរឲ្យរឭកក្នុងទីនោះ នោះឯង ឈ្មោះថា ការជួបគ្នានៃយើងខ្ញុំ ( ឯការជួបគ្នា ) ខាងក្រោយ និងខាងមុខ អំពីកាលនោះ មិនមានឡើយ ។

ព្រះរាជាត្រាស់ថា

ម្នាលព្រាហ្មណ៍ ការជួបនឹងសប្បុរស ក្នុងពួកមនុស្សក្នុងកាលណា ពួកបណ្ឌិតមិនដែលបំបាត់ការជួប និងសេចក្តីស្និទ្ធស្នាល ឬគុណដែលគេធ្វើហើយក្នុងកាលមុនទេ ។

ចំណែកខាងពួកពាល តែងបំបាត់ការជួប និងសេចក្តីស្និទ្ធស្នាល ឬគុណដែលគេធ្វើហើយក្នុងកាលមុន គុណសូម្បីច្រើនដែលគេ

ធ្វើហើយចំពោះពួកពាល រមែងបាត់ទៅពិតដូច្នោះមែន ពួកពាលមានសភាពជាមនុស្សអកតញ្ញូ ។

ចំណែកខាងពួកបណ្ឌិត មិនបំបាត់ការជួប និងសេចក្ដីស្និទ្ធស្នាល ឬគុណដែលគេធ្វើហើយក្នុងកាលមុនទេ គុណសូម្បីតិចដែលគេធ្វើហើយចំពោះពួកបណ្ឌិត រមែងមិនបាត់ពិតដូច្នោះមែន ពួកបណ្ឌិតមានសភាពជាមនុស្សកតញ្ញូ យើងនឹងឲ្យស្រុកសួយ ៥ ទាសី ១០០ នាក់ គោ ៧០០ មាសគ្រោងជាង ១០០០ ដល់អ្នក ម្យ៉ាងទៀត យើងនឹងឲ្យភរិយាពីរដែលមានរូបសណ្ឋានដូចគ្នាដល់អ្នក ។

ព្រាហ្មណ៍ក្រាបទូលថា

បពិត្រព្រះរាជា ការជួបជុំសប្បុរស តែងមានយ៉ាងនេះ បពិត្រព្រះអង្គជាម្ចាស់នៃដែនកាសី ដូចយ៉ាង ( ព្រះចន្ទឋិតនៅក្នុងកណ្ដាល ) នៃពួកផ្កាយ រមែងពេញឡើង យ៉ាងណាមិញ ទូលព្រះបង្គំជាខ្ញុំ ( ពេញប្រៀបដោយស្រុកសួយជាដើម ដែលព្រះអង្គប្រទានក្នុងថ្ងៃនេះ ក៏យ៉ាងនោះដែរ ) ព្រោះការជួបនឹងព្រះអង្គ ខ្ញុំបានហើយក្នុងថ្ងៃនេះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សាទិសី** សេចក្ដីថា សូមទ្រង់ប្រទានភរិយាដែលមានយសធំពីរនាក់ ដែលដូចគ្នានឹងទូលបង្គំ គឺជាបុគ្គលស្មើគ្នានឹងទូលបង្គំដោយរូប ពណ៌សម្បុរ ជាតិត្រកូល និងប្រទេសនោះឯង ។ បទថា

**ភឹសរូបោ** សេចក្តីថា ព្រះរាជាត្រាស់សួរថា ម្នាលព្រាហ្មណ៍ តបកម្មដែលបានដល់គុណ គឺសីល និងអាចារៈដែលមានកម្លាំងរបស់អ្នក មានឬ ។ បទថា **មន្តា នុ តេ** សេចក្តីថា មន្តដែលខ្លាំងក្រៃលែង ដែលឲ្យសម្រេចប្រយោជន៍គ្រប់យ៉ាងរបស់អ្នក មានឬ ។ បទថា **អស្សវា** សេចក្តីថា ពួកយក្ខដែលធ្វើតាមពាក្យ ដែលឲ្យវត្ត ដែលអ្នកប្រាថ្នាពួកខ្លះរបស់អ្នក មានឬ ។ បទថា **កត្តំ** កែជា **កតំ** សេចក្តីថា ព្រះរាជាត្រាស់សួរថា អ្នកនឹកដល់ប្រយោជន៍ណាមួយដែលធ្វើដល់ខ្ញុំបានឬ ។ បទថា **សង្គតិមត្តំ** សេចក្តីថា ព្រាហ្មណ៍ក្រាបទូលថា ហេតុត្រឹមតែការមកជួបនឹងទ្រង់ មានដល់ទូលបង្គំក្នុងកាលមុន ។ បទថា **ជានតោ មេ** សេចក្តីថា នេះជាការឃើញគ្រាដំបូងរបស់អ្នក និងខ្ញុំដែលជាបណ្ឌិត ។ បទថា **ន តាភិជានាមិ** សេចក្តីថា ខ្ញុំមិនស្គាល់អ្នក ។ បទថា **តិមិស្សកាយំ** បានដល់ កណ្តាលយប់ងងឹត ។ បទថា **តេ តត្ថ ឋត្វាន** សេចក្តីថា យើងទាំងនោះ ឈរនៅក្នុងទីដែលស្ទាបះទង្គិចគ្នានោះ ។ បទថា **វីតិសារិម្ហ តត្ថ** សេចក្តីថា ព្រាហ្មណ៍ក្រាបទូលថា ក្នុងទីត្រង់នោះឯង ពួកយើងបានញុំាងពាក្យដែលគួររឭកដល់ ឲ្យហូរចេញមក គឺទូលបង្គំក្រាបទូលថា ភាជនកិច្ចារបស់ទូលបង្គំ ដែលទ្រង់ទង្គិចបែកហើយ សូមទ្រង់ប្រទានថ្លៃកត្តាហារដល់ទូលបង្គំ ទ្រង់ត្រាស់ថា ឥឡូវនេះ ខ្ញុំមិនអាចសងតម្លៃកត្តាហារដល់អ្នកបាន តែខ្ញុំជាឱរសព្រះបាទកាសី ឈ្មោះជុណ្ហកុមារ កាលខ្ញុំតាំងនៅក្នុងរាជសម្បត្តិ សឹមអ្នកមកទារទ្រព្យជាមួយនឹងខ្ញុំ សារាណីយកថានេះ ពួកយើងបានធ្វើដល់គ្នានិងគ្នាហើយ ។ បទថា **សាយេវ នោ**

**សង្គតិមត្តមាសិ** សេចក្ដីថា ព្រាហ្មណ៍សម្ដែងថា បពិត្រព្រះសម្មតិទេព ពួកយើង ត្រឹមតែបានជួបគ្នានិងគ្នា គឺបានជួបគ្នាត្រឹមមួយភ្លែត ។ បទថា **តតោ** សេចក្ដីថា ខាងក្រោយ ឬមុនអំពីនោះ គឺចាកមិត្តភាពមួយភ្លែតនោះ មិនធ្លាប់មានការជួបរបស់ពួកយើង ក្នុងកាលណា ( ទៀត ) ឡើយ ។ បទថា **ន បណ្ឌិតា** សេចក្ដីថា នៃព្រាហ្មណ៍ ធម្មតាបណ្ឌិតទាំងឡាយ រមែងមិនធ្វើឲ្យការជួបត្រឹមតែមួយស្របក់នោះ ឬការស្និទ្ធស្នាលគ្នាអស់កាលយូរ ឬគុណដែលអ្នកធ្វើក្នុងកាលមុនណាមួយ សាបសូន្យទៅ ។ បទថា **ពហុំបិ** បានដល់ សូម្បីច្រើន ។ បទថា **អកតញ្ញុរូបា** សេចក្ដីថា ព្រោះហេតុដែលពួកបុគ្គលពាល មានសភាវៈជាអកតញ្ញូ ដូច្នោះ ឧបការគុណដែលអ្នកធ្វើក្នុងពួកបុគ្គលពាលនោះ ទោះបីមានច្រើនក៏រលាយសូន្យទៅ ។ បទថា **សុកតញ្ញុរូបា** បានដល់ មានភាសវៈដឹងឧបការគុណដែលអ្នកធ្វើហើយដោយល្អ ។ **ហិ** អក្ខរៈក្នុងពាក្យថា **តថា ហិ** ទាំងក្នុងទីនេះ ទាំងក្នុងទីនោះ មានការណៈជាអត្ថ ។ បទថា **ទទាមិ តេ** សេចក្ដីថា ព្រះរាជាកាលព្រះរាជទានតាមដែលព្រាហ្មណ៍ទូលសូម ទើបបានត្រាស់យ៉ាងនោះ ។ ព្រាហ្មណ៍កាលធ្វើអនុមោទនាដល់ព្រះរាជា ទើបបានក្រាបទូលគាថាថា **ឯវំ សតំ** ជាដើម គឺឈ្មោះថាការរួមសមាគម បានដល់ ការជួបនឹងសប្បុរស គឺលោកអ្នកជាមនុស្សល្អទាំងឡាយត្រឹមតែម្ដង ក៏មានសភាពយ៉ាងនេះ ។ **វិវ** អក្ខរៈ ក្នុងបទថា **នក្ខត្តរាជារិវ** ត្រឹមតែជានិបាត ។ បទថា **តារកានំ** បានដល់ ក្នុងកណ្ដាលនៃហ្វូងផ្កាយទាំងឡាយ ។ ព្រាហ្មណ៍ហៅព្រះរាជាដោយពាក្យថា **កាសិបតី** អធិប្បាយថា

បពិត្រព្រះសម្មតិទេពដ៏ជាធំក្នុងកាសីរដ្ឋ ព្រះចន្ទស្ថិតនៅកណ្តាលនៃពពកផ្កាយ គឺមានហ្វូងនៃតារាចោមរោម រមែងភ្លឺផ្លេកចាប់តាំងអំពីថ្ងៃ ១ កើត រហូតដល់ថ្ងៃ ១៥ កើត យ៉ាងណា ទូលបង្គំក៏ដូច្នោះ ថ្ងៃនេះ កំពុងពេញប្រៀបដោយស្រុកសួយជាដើម ដែលទ្រង់ព្រះរាជទាន ។ បទថា **តយា ហិ មេ** សេចក្តីថា ព្រាហ្មណ៍ទូលថា ការជួបនឹងទ្រង់ សូម្បីទូលបង្គំបានហើយក្នុងកាលមុន ក៏ដូចជាមិនបាន តែក្នុងថ្ងៃនេះ ព្រោះមនោរថរបស់ទូលបង្គំសម្រេច ការជួបនឹងទ្រង់ ឈ្មោះថា ទូលបង្គំបានហើយនោះឯង ព្រោះហេតុនោះ ផលនៃមេត្រីចិត្តរបស់ទូលបង្គំ និងទ្រង់ ទើបសម្រេចផលហើយ ។ ព្រះពោធិសត្វបានប្រទានយសធំដល់ព្រាហ្មណ៍នោះ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន តថាគតក៏ធ្លាប់ឲ្យអានន្ទឆ្អែតដោយពរដូចគ្នា ដូច្នេះហើយ ទើបទ្រង់ប្រជុំជាតកថា ព្រាហ្មណ៍ក្នុងកាលនោះ បានមកជាអានន្ទ ក្នុងកាលឥឡូវនេះ ចំណែកព្រះរាជាក្នុងកាលនោះ គឺតថាគតនេះឯង ។ល។

## អដ្ឋកថា ជុណ្ហជាតក ចប់

# សុត្តន្តបិដក

## ធម្មទេវបុត្តជាតក

[ ៨១៣ ] ( ធម្មទេវបុត្រពោលថា ) ម្នាលអធម្មទេវបុត្រ ខ្ញុំឈ្មោះធម្មៈ ជាអ្នកធ្វើយស ធ្វើបុណ្យ ខ្ញុំដែលពួកសមណ-ព្រាហ្មណ៍សរសើរជានិច្ច ដែលទេវតា និងមនុស្សបូជាហើយ គួរបានផ្លូវ អ្នកចូរឲ្យផ្លូវ ។

[ ៨១៤ ] ( អធម្មទេវបុត្រពោលថា ) ម្នាលធម្មៈ ខ្ញុំជិះរថឈ្មោះអធម្មយានដ៏មាំ ជាអ្នកមិនតក់ស្លុត មានកម្លាំង ខ្ញុំនោះនឹងឲ្យផ្លូវដល់អ្នកដែលមិនធ្លាប់ឲ្យហើយក្នុងថ្ងៃនេះ ព្រោះហេតុអ្វី ។

[ ៨១៥ ] ( ធម្មទេវបុត្រ ... ) ធម៌បានកើតមុន អធម៌កើតក្រោយក្នុងលោក ខ្ញុំជាច្បងផង ប្រសើរជាងផង មានតាំងពីព្រេងនាយផង ម្នាលប្អូនអ្នកចូរចៀសចេញអំពីផ្លូវរបស់បង ។

[ ៨១៦ ] ( អធម្មទេវបុត្រ ... ) ខ្ញុំមិនត្រូវឲ្យផ្លូវដល់អ្នកដោយសេចក្តីអង្វរ មិនត្រូវឲ្យដោយពាក្យសមគួរ មិនត្រូវឲ្យព្រោះខ្ញុំគួរបានផ្លូវ យើងទាំងពីរនាក់ចូរច្បាំងគ្នាក្នុងថ្ងៃនេះ អ្នកណាឈ្នះក្នុងចម្បាំង ផ្លូវជារបស់អ្នកនោះ ។

[ ៨១៧ ] ( ធម្មទេវបុត្ត ... ) ម្នាលអធម្មៈ ខ្ញុំឈ្មោះធម្មៈ ជាអ្នកល្បីល្បាញសព្វទិស មានកម្លាំងច្រើន មានយសរាប់មិនអស់ មិនមានអ្នកណាផ្ទឹមបាន មានសភាពជាអ្នកប្រកបដោយគុណគ្រប់យ៉ាង អ្នកនឹងឈ្នះ ( ខ្ញុំ ) ដូចម្តេចបាន ។

[ ៨១៨ ] ( អធម្មទេវបុត្ត ... ) គេតែងជំមាសដោយដែក គេមិនដែលជំដែកដោយមាសទេ បើអធម្ម:ជំធម្ម: ក្នុងថ្ងៃនេះ ដូចជាដែកជំមាស បុគ្គលគួរមើលដែរ ។

[ ៨១៩ ] ( ធម្មទេវបុត្ត ... ) ម្នាលអធម្ម: បើអ្នកមានកម្លាំងនឹងច្បាំងបុគ្គលចាស់ និងបុគ្គលជាគ្រូមិនមានដល់អ្នក ខ្ញុំនឹងឲ្យនូវផ្លូវដល់អ្នក ដោយពាក្យជាទីស្រឡាញ់ និងមិនជាទីស្រឡាញ់ផង ខ្ញុំនឹងអត់ទ្រាំ នូវពាក្យទ្រគោះបោះបោករបស់អ្នកផង ។

[ ៨២០ ] ( ព្រះភគវាបានត្រាស់ថា ) អធម្មទេវបុត្ត ឮពាក្យនេះហើយ មានក្បាលសំយុងចុះ មានជើងឡើងលើ ក៏ធ្លាក់ចុះពោលពាក្យថា អញត្រូវការដោយចម្បាំង តែមិនបាននូវការច្បាំងឡើយ អធម្មទេវបុត្តក៏ស្លាប់ ដោយហេតុត្រឹមប៉ុណ្ណោះឯង ។

[ ៨២១ ] ធម្មទេវបុត្តមានខន្តិធម៌ជាកម្លាំង មានចិត្ត មានកម្លាំងក្រៃពេក មានព្យាយាមដ៏ទៀងទាត់ បានផ្ចាញ់ បានសម្លាប់នូវអធម្មទេវបុត្ត ដែលមានចម្បាំងជាកម្លាំង ទម្លាក់ទៅលើផែនដី ហើយឡើងកាន់រថ ( របស់ខ្លួន ) បរទៅតាមផ្លូវដដែល ។

[ ៨២២ ] បុគ្គលណា មិនបានធ្វើសក្ការ: ដល់មាតាបិតា និងសមណព្រាហ្មណ៍ ក្នុងផ្ទះរបស់ខ្លួន បុគ្គលនោះ លុះដាក់ចុះនូវរាងកាយ គឺសរីរ: បែកធ្លាយរាងកាយក្នុងលោកនេះ រមែងទៅកាន់នរក ដូចជាអធម្មទេវបុត្ត ដែលសំយុងក្បាលធ្លាក់ចុះ ។

[ ៨២៣ ] បុគ្គលណា បានធ្វើសក្ការៈដល់មាតាបិតា និងសមណ-ព្រាហ្មណ៍ ក្នុងផ្ទះរបស់ខ្លួន បុគ្គលនោះ លុះដាក់ចុះនូវរាងកាយ គឺសរីរៈ បែកធ្លាយរាងកាយក្នុងលោកនេះ រមែងទៅកាន់សុគតិ ដូចជាធម្មទេវបុត្ត ឡើងកាន់រថរបស់ខ្លួន ដូច្នោះ ។

**ធម្មទេវបុត្តជាតកទី ៣ ចប់**

# អដ្ឋកថា

## ធម្មទេវបុត្តជាតក

[ ៨១៣-៨២៣ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធដល់ការដែលផែនដីស្រូបទេវទត្តភិក្ខុ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **យសោករោ បុញ្ញករោហមស្មិ** ដូច្នេះជាដើម ។

សេចក្តីសង្ខេបថា ក្នុងកាលនោះ ភិក្ខុទាំងឡាយអង្គុយសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ ទេវទត្តបដិបត្តិជាសត្រូវជាមួយព្រះតថាគត ត្រូវផែនដីស្រូបហើយ ។ ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អំបាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ កាលភិក្ខុទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបហើយ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលទេវទត្តឲ្យនូវការប្រហារក្នុងជិនចក្ករបស់តថាគត ត្រូវផែនដីស្រូប សូម្បីក្នុងកាលមុន ទេវទត្តឲ្យនូវការប្រហារក្នុងធម្មចក្ក ត្រូវផែនដីស្រូប បែរមុខទៅកាន់អវិចីមហានរកដូច្នេះហើយ ទើបទ្រង់នាំអតីតនិទានមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតជាទេវបុត្រ ឈ្មោះធម្មទេវបុត្រ ក្នុងកាមាវចរទេវលោក ។ ចំណែកទេវទត្តកើតជាទេវបុត្រ ឈ្មោះអធម្មទេវបុត្រ ។ ទេវបុត្រទាំងពីរអង្គនោះ ធម្មទេវបុត្រប្រដាប់ដោយគ្រឿងអលង្ការដែលជាទិព្វ ទ្រង់រថទិព្វដ៏ប្រសើរ ចោមរោមដោយពួកទេពអប្សរ កាលពួកមនុស្សបរិភោគអាហារល្ងាចហើយ អង្គុយសន្ទនាគ្នាយ៉ាងសប្បាយត្រង់ទ្វារផ្ទះ រៀងៗ ខ្លួន ក៏ស្ថិតនៅក្នុង

អាកាស ក្នុងគាមនិគម ជនបទ និងរាជធានី ក្នុងថ្ងៃពេញបូណ៌មី ដែលជាថ្ងៃឧបោសថ ដឹកនាំពួកជនឲ្យកាន់យកនូវកុសលកម្មបថ ១០ ប្រការថា អ្នកទាំងឡាយ ចូរវៀរចាកអកុសលកម្មបថ ១០ ប្រការ មានសម្លាប់សត្វជាដើម នាំគ្នាបំពេញធម៌ គឺការទំនុកបម្រុងមាតាបិតា មួយអន្លើដោយសុចរិត ៣ ប្រការ ទាំងអស់គ្នាចុះ កាលបំពេញយ៉ាងនេះនឹងមានឋានសួគ៌ជាទីទៅខាងមុខ សោយនូវយសធំ ដូច្នេះហើយ ធ្វើប្រទក្សិណជម្ពូទ្វីប ។ ចំណែកអធម្ម-ទេវបុត្រ ដឹកនាំឲ្យកាន់យកអកុសលកម្មបថ ១០ ប្រការ ដោយន័យជាដើមថា ចូរពួកអ្នកសម្លាប់សត្វចុះ ដូច្នេះហើយ ទើបធ្វើនូវវាមៈ គឺការវិលទៅឆ្វេងជុំវិញជម្ពូទ្វីប គ្រានោះ រថរបស់ទេវបុត្រទាំងនោះ បានជួបគ្នាក្នុងអាកាស ។ តមក ពួកបរិស័ទរបស់ទេវបុត្រទាំងនោះសួរគ្នាថា ពួកលោកជាចំណែកខាងណា ពួកលោកជាចំណែកខាងណា ក៏ឆ្លើយឆ្លងគ្នាថា ពួកយើងខាងធម្មទេវបុត្រ ពួកយើងខាងអធម្មទេវបុត្រ ទើបបែកគ្នាជាពីរចំណែក ។ ឯធម្មទេវបុត្រ ហៅអធម្មទេបុត្រមកពោលថា នែសម្លាញ់ អ្នកជាចំណែកអធម៌ ខ្ញុំជាចំណែកធម៌ ផ្លូវសមគួរដល់ខ្ញុំ ចូរអ្នកបររថរបស់អ្នកចៀសចេញទៅ ចូរឲ្យផ្លូវដល់ខ្ញុំចុះ ហើយពោលគាថាទី ១ ថា

ម្នាលអធម្មទេវបុត្រ ខ្ញុំ ឈ្មោះធម្មៈ ជាអ្នកធ្វើយស ធ្វើបុណ្យ
ខ្ញុំដែលពួកសមណព្រាហ្មណ៍សរសើរជានិច្ច ដែលទេវតា និង
មនុស្សបូជាហើយ គួរបានផ្លូវ អ្នកចូរឲ្យផ្លូវ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យសោករោ** បានដល់ ខ្ញុំជាអ្នកធ្វើនូវយស

ឲ្យដល់ទេវតា និងមនុស្សទាំងឡាយ សូម្បីក្នុងបទទីពីរ ក៏ន័យនេះដូចគ្នា ។ បទថា **សមត្ថុតោ** បានដល់ បានទទួលនូវការសរសើរគ្រប់កាល សរសើរជានិច្ច ។ លំដាប់នោះ អធម្មទេវបុត្រពោលថា

ម្នាលធម្មៈ ខ្ញុំជិះរថ ឈ្មោះអធម្មយានដ៏មាំ ជាអ្នកមិនតក់ស្លុត មានកម្លាំង ខ្ញុំនោះ នឹងឲ្យផ្លូវដល់អ្នកដែលមិនធ្លាប់ឲ្យហើយក្នុងថ្ងៃនេះ ព្រោះហេតុអ្វី ដូច្នេះ ។

ធម្មទេវបុត្តពោលថា

ធម៌ បានកើតមុន អធម៌ កើតក្រោយក្នុងលោក ខ្ញុំជាច្បងផង ប្រសើរជាងផង មានតាំងពីព្រេងនាយផង ម្នាលប្អូន អ្នកចូរចៀសចេញអំពីផ្លូវរបស់បង ដូច្នេះ ។

អធម្មទេវបុត្តពោលថា

ខ្ញុំមិនត្រូវឲ្យផ្លូវដល់អ្នក ដោយសេចក្តីអង្វរ មិនត្រូវឲ្យដោយពាក្យសមគួរ មិនត្រូវឲ្យ ព្រោះខ្ញុំគួរបានផ្លូវ យើងទាំងពីរនាក់ ចូរច្បាំងគ្នាក្នុងថ្ងៃនេះ អ្នកណាឈ្នះក្នុងចម្បាំង ផ្លូវជារបស់អ្នកនោះ ដូច្នេះ ។

ធម្មទេវបុត្តពោលថា

ម្នាលអធម្មៈ ខ្ញុំឈ្មោះធម្មៈ ជាអ្នកល្បីល្បាញសព្វទិស មានកម្លាំងច្រើន មានយសរាប់មិនអស់ មិនមានអ្នកណាផ្ទឹមបាន មានសភាពជាអ្នកប្រកបដោយគុណគ្រប់យ៉ាង អ្នកនឹងឈ្នះ ( ខ្ញុំ )

ដូចម្ដេចបាន ដូច្នេះ ។

អធម្មទេវបុត្តពោលថា

គេតែងដំមាសដោយដែក គេមិនដែលដំដែកដោយមាសទេ បើអធម្មៈដំធម្មៈ ក្នុងថ្ងៃនេះ ដូចជាដែកដំមាស បុគ្គលគួរមើលដែរ ដូច្នេះ ។

ធម្មទេវបុត្តពោលថា

ម្នាលអធម្មៈ បើអ្នកមានកម្លាំង នឹងច្បាំងបុគ្គលចាស់ និងបុគ្គលជាគ្រូមិនមានដល់អ្នក ខ្ញុំនឹងឲ្យនូវផ្លូវដល់អ្នក ដោយពាក្យជាទីស្រឡាញ់ និងមិនជាទីស្រឡាញ់ផង ខ្ញុំនឹងអត់ទ្រាំនូវពាក្យទ្រគោះបោះបោករបស់អ្នកផង ដូច្នេះ ។

គាថាទាំង ៦ នេះ លោកពោលដោយអំណាចជាពាក្យឆ្លើយឆ្លងគ្នារវាងទេវបុត្រទាំងពីរនោះឯង ។

បណ្ដាបទទាំងនោះ បទថា **ស កិស្ស ហេតុម្ហិ តវជ្ជធម្ម** សេចក្ដីថា ខ្ញុំឈ្មោះអធម៌ ឡើងរថដែលជាយានរបស់អធម៌ហើយ មិនធ្លាប់ខ្លាចចំពោះអ្នកណា ជាអ្នកមានកម្លាំង នៃធម្មទេវបុត្រ ហេតុអ្វីក្នុងថ្ងៃនេះ ខ្ញុំត្រូវឲ្យផ្លូវដែលមិនធ្លាប់ឲ្យដល់អ្នកណាដល់អ្នក ។ បទថា **បុព្វេ** សេចក្ដីថា ក្នុងបឋមកប្ប ធម៌ គឺកុសលកម្មបថ ១០ ប្រាកដហើយក្នុងលោកនេះមុននោះឯង អធម៌កើតឡើងខាងក្រោយ ។ បទថា **ជេដ្ឋោ ច** នេះ ធម្មទេវបុត្រពោលថា ព្រោះភាពដែលធម៌កើតមុន ទើបខ្ញុំចម្រើនជាង ប្រសើរជាង ចាស់ជាង ឯ

អ្នកជាប្អូន ហេតុនោះ ចូរអ្នកចៀសអំពីផ្លូវ ។ បទថា **ឧបិ ចាជិរថា** សេចក្ដីថា ខ្ញុំមិនព្រមឲ្យផ្លូវដល់អ្នកព្រោះពាក្យអន្ធរ ដោយពាក្យដែលពោលសមគួរ ព្រោះជាអ្នកគួរដល់ផ្លូវ ។ បទថា **អនុវិស្សុតោ** សេចក្ដីថា ខ្ញុំមានឈ្មោះល្បីទៅហើយ ខ្ចរខ្ចាទៅហើយ ប្រាកដដោយគុណរបស់ខ្លួនគ្រប់ទិស គឺក្នុងទិសធំ ៤ ទិសតូច ៤ ។ បទថា **លោហេន** បានដល់ ដោយញញួរដែក ។ បទថា **ហញ្ញតិ** បានដល់ នឹងសម្លាប់ ។ បទថា **យុទ្ធពលោ អធម្ម** សេចក្ដីថា បើអ្នកជាអ្នកមានកម្លាំងក្នុងការច្បាំង ។ បទថា **វុឌ្ឍា ច គរូ ច** សេចក្ដីថា បើបុគ្គលជាធំទាំងនេះ គ្រូទាំងនេះជាបណ្ឌិត រមែងមិនមានដល់អ្នក ។ បទថា **បិយាប្បិយេន** សេចក្ដីថា ខ្ញុំនឹងឲ្យដោយត្រេកអរក្ដី មិនត្រេកអរក្ដី ក៏នឹងឲ្យផ្លូវដល់អ្នក ដូចគ្នានឹងឲ្យដោយត្រេកអរ ។

ក្នុងខណៈដែលព្រះពោធិសត្វពោលគាថានេះចប់នោះឯង អធម្មទេវបុត្រមិនអាចតាំងនៅក្នុងរថបាន ដាំដូងចុះធ្លាក់មកលើប្រឹថពី ផែនដីក៏បើកចន្លោះឲ្យបានទៅកើតក្នុងអវិចីនរកនោះឯង ។ ព្រះសាស្ដា កាលទ្រង់ត្រាស់ដឹងឯងដោយប្រពៃ កាលទ្រង់ជ្រាបសេចក្ដីនេះហើយ បានត្រាស់អភិសម្ពុទ្ធគាថាដ៏សេសដូច្នេះថា

> អធម្មទេវបុត្ត ឮពាក្យនេះហើយ មានក្បាលសំយុងចុះ មាន
> ជើងឡើងលើ ក៏ធ្លាក់ចុះ ពោលពាក្យថា អញត្រូវការដោយ
> ចម្បាំង តែមិនបាននូវការច្បាំងឡើយ អធម្មទេវបុត្តក៏ស្លាប់
> ដោយហេតុត្រឹមប៉ុណ្ណោះឯង ។

ធម្មទេវបុត្តមានខន្តិធម៌ជាកម្លាំង មានចិត្ត មានកម្លាំងក្រៃពេក
មានព្យាយាមដ៏ទៀងទាត់ បានផ្ចាញ់ បានសម្លាប់នូវអធម្មទេវ-
បុត្ត ដែលមានចម្បាំងជាកម្លាំង ទម្លាក់ទៅលើផែនដី ហើយ
ឡើងកាន់រថ ( របស់ខ្លួន ) បរទៅតាមផ្លូវដដែល ។
បុគ្គលណា មិនបានធ្វើសក្ការៈ ដល់មាតា បិតា និងសមណ-
ព្រាហ្មណ៍ក្នុងផ្ទះរបស់ខ្លួន បុគ្គលនោះ លុះដាក់ចុះនូវរាងកាយ
គឺសរីរៈ បែកធ្លាយរាងកាយក្នុងលោកនេះ រមែងទៅកាន់នរក
ដូចជាអធម្មទេវបុត្ត ដែលសំយុងក្បាលធ្លាក់ចុះ ។
បុគ្គលណា បានធ្វើសក្ការៈ ដល់មាតា បិតា និងសមណព្រាហ្មណ៍
ក្នុងផ្ទះរបស់ខ្លួន បុគ្គលនោះ លុះដាក់ចុះនូវរាងកាយ គឺសរីរៈ
បែកធ្លាយរាងកាយក្នុងលោកនេះ រមែងទៅកាន់សុគតិ ដូចជា
ធម្មទេវបុត្ត ឡើងកាន់រថរបស់ខ្លួនដូច្នោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យុទ្ធត្ថិកោ វ** នេះ ជាពាក្យរវើរវាយរបស់អធម្មទេវបុត្តនោះ ។ បានឮថា ទេវបុត្រនោះ កំពុងរវើរវាយនោះឯងធ្លាក់ចុះកាន់ផែនដីទៅហើយ ។ បទថា **ឃត្តាវតា** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ អធម្មទេវបុត្រលិចចុះទៅកាន់ផែនដីត្រឹមណា អធម្មទេវបុត្រ ឈ្មោះថា ត្រូវកម្ចាត់ហើយត្រឹមនោះ ។ បទថា **ខន្តិពលោ** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ អធម្មទេវបុត្រ លិចចុះទៅក្នុងផែនដីយ៉ាងនេះហើយ ធម្មទេវបុត្រដែលជាអ្នកមានកម្លាំង គឺអធិវាសនខន្តិ ឈ្នះអធម្មទេវបុត្រ ដែលប្រាថ្នានឹង

ច្បាំង កាប់ចាក់ ឲ្យធ្លាក់ចុះទៅក្នុងផែនដី មានចិត្តពិតប្រាកដ ព្រោះកើតនូវការគិតឡើង ឡើងកាន់រថរបស់ខ្លួន មានការប្រឹងប្រែងក្នុងសភាវធម៌ដែលពិត គឺមានសេចក្តីព្យាយាមយ៉ាងទៀងទាត់ បានទៅតាមផ្លូវនោះឯង ។ បទថា **អសម្មានិតា** បានដល់ ដែលគេមិនធ្វើសក្ការៈ ។ បទថា **សរីរទេហំ** បានដល់ បានដាក់ចុះនូវរាងកាយ ពោល គឺសរីរៈក្នុងលោកនេះឯង ។ បទថា **និរយំ វជន្តិ** សេចក្តីថា ជនទាំងនោះសមគួរដល់សក្ការៈ ដែលបុគ្គលអាក្រក់ណាមិនធ្វើសក្ការៈក្នុងផ្ទះ បុគ្គលអាក្រក់បែបនោះ រមែងជាំដូចធ្លាក់ទៅកាន់នរក ដូចអធម្មទេវបុត្រ យកក្បាលចុះទៅក្រោម ដូច្នោះ ។ បទថា **សុគតឹ វជន្តិ** សេចក្តីថា ពួកបណ្ឌិត ជាបុគ្គលបែបនោះ ដែលបុគ្គលណាធ្វើសក្ការៈហើយ បុគ្គលនោះរមែងទៅកាន់សុគតិ ដូចធម្មទេវបុត្រឡើងរថចម្បាំង ទៅកាន់ទេវលោក ដូច្នោះ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ទេវទត្តក៏បដិបត្តិជាសត្រូវចំពោះតថាគត ត្រូវផែនដីស្រូបទៅហើយ ទើបទ្រង់ប្រជុំជាតកថា អធម្មទេវបុត្រក្នុងកាលនោះ បានមកជាទេវទត្ត ក្នុងកាលឥឡូវនេះ បរិស័ទរបស់អធម្មទេវបុត្រ ក្នុងកាលនោះ បានមកជាបរិស័ទរបស់ទេវទត្ត បរិស័ទរបស់ធម្មទេវបុត្រ ក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទ ចំណែកធម្មទេវបុត្រក្នុងកាលនោះ គឺតថាគតនេះឯង ។៚

**អដ្ឋកថា ធម្មទេវបុត្តជាតក ចប់**

# សុត្តន្តបិដក

## ឧទយជាតក

[ ៨២៤ ] ( សក្កទេវរាជពោធិសត្វពោលថា ) ម្នាលនាងមាន ចក្ខុប្រាកដស្មើ ដោយភ្នែកនៃកិន្នរ នាងស្លៀកសំពត់ដ៏ស្អាត មាន ភ្លៅរៀបស្រួលបួល មានអវយវៈតិះដៀលមិនបាន ឡើងកាន់ ប្រាសាទ អង្គុយតែម្នាក់ឯង បងសូមអង្វរនាង សូមយើងទាំង ពីរនាក់នៅ ( ជាមួយគ្នា ) អស់មួយយប់នេះ ។

[ ៨២៥ ] ( ព្រះរាជធីតាពោលថា ) បុរីនេះ មានគូខាន់ជាសង្កាត់ៗ មានប៉ម និងខ្លោងទ្វារយ៉ាងមាំ ( មានទាហាន ១០០០០ នាក់ ) កាន់ព្រះខ័នគ្រប់ដៃរក្សាហើយ ចូលបានដោយក្រ ។ មិនមាន ប្រុសជំទង់ ឬប្រុសកំលោះមក ( ក្នុងទីនេះទាំងថ្មើរណោះទេ ) បើ យ៉ាងនេះ តើហេតុអ្វី បានជាអ្នកចង់មកជួបនឹងខ្ញុំ ( ទាំងថ្មើរ ណោះ ) ។

[ ៨២៦ ] ( សក្កទេវរាជ ... ) ម្នាលនាងកល្យាណី យើងជា យក្ខ មកក្នុងសម្នាក់នាង ម្នាលនាងដ៏ចម្រើន នាងចូរត្រេកអរនឹង យើង យើងនឹងឲ្យភាជន៍មាស ដ៏ពេញដោយមាសដល់នាង ។

[ ៨២៧ ] ( ព្រះរាជធីតា ... ) ម្នាលទេវបុត្ត មានអានុភាព ច្រើន ខ្ញុំមិនប្រាថ្នាបុគ្គលដទៃ ទោះបីជាទេវតា យក្ខ ឬមនុស្ស លើសជាងព្រះបាទឧទយៈទេ អ្នកចូរទៅចុះ លុះអ្នកទៅហើយ កុំត្រឡប់មកវិញឡើយ ។

[ ៨២៨ ] ( សក្កទេវរាជ ... ) សេចក្ដីត្រេកត្រអាលណា ដ៏ឧត្តមរបស់ពួកសត្វ អ្នកបរិភោគកាម ពួកសត្វប្រព្រឹត្តមិនស្មើ ព្រោះហេតុនៃសេចក្ដីត្រេកត្រអាលណា នាងកុំផ្ចាញ់សេចក្ដីត្រេក-ត្រអាលនោះ ក្នុងធម្មជាតស្អាតរបស់នាង យើងនឹងឲ្យកាជន៍ប្រាក់ ដ៏ពេញដោយមាសដល់នាង ។

[ ៨២៩ ] ( ព្រះរាជធីតា ... ) បុរសកាលលួងលោមស្ត្រីដោយទ្រព្យ ធ្វើនូវសេចក្ដីពេញចិត្ត ក្នុងស្ត្រីណា ក៏លើកតម្កើងស្ត្រីនោះ ទេវធម៌របស់អ្នកខុសនឹងគេ ( ព្រោះថា ) អ្នកមកដោយវត្ថុ រឹតតែតិចដោយពិតប្រាកដ ។

[ ៨៣០ ] ( សក្កទេវរាជ ... ) ម្នាលនាងមានខ្លួនល្អ អាយុនិងវណ្ណៈរបស់ពួកមនុស្ស ក្នុងមនុស្សលោក រមែងសាបសូន្យទៅ ព្រោះហេតុនោះឯង បានជាទ្រព្យរបស់នាង ក៏សាបសូន្យដែរ នាងរឹតតែចាស់ទៅក្នុងថ្ងៃនេះ ។ ម្នាលរាជបុត្រីមានយសកាលយើងរមិលមើលយ៉ាងនេះ ពណ៌សម្បុររបស់នាង ក៏សាបសូន្យទៅ ក្នុងកាលកន្លងទៅ នៃថ្ងៃ និងយប់ទាំងឡាយ ម្នាលរាជបុត្រីមានប្រាជ្ញាល្អ នាងគប្បីប្រព្រឹត្តព្រហ្មចារ្យ ដោយវ័យនេះ នាងមុខជានឹងមានពណ៌សម្បុរដ៏ក្រៃលែង ។

[ ៨៣១ ] ( ព្រះរាជធីតា ... ) ទេវតាទាំងឡាយមិនចាស់ ដូចជាពួកមនុស្សទេ ការជ្រួញជ្រីវក្នុងខ្លួន របស់ទេវតាទាំងនោះ មិន

មានទេឬ បពិត្រយក្ខ ខ្ញុំសូមសួរលោក ដែលមានអានុភាពច្រើន រាងកាយ គឺសរីរៈរបស់ទេវតាទាំងឡាយ ( មិនចាស់ ) តើដោយហេតុអ្វី ។

[ ៨៣២ ] ( សក្កទេវរាជ ... ) ទេវតាទាំងឡាយមិនចាស់ ដូចពួកមនុស្សទេ ការជ្រួញជ្រីវក្នុងខ្លួន របស់ទេវតាទាំងនោះ មិនមានឡើយ ពណ៌សម្បុរជាទិព្វ និងភោគៈដ៏ច្រើន របស់ទេវតាទាំងឡាយនោះ រីងរឹតតែចម្រើនឡើង រាល់ៗ ថ្ងៃ ។

[ ៨៣៣ ] ( ព្រះរាជធីតា ... ) ប្រជុំជនដ៏ច្រើនក្នុងលោកនេះខ្លាចអ្វី ( ទើបមិនទៅកាន់ទេវលោក ) ម្យ៉ាងទៀត ផ្លូវ ( ទៅទេវលោក ) បណ្ឌិតសម្ដែងដោយអណ្ដូង គឺកំពង់ច្រើន ( ផ្លូវណា ជាផ្លូវទៅទេវលោក ) បពិត្រយក្ខ មានអានុភាពច្រើន ខ្ញុំសូមសួរលោក បុគ្គល ( កាលទៅ ) កាន់បរលោក តើឋិតនៅក្នុងផ្លូវណា ទើបមិនខ្លាច ។

[ ៨៣៤ ] ( សក្កទេវរាជ ... ) បុគ្គលបានតាំងវាចា និងចិត្តដោយត្រឹមត្រូវ មិនធ្វើបាបទាំងឡាយដោយកាយ នៅគ្រប់គ្រងផ្ទះ ដែលមានបាយ និងទឹកដ៏ច្រើន ជាអ្នកមានសទ្ធា មានចិត្តទន់ បានចែករំលែកនូវទាន ជាអ្នកដឹងនូវពាក្យស្លូត ជាអ្នកសង្គ្រោះគេ មានវាចាផ្អែម មានវាចាល្អិតល្អ បានឋិតនៅក្នុងគំនរនៃគុណនេះហើយ ( កាលនឹងទៅ ) កាន់បរលោក មិនខ្លាចឡើយ ។

[ ៨៣៥ ] ( ព្រះរាជធីតា ... ) បពិត្រទេវបុត្ត លោកប្រៀនប្រដៅខ្ញុំដូចជាមាតា ដូចជាបិតា បពិត្រលោកមានសម្បុរដ៏លើសលុប ខ្ញុំសូមសួរលោក មានសរីរៈសមរម្យល្អ លោកជាអ្វី ។

[ ៨៣៦ ] ( ព្រះពោធិសត្វ ... ) ម្នាលនាងកល្យាណី យើងឈ្មោះឧទយៈ បានមកក្នុងទីនេះ ដើម្បីដោះពាក្យប្តេជ្ញា យើងប្រាប់នាងហើយទៅ យើងរួចចាកពាក្យប្តេជ្ញារបស់នាងហើយ ។

[ ៨៣៧ ] ( ព្រះរាជធីតា ... ) បពិត្រព្រះរាជបុត្ត ប្រសិនបើព្រះអង្គ ព្រះនាមឧទយៈ បានមកក្នុងទីនេះ ដើម្បីប្រយោជន៍ដល់ពាក្យប្តេជ្ញា សូមព្រះអង្គប្រៀនប្រដៅខ្ញុំ ឲ្យបានជួបគ្នាទៀត ។

[ ៨៣៨ ] ( ព្រះមហាសត្វ ... ) វ័យកន្លងទៅឆាប់ ខណៈចិត្តក៏កន្លងទៅឆាប់ដូចគ្នា ការតាំងនៅ ( នៃសង្ខារទាំងឡាយ ) មិនមាន ពួកសត្វតែងច្យុតទៅដោយពិត សរីរៈមិនទៀង តែងទ្រុឌទ្រោមទៅ ម្នាលនាងឧទយភទ្ទា នាងកុំប្រមាទ ចូរប្រព្រឹត្តធម៌ចុះ ។ ផែនដីទាំងមូល របស់ស្តេចតែមួយព្រះអង្គ ដ៏ពេញដោយទ្រព្យ ជាផែនដីដែលអ្នកដទៃ ទ្រទ្រង់មិនបាន ឯបុគ្គលដែលមិនទាន់ប្រាសចាករាគៈ រមែងលះបង់នូវទ្រព្យនោះ ម្នាលនាងឧទយ-ភទ្ទា នាងកុំប្រមាទ ចូរប្រព្រឹត្តធម៌ចុះ ។

មាតា បិតា បងប្អូនប្រុស បងប្អូនស្រី និងប្រពន្ធក្តី ប្តីក្តី ព្រមទាំងទ្រព្យ ឯជនទាំងនោះ រមែងលះបង់នូវគ្នានិងគ្នា ម្នាលនាង

ឧទយភទ្ទា នាងកុំប្រមាទ ចូរប្រព្រឹត្តធម៌ចុះ ។ ម្នាលនាងឧទយ-ភទ្ទា នាងដឹងថា កាយជាចំណីនៃពួកសត្វដទៃ ដឹងថា សុគតិ និងទុគ្គតិក្នុងសង្សារ ជាលំនៅរបស់សត្វថោកទាប ដូច្នេះហើយ កុំប្រមាទ ចូរប្រព្រឹត្តធម៌ចុះ ។

[ ៨៣៩ ] ( ព្រះរាជធីតា ... ) យក្ខនេះ ពោលពីរោះណាស់ ជីវិតរបស់ពួកសត្វខ្លី លំបាកផង តិចផង ព្រោះជីវិតនោះ ប្រកប ដោយទុក្ខ ខ្ញុំនោះ នឹងលះដែនកាសី និងក្រុងសុរុន្ធនៈ បួសតែ ម្នាក់ឯង ។

## ឧទយជាតកទី ៤ ចប់

# អដ្ឋកថា

## ឧទយជាតក

[ ៨២៤-៨៣៩ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអ្នកអផ្សុក ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ឯកានិសិន្នា** ដូច្នេះជាដើម ។ រឿងនឹងមានច្បាស់ក្នុងកុសជាតកខាងមុខ ។

ព្រះសាស្តាត្រាស់សួរភិក្ខុនោះថា ម្នាលភិក្ខុ ពិតឬ ដែលអ្នកជាបុគ្គលអផ្សុក កាលភិក្ខុនោះក្រាបទូលថា ករុណាព្រះអង្គ ពិតមែន ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុ ហេតុអ្វីទើបអ្នកបព្វជ្ជាក្នុងសាសនា ដែលជាទីនាំសត្វចេញចាកទុក្ខបែបនេះ ជាអ្នកអផ្សុកដោយអំណាចកិលេស សូម្បីតែបណ្ឌិតក្នុងកាលមុន សោយរាជសម្បត្តិក្នុងសុរុន្ធនគរ ដែលមានបរិមណ្ឌល ១២ យោជន៍ដ៏មាំទាំ ទោះបីនៅរួមក្នុងបន្ទប់ជាមួយស្រី ដែលប្រៀបស្មើដោយទេពអប្សរ អស់ ៧០០ ឆ្នាំ ក៏មិនបានទម្លាយឥន្ទ្រិយ សម្លឹងមើលដោយអំណាចលោភៈឡើយ ដូច្នេះហើយ ទើបទ្រង់នាំអតីតនិទានមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទកាសីសោយរាជសម្បត្តិក្នុងសុរុន្ធនគរ ដែនកាសី ទ្រង់មិនធ្លាប់មានព្រះឱរស ឬព្រះរាជធីតាឡើយ ។ ទ្រង់ត្រាស់នឹងព្រះទេវីទាំងឡាយរបស់ទ្រង់ថា ចូរពួកនាងនាំគ្នាប្រាថ្នាបុត្រចុះ ។ ព្រះរាជទេវីទទួលព្រះរាជតម្រាស់ហើយ បានធ្វើដូច្នោះ ។ កាលនោះ ព្រះពោធិសត្វចុតិអំពីព្រហ្មលោក បដិសន្ធិក្នុងឧទរនៃព្រះអគ្គមហេសីរបស់ព្រះរាជា ។ គ្រានោះ ព្រះញាតិទាំងឡាយ ថ្វាយព្រះនាមព្រះរាជកុមារនោះថា **ឧទយភទ្ទ** ព្រោះទ្រង់កើតឡើង ធ្វើឲ្យហទយៈរបស់មហាជនចម្រើន ។ ក្នុងកាលដែល

*ព្រះរាជកុមារទ្រង់យាងទៅដោយព្រះបាទបាន សត្វដទៃចុតិអំពីព្រហ្មលោក កើតជាកុមារិកាក្នុងព្រះឧទររបស់ព្រះទេវីអគ្គណាមួយ របស់ព្រះរាជាអង្គនោះឯង ។ ពួកញាតិទ្រង់ថ្វាយព្រះនាមព្រះរាជកុមារីនោះថា* **ឧទយភទ្ទា** ។ *កុមារទ្រង់ចម្រើនវ័យ ចប់ការសិក្សាសិល្បសាស្ត្រទាំងអស់ តែទ្រង់ជាព្រហ្មចារីដោយកំណើត ទ្រង់មិនជ្រាបរឿងមេថុនធម្ម សូម្បីដោយការយល់សប្តិ ។ ព្រះហឫទ័យរបស់ទ្រង់មិនបានពាក់ព័ន្ធក្នុងកិលេសទាំងឡាយឡើយ ។ ព្រះរាជាទ្រង់បំណងនឹងអភិសេកព្រះរាជឱរស ទ្រង់បញ្ជូនដំណឹងទៅថា នែបុត្រឥឡូវនេះ ជាកាលសោយនូវសេចក្តីសុខក្នុងរាជសម្បត្តិរបស់កូន បិតានឹងឲ្យរាជសម្បត្តិទាំងអស់ដល់កូន ព្រះពោធិសត្វឃាត់ថា ទូលបង្គំមិនត្រូវការដោយរាជសម្បត្តិឡើយ ចិត្តរបស់ទូលបង្គំ មិនបានពាក់ព័ន្ធក្នុងគំនរកិលេសឡើយ កាលបានទទួលព្រះរាជតម្រាស់ជាស់តឿនរឿយៗ ទើបឲ្យជាងធ្វើរូបស្ត្រី សម្រេចដោយមាសជម្ពូនទៈ ហើយទ្រង់បញ្ជូនដំណឹងដល់ព្រះបិតា និងព្រះរាជមាតាថា បើទ្រង់រកបានស្រីស្អាតបែបនេះសោត ទូលបង្គំព្រមទទួលរាជសម្បត្តិ ។ ព្រះរាជបិតា និងព្រះរាជមាតាឲ្យអមាត្យនាំយករូបមាសនោះដង្ហែទៅពេញជម្ពូទ្វីប កាលមិនបានស្រីស្អាតបែបនោះ ទើបតាក់តែងព្រះនាងឧទយភទ្ទា ឲ្យប្រថាប់នៅក្នុងវាំងរបស់ព្រះរាជកុមារនោះ ។ ព្រះនាងទ្រង់ស្អាតជាងរូបមាសនោះទៅទៀត ។ កាលនោះ ព្រះរាជបិតា និងព្រះរាជមាតាទ្រង់អភិសេកព្រះពោធិសត្វ ទ្រង់ធ្វើព្រះនាងដែលមានមាតាដទៃ ព្រះនាមឧទយភទ្ទារាជកុមារី ឲ្យជាព្រះអគ្គមហេសី ទាំងដែលព្រះរាជកុមារ និងព្រះ*

រាជកុមារីទាំងពីររបស់ទ្រង់មិនប្រាថ្នាឡើយ ។ តែទាំងពីរអង្គនោះ ក៏ទ្រង់ប្រថាប់នៅដោយការនៅដូចប្រព្រឹត្តព្រហ្មចរិយៈនោះឯង ។ ក្នុងកាលតមកព្រះរាជបិតា និងព្រះរាជមាតាសោយទិវង្គតទៅ ព្រះពោធិសត្វ ក៏គ្រប់គ្រងរាជសម្បត្តិ ។ ក្សត្រទាំងពីរ ប្រថាប់រួមបន្ទប់ជាមួយគ្នា ក៏មិនបានទម្លាយឥន្ទ្រិយ ទតមើលគ្នាដោយអំណាចលោភៈឡើយ តែទ្រង់ធ្វើកតិកាគ្នាថា យើងទាំងពីរ អ្នកណាអស់ព្រះជន្មទៅមុន អ្នកនុ៎ះត្រូវមកអំពីទីដែលខ្លួនកើតហើយមកប្រាប់ថា ខ្ញុំកើតក្នុងទីឈ្មោះនោះ ដូច្នេះ ។ លុះកន្លងទៅបាន ៧០០ ឆ្នាំរាប់តាំងអំពីពេលអភិសេក ព្រះពោធិសត្វក៏សោយទិវង្គត ។ អ្នកដទៃដែលជាព្រះរាជា មិនមានឡើយ ព្រះនាងឧទយភទ្ទាមួយអង្គឯង ទ្រង់សម្រេចរាជការជំនួស ពួកអមាត្យប្រឹក្សាគ្រប់គ្រងរាជសម្បត្តិ ចំណែកព្រះពោធិសត្វក្នុងខណៈដែលទ្រង់ចុតិ ទ្រង់កើតជាសក្កៈ ក្នុងតាវត្តិង្សពិភព ព្រោះទ្រង់មានយសធំ មិនអាចទ្រង់អនុស្សរណៈ គឺរឭកមិនបាន អស់ ៧ ថ្ងៃ ។ ដូច្នោះជាពេលដែលកន្លងទៅអស់ ៧០០ ឆ្នាំ ដោយការរាប់ឆ្នាំរបស់មនុស្ស ទើបទ្រង់រឭកបាន ទើបព្រះតម្រិះថា អញនឹងពិសោធព្រះធីតាឧទយភទ្ទាដោយទ្រព្យ ហើយបន្លឺសីហនាទសម្តែងធម៌ ដោះនូវការបដិញ្ញាហើយ ទើបមក ។ បានឮថា ក្នុងកាលនោះ ជាកាលដែលមនុស្សមានអាយុ ១ ម៉ឺនឆ្នាំ យប់នោះឯងព្រះរាជធីតាមួយអង្គប៉ុណ្ណោះ ប្រថាប់គង់មិនកម្រើក ព្រះនាងនឹកដល់សីលរបស់ព្រះនាងក្នុងបន្ទប់ដែលមានសិរីដ៏ឧត្តម ក្នុងផ្ទៃប្រាសាទជាន់លើនៃប្រាសាទ ៧ ជាន់ ក្នុងកាលរាជបុរសបិទទ្វារហើយ ទ្រង់ដាក់ព្រះកាយរៀបរយ

ហើយ ។ កាលនោះ សក្កទេវរាជ កាន់យកថាសមាសមួយ ដាក់ហិរញ្ញមាសក និងមាសរហូតពេញ ប្រាកដព្រះកាយក្នុងបន្ទប់ផ្ទំនោះឯង ប្រថាប់គង់ក្នុងចំណែកម្ខាង ។ កាលព្រះពោធិសត្វ ត្រាស់ប្រាស្រ័យជាមួយព្រះនាង ទើបត្រាស់ព្រះគាថាទី ១ ថា

ម្នាលនាង មានចក្ខុប្រាកដស្មើដោយភ្នែកនៃកិន្នរ នាងស្លៀកសំពត់ដ៏ស្អាត មានភ្លៅរៀបស្រួលបួល មានអវយវៈតិះដៀលមិនបាន ឡើងកាន់ប្រាសាទ អង្គុយតែម្នាក់ឯង បងសូមអង្វរនាង សូមយើងទាំងពីរនាក់នៅ ( ជាមួយគ្នា ) អស់មួយយប់នេះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សុចិ** បានដល់ ទ្រទ្រង់នូវសំពត់ដ៏ស្អាត ។ បទថា **សញ្ញតូរុ** អធិប្បាយថា ភ្លៅទាំងពីរខាង ប្រតិស្ឋាននៅដោយល្អ ព្រះនាងរៀបចំឥរិយាបទយ៉ាងល្អ ទ្រទ្រង់នូវព្រះភូសាដ៏ស្អាត ប្រថាប់គង់ត្រឹមតែមួយព្រះអង្គឯង ។ បទថា **អនិន្ទិតង្គី** សេចក្ដីថា ព្រះនាងមានព្រះវរកាយតិះដៀលមិនបាន តាំងអំពីចុងព្រះបាទ រហូតដល់ចុងព្រះកេសា គឺមានព្រះសរីរៈដ៏ល្អត្រកាល ។ បទថា **កិន្នរនេត្តចក្ខុ** សេចក្ដីថា ព្រះនាងទ្រង់មានព្រះនេត្រទាំងគូ ប្រៀបបាននឹងភ្នែកកិន្នរ ព្រោះស្អាតដោយមណ្ឌលទាំង ៣ និងបសាទទាំង ៥ ។ បទថា **ឥមេករត្តិំ** សេចក្ដីថា សក្កទេវរាជអង្វរថា ខ្ញុំសូមនៅរួមក្នុងបន្ទប់ផ្ទំដែលប្រដាប់តាក់តែងនេះ អស់រាត្រីមួយនេះ គឺយប់នេះ ។

លំដាប់នោះ ព្រះនាងបានត្រាស់ ២ គាថា ដោយសេចក្ដីថា

បុរីនេះ មានគូខាន់ជាសង្កាត់ៗ មានប៉ម និងខ្លោងទ្វារយ៉ាងមាំ ( មានទាហាន ១០០០០ នាក់ ) កាន់ព្រះខ័នគ្រប់ដៃរក្សាហើយ ចូលបានដោយក្រ ។ មិនមានប្រុសជំទង់ ឬប្រុសកំលោះមក ( ក្នុងទីនេះ ទាំងថ្មើរណោះទេ ) បើយ៉ាងនេះ តើហេតុអ្វី បានជាអ្នកចង់មកជួបនឹងខ្ញុំ ( ទាំងថ្មើរណោះ ) ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ខុំកិណ្ណាន្តរបរិក្ខំ** សេចក្ដីថា បុរីដែលមានឈ្មោះថាសុរុន្ធនៈនេះមានបរិវេណ ១២ យោជន៍ មានគូទឹកព័ទ្ធជុំវិញខាន់ជាចន្លោះៗ ព្រោះមានគូរៀងគ្នាជាលំដាប់ៗ គឺគូទឹក គូភក់ និងគូស្ងួត ។ បទថា **ទឡ្ហមដ្ដាលកោដ្ឋកំ** សេចក្ដីថា ប្រកបដោយប៉ម និងខ្លោងទ្វារយ៉ាងរឹងមាំ ។ បទថា **ខគ្គហត្ថេហិ** សេចក្ដីថា មានទាហាន ១ ម៉ឺន សុទ្ធតែកាន់អាវុធឈរយាមដ៏ក្រាស់ក្រែល ។ បទថា **ទុប្បវេសមិទំ បុរំ** សេចក្ដីថា បុរីទាំងមូលក្ដី ព្រះរាជវាំងដែលជាលំនៅរបស់ខ្ញុំ ដែលសាងក្នុងបុរីនោះក្ដី ទាំងពីរកន្លែង បុគ្គលណាម្នាក់មិនអាចនឹងចូលទៅបាន ។ បទថា **អាគមោ ច** សេចក្ដីថា មួយវិញទៀត ក្នុងនគរនេះ ក្នុងពេលនេះ ឈ្មោះថា ការមកដល់របស់បុគ្គលដែលសម្បូរដោយកម្លាំង ដែលជាជំទង់ ឬកំលោះ ឬរបស់អ្នកដទៃ ដែលបង្អោននាំបណ្ណាការជាច្រើនមក ក៏មិនមាន ។ បទថា **សង្គមំ** សេចក្ដីថា កាលបើដូច្នោះ អ្នកលបលួចចូលមកជួបខ្ញុំបានក្នុងពេលនេះ បានដោយហេតុដូចម្ដេច ។ លំដាប់នោះ សក្កទេវរាជក៏ត្រាស់គាថាទី ៤ ថា

ម្នាលនាងកល្យាណី យើងជាយក្ខ មកក្នុងសម្នាក់នាង ម្នាល

នាងដ៏ចម្រើន នាងចូរត្រេកអរនឹងយើង យើងនឹងឲ្យភាជន៍មាស
ដ៏ពេញដោយមាសដល់នាង ដូច្នេះ ។

ពាក្យដែលជាគាថានោះ មានអធិប្បាយថា នែនាងកល្យាណី គឺមើលត្រង់ណាក៏ល្អព្រម ខ្ញុំជាទេវបុត្រមួយអង្គ មកដល់ព្រះដំណាក់នេះបានដោយទេវានុភាព ថ្ងៃនេះ សូមព្រះនាងត្រេកអរជាមួយខ្ញុំចុះ ខ្ញុំនឹងថ្វាយថាសមាសដែលពេញដោយមាសកមាសនេះដល់ព្រះនាង ។ ព្រះរាជធីតាស្តាប់ដូច្នោះហើយ ទើបត្រាស់គាថាទី ៥ ថា

ម្នាលទេវបុត្ត មានអានុភាពច្រើន ខ្ញុំមិនប្រាថ្នាបុគ្គលដទៃ ទោះបី
ជាទេវតា យក្ខ ឬមនុស្ស លើសជាងព្រះបាទឧទយៈទេ អ្នក
ចូរទៅចុះ លុះអ្នកទៅហើយ កុំត្រឡប់មកវិញឡើយ ដូច្នេះ ។

ពាក្យដែលជាគាថានោះ មានអធិប្បាយថា នែទេវរាជ ក្រៅអំពីព្រះបាទឧទយៈហើយ ខ្ញុំមិនត្រូវការប្រុសដទៃទោះជាទេវតា យក្ខ ឬមនុស្សឡើយ សូមអ្នកទៅចុះ កុំនៅក្នុងទីនេះឡើយ ខ្ញុំមិនត្រូវការបណ្ណាការដែលនាំមកឡើយ កាលអ្នកទៅហើយ កុំត្រឡប់មកទៀត ។

សក្កទេវរាជ ទ្រង់ស្តាប់សីហនាទរបស់ព្រះនាងហើយ ធ្វើអាកប្បកិរិយាមិននៅ ហើយទៅ ក៏បាត់ត្រង់ទីនោះឯង ។ ស្អែកឡើង ក្នុងពេលនោះឯង សក្កទេវរាជកាន់យកថាសប្រាក់ពេញដោយមាសកមាសមក កាលទ្រង់សន្ទនាជាមួយព្រះនាង ទើបត្រាស់គាថាទី ៦ ថា

សេចក្តីត្រេកត្រអាលណា ដ៏ឧត្តមរបស់ពួកសត្វ អ្នកបរិភោគ

កាម ពួកសត្វប្រព្រឹត្តមិនស្មើ ព្រោះហេតុនៃសេចក្តីត្រេកត្រអាលណា នាងកុំផ្ចាញ់សេចក្តីត្រេកត្រអាលនោះ ក្នុងធម្មជាតិស្អាតរបស់នាង យើងនឹងឲ្យភាជន៍ប្រាក់ ដ៏ពេញដោយមាសដល់នាងដូច្នេះ ។

ពាក្យដែលជាគាថានោះ មានអធិប្បាយថា បពិត្ររាជធីតា បណ្តាសេចក្តីត្រេកអររបស់ពួកសត្វអ្នកបរិភោគកាម ឈ្មោះថា សេចក្តីត្រេកអរក្នុងកាម គឺមេថុន ជារបស់ឧត្តមបំផុត សេចក្តីត្រេកអរដ៏ឧត្តមនេះ ព្រោះហេតុនៃសេចក្តីត្រេកអរណា ទើបពួកសត្វនាំគ្នាប្រព្រឹត្តធម៌ខុស មានកាយទុច្ចរិតជាដើម បពិត្រព្រះនាង សូមព្រះនាងកុំធ្វើសេចក្តីត្រេកអរនោះឲ្យវិនាសទៅក្នុងផ្លូវដែលស្អាតរបស់ព្រះនាងឡើយ គឺព្រោះការពេញចិត្តត្រេកអររបស់ព្រះនាងឡើយ ។ កាលខ្ញុំមក ក៏មិនមែនដៃទទេ ម្សិលមិញនាំថាសមាសដែលពេញដោយមាសកមាសមក ថ្ងៃនេះ ក៏នាំថាសប្រាក់ដែលពេញដោយមាសកមាសមក ខ្ញុំសូមថ្វាយថាសប្រាក់ ដែលពេញដោយមាសកមាសនេះដល់ព្រះនាង ។

ព្រះរាជធីតា ទ្រង់ព្រះតម្រិះថា ទេវបុត្រនេះ កាលបាននូវការសន្ទនាប្រាស្រ័យគ្នាគង់មករឿយៗ ពេលនេះ អញនឹងមិនពោលជាមួយទេវបុត្រនេះឡើយ ព្រះនាងមិនបានត្រាស់ពាក្យណាមួយឡើយ ។ សក្កទេវរាជទ្រង់ជ្រាបភាពដែលព្រះនាងមិនត្រាស់ ក៏បាត់ទៅក្នុងទីនោះឯង ។ ស្អែកឡើង លុះដល់ពេលនោះ ក៏កាន់យកថាសលោហៈ ពេញដោយកហាបណៈមក ត្រាស់

ថា ព្រះនាងដ៏ចម្រើន ព្រះនាងត្រាប្រណីខ្ញុំដោយការត្រេកអរក្នុងកាមចុះ ខ្ញុំនឹងថ្វាយថាសលោហៈដែលពេញដោយកហាបណៈដល់ព្រះនាង ថ្ងៃនោះ ព្រះរាជធីតាបានត្រាស់គាថាទី ៧ ថា

បុរស កាលលួងលោមស្ត្រីដោយទ្រព្យ ធ្វើនូវសេចក្តីពេញចិត្ត
ក្នុងស្ត្រីណា ក៏លើកតម្កើងស្ត្រីនោះ ទេវធម៌របស់អ្នកខុសនឹងគេ
( ព្រោះថា ) អ្នកមកដោយវត្ថុ រឹតតែតិចដោយពិតប្រាកដ
ដូច្នេះ ។

ពាក្យដែលជាគាថានោះ មានអធិប្បាយថា នែបុរស អ្នកឯងជាមនុស្សល្ងង់ខ្លៅ ធម្មតាបុរសបំណងនឹងឲ្យស្ត្រីទន់ចិត្ត លួងលោមដោយទ្រព្យព្រោះហេតុនៃសេចក្តីត្រេកអរ ដោយអំណាចកិលេស រមែងប្រមូលពណ៌នាសរសើរលួងលោមដោយទ្រព្យដែលច្រើនជាង រហូតដល់នាងពេញចិត្ត តែទេវសភាវៈនេះរបស់អ្នកផ្ទុយអំពីគេ ព្រោះអ្នកនាំទ្រព្យមកបន្ថយតិចទៅរឿយៗ ដូចប្រាប់ដល់ខ្ញុំ គឺថ្ងៃមុននាំថាសមាស ពេញដោយកហាបណៈមាសមកថ្ងៃទី ២ នាំថាសប្រាក់ពេញដោយកហាបណៈមាស ថ្ងៃទី ៣ នាំថាសលោហៈពេញដោយកហាបណៈមក ។

សក្កទេវរាជទ្រង់បានស្តាប់ដូច្នោះហើយ ទើបត្រាស់ថា បពិត្រព្រះរាជ-កុមារីដ៏ចម្រើន ខ្ញុំជាឈ្មួញឈ្លាស រមែងមិនញុំាងប្រយោជន៍ឲ្យវិនាសដោយឥតប្រយោជន៍ បើព្រះនាងចម្រើនដោយព្រះជន្មាយុ ឬដោយព្រះឆវីវណ្ណសោភាខ្ញុំក៏គប្បីនាំបណ្ណាការបន្ថែមឡើងដល់ព្រះនាង តែព្រះនាង មានតែអស់ទៅ

( ចាស់ទៅ ) តែម្យ៉ាង ហេតុនោះ ខ្ញុំត្រូវបន្ថយចំនួនទ្រព្យដូច្នេះឯង ហើយទ្រង់ភាសិត ៣ គាថាថា

ម្នាលនាងមានខ្លួនល្អ អាយុ និងវណ្ណៈរបស់ពួកមនុស្ស ក្នុងមនុស្សលោក រមែងសាបសូន្យទៅ ព្រោះហេតុនោះឯង បានជាទ្រព្យរបស់នាង ក៏សាបសូន្យដែរ នាងរឹតតែចាស់ទៅក្នុងថ្ងៃនេះ ។ ម្នាលរាជបុត្រីមានយស កាលយើងរមិលមើលយ៉ាងនេះ ពណ៌សម្បុររបស់នាង ក៏សាបសូន្យទៅ ក្នុងកាលកន្លងទៅនៃថ្ងៃ និងយប់ទាំងឡាយ ម្នាលរាជបុត្រីមានប្រាជ្ញាល្អ នាងគប្បីប្រព្រឹត្តព្រហ្មចារ្យ ដោយវ័យនេះ នាងមុខជានឹងមានពណ៌សម្បុរដ៏ក្រៃលែង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឆិយ្យតិ** សេចក្តីថា អាយុ និងវណ្ណៈរបស់ពួកមនុស្ស រមែងវិនាសថមថយទៅ ដូចទឹកដែលស្រក់ចុះអំពីធម្មក្រកមែនពិត ជីវិត ពណ៌សម្បុរ បសាទចក្ខុជាដើមរបស់ពួកសត្វក្នុងមនុស្ស-លោក រមែងសាបសូន្យរាល់ៗ ថ្ងៃ ។ បទថា **ឩណ្ហាតរាសិ** សេចក្តីថា ព្រះជន្មាយុរបស់ព្រះនាង ដែលប្រព្រឹត្តទៅក្នុងថ្ងៃដំបូង មិនមកដល់អាយុម្សិលមិញ ព្រះជន្មាយុដែលប្រព្រឹត្តទៅក្នុងថ្ងៃដែលខ្ញុំមកដំបូង រលត់ទៅក្នុងថ្ងៃនោះឯង ដូចត្រូវកាប់ដោយចប សូម្បីព្រះជន្មាយុដែលប្រព្រឹត្តទៅហើយក្នុងថ្ងៃម្សិលមិញ ក៏មិនមកដល់ថ្ងៃនេះ គង់រលត់ទៅក្នុងថ្ងៃម្សិលមិញនោះឯង ដូចត្រូវកាប់ដោយចបក្នុងថ្ងៃម្សិលមិញនោះឯង ព្រោះហេតុនោះ ក្នុងថ្ងៃនេះ ព្រះ

នាង រមែងជរាជាងដែលធ្លាប់ឃើញក្នុងថ្ងៃម្សិលមិញ ។ បទថា **ឃរំ មេ** សេចក្ដីថា កាលខ្ញុំឃើញក្នុងថ្ងៃម្សិលមិញ សម្លឹងមើលក្នុងថ្ងៃនេះ ព្រះឆវីវណ្ណសាបសូន្យទៅជាងថ្ងៃមុនៗ ។ បទថា **អហោរត្តានមច្ចយេ** នេះ សម្ដែងថា ចាប់ពីឥឡូវនេះទៅ កាលយប់ និងថ្ងៃកន្លងទៅ ព្រោះកន្លងទៅច្រើនថ្ងៃ ច្រើនយប់ ព្រះឆវីវណ្ណនឹងត្រូវជាការៈមិនមានបញ្ញត្តិបាននោះឯង ។ បទថា **ឥមិនាវ** សេចក្ដីថា បពិត្រព្រះនាង ហេតុនោះ បើព្រះនាងប្រព្រឹត្តព្រហ្មចរិយៈ គឺបួសបំពេញសមណធម៌ ដោយថ្ងៃនេះនុ៎ះឯង គឺក្នុងកាលព្រះសរីរៈ ដែលមានវណ្ណៈដូចមាស នឹងមិនត្រូវជរាបៀនទៅជាមុន ។ បទថា **ភិយ្យោ វណ្ណវតី សិយា** សេចក្ដីថា ព្រះនាង គប្បីមានព្រះឆវីវណ្ណក្រៃលែងៗ ឡើងចុះ ។

លំដាប់នោះ ព្រះរាជធីតាត្រាស់គាថាបន្ដថា

ទេវតាទាំងឡាយមិនចាស់ ដូចជាពួកមនុស្សទេ ការជ្រួញជ្រីវ
ក្នុងខ្លួនរបស់ទេវតាទាំងនោះមិនមានទេឬ បពិត្រយក្ខ ខ្ញុំសូមសួរ
លោក ដែលមានអានុភាពច្រើន រាងកាយ គឺសរីរៈរបស់ទេវតា
ទាំងឡាយ ( មិនចាស់ ) តើដោយហេតុអ្វី ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សរីរទេហោ** សេចក្ដីថា រាងកាយ គឺសរីរៈ ព្រះរាជធីតាត្រាស់ថា សរីរៈរបស់ទេវតា រមែងមិនចាស់ជរា បានដូចម្ដេច ខ្ញុំសូមសួរលោកក្នុងសេចក្ដីនេះ ។

លំដាប់នោះ សក្កទេវរាជ កាលត្រាស់ប្រាប់ដល់ព្រះនាង ទើបត្រាស់ព្រះគាថាតទៅ

ទេវតាទាំងឡាយមិនចាស់ ដូចពួកមនុស្សទេ ការជ្រួញជ្រីវក្នុងខ្លួនរបស់ទេវតាទាំងនោះ មិនមានឡើយ ពណ៌សម្បុរជាទិព្វ និងភោគៈដ៏ច្រើន របស់ទេវតាទាំងឡាយនោះ រឹងរឹតតែចម្រើនឡើងរាល់ៗ ថ្ងៃ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យថា មនុស្សា** សេចក្ដីថា ពួកមនុស្សនាំគ្នាចាស់ជរា សាបសូន្យដោយរូប ដោយពណ៌សម្បុរ ដោយភោគៈ ដោយបសាទ មានចក្ខុបសាទជាដើមយ៉ាងណា ទេវតាមិនដូច្នោះឡើយ ព្រោះថា ក្នុងខ្លួនរបស់ទេវតាទាំងនោះ សូម្បីតែសរសៃក៏មិនមានឡើយ ទើបសរីរៈមានពណ៌ដូចមាស គឺរលោងតែម្យ៉ាង ។ បទថា **សុវេ សុវេ** គឺរាល់ៗ ថ្ងៃ ។ បទថា **ភិយ្យតរោវ** សេចក្ដីថា ពណ៌សម្បុរដែលជាទិព្វ និងភោគៈទាំងឡាយរបស់ទេវតាទាំងនោះរឹងរឹតតែចម្រើន និងបរិបូណ៌ឡើងតែម្យ៉ាង ។ មែនពិត ក្នុងពួកមនុស្ស ការវិនាសថមថយនៃរូបជាប្រចក្សថា កើតមកហើយយូរ ក្នុងពួកទេវតា រូបសម្បត្តិរឹងរឹតតែក្រៃលែងឡើង បរិវារសម្បត្តិក៏ច្រើនឡើង ជាសាក្សីបញ្ជាក់ថាកើតមកយូរ ។ ទេវលោកនោះបានឈ្មោះថា មានការមិនសាបសូន្យជាធម្មតាដោយប្រការដូច្នេះ ហេតុនោះ ទើបព្រះនាងមិនទាន់ដល់នូវភាពជរានោះឯង ចូរចេញបួសចុះ កាលចុតិអំពីមនុស្សលោក ដែលមានតែការវិនាសថមថយជាសភាវៈបែបនេះហើយ នឹងយាងទៅកាន់ទេវលោក ដែលមានតែវត្ថុដែលមិនសាបសូន្យជាសភាវៈបែបនេះ ។ ព្រះនាងបានស្ដាប់ព្រះតម្រាស់ពណ៌នាដល់ទេវលោកដូច្នេះហើយ កាលនឹងត្រាស់សួរដល់ផ្លូវទៅកាន់ទេវលោក

នោះ ទើបត្រាស់ព្រះគាថាតទៅ

ប្រជុំជនដ៏ច្រើនក្នុងលោកនេះ ខ្លាចអ្វី ( ទើបមិនទៅកាន់ទេវ-លោក ) ម្យ៉ាងទៀត ផ្លូវ ( ទៅទេវលោក ) បណ្ឌិតសម្ដែងដោយអណ្ដូង គឺកំពង់ច្រើន ( ផ្លូវណា ជាផ្លូវទៅទេវលោក ) បពិត្រយក្ខ មានអានុភាពច្រើន ខ្ញុំសូមសួរលោក បុគ្គល ( កាលទៅ ) កាន់បរលោក តើឋិតនៅក្នុងផ្លូវណា ទើបមិនខ្លាចដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កឹសូធ ភីតា** នេះ ព្រះរាជធីតាត្រាស់សួរថា បពិត្រទេវរាជ ខ្ញុំសូមសួរអ្នក ពួកជនមានក្សត្រជាដើមនេះ មិនមែនតិចតួចឡើយនាំគ្នាពោលអ្វី គឺព្រោះសេចក្ដីខ្លាចអ្វី ទើបមិននាំគ្នាទៅកាន់ទេវលោកអំពីមនុស្សលោក ដែលមានតែវត្ថុ ដែលគប្បីថមថយជាសភាវៈ ។ បទថា **មគ្គោ** បានដល់ ផ្លូវដែលទៅកាន់ទេវលោក ។ ក្នុងសេចក្ដីនេះ កាលសួរថា ខ្លាចអ្វី ហើយគួរតាំងសំណួរតទៅថា ផ្លូវណា ។ ក្នុងទីនេះ លោកពោលអត្ថនេះថា ផ្លូវទៅកាន់ទេវលោក ដែលបណ្ឌិតទាំងឡាយពោលចែក ដោយអំណាចតាំងជាលទ្ធិដ៏ច្រើន ជាផ្លូវណា គឺជាផ្លូវណា ។ បទថា **កត្ថ ឋិតោ** សេចក្ដីថា បុគ្គលទោះទៅកាន់បរលោក តាំងនៅក្នុងផ្លូវណា ទើបមិនតក់ស្លុត ។

លំដាប់នោះ កាលសក្កទេវរាជត្រាស់ប្រាប់ដល់នាង ទើបពោលគាថាតទៅ

បុគ្គលបានតាំងវាចា និងចិត្ត ដោយត្រឹមត្រូវ មិនធ្វើបាបទាំង
ឡាយ ដោយកាយ នៅគ្រប់គ្រងផ្ទះ ដែលមានបាយ និងទឹកដ៏
ច្រើន ជាអ្នកមានសទ្ធា មានចិត្តទន់ បានចែករំលែកនូវទាន ជា
អ្នកដឹងនូវពាក្យស្លូត ជាអ្នកសង្គ្រោះគេ មានវាចាផ្អែម មានវាចា
ល្អិតល្អ បានឋិតនៅក្នុងគំនរនៃគុណនេះហើយ ( កាលទីងទៅ )
កាន់បរលោក មិនខ្លាចឡើយ ដូច្នេះ ។

ពាក្យដែលជាគាថានោះ មានអធិប្បាយដូចតទៅនេះថា បពិត្រព្រះនាង បុគ្គលណាតាំងវាចា និងចិត្តដោយប្រពៃ មិនធ្វើបាបដោយកាយ សមាទានកុសលកម្មបថ ១០ ប្រការ ហើយប្រព្រឹត្ត កាលនៅគ្រប់គ្រងផ្ទះ ដែលមានបាយ និងទឹកច្រើន គឺមានទេយ្យធម៌ច្រើន ប្រកបដោយការជឿមាំថា វិបាកនៃទានមាន ដូច្នេះហើយ មានចិត្តទន់ភ្លន់ បានឈ្មោះថា **សំវិភាគី** ព្រោះការចែកទាន បានឈ្មោះថា **វទញ្ញូ** ព្រោះជ្រាបដល់នូវការឲ្យបច្ច័យដល់ពួកបព្វជិត ដែលត្រាច់ទៅដើម្បីកិច្ចា និងព្រោះជ្រាបវាទៈនេះ ឈ្មោះថា **សង្គហាកោ** ព្រោះសង្គ្រោះដោយសង្គហវត្ថុ ៤ ឈ្មោះថា **សខិលោ** ព្រោះជាអ្នកពោលតែវាចាជាទីស្រឡាញ់ ឈ្មោះថា **សណ្ហវាចោ** ព្រោះពោលវាចាដែលជាប្រយោជន៍ បុគ្គលនោះតាំងនៅក្នុងគំនរនៃគុណធម៌នេះ គឺមានប្រមាណប៉ុណ្ណេះ កាលទៅកាន់បរលោកក៏មិនតក់ស្លុតឡើយ ។ លំដាប់នោះ ព្រះរាជធីតាបានស្តាប់ពាក្យរបស់សក្កៈហើយ កាលព្រះនាងធ្វើនូវការសរសើរ ទើបពោលគាថាបន្តថា

បពិត្រទេវបុត្ត លោកប្រៀនប្រដៅខ្ញុំ ដូចជាមាតា ដូចជាបិតា បពិត្រលោកមានសម្បុរដ៏លើសលុប ខ្ញុំសូមសួរលោកមានសរីរៈសមរម្យល្អ លោកជាអ្វី ដូច្នេះ ។

ពាក្យដែលជាគាថានោះ មានអធិប្បាយថា មាតាបិតា ទូន្មានបុត្រតូចយ៉ាងណា អ្នកក៏ប្រៀនប្រដៅខ្ញុំយ៉ាងនោះ ។ បពិត្រអ្នកមានពណ៌សម្បុរល្អក្រៃលែង គឺជាអ្នកទ្រទ្រង់នូវរូប ដែលដល់នូវភាពជាបុគ្គលស្អាត តើអ្នកជានរណា ទើបមានរាងកាយស្អាតយ៉ាងនេះ ។

លំដាប់នោះ ព្រះពោធិសត្វក៏ត្រាស់ព្រះគាថាជាបន្ត

ម្នាលនាងកល្យាណី យើងឈ្មោះឧទយៈ បានមកក្នុងទីនេះ ដើម្បីដោះពាក្យប្តេជ្ញា យើងប្រាប់នាងហើយទៅ យើងរួចចាកពាក្យប្តេជ្ញារបស់នាងហើយ ដូច្នេះ ។

ពាក្យដែលជាគាថានោះ មានអធិប្បាយដូចតទៅនេះថា នែនាងមានរូបស្អាត គួរពិតពិលរមិលមើល ក្នុងភពមុនខ្ញុំជាប្តីរបស់នាង ឈ្មោះឧទយៈកើតជាសក្កទេវរាជក្នុងតាវត្តិង្សពិភព មកក្នុងទីនេះ មិនមែនមកដោយអំណាចកិលេស តែគិតថា មកសាកល្បងមើល ហើយនឹងដោះនូវប្តេជ្ញា ជាការមកតាមសន្យា គឺមកតាមការណាត់គ្នាក្នុងកាលមុន ឥឡូវនេះ ខ្ញុំបានប្រាប់នាងហើយ នឹងសូមលាទៅ ខ្ញុំផុតចាកការប្តេជ្ញារបស់នាងហើយ ។

ព្រះរាជធីតា ត្រេកអរក្នុងព្រះរាជហឫទ័យ ទ្រង់មានព្រះរាជសុវនីយ៍ថា ព្រះអង្គ គឺព្រះបាទឧទយកទូដូច្នេះបណ្តើរ ក៏មានខ្សែព្រះអស្សុជលធាហូរ

មក ត្រាស់ថា ខ្ញុំមិនអាចនៅឆ្ងាយអំពីទ្រង់បាន សូមទ្រង់ទូន្មានខ្ញុំ តាមដែលខ្ញុំនៅជិតទ្រង់បានចុះ ដូច្នេះហើយ ទើបត្រាស់ព្រះគាថាបន្ត

បពិត្រព្រះរាជបុត្ត ប្រសិនបើ ព្រះអង្គព្រះនាមឧទយៈ បានមកក្នុងទីនេះ ដើម្បីប្រយោជន៍ដល់ពាក្យប្តេជ្ញា សូមព្រះអង្គប្រៀនប្រដៅខ្ញុំ ឲ្យបានជួបគ្នាទៀត ដូច្នេះ ។

លំដាប់នោះ កាលព្រះមហាសត្វ ទ្រង់ទូន្មានព្រះនាង ទើបបានត្រាស់ ៤ គាថាថា

វ័យកន្លងទៅឆាប់ ខណៈចិត្ត ក៏កន្លងទៅឆាប់ដូចគ្នា ការតាំងនៅ ( នៃសង្ខារទាំងឡាយ ) មិនមាន ពួកសត្វតែងច្យុតទៅដោយពិត សរីរៈមិនទៀង តែងទ្រុឌទ្រោមទៅ ម្នាលនាងឧទយភទ្ទា នាងកុំប្រមាទ ចូរប្រព្រឹត្តធម៌ចុះ ។ ផែនដីទាំងមូល របស់ស្តេចតែមួយព្រះអង្គ ដ៏ពេញដោយទ្រព្យ ជាផែនដីដែលអ្នកដទៃទ្រទ្រង់មិនបាន ឯបុគ្គលដែលមិនទាន់ប្រាសចាករាគៈ រមែងលះបង់នូវទ្រព្យនោះ ម្នាលនាងឧទយភទ្ទា នាងកុំប្រមាទ ចូរប្រព្រឹត្តធម៌ចុះ ។

មាតា បិតា បងប្អូនប្រុស បងប្អូនស្រី និងប្រពន្ធក្តី ប្តីក្តី ព្រមទាំងទ្រព្យ ឯជនទាំងនោះ រមែងលះបង់នូវគ្នានិងគ្នា ម្នាលនាងឧទយភទ្ទា នាងកុំប្រមាទ ចូរប្រព្រឹត្តធម៌ចុះ ។ ម្នាលនាងឧទយ-ភទ្ទា នាងដឹងថា កាយជាចំណីនៃពួកសត្វដទៃ ដឹងថា សុគតិ និង

ទុគ្គតិក្នុងសង្សារ ជាលំនៅរបស់សត្វលោកទាប ដូច្នេះហើយ កុំ
ប្រមាទ ចូរប្រព្រឹត្តធម៌ចុះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អតិបតតិ** សេចក្ដីថា វ័យកន្លងទៅឆាប់រហ័សពន់ពេក គឺធ្លងទៅដោយឆាប់រួសរាន់ ។ បទថា **វយោ** បានដល់ ក្នុងវ័យទាំង ៣ មានបឋមវ័យជាដើម ។ បទថា **ខណោ តថេវ** បានដល់ ទាំងឧប្បាទខណៈ ឋិតិខណៈ និងភង្គខណៈ រមែងឆាប់កន្លងទៅដូច្នោះដូចគ្នា ដោយបទទាំងពីរ ដូចពោលមកនេះ សក្កទេវរាជសម្ដែងថា ឈ្មោះថាអាយុសង្ខាររបស់សត្វទាំងនេះ ជាសភាវៈបែកធ្លាយ ឈ្មោះថារមែងកន្លងទៅដោយរួសរាន់ ព្រោះប្រែប្រួលទៅឆាប់រហ័សក្រៃលែងដូចស្ទឹងមានក្រសែហូរខ្លួលខ្លាញ់ដូច្នោះ។ បទថា **ឋានំ នត្ថិ** សេចក្ដីថា សក្កទេវរាជទ្រង់សម្ដែងថា ឈ្មោះថាការឈប់នៃវ័យ និងខណៈទាំងពីរនោះ មិនមានឡើយ សូម្បីដោយសេចក្ដីប្រាថ្នាថា សង្ខារទាំងឡាយដែលកើតឡើងហើយ កុំបែកធ្លាយ តាំងនៅដូច្នេះ ក៏មិនប្រព្រឹត្តទៅបាន សត្វទាំងពួងតាំងអំពីព្រះដ៏មានព្រះភាគដ៏ជាសម្មាសម្ពុទ្ធ រមែងចុតិទៅពិតប្រាកដ គឺដោយចំណែកមួយប៉ុណ្ណោះ នែនាង ចូរនាងចម្រើនមរណស្សតិយ៉ាងនេះថា ការស្លាប់ពិតប្រាកដ ការប្រព្រឹត្តទៅមិនពិតប្រាកដឡើយ ។ បទថា **បរិជីយតិ** សេចក្ដីថា សរីរៈដែលមានពណ៌ដូចមាសនេះ គ្រាំគ្រាទាំងអស់នោះឯង ចូរនាងដឹងយ៉ាងនេះចុះ ។ បទថា **មា បមាទ** សេចក្ដីថា ម្នាលនាងឧទយកន្យា ហេតុនោះ នាងកុំប្រមាទឡើយ ចូរជាអ្នកមិនប្រមាទ ប្រព្រឹត្តធម៌ គឺកុសលកម្មបថ ១០ ប្រការចុះ ។ បទថា **កសិណា**

បានដល់ ទាំងមូល ។ បទថា **ឯកស្សេវ** សេចក្តីថា បើជារបស់ព្រះរាជាមួយអង្គប៉ុណ្ណោះ ទោះជាអតីត អនាគត ក៏រស់នៅក្នុងព្រះរាជាអង្គនោះមួយអង្គ ។ បទថា **តំ ជហិ ជហាតិ អវីតរាគោ** សេចក្តីថា សក្កទេវរាជទ្រង់សម្តែងថា បុគ្គលធ្លាក់ទៅក្នុងអំណាចនៃតណ្ហា មិនឆ្អែតដោយយសដែលមានត្រឹមប៉ុណ្ណោះឡើយ ក្នុងវេលាស្លាប់ នឹងត្រូវលះបង់ចោលនូវផែនដីនោះទៅ ទាំងដែលមិនទាន់អស់ស្រឡាញ់ ចូរនាងដឹងថា តណ្ហា ជាធម្មជាតដែលមិនពេញដោយអាការយ៉ាងនេះចុះ ។

បទថា **តេ ជហិ** សេចក្តីថា បុគ្គលទាំងនេះ រមែងលះបង់ចោលគ្នាទៅ គឺរមែងព្រាត់ប្រាសចាកគ្នាទៅ មាតាបិតារមែងលះចោលនូវបុត្រ បុត្ររមែងលះចោលមាតាបិតា ភរិយាចោលស្វាមី ស្វាមីចោលភរិយា ចូរនាងជ្រាបថា ពួកសត្វត្រូវព្រាត់ប្រាសចាកគ្នានិងគ្នាដោយប្រការដូច្នេះ ។ បទថា **បរភោជនំ** សេចក្តីថា នាងគប្បីជ្រាបចុះថា កាយជាអាហាររបស់សត្វដទៃ មានក្អែកជាដើម ។ បទថា **ឥត្តរវាសោ** សេចក្តីថា គប្បីជ្រាបចុះថា សង្សារនេះ សុគតិ គឺទីកើតរបស់មនុស្ស និងទុគ្គតិ គឺទីកើតរបស់តិរច្ឆាននេះ ទាំងពីរនោះ ជាទីសម្រាកបណ្តោះអាសន្ន ចូរនាងកុំប្រមាទ ចូរប្រព្រឹត្តធម៌ ការមកអំពីទីផ្សេងៗ ហើយជួបគ្នាក្នុងទីកន្លែងជាមួយគ្នា របស់សត្វទាំងនោះ ជាការតិចតួច សត្វទាំងនេះ នៅរួមគ្នាអស់កាលមានប្រមាណតិចតួចប៉ុណ្ណោះ ព្រោះដូច្នោះ ចូរនាងកុំប្រមាទ ។ ព្រះមហាសត្វបានប្រទានឱវាទដល់ព្រះនាងដោយប្រការដូច្នេះឯង ។

ចំណែកព្រះនាង ទ្រង់ជ្រះថ្លាក្នុងធម្មកថារបស់សក្កៈ កាលធ្វើនូវការសរសើរ ទើបត្រាស់អវសានគាថាដូច្នេះថា

យក្ខនេះ ពោលពីរោះណាស់ ជីវិតរបស់ពួកសត្វខ្លី លំបាកផង

តិចផង ព្រោះជីវិតនោះ ប្រកបដោយទុក្ខ ខ្ញុំនោះនឹងលះដែនកាសី

និងក្រុងសុរុន្ធនៈ បួសតែម្នាក់ឯង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សាធុ** បានដល់ ល្អពិត ។ បទថា **អប្បំ មច្ចាន ជីវិតំ** សេចក្ដីថា ទេវរាជនេះ កាលនឹងត្រាស់ រមែងត្រាស់ថា ជីវិតរបស់ពួកសត្វ ជារបស់បន្តិចបន្តួច ទេវបុត្រនេះត្រាស់ល្អពិតហ្ន៎ ព្រោះហេតុអ្វី ព្រោះថា ជីវិតនេះក្រីក្រជាទុក្ខ ប្រាសចាកសេចក្ដីត្រេកអរ ទាំងជារបស់បន្តិចបន្តួច គឺមិនច្រើន ជារបស់មួងម្កាល បើជីវិតជារបស់លំបាក គប្បីប្រព្រឹត្តទៅអស់កាលយូរ ទាំងដែលជារបស់តិចតួច គប្បីមានសេចក្ដីសុខបាន តែជីវិតនេះ ជារបស់លំបាកផង តិចតួចផង ប្រកប គឺសម្បយុត្តដោយវដ្តទុក្ខទាំងមូល ។ បទថា **សាហំ** កាត់បទជា **សា អហំ** ។ បទថា **សុរុន្ធនំ** សេចក្ដីថា ព្រះនាងត្រាស់ថា ខ្ញុំនឹងលះបង់នគរសុរុន្ធនៈ និងដែនកាសី ទៅបួសតែម្នាក់ឯង ។

ព្រះពោធិសត្វប្រទានឱវាទដល់ព្រះនាងហើយ ទើបទៅកាន់លំនៅរបស់ទ្រង់វិញ ។ ចំណែកព្រះនាង លុះស្អែកឡើង ក៏ទ្រង់ប្រគល់រាជសម្បត្តិឲ្យពួកអមាត្យ ទ្រង់បួសជាតបស្វិនី ក្នុងព្រះរាជឧទ្យានដែលគួរជាទីត្រេកអរ ខាងក្នុងនគរនោះឯង ទ្រង់ប្រព្រឹត្តធម៌ ក្នុងទីបំផុតនៃព្រះជន្មាយុ ក៏បានកើតជា

បាទបរិចារិការបស់ព្រះពោធិសត្វ ក្នុងតាវត្តិង្សព្រិកពនោះឯង ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះ មកសម្តែងហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ ( ក្នុងកាលចប់សច្ចៈ ភិក្ខុអផ្សុកតាំងនៅក្នុងសោតាបត្តិផល ) ហើយទ្រង់ប្រជុំជាតកថា ព្រះរាជធីតាក្នុងកាលនោះ បាន មកជារាហុលមាតា ក្នុងកាលឥឡូវនេះ ចំណែកសក្កទេវរាជ ក្នុងកាលនោះ គឺតថាគតនេះឯង ៕ល៚

**អដ្ឋកថា ឧទយជាតក ចប់**

# សុត្តន្តបិដក

## ចាតិយជាតក

[ ៨៤០ ] ( ព្រះបច្ចេកពុទ្ធទី ១ បានសម្តែងថា ) អាត្មាភាព ជាមិត្ត ( នៃមិត្តម្នាក់ ) បានប្រើប្រាស់ទឹក ដែលមិត្តនោះមិនឲ្យ ហើយ ហេតុនោះអាត្មាភាព ខ្ពើមរអើម ក្នុងកាលជាខាងក្រោយ អាត្មាភាពបានធ្វើបាបនោះហើយ អាត្មាភាព លែងធ្វើបាបទៀត ហើយ ព្រោះហេតុនោះ បានជាអាត្មាភាពបួស ។

[ ៨៤១ ] ( ព្រះបច្ចេកពុទ្ធទី ២ ... ) សេចក្តីប្រាថ្នា ( ក្នុងកាម ) កើតឡើងដល់អាត្មាភាព ព្រោះឃើញនូវប្រពន្ធ របស់បុគ្គលដទៃ ព្រោះហេតុនោះ អាត្មាភាពខ្ពើមរអើម ក្នុងកាលជាខាងក្រោយ អាត្មាភាព បានធ្វើបាបនោះហើយ អាត្មាភាពលែងធ្វើបាបទៀត ហើយ ព្រោះហេតុនោះ បានជាអាត្មាភាពបួស ។

[ ៨៤២ ] ( ព្រះបច្ចេកពុទ្ធទី ៣ ... ) បពិត្រមហារាជ ពួកចោរ បានចាប់បិតា របស់អាត្មាភាពក្នុងព្រៃ អាត្មាភាព ដែលពួកចោរ នោះសួរហើយ ទុកជាដឹងក៏ប្រាប់ហេតុនោះ ដោយចំណែកដទៃ វិញ ព្រោះហេតុនោះ អាត្មាភាពខ្ពើមរអើម ក្នុងកាលជាខាង ក្រោយ អាត្មាភាពបានធ្វើបាបនោះហើយ អាត្មាភាពលែងធ្វើបាប ទៀតហើយ ព្រោះហេតុនោះ បានជាអាត្មាភាពបួស ។

[ ៨៤៣ ] ( ព្រះបច្ចេកពុទ្ធទី ៤ ... ) ការសែនព្រេន ឈ្មោះ សោមយាគតាំងឡើងហើយ ពួកមនុស្ស បានធ្វើបាណាតិបាត

អាត្មាភាពក៏អនុញ្ញាត ឲ្យពួកមនុស្សនោះ ព្រោះហេតុនោះ អាត្មាភាពខ្មើមរអើម ក្នុងកាលជាខាងក្រោយ អាត្មាភាពបានធ្វើបាបនោះហើយ អាត្មាភាពលែងធ្វើបាបទៀតហើយ ព្រោះហេតុនោះ បានជាអាត្មាភាពបួស ។

[ ៨៤៤ ] ( ព្រះបច្ចេកពុទ្ធទី ៥ ... ) ពួកជនណា ( ក្នុងស្រុក ) របស់យើង ដែលសម្គាល់សុរា និងមេរ័យថា ដូចទឹកឃ្មុំ ជាជន ( មានសភាពយ៉ាងនេះ ) ជាដំបូង ពួកជននោះ បានចាត់ចែងទឹកស្រវឹង ដើម្បីសេចក្ដីវិនាស ដល់ពួកជនច្រើន អាត្មាភាពបានអនុញ្ញាតឲ្យពួកជននោះ ព្រោះហេតុនោះ អាត្មាភាពខ្មើមរអើម ក្នុងកាលជាខាងក្រោយ អាត្មាភាពបានធ្វើបាបនោះហើយ អាត្មាភាពលែងធ្វើបាបទៀតហើយ ព្រោះហេតុនោះ បានជាអាត្មាភាពបួស ។

[ ៨៤៥ ] ( ព្រះរាជា ... ) គួរឲ្យតិះដៀលកាមដ៏ច្រើន ដែលមានក្លិនអាក្រក់ មានសត្រូវច្រើន ព្រោះថា អាត្មាអញបានសេពហើយ ក៏មិនបានសេចក្ដីសុខ ( ក្នុងឈាន ) ប្រាកដដូច្នោះ ។

[ ៨៤៦ ] ( អគ្គមហេសី ... ) កាមទាំងឡាយ មានសេចក្ដីរីករាយច្រើន ជាសុខ សេចក្ដីសុខក្រៅអំពីកាម មិនមានទេ ពួកជនណា បានសេពកាមទាំងឡាយ ពួកជននោះ តែងកើតក្នុងឋានសួគ៌ ។

[ ៨៤៧ ] ( ព្រះរាជា ... ) កាមទាំងឡាយ មានសេចក្ដីរីករាយតិច ជាទុក្ខ សេចក្ដីទុក្ខក្រៅអំពីកាម មិនមានទេ ពួកជនណាសេពកាមទាំងឡាយ ពួកជននោះ តែងកើតក្នុងនរក ។

[ ៨៤៨ ] កាមទាំងឡាយមានសេចក្ដីទុក្ខ លើសជាងដាវដែលសំលៀងហើយ ជាងព្រះខ័នដែលលាបដោយថ្នាំពិស ទាំងជាងលំពែង ដែលពួយត្រង់ទ្រូង ។

[ ៨៤៩ ] កាមទាំងឡាយមានសេចក្ដីទុក្ខ លើសជាងរណ្ដើកភ្លើងដ៏ប្រាលក្ដៅ ជាងរណ្ដៅរណ្ដើកភ្លើង មានជម្រៅមួយទទួង ឬអណ្ដាតភ្លើង ដែលក្ដៅពេញមួយថ្ងៃ ។

[ ៨៥០ ] កាមទាំងឡាយមានសេចក្ដីទុក្ខ លើសជាងថ្នាំពុលដ៏ក្លៀវក្លា ឬប្រេងកំពុងពុះ ឬក៏ទង់ដែងរលាយ ។

**បាទិយជាតកទី ៥ ចប់**

# អដ្ឋកថា

## ចានីយជាតក

[ ៨៤០-៨៥០ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវការសង្កត់កិលេស ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **មិត្តោ មិត្តស្ស** ដូច្នេះជាដើម ។

សេចក្តីពិស្តារថា សម័យមួយ គ្រហស្ថដែលជាសម្លាញ់អ្នកក្រុងសាវត្ថីប្រមាណ ៥០០ នាក់ ស្តាប់ព្រះធម្មទេសនារបស់ព្រះតថាគតហើយ ចេញបព្វជ្ជា និងឧបសម្បទា នាំគ្នានៅក្នុងកោដ្ឋិសណ្ឋាគារ លុះដល់ពេលយប់ ក៏នាំគ្នាត្រិះរិះនូវកាមវិតក្ក រឿងទាំងអស់បណ្ឌិតគប្បីឲ្យពិស្តារដោយន័យដែលពោលហើយខាងដើមនោះឯង ប្លែកគ្នាត្រង់ថា កាលព្រះអានន្ទឲ្យភិក្ខុសង្ឃប្រជុំគ្នាដោយអាណត្តិ ( អាជ្ញា ) របស់ព្រះដ៏មានព្រះភាគហើយ ព្រះសាស្តាគង់លើអាសនៈដែលគេរៀបចំថ្វាយ ទ្រង់ធ្វើមិនឲ្យជាការបោះចំពោះ មិនត្រាស់ថា ពួកអ្នកនាំគ្នាត្រិះរិះដល់កាមវិតក្ក ហើយត្រាស់ដោយអំណាចជាព្រះតម្រាស់សង្គ្រោះដល់ភិក្ខុទាំងពួងថា ម្នាលភិក្ខុទាំងឡាយ ឈ្មោះថា កិលេសជារបស់តិចតួច មិនមានឡើយ ធម្មតាភិក្ខុត្រូវសង្កត់កិលេសដែលកើតឡើងហើយ បណ្ឌិតក្នុងកាលមុន កាលព្រះពុទ្ធមិនទាន់កើត ក៏សង្កត់កិលេសទាំងឡាយចេញបាន សម្រេចព្រះបច្ចេកពោធិញ្ញាណ ដូច្នេះហើយ ទើបទ្រង់នាំអតីតនិទានមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី សម្លាញ់ ២ នាក់នៅក្នុងស្រុកតូចមួយ នាដែនកាសី នាំគ្នាកាន់ក្អមទឹកទៅកាន់

ព្រៃ ដាក់ក្អមក្នុងចំណែកម្ខាងហើយ កាប់ចម្ការ ក្នុងពេលស្រេកទឹក ក៏នាំគ្នាផឹកទឹក ។ ក្នុងបុគ្គល ២ នាក់នោះ ម្នាក់កាលមកផឹកទឹក ក៏រក្សាទឹករបស់ខ្លួនទុក ផឹកទឹកក្នុងក្អមរបស់សម្លាញ់ម្នាក់ទៀត ពេលល្ងាចចេញអំពីព្រៃហើយឈរងូតទឹក ពិចារណាថា ថ្ងៃនេះ អញបានធ្វើបាបអ្វីដោយកាយទ្វារជាដើមមានដែរឬទេ ឃើញការដែលលួចផឹកទឹករបស់សម្លាញ់ ទើបសង្វេគ គិតថាតណ្ហានេះ កាលចម្រើន គង់បោះអញទៅក្នុងអបាយដោយពិត អញនឹងសង្កត់កិលេសនេះឲ្យបាន ធ្វើការលួចទឹកផឹករបស់សម្លាញ់នោះ ឲ្យជាអារម្មណ៍ចម្រើននូវវិបស្សនា ធ្វើបច្ចេកពោធិញ្ញាណឲ្យកើតបាន ហើយឈរពិចា-រណាដល់គុណដែលខ្លួនបានទទួល ។ លំដាប់នោះ បុរសម្នាក់ទៀតងូតទឹកហើយ ឡើងមកពោលថា មកសម្លាញ់ យើងនាំគ្នាទៅផ្ទះ ព្រះបច្ចេកពុទ្ធតបថា អើ ទៅចុះ អាត្មាមិនមានចិត្តគិតដល់ផ្ទះឡើយ អាត្មាជាព្រះបច្ចេកពុទ្ធហើយ បុរសនោះពោលថា ព្រះបច្ចេកពុទ្ធទាំងឡាយ មិនមានសភាពដូចអ្នកទេ ។ លំដាប់នោះ ទើបលោកសួរថា តើព្រះបច្ចេកពុទ្ធដូចអ្វី ។ បុរសនោះឆ្លើយថា ព្រះបច្ចេកពុទ្ធទាំងឡាយ មានសក់ត្រឹមតែ ២ ធ្នាប់ ដណ្តប់សំពត់ដែលជ្រលក់ដោយទឹកអម្ចត់ នាំគ្នានៅត្រង់ញកភ្នំនន្ទមូលកៈ ក្នុងហិមវន្ត-ប្បទេស ទិសខាងជើង ។ ព្រះបច្ចេកពុទ្ធស្ទាបសីសៈក្នុងពេលនោះឯង គិហិ-ភាវៈរបស់លោកក៏អន្តរធានទៅ ក្លាយជាបុគ្គលដែលដណ្តប់សំពត់ពីរជាន់ដែលជ្រលក់ហើយ ចងវត្ថពន្ធចង្កេះ ដូចផ្លេកបន្ទោរ មានចីវរឆៀងស្មា មានពណ៌ដូចល័ក្ត ដណ្តប់ឆៀងស្មាម្ខាង មានសំពត់បង្សុកូល មានពណ៌ដូចមេឃ

ដាក់លើចង្កួយស្មាខាងស្តាំ មានបាត្រដីពណ៌ដូចមេក្អៀង ពាក់នៅត្រង់ចង្កួយស្មាខាងឆ្វេង លោកស្ថិតនៅក្នុងអាកាស សម្តែងធម៌ហើយ ហោះទៅកាន់ញកភ្នំនន្ទមូលកៈមួយរំពេច ។ សម័យនោះដែរ មានកុដុម្ពិកៈម្នាក់ ក្នុងកាសិកគ្រាមនោះអង្គុយត្រង់ផ្សារ ឃើញបុរសម្នាក់ នាំកិរិយាដើរទៅ ទម្លាយឥន្ទ្រិយ សម្លឹងមើលរូបសម្រស់របស់កិរិយាគេនោះ តែក៏បែរជាពិចារណាថា លោកៈនេះឯង បើវាចម្រើន នឹងបោះអញទៅក្នុងអបាយទាំងឡាយបាន មានចិត្តសង្វេគ ចម្រើនវិបស្សនា សម្រេចបច្ចេកពោធិញ្ញាណ ស្ថិតនៅក្នុងអាកាសសម្តែងធម៌ហើយ ហោះទៅកាន់ញកភ្នំនន្ទមូលកៈដូចគ្នា ។ មានបិតា និងបុត្រ ២ នាក់ ជាអ្នកកាសិកគ្រាមដូចគ្នា ធ្វើដំណើរទៅជាមួយគ្នា ពួកចោរនាំគ្នាស្កាត់ផ្លូវត្រង់មាត់ព្រៃ ពួកចោរទាំងនោះ ចាប់បិតា និងបុត្របាន ទុកបុត្រហើយលែងបិតាទៅដោយប្រាប់ថា ចូរទៅនាំទ្រព្យមកលោះកូនរបស់អ្នកចុះ បើចាប់បងប្អូនពីរនាក់បាន ក៏ទុកប្អូន ហើយលែងបងទៅ បើចាប់អាចារ្យនិងអន្តេវាសិកបាន ទុកអាចារ្យ លែងអន្តេវាសិកទៅ ។ អន្តេវាសិកត្រូវតែនាំទ្រព្យមកដើម្បីលោះអាចារ្យ ព្រោះចង់បាននូវសិប្បៈ ។ លំដាប់នោះ ឪពុកនិងកូននោះ ដឹងថា ពួកចោរស្កាត់ត្រង់ទីនោះ ទើបធ្វើកតិកាគ្នាថា ឯងកុំហៅយើងថា ពុក សូម្បីអញក៏មិនហៅឯងថា កូន ។ ក្នុងកាលពួកចោរចាប់បាន កាលចោរសួរថា ឯងជាអ្វីនឹងគ្នា ក៏នាំគ្នានិយាយកុហកទាំងដែលដឹងខ្លួន រួចក្មេងឆ្លើយថា ខ្ញុំមិនមែនជាអ្វីនឹងគ្នាឡើយ ។ ជនទាំងពីរចេញផុតអំពីព្រៃ ឈរងូតទឹកក្នុងពេលល្ងាច កូនប្រុសជម្រះសីលរបស់ខ្លួន ឃើញមុសាវាទនោះ

គិតថា បាបនេះ កាលចម្រើន នឹងបោះអញទៅក្នុងអបាយទាំងឡាយបាន អញនឹងសង្កត់កិលេសនេះឲ្យបាន ដូច្នេះ ចម្រើនវិបស្សនា ធ្វើបច្ចេកពោធិញ្ញាណឲ្យកើតឡើងហើយ ស្ថិតនៅក្នុងអាកាស សម្ដែងធម៌ដល់បិតា ហោះទៅកាន់ញកភ្នំនន្ទមូលកៈដូចគ្នា ។ នៅមានបុរសម្នាក់ទៀត ជាមេស្រុកក្នុងកាសិក-គ្រាមនោះឯង ប្រាប់ឲ្យមនុស្សសម្លាប់សត្វ ក្នុងកាលធ្វើពលីកម្ម មហាជនប្រជុំគ្នាហើយ ពោលថា បពិត្រលោកម្ចាស់ ពួកយើងនឹងសម្លាប់ម្រឹគ និងជ្រូកជាដើម ធ្វើពលីកម្មដល់ពួកយក្ខ កាលនេះ ជាកាលនៃពលីកម្ម ក៏ពោលថា ចូរពួកលោកធ្វើតាមបែប ដែលធ្លាប់ធ្វើមកក្នុងកាលមុននោះឯង ។ ពួកមនុស្សបានធ្វើបាណាតិបាតសន្ធឹកសន្ធាប់ គាត់សម្លឹងឃើញត្រី និងសាច់ជាច្រើន សោកស្ដាយថា មនុស្សទាំងនេះសម្លាប់សត្វមានប្រមាណប៉ុណ្ណេះ គឺសម្លាប់តាមពាក្យរបស់អញតែម្នាក់ប៉ុណ្ណោះ ដូច្នេះហើយ ទើបឈរផ្អែកបង្អួច ចម្រើនវិបស្សនា ធ្វើបច្ចេកពោធិញ្ញាណឲ្យកើតហើយ ស្ថិតនៅក្នុងអាកាស សម្ដែងធម៌ ហោះទៅកាន់ញកភ្នំនន្ទមូលកៈដូចគ្នា ។ បុរសម្នាក់ទៀត ជាមេស្រុក ក្នុងដែនកាសិកៈនោះដូចគ្នា ឃាត់នូវការលក់ដូរទឹកស្រវឹងយ៉ាងដាច់ខាត ត្រូវមហាជនសួរថា បពិត្រលោកម្ចាស់ ក្នុងកាលមុនពេលនេះ ជាពេលនក្ខត្តឫក្ស ដែលហៅថាសុរាឆណៈ ពួកខ្ញុំនឹងធ្វើអ្វី ទើបពោលថា ចូរពួកលោកធ្វីតាមបែបពីមុននោះឯង ។ ពួកមនុស្សនាំគ្នាលេងនូវមហោស្រព ផឹកស្រាស្រវឹង ហើយឈ្លោះគ្នាហូតដៃជើងបែកបាក់ បែកក្បាល ដាច់ត្រចៀក ត្រូវចងដោយបំណុល ( ជំពាក់បំណុល ) ជាច្រើន ។ មេស្រុកឃើញជន

ទាំងនោះហើយ គិតថា កាលយើងមិនអនុញ្ញាត ជនទាំងនេះ ក៏មិនជួបនូវទុក្ខ បុរសនោះ ធ្វើនូវការរំខានចិត្តដោយហេតុត្រឹមប៉ុណ្ណេះ ឈរផ្អែកបង្អួចចម្រើនវិបស្សនា សម្រេចបច្ចេកពោធិញ្ញាណហើយ ស្ថិតនៅក្នុងអាកាសសម្តែងធម៌ថា ពួកអ្នកកុំជាអ្នកប្រមាទ ហើយហោះទៅកាន់ញកភ្នំនន្ទមូលកៈដូចគ្នា ។

ចំណេរកាលតមក ព្រះបច្ចេកពុទ្ធទាំង ៥ អង្គ នាំគ្នាហោះចុះត្រង់ទ្វារក្រុងពារាណសីដើម្បីភិក្ខាចារ ហើយស្លៀកដណ្តប់នូវសំពត់រៀបរយ ត្រាច់ប្រោសសត្វដោយឥរិយាបថ មានការឈានទៅមុខជាដើមដែលគួរជ្រះថ្លា រហូតដល់ទ្វារព្រះរាជវាំង ព្រះរាជាទ្រង់ទតឃើញព្រះបច្ចេកពុទ្ធទាំងនោះ ទ្រង់មានចិត្តជ្រះថ្លា និមន្តឲ្យចូលកាន់ព្រះរាជនិវេសន៍ លាងនូវជើង លាបដោយប្រេងក្រអូប អង្គាសដោយខាទនីយៈ និងភោជនីយៈដ៏ប្រណីត បានប្រថាប់គង់ក្នុងចំណែកម្ខាង ត្រាស់សួរថា បពិត្រលោកម្ចាស់ទាំងឡាយ ការបំពេញបព្វជ្ជាក្នុងបឋមវ័យរបស់លោកម្ចាស់ទាំងឡាយ មើលទៅល្អពិត កាលបព្វជ្ជាក្នុងវ័យនេះ លោកម្ចាស់ទាំងឡាយ ឃើញទោសក្នុងកាមទាំងឡាយដូចម្តេច អ្វីជាអារម្មណ៍របស់លោកម្ចាស់ កាលព្រះបច្ចេកពុទ្ធទាំងនោះ ទូលដល់ព្រះរាជា ទើបពោលគាថាមួយអង្គ ១ គាថាដូចតទៅ

អាត្មាភាពជាមិត្ត ( នៃមិត្តម្នាក់ ) បានប្រើប្រាស់ទឹក ដែលមិត្ត
នោះមិនឲ្យហើយ ហេតុនោះ អាត្មាភាព ខ្ពើមរអើមក្នុងកាល
ជាខាងក្រោយ អាត្មាភាពបានធ្វើបាបនោះហើយ អាត្មាភាពលែង
ធ្វើបាបទៀតហើយ ព្រោះហេតុនោះ បានជាអាត្មាភាពបួស ។

សេចក្ដីប្រាថ្នា ( ក្នុងកាម ) កើតឡើងដល់អាត្មាភាព ព្រោះឃើញនូវប្រពន្ធរបស់បុគ្គលដទៃ ព្រោះហេតុនោះ អាត្មាភាពខ្ពើមរអើម ក្នុងកាលជាខាងក្រោយ អាត្មាភាពបានធ្វើបាបនោះហើយ អាត្មាភាពលែងធ្វើបាបទៀតហើយ ព្រោះហេតុនោះ បានជាអាត្មាភាពបួស ។

បពិត្រមហារាជ ពួកចោរ បានចាប់បិតា របស់អាត្មាភាពក្នុងព្រៃ អាត្មាភាព ដែលពួកចោរនោះសួរហើយ ទុកជាដឹង ក៏ប្រាប់ហេតុនោះ ដោយចំណែកដទៃវិញ ព្រោះហេតុនោះ អាត្មាភាពខ្ពើមរអើម ក្នុងកាលជាខាងក្រោយ អាត្មាភាពបានធ្វើបាបនោះហើយ អាត្មាភាពលែងធ្វើបាបទៀតហើយ ព្រោះហេតុនោះ បានជាអាត្មាភាពបួស ។

ការសែនព្រេន ឈ្មោះសោមយាគតាំងឡើងហើយ ពួកមនុស្សបានធ្វើបាណាតិបាត អាត្មាភាពក៏អនុញ្ញាត ឲ្យពួកមនុស្សនោះ ព្រោះហេតុនោះ អាត្មាភាពខ្ពើមរអើម ក្នុងកាលជាខាងក្រោយ អាត្មាភាពបានធ្វើបាបនោះហើយ អាត្មាភាពលែងធ្វើបាបទៀតហើយ ព្រោះហេតុនោះ បានជាអាត្មាភាពបួស ។

ពួកជនណា ( ក្នុងស្រុក ) របស់យើង ដែលសម្គាល់សុរា និងមេរ័យ ថាដូចទឹកឃ្មុំ ជាជន ( មានសភាពយ៉ាងនេះ ) ជាដំបូង ពួកជននោះ បានចាត់ចែងទឹកស្រវឹង ដើម្បីសេចក្ដីវិនាស ដល់

ពួកជនច្រើន អាត្មាភាពបានអនុញ្ញាតឲ្យពួកជននោះ ព្រោះហេតុនោះ អាត្មាភាពខ្ពើមរអើម ក្នុងកាលជាខាងក្រោយ អាត្មាភាពបានធ្វើបាបនោះហើយ អាត្មាភាពលែងធ្វើបាបទៀតហើយ ព្រោះហេតុនោះ បានជាអាត្មាភាពបួស ដូច្នេះ ។

ព្រះបច្ចេកពុទ្ធទាំងឡាយ បានភាសិតគាថាទាំង ៥ នេះដោយលំដាប់ ។ ចំណែកព្រះរាជា ទ្រង់ស្តាប់ព្យាកររបស់ព្រះបច្ចេកពុទ្ធមួយអង្គៗ ហើយ ទ្រង់សរសើរថា បពិត្រលោកម្ចាស់ទាំងឡាយ បព្វជ្ជានេះ សមគួរដល់លោកម្ចាស់ទាំងឡាយនោះឯង ។

បណ្តាបទទាំងនោះ បទថា **មិត្តោ មិត្តស្ស** សេចក្តីថា មហាបពិត្រ អាត្មាភាពជាបុគ្គលម្នាក់ បរិភោគទឹករបស់សម្លាញ់ដោយទំនងនេះ ។ បទថា **តស្មា** សេចក្តីថា ព្រោះអាត្មាមិនធ្វើបាបកម្មដដែលទៀត ដូចពួកបុថុជ្ជនធ្វើ ។ បទថា **ចាបំ** សេចក្តីថា អាត្មាភាពធ្វើបាបនេះឲ្យជាអារម្មណ៍ ហើយបួស ។ បទថា **ឆន្ទោ** សេចក្តីថា មហាបពិត្រ ព្រោះឃើញកិរិយារបស់អ្នកដទៃ ដោយទំនងនេះ ការពេញចិត្តក្នុងកាម កើតឡើងដល់អាត្មាភាពហើយ ។ បទថា **អគណ្ហុ** សេចក្តីថា បានចោមចាប់ ។ បទថា **ជានំ** សេចក្តីថា អាត្មាត្រូវពួកចោរនោះសួរថា បុគ្គលនេះជាអ្វីនឹងឯង ទាំងដឹងខ្លួននោះឯង ក៏ពោលឆ្លើយដទៃថា មិនបានជាអ្វីឡើយ ។ បទថា **សោមយាគេ** សេចក្តីថា កាលមហោស្រពថ្មីកើតឡើងហើយ ពួកមនុស្សនាំគ្នាធ្វើពលីកម្មដល់យក្ខ ឈ្មោះថា វិធីសោមយាគៈ កាលពលិកម្មនោះប្រាកដហើយ អាត្មាក៏ពិចារណានូវការ

អនុញ្ញាត ។ បទថា **សុរាមេរយមធុកា** សេចក្តីថា ពួកជនសម្គាល់នូវសុរា មានសុរាលាយដោយម្សៅជាដើម និងមេរ័យ មានទឹកដែលត្រាំដោយផ្កាជាដើមថា ដូចជាទឹកឃ្មុំ ។ បទថា **យេ ជនា បឋមាសុ នោ** សេចក្តីថា ពួកជនបែបនេះ មានហើយ បានមានមុន ក្នុងស្រុករបស់ពួកយើង ។ បទថា **ពហុន្នំ តេ** សេចក្តីថា ពួកជនទាំងនោះ ក្នុងថ្ងៃមួយ កាលដល់នូវការងារមហោស្រពមួយ មានការផឹកនូវទឹកស្រវឹង ដែលជាហេតុវិនាសដល់ជនច្រើន ។

ព្រះរាជាទ្រង់ស្តាប់ព្រះធម្មទេសនារបស់ព្រះបច្ចេកពុទ្ធទាំងនេះ ទ្រង់មានចិត្តជ្រះថ្លា ទ្រង់ថ្វាយសំពត់ចីវរ និងភេសជ្ជៈ ទ្រង់បញ្ជូនព្រះបច្ចេកពុទ្ធទៅហើយ កាលព្រះបច្ចេកពុទ្ធទាំងនោះធ្វើអនុមោទនាដល់ទ្រង់ ក៏បាននាំគ្នាទៅក្នុងទីនោះឯង ។ តាំងអំពីនោះមក ព្រះរាជាទ្រង់នឿយណាយ មិនត្រេកអរក្នុងវត្ថុកាមទាំងឡាយ ទ្រង់សោយព្រះក្រយាហារ មានរសដ៏ប្រសើរផ្សេងៗ ទ្រង់ក៏មិនបានហៅ ទ្រង់មិនបានទតពួកស្ត្រី ទ្រង់មានចិត្តនឿយណាយ យាងចូលបន្ទប់ដ៏មានសិរី ប្រថាប់គង់ធ្វើកសិណបរិកម្មត្រង់ជញ្ជាំងដែលមានពណ៌ស ទ្រង់ធ្វើឈានឲ្យកើតឡើងហើយ ។ ព្រះរាជាទ្រង់សម្រេចឈានហើយ កាលទ្រង់តិះដៀលកាមទាំងឡាយ ទើបត្រាស់ព្រះគាថាថា

គួរឲ្យតិះដៀលកាមដ៏ច្រើន ដែលមានក្លិនអាក្រក់ មានសត្រូវ<br>ច្រើន ព្រោះថា អាត្មាអញបានសេពហើយ ក៏មិនបានសេចក្តី<br>សុខ ( ក្នុងឈាន ) ប្រាកដដូច្នោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ពហុកណ្ដកេ** បានដល់ មានពួកបច្ចាមិត្ត ជាច្រើន ។ បទថា **យោ ច** កែជា **យោ អហំ** ម្យ៉ាងទៀត បាលីក៏យ៉ាង នោះឯង ។ បទថា **តានិសំ** បានដល់ សេចក្តីសុខក្នុងឈានបែបនោះ គឺវៀរ បាកកិលេស ។

លំដាប់នោះ ព្រះអគ្គមហេសីរបស់ទ្រង់ ព្រះតម្រិះថា ព្រះរាជាអង្គនេះ ស្តាប់ព្រះធម្មកថារបស់ព្រះបច្ចេកពុទ្ធទាំងឡាយហើយ ទ្រង់មានអាកប្បកិរិយា នឿយណាយ មិនបានត្រាស់ជាមួយពួកយើងឡើយ ទ្រង់ចូលព្រះដំណាក់ដ៏ មានសិរី អញនឹងចាំចាប់ទោសរបស់ទ្រង់ ដូច្នេះហើយ ក៏យាងទៅកាន់ទ្វារ ដំណាក់ដ៏មានសិរី ប្រថាប់ឈរត្រង់ទ្វារ ទ្រង់ស្តាប់ព្រះឧទានរបស់ព្រះរាជា ដែលកំពុងតិះដៀលនូវកាមទាំងឡាយ ទើបត្រាស់ថា បពិត្រព្រះអង្គ ទ្រង់ តិះដៀលកាម សេចក្តីសុខដូចគ្នានឹងកាមសុខ មិនមាន កាលព្រះនាង ពណ៌នាដល់សេចក្តីសុខក្នុងកាម ទើបត្រាស់ព្រះគាថាបន្ទថា

កាមទាំងឡាយ មានសេចក្តីរីករាយច្រើន ជាសុខ សេចក្តីសុខ
ក្រៅអំពីកាម មិនមានទេ ពួកជនណា បានសេពកាមទាំងឡាយ
ពួកជននោះ តែងកើតក្នុងឋានសួគ៌ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មហស្សាទា** សេចក្តីថា បពិត្រព្រះអង្គ ធម្មតាកាមទាំងនេះ មានរសជាតិច្រើន សេចក្តីសុខដទៃដែលក្រៃលែងជាង នេះ មិនមានទេ ព្រោះបុគ្គលសេពកាមជាប្រក្រតី មិនចូលដល់អបាយទាំង ឡាយ នឹងនាំគ្នាទៅកើតក្នុងឋានសួគ៌ ។

ព្រះពោធិសត្វ ទ្រង់ស្តាប់ព្រះរាជសវនីយ៍នេះហើយ កាលទ្រង់តិះដៀល ថា ចូរវិនាសចុះជនថោកថយ នាំងពោលអ្វី ឈ្មោះថា សេចក្ដីសុខក្នុងកាម ទាំងឡាយមានមកអំពីទីណា ព្រោះកាមទាំងនេះ ជាបរិណាមទុក្ខទាំងអស់នោះ ឯង ទើបភាសិត ( ពោល ) គាថាដ៏សេសថា

កាមទាំងឡាយ មានសេចក្ដីរីករាយតិច ជាទុក្ខ សេចក្ដីទុក្ខ ក្រៅអំពីកាម មិនមានទេ ពួកជនណា សេពកាមទាំងឡាយ ពួកជននោះ តែងកើតក្នុងនរក ។

កាមទាំងឡាយ មានសេចក្ដីទុក្ខ លើសជាងដាវដែលសំលៀង ហើយ ជាងព្រះខ័នដែលលាបដោយថ្នាំពិស ទាំងជាងលំពែង ដែលពួយត្រង់ទ្រូង ។

កាមទាំងឡាយ មានសេចក្ដីទុក្ខ លើសជាងរងើកភ្លើងដ៏ប្រាល ឆ្អៅ ជាងរណ្ដៅរងើកភ្លើង មានជម្រៅមួយទទូង ឬអណ្ដាតភ្លើង ដែលក្ដៅពេញមួយថ្ងៃ ។

កាមទាំងឡាយ មានសេចក្ដីទុក្ខ លើសជាងថ្នាំពុលដ៏ក្លៀវក្លា ឬប្រេងកំពុងពុះ ឬក៏ទង់ដែងរលាយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឆេត្តឹសោ** ស្មើគ្នានឹង **ឆេត្តិសោ** ។ ពាក្យ ថា **ឆេត្តឹសោ** នេះ ជាឈ្មោះរបស់ព្រះខ័នមួយប្រភេទ ។ បទថា **ឧក្កូតរា** សេចក្ដីថា សេចក្ដីទុក្ខឯណាកើតឡើងដល់បុគ្គល ព្រោះអាស្រ័យរណ្ដៅរងើក ភ្លើងដែលឆេះសន្ធោសន្ធៅ ឬបន្ទះដែកដែលត្រូវដុតអស់មួយថ្ងៃបែបនេះ កាម

ទាំងឡាយនោះឯង ជាទុក្ខក្រៃលែងជាងសេចក្តីទុក្ខនោះ ។ ក្នុងគាថាបន្តៗទៅ មានអត្ថថា ថ្នាំពិសជាដើមនេះ ឈ្មោះថា ជាទុក្ខ ព្រោះនាំទុក្ខមកឲ្យយ៉ាងណា កាមទាំងឡាយ ក៏ជាទុក្ខដូច្នោះ តែសេចក្តីទុក្ខព្រោះកាមនោះជាទុក្ខក្រៃលែងជាងសេចក្តីទុក្ខដ៏សេស ។

ព្រះមហាសត្វ ទ្រង់សម្តែងធម៌ដល់ព្រះទេវីយ៉ាងនេះហើយ ទ្រង់បានឲ្យពួកអមាត្យប្រជុំគ្នាហើយ ត្រាស់ថា ម្នាលអមាត្យដ៏ចម្រើន ចូរពួកអ្នកទទួលរាជសម្បត្តិចុះ ខ្ញុំនឹងបួស ទាំងដែលមហាជនកំពុងយំនោះឯង ទ្រង់ក្រោកឡើងទៅប្រថាប់ក្នុងអាកាសប្រទានឱវាទ យាងទៅកាន់ព្រៃហិមពាន្ត នាទិសខាងជើងតាមអាកាសនោះឯង ទ្រង់សាងអាស្រមក្នុងប្រទេសដែលគួរត្រេកអរ បួសជាឥសី ក្នុងទីបំផុតនៃព្រះជន្មាយុ បានយាងទៅកាន់ព្រហ្មលោកហើយ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឈ្មោះថា កិលេស ជារបស់តិចតួចមិនមានឡើយ ទោះបីមានប្រមាណតូច បណ្ឌិតទាំងឡាយ ក៏គួរសង្កត់សង្កិននោះឯងដូច្នេះហើយ ទើបទ្រង់ប្រកាសសច្ចៈទាំងឡាយ ( ក្នុងកាលចប់សច្ចៈ ភិក្ខុ ៥០០ រូប តាំងនៅក្នុងអរហត្តផល ) ហើយទ្រង់ប្រជុំជាតកថា ព្រះបច្ចេកពុទ្ធទាំងឡាយក្នុងកាលនោះបរិនិព្វានហើយ ព្រះទេវីក្នុងកាលនោះ បានមកជារាហុលមាតា ចំណែកព្រះបាទពារាណសីក្នុងកាលនោះ គឺតថាគតនេះឯង ៕

**អដ្ឋកថា ចាណីយជាតក ចប់**

# សុត្តន្តបិដក

## យុធញ្ជយជាតក

[ ៨៥១ ] ( ព្រះរាជកុមារពោធិសត្វពោលថា ) បពិត្រព្រះរាជាជាធំក្នុងរថ ខ្ញុំព្រះអង្គសូមថ្វាយបង្គំ ( ព្រះអង្គ ) ដែលមិត្ត និងអាមាត្យចោមរោមហើយ ខ្ញុំព្រះអង្គនឹងបួស សូមព្រះសម្មតិទេពអនុញ្ញាតផ្នួសនោះ ( ដល់ខ្ញុំព្រះអង្គ ) ។

[ ៨៥២ ] ( ព្រះរាជាទ្រង់ត្រាស់ថា ) បើកូនឯងខ្វះកាមទាំងឡាយ ឪពុកនឹងបំពេញឲ្យគ្រប់គ្រាន់ដល់អ្នក បុគ្គលណាបៀតបៀនអ្នក ឪពុកនឹងឃាត់ ( បុគ្គលនោះ ) ម្នាលយុធញ្ជ័យ អ្នកកុំបួសឡើយ ។

[ ៨៥៣ ] ( ព្រះរាជកុមារ ... ) ខ្ញុំព្រះអង្គ មិនមានសេចក្តីខ្វះកាមទាំងឡាយទេ បុគ្គលទីមួយ បៀតបៀននូវខ្ញុំព្រះអង្គ ក៏មិនមានដែរ តែថា ខ្ញុំព្រះអង្គ ប្រាថ្នានឹងធ្វើនូវទីពឹង ( ដល់ខ្លួន ) ដែលជរាកម្ចាត់បង់មិនបាន ។

[ ៨៥៤ ] ( ព្រះសាស្តា ... ) បុត្តអង្វរនូវបិតា បិតាក៏អង្វរនូវបុត្តឱរសដែរ ព្រះរាជាទ្រង់ត្រាស់ថា ម្នាលកូន ជនអ្នកនៅក្នុងនិគមអង្វរអ្នក ម្នាលយុធញ្ជ័យ អ្នកកុំបួសឡើយ ។

[ ៨៥៥ ] ( ព្រះរាជកុមារ ... ) បពិត្រព្រះបិតា ជាធំក្នុងរថ សូមព្រះអង្គ កុំឃាត់ផ្នួសខ្ញុំព្រះអង្គនោះ កុំឲ្យខ្ញុំព្រះអង្គពោរពេញដោយកាមទាំងឡាយ ឲ្យលុះក្នុងអំណាចជរាឡើយ ។

[ ៨៥៦ ] ( ព្រះមាតា ... ) ម្នាលកូន យើងសូមអង្វរអ្នក ម្នាលកូន យើងសូមឃាត់អ្នក យើងចង់ឃើញអ្នកអស់កាលយូរ ម្នាលយុធញ្ជ័យ ចូរអ្នកកុំបួសឡើយ ។

[ ៨៥៧ ] ( ព្រះរាជកុមារ ... ) ទឹកសន្សើមលើចុងស្មៅ តែងធ្លាក់ចុះ ( លើផែនដី ) ក្នុងកាលព្រះអាទិត្យរះឡើង យ៉ាងណាមិញ អាយុរបស់មនុស្សទាំងឡាយ ក៏យ៉ាងនោះដែរ បពិត្រព្រះមាតា សូមព្រះមាតាកុំឃាត់ខ្ញុំឡើយ ។

[ ៨៥៨ ] បពិត្រព្រះបិតាជាធំក្នុងរថ សូមឲ្យ ( បុរស ) ចម្លងព្រះមាតា ( របស់ខ្ញុំព្រះអង្គ ) ឲ្យឡើងកាន់ព្រះរាជយាននេះ កុំឲ្យព្រះមាតា ធ្វើនូវសេចក្តីអន្តរាយ ដល់ខ្ញុំព្រះអង្គ ដែលកំពុងឆ្លង ។

[ ៨៥៩ ] ( ព្រះមាតា ... ) នាងទាំងឡាយចូរស្ទុះទៅ សេចក្តីចម្រើន ( នឹងមាន ) ដល់នាង នគររម្មកៈមុខជានឹងសូន្យ ( ព្រោះថា ) យុធញ្ជយកុមារ ព្រះរាជាសព្វទត្ត អនុញ្ញាត ( ឲ្យបួសហើយ ) ។

[ ៨៦០ ] ព្រះរាជកុមារណានៅក្មេង មានសម្បុរផ្ទឹមនឹងមាស ប្រសើរបំផុតជាងព្រះរាជបុត្ត ១០០០ ព្រះរាជកុមារនោះ ជាអ្នកមានកម្លាំង ស្លៀកសំពត់កាសាយៈបួសហើយ ។

[ ៨៦១ ] ( ព្រះសាស្តា ... ) កុមារទាំងពីរអង្គ គឺយុធញ្ជ័យ ១ យុធិដ្ឋិលៈ ១ លះបង់នូវព្រះមាតានិងព្រះបិតា ផ្តាច់ចោលនូវគ្រឿងជាប់ជំពាក់ របស់មច្ចុមារបួសហើយ ។

## យុធញ្ជយជាតកទី ៦ ចប់

# អដ្ឋកថា

## យុធញ្ជយជាតក

[ ៨៥១-៨៦១ ] *ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការចេញមហាភិនេស្ក្រមណ៍ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា* **មិត្តាមច្ចបរិព្យូឡ្ហំ** *ដូច្នេះជាដើម ។*

*សេចក្តីពិស្តារថា ថ្ងៃមួយ ភិក្ខុទាំងឡាយប្រជុំគ្នាក្នុងធម្មសភា ពោលនូវពាក្យសរសើរគុណរបស់ព្រះសាស្តាថា អាវុសោទាំងឡាយ បើព្រះទសពលគប់គ្រងផ្ទះសោត ក៏បានជាស្តេចចក្រពត្តិក្នុងផ្ទៃចក្កវាឡ មានរតនៈ ៧ ប្រការគ្រប់គ្រាន់ ទ្រទ្រង់នូវឫទ្ធិទាំង ៤ មានព្រះឱរសជាងមួយពាន់ជាបរិវារ ទ្រង់លះរាជសម្បត្តិដ៏មានសិរីបែបនេះ ទ្រង់ឃើញទោសក្នុងកាមទាំងឡាយ ទ្រង់ផែលសេះកណ្ឋកៈ មាននាយឆន្នជាសម្លាញ់ ចេញអំពីនគរក្នុងវេលាកណ្តាលយប់ ទ្រង់បួសត្រង់ស្ទឹងឈ្មោះអនោមា ទ្រង់បំពេញទុក្ករកិរិយា អស់ ៦ វស្សា ទើបទ្រង់សម្រេចសម្មាសម្ពោធិញ្ញាណបានដូចបំណង ។ ព្រះសាស្តាយាងមកហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អំបាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ កាលភិក្ខុទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលតថាគតយាងចេញមហាភិនេស្ក្រមណ៍ សូម្បីក្នុងកាលមុន ក៏ធ្លាប់លះរាជសម្បត្តិ ក្នុងនគរពារាណសី ដែលមានប្រមាណ ១២ យោជន៍ ចេញបួសហើយដូចគ្នាដូច្នេះហើយ ទើបទ្រង់នាំអតីតនិទានមកសាធកៈដូចតទៅ*

ក្នុងអតីតកាល ព្រះរាជាមួយអង្គព្រះនាមសព្វទត្តៈ ក្នុងនគររម្មៈ ។ ពិតហើយ ក្រុងពារាណសីនេះ ក្នុងឧទយជាតក មានឈ្មោះថា **សុរុន្ធនៈ** ក្នុងចុល្លសុត្តសោមជាតក មានឈ្មោះថា **សុទស្សនៈ** ក្នុងសោណនន្ទជាតក មានឈ្មោះថា **ព្រហ្មវឌ្ឍនៈ** ក្នុងកណ្ហាលជាតក ( ចន្ទកុមារជាតក ) មានឈ្មោះថា **បុប្ផវតី** តែក្នុងយុធញ្ជយជាតកនេះ មានឈ្មោះថា **រម្មៈ** នាមរបស់ព្រះនគរនេះ បានប្រែប្រួលទៅក្នុងកាលខ្លះ ដោយប្រការដូច្នេះ ។ ក្នុងនគររម្មៈនោះ ព្រះបាទសព្វទត្តៈមានព្រះរាជបុត្រមួយពាន់អង្គ ទ្រង់ព្រះរាជទានស្ថាបនាព្រះរាជបុត្រច្បង ព្រះនាមយុធញ្ជយៈជាព្រះឧបរាជ ។ ឧបរាជនោះបានបំពេញមហាទានរាល់ៗ ថ្ងៃ ក្នុងកាលកន្លងទៅយ៉ាងនេះ ថ្ងៃមួយ ព្រះពោធិសត្វ ទ្រង់រថដ៏ប្រសើរអំពីព្រលឹម ទ្រង់យាងទៅកាន់កីឡាក្នុងព្រះរាជឧទ្យានដោយព្រះសិរីសម្បត្តិដ៏ធំ ទតឃើញតំណក់ទឹកសន្សើម ដែលជាប់នៅដូចសំណាញ់ ដែលធ្វើដោយសរសៃអំបោះក្នុងទីផ្សេងៗ មានត្រួយឈើ ត្រួយស្មៅ ចុងមែកឈើ និងត្រង់សរសៃពីងពាងជាដើម ទើបត្រាស់សួរថា នែសារថីសម្លាញ់ នេះហៅថាអ្វី ទ្រង់បានស្តាប់ថា បពិត្រព្រះអង្គ នេះគេហៅទឹកសន្សើមដែលធ្លាក់ក្នុងរដូវសន្សើមធ្លាក់ ទ្រង់លេងក្នុងព្រះរាជឧទ្យានអស់មួយថ្ងៃ យាងត្រឡប់ក្នុងពេលល្ងាច មិនបានឃើញតំណក់ទឹកសន្សើមទាំងនោះឡើយ ក៏ត្រាស់សួរថា នែសារថីសម្លាញ់ តំណក់ទឹកសន្សើមទាំងនេះទៅណាអស់ហើយ ឥឡូវនេះ ខ្ញុំមិនឃើញវាឡើយ ទ្រង់បានស្តាប់ថា បពិត្រព្រះអង្គ តំណក់ទឹកសន្សើមទាំងនេះ កាលព្រះអាទិត្យរះឡើង ក៏ធ្លាក់ចុះកាន់

ផែនដីអស់រលីង ដូច្នេះហើយ ទ្រង់សង្វេគ ត្រិះរិះថា ជីវិត និងសង្ខារនៃសត្វទាំងនេះ ក៏ដូចគ្នានឹងតំណក់ទឹកសន្សើមលើចុងស្មៅ យើងនៅមិនទាន់ត្រូវជរា ព្យាធិ មរណៈបៀតបៀន គួរលាព្រះមាតា ព្រះបិតាបួស ដូច្នេះហើយ ទើបទ្រង់ធ្វើតំណក់ទឹកសន្សើមនោះឯងឲ្យជាអារម្មណ៍ ទ្រង់ឃើញភពទាំង ៣ ដូចភ្លើងឆេះទូទៅ យាងមកដល់ព្រះដំណាក់របស់ទ្រង់ហើយ ទ្រង់យាងទៅកាន់ព្រះដំណាក់ព្រះរាជបិតា ដែលប្រថាប់គង់ក្នុងសាលាវិនិច្ឆ័យដែលប្រដាប់តាក់តែងល្អហើយ ថ្វាយបង្គំព្រះរាជបិតា ប្រថាប់ឈរក្នុងចំណែកម្ខាង កាលទូលសូមអនុញ្ញាតបព្វជ្ជា ទើបត្រាស់គាថាទី ១ ថា

បពិត្រព្រះរាជា ជាធំក្នុងរថ ខ្ញុំព្រះអង្គសូមថ្វាយបង្គំ ( ព្រះអង្គ )
ដែលមិត្ត និងអាមាត្យចោមរោមហើយ ខ្ញុំព្រះអង្គនឹងបួស សូម
ព្រះសម្មតិទេព អនុញ្ញាតផ្នួសនោះ ( ដល់ខ្ញុំព្រះអង្គ ) ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បរិព្យូឡ្ហំ** បានដល់ ចោមរោមហើយ ។ បទថា **តំ មេរាជា** សេចក្ដីថា សូមទ្រង់អនុញ្ញាតការបួសដល់ខ្ញុំចុះ ។

លំដាប់នោះ ព្រះរាជា កាលទ្រង់ហាម ទើបត្រាស់គាថាទី ២ ថា

បើកូនឯងខ្វះកាមទាំងឡាយ ឪពុកនឹងបំពេញ ឲ្យគ្រប់គ្រាន់ដល់
អ្នក បុគ្គលណា បៀតបៀនអ្នក ឪពុកនឹងឃាត់ ( បុគ្គលនោះ )
ម្នាលយុធញ្ជ័យ អ្នកកុំបួសឡើយ ដូច្នេះ ។

ព្រះរាជកុមារ បានស្ដាប់ព្រះរាជតម្រាស់នោះហើយ ទើបត្រាស់គាថាទី ៣ ថា

ខ្ញុំព្រះអង្គ មិនមានសេចក្ដីខ្វះកាមទាំងឡាយទេ បុគ្គលទីមួយបៀតបៀននូវខ្ញុំព្រះអង្គ ក៏មិនមានដែរ តែថា ខ្ញុំព្រះអង្គប្រាថ្នានឹងធ្វើនូវទីពឹង ( ដល់ខ្លួន ) ដែលជរាកម្ចាត់បង់មិនបាន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឱបញ្ញ** សេចក្ដីថា បពិត្រព្រះអង្គ ការខ្វះខាតនូវកាមទាំងឡាយរបស់ទូលបង្គំមិនមានឡើយ បុគ្គលណាម្នាក់ដែលបៀតបៀនទូលបង្គំសោតក៏មិនមាន តែទូលបង្គំប្រាថ្នាធ្វើនូវទីពឹងរបស់ទូលបង្គំដើម្បីទៅកាន់បរលោក ។ បទថា **យំ ជរា នាភិ កីរតិ** សេចក្ដីថា ព្រះរាជកុមារត្រាស់ថា ខ្ញុំប្រាថ្នានឹងធ្វើកោះដែលជរាគ្របសង្កត់មិនបាន និងកម្ចាត់មិនបាន គឺស្វែងរកអមតមហានិព្វាន ខ្ញុំមិនត្រូវការដោយកាមទាំងឡាយឡើយ បពិត្រមហារាជ សូមទ្រង់អនុញ្ញាតដល់ទូលបង្គំចុះ ។

ព្រះរាជកុមារទូលសូមបព្វជ្ជារឿយៗ ដោយប្រការដូច្នេះ ។ ព្រះរាជាត្រាស់ឃាត់ថា នែបា ចូរបាកុំបួសឡើយ ។

ព្រះសាស្ដា កាលទ្រង់ប្រកាសសេចក្ដីនោះ ទើបត្រាស់កន្លះគាថាថា

បុត្តអង្វរនូវបិតា បិតាក៏អង្វរនូវបុត្តឱរសដែរ ដូច្នេះ ។

**វា** អក្ខរៈ ក្នុងព្រះគាថានោះ ជាសម្បិណ្ឌនត្ថៈ គឺមានការប្រមូលមកជាអត្ថ ។ សេចក្ដីនេះមានពុទ្ធាធិប្បាយថា ម្នាលភិក្ខុទាំងឡាយ ព្រះឱរសក៏អង្វរព្រះរាជបិតា ព្រះរាជបិតាក៏អង្វរព្រះរាជឱរស ។ ព្រះរាជាត្រាស់កន្លះគាថាដ៏សេសថា

ព្រះរាជាទ្រង់ត្រាស់ថា ម្នាលកូន ជនអ្នកនៅក្នុងនិគម អង្វរអ្នក ម្នាលយុធញ្ជ័យ អ្នកកុំបួសឡើយ ដូច្នេះ ។

ពាក្យដែលជាគាថានោះ មានអធិប្បាយថា នែបា មហាជន អ្នកនិគមនេះនាំគ្នាអង្វរកូន សូម្បីអ្នកនគរក៏នាំគ្នាអង្វរកូនដូចគ្នា សូមកូនកុំបួសឡើយ ។

ព្រះរាជកុមារត្រាស់គាថាទី ៥ ថា

បពិត្រព្រះបិតាជាធំក្នុងរថ សូមព្រះអង្គកុំឃាត់ផ្លូវខ្ញុំព្រះអង្គនោះ
កុំឲ្យខ្ញុំព្រះអង្គពោរពេញដោយកាមទាំងឡាយ ឲ្យលុះក្នុងអំណាច
ជរាឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វសមន្វគូ** សេចក្តីថា ខ្ញុំកុំជាមនុស្សលិចលង់ក្នុងកាមទាំងឡាយ បានឈ្មោះថា ដើរទៅកាន់អំណាចនៃជរាឡើយ អធិប្បាយថា សូមទ្រង់ទតខ្ញុំដោយឋានៈ ដែលជាអ្នកនៅក្នុងវដ្តទុក្ខឲ្យអស់ទៅហើយ ត្រាស់ដឹងនូវសព្វញ្ញុតញ្ញាណចុះ ។

កាលព្រះពោធិសត្វបានក្រាបទូលយ៉ាងនេះហើយ ព្រះរាជាទ្រង់បានយល់ព្រម ចំណែកព្រះរាជមាតារបស់ព្រះពោធិសត្វនោះ ព្រះនាងបានឮថា ព្រះឱរសរបស់ព្រះនាង កំពុងក្រាបទូលឲ្យព្រះបិតាទ្រង់អនុញ្ញាតដើម្បីបួស ព្រះនាងត្រាស់ថា ពួកឯងនាំគ្នានិយាយរឿងអ្វី ទាំងដែលព្រះកក្រ្គមិនបានតាក់តែងប្រថាប់គង់លើវមាស ប្រញាប់ទៅកាន់ទីវិនិច្ឆ័យដើម្បីអង្វរ ទើបត្រាស់គាថាទី ៦ ថា

ម្នាលកូន យើងសូមអង្វរអ្នក ម្នាលកូន យើងសូមឃាត់អ្នក យើងចង់ឃើញអ្នកអស់កាលយូរ ម្នាលយុធញ្ជ័យ ចូរអ្នកកុំបួសឡើយ ដូច្នេះ ។

ព្រះរាជកុមារបានស្ដាប់ព្រះសវនីយ៍នោះហើយ ទើបត្រាស់គាថាទី ៧ ថា

ទឹកសន្សើមលើចុងស្មៅ តែងធ្លាក់ចុះ ( លើផែនដី ) ក្នុងកាលព្រះអាទិត្យរះឡើង យ៉ាងណាមិញ អាយុរបស់មនុស្សទាំងឡាយ ក៏យ៉ាងនោះដែរ បពិត្រព្រះមាតា សូមព្រះមាតាកុំឃាត់ខ្ញុំឡើយ ដូច្នេះ ។

ពាក្យដែលជាគាថានោះ មានអធិប្បាយថា បពិត្រព្រះមាតា ដំណក់ទឹកសន្សើមលើស្មៅ លុះព្រះអាទិត្យរះឡើងក៏ស្ងួតទៅ មិនអាចតាំងនៅបាន គឺធ្លាក់ចុះត្រង់ផែនដី យ៉ាងណា ជីវិតរបស់ពួកសត្វទាំងនោះក៏ដូច្នោះ ជារបស់បន្តិចបន្តួច ប្រព្រឹត្តទៅមួយជួរខណៈ មិនបានតាំងនៅយូរឡើយ ក្នុងលោកសន្និវាសបែបនេះ ទ្រង់នឹងឃើញទូលបង្គំអស់កាលយូរបានដូចម្ដេច សូមទ្រង់កុំឃាត់ទូលបង្គំឡើយ ។

កាលព្រះពោធិសត្វក្រាបទូលយ៉ាងនេះហើយ ព្រះនាងក៏ត្រាស់អង្វរហើយអង្វរទៀតនោះឯង ។ លំដាប់នោះ ព្រះមហាសត្វកាលក្រាបទូលដាស់តឿនព្រះរាជបិតា ទើបត្រាស់គាថាទី ៨ ថា

បពិត្រព្រះបិតាជាធំក្នុងរថ សូមឲ្យ ( បុរស ) ចម្លង ព្រះមាតា ( របស់ខ្ញុំព្រះអង្គ ) ឲ្យឡើងកាន់ព្រះរាជយាននេះ កុំឲ្យព្រះមាតា

ធ្វើនូវសេចក្តីអន្តរាយ ដល់ខ្ញុំព្រះអង្គ ដែលកំពុងធ្វើង ដូច្នេះ ។

ពាក្យដែលជាគាថានោះ មានអធិប្បាយថា បពិត្រព្រះអង្គជាធំជាងរថ សូមទ្រង់ត្រាស់ឲ្យមនុស្សប្រញាប់យាងមាតារបស់ទូលបង្គំនេះ លើកឡើងកាន់យាន គឺវមាស ព្រះមាតាកុំធ្វើអន្តរាយដល់ទូលបង្គំ ដែលកំពុងឈានកន្លងកន្តារ គឺជាតិ ជរា ព្យាធិ និងមរណៈឡើយ ។

ព្រះរាជាបានស្តាប់ព្រះតម្រាស់ព្រះឱរសហើយ ត្រាស់ថា នែនាងដ៏ចម្រើន សូមនាងទៅចុះ ចូរប្រថាប់គង់លើវមាសរបស់នាង ឡើងកាន់ប្រាសាទដែលញុំាំងសេចក្តីត្រេកអរឲ្យចម្រើនចុះ ព្រះនាងស្តាប់ព្រះតម្រាស់របស់ព្រះរាជានោះ កាលមិនអាចប្រថាប់នៅបាន ទ្រង់ចោមរោមទៅដោយពួកនារី ទៅកាន់ប្រាសាទ បានប្រថាប់ឈរទតទីវិនិច្ឆ័យដោយបំណងថា កូនជាទីស្រឡាញ់នឹងប្រព្រឹត្តទៅដូចម្តេចហ្ន៎ ។ ចំណែកព្រះពោធិសត្វ កាលព្រះមាតាយាងទៅហើយ ទ្រង់អង្វរព្រះរាជបិតាទៀត ព្រះរាជាកាលទ្រង់មិនអាចឃាត់បាន ទ្រង់អនុញ្ញាតថា នែបា បើដូច្នេះ ចូរធ្វើចិត្តរបស់អ្នកឲ្យដល់ទីបំផុតចុះ ចូរបាបួសចុះ ។ ក្នុងកាលដែលព្រះរាជាទ្រង់អនុញ្ញាតហើយ ព្រះកនិដ្ឋារបស់ព្រះពោធិសត្វព្រះនាមយុធិដ្ឋិលកុមារ ថ្វាយបង្គំព្រះរាជបិតា ក្រាបទូលសូមអនុញ្ញាតថា បពិត្រព្រះអង្គ សូមទ្រង់អនុញ្ញាតការបួសដល់ខ្ញុំផងចុះ ។ បងប្អូនទាំងពីរថ្វាយបង្គំព្រះរាជបិតា លះនូវកាមទាំងឡាយ មានមហាជនចោមរោម នាំគ្នាចេញអំពីទីវិនិច្ឆ័យ ។ ចំណែកព្រះទេវីទតមើលព្រះមហាសត្វ ទ្រង់ព្រះកន្សែងថា កាលកូនខ្ញុំបួសហើយ រម្មនគរក៏នឹងទទេ ទើបត្រាស់ ២ គាថាថា

នាងទាំងឡាយចូរស្ទុះទៅ សេចក្ដីចម្រើន ( នឹងមាន ) ដល់នាង
នគររម្មកៈមុខជានឹងសូន្យ ( ព្រោះថា ) យុធញ្ជយកុមារ
ព្រះរាជាសព្វទត្ត អនុញ្ញាត ( ឲ្យបួសហើយ ) ។
ព្រះរាជកុមារណា នៅក្មេង មានសម្បុរផ្ទឹមនឹងមាស ប្រសើរ
បំផុតជាងព្រះរាជបុត្ត ១០០០ ព្រះរាជកុមារនោះ ជាអ្នកមាន
កម្លាំង ស្លៀកសំពត់កាសាយៈបួសហើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អភិធាវថ** សេចក្ដីថា ព្រះនាងត្រាស់បញ្ជាពួកនារី ដែលឈរចោមរោមទាំងអស់គ្នាថា នែនាងទាំងឡាយ ចូរនាងទាំងឡាយប្រញាប់ស្ទុះទៅចុះ ។ ដោយបទថា **ភទ្ទន្តេ** ព្រះនាងត្រាស់ថា សេចក្ដីចម្រើនព្រោះការទៅយ៉ាងនោះ ចូរមានដល់នាងចុះ ។ បទថា **រម្មកំ** ព្រះនាងត្រាស់សំដៅដល់រម្មនគរ ។ បទថា **យោធា សេដ្ឋោ** សេចក្ដីថា ព្រះឱរសរបស់ព្រះរាជា ប្រសើរជាងព្រះឱរសទាំងមួយពាន់នោះ ទ្រង់បួសហើយ ដូច្នេះ ព្រះនាងត្រាស់សំដៅដល់ព្រះមហាសត្វ ដែលកំពុងយាងទៅ ដើម្បីទ្រង់ផ្នួស ដោយប្រការដូច្នេះ ។

ចំណែកព្រះពោធិសត្វ ទ្រង់មិនទាន់ផ្នួសក្លាមនោះឡើយ ទ្រង់ថ្វាយបង្គំព្រះមាតា ព្រះបិតាហើយ ទ្រង់បបួលព្រះកនិដ្ឋាយុធិដ្ឋិលកុមារ យាងចេញអំពីព្រះនគរ ឲ្យមហាជននាំគ្នាត្រឡប់ទៅហើយ បងប្អូនទាំងពីរអង្គ យាងទៅកាន់ព្រៃហិមពាន្ត ទ្រង់សាងអាស្រមក្នុងទីដែលគួរត្រេកអរ ទ្រង់បួសជាឥសី ធ្វើឈាន និងអភិញ្ញាឲ្យកើតបានហើយ ចិញ្ចឹមជីវិតដោយផ្លែឈើ ឫសឈើ

ក្នុងព្រៃជាដើម រហូតដល់អស់ជន្មាយុ មានព្រហ្មលោកជាទីទៅខាងមុខ ។ ព្រះសាស្ដា កាលទ្រង់ប្រកាសសេចក្ដីនោះ ទើបត្រាស់ព្រះគាថាចុងក្រោយថា

កុមារទាំងពីរអង្គ គឺយុធញ្ជ័យ ១ យុធិដ្ឋិលៈ ១ លះបង់នូវព្រះមាតា និងព្រះបិតា ផ្ដាច់ចោលនូវគ្រឿងជាប់ជំពាក់របស់មច្ចុមារ បួសហើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **មច្ចុនោ** បានដល់ នៃមារ ។ មានពុទ្ធាធិប្បាយថា ម្នាលភិក្ខុទាំងឡាយ ព្រះរាជកុមារទាំងពីរអង្គនោះ មានយុធញ្ជ័យ និងយុធិដ្ឋិលៈ ទ្រង់លះព្រះរាជមាតា និងព្រះរាជបិតា កាត់នូវគ្រឿងជាប់ជំពាក់របស់មារ គឺកិលេសជាគ្រឿងជាប់ជំពាក់ បានដល់ រាគៈ ទោសៈ និងមោហៈ នាំគ្នាបួសហើយ ។

ព្រះសាស្ដា កាលទ្រង់នាំយកព្រះធម្មទេសនានេះ មកសម្ដែងហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន តថាគតក៏ធ្លាប់លះរាជសម្បត្តិ ហើយចេញបួសដូចគ្នា ដូច្នេះហើយ ទើបទ្រង់ប្រជុំជាតកថា ព្រះរាជមាតាព្រះរាជបិតាក្នុងកាលនោះ បានមកជាត្រកូលមហារាជក្នុងកាលឥឡូវនេះ យុធិដ្ឋិលកុមារក្នុងកាលនោះ បានមកជាអានន្ទ យុធញ្ជ័យក្នុងកាលនោះ គឺតថាគតនេះឯង ៕៚

**អដ្ឋកថា យុធញ្ជយជាតក ចប់**

# សុត្តន្តបិដក

## ទសរថជាតក

[ ៨៦២ ] ( រាមបណ្ឌិតកុមារ បានពោលថា ) ម្នាលលក្ខណៈ និងនាងសីតា អ្នកទាំងឡាយចូរមក អ្នកទាំង ២ នាក់ចូរចុះទឹក ភរតកុមារ បាននិយាយយ៉ាងនេះថា ព្រះបាទទសរថ ទ្រង់ទិវង្គត ហើយ ។

[ ៨៦៣ ] ( ភរតកុមារ ... ) បពិត្រព្រះរាមៈ ដោយអានុភាព អ្វី ទើបទ្រង់បានឮថា ព្រះបិតាទិវង្គតហើយ មិនសោកស្តាយ របស់ដែលគួរសោកស្តាយ សេចក្តីទុក្ខមិនគ្របសង្កត់ទ្រង់ ។

[ ៨៦៤ ] ( រាមបណ្ឌិតកុមារ ... ) ជីវិតណា ( របស់ពួក សត្វ ) បណ្តាពួកបុរសដែលរវើរវាយ បុរស ( សូម្បីតែម្នាក់ ) ក៏មិនអាចដើម្បីរក្សាជីវិតច្រើននោះបានទេ វិញ្ញូជនជាមេធាវីនោះ ធ្វើខ្លួនឲ្យក្តៅក្រហាយដើម្បីអ្វី ។

[ ៨៦៥ ] សេចក្តីពិតថា ជនទាំងឡាយណា ទាំងក្មេង ទាំង ចាស់ ទាំងល្ងង់ ទាំងប្រាជ្ញ ទាំងអ្នកមាន ទាំងអ្នកក្រ ជនទាំង អស់នោះ សុទ្ធតែមានសេចក្តីស្លាប់នៅខាងមុខ ។

[ ៨៦៦ ] ផ្លែឈើទុំទាំងឡាយ មានសេចក្តីខ្លាច អំពីកិរិយាជ្រុះ ជានិច្ច យ៉ាងណាមិញ ពួកសត្វកើតហើយ ក៏មានសេចក្តីខ្លាច អំពីសេចក្តីស្លាប់ជានិច្ច យ៉ាងនោះដែរ ។

[ ៨៦៧ ] ជនទាំងឡាយច្រើនពួកខ្លះ គេឃើញក្នុងវេលាព្រឹក វេលាល្ងាចមិនឃើញ ជនទាំងឡាយច្រើនពួកខ្លះ គេឃើញក្នុងវេលាល្ងាច វេលាព្រឹកមិនឃើញ ។

[ ៨៦៨ ] បើបុគ្គលអ្នកវង្វេង កាលខ្សឹកខ្សួល បៀតបៀនខ្លួន ហើយគប្បីនាំមកនូវប្រយោជន៍ បន្តិចបន្តួចបាន អ្នកប្រាជ្ញក៏គប្បីធ្វើសេចក្តីខ្សឹកខ្សួលនោះដែរ ។

[ ៨៦៩ ] ( បុគ្គលខ្សឹកខ្សួល ) បៀតបៀនខ្លួនរបស់ខ្លួន ជាអ្នកស្គម មិនមានពណ៌សម្បុរ ពួកសត្វដែលទៅកាន់បរលោក មិនមែនញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយសេចក្តីខ្សឹកខ្សួលនោះឡើយ ព្រោះថា សេចក្តីខ្សឹកខ្សួល មិនមានប្រយោជន៍ទេ ។

[ ៨៧០ ] ( បណ្ឌិតបុរស ) គប្បីញុំាងផ្ទះ ដែលភ្លើងឆេះឲ្យរលត់ ដោយទឹកបាន យ៉ាងណាមិញ ធីរជនជាមេធាវីបណ្ឌិត បានស្តាប់ហើយ គប្បីញុំាងសេចក្តីសោក ដែលកើតហើយ ឲ្យរលត់ឆាប់ ដូចខ្យល់បក់ផាត់នូវប៉ុយ យ៉ាងនោះដែរ ។

[ ៨៧១ ] សត្វរមែងទៅកាន់បរលោកតែម្នាក់ឯង កើតក្នុងត្រកូលក៏តែម្នាក់ឯង ការសមគប់នៃពួកសត្វទាំងអស់ គឺមានការជួបជុំ ជាការប្រសើរបំផុត ។

[ ៨៧២ ] ព្រោះហេតុនោះ សេចក្តីសោកទាំងឡាយ សូម្បីធំក៏មិនដុតកម្តៅនូវហទយវត្ថុ និងចិត្តរបស់អ្នកប្រាជ្ញ ជាពហុស្សូត

ដែលឃើញច្បាស់នូវលោកនេះ និងលោកខាងមុខ ព្រោះដឹងច្បាស់នូវធម៌ ។

[ ៨៧៣ ] ឃើងនោះ នឹងរក្សានូវយសផង ភោគៈផង ភរិយាទាំងឡាយផង ញាតិទាំងឡាយផង និងជនដ៏សេសផង នេះជាកិច្ចរបស់អ្នកប្រាជ្ញ ។

[ ៨៧៤ ] ( ព្រះសាស្តាទ្រង់ត្រាស់ថា ) ព្រះបាទរាមៈ មានព្រះសូរងដូចជារូបសំណាកមាស មានព្រះពាហុធំ បានសោយរាជ្យអស់ ១៦០០០ ឆ្នាំ ។

**ទសរថជាតកទី ៧ ចប់**

# អដ្ឋកថា

## ទសរថជាតក

[ ៨៦២-៨៧៤ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធកុដុម្ពិកៈដែលមានបិតាស្លាប់ម្នាក់ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ឯថ លក្ខណាសីតា ច** ដូច្នេះជាដើម ។

សេចក្តីពិស្តារថា កុដុម្ពិកៈនោះកាលបិតាស្លាប់ហើយ ត្រូវសេចក្តីសោកគ្របសង្កត់ ទើបបោះបង់ការងារគ្រប់យ៉ាង គិតតែសោយសោកតែម្យ៉ាងប៉ុណ្ណោះ ។ ព្រះសាស្តា ទ្រង់ប្រមើលមើលសត្វលោកក្នុងពេលទៀបភ្លឺ ទតឃើញឧបនិស្ស័យនៃសោតាបត្តិផលរបស់បុរសនោះ ស្អែកឡើង ទើបយាងប្រោសសត្វក្នុងក្រុងសាវត្ថី សោយព្រះក្រយាហារស្រេចហើយ ទ្រង់បញ្ជូនភិក្ខុទាំងឡាយត្រឡប់ ទ្រង់បបួលជាបច្ឆាសមណៈត្រឹមតែមួយរូប យាងទៅកាន់ផ្ទះរបស់កុដុម្ពិកៈ កាលកុដុម្ពិកៈនោះថ្វាយបង្គំហើយ ទើបព្រះសាស្តាត្រាស់ដោយព្រះតម្រាស់ដ៏ពីរោះថា ម្នាលឧបាសក អ្នកសោយសោកព្រោះហេតុអ្វី កាលបុរសនោះក្រាបទូលថា បពិត្រព្រះអង្គ សេចក្តីសោយសោកដល់បិតាដ៏មានកម្លាំងបៀតបៀនខ្ញុំព្រះអង្គ ទើបព្រះសាស្តាត្រាស់ថា ម្នាលឧបាសក បណ្ឌិតក្នុងកាលមុន ជ្រាបលោកធម៌ ៨ ប្រការតាមសេចក្តីពិតកាលបិតាអនិច្ចកម្មហើយ ក៏មិនបានជួបសេចក្តីសោកតិចតួចឡើយ កាលកុដុម្ពិកៈអារាធនា ទើបទ្រង់នាំអតីតនិទានមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទទសរថមហារាជ ទ្រង់លះការដល់នូវអគតិ សោយរាជសម្បត្តិដោយធម៌ក្នុងនគរពារាណសី អគ្គមហេសីជាធំជាងស្ត្រី ១ ម៉ឺន

៦ ពាន់ របស់ព្រះរាជា ប្រសូតព្រះឱរសពីរអង្គ ព្រះរាជធីតា ១ អង្គ ព្រះឱរសធំរបស់ទ្រង់ព្រះនាមរាមបណ្ឌិត ព្រះរាជអនុជព្រះនាមលក្ខណកុមារ ព្រះរាជធីតាមួយអង្គព្រះនាមសិតាទេវី ។ ចំណេរកាលតមក អគ្គមហេសីអស់ព្រះជន្ម ព្រះរាជាកាលព្រះនាងអស់ព្រះជន្មហើយ ទ្រង់ដល់នូវអំណាចនៃសេចក្ដីសោកអស់កាលយូរ ពួកអមាត្យនាំគ្នាក្រាបទូលឲ្យទ្រង់ស្វាង ធ្វើនូវការបរិហារ ដែលគួរធ្វើដល់ព្រះនាងហើយ ទ្រង់តាំងស្ត្រីដទៃក្នុងតំណែងអគ្គមហេសី ព្រះនាងជាទីស្រឡាញ់ ដែលជាទីចម្រើនព្រះរាជហឫទ័យរបស់ព្រះរាជាក្នុងកាលតមក ព្រះនាងក៏ទ្រង់ព្រះគភ៌ ទ្រង់បានទទួលព្រះរាជទានគ្រឿងគព្ភបរិហារ ទើបប្រសូតព្រះរាជឱរស ។ ពួកញាតិថ្វាយព្រះនាមព្រះរាជឱរសនោះថា **ភរតកុមារ** ។

ព្រះរាជាត្រាស់ដោយសេចក្ដីស្រឡាញ់ក្នុងព្រះរាជឱរសថា នែនាងដ៏ចម្រើន យើងសូមឲ្យពរដល់នាង ចូរនាងទទួលចុះ ។ ព្រះនាងទ្រង់ទទួលពរទុក រហូតព្រះរាជកុមារមានព្រះជន្មបាន ៧-៨ វស្សា ទើបចូលទៅគាល់ព្រះរាជា ក្រាបទូលថា បពិត្រព្រះអង្គ ទ្រង់ព្រះរាជទានពរដល់បុត្ររបស់ខ្ញុំម្ចាស់ ឥឡូវនេះ សូមទ្រង់មេត្តាព្រះរាជទានពរនោះដល់កុមារ កាលព្រះរាជាទទួលថា យកចុះ ទើបក្រាបទូលថា បពិត្រព្រះអង្គ សូមទ្រង់ព្រះរាជទានរាជសម្បត្តិដល់បុត្ររបស់ខ្ញុំម្ចាស់ចុះ ។ ព្រះរាជាទ្រង់ទះព្រះហស្ថសម្គុតថា ចូរនាងវិនាសចុះ ស្រីថោកទាប បុត្ររបស់យើងពីរអង្គ រុងរឿងដូចគំនរភ្លើង នាងឲ្យយើងសម្លាប់គេទាំងពីរហើយ សូមរាជសម្បត្តិឲ្យដល់កូនរបស់នាង ។

ព្រះនាងកិតភ័យ យាងចូលទៅកាន់ព្រះដំណាក់ដ៏មានសិរី ។ ក្នុងថ្ងៃដទៃៗ ក៏ទូលសូមរាជសម្បត្តិជាមួយព្រះរាជារឿយៗ នោះឯង ។ ព្រះរាជា កាលទ្រង់មិនព្រះរាជទានដល់ព្រះនាង ទើបទ្រង់ព្រះតម្រិះថា ឈ្មោះថាមាតុគ្រាម ជាអកតញ្ញូ ច្រើនដោយការទម្លាយមិត្រ ស្រីនេះគប្បីក្លែងសំបុត្រ ឬជួលបុគ្គលល្ងង់ខ្លៅសម្លាប់កូនទាំងពីររបស់យើងបាន ។ ទើបព្រះរាជាត្រាស់ឲ្យព្រះរាជ-ឱរសទាំងពីរចូលគាល់ ប្រាប់សេចក្តីនោះដោយព្រះតម្រាស់ថា នែបា អន្តរាយនឹងមានដល់បាទាំងឡាយដែលនៅក្នុងទីនេះ បាទាំងឡាយ ចូរនាំគ្នាទៅកាន់ដែននៃសាមន្តរាជ ឬនៅក្នុងព្រៃ ចូរនាំគ្នាមកកាលបិតាស្លាប់ហើយ ដណ្តើមយករាជសម្បត្តិរបស់ត្រកូលចុះ ត្រាស់ឲ្យពួកហោរាចារ្យ ចូលគាល់ទៀត ត្រាស់សួរកំណត់ព្រះជន្មាយុរបស់ទ្រង់ ទ្រង់បានឮថា នៅបាន ១២ ឆ្នាំទៅខាងមុខ ទើបត្រាស់ថា នែបា កន្លងទៅ ១២ ឆ្នាំបន្ទាប់អំពីនេះ ចូរពួកអ្នកនាំគ្នាមក ឲ្យមហាជនលើកស្វេតច្ឆត្រថ្វាយ ។ ព្រះរាជឱរសទាំងនោះក្រាបទូលថា សាធុ នាំគ្នាថ្វាយបង្គំព្រះរាជបិតា ទ្រង់ព្រះកន្សែង យាងចុះអំពីប្រាសាទ ។ ព្រះនាងសិតាទេវី ទ្រង់ព្រះតម្រិះថា អញក៏នឹងទៅជាមួយបងទាំងពីរ ថ្វាយបង្គំព្រះរាជបិតា ទ្រង់ព្រះកន្សែងយាងចេញទៅ ។ ក្សត្រទាំង ៣ អង្គនោះចោមរោមដោយពួកមហាជន ចេញអំពីព្រះនគរ ទ្រង់ឲ្យមហាជននាំគ្នាត្រឡប់ ហើយយាងទៅកាន់ហិមវន្តប្បទេសដោយលំដាប់ សាងអាស្រមក្នុងប្រទេសដែលមានទឹក និងមូលផលាផលសម្បូរ ទ្រង់ចិញ្ចឹមព្រះជន្មជីពដោយផលាផលនាំគ្នាប្រថាប់នៅហើយ ។ ចំណែកលក្ខណបណ្ឌិត និងព្រះនាងសិតា បាន

ទូលសូមព្រះរាមបណ្ឌិតឲ្យទទួលប្តេជ្ញាថា ទ្រង់តាំងនៅក្នុងឋានៈនៃព្រះរាជបិតា របស់ទូលបង្គំ ហេតុនោះ សូមទ្រង់ប្រថាប់ជាប្រចាំក្នុងអាស្រមបទប៉ុណ្ណោះចុះ ទូលបង្គំទាំងពីរ នឹងនាំផលាផលមកទំនុកបម្រុងទ្រង់ ។ ចាប់តាំងពីនោះមក រាមបណ្ឌិតប្រថាប់ជាប្រចាំក្នុងអាស្រមបទនោះប៉ុណ្ណោះ ។ ព្រះលក្ខណ-បណ្ឌិត និងព្រះនាងសិតា នាំគ្នារកផលាផលមកប្រណិបតិទ៍ទ្រង់ កាលក្សត្រទាំង ៣ អង្គនោះ ទ្រង់ចិញ្ចឹមជីវិតដោយផលាផលទាំងនេះ ព្រះបាទទសរថមហារាជ ទ្រង់សោយទិវង្គតក្នុងឆ្នាំទី ៩ ព្រោះទ្រង់សោកដល់ព្រះរាជឱរស ។ កាលថ្វាយព្រះភ្លើងព្រះបរមសពរបស់ព្រះបាទទសរថស្រេចហើយ ព្រះទេវីមានព្រះតម្រាស់ឲ្យពួកអមាត្យថ្វាយស្វេតច្ឆត្រដល់ភរតកុមារ ដែលជាឱរសរបស់ខ្លួន ។ តែពួកអមាត្យទូលថា ម្ចាស់របស់ស្វេតច្ឆត្រនៅក្នុងព្រៃ ដូច្នេះហើយ ទើបមិនព្រមថ្វាយ ។ ភរតកុមារត្រាស់ថា ខ្ញុំនឹងយាងរាមបណ្ឌិតដែលជាព្រះភាតាមកអំពីព្រៃ ឲ្យទ្រង់ច្ឆង់ស្វេតច្ឆត្រ ទ្រង់កាន់គ្រឿងរាជកកុធ-ភណ្ឌ ៥ យ៉ាង មួយអន្លើដោយចតុរង្គសេនា ដល់ទីប្រថាប់របស់រាមបណ្ឌិតនោះ បានតាំងបន្ទាយស្នាក់នៅក្នុងទីមិនឆ្ងាយ ចូលទៅកាន់អាស្រមបទជាមួយអមាត្យ ២-៣ នាក់ ក្នុងពេលដែលព្រះលក្ខណបណ្ឌិត និងព្រះនាងសិតាយាងទៅព្រៃ ចូលគាល់ព្រះរាមបណ្ឌិត ដែលប្រាសចាកសេចក្តីរង្កៀសប្រថាប់គង់យ៉ាងសប្បាយ ហាក់បីរូបបដិមាមាស ដែលគេតម្កល់ត្រង់ទ្វារអាស្រមបទ ថ្វាយបង្គំហើយ ប្រថាប់ឈរក្នុងទីសមគួរនាចំណែកម្ខាង ក្រាបទូលដំណឹងរបស់ព្រះរាជាហើយ ក៏ក្រាបចុះទៀបបាទជើងទាំងគូ ទ្រង់ព្រះកន្សែង

មួយអន្ទើដោយពួកអមាត្យ ។ ព្រះរាមបណ្ឌិត មិនបានសោយសោកឡើយ មិនបានព្រះកន្សែងឡើយ សូម្បីត្រឹមតែការខុសប្រក្រតីនៃឥន្ទ្រិយ ក៏មិនមានដល់ទ្រង់ក្នុងកាលដែលព្រះភរតៈទ្រង់ព្រះកន្សែងប្រថាប់គង់ជាពេលសាយណ្ហ-សម័យ ព្រះលក្ខណបណ្ឌិត និងព្រះនាងសិតាទាំងពីរអង្គ ទ្រង់នាំគ្នាកាន់ផលាផលយាងមកដល់ ព្រះរាមបណ្ឌិតទ្រង់ព្រះតម្រិះថា លក្ខណៈ និងសិតានៅតូច មិនមានបញ្ញាកំណត់ដូចអាត្មាអញ បានដំណឹងថា បិតាសោយទិវង្គតហើយដោយរហ័ស នឹងមិនអាចទប់នូវសេចក្ដីសោកបាន សូម្បីបេះដូងក៏អាចបែកទៅបាន អញត្រូវប្រើឧបាយឲ្យលក្ខណៈ និងសិតាចុះទៅត្រាំទឹក ហើយទើបឲ្យស្ដាប់ដំណឹងនោះ ។ លំដាប់នោះ ទ្រង់ចង្អុលថ្មុកទឹកមួយកន្លែង ខាងមុខនៃក្សត្រទាំងពីរអង្គនោះ ត្រាស់ថា ឯងទាំងពីរមកយឺត នេះជាទណ្ឌកម្មរបស់ឯង ចូរឯងចុះទៅឈរត្រាំទឹក ដូច្នេះហើយ ទើបត្រាស់កន្លះគាថាថា

ម្នាលលក្ខណៈ និងនាងសីតា អ្នកទាំងឡាយចូរមក អ្នកទាំង ២
នាក់ ចូរចុះទឹក ដូច្នេះ ។

ពាក្យដែលជាគាថានោះ មានអធិប្បាយថា នៃលក្ខណៈ និងសីតា ចូរនាំគ្នាមក ចូរចុះកាន់ទឹកទាំងពីរនាក់ ។

ព្រះលក្ខណៈ និងព្រះនាងសីតាទាំងពីរអង្គនោះ នាំគ្នាយាងចុះទៅប្រថាប់ឈរ ដោយព្រះតម្រាស់ត្រឹមតែម្ដងប៉ុណ្ណោះ ។ លំដាប់នោះ រាមបណ្ឌិតកាលទ្រង់ប្រាប់ដំណឹងនៃព្រះរាជបិតាដល់ក្សត្រទាំងពីរ ទើបត្រាស់កន្លះគាថាដ៏សេសថា

ភរតកុមារ បាននិយាយយ៉ាងនេះថា ព្រះបាទទសរថ ទ្រង់ទិវង្គត
ហើយ ដូច្នេះ ។

ព្រះលក្ខណៈ និងព្រះនាងសីតាទាំងពីរអង្គនោះ គ្រាន់តែបានឮថា ព្រះរាជបិតាសោយទិវង្គតប៉ុណ្ណោះ ក៏នាំគ្នាសន្លប់អស់ទៅ ។ រាមបណ្ឌិតត្រាស់ប្រាប់ដដែលទៀត ក៏នាំគ្នាសន្លប់ម្ដងទៀត ពួកអមាត្យនាំគ្នាត្រកងក្សត្រទាំងពីរអង្គ ដែលទ្រង់ដល់នូវវិសញ្ញីភាពអស់វារៈ ៣ ដង ដោយអាការយ៉ាងនេះ ឡើងអំពីទឹក ឲ្យប្រថាប់គង់លើគោក ។ កាលក្សត្រទាំងពីរ បាននូវអស្សាសបស្សាសៈហើយ ស្ដេចគ្រប់អង្គក៏ប្រថាប់គង់ខ្សឹកខ្សួលរឿយៗ ។ កាលនោះព្រះភរតកុមារទ្រង់ព្រះតម្រិះថា ព្រះភាតានៃយើង លក្ខណកុមារ និងព្រះភគិនីសីតាទេវីរបស់យើង ស្ដាប់ដំណឹងថា ព្រះបាទទសរថសោយទិវង្គតហើយ មិនអាចបញ្ឈប់សេចក្ដីសោកបាន តែរាមបណ្ឌិត មិនបានសោយសោក មិនបានខ្សឹកខ្សួលឡើយ អ្វីហ្ន៎ ជាហេតុនៃការមិនសោយសោករបស់ទ្រង់ នឹងសួរព្រះអង្គមើល ។ កាលភរតកុមារត្រាស់សួរ ទើបត្រាស់គាថាទី ២ ថា

បពិត្រព្រះរាមៈ ដោយអានុភាពអ្វី ទើបទ្រង់បានឮថា ព្រះបិតា
ទិវង្គតហើយ មិនសោកស្ដាយ របស់ដែលគួរសោកស្ដាយ
សេចក្ដីទុក្ខមិនគ្របសង្កត់ទ្រង់ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បភាវេន** ប្រែថា ដោយអានុភាព ។ បទថា **ន តំ បសហតេ ទុខំ** សេចក្ដីថា សេចក្ដីទុក្ខបែបនេះ ហេតុអ្វី ទើបមិនគ្របសង្កត់ព្រះជង្ឃាបាន អ្វីជាគ្រឿងហាមឃាត់មិនឲ្យបងសោយសោក សូម

ទ្រង់ប្រាប់ដល់ទូលបង្គំផង ។

លំដាប់នោះ រាមបណ្ឌិត កាលសម្តែងហេតុដែលមិនឲ្យទ្រង់សោយសោក ដល់ភរតកុមារនោះ ទើបត្រាស់ថា

ជីវិតណា ( របស់ពួកសត្វ ) បណ្តាពួកបុរសដែលរវើរវាយ
បុរស ( សូម្បីតែម្នាក់ ) ក៏មិនអាចដើម្បីរក្សាជីវិតច្រើននោះ
បានទេ វិញ្ញូជនជាមេធាវីនោះ ធ្វើខ្លួនឲ្យក្តៅក្រហាយដើម្បីអ្វី ។
សេចក្តីពិតថា ជនទាំងឡាយណា ទាំងក្មេង ទាំងចាស់ ទាំង
ល្ងង់ ទាំងប្រាជ្ញ ទាំងអ្នកមាន ទាំងអ្នកក្រ ជនទាំងអស់នោះ
សុទ្ធតែមានសេចក្តីស្លាប់នៅខាងមុខ ។
ផ្លែឈើទុំទាំងឡាយ មានសេចក្តីខ្លាច អំពីកិរិយាជ្រុះជានិច្ច
យ៉ាងណាមិញ ពួកសត្វកើតហើយ ក៏មានសេចក្តីខ្លាច អំពី
សេចក្តីស្លាប់ជានិច្ច យ៉ាងនោះដែរ ។
ជនទាំងឡាយច្រើនពួកខ្លះ គេឃើញក្នុងវេលាព្រឹក វេលាល្ងាច
មិនឃើញ ជនទាំងឡាយច្រើនពួកខ្លះ គេឃើញក្នុងវេលាល្ងាច
វេលាព្រឹកមិនឃើញ ។
បើបុគ្គលអ្នកវង្វេង កាលខ្សឹកខ្សួល បៀតបៀនខ្លួន ហើយគប្បី
នាំមកនូវប្រយោជន៍ បន្តិចបន្តួចបាន អ្នកប្រាជ្ញក៏គប្បីធ្វើសេចក្តី
ខ្សឹកខ្សួលនោះដែរ ។
( បុគ្គលខ្សឹកខ្សួល ) បៀតបៀនខ្លួនរបស់ខ្លួន ជាអ្នកស្គម មិន

មានពណ៌សម្បុរ ពួកសត្វដែលទៅកាន់បរលោក មិនមែន
ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយសេចក្តីខ្សឹកខ្សួលនោះឡើយ
ព្រោះថា សេចក្តីខ្សឹកខ្សួល មិនមានប្រយោជន៍ទេ ។

( បណ្ឌិតបុរស ) គប្បីញុំាងផ្ទះ ដែលភ្លើងឆេះ ឲ្យរលត់ដោយ
ទឹកបាន យ៉ាងណាមិញ ធីរជនជាមេធាវីបណ្ឌិត បានស្តាប់
ហើយ គប្បីញុំាងសេចក្តីសោក ដែលកើតហើយ ឲ្យរលត់ឆាប់
ដូចខ្យល់បក់ផាត់នូវប៉ុយ យ៉ាងនោះដែរ ។

សត្វរមែងទៅកាន់បរលោកតែម្នាក់ឯង កើតក្នុងត្រកូល ក៏តែ
ម្នាក់ឯង ការសមគប់នៃពួកសត្វទាំងអស់ គឺមានការជួបជុំជា
ការប្រសើរបំផុត ។

ព្រោះហេតុនោះ សេចក្តីសោកទាំងឡាយ សូម្បីធំ ក៏មិនដុត
កម្តៅនូវហទយវត្ថុ និងចិត្តរបស់អ្នកប្រាជ្ញ ជាពហុស្សូត ដែល
ឃើញច្បាស់នូវលោកនេះ និងលោកខាងមុខ ព្រោះដឹងច្បាស់
នូវធម៌ ។

យើងនោះ នឹងរក្សានូវយសផង ភោគៈផង ភរិយាទាំងឡាយផង
ញាតិទាំងឡាយផង និងជនដ៏សេសផង នេះជាកិច្ចរបស់អ្នក
ប្រាជ្ញ ដូច្នេះ ។

រាមបណ្ឌិត បានប្រកាសដល់អនិច្ចតាដោយ ៦ គាថា នេះ ។ បណ្តាបទ
ទាំងនោះ បទថា **ធាលេតុំ** បានដល់ ដើម្បីនឹងរក្សា ។ បទថា **លបតំ** បាន

ដល់ ជាអ្នករវើរវាយ លោកពោលពាក្យអធិប្បាយដូច្នេះថា នៃករត: ជីវិតរបស់សត្វទាំងឡាយ បណ្តាបុគ្គលដែលនាំគ្នាកន្ទក់កន្ទេញជាច្រើន សូម្បីតែម្នាក់ ក៏មិនអាចរក្សាទុកបានថា កុំដាច់ទៅឡើយ ឥឡូវនេះ បុគ្គលដូចជាយើងនេះ ដឹងនូវលោកធម៌ទាំង ៨ ប្រការ ដោយសេចក្តីពិត ឈ្មោះថាវិញ្ញូជនមានការមុតស្រួច ជាបណ្ឌិត ក្នុងកាលពួកសត្វដែលមានជីវិត មានសេចក្តីស្លាប់ជាទីបំផុត ស្លាប់ទៅហើយ គង់នឹងញុំាងខ្លួនឲ្យបូលទៅក្តៅក្រហាយដើម្បីអ្វី គឺហេតុអ្វី ទើបដុតខ្លួនឯងដោយសេចក្តីទុក្ខរបស់ខ្លួន ដែលមិនមានឧបការ: ។ គាថាថា **ឧហរា ៩** ជាដើម មានអធិប្បាយថា នៃបាករត: ឈ្មោះថា មច្ចុនេះ មិនមានខ្លាសចំពោះបុគ្គលកំលោះ ដូចជារូបមាស មានខត្តិយកុមារជាដើមឡើយ និងមិនបានខ្លាចក្រែងចំពោះមហាយោធាទាំងឡាយ អ្នកដល់នូវសេចក្តីចម្រើនដោយគុណ មិនកោតញញើតពួកសត្វដែលជាបុគ្គលពាល មិនកោតក្រែងពួកបណ្ឌិត មានព្រះពុទ្ធជាដើម មិនបានខ្លាចក្រែងពួកឥស្សរជន មានស្តេចចក្រពត្តិជាដើម មិនអត់ធន់ចំពោះអ្នកក្រីក្រ មិនវៀរពួកសត្វណាមួយឡើយ ពួកសត្វទាំងអស់នេះ បែរមុខទៅរកមច្ចុ នាំគ្នាលំបាកក្នុងមាត់នៃសេចក្តីស្លាប់ទាំងអស់ ។ បទថា **និច្ចំ បតនតោ** បានដល់ ដោយការធ្លាក់ទៅ អធិប្បាយថា នៃបាករត: ប្រៀបដូចផ្លែឈើដែលទុំហើយ តាំងអំពីដែលទុំហើយទៅ មានតែការរង់ចាំការរុះរោយ ព្រាត់ប្រាសចាកទងក្នុងកាលឥឡូវនេះ ព្រាត់ប្រាសចាកទងក្នុងកាលឥឡូវនេះ គឺផ្លែឈើទាំងនោះ មានតែរង្កៀសយ៉ាងនេះថា ការញាប់ញ័រ ដែលត្រូវជ្រុះជាការពិត

ប្រាកដពិត មានតែរឿងនោះតែម្យ៉ាងប៉ុណ្ណោះ យ៉ាងណា ហ្វូងសត្វដែលត្រូវស្លាប់ ដែលកើតមកហើយក៏ដូច្នោះ ខ្លាចក្រែងតែមានការស្លាប់តែម្យ៉ាងប៉ុណ្ណោះ ខណៈ ឬរយៈដែលហ្វូងសត្វទាំងនោះ មិនចាំបាច់រង្កៀសក្នុងសេចក្តីស្លាប់នោះ មិនមានឡើយ ។ បទថា **សាយំ** បានដល់ ក្នុងពេលល្ងាច ។ ដោយបទថា **សាយំ** នេះ លោកសម្តែងថា សត្វដែលឃើញគ្នាក្នុងពេលយប់ លុះពេលថ្ងៃក៏មិនឃើញ សត្វដែលឃើញគ្នាក្នុងពេលថ្ងៃ លុះពេលយប់ក៏មិនឃើញ ។ បទថា **កិញ្ចិនត្ថំ** សេចក្តីថា បើមនុស្សយើងខ្សឹកខ្សួលដោយគិតថា ឪពុករបស់អញ កូនរបស់អញ ដូច្នេះជាដើម វង្វេងបៀតបៀនខ្លួនឲ្យខ្លួនលំបាក នឹងគប្បីនាំប្រយោជន៍មកតិចតួច ។ បទថា **កយិរា តំ វិចក្ខណោ** សេចក្តីថា កាលបើដូច្នោះ បុរសដែលជាបណ្ឌិត គប្បីកន្ទក់កន្ទេញដូច្នោះ តែព្រោះបុគ្គលដែលកន្ទក់កន្ទេញ មិនអាចនាំបុគ្គលដែលស្លាប់ហើយមកបាន ឬអាចធ្វើនូវសេចក្តីចម្រើនដទៃៗ ដល់អ្នកស្លាប់ហើយនោះបាន ហេតុនោះ ទើបជាកិរិយាឥតប្រយោជន៍ដល់បុគ្គលដែលខ្សឹកខ្សួល ទើបបណ្ឌិតទាំងឡាយមិនខ្សឹកខ្សួល ។ បទថា **អត្តានមត្តនោ** សេចក្តីថា បុគ្គលខ្សឹកខ្សួល កំពុងបៀតបៀនអត្តភាពរបស់ខ្លួនដោយទុក្ខ គឺសេចក្តីសោក និងសេចក្តីខ្សឹកខ្សួល ។ បទថា **ន តេន** សេចក្តីថា ដោយការយំនោះ ហ្វូងសត្វដែលទៅបរលោកហើយ រមែងជាអ្នកគ្រប់គ្រងមិនបាន នឹងញ៉ាំងខ្លួនឲ្យរស់នៅមិនបានឡើយ ។ បទថា **និរត្ថា** សេចក្តីថា ព្រោះហេតុនោះ ទើបការខ្សឹកខ្សួលដល់ពួកសត្វដែលស្លាប់ទៅហើយនោះ ជាកិរិយាដែលមិនមាន

ប្រយោជន៍ ។ បទថា **សរណំ** បានដល់ ផ្ទះដែលជាទីនៅអាស្រ័យ លោកពោលពាក្យអធិប្បាយថា បុរសដែលជាបណ្ឌិត កាលផ្ទះត្រូវភ្លើងឆេះ ក៏មិនត្រូវតក់ស្លុត សូម្បីត្រឹមមួយរំពេច ប្រញាប់លត់ដោយទឹករាប់ពាន់ក្អមមួយរំពេច យ៉ាងណា ធីរជន ក៏ដូច្នោះ គប្បីរម្ងាត់សេចក្ដីសោកដែលកើតឡើងហើយ ដោយរំពេចនោះឯង កម្ចាត់កម្ចាយចោលដោយវិធី ដែលសេចក្ដីសោកមិនអាចតាំងនៅបាន ដូចខ្យល់ផាត់ប៉ុយដូច្នោះ ។ ក្នុងបទថា **ឯកោវ មច្ចោ** មានអធិប្បាយដូចតទៅនេះ នៃបាករតៈ ហ្វូងសត្វទាំងនេះ ឈ្មោះថាមានកម្មជារបស់ខ្លួន សត្វទៅកាន់បរលោកអំពីលោកនេះ ជាបុគ្គលតែឯងចាកហ្វូងសត្វទាំងនោះ កន្លងទៅ ធ្លងទៅ កាលកើតក្នុងត្រកូលក្សត្រជាដើមម្នាក់ឯងប៉ុណ្ណោះ ទៅកើត ។ ចំណែកការរួបរួមគ្នារបស់សត្វក្នុងទីនោះៗ មានការជាប់ជំពាក់គ្នានោះថា បុគ្គលនេះ ជាបិតារបស់អញ បុគ្គលនេះ ជាមាតារបស់អញ បុគ្គលនេះ ជាញាតិមិត្ររបស់អញ ដូច្នេះ ដោយអំណាចដែលទាក់ទងគ្នាជាញាតិ ជាមិត្រប៉ុណ្ណោះ យ៉ាងក្រៃលែង តែដោយបរមត្ថ ហ្វូងសត្វទាំងនេះ ក្នុងភពទាំង ៣ មានកម្មជារបស់ខ្លួនទាំងអស់ ។ បទថា **តស្មា** សេចក្ដីថា ព្រោះវៀរនូវការជាប់ជំពាក់របស់ញាតិមិត្រ ដែលត្រឹមតែជាការគប់រកគ្នាជាញាតិ និងមិត្ររបស់សត្វទាំងនេះហើយ បន្ទាប់អំពីនោះ រមែងជាដទៃទៅមិនបាន ដូច្នោះ ។ បទថា **សម្បស្សតោ** បានដល់ ឃើញលោកនេះនិងលោកខាងមុខ ដែលមានការព្រាត់ប្រាសចាកគ្នា ជាសភាវៈដោយប្រពៃ ។ បទថា **អញ្ញាយ ធម្មំ** បានដល់ ព្រោះដឹងលោកធម៌ ៨ ប្រការ ។ បទថា

**ហានយំ មនញ្ច** នេះ ទាំងពីរបទ ជាឈ្មោះរបស់ចិត្តនោះឯង ។ លោកពោលពាក្យអធិប្បាយក្នុង ( កាឡពាហុជាតក ) ដូច្នេះថា

លាភក្តី អលាភក្តី យសក្តី អយសក្តី និន្ទាក្តី បសំសាក្តី សុខក្តី ទុក្ខក្តី លោកធម៌ទាំង ៨ នោះ មិនទៀង ក្នុងមនុស្សសត្វទាំងឡាយទេ ម្នាលបោដ្ឋបាទ អ្នកកុំសោកស្តាយឡើយ អ្នកនឹងសោកស្តាយធ្វើអ្វី ដូច្នេះ ។

សេចក្តីសោកសូម្បីធំក្រៃលែង ដែលមានបុត្រជាទីស្រឡាញ់ស្លាប់ទៅជាវត្ថុរមែងប្រាកដផ្លូវចិត្ត ដោយលោកធម៌ ៨ ប្រការឯណានីមួយនេះ នឹងរមែងមិនដុតរោលហទយៈរបស់ធីរជនដែលតាំងនៅ ព្រោះបានដឹងដល់សភាវធម៌នោះថា ជារបស់មិនទៀង ។ ម្យ៉ាងទៀត គប្បីឃើញក្នុងសេចក្តីនេះយ៉ាងនេះថា ការសោកស្តាយទោះបីធំក្រៃលែង ក៏ដុតរោលហទយវត្ថុ និងចិត្តរបស់ធីរជនមិនបាន ព្រោះជ្រាបនូវលោកធម៌ ៨ ប្រការនេះ ។ បទថា **សោឍំ យសញ្ច ភោគញ្ច** សេចក្តីថា បាករតៈ ការយំខ្សឹកខ្សួល ជារបស់ពួកក្មេងអន្ធពាល មិនសមគួរដល់បងឡើយ តែបង កាលព្រះបិតាសោយទិវង្គតទៅតាំងនៅក្នុងឋានៈរបស់ទ្រង់នោះឯង នឹងឲ្យទានដល់បុគ្គលដែលគួរឲ្យ មានមនុស្សកំព្រាជាដើម ឲ្យតំណែងដល់បុគ្គលដែលគួរឲ្យ ឲ្យយសដល់បុគ្គលដែលគួរឲ្យយស បរិភោគឥស្សរិយយស ដោយន័យដែលព្រះរាជបិតារបស់យើងទ្រង់បរិភោគ ទ្រង់ចិញ្ចឹមពួកញាតិ និងគ្រប់គ្រងបុគ្គលដ៏សេស គឺបុគ្គលខាងក្នុង និងបុគ្គលដែលជាបរិវារ នឹងធ្វើនូវការការពារគ្រប់គ្រងគ្នាដោយធម៌

ដល់សមណៈ និងព្រាហ្មណ៍ដែលទ្រទ្រង់នូវធម៌ ព្រោះទាំងនេះ ជាកិច្ចដែលសមគួររបស់បុគ្គលអ្នកដឹង គឺបុគ្គលដែលជាបណ្ឌិត ។

ពួកជនស្តាប់ធម្មទេសនា ដែលប្រកាសភាពមិនទៀងរបស់រាមបណ្ឌិតនេះហើយ នាំគ្នាស្វាងនូវសេចក្តីសោក ។ បន្ទាប់អំពីនោះ ភរតកុមារថ្វាយបង្គំរាមបណ្ឌិតទូលថា សូមទ្រង់ទទួលរាជសម្បត្តិក្នុងនគរពារាណសីចុះ ។ព្រះរាមបណ្ឌិតពោលថា នែបា ចូរបានាំលក្ខណៈ និងសីតាទេវីទៅគ្រងរាជសម្បត្តិចុះ ។ ភរតៈទូលសួរថា ចុះព្រះអង្គវិញ ព្រះរាមបណ្ឌិតត្រាស់ថា នែបា បិតារបស់យើង បានត្រាស់នឹងយើងថា លុះកន្លងទៅ ១២ ឆ្នាំ សឹមបាមកគ្រងរាជសម្បត្តិ កាលខ្ញុំនឹងទៅក្នុងកាលឥឡូវនេះ ក៏ឈ្មោះថា មិនធ្វើតាមព្រះតម្រាស់របស់ទ្រង់ បន្ទាប់អំពីនេះទៅ ៣ ឆ្នាំ យើងនឹងទៅ ។ ភរតៈទូលសួរថា អស់កាលមានប្រមាណប៉ុណ្ណោះ អ្នកណានឹងគ្រងរាជសម្បត្តិ ព្រះរាមបណ្ឌិតត្រាស់ថា ពួកអ្នកគ្រប់គ្រងចុះ ។ ភរតកុមារទូលថា ពួកខ្ញុំមិនគ្រប់គ្រង ព្រះរាមបណ្ឌិតត្រាស់ថា បើដូច្នោះ ទ្រនាប់ជើងមួយគូនេះ គ្រប់គ្រងសិន ទម្រាំយើងទៅ ហើយទ្រង់ដោះទ្រនាប់ជើងដែលធ្វើដោយស្មៅប្រទានឲ្យ ។ ក្សត្រទាំង ៣ ទទួលទ្រនាប់ជើង ថ្វាយបង្គំលារាមបណ្ឌិត ចោមរោមដោយមហាជន យាងទៅកាន់នគរពារាណសី ។ បាទុកាគ្រងរាជសម្បត្តិអស់ ៣ ឆ្នាំ ពួកអមាត្យនាំគ្នាដាក់បាទុកាដែលធ្វើអំពីស្មៅលើរាជបល្ល័ង្ក ហើយនាំគ្នាកាត់ក្តី បើកាត់មិនល្អ បាទុកាក៏ទង្គិចគ្នាដោយសញ្ញានោះ នឹងនាំគ្នាកាត់ជាថ្មី ពេលដែលកាត់ប្រពៃហើយ បាទុកាប្រាសចាកសំឡេង នៅស្ងៀមនោះ

ឯង ។ បន្ទាប់អំពីនោះ ៣ ឆ្នាំ ទើបរាមបណ្ឌិតយាងចេញអំពីព្រៃដល់នគរពារាណសី ទ្រង់ចូលកាន់រាជឧទ្យាន រាជកុមារទាំងឡាយជ្រាបភាពដែលទ្រង់យាងមក មានពួកអមាត្យចោមរោម ក៏យាងទៅកាន់ឧទ្យាន ទ្រង់ធ្វើនាងសីតាជាអគ្គមហេសី ហើយអភិសេកទាំងគូ ។ ព្រះមហាសត្វទ្រង់អភិសេកហើយ ប្រថាប់លើរាជរថដ៏ឧត្តម យាងចូលកាន់ព្រះនគរដោយបរិវារធំ ទ្រង់ទតព្រះនគរហើយ ឡើងកាន់ផ្ទៃសុនន្ទប្រាសាទ[1] ។ តាំងអំពីនោះ ទ្រង់គ្រងរាជសម្បត្តិដោយធម៌ រហូត ១ ម៉ឺន ៦ ពាន់ឆ្នាំ ក្នុងកាលអស់ព្រះជន្មាយុ ទ្រង់ញុំាងសួគ៌ឲ្យពេញហើយ ។ ព្រះសាស្តា ទ្រង់បានត្រាស់ដឹងហើយ ទ្រង់ត្រាស់អភិសម្ពុទ្ធគាថានេះថា

ព្រះបាទរាមៈ មានព្រះសូរង៍ដូចជារូបសំណាកមាស មានព្រះ
ពាហុធំ បានសោយរាជ្យ អស់ ១៦០០០ ឆ្នាំ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កម្ពុគីវោ** សេចក្តីថា មានព្រះសូរង៍ដូចគ្នានឹងស្គរតូចដែលធ្វើអំពីមាស ។ មែនពិត មាស លោកហៅថា **កម្ពុ**។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះ មកសម្តែងហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងកាលចប់សច្ចៈ កុដុម្ពិកៈតាំងនៅក្នុងសោតាបត្តិផល ព្រះសាស្តាទ្រង់ប្រជុំជាតកថា ព្រះបាទទសរថមហារាជក្នុង

---

១- ក្នុងទីខ្លះជាចន្ទកប្រាសទ ។

កាលនោះ បានមកជាព្រះបាទសុទ្ធោទនមហារាជ ក្នុងកាលឥឡូវនេះ ព្រះមាតាក្នុងកាលនោះ បានមកជាព្រះនាងមហាមាយា ព្រះនាងសីតាក្នុងកាលនោះ បានមកជារាហុលមាតា ភរតៈក្នុងកាលនោះ បានមកជាអានន្ទ លក្ខណៈក្នុងកាលនោះ បានមកជាសារីបុត្ត បរិស័ទក្នុងកាលនោះ បានមកជាពុទ្ធ-បរិស័ទ ចំណែកការមបណ្ឌិតក្នុងកាលនោះ គឺតថាគតនេះឯង ។៚

**អដ្ឋកថា ទសរថជាតក ចប់**

# សុត្តន្តបិដក

## សំវរជាតក

[ ៨៧៥ ] ( ឧបោសថកុមារ បានពោលថា ) បពិត្រមហារាជ ព្រះជិនាធិបៈ ( ជាព្រះបិតា ) ប្រហែលទ្រង់ជ្រាបនូវសីលរបស់ព្រះអង្គហើយ បានជាព្រះអង្គបូជា នូវព្រះរាជកុមារទាំងនេះ ( ដោយជនបទនោះៗ ) មិនសម្គាល់នូវព្រះអង្គ ដោយជនបទណាមួយឡើយ ។

[ ៨៧៦ ] កាលដែលមហារាជ គង់ព្រះជន្មនៅ ឬកាលដែលព្រះអង្គ ( ជាបិតារបស់ពួកយើង ) ទិវង្គតហើយ ពួកញាតិកាលឃើញសេចក្តីចម្រើនរបស់ខ្លួន បានយល់ព្រមឲ្យព្រះអង្គ ( សោយរាជ្យ ) ។

[ ៨៧៧ ] បពិត្រព្រះបាទសំវរៈ ព្រះអង្គគ្របសង្កត់ ( នូវបង ៩៩ ព្រះអង្គ ) ដែលកើតជាមួយ តើដោយវត្តដូចម្តេច ឯពួកញាតិ ដែលមកប្រជុំគ្នាហើយ ក៏មិនគ្របសង្កត់នូវព្រះអង្គ តើដោយវត្តដូចម្តេច ។

[ ៨៧៨ ] ( ព្រះបាទសំវរៈ ... ) បពិត្ររាជបុត្ត ខ្ញុំមិនប្រណែនខ្ញុំថ្វាយបង្គំព្រះបាទទាំងឡាយ របស់ពួកសមណៈ ជាតាទិបុគ្គលបាននមស្ការពួកសមណៈទាំងនោះ ដោយគោរព ។

[ ៨៧៩ ] សមណៈទាំងនោះ ជាអ្នកត្រេកអរក្នុងធម្មគុណ របស់ឥសី បានប្រៀនប្រដៅខ្ញុំ ឲ្យប្រកបក្នុងធម្មគុណ ឲ្យជាអ្នកត្រេង

ត្រាប់មិនប្រណែន ។

[ ៨៨០ ] ខ្ញុំបានស្តាប់ពាក្យ របស់ពួកសមណៈ អ្នកស្វែងរកនូវគុណនោះហើយ មិនមើលងាយបន្តិចបន្តួចសោះ ចិត្តរបស់ខ្ញុំក៏ត្រេកអរ ក្នុងធម៌ជានិច្ច ។

[ ៨៨១ ] ពួកទាហានជិះដំរី ពួកទាហាន ដែលឋិតនៅក្នុងក្បួនទ័ព ពួកទាហានជិះរថ ពួកពលថ្មើរជើង ខ្ញុំមិនបន្ថយនូវបាយនិងថ្លៃឈ្នួល ដែលពួកទាហាននោះ ចាត់ចែងហើយ ។

[ ៨៨២ ] ពួកមហាមាត្យ ពួកមន្ត្រី ពួកអ្នកបម្រើ របស់ខ្ញុំមានពួកជនបានចាត់ចែងនូវសាច់ និងទឹកសុរាដ៏ច្រើន ក្នុងក្រុងពារាណសី ។

[ ៨៨៣ ] មួយទៀត សូម្បីពួកពាណិជ ដែលមកអំពីដែនផ្សេងៗក៏សម្បូរ ខ្ញុំបានចាត់ចែងការរក្សា ចំពោះពួកពាណិជទាំងនោះ បពិត្រឧបោសថជាបង សូមព្រះបងជ្រាបយ៉ាងនេះចុះ ។

[ ៨៨៤ ] ( ឧបោសថកុមារ ... ) បពិត្រព្រះបាទសំវរៈ ឮថាព្រះអង្គ ( គ្របសង្កត់អានុភាព ) របស់ពួកញាតិ ( បង ៩៩ ព្រះអង្គ ) ដោយធម៌ សូមព្រះអង្គសោយរាជ្យចុះ ព្រះអង្គជា

អ្នកមានប្រាជ្ញាផង ជាបណ្ឌិតផង ទាំងជាប្រយោជន៍ដល់ពួកញាតិផង ។

[ ៨៨៥ ] ពួកសត្រូវ មិនអាចគ្របសង្កត់ព្រះអង្គ ដែលពួកញាតិចោមរោមហើយ ជាអ្នកកុះករដោយរតនវត្ថុផ្សេងៗ ដូចជាស្ដេចអសុរ មិនអាចគ្របសង្កត់ព្រះឥន្ទ្រ ដូច្នោះដែរ ។

### សំវរជាតកទី ៨ ចប់

# អដ្ឋកថា

## សំវរជាតក

[ ៨៧៥-៨៨៥ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុលះបង់សេចក្តីព្យាយាមមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ជានន្តោ នោ មហារាជ** ដូច្នេះជាដើម ។

មានរឿងពិស្តារថា ភិក្ខុនោះជាកុលបុត្រអ្នកនគរសាវត្ថី ស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តា បានបួស និងឧបសម្បទាហើយ បំពេញអាចរិយវត្តនិងឧបជ្ឈាយវត្ត ទន្ទេញបាតិមោក្ខទាំង ២ ចប់ស្ទាត់ជំនាញ មានវស្សាជាគម្រប់ ៥ បរិបូរ រៀនកម្មដ្ឋាន លាអាចារ្យ និងឧបជ្ឈាយ៍ថា ខ្ញុំនឹងនៅព្រៃ ទៅដល់ស្រុកជាយដែនទាតំបន់មួយក្នុងដែនកោសល ពួកមនុស្សនាំគ្នាជ្រះថ្លាក្នុងឥរិយាបថ នាំគ្នាសាងបណ្ណសាលា ទំនុកបម្រុងក្នុងស្រុកនោះ កាលចូលវស្សា បំពេញនូវសេចក្តីព្យាយាមចម្រើនកម្មដ្ឋានអស់ត្រៃមាស ដោយសេចក្តីព្យាយាមដែលប្រារព្ធហើយ មិនអាចឲ្យគុណត្រឹមតែឱភាសកើតឡើងបានឡើយ ត្រិះរិះថា ក្នុងបុគ្គល ៤ ពួក ដែលព្រះសាស្តាត្រាស់សម្តែងហើយ អញគង់ជាបទបរមបុគ្គលពិត អញនៅព្រៃធ្វើអ្វី ទៅវត្តជេតពន សម្លឹងមើលព្រះរូបព្រះឆោមរបស់ព្រះតថាគត ស្តាប់ធម្មទេសនាដ៏ពីរោះ ឲ្យពេលវេលាកន្លងទៅចុះ ។ ភិក្ខុនោះលះបង់នូវសេចក្តីព្យាយាម ចេញអំពីស្រុកនោះទៅដល់វត្តជេតពនដោយលំដាប់ ត្រូវអាចារ្យ និងឧបជ្ឈាយ៍ និងភិក្ខុដែលធ្លាប់ស្គាល់ស្និទ្ធស្នាល ចោមរោមសួរដល់ហេតុដែលត្រឡប់មក ក៏ប្រាប់រឿងនោះ ត្រូវភិក្ខុទាំងនោះតិះដៀលថា ហេតុអ្វី ទើបលោកធ្វើយ៉ាងនេះ នាំខ្លួនទៅកាន់

សម្នាក់ព្រះសាស្តា កាលព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកនាំភិក្ខុមិនប្រាថ្នាមកឬ ភិក្ខុទាំងឡាយក៏ក្រាបទូលថា បពិត្រព្រះអង្គ ភិក្ខុនេះបោះបង់នូវសេចក្តីព្យាយាមមកហើយ ។ ព្រះសាស្តាត្រាស់សួរថា ម្នាលភិក្ខុពាក្យនុ៎ះពិតឬ កាលភិក្ខុនោះក្រាបទូលថា ពិតហើយព្រះអង្គ ទើបត្រាស់ថា ម្នាលភិក្ខុ ហេតុអ្វី ទើបអ្នកលះបង់សេចក្តីព្យាយាម ។ ពិតហើយ ផលដ៏ប្រសើរក្នុងសាសនានេះ មានឈ្មោះថាអរហត្តផល រមែងមិនមានដល់បុគ្គលដែលខ្ជិលច្រអូស ជាអ្នកបោះបង់សេចក្តីព្យាយាម បុគ្គលដែលមានសេចក្តីព្យាយាមប្រារព្ធហើយ ទើបសម្រេចធម៌ជាន់ខ្ពស់បាន ក្នុងកាលមុន អ្នកជាបុគ្គលមានព្យាយាម អត់ធន់ចំពោះឱវាទ ដោយហេតុនោះឯង សូម្បីជាប្អូនពៅនៃឱរសមួយរយអង្គ របស់ព្រះបាទពារាណសី តាំងនៅក្នុងឱវាទរបស់បណ្ឌិតទាំងឡាយ ក៏ដល់នូវស្វេតច្ឆត្របាន ហើយទ្រង់នាំអតីតនិទានមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះឱរសពៅនេះទ្រង់បានសម្ពន្ធភាពយ៉ាងស្និតជាមួយពួកជនក្នុងនគរពារាណសី ដោយសង្គហវត្ថុនោះៗ បានជាទីស្រឡាញ់ ជាទីត្រេកអររបស់បុគ្គលទាំងពួង ។

( ច្បាប់កូមាមានសេចក្តីថា ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះរាជបុត្តពៅក្នុងចំណោមព្រះរាជបុត្តមួយរយអង្គ ព្រះនាមថា សំវរកុមារ ព្រះរាជាទ្រង់ប្រគល់រាជបុត្តមួយអង្គៗ ដល់អមាត្យម្នាក់ៗ ថា អ្នកទាំងឡាយ ចូរឲ្យរាជបុត្តសិក្សាវត្ថុដែលគួរសិក្សា

អមាត្យ ដែលជាអាចារ្យរបស់សំវរកុមារជាព្រះពោធិសត្វ ជាបណ្ឌិត ឈ្លាស វៃ តាំងនៅក្នុងឋានៈជាបិតារបស់ព្រះរាជាកុមារនោះ ។ ពួកអមាត្យបង្ហាញព្រះរាជបុត្រដែលសម្រេចសិប្បៈហើយដល់ព្រះរាជា ។ ព្រះរាជាទ្រង់ព្រះរាជ-ទានជនបទដល់ព្រះរាជបុត្រទាំងនោះ ទ្រង់បញ្ជូនទៅឲ្យគ្រប់គ្រងហើយ ។ សំវរកុមារសម្រេចសិប្បៈទាំងអស់ហើយ សួរព្រះពោធិសត្វថា បពិត្រលោកឪពុក បើព្រះរាជបិតាទ្រង់បញ្ជូនខ្ញុំទៅកាន់ជនបទ ខ្ញុំនឹងធ្វើដូចម្តេចល្អ ព្រះពោធិសត្វប្រាប់ថា នែបា បើព្រះរាជបិតាព្រះរាជទានជនបទ កូនកុំទទួល គប្បីក្រាបទូលថា បពិត្រព្រះសម្មតិទេព ទូលបង្គំជាកូនពៅ បើទូលបង្គំទៅហើយ អ្នកក្បែរខាងរបស់ព្រះអង្គនឹងទទេ ទូលបង្គំនឹងនៅក្បែរទ្រង់នោះឯង ដូច្នេះ ។ សម័យថ្ងៃមួយ ព្រះរាជាត្រាស់សួរសំវរកុមារដែលថ្វាយបង្គំហើយ អង្គុយក្នុងទីបំផុតទាចំណែកម្ខាងថា នែកូន បារៀនសិប្បៈសម្រេចហើយឬ ព្រះរាជ-កុមារក្រាបទូលថា បពិត្រព្រះសម្មតិទេព សម្រេចហើយ ព្រះរាជាត្រាស់ថា យើងនឹងឲ្យជនបទដល់បា ព្រះរាជកុមារក្រាបទូលថា បពិត្រព្រះសម្មតិទេព អ្នកក្បែរខាងរបស់ព្រះអង្គនឹងទទេ ទូលបង្គំនឹងនៅទៀបបាទមូល ។ ព្រះរាជាទ្រង់ត្រេកអរត្រាស់ថា សាធុ ។ ចាប់តាំងអំពីនោះ ព្រះរាជកុមារទទួលបម្រើទៀបបាទមូលរបស់ព្រះរាជា ត្រាស់សួរព្រះពោធិសត្វទៀតថា បពិត្រលោកឪពុក ខ្ញុំនឹងធ្វើអ្វីទៀតទើបល្អ ព្រះពោធិសត្វត្រាស់ថា នែបា ចូរកូនទូលសូមព្រះរាជឧទ្យានចាស់មួយកន្លែងជាមួយព្រះរាជា ព្រះរាជកុមារពោលថា សាធុ ហើយទូលសូមឧទ្យាន ទ្រង់ធ្វើការសង្គ្រោះឥស្សរជនក្នុងនគរដោយផ្កា

និងផ្លែឈើ ដែលកើតក្នុងឧទ្យាននោះ ហើយសួរព្រះពោធិសត្វទៀតថា បពិត្រលោកឪពុក ខ្ញុំនឹងធ្វើអ្វីទៀត ព្រះពោធិសត្វប្រាប់ថា នែកូន ចូរកូនទូលសូមអនុញ្ញាតព្រះរាជា សូមធ្វើជាអ្នកចែកប្រាក់បៀវត្សខាងក្នុងព្រះនគរ ។ កុមារបានធ្វើហើយយ៉ាងនោះ ចែកបៀវត្សដោយមិនឲ្យខ្វះខាតចំពោះបុគ្គលណាម្នាក់ ហើយសួរព្រះពោធិសត្វទៀត កាលព្រះពោធិសត្វប្រាប់ហើយ ក៏ព្រះរាជទានប្រាក់បំណាច់ដល់ទាសៈ និងកម្មករខាងក្នុងព្រះរាជនិវេសន៍ និងដល់ពលដំរី ពលសេះ ពលថ្មើរជើង មិនឲ្យខ្វះខាត ទ្រង់ធ្វើករណីយកិច្ចទាំងពួងដោយព្រះអង្គឯង គឺរកទីស្នាក់អាស្រ័យជាដើម ដល់ពួកទូតដែលមកអំពីនគរដទៃ ទុកដាក់កាសីរបស់ពួកឈ្មួញ ។ ព្រះរាជកុមារតាំងនៅក្នុងឱវាទរបស់ព្រះមហាសត្វយ៉ាងនេះ ទ្រង់ចងចិត្តមហាជនទាំងខាងក្នុង ទាំងខាងក្រៅ ទាំងអ្នកក្រុង ទាំងអ្នកដែន ទាំងអាគន្តុកៈ និងអ្នករាជការ ដោយសង្គហវត្ថុនោះៗ ទ្រង់បានជាទីស្រឡាញ់ពេញចិត្តរបស់ជនទាំងពួង ) ។

ក្នុងកាលតមក ពួកអមាត្យនាំគ្នាក្រាបទូលសួរព្រះរាជា ដែលប្រថាប់គង់លើព្រះទែន សម្រាប់សោយទិវង្គតថា បពិត្រព្រះសម្មតិទេព កាលទ្រង់សោយទិវង្គតទៅហើយ ពួកទូលបង្គំនឹងថ្វាយស្វេតច្ឆត្រឲ្យដល់បុគ្គលណា ព្រះរាជាត្រាស់ថា នែបា កូនរបស់យើងទាំងអស់ ជាម្ចាស់នៃស្វេតច្ឆត្រ តែបុគ្គលណាត្រូវចិត្តពួកអ្នក ចូរពួកអ្នកឲ្យស្វេតច្ឆត្រដល់អ្នកនោះចុះ ។ កាលព្រះរាជាសោយទិវង្គត ពួកអមាត្យនោះចាត់ការថ្វាយព្រះភ្លើងព្រះសពរបស់ព្រះរាជាស្រេចបាច់ ប្រជុំគ្នាក្នុងថ្ងៃទី ៧ សម្រេចថា ព្រះរាជាផ្តាំថា

បុគ្គលណាចងចិត្តពួកអ្នកបាន ពួកអ្នកគប្បីលើកស្វេតច្ឆត្រឲ្យដល់បុគ្គលនោះ ឯព្រះសំវរកុមារអង្គនេះ គាប់ចិត្តពួកយើង ហើយនាំគ្នាលើកស្វេតច្ឆត្រ-កាញ្ចនមាលា ថ្វាយដល់សំវរកុមារអង្គនោះ ព្រះបាទសំវររាជ តាំងនៅក្នុងឱវាទរបស់ព្រះពោធិសត្វ គ្រងរាជសម្បត្តិដោយធម៌ ព្រះរាជកុមារ ៩៩ អង្គក្រៅអំពីនោះ នាំគ្នាត្រាស់ថា បានឮថា ព្រះរាជបិតារបស់ពួកយើងសោយទិវង្គតហើយ ពួកអមាត្យលើកស្វេតច្ឆត្រថ្វាយដល់សំវរកុមារ ទ្រង់ជាកូនពៅមិនអាចដល់ស្វេតច្ឆត្ររបស់ព្រះបិតាឡើយ ពួកយើងត្រូវលើកស្វេតច្ឆត្រថ្វាយព្រះរាជបុត្តច្បង ហើយក៏មកជួបជុំគ្នា បញ្ជូនលិខិតដល់ព្រះបាទសំវរមហារាជថា ឲ្យស្វេតច្ឆត្រដល់ពួកយើង ឬច្បាំងគ្នា ហើយនាំគ្នាព័ទ្ធព្រះនគរ ។ ព្រះរាជាត្រាស់ប្រាប់រឿងនោះដល់ព្រះពោធិសត្វ ហើយត្រាស់សួរថា គ្រានេះ ពួកយើងនឹងធ្វើអ្វី ។ ព្រះពោធិសត្វក្រាបទូលថា បពិត្រមហារាជ ទ្រង់មិនចាំបាច់ធ្វើនូវចម្បាំងជាមួយម្ចាស់បងទាំងនោះឡើយ សូមទ្រង់ចែករាជទ្រព្យរបស់បិតាជា ៩៩ ចំណែក បញ្ជូនទៅថ្វាយដល់ម្ចាស់បង ៩៩ អង្គ ទ្រង់បញ្ជូនសាសន៍ទៅថា សូមម្ចាស់បងទាំងឡាយ ទទួលរាជទ្រព្យរបស់បិតាចុះ ទូលបង្គំមិនច្បាំងជាមួយម្ចាស់បងឡើយ ។ ហើយទ្រង់ធ្វើយ៉ាងនោះ ។

កាលនោះ ព្រះរាជបុត្រច្បង ព្រះនាមឧបោសថកុមារ ត្រាស់ហៅប្អូនៗដ៏សេសមកត្រាស់ថា នែបាទាំងឡាយ បុគ្គលដែលអាចញាំញីព្រះរាជាបានមិនមាន ម្យ៉ាងទៀត ម្ចាស់ប្អូនរបស់ពួកយើងអង្គនេះ មិនបានតាំងខ្លួនជាសត្រូវ តបតជាមួយពួកយើង បញ្ជូនរាជសម្បត្តិរបស់បិតាឲ្យពួកយើង បញ្ជូន

សាសន៍មកថា ខ្ញុំមិនច្បាំងជាមួយម្ចាស់បង ឯពួកយើងនឹងលើកស្វេតច្ឆត្រ ឡើងក្នុងខណៈតែមួយជាមួយគ្នាមិនបាន ពួកយើងឲ្យស្វេតច្ឆត្រដល់ទ្រង់តែមួយក៏ជាការស្រេច ម្ចាស់ប្អូននេះប៉ុណ្ណោះ ចូរជាព្រះរាជាចុះ មកអ្នកទាំងឡាយ ពួកយើងនាំគ្នាទៅជួបទ្រង់ប្រគល់រាជទ្រព្យ ហើយនាំគ្នាទៅកាន់ជនបទរបស់ពួកយើងវិញ ។ គ្រានោះ ព្រះរាជកុមារទាំងអស់ ក៏ឲ្យបើកទ្វារក្រុងមិនបានជាសត្រូវឡើយ នាំគ្នាចូលកាន់ព្រះនគរ ចំណែកព្រះរាជាត្រាស់ឲ្យពួកអមាត្យធ្វើសក្ការៈ ដើម្បីព្រះរាជកុមារទាំងនោះ ទ្រង់បញ្ជូនចំណែកផ្លូវទៅ ព្រះកុមារទ្រង់យាងមកដោយបរិវារដ៏ច្រើន ឡើងកាន់ព្រះរាជវាំង សម្ដែងការគោរពដល់ព្រះបាទសំវរមហារាជ នាំគ្នាប្រថាប់គង់លើអាសនៈទាប ព្រះបាទសំវរៈ ទ្រង់ប្រថាប់គង់លើសីហាសនៈខាងក្រោមស្វេតច្ឆត្រ ព្រះយសធំព្រះសិរីធំ បានប្រាកដហើយ ស្ថានទីដែលទតហើយក៏ញាប់ញ័រទៅ ។ ព្រះឧបោសថកុមារ ទតឃើញសិរីសម្បត្តិរបស់ព្រះបាទសំវរមហារាជហើយ ទ្រង់ត្រិះរិះថា ព្រះបិតារបស់ពួកយើង ទ្រង់ជ្រាបភាពដែលសំវរកុមារជាព្រះរាជាកាលទ្រង់សោយទិវង្គតទៅ ទើបប្រទានជនបទដទៃៗ ដល់ពួកយើង មិនបានប្រទានដល់សំវរកុមារនេះ កាលទ្រង់ប្រាស្រ័យជាមួយសំវរមហារាជនោះ ទើបត្រាស់ ៣ គាថាថា

បពិត្រមហារាជ ព្រះជិនាធិបៈ ( ជាព្រះបិតា ) ប្រហែលទ្រង់ជ្រាបនូវសីលរបស់ព្រះអង្គហើយ បានជាព្រះអង្គបូជានូវព្រះរាជកុមារទាំងនេះ ( ដោយជនបទនោះៗ ) មិនសម្គាល់នូវព្រះ

អគ្គ ដោយជនបទណាមួយឡើយ ។

កាលដែលមហារាជ គង់ព្រះជន្មនៅ ឬកាលដែលព្រះអគ្គ ( ជាបិតារបស់ពួកយើង ) ទិវង្គតហើយ ពួកញាតិ កាលឃើញសេចក្តីចម្រើនរបស់ខ្លួន បានយល់ព្រមឲ្យព្រះអគ្គ ( សោយរាជ្យ ) ។

បពិត្រព្រះបាទសំវរៈ ព្រះអគ្គគ្រប់សង្កត់ ( នូវបង ៩៩ ព្រះអគ្គ ) ដែលកើតជាមួយ តើដោយវត្តដូចម្តេច ឯពួកញាតិ ដែលមកប្រជុំគ្នាហើយ ក៏មិនគ្រប់សង្កត់នូវព្រះអគ្គ តើដោយវត្តដូចម្តេចដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ជានន្តោ នោ** បានដល់ ទ្រង់ជ្រាបពិតប្រាកដ ។ បទថា **ជនាធិបោ** សេចក្តីថា ព្រះរាជាជាធំជាងជន បិតារបស់ពួកយើង ។ បទថា **ឥមេ** បានដល់ នូវព្រះរាជកុមារ ៩៩ អង្គនេះ ។ តែក្នុងគម្ពីរព្រះបាលីទាំងឡាយ លោករចនាថា កុមារពួកដទៃ ។ បទថា **បូជេន្តោ** សេចក្តីថា ទ្រង់សរសើរដោយជនបទនោះៗ ។ បទថា **ន តំ កោចិ** សេចក្តីថា តែទ្រង់មិនបានសម្គាល់ព្រះអគ្គថា គួរទ្រង់សរសើរដោយជនបទតូចៗ ឡើយ ប្រហែលជាទ្រង់ជ្រាបដល់ព្រះអគ្គថា បុគ្គលនេះ កាលអញសោយទិវង្គតទៅ នឹងបានជាព្រះរាជា ទើបឲ្យប្រថាប់ទៀបបាទមូលរបស់ខ្លួន ។ បទថា **តិដ្ឋន្តេ នោ** សេចក្តីថា ទោះជាមហារាជទ្រង់គង់ព្រះជន្មនៅ ។ ទ្រង់ត្រាស់សួរ ដោយបទ

ថា **នុ**[១] ប្រែថា មិនមែនឬ ។ បទថា **អាទុ ទេវេ** សេចក្ដីថា កាលព្រះបិតារបស់ពួកយើងសោយទិវង្គត ពួកញាតិ និងពួកនិគមជនបទដែលជាខ្ញុំរាជការឃើញប្រយោជន៍ គឺសេចក្ដីចម្រើនរបស់ខ្លួន រមែងព្រមរាប់អានទ្រង់ថា ជាព្រះរាជាចុះ ។ បទថា **វត្តេន** បានដល់ ដោយសីល និងអាចារៈ ។ បទថា **សញ្ញាតេ អភិតិដ្ឋសិ** សេចក្ដីថា ទ្រង់គ្របសង្កត់ព្រះញាតិ ដែលមានកំណើតស្មើគ្នា គឺព្រះភាតា ៩៩ អង្គ ។ បទថា **នាតិវត្តន្តិ** សេចក្ដីថា ព្រះញាតិទាំងនោះ នាំគ្នាគ្របសង្កត់ទ្រង់មិនបាន ។

ព្រះបាទសំវរមហារាជ ទ្រង់ស្ដាប់ព្រះតម្រាស់នោះ កាលទ្រង់ថ្លែងព្រះគុណរបស់ទ្រង់ ទើបត្រាស់ព្រះ ៦ គាថាថា

បពិត្ររាជបុត្ត ខ្ញុំមិនប្រណែន ខ្ញុំថ្វាយបង្គំព្រះបាទទាំងឡាយ
របស់ពួកសមណៈ ជាតាទិបុគ្គល បាននមស្ការពួកសមណៈ
ទាំងនោះ ដោយគោរព ។

សមណៈទាំងនោះ ជាអ្នកត្រេកអរក្នុងធម្មគុណ របស់ឥសី បាន
ប្រៀនប្រដៅខ្ញុំ ឲ្យប្រកបក្នុងធម្មគុណ ឲ្យជាអ្នកត្រងត្រាប់ មិន
ប្រណែន ។

ខ្ញុំបានស្ដាប់ពាក្យរបស់ពួកសមណៈ អ្នកស្វែងរកនូវគុណនោះ
ហើយ មិនមើលងាយបន្តិចបន្តួចសោះ ចិត្តរបស់ខ្ញុំ ក៏ត្រេកអរ
ក្នុងធម៌ជានិច្ច ។

---

១- សព្ទនេះ លោកកែសព្ទថា តិដ្ឋន្តេ នោ មកជា តិដ្ឋន្តេ នុ ។

ពួកទាហានជិះដំរី ពួកទាហានដែលឋិតនៅក្នុងក្បួនទ័ព ពួកទាហានជិះរថ ពួកពលថ្មើរជើង ខ្ញុំមិនបន្ថយនូវបាយ និងថ្លៃឈ្នួល ដែលពួកទាហាននោះ ចាត់ចែងហើយ ។

ពួកមហាមាត្យ ពួកមន្ត្រី ពួកអ្នកបម្រើរបស់ខ្ញុំមាន ពួកជនបានចាត់ចែងនូវសាច់ និងទឹកសុរាដ៏ច្រើន ក្នុងក្រុងពារាណសី ។

មួយទៀត សូម្បីពួកពាណិជ ដែលមកអំពីដែនផ្សេងៗ ក៏សម្បូរ ខ្ញុំបានចាត់ចែងការរក្សា ចំពោះពួកពាណិជទាំងនោះ បពិត្រឧបោសថជាបង សូមព្រះបងជ្រាបយ៉ាងនេះចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ន រាជបុត្ត** សេចក្តីថា បពិត្រព្រះរាជបុត្ត ខ្ញុំមិនបានបៀតបៀនដល់អ្នកណាមួយឡើយថា សម្បត្តិយ៉ាងនេះ កុំមានដល់បុគ្គលនេះ ។ បទថា **តាទិនំ** សេចក្តីថា ខ្ញុំក្រាបថ្វាយបង្គំបាទាដោយបញ្ចង្គប្រតិស្ឋានដល់ពួកសមណៈ ដែលប្រកបដោយលក្ខណៈជាតាទិបុគ្គល ព្រោះលោកស្ងប់បាបហើយ បានឈ្មោះថា **មហេសិនំ** ព្រោះលោកស្វែងរកគុណមានសីលក្ខន្ធជាដើមដ៏ធំ កាលនឹងឲ្យទានដែលប្រកបដោយធម៌ កាលនឹងចាត់ការគ្រប់គ្រងរក្សាការពារប្រកបដោយធម៌ដល់លោកទាំងនោះ ក៏ថ្វាយបង្គំលោកទាំងនោះដោយគោរព គឺបូជាដោយចិត្តស្រឡាញ់នោះឯង ។ បទថា **តេ មំ** សេចក្តីថា សមណៈទាំងនោះ ស្គាល់ខ្ញុំដោយពិតថា កុមារនេះខ្វល់ខ្វាយក្នុងចំណែកនៃធម៌ ស្តាប់ដោយល្អ មិនមានការប្រណែន នាំគ្នាប្រៀនប្រដៅខ្ញុំដែលប្រកបដោយធម្មគុណត្រងត្រាប់ស្តាប់ដោយល្អ មិនប្រណែន គឺនាំគ្នាឲ្យ

ឱវាទថា ចូរធ្វើកម្មនេះ កុំធ្វើកម្មនេះ ។ បទថា **តេសាហំ** កាត់បទជា **តេសំ អហំ** ។ បទថា **ហត្ថារោហា** សេចក្ដីថា ពួកពលដំរី គឺអ្នកចម្បាំងដែលជិះដំរី ។ បទថា **អនីកដ្ឋា** សេចក្ដីថា តាំងនៅក្នុងកងទ័ពដំរីជាដើម ។ បទថា **រថិកា** បានដល់ ពលរថ ។ បទថា **បត្តិការកា** បានដល់ ពួកពលថ្មើរជើង ។ បទថា **និវិដ្ឋំ** សេចក្ដីថា ថ្ងៃឈ្នួលណាដែលជនទាំងនោះរៀបចំ ខ្ញុំមិនបានកាត់បន្ថយនូវប្រាក់បំណាច់នោះ គឺឲ្យដោយមិនបន្ថយ ។ បទថា **មហាមត្តា** សេចក្ដីថា បពិត្របងប្រុស ពួកអមាត្យដែលមានបញ្ញាច្រើន គឺជាអ្នកឈ្លាសក្នុងមន្តទាំងឡាយ និងបុគ្គលដែលទំនុកបម្រុង ប្រកបដោយមធ្យោបាយដ៏សេសរបស់ខ្ញុំមាន ដោយពាក្យនេះ សំវរកុមារសម្តែងរឿងនេះថា ឯម្ចាស់បងមិនបានអាចារ្យដែលសម្បូរដោយការគិត ជាបណ្ឌិត តែអាចារ្យរបស់ខ្ញុំជាបណ្ឌិតឈ្លាសក្នុងឧបាយ ទើបលោកទាំងនោះ ស្ដាបនាខ្ញុំក្នុងស្វេតច្ឆត្រ ។ បទថា **ពារាណសឹ** សេចក្ដីថា បពិត្រម្ចាស់បង ចាប់តាំងពីកាលលើកស្វេតច្ឆត្រឲ្យដល់ទូលបង្គំហើយ ពួកលោកទាំងនោះ ដឹងដល់មច្ឆមំសាហារ ដែលគួរទំពាស៊ី និងទឹកល្អៗ ដែលគួរផឹក នឹងមានក្នុងនគរពារាណសីថា ព្រះរាជារបស់ពួកយើងទ្រទ្រង់នូវធម៌ ភ្លៀងរមែងធ្លាក់រៀងរាល់កន្លះខែ ស្រូវផ្សេងៗរមែងសម្បូរដោយអាការយ៉ាងនេះ អ្នកនគរ ក៏នាំគ្នាធ្វើនូវព្រះនគរពារាណសីឲ្យមានមច្ឆមំសាហារ និងកំពង់ទឹកច្រើន ។ បទថា **ជីតា** សេចក្ដីថា ពួកឈ្មួញដែលមិនត្រូវប្រទូសរ៉ាយ នាំដំរីកែវ សេះកែវ និងកែវមុក្តាជាដើម មកធ្វើការជួញដូរ ក្លាយជាអ្នកមានស្តុកស្តម្ភជាលំដាប់ ។ បទថា **ឃរំ ជាធាហិ**

សេចក្ដីថា បពិត្រព្រះឧបោសថ ដោយហេតុទាំងនេះត្រឹមប៉ុណ្ណោះ ទោះខ្ញុំជាប្អូនពៅ ក៏គ្រប់សង្កត់បងទាំងឡាយរបស់ខ្ញុំ ដល់នូវស្វេតច្ឆត្របាន សូមទ្រង់ជ្រាបដោយប្រការដូច្នេះ ។

កាលឧបោសថកុមារ ទ្រង់ស្ដាប់ព្រះគុណរបស់ព្រះអនុជហើយ បានត្រាស់ ២ គាថាថា

បពិត្រព្រះបាទសំវរៈ ឮថា ព្រះអង្គ ( គ្រប់សង្កត់អានុភាព ) របស់ពួកញាតិ ( បង ៩៩ ព្រះអង្គ ) ដោយធម៌ សូមព្រះអង្គសោយរាជ្យចុះ ព្រះអង្គជាអ្នកមានប្រាជ្ញាផង ជាបណ្ឌិតផង ទាំងជាប្រយោជន៍ដល់ពួកញាតិផង ។

ពួកសត្រូវ មិនអាចគ្រប់សង្កត់ព្រះអង្គ ដែលពួកញាតិចោមរោមហើយ ជាអ្នកកុះករដោយរតនវត្ថុផ្សេងៗ ដូចជាស្ដេចអសុរ មិនអាចគ្រប់សង្កត់ព្រះឥន្ទ្រ ដូច្នោះដែរ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ធម្មេន កិរ** សេចក្ដីថា បពិត្រព្រះសំវរមហារាជ បានឮថា ទ្រង់គ្រប់សង្កត់អានុភាពនៃញាតិ គឺព្រះជេដ្ឋភាតាទាំងឡាយរបស់ទ្រង់ទាំង ៩៩ អង្គ ។ ចាប់តាំងអំពីនេះ សូមទ្រង់គ្រប់គ្រងរាជសម្បត្តិដោយធម៌ចុះ ទ្រង់មុតស្រួចផង ជាបណ្ឌិតផង ញុំាងប្រយោជន៍ដល់ពួកញាតិផង ។ បទថា **តំ តំ** បានដល់ ទ្រង់សម្បូរដោយគុណផ្សេងៗយ៉ាងនេះ ។ បទថា **ញាតិបរិព្យូឡ្ហំ** សេចក្ដីថា ដែលពួកខ្ញុំជាញាតិ ៩៩ នាក់ចោមរោមហើយ ។ បទថា **នានារតនមោចិតំ** សេចក្ដីថា ទ្រង់សម្បូរ

ដោយសម្បត្តិមាំទាំ ដោយរតនៈជាច្រើន គឺទ្រង់សន្សំរតនៈច្រើន ។ បទថា **អសុរាធិបោ** សេចក្តីថា ឧបោសថកុមារសម្តែងថា ប្រៀបដូចស្តេចអសុរមិនអាចញាំញីព្រះឥន្ទ្រ ដែលជាទេវតាជាន់តាវត្តិង្សចោមរោមហើយ យ៉ាងណា ពួកមិត្តមិនញាំញីទ្រង់ ដែលពួកខ្ញុំចោមរោមការពារហើយ ទ្រង់គ្រងរាជសម្បត្តិក្នុងព្រះនគរពារាណសី មានបរិមណ្ឌល ១២ យោជន៍ ក្នុងដែនកាសី ដែលមានអាណាខេត្ត ៣០០ យោជន៍ ដូច្នេះ ។

ព្រះបាទសំវរមហារាជ ទ្រង់ប្រទានយសធំដល់ព្រះជេដ្ឋាគ្រប់អង្គ ព្រះជេដ្ឋាទាំងនោះ ប្រថាប់នៅក្នុងសម្នាក់របស់ទ្រង់អស់កន្លះខែ បានក្រាបទូលថា បពិត្រមហារាជ ពួកខ្ញុំនឹងឃ្លាំចាំរក្សាពួកចោរ ដែលបះបោរក្នុងជនបទទាំងឡាយ សូមទ្រង់សោយរាជ្យជាសុខក្នុងរាជសម្បត្តិចុះ ហើយយាងទៅកាន់ជនបទរៀងៗខ្លួន ។ ព្រះរាជាទ្រង់តាំងនៅក្នុងឱវាទរបស់ព្រះពោធិសត្វ ក្នុងទីបំផុតនៃព្រះជន្មាយុ បានធ្វើទេវនគរឲ្យពេញ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះ មកសម្តែងហើយ ទើបត្រាស់ថា ម្នាលភិក្ខុ ក្នុងកាលមុន អ្នកអត់ធន់ចំពោះឱវាទបែបនេះ ឥឡូវនេះ ហេតុអ្វី មិនធ្វើសេចក្តីព្យាយាម ហើយទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងកាលចប់សច្ចៈ ភិក្ខុនោះតាំងនៅក្នុងសោតាបត្តិផល ទ្រង់ប្រជុំជាតកថា

សំវរកុមារដែលជាព្រះរាជាក្នុងកាលនោះ បានមកជាភិក្ខុនេះ ក្នុងកាលឥឡូវនេះ ឧបោសថកុមារ ក្នុងកាលនោះ បានមកជាសារីបុត្ត ម្ចាស់បងដ៏សេសក្នុងកាលនោះ បានមកជាថេរានុថេរៈ បរិស័ទក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទ ឯអមាត្យដែលឲ្យឱវាទក្នុងកាលនោះ គឺតថាគតនេះឯង ។ល។

**អដ្ឋកថា សំវរជាតក ចប់**

# សុត្តន្តបិដក

## សុប្បារកជាតក

[ ៨៨៦ ] ( ពួកពាណិជបានពោលថា ) មនុស្សទាំងឡាយ មានប្រមុះដូចកាំបិតកោរ ងើបមុជ ( ក្នុងសមុទ្រនេះ ) ពួកយើងសូមសួរលោក ឈ្មោះសុប្បារកៈ សមុទ្រនេះ តើឈ្មោះអ្វី ។

[ ៨៨៧ ] ( ព្រះមហាសត្វបានពោលថា ) កាលសំពៅរបស់ពួកពាណិជ អ្នកស្វែងរកទ្រព្យ ចេញទៅអំពីកំពង់ករុកច្ឆៈ លឿនទៅកាន់ប្រទេសផ្សេង សមុទ្រនេះ ហៅថា ខុរមាលី ។

[ ៨៨៨ ] ( ពួកពាណិជបានពោលថា ) សមុទ្រដែលប្រាកដចំពោះមុខ ហាក់ដូចជាភ្លើង និងព្រះអាទិត្យ ពួកយើងសូមសួរលោកសុប្បារកៈ សមុទ្រនេះ តើឈ្មោះអ្វី ។

[ ៨៨៩ ] ( ព្រះមហាសត្វ ... ) កាលសំពៅរបស់ពួកពាណិជ អ្នកស្វែងរកទ្រព្យ ចេញទៅអំពីកំពង់ករុកច្ឆៈ លឿនទៅកាន់ប្រទេសផ្សេង សមុទ្រនេះ ហៅថា អគ្គិមាលី ។

[ ៨៩០ ] ( ពួកពាណិជ ... ) សមុទ្រដែលប្រាកដចំពោះមុខ ហាក់ដូចជាទឹកដោះជូរ និងទឹកដោះស្រស់ ពួកយើងសូមសួរលោកសុប្បារកៈ សមុទ្រនេះ តើឈ្មោះអ្វី ។

[ ៨៩១ ] ( ព្រះមហាសត្វ ... ) កាលសំពៅរបស់ពួកពាណិជ អ្នកស្វែងរកទ្រព្យ ចេញទៅអំពីកំពង់ករុកច្ឆៈ លឿនទៅកាន់ប្រទេសផ្សេង សមុទ្រនេះ ហៅថា ទធិមាលី ។

[ ៨៩២ ] ( ពួកពាណិជ ... ) សមុទ្ទដែលប្រាកដចំពោះមុខ ហាក់ដូចជាស្បូវក្លាំង និងសម្ពួង ពួកយើងសូមសួរលោកសុប្បារកៈ សមុទ្ទនេះ តើឈ្មោះអ្វី ។

[ ៨៩៣ ] ( ព្រះមហាសត្វ ... ) កាលសំពៅពួកពាណិជ អ្នកស្វែងរកទ្រព្យ ចេញទៅអំពីកំពង់ករុកច្ឆៈ លឿនទៅកាន់ប្រទេសផ្សេង សមុទ្ទនេះ ហៅថា កុសមាលី ។

[ ៨៩៤ ] ( ពួកពាណិជ ... ) សមុទ្ទដែលប្រាកដចំពោះមុខ ហាក់ដូចជាបបុស និងឫស្សី ពួកយើងសូមសួរលោកសុប្បារកៈ សមុទ្ទនេះ តើឈ្មោះអ្វី ។

[ ៨៩៥ ] ( ព្រះមហាសត្វ ... ) កាលសំពៅពួកពាណិជ អ្នកស្វែងរកទ្រព្យ ចេញទៅអំពីកំពង់ករុកច្ឆៈ លឿនទៅកាន់ប្រទេសផ្សេង សមុទ្ទនេះ ហៅថា នឡមាលី ។

[ ៨៩៦ ] ( ពួកពាណិជ ... ) សំឡេងរបស់អមនុស្ស គួរឲ្យភ័យខ្លាំង គួរឲ្យស្បើម ដែលពួកយើងបានឮជាក់ សមុទ្ទដែលប្រាកដចំពោះមុខ ហាក់ដូចជារណ្តៅ និងជ្រោះ ពួកយើងសូមសួរលោកសុប្បារកៈ សមុទ្ទនេះ តើឈ្មោះអ្វី ។

[ ៨៩៧ ] ( ព្រះមហាសត្វ ... ) កាលសំពៅពួកពាណិជ អ្នកស្វែងរកទ្រព្យ ចេញទៅអំពីកំពង់ករុកច្ឆៈ លឿនទៅកាន់ប្រទេសផ្សេង សមុទ្ទនេះ ហៅថា ពលវាមុខី ។

[ ៨៩៨ ] ( ព្រះមហាសត្វ ធ្វើសច្ចកិរិយាថា ) តាំងពីកាលដែលខ្ញុំរឭកឃើញនូវខ្លួន តាំងពីកាលដែលខ្ញុំ ដល់នូវភាពជាអ្នកដឹងក្តី ខ្ញុំមិនចេះក្លែងដើម្បីបៀតបៀនសត្វ សូម្បីតែមួយឡើយ សូមឲ្យសំពៅត្រឡប់ទៅកាន់ទីមានសួស្តី ដោយការពោលពាក្យសច្ចៈនេះចុះ ។

សុប្បារកជាតកទី ៩ ចប់

## ឧទ្ទាននៃជាតកនោះ គឺ

និយាយអំពីដីរីដ៏ប្រសើរចិញ្ចឹមមាតា ១ ព្រះរាជាព្រះនាមជុណ្ហៈ ១ ធម្មទេវបុត្ត ១ ព្រះរាជាព្រះនាមឧទយៈ ១ ទឹកផឹក ១ ព្រះរាជាព្រះនាមយុធញ្ជ័យ ១ ព្រះរាជាព្រះនាមទសរថ ១ ព្រះរាជាព្រះនាមសំវរៈ ១ សំពៅត្រឡប់កាន់ត្រើយ ១ ត្រូវជា ៩ ជាតក ។

ឯកាទសកនិបាត ចប់

# អដ្ឋកថា

## សុប្បារកជាតក

[ ៨៨៦-៨៩៨ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធបញ្ញាបារមី ទើបត្រាស់រឿងនេះ មានពាក្យផ្តើមថា **ឧម្មុជ្ជន្តិ និមុជ្ជន្តិ** ដូច្នេះជាដើម ។

រឿងពិស្តារមានដូច្នេះថា ថ្ងៃមួយ ក្នុងពេលល្ងាច ពួកភិក្ខុនាំគ្នារង់ចាំព្រះតថាគតយាងចេញសម្តែងធម៌ អង្គុយក្នុងធម្មសភា ពណ៌នាអំពីបញ្ញាបារមីរបស់ព្រះទសពលថា អាវុសោទាំងឡាយ អស្ចារ្យពន់ពេក ព្រះសាស្តាទ្រង់មានមហាបញ្ញា មានហាសបញ្ញា មានជវនបញ្ញា មានតិក្ខបញ្ញា មាននិព្វេធិកបញ្ញា[១] ទ្រង់ប្រកបដោយប្រាជ្ញាដែលជាឧបាយក្នុងករណីយកិច្ចនោះៗក្រាស់ស្មើដោយផែនដី ជ្រៅដូចមហាសមុទ្រ ទូលាយរហូតដល់គ្មានទីបំផុតដូចអាកាស បញ្ហាដែលតាំងឡើងក្នុងជម្ពូទ្វីប ដែលបានឈ្មោះថាកន្លងផុតព្រះទសពលទៅ មិនមានឡើយ ដូចរលកដែលតាំងឡើងក្នុងមហាសមុទ្រ គ្រាន់តែដល់ច្រាំងប៉ុណ្ណោះ ក៏បែកខ្ចាយទៅ យ៉ាងណា បញ្ហាឯណានីមួយដែលតាំងឡើង ក៏មិនបានកន្លងផុតទ្រង់ទៅបាន ដល់បាទមូលព្រះសាស្តាហើយ ក៏នឹងរលត់រលាយទៅនោះឯង ព្រះសាស្តាយាងមកហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើប

---

១- សេចក្តីពិស្តាររបស់បញ្ញាទាំងនេះ សូមកាន់យកក្នុងខុទ្ទកនិកាយ បដិសម្ភិទាមគ្គឯណោះចុះ ។

ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលតថាគតមានបញ្ញា សូម្បីក្នុងកាលមុន តថាគតក៏ជាអ្នកមានបញ្ញាដោយញាណដែលមិនចាស់ក្លា ទោះបីជាមនុស្សខ្វាក់ ក៏គង់ដឹងបានថា ក្នុងសមុទ្រនេះ មានរតនៈឈ្មោះនេះ ដោយការកំណត់ទឹកក្នុងមហាសមុទ្រ ហើយទ្រង់នាំអតីតនិទានមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទកុរុរាជ សោយរាជសម្បត្តិក្នុងដែនកុរុ មានស្រុកដែលជាកំពង់ទូក ឈ្មោះករុកច្ឆៈ[១] ។ គ្រានោះ ព្រះពោធិសត្វសោយព្រះជាតិជាកូនរបស់នាយសំពៅក្នុងដែនករុកច្ឆៈ ជាបុគ្គលគួរជ្រះថ្លា មានពណ៌សម្បុរដូចមាស ពួកញាតិថ្វាយព្រះនាមថា **សុប្បារកកុមារ** ចម្រើនដោយបរិវារច្រើន ក្នុងកាលមានអាយុ ១៦ ឆ្នាំនោះឯង សម្រេចសិប្បៈរបស់នាយសំពៅហើយ អំណឹះឥតអំពីបិតាទៅ ក៏បានជានាយសំពៅ ធ្វើនាទីជានាយសំពៅបានជាបណ្ឌិតដែលសម្បូរដោយញាណ ។ បណ្តាសំពៅដែលចេញទៅហើយ មិនមានរឿងដែលហៅថាបែកធ្លាយឡើយ ក្នុងថ្ងៃក្រោយមក ភ្នែកទាំងគូរបស់ព្រះពោធិសត្វ ប៉ះនឹងទឹកប្រៃក៏ខូចទៅ ។ ទោះបីលោកជានាយសំពៅ ក៏ធ្វើនាទីខ្លួនមិនបាន គិតថា អញគប្បីចិញ្ចឹមជីវិតដោយសារព្រះរាជាចុះ ហើយចូលទៅគាល់ព្រះរាជា កាលនោះ ព្រះរាជាទ្រង់តែងតាំងលោកជាភ្នាក់ងារវាយតម្លៃទំនិញ ។ តាំងអំពីនោះមក លោកក៏ចាំវាយតម្លៃដំរីកែវ សេះកែវ ដុំកែវមុក្តា និងកែវមណីជាដើម ។

---

១- ក្នុងទីខ្លះជា កុរុកច្ឆៈ ។

ថ្ងៃមួយ មនុស្សទាំងឡាយនាំដំរីមួយមានពណ៌ដូចផ្កាថ្ម ទូលថ្វាយដល់ព្រះរាជា ដោយគិតថានឹងជាមង្គលហត្ថី ព្រះរាជាទតដំរីនោះហើយ ត្រាស់ថា អ្នកទាំងឡាយ ចូរឲ្យបណ្ឌិតមកមើល កាលជនទាំងនោះនាំដំរីនោះទៅកាន់សម្នាក់របស់លោកហើយ ព្រះពោធិសត្វយកដៃស្ទាបសរីរៈដំរីពេញទាំងអស់ហើយពោលថា ដំរីនេះមិនសមជាមង្គលហត្ថី ដំរីនេះគ្រេចបន្តិចត្រង់ជើងក្រោយទាំងពីរ ព្រោះមេដំរីកើតកូនដំរីនេះ មិនអាចគាបកូនដោយភ្លៅបាន ហេតុនោះកូនដំរីក៏ធ្លាក់ដល់ផែនដី ទើបជើងទាំងគូគ្រេចបន្តិច ជនទាំងនោះនាំគ្នាសួរអ្នកនាំដំរីនោះមក ជនទាំងនោះក៏ពោលថា បណ្ឌិតនេះនិយាយពិត ព្រះរាជាទ្រង់ស្តាប់ហេតុនោះទ្រង់ត្រេកអរ ប្រទានរាជទ្រព្យ ៨ កហាបណៈដល់ព្រះពោធិសត្វ ។

ថ្ងៃក្រោយមកទៀត មានអ្នកនាំសេះមួយមកទូលថ្វាយដល់ព្រះរាជាថា សេះនឹងជាសេះមង្គលបាន ព្រះរាជាឲ្យបញ្ជូនសេះនោះ ទៅកាន់សម្នាក់របស់បណ្ឌិត ព្រះពោធិសត្វប្រើដៃស្ទាបសេះដូចគ្នាហើយ ប្រាប់ថា សេះនេះមិនសមគួរជាសេះមង្គលទេ ព្រោះក្នុងថ្ងៃដែលវាកើតនោះឯង មេរបស់វាងាប់ចោល ព្រោះហេតុនោះ សេះនេះមិនបានទឹកដោះពិត ទើបមិនចម្រើនតាមសមគួរ ពួកមនុស្សដែលដឹកសេះមកពោលថា ពាក្យរបស់លោកជាពាក្យពិត ព្រះរាជាទ្រង់ស្តាប់រឿងនោះក៏ទ្រង់ត្រេកអរ ព្រះរាជទានទ្រព្យ ៨ កហាបណៈដូចគ្នា ។

ថ្ងៃមួយ មានមនុស្សនាំរថមកថ្វាយដល់ព្រះរាជា ដោយគិតថា រថនេះ

នឹងជារថមង្គល ព្រះរាជាទ្រង់បញ្ជូនរថនោះទៅកាន់សម្នាក់លោក ព្រះពោធិ-សត្វស្ទាបរថនោះ សព្វគ្រប់ហើយ ពោលថា រថនេះធ្វើដោយដើមឈើប្រហោង ហេតុនោះ មិនសមគួរដល់ព្រះរាជា ពាក្យរបស់ព្រះពោធិសត្វនោះក៏ជាការពិត ព្រះរាជាទ្រង់ស្ដាប់រឿងនោះទ្រង់ត្រេកអរ ព្រះរាជទានទ្រព្យ ៨ កហាបណៈ ។ កាលនោះ មានអ្នកនាំសំពត់កម្ពលដែលមានតម្លៃច្រើន មកថ្វាយព្រះរាជាអន្ធនោះ ព្រះរាជាទ្រង់បញ្ជូនសំពត់កម្ពលនោះទៅឲ្យដល់ព្រះពោធិសត្វដូចគ្នា ព្រះពោធិសត្វយកដៃស្ទាបសំពត់នោះសព្វគ្រប់ហើយ ពោលថា សំពត់នេះ មានស្នាមកណ្ដុរកាត់មួយកន្លែង មនុស្សទាំងនោះនាំគ្នាលាតមើល ឃើញស្នាមនោះ នាំគ្នាក្រាបទូលដល់ព្រះរាជាៗ ទ្រង់ស្ដាប់រឿងនោះទ្រង់ត្រេកអរ ព្រះរាជទានទ្រព្យ ៨ កហាបណៈ ។ ព្រះពោធិសត្វគិតថា ព្រះរាជាអន្ធនេះ ឃើញភាពអស្ចារ្យដល់ម៉្លេះ ក៏នៅតែប្រទានទ្រព្យ ៨ កហាបណៈៗ ប៉ុណ្ណោះ ដែលជារង្វាន់សម្រាប់ជាងកោរកាត់ ព្រះរាជាអន្ធនេះមានពូជពង្សជាជាងកោរកាត់ពិត អញបម្រើព្រះរាជាបែបនេះធ្វើអ្វី ទៅកាន់លំនៅរបស់អញវិញល្អជាង ហើយក៏ត្រឡប់មកកាន់កំពង់ឈ្មោះករុកច្ឆៈវិញ កាលលោកស្នាក់នៅក្នុងស្រុកនោះ ពួកឈ្មួញរៀបចំសំពៅ បានប្រឹក្សាគ្នាថា នឹងធ្វើនរណាឲ្យជាប្រធាន ក៏ឃើញស្របគ្នាថា សំពៅដែលសុប្បារកបណ្ឌិតឡើងជិះទៅហើយ មិនដែលបែកធ្លុះធ្លាយឡើយ បុរសនេះជាបណ្ឌិត ឈ្លាសក្នុងឧបាយ ជាបុគ្គលភ្នែកខ្វាក់ សុប្បារកបណ្ឌិត ជាបុគ្គលឧត្ដម នាំគ្នាចូលទៅរក ប្រាប់ថា សូមអញ្ជើញអ្នកធ្វើជាប្រធានរបស់ពួកយើង កាលលោក

ពោលថា នែបាទាំងឡាយ ខ្ញុំជាមនុស្សក្អែកខ្វាក់ នឹងធ្វើនាទីបានដូចម្តេច លុះគេនាំគ្នាអង្វររឿយៗ ថា នែអ្នក ទោះអ្នកក្អែកខ្វាក់នោះឯង ក៏គង់ឧត្តមជាងពួកខ្ញុំ ព្រះពោធិសត្វទទួលពាក្យថា អ្នកទាំងឡាយ ខ្ញុំយល់ព្រម ខ្ញុំនឹងធ្វើជាប្រធានដោយការកំណត់ ដែលពួកអ្នកធ្លាប់ប្រាប់ ហើយឡើងសំពៅរបស់ជនទាំងនោះ ។ ជនទាំងនោះ នាំគ្នាចេញសំពៅទៅកាន់មហាសមុទ្រ សំពៅផុតភ័យបាន ៧ ថ្ងៃ លំដាប់នោះ ខ្យល់ពុំគួកាលក៏បក់ឡើង សំពៅអណ្តែតក្នុងសមុទ្រអស់ ៤ ខែនោះឯង ក៏ដល់សមុទ្រមួយ ឈ្មោះថា ខុរមាលី ក្នុងសមុទ្រឈ្មោះខុរមាលីនោះ ហ្វូងត្រីមានរាងកាយស្រដៀងមនុស្ស មានច្រមុះមុត នាំគ្នាហែលធ្មៀលធ្លាត់ក្នុងទឹក ពួកឈ្មួញឃើញហ្វូងត្រីនោះហើយ កាលនឹងសួរឈ្មោះសមុទ្រនោះនឹងព្រះមហាសត្វ ក៏ពោលគាថាទី ១ ថា

មនុស្សទាំងឡាយ មានច្រមុះដូចកាំបិតកោរ ងើបមុជ ( ក្នុង
សមុទ្ទនេះ ) ពួកយើងសូមសួរលោក ឈ្មោះសុប្បារកៈ សមុទ្ទ
នេះ តើឈ្មោះអ្វី ដូច្នេះ ។

ព្រះមហាសត្វត្រូវជនទាំងនោះនាំគ្នាសួរយ៉ាងនេះហើយ ស្ទាបស្ទង់តាមតម្រាអ្នកដើរសមុទ្រ ទើបពោលគាថាទី ២ ថា

កាលសំពៅរបស់ពួកពាណិជ អ្នកស្វែងរកទ្រព្យ ចេញទៅអំពី
កំពង់ភរុកច្ឆៈ លឿនទៅកាន់ប្រទេសផ្សេង សមុទ្ទនេះ ហៅថា
ខុរមាលី ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បយាតានំ** សេចក្តីថា កាលពួកអ្នកដែល

ជាឈ្មួញ នាំគ្នាចេញសំពៅអំពីកំពង់ភរុកច្ឆៈ ។ បទថា **ធនេសិនំ** សេចក្តីថា ពួកអ្នកជាឈ្មួញស្វែងរកទ្រព្យ ។ បទថា **នាវាយ វិប្បនដ្ឋាយ** សេចក្តីថា នៃបាទាំងឡាយ សមុទ្រនេះដែលសំពៅស្ទុះទៅខុសទិសដៅ រំលងសមុទ្រប្រក្រតីទៅ ព្រោះកម្លាំងកម្មរបស់អ្នកទាំងឡាយ គេហៅថា ខុរមាលី គឺ បណ្ឌិតទាំងឡាយ រមែងហៅសមុទ្រនេះយ៉ាងនេះឯង ។

ក្នុងសមុទ្រនោះមានពេជ្រច្រើន ព្រះមហាសត្វគិតថា បើអញប្រាប់ដល់ពួកជនទាំងនេះយ៉ាងនេះ ថាទីនេះជាសមុទ្រពេជ្រ ជនទាំងនេះនឹងនាំគ្នាយកពេជ្រច្រើនដោយសេចក្តីលោភ សំពៅនឹងលិចបាន ទើបមិនប្រាប់ដល់ជនទាំងនោះឡើយ ឲ្យបង្អង់សំពៅប្រើឧបាយឲ្យចាប់ខ្សែបង់សំណាញ់ចុះទៅដោយទំនងដែលចាប់ត្រី ជញ្ជូនដុំពេជ្រឡើងដាក់ក្នុងសំពៅ ឲ្យទម្លាក់ចោលទ្រព្យដែលមានតម្លៃតិច ។ សំពៅបានឆ្លងសមុទ្រនោះទៅដល់ទីឈ្មោះអគ្គិមាលីបន្តទៅទៀត សមុទ្រនោះមានពន្លឺរុងរឿង ប្រាកដដូចគំនរភ្លើងឆេះទ្រលោម និងដូចព្រះអាទិត្យក្នុងពេលថ្ងៃត្រង់ ពួកឈ្មួញនាំគ្នាសួរដោយគាថាថា

សមុទ្ទដែលប្រាកដចំពោះមុខ ហាក់ដូចជាភ្លើង និងព្រះអាទិត្យ
ពួកយើងសូមសួរលោកសុប្បារកៈ សមុទ្ទនេះ តើឈ្មោះអ្វី ដូច្នេះ ។

ចំណែកព្រះមហាសត្វ ក៏ប្រាប់រឿងនោះដល់ជនទាំងនោះ ដោយគាថាបន្តថា

កាលសំពៅរបស់ពួកពាណិជ អ្នកស្វែងរកទ្រព្យ ចេញទៅអំពី
កំពង់ភរុកច្ឆៈ លឿនទៅកាន់ប្រទេសផ្សេង សមុទ្ទនេះ ហៅថា

អគ្គិមាលី ដូច្នេះ ។

ក្នុងផ្ទៃសមុទ្រនោះ មានមាសជាច្រើន ចំណែកព្រះមហាសត្វក៏ឲ្យជនទាំងនោះ កាន់យកមាសអំពីសមុទ្រនោះដាក់ក្នុងសំពៅ ដោយន័យមុនដូចគ្នា ចំណែកសំពៅសោត់ហួសសមុទ្រនោះទៅ ដល់សមុទ្រដែលមានពណ៌ដូចទឹកដោះស្រស់ និងទឹកដោះជូរដែលមានឈ្មោះថា ទធិមាលី ពួកឈ្មួញនាំគ្នាសួរឈ្មោះរបស់សមុទ្រនោះដោយគាថានេះថា

សមុទ្ទដែលប្រាកដចំពោះមុខ ហាក់ដូចជាទឹកដោះជូរ និងទឹកដោះស្រស់ ពួកយើងសូមសួរលោកសុប្បារកៈ សមុទ្ទនេះ តើឈ្មោះអ្វី ដូច្នេះ ។

ព្រះមហាសត្វប្រាប់ដល់ជនទាំងនោះ ដោយគាថាបន្តថា

កាលសំពៅរបស់ពួកពាណិជ អ្នកស្វែងរកទ្រព្យ ចេញទៅអំពីកំពង់ករុកច្ឆៈ លឿនទៅកាន់ប្រទេសផ្សេង សមុទ្ទនេះ ហៅថា ទធិមាលី ដូច្នេះ ។

ក្នុងបាតសមុទ្រនោះឯង មានប្រាក់ជាច្រើន កាលនោះ ព្រះពោធិសត្វក៏ឲ្យជនទាំងនោះ ជញ្ជូនប្រាក់ដាក់សំពៅដោយឧបាយ ។ សំពៅសោត់ធ្វងផុតសមុទ្រនោះ ដល់សមុទ្រដែលមានពណ៌ខៀវ បញ្ចេញពន្លឺដូចស្បូវភ្លាំងពណ៌ខៀវ និងដូចសម្ទូងដែលកំពុងលាស់ខ្ចី ដែលមានឈ្មោះថា កុសមាលី ពួកឈ្មួញនាំគ្នាសួរដល់ឈ្មោះសមុទ្រនោះ ដោយគាថាថា

សមុទ្ទដែលប្រាកដចំពោះមុខ ហាក់ដូចជាស្បូវភ្លាំង និងសម្ទូង

ពួកយើងសូមសួរលោកសុប្បារកៈ សមុទ្រនេះ តើឈ្មោះអ្វី
ដូច្នេះ ។

ព្រះពោធិសត្វឆ្លើយដោយគាថាដូច្នេះថា

កាលសំពៅពួកពាណិជ អ្នកស្វែងរកទ្រព្យ ចេញទៅអំពីកំពង់
ករុកច្ឆៈ លឿនទៅកាន់ប្រទេសផ្សេង សមុទ្រនេះ ហៅថា
កុសមាលី ដូច្នេះ ។

ក្នុងសមុទ្រនោះ មានកែវនិលមណី ( កែវមរកត ) ជាច្រើន ព្រះពោធិសត្វក៏ឲ្យជនទាំងនោះ ជញ្ជូនកែវទាំងនោះដាក់សំពៅដោយឧបាយ ។ សំពៅក៏ឆ្លងសមុទ្រនោះ ទៅដល់សមុទ្រដែលប្រាកដដូចព្រៃបបុស និងព្រៃឫស្សី ដែលមានឈ្មោះថានឡមាលី ពួកឈ្មួញនាំគ្នាសួរឈ្មោះរបស់សមុទ្រនោះដោយគាថាថា

សមុទ្រដែលប្រាកដចំពោះមុខ ហាក់ដូចជាបបុស និងឫស្សី ពួក
យើងសូមសួរលោកសុប្បារកៈ សមុទ្រនេះ តើឈ្មោះអ្វី ដូច្នេះ ។

ព្រះមហាសត្វប្រាប់សមុទ្រនោះ ដោយគាថាបន្តថា

កាលសំពៅពួកពាណិជ អ្នកស្វែងរកទ្រព្យ ចេញទៅអំពីកំពង់
ករុកច្ឆៈ លឿនទៅកាន់ប្រទេសផ្សេង សមុទ្រនេះ ហៅថា
នឡមាលី ដូច្នេះ ។

ក្នុងសមុទ្រនោះមានកែវមក៌ត និងកែវពិទូរ្យជាច្រើន ព្រះពោធិសត្វឲ្យជញ្ជូនដាក់សំពៅដោយឧបាយមុននោះឯង ។

ន័យម្យ៉ាងទៀត បទថា **ឆគ្គោ** បានដល់ ដើមបបុសខ្ទួយ ឬ បបុសក្តាម បបុសប្រភេទនោះមានពណ៌ក្រហម ចំណែកដែលថា ដើមឫស្សីនោះ ជាឈ្មោះរបស់កែវប្រពាលនោះឯង សមុទ្រនោះច្រើនដោយកែវប្រពាល ទើបមានពន្លឺក្រហមប្រាល ។ ហេតុនោះ ទើបពួកឈ្មួញនាំគ្នាសួរថា ដូចដើមបបុស និងដើមឫស្សី ។

ព្រះមហាសត្វឲ្យជនទាំងនោះ ជញ្ជូនកែវប្រពាលអំពីសមុទ្រនោះ ពួកឈ្មួញទាំងនោះ ឆ្លងផុតសមុទ្រនឡមាលីទៅហើយ ជួបសមុទ្រមួយឈ្មោះថា ពលវាមុខៈ ទឹកក្នុងសមុទ្រនោះក្តៅផ្សាយឡើង ហាក់ដូចជាប់តគ្នារហូតទៅ ទឹកដែលផ្សាយឡើងជាជួររហូតទៅក្នុងផ្ទៃសមុទ្រនោះ ប្រាកដដូចជ្រោះធំក្បែរថ្លាស ដាច់ដោយចំណែកទូទៅ កាលរលកបោកឡើង ក៏ដូចជាជ្រោះជាប់តគ្នា សំឡេងគួរខ្លាចបានលាន់ឮឡើង ដូចទម្លាយត្រចៀកទាំងពីរ និងពុះប្រៀកនូវហទយៈ ពួកឈ្មួញឃើញសមុទ្របែបនោះហើយ នាំគ្នាខ្លាចរន្ធត់ សួរឈ្មោះរបស់សមុទ្រនោះដោយគាថាថា

សំឡេងរបស់អមនុស្ស គួរឲ្យភ័យខ្លាំង គួរឲ្យស្ញែម ដែលពួក
យើងបានឮជាក់ សមុទ្ទដែលប្រាកដចំពោះមុខ ហាក់ដូចជារណ្តៅ
និងជ្រោះ ពួកយើងសូមសួរលោកសុប្បារកៈ សមុទ្ទនេះ តើ
ឈ្មោះអ្វី ដូច្នេះ ។

បទថា **សុយ្យតិ មានុសោ** សេចក្តីថា សំឡេងដែលស្តាប់ជាសំឡេងអមនុស្ស ។

ព្រះមហាសត្វប្រាប់ឈ្មោះរបស់សមុទ្រនោះ ដោយគាថាដូច្នេះថា

កាលសំពៅពួកពាណិជ អ្នកស្វែងរកទ្រព្យ ចេញទៅអំពីកំពង់ ភរុកច្ឆៈ លឿនទៅកាន់ប្រទេសផ្សេង សមុទ្ទនេះ ហៅថា ពល-វាមុខី ដូច្នេះ ។

ព្រះមហាសត្វ កាលប្រាប់ឈ្មោះរបស់សមុទ្រនោះ ដោយគាថាតាមលំដាប់ ពោលថា បាទាំងឡាយ បណ្តាសំពៅដែលដល់សមុទ្រពលវាមុខៈនេះ ដែលអាចត្រឡប់បាន មិនមានឡើយ សមុទ្រនេះញុំាងសំពៅដែលធ្លាក់ចូលទៅហើយ ឲ្យលិចចុះរហូតបែកធ្លាយ ។ ឯពួកមនុស្សប្រមាណ ៧០០ នាក់ នាំគ្នាឡើងសំពៅនោះទៅ ជនទាំងនោះនាំគ្នាខ្លាចចំពោះមរណភ័យ បន្លឺសំឡេងតក់ស្លុតដូចគ្នាតែមួយ ដូចហ្វូងសត្វដែលកំពុងឆេះក្នុងអវីចីមហានរក ដូច្នោះ ព្រះមហាសត្វត្រិះរិះថា វៀរអាត្មាអញហើយ អ្នកដទៃ ឈ្មោះថា អាចធ្វើនូវសួស្តីឲ្យដល់ជនទាំងនេះ មិនមានឡើយ អញត្រូវតាំងសច្ចកិរិយាធ្វើសួស្តីឲ្យដល់ជនទាំងនេះ ហៅពួកជនទាំងនោះមកពោលថា បាទាំងឡាយ ចូរពួកអ្នកឲ្យយើងងូតទឹកដោយទឹកក្រអូប ស្លៀកនូវសំពត់ថ្មី ត្រៀមថាសទឹកទុកត្រង់ចន្ទ្លុតសំពៅឲ្យធាប់ចុះ ឈ្មួញទាំងនោះនាំគ្នាធ្វើតាមនោះ ។ ព្រះមហាសត្វកាន់យកថាសពេញដោយទឹកដោយដៃទាំងពីរ ឈរត្រង់មុខសំពៅ កាលនឹងធ្វើនូវសច្ចកិរិយា ទើបពោលគាថាចុងក្រោយថា

តាំងពីកាលដែលខ្ញុំរឭកឃើញនូវខ្លួន តាំងពីកាលដែលខ្ញុំដល់នូវភាពជាអ្នកដឹងក្តី ខ្ញុំមិនចេះក្លែងដើម្បីបៀតបៀនសត្វ សូម្បីតែមួយ

ឡើយ សូមឲ្យសំពៅត្រឡប់ទៅកាន់ទីមានសួស្តី ដោយការពោលពាក្យសច្ចៈនេះចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យតោ** សេចក្តីថា ខ្ញុំរឭកខ្លួនបាន ចាប់តាំងពីកាលណា អធិប្បាយថា ខ្ញុំដល់នូវភាពជាអ្នកដឹងក្តីហើយ ចាប់តាំងអំពីកាលណា ។ បទថា **ឯកបាណម្បិ ហឹសិតំ** សេចក្តីថា ក្នុងចន្លោះនេះ ខ្ញុំមិនធ្លាប់ក្លែងសម្លាប់សត្វ សូម្បីត្រឹមតែស្រមោចក្រហមមួយឡើយ ។ បទនេះត្រឹមតែជាទេសនាប៉ុណ្ណោះ ។ ព្រះពោធិសត្វ ធ្វើសច្ចកិរិយាដោយអំណាចនៃសីល ៥ យ៉ាងនេះថា ទ្រព្យអ្នកដទៃ កំណាត់ត្រឹមតែស្បូវក្លាំង ក៏មិនធ្លាប់កាន់យកឡើយ ភរិយារបស់អ្នកដទៃ មិនធ្លាប់សម្លឹងមើលដោយសេចក្តីលោភ ពាក្យកុហកក៏មិនធ្លាប់ពោល ទឹកស្រវឹងក៏មិនធ្លាប់ផឹក សូម្បីមួយតំណក់ដែលជ្រលក់ដោយចុងស្បូវក្លាំង ។

កាលព្រះមហាសត្វធ្វើសច្ចកិរិយាហើយ ក៏ស្រោចទឹកក្នុងថាសដែលពេញដោយទឹកលើចង្កូតសំពៅ សំពៅដែលរសាត់ខុសទិសអស់ ៤ ខែ ក៏បែរមុខត្រឡប់ទៅដល់កំពង់ភរុកច្ឆៈត្រឹមមួយថ្ងៃប៉ុណ្ណោះ ដោយអានុភាពនៃសច្ចៈ ដូចបុគ្គលមានឫទ្ធិ បណ្តាលឡើងដូច្នោះ លុះដល់ហើយ ក៏ជ្រុលឡើងទៅលើគោកបាន ៨ ឧសភៈ ឈប់ត្រង់ទ្វារផ្ទះរបស់នាយសំពៅល្មម ។

ព្រះមហាសត្វបែងចែកមាស ប្រាក់ កែវមណី កែវប្រពាល និងពេជ្រឲ្យដល់ឈ្មួញទាំងនោះ ឲ្យឱវាទដល់ជនទាំងនោះថា រតនៈមានប្រមាណប៉ុណ្ណេះ ក៏ជាការល្មមហើយសម្រាប់អ្នកទាំងឡាយ ពួកអ្នកកុំទៅកាន់សមុទ្រទៀតឡើយ ធ្វើបុណ្យផ្សេងៗ មានឲ្យទានជាដើម ដរាបដល់អស់ជីវិត បានធ្វើឋានសួគ៌ឲ្យពេញហើយ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះ មកសម្តែងហើយ ត្រាស់បញ្ជាក់ថា ម្នាលភិក្ខុទាំងឡាយ សូម្បីក្នុងកាលមុន តថាគតក៏មានបញ្ញាច្រើនយ៉ាងនេះដូចគ្នា ហើយទ្រង់ប្រជុំជាតកថា បរិស័ទរបស់សុប្បារកៈពិការក្អែកក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទក្នុងកាលឥឡូវនេះ ចំណែកសុប្បារកបណ្ឌិតក្នុងកាលនោះ គឺតថាគតនេះឯង ៕

**អដ្ឋកថា សុប្បារកជាតក ចប់**

**ឯកាទសកនិបាត ចប់**

# សុត្តន្តបិដក
## ទ្វាទសនិបាតជាតក

### ចុល្លកុណាលជាតក

[ ៨៩៩ ] ( សត្វតាវ៉ៅបានពោលថា ) បុរសដែលមិនជាប់ចំពាក់ដោយទេវតា ( ខ្មោចមិនចូល ) មិនគួរជឿ ( នូវសីល និងវត្ត ) របស់ពួកស្ត្រីជាអ្នកឈ្លានពាន មានចិត្តរហ័ស មិនដឹងនូវឧបការគុណ ដែលគេធ្វើហើយ ជាអ្នកទ្រុស្តមិត្តទេ ។

[ ៩០០ ] ស្ត្រីទាំងនោះ មិនដឹងនូវឧបការគុណ ដែលគេធ្វើហើយដល់ខ្លួន មិនដឹងច្បាស់នូវកិច្ច ( ដែលខ្លួនត្រូវធ្វើ ) មិនដឹងច្បាស់នូវមាតាបិតា ឬបងប្អូន មិនអៀនខ្មាស តែងប្រព្រឹត្តកន្លងច្បាប់ជាធម្មតា លុះក្នុងអំណាចនៃចិត្តរបស់ខ្លួន ។

[ ៩០១ ] ស្ត្រីទាំងនោះ តែងលះបង់នូវបុរសនោះ ដែលជាទីស្រឡាញ់ ជាទីគាប់ចិត្ត សូម្បីនៅជាមួយគ្នា អស់កាលយូរ ជាអ្នកអនុគ្រោះ សូម្បីស្មើដោយជីវិត ក្នុងគ្រោះថ្នាក់ទាំងឡាយផង ក្នុងកិច្ចការទាំងឡាយផង ព្រោះហេតុនោះ ខ្ញុំមិនស្និទ្ធស្នាលនឹងស្ត្រីទាំងឡាយឡើយ ។

[ ៩០២ ] ព្រោះថា ចិត្តរបស់ពួកស្ត្រីប្រែប្រួល ដូចជាសត្វស្វា ឬដូចជាម្លប់ឈើ ចិត្តរបស់ពួកស្ត្រីប្រាស់ប្រាល់ វិលវង់ ដូចជា

ខ្នងកង់កាលវិលទៅ ដូច្នោះ ។

[ ៩០៣ ] ក្នុងកាលដែលស្ត្រីទាំងនោះ សម្លឹងឃើញទ្រព្យរបស់បុរស មានសភាពគួរយកបាន ក៏នាំបុរសនុ៎ះទៅ ( កាន់អំណាចខ្លួន ) ដោយសម្ដីដ៏ផ្អែមល្ហែមទាំងឡាយ ដូចជាពួកជន អ្នកនៅក្នុងដែនកម្ពោជៈ កាលនាំសេះទៅកាន់អំណាចខ្លួន ដោយស្មៅ ដូច្នោះ ។

[ ៩០៤ ] ក្នុងកាលដែលស្ត្រីទាំងនោះ សម្លឹងមើលមិនឃើញទ្រព្យរបស់បុរស មានសភាពគួរយកបានទេ ក៏គេចចៀសបុរសនុ៎ះដោយជុំវិញ ដូចជាបុគ្គលអ្នកឆ្លង ទៅដល់ត្រើយស្ទឹងហើយ ក៏វៀរបង់នូវក្បូន ដូច្នោះ ។

[ ៩០៥ ] ស្ត្រីទាំងនោះ មានសេចក្ដីប្រៀបធៀបដោយជ័រ ដូចជាភ្លើងដែលស៊ីនូវវត្ថុគ្រប់យ៉ាង មានមាយាដ៏ក្លៀវក្លា ដូចជាស្ទឹងមានខ្សែទឹកដ៏រហ័ស ព្រោះថាស្ត្រីទាំងនុ៎ះ តែងសេពនូវបុរសជាទីស្រឡាញ់ និងមិនជាទីស្រឡាញ់ ដូចជាទូកដែលអែបនៅច្រាំងទាំងខាងអាយ ទាំងច្រាំងខាងនាយ ដូច្នោះ ។

[ ៩០៦ ] ស្ត្រីទាំងនោះ មិនមែនរបស់បុរសម្នាក់ មិនមែនរបស់បុរសពីរនាក់ទេ ដូចជាភាជនផ្សារ ដែលគេរៀបហើយ បុរសណាសម្គាល់នូវស្ត្រីទាំងនោះ ថាជារបស់អញ បុរសនោះ គប្បីចងខ្យល់ ដោយសំណាញ់បាន ។

[ ៩០៧ ] ស្ពឹង ផ្លូវ តៀមស្រា រោងសម្រាប់ប្រជុំ និងអណ្តូង យ៉ាងណា ធម្មតាស្ត្រីទាំងឡាយក្នុងលោក ក៏យ៉ាងនោះដែរ ឯវេលារបស់ស្ត្រីទាំងនោះ មិនមានឡើយ ។

[ ៩០៨ ] ស្ត្រីទាំងនោះ ស្មើដោយភ្លើងឆេះឆ្នាំងខ្លាញ់ ឧបមាដោយក្បាលពស់វែក ឬដូចជាពួកគោស៊ីច្បិចតែចុងស្មៅដ៏ប្រសើរៗ ខាងក្រៅ ។

[ ៩០៩ ] នរជនគប្បីសង្រួមជានិច្ច ហើយគប់រកនូវជនទាំងនេះ គឺភ្លើង ១ ដំរី ១ ពស់វែក ១ ស្តេចដែលបានមុទ្ធាភិសេកហើយ ១ ពួកស្ត្រីទាំងអស់ ១ ភាវៈទៀងទាត់របស់ជនទាំងនោះ គេស្គាល់បានដោយក្រ ។

[ ៩១០ ] ស្ត្រីមានសម្បុរល្អធេីត បុរសមិនគួរសេពទេ ស្ត្រីជាទីស្រឡាញ់នៃបុរសច្រើនគ្នា បុរសមិនគួរសេពទេ ស្ត្រីប្រសប់រាំច្រៀង បុរសមិនគួរសេពទេ ស្ត្រីជាប្រពន្ធរបស់បុគ្គលដទៃ បុរសមិនគួរសេពទេ ស្ត្រី ( គប់រកបុរស ) ព្រោះហេតុតែទ្រព្យ បុរសមិនគួរសេពទេ ស្ត្រីទាំង ៥ ពួកនេះ បុរសមិនគួរសេពឡើយ ។

**ចុល្លកុណាលជាតកទី ១ ចប់**

# អដ្ឋកថា

# ទ្វាទសកនិបាតជាតក

## ចុល្លកុណាលជាតក

[ ៨៩៩-៩១០ ] *ជាតកនេះមានពាក្យផ្តើមថា* **ខុទ្ទានំ លហុចិត្តានំ** *ដូច្នេះជាដើម នឹងមានជាក់ច្បាស់ក្នុងកុណាលជាតក ( អសីតិនិបាត ) ឯនោះ ។ល។*

**អដ្ឋកថា ចុល្លកុណាលជាតក ចប់**

# សុត្តន្តបិដក

## ភទ្ទសាលជាតក

[ ៩១១ ] ( ព្រះរាជាទ្រង់ត្រាស់ថា ) អ្នកជាអ្វី ដែលមានសំពត់ទាំងឡាយដ៏ស្អាត បានឋិតនៅលើអាកាសវេហាស៍ ទឹកភ្នែកទាំងឡាយ របស់អ្នកហូរចេញ តើដោយហេតុអ្វី ភ័យមកចំពោះអ្នកព្រោះអ្វី ។

[ ៩១២ ] ( ទេវរាជត្រាស់ថា ) បពិត្រព្រះសម្មតិទេព ជនទាំងឡាយ ក្នុងដែនរបស់ព្រះអង្គ ស្គាល់ច្បាស់នូវខ្ញុំថា ជាភទ្ទ-សាលព្រឹក្ស កាលខ្ញុំឋិតនៅ ( ក្នុងឧទ្យាននេះ ) អស់ ៦ ម៉ឺនឆ្នាំ ជនទាំងឡាយបានបូជាហើយ ។

[ ៩១៣ ] បពិត្រព្រះអង្គជាម្ចាស់ទិស ( ព្រះរាជាទាំងឡាយពីដើមក្នុងនគរនេះ ) កាលឲ្យគេសាងទីក្រុងទាំងឡាយផង ដំណាក់ទាំងឡាយផង ប្រាសាទផ្សេងៗ ផង មិនដែលបៀតបៀនខ្ញុំឡើយ ព្រះរាជាទាំងនោះបូជាខ្ញុំ យ៉ាងណា សូមព្រះអង្គបូជាខ្ញុំយ៉ាងនោះដែរ ។

[ ៩១៤ ] ( ព្រះរាជា ... ) ខ្ញុំមិនធ្លាប់ឃើញអ្នក ជាដើមឈើធំដោយកាយរបស់អ្នកទេ អ្នកជាឈើមានទ្រង់ទ្រាយដ៏ល្អ ដោយកម្ពស់ និងទំហំ និងកំណើត ។

[ ៩១៥ ] ម្នាលយក្ខ ខ្ញុំនឹងឲ្យគេធ្វើប្រាសាទ មានសសរតែមួយជាទីរីករាយនៃចិត្ត ខ្ញុំនឹងនាំយកអ្នក ចូលទៅក្នុងប្រាសាទនោះ

ជីវិតរបស់អ្នក ( នឹងមាន ) អស់កាលយូរ ។

[ ៩១៦ ] ( ទេវរាជ ... ) ( បើ ) ព្រះហឫទ័យ ( របស់ទ្រង់ ) កើតឡើងយ៉ាងនេះ សេចក្ដីព្រាត់ប្រាស ( ចាកភទ្ទសាលព្រឹក្ស ) ជាសរីរៈ ( របស់ខ្ញុំ នឹងមានប្រាកដ ) ( កាលបើយ៉ាងនេះ ) សូមព្រះអង្គកាត់ខ្ញុំ ជាច្រើនកំណាត់ កាត់ជាកំណាត់តូចធំចុះ ។

[ ៩១៧ ] តែសូមព្រះអង្គកាត់ត្រង់ចុង និងកណ្ដាល ( មុន ) រួចកាត់ត្រង់គល់ក្នុងកាលជាខាងក្រោយ កាលបើខ្ញុំត្រូវព្រះអង្គកាត់យ៉ាងនេះ សេចក្ដីស្លាប់មិនគប្បីជាទុក្ខទេ ។

[ ៩១៨ ] ( ព្រះរាជា ... ) ដូចយ៉ាងបុគ្គលកាត់ដៃ និងជើងផង ត្រចៀក និងច្រមុះផង ឲ្យស្លាប់បាត់ជីវិត តពីនោះ គេកាត់នូវក្បាលក្នុងកាលខាងក្រោយ សេចក្ដីស្លាប់នោះ ក៏ជាទុក្ខដែរ ។

[ ៩១៩ ] ម្នាលភទ្ទសាលព្រឹក្ស ជាម្ចាស់នៃព្រៃ ការកាត់ជាកំណាត់ស្រួលឬ ព្រោះហេតុអ្វី ប្រារព្ធហេតុអ្វី បានជាអ្នកចង់ឲ្យគេកាត់ជាកំណាត់ ។

[ ៩២០ ] ( ទេវរាជ ... ) បពិត្រមហារាជ ខ្ញុំចង់ឲ្យគេកាត់ជាកំណាត់ ព្រោះអាស្រ័យហេតុដែលប្រកបដោយហេតុណា សូមព្រះអង្គទ្រង់ស្ដាប់នូវហេតុនោះ របស់ខ្ញុំចុះ ។

[ ៩២១ ] ពួកឈើជាញាតិរបស់ខ្ញុំ ចម្រើនដុះដាលដោយសេចក្ដីសុខ កើតក្នុងទីមិនមានខ្យល់នៅជិតខាងខ្ញុំ ( កាលបើ

ទ្រង់កាប់រំលំខ្ញុំ ) ខ្ញុំមុខជានឹងរលំសង្កត់ពួកឈើជាញាតិនោះ សេចក្តីទុក្ខ នឹងកើតមានដល់ពួកឈើជាញាតិដទៃទៀត ។

[ ៩២២ ] ( ព្រះរាជា ... ) ម្នាលកុទ្ទុសាលព្រឹក្សជាម្ចាស់នៃព្រៃ អ្នកគិតនូវហេតុដែលមានសភាពគួរគិត អ្នកជាឈើប្រាថ្នានូវប្រយោជន៍ដល់ពួកឈើជាញាតិ ម្នាលសម្លាញ់ ខ្ញុំឲ្យអភ័យដល់អ្នក ។

## កុទ្ទុសាលជាតកទី ២ ចប់

# អដ្ឋកថា

## ភទ្ទសាលជាតក

[ ៩១១-៩២២ ] ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការបំពេញប្រយោជន៍ដល់ព្រះញាតិ ត្រាស់រឿងនេះ មានពាក្យផ្ដើមថា **កា ត្វំ សុទ្ធេហិ វត្ថេហិ** ដូច្នេះជាដើម ។

រឿងពិស្ដារមានដូច្នេះថា ការឆាន់ជាប្រចាំរបស់ភិក្ខុ ៥០០ រូប ប្រព្រឹត្តទៅក្នុងនិវេសន៍របស់អនាថបិណ្ឌិក ក្នុងនគរសាវត្ថីដោយទំនងនោះ ក្នុងនិវេសន៍របស់នាងវិសាខា និងក្នុងព្រះរាជវាំងរបស់ព្រះបាទកោសល ( ក៏ដូចគ្នា ) ។ ក្នុងរាជនិវេសន៍នោះ ភ្នាក់ងារដែលតែងថ្វាយភោជនមានរសដ៏ប្រសើរផ្សេងៗដោយពិត តែបុគ្គលណាម្នាក់ជាទីស្និទ្ធស្នាលរបស់ភិក្ខុមិនមានឡើយ ហេតុនោះ ទើបពួកភិក្ខុមិនសូវឆាន់ក្នុងព្រះរាជនិវេសន៍ ភិក្ខុទាំងនោះទទួលភត្ត នាំគ្នាទៅកាន់ផ្ទះរបស់អនាថបិណ្ឌិក ឬនាងវិសាខា ឬបើមិនដូច្នោះ ក៏ឆាន់ក្នុងផ្ទះបុគ្គលដែលស្និទ្ធស្នាលដទៃៗ ។ ថ្ងៃមួយ ព្រះរាជាទ្រង់បញ្ជូនបណ្ណាការ ដែលមនុស្សនាំមកទៅកាន់រោងឆាន់ថា ចូរពួកអ្នកប្រគេនដល់ពួកភិក្ខុ កាលរាជបុរសក្រាបទូលថា ក្នុងរោងឆាន់មិនមានភិក្ខុ ក៏ត្រាស់សួរថា លោកទៅទីណាអស់ហើយ ទ្រង់បានព្វថា នាំគ្នាទៅឆាន់ត្រង់ផ្ទះរបស់បុគ្គលដែលខ្លួនស្និទ្ធស្នាល លុះទ្រង់សោយព្រះក្រយាហារព្រឹកហើយ យាងទៅកាន់សម្នាក់របស់ព្រះសាស្ដា ទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ឈ្មោះថា ភោជនមានអ្វីជាកំពូល ព្រះសាស្ដាត្រាស់ថា មហាបពិត្រ ភោជនមានការស្និទ្ធស្នាលជាកំពូល ព្រោះគ្រាន់តែបាយក្ដាំង និងបាយចុងអង្ករ ដែលមនុស្ស

ស្និទ្ធស្នាលឲ្យ រមែងមានរសឆ្ងាញ់ ។ ព្រះរាជាទូលសួរថា បពិត្រព្រះអង្គ ការស្និទ្ធស្នាលរបស់ភិក្ខុ នឹងមានជាមួយបុគ្គលពួកណា ព្រះសាស្តាត្រាស់ថា មហាបពិត្រ គឺមានជាមួយពួកញាតិ ឬជាមួយត្រកូលនៃព្រះសេក្ខៈ ។

កាលនោះ ព្រះរាជាទ្រង់ព្រះតម្រិះថា អាត្មាអញត្រូវយាងព្រះរាជធីតានៃសក្យៈមួយអង្គ មកតែងតាំងជាអគ្គមហេសីដោយវិធីនេះ ការស្និទ្ធស្នាលដ៏ក្រៃលែង ជាញាតិរបស់ពួកភិក្ខុ ជាមួយអញគង់មានពិតប្រាកដ ទ្រង់ក្រោកអំពីអាសនៈ ទៅកាន់ព្រះរាជនិវេសន៍របស់ទ្រង់ បញ្ជូនទូតទៅកាន់នគរកបិលពស្តុ ដោយព្រះតម្រាស់ថា សូមសក្យៈឲ្យធីតាដល់ខ្ញុំ ខ្ញុំត្រូវការភាពជាញាតិជាមួយពួកទ្រង់ ។ ស្តេចសក្យៈស្តាប់ពាក្យនោះហើយ ប្រឹក្សាគ្នាថា ពួកយើងនៅក្នុងទឹកដីដែលប្រព្រឹត្តទៅក្នុងអាណារបស់ស្តេចកោសល បើពួកយើងមិនឲ្យទារិកា នឹងមានពៀរធំ តែបើយើងឲ្យសោត ខ្សែស្រឡាយរបស់ពួកយើង នឹងលាយឡំដោយឈាមជ័រជទៃ គួរធ្វើយ៉ាងណាល្អហ្ន៎ ។ កាលនោះ ស្តេចមហានាម ត្រាស់នឹងពួកសក្យៈនោះថា កុំក្តៅក្រហាយឡើយ ធីតារបស់ខ្ញុំឈ្មោះវាសភខត្តិយា កើតក្នុងផ្ទៃទាសីឈ្មោះនាគមុណ្ឌា អាយុបាន ១៦ ឆ្នាំ មានរូបរាងល្អល្អះ ដល់នូវលម្អក្រៃលែង ដូចគ្នានឹងពង្សក្សត្រ ដោយអំណាចរបស់បិតា ពួកយើងនឹងបញ្ជូននាងទៅឲ្យដល់ព្រះបាទកោសលនោះថា ជាខត្តិយកញ្ញា ។ ស្តេចសក្យៈទាំងឡាយទទួលថា សាធុ បានហៅពួកទូតមកពោលថា ជាការប្រពៃ ពួកខ្ញុំនឹងថ្វាយទារិកា ចូរពួកអ្នកទទួលនាងទៅឥឡូវនេះចុះ ។ ពួកទូតស្តាប់ពាក្យនោះហើយ គិតគ្នាថា ធម្មតាសក្យរាជទាំងនេះ

ប្រកាន់ខ្លួន រឹងត្អឹងក្រៃលែង ព្រោះអាស្រ័យជាតិ គប្បីពោលថា នាងនេះស្មើជាមួយពួកយើង ហើយឲ្យស្រីដែលមិនស្មើគ្នាក៏បាន ពួកយើងនឹងព្រមទទួលយក តែស្រីដែលរួមបរិភោគជាមួយជនទាំងនេះប៉ុណ្ណោះ ទូតទាំងនោះនាំគ្នាទូលយ៉ាងនេះថា បើពួកទូលបង្គំទទួល ទទួលតែស្រីដែលសោយជាមួយទ្រង់ ទើបស្តេចសក្យៈទាំងឡាយឲ្យទីសម្រាកដល់ពួកទូត គិតគ្នាថា យើងនឹងធ្វើដូចម្តេចហ្ន៎ ស្តេចមហានាមត្រាស់ថា ពួកអ្នកកុំក្តៅក្រហាយឡើយ ខ្ញុំនឹងធ្វើនូវឧបាយ ក្នុងពេលដែលខ្ញុំកំពុងបរិភោគ ចូរពួកអ្នកប្រដាប់តាក់តែងនាងវាសភខត្តិយា ហើយនាំមក លុះខ្ញុំចាប់ដុំបាយមួយដុំប៉ុណ្ណោះ ចូរពួកអ្នកបញ្ជូនសំបុត្រឲ្យមើល ប្រាប់ថា ព្រះរាជាអង្គនោះ ទ្រង់បញ្ជូនសំបុត្រមក សូមទ្រង់មើលសំបុត្រនេះសិន ដូច្នេះ ។ ស្តេចសក្យៈទាំងនោះទទួលថា សាធុ កាលព្រះរាជាកំពុងសោយ ក៏តាក់តែងកុមារិកា ។

ស្តេចមហានាមត្រាស់ថា ចូរពួកអ្នកនាំកូនស្រីរបស់ខ្ញុំមក ចូរនាងបរិភោគរួមជាមួយខ្ញុំចុះ កាលនោះស្តេចសក្យៈ នាំគ្នាតាក់តែងនាង ធ្វើជាយឺតយូរបន្តិច ហើយនាំមក នាងគិតថា នឹងបរិភោគរួមជាមួយបិតា ទើបលូកព្រះហស្តចុះក្នុងថាសតែមួយ ព្រះបាទមហានាមទ្រង់កាន់ពំនូតបាយមួយជាមួយនាង ហើយទ្រង់ដាក់ក្នុងព្រះឱស្ឋ លុះទ្រង់លូកព្រះហស្តដើម្បីពំនូតទីពីរ ពួកសក្យៈក៏ហុចសំបុត្រចូលទៅថ្វាយថា បពិត្រព្រះអង្គ ព្រះរាជាឈ្មោះនោះទ្រង់បញ្ជូនសំបុត្រមក សូមទ្រង់ស្តាប់សាសន៍នេះសិនចុះ ព្រះមហានាមត្រាស់ថា នែនាង ចូរនាងបរិភោគចុះ ទ្រង់ដាក់ព្រះហស្តស្តាំក្នុងថាសនោះឯង ទ្រង់

ទទួលសំបុត្រដោយព្រះហស្តឆ្វេង ទ្រង់មើលសំបុត្រ កាលព្រះរាជាកំពុងទត សំបុត្រនោះឯង នាងក៏សោយស្រេច ។ ក្នុងកាលនាងបរិភោគស្រេចហើយ ទើបព្រះរាជាលាងព្រះហស្ត ខ្ពុរព្រះឱស្ឋ ពួកទូតទាំងនោះឃើញហើយ ទាំគ្នាដាក់ចិត្តថា ស្រីនោះជាព្រះធីតារបស់ព្រះមហានាមនេះ ដោយប្រាសចាកការសង្ស័យ មិនអាចដឹងសេចក្តីនោះបាន ព្រះបាទមហានាមទ្រង់បញ្ជូនធីតាទៅដោយបរិវារធំ ពួកទូតទាំងនោះនាំនាងមកកាន់នគរសាវត្ថី ក្រាបទូលថា កុមារីនេះសម្បូរដោយជាតិ ជាធីតារបស់ព្រះបាទមហានាម ។

កាលនោះ ព្រះរាជាទ្រង់ស្តាប់រឿងនោះ ទ្រង់សប្បាយព្រះហឫទ័យ ឲ្យតាក់តែងព្រះនគរទាំងមូល ឲ្យនាងស្ថិតនៅលើគំនររតនៈ ទ្រង់អភិសេកស្ថាបនាក្នុងតំណែងអគ្គមហេសី នាងបានជាទីស្រឡាញ់ ជាទីត្រេកអររបស់ព្រះរាជា ។ មិនយូរប៉ុន្មាន នាងក៏តាំងគភ៌ ព្រះរាជាបានប្រទានគ្រឿងបរិហារគភ៌ គ្រប់កំណត់ទសមាស នាងប្រសូតព្រះរាជបុត្រ មានពណ៌ដូចមាស ។ ក្នុងថ្ងៃថ្វាយព្រះនាមរបស់ព្រះរាជកុមារនោះ ព្រះរាជាទ្រង់បញ្ជូនដំណឹងទៅកាន់សម្នាក់អយ្យការបស់ព្រះរាជកុមារថា ធីតារបស់សក្យរាជវាសភខត្តិយាប្រសូតព្រះរាជបុត្រ តើទ្រង់ថ្វាយព្រះនាមដល់បុត្រនោះដូចម្តេច ។ អមាត្យអ្នកនាំរាជសាសន៍នោះ ជាមនុស្សត្រចៀកថ្ងន់ ចូលដល់ដំណាក់នោះហើយ ក្រាបទូលដល់ព្រះអយ្យការបស់ព្រះរាជកុមារ ព្រះរាជាទ្រង់ស្តាប់រាជសាសន៍នោះហើយ ត្រាស់ថា នាងវាសភខត្តិយា សូម្បីមិនទាន់ប្រសូតព្រះឱរស ក៏គង់គ្របសង្កត់ជនទាំងអស់បាន ឥឡូវនេះ នាងជាទីប្រោសប្រាណយ៉ាង

ក្រៃលែងអំពីព្រះរាជា អមាត្យត្រចៀកថ្ងន់ស្តាប់ពាក្យថា វល្លភាមិនច្បាស់ បែរជាឮថា វិដ្ដុភៈ កាលចូលទៅគាល់ព្រះរាជា ក្រាបទូលថា បពិត្រព្រះអង្គ ទូលបង្គំបានឮមក ទ្រង់ថ្វាយព្រះនាមព្រះរាជកុមារថា វិដ្ដុភៈ ព្រះរាជាទ្រង់ព្រះតម្រិះថា គង់ជាឈ្មោះដែលត្រកូលឲ្យក្នុងសម័យបុរាណរបស់ពួកយើង ទើបទ្រង់ថ្វាយព្រះនាមព្រះឱរសនោះថា វិដ្ដុភៈ[១] ។

តាំងអំពីនោះមក កុមារចម្រើនដោយកុមារបរិហារ លុះមានអាយុ ៧ ឆ្នាំ ឃើញរូបដំរី និងរូបសេះជាដើម ដែលមនុស្សនាំមកអំពីត្រកូលជីដូនជីតាដល់កុមារដទៃៗ ក៏សួរមាតាថា បពិត្រមាតា បណ្ណាការអំពីត្រកូលជីដូនជីតានាំមកឲ្យដល់ក្មេងដទៃៗ ឯខ្ញុំមិនមានអ្នកបញ្ជូនអ្វីមកឲ្យឡើយ មាតាមិនមានមាតាបិតាទេឬ កាលនាងពោលលួងកូនថា នែបា បណ្តាសក្យរាជ អយ្យកោអយ្យការបស់ឯងនៅឆ្ងាយ ហេតុនោះ ទើបលោកទាំងនោះ មិនបញ្ជូនអ្វីមកឲ្យ លុះដល់កុមារមានអាយុ ១៦ ឆ្នាំ ក៏ពោលថា បពិត្រមាតា ខ្ញុំនឹងទៅសួរសុខទុក្ខ ត្រកូលអយ្យកោអយ្យកា កាលនាងឃាត់ថា នែបា កុំឡើយ ឯងនឹងធ្វើអ្វីក្នុងទីនោះ ក៏អង្វររឿយៗ កាលនោះ មាតាក៏ត្រាស់ថា បើយ៉ាងនោះទៅក៏ទៅចុះ កុមារក្រាបទូលព្រះបិតា ចេញទៅដោយបរិវារធំ ។ នាងវាសភខត្តិយាបញ្ជូនសំបុត្រទៅមុនថា ខ្ញុំនៅទីនេះសុខសប្បាយ សូមទ្រង់កុំសម្តែងអាថ៌កំបាំងណាមួយដល់ព្រះរាជកុមារឡើយ ។ ស្តេចសក្យៈទាំងឡាយ ដឹងរឿងនៃការមករបស់វិដ្ដុភៈ គិតគ្នាថា ពួកយើងមិនអាចថ្វាយបង្គំកុមារនោះ

---

១- ក្នុងទីខ្លះជាវិឌូឌភៈ ។

បាន ហេតុនោះ ទើបនាំគ្នាបញ្ជូនព្រះរាជកុមារក្មេងៗ ទៅកាន់ជនបទ ។ លុះកុមារទៅដល់នគរកបិលពស្តុ ពួកសក្យៈនាំគ្នាប្រជុំគ្នាក្នុងសណ្ឋាគារ កុមារទៅដល់សណ្ឋាគារ ក៏ឈរក្នុងទីនោះ ។ កាលនោះ ពួកជនទាំងនោះ នាំគ្នាពោលថា នែបា នេះជាតារបស់ឯង នេះជាអ៊ំរបស់ឯង កុមារថ្វាយបង្គំរៀយៗទៅគ្រប់គ្នា រហូតដល់ចុកខ្នង ចុងចង្កេះ មិនឃើញមានអ្នកមកថ្វាយបង្គំខ្លួនសូម្បីត្រឹមតែម្នាក់ ទើបសួរថា បុគ្គលដែលថ្វាយបង្គំខ្ញុំមិនមានទេឬ ពួកសក្យៈនាំគ្នាប្រាប់ថា នែបា កុមារដែលជាប្អូនរបស់ឯងនាំគ្នាទៅលេងជនបទអស់ហើយ ។ ហើយនាំគ្នាធ្វើសក្ការៈដ៏ធំដល់កុមារ ។ កុមារស្នាក់នៅទីនោះ ២-៣ ថ្ងៃ ហើយត្រឡប់ទៅដោយបរិវារធំ ។

គ្រានោះ ទាសីម្នាក់ជេរថា បន្ទះក្តារនេះ ជាក្តារដែលកូនទាសីវាសភខត្តិយាវាមកអង្គុយ ហើយលាងបន្ទះក្តារដែលកុមារអង្គុយ ក្នុងសណ្ឋាគារដោយទឹកដោះ បុរសម្នាក់ភ្លេចអាវុធរបស់ខ្លួន ត្រឡប់មកយកអាវុធ បានឮសំឡេងជេរវិដូភកុមារនោះ ទើបសួរទាសីនោះ បានដឹងថា វាសភខត្តិយាកើតក្នុងផ្ទៃរបស់ទាសីនៃមហានាមសក្យរាជ ក៏ទៅថ្លាថ្លែងដល់ពួកពលនិកាយក៏ចលាចលធំថា បានឮថា នាងវាសភខត្តិយាជាកូនទាសី ។

កុមារបានស្តាប់ពាក្យនោះ តាំងចិត្តថា ទុកឲ្យជនទាំងនេះលាងបន្ទះក្តារដែលអញអង្គុយដោយទឹកដោះសិនចុះ ចាំមើលអញសោយរាជ្យហើយ អញនឹងយកឈាមបំពង់ករបស់ពួកវា លាងបន្ទះក្តារដែលអញអង្គុយឲ្យបាន ។ លុះដល់ក្រុងសាវត្ថី ពួកអមាត្យនាំគ្នាក្រាបទូលព្រឹត្តិហេតុនោះដល់ព្រះរាជាៗ ទ្រង់

ស្តាប់រឿងនោះ ពិគ្រោះជាមួយស្តេចសក្យៈទាំងឡាយថា ឲ្យធីតាទាសីដល់អញ ទ្រង់បញ្ឈប់ការបរិហារដែលព្រះរាជទានដល់នាងវាសភខត្តិយា និងឱរសទាំងអស់ ព្រះរាជទានត្រឹមតែស្មើនឹងពួកទាសៈ និងទាសីដែលបានទទួលប៉ុណ្ណោះ ។ បន្ទាប់អំពីនោះ កន្លងទៅបាន ២-៣ ថ្ងៃ ព្រះសាស្តាយាងទៅកាន់ព្រះរាជនិវេសន៍ ប្រថាប់គង់ ព្រះរាជាថ្វាយបង្គំ ព្រះសាស្តាក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពួកញាតិរបស់ទ្រង់នាំគ្នាឲ្យធីតាជាទាសីដល់ខ្ញុំព្រះអង្គ ហេតុនោះ ខ្ញុំព្រះអង្គចាំបាច់កាត់នូវការបរិហាររបស់នាង ព្រមទាំងកូន បានត្រឹមតែបរិហារស្មើនឹងទាសា និងទាសីប៉ុណ្ណោះ ព្រះសាស្តាត្រាស់ថា មហាបពិត្រ ពួកសក្យៈធ្វើកម្មមិនសមគួរឡើយ ធម្មតាកាលនឹងឲ្យ ក៏ត្រូវឲ្យស្រីដែលមានជាតិស្មើគ្នា មហាបពិត្រ តថាគតថ្វាយព្រះពរនឹងមហាបពិត្រ នាងវាសភខត្តិយាជារាជធីតា បានអភិសេកក្នុងព្រះរាជវាំងរបស់ខត្តិយរាជ ចំណែកវិដូភៈក៏ប្រសូត ព្រោះអាស្រ័យខត្តិយរាជដូចគ្នា ឈ្មោះថាគោត្ររបស់មាតានឹងធ្វើអ្វីបាន គោត្ររបស់បិតាឯណោះទេតើ ទើបជាប្រមាណ ហើយទ្រង់ត្រាស់កដ្ឋហារិជាតកថា បុរាណកបណ្ឌិតបានឲ្យតំណែងដល់អគ្គមហេសីដែលជាស្រីក្រីក្ររកឧស កុមារដែលកើតក្នុងផ្ទៃរបស់នាង គ្រងរាជសម្បត្តិក្នុងនគរពារាណសី ដែលមានបរិវេណ ១២ យោជន៍ ទ្រង់ព្រះនាមថា កដ្ឋហារិករាជ ។ ព្រះរាជាទ្រង់ស្តាប់ធម្មកថារបស់ព្រះសាស្តា ទ្រង់សប្បាយព្រះហឫទ័យថា គោត្ររបស់បិតាប៉ុណ្ណោះជាប្រមាណ ដូច្នេះហើយ ទើបប្រទានគ្រឿងបរិហារដូចដើម ដល់មាតា និងបុត្រ ។

ចំណែកសេនាបតីរបស់ព្រះរាជា មានឈ្មោះថា ពន្ធុលៈ បញ្ជូនភរិយារបស់ខ្លួនឈ្មោះមល្លិកា ដែលជាស្រីអារ ទៅកាន់នគរកុសិនារាដោយពាក្យថា ចូរនាងទៅកាន់ផ្ទះនៃត្រកូលរបស់នាងចុះ នាងគិតថា នឹងគាល់ព្រះសាស្តាហើយសឹមទៅ ចូលទៅកាន់វិហារជេតពន ថ្វាយបង្គំព្រះសាស្តាហើយឈរក្នុងចំណែកម្ខាង ត្រូវព្រះសាស្តាត្រាស់សួរថា នាងទៅណា ក៏ក្រាបទូលថា បពិត្រព្រះអង្គ ប្តីរបស់ខ្ញុំម្ចាស់បញ្ជូនខ្ញុំទៅផ្ទះនៃត្រកូល ព្រះសាស្តាត្រាស់ថា ព្រោះហេតុអ្វី ក៏ក្រាបទូលថា ខ្ញុំម្ចាស់ជាស្រីអារ មិនមានកូន ព្រះសាស្តាត្រាស់ថា បើដូច្នោះ នាងមិនចាំបាច់ទៅឡើយ ចូរនាងត្រឡប់ចុះ នាងសប្បាយចិត្ត ថ្វាយបង្គំព្រះសាស្តា បានទៅកាន់និវេសន៍មួយរំពេច កាលត្រូវស្វាមីសួរថា ហេតុអ្វី ទើបនាងត្រឡប់មកវិញ ក៏ប្រាប់ថា ព្រះទសពលបានឲ្យខ្ញុំត្រឡប់ សេនាបតីពោលថា ព្រះតថាគតទ្រង់ឃើញហេតុការណ៍នេះពិត ៗ មិនយូរប៉ុន្មាននាងក៏មានគភ៌ ហើយចាញ់ផ្ទៃ ទើបពោលថា ខ្ញុំចាញ់ផ្ទៃហើយ ពន្ធុលសេនាបតីសួរថា នាងចាញ់ផ្ទៃដូចម្តេច ក៏ប្រាប់ថា ខ្ញុំប្រាថ្នានឹងចុះងូតទឹក ផឹកទឹកក្នុងស្រះបោក្ខរណី ដែលជាមង្គល ជាទីអភិសេកនៃគណៈរាជត្រកូលក្នុងនគរវេសាលី សេនាបតីពោលថា សាធុ ចាប់ធ្នូសហស្សថាមៈ បីនាងឡើងរថ ចេញអំពីនគរសាវត្ថី បររថទៅកាន់ក្រុងវេសាលី ក្នុងកាលនោះមហាលិដែលពិការភ្នែក ជាសិស្សរួមអាចារ្យជាមួយព្រះបាទកោសល និងពន្ធុលសេនាបតី បង្រៀនអត្ថ និងធម៌ដល់ពួកស្តេចលិច្ឆវី ប្រថាប់ឈរក្បែរទ្វារនោះឯង ទ្រង់ស្តាប់សំឡេងរថដែលប៉ះធរណីទ្វារ ពោលថា នុ៎ះជាសំឡេង

រថ ជាពាហនៈរបស់ស្តេចឈ្មោះពន្ធុលៈ ថ្ងៃនេះភ័យនឹងកើតដល់ស្តេចលិច្ឆវី ។ ការរក្សាស្រះបោក្ខរណី មាំទាំទាំងខាងក្នុង និងខាងក្រៅ ខាងលើមានពាសសំណាញ់ ដាក់គន្លឹះ សូម្បីតែហ្វូងបក្សីក៏ចូលមិនបាន ។

សេនាបតីចុះអំពីរថ វាយពួកអ្នកយាម ដោយព្រះខ័នឲ្យគេចទៅ យកដាវកាប់សំណាញ់ដែក ឲ្យភរិយាចុះទៅក្នុងស្រះបោក្ខរណីងូត និងផឹក ខ្លួនឯងក៏ចុះងូតដូចគ្នា ហើយបីនាងមល្លិកាដាក់លើរថ ចេញអំពីនគរទៅតាមផ្លូវដែលមកនោះឯង ពួកអ្នកយាមនាំគ្នាទៅក្រាបទូលដល់ស្តេចលិច្ឆវីៗ ទាំងនោះនាំគ្នាក្រេវក្រោធ ឡើងរថ ៥០០ ដេញទៅដោយត្រិះរិះថា ពួកយើងនឹងចាប់ស្តេចមល្លៈឈ្មោះពន្ធុលឲ្យបាន ហើយប្រាប់រឿងនោះដល់មហាលិៗ ពោលថា ពួកអ្នកកុំទៅឡើយ គេនឹងសម្លាប់ពួកអ្នកទាំងអស់ ចំណែកជនទាំងនោះនាំគ្នាពោលថា ពួកខ្ញុំត្រូវទៅឲ្យបាន មហាលិផ្តាំថា បើដូច្នេះ ពួកអ្នកឃើញកង់រថលិចដល់ដុំ ឆាប់នាំគ្នាត្រឡប់ចុះ បើមិនត្រឡប់ទេនោះ នឹងបានឮសំឡេងរន្ទះនៅខាងមុខ គប្បីឆាប់ត្រឡប់ បើមិនត្រឡប់ពេលនោះទេ ពួកអ្នកនឹងឃើញប្រហោងត្រង់ចន្ទោលរថរបស់ពួកអ្នក អ្នកកុំនាំគ្នាទៅជាដាច់ខាត ពួកស្តេចលិច្ឆវីទាំងនោះ មិនព្រមត្រឡប់តាមពាក្យរបស់មហាលិ នាំគ្នាដេញតាមពន្ធុលនោះទៅទាល់តែបាន ។ នាងមល្លិកាឃើញហើយប្រាប់ថា បពិត្រអ្នក រថប្រាកដជាច្រើន ពន្ធុលពោលថា បើដូច្នោះ នាងចាំប្រាប់យើង ក្នុងពេលដែលរថប្រាកដតែមួយ គឺរថមើលឃើញតែមួយ ។ នាងមល្លិកាប្រាប់ថា បពិត្រអ្នក ចន្ទោលរថប្រាកដហើយ ពន្ធុលហុចខ្សែរសេះឲ្យដល់នាងមល្លិកា

ប្រាប់ថា ចូរនាងកាន់ខ្សែរសេះនេះ ឈរលើរថ យឹតនូវធ្នូ សំឡេងក៏លាន់ដូចរន្ទះ ចំណែកជនទាំងនោះមិនព្រមត្រឡប់អំពីទីនោះ នាំគ្នាដេញតាមរឿយៗទៅ ពន្ទុលក៏បាញ់ព្រួញមួយទៅ ព្រួញនោះក៏ទម្លុះចន្លោលរថទាំង ៥០០ហើយ ទម្លុះក្រោះរបស់ព្រះរាជាទាំង ៥០០ ហើយលិចចូលទៅក្នុងដី ។ ស្ដេចលិច្ឆវីទាំងនោះមិនដឹងថា ខ្លួនត្រូវព្រួញ នៅតែស្រែកថា ឈប់មនុស្សអាក្រក់ឈប់មនុស្សអាក្រក់ ដេញតាមរឿយៗ ទៅ ពន្ទុលបញ្ឈប់រថពោលថា ពួកឯងជាមនុស្សស្លាប់ហើយ មិនមានទំនៀមឡើយ ដែលយើងច្បាំងនឹងមនុស្សស្លាប់ ស្ដេចលិច្ឆវីត្រាស់ថា ឈ្មោះថា មនុស្សស្លាប់ហើយ ដូចពួកយើងមិនមានទេ ពន្ទុលក៏ពោលថា បើដូច្នោះ ចូរឯងដោះក្រោះមនុស្សដែលជិះរថចុងក្រោយ ស្ដេចលិច្ឆវីទាំងនោះនាំគ្នាដោះក្រោះ ស្ដេចអង្គនោះ គ្រាន់តែដោះក្រោះប៉ុណ្ណោះ ក៏ដួលចុះអស់ព្រះជន្ម ។ ពន្ទុលពោលនឹងស្ដេចទាំងនោះថាពួកឯងទាំងអស់ក៏ដូចស្ដេចអង្គនោះ ចូរពួកឯងនាំគ្នាទៅផ្ទះរៀងៗខ្លួន ត្រៀមការងារដែលគួរចាត់ការ ផ្ដាំកូនប្រពន្ធហើយ សឹមដោះក្រោះ ស្ដេចទាំងនោះនាំគ្នាធ្វើតាមនោះ ហើយក៏សោយទិវង្គតទាំងអស់ ។

ចំណែកពន្ទុលនាំនាងមល្លិកាមកកាន់នគរសាវត្ថី ប្រសូតបុត្រភ្លោះ ១៦ដង សុទ្ធតែជាកូនប្រុស ជាអ្នកក្លៀវក្លា សម្បូរដោយកម្លាំង ជាអ្នកសម្រេចក្នុងសិប្បៈគ្រប់ប្រការ ម្នាក់ៗ មានបរិវារមួយពាន់ លានព្រះរាជវាំងកុះករដោយជនទាំងនោះ ទៅកាន់ព្រះរាជនិវេសន៍ជាមួយបិតានោះឯង ។ ថ្ងៃមួយពួកមនុស្សដែលត្រូវចាញ់ក្ដីដោយការកាត់ក្ដីកោង ត្រង់ទីវិនិច្ឆ័យ ឃើញពន្ទុល

កំពុងដើរមក ក៏ស្រែកកងរំពងប្រាប់អំពីការកាត់ក្ដីមិនយុត្តិធម៌ របស់អាមាត្យដែលជាអ្នកវិនិច្ឆ័យក្ដីដល់ពន្ទុល គាត់ទៅកាន់ទីវិនិច្ឆ័យពិចារណាក្ដីនោះ បានធ្វើម្ចាស់ទ្រព្យឲ្យជាម្ចាស់ទ្រព្យ អ្នកមិនមែនម្ចាស់ទ្រព្យ ឲ្យជាអ្នកមិនមែនជាម្ចាស់ទ្រព្យ មហាជននាំគ្នាឲ្យសាធុការដោយសំឡេងខ្លាំង ព្រះរាជាត្រាស់សួរថា នេះជាសំឡេងអ្វី ទ្រង់បានឮសេចក្ដីនោះ ទ្រង់ត្រេកអរ ត្រាស់ឲ្យដកអមាត្យទាំងនោះចេញ ប្រគល់ការវិនិច្ឆ័យក្ដីឲ្យដល់ពន្ទុល ។

ចាប់តាំងពីនោះ ពន្ទុលកាត់ក្ដីដោយយុត្តិធម៌ ។ កាលនោះ ពួកអ្នកកាត់ក្ដីចាស់ៗ កាលមិនបានសំណូកក៏មានចំណូលតិច នាំគ្នាញុះញង់រាជត្រកូលថា ពន្ទុលប្រាថ្នារាជសម្បត្តិ ព្រះរាជាទ្រង់ស្ដាប់ពាក្យរបស់អមាត្យទាំងនោះ មិនអាចសង្កត់ព្រះហឫទ័យបាន ទ្រង់ត្រិះរិះថា បើអញសម្លាប់ពន្ទុលនេះ ក្នុងព្រះនគរនេះ ការនិន្ទានឹងកើតឡើង ទ្រង់ព្រះតម្រិះបន្តថា ត្រូវរៀបចំមនុស្សឲ្យទៅប្លន់ជាយដែន ហើយបញ្ជូនទាហានទៅបង្រ្កាប ជនទាំងនោះពេលនាំគ្នាត្រឡប់មក ក៏ឲ្យមនុស្សសម្លាប់ មួយអន្លើដោយកូនទាំងអស់ក្នុងរវាងផ្លូវ កាលទ្រង់ព្រះតម្រិះហើយ ត្រាស់ឲ្យពន្ទុលចូលមកគាល់ បញ្ជូនទៅថា បានឮថា ជាយដែនមានការបះបោរ អ្នក ព្រមទាំងកូន ចូរទៅចាប់ពួកចោរនោះចុះ ហើយទ្រង់បញ្ជូនមហាយោធាដទៃ ដែលអាចទៅជាមួយពន្ទុលនិងបុត្រទាំងនោះដោយត្រាស់ថា ចូរពួកឯងកាត់ក្បាលពន្ទុល និងកូនទាំង ៣២ នាក់ក្នុងទីនោះឲ្យបាន ហើយនាំមកចុះ ។ កាលពន្ទុលទៅដល់ជាយដែនប៉ុណ្ណោះ ពួកចោរដែលក្លែងធ្វើជាចោរនាំគ្នាពោលថា បានឮថា លោកសេនាបតី

កំពុងលើកគ្នាមក ទើបគេចទៅ ពន្ធុលសេនាបតីរៀបចំឲ្យតំបន់នោះរាបទាប ហើយ តាំងជនបទបានហើយ ក៏ត្រឡប់ ។ កាលនោះ ពួកជនដែលទៅជាមួយនោះ នាំគ្នាកាត់ក្បាលរបស់ពន្ធុលសេនាបតី និងកូនទាំងនោះក្នុងទីមិនឆ្ងាយអំពីនគរ ថ្ងៃនោះ ព្រះនាងមល្លិកានិមន្តអគ្គសាវ័ក និងភិក្ខុ ៥០០ រូប ។ នៅពេលព្រឹក មានអ្នកនាំសារមកឲ្យនាងថា ស្វាមី និងកូន ត្រូវយោធាទាំងនោះ កាត់ក្បាលហើយ នាងជ្រាបរឿងនោះហើយ មិនពោលពាក្យណាមួយដល់បុគ្គលណាឡើយ ទុកសំបុត្រក្នុងថ្នក់ អង្គាសភិក្ខុរឿយៗ ទៅ កាលនោះ ពួកអ្នកបម្រើរបស់នាង ប្រគេនភត្តាហារដល់ភិក្ខុហើយ លើកថាសសប្បិមកធ្វើថាសបែកចំពោះមុខព្រះថេរៈទាំងឡាយ ព្រះធម្មសេនាបតីពោលថា ឧបាសិការបស់ដែលមានការបែកជាធម្មតា បានបែកទៅហើយ នាងកុំទោមនស្សឡើយ នាងបានយកសំបុត្រចេញអំពីថ្នក់ ពិតព្រះសារីបុត្តថា មនុស្សនាំសំបុត្រនេះមកឲ្យខ្ញុំថា ឪពុក និងកូន ៣២ នាក់ត្រូវគេកាត់ក្បាលហើយ ទោះបីបានស្តាប់រឿងនេះ ខ្ញុំមិនទោមនស្សឡើយ ចំណង់បើថាសនេះបែក នឹងទោមនស្សដូចម្តេច ។

ព្រះធម្មសេនាបតីពោលពាក្យជាដើមថា ជីវិតមិនមាននិមិត្ត មិនមានអ្នកណាដឹង សម្តែងធម៌ហើយក្រោកចាកអាសនៈទៅកាន់វិហារ ចំណែកនាងហៅកូនប្រសាទាំង ៣២ នាក់មកទូន្មានថា ប្តីរបស់ពួកនាងមិនមានកំហុស បានទទួលផលនៃកម្ម ដែលធ្វើក្នុងកាលមុនរបស់ខ្លួន ពួកនាងកុំសោយសោកឡើយ កុំធ្វើចិត្តប្រទូស្តក្នុងព្រះរាជាឡើយ ចារបុរសរបស់ព្រះរាជាស្តាប់ពាក្យនោះ

នាំគ្នាក្រាបទូលភាពដែលបុគ្គលទាំងនោះ មិនមានទោសដល់ព្រះរាជាៗ ទ្រង់ស្ងួតក្នុងព្រះហឫទ័យ យាងទៅកាន់លំនៅរបស់នាងមល្លិកា សូមខមាទោសនាងមល្លិកា និងកូនប្រសារបស់នាងហើយ បានប្រទានពរដល់នាងមល្លិកាៗ ក្រាបទូលថា ពរដែលខ្ញុំម្ចាស់ទទួលព្រះរាជទាន សូមទុកសិនចុះ កាលព្រះរាជាយាងទៅហើយ នឹងថ្វាយមតកកត្ត ងូតហើយ តាក់តែងកាយចូលគាល់ព្រះរាជា ក្រាបទូលថា បពិត្រព្រះសម្មតិទេព ទ្រង់ប្រទានពរដល់ខ្ញុំម្ចាស់ហើយ ខ្ញុំម្ចាស់មិនត្រូវការពរដទៃឡើយ សូមទ្រង់អនុញ្ញាតឲ្យខ្ញុំម្ចាស់ និងកូនប្រសាទាំង ៣២ នាក់ទៅកាន់ត្រកូលវិញចុះ ព្រះរាជាទ្រង់ទទួលពាក្យរបស់នាង នាងបញ្ជូនកូនប្រសា ៣២ នាក់ ទៅកាន់ត្រកូលរៀងៗ ខ្លួន ខ្លួនឯងក៏បានទៅកាន់ផ្ទះនៃត្រកូលរបស់ខ្លួន ក្នុងកុសិនារានគរ ចំណែកព្រះរាជាព្រះរាជទានតំណែងជាសេនាបតី ដល់ក្មួយរបស់ពន្ធុលសេនាបតី គឺទីឃការាយនៈ គាត់ត្រិះរិះថា ព្រះរាជាអង្គនេះ សម្លាប់អ៊ំរបស់អញ ដូច្នេះហើយ រកឱកាសទម្លាក់ព្រះរាជារឿយៗ ព្រះរាជា តាំងអំពីសម្លាប់ពន្ធុលដែលប្រាសចាកកំហុសហើយ ទ្រង់មានតែការក្ដៅក្រហាយព្រះហឫទ័យ ទ្រង់មិនបានទទួលការត្រេកអរ ទ្រង់មិនមានសេចក្ដីសុខក្នុងរាជសម្បត្តិឡើយ កាលនោះ ព្រះសាស្ដាទ្រង់អាស្រ័យនិគមឈ្មោះវេតនុប្បន្នកុលៈ[១] ប្រថាប់នៅ ។ ព្រះរាជាយាងទៅក្នុងនិគមនោះ ទ្រង់បោះជំរំទ័ពមិនឆ្ងាយអំពីអារាម ចូលទៅកាន់ព្រះវិហារដោយរាជបរិវារច្រើន ដោយទ្រង់ព្រះតម្រិះថា នឹងថ្វាយបង្គំព្រះសាស្ដា ប្រទាន

---

១- ក្នុងទីខ្លះថា និគមឈ្មោះវេឡុរបស់ពួកសក្យៈ ។

បញ្ចរាជកកុធកណ្ឌដល់ទីឃកាកាយនៈ ទ្រង់យាងទៅមួយអន្លើឯងប៉ុណ្ណោះ ចូលកាន់ព្រះគន្ធកុដិ ។ រឿងទាំងអស់ គប្បីជ្រាបតាមគន្លងធម្មចេតិយសូត្រនោះឯង ។

កាលព្រះរាជាចូលកាន់ព្រះគន្ធកុដិ ទីឃកាកាយនៈកាន់យករាជកកុធ-កណ្ឌទាំងនោះ ធ្វើវិដូឌភកុមារឲ្យជាព្រះរាជា ទុកសេះ និងស្រីម្នាក់ សម្រាប់ព្រះរាជា ហើយលើកទ័ពទៅកាន់នគរសាវត្ថី ព្រះរាជាទ្រង់ត្រាស់បិយកថាជាមួយព្រះសាស្ដា ហើយយាងចេញ ទ្រង់មិនឃើញកងទាហាន ត្រាស់សួរស្រីនោះ ទ្រង់ស្ដាប់រឿងនោះហើយ ទ្រង់ព្រះតម្រិះថា យើងត្រូវទៅបបួលអជាតសត្តុដែលជាក្មួយរបស់យើង មកចាប់វិដូឌភៈឲ្យបាន ហើយទ្រង់យាងទៅកាន់នគររាជគ្រឹះ តែជួនជាពេលយប់ងងឹត ទ្វារនគរក៏បិទអស់ហើយ ទ្រង់មិនអាចចូលកាន់នគរបាន ទ្រង់ផ្ទុំក្នុងសាលាមួយខាងនោះ ទ្រង់ត្រូវខ្យល់ និងកម្ដៅថ្ងៃ ពេលយប់ក៏សោយទិវង្គតក្នុងសាលានោះឯង ។ លុះភ្លឺស្វាងហើយ មហាជនទាំគ្នាស្ដាប់សំឡេងយំរបស់ស្រីនោះ ដែលយំរៀបរាប់ថា ឱត្រកូលមហារាជ ជាធំជាងជនកោសលរដ្ឋ ឥឡូវនេះ ទ្រង់ឥតទីពឹងហើយ ក៏នាំគ្នាក្រាបទូលដល់ព្រះរាជាៗ ទ្រង់ត្រាស់ឲ្យធ្វើសរីរកិច្ចរបស់ព្រះមាតុលាធិរាជដោយសក្ការៈដ៏ធំ ។ ចំណែកព្រះបាទវិដូឌភៈបានរាជសម្បត្តិ នឹកឃើញដល់ពៀរនោះ ទ្រង់ត្រិះរិះថា អញត្រូវសម្លាប់ស្ដេចសក្យៈឲ្យស្លាប់អស់ យាងចេញដោយសេនានុភាពធំ ថ្ងៃនោះ ព្រះសាស្ដាទ្រង់ប្រមើលមើលលោកក្នុងពេលទៀបភ្លឺ ទ្រង់ទតឃើញសេចក្ដីវិនាសរបស់ពួកញាតិ ទ្រង់ព្រះតម្រិះថា

តថាគតគួរធ្វើការសង្គ្រោះញាតិ ទ្រង់យាងប្រោសសត្វអំពីព្រឹក យាងត្រឡប់អំពីបិណ្ឌបាតហើយ ទ្រង់សម្រេចសីហសេយ្យាក្នុងព្រះគន្ធកុដិ ពេលល្ងាចយាងទៅតាមអាកាស ប្រថាប់គង់ត្រង់គល់ឈើដែលមិនមានម្លប់មួយកន្លែងក្បែរនគរកបិលពស្តុ ក្នុងទីមិនឆ្ងាយអំពីនោះ ក្នុងរាជសីមានៃស្តេចវិដូឌភៈ មានដើមជ្រៃធំម្លប់ត្រជាក់ល្អមួយដើម ស្តេចវិដូឌភៈឃើញព្រះសាស្តា ចូលទៅគាល់ថ្វាយបង្គំហើយ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងពេលក្តៅបែបនេះ ហេតុអ្វីទើបទ្រង់គង់ត្រង់គល់ឈើដែលមិនមានម្លប់ ដូច្នេះសូមទ្រង់គង់ត្រង់គល់ជ្រៃ ដែលមានម្លប់ត្រឈឹងត្រឈៃចុះ កាលព្រះសាស្តាត្រាស់ថា មិនថ្វីទេ មហាបពិត្រ ធម្មតាម្លប់របស់ពួកញាតិត្រជាក់សប្បាយ ក៏ត្រិះរិះថា ព្រះសាស្តាគង់យាងមកដើម្បីការពារពួកញាតិ ថ្វាយបង្គំព្រះសាស្តា ទ្រង់យាងត្រឡប់ទៅកាន់នគរសាវត្ថីវិញ ព្រះសាស្តាក៏ហោះទៅកាន់វិហារជេតពនដូចគ្នា ។ ព្រះរាជាទ្រង់រឭកដល់ទោសរបស់ពួកសក្យៈបាន ក៏លើកពលចេញទៅលើកទី ២ ជួបនឹងព្រះសាស្តាត្រង់នោះដូចគ្នា ហើយទ្រង់យាងត្រឡប់ ក្នុងវារៈទី ៣ ទ្រង់លើកពលចេញ ជួបព្រះសាស្តាត្រង់ទីនោះៗ ឯង ក៏ត្រឡប់ ។

តែក្នុងវារៈទី ៤ កាលព្រះរាជាលើកពលចេញទៅ ព្រះសាស្តាទ្រង់ប្រមើលមើលបុព្វកម្មរបស់ពួកសក្យៈ ទ្រង់ជ្រាបភាពដែលកម្មនោះជាបាប គឺដោយការបាចថ្នាំពិសក្នុងស្ទឹងរបស់សក្យៈទាំងនោះ ជាកម្មដែលបុគ្គលណាម្នាក់ឃាត់មិនបាន ទើបមិនយាងទៅក្នុងវារៈទី ៤ ។ ព្រះរាជាវិដូឌភៈសម្លាប់

ពួកសក្យៈទាំងអស់ តាំងតែអំពីក្មេងដែលកំពុងបៅដោះ យកឈាមត្រង់បំពង់កលាងបន្ទះក្តារដែលខ្លួនអង្គុយ ហើយយាងត្រឡប់មក ។ កាលព្រះសាស្តាទ្រង់ត្រឡប់ក្នុងវារៈទី ៣ ស្អែកឡើង យាងទៅប្រោសសត្វ ហើយទ្រង់យាងចូលកាន់ព្រះគន្ធកុដិ លុះដល់ពេលល្ងាច ពួកភិក្ខុប្រជុំគ្នាក្នុងធម្មសភា នាំគ្នាថ្លាថ្លែងព្រះគុណរបស់ព្រះមានព្រះភាគថា អាវុសោទាំងឡាយ ព្រះសាស្តា ទ្រង់បង្ហាញខ្លួនឲ្យព្រះរាជាត្រឡប់ ទ្រង់ដោះពួកញាតិអំពីមរណភ័យ ព្រះសាស្តាទ្រង់ប្រព្រឹត្តប្រយោជន៍ដល់ពួកញាតិយ៉ាងនេះ ព្រះសាស្តាយាងមកហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អំបាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយ ក្រាបទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គ ដោយកថាឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលតថាគតប្រព្រឹត្តប្រយោជន៍ដល់ពួកញាតិ សូម្បីក្នុងកាលមុន ក៏បានប្រព្រឹត្តហើយដូចគ្នា ភិក្ខុទាំងនោះក្រាបទូលអារាធនា ទើបទ្រង់នាំអតីតនិទានមកត្រាស់ដូចតទៅ

ក្នុងអតីតកាល ព្រះរាជាព្រះនាមព្រហ្មទត្ត ទ្រង់មិនបានកន្លងនូវទសពិធរាជធម៌ សោយរាជសម្បត្តិដោយធម៌ក្នុងនគរពារាណសី ថ្ងៃមួយ ទ្រង់ព្រះតម្រិះថា បណ្តាព្រះរាជាក្នុងជម្ពូទ្វីប នាំគ្នានៅក្នុងប្រាសាទមានសសរច្រើន ហេតុនោះ ការសាងប្រាសាទដោយសសរច្រើនមិនជាអស្ចារ្យឡើយ បើដូច្នោះ អញនឹងសាងប្រាសាទសសរមួយសាកមើល បើយ៉ាងនេះ អញនឹងជាព្រះរាជាដ៏អស្ចារ្យជាងព្រះរាជាទាំងពួងបាន ទើបទ្រង់ត្រាស់ឲ្យហៅជាងឈើមក

គាល់ ត្រាស់ថា ចូរពួកអ្នកសាងប្រាសាទសសរមួយ ដែលមានលម្អក្រៃលែងដល់យើង ជាងឈើទាំងនោះទទួលព្រះតម្រាស់ថា សាធុ នាំគ្នាចូលព្រៃ ជួបដើមឈើត្រង់ផង ធំផង សមនឹងសាងប្រាសាទសសរមួយជាច្រើន គិតគ្នាថា ដើមឈើទាំងនេះប្រើបាន តែផ្លូវមិនរាបស្មើ មិនអាចយកទៅបាន ពួកយើងនឹងនាំគ្នាក្រាបទូលព្រះរាជា ហើយបានធ្វើយ៉ាងនោះ ព្រះរាជាត្រាស់ថា ចូរអ្នកនាំមកសន្សឹមៗ ដោយឧបាយមិនបានឬ កាលជនទាំងនោះ នាំគ្នាក្រាបទូលថា បពិត្រព្រះអង្គ ទោះប្រើឧបាយដូចម្តេច ក៏មិនអាចអូសមកបាន ព្រះរាជាត្រាស់ថា បើដូច្នោះ ចូរពិនិត្យមើលដើមឈើមួយដើម ក្នុងឧទ្យានរបស់យើងចុះ ពួកជាងឈើនាំគ្នាទៅកាន់ឧទ្យាន ឃើញដើមរាំងដែលជាឈើមង្គលមួយដើម ជាឈើមានដើមមូល និងត្រង់ អ្នកស្រុកអ្នកភូមិនាំគ្នាបូជា បានពលីកម្មអំពីរាជត្រកូល នាំគ្នាទៅកាន់រាជសម្នាក់ ក្រាបទូលសេចក្តីនោះ ព្រះរាជាត្រាស់ថា ធម្មតាដើមឈើក្នុងឧទ្យានរបស់យើង ជារបស់ដែលយើងបានចំពោះ ទៅចុះ នាំគ្នាកាប់ដើមឈើនោះមក ជាងឈើទាំងនោះនាំគ្នាទទួលព្រះតម្រាស់ថា សាធុ ហើយកាន់នូវគ្រឿងក្រអូប និងផ្កាជាដើមទៅកាន់ឧទ្យាន ធ្វើនូវការគូស ៥ ធ្នាប់ ដោយម្សៅក្រអូបត្រង់ដើមឈើ ចងអំបោះសំយុងកម្រងផ្កា អុជប្រទីបធ្វើនូវពលីកម្ម ស្រែកប្រាប់ថា ក្នុងថ្ងៃទី ៧ បន្ទាប់អំពីថ្ងៃនេះ ពួកយើងនឹងនាំគ្នាកាប់ដើមឈើ ព្រះរាជាទ្រង់អនុម័តឲ្យកាត់បាន សូមអញ្ជើញទេវតាដែលកើតក្នុងដើមឈើនេះ ទៅក្នុងទីដទៃ ទោសពៃរ៍កុំមានដល់យើងទាំងឡាយឡើយ ។ កាលនោះ ទេវតាដែលកើតត្រង់ដើមឈើ

នោះ ស្តាប់ពាក្យនោះហើយ គិតថា អញមិនចាំបាច់សង្ស័យឡើយ ជាង ឈើទាំងនេះគង់នឹងកាប់ដើមឈើនេះ វិមានរបស់អញត្រូវវិនាស ជីវិតរបស់ អញអាស្រ័យត្រង់វិមាននេះប៉ុណ្ណោះឯង វិមានជាច្រើន នៃពួកទេវតាជាញាតិ របស់អញ ដែលនាំគ្នាកើតហើយក្នុងដើមរាំងជំទង់ៗ ដែលដុះជុំវិញដើមឈើ នេះ នឹងត្រូវវិនាសដូចគ្នា ការវិនាសរបស់ពួកញាតិទាំងឡាយ មិនបៀត បៀនអញដោយប្រការណា ការវិនាសរបស់អញ ចូរបៀតបៀនអញដោយ ប្រការនោះចុះ ហេតុនោះ គួរអញឲ្យជីវិតទានដល់ពួកញាតិទាំងនោះ លុះ ដល់ពេលយប់ ប្រដាប់កាយដោយគ្រឿងអលង្ការដែលជាទិព្វ ចូលទៅកាន់ បន្ទប់ដ៏មានសិរីរបស់ព្រះរាជា ធ្វើនូវបន្ទប់គ្រប់ចំណែកឲ្យភ្លឺស្វាងតែមួយ បាន ឈរយំត្រង់សីសៈព្រះរាជាៗ ទតឃើញទេវតានោះ ទ្រង់តក់ស្លុត កាលទ្រង់ ប្រាស្រ័យជាមួយទេវតានោះ ទើបត្រាស់គាថាជាបឋមថា

អ្នកជាអ្វី ដែលមានសំពត់ទាំងឡាយដ៏ស្អាត បានឋិតនៅលើ អាកាសវេហាស៍ ទឹកភ្នែកទាំងឡាយរបស់អ្នកហូរចេញ តើដោយ ហេតុអ្វី ភ័យមកចំពោះអ្នក ព្រោះអ្វី ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កា តុំ** សេចក្តីថា ព្រះរាជាត្រាស់សួរថា ក្នុងបណ្តាអមនុស្ស មាននាគ យក្ខ គ្រុឌ និងសក្កៈជាដើម អ្នកឈ្មោះថាជា អ្វី ។ បទថា **វត្ថេហិ** នេះត្រឹមតែជាពាក្យប៉ុណ្ណោះ ។

សេចក្តីពិត ព្រះរាជាត្រាស់សំដៅយកគ្រឿងប្រដាប់ជាទិព្វទាំងអស់នោះ ឯង ។ បទថា **អឃេ** បានដល់ ក្នុងអាកាសដែលមិនមានទីទើសទាក់ ។

បទថា **វេហាយសំ** នេះ ជាវេវចនៈរបស់អាកាសនោះឯង ។ បទថា **កេន ឥយស្សុនិ** សេចក្ដីថា ទឹកភ្នែករបស់អ្នកហូរដោយហេតុអ្វី ។ បទថា **ក្រុតោ** សេចក្ដីថា ព្រះរាជាត្រាស់សួរថា ភ័យមកដល់អ្នកព្រោះអាស្រ័យរឿងអ្វី ក្នុងបណ្ដាអនត្ថ មានការព្រាត់ប្រាសញាតិ និងការវិនាសនៃទ្រព្យជាដើម ។

ទេវតាស្ដាប់ព្រះតម្រាស់នោះហើយ បានពោល ២ គាថាថា

បពិត្រព្រះសម្មតិទេព ជនទាំងឡាយ ក្នុងដែនរបស់ព្រះអង្គ ស្គាល់ច្បាស់នូវខ្ញុំថា ជាភទ្ទសាលព្រឹក្ស កាលខ្ញុំឋិតនៅ ( ក្នុងឧទ្យាននេះ ) អស់ ៦ ម៉ឺនឆ្នាំ ជនទាំងឡាយបានបូជាហើយ ។

បពិត្រព្រះអង្គជាម្ចាស់ទិស ( ព្រះរាជាទាំងឡាយពីដើម ក្នុងនគរនេះ ) កាលឲ្យគេសាងទីក្រុងទាំងឡាយផង ដំណាក់ទាំងឡាយផង ប្រាសាទផ្សេងៗ ផង មិនដែលបៀតបៀនខ្ញុំឡើយ ព្រះរាជាទាំងនោះបូជាខ្ញុំ យ៉ាងណា សូមព្រះអង្គបូជាខ្ញុំយ៉ាងនោះដែរ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **តិដ្ឋតោ** សេចក្ដីថា ទេវតាសម្ដែងថា បពិត្រមហារាជ កាលខ្ញុំដែលពួកអ្នកក្រុងពារាណសីទូទៅ អ្នកស្រុក និងអ្នកនិគម សូម្បីទ្រង់ក៏បានបូជា ខ្ញុំបានទទួលពលីកម្ម និងសក្ការៈជានិច្ច តាំងនៅក្នុងឧទ្យាននេះអស់កាលប៉ុណ្ណោះកន្លងទៅ ។ បទថា **ឆគរានិ** សេចក្ដីថា ធ្វើនូវបដិសន្ថរណៈ គឺជួសជុលនគរ ។ បទថា **អគារេ ច** បានដល់ ផ្ទះលើផែនដី ។ បទថា **ទិសម្បតិ** សេចក្ដីថា បពិត្រមហារាជ ជាធំនៃទិស ។ បទថា

**ឆ មន្តេ** សេចក្តីថា ទេវតាពោលថា លោកទាំងនោះ គឺព្រះរាជាតាំងអំពីបុរាណ ក្នុងព្រះនគរនេះ កាលទ្រង់ធ្វើនូវការជួសជុលនូវព្រះនគរជាដើម ទ្រង់មិនមើលងាយ មិនជ្រៀតបៀត គឺមិនបៀតបៀនខ្ញុំឡើយ មិនបានកាប់ដើមឈើដែលជាលំនៅរបស់ខ្ញុំ ធ្វើនូវកម្មរបស់ខ្លួន តែគង់ធ្វើសក្ការៈដល់ខ្ញុំដោយចំណែកមួយ ។ បទថា **យថេវ** សេចក្តីថា ព្រោះហេតុនោះ ព្រះរាជាក្នុងកាលមុននោះ នាំគ្នាបូជាខ្ញុំ សូម្បីត្រឹមតែមួយអង្គមិនធ្លាប់បញ្ជាឲ្យកាប់ដើមឈើ យ៉ាងណា សូម្បីទ្រង់សោត ក៏ទ្រង់បូជា កុំកាប់ដើមឈើរបស់ខ្ញុំឡើយ ដូច្នេះដូចគ្នា ។

លំដាប់នោះ ព្រះរាជាបានត្រាស់ ២ គាថាថា

ខ្ញុំមិនធ្លាប់ឃើញអ្នក ជាដើមឈើធំ ដោយកាយរបស់អ្នកទេ អ្នក
ជាឈើមានទ្រង់ទ្រាយដ៏ល្អ ដោយកម្ពស់ និងទំហំ និងកំណើត ។
ម្នាលយក្ខ ខ្ញុំនឹងឲ្យគេធ្វើប្រាសាទ មានសសរតែមួយ ជាទីរីករាយ
នៃចិត្ត ខ្ញុំនឹងនាំយកអ្នក ចូលទៅក្នុងប្រាសាទនោះ ជីវិតរបស់
អ្នក ( នឹងមាន ) អស់កាលយូរ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កាយេន** បានដល់ ដោយប្រមាណ ។ លោកពោលពាក្យអធិប្បាយនេះថា ខ្ញុំមិនបានឃើញដើមឈើដទៃៗ ដែលធំដោយទំហំ ដូចដើមឈើរបស់អ្នកឡើយ ដើមឈើរបស់អ្នកនោះឯងមានទ្រង់ទ្រាយល្អ គឺដល់នូវចំណែកនៃលម្អ សមគួរដល់ប្រាសាទសសរមួយ ដោយកម្ពស់ និងទំហំ និងដោយជាតិកំណើតល្អ មានសណ្ឋានមូលត្រង់ជាពិសេស ។

បទថា **ចាសាធំ** សេចក្ដីថា ព្រោះហេតុនោះ ទើបខ្ញុំឲ្យមនុស្សកាប់ដើមឈើសាងប្រាសាទនោះឯង ។ បទថា **តំ** សេចក្ដីថា នែទេវរាជសម្លាញ់ តែខ្ញុំនឹងអញ្ជើញអ្នកចូលនៅក្នុងប្រាសាទនោះ អ្នកកាលនៅរួមនឹងខ្ញុំ នឹងបានទទួលគ្រឿងក្រអូប និងផ្កាជាដើមដ៏ប្រសើរ ស្អុកស្កកដោយសក្ការៈ ជាអ្នកនៅយ៉ាងសប្បាយ អ្នកកុំក្ដៅក្រហាយចិត្តថា សេចក្ដីវិនាសនឹងមានដល់ខ្ញុំ ព្រោះមិនមានលំនៅ ជីវិតរបស់អ្នកនឹងរស់យឺតយូរ ។ ទេវតាស្ដាប់ពាក្យនោះហើយបានពោល ២ គាថាថា

*( បើ ) ព្រះហឫទ័យ ( របស់ទ្រង់ ) កើតឡើងយ៉ាងនេះ សេចក្ដីព្រាត់ប្រាស ( ចាកកទូសាលព្រឹក្ស ) ជាសរីរៈ ( របស់ខ្ញុំ នឹងមានប្រាកដ ) ( កាលបើយ៉ាងនេះ ) សូមព្រះអង្គកាត់ខ្ញុំជាច្រើនកំណាត់ កាត់ជាកំណាត់តូចធំចុះ ។*

*តែសូមព្រះអង្គកាត់ត្រង់ចុង និងកណ្ដាល ( មុន ) រួចកាត់ត្រង់គល់ក្នុងកាលជាខាងក្រោយ កាលបើខ្ញុំត្រូវព្រះអង្គកាត់យ៉ាងនេះ សេចក្ដីស្លាប់ មិនគប្បីជាទុក្ខទេ ដូច្នេះ ។*

បណ្ដាបទទាំងនោះ បទថា **ឯវំ ចិត្តំ ឧទបាទិ** សេចក្ដីថា បើការគិតយ៉ាងនេះ កើតដល់ព្រះអង្គហើយ ។ បទថា **សរីរេន វិនាភាវោ** សេចក្ដីថា បើការព្រាត់ប្រាសចាកសរីរៈរបស់ខ្ញុំ គឺដើមរាំងដ៏ស្អាត ព្រះអង្គបានតាំងទុកដល់ខ្ញុំ ។ បទថា **បុថុសោ** សេចក្ដីថា បើយ៉ាងនោះ សូមទ្រង់កាប់នូវដើមរាំងដ៏ស្អាតនោះឲ្យច្រើន ( កំណាត់ ) ។ បទថា **វិកន្តត្វា** បានដល់ កាប់

ហើយ ។ បទថា **ខណ្ឌសោ** បានដល់ កាត់ជាកំណាត់ៗ ។ បទថា **អគ្គេ ច** សេចក្តីថា ទេវតាអង្វរថា កាលកាត់ ចូរកាត់ខាងចុងមុន បន្ទាប់អំពីនោះ កាត់ត្រង់កណ្តាល ក្រោយគេបង្អស់ ចូរកាត់ត្រង់គល់ កាលខ្ញុំត្រូវកាត់យ៉ាងនេះ ការស្លាប់ក៏មិនគប្បីជាទុក្ខ គង់មានសេចក្តីសុខជាអន្ទើៗ ។ លំដាប់នោះ ព្រះរាជាបានត្រាស់ ២ គាថាថា

ដូចយ៉ាងបុគ្គលកាត់ដៃ និងជើងផង ត្រចៀក និងច្រមុះផង ឲ្យស្លាប់បាត់ជីវិត តពីនោះ គេកាត់នូវក្បាលក្នុងកាលខាងក្រោយ សេចក្តីស្លាប់នោះ ក៏ជាទុក្ខដែរ ។

ម្នាលកទ្ទសាលព្រឹក្ស ជាម្ចាស់នៃព្រៃ ការកាត់ជាកំណាត់ស្រួល ឬ ព្រោះហេតុអ្វី ប្រារព្ធហេតុអ្វី បានជាអ្នកចង់ឲ្យគេកាត់ជាកំណាត់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ហត្ថបាទំ** បានដល់ នូវដៃ និងជើង ។ បទថា **តំ ទុក្ខំ** សេចក្តីថា កាលចោរត្រូវកាត់ដោយលំដាប់យ៉ាងនេះ ការស្លាប់គប្បីជាទុក្ខ ។ បទថា **សុខំ នុ** សេចក្តីថា នៃដើមរាំងសម្លាញ់ ចោរដែលត្រូវទោសប្រហារ ប្រាថ្នាសេចក្តីស្លាប់ដោយសេចក្តីសុខ រមែងសូមឲ្យកាត់ក្បាល មិនសូមឲ្យកាត់ជាកំណាត់ៗ នោះឡើយ តែអ្នកសូមយ៉ាងនេះ ហេតុនោះ ខ្ញុំសូមសួរអ្នកថា មានសុខមកអំពីណា ដែលត្រូវកាត់ជាកំណាត់ៗ ។ បទថា **កឹ ហេតុ** សេចក្តីថា ឈ្មោះថាការកាត់ជាកំណាត់ៗ មិនមានសេចក្តីសុខឡើយ តែក្នុងរឿងនេះគង់មានហេតុ ព្រះរាជាកាលត្រាស់សួរដូច្នេះ ជា

មួយទេវតានោះ ទើបត្រាស់យ៉ាងនេះ ។

លំដាប់នោះ ភទ្ទសាលទេវតា កាលប្រាប់ដល់ព្រះរាជា ទើបពោល ២ គាថាថា

បពិត្រមហារាជ ខ្ញុំចង់ឲ្យគេកាត់ជាកំណាត់ ព្រោះអាស្រ័យ
ហេតុដែលប្រកបដោយហេតុណា សូមព្រះអង្គទ្រង់ស្ដាប់នូវ
ហេតុនោះ របស់ខ្ញុំចុះ ។

ពួកឈើជាញាតិរបស់ខ្ញុំ ចម្រើនដុះដាលដោយសេចក្ដីសុខ កើត
ក្នុងទីមិនមានខ្យល់នៅជិតខាងខ្ញុំ ( កាលបើទ្រង់កាប់រំលំខ្ញុំ ) ខ្ញុំ
មុខជានឹងរំលំសង្កត់ពួកឈើជាញាតិនោះ សេចក្ដីទុក្ខនឹងកើតមាន
ដល់ពួកឈើជាញាតិដទៃទៀត ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ហេតុធម្មូបសញ្ហិតំ** សេចក្ដីថា បពិត្រមហារាជ ខ្ញុំប្រាថ្នា គឺបំណងហេតុដែលសមគួរដល់សេចក្ដីពិតនោះឯង មិនមែនត្រឹមហេតុមិនសម ខ្ញុំប្រាថ្នាឲ្យកាត់ជាកំណាត់ សូមទ្រង់ផ្ទៀងព្រះសោតៈស្ដាប់ហេតុនោះចុះ ។ បទថា **ញាតិ មេ** សេចក្ដីថា ពួកទេវតាជាញាតិរបស់ខ្ញុំ នាំគ្នាជំជាត់ជាសុខ ក្នុងម្លប់នៃសាលព្រឹក្សដ៏ស្អាតរបស់ខ្ញុំ ។ បទថា **មម បស្សេ** សេចក្ដីថា ទេវតាជាញាតិរបស់ខ្ញុំ កើតឡើងក្នុងសាលព្រឹក្សជុំទង់ៗ បានឈ្មោះថា កើតក្នុងទីមិនមានខ្យល់ ព្រោះខ្ញុំជួយការពារកុំឲ្យមានខ្យល់ កាលខ្ញុំមានមែក និងប្រគាបធំទូលាយ ត្រូវកាត់ត្រង់គល់រំលំចុះ គប្បីបៀតបៀនដល់ញាតិបាន គឺធ្វើឲ្យវិមានបាក់បែកខ្ទេចខ្ទីបាន ។ បទថា **បរេសំ អសុ-**

**ទោចិតំ** សេចក្តីថា ទេវតាមានបំណងដូច្នេះថា ការមិនសុខ គឺសេចក្តីទុក្ខ ឈ្មោះថា ខ្ញុំប្រមូលឲ្យ បន្ថែមឲ្យដល់អ្នកដទៃ គឺដល់ពួកទេវតាជាញាតិទាំងនោះ ខ្ញុំមិនបានប្រាថ្នាសេចក្តីទុក្ខដល់ជនទាំងនោះឡើយ ព្រោះហេតុនោះ ទើបខ្ញុំសូមឲ្យកាត់កទ្ទសាលព្រឹក្សនោះ ជាកំណាត់ៗ ។

ព្រះរាជាស្តាប់ទេវាធិប្បាយនោះហើយ ទ្រង់ត្រេកអរថា ទេវបុត្រនេះជាអ្នកទ្រទ្រង់ធម៌ពិត មិនបានប្រាថ្នាទម្លាយវិមានរបស់ពួកញាតិ ព្រោះការវិនាសនៃវិមានរបស់ខ្លួន ប្រព្រឹត្តប្រយោជន៍ដល់ពួកញាតិ ខ្ញុំត្រូវឲ្យអភ័យដល់អ្នក ហើយត្រាស់អវសានគាថាថា

ម្នាលកទ្ទសាលព្រឹក្សជាម្ចាស់នៃព្រៃ អ្នកគិតនូវហេតុដែលមានសភាពគួរគិត អ្នកជាឈើប្រាថ្នានូវប្រយោជន៍ដល់ពួកឈើជាញាតិ ម្នាលសម្លាញ់ ខ្ញុំឲ្យអភ័យដល់អ្នក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ចេតេយ្យរូបំ ចេតេសិ** សេចក្តីថា នៃកទ្ទសាលសម្លាញ់ អ្នកគិតរឿងដែលឈ្មោះថាគួរគិត ព្រោះមានចិត្តទន់ក្នុងពួកញាតិនោះឯង ។ បាលីថា **ចេតយ្យរូបំ ចេតេសិ** ដូច្នេះក៏មាន ពាក្យនោះមានអធិប្បាយថា កាលអ្នកប្រាថ្នាឲ្យកាត់ជាកំណាត់ ជាការឲ្យកាត់ត្រឹមត្រូវតាមដែលគួរកាប់នោះឯង ។ បទថា **អភយំ** សេចក្តីថា ព្រះរាជាត្រាស់ថា នៃសម្លាញ់ ខ្ញុំជ្រះថ្លាក្នុងគុណរបស់អ្នក ខ្ញុំឲ្យអភ័យដល់អ្នក ខ្ញុំមិនត្រូវការប្រាសាទ ខ្ញុំនឹងមិនឲ្យគេកាប់ដើមឈើនោះ សូមអ្នកទៅចុះ សូមអ្នកមានពួកញាតិចោមរោម បានទទួលសក្ការៈ បានទទួលសេចក្តីគោរព តម្កល់ជីវិត

ជាសុខចុះ ។ ទេវតាសម្ដែងធម៌ថ្វាយព្រះរាជា ហើយបានត្រឡប់ទៅ ព្រះរាជាតាំងនៅក្នុងឱវាទរបស់ទេវតា ទ្រង់ធ្វើបុណ្យមានទានជាដើម ធ្វើផ្លូវទៅស្ថានសួគ៌ឲ្យពេញ ។

ព្រះសាស្ដា ទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែងហើយ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សូម្បីក្នុងកាលមុន តថាគតក៏បានប្រព្រឹត្តញាតត្ថចរិយាហើយដូចគ្នាយ៉ាងនេះ ទ្រង់ប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទក្នុងកាលឥឡូវនេះ ពួកទេវតាដែលកើតត្រង់ដើមរាំងជំទង់ៗ ក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទ ចំណែកភទ្ទសាលទេវរាជក្នុង កាលនោះ គឺតថាគតនេះឯង ។៚

**អដ្ឋកថា ភទ្ទសាលជាតក ចប់**

# សុត្តន្តបិដក

## សមុទ្ទវាណិជជាតក

[ ៩២៣ ] ( ព្រះសាស្តា ទ្រង់សម្តែងនូវឧទានរបស់បុរសម្នាក់ថា ) ពួកមនុស្សជន ( ក្នុងជម្ពូទ្វីប ) ទាំងនោះ អាស្រ័យចិញ្ចឹមជីវិតដោយផលនៃការងារ រមែងសាបព្រោះ ក៏មិនបានមួយចំណែកនៃកោះនេះឡើយ ឯកោះរបស់យើងនេះប្រសើរជាងជម្ពូទ្វីប ។

[ ៩២៤ ] ( ធម្មិកទេវបុត្របានពោលថា ) កាលបើព្រះចន្ទដើរដល់រាត្រី ១៥ កើត សមុទ្រនៃសាគរដ៏ធំនឹងជោរលិចកោះដ៏ថ្កុំថ្កើងនេះ សមុទ្រនៃសាគរនោះ កុំសម្លាប់អ្នកទាំងឡាយឡើយ អ្នកទាំងឡាយ ចូរទៅរកទីជ្រកកោនដទៃចុះ ។

[ ៩២៥ ] ( អធម្មិកទេវបុត្របានពោលថា ) សមុទ្រនៃទឹកក្នុងសាគរនេះ មិនមែនជោរលិចកោះដ៏ថ្កុំថ្កើងនេះទេ ដំណើរនោះយើងឃើញដោយនិមិត្តដ៏ច្រើន អ្នកទាំងឡាយកុំខ្លាច សោយសោក ព្រោះហេតុអ្វី ចូររីករាយចុះ ។

[ ៩២៦ ] អ្នកទាំងឡាយ បានដល់លំនៅដ៏ថ្កុំថ្កើងនេះ ជាកន្លែងមានចំណីដ៏ច្រើន មានបាយ និងទឹកដ៏ច្រើន យើងមិនឃើញភ័យបន្តិចបន្តួចនៃអ្នកទាំងឡាយឡើយ អ្នកទាំងឡាយ ចូររីករាយជាមួយនឹងកូន និងចៅទាំងឡាយចុះ ។

[ ៩២៧ ] ជាងឈើជាមនុស្សពាលបានពោលថា ទេវតាណា ឋិតក្នុងទិសខាងត្បូង និយាយប្រាប់សេចក្ដីក្សេម ពាក្យរបស់ទេវតានោះពិត ទេវតាដែលឋិតក្នុងទិសខាងជើង មិនដឹងនូវហេតុដែលគួរខ្លាច និងមិនគួរខ្លាចទេ អ្នកទាំងឡាយ កុំខ្លាចឡើយ សោយសោកធ្វើអ្វី ចូរនាំគ្នារីករាយចុះ ។

[ ៩២៨ ] ( ជាងឈើជាបណ្ឌិតបានពោលថា ) យក្ខទាំងនេះពោលខុសគ្នា យក្ខម្នាក់ប្រាប់នូវភ័យ យក្ខម្នាក់ប្រាប់នូវសេចក្ដីក្សេម ណ្ហើយចុះ អ្នកទាំងឡាយ ចូរស្ដាប់នូវពាក្យយើងចុះ យើងទាំងអស់គ្នា កុំវិនាសឆាប់រួសរាន់ឡើយ ។

[ ៩២៩ ] យើងទាំងអស់គ្នា ចូរប្រជុំគ្នាធ្វើទូក គឺទូកកម្រោលមាំ ប្រកបដោយយន្ដគ្រប់យ៉ាង បើទេវតាដែលឋិតក្នុងទិសខាងត្បូងនេះនិយាយពិត ទេវតាដែលឋិតក្នុងទិសខាងជើងនិយាយប្រាប់នេះ មិនពិតឡើយ ។

[ ៩៣០ ] ទូករបស់យើងនោះ នឹងមានប្រយោជន៍ដល់សេចក្ដីអន្ដរាយ ( ដែលកើតខាងក្រោយ ) ពួកយើងមិនលះបង់នូវកោះនេះទេ បើទេវតាដែលឋិតក្នុងទិសខាងជើងនិយាយពិត ទេវតាដែលឋិតក្នុងទិសខាងត្បូងនេះ និយាយមិនពិតទេ ។

[ ៩៣១ ] យើងទាំងអស់គ្នា ឡើងជិះទូកនោះឯង ហើយគប្បីឆ្លងទៅរកត្រើយខាងនាយដោយសួស្ដីយ៉ាងនេះ បុគ្គលមិនគប្បី

ជឿដោយងាយថា ពាក្យដែលបុគ្គលទីមួយពោលហើយ ជាពាក្យប្រសើរដូច្នេះទេ នរជនណាក្នុងលោកនេះ កាន់យកនូវពាក្យនៃបុគ្គលទី ២ ដែលដល់នូវគន្លងនៃត្រចៀក ហើយពិចារណា ( នូវពាក្យខាងដើម និងពាក្យខាងចុង ) ហើយជឿនូវពាក្យជាកណ្តាល នរជននោះ រមែងដល់នូវទីដ៏ប្រសើរ ។

[ ៩៣២ ] ( អភិសម្ពុទ្ធគាថា ) ពាណិជទាំងនោះបានទៅដោយសួស្តី ក្នុងកណ្តាលនៃទឹកសមុទ្រដោយកម្មរបស់ខ្លួន យ៉ាងណាមិញ កុលបុត្រមានប្រាជ្ញាដូចផែនដី បានដឹងច្បាស់នូវប្រយោជន៍ជាអនាគតហើយ មិនប្រព្រឹត្តកន្លងនូវប្រយោជន៍ ( របស់ខ្លួន ) សូម្បីតិចក៏យ៉ាងនោះដែរ ។

[ ៩៣៣ ] ពួកជនពាលដែលជាប់ក្នុងរសដោយមោហៈ មិនបានដឹងច្បាស់នូវប្រយោជន៍ជាអនាគត ក៏លិចចុះក្នុងប្រយោជន៍ជាបច្ចុប្បន្ន ដូចជាមនុស្សទាំងនោះ ( ដល់នូវសេចក្តីវិនាស ) ក្នុងកណ្តាលសមុទ្រ ។

[ ៩៣៤ ] បុគ្គលគប្បីគ្រោងទុកនូវកិច្ចជាអនាគត ( ដោយបំណងថា ) កិច្ចកុំបៀតបៀនអញក្នុងកាលដែលមានកិច្ចឡើយ ឯកិច្ចនោះមិនបានបៀតបៀននូវបុគ្គលនោះ ជាអ្នកធ្វើកិច្ចដែលខ្លួនបានគ្រោងទុកហើយ ប្រាកដដូច្នោះ ក្នុងកាលជាទីធ្វើកិច្ច ។

**សមុទ្ទវាណិជជាតកទី ៣ ចប់**

# អដ្ឋកថា

## សមុទ្ទវាណិជជាតក

[ ៩២៣-៩៣៤ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភាពដែលទេវទត្តនាំត្រកូល ៥០០ ទៅកាន់នរក ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **កសន្តិ វបន្តិ តេ ជនា** ដូច្នេះជាដើម ។

មានរឿងពិស្តារថា ទេវទត្តនោះ កាលអគ្គសាវកនាំបរិស័ទចៀសចេញទៅហើយ មិនអាចអត់សង្កត់សេចក្តីសោកបាន កាលឈាមក្តៅហូរចេញមកអំពីមាត់ ត្រូវវេទនាដ៏មានកម្លាំងគ្របសង្កត់ រឭកដល់គុណរបស់ព្រះដ៏មានព្រះភាគ គិតថា អញតែម្នាក់គិតនឹងទម្លាយចក្ររបស់ព្រះតថាគត អស់កាល ៩ ខែ តែព្រះសាស្តាមិនបានមានចិត្តប្រទូស្តក្នុងអញឡើយ សូម្បីព្រះថេរៈ ៨០ អង្គ ក៏មិនមានអាឃាតក្នុងអញ អញឥតទីពឹង ឥឡូវនេះ ដោយកម្មដែលអញធ្វើ ព្រះសាស្តាសោត ក៏ទ្រង់បោះបង់អញចោល ព្រះមហាថេរៈទាំងឡាយក៏បោះបង់អញចោលហើយ ព្រះរាហុលត្ថេរ ញាតិដ៏ប្រសើររបស់អញសោតក៏បោះបង់អញដែរ សូម្បីសក្យរាជត្រកូល ក៏នាំគ្នាបោះបង់អញចោលដែរ អញត្រូវទៅក្រាបទូលសូមខមាទោសជាមួយព្រះសាស្តា ហើយឲ្យសញ្ញាដល់បរិស័ទ ឲ្យជួយសែងខ្លួនទៅដោយគ្រែ ខាងរនោចរហូតដល់ដែនកោសល ។ ព្រះអានន្ទត្ថេរក្រាបទូលដល់ព្រះសាស្តាថា បពិត្រព្រះអង្គ បានឮថា ទេវទត្តកំពុងធ្វើដំណើរមក ដើម្បីឲ្យទ្រង់អត់ទោស ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទទេវទត្តមិនបានឃើញតថាគតឡើយ ។ កាលនោះ កាលទេវទត្តដល់ទ្វារនគរសាវត្ថី ព្រះអានន្ទត្ថេរក្រាបទូលទៀត ព្រះដ៏មានព្រះភាគ ក៏ទ្រង់មានព្រះ

តម្រាស់យ៉ាងនោះដូចគ្នា កាលទេវទត្តដល់ក្បែរស្រះបោក្ខរណីជេតពន ក្បែរទ្វារព្រះវិហារជេតពន បាបកម្មក៏ដល់ទីបំផុត ការក្តៅក្រហាយកើតឡើងក្នុងរាងកាយ ទេវទត្តប្រាថ្នានឹងងូតទឹក ផឹកទឹកទើបពោលថា អាវុសោទាំងឡាយឲ្យខ្ញុំចុះអំពីគ្រែចុះ ខ្ញុំនឹងផឹកទឹក លុះទេវទត្តនោះឈានចុះជាន់ផែនដីប៉ុណ្ណោះ ដែលមិនទាន់បានសមដូចបំណងឡើយ មហាប្រឹថពីបានបើកចន្លោះឲ្យរំពេចនោះឯង អណ្តាតភ្លើងចេញអំពីអវិចី ក៏លេបត្របាក់យកទេវទត្តទៅ ទេវទត្តគិតថា បាបកម្មអញដល់ទីបំផុតហើយ ដូច្នេះហើយ ទើបរឭកដល់ព្រះគុណរបស់ព្រះតថាគត តាំងនៅក្នុងសរណៈដោយគាថានេះថា

ខ្ញុំសូមដល់ព្រះពុទ្ធ ជាបុគ្គលដ៏ប្រសើរ ជាទេវតានៃទេវតា ជាសារថីនៃបុគ្គលដែលគួរទូន្មាន មានព្រះចក្ខុឃើញដោយជុំវិញ ទ្រទ្រង់នូវបុញ្ញលក្ខណៈរាប់រយ ព្រះអង្គនោះជាជាទីពឹង ដោយខ្យល់ដង្ហើម និងឆ្អឹងទាំងឡាយនេះ ដូច្នេះ ។

បានបែរមុខទៅកាន់អវិចី ឯត្រកូលឧបដ្ឋាករបស់ទេវទត្តនោះ មានដល់ទៅ ៥០០ ត្រកូល សូម្បីត្រកូលទាំងនោះ នាំគ្នាចូលខាងទេវទត្តនោះ ជេរព្រះទសពល នាំគ្នាទៅក្នុងអវិចីទាំងអស់ ។ ទេវទត្តនោះដឹកនាំត្រកូល ៥០០ ឲ្យទៅកាន់អវិចីនរក ដោយប្រការដូច្នេះ ។

សម័យមួយ ភិក្ខុទាំងឡាយនាំគ្នាលើករឿងឡើងសន្ទនាក្នុងធម្មសភាថា អាវុសោទាំងឡាយ ទេវទត្តជាមនុស្សបាប ចងសេចក្តីក្រោធដែលមិនមែនជាឋានៈ ក្នុងព្រះសម្មាសម្ពុទ្ធ ព្រោះលិចក្នុងលាភសក្ការៈ មិនសម្លឹងមើលភ័យ

ក្នុងអនាគតឡើយ ត្រូវបែរមុខទៅកាន់អវីចិជាមួយត្រកូលទាំង ៥០០ ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អំបាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលថា បពិត្រអង្គ ដោយរឿងឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលទេវទត្តលិចលង់ក្នុងលាភ និងសក្ការៈ មិនសម្លឹងមើលភ័យក្នុងអនាគត សូម្បីក្នុងកាលមុន ក៏មិនសម្លឹងមើលភ័យក្នុងអនាគត ដល់នូវសេចក្តីវិនាសធំជាមួយគ្នីគ្នា ព្រោះស្វែងរកសេចក្តីសុខចំពោះមុខ ដូច្នេះហើយ ទ្រង់នាំអតីតនិទានមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ក្នុងទីដែលមិនឆ្ងាយអំពីនគរពារាណសី មានស្រុកជាងឈើដ៏ធំមួយ មានត្រកូលមួយពាន់រស់នៅ ក្នុងទីនោះពួកជាងឈើនាំគ្នាពោលថា ពួកខ្ញុំនឹងធ្វើគ្រែឲ្យដល់ពួកអ្នក នឹងធ្វើតាំង នឹងធ្វើផ្ទះឲ្យដល់ពួកអ្នក ក៏ខ្ចីបំណុលជាច្រើនអំពីដៃរបស់ពួកមនុស្ស ហើយមិនអាចធ្វើអ្វីបានឡើយ ហ្វូងមនុស្សក៏នាំគ្នាតឹងទារក្នុងទីដែលជួបពួកជាងឈើនោះ ៗ ពួកជាងឈើនោះ ត្រូវម្ចាស់បំណុលតឹងទារ កាលមិនអាចនៅជាសុខបាន ទើបនិយាយទៀតថា ពួកយើងនឹងនាំគ្នាទៅកាន់ប្រទេសដទៃ ទៅនៅក្នុងទីឯណានីមួយចុះ បបួលគ្នាចូលព្រៃកាប់ឈើធ្វើទូកដ៏ធំ អុំមកចតក្នុងទីកន្ទះយោជន៍ និងមួយគាវុតអំពីស្រុក លុះដល់ពេលយប់ នាំគ្នាមកនាំកូនប្រពន្ធឡើងទូកដែលចត ចេញដំណើរទៅកាន់សមុទ្រដោយលំដាប់ ៗ កាលទូកត្រាច់ទៅដោយអំណាចខ្យល់ នាំគ្នាដល់

កោះមួយកន្លែងកណ្ដាលមហាសមុទ្រ ។ ក្នុងកោះនោះ មានផ្លែឈើផ្សេងៗច្រើនយ៉ាង មានស្រូវសាលី អំពៅ ចេក ស្វាយ ព្រីង ខ្នុរ ត្នោត ដូងជាដើម កើតឯងក្នុងទីនោះ បានឮថា មានបុរសទូកលិចម្នាក់ទៅដល់កោះនោះមុន បរិភោគស្រូវសាលី ទំពាស៊ីនូវអំពៅជាដើម មានរាងកាយធាត់ ជាមនុស្សអាក្រាតកាយ មានសក់ និងពុកមាត់ដុះទ្រុបទ្រុល ស្នាក់នៅត្រង់កោះនោះ កាលនោះ ពួកជាងឈើទាំងនោះគិតគ្នាថា បើកោះនេះមានអរក្សទឹកគ្រប់គ្រង ពួកយើងទាំងអស់នឹងនាំគ្នាដល់សេចក្ដីវិនាស ពួកយើងត្រូវពិនិត្យមើលកោះជាមុន ពេលនោះ បុរស ៧-៨ នាក់ ជាមនុស្សក្លាហាន មានកម្លាំងសៀតនូវអាវុធ ៥ ប្រការ ទៅពិនិត្យមើលកោះ ។ ខណៈនោះ បុរសនោះបរិភោគអាហារព្រឹក ហើយផឹកទឹកអំពៅដោយមានសេចក្ដីសុខ ដេកផ្ងារក្នុងម្លប់ដ៏ត្រជាក់លើផ្ទៃខ្សាច់ ដូចកម្រាលប្រាក់ ក្នុងប្រទេសដែលគួរជាទីរីករាយកាលនឹងច្រៀងថា អ្នកជម្ពូទ្វីបនាំគ្នាភ្ជួរ នាំគ្នាសាបព្រោះ មិនបានសេចក្ដីសុខបែបនេះឡើយ កោះតូចរបស់យើងនេះប៉ុណ្ណោះ ប្រសើរជាងជម្ពូទ្វីប បន្លឺឧទាននេះ ។ លំដាប់នោះ ព្រះសាស្ដាត្រាស់ហៅភិក្ខុទាំងឡាយ កាលទ្រង់សម្ដែងថា ម្នាលភិក្ខុទាំងឡាយ បុរសនោះបន្លឺឧទាននេះហើយ ត្រាស់គាថាទី ១ ថា

> ពួកមនុស្សជន ( ក្នុងជម្ពូទ្វីប ) ទាំងនោះ អាស្រ័យចិញ្ចឹមជីវិត
> ដោយផលនៃការងារ រមែងសាបព្រោះ ក៏មិនបានមួយចំណែកនៃ
> កោះនេះឡើយ ឯកោះរបស់យើងនេះប្រសើរជាងជម្ពូទ្វីប ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **តេ ជនា** បានដល់ ជនអ្នកជម្ពូទ្វីប ។ បទ

ថា **កម្មជលូបជីវិនោ** សេចក្ដីថា ជាសត្វដែលត្រូវចិញ្ចឹមជីវិតដោយផលនៃកម្មផ្សេងៗ ។ លំដាប់នោះ ពួកបុគ្គលដែលត្រួតត្រាមើលកោះនោះ ស្ដាប់សំឡេងច្រៀងរបស់បុរសនោះ នាំគ្នាពោលថា ពួកយើងស្ដាប់មើលដូចសំឡេងមនុស្ស យើងត្រូវដឹងសំឡេងនោះឲ្យបាន នាំគ្នាដើរតាមខ្សែសំឡេង ឃើញបុរសនោះនាំគ្នាភ័យខ្លាច ដូចឃើញយក្ខ នាំគ្នាផ្ទប់ព្រួញ ចំណែកបុរសនោះ ឃើញមនុស្សទាំងនោះដោយខ្លាចមនុស្សទាំងនោះសម្លាប់ខ្លួន ទើបអង្វរថា នែអ្នក ខ្ញុំមិនមែនយក្ខទេ ខ្ញុំជាមនុស្ស សូមឲ្យជីវិតដល់ខ្ញុំចុះ កាលជនទាំងនោះពោលថា ធម្មតាមនុស្សដែលអាក្រាតដូចឯងមិនមានឡើយ ទើបអង្វរហើយអង្វរទៀត ឲ្យជនទាំងនោះដឹងភាពដែលខ្លួនជាមនុស្ស រហូតទាល់តែបាន ។ ជនទាំងនោះ នាំគ្នាចូលទៅរកបុរសនោះ ធ្វើនូវសម្មោទនីយកថាហើយ សួរដល់រឿងដែលបុរសនោះមកក្នុងកោះនោះ ។ បុរសនោះ ក៏និទានរឿងទាំងពួងដល់ជនទាំងនោះ ហើយពោលថា ពួកអ្នកនាំគ្នាមកក្នុងទីនេះដោយបុញ្ញសម្បត្តិរបស់ខ្លួន កោះនេះជាកោះឧត្តម ក្នុងកោះនេះ បុគ្គលមិនចាំបាច់ធ្វើនូវការងារដោយដៃរបស់ខ្លួនឡើយ ក៏នាំគ្នារស់នៅបានស្រូវសាលីដុះឯងអំពៅជាដើមក្នុងកោះនេះមិនមានទីបំផុតឡើយ ព្រោះហេតុនោះ សូមពួកអ្នករស់នៅដោយមិនចាំបាច់ខ្វល់ខ្វាយចុះ ។ ជនទាំងនោះសួរថា អន្តរាយណាមួយមិនមានដល់ពួកយើងដែលនៅក្នុងកោះនេះទេឬ បុរសនោះឆ្លើយថា ភ័យដទៃមិនមានក្នុងកោះនេះឡើយ តែកោះនេះអមនុស្សគ្រប់គ្រង ពួកអមនុស្សឃើញឧច្ចារៈ និងបស្សាវៈរបស់ពួកអ្នកហើយ គប្បីខឹងក្រោធបាន ហេតុនោះ កាល

បន្ទោបង់ឧច្ចារបស្សាវៈ គប្បីជីកខ្សាច់ហើយលុបផង ក័យក្នុងកោះ នេះមានប្រមាណប៉ុណ្ណេះ មិនមានដទៃទៀយ ពួកអ្នកគប្បីនាំគ្នាមិនប្រមាទជានិច្ចចុះ ។ ពួកជនទាំងនោះ អាស្រ័យនៅក្នុងកោះនោះ ។ ក្នុងមួយពាន់ត្រកូលនោះ មានជាងឈើ ២ នាក់ជាប្រធាន ម្នាក់មានបរិវារ ៥០០ ត្រកូល ក្នុងមេជាងទាំងពីរនោះ មេជាងម្នាក់ជាបុគ្គលពាល ឈ្លក់វង្វេងក្នុងរស ម្នាក់ទៀតជាបណ្ឌិតមិនជាប់ជ្រប់ក្នុងរសទាំងឡាយ ក្នុងកាលតមក ក្រុមគ្រួសារទាំងនោះ ក៏នាំគ្នានៅយ៉ាងសប្បាយក្នុងកោះនោះ មានរាងកាយធាត់ គិតគ្នាថា ពួកយើងឆ្ងាយអំពីសុរាណាស់ ពួកយើងនាំគ្នាធ្វើមេរ័យដោយទឹកអំពៅ ផឹកជាមួយគ្នាចុះ ជនទាំងនោះនាំគ្នាធ្វើមេរ័យផឹក នាំគ្នារាំលេង ប្រមាទដោយសេចក្តីស្រវឹង បន្ទោបង់ឧច្ចារ និងបស្សាវៈ ក្នុងទីនោះហើយមិនលុប ធ្វើកោះឲ្យស្មោកគ្រោក បដិកូល ពួកទេវតាក្រោធ ពោលថា ពួកមនុស្សទាំងនេះ នាំគ្នាធ្វើទីលេងរបស់យើងឲ្យស្មោកគ្រោក គិតគ្នាថា ត្រូវឲ្យទឹកសមុទ្រជន់ឡើង ធ្វើនូវការលាងកោះនេះចេញ នាំគ្នាកំណត់ថ្ងៃថា ថ្ងៃនេះជាកាលបក្ខ សមាគមរបស់ពួកយើង ក៏ត្រូវទម្លាយ ហើយក្នុងថ្ងៃនេះ ក្នុងថ្ងៃឧបោសថទី ១៥ បន្ទាប់អំពីថ្ងៃនេះ ពេលព្រះចន្ទរះឡើងហើយ ពួកយើងឲ្យទឹកសមុទ្រជន់សម្លាប់មនុស្សទាំងនេះចោលឲ្យអស់នោះឯង ។ កាលនោះ ក្នុងក្រុមនៃទេវតាទាំងនោះ ទេវបុត្រមួយអង្គ ជាអ្នកទ្រទ្រង់ធម៌ មានសេចក្តីករុណាថា ជនទាំងនេះ ចូរកុំវិនាសទៅទាំងដែលអាត្មាអញកំពុងឃើញនេះឡើយ កាលមនុស្សទាំងនោះបរិភោគអាហារល្ងាចហើយ អង្គុយសន្ទនាគ្នាយ៉ាងសប្បាយត្រង់ទ្វារ

ផ្ទះ ទើបប្រដាប់កាយដោយអាភរណៈទាំងពួង ធ្វើនូវកោះទាំងអស់ឲ្យភ្លឺរុង
រឿងតែមួយ ឈរនៅក្នុងអាកាសទិសខាងជើង ពោលថា នែជាងឈើទាំង
ឡាយ ពួកទេវតានាំគ្នាក្រោធចំពោះអ្នក ពួកអ្នកកុំនាំគ្នានៅក្នុងទីនេះឡើយ
កន្លះខែកន្លងទៅអំពីថ្ងៃនេះ ពួកទេវតានឹងនាំទឹកសមុទ្រឲ្យជន់ឡើងសម្លាប់ពួក
អ្នកទាំងអស់នោះឯង ចូរពួកអ្នកនាំគ្នាចេញអំពីកោះនេះចុះ ហើយពោល
គាថាទី ២ ថា

កាលបើព្រះចន្ទ ដើរដល់រាត្រី ១៥ កើត សមុទ្រនៃសាគរដ៏ធំ
នឹងជោរលិចកោះដ៏ថ្កុំថ្កើងនេះ សមុទ្រនៃសាគរនោះ កុំសម្លាប់
អ្នកទាំងឡាយឡើយ អ្នកទាំងឡាយ ចូរទៅរកទីជ្រកកោនដទៃចុះ
ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧច្ចាវស្សំ** គឺហូរចូលទៅ បានដល់ ជន់
លិចកោះនេះ ។ បទថា **មា វោ វធិ** សេចក្តីថា រលកនៃសាគរនោះ កុំបី
កម្ចាត់ពួកអ្នកឡើយ ។

ទេវបុត្រនោះ ឲ្យឱវាទដល់ជនទាំងនោះយ៉ាងនេះហើយ ក៏ទៅកាន់ដែន
របស់ខ្លួនមួយរំពេច កាលទេវបុត្រនោះទៅហើយ ទេវបុត្រមួយទៀត ជាទេវបុត្រ
អាក្រក់ រឹងត្អឹង គិតថា ជនទាំងនេះគប្បីជឿពាក្យរបស់ទេវបុត្រអង្គនេះ នាំ
គ្នាគេចទៅ អញត្រូវឃាត់ការទៅរបស់ជនទាំងនោះ ត្រូវឲ្យដល់នូវសេចក្តី
វិនាសទាំងអស់ ទើបប្រដាប់ដោយគ្រឿងអលង្ការដែលជាទិព្វ ធ្វើស្រុកទាំង
អស់ ឲ្យភ្លឺស្វាងតែមួយ ឈរក្នុងអាកាសត្រង់ទិសទក្សិណ សួរថា ទេវបុត្រ

មួយអន្លមកទីនេះឬ កាលជនទាំងនោះឆ្លើយថា មក ក៏សួរថា គេនិយាយអ្វី នឹងពួកអ្នក កាលជនទាំងនោះនាំគ្នាឆ្លើយថា ពោលរឿងឈ្មោះនេះ ទើបពោលថា ទេវបុត្រនោះ មិនចង់ឲ្យពួកអ្នកនៅក្នុងទីនេះ ពោលដោយការទើសទាល់ ពួកអ្នកមិនចាំបាច់ទៅទីដទៃឡើយនាំគ្នានៅទីនេះចុះ បានពោល ២ គាថា ដោយសេចក្តីថា

សមុទ្រនៃទឹកក្នុងសាគរនេះ មិនមែនជាវលិចកោះដ៏ធំធំធ្វើងនេះទេ
ដំណើរនោះ យើងឃើញដោយនិមិត្តដ៏ច្រើន អ្នកទាំងឡាយ
កុំខ្លាច សោយសោក ព្រោះហេតុអ្វី ចូររីករាយចុះ ។
អ្នកទាំងឡាយ បានដល់លំនៅដ៏ធំធ្វើងនេះ ជាកន្លែងមានចំណី
ដ៏ច្រើន មានបាយ និងទឹកដ៏ច្រើន យើងមិនឃើញភ័យបន្តិច
បន្តួចនៃអ្នកទាំងឡាយឡើយ អ្នកទាំងឡាយ ចូររីករាយជាមួយ
នឹងកូន និងចៅទាំងឡាយចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឆ ជាតយំ** កាត់បទជា **ឆ ជាតុ អយំ** ។ បទថា **មា ភេថ** បានដល់ កុំខ្លាចឡើយ ។ បទថា **បមោទថវ្ហោ** សេចក្តីថា ចូរអ្នកទាំងឡាយនាំគ្នាត្រេកអរ កើតនូវបីតិសោមនស្ស ។ បទថា **អាបុត្ត-បុត្តេហិ** សេចក្តីថា ចូរត្រេកអរអស់មួយជួរកូន មួយជួរចៅចុះ ក្នុងទីនេះរមែងមិនមានភ័យដល់ពួកអ្នកឡើយ ។ ទេវបុត្រនោះ លួងលោមពួកមនុស្សទាំងនោះដោយគាថា ២ គាថានេះហើយ ចៀសចេញទៅ ។ ក្នុងពេលដែលទេវបុត្រនោះបានត្រឡប់ទៅហើយ ជាងឈើដែលជាបុគ្គលពាល ស្តាប់ពាក្យ

របស់ទេវបុត្រ ដែលតាំងនៅក្នុងធម៌ហើយមិនជឿ ក៏ដាស់តឿនពួកជាងឈើដ៏សេសថា ម្នាលគ្នាយើង សូមអ្នកស្តាប់ពាក្យរបស់ខ្ញុំ ហើយពោលគាថាទី ៥ ថា

ជាងឈើជាមនុស្សពាលបានពោលថា ទេវតាណា បិតក្នុងទិស
ខាងត្បូង និយាយប្រាប់សេចក្តីក្សេម ពាក្យរបស់ទេវតានោះពិត
ទេវតាដែលបិតក្នុងទិសខាងជើង មិនដឹងនូវហេតុ ដែលគួរខ្លាច
និងមិនគួរខ្លាចទេ អ្នកទាំងឡាយកុំខ្លាចឡើយ សោយសោកធ្វើអ្វី
ចូរនាំគ្នារីករាយចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ទក្ខិណាយំ** បានដល់ ក្នុងទក្ខិណទិសម្យ៉ាងទៀត បាលីក៏យ៉ាងនោះដូចគ្នា ។

ពួកជាងឈើ ៥០០ ងប់ជ្រប់ក្នុងរស ស្តាប់ពាក្យនោះហើយ កាន់យកពាក្យរបស់ជាងឈើពាលនោះ ។ ចំណែកជាងឈើដែលជាបណ្ឌិតម្នាក់ទៀតមិនព្រមជឿពាក្យរបស់ជាងឈើនោះ ហៅជាងឈើទាំងនោះមក បានពោល ៤ គាថាថា

យក្ខទាំងនេះ ពោលខុសគ្នា យក្ខម្នាក់ប្រាប់នូវភ័យ យក្ខម្នាក់
ប្រាប់នូវសេចក្តីក្សេម ណ្ហើយចុះ អ្នកទាំងឡាយ ចូរស្តាប់នូវ
ពាក្យយើងចុះ យើងទាំងអស់គ្នា កុំវិនាសឆាប់រួសរាន់ឡើយ ។
យើងទាំងអស់គ្នា ចូរប្រជុំគ្នាធ្វើទូក គឺទូកកម្រោលមាំ ប្រកប
ដោយយន្តគ្រប់យ៉ាង បើទេវតាដែលបិតក្នុងទិសខាងត្បូងនេះ

និយាយពិត ទេវតាដែលឋិតក្នុងទិសខាងជើង និយាយប្រាប់នេះ
មិនពិតឡើយ ។

ទូករបស់យើងនោះ នឹងមានប្រយោជន៍ដល់សេចក្តីអន្តរាយ
( ដែលកើតខាងក្រោយ ) ពួកយើងមិនលះបង់នូវកោះនេះទេ
បើទេវតាដែលឋិតក្នុងទិសខាងជើងនិយាយពិត ទេវតាដែលឋិត
ក្នុងទិសខាងត្បូងនេះនិយាយមិនពិតទេ ។

យើងទាំងអស់គ្នា ឡើងជិះទូកនោះឯង ហើយគប្បីឆ្លងទៅរក
ត្រើយខាងនាយដោយសួស្តីយ៉ាងនេះ បុគ្គលមិនគប្បីជឿដោយ
ងាយថា ពាក្យដែលបុគ្គលទីមួយពោលហើយ ជាពាក្យប្រសើរ
ដូច្នេះទេ នរជនណាក្នុងលោកនេះ កាន់យកនូវពាក្យនៃបុគ្គលទី
២ ដែលដល់នូវគន្លងនៃត្រចៀក ហើយពិចារណា ( នូវពាក្យ
ខាងដើម និងពាក្យខាងចុង ) ហើយជឿនូវពាក្យជាកណ្តាល
នរជននោះ រមែងដល់នូវទីដ៏ប្រសើរ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វិប្បវទន្តិ** សេចក្តីថា ពោលជំទាស់គ្នានិង
គ្នា ។ បទថា **លហុំ** ជាបទសម្តែងដល់សេចក្តីនៃពាក្យមុន ។ បទថា **ទោណឹ**
គឺជាទូកធំជ្រៅ ។ បទថា **សព្ពយន្តូបបន្នំ** គឺប្រកបទៅដោយគ្រឿងយន្ត
មានខ្សែយន្ត និងថ្នាលគ្រប់យ៉ាងជាដើម ។ បទថា **សា ចេវ នោ ហេហិតិ
អាបទត្ថា** សេចក្តីថា សំពៅនុ៎ះរបស់ពួកយើង កាលអន្តរាយកើតឡើងអំពី
ខាងក្រោយ ក៏មិនមែនជាប្រយោជន៍ ពួកយើងមិនត្រូវបោះបង់កោះនេះ ។ បទ

ថា **តរេមុ** បានដល់ នាំគ្នាឆ្លងទៅ ។ បទថា **ឆ វេ សុគណ្ហំ** គឺពួកយើង មិនបានជឿដោយងាយ ដោយចំណែកមួយ ។ បទថា **សេដ្ឋំ** គឺឧត្តមបំផុត ពិតប្រាកដ ។ បទថា **កណិដ្ឋំ** សេចក្តីថា ប្រៀបធៀបជាមួយពាក្យមុនហើយ ក៏ជាពាក្យក្រោយ ទើបឈ្មោះថា ពាក្យខាងក្រោយ សូម្បីពាក្យនេះ ក៏ប្រកប ក្នុងសេចក្តីដែលអនុលោមតាមពាក្យថា ពួកយើង ក៏មិនកាន់យកងាយៗ ដូចគ្នា ។ លោកអធិប្បាយពាក្យនេះថា ពួកជាងឈើដ៏ចម្រើន ពាក្យដែលទេវបុត្រអង្គមុនណាមួយពោលហើយ ពួកយើងមិនបានជឿងាយៗ ថា ពាក្យនេះប៉ុណ្ណោះប្រសើរពិតប្រាកដនោះឡើយ ។ ពាក្យនោះយ៉ាងណា សូម្បីពាក្យដែលជាខាងក្រោយ គឺពាក្យដែលទេវបុត្រពោលឯក្រោយក៏ដូច្នោះ ពួកយើងមិនបានជឿថា ពាក្យនេះប៉ុណ្ណោះប្រសើរពិត តែពាក្យណាចូលដល់គន្លងសោតវិស័យ បុរសដែលជាបណ្ឌិតនៃលោកនេះ កាន់យកពាក្យដែលមកប្រាកដនោះហើយ ជ្រើសរើសពាក្យមុន និងពាក្យក្រោយ គឺជ្រើសរើសពិចារណា សម្លឹង ពិនិត្យ កាន់យកចំណែកកណ្តាលបាន គឺពាក្យណាទៀងពិត ជាពាក្យដែលអះអាង រមែងកាន់យកសេចក្តីនោះឯង ធ្វើឲ្យប្រចក្សបាន ។ បទថា **សវេ ឆកោ សេដ្ឋមុបេតិ ឋានំ** សេចក្តីថា នរជននោះ រមែងចូលដល់សម្រេច ជួប ត្រឡប់បាននូវឋានៈដ៏ឧត្តម ។

កាលពោលដូច្នេះហើយ ជាងឈើដែលជាបណ្ឌិតនោះ ពោលបន្តថា នែបា ពួកយើងត្រូវធ្វើតាមពាក្យរបស់ទេវបុត្រទាំងពីរ ពួកយើងគប្បីត្រៀមទូក បន្ទាប់អំពីនោះ បើពាក្យរបស់ទេវបុត្រអង្គមុនជាពាក្យពិត ពួកយើង ក៏

នាំគ្នាឡើងសំពៅចៀសចេញទៅ បើពាក្យរបស់ទេវបុត្រមួយទៀតជាពាក្យពិត ពួកយើងក៏ចតសំពៅទុកម្ខាង ហើយនៅក្នុងកោះនេះបន្តទៅ ។ កាលជាងឈើជាបណ្ឌិតពោលយ៉ាងនេះ ជាងឈើពាលពោលថា នែបា ពួកលោកឃើញក្រពើក្នុងត្រពាំងទឹក ជាអ្នកឃើញកាលវែងហួសហេតុ ទេវបុត្រដំបូងនិយាយដោយការចង្អៀតចង្អល់ជាមួយពួកយើង ទេវបុត្រក្រោយ ពោលដោយសេចក្តីស្រឡាញ់ ពួកយើងនឹងនាំគ្នាបោះបង់កោះដ៏ប្រសើរបែបនេះទៅណា បើពួកលោកចង់ទៅ ក៏ចូរសេពគប់អ្នកដែលធ្វើសំពៅចុះ ពួកខ្ញុំមិនមានរឿងដែលប្រើសំពៅ ។ ជាងឈើដែលជាបណ្ឌិត បបួលបរិស័ទរបស់ខ្លួន ត្រៀមសំពៅដឹកគ្រឿងឧបករណ៍សព្វយ៉ាង ព្រមទាំងបរិស័ទ ស្នាក់នៅក្នុងសំពៅ បន្ទាប់អំពីនោះ មកដល់ថ្ងៃពេញបូណ៌ លុះព្រះចន្ទរះឡើង រលកក៏បក់ឡើងអំពីសមុទ្រមានប្រមាណស្មើក្បាលជង្គង់ បក់បោកមកលើកោះ ជាងឈើដែលជាបណ្ឌិត ជ្រាបភាពចម្លែកនៃសមុទ្រក៏ចេញសំពៅ តែគ្រួសារទាំង ៥០០ ដែលជាគ្នីគ្នារបស់ជាងឈើល្ងង់ខ្លៅ អង្គុយនិយាយគ្នារឿយៗ ថា រលកឡើងអំពីសមុទ្រ លាងនូវកោះត្រឹមនេះប៉ុណ្ណោះ ។ បន្ទាប់អំពីនោះ រលកក្នុងសមុទ្រក៏បក់មកលើកោះត្រឹមចង្កេះ ត្រឹមមួយជួរបុរស ត្រឹមមួយជួរដើមត្នោត បណ្ឌិតដែលមិនជាប់ក្នុងរស ព្រោះជាអ្នកឈ្លាសក្នុងឧបាយ បានទៅដោយសួស្តី ជាងឈើដែលជាពាល មិនឃើញនូវភ័យចំពោះមុខ ព្រោះជ្វាក់ក្នុងរស ដល់នូវការវិនាសទាំង ៥០០ គ្រួសារនោះឯង ។

អនុសាសនីបន្ទាប់អំពីនេះ ជាអភិសម្ពុទ្ធគាថា ៣ គាថា ដែលធ្លុះបញ្ចាំង

សេចក្តីនោះដូច្នេះថា

ពាណិជទាំងនោះ បានទៅដោយសួស្តីក្នុងកណ្តាលនៃទឹកសមុទ្រ ដោយកម្មរបស់ខ្លួន យ៉ាងណាមិញ កុលបុត្រមានប្រាជ្ញាដូចផែនដី បានដឹងច្បាស់នូវប្រយោជន៍ ជាអនាគតហើយ មិនប្រព្រឹត្តកន្លងនូវប្រយោជន៍ ( របស់ខ្លួន ) សូម្បីតិចក៏យ៉ាងនោះដែរ ។

ពួកជនពាល ដែលជាប់ក្នុងរសដោយមោហៈ មិនបានដឹងច្បាស់នូវប្រយោជន៍ជាអនាគត ក៏លិចចុះក្នុងប្រយោជន៍ជាបច្ចុប្បន្ន ដូចជាមនុស្សទាំងនោះ ( ដល់នូវសេចក្តីវិនាស ) ក្នុងកណ្តាលសមុទ្រ ។

បុគ្គលគប្បីគ្រោងទុកនូវកិច្ចជាអនាគត ( ដោយបំណងថា ) កិច្ចកុំបៀតបៀនអញក្នុងកាលដែលមានកិច្ចឡើយ ឯកិច្ចនោះមិនបានបៀតបៀននូវបុគ្គលនោះ ជាអ្នកធ្វើកិច្ចដែលខ្លួនបានគ្រោងទុកហើយ ប្រាកដដូច្នោះ ក្នុងកាលជាទីធ្វើកិច្ច ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សកម្មុនា** សេចក្តីថា ដោយកម្មរបស់ខ្លួនដែលធ្វើស្រេចមុន ព្រោះឃើញភ័យក្នុងអនាគត ។ បទថា **សោត្ថិំ វហឹសុ** សេចក្តីថា នាំគ្នាទៅដោយសេចក្តីក្សេម ។បទថា **វាណិជា** បានដល់ ពោលដល់ឈ្មួញដោយការៈដែលត្រាច់ទៅក្នុងកណ្តាលសមុទ្រ ។ បទថា **បដិវិជ្ឈិយាន** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ កុលបុត្រដែលមានបញ្ញាទូលាយក្នុងលោកនេះ

គន់ជ្រាបច្បុះឆ្ងាយដល់ប្រយោជន៍ខាងមុខ ដែលគប្បីធ្វើទុកជាមុន រមែងមិនធ្វើប្រយោជន៍របស់ខ្លួន សូម្បីមានប្រមាណតិច ឲ្យឃ្លៀងឃ្លាតទៅ ធ្លងទៅ គឺវិនាសទៅ ។ បទថា **អប្បដិវិជ្ឈយត្ថំ** សេចក្តីថា បុគ្គលពាលមិនជ្រាបច្បុះឆ្ងាយ មិនធ្វើប្រយោជន៍ដែលគួរធ្វើមុននោះឯង ។ បទថា **បច្ចុប្បន្នេ** សេចក្តីថា កាលណាកិច្ចអនាគតនោះ កើតជាសេចក្តីត្រូវការឡើង កាលនោះ រមែងនាំគ្នាលិចចុះ ក្នុងកាលកើតនូវសេចក្តីត្រូវការឡើងក្នុងបច្ចុប្បន្ន គឺរមែងមិនបានទីពឹងដល់ខ្លួន នាំគ្នាដល់នូវសេចក្តីវិនាស ដូចពួកជាងឈើពាលដូច្នោះ ដែលនាំគ្នាលិចចូលក្នុងសមុទ្រ ដូច្នោះ ។ បទថា **អនាគតំ** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ បុរសបណ្ឌិតគប្បីត្រៀមធ្វើ គឺគប្បីធ្វើមុននោះឯងនូវកិច្ចអនាគតដែលត្រូវធ្វើមុន និងជាកិច្ចឲ្យផលខាងមុខ ឬកិច្ចឲ្យផលបច្ចុប្បន្នក៏ដោយ ព្រោះហេតុអ្វី ព្រោះកុំឲ្យកិច្ចបៀតបៀនយើងបាន ក្នុងពេលត្រូវការ ដ្បិតថាកិច្ចដែលត្រូវធ្វើឲ្យស្រេចមុន កាលមិនធ្វើមុន លុះដល់បច្ចុប្បន្ន ឬក្នុងកាលខាងក្រោយ រមែងបៀតបៀនកាយ និងចិត្តក្នុងវេលាដែលខ្លួនត្រូវការ ហេតុនោះ បណ្ឌិតគប្បីធ្វើកិច្ចនោះមុននោះឯង ។ បទថា **តំ តាទិសំ** បានដល់បុរសដែលតាំងនៅយ៉ាងនោះ ។ បទថា **បដិកតកិច្ចការឹ** បានដល់ ជាអ្នកប្រញាប់ធ្វើនូវកិច្ចដែលគួរធ្វើភ្លាម ។ បទថា **តំ កិច្ចំ កិច្ចកាលេ** សេចក្តីថា កិច្ចអនាគតដែលត្រូវធ្វើ គឺដល់នូវភាពជាបច្ចុប្បន្នក្នុងកាលជាខាងក្រោយ ក្នុងពេលដែលកាយ និងចិត្តអាពាធ រមែងមិនបៀតបៀន មិនរង្កៀសបុរសបែបនោះ ព្រោះហេតុអ្វី ព្រោះធ្វើកិច្ចស្រេចមុននោះឯង ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះ មកសម្តែងហើយ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ទេវទត្ត រវល់តែជាប់ជំពាក់ក្នុងសុខបច្ចុប្បន្ន មើលមិនឃើញភ័យក្នុងអនាគត ដល់នូវសេចក្តីវិនាស មួយអន្លើដោយបរិស័ទ ទ្រង់ប្រជុំជាតកថា ជាងឈើពាលក្នុងកាលនោះ បានមកជាទេវទត្ត ដែលជាប់ជំពាក់សុខក្នុងបច្ចុប្បន្ន ទេវបុត្រដែលមិនតាំងនៅក្នុងធម៌ស្ថិតនៅក្នុងទិសខាងត្បូង ក្នុងកាលនោះ បានមកជាកោកាលិកៈ ទេវបុត្រដែលទ្រទ្រង់នូវធម៌ស្ថិតនៅក្នុងទិសខាងជើង ក្នុងកាលនោះ បានមកជាសារីបុត្ត ចំណែកជាងឈើដែលជាបណ្ឌិតក្នុងកាលនោះ គឺតថាគតនេះឯង ។ល។

## អដ្ឋកថាសមុទ្ទវាណិជជាតក ចប់

# សុត្តន្តបិដក

## កាមជាតក

[ ៩៣៥ ] ( ព្រះមហាសត្វបានពោលថា ) កាលបុគ្គលប្រាថ្នានូវកាម បើកាមនោះសម្រេចដល់បុគ្គលនោះ សត្វប្រាថ្នាកាមណាបានហើយ រមែងជាអ្នកមានចិត្តរីករាយក្នុងវត្ថុនោះ ដោយពិត ។

[ ៩៣៦ ] កាលបុគ្គលប្រាថ្នាកាម បើកាមនោះសម្រេចដល់បុគ្គលនោះ បុគ្គលនោះរមែងបាននូវចំណង់ដទៃជាងនោះទៅទៀត ដូចជា ( បុគ្គលហត់នឿយ ) បាននូវចំណង់ ( ស្រេក ) ក្នុងរដូវក្តៅ ។

[ ៩៣៧ ] កាលគោជាសត្វមានស្នែងកំពុងចម្រើន ស្នែងរមែងចម្រើនដែរ យ៉ាងណា កាលសត្វអ្នកមានបញ្ញាទន់ ល្ងង់ខ្លៅមិនដឹងអ្វី កំពុងចម្រើន តណ្ហា និងសេចក្តីស្រេកឃ្លាន រមែងរឹងរឹតចម្រើនឡើងយ៉ាងនោះដែរ ។

[ ៩៣៨ ] ប្រសិនបើ ( មាណពនោះ ) ឲ្យស្រែស្រូវខ្សាយ ឲ្យស្រែស្រូវជំណើប ឲ្យគោ សេះ និងបុរសជាខ្ញុំប្រុសលើផែនដី ( ដល់បុគ្គលណាមួយ វត្ថុទាំងប៉ុណ្ណោះនេះ ) ក៏មិនល្មមដល់បុគ្គលម្នាក់ឡើយ បុរសដឹងយ៉ាងនេះហើយ គប្បីប្រព្រឹត្តឲ្យស្មើ ។

[ ៩៣៩ ] ស្តេចកំហែងច្បាំងឈ្នះនូវផែនដី ហើយគ្រប់គ្រងផែនដី

មានសាគរជាទីបំផុត មានសភាពជាអ្នកមិនឆ្អែតនឹងត្រើយសមុទ្រខាងអាយ ក៏ចង់បាននូវត្រើយសមុទ្រខាងនាយទៀត ។

[ ៩៤០ ] បុរសកាលនឹកស្រណោះ នូវកាមទាំងឡាយដោយចិត្ត ( ដរាបណា ) ក៏មិនដល់នូវសេចក្ដីឆ្អែតដរាបនោះ ពួកសត្វណាត្រឡប់ចិត្តចេញ គេចខ្លួនថយអំពីកាមនោះហើយ ឃើញ ( ទោសកាមដោយញាណ ) ជាអ្នកឆ្អែតដោយប្រាជ្ញា ពួកសត្វនោះ ទើបឈ្មោះថា ឆ្អែតពិតមែន ។

[ ៩៤១ ] បុរសនោះ មិនក្ដៅក្រហាយដោយកាមទាំងឡាយ ( នេះ ) ជាអំពើដ៏ប្រសើររបស់ពួកជនអ្នកឆ្អែតដោយប្រាជ្ញា តណ្ហាមិនធ្វើបុរសដែលឆ្អែតដោយប្រាជ្ញា ឲ្យលុះក្នុងអំណាចបានឡើយ ។

[ ៩៤២ ] សូមព្រះអង្គកម្ចាត់បង់នូវកាមទាំងឡាយចេញ បុរសអ្នកមានប្រាជ្ញាប៉ុនសមុទ្រ អ្នកមានសេចក្ដីប្រាថ្នាតិច អ្នកមិនលោភលន់ បុរសនោះ រមែងមិនក្ដៅក្រហាយដោយកាមទាំងឡាយ ។

[ ៩៤៣ ] បុគ្គលលះបង់នូវចំណែកនៃកាមទាំងឡាយណាៗ សេចក្ដីសុខក៏សម្រេច ( ដល់បុគ្គលនោះ ) ព្រោះចំណែកនៃកាមទាំងឡាយនោះៗ ដូចជាងស្បែកកាលកាត់ស្បែកជើង ( តែងចៀរនូវចំនៀរ ) នៃស្បែកចោល ( ក៏បាននូវថ្លៃស្បែកជើងឈ្មោះថា ជាអ្នកបានសេចក្ដីសុខ ) បើបុគ្គលប្រាថ្នានូវសេចក្ដី

សុខគ្រប់យ៉ាង ត្រូវលះកាមទាំងអស់ចេញ ។

[ ៩៤៤ ] ( ព្រះរាជាទ្រង់ត្រាស់ថា ) គាថាទាំងអស់ ៨ ដែលអ្នកពោលហើយ គួរដល់ថ្លៃ ១០០០ កហាបណៈ ម្នាលមហាព្រាហ្មណ៍ អ្នកចូរទទួលយក ( នូវកហាបណៈទាំងនេះ ) ចុះកាសិតរបស់អ្នកនេះប្រពៃណាស់ ។

[ ៩៤៥ ] ( ព្រះមហាសត្វ ... ) ខ្ញុំព្រះអង្គមិនត្រូវការដោយកហាបណៈទាំងរយ ទាំងពាន់ ទាំងម៉ឺនទេ កាលដែលខ្ញុំព្រះអង្គកំពុងពោលគាថាខាងចុង ចិត្តរបស់ខ្ញុំព្រះអង្គមិនត្រេកអរក្នុងកាមឡើយ ។

[ ៩៤៦ ] ( ព្រះរាជា ... ) អ្នកប្រាជ្ញណាកំណត់ដឹងនូវតណ្ហាដែលញុំាងសេចក្តីទុក្ខឲ្យកើតឡើង អ្នកប្រាជ្ញនោះ គឺមាណពដ៏ចម្រើន ដែលជាអ្នកដឹងនូវលោកទាំងមូលនេះទេតើ ។

**កាមជាតកទី ៤ ចប់**

# អដ្ឋកថា

## កាមជាតក

[ ៩៣៥-៩៤៦ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រាហ្មណ៍ម្នាក់ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **កាមំ កាមយមានស្ស** ដូច្នេះជាដើម ។

មានរឿងពិស្តារថា ព្រាហ្មណ៍អ្នកក្រុងសាវត្ថីម្នាក់ កាប់ព្រៃដើម្បីធ្វើចម្ការក្បែរឆ្នេរស្ទឹងអចិរវតី ។ ព្រះសាស្តា ទ្រង់ឃើញឧបនិស្ស័យរបស់បុគ្គលនោះ កាលយាងទៅប្រោសសត្វក្នុងនគរសាវត្ថី ទ្រង់ចុះអំពីផ្លូវ ធ្វើបដិសណ្ឋារៈជាមួយព្រាហ្មណ៍នោះ ត្រាស់ថា ម្នាលព្រាហ្មណ៍ អ្នកធ្វើអ្វី ព្រាហ្មណ៍ក្រាបទូលថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គរានដីចម្ការ ព្រះសាស្តាត្រាស់ថា សាធុ ព្រាហ្មណ៍ ចូរអ្នកធ្វើការងារចុះ ហើយក៏យាងហួសទៅ ទ្រង់បានយាងទៅធ្វើបដិសណ្ឋារៈជាមួយព្រាហ្មណ៍នោះរឿយៗ គឺក្នុងពេលដែលគាត់ជញ្ជូនដើមឈើដែលកាប់ហើយ និងជម្រះចម្ការក្នុងពេលលើកភ្លឺ ក្នុងពេលភ្ជួរ ក្នុងពេលសាបព្រោះ ដោយឧបាយយ៉ាងនេះឯង ស្នេហ៍កើតឡើង ព្រាហ្មណ៍នោះក្រាបទូលថា បពិត្រព្រះគោតម ថ្ងៃនេះ ជាថ្ងៃមង្គលក្នុងការព្រោះស្រូវរបស់ខ្ញុំព្រះអង្គៗ នឹងថ្វាយមហាទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានក្នុងកាលបាយ និងទឹកសម្រេចហើយ ព្រះសាស្តាទ្រង់ទទួលដោយតុណ្ហីភាព ទ្រង់ចៀសចេញទៅ ។ ថ្ងៃមួយ ព្រាហ្មណ៍ឈរមើលសន្ទូង ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលព្រាហ្មណ៍ អ្នកកំពុងធ្វើអ្វីត្រង់នោះ កាលព្រាហ្មណ៍ក្រាបទូលថា បពិត្រព្រះគោតម ខ្ញុំព្រះអង្គកំពុងមើលស្រែ ព្រះសាស្តាត្រាស់ថា

សាធុ ហើយយាងចៀសចេញទៅ ។ ក្នុងកាលនោះ ព្រាហ្មណ៍គិតថា ព្រះសមណគោតមមករឿយៗ គង់មានសេចក្តីត្រូវការកត្តណាមួយដោយឥតសង្ស័យ អញនឹងថ្វាយកត្តដល់ទ្រង់ ក្នុងថ្ងៃដែលព្រាហ្មណ៍គិតយ៉ាងនេះហើយទៅកាន់ផ្ទះ ។ សូម្បីព្រះសាស្តាក៏យាងទៅក្នុងទីនោះ កាលនោះ វិសាសៈ ( សេចក្តីស្និទ្ធស្នាល ) កើតឡើងដល់ព្រាហ្មណ៍ពន់ពេក កាលស្រូវទុំហើយព្រាហ្មណ៍សម្រេចចិត្តថា ស្អែកនេះ អញនឹងច្រូតស្រូវក្នុងស្រែហើយក៏ដេក ។ ភ្លៀងព្រឹលធ្លាក់ចុះមកទាំងកណ្តាលយប់ ខាងលើរបស់ស្ទឹងអចិរវតី ជំនន់ទឹកធំបានហូរមកនាំយកស្រូវទាំងអស់ ចូលទៅកាន់សមុទ្រមិនមានសេសសល់សូម្បីត្រឹមតែមួយនាឡិ កាលជំនន់ទឹករីងស្ងួតហើយ ព្រាហ្មណ៍សម្លឹងមើលនូវការវិនាសរបស់ស្រូវហើយ មិនអាចតាំងនៅដោយការៈរបស់ខ្លួនបាន ត្រូវទោមនស្សដ៏ខ្លាំងក្លាគ្របសង្កត់ លើកដៃវាយទ្រូង កន្ទក់កន្ទេញទៅដល់ផ្ទះហើយដេករវើរវាយ ។

ក្នុងពេលទៀបភ្លឺ ព្រះសាស្តា ទតឃើញព្រាហ្មណ៍ត្រូវទោមនស្សគ្របសង្កត់ ទ្រង់ត្រិះរិះថា តថាគតនឹងជាទីពឹងរបស់ព្រាហ្មណ៍ ។ ព្រឹកឡើងទ្រង់ត្រាច់ប្រោសសត្វក្នុងនគរសាវត្ថី ក្រោយមក បន្ទាប់អំពីសោយស្រេចហើយ ទ្រង់យាងត្រឡប់ ទ្រង់បញ្ជូនពួកភិក្ខុទៅកាន់ព្រះវិហារ ទ្រង់យាងទៅកាន់ផ្ទះរបស់ព្រាហ្មណ៍នោះ មួយអន្លើដោយបច្ឆាសមណៈ ។ ព្រាហ្មណ៍បានឮភាពដែលព្រះសាស្តាយាងមក ពោលថា សម្លាញ់របស់យើងគង់មកសួរសុខទុក្ខគ្រាន់បាន ជូរស្រោលចិត្ត រៀបចំអាសនៈ ព្រះសាស្តាយាងចូលទៅ

ប្រថាប់គង់លើអាសនៈដែលរៀបចំ ត្រាស់សួរថា ម្នាលព្រាហ្មណ៍ ហេតុអ្វី ទើបអ្នកសៅហ្មង អ្នកមិនសប្បាយរឿងអ្វី ក៏ក្រាបទូលថា បពិត្រព្រះគោតម ទ្រង់រមែងជ្រាបការងារដែលខ្ញុំព្រះអង្គធ្វើ ចាប់តាំងអំពីកាប់ដើមឈើ ត្រង់ប្រាំងស្ទឹងអចិរវតី ខ្ញុំព្រះអង្គធ្លាប់ក្រាបទូលថា កាលសន្ទូងនេះសម្រេចហើយ ខ្ញុំព្រះអង្គនឹងថ្វាយទានដល់ព្រះអង្គ ឥឡូវនេះ ជំនន់ទឹកជំនាំយកនូវសន្ទូងរបស់ខ្ញុំព្រះអង្គទៅកាន់សមុទ្រអស់រលីង សន្ទូងមិនមានសល់តិចតួច ស្រូវប្រមាណមួយរយរទេះ វិនាសអស់ ហេតុនោះ សេចក្ដីសោកយ៉ាងធំកើតឡើងដល់ខ្ញុំព្រះអង្គ ព្រះសាស្ដាត្រាស់ថា ម្នាលព្រាហ្មណ៍ កាលអ្នកសោយសោកក្នុងវត្ថុដែលវិនាសទៅហើយ ត្រឡប់បានមកវិញឬ ព្រាហ្មណ៍ក្រាបទូលថា បពិត្រព្រះគោតម សេចក្ដីនោះប្រព្រឹត្តទៅមិនបានពិតប្រាកដ ទើបព្រះសាស្ដាត្រាស់ថា កាលបើយ៉ាងនេះ អ្នកសោយសោកធ្វើអ្វី ឈ្មោះថា ទ្រព្យនិងស្រូវរបស់សត្វទាំងនេះ ដល់នូវការកើតក៏កើតឡើង ដល់នូវពេលវិនាសក៏វិនាស សង្ខារធម៌ទាំងឡាយ ឈ្មោះថា មិនវិនាសជាធម្មតាមិនមានទេ អ្នកកុំគិតថ្វីឡើយ ។ ព្រះសាស្ដាទ្រង់លួងលោមព្រាហ្មណ៍ដោយប្រការដូច្នេះ កាលទ្រង់សម្ដែងធម៌ដែលជាសប្បាយដល់ព្រាហ្មណ៍ ទើបត្រាស់កាមសូត្រ កាលព្រះសូត្រដល់ទីបញ្ចប់ ព្រាហ្មណ៍តាំងនៅក្នុងសោតាបត្តិផល ព្រះសាស្ដាធ្វើឲ្យព្រាហ្មណ៍បាត់សោយសោក ហើយទ្រង់ក្រោកចាកអាសនៈទៅកាន់វិហារ ។

អ្នកនគរទាំងអស់ដឹងទូទៅថា ព្រះសាស្ដាទ្រង់ធ្វើព្រាហ្មណ៍នោះ ដែលដល់ព្រមដោយសេចក្ដីសោក ឲ្យប្រាសចាកសេចក្ដីសោក ហើយតាំងនៅក្នុង

សោតាបត្តិផល ពួកភិក្ខុនាំគ្នាលើករឿងឡើងសន្ទនាក្នុងធម្មសភាថា អាវុសោទាំងឡាយ ព្រះទសពលទ្រង់ធ្វើមេត្រីជាមួយព្រាហ្មណ៍ ដែលស្និទ្ធស្នាលគ្នា ទ្រង់សម្តែងធម៌ដល់បុគ្គលដែលបៀមទៅដោយសេចក្តីសោក ដោយឧបាយត្រឹមតែម្តង ទ្រង់ធ្វើឲ្យព្រាហ្មណ៍ប្រាសចាកសេចក្តីសោកបាន ឲ្យប្រតិស្ឋានក្នុងសោតាបត្តិផល ព្រះសាស្តាយាងមកហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អំបាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន តថាគតក៏បានធ្វើឲ្យព្រាហ្មណ៍នេះ ប្រាសចាកសេចក្តីសោកហើយដូចគ្នា ទើបទ្រង់នាំអតីតនិទានមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ទ្រង់មានព្រះឱរសពីរអង្គ ទ្រង់ប្រទាននាទីជាឧបរាជ ដល់ព្រះរាជបុត្រច្បង ព្រះរាជទានតំណែងជាសេនាបតីដល់ព្រះឱរសពៅ ។ ក្នុងកាលតមក ព្រះរាជាក៏សោយទិវង្គត ពួកអមាត្យនាំគ្នាអភិសេកព្រះឱរសច្បង តែទ្រង់ត្រាស់ថា យើងមិនត្រូវការគ្រងរាជសម្បត្តិ ចូរពួកអ្នកនាំគ្នាឲ្យដល់ប្អូនប្រុសរបស់យើងចុះ សូម្បីបានទទួលពាក្យអង្វររឿយៗ ក៏ទ្រង់នៅតែឃាត់ កាលពួករាជ-អមាត្យធ្វើអភិសេក ថ្វាយព្រះរាជបុត្រដែលជាប្អូនហើយ ទ្រង់ត្រិះរិះថា អញមិនត្រូវការភាពជាធំ មិនប្រាថ្នាតំណែងសូម្បីត្រឹមតែឧបរាជជាដើម ទោះបីពួកអមាត្យក្រាបថា បើដូច្នោះ សូមទ្រង់សោយភោជនដែលមានរសល្អៗ ប្រថាប់

នៅក្នុងព្រះនគរនេះចុះ ក៏ត្រាស់ថា ខ្ញុំមិនមានកិច្ចដែលត្រូវធ្វើក្នុងព្រះនគរនេះ ហើយយាងចេញអំពីនគរពារាណសី ទៅកាន់ជនបទជាយដែន អាស្រ័យត្រកូលសេដ្ឋីមួយ ទ្រង់ធ្វើការងារដោយព្រះហស្តរបស់ព្រះអង្គឯង ហើយប្រថាប់នៅ ។

ក្នុងកាលតមក ពួកជនទាំងនោះដឹងនូវភាពដែលព្រះរាជា ជាព្រះរាជកុមារក៏នាំគ្នាមិនព្រមឲ្យធ្វើការងារ នាំគ្នាបោមរោមព្រះរាជាដោយការបរិហារក្នុងឋានៈជាព្រះរាជកុមារនោះឯង ។ ចំណេរកាលតមក ពួកខ្ញុំរាជការនាំគ្នាទៅកាន់ជនបទជាយដែន បានទៅដល់ស្រុកនោះដើម្បីវាស់ពន្ធស្រែ លោកសេដ្ឋីចូលទៅគាល់ព្រះរាជកុមារក្រាបទូលថា បពិត្រព្រះអង្គ ពួកទូលបង្គំនាំគ្នាទំនុកបម្រុងបម្រើទ្រង់ សូមទ្រង់បញ្ជូនសំបុត្រដល់ម្ចាស់ប្អូន ឲ្យទ្រង់បន្ធូរបន្ថយសួយដល់ពួកទូលបង្គំចុះ ព្រះរាជកុមារទ្រង់ទទួលថា សាធុ ហើយទ្រង់បញ្ជូនសំបុត្រទៅថា ខ្ញុំអាស្រ័យត្រកូលសេដ្ឋីឈ្មោះនោះ ស្នាក់នៅ សូមយល់ដល់ខ្ញុំ លើកលែងសួយដល់ពួកជនទាំងនោះចុះ ព្រះរាជាត្រាស់ថា សាធុ ហើយទ្រង់ឲ្យធ្វើយ៉ាងនោះ កាលនោះ ពួកអ្នកស្រុកទាំងអស់ខ្លះ ពួកអ្នកជនបទខ្លះ អ្នកស្រុកដទៃៗ ខ្លះ នាំគ្នាចូលទៅកាន់សម្នាក់ព្រះរាជកុមារទូលថា ពួកទូលបង្គំនឹងថ្វាយសួយដល់ទ្រង់ប៉ុណ្ណោះ សូមទ្រង់ឲ្យព្រះរាជាលើកលែងដល់ពួកទូលបង្គំផងចុះ ព្រះរាជកុមារទ្រង់បញ្ជូនសំបុត្រទៅ ដើម្បីជួយពួកជនទាំងនោះ ឲ្យព្រះរាជាទ្រង់លើកលែងសួយឲ្យ ។ តាំងអំពីនោះមក ពួកជនទាំងនោះ ក៏នាំគ្នាថ្វាយសួយដល់ព្រះរាជកុមារ ទើបកើតលាភសក្ការៈធំដល់ទ្រង់ ដោយហេតុនោះ ការចង់បានរបស់ព្រះរាជាក៏រីកចម្រើនធំឡើង ក្នុងកាលតមក ព្រះរាជកុមារ

ទូលសូមជនបទទាំងអស់នោះ ហើយទូលសូមរាជសម្បត្តិពាក់កណ្តាល សូម្បីម្ចាស់ប្អូន ក៏បានប្រទានដល់ទ្រង់តាមនោះ ព្រះរាជាកាលចំណង់ចម្រើនឡើង មិនពេញព្រះហឫទ័យដោយរាជសម្បត្តិត្រឹមពាក់កណ្តាលនោះ ទ្រង់ត្រិះរិះនឹងដណ្តើមរាជសម្បត្តិ ហោមរោមដោយអ្នកជនបទយាងទៅកាន់នគរនោះ ស្នាក់នៅខាងក្រៅព្រះនគរ ទ្រង់បញ្ជូនសំបុត្រដល់ម្ចាស់ប្អូនថា សូមទ្រង់ឲ្យរាជ-សម្បត្តិដល់យើង ឬនឹងធ្វើចម្បាំងក៏បាន ។

ព្រះរាជាជាប្អូនត្រិះរិះថា ព្រះជេដ្ឋារបស់អញជាបុគ្គលពាល ក្នុងកាលមុន ទ្រង់បដិសេធរាជសម្បត្តិ សូម្បីតំណែងជាឧបរាជក៏បដិសេធ ពេលនេះបែរជាត្រាស់ថា នឹងដណ្តើមយកដោយការច្បាំង បើអញសម្លាប់ម្ចាស់បងនេះឲ្យសោយទិវង្គតដោយការច្បាំង ការនិន្ទានឹងកើតឡើងដល់អញ អញត្រូវការអ្វីដោយរាជសម្បត្តិ ទើបទ្រង់បញ្ជូនសាសន៍ដល់ព្រះរាជកុមារថា មិនចាំបាច់ច្បាំងឡើយ សូមទ្រង់យាងគ្រងរាជសម្បត្តិចុះ ។ ព្រះរាជាទ្រង់គ្រងរាជ-សម្បត្តិ ប្រទានតំណែងឧបរាជដល់ម្ចាស់ប្អូន ចាប់តាំងអំពីនោះ ទ្រង់គ្រងរាជសម្បត្តិ ធ្លាក់ក្នុងអំណាចនៃតណ្ហា មិនបានពេញព្រះហឫទ័យដោយរាជ-សម្បត្តិក្នុងនគរមួយ ទ្រង់ប្រាថ្នារាជសម្បត្តិ ២-៣ នគរ ទ្រង់មិនឃើញទីបំផុតនៃចំណង់ឡើយ កាលនោះ សក្កទេវរាជទ្រង់ប្រមើលមើលថា ក្នុងលោកជនពួកណាខ្លះដែលបម្រើមាតាបិតា ជនពួកណាធ្វើបុណ្យផ្សេងៗ មានឲ្យទានជាដើម ជនពួកណាធ្លាក់ក្នុងអំណាចតណ្ហា ទ្រង់ជ្រាបភាពដែលព្រះរាជាប្រព្រឹត្តទៅក្នុងអំណាចតណ្ហា ទ្រង់ត្រិះរិះថា ព្រះរាជាអង្គនេះ ជាបុគ្គលពាល

ទ្រង់មិនពេញព្រះហឫទ័យដោយរាជសម្បត្តិ ក្នុងនគរពារាណសី អាត្មាអញត្រូវឲ្យទ្រង់សិក្សាខ្លះ កាឡាខ្លួនជាមាណព ប្រថាប់ឈរត្រង់ទ្វារព្រះរាជវាំង ឲ្យមនុស្សក្រាបទូលថា មាណពអ្នកឈ្លាសវៃក្នុងឧបាយម្នាក់ ឈរត្រង់ទ្វារព្រះរាជវាំង កាលព្រះរាជាត្រាស់ថា ឲ្យគេចូលមកចុះ ក៏យាងចូលទៅក្រាបទូលថ្វាយពរជ័យព្រះរាជា កាលព្រះរាជាត្រាស់ថា អ្នកមកដោយហេតុអ្វី ក៏ក្រាបទូលថា បពិត្រមហារាជ ទូលបង្គំមានរឿងនឹងក្រាបទូល ទូលបង្គំត្រូវការទីស្ងាត់ ។ ដោយអានុភាពរបស់សក្កទេវរាជ ពួកមនុស្សក៏នាំគ្នាត្រឡប់ទៅអស់រំពេចនោះឯង ។ កាលនោះ មាណពក្រាបទូលព្រះរាជាថា បពិត្រមហារាជ ទូលបង្គំឃើញ ៣ ព្រះនគរ ស្តុកស្តម្ភ មានមនុស្សកុះករ សម្បូរដោយពល និងពាហនៈ ទូលបង្គំនឹងដណ្តើមរាជសម្បត្តិក្នុងនគរទាំង ៣ ដោយអានុភាពរបស់ខ្ញុំ ថ្វាយដល់ទ្រង់ សូមទ្រង់កុំយឺតយូរ ប្រញាប់យាងទៅចុះ ព្រះរាជាទ្រង់ធ្លាក់ទៅក្នុងអំណាចនៃសេចក្តីលោភ ត្រាស់ថា សាធុ តែដោយអានុភាពនៃសក្កទេវរាជ ទ្រង់មិនបានសួរថា អ្នកជានរណា អ្នកមកអំពីណា ឬថា អ្នកគួរបានរបស់ណា សក្កទេវរាជនោះ ត្រាស់ត្រឹមប៉ុណ្ណោះហើយ ក៏យាងទៅកាន់តាវត្តិង្សពិភពនោះឯង ។

ព្រះរាជាត្រាស់ឲ្យពួកអមាត្យមកគាល់ ត្រាស់ថា មាណពម្នាក់ពោលថា នឹងដណ្តើមរាជសម្បត្តិ ៣ នគរឲ្យយើង ចូរពួកអ្នកប្រញាប់ហៅមាណពនោះមកចុះ ចូរនាំស្គរទៅវាយប្រកាសក្នុងព្រះនគរ ប្រជុំពលនិកាយ យើងត្រូវការគ្រប់គ្រងរាជសម្បត្តិក្នុងនគរទាំង ៣ ដោយមិនយឺតយូរ កាលពួកអមាត្យ

នាំគ្នាក្រាបទូលថា បពិត្រមហារាជ ទ្រង់ធ្វើសក្ការៈដល់មាណពនោះដូចម្ដេច ឬទ្រង់បានសួរទីនៅអាស្រ័យរបស់មាណពនោះដូចម្ដេច ព្រះរាជាត្រាស់ថា យើងមិនបានធ្វើសក្ការៈឡើយ មិនបានសួរទីស្នាក់អាស្រ័យឡើយ ចូរពួកអ្នកនាំគ្នារកមើលចុះ ពួកអមាត្យនាំគ្នាគយគន់រកមើលក៏មិនឃើញ ក្រាបទូលថា បពិត្រមហារាជ ពួកទូលបង្គំមិនឃើញមាណពនោះ ទោះបីរកពេញនគរ ព្រះរាជាស្ដាប់ពាក្យនោះហើយ ទ្រង់កើតទោមនស្ស ទ្រង់ត្រិះរិះរឿយៗ ថា រាជសម្បត្តិក្នុងនគរទាំង ៣ វិនាសហើយ យើងវិនាសចាកយសធំ មាណពប្រហែលជាខឹងនឹងអញថា មិនឲ្យស្បៀងដល់អញផង មិនឲ្យទីនៅអាស្រ័យផង ដូច្នេះហើយ ទើបមិនមក ។ កាលនោះ កម្ដៅកើតឡើងក្នុងព្រះកាយនៃព្រះរាជា ដែលធ្លាក់នៅក្នុងអំណាចតណ្ហា កាលសរីរៈគ្រប់ចំណែកក្ដៅ ការស្ទុះទៅនៃលោហិត ក៏ធ្វើផ្ទៃឲ្យកម្រើក ហើយផ្សាយឡើង ភាជនៈមួយចូល ភាជនៈមួយចេញ ពួកពេទ្យមិនអាចថ្វាយការព្យាបាលបាន ។ ព្រះរាជាទ្រង់លំបាក ។ សម័យនោះ កាលដែលទ្រង់ត្រូវជំងឺបៀតបៀន បានល្បីខ្ចរខ្ចាយទៅពេញព្រះនគរ ។

កាលនោះ ព្រះពោធិសត្វ រៀនសិប្បៈសម្រេចអំពីនគរតក្កសិលា មកកាន់សម្នាក់មាតាបិតា ក្នុងនគរពារាណសី ស្ដាប់រឿងរបស់ព្រះរាជានោះ គិតថា អញត្រូវថ្វាយការរក្សា ទៅកាន់ព្រះរាជទ្វារឲ្យក្រាបទូលថា បានឮថា មាណពម្នាក់ មកថ្វាយការរក្សាទ្រង់ ព្រះរាជាត្រាស់ថា សូម្បីពួកពេទ្យដែលជាទិសាបាមោក្ខធំៗ គង់មិនអាចរក្សាបាន មាណពកំលោះ នឹងព្យាបាលបាន

ដូចម្តេច ចូរពួកអ្នកនាំគ្នាឲ្យស្បៀង ហើយបញ្ជូនគេទៅចុះ មាណពស្តាប់ព្រះតម្រាស់នោះហើយ ពោលថា ខ្ញុំមិនមានរឿងដែលត្រូវធ្វើដោយថ្លៃកំណល់គ្រូឡើយ ខ្ញុំនឹងថ្វាយការរក្សា សូមឲ្យត្រឹមតែថ្លៃថ្នាំប៉ុណ្ណោះ ព្រះរាជាស្តាប់ពាក្យនោះហើយ ទ្រង់ត្រាស់ថា សាធុ ត្រាស់ឲ្យហៅមាណពចូលមក ។ មាណពលុះពិនិត្យមើលព្រះរាជាហើយ ក្រាបទូលថា បពិត្រមហារាជ សូមទ្រង់កុំខ្លាចឡើយ ទូលបង្គំនឹងថ្វាយការរក្សា តែសូមទ្រង់ប្រាប់សមុដ្ឋានរោគដល់ទូលបង្គំចុះ ។ ព្រះរាជាទ្រង់ពេញព្រះហឫទ័យ ត្រាស់ថា អ្នកចង់ដឹងសមុដ្ឋានធ្វើអ្វី ចូរប្រាប់នូវថ្នាំប៉ុណ្ណោះចុះ ព្រះពោធិសត្វក្រាបទូលថា បពិត្រមហារាជ ធម្មតាគ្រូពេទ្យ ជ្រាបថា ជំងឺតម្កាត់នេះ កើតឡើងព្រោះអាស្រ័យហេតុនេះ រមែងផ្សំថ្នាំឲ្យត្រឹមត្រូវជាមួយជំងឺនោះបាន ព្រះរាជាត្រាស់ថា ត្រូវហើយបា កាលត្រាស់សមុដ្ឋាន បានត្រាស់រឿងទាំងអស់ តាំងពីមាណពម្នាក់មកប្រាប់ថា នឹងយករាជសម្បត្តិក្នុង ៣ នគរមកឲ្យ ហើយត្រាស់ថា នែបាយើងឈឺពេលនេះព្រោះតណ្ហា បើបារក្សាបានក៏ចូររក្សាចុះ ។ មាណពទូលសួរថា បពិត្រមហារាជ ទ្រង់អាចបានព្រះនគរទាំងនោះ ដោយការសោកស្តាយឬ ព្រះរាជាត្រាស់ថា មិនអាចទេបា ក៏ក្រាបទូលថា បើដូច្នោះ ហេតុអ្វីទើបទ្រង់សោយសោក ធម្មតាសត្វទាំងឡាយ រមែងលះរាងកាយរបស់ខ្លួនជាដើម រហូតដល់សវិញ្ញាណកទ្រព្យ និងអវិញ្ញាណកទ្រព្យទាំងអស់ទៅ សូម្បីទ្រង់គ្រប់គ្រងរាជសម្បត្តិក្នុងនគរទាំង ៤ បាន ទ្រង់ក៏សោយព្រះក្រយាហារក្នុងសុវណ្ណភាជនៈទាំង ៤ ផ្ទំលើព្រះទែនទាំង ៤ ទ្រទ្រង់គ្រឿងប្រដាប់ទាំង ៤ ព្រម

គ្នាតែម្តងមិនបាន ទ្រង់មិនគួរធ្លាក់នៅក្នុងអំណាចនៃតណ្ហា ព្រោះតណ្ហានេះ កាលចម្រើនឡើង រមែងមិនបណ្តោយឲ្យផុតចាកអបាយទាំង ៤ បានឡើយ ។ ព្រះមហាសត្វ កាលទ្រង់ថ្វាយឱវាទព្រះរាជាដូច្នេះហើយ កាលសម្តែងធម៌ដល់ព្រះរាជា បានពោលគាថាទាំងឡាយថា

កាលបុគ្គលប្រាថ្នានូវកាម បើកាមនោះ សម្រេចដល់បុគ្គលនោះ សត្វប្រាថ្នាកាមណាបានហើយ រមែងជាអ្នកមានចិត្តរីករាយក្នុងវត្ថុនោះ ដោយពិត ។

កាលបុគ្គលប្រាថ្នាកាម បើកាមនោះ សម្រេចដល់បុគ្គលនោះ បុគ្គលនោះ រមែងបាននូវចំណង់ដទៃជាងនោះទៅទៀត ដូចជា ( បុគ្គលហត់នឿយ ) បាននូវចំណង់ ( ស្រេក ) ក្នុងរដូវក្តៅ ។

កាលគោជាសត្វមានស្នែងកំពុងចម្រើន ស្នែងរមែងចម្រើនដែរ យ៉ាងណា កាលសត្វអ្នកមានបញ្ញាទន់ ល្ងង់ខ្លៅ មិនដឹងអ្វី កំពុងចម្រើន តណ្ហា និងសេចក្តីស្រេកឃ្លាន រមែងរឹងរឹតចម្រើនឡើងយ៉ាងនោះដែរ ។

ប្រសិនបើ ( មាណពនោះ ) ឲ្យស្រែស្រូវខ្សាយ ឲ្យស្រែស្រូវជំណើប ឲ្យគោ សេះ និងបុរសជាខ្ញុំប្រុសលើផែនដី ( ដល់បុគ្គលណាមួយ វត្ថុទាំងប៉ុណ្ណោះនេះ ) ក៏មិនល្មមដល់បុគ្គលម្នាក់ឡើយ បុរសដឹងយ៉ាងនេះហើយ គប្បីប្រព្រឹត្តឲ្យស្មើ ។

ស្តេចកំហែងច្បាំងឈ្នះនូវផែនដី ហើយគ្រប់គ្រងផែនដី មាន

សាគរជាទីបំផុត មានសភាពជាអ្នកមិនឆ្អែតនឹងត្រើយសមុទ្រខាងអាយ ក៏ចង់បាននូវត្រើយសមុទ្រខាងនាយទៀត ។

បុរសកាលទឹកស្រណោះនូវកាមទាំងឡាយ ដោយចិត្ត ( ដរាបណា ) ក៏មិនដល់នូវសេចក្ដីឆ្អែតដរាបនោះ ពួកសត្វណា ត្រឡប់ចិត្តចេញ គេចខ្លួនថយអំពីកាមនោះ ហើយឃើញ ( ទោសកាមដោយញាណ ) ជាអ្នកឆ្អែតដោយប្រាជ្ញា ពួកសត្វនោះ ទើបឈ្មោះថា ឆ្អែតពិតមែន ។

បុរសនោះ មិនក្ដៅក្រហាយដោយកាមទាំងឡាយ ( នេះ ) ជាអំពើដ៏ប្រសើររបស់ពួកជនអ្នកឆ្អែតដោយប្រាជ្ញា តណ្ហាមិនធ្វើបុរសដែលឆ្អែតដោយប្រាជ្ញា ឲ្យលុះក្នុងអំណាចបានឡើយ ។

សូមព្រះអង្គកម្ចាត់បង់នូវកាមទាំងឡាយចេញ បុរសអ្នកមានប្រាជ្ញាប៉ុនសមុទ្រ អ្នកមានសេចក្ដីប្រាថ្នាតិច អ្នកមិនលោភលន់ បុរសនោះ រមែងមិនក្ដៅក្រហាយដោយកាមទាំងឡាយ ។

បុគ្គលលះបង់នូវចំណែកនៃកាមទាំងឡាយណាៗ សេចក្ដីសុខក៏សម្រេច ( ដល់បុគ្គលនោះ ) ព្រោះចំណែកនៃកាមទាំងឡាយនោះៗ ដូចជាងស្បែកកាលកាត់ស្បែកជើង ( តែងចៀរនូវចំនៀរ ) នៃស្បែកចោល ( ក៏បាននូវថ្លៃស្បែកជើង ឈ្មោះថា ជាអ្នកបានសេចក្ដីសុខ ) បើបុគ្គលប្រាថ្នានូវសេចក្ដីសុខគ្រប់យ៉ាង ត្រូវលះកាមទាំងអស់ចេញ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កាមំ** បានដល់ ទាំងវត្ថុកាម ទាំងកិលេសកាម ។ បទថា **កាមយមានស្ស** បានដល់ ប្រាថ្នា ។ បទថា **តស្ស ចេ តំ សមិជ្ឈតិ** សេចក្តីថា វត្ថុដែលគេប្រាថ្នារមែងសម្រេច និងរមែងឲ្យផលដល់បុគ្គលនោះ ។ បទថា **ឆំ** ក្នុងពាក្យថា **តតោ ឆំ អបរំ កាមេ** នេះ ត្រឹមតែជានិបាត ។ បទថា **អបរំ** ជាបទសម្តែងចំណែកដទៃ ។ បទថា **កាមេ** ជាពហុវចនៈ ប្រើក្នុងអត្ថនៃទុតិយាវិភត្តិ ។ លោកអធិប្បាយពាក្យនេះថា បើគេប្រាថ្នាកាម វត្ថុដែលគេប្រាថ្នានោះ រមែងសម្រេចដល់បុគ្គលនោះសមបំណង វត្ថុនោះសម្រេចហើយ បុគ្គលនោះគង់ប្រាថ្នាបន្តទៅទៀត រមែងជួប គឺបានទទួលកាម ពោល គឺកាមតណ្ហា ដូចបុគ្គលដែលត្រូវខ្យល់ កម្តៅថ្ងៃ ក្នុងរដូវក្តៅ រមែងកើតការចង់បាន គឺបានទទួលនូវការស្រោចទឹក ដូច្នោះ ។ តណ្ហា មានរូបតណ្ហាជាដើម រមែងចម្រើនដល់បុគ្គលនោះឯង ។ បទថា **គវំវ** បានដល់ ដូចរូបគោ ។ បទថា **សិង្គិនោ** បានដល់ ស្នែងដែលដុះទម្លុះឡើងអំពីក្បាល ។ បទថា **មន្ទស្ស** បានដល់ ជាអ្នកមានបញ្ញាតិច ។ បទថា **ពាលស្ស** បានដល់ បុគ្គលប្រកបដោយពាលធម៌ ។ លោកអធិប្បាយពាក្យនេះថា ស្នែងគោ រមែងធំចម្រើនជាមួយរូបរាងរបស់កូនគោដែលកំពុងធំធាត់យ៉ាងណា កាមតណ្ហាដែលមិនទាន់មកដល់ក្តី ការស្រេកក្នុងកាមមកដល់ហើយក្តី រមែងចម្រើនក្រៃលែងជាលំដាប់ សម្រាប់ពួកអន្ធពាលជន ។ បទថា **សាលិយវកំ** បានដល់ ស្រែស្រូវសាលី និងស្រែស្រូវដំណើប ។ ដោយបទនេះ លោកសម្តែងធញ្ញជាតិទាំងអស់ មានស្រូវសាលី និងស្រូវដំណើប

ជាដើម ។ ដោយបទទី ២ លោកសម្តែងដល់សត្វជើង ២ និងសត្វជើង ៤ ។ ឬដោយបទទី ១ លោកសម្តែងដល់វត្ថុដែលមិនមានវិញ្ញាណទាំងអស់ ដោយបទក្រៅអំពីនេះ លោកសម្តែងដល់វត្ថុដែលមានវិញ្ញាណទាំងអស់ ។ បទថា **ឧត្វាបិ** បានដល់ សូម្បីឲ្យហើយ លោកអធិប្បាយពាក្យនេះថា អាណាចក្រទាំង ៣ ចូរលើកទុក បើមាណពនោះ ឲ្យវត្ថុដទៃៗ ឬផែនដីទាំងមូល ដែលមានវិញ្ញាណ និងមិនមានវិញ្ញាណ ទាំងរតនបុរីដល់អ្នកណាហើយទៅ វត្ថុមានប្រមាណប៉ុណ្ណេះ រមែងមិនដល់ទីបំផុតដល់បុគ្គលម្នាក់ប៉ុណ្ណោះ នេះឈ្មោះថា តណ្ហា ឲ្យពេញបានដោយលំបាក ដោយប្រការដូច្នេះ ។ បទថា **ឥតិវិទ្វា សមំ ចរេ** សេចក្តីថា បុរសដែលដឹងយ៉ាងនេះ ជាអ្នកមិនប្រព្រឹត្តទៅក្នុងអំណាចនៃតណ្ហា បំពេញកាយសុចរិតជាដើមឲ្យបរិបូណ៌ គប្បីប្រព្រឹត្តឲ្យស្មើ ។ បទថា **ឱរំ** បានដល់ ដល់នូវចំណែកដែលមានខាងក្នុង ។ ដោយបទនោះ លោកសម្តែងថា បុគ្គលដែលមិនទាន់ឆ្អែតគប្បីប្រាថ្នា សូម្បីប្រាំងនៃសមុទ្រទៀត ឈ្មោះថា សត្វដែលប្រព្រឹត្តទៅក្នុងអំណាចនៃតណ្ហា ជាបុគ្គលដែលបុគ្គលណាម្នាក់ឲ្យពេញបានដោយក្រ ដោយប្រការយ៉ាងនេះ ។ បទថា **យាវ** ជាពាក្យកំណត់ការរាប់មិនពិតប្រាកដ ។ បទថា **អនុស្សរំ** សេចក្តីថា រឭកដល់ ។ បទថា **នាជ្ឈគា** បានដល់ រមែងមិនជួប ។ លោកអធិប្បាយពាក្យនេះថា បពិត្រមហារាជ បុរសមានចិត្តរឭកដល់កាមទាំងឡាយ ដែលមិនមានទីបំផុត រមែងមិនជួបនូវការឆ្អែត ប្រាថ្នានឹងសម្រេចដល់នោះឯង កាលបើដូច្នោះ តណ្ហាក្នុងកាមទាំងឡាយ រមែងចម្រើនដល់សត្វទាំងឡាយនោះឯង ។

បទថា **តតោ និវត្តា** សេចក្តីថា បុគ្គលទាំងឡាយណា មានចិត្ត និងកាយត្រឡប់ចាកវត្ថុកាម និងកិលេសកាមហើយ ឃើញទោសដោយបញ្ញានោះឯងឆ្អែតបរិបូណ៌ដោយបញ្ញា បុគ្គលនោះឯង ឈ្មោះថា រមែងឆ្អែត ។ បទថា **បញ្ញាយ តិត្តីនំ សេដ្ឋំ** បានដល់ បណ្តាការឆ្អែតទាំងឡាយ ការឆ្អែតដោយបញ្ញានេះ រមែងជារបស់ប្រសើរបំផុត ។ម្យ៉ាងទៀត បាលី ក៏យ៉ាងនេះដូចគ្នា ។ បទថា **ន សោ កាមេហិ តប្បតិ** នេះ បាលីថា រមែងមិនត្រូវកាមទាំងឡាយដុតពោល អធិប្បាយថា ព្រោះហេតុដែលបុរសឆ្អែតដោយបញ្ញារមែងមិនត្រូវកាមដុតពោល ។ បទថា **ន កុរុតេ វសំ** សេចក្តីថា ព្រោះតណ្ហាមិនអាចធ្វើបុរសបែបនោះ ឲ្យធ្លាក់នៅក្នុងអំណាចបាន បុរសនោះឯងឃើញទោសនៃតណ្ហាហើយ រមែងមិនប្រព្រឹត្តទៅក្នុងអំណាចនៃតណ្ហា ដូចសរភង្គមាណព និងដូចព្រះរាជាឈ្មោះអឌ្ឍមាសក ដូច្នោះ ។ បទថា **អបចិនេថេវ** បានដល់ គប្បីកម្ចាត់ចោល ។ បទថា **សមុទ្ទមត្តោ** បានដល់ មានប្រមាណស្មើសមុទ្រ ព្រោះប្រកបដោយបញ្ញាច្រើន ។ បុរសនោះ រមែងមិនក្តៅក្រហាយ គឺមិនចោមរោមដោយកិលេសកាមទាំងឡាយ ដូចសមុទ្រមិនក្តៅព្រោះភ្លើងធំ ដូច្នោះ ។ បទថា **រថការោ** បានដល់ ជាងស្បែក ។ បទថា **បរិកន្តំ** បានដល់ កាលកាត់ ។ លោកអធិប្បាយពាក្យនេះថា ជាងស្បែកកាត់នូវស្បែកជើង វៀរទីដែលស្បែកមិនចូលលក្ខណៈដែលគួរកាន់យកបានធ្វើឲ្យជាស្បែកជើង បានតម្លៃរបស់រយជន រមែងបានទទួលសេចក្តីសុខ យ៉ាងណា បណ្ឌិតក៏ដូច្នោះដូចគ្នា ពិចារណាដោយបញ្ញា ដែលដូចគ្នានឹងកាំបិត

របស់ជាន់ស្បែកជើង រមែងលះដែនណាមួយរបស់លោកទាំងឡាយបាន កាយកម្ម វចីកម្ម និងមនោកម្មនោះៗ របស់បណ្ឌិតដែលវៀរចាកដែននៃកាម នោះ រមែងដល់នូវសេចក្ដីសុខ ប្រាសចាកសេចក្ដីក្រវល់ក្រវាយ បើគប្បី ប្រាថ្នាសេចក្ដីសុខ មានកាយកម្មជាដើម គ្រប់យ៉ាងដែលប្រាសចាកការក្ដៅ ក្រហាយ ចម្រើនកសិណ ញ៉ាំងឈានឲ្យកើតហើយ លះនូវកាមទាំងពួង ។

ឱទាតកសិណជ្ឈានកើតឡើងដល់ព្រះពោធិសត្វ ដែលកំពុងពោលគាថា នេះ ព្រោះទាញយកស្វេតច្ឆត្ររបស់ព្រះរាជាជាអារម្មណ៍ ។ សូម្បីព្រះរាជា ក៏ទ្រង់ស្បើយចាករោគ ទ្រង់មានសេចក្ដីត្រេកអរ ក្រោកចាកទីបន្ទំ មានព្រះ តម្រាស់ថា ពួកពេទ្យប៉ុណ្ណោះ គង់មិនអាចព្យាបាលបាន តែមាណពនេះជា បណ្ឌិត បានធ្វើយើងឲ្យប្រាសចាករោគ ដោយញាណវិស័យរបស់ខ្លួនបាន កាលទ្រង់ប្រាស្រ័យជាព្រះពោធិសត្វ ទើបត្រាស់គាថាទី ១០ ថា

គាថាទាំងអស់ ៨ ដែលអ្នកពោលហើយ គួរដល់ថ្លៃ ១០០០ កហាបណៈ ម្នាលមហាព្រហ្ម អ្នកចូរទទួលយក ( នូវ កហាបណៈទាំងនេះ ) ចុះ ភាសិតរបស់អ្នកនេះ ប្រពៃណាស់ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អដ្ឋ** បានដល់ ៨ គាថា ដែលប្រកប ដោយទោសនៃកាម តាំងអំពីគាថាទី ២ ទៅ ។ បទថា **សហស្សិយា** បាន ដល់ គួរដល់តម្លៃមួយពាន់ ។ បទថា **បដិគ្គណ្ហ** សេចក្ដីថា ចូរទទួលយក ទ្រព្យ ៨ ពាន់ ។ បទថា **សាធេតំ តវ ភាសិតំ** បានដល់ ពាក្យដែលអ្នក

ពោលនេះ គង់ញុំាងប្រយោជន៍ឲ្យសម្រេច ។ ព្រះមហាសត្វបានស្តាប់ដូច្នោះហើយ ទើបពោលគាថាទី ១១ ថា

ខ្ញុំព្រះអង្គមិនត្រូវការដោយកហាបណៈទាំងរយ ទាំងពាន់ ទាំងម៉ឺនទេ កាលដែលខ្ញុំព្រះអង្គ កំពុងពោលគាថាខាងចុង ចិត្តរបស់ខ្ញុំព្រះអង្គ មិនត្រេកអរក្នុងកាមឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បច្ឆិមំ** សំដៅដល់គាថាដែលមានពាក្យផ្តើមថា **វេចកោរេ ចម្មស្ស** ដូច្នេះ ។ បទថា **កាមេ មេ ន រតោ មនោ** សេចក្តីថា បពិត្រមហារាជ កាលបើទូលបង្គំកំពុងពោលគាថានោះឯង ចិត្តមិនត្រេកអរទាំងក្នុងវត្ថុកាម ទាំងក្នុងកិលេសកាម ព្រោះទូលបង្គំ កាលពោលគាថានេះ ញុំាងឈានឲ្យកើតដោយធម្មទេសនារបស់ខ្លួន ។

ព្រះរាជាទ្រង់ត្រេកអរពន់ប្រមាណ កាលទ្រង់សរសើរព្រះមហាសត្វបានត្រាស់គាថាចុងក្រោយថា

អ្នកប្រាជ្ញណាកំណាត់ដីងនូវតណ្ហា ដែលញុំាងសេចក្តីទុក្ខឲ្យកើតឡើង អ្នកប្រាជ្ញនោះ គឺមាណពដ៏ចម្រើន ដែលជាអ្នកដឹងនូវលោកទាំងមូលនេះទេតើ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ទុក្ខជននឹ** បានដល់ ញុំាងទុក្ខក្នុងវដ្តទាំងមូលឲ្យកើត ។ បទថា **បរិជានាតិ** បានដល់ កំណាត់ដឹងហើយ គឺកំណាត់កាត់ផ្តាច់នាំចេញទៅ ព្រោះហេតុនោះ កាលសរសើរព្រះពោធិសត្វ ទើបបានត្រាស់យ៉ាងនេះ ។

ព្រះពោធិសត្វថ្វាយឱវាទព្រះរាជាថា បពិត្រមហារាជ សូមទ្រង់ជាអ្នកមិនប្រមាទប្រព្រឹត្តធម៌ចុះ ហើយហោះទៅកាន់ហិមវន្តប្បទេស បួសជាឥសីចម្រើនព្រហ្មវិហារជាបដល់អស់អាយុ ហើយទៅកើតក្នុងព្រហ្មលោក ។

ព្រះសាស្ដា កាលទ្រង់នាំយកព្រះធម្មទេសនានេះ មកសម្ដែងហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សូម្បីក្នុងកាលមុន តថាគតក៏ធ្លាប់ធ្វើឲ្យព្រាហ្មណ៍នេះប្រាសចាកសេចក្ដីសោក ដោយប្រការដូច្នេះ ហើយទ្រង់ប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះ បានមកជាព្រាហ្មណ៍នេះ ក្នុងកាលឥឡូវនេះ ឯមាណពដែលជាបណ្ឌិតក្នុងកាលនោះ គឺតថាគតនេះឯង ។៙

**អដ្ឋកថា កាមជាតក ចប់**

# សុត្តន្តបិដក

## ជនសន្ធជាតក

[ ៩៤៧ ] ( ព្រះសាស្តាទ្រង់ត្រាស់ថា ) ព្រះបាទជនសន្ធៈទ្រង់មានព្រះឱង្ការថា បុគ្គលណាមិនបានធ្វើហេតុទាំង ១០ នេះទុកជាមុនទេ បុគ្គលនោះតែងក្តៅក្រហាយក្នុងកាលជាខាងក្រោយ ។

[ ៩៤៨ ] បុគ្គលមិនបានទ្រព្យ ដែលខ្លួនមិនបានឲ្យកើតឡើងក្នុងកាលមុន រមែងក្តៅក្រហាយ តែងក្តៅក្រហាយរឿយៗ ក្នុងកាលជាខាងក្រោយថា អាត្មាអញមិនបានស្វែងរកទ្រព្យទុកក្នុងកាលមុន ។

[ ៩៤៩ ] បុគ្គលតែងក្តៅក្រហាយរឿយៗ ក្នុងកាលជាខាងក្រោយថា សិល្បៈជាគុណមានសភាពអង់អាច អាត្មាអញមិនបានរៀនទុកក្នុងកាលមុន ការចិញ្ចឹមជីវិតនៃបុគ្គលអ្នកមិនមានសិល្បៈលំបាក ។

[ ៩៥០ ] បុគ្គលតែងក្តៅក្រហាយរឿយៗ ក្នុងកាលជាខាងក្រោយថា កាលពីដើម អាត្មាអញ ជាអ្នកប៉ិនប្រសប់ក្នុងអំពើកោងផង ជាអ្នកញុះញង់ផង ស៊ីសាច់ខ្នងគេ គឺស៊ីសំណូកផង ជាអ្នកកាចផង អាក្រក់ផង ។

[ ៩៥១ ] បុគ្គលតែងក្តៅក្រហាយរឿយៗ ក្នុងកាលជាខាងក្រោយថា កាលពីដើម អាត្មាអញ ជាអ្នកសម្លាប់សត្វផង កាចអាក្រក់ផង ជាអ្នកមិនប្រសើរផង មិនកោតកែងចំពោះពួក

សត្វផង ។

[ ៩៥២ ] បុគ្គលតែងក្តៅក្រហាយរឿយៗ ក្នុងកាលជាខាង ក្រោយថា អើហ្ន៎ កាលដែលពួកស្ត្រីមានច្រើនគរគោក ជាស្ត្រី មិនមានអន្តរាយ ( មិនមានគេកាន់កាប់សោះ ) អាត្មាអញសេព និងប្រពន្ធគេ ។

[ ៩៥៣ ] បុគ្គលតែងក្តៅក្រហាយរឿយៗ ក្នុងកាលជាខាង ក្រោយថា អើហ្ន៎ កាលពីដើម អាត្មាអញ មានបាយ និងទឹក ច្រើនគរគោក តែមិនបានឲ្យទានសោះ ។

[ ៩៥៤ ] បុគ្គលតែងក្តៅក្រហាយរឿយៗ ក្នុងកាលជាខាង ក្រោយថា កាលអាត្មាអញមានទ្រព្យច្រើន មិនបានចិញ្ចឹមមាតា និងបិតាដែលចាស់ មានវ័យកន្លងហើយ ។

[ ៩៥៥ ] បុគ្គលតែងក្តៅក្រហាយរឿយៗ ក្នុងកាលជាខាង ក្រោយថា អាត្មាអញបានមើលងាយបិតាដែលជាអាចារ្យ អ្នក ប្រៀនប្រដៅ ជាអ្នកនាំមកនូវរសគ្រប់យ៉ាង ។

[ ៩៥៦ ] បុគ្គលតែងក្តៅក្រហាយរឿយៗ ក្នុងកាលជាខាង ក្រោយថា ក្នុងកាលមុន អាត្មាអញ មិនបានចូលទៅជិតពួក សមណៈ និងព្រាហ្មណ៍អ្នកមានសីល ជាពហុស្សូតឡើយ ។

[ ៩៥៧ ] បុគ្គលតែងក្តៅក្រហាយរឿយៗ ក្នុងកាលជាខាង ក្រោយថា តបៈ គឺសុចរិតធម៌ ដែលគេសន្សំហើយផង បុគ្គល

អ្នកស្ងប់ដែលគេចូលទៅអង្គុយជិតផង ជាការប្រពៃ តបះ ( មានសភាពយ៉ាងនេះ ) អាត្មាអញមិនបានសន្សំហើយ ក្នុងកាលពីដើម ។

[ ៩៥៨ ] ចំណែកបុគ្គលណា កាលធ្វើកិច្ចរបស់បុរសទាំងឡាយ ហើយប្រតិបត្តិនូវហេតុទាំងនេះដោយយោបល់ បុគ្គលនោះរមែងមិនក្តៅក្រហាយរឿយៗ ក្នុងកាលជាខាងក្រោយឡើយ ។

**ជនសន្ធជាតកទី ៥ ចប់**

# អដ្ឋកថា

## ជនសន្ធជាតក

[ ៩៤៧-៩៥៨ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់មានពុទ្ធបំណងប្រទានឱវាទដល់ព្រះបាទកោសល ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ទស ខលុមានិ ឋានានិ** ដូច្នេះជាដើម ។

សេចក្តីពិស្តារថា ក្នុងគ្រាមួយ ព្រះបាទកោសល ទ្រង់ស្រវឹងដោយឥស្សរិយយស លិចចុះក្នុងសេចក្តីសុខដែលកើតអំពីកិលេស មិនប្រាថ្នាវិនិច្ឆ័យក្តី សូម្បីការទំនុកបម្រុងព្រះសម្ពុទ្ធ ក៏ទ្រង់ភ្លេច ។ ថ្ងៃមួយ ទ្រង់រឭកដល់ព្រះទសពល ទើបទ្រង់ព្រះតម្រិះថា អញនឹងថ្វាយបង្គំព្រះសាស្តា លុះសោយព្រះក្រយាហារព្រឹកហើយ ទ្រង់ឡើងព្រះរាជយានទៅកាន់ព្រះវិហារ ថ្វាយបង្គំព្រះសាស្តាហើយប្រថាប់គង់ លំដាប់នោះ ព្រះសាស្តាត្រាស់នឹងព្រះរាជាថា មហាបពិត្រ យូរមកហើយ ទ្រង់មិនបានយាងមក ព្រោះហេតុអ្វីហ្ន៎ ព្រះបាទកោសលទូលថា ព្រោះខ្ញុំព្រះអង្គមានរាជកិច្ចច្រើន មិនមានឱកាសដែលនឹងមកគាល់ទ្រង់បាន ទើបព្រះសាស្តាត្រាស់ថា មហាបពិត្រ កាលព្រះសព្វញ្ញុពុទ្ធ អ្នកឲ្យឱវាទដូចតថាគតនៅក្នុងវិហារជិតបង្កើយ មិនគួរទ្រង់ប្រមាទ វិស័យព្រះរាជាត្រូវមិនប្រមាទ ក្នុងរាជកិច្ចទាំងឡាយ តម្កល់ខ្លួនស្មើដោយមាតាបិតារបស់អ្នកដែន លះនូវអគតិ គ្រងរាជសម្បត្តិដោយទសពិធរាជធម៌ទើបគួរ ព្រោះកាលព្រះរាជាប្រព្រឹត្តធម៌ សូម្បីបរិស័ទរបស់ទ្រង់ក៏ប្រព្រឹត្តធម៌ កាលតថាគតទូន្មាន ទ្រង់គប្បីគ្រងរាជសម្បត្តិដោយធម៌ នុ៎ះមិនជាអស្ចារ្យឡើយ បោរាណកបណ្ឌិតទាំងឡាយ មិនមានអាចារ្យទូន្មាន គង់តាំងនៅក្នុង

សុចរិតធម៌ ៣ ប្រការ សម្តែងធម៌ដល់មហាជន តាមចំណោះរបស់ខ្លួន នាំបរិស័ទទៅឋានសួគ៌បាន ។ ព្រះបាទកោសលទូលអារាធនាឲ្យទ្រង់ត្រាស់រឿងនោះ ព្រះពុទ្ធអង្គទ្រង់នាំអតីតនិទានមកត្រាស់ដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វ បដិសន្ធិក្នុងគភ៌របស់ព្រះអគ្គមហេសីនៃព្រះរាជាអង្គនោះ ។ ព្រះញាតិទាំងឡាយបានថ្វាយព្រះនាមថា ជនសន្ធកុមារ កាលព្រះពោធិសត្វចម្រើនវ័យ រៀននូវសិប្បវិជ្ជាក្នុងនគរតក្កសិលា ត្រឡប់មកហើយ ព្រះរាជាមានព្រះតម្រាស់ឲ្យជម្រះគុកទាំងអស់ឲ្យស្អាត ហើយព្រះរាជទានតំណែងជាឧបរាជ ។

កាលតមក កាលព្រះរាជបិតាសោយទិវង្គតហើយ ព្រះពោធិសត្វបានគ្រងរាជសម្បត្តិ ទ្រង់ត្រាស់ឲ្យសាងសាលាធទាន គឺត្រង់ទ្វារនគរទាំង ៤ ត្រង់កណ្តាលព្រះនគរ និងត្រង់ទ្វារព្រះរាជវាំង បរិច្ចាគព្រះរាជទ្រព្យមួយថ្ងៃ ៦ សែន ទ្រង់បំពេញមហាទាន រហូតល្បីខ្ទរខ្ទារទៅពេញជម្ពូទ្វីប ត្រាស់ឲ្យបើកគុកជានិច្ច ឲ្យគោះរគាំងប្រកាសឲ្យមកស្តាប់ធម៌ ទ្រង់សង្គ្រោះនូវ ( សត្វ ) លោកដោយសង្គហវត្ថុ ៤ រក្សាសីល ៥ និងឧបោសថសីល គ្រងរាជសម្បត្តិដោយធម៌ ។ ឲ្យអ្នកដែនប្រជុំគ្នាម្តងម្កាល ហើយសម្តែងធម៌ថា អ្នកទាំងឡាយ ចូរឲ្យទាន ចូរសមាទានសីល ចូរប្រព្រឹត្តធម៌ ចូរប្រកបការងារ និងការលក់ដូរដោយធម៌ បើជាកុមារ ចូររៀនសិប្បវិជ្ជា ចូរស្វែងរកទ្រព្យ កុំតែបំបាត់អ្នកស្រុក កុំធ្វើនូវការញុះញង់ កុំជាមនុស្សឃោរឃៅ ចូរបម្រើមាតា

បិតា ចូរមានសេចក្ដីគោរពឱនលំទោនចំពោះត្រកូលរៀមច្បង ទ្រង់បានធ្វើមហាជនឲ្យតាំងនៅក្នុងសុចរិតធម៌ ។

ថ្ងៃមួយ ជាថ្ងៃបណ្ណរសីឧបោសថ ព្រះពោធិសត្វទ្រង់សមាទានឧបោសថសីលហើយ ទ្រង់ត្រិះរិះថា អញនឹងសម្ដែងធម៌ដល់មហាជនដើម្បីប្រយោជន៍ និងសុខក្រៃលែង ដើម្បីឲ្យមហាជននៅដោយសេចក្ដីមិនប្រមាទ ត្រាស់ឲ្យវាយស្គរ ប្រកាសទូទៅពេញព្រះនគរ ឲ្យអ្នកនគរទាំងអស់ តាំងអំពីស្ត្រីរបស់ទ្រង់ឡើងទៅ មកប្រជុំគ្នា ហើយប្រថាប់គង់លើបល្ល័ង្កដ៏ប្រសើរ ដែលតាក់តែងកណ្ដាលរតនមណ្ឌប ដែលតាក់តែងហើយក្នុងលានព្រះរាជវាំង ត្រាស់ថា អ្នកនគរជាទីស្រឡាញ់ទាំងឡាយ ខ្ញុំនឹងសម្ដែងធម៌ ដែលធ្វើខ្លួនឲ្យក្ដៅខ្លះ មិនធ្វើខ្លួនក្ដៅខ្លះ ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយកុំប្រមាទ ចូរផ្ទៀងនូវសោតៈស្ដាប់ដោយគោរពចុះ ហើយទ្រង់សម្ដែងធម៌ ។

ព្រះសាស្ដា ទ្រង់បើកព្រះឱស្ឋកែវ ដែលអប់រំហើយដោយអរិយសច្ចកាលត្រាស់ទេសនានោះ ឲ្យជាក់ច្បាស់ដល់ព្រះបាទកោសល ដោយព្រះសូរសៀងដ៏ពីរោះ បានត្រាស់ព្រះគាថាទាំងនេះថា

ព្រះបាទជនសន្ធៈ ទ្រង់មានព្រះឱង្ការថា បុគ្គលណាមិនបានធ្វើហេតុទាំង ១០ នេះទុកជាមុនទេ បុគ្គលនោះ តែងក្ដៅក្រហាយក្នុងកាលជាខាងក្រោយ ។

បុគ្គលមិនបានទ្រព្យដែលខ្លួនមិនបានឲ្យកើតឡើង ក្នុងកាលមុន រមែងក្ដៅក្រហាយ តែងក្ដៅក្រហាយរឿយៗ ក្នុងកាលជាខាង

ក្រោយថា អាត្មាអញមិនបានស្វែងរកទ្រព្យទុក ក្នុងកាលមុន ។

បុគ្គលតែងក្តៅក្រហាយរឿយៗ ក្នុងកាលជាខាងក្រោយថា សិល្បៈជាគុណមានសភាពអង់អាច អាត្មាអញមិនបានរៀនទុក ក្នុងកាលមុន ការចិញ្ចឹមជីវិតនៃបុគ្គលអ្នកមិនមានសិល្បៈ លំបាក ។

បុគ្គលតែងក្តៅក្រហាយរឿយៗ ក្នុងកាលជាខាងក្រោយថា កាលពីដើម អាត្មាអញជាអ្នកប៉ិនប្រសប់ក្នុងអំពើកោងផង ជាអ្នកញុះញង់ផង ស៊ីសាច់ខ្នងគេ គឺស៊ីសំណូកផង ជាអ្នកកាចផង អាក្រក់ផង ។

បុគ្គលតែងក្តៅក្រហាយរឿយៗ ក្នុងកាលជាខាងក្រោយថា កាលពីដើម អាត្មាអញជាអ្នកសម្លាប់សត្វផង កាចអាក្រក់ផង ជាអ្នកមិនប្រសើរផង មិនកោតក្រែងចំពោះពួកសត្វផង ។

បុគ្គលតែងក្តៅក្រហាយរឿយៗ ក្នុងកាលជាខាងក្រោយថា អើហ្ន៎ កាលដែលពួកស្ត្រីមានច្រើនគរគោក ជាស្ត្រីមិនមានអន្តរាយ ( មិនមានគេកាន់កាប់សោះ ) អាត្មាអញសេពនឹងប្រពន្ធគេ ។

បុគ្គលតែងក្តៅក្រហាយរឿយៗ ក្នុងកាលជាខាងក្រោយថា អើហ្ន៎ កាលពីដើម អាត្មាអញមានបាយ និងទឹកច្រើនគរគោក តែមិនបានឲ្យទានសោះ ។

បុគ្គលតែងក្តៅក្រហាយរឿយៗ ក្នុងកាលជាខាងក្រោយថា កាលអាត្មាអញមានទ្រព្យច្រើន មិនបានចិញ្ចឹមមាតា និងបិតា ដែលចាស់ មានវ័យកន្លងហើយ ។

បុគ្គលតែងក្តៅក្រហាយរឿយៗ ក្នុងកាលជាខាងក្រោយថា អាត្មាអញបានមើលងាយបិតាដែលជាអាចារ្យ អ្នកប្រៀនប្រដៅ ជាអ្នកនាំមកនូវរសគ្រប់យ៉ាង ។

បុគ្គលតែងក្តៅក្រហាយរឿយៗ ក្នុងកាលជាខាងក្រោយថា ក្នុងកាលមុន អាត្មាអញមិនបានចូលទៅជិតពួកសមណៈ និង ព្រាហ្មណ៍អ្នកមានសីល ជាពហុស្សូតឡើយ ។

បុគ្គលតែងក្តៅក្រហាយរឿយៗ ក្នុងកាលជាខាងក្រោយថា តបៈ គឺសុចរិតធម៌ ដែលគេសន្សំហើយផង បុគ្គលអ្នកស្ងប់ ដែលគេចូលទៅអង្គុយជិតផង ជាការប្រពៃ តបៈ ( មាន សភាពយ៉ាងនេះ ) អាត្មាអញមិនបានសន្សំហើយ ក្នុងកាល ពីដើម ។

ចំណែកបុគ្គលណា កាលធ្វើកិច្ចរបស់បុរសទាំងឡាយ ហើយ ប្រតិបត្តិនូវហេតុទាំងនេះដោយយោបល់ បុគ្គលនោះ រមែងមិន ក្តៅក្រហាយរឿយៗ ក្នុងកាលជាខាងក្រោយឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឋានានិ** បានដល់ ហេតុទាំងឡាយ ។ បទ ថា **បុព្វេ** បានដល់ មិនធ្វើទុកក្នុងកាលមុនឡើយ ។ បទថា **ស បច្ឆា អនុ-**

**តប្បតិ** សេចក្តីថា បុរសមិនធ្វើកិច្ចដែលគួរធ្វើមុន រមែងក្តៅក្រហាយក្នុងកាលជាខាងក្រោយ គឺរមែងលំបាក ទាំងក្នុងលោកនេះ ទាំងក្នុងលោកខាងមុខ ។ មួយវិញទៀត បាលីថា **បច្ឆា អនុតប្បតិ** រមែងតាមក្តៅក្រហាយក្នុងកាលជាខាងក្រោយ ដូច្នេះក៏មាន ។ បទថា **ឥច្ចាហ** សេចក្តីថា ព្រះបាទជនសន្ធៈបានត្រាស់យ៉ាងនោះ ។ បាលីថា **ឥច្ចាសុហ** ដូច្នេះក៏មាន ។ **សុ** អក្ខរៈ ក្នុងបទថា **ឥច្ចាសុហ** នោះ ត្រឹមតែជានិបាត កាត់បទជា **ឥច្ចាសុ អាហ** ។ ដើម្បីសម្តែងហេតុដែលជាទីតាំងនៃការក្តៅក្រហាយ ១០ យ៉ាងនេះ ទើបព្រះពោធិសត្វពោលធម្មកថា ។

បណ្តាបទទាំងនោះ បទថា **បុព្វេ** សេចក្តីថា ព្រះបាទជនសន្ធៈសម្តែងថា បុគ្គលកាលនៅជាកំលោះដំបូងនោះឯង មិនធ្វើនូវការប្រឹងប្រែង កាលចាស់រកទ្រព្យមិនបាន មិនដុះដាល គឺមិនកើតឡើង រមែងក្តៅក្រហាយសោយសោក ឃើញមនុស្សទាំងឡាយ មានសេចក្តីសុខ ខ្លួនឯងជាអ្នកនៅលំបាក រមែងក្តៅក្រហាយក្នុងកាលជាខាងក្រោយយ៉ាងនេះថា កាលមុន អញមិនបានស្វែងរកទ្រព្យ កាលចាស់ រមែងលំបាក ព្រោះដូច្នោះ កាលត្រូវការ មានសេចក្តីសុខក្នុងពេលចាស់ ត្រូវធ្វើការងារ មានកសិកម្មជាដើមដែលប្រពៃតាមធម៌ ហើយស្វែងរកទ្រព្យ តាំងអំពីកាលនៅជាកំលោះនោះចុះ ។ បទថា **បុរេ សន្តំ** សេចក្តីថា ក្នុងកាលមុន គឺក្នុងកាលដែលអញនៅក្មេង មិនចូលទៅរកអាចារ្យទាំងឡាយ មិនសិក្សាសិប្បៈណាមួយ មានសិប្បៈដំរីជាដើមដែលសមគួរខ្លួនធ្វើ ។ បទថា **កិច្ចា** សេចក្តីថា ក្នុងពេលចាស់ បុគ្គលមិន

សិក្សាសិប្បៈ ទើបមិនអាចតាំងជីវិតឲ្យផុតចាកទុក្ខ ក្នុងកាលនោះ ទើបគួរសិក្សាសិប្បៈ ព្រោះដូច្នោះ អ្នកទាំងឡាយ ដែលប្រាថ្នាញ៉ាំងជីវិតឲ្យមានសេចក្តីសុខក្នុងកាលឯចាស់ ចូរសិក្សាសិប្បៈក្នុងវេលាដែលនៅក្មេងនោះឯង ។ បទថា **កូដវេទី** សេចក្តីថា បុគ្គលណា ញ៉ាំងនូវការកោងឲ្យកើត គៃប្រវញ្ចអ្នកស្រុក ញ៉ាំងនូវសេចក្តីវិនាសឲ្យដល់សត្វលោក កោងដោយក្អែកជញ្ជីងកោងដោយស៊ីសំណូក ។ បទថា **អាសឹ** សេចក្តីថា ក្នុងកាលមុន យើងមានសភាពដូច្នោះ ។ បទថា **បិសុណោ** បានដល់ ដែលធ្វើនូវការញុះញង់ ។ បទថា **បិដ្ឋិមំសិកោ** សេចក្តីថា ស៊ីសំណូក ធ្វើបុគ្គលមិនមែនម្ចាស់ទ្រព្យឲ្យជាម្ចាស់ទ្រព្យ ធ្វើម្ចាស់ទ្រព្យមិនឲ្យជាម្ចាស់ទ្រព្យ ឈ្មោះថា ស៊ីសាច់ខ្នងរបស់ជនដទៃ ។ បទថា **ឥតិ បច្ឆា** សេចក្តីថា ដេកលើគ្រែសម្រាប់ស្លាប់តែងក្តៅក្រហាយក្នុងកាលជាក្រោយ ដោយប្រការដូច្នោះ ព្រោះដូច្នោះ បើអ្នកមិនចង់ធ្លាក់នរក កុំធ្វើបាបកម្មមានភាពបែបនេះ ។ បទថា **លុទ្ទោ** សេចក្តីថា ជាមនុស្សឃោរឃៅ ។ បទថា **អនារិយោ** សេចក្តីថា បុគ្គលមិនមែនព្រះអរិយៈ មិនសង្រួម ជាបុគ្គលទ្រុស្តសីល មានអាចារៈថោកថយ ។ បទថា **នាបចាយិស្សំ** សេចក្តីថា ខ្ញុំមិនមែនជាអ្នកមានការប្រព្រឹត្តឱនលំទោនដោយអំណាចខន្តី មេត្តា និងការអណិតអាសូរ ។ ពាក្យដ៏សេស គប្បីប្រកបដោយន័យមុននោះឯង ។

បទថា **អនាបនាសុ** សេចក្តីថា ការអាងសិទ្ធិ ឈ្មោះថា **អាបនោ** អធិប្បាយថា មានម្ចាស់ហួងហែង ។ ការអាងសិទ្ធិមិនមានដល់ស្ត្រីពួកណា

ព្រោះហេតុនោះ ស្ត្រីទាំងនោះ ឈ្មោះថា **អនាបនោ** ។ បទថា **ឧបដ្ឋិតេ** បានដល់ ប្រាកដចំពោះ ។ បទថា **ន បុព្វេ** សេចក្តីថា កាលមុននេះ អញមិនបានឲ្យទានឡើយ ។ បទថា **បហុសន្តោ** សេចក្តីថា ជាអ្នកអាច គឺអាចចិញ្ចឹមដោយកម្លាំងទ្រព្យ និងដោយកម្លាំងកាយ ។

បទថា **អាចរិយំ** សេចក្តីថា បិតាក្នុងទីនេះ លោកបំណងយកអាចារ្យ ព្រោះឲ្យសិក្សាមារយាទ ។ បទថា **អនុសត្ថារំ** បានដល់ អ្នកប្រៀនប្រដៅ ។ បទថា **សព្វកាមរសា ហារំ** សេចក្តីថា បុគ្គលនាំរស គឺវត្ថុកាមគ្រប់យ៉ាងមកចិញ្ចឹម ។ បទថា **អតិមញ្ញិស្សំ** សេចក្តីថា កាលមិនកាន់យកឱវាទរបស់លោក ឈ្មោះថា មើលងាយលោកពន់ពេក ។ បទថា **ន បុព្វេ** សេចក្តីថា កាលមុនអំពីនេះ មិនបានចូលទៅរកសមណព្រាហ្មណ៍ ដែលទ្រទ្រង់ធម៌ អ្នកជំងឺ បុគ្គលលំបាក មិនប្រណិប័តន៍ដោយប្រគេនបច្ច័យ មានចីវរជាដើម ។ បទថា **តបោ** បានដល់ ជាអ្នកមានសេចក្តីព្យាយាមជាគ្រឿងដុតកិលេស គឺសុចរិត ។ បទថា **សន្តោ** សេចក្តីថា ជាអ្នកមានសីល ចូលទៅស្ងប់ដោយទ្វារ មានកាយទ្វារជាដើម ។ លោកអធិប្បាយថា បុគ្គលប្រព្រឹត្តតបៈ ពោលគឺសុចរិត ៣ និងបុគ្គលស្ងប់បែបនេះ ឈ្មោះថា ចូលទៅអង្គុយជិត ជាការញុំាងប្រយោជន៍ឲ្យសម្រេច គឺជាការល្អ ។ បទថា **ន បុព្វេ** សេចក្តីថា កាលអញនៅកំលោះ មិនបានប្រព្រឹត្តព្រហ្មចរិយៈបែបនេះ ក្រោយមក គ្រាំគ្រាចាស់ជរា ត្រូវមរណភ័យគំរាម ទើបក្តៅក្រហាយសោយសោក ក្នុងកាលជាខាងក្រោយ ដោយប្រការដូច្នេះ ។ លោកពោលថា បើអ្នកប្រាថ្នាមិនសោក

ស្តាយយ៉ាងនេះ ចូរធ្វើតបធម៌ចុះ ។ បទថា **យោ ច ឯតានិ ឋានានិ** សេចក្តីថា បុគ្គលណាបដិបត្តិហេតុ ១០ ប្រការ ដោយឧបាយមុននោះឯង សមាទានប្រព្រឹត្តធ្វើនូវកិច្ចដែលប្រកបដោយធម៌ ដែលបុរសទាំងឡាយគួរធ្វើ បុរសដែលនៅដោយការមិនប្រមាទនោះ រមែងមិនតាមក្តៅក្រហាយក្នុងកាលជាខាងក្រោយ រមែងបានទទួលសោមនស្សនោះឯង ។

ព្រះមហាសត្វ សម្តែងធម៌ដល់មហាជនដោយទំនងនេះ រាល់ៗ កន្លះខែ ដោយប្រការដូច្នេះ មហាជនក៏តាំងនៅក្នុងឱវាទរបស់ព្រះអង្គ បំពេញឋានៈ ១០ ប្រការទាំងនោះ ឲ្យបរិបូណ៌ ហើយបានទៅកាន់ស្ថានសួគ៌ ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកសម្តែងហើយ ត្រាស់ថា មហាបពិត្រ បោរាណកបណ្ឌិត មិនមានអាចារ្យ សម្តែងធម៌តាមប្រាជ្ញារបស់ខ្លួន នាំមហាជនទៅកាន់ស្ថានសួគ៌បានយ៉ាងនេះ ហើយទ្រង់ប្រជុំជាតកថា បរិស័ទក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទ ក្នុងកាលឥឡូវនេះ ឯព្រះបាទជនសន្ធរាជក្នុងកាលនោះ គឺតថាគតនេះឯង ។ល។

**អដ្ឋកថា ជនសន្ធជាតក ចប់**

# សុត្តន្តបិដក

## មហាកណ្ហជាតក

[ ៩៥៩ ] ( ព្រះរាជាត្រាស់សួរថា ) ម្នាលអ្នកមានព្យាយាម ឆ្កែរបស់អ្នកខ្មៅណាស់ គួរស្បើម មានចង្កូមសស្អាច អ្នកចង ដោយខ្សែ ៥ តើវាមានប្រយោជន៍អ្វីដល់អ្នក ។

[ ៩៦០ ] ( សក្កទេវរាជពោលថា ) បពិត្រព្រះបាទឧសិន្នរៈ ឆ្កែនេះមិនមកដើម្បីប្រយោជន៍ដល់ពួកម្រឹគទេ ឆ្កែខ្មៅបំផ្លិចបំផ្លាញ នូវពួកមនុស្ស ក្នុងកាលណានឹងរបូតទៅ ( អំពីដៃខ្ញុំ ) ក្នុង កាលនោះ ។

[ ៩៦១ ] ពួកសមណៈត្រងោល មានបាត្រក្នុងដៃ ឃ្មុំសង្ឃាដិ នឹងភ្ជួររាស់ដោយនង្គ័លទាំងឡាយ ( ក្នុងកាលណា ) ឆ្កែខ្មៅ នឹងរបូត ( ស៊ុះទៅស៊ីនូវសមណៈទាំងនោះ ) ក្នុងកាលនោះ ។

[ ៩៦២ ] ពួកភិក្ខុនីមានតបៈ ជាអ្នកបួសត្រងោល ឃ្មុំសង្ឃាដិ នឹងទៅ ( បរិភោគកាម ) ក្នុងលោក ក្នុងកាលណា ឆ្កែខ្មៅនឹង របូត ( ស៊ុះទៅស៊ីនូវនាងភិក្ខុនីទាំងនោះ ) ក្នុងកាលនោះ ។

[ ៩៦៣ ] ពួកជដិលមានបបូរមាត់ខាងលើវែង មានធ្មេញ ប្រកបដោយមន្ទិល មានធូលីលើក្បាល នឹងទៅទារបំណុល ( ក្នុងកាលណា ) ឆ្កែខ្មៅនឹងរបូត ( ស៊ុះទៅស៊ីនូវជដិលទាំង នោះ ) ក្នុងកាលនោះ ។

[ ៩៦៤ ] ពួកព្រាហ្មណ៍បានរៀនវេទទាំងឡាយផង សាវិត្តិ-សាស្ត្រផង យញ្ញសូត្រក្នុងសាវិត្តិសាស្ត្រនោះផង នឹងបូជាដើម្បីថ្ងៃឈ្នួល ( ក្នុងកាលណា ) ក្អែខ្មៅនឹងរបូត ( ស្ទុះទៅស៊ីនូវព្រាហ្មណ៍ទាំងនោះ ) ក្នុងកាលនោះ ។

[ ៩៦៥ ] ពួកជនអ្នកមានទ្រព្យច្រើន នឹងមិនចិញ្ចឹមមាតាបិតាដែលជរា មានវ័យកន្លងហើយ ( ក្នុងកាលណា ) ក្អែខ្មៅនឹងរបូត ( ស្ទុះទៅស៊ីនូវជនអ្នកមានទ្រព្យទាំងនោះ ) ក្នុងកាលនោះ ។

[ ៩៦៦ ] ពួកជននឹងនិយាយទៅកាន់មាតាបិតាដែលជរា មានវ័យកន្លងហើយថា អ្នកទាំងឡាយ ជាមនុស្សពាលដូច្នេះ ( ក្នុងកាលណា ) ក្អែខ្មៅនឹងរបូត ( ស្ទុះទៅស៊ីនូវជនទាំងនោះ ) ក្នុងកាលនោះ ។

[ ៩៦៧ ] ពួកជនប្រព្រឹត្ត ( សេវនកិច្ច ) នឹងភរិយារបស់អាចារ្យ ភរិយារបស់សម្លាញ់ ម្តាយធំ ម្តាយមីងខាងម្តាយ ម្តាយធំ ម្តាយមីងខាងឪពុកក្នុងលោក ក្នុងកាលណា ក្អែខ្មៅនឹងរបូត ( ស្ទុះទៅស៊ីនូវជនទាំងនោះ ) ក្នុងកាលនោះ ។

[ ៩៦៨ ] ពួកព្រាហ្មណ៍កាន់ដាវ និងខែល ឆាព្រះខ័ន ធ្វើនូវការសម្លាប់នូវអ្នកដើរផ្លូវក្នុងកាលណា ក្អែខ្មៅនឹងរបូត ( ស្ទុះទៅស៊ីនូវពួកព្រាហ្មណ៍ទាំងនោះ ) ក្នុងកាលនោះ ។

[ ៩៦៩ ] ពួកបុរសមានស្បែកសម្បុរថ្ងៃសស្អាត មានដើមដៃថ្លោស មានអាជីវៈមិនប្រាកដ មានពុំទៀរនឹងស្រ្តីមេម៉ាយ នឹងធ្វើនូវការបំបែកមិត្ត ( ក្នុងកាលណា ) ក្អែខ្មៅនឹងរបូត ( ស្ទុះទៅស៊ីនូវបុរសនោះ ) ក្នុងកាលនោះ ។

[ ៩៧០ ] ពួកជនអ្នកមានមាយា ជាអ្នកបោកប្រាស មានគំនិតជាអសប្បុរសនឹងមានក្នុងលោក ( ក្នុងកាលណា ) ក្អែខ្មៅនឹងរបូត ( ស្ទុះទៅស៊ីនូវជនមានមាយាទាំងនោះ ) ក្នុងកាលនោះ ។

មហាកណ្ហជាតកទី ៦ ចប់

# អដ្ឋកថា

## មហាកណ្ហជាតក

[ ៩៥៩-៩៧០ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការប្រព្រឹត្តប្រយោជន៍ដល់សត្វលោក ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **កណ្ហោ កណ្ហោ ច ឃោរោ ច** ដូច្នេះជាដើម ។

សេចក្តីពិស្តារថា ថ្ងៃមួយ ភិក្ខុទាំងឡាយអង្គុយក្នុងធម្មសភា ពណ៌នាដល់ព្រះគុណរបស់ព្រះទសពល ដែលទ្រង់ប្រព្រឹត្តប្រយោជន៍ដល់សត្វលោកថា អាវុសោទាំងឡាយ ព្រះសាស្តាទ្រង់បដិបត្តិដើម្បីប្រយោជន៍ដល់ជនជាច្រើន ទ្រង់លះនូវផាសុកផ្ទាល់ព្រះអង្គ ទ្រង់ប្រព្រឹត្តប្រយោជន៍ដល់សត្វ-លោកដោយចំណែកមួយ ចាប់តាំងអំពីសម្រេចព្រះបរមាភិសម្ពោធិញ្ញាណហើយ ទ្រង់កាន់បាត្រចីវរដោយព្រះអង្គឯង ទ្រង់ពុទ្ធដំណើរអស់ចម្ងាយផ្លូវ ១៨ យោជន៍ ទ្រង់បន្លិលធម្មចក្រឲ្យប្រព្រឹត្តទៅដល់បញ្ចវគ្គិយភិក្ខុ ក្នុងតិថីទី ៥ នៃបក្ខ ត្រាស់អនត្តលក្ខណសូត្រ ប្រទានអរហត្តដល់ព្រះថេរៈជាបញ្ចវគ្គិយទាំងអស់ ហើយយាងទៅឧរុវេលាបទេស ទ្រង់សម្តែងព្រះបាដិហារ្យ ៣៥០០ ដល់ជដិល ៣ នាក់បងប្អូន ឲ្យបព្វជ្ជាហើយ នាំទៅគយាសីសបទេស ទ្រង់សម្តែងអាទិត្តបរិយាយសូត្រ ប្រទានអរហត្តដល់ជដិល ១០០០ យាងទៅទទួលព្រះមហាកស្សបៈអស់ចម្ងាយផ្លូវ ៣ គាវុត ប្រទានឧបសម្បទា ដោយឱវាទ ៣ ។ សម័យមួយ ក្រោយបច្ឆាភត្ត ទ្រង់យាងចូងមាគាតែមួយព្រះអង្គឯងអស់ចម្ងាយផ្លូវ ៤៥ យោជន៍ ឲ្យបុក្កុសាតិកុលបុត្រ តាំងនៅក្នុងអនាគាមិផលយាងទៅទទួលព្រះមហាកប្បិន អស់ចម្ងាយផ្លូវ ១២០ យោជន៍ ប្រទាននូវ

អរហត្ត ។ ក្នុងពេលមួយ ក្នុងពេលបច្ឆាភត្ត ទ្រង់យាងតាមមាគ៌ាតែមួយព្រះអង្គឯង អស់ចម្ងាយផ្លូវ ៣០ យោជន៍ បានឲ្យអង្គុលិមាល ដែលជាបុគ្គលគ្រោតគ្រាត តាំងនៅក្នុងអរហត្ត ។ ក្នុងពេលមួយ ទ្រង់យាងតាមមាគ៌ា អស់ ៣០ យោជន៍ ប្រោសអាឡវកយក្ខ ឲ្យតាំងនៅក្នុងសោតាបត្តិផល ទ្រង់ធ្វើនូវសួស្តីដល់កុមារដែលជាអាហារយក្ខ ។ ពេលមួយ ទ្រង់ចាំវស្សាក្នុងតាវត្តិង្សភព អស់ ៣ ខែ ឲ្យទេវតា ៨០ កោដិសម្រេចធម្មាភិសម័យ ហើយយាងទៅកាន់ព្រហ្មលោក ទម្លាយនូវទិដ្ឋិរបស់ពួកព្រហ្ម ប្រទានអរហត្តដល់ពួកព្រហ្ម ១ ម៉ឺនរូប ទ្រង់ចារិកទៅ ៣ មណ្ឌល រាល់ៗ ឆ្នាំ ប្រទានសរណៈ និងសីលដល់ពួកមនុស្សដែលមានឧបនិស្ស័យសម្បូរ ទ្រង់ប្រព្រឹត្តប្រយោជន៍ មានប្រការផ្សេងៗ ដល់នាគ និងគ្រុឌជាដើម ។

ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អំបាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតសម្រេចនូវអភិសម្ពោធិញ្ញាណហើយ ប្រព្រឹត្តប្រយោជន៍ដល់សត្វលោកក្នុងកាលឥឡូវនេះ មិនជាអស្ចារ្យឡើយ សូម្បីក្នុងកាលមុន កាលតថាគតនៅមានកិលេស មានរាគៈជាដើម ក៏បានប្រព្រឹត្តប្រយោជន៍ដល់សត្វលោកមកហើយដូចគ្នា ទើបទ្រង់នាំអតីតនិទានមកសាធកៈដូចតទៅ

ក្នុងអតីតកាល ក្នុងសាសនាព្រះកស្សបសម្មាសម្ពុទ្ធ ព្រះបាទឧសិន្នររាជ[១] សោយរាជសម្បត្តិក្នុងនគរពារាណសី កាលព្រះកស្សបសម្ពុទ្ធ ដោះនូវមហាជនឲ្យផុតគ្រឿងចង គឺកិលេស ដោយចតុរារិយសច្ចទេសនា ធ្វើព្រះនគរ គឺព្រះនិព្វានឲ្យពេញហើយ ទ្រង់បរិនិព្វានក្នុងកាលកន្លងមក សាសនាក៏សាបសូន្យ ភិក្ខុទាំងឡាយ ចិញ្ចឹមជីវិតដោយអនេសនា ២១ ប្រការ ធ្វើនូវការប្រឡូកប្រឡំជាមួយពួកភិក្ខុនី រហូតមានបុត្រធីតា ភិក្ខុ ភិក្ខុនី ឧបាសក និងព្រាហ្មណ៍ លះនូវធម៌របស់ខ្លួនចោលដោយច្រើន ពួកមនុស្សប្រព្រឹត្តអកុសលកម្មបថ ១០ បុគ្គលដែលស្លាប់ទៅ ទើបកុះករក្នុងអបាយ ។

កាលនោះ សក្កទេវរាជមិនឃើញទេវបុត្រថ្មី ទើបប្រមើលមើលមនុស្សលោក ទ្រង់ជ្រាបថា ពួកមនុស្សលោកទៅកើតក្នុងអបាយ ទ្រង់សម្លឹងឃើញសាសនារបស់ព្រះសាស្តាវិនាសសាបសូន្យ ទ្រង់ត្រិះរិះថា នឹងធ្វើដូចម្តេចល្អហ្ន៎ ទ្រង់ឃើញឧបាយមួយ ទើបសម្រេចព្រះហឫទ័យថា អញត្រូវធ្វើឲ្យមហាជនខ្លាច តក់ស្លុត ហើយសឹមសម្តែងធម៌ លើកនូវសាសនាដែលវិនាសហើយ ឲ្យគង់វង្សទៅបានមួយពាន់ឆ្នាំទៀត ត្រាស់ឲ្យមាតលិទេវបុត្រ កាឡាខ្លួនជាឆ្កែខ្មៅ ធំប៉ុនសេះអាជានេយ្យ មានរូបរាងគួរខ្លាច មានចង្កូមប៉ុនៗ ផ្លែចេក មានរស្មី ក្តៅដូចភ្លើងផ្សាយចេញអំពីចង្កូមទាំង ៤ មានរូបគួរខ្លាច ស្រីមានគភ៌ឃើញ អាចរលូតកូន មានខ្សែចង ៥ កន្លែង គឺត្រង់ជើងទាំង ៤ និងត្រង់ក លើក្បាលប្រដាប់ដោយកម្រងផ្កាក្រហម ។ សក្កទេវរាជកាឡាខ្លួន

---

១- បិដកខ្មែរជា ឧសិន្នរៈ ។

ជាព្រានព្រៃ កាន់ចុងខ្សែ ស្លៀកសំពត់ជ្រលក់ដោយទឹកអម្ចត់ពីរផ្ទាំង បួង សក់ខាងក្រោយ ហើយប្រដាប់ដោយកម្រងផ្កាក្រហម កាន់ធ្នូធំ មានខ្សែ ដូចកែវប្រពាល គ្រវីវជិរាវុធដែលជាអាវុធបន្សាត់ទៅដោយក្រចក ហោះចុះ ខាងចុងព្រះនគរចម្ងាយមួយយោជន៍ ស្រែកខ្ទាំងៗ ៣ ដងថា នែអ្នកដ៏ចម្រើន ទាំងឡាយ ទ្វីបលោកនឹងវិនាស ធ្វើឲ្យមនុស្សទាំងឡាយតក់ស្លុត ហើយទៅ ត្រង់ព្រះនគរ បន្លឺសំឡេងឡើងទៀត ពួកមនុស្សឃើញឆ្កែនោះក៏តក់ស្លុត នាំ គ្នាចូលព្រះនគរ ក្រាបទូលការប្រព្រឹត្តទៅ ឲ្យព្រះរាជាទ្រង់ជ្រាប ព្រះរាជា ត្រាស់ឲ្យបិទទ្វារព្រះនគរដោយប្រញាប់ សក្កទេវរាជបានលោតផ្លោះកំពែង ដែលមានកម្ពស់ ១៨ ហត្ថ ចូលទៅខាងក្នុងព្រះនគរជាមួយឆ្កែ ពួកមនុស្ស តក់ស្លុត នាំគ្នាគេចចូលផ្ទះបិទទ្វារ ចំណែកឆ្កែខ្មៅ ក៏រត់ដេញពួកមនុស្សដែល ខ្លួនបានឃើញ ធ្វើឲ្យពួកមនុស្សតក់ស្លុត ទៅកាន់ព្រះរាជនិវេសន៍ ។

ពួកមនុស្សត្រង់លានរាជវាំង នាំគ្នារត់ទៅដោយសេចក្តីខ្លាច ចូលព្រះ រាជនិវេសន៍ហើយបិទទ្វារ សូម្បីព្រះបាទឧសិន្នររាជ ក៏នាំស្រីស្នំទាំងឡាយ ឡើងប្រាសាទ ឆ្កែខ្មៅធំយកជើងមុខតោងសន្ទះទ្វារហើយព្រុស សំឡេងកង រំពង ខាងក្រោមលាន់ឮដល់អវិចី ខាងលើដល់ភវគ្គព្រហ្ម សកលចក្កវាឡ ខ្ទរខ្ទារទូទៅដូចគ្នាទាំងអស់ ។ សំឡេងបែបនេះ មានក្នុងជម្ពូទ្វីប ៤ ដង គឺ សំឡេងបុណ្ណកយក្ខ ក្នុងបុណ្ណកជាតក ( វិធុរជាតក ) ម្តង សំឡេងរបស់ ព្រះបាទកុសរាជ ក្នុងកុសជាតកម្តង សំឡេងរបស់ព្រះបាទសុទស្សននាគរាជ ក្នុងភូរិទត្តជាតកម្តង សំឡេងក្នុងមហាកណ្ហជាតកម្តង ។ ពួកអ្នកនគរនាំគ្នា

តក់ស្លុត សូម្បីបុរសម្នាក់ ក៏មិនអាចចរចាជាមួយសក្កទេវរាជបាន ។

ព្រះរាជាប៉ុណ្ណោះ ទ្រង់តាំងសតិមាំទាំ បើកបង្អួចហៅសក្កទេវរាជមកត្រាស់ថា នែព្រានដ៏ចម្រើន ឆ្កែរបស់អ្នកព្រុសដើម្បីអ្វី សក្កទេវរាជឆ្លើយថា ព្រុសដោយឃ្លាន ព្រះរាជាត្រាស់ថា បើដូច្នោះ យើងនឹងឲ្យបាយដល់សុនខ ហើយត្រាស់ឲ្យមនុស្សយកបាយ ដែលចម្អិនសម្រាប់មនុស្សក្នុងរាជសម្នាក់ និងសម្រាប់ទ្រង់ទាំងអស់ ឲ្យដល់ឆ្កែ ។ ឆ្កែបានធុំបាយទាំងអស់នោះ ធ្វើឲ្យជាបាយមួយដុំ ហើយក៏ព្រុសទៀត ។ ព្រះរាជាត្រាស់សួរទៀត ក៏បានឮថា ឆ្កែរបស់ទូលបង្គំនៅតែឃ្លាន ទើបត្រាស់ឲ្យនាំអាហារដែលចម្អិនសម្រាប់ដំរីសេះជាដើមទាំងអស់មកឲ្យ ឆ្កែបានស៊ីតែមួយមាត់ដូចគ្នា ហើយទ្រង់ត្រាស់ឲ្យយកអាហារដែលចម្អិនសម្រាប់ព្រះនគរទាំងមូល ឆ្កែបានស៊ីអាហារនោះដោយទំនងនោះឯង ហើយក៏ព្រុសទៀត ព្រះរាជាទ្រង់តក់ស្លុត បានព្រះតម្រិះថា ឆ្កែនេះប្រហែលជាមិនមែនឆ្កែ ពិតជាយក្ខដោយឥតសង្ស័យ អញនឹងសួរហេតុដែលមករបស់ព្រាននេះ កាលនឹងត្រាស់សួរ ទើបត្រាស់គាថាទី ១ ថា

> ម្នាលអ្នកមានព្យាយាម ឆ្កែរបស់អ្នកខ្មៅណាស់ គួរស្បើម មានចង្កូមសស្គាច អ្នកចងដោយខ្សែ ៥ តើវាមានប្រយោជន៍អ្វី ដល់អ្នក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កណ្ហោ កណ្ហោ** សេចក្តីថា បញ្ចេញសំឡេងដដែលដោយអំណាចការខ្លាច ឬដោយអំណាចការធ្វើឲ្យមាំ ។ បទថា **ឃោរោ** បានដល់ ឲ្យកើតនូវការខ្លាច ដល់បុគ្គលអ្នកបានឃើញ ។ បទថា

**បទភាជនីយ** សេចក្តីថា មានកម្តៅក្តៅ ដោយរស្មីដែលផ្សាយចេញអំពីចង្កូមទាំងឡាយ ។ បទថា **កឹ វីរ** សេចក្តីថា ព្រះរាជាត្រាស់យ៉ាងនោះ ដោយបំណងថា នែបុរសអ្នកមានសេចក្តីព្យាយាម ខ្លាកាចរបស់អ្នកបែបនេះ ធ្វើអ្វី វាចាប់ម្រឹគស៊ី ឬចាប់សត្រូវឲ្យអ្នក អ្នកបំណងប្រយោជន៍អ្វីដោយខ្លានេះ ចូរលែងវាទៅចុះ ។

សក្កទេវរាជទ្រង់បានស្តាប់ដូច្នោះ ទើបត្រាស់គាថាទី ២ ថា

បពិត្រព្រះបាទឧសិន្នរៈ ខ្លានេះ មិនមកដើម្បីប្រយោជន៍ដល់ពួកម្រឹគទេ ខ្លាខ្មៅបំផ្លិចបំផ្លាញនូវពួកមនុស្ស ក្នុងកាលណានឹងរបូតទៅ ( អំពីដៃខ្ញុំ ) ក្នុងកាលនោះ ដូច្នេះ ។

ពាក្យដែលជាគាថានោះ មានអធិប្បាយថា ខ្លានេះ មិនបានមកក្នុងទីនេះ ដោយបំណងនឹងស៊ីម្រឹគ ព្រោះដូច្នោះ មិនមានប្រយោជន៍សម្រាប់ពួកម្រឹគ តែមកដើម្បីស៊ីសាច់មនុស្ស ព្រោះដូច្នោះ ទើបជាខ្លាដែលធ្វើសេចក្តីវិនាសឲ្យដល់មនុស្សទាំងនោះ កាលណាខ្លានោះធ្វើនូវពួកមនុស្ស ឲ្យដល់នូវសេចក្តីវិនាស កាលនោះ ខ្លាខ្មៅនេះ រមែងរបូត គឺនឹងរបូតចាកដៃរបស់ខ្ញុំ ទៅស៊ីបុគ្គលនោះ ។

លំដាប់នោះ ព្រះរាជាត្រាស់សួរសក្កទេវរាជថា នែព្រានដ៏ចម្រើន ខ្លាខ្មៅរបស់អ្នក ស៊ីសាច់មនុស្សគ្រប់គ្នា ឬស៊ីតែបុគ្គលដែលជាសត្រូវរបស់អ្នកតែប៉ុណ្ណោះ សក្កទេវរាជឆ្លើយថា បពិត្រព្រះរាជាជាធំ ខ្លានឹងស៊ីសាច់មនុស្សដែលមិនមែនមិត្ររបស់ខ្ញុំប៉ុណ្ណោះ ព្រះរាជាត្រាស់សួរថា បុគ្គលដូចម្តេចដែល

មិនមែនជាមិត្ររបស់អ្នកក្នុងទីនេះ សក្កទេវរាជឆ្លើយថា បុគ្គលដែលត្រេកអរក្នុងអធម៌ មានការប្រព្រឹត្តមិនរៀបរយ ឈ្មោះថា ជាបុគ្គលមិនមែនមិត្រ ព្រះរាជាត្រាស់ថា សូមអ្នកពោលលក្ខណៈមនុស្សទាំងនោះ ឲ្យយើងដឹងសិន ។

លំដាប់នោះ សក្កទេវរាជ កាលត្រាស់ប្រាប់ដល់ព្រះរាជា បានត្រាស់ ១០ គាថាថា

ពួកសមណៈត្រងោល មានបាត្រក្នុងដៃ ឃ្លុំសង្ឃាដិ នឹងក្អួររាស់ដោយនង្គ័លទាំងឡាយ ( ក្នុងកាលណា ) ក្អែខ្មៅ នឹងរបូត ( ស្ទុះទៅស៊ីនូវសមណៈទាំងនោះ ) ក្នុងកាលនោះ ។

ពួកភិក្ខុនីមានតបៈ ជាអ្នកបួសត្រងោល ឃ្លុំសង្ឃាដិ នឹងទៅ ( បរិភោគកាម ) ក្នុងលោក ក្នុងកាលណា ក្អែខ្មៅ នឹងរបូត ( ស្ទុះទៅស៊ីនូវនាងភិក្ខុនីទាំងនោះ ) ក្នុងកាលនោះ ។

ពួកជដិលមានបបូរមាត់ខាងលើវែង មានធ្មេញ ប្រកបដោយមន្ទិល មានធូលីលើក្បាល នឹងទៅទារបំណុល ( ក្នុងកាលណា ) ក្អែខ្មៅនឹងរបូត ( ស្ទុះទៅស៊ីនូវជដិលទាំងនោះ ) ក្នុងកាលនោះ ។

ពួកព្រាហ្មណ៍បានរៀនវេទទាំងឡាយផង សាវិត្តិសាស្ត្រផង យញ្ញសូត្រក្នុងសាវិត្តិសាស្ត្រនោះផង នឹងបូជាដើម្បីថ្លៃឈ្នួល ( ក្នុងកាលណា ) ក្អែខ្មៅ នឹងរបូត ( ស្ទុះទៅស៊ីនូវព្រាហ្មណ៍ទាំងនោះ ) ក្នុងកាលនោះ ។

ពួកជនអ្នកមានទ្រព្យច្រើន នឹងមិនចិញ្ចឹមមាតាបិតាដែលជរា មាន

វ័យកន្លងហើយ ( ក្នុងកាលណា ) ភ្លៀងខ្មៅ នឹងរបួត ( សុះទៅស៊ីនូវជនអ្នកមានទ្រព្យទាំងនោះ ) ក្នុងកាលនោះ ។

ពួកជននឹងនិយាយទៅកាន់មាតាបិតាដែលជរា មានវ័យកន្លងហើយថា អ្នកទាំងឡាយ ជាមនុស្សពាលដូច្នេះ ( ក្នុងកាលណា ) ភ្លៀងខ្មៅនឹងរបួត ( សុះទៅស៊ីនូវជនទាំងនោះ ) ក្នុងកាលនោះ ។

ពួកជនប្រព្រឹត្ត ( សេវនកិច្ច ) នឹងភរិយារបស់អាចារ្យ ភរិយារបស់សម្លាញ់ ម្ដាយធំ ម្ដាយមីងខាងម្ដាយម្ដាយធំ ម្ដាយមីងខាងឪពុកក្នុងលោក ក្នុងកាលណា ភ្លៀងខ្មៅនឹងរបួត ( សុះទៅស៊ីនូវជនទាំងនោះ ) ក្នុងកាលនោះ ។

ពួកព្រាហ្មណ៍កាន់ដាវ និងខែល ឆាព្រះខ័ន ធ្វើនូវការសម្លាប់នូវអ្នកដើរផ្លូវក្នុងកាលណា ភ្លៀងខ្មៅនឹងរបួត ( សុះទៅស៊ីនូវពួកព្រាហ្មណ៍ទាំងនោះ ) ក្នុងកាលនោះ ។

ពួកបុរសមានស្បែកសម្បុរថ្លៃសស្អាត មានដើមដៃថ្លោស មានអាជីវៈមិនប្រាកដ មានពុំនៀរនឹងស្ត្រីមេម៉ាយ នឹងធ្វើនូវការបំបែកមិត្ត ( ក្នុងកាលណា ) ភ្លៀងខ្មៅនឹងរបួត ( សុះទៅស៊ីនូវបុរសនោះ ) ក្នុងកាលនោះ ។

ពួកជនអ្នកមានមាយា ជាអ្នកបោកប្រាស មានគំនិតជាអសប្បុរសនឹងមានក្នុងលោក ( ក្នុងកាលណា ) ភ្លៀងខ្មៅនឹងរបួត ( សុះទៅស៊ីនូវជនមានមាយាទាំងនោះ ) ក្នុងកាលនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សមណាកា** សេចក្តីថា សក្កទេវរាជត្រាស់យ៉ាងនេះដោយវោហាររង្កៀស ដោយត្រឹមតែប្តេជ្ញាខ្លួនថា ពួកយើងជាសមណៈ ។ បទថា **កសិស្សន្តិ** សេចក្តីថា បុគ្គលទាំងនោះ រមែងធ្វើស្រែធ្វើចម្ការចិញ្ចឹមជីវិតតែម្យ៉ាង ក្នុងកាលនោះ សក្កៈធ្វើដូចជាមិនដឹង ទើបពោលយ៉ាងនេះ ។ ពិតហើយ សក្កទេវរាជមានបំណងដូច្នេះថា បុគ្គលបែបនេះ គឺបែបនេះ ជាបុគ្គលទ្រុស្តសីល មិនមែនជាមិត្ររបស់យើង កាលណាឆ្កែរបស់យើងនឹងខាំស៊ីសាច់បុគ្គលនេះ កាលនោះ ឆ្កែខ្មៅនេះរមែងរបូតផុតអំពីចំណង គឺខ្សែទាំង ៥ សរសៃនេះ គប្បីជ្រាបពាក្យប្រកបអធិប្បាយក្នុងគាថាទាំងពួង ដោយឧបាយនេះ ។ បទថា **បព្វជិតា** បានដល់ ជាអ្នកបួសក្នុងព្រះពុទ្ធសាសនា ។ បទថា **គមិស្សន្តិ** សេចក្តីថា ត្រាច់បរិភោគកាមគុណ ៥ ក្នុងកណ្តាលផ្ទះ ។ បទថា **ទីឃុត្តរោដ្ឋា** សេចក្តីថា ឈ្មោះថា មានពុកមាត់វែង ព្រោះមានពុកមាត់ពុកចង្ការស្អេកស្កះ ។ បទថា **បង្កទន្តា** បានដល់ មានធ្មេញប្រកបដោយមន្ទិល ដូចភក់ ។ បទថា **ឥណំ ចោទាយ** សេចក្តីថា ប្រមូលទ្រព្យដោយការដើរសូម ឲ្យខ្ចីនូវបំណុលដើម្បីការប្រាក់ ត្រេកអរក្នុងការធ្វើយ៉ាងនោះ ចិញ្ចឹមជីវិតដោយទ្រព្យ ដែលបានមកអំពីការឲ្យខ្ចីបុលចិញ្ចឹមជីវិតនោះក្នុងកាលណា ។ បទថា **សាវិត្តឹ** បានដល់ រៀននូវវេទ គឺសាវិត្តិសាស្ត្រ ។ បទថា **យញ្ញំ តត្រញ្ញុ** បានដល់ រៀននូវយញ្ញវិធី និងយញ្ញ-សូត្រក្នុងយញ្ញពិធីនោះ ។ បទថា **ភតិកាយ** សេចក្តីថា ពួកព្រាហ្មណ៍ទាំងនោះ ចូលទៅរកព្រះរាជា និងរាជមហាមាត្យ ហើយបូជាយញ្ញ ដើម្បីត្រូវការ

ថ្ងៃឈ្នួលយ៉ាងនេះថា យើងនឹងបូជាយញ្ញដើម្បីលោក សូមលោកឲ្យទ្រព្យដល់យើង ។ បទថា **បហុសណ្ឋា** សេចក្តីថា ជាអ្នកអាចដើម្បីចិញ្ចឹម ។ បទថា **ពាលា តុម្ហេ** សេចក្តីថា រមែងពោលពាក្យជាដើមថា អ្នកទាំងឡាយជាបុគ្គលពាលមិនដឹងអ្វី ។ បទថា **គមិស្សន្តិ** សេចក្តីថា នឹងទៅដោយអំណាចការសេពមោក្ខធម៌ ។ បទថា **បន្ថឃាតំ** សេចក្តីថា ឈរនៅក្នុងផ្លូវហើយប្លន់សម្លាប់មនុស្ស ដណ្តើមយកទ្រព្យរបស់មនុស្សទាំងនោះ ។ បទថា **សុក្កច្ឆវី** សេចក្តីថា មានពណ៌សម្បុរសដែលកើតអំពីការដុសខាត់ដោយលម្អិត និងទឹកចត់ជាដើម ។ ក្នុងបទថា **វេធវេរា** មានវិគ្គហៈថា ដែលឈ្មោះថា **វេធវេរា** ព្រោះអត្ថថា ប្រព្រឹត្តពាំនៀរជាមួយស្រីមេម៉ាយ គឺស្រីប្តីស្លាប់ទាំងនោះ ។ បទថា **ថូលពាហូ** សេចក្តីថា មានរាងកាយធាត់ ដោយការទំនុកបម្រុងរាងកាយជាដើម មានការគក់ច្របាច់ជើងជាដើម ។ បទថា **អធាតុកា** សេចក្តីថា ព្រោះមិនប្រាកដ អធិប្បាយថា ព្រោះមិនធ្វើទ្រព្យឲ្យកើត ។ បទថា **មិត្តភេទំ** បានដល់ ទម្លាយនូវមិត្រ ។ ម្យ៉ាងទៀត បាលីក៏យ៉ាងនេះដូចគ្នា ។ លោកអធិប្បាយពាក្យនេះថា កាលណាអ្នកលេងស្រីបែបនេះគិតថា ស្រីទាំងនេះ នឹងមិនលះបង់ពួកយើង ទើបចូលទៅរកស្រីមេម៉ាយដែលមានប្រាក់ រួមសង្វាសគ្នា បំផ្លាញទ្រព្យរបស់ស្រីទាំងនោះ ទម្លាយមិត្រជាមួយស្រីទាំងនោះ ទម្លាយការស្និទ្ធស្នាល ទៅរកស្រីដទៃដែលមានទ្រព្យតទៅ កាលនោះ ក្តៅខ្លោនេះ នឹងរបូតទៅស៊ីមនុស្សទាំងអស់នោះដែលជាចោរ ។ បទថា **អសប្បុរិសចិន្តិកា** សេចក្តីថា មានប្រក្រតីគិតដូច

អសប្បុរស គឺគិតប្រទូស្តអ្នកដទៃ កាលនោះ ភ្លើងខ្មៅនឹងរបូតចេញ សម្រាប់ជនទាំងនោះ ទំពាស៊ីសាច់នោះឯង ។

កាលត្រាស់យ៉ាងនេះហើយ សក្កទេវរាជបានត្រាស់ថា បពិត្រមហារាជ មនុស្សទាំងនេះមិនមែនមិត្ររបស់ខ្ញុំ ហើយទ្រង់បង្ហាញសុនខ ធ្វើជាចង់រត់ទៅខាំពួកជនអធម៌នោះៗ ខណៈនោះ មហាជនមានចិត្តតក់ស្លុត សក្កទេវរាជធ្វើជាទាញខ្សែយោគសុនខនោះ ហើយលះភេទជាព្រាន ហោះឡើងទៅក្នុងអាកាសដូចព្រះអាទិត្យរះឡើងរុងរឿង ដោយអានុភាពរបស់ទ្រង់ ហើយត្រាស់ថា បពិត្រមហារាជ ខ្ញុំ គឺសក្កទេវរាជមកដោយឃើញថា លោកនេះនឹងវិនាសព្រោះឥឡូវនេះ មហាជននាំគ្នាប្រមាទប្រព្រឹត្តអធម៌ ស្លាប់ទៅទៅកកកុញក្នុងអបាយ ទេវលោកស្ងាត់ទទេ តាំងអំពីនេះទៅ ខ្ញុំនឹងដឹងវត្តុដែលគួរធ្វើសម្រាប់បុគ្គលដែលមិនប្រព្រឹត្តធម៌ សូមទ្រង់ជាអ្នកមិនប្រមាទចុះ ហើយសម្តែងធម៌ដោយព្រះគាថា ដែលមានតម្លៃរាប់រយ ៤ គាថា ឲ្យមនុស្សទាំងឡាយតាំងនៅក្នុងទាន និងសីល ធ្វើសាសនាដែលថមថយ ឲ្យអាចប្រព្រឹត្តទៅបានមួយពាន់ឆ្នាំទៀត ហើយនាំមាតលីទេវបុត្រយាងទៅកាន់វិមានរបស់ទ្រង់វិញ ។ មហាជននាំគ្នាបំពេញបុណ្យទាំងឡាយ មានទាន និងសីលជាដើម ហើយកើតក្នុងទេវលោក ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះ មកសម្តែងហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតប្រព្រឹត្តប្រយោជន៍ដល់សត្វលោក ក្នុងកាលមុនយ៉ាងនេះ ហើយទ្រង់ប្រជុំជាតកថា មាតលីទេវបុត្រក្នុងកាលនោះ បានមកជាអានន្ទ ក្នុងកាលឥឡូវនេះ ចំណែកសក្កទេវរាជ ក្នុងកាលនោះ គឺតថាគតនេះឯង ។ល។

## អដ្ឋកថា មហាកណ្ហជាតក ចប់

# សុត្តន្តបិដក

## កោសិយជាតក

[ ៩៧១ ] ( កោសិយសេដ្ឋីពោលថា ) ខ្ញុំមិនទិញមិនលក់ទេ ម្យ៉ាងទៀត ការសន្សំ ( នូវទ្រព្យ ) របស់ខ្ញុំ ក៏មិនមានក្នុងទីនេះដែរ បាយនេះតិច មានសភាពក្រក្រៃពេក បាយអង្ករ ១ កំបង់នេះ មិនល្មមដល់ជនពីរនាក់ទេ ។

[ ៩៧២ ] ( សក្កទេវរាជពោលថា ) បុគ្គលគប្បីឲ្យវត្ថុតិច អំពីវត្ថុតិច គប្បីឲ្យវត្ថុពាក់កណ្តាល អំពីវត្ថុពាក់កណ្តាល គប្បីឲ្យវត្ថុច្រើន អំពីវត្ថុច្រើន ការមិនឲ្យមិនកើតទេ ។ ម្នាលកោសិយសេដ្ឋី ហេតុនោះ ខ្ញុំសូមនិយាយនឹងអ្នក អ្នកចូរឲ្យទានទាំងឡាយផង ចូរបរិភោគផង ចូរឡើងកាន់អរិយមគ្គផង បុគ្គលស៊ីម្នាក់ឯងមិនបានសេចក្តីសុខទេ ។

[ ៩៧៣ ] ( ចន្ទទេវបុត្រពោលថា ) បុគ្គលណា កាលដែលភ្ញៀវអង្គុយហើយ បរិភោគភោជនតែម្នាក់ឯង ការបូជារបស់បុគ្គលនោះឈ្មោះថាឥតអំពើផង ការព្យាយាមញុំាងទ្រព្យឲ្យកើតរបស់បុគ្គលនោះឈ្មោះថាឥតអំពើផង ។ ម្នាលកោសិយសេដ្ឋី ហេតុនោះ ខ្ញុំសូមនិយាយនឹងអ្នក អ្នកចូរឲ្យទានទាំងឡាយផង ចូរបរិភោគផង ចូរឡើងកាន់អរិយមគ្គផង បុគ្គលស៊ីម្នាក់ឯងមិនបានសេចក្តីសុខទេ ។

[ ៩៧៤ ] ( សុរិយទេវបុត្រពោលថា ) បុគ្គលណា កាលដែលភ្ញៀវអង្គុយហើយ មិនបរិភោគភោជនតែម្នាក់ឯង ការបូជារបស់បុគ្គលនោះ ឈ្មោះថា សច្ចៈផង ការព្យាយាមញ៉ាំងទ្រព្យឲ្យកើតរបស់បុគ្គលនោះ ឈ្មោះថា សច្ចៈផង ។ ម្នាលកោសិយសេដ្ឋី ហេតុនោះ ខ្ញុំសូមនិយាយនឹងអ្នក អ្នកចូរឲ្យទានទាំងឡាយផង ចូរបរិភោគផង ចូរឡើងកាន់អរិយមគ្គផង បុគ្គលស៊ីម្នាក់ឯង មិនបានសេចក្តីសុខទេ ។

[ ៩៧៥ ] ( មាតលិទេវបុត្រពោលថា ) បុរស ( ចូលទៅរក ) ស្រះហើយ បូជាក្នុងទន្លេផង ក្នុងស្រះបោក្ខរណីផង ក្នុងកំពង់ឈ្មោះទោណៈផង ក្នុងកំពង់ឈ្មោះតិម្ពរុផង ក្នុងស្ទឹងធំមានខ្សែទឹកដ៏រហ័សផង ។ បុគ្គលណា កាលដែលភ្ញៀវអង្គុយហើយ មិនបរិភោគភោជនតែម្នាក់ឯង ការបូជារបស់បុគ្គលនោះ ឈ្មោះថា មានក្នុងទីនោះផង ការព្យាយាមញ៉ាំងទ្រព្យឲ្យកើតរបស់បុគ្គលនោះ ឈ្មោះថា មានក្នុងទីនោះផង ។ ម្នាលកោសិយសេដ្ឋី ហេតុនោះ ខ្ញុំសូមនិយាយនឹងអ្នក អ្នកចូរឲ្យទានទាំងឡាយផង ចូរបរិភោគផង ចូរឡើងកាន់អរិយមគ្គផង បុគ្គលស៊ីម្នាក់ឯង មិនបានសេចក្តីសុខទេ ។

[ ៩៧៦ ] ( បញ្ចសិខទេវបុត្រពោលថា ) បុគ្គលណា កាលដែលភ្ញៀវអង្គុយហើយ បរិភោគភោជនតែម្នាក់ឯង បុគ្គលនោះ

ឈ្មោះថា លេបនូវសន្ទូចមានខ្សែវែង ព្រមទាំងរនង ។ ម្នាល កោសិយសេដ្ឋី ហេតុនោះ ខ្ញុំសូមនិយាយនឹងអ្នក អ្នកចូរឲ្យទាន ទាំងឡាយផង ចូរបរិភោគផង ចូរឡើងកាន់អរិយមគ្គផង បុគ្គល ស៊ីម្នាក់ឯង មិនបានសេចក្ដីសុខទេ ។

[ ៩៧៧ ] ( កោសិយសេដ្ឋី ... ) ឱហ្ន៎ ព្រាហ្មណ៍ទាំងនេះ មាន វណ្ណៈដ៏លើសលុប ទាំងឆ្កែរបស់ពួកគាត់នេះ ក៏បញ្ចេញនូវពន្លឺ នៃវណ្ណៈផ្សេងៗ តើព្រោះហេតុអ្វី ម្នាលព្រាហ្មណ៍ទាំងឡាយ អ្នកទាំងឡាយ ចូរប្រាប់ដល់យើងចុះ តើពួកអ្នកជាអ្វី ។

[ ៩៧៨ ] ( សក្កទេវរាជ ... ) ទេវបុត្រទាំងពីរអង្គ គឺចន្ទទេវ- បុត្រ ១ សុរិយទេវបុត្រ ១ មកក្នុងទីនេះ ឯទេវបុត្រនេះឈ្មោះ មាតលិ ជាសារថីរបស់ទេវតា យើងឈ្មោះសក្កៈ ជាធំជាងពួក ទេវតាជាន់ត្រៃត្រឹង្ស ឯទេវបុត្រនេះ គេហៅថា បញ្ចសិខៈ ។

[ ៩៧៩ ] សំឡេងទះដៃទាំងឡាយផង សម្ភោរតូចទាំងឡាយ ផង សម្ភោរធំ និងស្គរធំទាំងឡាយផង រមែងញុំាងបញ្ចសិខ- ទេវបុត្រនេះ ដែលដេកលក់ឲ្យភ្ញាក់ឡើង បញ្ចសិខទេវបុត្រនេះ លុះភ្ញាក់ហើយ ក៏ត្រេកអរ ។

[ ៩៨០ ] ពួកជនណានីមួយ ជាអ្នកកំណាញ់ស្វិតស្វាញ ប្រទេច ផ្ដាសានូវសមណៈ និងព្រាហ្មណ៍ទាំងឡាយ លុះទម្លាក់ចោល នូវរាងកាយ គឺសរីរៈក្នុងលោកនេះ បែកធ្លាយរាងកាយហើយ ក៏ទៅកាន់នរក ។

[ ៩៨១ ] ពួកជនណានីមួយ កាលប្រាថ្នានូវសុគតិ ឋិតនៅក្នុងធម៌ ក្នុងសេចក្ដីសង្រួម ក្នុងការចែករំលែក លុះទម្លាក់ចោលរាងកាយ គឺសរីរៈក្នុងលោកនេះ បែកធ្លាយរាងកាយហើយ ក៏ទៅកាន់សុគតិ ។

[ ៩៨២ ] អ្នកជាញាតិរបស់ពួកយើងក្នុងជាតិមុន អ្នកនោះឈ្មោះថា កោសិយៈ ជាអ្នកមានសេចក្ដីកំណាញ់ មានធម៌ដ៏លាមក ពួកយើងមកក្នុងទីនេះ ដើម្បីប្រយោជន៍ដល់អ្នក ( ដោយគិតថា ) កុំឲ្យអ្នកមានធម៌ដ៏លាមក ទៅកាន់នរកឡើយ ។

[ ៩៨៣ ] ( កោសិយសេដ្ឋី ... ) ពួកលោកឈ្មោះថាប្រាថ្នានូវប្រយោជន៍ដល់ខ្ញុំដោយពិត ព្រោះពួកលោក បានប្រៀនប្រដៅខ្ញុំ ខ្ញុំនោះនឹងធ្វើតាមពាក្យទាំងអស់ ដែលពួកលោកជាអ្នកប្រាថ្នានូវប្រយោជន៍ បានពោល ( រម្លឹក ) ហើយដោយប្រការដូច្នោះ ។ ខ្ញុំនេះនឹងវៀរលែង ( ចាកសេចក្ដីកំណាញ់ ) នេះឯង ខ្ញុំនឹងឈប់ធ្វើបាបតិចតួចហើយ ទាំងវត្ថុតិចតួចដែលខ្ញុំមិនគប្បីឲ្យ មិនមាន ខ្ញុំបើមិនបានឲ្យទានទឹក នឹងមិនផឹកទឹកឡើយ ។ បពិត្រវាសវៈ កាលបើខ្ញុំឲ្យទានអស់កាលទាំងពួងយ៉ាងនេះ ភោគៈទាំងឡាយក្នុងទីនេះនឹងអស់ទៅ បពិត្រសក្កៈ តពីនោះទៅ ខ្ញុំនឹងលះបង់កាមទាំងឡាយ តាមសមគួរដល់ចំណែកហើយនឹងបួស ។

**កោសិយជាតកទី ៧ ចប់**

# អដ្ឋកថា

## កោសិយជាតក

[ ៩៧១-៩៨៣ ] ក្នុងកោសិយជាតក មានច្បាស់ក្នុងសុធាភោជនជាតកឯណោះហើយ ។ ល។

**អដ្ឋកថា កោសិយជាតក ចប់**

# សុត្តន្តបិដក

## មេណ្ឌកបញ្ហាជាតក

[ ៩៨៤ ] ( ព្រះបាទវិទេហរាជ្រ្ត ទ្រង់ត្រាស់សួរពួកអ្នកប្រាជ្ញថា ) តាំងពីកាលណាមក ក្នុងលោកនេះ មិនធ្លាប់មានពួកសត្វណាមានជើង ៧[១] យកគ្នាជាសម្លាញ់ឡើយ សត្វទាំងពីរនោះជាសត្រូវនឹងគ្នាទេ ( តែឥឡូវ ) ត្រឡប់ជាយកគ្នាធ្វើជាសម្លាញ់ប្រព្រឹត្តរាប់អានគ្នា តើព្រោះហេតុដូចម្តេច ។

[ ៩៨៥ ] ប្រសិនបើ អ្នកទាំងឡាយ មិនអាចដោះប្រស្នាយើងនុ៎ះ ក្នុងពេលបាយព្រឹក ក្នុងថ្ងៃនេះបានទេ យើងនឹងបំបរបង់អ្នកទាំងអស់គ្នាអំពីដែន ព្រោះយើងមិនត្រូវការ នឹងពួកមនុស្សឥតប្រាជ្ញាឡើយ ។

[ ៩៨៦ ] ( អាចារ្យសេនកៈ បែរមើលទៅពោធិសត្វ ហើយក្រាបទូលព្រះបាទវិទេហរាជ្រ្តថា ) កាលបើមានការប្រជុំនៃមហាជនគគ្រឹកគគ្រេង កាលបើមានការជួបជុំ រជើបរជួលនៃជនកើតឡើងហើយ ( យ៉ាងនេះ ) យើងខ្ញុំមានចិត្តរវើរវាយ មានចិត្តមិននឹងនៅក្នុងអារម្មណ៍តែមួយ មិនអាចឆ្លើយប្រស្នានុ៎ះបានទេ ។

[ ៩៨៧ ] បពិត្រព្រះបាទជនិន្ទ្រាធិរាជ អ្នកប្រាជ្ញទាំងឡាយម្នាក់ៗ មានចិត្តតាំងនៅក្នុងអារម្មណ៍តែមួយ ទៅក្នុងទីស្ងាត់

---

១- ពពែ និងឆ្កែ សត្វទាំងពីរនេះមានជើងបួនៗ តែឆ្កែខ្វចជើងមួយ ។

ហើយ គិតនូវសេចក្ដីទាំងឡាយ ពិចារណានូវកាយវិវេក និង ចិត្តវិវេក ទើបក្រាបទូលសេចក្ដីនុ៎ះ ក្នុងកាលជាខាងក្រោយ បាន ។

[ ៩៨៨ ] ( អាចារ្យសេនកៈក្រាបទូលថា ) សាច់ពពែជាទីពេញចិត្ត ជាទីគាប់ចិត្តរបស់កូនអាមាត្យ និងព្រះរាជបុត្រទាំងឡាយ ពួកកូនអាមាត្យ និងព្រះរាជបុត្រទាំងនោះ មិនបរិភោគសាច់ឆ្កែទេ បានជាពពែ និងឆ្កែយកគ្នាជាសម្លាញ់ ។

[ ៩៨៩ ] ( អាចារ្យបុក្កុសៈទូលថា ) ពួកជនតែងពន្លះស្បែកពពែសម្រាប់ក្រាលលើខ្នងសេះ ព្រោះហេតុចង់ឲ្យស្រួល តែពួកជនទាំងនោះមិនក្រាលស្បែកឆ្កែទេ បានជាពពែ និងឆ្កែយកគ្នាជាសម្លាញ់ ។

[ ៩៩០ ] ( អាចារ្យកាមិន្ទទូលថា ) ពពែមានស្នែងជារង្វង់ ឯឆ្កែគ្មានស្នែងទេ ពពែស៊ីស្មៅឆ្កែស៊ីសាច់ បានជាពពែ និងឆ្កែយកគ្នាជាសម្លាញ់ ។

[ ៩៩១ ] ( អាចារ្យទេវិន្ទទូលថា ) ពពែស៊ីស្មៅ ស៊ីស្លឹកឈើ ឯឆ្កែមិនស៊ីស្មៅ មិនស៊ីស្លឹកឈើទេ ឆ្កែខាំតែទន្សាយ និងសំពោច បានជាពពែ និងឆ្កែយកគ្នាជាសម្លាញ់ ។

[ ៩៩២ ] ( ព្រះមហោសធទូលថា ) សត្វជើង ៧ កន្លះ គឺឆ្កែមានជើង ៣ កន្លះ ពពែមានជើង ៤ មានក្រចក ៨ បន្លំលួចសាច់

ឯក្អែកនេះលួច ( ស្មៅ ) ឲ្យពពែនេះ ពពែនេះ លួចសាច់ឲ្យក្អែក ឯនោះ ។

[ ៩៩៣ ] ឮថា ព្រះបាទវិទេហរាស្ត្រ ជាស្តេចដ៏ប្រសើរ ជាធំជាងជន ស្តេចគង់នៅលើប្រាសាទដ៏ប្រសើរ ទ្រង់ទតឃើញជាក់ច្បាស់នូវការផ្លាស់ប្តូរភោជន ដល់គ្នានិងគ្នាទុំះ របស់ក្អែក និងពពែ ដែលដើរទៅលួចអាហារ ពេញមាត់មកឲ្យគ្នាបរិភោគ ។

[ ៩៩៤ ] ( ព្រះបាទវិទេហរាស្ត្រ ទ្រង់មានព្រះរាជឱង្ការថា ) យើងហៅពេញជាមានលាភ មានសភាពមិនតិចទេ ព្រោះអ្នកប្រាជ្ញទាំងឡាយបែបនេះ មាននៅក្នុងត្រកូលរបស់យើង អ្នកប្រាជ្ញទាំងនេះ យល់អាថ៌ប្រស្នាដ៏ជ្រាលជ្រៅល្អិត ដោយសុភាសិតបាន ។

[ ៩៩៥ ] យើងមានចិត្តត្រេកអរដ៏ក្រៃលែង យើងឲ្យសេះអស្សតរនិងរថមួយៗ ម្នាក់ ឲ្យស្រុកសួយដែលបរិបូណ៌មួយៗ ម្នាក់ ដល់អ្នកទាំងអស់គ្នា ជាអ្នកប្រាជ្ញព្រោះសុភាសិត ។

## មេណ្ឌកបញ្ហាជាតកទី ៨ ចប់

# អដ្ឋកថា

## មេណ្ឌកបញ្ហាជាតក

[ ៩៨៤-៩៩៥ ] មេណ្ឌកបញ្ហ   នឹងមានជាក់ច្បាស់ក្នុងឧមង្គជាតក

ឯណោះ ៗ ៚

**អដ្ឋកថា មេណ្ឌកបញ្ហាជាតក ចប់**

# សុត្តន្តបិដក

## មហាបទុមជាតក

[ ៩៩៦ ] ( ពួកជនក្រាបទូលថា ) ព្រះរាជាជាឥស្សរៈ បើមិនទាន់ឃើញទោសតូចធំ ដោយសព្វគ្រប់ អំពីសម្នាក់បុគ្គលដទៃ ទាំងមិនទាន់ពិចារណា ឲ្យឃើញច្បាស់ដោយខ្លួនឯងទេ មិនគប្បីដាក់អាជ្ញាឡើយ ។

[ ៩៩៧ ] បើក្សត្រិយ៍ណា មិនទាន់ពិចារណា ហើយធ្វើអាជ្ញាក្សត្រិយ៍នោះ ឈ្មោះថា លេបភោជនប្រកបដោយបន្លា ប្រកបដោយរុយ ដូចជាមនុស្សខ្វាក់ ។

[ ៩៩៨ ] ព្រះរាជាណា ដាក់អាជ្ញាដល់បុគ្គល ដែលមិនគួរដាក់អាជ្ញា មិនដាក់អាជ្ញាដល់បុគ្គល ដែលគួរដាក់អាជ្ញា ព្រះរាជានោះ ឈ្មោះថា មិនដឹងការស្មើ និងមិនស្មើ ដូចជាមនុស្សខ្វាក់ដើរតាមផ្លូវមិនរាបស្មើ ។

[ ៩៩៩ ] ព្រះរាជាណា ឃើញនូវហេតុទាំងឡាយតូច និងធំទាំំង ដោយសព្វគ្រប់ ជាហេតុដែលឃើញត្រឹមត្រូវហើយ សឹមប្រៀនប្រដៅ ព្រះរាជានោះ ទើបគួរហៅថាព្រះរាជាបាន ។

[ ១០០០ ] ព្រះរាជា ដែលមានព្រះហឫទ័យទន់ពេក មានព្រះហឫទ័យរឹងពេក ក៏មិនអាចតាំងខ្លួនក្នុងភាពជាធំបានទេ ហេតុនោះ ព្រះរាជាគួរប្រព្រឹត្តនូវហេតុទាំងពីរ ។

[ ១០០១ ] ( ព្រោះ ) ព្រះរាជា ដែលមានព្រះហឫទ័យទន់ ត្រូវពួករាស្ត្រមើលងាយ ឯព្រះរាជាមានព្រះហឫទ័យរឹងពេក រមែងមានពៀរ ព្រះរាជាជ្រាបហេតុទាំងពីរនោះហើយ ត្រូវប្រព្រឹត្តជាកណ្តាល ។

[ ១០០២ ] បុគ្គលត្រេកអរហើយ និយាយច្រើនក៏មាន បុគ្គលខឹងហើយនិយាយច្រើនក៏មាន បពិត្រមហារាជ ព្រះអង្គមិនគួរសម្លាប់ព្រះរាជបុត្រព្រោះហេតុតែស្ត្រីទេ ។

[ ១០០៣ ] ( ព្រះរាជា ... ) មនុស្សលោកទាំងអស់ ( ជាបក្ខពួកខាងកុមារ ) ឯស្ត្រីនេះតែម្នាក់ឯងទេ ព្រោះហេតុនោះ យើងនឹងប្រតិបត្តិ ( តាមពាក្យនាងនេះវិញ ) អ្នកឯងចូរទៅទម្លាក់វា ( ក្នុងជ្រោះភ្នំទៅ ) ។

[ ១០០៤ ] យើងជាបិតា បានឲ្យគេយកកូនឯង ទៅបោះក្នុងជ្រោះភ្នំដ៏ជ្រៅ ច្រើនជួរគ្នោត មិនងាយឡើងមករួចទេ ហេតុអ្វីបានជាកូនឯង មិនស្លាប់ក្នុងជ្រោះនោះ ។

[ ១០០៥ ] ( មហាបទុមតាបស ... ) ក្នុងវេលានោះ នាគរាជមានកម្លាំងដ៏ខ្លាំងពូកែ អាស្រ័យនៅនឹងភ្នំ បានទទួលទ្រអាត្មាភាពដោយភ្នែនទាំងឡាយ ហេតុនោះ បានជាអាត្មាភាព មិនស្លាប់ក្នុងជ្រោះនោះ ។

[ ១០០៦ ] ( ព្រះរាជា ... ) ម្នាលរាជបុត្ត សូមលោកនិមន្តមក

យើងនឹងនាំលោកទៅកាន់ផ្ទះរបស់ខ្លួនវិញ ម្នាលលោកដ៏ចម្រើន សូមលោកគ្រប់គ្រងរាជសម្បត្តិចុះ លោកនៅធ្វើអ្វីក្នុងព្រៃ ។

[ ១០០៧ ] ( មហាបទុមតាបស ... ) បុគ្គលលេបថ្នាំសន្ទូច ហើយទាញចេញមក លុះទាញចេញមក ព្រមទាំងឈាម គប្បីជាសុខយ៉ាងណា អាត្មាភាពឃើញច្បាស់ដោយខ្លួនឯង ក៏យ៉ាងនោះដែរ ។

[ ១០០៨ ] ( ព្រះរាជា ... ) លោកពោលថា អ្វីជាថ្នាំសន្ទូច លោកពោលថា អ្វីជាឈាម លោកពោលថា អ្វីទាញចេញមក កាលបើយើងសួរហើយ លោកចូរប្រាប់រឿងនោះ ។

[ ១០០៩ ] ( មហាបទុមតាបស ... ) អាត្មាភាព ពោលនូវកាមថាជាថ្នាំសន្ទូច ពោលនូវដំរី និងសេះថាជាឈាម ពោលនូវការលះបោលថា ជាគ្រឿងទាញចេញមក បពិត្រក្សត្រិយ៍ សូមព្រះអង្គជ្រាបយ៉ាងនេះចុះ ។

[ ១០១០ ] ( ប្រជុំជាតក ) មាតាចុងនៃតថាគត គឺនាងចិញ្ចមាណវិកា បិតាតថាគត គឺទេវទត្ត នាគរាជ គឺអានន្ទជាអ្នកប្រាជ្ញ ទេវតា គឺសារីបុត្ត រាជបុត្តក្នុងកាលនោះ គឺតថាគត អ្នកទាំងឡាយចូរចាំទុកនូវជាតក ដោយប្រការយ៉ាងនេះចុះ ។

**មហាបទុមជាតកទី ៩ ចប់**

# អដ្ឋកថា

## មហាបទុមជាតក

[ ៩៩៦-១០១០ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនាងចិញ្ចមាណវិកា ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **នាទិដ្ឋា បរតោ ទោសំ** ដូច្នេះជាដើម ។

សេចក្តីពិស្តារថា ក្នុងបឋមពោធិកាល សាវករបស់ព្រះទសពលមានច្រើនឡើង ទេវតា និងមនុស្សចុះកាន់អរិយភូមិប្រមាណមិនបាន គុណរបស់ព្រះសាស្តា បានផ្សាយទូទៅ លាភសក្ការៈបានកើតឡើងសន្ធឹកសន្ធាប់ ពួកតិរ្ថិយវិនាសចាកលាភសក្ការៈ ដូចអំពិលអំពែកក្នុងពេលព្រះអាទិត្យរះឡើង ទើបនាំគ្នាឈរក្នុងចន្លោះផ្លូវ បបួលមនុស្សទាំងឡាយយ៉ាងនេះថា ព្រះគោតមជាព្រះពុទ្ធតែមួយអង្គប៉ុណ្ណោះឬ សូម្បីពួកយើងក៏ជាព្រះពុទ្ធ ទានដែលថ្វាយដល់ព្រះគោតមមានផលច្រើន សូម្បីថ្វាយដល់ពួកយើងក៏មានផលច្រើនដូចគ្នា ចូរអ្នកទាំងឡាយធ្វើទានដល់ពួកយើងខ្លះ ដូច្នេះក៏មិនបានលាភសក្ការៈ ទើបប្រជុំសម្ងាត់ពិភាក្សាគ្នាថា ពួកយើងប្រើឧបាយដូចម្តេចល្អហ្ន៎ ទើបធ្វើនូវកំហុសរបស់ព្រះគោតមឲ្យប្រាកដក្នុងពួកមនុស្ស ហើយធ្វើលាភសក្ការៈឲ្យវិនាសបាន ។

កាលនោះ ក្នុងនគរសាវត្ថីមានបរិព្វាជិកាម្នាក់ ឈ្មោះចិញ្ចមាណវិកា មានរូបរាងល្អលើស ដូចទេពអប្សរ មានរស្មីផ្សាយចេញអំពីរាងកាយរបស់នាង តិរ្ថិយម្នាក់មានគំនិតមុតស្រួចជាងគេ បានពោលយ៉ាងនេះថា ពួកយើងគប្បីអាស្រ័យនាងចិញ្ចមាណវិកា សាងនូវកំហុសឡើងដល់សមណ-

គោតម ធ្វើលាភសក្ការៈឲ្យវិនាស ពួកតិត្ថិយទទួលថា ឧបាយរបស់អ្នកពេញជាល្អ ។ កាលនោះ នាងចិញ្ចមាណវិកាមកកាន់អារាមតិត្ថិយ ថ្វាយបង្គំហើយឈរ ពួកតិត្ថិយមិនបានពោលជាមួយនាង ទើបនាងគិតថា អញមានកំហុសដូចម្ដេចហ្ន៎ ហើយពោលថា បពិត្រលោកម្ចាស់ទាំងឡាយ ខ្ញុំថ្វាយបង្គំដូច្នេះដល់ទៅ ៣ ដង ហើយក៏ពោលថា បពិត្រលោកម្ចាស់ទាំងឡាយ ខ្ញុំមានកំហុសអ្វីហ្ន៎ ហេតុអ្វីទើបលោកទាំងឡាយមិននិយាយនឹងខ្ញុំ ពួកតិត្ថិយពោលថា នែប្អូនស្រី នាងមិនដឹងទេឬថា ព្រះសមណគោតម បៀតបៀនពួកយើងដើរធ្វើពួកយើងឲ្យវិនាសចាកលាភសក្ការៈ នាងពោលថា ខ្ញុំមិនដឹង តើខ្ញុំនឹងធ្វើអ្វីបានក្នុងរឿងនេះ ពួកតិត្ថិយពោលថា នែប្អូនស្រី បើនាងប្រាថ្នានូវសេចក្ដីសុខដល់ពួកយើង ចូរប្រើខ្លួននាង សាងនូវភាពមិនល្អឡើងដល់ព្រះសមណគោតម ធ្វើលាភសក្ការៈឲ្យវិនាស នាងទទួលថា សាធុ រឿងនេះជាភារៈរបស់ខ្ញុំ សូមលោកម្ចាស់ទាំងឡាយកុំវិតក្កឡើយ ហើយចៀសចេញទៅ ។ ដោយនាងជាអ្នកឈ្លាសក្នុងមាយាស្ត្រី តាំងអំពីនោះមក ពេលអ្នកនគរសាវត្ថីស្ដាប់ធម្មកថាហើយ ចេញអំពីវត្តជេតពន នាងដណ្ដប់សំពត់មានពណ៌ដូចមេភ្លៀង កាន់គ្រឿងក្រអូប និងផ្កាជាដើម ដើរតម្រង់ទៅវត្តជេតពន កាលមានមនុស្សសួរថា នាងទៅណាក្នុងពេលនេះ ក៏ពោលថា ប្រយោជន៍អ្វីដោយទីទៅរបស់ខ្ញុំសម្រាប់អ្នក ហើយក៏ចូលអារាមតិត្ថិយ ដែលនៅក្បែរៗវត្តជេតពន លុះដល់ពេលព្រឹក កាលពួកឧបាសកចេញអំពីក្រុងសាវត្ថី ដើម្បីទៅថ្វាយបង្គំព្រះដ៏មានព្រះភាគ នាងក៏ធ្វើជានៅក្នុងវត្តជេតពន ហើយចូល

ទៅកាន់ព្រះនគរ កាលមានមនុស្សសួរថា នាងនៅទីណា ក៏ពោលថា ប្រយោជន៍អ្វីដោយការនៅរបស់ខ្ញុំសម្រាប់អ្នក កាលកន្លងទៅ ១ ខែ ២ ខែ ត្រូវសួរទៀត នាងក៏ពោលថា ខ្ញុំនៅរួមព្រះគន្ធកុដិជាមួយព្រះសមណគោតម ក្នុងវត្តជេតពន បានធ្វើសេចក្តីសង្ស័យដល់ពួកបុថុជ្ជនថា នាងចិញ្ចមាណវិកានិយាយនេះ ពិត ឬមិនពិតហ្ន៎ ។ កាលកន្លងទៅ ៣-៤ ខែ នាងក៏យកសំពត់កន្ទបមករុំពោះធ្វើជាស្រីមានគភ៌ យកសំពត់ក្រហម ដណ្តប់ខាងលើ ធ្វើឲ្យពួកអន្ធពាលជឿថា មានផ្ទៃពោះជាមួយព្រះសមណគោតម កាលកន្លងទៅ ៨-៩ ខែ នាងក៏យកឈើមូលចងត្រង់ពោះ យកសំពត់ដណ្តប់ពីលើ ឲ្យពួកតិរ្ថិយយកឈើដែលមានស្នាដូចចង្កាគោ មកវាយខ្នងដៃ ខ្នងជើងឲ្យហើម មានឥន្ទ្រិយសៅហ្មង ។ លុះដល់ពេលល្ងាច កាលព្រះតថាគតគង់សម្តែងធម៌លើធម្មាសនៈ ដែលគេតាក់តែង នាងទៅកាន់ធម្មសភា ឈរចំពោះព្រះភក្ត្រព្រះតថាគត ដូចបុគ្គលដែលព្យាយាមយកលាមកគ្រវែងជួងព្រះចន្ទ ជេរព្រះដ៏មានព្រះភាគ ក្នុងកណ្តាលបរិស័ទថា នែមហាសមណៈ ទ្រង់សម្តែងធម៌ដល់មហាជន សំឡេងរបស់ទ្រង់ពីរោះ បបូរមាត់ជិតស្និទ្ធល្អ តែខ្ញុំមានទម្ងន់ព្រោះទ្រង់ ពេលនេះ ក៏គ្រប់កំណត់ហើយ ទ្រង់មិនទាន់ត្រៀមផ្ទះប្រសូតដល់ខ្ញុំ សប្បិ និងប្រេងជាដើមក៏មិនទាន់មាន បើទ្រង់មិនធ្វើឯងគួរប្រាប់ដល់ឧបដ្ឋាករបស់ទ្រង់ណាមួយ ដូចជាព្រះបាទកោសល អនាថបិណ្ឌិកសេដ្ឋី មហាឧបាសិកាវិសាខាថា សូមជួយធ្វើវត្ថុដែលគួរធ្វើដល់នាងចិញ្ចមាណវិកានេះ ទ្រង់ចេះតែអភិរម្យប៉ុណ្ណោះ មិនចេះបរិហារគភ៌ ។ ព្រះ

តថាគត ទ្រង់បានស្តាប់ដូច្នោះ ទើបបញ្ឈប់ធម្មកថា បន្ទឹសីហនាទថា ម្នាលប្អូនស្រី តថាគត និងនាងពីរនាក់ប៉ុណ្ណោះ ដឹងពាក្យដែលនាងពោល ថាពិត ឬមិនពិត នាងចិញ្ចមាណវិកាពោលថា ត្រូវហើយព្រះសមណៈ រឿងនេះកើតឡើងព្រោះទ្រង់ និងខ្ញុំ ទើបដឹងតែពីរនាក់ ។

ខណៈនោះ ភពរបស់សក្កទេវរាជបានសម្តែងអាការក្តៅ សក្កទេវរាជពិចារណាមើល ក៏ទ្រង់ជ្រាបថា នាងចិញ្ចមាណវិកាជេរព្រះតថាគត ដោយរឿងដែលមិនពិត ទើបទ្រង់ព្រះតម្រិះថា អញនឹងជម្រះរឿងនេះ ហើយចុះមកជាមួយទេវបុត្រ ៤ អង្គ ។ ទេវបុត្រទាំងនោះ កាឡាខ្លួនជាកណ្តុរចូលទៅកាត់ខ្សែ ដែលចងឈើមូលព្រមគ្នា មានខ្យល់បក់បើកសំពត់ដណ្តប់ឡើង ឈើមូលក៏ធ្លាក់ត្រូវខ្នងជើងរបស់នាងចិញ្ចមាណវិកា ចុងជើងទាំងពីរបែក ពួកមនុស្សឃើញដូច្នោះ ទើបពោលថា ហោងកាឡកិណី ហង់ជេរព្រះសម្មាសម្ពុទ្ធ ហើយនាំគ្នាស្តោះទឹកមាត់ដាក់លើក្បាល កាន់ដុំដី និងកំណាត់ឈើ ដេញចេញអំពីវត្តជេតពន ។ លុះនាងចិញ្ចមាណវិកា បានផុតគន្លងចក្ខុព្រះតថាគត មហាប្រឹថពីក៏បែកជាពីរចំណែក អណ្តាតភ្លើងក៏ផ្សាយឡើងអំពីអវិចី បានលេបត្របាក់នាងចិញ្ចមាណវិកា ដូចដណ្តប់សំពត់កម្ពល ដែលត្រកូលឲ្យលិចចុះទៅដល់អវិចី លាភសក្ការៈរបស់តិរ្ថិយទាំងឡាយ ក៏វិនាសទៅ តែរបស់ព្រះតថាគត រឹងរឹតតែចម្រើនឡើងពន់ប្រមាណ ។

ស្អែកឡើង ពួកភិក្ខុទាំងឡាយ លើករឿងឡើងសន្ទនាក្នុងធម្មសភាថា អាវុសោទាំងឡាយនាងចិញ្ចមាណវិកាជេរព្រះសម្មាសម្ពុទ្ធ ដែលជាអគ្គទក្ខិ-

ណោយបុគ្គលដ៏ឧឡារដោយរឿងមិនពិត ដល់នូវសេចក្ដីវិនាសធំ ។ ព្រះសាស្ដាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អំបាញ់មិញនេះពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ កាលភិក្ខុទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលនាងចិញ្ចមាណវិកានេះ ជេរតថាគតដោយរឿងមិនពិតហើយដល់នូវសេចក្ដីវិនាស សូម្បីក្នុងកាលមុន នាងក៏ជេរតថាគតដោយរឿងមិនពិត ហើយដល់នូវសេចក្ដីវិនាសដូចគ្នា ទើបទ្រង់នាំអតីតនិទានមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វ កើតក្នុងព្រះគភ៌អគ្គមហេសីរបស់ព្រះបាទព្រហ្មទត្តនោះ ព្រះញាតិទាំងឡាយថ្វាយព្រះនាមព្រះពោធិសត្វថា បទុមកុមារ ព្រោះមានភក្រ្តល្អដូចផ្កាឈូក ព្រះពោធិសត្វនោះចម្រើនវ័យហើយ ទៅរៀនសិប្បវិជ្ជាទាំងពួងសម្រេចហើយត្រឡប់មក ។ លំដាប់នោះ ព្រះជននីរបស់ទ្រង់អស់ព្រះជន្ម ព្រះបិតាបានតាំងស្រីដទៃជាអគ្គមហេសី ហើយព្រះរាជទានតំណែងឧបរាជដល់ព្រះឱរស ។ បន្ទាប់មក ព្រះរាជាយាងទៅបង្ក្រាបបច្ចន្តប្រទេសដែលបះបោរ ត្រាស់នឹងអគ្គមហេសីថា នែនាង ចូរនាងនៅទីនេះ យើងនឹងទៅបង្ក្រាបបច្ចន្តប្រទេស ព្រះនាងទូលថា ខ្ញុំម្ចាស់មិននៅទីនេះទេ នឹងសូមទៅជាមួយទ្រង់ ព្រះរាជាត្រាស់ទោសក្នុងទីលានចម្បាំងឲ្យស្ដាប់ហើយ ត្រាស់ថា ចូរនាងកុំក្រវល់ក្រវាយ ចូរនៅចុះទម្រាំយើងមក យើងឲ្យបទុមកុមារ

មិនឲ្យភ្លេចកិច្ចការដែលគួរធ្វើដល់នាង ដូច្នេះហើយ ទ្រង់ធ្វើតាមពាក្យតម្រាស់ ហើយយាងទៅបង្ក្រាបបច្ចាមិត្ត ធ្វើជនបទឲ្យស្ងប់រាបទាប ហើយក៏យាងត្រឡប់មក បោះព្រះពន្លាទ័ពខាងក្រៅព្រះនគរ ។

ព្រះពោធិសត្វជ្រាបថា ព្រះជនកយាងមក ក៏ឲ្យប្រដាប់ព្រះនគរ តាក់តែងព្រះរាជមន្ទីរ ហើយទៅកាន់សម្នាក់ព្រះរាជអគ្គមហេសី តែមួយអង្គឯងព្រះអគ្គមហេសីឃើញរូបសម្បត្តិរបស់ព្រះពោធិសត្វក៏មានចិត្តស្រឡាញ់ ព្រះពោធិសត្វថ្វាយបង្គំព្រះនាងហើយទូលសួរថា បពិត្រព្រះមាតាៗ ប្រាថ្នាវត្ថុណាទូលបង្គំនឹងធ្វើថ្វាយ ។ លំដាប់នោះ ព្រះនាងត្រាស់ថា អ្នកកុំហៅយើងថាមាតា ហើយព្រះនាងក្រោកឡើងចាប់ដៃព្រះពោធិសត្វត្រាស់ថា ចូរឯងឡើងកាន់ទីបន្ទំចុះ ព្រះពោធិសត្វទូលសួរថា ដើម្បីអ្វី ព្រះនាងត្រាស់ថា យើងទាំងពីរនឹងអភិរម្យដោយសេចក្ដីត្រេកអរក្នុងកិលេស អស់កាលដែលព្រះរាជាមិនទាន់យាងមក ព្រះពោធិសត្វត្រាស់ថា បពិត្រព្រះមាតាៗ ជាមាតារបស់ទូលបង្គំផង មានស្វាមីផង ឈ្មោះថា ជាស្រីមានអ្នកដទៃហួងហែង ទូលបង្គំមិនធ្លាប់ទម្លាយឥន្ទ្រិយសម្លឹងមើលដោយអំណាចកិលេសឡើយ ទូលបង្គំនឹងធ្វើកម្មដែលសៅហ្មងដល់ម្ដេះ ជាមួយព្រះមាតាបានដូចម្ដេច ព្រះនាងបានត្រាស់អស់វារៈ ២-៣ ដង កាលព្រះពោធិសត្វមិនប្រាថ្នា ទើបព្រះនាងត្រាស់ថា ឯងធ្វើតាមពាក្យរបស់យើង ឬមិនធ្វើ ព្រះពោធិសត្វទូលថា បពិត្រព្រះមាតា ទូលបង្គំធ្វើមិនបាន ព្រះនាងត្រាស់ថា បើដូច្នោះ យើងនឹងក្រាបទូលដល់ព្រះរាជាយ៉ាងនេះ ហើយនឹងកាត់ក្បាលរបស់ឯងចោល ព្រះមហាសត្វ

ត្រាស់ថា សូមធ្វើតាមគាប់ចិត្តរបស់ព្រះមាតាចុះ បានធ្វើឲ្យព្រះនាងខ្មាសក្នុងព្រះហឫទ័យហើយ ក៏ចៀសចេញទៅ ។

ព្រះនាងមានសេចក្តីតក់ស្លុត ត្រិះរិះថា បើកុមារនេះទៅក្រាបទូលព្រះបិតាមុនអញ អញគង់មិនរួចជីវិត អញនឹងក្រាបទូលមុន ។ កាលព្រះនាងត្រិះរិះដូច្នេះហើយ មិនសោយព្រះក្រយាហារ ជណ្តប់សំពត់សៅហ្មង សម្តែងស្នាមក្រចកត្រង់សរីរៈ ហើយឲ្យសញ្ញាដល់ពួកស្រីអ្នកបម្រើថា បើព្រះរាជាត្រាស់សួរថា ព្រះទេវីយាងទៅណា ចូរអ្នកទាំងឡាយទូលថា ព្រះនាងមានជំងឺ បញ្ឆោតធ្វើជាឈឺហើយផ្ទំ ។ ព្រះរាជាទ្រង់ធ្វើប្រទក្សិណព្រះនគរហើយទ្រង់ឡើងកាន់ព្រះរាជនិវេសន៍ កាលមិនឃើញព្រះទេវី ទើបត្រាស់សួរថា ព្រះទេវីទៅណា ទ្រង់បានឮថាមានជំងឺ ទើបចូលទៅកាន់ទីបន្ទំ ត្រាស់សួរថា នែទេវី នាងមិនសប្បាយឬ ព្រះនាងធ្វើជាមិនបានឮព្រះតម្រាស់របស់ព្រះរាជាត្រូវសួរ ២-៣ ដង ក៏នៅស្ងៀម ។ ព្រះរាជាត្រាស់សួរថា នែទេវី ហេតុអ្វីទើបនាងមិននិយាយនឹងយើង ព្រះនាងទូលថា បណ្តាស្រីដែលមានប្តីហើយមិនមានអ្នកណាដូចខ្ញុំម្ចាស់ ព្រះរាជាត្រាស់សួរថា អ្នកណាបៀតបៀននាងឬ ចូរប្រាប់យើងឲ្យរហ័ស យើងនឹងកាត់ក្បាលវា ព្រះនាងទូលថា បពិត្រមហារាជ ទ្រង់តែងតាំងឲ្យអ្នកណារក្សាព្រះនគរ ហើយយាងទៅ ព្រះរាជាត្រាស់ថា យើងតាំងបទុមកុមារឱរសរបស់យើង ព្រះនាងទូលថា បទុមកុមារមកត្រង់លំនៅរបស់ខ្ញុំម្ចាស់ សូម្បីខ្ញុំម្ចាស់ពោលថា នែបា បាកុំធ្វើយ៉ាងនេះ យើងជាម្តាយរបស់ឯង បទុមកុមារពោលថា ក្រៅអំពីយើង អ្នកដទៃឈ្មោះ

ថាជាព្រះរាជា មិនមាន យើងនឹងឲ្យព្រះនាងនៅក្នុងព្រះរាជដ្ឋាន អភិរម្យជាមួយគ្នាដោយសេចក្តីត្រេកអរនៃកិលេស ហើយចាប់ផ្តួងសក់ខ្ញុំម្ចាស់ទាញទៅមកវាយខ្ញុំម្ចាស់ កាលខ្ញុំម្ចាស់មិនធ្វើតាមពាក្យរបស់ខ្លួន ក៏ចេញទៅ ។

ព្រះរាជាទ្រង់មិនពិចារណាជាមុន ទ្រង់ព្រះពិរោធដូចអាសិរពិស បញ្ជាពួករាជបុរសថា ចូរពួកឯងចងបទុមកុមារនាំមក ។ ពួករាជបុរសនាំគ្នាទៅកាន់ព្រះរាជដំណាក់កុមារ ដូចលើកគ្នាទៅពេញនគរ ចាប់បទុមកុមារវាយ ហើយចងក្រពាត់ស្លាបសេកយ៉ាងមាំ យកប្រវាក់ទាក់ក ធ្វើជាអ្នកទោសប្រហារជីវិតវាយបណ្តើរ នាំទៅបណ្តើរ ព្រះពោធិសត្វគិតថា នេះជាការធ្វើរបស់ព្រះទេវី ទើបដើរបណ្តើរនិយាយបណ្តើរថា នែបុរសដ៏ចម្រើនទាំងឡាយ យើងមិនបានប្រទូស្តព្រះរាជា យើងមិនមានកំហុសឡើយ ។ អ្នកនគរទាំងមូល នាំគ្នាភ្ញាក់ផ្អើលពោលថា បានឮថា ព្រះរាជាជឿពាក្យស្រី ត្រាស់ឲ្យសម្លាប់បទុម-កុមារ ប្រជុំគ្នាយំបម្រះនទៀលទៀបបាតជើងព្រះរាជកុមារ រៀបរាប់ដោយសំឡេងខ្លាំងថា បពិត្រលោកម្ចាស់ កម្មនេះ មិនសមគួរដល់លោកឡើយ ខណៈនោះ ពួករាជបុរស នាំព្រះរាជកុមារទៅបង្ហាញដល់ព្រះរាជាៗ ទតហើយមិនអាចអត់សង្កត់ព្រះពិរោធបាន ទើបត្រាស់ថា កុមារនេះ មិនមែនជាព្រះរាជាឡើយ ធ្វើអាកប្បកិរិយាជាព្រះរាជា ជាឱរសរបស់យើង ធ្វើខុសក្នុងអគ្គមហេសី ចូរពួកលោកចាប់កុមារនេះបោះក្នុងជ្រោះ ដែលសម្រាប់ទម្លាក់ចោរ ឲ្យវិនាសបង់ ព្រះមហាសត្វអង្វរព្រះជនកថា បពិត្រព្រះបិតា ទូលបង្គំមិនមានកំហុសដល់ម្ល៉ោះឡើយ សូមទ្រង់កុំជឿពាក្យរបស់ស្រី ធ្វើឲ្យទូលបង្គំ

វិនាសឡើយ ព្រះរាជាទ្រង់មិនជឿពាក្យរបស់ព្រះពោធិសត្វ ។ លំដាប់នោះ ស្រីស្នំ ១ ម៉ឺន ៦ ពាន់ យំរៀបរាប់ថា ឱ បទុមកុមារទ្រង់បានទទួលកម្មនេះ ដែលមិនសមគួរដល់ខ្លួនឡើយ ពួកអ្នកធំទាំងអស់ មានក្សត្រមហាសាល ជាដើម រហូតដល់អមាត្យ រាជសេវកៈទាំងឡាយនាំគ្នាក្រាបទូលថា បពិត្រ ព្រះអង្គ កុមារនេះសម្បូរដោយគុណ គឺសីលាចារវត្ត ជាវង្សទាយាទ ជាអ្នក បន្តវង្ស សូមទ្រង់កុំជឿពាក្យរបស់ស្រី ទ្រង់មិនពិចារណាជាមុន ហើយធ្វើ ព្រះរាជកុមារឲ្យវិនាសឡើយ វិស័យព្រះរាជា ត្រូវពិចារណាមុន សឹមធ្វើ ហើយពោល ៧ គាថាថា

ព្រះរាជាជាឥស្សរៈ បើមិនទាន់ឃើញទោសតូចធំ ដោយសព្វ គ្រប់ អំពីសម្នាក់បុគ្គលដទៃ ទាំងមិនទាន់ពិចារណាឲ្យឃើញ ច្បាស់ដោយខ្លួនឯងទេ មិនគប្បីដាក់អាជ្ញាឡើយ ។

បើក្សត្រិយ៍ណា មិនទាន់ពិចារណា ហើយធ្វើអាជ្ញា ក្សត្រិយ៍ នោះ ឈ្មោះថា លេបភោជនប្រកបដោយបន្លា ប្រកបដោយ រុយ ដូចជាមនុស្សខ្វាក់ ។

ព្រះរាជាណា ដាក់អាជ្ញាដល់បុគ្គល ដែលមិនគួរដាក់អាជ្ញា មិន ដាក់អាជ្ញាដល់បុគ្គល ដែលគួរដាក់អាជ្ញា ព្រះរាជានោះ ឈ្មោះថា មិនដឹងការស្មើ និងមិនស្មើ ដូចជាមនុស្សខ្វាក់ ដើរតាមផ្លូវមិន រាបស្មើ ។

ព្រះរាជាណា ឃើញនូវហេតុទាំងឡាយតូច និងធំទុំៈ ដោយ

សព្វគ្រប់ ជាហេតុដែលឃើញត្រឹមត្រូវហើយ សឹមប្រៀនប្រដៅ
ព្រះរាជានោះ ទើបគួរហៅថា ព្រះរាជាបាន ។
ព្រះរាជា ដែលមានព្រះហឫទ័យទន់ពេក មានព្រះហឫទ័យរឹង
ពេក ក៏មិនអាចតាំងខ្លួនក្នុងភាពជាធំបានទេ ហេតុនោះ ព្រះរាជា
គួរប្រព្រឹត្តនូវហេតុទាំងពីរ ។
( ព្រោះ ) ព្រះរាជា ដែលមានព្រះហឫទ័យទន់ ត្រូវពួករាស្ត្រ
មើលងាយ ឯព្រះរាជាមានព្រះហឫទ័យរឹងពេក រមែងមានពៀរ
ព្រះរាជាជ្រាបហេតុទាំងពីរនោះហើយ ត្រូវប្រព្រឹត្តជាកណ្តាល ។
បុគ្គលត្រេកអរហើយ និយាយច្រើនក៏មាន បុគ្គលខឹងហើយ
និយាយច្រើនក៏មាន បពិត្រមហារាជ ព្រះអង្គមិនគួរសម្លាប់ព្រះ
រាជបុត្រ ព្រោះហេតុតែស្ត្រីទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អាទិដ្ឋា** បានដល់ មិនបានឃើញ ។ បទថា **បរតោ** បានដល់ របស់អ្នកដទៃ ។ បទថា **សព្វសោ** បានដល់ ទាំងពួង ។ បទថា **អណុំថូលានិ** បានដល់ ទោសតូច និងទោសធំ ។ បទថា **សាមំ អប្បដិវេក្ខិយ** សេចក្តីថា ព្រះរាជាជាធំក្នុងផែនដី លះបង់ពាក្យរបស់អ្នកដទៃ មិនធ្វើឲ្យប្រចក្សដល់ខ្លួន ទ្រង់មិនកាត់ គឺមិនគប្បីផ្តើមដាក់អាជ្ញា ។ មែនពិត ក្នុងរជ្ជកាលនៃព្រះបាទមហាសម្មតិ សត្វ ឈ្មោះថា មានអាជ្ញាក្រៃលែង រមែងមិនមាន ឈ្មោះថា ការព្យាយាមក្នុងការកាត់ដៃ និងជើង ក្រៃលែងជាងវាយ តិះដៀល បណ្តេញ រមែងមិនមាន ហេតុការណ៍នោះ កើតឡើងក្នុងសម័យ

នៃព្រះរាជាអាក្រក់ ក្នុងកាលឯក្រោយ ពួកអមាត្យកាលពោលថា ការមិនពិចារណាឃើញទោសរបស់អ្នកដទៃដោយខ្លួនឯង ដាក់ទោសដោយចំណែកមួយ មិនសមគួរឡើយ ទើបពោលយ៉ាងនេះ សំដៅយកហេតុការណ៍នោះ ។ បទថា **យោ ច អប្បដិវេក្ខិត្វា** សេចក្តីថា បពិត្រមហារាជ ព្រះរាជាណាកាលពិចារណា កាត់ទោសដែលសមគួរដល់ទោសយ៉ាងនេះ តាំងនៅក្នុងការលុះអគតិ មិនពិចារណាឃើញទោសនោះ ដាក់អាជ្ញា មានការកាត់ដៃជាដើម ព្រះរាជានោះ កាលញ៉ាំងហេតុឲ្យដល់ខ្លួន ឈ្មោះថា លេបព្រះក្រយាហារទាំងបន្លា ដូចមនុស្សក្លែកខ្វាក់លេបបាយទាំងរុយ ដូច្នោះ ។ បទថា **អទណ្ឌិយំ** សេចក្តីថា ព្រះរាជាណាទ្រង់ដាក់អាជ្ញាដែលមិនគួរដាក់ និងមិនដាក់អាជ្ញាដែលគួរដាក់ ធ្វើតាមការគាប់ចិត្តរបស់ខ្លួនប៉ុណ្ណោះ ព្រះរាជានោះ ដូចមនុស្សក្លែកខ្វាក់ ដើរក្នុងផ្លូវមិនរាបស្មើ មិនដឹងថា ផ្លូវរាប ឬមិនរាប ដើរទៅ រមែងដល់នូវទុក្ខធំក្នុងមហានរក ក្នុងអបាយទាំង ៤ ដូចមនុស្សក្លែកខ្វាក់ រអិលដួលត្រង់ជុំថ្ម ដូច្នោះ ។ បទថា **ឋានានិ ឋានានិ** សេចក្តីថា ព្រះរាជាណាទ្រង់ឃើញហេតុដែលគួរដាក់នូវអាជ្ញា និងមិនគួរដាក់អាជ្ញា ទ្រង់ឃើញទោសតូច-ធំ ក្នុងហេតុដែលគួរដាក់អាជ្ញាទាំងអស់យ៉ាងល្អ ហើយទ្រង់គ្រប់គ្រងនគរ ព្រះរាជាអង្គនោះ សមគួរគ្រប់គ្រងរាជសម្បត្តិ ។ បទថា **អត្តំ មហន្តំ ឋបេតុំ** សេចក្តីថា ព្រះរាជាមានព្រះហឫទ័យទន់ភ្លន់ ឬមានព្រះហឫទ័យរឹងត្អឹងដោយចំណែកមួយ មិនអាចធ្វើភោគទ្រព្យដែលមិនទាន់កើតឡើង ឲ្យកើតឡើង ធ្វើភោគទ្រព្យដែលកើតឡើងហើយឲ្យស្ថិតស្ថេរ ហើយតម្កល់

ខ្លួនក្នុងភាពជាធំបានឡើយ ។ បទថា **មុទុ** សេចក្តីថា ព្រះរាជាមានហឫទ័យទន់ភ្លន់ ជាទីមើលងាយរបស់អ្នកដែន ទ្រង់ត្រូវគេមើលងាយ រមែងមិនអាចធ្វើរាជសម្បត្តិឲ្យប្រាសចាកចោរបាន ។ បទថា **វេរវា** សេចក្តីថា អ្នកដែនទាំងអស់ ជាអ្នកមានពៀរចំពោះព្រះរាជា ដែលមានព្រះហឫទ័យរឹងត្អឹងពេក ព្រោះដូច្នោះ ទ្រង់ ឈ្មោះថា ជាអ្នកមានពៀរ ។ បទថា **អនុមជ្ឈំ** សេចក្តីថា ជាព្រះរាជាគប្បីប្រព្រឹត្តជាកណ្តាល គឺជាកណ្តាលនៃការទន់ និងការរឹង គឺមិនទន់ពេក មិនរឹងពេក ហើយគ្រប់គ្រងរាជសម្បត្តិ ។ បទថា **ន ឥត្ថិការណា** សេចក្តីថា បពិត្រមហារាជ ទ្រង់មិនគួរប្រើឲ្យប្រហារព្រះរាជបុត្រដែលជារជ្ជទាយាទ បន្តសន្តិវង្ស ព្រោះអាស្រ័យមាតុគ្រាមដ៏លាមកឡើយ ។

អមាត្យ រាជសេវកៈទាំងឡាយ នាំគ្នាក្រាបទូលដោយហេតុផ្សេងៗ យ៉ាងនេះ ក៏មិនអាចឲ្យព្រះរាជាជឿពាក្យរបស់ខ្លួនបាន ព្រះពោធិសត្វក៏អង្វរ តែមិនអាចឲ្យព្រះរាជាជឿពាក្យរបស់ខ្លួនបាន ។ ចំណែកព្រះរាជា ជាបុគ្គលល្ងង់ខ្លៅ កាលទ្រង់ត្រាស់បញ្ជាអមាត្យថា ចូរពួកលោកចាប់បទុមកុមារនេះ បោះក្នុងជ្រោះជាទីទម្លាក់ចោរ បានត្រាស់គាថាទី ៨ ថា

មនុស្សលោកទាំងអស់ ( ជាបក្ខពួកខាងកុមារ ) ឯស្ត្រីនេះ តែម្នាក់ឯងទេ ព្រោះហេតុនោះ យើងនឹងប្រតិបត្តិ ( តាមពាក្យនាងនេះវិញ ) អ្នកឯងចូរទៅទម្លាក់វា ( ក្នុងជ្រោះភ្នំទៅ ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តេនាហំ** សេចក្តីថា ដោយហេតុណា សត្វលោកទាំងពួង ទើបរួមគ្នាជាចំណែកនៃកុមារ ចំណែកមហេសីមួយអង្គប៉ុណ្ណោះ

មិនមានគ្នីគ្នា ដោយហេតុនោះ យើងនឹងបដិបត្តិតាមពាក្យរបស់នាងទៅចុះ ចូរអ្នកទាំងឡាយលើកបទុមកុមារនោះឡើងកាន់ភ្នំ ហើយបោះក្នុងជ្រោះចុះ ។

កាលព្រះរាជា មានព្រះរាជឱង្ការត្រាស់យ៉ាងនេះហើយ ស្រីស្នំ ១ ម៉ឺន ៦ ពាន់ សូម្បីត្រឹមតែម្នាក់ក៏មិនអាចតាំងនៅក្នុងការៈរបស់ខ្លួនបាន នាំគ្នាស្រែកយំរៀបរាប់ អ្នកនគរទាំងមូលឱបទ្រូងទ្រហោយំ រំសាយសក់កន្ទក់កន្ទេញ ព្រះរាជាទ្រង់ត្រិះរិះថា មនុស្សទាំងនេះ គប្បីហាមការបោះកុមារទៅក្នុងជ្រោះទើបយាងទៅជាមួយបរិវារ ។ កាលមហាជនកំពុងយំសោកនោះឯង ឲ្យចាប់បទុមកុមារ យកជើងឡើងលើ យកសីសៈចុះក្រោម ហើយបោះទៅក្នុងជ្រោះរំពេចនោះ ដោយអានុភាពមេត្តាភាវនារបស់បទុមកុមារ ទេវតាដែលអាស្រ័យត្រង់ភ្នំនោះ បានលួងលោមព្រះរាជកុមារថា កុំខ្លាចឡើយ ហើយលាដៃទាំងពីរទទួលត្រង់ព្រះហឫទ័យ ឲ្យបាននូវសម្ផស្សទិព្វ ហើយនាំទៅប្រថាប់លើពពារនាគក្នុងនាគពិភព ដែលតាំងនៅត្រង់ជើងភ្នំ ស្តេចនាគបាននាំព្រះពោធិសត្វទៅកាន់នាគពិភពហើយ ចែកសម្បត្តិរបស់ខ្លួនពាក់កណ្តាល ។ ព្រះពោធិសត្វនៅក្នុងនាគពិភពបាន ១ ឆ្នាំ ពោលថា យើងនឹងទៅកាន់ដែនដីមនុស្ស ស្តេចនាគសួរថា ទ្រង់ទៅធ្វើអ្វី ព្រះកុមារត្រាស់ថា យើងនឹងបួសក្នុងហិមវន្តប្បទេស ស្តេចនាគទទួលថា សាធុ ហើយនាំព្រះពោធិសត្វដល់ដែនដីមនុស្សថ្វាយនូវបព្វជិតបរិក្ខារហើយ ត្រឡប់ទៅកាន់លំនៅរបស់ខ្លួន ។

ចំណែកព្រះពោធិសត្វ ចូលកាន់ហិមវន្តប្បទេស បួសជាឥសី ញុំាងឈាន និងអភិញ្ញាឲ្យកើត មានត្រាវ ដំឡូង ផ្លែឈើជាអាហារ អាស្រ័យនៅ

ក្នុងទីនោះ ។ កាលនោះ ព្រានព្រៃអ្នកក្រុងពារាណសីម្នាក់ ទៅដល់ទីនោះ ស្គាល់ព្រះពោធិសត្វ ទើបសួរថា បពិត្រព្រះអង្គ ទ្រង់ គឺមហាបទុមកុមារ មិនមែនឬ កាលព្រះពោធិសត្វត្រាស់ថា ត្រូវហើយសម្លាញ់ ក៏បានទមស្ការព្រះពោធិសត្វ នៅក្នុងទីនោះអស់ ២-៣ ថ្ងៃហើយ ទៅកាន់នគរពារាណសី ក្រាបទូលដល់ព្រះរាជាថា បពិត្រព្រះអង្គ ព្រះឱរសរបស់ព្រះអង្គបួសជាឥសី នៅក្នុងបណ្ណសាលានាហិមវន្តប្បទេស ទូលបង្គំបានអាស្រ័យក្នុងសម្នាក់របស់ព្រះរាជបុត្រនោះ ២-៣ ថ្ងៃហើយ ក៏លាវិលត្រឡប់មក ។ ព្រះរាជាត្រាស់សួរថា ឯងឃើញច្បាស់ហើយឬ ព្រានព្រៃក្រាបទូលថា ច្បាស់ហើយព្រះអង្គ ។ ព្រះរាជាទ្រង់ចោមរោមដោយពលនិកាយដ៏ច្រើន យាងទៅក្នុងទីនោះ បោះព្រះពន្លាត្រង់ជាយព្រៃ ចោមរោមទៅដោយអមាត្យ យាងទៅកាន់បណ្ណ-សាលា ទតឃើញព្រះពោធិសត្វមានសិរី រុងរឿងដូចបដិមាមាស ប្រថាប់គង់ត្រង់ទ្វារបណ្ណសាលា ថ្វាយបង្គំហើយ ប្រថាប់គង់ក្នុងទីសមគួរនាចំណែកម្ខាង ពួកអមាត្យទមស្ការ និងធ្វើបដិសណ្ឋារៈហើយអង្គុយ ព្រះពោធិសត្វទ្រង់ធ្វើបដិសណ្ឋារៈទទួលព្រះរាជាដោយផ្លែឈើ ។

លំដាប់នោះ ព្រះរាជាត្រាស់សួរព្រះពោធិសត្វថា នែបា យើងឲ្យគេបោះបុត្រក្នុងជ្រោះជ្រៅ ហេតុអ្វីទើបបាមានជីវិត បានត្រាស់គាថាទី ៩ ថា

យើងជាបិតា បានឲ្យគេយកកូនឯង ទៅបោះក្នុងជ្រោះភ្នំដ៏ជ្រៅ
ច្រើនជួរគ្នោត មិនងាយឡើងមករួចទេ ហេតុអ្វី បានជាកូនឯង
មិនស្លាប់ក្នុងជ្រោះនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អនេកតាលេ** បានដល់ ប្រមាណច្រើនជួរ ត្នោត ។ បទថា **ឆាមរិ** កាត់បទជា **ឆ អមរិ** ។ ព្រះរាជកុមារទូលថា

ក្នុងវេលានោះ នាគរាជ មានកម្លាំងដ៏ខ្លាំងពូកែ អាស្រ័យនៅនឹងក្អំ បានទទួលទ្រអាត្មាភាព ដោយក្អែនទាំងឡាយ ហេតុនោះ បានជា អាត្មាភាព មិនស្លាប់ក្នុងជ្រោះនោះ ដូច្នេះ ។

ព្រះរាជាត្រាស់ថា

ម្នាលរាជបុត្ត សូមលោកនិមន្តមក យើងនឹងនាំលោកទៅកាន់ ផ្ទះរបស់ខ្លួនវិញ ម្នាលលោកដ៏ចម្រើន សូមលោកគ្រប់គ្រង រាជសម្បត្តិចុះ លោកនៅធ្វើអ្វីក្នុងព្រៃ ដូច្នេះ ។

ព្រះរាជកុមារទូលថា

បុគ្គលលេបផ្លែសន្ទូច ហើយទាញចេញមក លុះទាញចេញមក ព្រមទាំងឈាម គប្បីជាសុខយ៉ាងណា អាត្មាភាពឃើញច្បាស់ ដោយខ្លួនឯង ក៏យ៉ាងនោះដែរ ដូច្នេះ ។

ព្រះរាជាបានស្តាប់យ៉ាងនោះហើយ ត្រាស់ថា

លោកពោលថា អ្វីជាផ្លែសន្ទូច លោកពោលថា អ្វីជាឈាម លោកពោលថា អ្វីទាញចេញមក កាលបើយើងសួរហើយ លោក ចូរប្រាប់រឿងនោះ ដូច្នេះ ។

តាបសទូលថា

អាត្មាភាព ពោលនូវកាម ថាជាផ្លែសន្ទូច ពោលនូវដំរី និងសេះ

ថាជាឈាម ពោលនូវការលះចោល ថាជាគ្រឿងទាញចេញមក បពិត្រក្សត្រិយ៍ សូមព្រះអង្គជ្រាបយ៉ាងនេះចុះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បច្ចុគ្គហិ** សេចក្ដីថា ព្រះរាជកុមារទូលរឿងទាំងអស់ថា ក្នុងកាលទូលបង្គំធ្លាក់អំពីភ្នំ ស្ដេចនាគមានកម្លាំងទទួលទូលបង្គំ ដែលទេវតាទ្រហើយ លួងលោមដោយសម្ផស្សដែលជាទិព្វ នាំចូលទៅ កាលទទួលហើយ នាំទៅកាន់នាគពិភពឲ្យនូវយសធំ កាលទូលបង្គំពោលថា ចូរនាំខ្ញុំទៅកាន់ទឹកដីមនុស្ស ក៏នាំទូលបង្គំមកកាន់មនុស្សលោក ទូលបង្គំនោះមកបួសក្នុងទីនេះ ទូលបង្គំមិនស្លាប់ក្នុងទីនោះ ព្រោះអានុភាពរបស់ទេវតា និងស្ដេចនាគនោះ ដោយប្រការដូច្នេះ ។ បទថា **ឯហិ** សេចក្ដីថា ព្រះរាជាទ្រង់ស្ដាប់ពាក្យរបស់ព្រះរាជកុមារហើយ ដល់នូវសោមនស្សក្រាបចុះទៀបបាទាត្រាស់ថា នែបុត្រ ខ្ញុំជឿពាក្យរបស់ស្រីដោយភាវៈជាបុគ្គលល្ងង់ខ្លៅ កាលបើដូច្នេះ ឈ្មោះថា ខ្ញុំខុសក្នុងបុគ្គលដែលសម្បូរដោយគុណគឺសីល និងអាចារៈ សូមលោកម្ចាស់អត់ទោសឲ្យដល់ខ្ញុំចុះ កាលព្រះរាជកុមារទូលថា សូមមហាបពិត្រក្រោកឡើង ទូលបង្គំអត់ទោសដល់ទ្រង់ ខាងមុខអំពីនេះទៅ ទ្រង់កុំធ្វើដោយមិនពិចារណាយ៉ាងនេះទៀតឡើយ ទើបត្រាស់យ៉ាងនេះថា នែបា ចូរកូនលើកស្វេតច្ឆត្រដែលជារបស់ត្រកូល ហើយគ្រងរាជសម្បត្តិ ទើបឈ្មោះថា កូនអត់ទោសឲ្យដល់បិតា ។ បទថា **ឧទ្ធរិត្វា** សេចក្ដីថា បុគ្គលលេបផ្លែសន្ទូចចូលទៅមិនទាន់ដល់បេះដូង និងតម្រងបស្សាវៈជាដើម គប្បីដោះផ្លែសន្ទូចនោះចេញ ឈ្មោះថា មានសេចក្ដីសុខ ។

បទថា **អត្តានំ** សេចក្តីថា មហាបពិត្រ អាត្មាឃើញខ្លួនដូចបុរសលេបផ្លែសន្ទូចហើយដល់នូវសួស្តីវិញ ។ បទថា **កិន្នុ ត្វំ** នេះ ព្រះរាជាត្រាស់សួរដើម្បីស្តាប់សេចក្តីនោះដោយពិស្តារ ។ បទថា **កាមាហំ** បានដល់ អាត្មាពោលកាមគុណ ៥ ។ បទថា **ហត្ថិអស្សំ សលោហិតំ** បានដល់ អាត្មាពោលនូវពាហនៈ គឺដំរី សេះ រថ និងសម្បត្តិ មានរតនៈ ៧ ជាដើម ថាជាសន្ទូចប្រឡាក់ដោយឈាម ។ បទថា **ចត្តាហំ** កាត់បទជា **ចត្តំ អហំ** សេចក្តីថា ក្នុងកាលណា វត្ថុទាំងអស់នោះ អាត្មាលះហើយ លះអស់ហើយ ក្នុងកាលឥឡូវនេះ អាត្មាពោលថា ដោះ ( ផ្លែសន្ទូច ) ចេញបាន ។

ព្រះមហាសត្វ បានថ្វាយឱវាទដល់ព្រះជនកថា មហាបពិត្រ កិច្ចដោយរាជសម្បត្តិមិនមានដល់អាត្មា សូមទ្រង់កុំញ៉ាំងទសពិធរាជធម៌ឲ្យកម្រើក សូមលះនូវការលុះក្នុងអំណាចអគតិ គ្រងរាជសម្បត្តិដោយធម៌ចុះ ។ ព្រះរាជាទ្រង់ព្រះកន្សែង ហើយត្រឡប់មកកាន់ព្រះនគរ ក្នុងរវាងផ្លូវ បានត្រាស់សួរពួកអមាត្យថា យើងព្រាត់ចាកបុត្រដែលសម្បូរដោយអាចារគុណបែបនេះ ព្រោះអ្នកណា ពួកអមាត្យក្រាបទូលថា ព្រោះព្រះអគ្គមហេសី ព្រះរាជាត្រាស់ឲ្យចាប់អគ្គមហេសី យកជើងឡើងលើ បោះក្នុងជ្រោះជាទីទម្លាក់ចោរ ហើយទ្រង់គ្រងរាជសម្បត្តិដោយធម៌ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះ មកសម្តែងហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងកាលមុន នាងចិញ្ចមាណវិកានេះ ក៏ជេរតថាគត ហើយដល់នូវសេចក្តីវិនាសមកហើយយ៉ាងនេះ ទ្រង់ប្រជុំជាតក ដោយគាថាចុងក្រោយថា

មាតាចុងនៃតថាគត គឺនាងចិញ្ចមាណវិកា បិតាតថាគត គឺទេវទត្ត នាគរាជ គឺអានន្ទជាអ្នកប្រាជ្ញ ទេវតា គឺសារីបុត្ត រាជបុត្តក្នុងកាលនោះ គឺតថាគត អ្នកទាំងឡាយ ចូរចាំទុកនូវជាតក ដោយប្រការយ៉ាងនេះចុះ ដូច្នេះ ។

**អដ្ឋកថា មហាបទុមជាតក ចប់**

# សុត្តន្តបិដក

## មិត្តាមិត្តជាតក

[ ១០១១ ] ( ព្រះបាទព្រហ្មទត្ត សួរមហាសត្វថា ) បណ្ឌិត អ្នកមានប្រាជ្ញាឃើញ ឬឮពួកជន កំពុងធ្វើនូវអំពើអ្វីៗ គប្បីដឹងថា ជាអមិត្តបាន តើវិញ្ញូជនគប្បីព្យាយាមដូចម្តេច ។

[ ១០១២ ] ( ព្រះមហាសត្វ សម្តែងនូវលក្ខណៈ នៃបុគ្គលជាសត្រូវនោះថា ) បុគ្គលជាសត្រូវ ឃើញបុគ្គលនោះហើយ មិនញញឹម ១ មិនទទួលត្រេកអរនឹងសម្តីបុគ្គលនោះ ១ មិនឲ្យភ្នែកដល់បុគ្គលនោះ ១ ប្រព្រឹត្តទទឹងទាស់ ១ ។

[ ១០១៣ ] បុគ្គលអែបអបនឹងពួកសត្រូវ របស់បុគ្គលនោះ ១ មិនសេពគប់នឹងពួកមិត្ត របស់បុគ្គលនោះ ១ រារាំងពួកជនអ្នកនិយាយសរសើរ ១ សរសើរពួកជនអ្នកជេរ ១ ។

[ ១០១៤ ] មិនប្រាប់សេចក្តីកំបាំង ដល់បុគ្គលនោះ ១ មិនលាក់សេចក្តីកំបាំង របស់បុគ្គលនោះ ១ មិនសរសើរការងារ របស់បុគ្គលនោះ ១ មិនសរសើរប្រាជ្ញា របស់បុគ្គលនោះ ១ ។

[ ១០១៥ ] ត្រេកអរនឹងសេចក្តីវិនាស របស់បុគ្គលនោះ ១ មិនត្រេកអរនឹងសេចក្តីចម្រើន របស់បុគ្គលនោះ ១ បានភោជនចម្លែក មិននឹកនាដល់បុគ្គលនោះ ១ មិនអនុគ្រោះបុគ្គលនោះអំពីរបស់នោះថា ឱ មិត្តនោះ គប្បីបានរបស់នេះខ្លះ ១ ។

[ ១០១៦ ] បណ្ឌិតឃើញ ឬឮ ហើយស្គាល់ថា ជាអមិត្តបាន ដោយអាការទាំង ១៦ នេះ ដែលតម្កល់នៅក្នុងអមិត្ត ដោយប្រការ ដូច្នេះ ។

[ ១០១៧ ] ( ព្រះបាទព្រហ្មទត្ត ... ) បណ្ឌិតអ្នកមានប្រាជ្ញា ឃើញ ឬឮពួកជនកំពុងធ្វើការងារអ្វីៗ គប្បីដឹងថា ជាមិត្តបាន តើវិញ្ញូជនគប្បីព្យាយាមដូចម្ដេច ។

[ ១០១៨ ] ( មហាសត្វ ... ) បុគ្គលជាមិត្ត តែងនឹករឭកដល់មិត្ត ដែលនៅបែកគ្នា ១ ត្រេកអរនឹងមិត្តដែលមកដល់ ១ ជាអ្នករាប់អានចំពោះមិត្តនោះ ១ ទទួលរីករាយ ដោយវាចា ១ ។

[ ១០១៩ ] គប់រកនឹងពួកមិត្ត របស់មិត្តនោះ ១ មិនសេពគប់នឹងពួកអមិត្ត របស់មិត្តនោះ ១ ហាមឃាត់នូវពួកអ្នកជេរ ១ សរសើរពួកជន ដែលនិយាយសរសើរ ១ ។

[ ១០២០ ] ប្រាប់សេចក្ដីកំបាំង ដល់មិត្តនោះ ១ បិទបាំងសេចក្ដីកំបាំង របស់មិត្តនោះ ១ សរសើរការងារ របស់មិត្តនោះ ១ សរសើរប្រាជ្ញារបស់មិត្តនោះ ១ ។

[ ១០២១ ] ត្រេកអរនឹងសេចក្ដីចម្រើន របស់មិត្តនោះ ១ មិនត្រេកអរនឹងសេចក្ដីវិនាស របស់មិត្តនោះ ១ បានភោជនចម្លែកតែងនឹកនាដល់មិត្តនោះ ១ អនុគ្រោះមិត្តនោះ អំពីរបស់នោះថា ឱ មិត្តនោះ គប្បីបានរបស់នេះខ្លះ ១ ។

[ ១០២២ ] បណ្ឌិតឃើញ ឬឮហើយ ស្គាល់ថាជាមិត្ត ដោយអាការទាំង ១៦ នេះ ដែលតម្កល់នៅក្នុងមិត្ត ដោយប្រការ ដូច្នេះ ។

**មិត្តាមិត្តជាតកទី ១០ ចប់**

## ឧទ្ទាននៃទ្វាទសនិបាតនោះ គឺ

និយាយអំពីស្ត្រីចិត្តស្រាល ១ រុក្ខទេវតាឈ្មោះកទ្ទសាល ១ ពួកជនក្ខរាស់ ១ កាម ១ ហេតុ ១០ យ៉ាង ១ ក្អែខ្មៅ ១ កោសិយសេដ្ឋី ១ ពពែដ៏ប្រសើរ ១ មហាបទុមកុមារ ១ មិត្តដ៏ប្រសើរ ១ រួមត្រូវជា ១០ ។

**ទ្វាទសនិបាត ចប់**

# អដ្ឋកថា

## មិត្តាមិត្តជាតក

[ ១០១១-១០២២ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធអមាត្យអ្នកប្រព្រឹត្តប្រយោជន៍របស់ព្រះបាទកោសល ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **កានិ កម្មានិ កុព្វានំ** ដូច្នេះជាដើម ។

បានឮថា អមាត្យនោះ មានឧបការៈច្រើនដល់ព្រះរាជាៗ ក៏បានប្រទានសក្ការៈ និងការរាប់អានដោយអើពើ ពួកអមាត្យដ៏សេសអត់ធន់មិនបាន ទើបនាំគ្នាញុះញង់ថា បពិត្រព្រះសម្មតិទេព អមាត្យនោះនឹងធ្វើសេចក្តីវិនាសដល់ទ្រង់ ។ ព្រះរាជាទ្រង់កំណត់ពិចារណាមើលទោសរបស់អមាត្យនោះ ក៏មិនឃើញទោសណាមួយ ទ្រង់ព្រះតម្រិះថា យើងមិនឃើញទោសណាមួយរបស់អមាត្យនេះ ធ្វើម្តេចទើបយើងអាចដឹងថា អមាត្យនេះ ជាមិត្រ ឬមិនមែនមិត្រ ទ្រង់គិតបានថា វៀរព្រះតថាគតហើយ អ្នកដទៃមិនអាចដឹងបញ្ហានេះបាន អញនឹងទូលសួរ លុះទ្រង់សោយព្រះក្រយាហារស្រេចហើយ ក៏ចូលទៅគាល់ព្រះសាស្តាទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ធ្វើដូចម្តេចទើបបុគ្គលអាចដឹងថា នរណាជាមិត្រ ឬមិនមែនមិត្ររបស់ខ្លួន ។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងព្រះរាជាថា មហាបពិត្រ បណ្ឌិតក្នុងកាលមុនក៏គិតបញ្ហានេះ ហើយសាកសួរពួកបណ្ឌិត បណ្ឌិតទាំងឡាយនោះប្រាប់ ហើយវៀរជនដែលមិនមែនជាមិត្រ គប់រកតែមិត្រប៉ុណ្ណោះ ព្រះរាជាបានទូលអារាធនា ទើបទ្រង់នាំអតីតនិទានមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វសោយព្រះជាតិជាអមាត្យ ជាអ្នកបង្រៀនអត្ថ និងធម៌ដល់ព្រះរាជា កាលនោះ ក្នុងនគរពារាណសី មានអមាត្យម្នាក់ប្រព្រឹត្តប្រយោជន៍ដល់ព្រះរាជា ពួកអមាត្យដ៏សេសនាំគ្នាញុះញង់ព្រះរាជាៗ ទ្រង់មិនឃើញទោសរបស់អមាត្យនោះ ទ្រង់ព្រះតម្រិះថា ធ្វើម្ដេចហ្ន៎ ទើបអញដឹងថា អមាត្យនេះជាមិត្រ ឬមិនមែនមិត្រ កាលត្រាស់សួរព្រះមហាសត្វ បានត្រាស់គាថាទី ១ ថា

បណ្ឌិតអ្នកមានប្រាជ្ញាឃើញ ឬឮពួកជនកំពុងធ្វើនូវអំពើអ្វីៗ គប្បីដឹងថាជាអមិត្តបាន តើវិញ្ញូជនគប្បីព្យាយាមដូចម្ដេច ដូច្នេះ ។

ពាក្យដែលជាគាថានោះ មានអធិប្បាយថា បុរសជាបណ្ឌិតមានបញ្ញាឃើញបុគ្គលដែលធ្វើការងារដូចម្ដេចដោយចក្ខុ បានស្ដាប់រឿងនោះដោយត្រចៀក គប្បីដឹងថា បុគ្គលនេះ មិនមែនមិត្ររបស់យើង វិញ្ញូជនគប្បីព្យាយាមដូចម្ដេច ដើម្បីស្គាល់បុគ្គលនោះ ។

លំដាប់នោះ ព្រះមហាសត្វ កាលត្រាស់ប្រាប់លក្ខណៈរបស់បុគ្គលដែលមិនមែនជាមិត្រដល់ព្រះរាជា បានពោលព្រះគាថាដោយសេចក្ដីថា

បុគ្គលជាសត្រូវ ឃើញបុគ្គលនោះហើយ មិនញញឹម ១ មិនទទួលត្រេកអរនឹងសម្ដីបុគ្គលនោះ ១ មិនឲ្យភ្នែក ដល់បុគ្គលនោះ ១ ប្រព្រឹត្តទទឹងទាស់ ១ ។

បុគ្គលអែបអបនឹងពួកសត្រូវ របស់បុគ្គលនោះ ១ មិនសេព

គប់នឹងពួកមិត្ត របស់បុគ្គលនោះ ១ រារាំងពួកជន អ្នកនិយាយសរសើរ ១ សរសើរពួកជនអ្នកជេរ ១ ។

មិនប្រាប់សេចក្តីកំបាំង ដល់បុគ្គលនោះ ១ មិនលាក់សេចក្តីកំបាំងរបស់បុគ្គលនោះ ១ មិនសរសើរការងាររបស់បុគ្គលនោះ ១ មិនសរសើរប្រាជ្ញារបស់បុគ្គលនោះ ១ ។

ត្រេកអរនឹងសេចក្តីវិនាស របស់បុគ្គលនោះ ១ មិនត្រេកអរនឹងសេចក្តីចម្រើន របស់បុគ្គលនោះ ១ បានភោជនចម្លែក មិននឹកនាដល់បុគ្គលនោះ ១ មិនអនុគ្រោះបុគ្គលនោះ អំពីរបស់នោះថា ឱ មិត្តនោះ គប្បីបានរបស់នេះខ្លះ ១ ។

បណ្ឌិតឃើញ ឬឮហើយ ស្គាល់ថាជាអមិត្តបាន ដោយអាការទាំង ១៦ នេះ ដែលតម្កល់នៅក្នុងអមិត្តដោយប្រការដូច្នេះដូច្នេះ ។

ព្រះមហាសត្វត្រាស់គាថាទាំង ៥ នេះហើយ កាលព្រះរាជាត្រាស់សួរដល់លក្ខណៈរបស់មិត្រដោយគាថាទាំងនេះទៀតថា

បណ្ឌិតអ្នកមានប្រាជ្ញា ឃើញ ឬឮពួកជន កំពុងធ្វើការងារអ្វីៗ គប្បីដឹងថាជាមិត្តបាន តើវិញ្ញូជនគប្បីព្យាយាមដូចម្តេច ដូច្នេះ ។

ទើបព្រះមហាសត្វទូលគាថាដ៏សេសថា

បុគ្គលជាមិត្ត តែងនឹករឭកដល់មិត្តដែលនៅបែកគ្នា ១ ត្រេកអរនឹងមិត្តដែលមកដល់ ១ ជាអ្នករាប់អានចំពោះមិត្តនោះ ១ ទទួល

រីករាយដោយវាចា ១ ។

គប់រកនឹងពួកមិត្តរបស់មិត្តនោះ ១ មិនសេពគប់នឹងពួកអមិត្ត របស់មិត្តនោះ ១ ហាមឃាត់នូវពួកអ្នកជេរ ១ សរសើរពួកជន ដែលនិយាយសរសើរ ១ ។

ប្រាប់សេចក្ដីកំបាំង ដល់មិត្តនោះ ១ បិទបាំងសេចក្ដីកំបាំង របស់មិត្តនោះ ១ សរសើរការងាររបស់មិត្តនោះ ១ សរសើរ ប្រាជ្ញារបស់មិត្តនោះ ១ ។

ត្រេកអរនឹងសេចក្ដីចម្រើន របស់មិត្តនោះ ១ មិនត្រេកអរនឹង សេចក្ដីវិនាស របស់មិត្តនោះ ១ បានភោជនចម្លែក តែងនឹកនា ដល់មិត្តនោះ ១ អនុគ្រោះមិត្តនោះ អំពីរបស់នោះថា ឱ មិត្តនោះ គប្បីបានរបស់នេះខ្លះ ១ ។

បណ្ឌិតឃើញ ឬឮហើយ ស្គាល់ថាជាមិត្ត ដោយអាការទាំង ១៦ នេះ ដែលតម្កល់នៅក្នុងមិត្ត ដោយប្រការដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ន នំ ឧម្ហយតេ** សេចក្ដីថា បុគ្គលមិនមែន មិត្រ ឃើញមិត្របដិរូប មិនធ្វើនូវការញញឹម មិនសម្ដែងអាការត្រេកអរ ។ បទថា **ន ច នំ បដិនន្ទតិ** សេចក្ដីថា កាលទទួលពាក្យរបស់បុគ្គលនោះហើយ រមែងមិនសរសើរ មិនត្រេកអរ ។ បទថា **ចក្ខូនិ ចស្ស ន ទទា** សេចក្ដីថា កាលមិត្រសម្លឹងមើល ក៏មិនមើលតប ។ បទថា **បដិលោមញ្ច** សេចក្ដីថា ពោលទទឹងទាស់នូវពាក្យរបស់មិត្រ គឺជាសត្រូវ ។ បទថា **វណ្ណកាមេ** សេចក្ដី

ថា ពោលសរសើរគុណមិត្រ ។ បទថា **ឆក្ខាតិ** សេចក្តីថា បុគ្គលមិនមែនមិត្រ រមែងមិនប្រាប់អាថ៌កំបាំងរបស់ខ្លួនដល់មិត្រ ។ បទថា **កម្មំ តស្ស** សេចក្តីថា រមែងពណ៌នាកម្មដែលមិត្រនោះធ្វើ ។ បទថា **បញ្ញស្ស** សេចក្តីថា មិនសរសើរបញ្ញារបស់មិត្រ មិនសរសើរមិត្រដែលសម្បូរដោយបញ្ញា ។

បទថា **អភវេ** បានដល់ ក្នុងការមិនចម្រើន ។ បទថា **តស្ស នុប្បជ្ជតេ** សេចក្តីថា មិត្របដិរូប រមែងមិនកើតសតិថា អញនឹងឲ្យដល់មិត្ររបស់អញអំពីចំណែកនេះ ។ បទថា **ឆានុកម្បតិ** សេចក្តីថា រមែងមិនគិតដោយចិត្តទន់ភ្លន់ ។ បទថា **លភេយ្យិតោ** កាត់បទជា **លភេយ្យ ឥតោ** សេចក្តីថា មិត្រគប្បីបានលាភអំពីទីនេះ ។ បទថា **អាការា** បានដល់ ហេតុ ។ បទថា **បវុត្ថំ** បានដល់ ទៅទីឆ្ងាយ ។ បទថា **កេលាយិកោ** សេចក្តីថា បុគ្គលដែលជាមិត្រ រមែងស្រឡាញ់រាប់អានថា ជាសម្លាញ់របស់យើង ប្រាថ្នា ស្រឡាញ់ចូលចិត្ត ។ បទថា **វាចាយ** សេចក្តីថា កាលនឹងបន្ទឺនូវវាចាជាមួយមិត្រ ក៏បន្ទឺដោយពាក្យដែលពីរោះគួរត្រេកអរ ។ ពាក្យដ៏សេស គប្បីជ្រាបដោយន័យជាបដិបក្ខ ចំពោះពាក្យដែលពោលហើយនោះឯង ។

ព្រះរាជាមានព្រះហឫទ័យត្រេកអរ សរសើរនូវពាក្យរបស់ព្រះមហាសត្វ បានព្រះរាជទានយសធំក្រៃលែងដល់ព្រះមហាសត្វហើយ ។

ព្រះសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ត្រាស់ថា មហាបពិត្រ បញ្ហានេះ បានកើតឡើងក្នុងកាលមុនយ៉ាងនេះ បណ្ឌិតទាំងឡាយពោលដល់បញ្ហានេះថា បុគ្គលមិនមែនមិត្រ និងបុគ្គលជាមិត្រ គប្បីដឹងបានដោយអាការទាំង ៣២ នេះ ហើយទ្រង់ប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទ ក្នុងកាលឥឡូវនេះ អមាត្យដែលជាបណ្ឌិត ក្នុងកាលនោះ គឺតថាគតនេះឯង ។ល។

**អដ្ឋកថា មិត្តាមិត្តជាតក ចប់**

**ទ្វាទសកនិបាត ចប់**

# សុត្តន្តបិដក

## តេរសនិបាតជាតក

### អម្ពជាតក

[ ១០២៣ ] ( ព្រះបាទពារាណសី ត្រាស់សួរថា ) នែអ្នកប្រព្រឹត្ត ធម៌ដ៏ប្រសើរ កាលពីដើម អ្នកបានយកផ្លែស្វាយទាំងឡាយ តូចក៏មាន ធំក៏មាន មកឲ្យយើង នែព្រាហ្មណ៍ ឥឡូវនេះ ផ្លែឈើទាំងឡាយ មិនកើតប្រាកដដោយមន្តទាំងឡាយរបស់អ្នកនោះ ។

[ ១០២៤ ] ( ព្រាហ្មណមាណព ក្រាបទូលថា ) ខ្ញុំព្រះអង្គរាប់អាន នូវការប្រកបនូវនក្ខត្តឫក្ស ខ្ញុំព្រះអង្គមើលឃើញដោយមន្តតែមួយពេលមួយស្របក់ ខ្ញុំព្រះអង្គបាននូវការប្រកបនូវនក្ខត្តឫក្ស និងពេលហើយ សឹមខ្ញុំព្រះអង្គ នាំយកផ្លែស្វាយឲ្យបានច្រើន មកថ្វាយព្រះអង្គពុំខានឡើយ ។

[ ១០២៥ ] ( ព្រះរាជា ... ) កាលពីដើម អ្នកមិនបាននិយាយអាង នូវការប្រកបនូវនក្ខត្តឫក្ស ពីដើមមិនឃើញរកពេល រកស្របក់ តែអ្នកបានយកផ្លែស្វាយដ៏ច្រើន ដែលបរិបូណ៌ដោយពណ៌ ដោយក្លិន ដោយរស ( មកឲ្យយើង ) ។

[ ១០២៦ ] នែព្រាហ្មណ៍ កាលពីដើម ផ្លែឈើទាំងឡាយ រមែងកើតប្រាកដ ដោយការសូត្រសែកមន្តរបស់អ្នក ថ្ងៃនេះ អ្នកមិន

សូត្រសែកមន្ត តើធម្មតារបស់អ្នក ក្នុងថ្ងៃនេះដូចម្តេច ។

[ ១០២៧ ] ( មាណព ... ) កូនចណ្ឌាល បានឲ្យមន្តទាំងឡាយដល់ខ្ញុំព្រះអង្គដោយធម៌ ទាំងបាននិយាយប្រាប់ នូវប្រក្រតី គឺសេចក្តីវិនាសនៃមន្តទាំងឡាយថា បើមានគេសួរអ្នកកុំលាក់នាមនិងគោត្តរបស់ខ្ញុំ កុំឲ្យមន្តលះបង់អ្នកបាន ។

[ ១០២៨ ] ខ្ញុំព្រះអង្គ ដែលព្រះជនិន្ទ្រាធិរាជ សួរក្នុងប្រជុំជននោះ មានសេចក្តីលុបគុណគេគ្របសង្កត់ បានក្រាបទូលពាក្យកុហក ជាពាក្យខុសថា មន្តទាំងឡាយនេះ ជារបស់ព្រាហ្មណ៍ ខ្ញុំព្រះអង្គមានមន្តសាបសូន្យ ជាបុគ្គលកំព្រាយំទួញ ។

[ ១០២៩ ] ( ព្រះរាជា ... ) បុរសអ្នកត្រូវការដោយទឹកឃ្មុំ ទោះបានទឹកឃ្មុំ អំពីដើមល្ហុងខ្វែរក្តី អំពីដើមស្តៅក្តី ឬក៏អំពីដើមរលួសបាយក្តី ឯដើមឈើនោះ ឈ្មោះថា ជាឈើដ៏ប្រសើររបស់បុរសនោះ ។

[ ១០៣០ ] បុគ្គលចេះដឹងធម៌ អំពីជនណាទោះក្សត្រិយ៍ក្តី ព្រាហ្មណ៍ក្តី អ្នកជំនួញក្តី អ្នកគ្រួក្តី ចណ្ឌាលក្តី អ្នកចោលសំរាមក្តី ជននោះ ឈ្មោះថា ជាជនដ៏ប្រសើររបស់បុគ្គលនោះ ។

[ ១០៣១ ] បុរសណាញុំាងប្រយោជន៍ដ៏ឧត្តម ដែលខ្លួនបានមកហើយដោយលំបាក ឲ្យវិនាសទៅដោយមានះ និងអតិមានះ អ្នកទាំងឡាយ ចូរឲ្យនូវអាជ្ញាផង នូវការសម្លាប់ផង ដល់ជន

អាក្រក់នេះ ហើយចាប់បុរសដ៏លាមកនេះត្រង់កហើយញាំញី ។

[ ១០៣២ ] ( មាណព ... ) បុរសស្មានថា ( ទីនេះ ) រាបស្មើ ក៏លោតទៅកាន់ត្រពាំង គុហា ជ្រោះ និងឈើមានឫសស្អុយក្តី ដើរជាន់លើពស់វែកដោយស្មានថា ខ្សែក្តី បុគ្គលខ្វាក់ដើរជាន់ភ្លើងក្តី យ៉ាងណាៗ បពិត្រលោកប្រកបដោយប្រាជ្ញា សូមលោក ( អត់ទោស ) ចំពោះខ្ញុំ ដែលជាអ្នកភ្លាំងភ្លាត់ យ៉ាងនោះៗដែរ ហើយចែកមន្តឲ្យខ្ញុំ ដែលជាអ្នកមានមន្តសាបរលាបអស់ហើយ ម្តងទៀត ។

[ ១០៣៣ ] ( ពោធិសត្វ ... ) យើងបានឲ្យមន្តទាំងឡាយដល់អ្នក ដោយធម៌ហើយ គឺមិនយករង្វាន់អ្វីឡើយ ទាំងអ្នកក៏បានទទួលរៀនយកមន្ត ដោយធម៌ហើយដែរ យើងមានចិត្តត្រេកអរបានទាំងប្រាប់នូវប្រក្រតី ( នៃមន្ត ) ដល់អ្នកហើយ បើអ្នកតាំងនៅក្នុងធម៌ មន្តមិនលះបង់អ្នកបានទេ ។

[ ១០៣៤ ] ម្នាលបុគ្គលពាល អ្នកនោះ ធ្វើមន្តដែលខ្លួនបានហើយដោយលំបាក បានមកដោយកម្រ ក្នុងមនុស្សលោក ឲ្យវិនាសទៅក្នុងថ្ងៃនេះ អ្នកនោះជាអ្នកឥតប្រាជ្ញា ពោលពាក្យកុហកឈ្មោះថា ញុំាងជីវិតដែលខ្លួនបានដោយកម្រ ឲ្យវិនាស ។

[ ១០៣៥ ] យើងមិនឲ្យមន្តទាំងឡាយបែបនោះ ដល់មនុស្ស លួងខ្ញៅវង្វេង ជាអកតញ្ញូ ពោលពាក្យកុហក មិនសង្រួម ឯមន្តទាំងឡាយ មានមកពីណាទៀត អ្នកឯងចូរចេញទៅ អ្នកឯងមិនគាប់ចិត្តយើងទេ ។

## អម្ពជាតកទី ១ ចប់

# អដ្ឋកថា
# គោសនិបាតជាតក

## អម្ពជាតក

[ ១០២៣-១០៣៥ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធទេវទត្ត ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អាហាសិ មេ អម្ពផលានិ បុព្វេ** ដូច្នេះជាដើម ។

សេចក្តីពិស្តារថា ទេវទត្តលុបគុណអាចារ្យថា យើងជាព្រះពុទ្ធ ព្រះសមណគោតមមិនមែនអាចារ្យ មិនមែនឧបជ្ឈាយ៍របស់យើងឡើយ សាបសូន្យចាកឈាន បំបែកសង្ឃ កំពុងមកកាន់ក្រុងសាវត្ថីដោយលំដាប់ កាលផែនដីបើកឱកាស ចូលទៅកាន់អវីចីមហានរក ខាងក្រៅព្រះវិហារជេតពន ។ ក្នុងកាលនោះ ភិក្ខុទាំងឡាយ អង្គុយសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ ទេវទត្តលុបគុណអាចារ្យចោល ដល់នូវសេចក្តីវិនាសធំ កើតក្នុងអវីចីមហានរក ។ ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អំបាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ទេវទត្តក៏លុបគុណអាចារ្យដល់នូវសេចក្តីវិនាសដូចគ្នា ទើបទ្រង់នាំអតីតនិទានមកសាធក:ដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ត្រកូលនៃបុរោហិតរបស់ព្រះបាទព្រហ្មទត្តនោះវិនាសទៅដោយអហិវាតករោគ ។ កូនប្រុសម្នាក់ទម្លុះជញ្ជាំងផ្ទះរត់ទៅបាន ទៅដល់នគរតក្កសិលា រៀនត្រៃវេទ និងសិប្បៈដ៏សេស ក្នុងសម្នាក់អាចារ្យទិសាបាមោក្ខ ថ្វាយបង្គំលាអាចារ្យ ។ កាលនឹងចេញមកគិតថា អញនឹងត្រូវដឹងទំនៀមទំលាប់របស់ប្រទេស ទើបទៅដល់ជាយដែនមួយ ជាស្រុកធំនៃពួកចណ្ឌាល បានអាស្រ័យតំបន់នោះរស់នៅ ។ ក្នុងកាលនោះ ព្រះពោធិសត្វអាស្រ័យស្រុកនោះ បានជាបណ្ឌិតអ្នកឈ្លាសវៃ ដឹងមន្តដែលធ្វើឲ្យផ្លែស្វាយមានផ្លែពុំជួកាលបាន ។ លោកក្រោកឡើងអំពីព្រលឹម កាន់ដងរែកចេញអំពីស្រុកនោះ ទៅក្បែរដើមស្វាយមួយក្នុងព្រៃ ឈរក្នុងទីចម្ងាយ ៧ ជំហ៊ានរាយមន្ត បាចសាចដើមស្វាយនោះដោយទឹក ។ ខណៈនោះឯង ស្លឹកស្វាយចាស់ៗ ក៏ជ្រុះអំពីដើម ចេញត្រួយខ្ចី ចេញផ្កា ផ្លែស្វាយក៏មានឡើងមួយរំពេចប៉ុណ្ណោះ មានឱជាផ្អែម ដូចគ្នានឹងផ្លែស្វាយទិព្វ ហើយក៏ជ្រុះអំពីដើម ។ ព្រះមហាសត្វរើសផ្លែស្វាយនោះបរិភោគតាមសេចក្តីត្រូវការ ដាក់ពេញអម្រែករែកទៅកាន់ផ្ទះ លក់ដូរចិញ្ចឹមកូនប្រពន្ធ ។ ព្រាហ្មណកុមារនោះ ឃើញព្រះមហាសត្វនាំផ្លែស្វាយមកខុសរដូវកាល ហើយលក់ដូរ ទើបគិតថា មិនចាំបាច់សង្ស័យ ផ្លែស្វាយនោះ ពិតជាកើតឡើងដោយកម្លាំងរបស់មន្ត អាស្រ័យបុរសនេះ អញនឹងបានមន្តដែលមានតម្លៃកាត់ថ្លៃមិនបាននេះ រង់ចាំស្កាត់ផ្លូវដែលព្រះមហាសត្វនាំផ្លែស្វាយមក ក៏ដឹងពិតប្រាកដ កាលព្រះមហាសត្វមិនទាន់មកអំពីព្រៃ បានទៅកាន់ផ្ទះរបស់

លោក ធ្វើដូចមិនស្គាល់ សួរកិរិយារបស់លោកថា លោកអាចារ្យទៅណា កាលកិរិយាឆ្លើយថា ទៅព្រៃ ទើបឈររង់ចាំ លុះឃើញព្រះមហាសត្វមក ទើបទទួលអម្រែកអំពីដៃ ហើយរែកមកដាក់ក្នុងផ្ទះ ។ ព្រះពោធិសត្វសម្លឹងមើល ពោលនឹងកិរិយាថា នែនាង មាណពនេះមកដើម្បីមន្ត តែមន្តមិនតាំងនៅក្នុងដៃរបស់បុរសនេះបានឡើយ ព្រោះគេជាអសប្បុរស ចំណែកមាណពគិតថា អញត្រូវបំពេញឧបការៈដល់អាចារ្យ ទើបបានមន្តនេះ ។ តាំងអំពីនោះមក ធ្វើកិច្ចគ្រប់យ៉ាងក្នុងផ្ទះរបស់មហាសត្វ រកឧស បុកអង្ករ ចម្អិនបាយ ឲ្យទឹកលុបមុខ លាងជើងជាដើម ។ ថ្ងៃមួយ កាលព្រះមហាសត្វពោលថា នែមាណព ចូរអ្នកឲ្យគ្រឿងកល់ជើងគ្រែចុះ ។ មាណពមិនឃើញវត្ថុដទៃ ក៏យកជើងគ្រែដាក់លើភ្លៅរបស់ខ្លួន អង្គុយអស់មួយយប់ ។ ក្នុងកាលតមក កិរិយារបស់មហាសត្វប្រសូតបុត្រ បានធ្វើបរិកម្មក្នុងពេលប្រសូតបុត្រដល់នាង ។ ថ្ងៃមួយ ទើបនាងពោលជាមួយមហាសត្វថា បពិត្រអ្នក បុរសនេះសម្បូរជាយជាតិ ក៏គង់ធ្វើការងារឲ្យយើង ព្រោះហេតុតែមន្ត ទោះមន្តតាំងនៅក្នុងដៃរបស់គេ ឬមិនតាំងនៅក្តីក៏ហីទៅចុះ សូមឲ្យមន្តដល់បុរសនេះចុះ មហាសត្វទទួលថា សាធុ ហើយឲ្យមន្តដល់បុរសនោះ ហើយពោលយ៉ាងនេះថា នែបា មន្តនេះកាត់ថ្លៃមិនបាន លាភសក្ការៈដ៏ធំនឹងមានដល់ឯង ព្រោះអាស្រ័យមន្តនេះ ក្នុងពេលព្រះរាជា ឬមហាមាត្យរបស់ព្រះរាជាសួរថា នរណាជាអាចារ្យរបស់អ្នក កុំបំបាត់យើងចោល បើឯងលុបបំបាត់ពាក្យថា មនុស្សចណ្ឌាលជាអាចារ្យរបស់ខ្ញុំ ខ្ញុំរៀនមន្តអំពីសម្នាក់របស់មនុស្សចណ្ឌាល

នោះ ហើយពោលថា ព្រាហ្មណមហាសាលជាអាចារ្យរបស់ខ្ញុំសោត ផល របស់មន្តនេះនឹងមិនមានឡើយ បុរសនោះពោលថា រឿងអ្វីដែលខ្ញុំលុបបំបាត់ ក្នុងពេលដែលបុគ្គលណាម្នាក់សួរ ខ្ញុំត្រូវប្រាប់ដល់លោកអាចារ្យប៉ុណ្ណោះ រួច ថ្វាយបង្គំលាចេញអំពីស្រុកចណ្ឌាល សាកល្បងមន្តមើលហើយ ដល់នគរ ពារាណសីដោយលំដាប់ លក់ស្វាយបានទ្រព្យជាច្រើន ។

សម័យថ្ងៃមួយ ឧទ្យានបាល ទិញស្វាយអំពីដៃរបស់បុរសនោះ ថ្វាយ ដល់ព្រះរាជាៗ សោយស្វាយនោះហើយ ត្រាស់សួរថា គួរអស្ចារ្យ ស្វាយ នេះឆ្ងាញ់ក្រៃលែង ឯងបានស្វាយប្រភេទនេះមកអំពីណា បុរសនោះក្រាបទូល ថា បពិត្រព្រះអង្គ មាណពម្នាក់នាំផ្លែស្វាយនេះមកលក់ ទូលបង្គំកាន់យកអំពី មាណពនោះ ។ ទ្រង់ត្រាស់ថា ចូរឯងប្រាប់បុរសនោះថា តាំងអំពីនេះទៅ ចូរនាំផ្លែស្វាយមកកាន់ទីនេះ ។ ឧទ្យានបាលនោះ ក៏ធ្វើតាមព្រះតម្រាស់នោះ ។ តាំងអំពីនោះមក មាណពក៏នាំផ្លែស្វាយទាំងឡាយ ចូលទៅកាន់រាជត្រកូល កាលបានបញ្ជាថា ចូរឯងបម្រើយើងចុះ ក៏បម្រើព្រះរាជាបានទ្រព្យជាច្រើន និងការស្និទ្ធស្នាលដោយលំដាប់ ។ ថ្ងៃមួយ ព្រះរាជាត្រាស់សួរថា នែមាណព ឯងនាំផ្លែស្វាយដែលសម្បូរដោយក្លិន និងរសបែបនេះ ក្នុងសម័យមិនមែន ជារដូវកាលមកអំពីណា នាគ គ្រុឌ ឬទេវតាអង្គណាឲ្យដល់ឯង ឬថា នេះ ជាកម្លាំងនៃមន្ត បុរសនោះក្រាបទូលថា បពិត្រព្រះអង្គ មិនមានអ្នកណាឲ្យ ដល់ទូលបង្គំឡើយ តែមន្តដ៏មានតម្លៃរបស់ទូលបង្គំមាននេះ ជាកម្លាំងនៃមន្ត របស់ទូលបង្គំ ព្រះរាជាត្រាស់ថា បើយ៉ាងនោះ ពួកយើងចង់មើលកម្លាំងមន្ត

របស់ឯងបាន ១ ថ្ងៃ បុរសនោះក្រាបទូលថា បពិត្រព្រះអង្គ ទូលបង្គំនឹងសម្តែងថ្វាយទ្រង់ ។

ស្អែកឡើង ព្រះរាជាយាងទៅកាន់ព្រះរាជឧទ្យានជាមួយបុរសនោះ បានត្រាស់ថា ចូរឯងសម្តែងចុះ បុរសនោះទទួលព្រះតម្រាស់ថា សាធុ ដើរចូលទៅជិតដើមស្វាយឈរក្នុងទីចម្ងាយ ៧ ជំហ៊ាន រាយមន្ត ប្រស់ទឹកត្រង់ដើម ។ រំពេចនោះឯង ស្វាយក៏ចេញផ្លែដោយទំនងដូចពោលហើយខាងដើមនោះឯង ភ្លៀង គឺផ្លែស្វាយ ដូចគ្នានឹងមហាមេឃដែលធ្លាក់ចុះ ។ មហាជននាំគ្នាឲ្យសាធុការ ផ្ទាំងសំពត់ បានលើកឡើងកក្រើកទៅ ។ ព្រះរាជាទ្រង់សោយផ្លែស្វាយ ប្រទានទ្រព្យដ៏ច្រើនដល់បុរសនោះ ហើយត្រាស់សួរថា នែមាណពមន្តដ៏អស្ចារ្យរបស់ឯងនេះ ឯងរៀនក្នុងសម្នាក់របស់អ្នកណា មាណពគិតថា បើអញទូលថា ក្នុងសម្នាក់របស់ចណ្ឌាលក៏នឹងត្រូវអាប់រាសី អ្នកដទៃនឹងតិះដៀលបាន កុំដូច្នោះឡើយ មន្តរបស់អញស្ទាត់ជំនាញ គង់មិនវិនាសទៅក្នុងកាលឥឡូវនេះទេ អញនឹងយកអាចារ្យទិសាបាមោក្ខមកអាង ហើយធ្វើមុសាវាទពោលថា ទូលបង្គំរៀនក្នុងសម្នាក់អាចារ្យទិសាបាមោក្ខ ក្នុងនគរតក្កសិលា លុបបំបាត់នូវគុណរបស់អាចារ្យចោល រំពេចនោះឯង មន្តក៏វិនាស ។ ព្រះរាជាទ្រង់សោមនស្ស បបួលចូលកាន់ព្រះនគរ ស្អែកឡើងទ្រង់ព្រះតម្រិះថា អញនឹងសោយស្វាយ ទើបយាងចូលកាន់ព្រះរាជឧទ្យានប្រថាប់គង់លើផ្ទាំងថ្មដែលជាមង្គល ត្រាស់ថា មាណព ចូរឯងនាំស្វាយមកចុះ ។ បុរសនោះទទួលព្រះរាជតម្រាស់ថា សាធុ ហើយចូលទៅក្បែរដើម

ស្វាយ ឈរក្នុងចម្ងាយ ៧ ជំហ៊ាន គិតថា អញនឹងរាយមន្ត កាលមន្តមិនប្រាកដ ដឹងថា មន្តវិនាសហើយ ទើបឈរកើតទុក្ខ ។ ព្រះរាជាទ្រង់ព្រះតម្រិះថា ថ្ងៃមុន មាណពនេះ នាំស្វាយមកឲ្យអញក្នុងកណ្តាលបរិស័ទនោះឯង ឲ្យភ្លៀង គឺផ្លែស្វាយជ្រុះចុះមក ដូចភ្លៀងព្រិល ឥឡូវនេះ ឈរទ្រឹងព្រោះហេតុអ្វីហ្ន៎ កាលទ្រង់សាកសួរ ទើបត្រាស់គាថានេះថា

នៃអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ កាលពីដើម អ្នកបានយកផ្លែស្វាយទាំងឡាយ តូចក៏មាន ធំក៏មាន មកឲ្យយើង នៃព្រាហ្មណ៍ ឥឡូវនេះ ផ្លែឈើទាំងឡាយ មិនកើតប្រាកដដោយមន្តទាំងឡាយរបស់អ្នកនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អាហាសិ** បានដល់ នាំមកហើយ ។ បទថា **ទុមប្ផលានិ** បានដល់ ផ្លែនៃដើមឈើ ។ មាណពស្តាប់ព្រះតម្រាស់នោះហើយ គិតថា បើអញទូលថា ថ្ងៃនេះទូលបង្គំកាន់យកផ្លែស្វាយមកថ្វាយមិនបាន ព្រះរាជានឹងពិរោធអញ អញនឹងបញ្ឆោតព្រះរាជាដោយមុសាវាទ ទើបពោលគាថាទី ២ ថា

ខ្ញុំព្រះអង្គរាប់អាន នូវការប្រកបនូវនក្ខត្តឫក្ស ខ្ញុំព្រះអង្គមើលឃើញដោយមន្ត តែមួយពេល មួយស្របក់ ខ្ញុំព្រះអង្គបាននូវការប្រកបនូវនក្ខត្តឫក្ស និងពេលហើយ សឹមខ្ញុំព្រះអង្គ នាំយកផ្លែស្វាយឲ្យបានច្រើន មកថ្វាយព្រះអង្គពុំខានឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អទ្ធា ហរិស្សម្ពផលំ** សេចក្តីថា ទូលបង្គំ

នឹងនាំផ្លែស្វាយមកមិនខាន ។

ព្រះរាជាទ្រង់ព្រះតម្រិះថា មាណពនេះក្នុងកាលដទៃ មិនពោលដល់គន្ធន នក្ខត្តឫក្សឡើយ តើមានរឿងអ្វីហ្ន៎ កាលទ្រង់ត្រាស់សួរបានភាសិត ២ គាថាថា

កាលពីដើម អ្នកមិនបាននិយាយអាង នូវការប្រកបនូវនក្ខត្តឫក្ស ពីដើមមិនឃើញរកពេល រកស្របក់ តែអ្នកបានយកផ្លែស្វាយ ដ៏ច្រើន ដែលបរិបូណ៌ដោយពណ៌ ដោយក្លិន ដោយរស ( មក ឲ្យយើង ) ។

នែព្រាហ្មណ៍ កាលពីដើម ផ្លែឈើទាំងឡាយ រមែងកើតប្រាកដ ដោយការសូត្រសែកមន្តរបស់អ្នក ថ្ងៃនេះ អ្នកមិនសូត្រសែកមន្ត តើធម្មតារបស់អ្នក ក្នុងថ្ងៃនេះដូចម្ដេច ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ន វាទេសិ** បានដល់ រមែងមិនអាច ។ បទ ថា **ជប្បម្បិ** សេចក្ដីថា អ្នកនឹងនិយាយរវើរវាយក្ដី និងរាយមន្តក្ដី ។ បទថា **អយំ សោ** សេចក្ដីថា សភាវៈរបស់អ្នកនេះ ដូចម្ដេចក្នុងថ្ងៃនេះ ។

មាណពស្ដាប់ព្រះតម្រាស់នោះហើយ គិតថា អញមិនអាចបញ្ឆោត ព្រះរាជាដោយមុសាវាទ ទោះបីអញសារភាពសេចក្ដីពិតហើយ ទ្រង់គង់ មិនដាក់ព្រះរាជអាជ្ញា អញត្រូវសារភាពសេចក្ដីពិតចុះ ដូច្នេះហើយ ទើប ពោល ២ គាថាដោយសេចក្ដីថា

កូនចណ្ឌាល បានឲ្យមន្តទាំងឡាយ ដល់ខ្ញុំព្រះអង្គដោយធម៌ ទាំងបាននិយាយប្រាប់នូវប្រក្រតី គឺសេចក្ដីវិនាសនៃមន្តទាំងឡាយ

ថា បើមានគេសួរ អ្នកកុំលាក់នាម និងគោត្តរបស់ខ្ញុំ កុំឲ្យមន្ត លះបង់អ្នកបាន ។

ខ្ញុំព្រះអង្គ ដែលព្រះជនិន្ទ្រាធិរាជ សួរក្នុងប្រជុំជននោះ មាន សេចក្តីលុបគុណគេគ្របសង្កត់ បានក្រាបទូលពាក្យកុហក ជា ពាក្យខុសថា មន្តទាំងឡាយនេះ ជារបស់ព្រាហ្មណ៍ ខ្ញុំព្រះអង្គ មានមន្តសាបសូន្យ ជាបុគ្គលកំព្រាយំទួញ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ធម្មេន** សេចក្តីថា បានឲ្យមន្តដោយធម៌ ស្មើ ដោយហេតុ ដោយមិនបិទបាំងឡើយ ។ បទថា **បកតិញ្ច សំសិ** សេចក្តីថា កូនរបស់ចណ្ឌាល បានផ្តាំដល់ការវិនាស និងការប្រក្រតីនៃមន្ត ទាំងនោះដល់ខ្ញុំថា បើអ្នកណាម្នាក់សួរដល់នាម និងគោត្ររបស់យើង ឯងកុំ បិទបាំង បើបិទបាំង មន្តរបស់ឯងនឹងវិនាស ។ បទថា **ព្រាហ្មណោស្មាតិ មិច្ឆា** សេចក្តីថា ទូលបង្គំបានប្រាប់ខុសថា មន្តនេះទូលបង្គំបានរៀនមកអំពី សម្នាក់របស់ព្រាហ្មណ៍ ព្រោះដូច្នោះ ទើបមន្តទាំងឡាយរបស់ខ្ញុំវិនាស ខ្ញុំ មានមន្តវិនាសហើយ ឥឡូវនេះ ទួញយំដូចមនុស្សកំព្រា ។

ព្រះរាជាទ្រង់ស្តាប់ពាក្យនោះហើយ ទ្រង់ព្រះពិរោធត្រាស់ថា បុរសនេះ លាមក មើលមិនឃើញរតនៈបែបនេះ កាលបានរតនៈឧត្តមយ៉ាងនេះហើយ រឿងជាតិនឹងធ្វើអ្វីឲ្យបាន កាលទ្រង់តិះដៀល ទើបត្រាស់គាថាទាំងនេះថា

បុរសអ្នកត្រូវការដោយទឹកឃ្មុំ ទោះបានទឹកឃ្មុំ អំពីដើមល្ហុងខ្វែរ ក្តី អំពីដើមស្តៅក្តី ឬក៏អំពីដើមរលួសបាយក្តី ឯដើមឈើនោះ

ឈ្មោះថា ជាឈើដ៏ប្រសើររបស់បុរសនោះ ។

បុគ្គលចេះដឹងធម៌ អំពីជនណា ទោះក្សត្រិយ៍ក្តី ព្រាហ្មណ៍ក្តី អ្នកជំនួញក្តី អ្នកគ្រួក្តី ចណ្ឌាលក្តី អ្នកចោលសំរាមក្តី ជននោះ ឈ្មោះថា ជាជនដ៏ប្រសើររបស់បុគ្គលនោះ ។

បុរសណាញុំាងប្រយោជន៍ដ៏ឧត្តម ដែលខ្លួនបានមកហើយ ដោយលំបាក ឲ្យវិនាសទៅដោយមានះ និងអតិមានះ អ្នកទាំងឡាយ ចូរឲ្យនូវអាជ្ញាផង នូវការសម្លាប់ផង ដល់ជនអាក្រក់នេះ ហើយ ចាប់បុរសដ៏លាមកនេះត្រង់ក ហើយញុំាញី ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មជ្ឈត្តិកោ** សេចក្តីថា បុរសត្រូវការដោយទឹកឃ្មុំ ពិនិត្យមើលទឹកឃ្មុំក្នុងព្រៃ បានឃើញទឹកឃ្មុំត្រង់ដើមឈើនោះ អំពីទីណា ដើមឈើនោះឯង ចាត់ថាជាដើមឈើឧត្តមសម្រាប់បុគ្គលនោះ នរជនគប្បីដឹងធម៌ គឺហេតុនៃប្រយោជន៍ដែលគួរអំពីបុរសណា ក្នុងបណ្តាក្សត្រជាដើមយ៉ាងនោះ បុរសនោះឈ្មោះថា ជាបុគ្គលឧត្តមរបស់នរជននោះ ។ បទថា **ឥមស្ស ឧណ្ណាញ្ញ** សេចក្តីថា ចូរអ្នកទាំងឡាយបកស្បែកខ្នងរបស់បុរសដែលមានធម៌ដ៏លាមកនេះដោយចម្រៀកឫស្សីសម្រាប់វាយ និងដាក់អាជ្ញាគ្រប់យ៉ាង ហើយចាប់កបុរសថោកទាបនេះ បណ្តេញចេញទៅ ដាក់ទោសតាមទំនើងចិត្ត ហើយបណ្តេញទៅ ប្រយោជន៍អ្វីដោយបុរសនេះក្នុងទីនេះ ។

ពួករាជបុរសនាំគ្នាធ្វើតាមព្រះរាជអាជ្ញាយ៉ាងនេះ ហើយពោលថា ឯងទៅចុះ ទៅកាន់សម្នាក់អាចារ្យរបស់ឯង ធ្វើអាចារ្យរបស់ឯងឲ្យត្រេកអរ បើ

បានមន្តទៀតសឹមមកទីនេះ បើមិនបានកុំសម្លឹងមើលទិសនេះឡើយ ។ បានធ្វើបុរសនោះ ឲ្យអស់អំណាចនោះឯង បុរសនោះអស់ទីពឹងគិតថា វៀរអាចារ្យហើយទីពឹងដទៃរបស់អញមិនមាន អញត្រូវទៅរកលោក ធ្វើលោកឲ្យត្រេកអរ រៀននូវមន្តនោះសាជាថ្មី ទួញយំបណ្ដើរ ដើរទៅកាន់ស្រុកនោះបណ្ដើរ កាលនោះ មហាសត្វឃើញបុរសនោះដើរមក ក៏ហៅកិរិយាមកពោលថា នែនាងមើលចុះបុរសនេះអាក្រក់លាមក មន្តវិនាសអស់ហើយកំពុងត្រឡប់មក បុរសនោះចូលទៅរកព្រះមហាសត្វ ថ្វាយបង្គំហើយអង្គុយក្នុងទីសមគួរ នាចំណែកម្ខាង ព្រះពោធិសត្វសួរថា ហេតុអ្វីទើបឯងមក បុរសនោះពោលថា បពិត្រលោកអាចារ្យ ខ្ញុំធ្វើមុសាវាទលុបលូវគុណរបស់លោកអាចារ្យ ដល់នូវសេចក្ដីវិនាសធំ កាលសម្ដែងទោសដែលប្រព្រឹត្តកន្លងហើយ សូមរៀនមន្តជាថ្មី ទើបពោលគាថាដោយសេចក្ដីថា

បុរសស្មានថា ( ទីនេះ ) រាបស្មើ ក៏លោតទៅកាន់ត្រពាំង គុហាជ្រោះ និងឈើមានឫសស្អុយក្ដី ដើរជាន់លើពស់វែកដោយស្មានថា ខ្សែក្ដី បុគ្គលខ្វាក់ដើរជាន់ភ្លើងក្ដី យ៉ាងណាៗ បពិត្រលោកប្រកបដោយប្រាជ្ញា សូមលោក ( អត់ទោស ) ចំពោះខ្ញុំ ដែលជាអ្នកភ្លាំងភ្លាត់ យ៉ាងនោះៗ ដែរ ហើយចែកមន្តឲ្យខ្ញុំ ដែលជាអ្នកមានមន្តសាបរលាបអស់ហើយ ម្ដងទៀត ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យថា សមំ** សេចក្ដីថា បុរសសម្គាល់ថា ទីនេះ ជាទីរាបស្មើ គប្បីធ្លាក់ក្នុងអណ្ដូង គុហា ជ្រោះ ពោល គឺធ្លាក់អំពីទី

រាបស្មើ ឬឫសឈើពុក ។ បទថា **ឫតិចាធំ** សេចក្តីថា ដើមឈើធំក្នុងព្រៃហិមពាន្ត ជាឈើងាប់ កាលឫសទាំងឡាយរបស់ឈើធំនោះស្អុយរលួយ ទីនោះរមែងក្លាយជាអណ្តូងធំ នេះជាទីឈ្មោះថាអណ្តូងធំនោះ ។ បទថា **ជោតិ-មធិដ្ឋហេយ្យ** សេចក្តីថា គប្បីជាន់ភ្លើង ។ បទថា **ឯវម្បិ** សេចក្តីថា ខ្ញុំក៏ដូច្នោះ ជាបុគ្គលខ្វាក់ មិនមានភ្នែក គឺបញ្ញា មិនដឹងគុណវិសេសរបស់លោកភ្លាំងភ្លាត់ចំពោះលោកអាចារ្យ សូមលោកដឹងខ្ញុំថា ជាអ្នកភ្លាំងភ្លាត់ ។ បទថា **សបញ្ញា** សេចក្តីថា បពិត្រលោកអាចារ្យដែលសម្បូរដោយញាណ សូមឲ្យមន្តដល់ខ្ញុំដែលជាអ្នកវិនាសមន្តទៀតចុះ ។

លំដាប់នោះ អាចារ្យពោលនឹងបុរសនោះថា នែបា ឯងនិយាយអ្វី ធម្មតាបុគ្គលខ្វាក់ បើមានបុគ្គលឲ្យសញ្ញាហើយ រមែងចៀសអំពីអណ្តូងបាន ចំណែកយើងក៏ប្រាប់ឯងហើយអំពីដំបូងនោះឯង ឥឡូវនេះ ឯងចូលមករកយើងដើម្បីប្រយោជន៍អ្វី ហើយពោលគាថានេះថា

យើងបានឲ្យមន្តទាំងឡាយដល់អ្នក ដោយធម៌ហើយ គឺមិនយករង្វាន់អ្វីឡើយ ទាំងអ្នកក៏បានទទួលរៀនយកមន្តដោយធម៌ហើយដែរ យើងមានចិត្តត្រេកអរ បានទាំងប្រាប់នូវប្រក្រតី ( នៃមន្ត ) ដល់អ្នកហើយ បើអ្នកតាំងនៅក្នុងធម៌ មន្តមិនលះបង់អ្នកបានទេ ។ ម្នាលបុគ្គលពាល អ្នកនោះ ធ្វើមន្តដែលខ្វះបានហើយ ដោយលំបាក បានមកដោយកម្រ ក្នុងមនុស្សលោក ឲ្យវិនាសទៅក្នុងថ្ងៃនេះ អ្នកនោះជាអ្នកឥតប្រាជ្ញា ពោលពាក្យកុហក ឈ្មោះថា

ញាំងជីវិត ដែលខ្លួនបានដោយកម្រឲ្យវិនាស ។

យើងមិនឲ្យមន្តទាំងឡាយបែបនោះ ដល់មនុស្សល្ងង់ខ្លៅ វង្វេង ជាអកតញ្ញូ ពោលពាក្យកុហក មិនសង្រួម ឯមន្តទាំងឡាយ មានមកពីណាទៀត អ្នកឯងចូរចេញទៅ អ្នកឯងមិនគាប់ចិត្ត យើងទេ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ធម្មេន** សេចក្ដីថា យើងក៏មិនយកវង្វាន់ ទទួលប្រាក់ ឬមាសដែលជាទ្រព្យរបស់អាចារ្យ ព្រមប្រគល់ឲ្យដល់អ្នកដោយ ធម៌នោះឯង សូម្បីឯងសោតក៏មិនបានឲ្យអ្វី ទទួលយកដោយធម៌ ដោយហេតុ ស្មើគ្នា ។ បទថា **ធម្មេ ឋិតំ** បានដល់ តាំងនៅដោយធម៌របស់បុគ្គលដែល បូជាអាចារ្យ ។ បទថា **តាទិសកេ** សេចក្ដីថា យើងមិនព្រមឲ្យមន្តបែបនេះ គឺមន្តដែលឲ្យស្វាយមានផ្លែពុំជូកាល ចូរឯងទៅចុះ ឯងមិនគាប់ចិត្តយើង ឡើយ ។ បុរសនោះ ត្រូវអាចារ្យសម្ដីតយ៉ាងនេះ គិតថា អញនៅធ្វើអ្វី ទើបចូលទៅកាន់ព្រៃ ស្លាប់យ៉ាងអនាថា ។

ព្រះសាស្ដា កាលទ្រង់នាំយកព្រះធម្មទេសនានេះ មកសម្ដែងហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បី ក្នុងកាលមុន ទេវទត្តក៏លុបគុណអាចារ្យ ដល់នូវសេចក្ដីវិនាសធំមកហើយ ដូច្នេះហើយ ទើបទ្រង់ប្រជុំជាតកថា មាណពអកតញ្ញូក្នុងកាលនោះ បានមក ជាទេវទត្តក្នុងកាលឥឡូវនេះ ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទ ឯ បុត្រចណ្ឌាលក្នុងកាលនោះ គឺតថាគតនេះឯង ។៚

# សុត្តន្តបិដក

## ជន្ទុឆជាតក

[ ១០៣៦ ] ( កាឡសីហៈសួរថា ) អ្នកជាបុរសមានជីវក្នុងដៃ ចូលមកឈរនៅក្នុងព្រៃ នែសម្លាញ់ ខ្ញុំសួរហើយ ចូរអ្នកប្រាប់ តើអ្នកចង់កាប់ឈើអ្វី ។

[ ១០៣៧ ] ( វឌ្ឍកីព្រាហ្មណ៍តបថា ) អ្នកជាកាឡសីហៈ ត្រាច់ទៅកាន់ព្រៃស្មើ និងមិនស្មើ ម្នាលសម្លាញ់ ខ្ញុំសួរហើយ អ្នកចូរប្រាប់ឈើអ្វី ធ្វើខ្នងកង់ជាប់មាំ ។

[ ១០៣៨ ] ( កាឡសីហៈ ... ) ដើមរាំងក៏មិនជាប់ ដើមគគីរក៏មិនជាប់ ដើមត្រចៀកប្រើសក៏មិនជាប់ ដើមត្របែកក៏មិនជាប់ មានតែដើមពង្រ ឈើនោះ ធ្វើកង់រទេះជាប់មាំ ។

[ ១០៣៩ ] ( វឌ្ឍកី ... ) ស្លឹកពង្រនោះ បែបដូចម្តេច ដើមពង្រនោះបែបដូចម្តេច ម្នាលសម្លាញ់យើងសួរហើយ អ្នកចូរប្រាប់ យើងគប្បីស្គាល់ដើមពង្រយ៉ាងណា ។

[ ១០៤០ ] ( កាឡសីហៈ ... ) មែកឈើណា សំយុងចុះផង ទន់ទោរផង មិនបាក់ផង ខ្ញុំឈរក្បែរគល់ឈើណា ឈើនោះហើយជាដើមពង្រ ។

[ ១០៤១ ] ដើមពង្រនេះ គួរដល់ការងាររបស់អ្នក ដើម្បីកាំរទេះទាំងឡាយ ដើម្បីកង់ និងដុំរទេះទាំងឡាយ ដើម្បីចន្ទោលរទេះ និងខ្នងកង់រទេះ និងរបស់សព្វគ្រប់ ក្រៅពីនេះទាំងអស់ ។

[ ១០៤២ ] ( អភិសម្ពុទ្ធគាថា ) ព្រោះហេតុនោះ ទេវតាអាស្រ័យនៅលើដើមពន្រ្ទ បាននិយាយថា ពាក្យរបស់ខ្ញុំក៏មានដែរ ម្នាលការទ្វាជព្រាហ្មណ៍ អ្នកឯងចូរស្តាប់ពាក្យខ្ញុំសិន ។

[ ១០៤៣ ] អ្នកចូរអារយកស្បែកខ្លាឃ្មុំនេះត្រង់ក ចំនួន ៤ ធ្នាប់ ហើយយកស្បែកនោះ មកទ្រាប់ខ្នងកង់រទេះ ធ្វើយ៉ាងនេះ ទើបជាប់មាំមួន ។

[ ១០៤៤ ] ទេវតាដែលអាស្រ័យនៅលើដើមពន្រ្ទ បានសម្រេចពៀរហើយ បាននាំយកសេចក្តីទុក្ខ មកឲ្យដល់ខ្លាឃ្មុំទាំងឡាយ ដែលកើតហើយផង ដែលមិនទាន់កើតហើយផង ដោយប្រការដូច្នេះ ។

[ ១០៤៥ ] ដើមពន្រ្ទចងពៀរនឹងខ្លាឃ្មុំ ឯខ្លាឃ្មុំចងពៀរនឹងដើមពន្រ្ទ ហើយបានសម្លាប់គ្នាទៅវិញទៅមក ដោយការទាស់ទែងគ្នាទៅវិញទៅមក ដោយប្រការដូច្នេះឯង ។

[ ១០៤៦ ] ខ្លាឃ្មុំ និងដើមពន្រ្ទនោះ ចងពៀរវេរាយ៉ាងណា ការទាស់ទែងរបស់មនុស្សទាំងឡាយ កើតមានក្នុងទីណា មនុស្សទាំងនោះ ឈ្មោះថា រាំដូចជាក្ងោកពង្ស ក្នុងទីនោះក៏យ៉ាងនោះដែរ ។

[ ១០៤៧ ] តថាគតនឹងសម្តែងនូវហេតុនោះ ថ្វាយមហារាជ ពួកមនុស្សដែលមកប្រជុំក្នុងទីនេះ មានចំនួនប៉ុន្មាន សូមសេចក្តីចម្រើន មានដល់មហាបពិត្រ មានចំនួនប៉ុណ្ណោះ សូមមហា-

បពិត្រ ព្រមព្រៀងគ្នាកុំទាស់ទែងគ្នា កុំឲ្យដូចខ្លាឃ្មុំ និងដើមពន្រៃឡើយ ។

[ ១០៤៨ ] សូមមហាបពិត្រ សិក្សានូវសេចក្តីព្រមព្រៀងគ្នាតែម្យ៉ាង ព្រោះសេចក្តីព្រមព្រៀងគ្នានោះ ព្រះពុទ្ធទាំងឡាយសរសើរហើយ បុគ្គលអ្នកត្រេកអរ ក្នុងសេចក្តីព្រមព្រៀងគ្នាអ្នកតាំងនៅក្នុងធម៌ រមែងមិនសាបសូន្យចាកព្រះនិព្វាន ជាទីក្សេមចាកយោគៈទាំងឡាយឡើយ ។

**ផន្ទនជាតកទី ២ ចប់**

# អដ្ឋកថា

## ជវនជាតក

[ ១០៣៦-១០៤៨ ] ព្រះសាស្តា កាលគង់នៅទាប្រាំងស្ទឹងរោហិណី ទ្រង់ប្រារព្ធការឈ្លោះគ្នានៃព្រះញាតិ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **កុឋារិហត្ថោ បុរិសោ** ដូច្នេះជាដើម ។

សេចក្ដីនេះ នឹងមានច្បាស់ក្នុងកុណាលជាតក តែក្នុងកាលនោះ ព្រះសាស្ដាត្រាស់ហៅពួកញាតិមកត្រាស់ថា ថ្វាយព្រះពរមហាបពិត្រទាំងឡាយ ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី មានស្រុកជាងឈើនៅខាងក្រៅព្រះនគរ ត្រង់ស្រុកនោះ មានព្រាហ្មណ៍ម្នាក់ជាជាងឈើ រកឈើមកអំពីព្រៃ ធ្វើនូវរថចិញ្ចឹមជីវិត កាលនោះ ក្នុងហិមវន្តប្បទេស មានដើមពង្រធំ មានខ្លាឃ្មុំមួយដើររកស៊ី ហើយមកដេកត្រង់គល់ពង្រនោះ ។ ថ្ងៃមួយ កាលខ្យល់បក់មក មែកពង្រងាប់មួយបានធ្លាក់មកត្រូវកខ្លាឃ្មុំនោះ ។ ខ្លាឃ្មុំគ្រាន់តែមែកពង្រធ្លាក់មកត្រូវក ភិតភ័យ ក្រោកឡើងរត់ទៅ ហើយវិលត្រឡប់មកសាជាថ្មី សម្លឹងមើលផ្លូវដែលរត់មក មិនឃើញអ្វី គិតថា សីហៈ ឬខ្លាដទៃៗ ដែលដេញមកមិនមានឡើយ តែទេវតាដែលកើតត្រង់ដើមឈើនេះ ប្រហែលជាមិនចង់ឲ្យអញដេកក្នុងទីនេះ ណ្ហើយចុះយើងគង់ដឹងគ្នា ហើយចងសេចក្ដីក្រោធក្នុងហេតុដែលមិនគួរ ហើយយកក្រចកទះដើមពង្រ សម្តុតរុក្ខទេវតាថា អញមិនបានស៊ីស្លឹកឈើរបស់ឯងឡើយ អញមិនបានកាច់មែកឈើ ម្រឹគដទៃៗ នាំគ្នាដេកត្រង់ទីនេះ ឯងអត់ធន់បាន ឯអញឯងអត់ធន់មិនបាន ទោសអ្វីរបស់អញ រង់ចាំ ២-៣ ថ្ងៃទៀតចុះ

អញនឹងឲ្យគេជីកដើមឈើរបស់ឯងទាំងឫសទាំងគល់ ហើយឲ្យកាត់ជាកំណាត់តូច-ធំ ឲ្យខានតែបាន ហើយត្រាច់ដើររកបុរសណាមួយរឿយៗ ទៅ ។ កាលនោះ ព្រាហ្មណ៍ដែលជាជាងឈើនោះ នាំមនុស្ស ២-៣ នាក់ទៅដល់ទីនោះដោយយានតូច ដើម្បីឈើធ្វើរថ ចតយានតូចក្នុងទីមួយកន្លែង កាន់កាំបិតព្រា និងពូថៅ ដើរជ្រើសរើសដើមឈើ រហូតដល់ជិតដើមពន្រ ខ្លាឃ្មុំជួបបុរសនោះហើយ គិតថា ថ្ងៃនេះ អញនឹងឃើញខ្នងរបស់បច្ចាមិត្ត បានមកឈរត្រង់គល់ពន្រ ចំណែកជាងឈើវិញ សម្លឹងមើលក្នុងទីផ្សេងៗ ដើរទៅមិនឆ្ងាយអំពីដើមពន្រ ខ្លាឃ្មុំគិតថា អញត្រូវប្រាប់បុរសនេះកុំឲ្យគេដើរហួសទៅ ដូច្នេះហើយ ទើបពោលគាថាទី ១ ថា

អ្នកជាបុរសមានដឹងក្នុងដៃ ចូលមកឈរនៅក្នុងព្រៃ នែសម្លាញ់
ខ្ញុំសួរហើយ ចូរអ្នកប្រាប់ តើអ្នកចង់កាប់ឈើអ្វី ដូច្នេះ ។

បណ្តាបទថាទាំងនោះ បទថា **បុរិសោ** សេចក្តីថា អ្នកជាបុរសម្នាក់កាន់ដឹងចូលកាន់ព្រៃនេះ ហើយឈរ ។

បុរសនោះ ស្តាប់ពាក្យរបស់ខ្លាឃ្មុំហើយ គិតថា អស្ចារ្យពិតហ្ន៎ ម្រឹគពោលភាសាមនុស្ស អញមិនធ្លាប់ឃើញមកអំពីមុនឡើយ សត្វនេះគង់ស្គាល់ឈើដែលសមគួរដល់ការធ្វើរថ អញត្រូវសាកសួរសត្វនេះលមើល ទើបពោលគាថាទី ២ ថា

អ្នកជាកាឡសីហៈ ត្រាច់ទៅកាន់ព្រៃស្មើ និងមិនស្មើ ម្នាល
សម្លាញ់ ខ្ញុំសួរហើយ អ្នកចូរប្រាប់ ឈើអ្វី ធ្វើខ្នងកង់ជាប់មាំ

ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឱសោ** សេចក្ដីថា ឯងជាខ្វាឃ្មុំមួយត្រាច់ទៅក្នុងព្រៃ គង់ស្គាល់ឈើដែលគួរធ្វើកង់រថបាន ។ ខ្វាឃ្មុំស្ដាប់ដូច្នោះ គិតថា ឥឡូវនេះ មនោរថរបស់អញដល់ទីបំផុតហើយ ដូច្នេះហើយ ទើបពោលគាថា ទី ៣ ថា

ដើមរាំង ក៏មិនជាប់ ដើមគគីរ ក៏មិនជាប់ ដើមត្រចៀកប្រើស
ក៏មិនជាប់ ដើមត្របែក ក៏មិនជាប់ មានតែដើមពង្រ ឈើនោះ
ធ្វើកង់រទេះជាប់មាំ ដូច្នេះ ។

បុរសនោះបានស្ដាប់ពាក្យរបស់ខ្វាឃ្មុំនោះហើយ កើតនូវសោមនស្សថា ថ្ងៃនេះ ជាថ្ងៃល្អពិតហ្ន៎ ដែលអញចូលព្រៃ សត្វតិរច្ឆានប្រាប់ឈើដែលសមគួរ ធ្វើរថដល់អញ ឱ ល្អហ្ន៎ កាលនឹងសួរ ទើបពោលគាថាទី ៤ ថា

ស្លឹកពង្រនោះ បែបដូចម្ដេច ដើមពង្រនោះ បែបដូចម្ដេច ម្នាល
សម្លាញ់ យើងសួរហើយ អ្នកចូរប្រាប់ យើងគប្បីស្គាល់ដើមពង្រ
យ៉ាងណា ដូច្នេះ ។

លំដាប់នោះ ខ្វាឃ្មុំកាលនឹងប្រាប់ បានពោល ២ គាថាថា

មែកឈើណា សំយុងចុះផង ទន់ទោរផង មិនបាក់ផង ខ្ញុំឈរ
ក្បែរគល់ឈើណា ឈើនោះហើយ ជាដើមពង្រ ។

ដើមពង្រនេះ គួរដល់ការងាររបស់អ្នក ដើម្បីកាំរទេះទាំងឡាយ
ដើម្បីកង់ និងដុំរទេះទាំងឡាយ ដើម្បីចន្ទោលរទេះ និងខ្នងកង់

រទេះ និងរបស់សព្វគ្រប់ ក្រៅពីនេះទាំងអស់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អាភានំ** សេចក្តីថា ខ្លាឃ្មុំនោះគិតថា ជួនកាលបុរសនេះ មិនកាន់យកដើមឈើនេះក៏ថាបាន អញត្រូវប្រាប់នូវគុណរបស់ឈើនេះខ្លះ ទើបពោលយ៉ាងនេះ ។ បទថា **ឦសានេមិរថស្ស ច** សេចក្តីថា ដើមពង្រនេះគួរដល់ការងារ គឺសមដល់ការងារដែលនឹងធ្វើចន្ទោលរថ ខ្នងកង់រថ និងគ្រឿងរថដ៏សេសសព្វយ៉ាងរបស់លោក ។

ខ្លាឃ្មុំនោះកាលប្រាប់យ៉ាងនេះហើយត្រេកអរ ដើរទៅចំណែកម្ខាង ជាងឈើក៏ត្រៀមការកាប់ដើមឈើ ។ រុក្ខទេវតាគិតថា អ្វីៗ អញមិនបានឲ្យធ្លាក់លើខ្លួនខ្លាឃ្មុំៗ នេះ ចងអាឃាតក្នុងវត្ថុដែលមិនមែនជាហេតុ កំពុងទម្លាយវិមានរបស់អញ ខ្លួនអញនឹងលំបាក អញត្រូវបំផ្លាញខ្លាឃ្មុំនេះដោយឧបាយឯណានីមួយឲ្យបាន កាឡាខ្លួនជាមនុស្សធ្វើការក្នុងព្រៃ មកកាន់សម្នាក់របស់ជាងឈើនោះ ហើយសួរថា នែបុរសដ៏ចម្រើន លោកបានដើមឈើត្រូវចិត្តហើយ លោកកាប់ដើមឈើនេះទៅធ្វើអ្វី ជាងឈើឆ្លើយថា នឹងធ្វើកង់រថ ។ រុក្ខទេវតាសួរថា នរណាប្រាប់អ្នកថា ដើមឈើនេះធ្វើរថបាន ក៏ឆ្លើយថា ខ្លាឃ្មុំមួយជាអ្នកប្រាប់ រុក្ខទេវតាក៏ពោលថា ល្អហើយ ដែលខ្លាឃ្មុំនោះប្រាប់ តែបើលោកពន្លាត់ស្បែកកខ្លាឃ្មុំ ៤ ធ្នាប់ ហើយយកស្បែកនោះរុំត្រង់កង់រថ ដូចស្រោបដោយបន្ទះដែក កង់រថនឹងជាប់មាំក្រៃលែង ហើយអ្នកនឹងបានទ្រព្យច្រើន ។ ជាងឈើសួរថា ខ្ញុំនឹងបានស្បែកខ្លាឃ្មុំមកអំពីណា រុក្ខទេវតាពោលថា លោកជាមនុស្សល្ងង់ខ្លៅ ដើមឈើនេះតាំងនៅក្នុងព្រៃ មិនគេចទៅណាឡើយ ចូរ

លោកទៅកាន់សម្នាក់ខ្វាឃ្មុំដែលប្រាប់ដើមឈើនេះ បញ្ឆោតខ្វាឃ្មុំថា នែអ្នក ខ្ញុំកាប់ដើមឈើដែលអ្នកបង្ហាញត្រង់ណា ហើយនាំខ្វាឃ្មុំមក ខណៈដែលខ្វាឃ្មុំអស់រង្កៀស កំពុងឈរប្រាប់ថា កាប់ត្រង់នេះ ត្រង់នោះ ចូរលោកកាប់ខ្វាឃ្មុំដោយដឹងធំដ៏មុតឲ្យអស់ជីវិត ពន្លាត់ស្បែកស៊ីសាច់ដែលល្អៗ ហើយសឹមកាប់ដើមឈើ រុក្ខទេវតាបានចងពៀរនឹងខ្វាឃ្មុំសម្រេចហើយ ។

ព្រះសាស្តា កាលប្រកាសសេចក្តីនោះ ទើបត្រាស់គាថាទាំងនេះថា

ព្រោះហេតុនោះ ទេវតាអាស្រ័យនៅលើដើមពង្រ បាននិយាយ
ថា ពាក្យរបស់ខ្ញុំក៏មានដែរ ម្នាលភារទ្វាជព្រាហ្មណ៍ អ្នកឯងចូរ
ស្តាប់ពាក្យខ្ញុំសិន ។

អ្នកចូរអារយកស្បែកខ្វាឃ្មុំនេះត្រង់ក ចំនួន ៤ ធ្នាប់ ហើយយក
ស្បែកនោះ មកទ្រាប់ខ្នងកង់រទេះ ធ្វើយ៉ាងនេះ ទើបជាប់
មាំមួន ។

ទេវតាដែលអាស្រ័យនៅលើដើមពង្រ បានសម្រេចពៀរហើយ
បាននាំយកសេចក្តីទុក្ខ មកឲ្យដល់ខ្វាឃ្មុំទាំងឡាយ ដែលកើត
ហើយផង ដែលមិនទាន់កើតហើយផង ដោយប្រការ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ភារទ្វាជ** ជាពាក្យដែលទេវតាហៅជាងឈើដោយគោត្រ ។ បទថា **ឧបក្ខន្ធម្ហា** បានដល់ ត្រង់ជង្គក ។ បទថា **ឧក្កច្ច** បានដល់ ពន្លាត់ ។ ជាងឈើស្តាប់ពាក្យរបស់រុក្ខទេវតា គិតថា ឱ ថ្ងៃនេះ ជាថ្ងៃមង្គលរបស់អញ សម្លាប់ខ្វាឃ្មុំ កាប់ដើមពង្រហើយ ចៀសចេញទៅ ។

ព្រះសាស្តាកាលទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់គាថាទាំងឡាយថា

ដើមពង្រចងពៀរនឹងខ្លាឃ្មុំ ឯខ្លាឃ្មុំចងពៀរនឹងដើមពង្រហើយ

បានសម្លាប់គ្នាទៅវិញទៅមក ដោយការទាស់ទែងគ្នាទៅវិញ

ទៅមក ដោយប្រការដូច្នេះឯង ។

ខ្លាឃ្មុំ និងដើមពង្រនោះ ចងពៀរវេរាយ៉ាងណា ការទាស់ទែង

របស់មនុស្សទាំងឡាយ កើតមានក្នុងទីណា មនុស្សទាំងនោះ

ឈ្មោះថា រាំដូចជាក្ងោកពង្ស ក្នុងទីនោះ ក៏យ៉ាងនោះដែរ ។

តថាគតនឹងសម្តែងនូវហេតុនោះ ថ្វាយមហារាជ ពួកមនុស្ស

ដែលមកប្រជុំក្នុងទីនេះ មានចំនួនប៉ុន្មាន សូមសេចក្តីចម្រើន មាន

ដល់មហាបពិត្រ មានចំនួនប៉ុណ្ណោះ សូមមហាបពិត្រ ព្រម

ព្រៀងគ្នា កុំទាស់ទែងគ្នា កុំឲ្យដូចខ្លាឃ្មុំ និងដើមពង្រឡើយ ។

សូមមហាបពិត្រ សិក្សានូវសេចក្តីព្រមព្រៀងគ្នាតែម្យ៉ាង ព្រោះ

សេចក្តីព្រមព្រៀងគ្នានោះ ព្រះពុទ្ធទាំងឡាយ សរសើរហើយ

បុគ្គលអ្នកត្រេកអរក្នុងសេចក្តីព្រមព្រៀងគ្នា អ្នកតាំងនៅក្នុងធម៌

រមែងមិនសាបសូន្យចាកព្រះនិព្វាន ជាទីក្សេមចាកយោគៈទាំង

ឡាយឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អាឃាតយុំ** បានដល់ ញុះញង់ឲ្យសម្លាប់ គ្នាទៅវិញទៅមក ។ បទថា **មយូរនច្ចំ នច្ចន្តិ** សេចក្តីថា មហាបពិត្រ បណ្តាមនុស្សទាស់ទែងគ្នាមានក្នុងទីណា ហ្វូងមនុស្សក្នុងទីនោះ ដូចក្ងោករាំ

ពែនពង្ស ធ្វើទីដែលគួរបិទបាំង គឺកេ្តីខ្ញាសឲ្យប្រាកដ យ៉ាងណា មនុស្ស ទាំងនោះក៏ដូច្នោះដូចគ្នា កាលប្រកាសទោសនៃគ្នានិងគ្នា ឈ្មោះថា រាំដូចការ រាំពែនពង្សនៃបក្សីក្ងោក ។ ដូចខ្លាឃ្មុំ និងដើមពង្រទាំងនោះ ប្រកាសទោស នៃគ្នានិងគ្នា ក៏ឈ្មោះថា រាំ ។ បទថា **តំ វោ** សេចក្តីថា ព្រោះហេតុនោះ តថាគតសូមថ្វាយព្រះពរមហាបពិត្រទាំងឡាយ ។ បទថា **ភទ្ទំ វោ** បានដល់ សូមសេចក្តីចម្រើនមានដល់មហាបពិត្រទាំងឡាយ ។ បទថា **យាវន្តេត្ថ** កាត់ បទជា **យាវន្តោ ឯត្ថ** គឺពួកទ្រង់ទាំងឡាយ កុំមានសភាពដូចគ្នានឹងខ្លាឃ្មុំ និងដើមពង្រឡើយ ។ បទថា **សាមគ្យមេវ** សេចក្តីថា មហាបពិត្រទាំងឡាយ ចូរសិក្សាភាពជាអ្នកព្រមព្រៀងដល់គ្នានិងគ្នាតែម្យ៉ាងចុះ នេះជាប្រការដែល បណ្ឌិតអ្នកចម្រើនដោយបញ្ញាសរសើរហើយ ។ បទថា **ធម្មដ្ឋោ** សេចក្តីថា តាំងនៅក្នុងសុចរិតធម៌ ។ បទថា **យោគក្ខេមា** បានដល់ ចាកនិព្វានដែលជា ដែនក្សេមចាកយោគៈទាំងឡាយ ។ បទថា **ន ធំសតិ** សេចក្តីថា រមែងមិន សាបសូន្យ ។ ព្រះសាស្តា កាន់យកកំពូលនៃទេសនាដោយព្រះនិព្វាន ដោយ ប្រការដូច្នេះ ។ ព្រះរាជាទាំងឡាយ ទ្រង់ស្តាប់ធម្មកថារបស់ព្រះសាស្តាហើយ ទ្រង់ក៏សាមគ្គីព្រមព្រៀងគ្នាបាន ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះ មកសម្តែងហើយ ទើបទ្រង់ប្រជុំជាតកថា ទេវតាស្ថិតនៅក្នុងដងព្រៃនោះ ឃើញរឿងនោះ ក្នុងកាលនោះ គឺតថាគតនេះឯង ។៚

**អដ្ឋកថា ផន្ទនជាតក ចប់**

# សុត្តន្តបិដក

## ជវនហំសជាតក

[ ១០៤៩ ] ( ព្រះបាទពារាណសី មានព្រះរាជឱង្ការថា ) នែហង្ស ឯងចូរទំលើតាំងមាសនេះចុះ ការឃើញឯង ជាទីពេញចិត្តរបស់អញ ឯងសមគួរជាធំហើយ របស់ណាមានក្នុងទីនេះ ឯងចូរប្រាប់មកចុះ ។

[ ១០៥០ ] ( រាជហង្ស ... ) បុគ្គលខ្លះ គ្រាន់តែឮហើយស្រឡាញ់ក៏មាន ខ្លះគ្រាន់តែឃើញគ្នាហើយ អស់សេចក្តីស្រឡាញ់ក៏មាន ខ្លះឃើញផង ឮផង ទើបស្រឡាញ់ក៏មាន ចុះព្រះអង្គ គ្រាន់តែឃើញ តើស្រឡាញ់ខ្ញុំដែរឬទេ ។

[ ១០៥១ ] ( ព្រះរាជា ... ) អញគ្រាន់តែបានឮ ស្រឡាញ់ឯងទៅហើយ លុះបានឃើញ អញរឹតតែស្រឡាញ់ឡើង នែហង្ស ឯង អញឃើញហើយស្រឡាញ់យ៉ាងនេះ ឯងចូរនៅក្នុងសម្នាក់អញចុះ ។

[ ១០៥២ ] ( រាជហង្ស ... ) ខ្ញុំនៅក្នុងដំណាក់របស់ព្រះអង្គ ព្រះអង្គធ្វើសក្ការបូជា អស់កាលជានិច្ចហើយ តែក្រែងពេលណាមួយ ព្រះអង្គស្រវឹងដោយទឹកស្រវឹងហើយ ទ្រង់ត្រាស់បង្គាប់ថា នាយពិសេស ចូរចម្អិនសាច់ស្តេចហង្ស យកមកឲ្យយើង ។

[ ១០៥៣ ] ( ព្រះរាជា ... ) ថ្វីយ ! ខ្ញើម ការផឹកទឹកស្រវឹងដែលជាទីស្រឡាញ់របស់អញ ជាងឯង បើឯងនៅក្នុងដំណាក់

អញជរាបណា អញនឹងមិនផឹកទឹកស្រវឹងជរាបនោះ ។

[ ១០៥៤ ] ( រាជហង្ស ... ) សម្ដីរបស់ពួកចចក និងពួកបក្សី យល់បានងាយ បពិត្រមហារាជ សម្ដីរបស់ពួកមនុស្ស កម្រដឹងបាន ជាងសម្ដីសត្វនោះទៅទៀត ។

[ ១០៥៥ ] មួយទៀត បើបុរសណា កាលពីដើម មានចិត្តល្អ គេសម្គាល់ថាជាញាតិ ជាមិត្ត ឬជាសម្លាញ់ តែលុះដល់ពេលខាងក្រោយមក បុរសនោះ ត្រឡប់ជាសត្រូវនឹងគ្នាទៅវិញ ក៏មាន ។

[ ១០៥៦ ] បុគ្គលណា មានចិត្តស្មោះស្មើ ដោយសារសេចក្ដីស្រឡាញ់ បុគ្គលនោះ ឈ្មោះថានៅជិតជាមួយគ្នា បុគ្គលណា មានចិត្តមិនស្មោះស្មើ បុគ្គលនោះ ទោះនៅក្នុងទីជិត ក៏ហាក់ដូចជានៅក្នុងទីឆ្ងាយ ។

[ ១០៥៧ ] សម្លាញ់ណា ជាអ្នកមានចិត្តជ្រះថ្លារកគ្នា បើទុកជានៅឯត្រើយសមុទ្រខាងនាយ សម្លាញ់ដែលមានចិត្តជ្រះថ្លារកគ្នានោះ ក៏ឈ្មោះថា នៅក្នុងសមុទ្រជាមួយគ្នា សម្លាញ់ណាមានចិត្តប្រទូស្តរកគ្នា បើទុកជានៅក្នុងសមុទ្រជាមួយគ្នា សម្លាញ់ដែលមានចិត្តប្រទូស្តគ្នានោះ ក៏ឈ្មោះថា នៅត្រើយសមុទ្រខាងនាយវិញ ។

[ ១០៥៨ ] បពិត្រព្រះអង្គ ជាបុគ្គលប្រសើរលើរថ បុគ្គលទាំងឡាយណា ជាសត្រូវនឹងគ្នា បើទុកជានៅជាមួយគ្នា បុគ្គលទាំង

នោះ ក៏ឈ្មោះថានៅផ្សេងគ្នា បពិត្រព្រះអង្គ ជាបុគ្គលចម្រើនក្នុងដែន ពួកសប្បុរស ទោះបីនៅក្នុងទីឆ្ងាយ ក៏ឈ្មោះថា នៅក្នុងទីជាមួយដោយចិត្ត ។

[ ១០៥៩ ] បុគ្គលជាទីស្រឡាញ់ រមែងមិនស្រឡាញ់វិញ ព្រោះតែនៅជាមួយគ្នាយូរពេក ខ្ញុំសូមថ្វាយបង្គំលាព្រះអង្គទៅវិញ មុនពេលដែលខ្ញុំ មិនជាទីស្រឡាញ់របស់ព្រះអង្គ ។

[ ១០៦០ ] ( ព្រះរាជា ... ) កាលបើយើងអង្វរយ៉ាងនេះ អ្នកមិនទទួលដឹងនូវអញ្ជលី មិនធ្វើតាមពាក្យយើង ជាអ្នកបម្រើទេ យើងសូមអង្វរអ្នកយ៉ាងនេះថា អ្នកគប្បីធ្វើនូវការត្រឡប់មកទៀត ។

[ ១០៦១ ] ( រាជហង្ស ... ) បពិត្រមហារាជ ជាអ្នកមានសេចក្តីចម្រើនក្នុងដែន កាលបើយើងនៅយ៉ាងនេះ សេចក្តីអន្តរាយនឹងមិនមានដល់ព្រះអង្គ ទាំងដល់ទូលព្រះបង្គំជាខ្ញុំ សូមឲ្យយើងបានជួបគ្នា ក្នុងកាលកន្លងទៅនៃថ្ងៃ និងយប់ ។

**ជវនហំសជាតកទី ៣ ចប់**

# អដ្ឋកថា

## ជវនហំសជាតក

[ ១០៤៩-១០៦១ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះធម្មទេសនាទឡ្ហធម្មធនុគ្គហសូត្រ ទើបត្រាស់ព្រះធម្មទេសនានេះមានពាក្យផ្តើមថា **ឥធេវ ហំស និបត** ដូច្នេះជាដើម ។

សេចក្តីពិស្តារថា ចាប់តាំងពីថ្ងៃដែលព្រះមានព្រះភាគទ្រង់ត្រាស់សូត្រ ( ក្នុងសំយុត្តនិកាយ និទានវគ្គ ) នេះថា

ម្នាលភិក្ខុទាំងឡាយ ដូចជាខ្មាន់ធ្នូ ៤ នាក់ មានកម្លាំងមាំមួន បានសិក្សាដោយប្រពៃ មានសិល្បៈស្ទាត់ក្នុងដៃ បានសម្តែងសិល្បៈរួចហើយ ឈរនៅក្នុងទិសទាំង ៤ ។ គ្រានោះ មានបុរសម្នាក់ដើរមកដល់ គិតថា កាលបើខ្មាន់ធ្នូទាំង ៤ នាក់នេះដែលមានកម្លាំងមាំមួន បានសិក្សាដោយប្រពៃ មានសិល្បៈស្ទាត់ក្នុងដៃ បានសម្តែងសិល្បៈរួចហើយ បានបាញ់សរទៅក្នុងទិសទាំង ៤ មិនទាន់ធ្លាក់ដល់ផែនដីនៅឡើយ អាត្មាអញ នឹងចាប់នាំយកសរទាំង នោះមកឲ្យបាន ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សម្គាល់ហេតុនោះដូចម្តេច បុរសដែលមានសម្ទុះ ( នោះ ) គេគួរនឹងនិយាយថា ជាអ្នកប្រកបដោយសម្ទុះលឿនក្រៃលែងបាន ឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន សូម្បីតែខ្មាន់ធ្នូម្នាក់ ដែលមានកម្លាំងមាំមួន បានសិក្សាដោយប្រពៃ មានសិល្បៈស្ទាត់ក្នុងដៃ បានសម្តែងសិល្បៈ រួចហើយ បាញ់សរទៅ មិនទាន់ធ្លាក់ដល់

ផែនដីទៅឡើយ បុរសដែលមានសម្ទុះនោះ ក៏ចាប់នាំយក ( សរនោះ ) មកបាន គេគួរនឹងនិយាយថា ជាអ្នកប្រកបដោយសម្ទុះលឿនដ៏ក្រៃលែង បានណាស់ទៅហើយ នឹងចាំបាច់ពោលទៅថ្វីដល់ខ្មាន់ធ្នូ ៤ នាក់ ដែលមានកម្លាំងមាំមួន បានសិក្សាដោយប្រពៃ មានសិល្បៈស្ទាត់ក្នុងដៃ បានសម្តែងសិល្បៈរួចហើយ ។ ម្នាលភិក្ខុទាំងឡាយ សម្ទុះនៃបុរសនោះយ៉ាងណាក្តី សម្ទុះនៃព្រះចន្ទ្រ និងព្រះអាទិត្យ ដែលលឿនជាងសម្ទុះបុរសនោះ យ៉ាងណាក្តី ។ ម្នាលភិក្ខុទាំងឡាយ សម្ទុះនៃបុរសនោះយ៉ាងណាក្តី សម្ទុះនៃព្រះចន្ទ្រ និងព្រះអាទិត្យយ៉ាងណាក្តី សម្ទុះនៃទេវតាទាំងឡាយដែលស្ទុះទៅពីមុខព្រះចន្ទ្រ និងព្រះអាទិត្យនោះ លឿនជាងសម្ទុះនៃព្រះចន្ទ្រ និងព្រះអាទិត្យនោះទៅទៀតយ៉ាងណាក្តី ។ ម្នាលភិក្ខុទាំងឡាយ សម្ទុះនៃបុរសនោះយ៉ាងណាក្តី សម្ទុះនៃព្រះចន្ទ្រ និងព្រះអាទិត្យទាំងឡាយយ៉ាងណាក្តី សម្ទុះនៃទេវតាទាំងឡាយ ដែលស្ទុះទៅអំពីខាងមុខព្រះចន្ទ្រ និងព្រះអាទិត្យយ៉ាងណាក្តី អាយុសង្ខារទាំងឡាយ រមែងអស់ទៅឆាប់រហ័ស ជាងសម្ទុះទាំងនោះទៅទៀត ។ ម្នាលភិក្ខុទាំងឡាយ ហេតុដូច្នេះ ក្នុងសាសនានេះ អ្នកទាំងឡាយ គប្បីសិក្សាយ៉ាងនេះថា យើងទាំងឡាយ ជាអ្នកមិនប្រមាទ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសិក្សាយ៉ាងនេះចុះ ដូច្នេះ ។

ក្នុងថ្ងៃទីពីរ ពួកភិក្ខុសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ ព្រះសាស្តាទ្រង់តាំងនៅក្នុងពុទ្ធវិស័យរបស់ទ្រង់ ទ្រង់ចង្អុលបង្ហាញដល់អាយុសង្ខាររបស់សត្វទាំងនេះ ធ្វើឲ្យជារបស់មួយជួរខណៈ ទុព្វល ធ្វើឲ្យពួកភិក្ខុដែលជាបុថុជ្ជនដល់នូវសេចក្តីសង្វេគ ឲ្យរួចផុត ឱ កម្លាំងរបស់ព្រះពុទ្ធ គួរអស្ចារ្យពិត ៗ ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អំបាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនគួរអស្ចារ្យឡើយ ដែលតថាគតនោះសម្រេចសព្វញ្ញុតញ្ញាណហើយ ចង្អុលបង្ហាញដល់អាយុសង្ខារក្នុងពួកសត្វ ជាការៈមួយជួរខណៈ សម្តែងធម៌ឲ្យពួកភិក្ខុសង្វេគបាន ព្រោះក្នុងកាលមុន សូម្បីតថាគតកើតក្នុងកំណើតហង្ស ជាអហេតុកសត្វ ក៏ធ្លាប់ចង្អុលបង្ហាញភាពដែលសង្ខារទាំងឡាយ ជាសការៈមួយជួរខណៈ សម្តែងធម៌ឲ្យបរិស័ទទាំងអស់ តាំងអំពីព្រះបាទពារាណសីសង្វេគហើយ ទើបទ្រង់នាំអតីតនិទានមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងកំណើតជវនហង្ស មានហង្ស ៩ ម៉ឺនជាបរិវារ អាស្រ័យនៅនាភ្នំចិត្តកូដ ៗ ថ្ងៃមួយ ព្រះពោធិសត្វ មួយអន្ទើដោយបរិវារ រកស៊ីស្រូវសាលីកើតឯងក្នុងស្រះមួយកន្លែង ក្នុងផ្ទៃជម្ពូទ្វីប ហើរទៅកាន់ភ្នំចិត្តកូដដោយការហើរទៅដ៏ល្អ កាត់ពីលើក្រុងពារាណសី ជាមួយបរិវារជាច្រើន ហាក់បីដូចជាបុគ្គលលាតនូវកន្ទេលផែន ដែលធ្វើអំពីមាសទុកលើអាកាស ដូច្នោះ ៗ

កាលនោះ ព្រះបាទពារាណសី ទតឃើញព្រះពោធិសត្វនោះហើយ ត្រាស់ដល់ពួកអមាត្យថា ហង្សនេះប្រហែលជាព្រះរាជាដូចយើង ហើយទ្រង់កើតសេចក្ដីស្រឡាញ់ក្នុងព្រះពោធិសត្វនោះ ទ្រង់កាន់ផ្កា គ្រឿងក្រអូប និងគ្រឿងលាប ទតមើលព្រះពោធិសត្វនោះ ទ្រង់ត្រាស់ឲ្យប្រគំតន្ត្រីសព្វយ៉ាង ។ មហាសត្វឃើញព្រះរាជាទ្រង់ធ្វើសក្ការៈដល់ខ្លួន ទើបសួរពួកហង្សថា ព្រះរាជាទ្រង់ធ្វើសក្ការៈបែបនេះដល់យើង ទ្រង់បំណងដូចម្ដេចហ្ន៎ ពួកហង្សក៏ឆ្លើយថា បពិត្រព្រះសម្មតិទេព ព្រះរាជាទ្រង់បំណងមិត្តភាពជាមួយព្រះអង្គនោះឯង ព្រះពោធិសត្វពោលថា បើដូច្នោះ មិត្តភាពរបស់ពួកយើង ចូរមានដល់ព្រះរាជាចុះ ធ្វើមិត្តភាពដល់ព្រះរាជាហើយ ក៏ចៀសចេញទៅ ។

ថ្ងៃមួយ ពេលដែលព្រះរាជាយាងទៅកាន់ព្រះរាជឧទ្យាន ព្រះពោធិសត្វហើរទៅកាន់អនោតត្តស្រះ ប្រើស្លាបម្ខាងនាំទឹកមក ស្លាបម្ខាងនាំលម្អិតចន្ទន៍មកថ្វាយព្រះរាជាឲ្យទ្រង់ស្រង់ទឹកនោះ រោយលម្អិតចន្ទន៍ថ្វាយ កាលមហាជនកំពុងមើលនោះឯង បាននាំបរិវារហើរទៅកាន់ភ្នំចិត្តកូដ ។ ចាប់តាំងពីនោះ ព្រះរាជាប្រាថ្នានឹងឃើញមហាសត្វ ក៏ប្រថាប់រង់ចាំមើលផ្លូវ ដោយទ្រង់ចងចិត្តថា សម្លាញ់របស់អញគង់មកថ្ងៃនេះ ។ កាលនោះ កូនហង្សពីរ ជាប្អូនរបស់ព្រះមហាសត្វប្រឹក្សាគ្នាថា យើងនឹងហើរប្រណាំងជាមួយព្រះអាទិត្យ ប្រាប់ដល់មហាសត្វថា ខ្ញុំនឹងហើរប្រណាំងជាមួយព្រះអាទិត្យ ព្រះមហាសត្វពោលថា នែបា សម្ទុះរបស់ព្រះអាទិត្យរហ័សណាស់ ឯងទាំងពីរមិនអាចហើរប្រណាំងជាមួយព្រះអាទិត្យបានឡើយ នឹងត្រូវវិនាសក្នុងរវាងផ្លូវ កុំនាំគ្នាទៅឡើយ

ហង្សទាំងនោះនាំគ្នាអង្វរអស់វារៈ ២-៣ ដង ។ ព្រះពោធិសត្វក៏នៅតែហាម ហង្សទាំងពីរនោះអស់វារៈ ៣ ដងដូចគ្នា ហង្សទាំងពីរនោះរឹងត្អឹងដោយមានះ មិនស្គាល់នូវកម្លាំងរបស់ខ្លួន មិនប្រាប់មហាសត្វឡើយ គិតថា អញនឹងហើរប្រណាំងជាមួយព្រះអាទិត្យ ។ កាលព្រះអាទិត្យមិនទាន់រះ នាំគ្នាហើរទៅទំត្រង់ភ្នំយុគន្ធរ ព្រះមហាសត្វមិនឃើញហង្សទាំងពីរនោះ សួរថា ហង្សទាំងពីរទៅឯណា បានស្តាប់រឿងនោះហើយ គិតថា ហង្សទាំងពីរនោះ មិនអាចប្រណាំងជាមួយព្រះអាទិត្យ នឹងដល់នូវសេចក្តីវិនាសក្នុងរវាងផ្លូវដោយពិត អញត្រូវឲ្យជីវិតទានដល់ហង្សទាំងពីរនោះ ។ ព្រះមហាសត្វហើរទៅទំត្រង់កំពូលភ្នំយុគន្ធរដូចគ្នា កាលព្រះអាទិត្យរះឡើងហើយ ហង្សទាំងពីរក៏ហើរទៅអំពីខាងមុខព្រះអាទិត្យ ចំណែកមហាសត្វ ក៏ហើរទៅជាមួយហង្សទាំងពីរនោះ ។ ប្អូនពៅទៅបានត្រឹមវេលាថ្ងៃជិតត្រង់ ក៏អស់កម្លាំង ហាក់ដូចភ្លើងឆេះឡើងត្រង់សន្លាក់ស្លាបទាំងឡាយ ប្អូននោះ ក៏ឲ្យសញ្ញាដល់ព្រះពោធិសត្វឲ្យជ្រាបថា បពិត្របងប្រុស ខ្ញុំទៅលែងរួចហើយ ។

លំដាប់នោះ ព្រះពោធិសត្វលួងលោមថា កុំខ្លាចឡើយ យើងនឹងឲ្យជីវិតដល់ឯង ផ្គងទុកដោយស្លាប ឲ្យធូរស្រាលចិត្ត ហើយនាំទៅកាន់ភ្នំចិត្តកូដ ប្រគល់ឲ្យកណ្តាលហ្វូងហង្ស ហើរទៅទៀត ទាន់ព្រះអាទិត្យ ហើយហើរហួសទៅជាមួយប្អូនមួយទៀត ។ ប្រណាំងជាមួយព្រះអាទិត្យ រហូតដល់វេលាថ្ងៃត្រង់ក៏អស់កម្លាំង ដូចភ្លើងឆេះឡើងត្រង់សន្លាក់នៃស្លាបទាំងឡាយ លំដាប់នោះ ក៏ឲ្យសញ្ញាដល់ព្រះពោធិសត្វឲ្យជ្រាបថា បពិត្របងប្រុស ខ្ញុំទៅ

លែងរួចហើយ ព្រះមហាសត្វលួងលោមហង្សនោះ ដោយទំនងដូចគ្នា ផ្គង ដោយស្វាបនាំទៅកាន់ភ្នំចិត្តកូដ ។ ខណៈនោះ ព្រះអាទិត្យក៏ដល់កណ្តាលល្ហល្ហម ។ ព្រះមហាសត្វត្រិះរិះថា ថ្ងៃនេះ អញនឹងសាកល្បងកម្លាំងនៃសរីរៈរបស់អញ ហើយហើរទៅដោយរហ័ស ម្នាក់ឯងប៉ុណ្ណោះ ហើយទំត្រង់កំពូលភ្នំយុគន្ធរ ហោះពួយឡើងអំពីនោះ ប្រើកម្លាំងទាន់ព្រះអាទិត្យ ជួនកាលក៏ហួសទៅខាងមុខ ជួនកាលក៏នៅពីខាងក្រោយ បានគិតថា ការហើរប្រណាំងជាមួយព្រះអាទិត្យរបស់អញឥតប្រយោជន៍ កើតអំពីអយោនិសោមនសិការ អញត្រូវការអ្វីដោយសភាពបែបនេះ អញនឹងទៅកាន់នគរពារាណសី ពោលធម៌ប្រកបដោយអត្ថ ប្រកបដោយធម៌ដល់ព្រះរាជាជាសម្លាញ់របស់អញ ។ ព្រះមហាសត្វត្រឡប់មកក្នុងកាលព្រះអាទិត្យ មិនទាន់គោចរឆ្លងល្ហនៅឡើយ ហើរស្រេបតាមល្វែងចក្កវាឡទាំងមូល ដល់ទីបំផុតដោយរហ័ស ហើរមកកាន់ជម្ពូទ្វីបដល់ទីបំផុត ទើបមកកាន់នគរពារាណសី ព្រះនគរទាំងមូលមានបរិវេណ ១២ យោជន៍ ហាក់ដូចជាកំបាំងទុកហើយចំពោះហង្ស ឈ្មោះថា ចន្លោះៗ មិនប្រាកដឡើយ កាលភាពរហ័សបានបន្ថយចន្លោះៗ ទើបប្រាកដ មហាសត្វបន្ថយសម្ទុះ ចុះអំពីអាកាស ទំត្រង់សីហបញ្ជរ ។ ព្រះរាជាត្រាស់សោមនស្សថា សម្លាញ់របស់យើងមក ត្រាស់ឲ្យរៀបចំតាំងមាស ដើម្បីឲ្យព្រះមហាសត្វទំ ត្រាស់ថា នែសម្លាញ់ អញ្ជើញអ្នកមកចុះ ទំត្រង់នេះចុះ ហើយត្រាស់គាថាទី ១ ថា

នែហង្ស ឯងចូរទំលើតាំងមាសនេះចុះ ការឃើញឯង ជាទីពេញ

*ចិត្តរបស់អញ ឯងសមគួរជាធំហើយ របស់ណាមានក្នុងទីនេះ ឯងចូរប្រាប់មកចុះ ដូច្នេះ ។*

*បណ្ដាបទទាំងនោះ បទថា* **ឥធ** *សេចក្ដីថា ព្រះរាជាត្រាស់សំដៅយកតាំងមាស ។ បទថា* **និបត** *បានដល់ អញ្ជើញទំ ។ បទថា* **ឥស្សរោសិ** *នេះ ព្រះរាជាត្រាស់ថា អ្នកជាធំ ជាម្ចាស់របស់ទីនេះមកហើយ ។ បទថា* **យំ ឥធត្ថិ បវេទយ** *សេចក្ដីថា វត្ថុណាមានក្នុងនិវេសន៍នេះ អ្នកកុំខ្មាចចិត្ត ចូរប្រាប់ខ្ញុំ ដល់វត្ថុនោះចុះ ។*

*ព្រះមហាសត្វទំគ្រង់តាំងមាស ព្រះរាជាត្រាស់ឲ្យមនុស្សយកប្រេងមកលាបត្រង់ស្លាបរបស់មហាសត្វនោះ ដោយប្រេងដែលចម្រាញ់រាប់សែនដង ត្រាស់ឲ្យយកលាជលាយដោយទឹកឃ្មុំ និងទឹកស្ករក្រាម ដាក់ក្នុងចានមាស ព្រះរាជទានដល់ព្រះពោធិសត្វ ទ្រង់ធ្វើបដិសណ្ឋារៈយ៉ាងទន់ភ្លន់ ត្រាស់សួរថា នែសម្លាញ់ អ្នកមកតែម្នាក់ឯង ទៅណាមកណា ព្រះមហាសត្វនិយាយរឿងនោះដោយពិស្ដារ ។ លំដាប់នោះ ព្រះរាជាត្រាស់នឹងព្រះមហាសត្វថា នែសម្លាញ់ សូមអ្នកសម្ដែងនូវសម្មុះ ដែលប្រណាំងជាមួយព្រះអាទិត្យឲ្យខ្ញុំមើលខ្លះចុះ ព្រះមហាសត្វទូលថា បពិត្រមហារាជ ខ្ញុំមិនអាចសម្ដែងនូវភាពរហ័សប្រភេទនោះបានទេ ព្រះរាជាត្រាស់ថា បើដូច្នោះ សូមអ្នកសម្ដែងត្រឹមតែល្មមឃើញដល់ខ្ញុំចុះ ព្រះមហាសត្វទូលថា បាន មហារាជ ខ្ញុំនឹងសម្ដែងសម្មុះដែលល្មមឃើញថ្វាយ សូមទ្រង់ឲ្យខ្មាន់ធ្នូ អ្នកបាញ់រហ័សប្រជុំគ្នាចុះ ។ ព្រះរាជាទ្រង់ឲ្យនាយខ្មាន់ធ្នូមកប្រជុំគ្នាហើយ ព្រះមហាសត្វជ្រើសរើសខ្មាន់ធ្នូ*

បាន ៤ នាក់ដែលជាអ្នកមានប្ដីដែលជាខ្មាន់ធ្នូទាំងអស់ ចុះអំពីព្រះរាជនិវេសន៍ឲ្យបោះសសរថ្ម ត្រង់លានព្រះរាជវាំង ឲ្យចងកណ្ដឹងតូចៗ ត្រង់ករបស់ខ្លួន ហើយហើរទៅទំត្រង់ចុងសសរ ចំណែកខ្មាន់ធ្នូទាំង ៤ ឲ្យឈរផ្អែកសសរថ្ម បែរមុខទៅកាន់ទិសទាំង ៤ ទូលថា បពិត្រមហារាជ មនុស្ស ៤ នាក់នេះ ចូរបាញ់ព្រួញ ៤ ទៅក្នុងទិសទាំង ៤ ព្រមគ្នា ខ្ញុំនឹងពាំព្រួញនោះមក មិនឲ្យធ្លាក់ដល់ដីឡើយ ហើយទម្លាក់ចុះទៀបបាតជើងមនុស្សទាំងនោះ សូមទ្រង់ជ្រាបការដែលខ្ញុំទៅជាមួយព្រួញ ដោយសញ្ញានៃសំឡេងកណ្ដឹង តែខ្ញុំមិនប្រាកដឡើយ ហើយពាំព្រួញដែលខ្មាន់ធ្នូទាំង ៤ បាញ់ទៅព្រមគ្នា ដែលផុតទៅអំពីខ្សែហើយ មកទម្លាក់ក្បែរជើងរបស់ខ្មាន់ធ្នូទាំងនោះ ហើយទំត្រង់ចុងសសរថ្មនោះឯង ។ ក្រាបទូលថា បពិត្រមហារាជ ទ្រង់ឃើញសម្ទុះរបស់ខ្ញុំដែរឬទេ ហើយក្រាបទូលបន្តថា បពិត្រមហារាជ សម្ទុះរបស់ខ្ញុំនេះ មិនមែនជាសម្ទុះដ៏ឧត្ដមទេ មិនមែនសម្ទុះជាកណ្ដាលទេ ជាសម្ទុះជាន់ទាប ជាសម្ទុះថោកថយ បពិត្រមហារាជ សម្ទុះរបស់ខ្ញុំ គប្បីប្រព្រឹត្តទៅយ៉ាងនេះ ។

លំដាប់នោះ ព្រះរាជាទ្រង់ត្រាស់សួរថា នែសម្លាញ់ ឯការរហ័សដទៃក្រៃលែងជាងសម្ទុះរបស់អ្នកនៅមានឬ ព្រះមហាសត្វក្រាបទូលថា បពិត្រព្រះអង្គ មាន អាយុសង្ខាររបស់សត្វទាំងនេះអស់ទៅ ប្រែប្រួលទៅ រមែងដល់នូវការអស់រហ័ស ជាងការរហ័សរបស់ខ្ញុំរាប់រយ រាប់ពាន់ រាប់សែនដង ព្រះមហាសត្វសម្ដែងការប្រែប្រួលនៃអរូបធម៌ទាំងឡាយ ដោយអំណាចការរលត់ទៅគ្រប់ៗ ខណៈ ដោយប្រការដូច្នេះ ។ ព្រះរាជាទ្រង់ស្ដាប់ពាក្យរបស់ព្រះមហាសត្វ ទ្រង់ខ្លាចចំពោះមរណភ័យ មិនអាចតម្កល់ព្រះស្មារតីបាន រន្ធត់

ព្រះកាយ ដួលចុះលើផែនដី ។ មហាជនក៏នាំគ្នាស្រែយុតស្រែយង់ ពួកអមាត្យនាំយកទឹកមកស្រោចព្រះភក្ត្រព្រះរាជា ជួយឲ្យទ្រង់មានស្មារតី ។ លំដាប់នោះព្រះមហាសត្វក្រាបទូលថា បពិត្រមហារាជ ទ្រង់កុំខ្វាចក្រែងឡើយ សូមទ្រង់ចម្រើនមរណស្សតិចុះ ទ្រង់ប្រព្រឹត្តធម៌ចុះ ទ្រង់ធ្វើបុណ្យ មានទានជាដើមចុះ ទ្រង់កុំប្រមាទឡើយ ។ លំដាប់នោះ ព្រះរាជាទ្រង់អង្វរថា ខ្ញុំមិនអាចនៅបែកអំពីអាចារ្យ ដែលសម្បូរដោយញាណដូចអ្នកបានឡើយ អ្នកមិនចាំបាច់ទៅកាន់ភ្នំចិត្តកូដ សូមជាអ្នកទូន្មានធម៌ដល់ខ្ញុំ ជាអាចារ្យអ្នកឲ្យឱវាទក្នុងទីនេះចុះ ហើយពោលម្នាក់មួយគាថាថា

បុគ្គលខ្លះគ្រាន់តែឮហើយ ស្រឡាញ់ក៏មាន ខ្លះគ្រាន់តែឃើញគ្នាហើយ អស់សេចក្តីស្រឡាញ់ក៏មាន ខ្លះឃើញផង ឮផង ទើបស្រឡាញ់ក៏មាន ចុះព្រះអង្គ គ្រាន់តែឃើញ តើស្រឡាញ់ខ្ញុំដែរឬទេ ។

អញគ្រាន់តែបានឮ ស្រឡាញ់ឯងទៅហើយ លុះបានឃើញអញរឹតតែស្រឡាញ់ឡើង នែហង្ស ឯង អញឃើញហើយស្រឡាញ់យ៉ាងនេះ ឯងចូរនៅក្នុងសម្នាក់អញចុះ ដូច្នេះ ។

គាថាទាំងនោះមានអធិប្បាយថា នែហង្សសម្លាញ់ បុគ្គលមួយពួករមែងជាទីស្រឡាញ់ដោយការឮ គឺមានចិត្តទោរទន់ទៅដោយគ្រាន់តែបានស្តាប់ ព្រោះបានឮថា បុគ្គលនោះមានគុណយ៉ាងនេះ តែបុគ្គលពួកខ្លះគ្រាន់តែឃើញប៉ុណ្ណោះការពេញចិត្តក៏អស់ទៅ គឺការស្រឡាញ់ក៏អស់ទៅ ប្រាកដដូចពួកយក្ខ ដែល

នាំគ្នាមកដើម្បីស៊ី ជនពួកខ្លះ ជាបុគ្គលគួរស្រឡាញ់ បានទាំងពីរស្ថាន គឺទាំងបានឃើញ ទាំងបានឮ ហេតុនោះ ខ្ញុំសូមសួរអ្នក អ្នកស្រឡាញ់ខ្ញុំ ព្រោះការឃើញឬ ឬអ្នកពេញចិត្ត តែសម្រាប់ខ្ញុំ អ្នកជាទីស្រឡាញ់ ព្រោះបានឮលុះបានឃើញក៏រឹងរឹតតែស្រឡាញ់ អ្នកជាទីស្រឡាញ់របស់ខ្ញុំបែបនេះ កុំទៅកាន់ក្នុំចិត្តកូដឡើយ ចូរនៅក្នុងសម្នាក់របស់ខ្ញុំនេះឯង ។ ព្រះពោធិសត្វបានក្រាបទូលថា

ខ្ញុំនៅក្នុងដំណាក់របស់ព្រះអង្គ ព្រះអង្គធ្វើសក្ការបូជា អស់កាល
ជានិច្ចហើយ តែក្រែងពេលណាមួយ ព្រះអង្គស្រវឹងដោយទឹក
ស្រវឹងហើយ ទ្រង់ត្រាស់បង្គាប់ថា នាយពិសេស ចូរចម្អិនសាច់
ស្តេចហង្ស យកមកឲ្យយើង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មត្តោ ច ឯកទា** សេចក្តីថា បពិត្រមហារាជ ពួកខ្ញុំបានទទួលការបូជាជានិច្ច ក៏គួរនៅក្នុងព្រះរាជវាំងរបស់ព្រះអង្គ តែជួនកាល ទ្រង់ស្រវឹងទឹកចណ្ឌ គប្បីត្រាស់បានថា ចូរអាំងស្តេចហង្សឲ្យយើងចុះ ដូច្នេះ យើងនឹងសោយសាច់ ពេលនោះ ពួកអ្នកបម្រើរបស់ទ្រង់គប្បីសម្លាប់ខ្ញុំអាំង ដោយប្រការដូច្នេះ កាលនោះ ខ្ញុំនឹងធ្វើដូចម្តេចបាន ។

លំដាប់នោះ ព្រះរាជា កាលប្រទានបដិញ្ញាដល់ព្រះពោធិសត្វនោះថា បើដូច្នោះ ខ្ញុំនឹងមិនផឹកទឹកស្រវឹងជាដាច់ខាត ទើបត្រាស់គាថានេះថា

ថ្វីយ ! ខ្ញើម ការផឹកទឹកស្រវឹង ដែលជាទីស្រឡាញ់របស់អញ
ជាងឯង បើឯងនៅក្នុងដំណាក់អញដរាបណា អញនឹងមិនផឹក

ទឹកស្រវឹងដរាបនោះ ដូច្នេះ ។

បន្ទាប់ពីនោះ ព្រះពោធិសត្វបានពោល ៦ គាថាថា

សម្តីរបស់ពួកចចក និងពួកបក្សីយល់បានងាយ បពិត្រមហារាជ សម្តីរបស់ពួកមនុស្សក្រមដីងបាន ជាងសម្តីសត្វនោះទៅទៀត ។

មួយទៀត បើបុរសណា កាលពីដើម មានចិត្តល្អ គេសម្គាល់ថា ជាញាតិ ជាមិត្ត ឬជាសម្លាញ់ តែលុះដល់ពេលខាងក្រោយមក បុរសនោះ ត្រឡប់ជាសត្រូវនឹងគ្នាទៅវិញក៏មាន ។

បុគ្គលណា មានចិត្តស្មោះស្ម័ គ្រង់ ដោយសារសេចក្តីស្រឡាញ់ បុគ្គលនោះ ឈ្មោះថា នៅជិតជាមួយគ្នា បុគ្គលណា មានចិត្តមិនស្មោះស្ម័ បុគ្គលនោះ ទោះនៅក្នុងទីជិត ក៏ហាក់ដូចជានៅក្នុងទីឆ្ងាយ ។

សម្លាញ់ណា ជាអ្នកមានចិត្តជ្រះថ្លារកគ្នា បើទុកជានៅឯត្រើយសមុទ្រខាងនាយ សម្លាញ់ដែលមានចិត្តជ្រះថ្លារកគ្នានោះ ក៏ឈ្មោះថា នៅក្នុងសមុទ្រជាមួយគ្នា សម្លាញ់ណា មានចិត្តប្រទូស្តរកគ្នា បើទុកជានៅក្នុងសមុទ្រជាមួយគ្នា សម្លាញ់ដែលមានចិត្តប្រទូស្តគ្នានោះ ក៏ឈ្មោះថា នៅត្រើយសមុទ្រខាងនាយវិញ ។

បពិត្រព្រះអង្គ ជាបុគ្គលប្រសើរលើរថ បុគ្គលទាំងឡាយណា ជាសត្រូវនឹងគ្នា បើទុកជានៅជាមួយគ្នា បុគ្គលទាំងនោះ ក៏ឈ្មោះថា នៅឆ្ងាយគ្នា បពិត្រព្រះអង្គ ជាបុគ្គលចម្រើនក្នុងដែន ពួក

សប្បុរស ទោះបីនៅក្នុងទីឆ្ងាយ ក៏ឈ្មោះថា នៅក្នុងទីជាមួយ
ដោយចិត្ត ។

បុគ្គលជាទីស្រឡាញ់ រមែងមិនស្រឡាញ់វិញ ព្រោះតែនៅជា
មួយគ្នាយូរពេក ខ្ញុំសូមថ្វាយបង្គំលាព្រះអង្គទៅវិញ មុនពេល
ដែលខ្ញុំ មិនជាទីស្រឡាញ់របស់ព្រះអង្គ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វស្សិតំ** សេចក្តីថា បពិត្រមហារាជ ជាការពិត ពួកសត្វតិរច្ឆាន មានចិត្តត្រង់ ព្រោះហេតុនោះ សំឡេងយំរបស់សត្វតិរច្ឆាននោះ គេដឹងបានងាយ តែមនុស្សអាក្រក់ ពាក្យពោលរបស់មនុស្សនោះ យល់បានដោយលំបាក ។ បទថា **យោ បុព្វេ** សេចក្តីថា បុគ្គលណាមានចិត្តល្អ រាប់រកគ្នាក្នុងកាលមុន ក៏រាប់អានគ្នាយ៉ាងនេះថា អ្នកជាញាតិរបស់ខ្ញុំ ជាមិត្តរបស់ខ្ញុំ ជាសម្លាញ់រួមជីវិតរបស់ខ្ញុំ ក្រោយមក ជនទាំងនោះ ក៏ក្លាយទៅជាស្អប់គ្នា ជាអ្នកប្រកបដោយពៀរក៏បាន ចិត្តមនុស្សលំបាកយល់យ៉ាងនេះ ។ បទថា **និវិសតិ** សេចក្តីថា បពិត្រមហារាជ ចិត្តស្រឡាញ់ក្នុងបុគ្គលណា បុគ្គលនោះ ទោះនៅសែនឆ្ងាយ ក៏ដូចជានៅក្នុងទីជិត តែចិត្តស្អប់ខ្ពើមក្នុងបុគ្គលណា ទោះបីនៅក្នុងទីជិត ក៏ដូចជានៅឆ្ងាយ ។ បទថា **អន្តោបិ សោ ហោតិ** សេចក្តីថា បពិត្រមហារាជ បុគ្គលណា ជាសម្លាញ់មានចិត្តជ្រះថ្លា បុគ្គលនោះ ទោះបីនៅឯនាយសមុទ្រ ក៏ហាក់ដូចជានៅជិតបង្កើយ ព្រោះមានចិត្តផ្សាភ្ជាប់គ្នា បុគ្គលណា មានចិត្តគិតប្រទូស្ត បុគ្គលនោះ ក៏ឈ្មោះថា នៅម្នាក់ម្ខាងត្រើយនៃសមុទ្ទ ព្រោះចិត្តមិនផ្សាភ្ជាប់គ្នា ។ បទ

ថា **យេ ធិសា តេ** សេចក្តីថា ជនពួកណា ជាអ្នកមានពៀរ ជាសត្រូវនឹងគ្នា ទោះបីនៅរួមគ្នា ជនទាំងនោះក៏ឈ្មោះថានៅឆ្ងាយគ្នា តែបណ្ឌិតអ្នកស្ងប់រម្ងាប់ សូម្បីទៅក្នុងទីឆ្ងាយ នឹករឭកដល់គ្នាដោយចិត្ត ដែលអប់រំដោយមេត្តា ក៏ឈ្មោះថា នៅក្នុងទីជិត ។ បទថា **បុរា តេ ហោមិ** សេចក្តីថា ទាន់ខ្ញុំជាទីស្រឡាញ់របស់ទ្រង់ជរាបណា ក៏នឹងសូមថ្វាយបង្គំលាទ្រង់ជរាបនោះឯង ។ លំដាប់នោះ ព្រះរាជាត្រាស់នឹងព្រះពោធិសត្វថា

កាលបើយើងអង្វរយ៉ាងនេះ អ្នកមិនទទួលដឹងនូវអញ្ជលី មិនធ្វើតាមពាក្យយើង ជាអ្នកបម្រើទេ យើងសូមអង្វរអ្នកយ៉ាងនេះថា អ្នកគប្បីធ្វើនូវការត្រឡប់មកទៀត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឃរំ ចេ** សេចក្តីថា នៃស្តេចហង្ស ទោះបីខ្ញុំផ្គងអញ្ជលីអង្វរយ៉ាងនេះ អ្នកក៏មិនបានដឹងដល់ការរាប់អាននេះ មិនធ្វើតាមពាក្យរបស់ពួកយើង ដែលប្រតិបត្តិអ្នក កាលបើដូច្នោះ ពួកយើងគប្បីសំណូមពរយ៉ាងនេះ ។ បទថា **បុន កយិរាសិ បរិយាយំ** សេចក្តីថា អ្នកគប្បីកំណត់វារៈនៃការមកក្នុងទីនេះ តាមកាលដ៏សមគួរចុះ ។ លំដាប់នោះ ព្រះពោធិសត្វក្រាបទូលថា

បពិត្រមហារាជ ជាអ្នកមានសេចក្តីចម្រើនក្នុងដែន កាលបើយើងនៅយ៉ាងនេះ សេចក្តីអន្តរាយនឹងមិនមានដល់ព្រះអង្គ ទាំងដល់ទូលព្រះបង្គំជាខ្ញុំ សូមឲ្យយើងបានជួបគ្នា ក្នុងកាលកន្លងទៅនៃថ្ងៃ និងយប់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឃរំ ចេ ឆោ** សេចក្តីថា បពិត្រមហារាជ ទ្រង់ជាអ្នកចម្រើនក្នុងដែន ទ្រង់កុំទោមនស្សឡើយ កាលយើងនៅជាប្រក្រតី អន្តរាយនៃជីវិតនឹងមិនមាន ដែលជឿបានពិតប្រាកដថា យើងទាំងពីរនឹងត្រូវជួបគ្នាពិត ម្យ៉ាងទៀត ទ្រង់តាំងឱវាទដែលខ្ញុំថ្វាយទាំងអស់នោះ ក្នុងឋានៈជំនួសខ្ញុំ ទ្រង់កុំប្រមាទក្នុងលោកសន្និវាស ដែលមានការរស់នៅមួយជួរខណៈបែបនេះ ទ្រង់ធ្វើបុណ្យ មានទានជាដើម សូមទ្រង់កុំកន្លងនូវទសពិធ-រាជធម៌ គ្រងរាជ្យដោយធម៌ កាលទ្រង់ធ្វើតាមឱវាទរបស់ខ្ញុំដូច្នេះ នឹងឃើញខ្ញុំរឿយៗ ទៅដោយពិតប្រាកដនោះឯង ។ ព្រះមហាសត្វថ្វាយឱវាទព្រះរាជាយ៉ាងនេះហើយ ក៏ហើរទៅកាន់ភ្នំចិត្តកូដនោះឯង ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះ មកសម្តែងហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សូម្បីក្នុងកាលមុន តថាគតកើតក្នុងកំណើតតិរច្ឆាន ក៏ធ្លាប់ចង្អុលបង្ហាញនូវភាពទុព្វលរបស់អាយុសង្ខារ សម្តែងធម៌បានដូចគ្នា ដោយប្រការដូច្នេះ ហើយទ្រង់ប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទក្នុងកាលឥឡូវនេះ ប្អូនពៅក្នុងកាលនោះ បានមកជាមោគ្គល្លាន ប្អូនកណ្តាលក្នុងកាលនោះ បានមកជាសារីបុត្ត ហ្វូងហង្សដ៏សេស ក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទ ចំណែកជវនហង្សក្នុងកាលនោះ គឺតថាគតនេះឯង ។ ៚

**អដ្ឋកថា ជវនហំសជាតក ចប់**

# សុត្តន្តបិដក

## ចុល្លនារទកស្សបជាតក

[ ១០៦២ ] ( តាបសពោធិសត្វសួរថា ) ឧសកូនឯងមិនពុះ ទឹកកូនឯងមិនដង ភ្លើងក៏កូនឯងមិនបង្កាត់ កូនឯងជាមនុស្ស ល្ងង់ខ្លៅឬ បានជានៅសញ្ជប់សញ្ជឹង ។

[ ១០៦៣ ] ( តាបសកុមារតបថា ) ខ្ញុំមិនអាចនៅក្នុងព្រៃបាន ទេ បពិត្រកស្សបៈ ខ្ញុំសូមលាលោក ការនៅក្នុងព្រៃពិបាក ខ្ញុំចង់ ទៅដែនវិញ ។

[ ១០៦៤ ] ខ្ញុំចេញទៅពីព្រៃនេះ ហើយនៅក្នុងជនបទណា បពិត្រតាបសដ៏ប្រសើរ បុគ្គលគប្បីសិក្សាឫកពាយ៉ាងណា សូម ព្រះបិតា ប្រៀនប្រដៅទំនៀមទម្លាប់នោះដល់ខ្ញុំ ។

[ ១០៦៥ ] ( តាបស ... ) បើបាឯងលះបង់ព្រៃ និងមើមឈើ ផ្លែឈើហើយពេញចិត្តនឹងការនៅក្នុងដែនវិញបាឯងចូរស្តាប់ទំនៀម ទម្លាប់នោះរបស់អញ ។

[ ១០៦៦ ] បាឯងចូរកុំសេពថ្នាំពិស ចូរចៀសវាងអណ្តូង កុំឲ្យ លិចទៅក្នុងភក់ឡើយ ចូរប្រព្រឹត្តប្រយ័ត្ន នឹងពួកអាសិរពិស ។

[ ១០៦៧ ] ( តាបសកុមារ ... ) អ្វីជាថ្នាំពិស ជាអណ្តូង ជា ភក់ របស់អ្នកប្រព្រឹត្តព្រហ្មចរិយធម៌ លោកពោលនូវអ្វីថាជា អាសិរពិស ខ្ញុំសួរហើយ សូមលោកប្រាប់រឿងនោះដល់ខ្ញុំ ។

[ ១០៦៨ ] ( តាបសពោធិសត្វ ... ) នែបា គ្រឿងត្រាំក្នុងលោក គេហៅថា ស្រា ជារបស់ពេញចិត្ត ជារបស់ឈ្ងុយឈ្ងប់ ឆ្ងាញ់ពិសា មានឧបមាដូចរសផ្អែមតូចមួយ ម្នាលនារទ: ព្រះអរិយៈទាំងឡាយបានពោលថា ស្រានោះ ជាថ្នាំពិសរបស់បុគ្គលអ្នកប្រព្រឹត្តព្រហ្មចារ្យ ។

[ ១០៦៩ ] នែបា ស្ត្រីទាំងឡាយក្នុងលោក រមែងញាំញីនូវបុរសដែលស្រវឹងហើយ ពួកស្ត្រីទាំងនោះ តែងផ្សាយចិត្តទៅរកប្រុសកំលោះ ដូចជាខ្យល់ផាត់នូវប៉ុយគរ ដែលជ្រុះអំពីដើម ម្នាលនារទ: នោះហើយដែលលោកហៅថាអណ្ដូងរបស់អ្នកប្រព្រឹត្តព្រហ្មចារ្យ ។

[ ១០៧០ ] លាភ សេចក្ដីសរសើរ សក្ការ: និងការបូជាក្នុងត្រកូលអ្នកដទៃ ម្នាលនារទ: នោះឯងដែលលោកហៅថា កក់ល្បាប់របស់អ្នកប្រព្រឹត្តព្រហ្មចារ្យ ។

[ ១០៧១ ] នែបា ពួកស្ដេចធំៗ គ្រប់គ្រងផែនដីនេះ នែនារទ: កូន បាឯង ( ចូរគោរព ) ពួកស្ដេចទាំងនោះ ដែលជាធំ ជាមនុស្សដ៏ប្រសើរប្រាកដដូច្នោះ ។

[ ១០៧២ ] ចូរបា កុំប្រព្រឹត្តនៅផ្ចាល់ព្រះបាទា នៃពួកស្ដេចជាឥស្សរៈ ជាអធិបតីទាំងនោះឡើយ នែនារទ: ( នោះឯង ) ដែលគេហៅថា អាសិរពិស របស់អ្នកប្រព្រឹត្តព្រហ្មចារ្យ ។

[ ១០៧៣ ] បើបាត្រូវការកត្តក្នុងពេលកត្ត គប្បីចូលទៅកាន់ផ្ទះណា ដែលបាដឹងថា ត្រកូលណាមិនមានទោស ក្នុងស្រុកនោះ គប្បីប្រព្រឹត្តស្វែងរកអាហារ ក្នុងផ្ទះនោះចុះ ។ លុះចូលទៅកាន់ត្រកូលដទៃ ដើម្បីទឹកក្តី ដើម្បីភោជនក្តី គប្បីទំពាស៊ីឲ្យល្មមប្រមាណ គប្បីបរិភោគឲ្យល្មមប្រមាណ តែបា កុំគប្បីពេញចិត្តនឹងរូប ( ស្ត្រី ) ទាំងឡាយឡើយ ។

[ ១០៧៤ ] បាចូរចៀសវាង បេញឲ្យឆ្ងាយនូវទីគោឈរ តៀមស្រា មនុស្សអ្នកលេង មនុស្សអ្នកធបោក កន្លែងប្រជុំមនុស្សច្រើន និងកន្លែងដែលគេទុកដាក់ប្រាក់មាស ឲ្យដូចជាបុគ្គលទៅដោយយាន ( ដែលផ្ទុកដោយសប្បិ និងប្រេង ) វៀរនូវផ្លូវមិនរាបស្មើ ។

### ចុល្លនារទកស្សបជាតកទី ៤ ចប់

# អដ្ឋកថា

## ចុល្លនារទកស្សបជាតក

[ ១០៦២-១០៧៤ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការលួងលោមរបស់ថុល្លកុមារី ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ន តេ កដ្ឋានិ ភិន្នានិ** ដូច្នេះជាដើម ។

បានឮថា ធីតារបស់ត្រកូលអ្នកក្រុងសាវត្ថីម្នាក់ មានអាយុប្រមាណ ១៥-១៦ ឆ្នាំ ជាស្រីមានរូបរាងស្រស់បស់ តែមិនមានអ្នកណាដណ្តឹងនាង ។ លំដាប់នោះ មាតារបស់នាងគិតថា កូនស្រីរបស់អញក្រមុំហើយ តែមិនមានអ្នកដណ្តឹងសោះ អញត្រូវឲ្យនាងលួងលោមភិក្ខុរបស់សក្យៈមួយរូប ដូចបញ្ឆោតត្រីដោយនុយ ឲ្យសឹកទាល់តែបាន ហើយអាស្រ័យបុរសនោះចិញ្ចឹមជីវិត ។ កាលនោះ កុលបុត្រអ្នកក្រុងសាវត្ថីម្នាក់ បួសឧទ្ទិសជីវិតក្នុងព្រះសាសនា តាំងពីកាលឧបសម្បទាហើយ ក៏លះបង់សិក្ខាបទ ខ្ជិលច្រអូស គិតតែពីតាក់តែងរាងកាយ ។ មហាឧបាសិកា ចាត់ចែងបបរ កត្ត ខាទនីយៈ ភោជនីយៈ ក្នុងផ្ទះ ឈរត្រង់ទ្វារផ្ទះ ពិចារណារកមើលភិក្ខុដែលនិមន្តទៅក្នុងវាងផ្លូវរូបណាមួយ ដែលមានអកប្បកិរិយា ដែលនាងអាចចងបានដោយរសតណ្ហា កាលក្រុមភិក្ខុអ្នកទ្រទ្រង់ព្រះត្រៃបិដក ទ្រទ្រង់អភិធម្ម ទ្រទ្រង់ព្រះវិន័យនាំគ្នានិមន្តទៅជាមួយបរិវារជាច្រើន មិនទាន់ឃើញភិក្ខុរូបណាមួយ ដែលល្មមចងបានក្នុងក្រុមនៃព្រះធម្មកថិកដែលសម្តែងធម៌ពីរោះក្តី ក្នុងក្រុមនៃភិក្ខុដែលសមាទានបិណ្ឌបាតជាវត្តក្តី ដូចគ្នានឹងវលាហកៈដែលធ្វើឲ្យភ្លៀងធ្លាក់ក្តី ដែលនិមន្តទៅខាងក្រោយនៃក្រុមភិក្ខុនោះ ក៏មិនឃើញត្រឹមតែមួយរូបឡើយ កាល

ឃើញភិក្ខុមួយរូប បន្តក់ថ្នាំរហូតដល់ត្របកភ្នែក ស្លៀកអន្តរវាសក: ធ្វើដោយទុកូលពស្រ្ត ដណ្តប់សំពត់ចីវរសាច់ម៉ដ្ឋ កាន់នូវបាត្រពណ៌ដូចកែវមណីបាំងឆត្រយ៉ាងស្អាត ជាអ្នកលែងនូវឥន្រ្ទិយ មានរាងកាយធាត់ជំកំពុងនិមន្តមក គិតថា អញអាចចងភិក្ខុនេះបាន ទើបដើរទៅថ្វាយបង្គំទទួលបាត្រ ពោលថា សូមនិមន្តចូលមកគង់ក្នុងផ្ទះខ្ញុំចុះ ហើយអង្គាសដោយបបរជាដើម ពោលនឹងភិក្ខុនោះដែលឆាន់ស្រេចហើយថា បពិត្រលោកម្ចាស់ តាំងអំពីឥឡូវនេះទៅ សូមលោកម្ចាស់និមន្តមកទីនេះប៉ុណ្ណោះ ។ តាំងអំពីនោះមក ភិក្ខុនោះក៏ទៅផ្ទះនោះជាប្រចាំ រហូតស្និទ្ធស្នាលនឹងគ្នា ។

ថ្ងៃមួយ មហាឧបាសិកាឈរក្នុងចម្ងាយល្មមបានឮ ហើយពោលថា ក្នុងផ្ទះនេះ មានគ្រឿងឧបភោគបរិភោគល្មមប្រមាណ តែកូនប្រុស ឬកូនប្រសាដែលអាចគ្រប់គ្រងផ្ទះសម្បែងមិនមានឡើយ ។ ភិក្ខុនោះស្តាប់ពាក្យរបស់នាងគិតថា ស្រីនេះនិយាយដើម្បីប្រយោជន៍អ្វីហ្ន៎ ហាក់ដូចជាមុតទម្លុះបេះដូងចូលទៅបន្តិច ។ នាងពោលនឹងកូនស្រីថា ចូរនាងលួងលោមភិក្ខុនេះ ឲ្យប្រព្រឹត្តទៅក្នុងអំណាចរបស់នាងឲ្យបាន ។ តាំងអំពីនោះមក នាងក៏ប្រដាប់កាយលេងខ្លួនប្រាណ បញ្ចើចបញ្ចើដោយមាយាស្រ្តីផ្សេងៗ ។ ដែលហៅថា ថុល្ល-កុមារីនោះ មិនគប្បីយល់ថា មានរាងកាយធាត់ឡើយ ទោះជាអវយវ:ធាត់ ឬស្គមក៏ដោយ ក៏លោកហៅថុល្លកុមារីបាន ព្រោះក្រាស់ទៅដោយរាគ: ប្រកបដោយកាមគុណ ៥ ប្រការ ។ កាលលោកជាកំលោះ ក៏ធ្លាក់ទៅក្នុងអំណាចកិលេស គិតថា ឥឡូវនេះ ខ្ញុំមិនអាចតាំងនៅក្នុងព្រះពុទ្ធសាសនាបាន ពោល

ថា ខ្ញុំត្រូវទៅកាន់វិហារប្រគល់បាត្រ និងចីវរហើយ នឹងទៅទីត្រង់នោះ ចូរនាង បញ្ជូនសំពត់របស់ខ្ញុំទៅទីនោះ ហើយទៅកាន់វិហារប្រគល់បាត្រ និងចីវរ ពិតអាចារ្យ និងឧបជ្ឈាយ៍ថា ខ្ញុំនឹងសឹក ។ ព្រះថេរៈទាំងនោះនាំលោកទៅ កាន់សម្នាក់ព្រះសាស្តា ក្រាបទូលថា បពិត្រព្រះអង្គ ភិក្ខុនេះនឹងសឹក ព្រះ សាស្តាត្រាស់សួរថា ម្នាលភិក្ខុ បានឮថា អ្នកនឹងសឹកពិតឬ កាលភិក្ខុកំលោះ នោះ ក្រាបទូលឲ្យទ្រង់ជ្រាបថា ករុណាព្រះអង្គ ព្រះសាស្តាក៏ត្រាស់ថា ហេតុ អ្វីទើបអ្នកសឹក កាលភិក្ខុនោះក្រាបទូលថា ព្រោះថុល្លកុមារីព្រះអង្គ ទើបព្រះ សាស្តាត្រាស់ថា ម្នាលភិក្ខុ ក្នុងកាលមុន ស្រីនេះ ក៏ធ្លាប់ធ្វើអន្តរាយដល់ ព្រហ្មចរិយៈ ញុំាំងសេចក្តីវិនាសយ៉ាងធំដល់អ្នកក្នុងព្រៃ អ្នកអាស្រ័យស្រី នេះ សឹកទៀត ព្រោះហេតុអ្វី ពួកភិក្ខុក្រាបទូលអារាធនា ទើបទ្រង់នាំអតីត និទានមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ មានសម្បត្តិច្រើនក្នុងដែនកាសី រៀន នូវសិប្បៈសម្រេចហើយ ។ លំដាប់នោះ ភរិយារបស់ព្រះពោធិសត្វ ប្រសូត បុត្រម្នាក់ ក៏អនិច្ចកម្មទៅ ព្រះពោធិសត្វគិតថា ការស្លាប់នេះមានដល់ភរិយា ជាទីស្រឡាញ់របស់អញយ៉ាងណា ការស្លាប់នឹងមកដល់អញដូច្នោះ អញត្រូវ ការអ្វីដោយឃរាវាស អញនឹងបួសចុះ ហើយលះកាមទាំងឡាយ នាំកូនប្រុស ចូលកាន់ព្រៃហិមពាន្ត បួសជាឥសីជាមួយកូនប្រុសនោះ ញុំាំងឈាន និងអភិញ្ញា ឲ្យកើតឡើង មានត្រាវ ដំឡូង ផ្លែឈើក្នុងព្រៃជាអាហារ រស់នៅក្នុងដងព្រៃ ។

សម័យនោះ ពួកចោរប្លន់បច្ចន្តគ្រាម ចូលកាន់ជនបទប្លន់ស្រុក ចាប់មនុស្ស មកជាឈ្លើយឲ្យជញ្ជូនស្រូវអង្ករ ធ្វើដំណើរទៅកាន់ជាយដែន ។ ក្នុងបណ្តា ឈ្លើយទាំងនោះ កញ្ញាម្នាក់រូបស្អាត ប្រកបដោយភាពវៃឆ្លាតក្នុងការបញ្ឆោត នាងគិតថា ចោរនេះចាប់ពួកយើងទៅ គង់នឹងប្រើប្រាស់ដូចទាសៈ អញត្រូវ រកឧបាយណាមួយគេចទៅឲ្យបាន ទើបនាងពោលថា លោកម្ចាស់ ខ្ញុំបំណង នឹងធ្វើសរីរកិច្ច ឲ្យខ្ញុំឈប់បន្តិចចុះ ហើយបញ្ឆោតពួកចោរគេចទៅ កាលដើរ ក្នុងព្រៃ ក៏ដល់អាស្រមក្នុងពេលព្រឹក គឺក្នុងពេលដែលព្រះពោធិសត្វ ឲ្យកូន ប្រុសនៅចាំអាស្រម ហើយទៅរកផ្លែឈើ ហើយលួងលោមតាបសកុមារនោះ ដោយការត្រេកអរក្នុងកាម ទម្លាយនូវសីល ឲ្យធ្លាក់ក្នុងអំណាចរបស់ខ្លួនហើយ ពោលថា អ្នកនៅក្នុងព្រៃធ្វើអ្វី មកយើងនាំគ្នាទៅកាន់ស្រុក ព្រោះក្នុងស្រុក នោះ កាមគុណមានរូបជាដើមរកបានងាយ ចំណែកកុមារទទួលថា សាធុ ហើយ ពោលថា ឪពុករបស់ខ្ញុំទៅរកផ្លែឈើក្នុងព្រៃ យើងទាំងពីរចាំជួបលោកហើយ សឹមទៅព្រមគ្នា ។ នាងគិតថា តាបសនេះនៅក្មេងមិនដឹងអ្វី តែឪពុករបស់គេ បួសឯចាស់ គាត់មកហើយគង់វាយអញ ពោលថា ហេងមកធ្វើអ្វីក្នុងទីនេះ នឹងអូសអញទៅចោលក្នុងព្រៃក៏ថាបាន កាលគាត់មិនទាន់មកនោះឯង អញ នឹងគេចទៅមុន ។ កាលនោះ ទើបនាងពោលថា ខ្ញុំទៅមុន អ្នកគប្បីទៅឯ ក្រោយ ហើយប្រាប់សញ្ញាក្នុងផ្លូវហើយលួចចេញទៅ ។ តាំងពីនាងទៅហើយ កុមារកើតទោមនស្ស មិនធ្វើវត្តណាមួយដូចកាលមុន ដេកទទូរក្បាល សុប សៅខាងក្នុងបណ្ណសាលា ។ ព្រះមហាសត្វ នាំផ្លែឈើមក ឃើញស្នាមជើង

របស់នាង គិតថា នេះជាស្នាមជើងរបស់មាតុគ្រាម សីលរបស់កូនប្រុសអញ ពិតជាបែកធ្លាយដោយពិត ហើយចូលទៅកាន់បណ្ណសាលា ដាក់ផ្លែឈើស្រេចបាច់ហើយ កាលសួរកូនប្រុស ទើបពោលគាថាទី ១ ថា

ឧសកូនឯងមិនពុះ ទឹកកូនឯងមិនដង ភ្លើងក៏កូនឯងមិនបង្កាត់ កូនឯងជាមនុស្សល្ងង់ខ្លៅឬ បានជានៅសញ្ជប់សញ្ជឹង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អគ្គិបិ តេ ន ហាសិតោ** សេចក្ដីថា ភ្លើងឯងក៏មិនបង្កាត់ឲ្យឆេះ ។ បទថា **មន្ទោវ** សេចក្ដីថា ឯងជាបុគ្គលមិនមានបញ្ញា សញ្ជប់សញ្ជឹងដូចមនុស្សល្ងង់ខ្លៅ ។

កុមារបានឮពាក្យរបស់ឪពុកហើយ ក្រោកឡើងថ្វាយបង្គំឪពុក កាលនឹងប្រាប់ឲ្យដឹង ដើម្បីទៅកាន់ទឹកដីមនុស្សអំពីព្រៃដោយសេចក្ដីគោរព ទើបពោល ២ គាថាថា

ខ្ញុំមិនអាចនៅក្នុងព្រៃបានទេ បពិត្រកស្សបៈ ខ្ញុំសូមលាលោក ការនៅក្នុងព្រៃពិបាក ខ្ញុំចង់ទៅដែនវិញ ។

ខ្ញុំចេញទៅពីព្រៃនេះ ហើយនៅក្នុងជនបទណា បពិត្រតាបសដ៏ប្រសើរ បុគ្គលគប្បីសិក្សាឫកពាយ៉ាងណា សូមព្រះបិតាប្រៀនប្រដៅទំនៀមទម្លាប់នោះដល់ខ្ញុំ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កស្សបាមន្តយាមិ តំ** សេចក្ដីថា បពិត្រលោកឪពុកកស្សបៈ ខ្ញុំសូមជម្រាបលោកឪពុក ។ បទថា **គន្តវេ** បានដល់ដើម្បីនឹងទៅ ។ បទថា **អាចារំ** សេចក្ដីថា ខ្ញុំនៅក្នុងជនបទណា កាលនៅ

ក្នុងជនបទនោះ ត្រូវសិក្សា ត្រូវជ្រាបគោលដែលត្រូវប្រព្រឹត្ត គឺទំនៀមទម្លាប់របស់ជនបទយ៉ាងណា សូមលោកឪពុកបង្រៀនទូវទំនៀមនោះចុះ ។

ព្រះមហាសត្វពោលថា ល្អណាស់បា អញនឹងសម្តែងចារិតរបស់ប្រទេសដល់ឯង ហើយពោល ២ គាថាថា

បើបាឯងលះបង់ព្រៃ និងមើមឈើ ផ្លែឈើហើយពេញចិត្តនឹងការ
នៅក្នុងដែនវិញ បាឯងចូរស្តាប់ទំនៀមទម្លាប់នោះរបស់អញ ។
បាឯងចូរកុំសេពថ្នាំពិស ចូរចៀសវាងអណ្តូង កុំឲ្យលិចទៅក្នុង
ភក់ឡើយ ចូរប្រព្រឹត្តប្រយ័ត្ននឹងពួកអាសិរពិស ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ធម្មំ** សេចក្តីថា បើឯងគាប់ចិត្តនៅក្នុងដែន ចូរឯងសិក្សាធម៌ គឺទំនៀមរបស់ជនបទ ។ បទថា **យត្តោ អាសីវិសេ** សេចក្តីថា ឯងគប្បីប្រព្រឹត្តសង្រួមឲ្យដល់ព្រមត្រាច់ទៅជិតអាសិរពិស បើអាច គប្បីវៀរអាសិរពិសឲ្យឆ្ងាយ ។ តាបសកាលមិនដឹងអត្ថរបស់ពាក្យដែលឪពុកពោលដោយសង្ខេប ទើបសួរថា

អ្វីជាថ្នាំពិស ជាអណ្តូង ជាភក់ របស់អ្នកប្រព្រឹត្តព្រហ្មចរិយធម៌
លោកពោលនូវអ្វី ថាជាអាសិរពិស ខ្ញុំសួរហើយ សូមលោក
ប្រាប់រឿងនោះដល់ខ្ញុំ ដូច្នេះ ។

ចំណែកតាបសពោធិសត្វ បានព្យាករណ៍ដល់កូនថា

នែបា គ្រឿងស្រវឹងក្នុងលោក គេហៅថា ស្រា ជារបស់ពេញចិត្ត
ជារបស់ឈ្ងុយឈ្ងប់ ឆ្ងាញ់ពិសា មានឧបមាដូចរសផ្អែមតូច

មួយ ម្នាលនារទៈ ព្រះអរិយៈទាំងឡាយ បានពោលថា ស្រា នោះ ជាថ្នាំពិសរបស់បុគ្គលអ្នកប្រព្រឹត្តព្រហ្មចារ្យ ។

នែបា ស្រ្តីទាំងឡាយក្នុងលោក រមែងញាំញីនូវបុរស ដែលស្រវឹង ហើយ ពួកស្រ្តីទាំងនោះ តែងផ្សាយចិត្តទៅរកប្រុសកំលោះ ដូច ជាខ្យល់ផាត់នូវប៉ុយគរ ដែលជ្រុះអំពីដើម ម្នាលនារទៈ នុ៎ះ ហើយ ដែលលោកហៅថា អណ្តូងរបស់អ្នកប្រព្រឹត្តព្រហ្មចារ្យ ។

លាភ សេចក្តីសរសើរ សក្ការៈ និងការបូជាក្នុងត្រកូលអ្នកដទៃ ម្នាលនារទៈ នុ៎ះឯង ដែលលោកហៅថា ភក់ល្បាប់ របស់អ្នក ប្រព្រឹត្តព្រហ្មចារ្យ ។

នែបា ពួកស្តេចធំៗ គ្រប់គ្រងផែនដីនេះ នែនារទៈ កូន បាឯង ( ចូរគោរព ) ពួកស្តេចទាំងនោះ ដែលជាធំ ជាមនុស្សដ៏ប្រសើរ ប្រាកដដូច្នោះ ។

ចូរបា កុំប្រព្រឹត្តនៅផ្ចាល់ព្រះបាទា នៃពួកស្តេចជាឥស្សរៈ ជា អធិបតីទាំងនោះឡើយ នែនារទៈ ( នុ៎ះឯង ) ដែលគេហៅថា អាសិរពិស របស់អ្នកប្រព្រឹត្តព្រហ្មចារ្យ ។

បើបាត្រូវការភត្តក្នុងពេលភត្ត គប្បីចូលទៅកាន់ផ្ទះណា ដែលបា ដឹងថា ត្រកូលណាមិនមានទោស ក្នុងស្រុកនោះ គប្បីប្រព្រឹត្ត ស្វែងរកអាហារក្នុងផ្ទះនោះចុះ ។ លុះចូលទៅកាន់ត្រកូលដទៃ ដើម្បីទឹកក្តី ដើម្បីភោជនក្តី គប្បីទំពាស៊ីឲ្យល្មមប្រមាណ គប្បី

បរិភោគឲ្យល្មមប្រមាណ តែបា កុំគប្បីពេញចិត្តនឹងរូប ( ស្ត្រី ) ទាំងឡាយឡើយ ។

បាចូលចៀសវាង ចេញឲ្យឆ្ងាយនូវទីគោឈរ គៀមស្រា មនុស្សអ្នកលេង មនុស្សអ្នកធបោក កន្លែងប្រជុំមនុស្សច្រើន និងកន្លែងដែលគេទុកដាក់ប្រាក់មាស ឲ្យដូចជាបុគ្គលទៅដោយយាន ( ដែលផុកដោយសប្បិ និងប្រេង ) វៀរនូវផ្លូវមិនរាបស្មើ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អាសវោ** បានដល់ ថ្នាំពិស ដែលកើតអំពីការត្រាំផ្កាឈើជាដើម ។ បទថា **តទាហុ** សេចក្តីថា ព្រះអរិយៈទាំងឡាយពោលសុរានោះ ពោល គឺទឹកត្រាំថាជាថ្នាំពិសនៃព្រហ្មចរិយៈ ។ បទថា **បមត្តំ** បានដល់ បុគ្គលមិនមានស្មារតី ។ បទថា **តូលំ ភដ្ឋំវ** សេចក្តីថា ប្រៀបដូចប៉ុយគរដែលត្រូវខ្យល់បក់អំពីដើមជ្រុះចុះមក ។ បទថា **អក្ខាតោ** បានដល់ ដែលបណ្ឌិតមានព្រះពុទ្ធជាដើមត្រាស់ហើយ ។ បទថា **សិលោកោ** បានដល់ កិត្តិគុណ ។ បទថា **សក្ការោ** បានដល់ កម្ម មានអញ្ជលីកម្មជាដើម ។ បទថា **បូជា** បានដល់ ការបូជាដោយសក្ការៈ មានផ្កាកម្រង និងគ្រឿងក្រអូបជាដើម ។ បទថា **បង្កោ** សេចក្តីថា បណ្ឌិតទាំងឡាយពោលថា ភក់ ព្រោះអត្ថថា ធ្វើឲ្យលិចចុះ ។ បទថា **មហាន្តេ** បានដល់ ដល់នូវភាពជាបុគ្គលមានអានុភាពច្រើន ។ បទថា **ឆ តេសំ ចាឝតោ ចរេ** សេចក្តីថា មិនគប្បីត្រាច់ទៅជិតព្រះបាទារបស់ស្តេចទាំងនោះ គឺមិនគប្បីចូលដល់រាជត្រកូល ។ ពិតហើយ ព្រះរាជាទាំងឡាយ ទ្រង់ពិរោធហើយ រមែងឲ្យដល់

នូវការរីករវមួយរំពេចប៉ុណ្ណោះ ដូចអាសិរពិស ។ម្យ៉ាងទៀត បណ្ឌិតគប្បី ជ្រាបដោយអំណាចទោស ដូចពោលមកហើយ ក្នុងការចូលទៅក្នុងរាជវាំង ( របស់ព្រះអានន្ទ ) ។ បទថា **ភត្តត្ថោ** សេចក្តីថា ជាអ្នកមានសេចក្តីត្រូវការដោយភត្ត ។ បទថា **យមេត្ថ កុសលំ** សេចក្តីថា ក្នុងបណ្តាផ្ទះដែលឯងគប្បីចូលទៅ ផ្ទះណាជាកុសល មិនមានទោស ឯងគប្បីស្គាល់ផ្ទះដែលវៀរចាកអគោចរ ៥ ប្រការ គប្បីស្វែងរកអាហារក្នុងផ្ទះនោះ ។ បទថា **ឆ ចរេយ្យ មធំ ការេ** សេចក្តីថា កប្បកតាបសពោលថា គប្បីជាអ្នកស្គាល់ប្រមាណក្នុងត្រកូល កាលបរិភោគ ក៏កុំទុកចិត្តក្នុងស្ត្រី ក្នុងត្រកូលនោះ កុំបើកភ្នែកកាន់យកនិមិត្តក្នុងរូបស្ត្រី ។ បាលីក្នុងគម្ពីរទាំងឡាយថា **គុដ្ឋំ មជ្ជំ កិរាសញ្ច** ដូច្នេះ តែក្នុងអដ្ឋកថាលោកពោល **គោដ្ឋំ មជ្ជំ កិរាសញ្ច** ហើយពោលថា ទីដែលគោទាំងឡាយស្នាក់នៅ ឈ្មោះថា **គោដ្ឋំ** ។ បទថា **មជ្ជំ** បានដល់រោងស្រា ។ បទថា **កិរាសំ** បានដល់ មនុស្សដែលជាអ្នកលេងនិងមនុស្សខិលខូច ។ បទថា **សភានិកិរណានិ ច** បានដល់ ទីប្រជុំ ទីមានកំណាប់ទ្រព្យនៃប្រាក់ និងមាស ។ បទថា **អារកា** សេចក្តីថា ឯងគប្បីវៀរវត្ថុទាំងអស់នេះឲ្យឆ្ងាយ ។ បទថា **យានីវ** សេចក្តីថា ដូចបុគ្គលមានយាន ដែលពេញដោយសប្បិ និងប្រេងទៅកាន់ផ្លូវដែលមិនរាបស្មើ ដូច្នោះ ។ កាលបិតាកំពុងពោលទូន្មាននោះឯង មាណពត្រឡប់បានសតិពោលថា បពិត្រលោកឪពុក ខ្ញុំមិនគួរទៅកាន់ដែនដីមនុស្សឡើយ ។ លំដាប់នោះ ឥសីបិតាបានបង្រៀនវិធីចម្រើនមេត្តាជាដើមដល់តាបសកុមារៗ តាំងនៅក្នុងឱវាទរបស់ឪពុក

ញុំាងឈាន និងអភិញ្ញាឲ្យកើតឡើងក្នុងកាលមិនយូរឡើយ តាបសឪពុក និងកូន មានឈានមិនសាបសូន្យ បានទៅកើតក្នុងព្រហ្មលោក ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះ មកសម្តែងហើយ ទើបទ្រង់ប្រជុំជាតកថា កុមារិកាក្នុងកាលនោះ បានមកជាថុល្លកុមារីក្នុងកាល ឥឡូវនេះ តាបសកុមារក្នុងកាលនោះ បានមកជាភិក្ខុអផ្សុក ចំណែក តាបសបិតាក្នុងកាលនោះ គឺតថាគតនេះឯង ៕

## អដ្ឋកថា ចុល្លនារទកស្សបជាតក ចប់

# សុត្តន្តបិដក

## ទូតជាតក

[ ១០៧៥ ] ( ព្រះរាជាត្រាស់សួរថា ) ម្នាលព្រហ្ម យើងបានបញ្ជូនពួកទូតមកក្នុងសម្នាក់អ្នក ដែលកំពុងសុបសៅ ក្បែរប្រាំងគង្គា ពួកទូតទាំងនោះបានសួរហើយ តែអ្នកមិនឆ្លើយប្រាប់សោះ សេចក្តីទុក្ខ ( ណា ) ដែលកើតឡើងដល់អ្នក សេចក្តីទុក្ខនោះ នឹងបានតែអ្នកទេឬ ។

[ ១០៧៦ ] ( មហាសត្វទូលថា ) បពិត្រព្រះអង្គ ជាបុគ្គលចម្រើនក្នុងដែនរបស់អ្នកកាសី បើសេចក្តីទុក្ខ គប្បីកើតឡើងដល់ព្រះអង្គ បុគ្គលណា ដោះទុក្ខនោះមិនបានទេ សូមព្រះអង្គកុំប្រាប់សេចក្តីទុក្ខនោះ ដល់បុគ្គលនោះឡើយ ។

[ ១០៧៧ ] បុគ្គលណា គប្បីដោះទុក្ខព្រះអង្គនោះបានដោយធម៌ជាចំណែកនៃសេចក្តីសុខតែម្យ៉ាង សូមព្រះអង្គប្រាប់ដល់បុគ្គលនោះដោយពិត ។

[ ១០៧៨ ] សំឡេងពួកឆ្កែចចកក្តី ពួកសត្វក្រៀលក្តី ដឹងបានដោយងាយ បពិត្រមហារាជ ឯសម្តីរបស់មនុស្ស ដឹងបានដោយកម្រ ជាងសំឡេងនោះទៅទៀត ។

[ ១០៧៩ ] មួយទៀត កាលពីមុន បុរសណាមានចិត្តល្អ គេសម្គាល់ថាជាញាតិសន្តាន ឬមិត្តសម្លាញ់ តែដល់មកខាងក្រោយ បុរសនោះ ត្រឡប់ទៅជាសត្រូវនឹងគ្នាវិញក៏មាន ។

[ ១០៨០ ] ជនណា គេមិនសាកសួរសេចក្តីទុក្ខរបស់ខ្លួន ហើយនិយាយប្រាប់ ( នូវសេចក្តីកំបាំងរបស់ខ្លួន ) ក្នុងកាលមិនគួរ មិត្តទាំងឡាយជាអ្នកមិនត្រេកអរ ចំពោះជននោះក៏មាន ជាអ្នកស្វែងរកនូវប្រយោជន៍ មានសេចក្តីទុក្ខចំពោះជននោះក៏មាន ។

[ ១០៨១ ] អ្នកប្រាជ្ញដឹងនូវកាលគួរ ( នឹងនិយាយប្រាប់ ) ផងដឹងនូវមេធាវីជនថា មានចិត្តតែមួយជាមួយនឹងខ្លួនផង ទើបគួរប្រាប់នូវសេចក្តីទុក្ខទាំងឡាយដល់ជនឯទៀត មានប្រការដូច្នោះ ហើយគប្បីបញ្ចេញនូវពាក្យដ៏ពីរោះ ជាពាក្យមានប្រយោជន៍ ។

[ ១០៨២ ] អ្នកប្រាជ្ញ កាលបើសម្លឹងរំពឹងឃើញ នូវហិរិ និងឱត្តប្បៈជាក់ច្បាស់ហើយ រមែងដឹងនូវទុក្ខ ដែលខ្លួនពិបាកទ្រាំថាសេចក្តីសុខ ដែលនឹងមានដល់អាត្មាអញ មិនមែនមាន ( ព្រោះការលើកធុរៈដាក់ទម្ងន់ ទៅលើអ្នកដទៃទេ ) ហើយក៏អត់ទ្រាំទុក្ខដ៏ខ្លាំងក្លាតែម្នាក់ឯង ។

[ ១០៨៣ ] បពិត្រមហារាជ ទូលព្រះបង្គំ ជាអ្នកត្រូវការដោយទ្រព្យ ( យកទៅបូជា ) ដល់អាចារ្យ ទើបដើរសូមគេក្នុងដែននិគម និងរាជធានី ។

[ ១០៨៤ ] បពិត្រព្រះអង្គជាធំជាងជន ខ្ញុំព្រះអង្គ ( សូមឲ្យ ) ពួកគហបតី ពួករាជបុរស ពួកព្រាហ្មណមហាសាល បានធ្លោរមាស ៧ បពិត្រមហារាជ ធ្លោរមាសរបស់ខ្ញុំព្រះអង្គនោះបាត់

ហេតុនោះ បានជាខ្ញុំព្រះអង្គសោកដ៏ក្រៃលែង ។

[ ១០៨៥ ] បពិត្រមហារាជ ពួករាជបុរសរបស់ព្រះអង្គ ខ្ញុំព្រះអង្គបានត្រិះរិះដោយចិត្តថា មិនអាចដើម្បីជួយដោះខ្ញុំព្រះអង្គ ឲ្យរួចចាកទុក្ខបានទេ ហេតុនោះ ខ្ញុំព្រះអង្គ មិនប្រាប់ដល់រាជបុរសទាំងនោះឡើយ ។

[ ១០៨៦ ] បពិត្រមហារាជ ចំណែកព្រះអង្គ ខ្ញុំព្រះអង្គបានត្រិះរិះដោយចិត្តថា ព្រះអង្គអាចជួយដោះទុក្ខបាន ហេតុនោះ ខ្ញុំព្រះអង្គ ទើបក្រាបទូលដល់ព្រះអង្គ ។

[ ១០៨៧ ] ( អភិសម្ពុទ្ធគាថា ) ព្រះបាទពារាណសី ជាអ្នកចម្រើនក្នុងដែនរបស់អ្នកកាសី មានព្រះហឫទ័យជ្រះថ្លា បានប្រទានគ្រឿងមាសសុទ្ធ ចំនួន ១៤ ដុំ ដល់មហាសត្វនោះ ។

**ទូតជាតកទី ៥ ចប់**

# អដ្ឋកថា

## ទូតជាតក

[ ១០៧៥-១០៨៧ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការសរសើរបញ្ញារបស់ព្រះអង្គ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ទូតេ តេ ព្រហ្មេ ចាហេសឹ** ដូច្នេះជាដើម ។

ភិក្ខុទាំងឡាយសន្ទនាគ្នា ដល់ពាក្យប្រារព្ធព្រះគុណរបស់ព្រះសាស្តាក្នុងធម្មសភាថា អាវុសោទាំងឡាយ ចូរអ្នកទាំងឡាយមើលភាពឈ្លាសវៃក្នុងឧបាយរបស់ព្រះទសពលចុះ ទ្រង់បង្ហាញស្រីអប្សរទាំងឡាយដល់នន្ទកុលបុត្រ ហើយប្រទានអរហត្ត ទ្រង់ប្រទានសំពត់ចាស់ដល់ចូឡបន្ថកៈ ហើយប្រទានអរហត្ត មួយអន្ទើដោយបដិសម្ភិទា ទ្រង់ប្រទានផ្កាឈូកដល់ភិក្ខុដែលធ្លាប់ជាជាងមាស ហើយប្រទានអរហត្ត ទ្រង់ដឹកនាំសត្វទាំងឡាយដោយឧបាយផ្សេងៗយ៉ាងនេះ ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អំបាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលតថាគតជាអ្នកឈ្លាសក្នុងឧបាយ ដោយដឹងឧបាយថារបស់នេះ ត្រូវធ្វើយ៉ាងនេះ សូម្បីក្នុងកាលមុន តថាគតក៏ឈ្លាសក្នុងឧបាយដូចគ្នា ទើបទ្រង់នាំអតីតនិទានមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ជនបទមិនមានប្រាក់ចាយ ព្រោះព្រះបាទព្រហ្មទត្ត បញ្ជាឲ្យអ្នកជនបទ យក

ទ្រព្យទៅទុកក្នុងព្រះរាជវាំងទាំងអស់ ។

ក្នុងកាលនោះ ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងកាសិកគ្រាម ចម្រើនវ័យហើយ បានទៅកាន់នគរតក្កសិលា ពោលវាចាថា ខ្ញុំនឹងត្រាច់សូមគេដោយធម៌ នឹងនាំយកទ្រព្យមកឲ្យអាចារ្យ ក្នុងកាលជាខាងក្រោយ ហើយចាប់ផ្តើមរៀនសិល្បសាស្ត្រ កាលរៀនសិល្បសាស្ត្រចប់ហើយ ទើបប្រាប់អាចារ្យថា បពិត្រលោកអាចារ្យ ខ្ញុំនឹងនាំទ្រព្យថ្លៃបង្រៀនមកជូនលោក ហើយចេញទៅតាមជនបទ ស្វែងរកទ្រព្យតាមធម៌ បានមាស ៧ ដុំ ទើបធ្វើដំណើរទៅដោយគិតថា អញនឹងឲ្យអាចារ្យ ។ ក្នុងរវាងផ្លូវបានឡើងជិះទូកដើម្បីឆ្លងស្ទឹងគង្គា ទូកឃ្លោងទៅមកក្នុងស្ទឹងនោះ មាសរបស់ព្រះពោធិសត្វក៏ធ្លាក់ក្នុងទឹក ព្រះពោធិសត្វគិតថា មាសរបស់អញរកបានលំបាក បើអញស្វែងរកទ្រព្យថ្លៃបង្រៀនតាមជនបទ ក៏នឹងចំណាយពេលយូរ កុំដូច្នោះឡើយ អញគួរអង្គុយអត់អាហារត្រង់ឆ្នេរស្ទឹងគង្គានេះឯង ព្រះរាជាទ្រង់នឹងជ្រាបភាពដែលអញអង្គុយដោយលំដាប់ ក៏នឹងបញ្ជូនអមាត្យមក អញនឹងមិននិយាយជាមួយអមាត្យទាំងនោះ លំដាប់នោះ ព្រះរាជានឹងយាងមកឯង អញនឹងបានទ្រព្យថ្លៃឈ្នួលក្នុងសម្នាក់របស់ព្រះរាជាដោយឧបាយនេះ ហើយអង្គុយដណ្តប់សំពត់សាដកឆៀងស្មា យកយញ្ញ និងខ្សែសិញ្ចនៈព័ទ្ធដោយជុំវិញ អង្គុយត្រង់ឆ្នេរស្ទឹងគង្គា ដូចរូបបដិមាមាសលើផ្ទូកខ្សាច់ ដែលមានពណ៌ដូចកម្រាលប្រាក់ ។

មហាជនឃើញព្រះពោធិសត្វ អង្គុយអត់អាហារ ទើបសួរថា អ្នកអង្គុយ

ទីនេះដើម្បីអ្វី ព្រះពោធិសត្វក៏មិនពោលជាមួយបុគ្គលណាឡើយ ស្អែកឡើង បុគ្គលដែលនៅជិតទ្វារព្រះនគរ បានឮថា ព្រះពោធិសត្វអង្គុយទីនោះ ទើបនាំគ្នាទៅសួរ ។ ព្រះពោធិសត្វក៏មិនបានពោលដល់ជនទាំងនោះៗ ឃើញសេចក្ដីលំបាករបស់ព្រះពោធិសត្វ ក៏នាំគ្នាយំសោកចៀសចេញទៅ ។ ក្នុងថ្ងៃទី ៣ ពួកអ្នកនគរនាំគ្នាមក ។ ក្នុងថ្ងៃទី ៤ ឥស្សរជននាំគ្នាចេញអំពីព្រះនគរមក ក្នុងថ្ងៃទី ៥ រាជបុរសនាំគ្នាមក ក្នុងថ្ងៃទី ៦ ព្រះរាជាទ្រង់បញ្ជូនពួកអមាត្យមក ព្រះពោធិសត្វក៏មិនបានពោលដល់ជនទាំងនោះ ។ ក្នុងថ្ងៃទី ៧ ព្រះរាជាទ្រង់ខ្លាចភ័យ ទើបយាងទៅកាន់សម្នាក់របស់ព្រះពោធិសត្វ កាលនឹងត្រាស់សួរ ទើបពោលគាថាទី ១ ថា

ម្នាលព្រហ្ម យើងបានបញ្ជូនពួកទូតមកក្នុងសម្នាក់អ្នក ដែល
កំពុងសុបសៅ ក្បែរប្រាំងគង្គា ពួកទូតទាំងនោះបានសួរហើយ
តែអ្នកមិនឆ្លើយប្រាប់សោះ សេចក្ដីទុក្ខ ( ណា ) ដែលកើតឡើង
ដល់អ្នក សេចក្ដីទុក្ខនោះ នឹងបានតែអ្នកទេឬ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **តុយ្ហំ មតំ នុ តេ** សេចក្ដីថា ម្នាលព្រហ្ម សេចក្ដីទុក្ខដែលកើតដល់អ្នកនោះ ជាសេចក្ដីស្លាប់របស់អ្នកមិនមែនឬ ទើបអ្នកមិនប្រាប់ដល់អ្នកដទៃ ។

ព្រះពោធិសត្វបានស្ដាប់ដូច្នោះ ទើបទូលថា បពិត្រមហារាជ ទូលបង្គំប្រាប់ដល់បុគ្គលដែលអាចនាំសេចក្ដីទុក្ខទៅបានប៉ុណ្ណោះ មិនប្រាប់ដល់អ្នកដទៃ ហើយពោល ៧ គាថាថា

បពិត្រព្រះអង្គ ជាបុគ្គលចម្រើនក្នុងដែនរបស់អ្នកកាសី បើសេចក្តីទុក្ខ គប្បីកើតឡើងដល់ព្រះអង្គ បុគ្គលណា ដោះទុក្ខនោះមិនបានទេ សូមព្រះអង្គកុំប្រាប់សេចក្តីទុក្ខនោះ ដល់បុគ្គលនោះឡើយ ។

បុគ្គលណា គប្បីដោះទុក្ខព្រះអង្គនោះបានដោយធម៌ ជាចំណែកនៃសេចក្តីសុខតែម្យ៉ាង សូមព្រះអង្គប្រាប់ដល់បុគ្គលនោះដោយពិត ។

សំឡេងពួកចចកក្តី ពួកសត្វក្រៀលក្តី ដឹងបានដោយងាយ បពិត្រមហារាជ ឯសម្តីរបស់មនុស្ស ដឹងបានដោយកម្រ ជាងសំឡេងនោះទៅទៀត ។

មួយទៀត កាលពីមុន បុរសណាមានចិត្តល្អ គេសម្គាល់ថាជាញាតិសន្តាន ឬមិត្តសម្លាញ់ តែដល់មកខាងក្រោយ បុរសនោះត្រឡប់ទៅជាសត្រូវនឹងគ្នាវិញក៏មាន ។

ជនណា គេមិនសាកសួរសេចក្តីទុក្ខរបស់ខ្លួន ហើយនិយាយប្រាប់ ( នូវសេចក្តីកំបាំងរបស់ខ្លួន ) ក្នុងកាលមិនគួរ មិត្តទាំងឡាយជាអ្នកមិនត្រេកអរ ចំពោះជននោះក៏មាន ជាអ្នកស្វែងរកនូវប្រយោជន៍ មានសេចក្តីទុក្ខចំពោះជននោះក៏មាន ។

អ្នកប្រាជ្ញ ដឹងនូវកាលគួរ ( នឹងនិយាយប្រាប់ ) ផង ដឹងនូវមេធាវិជនថា មានចិត្តតែមួយជាមួយនឹងខ្លួនផង ទើបគួរប្រាប់នូវសេចក្តីទុក្ខទាំងឡាយ ដល់ជនឯទៀត មានប្រការដូច្នោះ ហើយ

គប្បីបញ្ចេញនូវពាក្យដ៏ពីរោះ ជាពាក្យមានប្រយោជន៍ ។

អ្នកប្រាជ្ញ កាលបើសម្លឹងរំពឹងឃើញ នូវហិរិ និងឱត្តប្បៈជាក់ច្បាស់ហើយ រមែងដឹងនូវទុក្ខ ដែលខ្លួនពិបាកទ្រាំថា សេចក្ដីសុខដែលនឹងមានដល់អាត្មាអញ មិនមែនមាន ( ព្រោះការលើកធុរៈជាក់ទម្ងន់ទៅលើអ្នកដទៃទេ ) ហើយក៏អត់ទ្រាំទុក្ខដ៏ខ្លាំងក្លាតែម្នាក់ឯង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឧប្បជ្ជេ** សេចក្ដីថា បើសេចក្ដីទុក្ខគប្បីកើតឡើងដល់ទ្រង់ ។ បទថា **មា អក្ខាហិ** បានដល់ កុំប្រាប់ ។ បទថា **ទុត្តិជា-ឆនាំ តតោ** សេចក្ដីថា ពាក្យរបស់មនុស្សដើងបានលំបាកក្រៃលែង ជាងពាក្យរបស់សត្វតិរច្ឆាន ព្រោះហេតុនោះ បុគ្គលមិនដឹងតាមសេចក្ដីពិត មិនគប្បីប្រាប់ទុក្ខរបស់ខ្លួន ដល់បុគ្គលដែលមិនអាចកម្ចាត់ទុក្ខបាន ។ បទថា **អបិ ចេ** អត្ថនៃបទនេះ លោកពោលហើយ ( ក្នុងជវនសំហជាតក ) ។ បទថា **អនានុបុដ្ឋោ** បានដល់ ត្រូវសួររឿយៗ ។ បទថា **បវេធយេ** បានដល់ រមែងពោល ។ បទថា **អកាលរូបេ** បានដល់ ក្នុងកាលដែលមិនសមគួរ ។ បទថា **កាលំ** សេចក្ដីថា កាលដែលពោលដល់ការកំបាំងរបស់ខ្លួន ។ បទថា **តថា-វិធស្ស** សេចក្ដីថា ស្គាល់បុរសដែលជាបណ្ឌិត ដឹងថា បុគ្គលណាម្នាក់ដែលដូចគ្នានឹងខ្លួនហើយ គប្បីប្រាប់ដល់បុគ្គលនោះ ។ បទថា **តិប្បានិ** បានដល់ ទុក្ខ ។ បទថា **សចេ** សេចក្ដីថា បើបុគ្គលអត់សង្កត់នូវសេចក្ដីទុក្ខរបស់ខ្លួនមិនបាន គប្បីដឹងថា ជានាទីរបស់ខ្លួនក្នុងកាលកម្លាំងនៃជាតិកូនប្រុសរបស់ខ្លួន

ឬរបស់អ្នកដទៃនៅមាន ។ បទថា **ឱតិ** សេចក្តីថា បវេណីរបស់លោក យ៉ាងនេះ អធិប្បាយថា លោកធម៌ ៨ ។ លោកអធិប្បាយដូច្នេះថា បវេណី របស់លោកនេះ នឹងមានដើម្បីដល់សេចក្តីសុខសម្រាប់ខ្ញុំប៉ុណ្ណោះ មិនបាន ឈ្មោះថាជាអ្នកផុតអំពីលោកធម៌ទាំង ៨ ប្រការ ដែលកើតឡើងហើយ រមែង មិនមាន កាលបើយ៉ាងនេះ អ្នកប្រាជ្ញ ប្រាថ្នាតែសេចក្តីសុខ ជាអ្នកសម្បូរ ដោយហិរិ និងឱត្តប្បៈ មិនគប្បីធ្វើកម្មដែលឈ្មោះថាលើកយកទុក្ខឲ្យដល់អ្នក ដទៃ ខ្ញុំក៏មានហិរិ និងឱត្តប្បៈ ព្រោះហេតុនោះ អ្នកប្រាជ្ញ កាលសម្លឹងហិរិ និងឱត្តប្បៈក្នុងខ្លួន ដែលជារបស់មានពិត មិនគប្បីប្រាប់ដល់បុគ្គលដទៃ គប្បីដេកទទួលទុក្ខតែម្នាក់ឯង ។

ព្រះមហាសត្វ កាលសម្តែងធម៌ថ្វាយព្រះរាជា ៧ គាថា យ៉ាងនេះ ហើយ កាលសម្តែងភាពដែលខ្លួនស្វែងរកទ្រព្យដើម្បីអាចារ្យ បានពោល ៤ គាថាថា

បពិត្រមហារាជ ទូលព្រះបង្គំ ជាអ្នកត្រូវការដោយទ្រព្យ ( យក ទៅបូជា ) ដល់អាចារ្យ ទើបដើរសូមគេក្នុងដែន និគម និង រាជធានី ។

បពិត្រព្រះអង្គជាធំជាងជន ខ្ញុំព្រះអង្គ ( សូមឲ្យ ) ពួកគហបតី ពួករាជបុរស ពួកព្រាហ្មណមហាសាល បានគ្រឿងមាស ៧ បពិត្រមហារាជ គ្រឿងមាសរបស់ខ្ញុំព្រះអង្គនោះបាត់ ហេតុនោះ បានជាខ្ញុំព្រះអង្គសោកដ៏ក្រៃលែង ។

បពិត្រមហារាជ ពួករាជបុរសរបស់ព្រះអង្គ ខ្ញុំព្រះអង្គបាន ត្រិះរិះដោយចិត្តថា មិនអាចដើម្បីជួយដោះខ្ញុំព្រះអង្គ ឲ្យរួចចាក ទុក្ខបានទេ ហេតុនោះ ខ្ញុំព្រះអង្គ មិនប្រាប់ដល់រាជបុរសទាំង នោះឡើយ ។

បពិត្រមហារាជ ចំណែកព្រះអង្គ ខ្ញុំព្រះអង្គបានត្រិះរិះដោយចិត្តថា ព្រះអង្គអាចជួយដោះទុក្ខបាន ហេតុនោះ ខ្ញុំព្រះអង្គទើបក្រាបទូល ដល់ព្រះអង្គ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ភិក្ខមាណោ** សេចក្ដីថា សូមជាមួយគហបតី ជាដើមនោះ ។ បទថា **តេ មេ** សេចក្ដីថា កាលខ្ញុំព្រះអង្គឆ្លងស្ទឹងគង្គា មាស របស់ខ្ញុំព្រះអង្គ ៧ ដុំក៏បាត់ហើយ គឺធ្លាក់ទៅក្នុងស្ទឹងគង្គា ។ បទថា **បុរិសា តេ** សេចក្ដីថា បពិត្រមហារាជ បុរសជាទូតរបស់ទ្រង់ ។ បទថា **មឲសានុ-វិចិន្តិតា** សេចក្ដីថា ទូលបង្គំដឹងថា មនុស្សទាំងនោះ មិនអាចដោះទូលបង្គំ ឲ្យផុតចាកទុក្ខបាន ។ បទថា **តស្មា** សេចក្ដីថា ព្រោះហេតុនោះ ទើបទូល បង្គំមិនប្រាប់សេចក្ដីទុក្ខរបស់ខ្លួនដល់ជនទាំងនោះ ។ បទថា **បវេទយឹ** បាន ដល់ បានក្រាបទូលហើយ ។

ព្រះសាស្ដា កាលទ្រង់ប្រកាសសេចក្ដីនោះ ទើបត្រាស់អភិសានគាថាថា ព្រះបាទពារាណសី ជាអ្នកចម្រើនក្នុងដែនរបស់អ្នកកាសី មាន ព្រះហឫទ័យជ្រះថ្លា បានប្រទានគ្រោរមាសសុទ្ធ ចំនួន ១៤ ដុំ ដល់មហាសត្វនោះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ជាតរូបមយេ** សេចក្ដីថា ទ្រង់បានព្រះរាជទានមាស ១៤ ដុំ ដល់ព្រះពោធិសត្វនោះ ។

ព្រះមហាសត្វថ្វាយឱវាទដល់ព្រះរាជាហើយ ឲ្យទ្រព្យដល់អាចារ្យ បានបំពេញកុសល មានទានជាដើម សូម្បីព្រះរាជាក៏តាំងនៅក្នុងឱវាទរបស់ព្រះមហាសត្វ ទ្រង់គ្រងរាជសម្បត្តិប្រកបដោយធម៌ ហើយជនទាំងពីរក៏ទៅតាមយថាកម្ម ។

ព្រះសាស្ដា កាលទ្រង់នាំយកព្រះធម្មទេសនានេះ មកសម្ដែងហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលតថាគតឈ្លាសក្នុងឧបាយ សូម្បីក្នុងកាលមុន តថាគតក៏ឈ្លាសក្នុងឧបាយដូចគ្នា ហើយទ្រង់ប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទ ក្នុងកាលឥឡូវនេះ អាចារ្យក្នុងកាលនោះ បានមកជាសារីបុត្ត ចំណែកមាណពក្នុងកាលនោះ គឺតថាគតនេះឯង ។៙

**អដ្ឋកថា ទូតជាតក ចប់**

# សុត្តន្តបិដក

## កាលិង្គពោធិជាតក

[ ១០៨៨ ] ( អភិសម្ពុទ្ធគាថា ) ព្រះបាទកាលិង្គជាស្តេចចក្រពត្តិ គ្រប់គ្រងមនុស្សលើផែនដីដោយធម៌ ស្តេចបានមកដល់ទីជិតពោធិព្រឹក្ស ដោយដំរីមានអានុភាពធំ ។

[ ១០៨៩ ] ការទ្វាជព្រាហ្មណបុរោហិត នៅក្នុងដែនកាលិង្គ លើកកម្បង់អញ្ជលីចំពោះព្រះរាជាចក្រពត្តិដែលទ្រង់ប្រសូតចាកត្រកូលសមណៈព្រះនាមចុល្លកាលិង្គ ក្រាបទូលពាក្យនេះថា ។

[ ១០៩០ ] បពិត្រមហារាជ សូមព្រះអង្គស្តេចចុះមក ចំណែកនៃផែនដីនេះ ជាប្រទេសដែលសមណៈសរសើរហើយ ព្រះពុទ្ធទាំងឡាយ មានគុណប្រឹងមិនបាន តែងត្រាស់ដឹងហើយ រុងរឿងក្នុងទីនេះ ។

[ ១០៩១ ] បពិត្រមហារាជ តាមដែលខ្ញុំព្រះអង្គឮមកថា ស្មៅនិងវល្លិ៍ទាំងឡាយ ក្នុងចំណែកនៃផែនដីនេះ វិលក្បួចទៅខាងស្តាំនេះជាផ្ចិតនៃផែនដី ។

[ ១០៩២ ] ផ្ចិតនៃផែនដីនេះ ដែលមានសមុទ្រសាគរជាទីបំផុត ជាទីទ្រទ្រង់នូវសត្វទាំងពួង សូមព្រះអង្គស្តេចចុះមកធ្វើនមស្ការ ។

[ ១០៩៣ ] ពួកដំរីណា ដែលកើតក្នុងឧបោសថត្រកូល ជាដំរីដ៏ប្រសើរ ដំរីទាំងនោះ រមែងមិនហ៊ានចូលទៅកាន់ប្រទេស មានប្រមាណប៉ុណ្ណោះទេ ។

[ ១០៩៤ ] ដំរីកើតក្នុងឧបោសថត្រកូលក៏ពិតហើយ តែប្រទេស ប៉ុណ្ណោះនេះ ដំរីនុ៎ះមិនហ៊ានចូលទៅជិតទេ សូមព្រះអង្គយកកន្សែរពេជ្រ ( កាប់ ) បញ្ជូនដំរីដ៏ប្រសើរ ដែលគេបានបង្ហឹកហើយ ( ឲ្យចូលទៅលមើល ) ។

[ ១០៩៥ ] ព្រះបាទកាលិង្គ ទ្រង់ព្រះសណ្ដាប់ពាក្យព្រាហ្មណ-បុរោហិតនោះហើយ ទ្រង់ពិចារណាតាមពាក្យបុរោហិត ជាអ្នកមើលលក្ខណៈ ទើបបង្ខំដំរីដ៏ប្រសើរ ដែលកើតក្នុងឧបោសថ-ត្រកូល ដោយគិតថា យើងនឹងបរ ( ដំរី ) ចូលទៅតាមពាក្យរបស់បុរោហិតនេះលមើល ។

[ ១០៩៦ ] ឯដំរីដែលស្ដេចបរចូលទៅ ក៏មិនអាចទទួលភារៈដ៏ធ្ងន់បាន ហើយស្រែកដូចជាសត្វក្រៀល ថយក្រោយ អន្ទុយ ( លើអាកាស ) ។

[ ១០៩៧ ] ភារទ្វាជព្រាហ្មណ៍ ក្នុងដែនកាលិង្គដឹងថា ដំរីនោះអស់អាយុហើយ ក៏ប្រញាប់ក្រាបទូលព្រះបាទកាលិង្គថា បពិត្រមហារាជ សូមព្រះអង្គគង់ដំរីដទៃវិញ ព្រោះដំរីនេះ អស់អាយុហើយ ។

[ ១០៩៨ ] ព្រះបាទកាលិង្គ បានឮពាក្យនោះហើយ ក៏ទ្រង់ប្រញាប់ទៅកាន់ដំរី ( ដទៃ ) កាលបើស្ដេចទ្រង់ឈានផុតទៅហើយ ដំរីក៏ដួលធ្លាក់មកលើផែនដីក្នុងទីនោះឯង ពាក្យព្រាហ្មណ-

បុរោហិតអ្នកទាយលក្ខណៈយ៉ាងណា ដីរក៏យ៉ាងនោះ ។

[ ១០៩៩ ] ព្រះបាទកាលិង្គ មានព្រះរាជឱង្ការនេះ នឹងកាលិង្គ-ភារទ្វាជព្រាហ្មណ៍ថា អ្នកឯងជាមនុស្សចេះដឹងដោយប្រពៃ ជាសព្វញ្ញូ ឃើញការសព្វគ្រប់ ។

[ ១១០០ ] កាលិង្គភារទ្វាជព្រាហ្មណ៍ មិនទទួលកាលសរសើរនោះ ក៏ក្រាបបង្គំទូលដូច្នេះថា បពិត្រមហារាជ ទូលព្រះបង្គំជាខ្ញុំគ្រាន់តែជាអ្នកទាយលក្ខណៈ ព្រះពុទ្ធទាំងឡាយ ទើបព្រះអង្គជាសព្វញ្ញូ ។

[ ១១០១ ] ព្រះពុទ្ធទាំងឡាយ ព្រះអង្គដឹងសព្វ ជ្រាបសព្វតែងដឹងដោយលក្ខណៈ ចំណែកយើងខ្ញុំ ( ចេះដឹង ) ដោយសារកម្លាំងសិល្បសាស្ត្រ ព្រះពុទ្ធទាំងឡាយ ទើបព្រះអង្គទ្រង់ជ្រាបសព្វ ។

[ ១១០២ ] ព្រះបាទកាលិង្គជ្រះថ្លានឹងពោធិមណ្ឌល ហើយនាំយកផ្កាកម្រង និងគ្រឿងក្រអូប គ្រឿងលាប ព្រមទាំងតូរ្យតន្ត្រីទាំងឡាយផ្សេងៗ ទ្រង់ឲ្យធ្វើកំពែងព័ទ្ធជុំវិញហើយ ទើបទ្រង់យាងចេញទៅ ។

[ ១១០៣ ] ព្រះបាទកាលិង្គបានឲ្យរាជបុរស បេះផ្កាឈើទាំងឡាយ ចំនួនប្រាំមួយម៉ឺនរទេះ មកបូជាកន្លែងដាំពោធិព្រឹក្សដ៏ប្រសើរបំផុត ( នោះ ) ។

# អដ្ឋកថា

## កាលិង្គពោធិជាតក

[ ១០៨៨-១១០៣ ] ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការបូជាមហាពោធិ៍ ដែលព្រះអានន្ទត្ថេរធ្វើហើយ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **រាជា កាលិង្គោ ចក្កវត្តិ** ដូច្នេះជាដើម ។

សេចក្ដីពិស្ដារថា កាលព្រះតថាគតទ្រង់យាងចារិកតាមជនបទ ដើម្បីប្រយោជន៍សង្គ្រោះវេនេយ្យសត្វ អ្នកក្រុងសាវត្ថីកាន់គ្រឿងក្រអូប និងកម្រងផ្កាជាដើមទៅកាន់វត្តជេតពន មិនបានបូជនីយដ្ឋានដទៃ ក៏ដាក់តម្កល់ត្រង់ទ្វារព្រះគន្ធកុដិ ហើយចៀសចេញទៅ ដោយហេតុនោះ ជនទាំងនោះ ក៏មានបាមោជ្ជយ៉ាងក្រៃលែង ។ អនាថបិណ្ឌិកសេដ្ឋី ជ្រាបហេតុនោះហើយ ទើបទៅកាន់សម្នាក់ព្រះអានន្ទត្ថេរ ក្នុងពេលដែលព្រះតថាគតយាងមកវត្តជេតពន ពោលថា បពិត្រលោកម្ចាស់ កាលព្រះដ៏មានព្រះភាគយាងចារិកទៅ វិហារនេះមិនមានបច្ច័យ មនុស្សទាំងឡាយមិនមានទីបូជាដោយគ្រឿងក្រអូប និងផ្កាជាដើម បពិត្រលោកម្ចាស់ ខ្ញុំសូមឱកាសទៅចុះ សូមលោកម្ចាស់ក្រាបទូលរឿងនេះដល់ព្រះតថាគត ហើយចូរដឹងទីដែលគួរបូជាត្រង់ណាមួយកន្លែង ។

ព្រះអានន្ទត្ថេរទទួលថា សាធុ ហើយទូលសួរព្រះតថាគតថា បពិត្រព្រះអង្គ ចេតិយមានប៉ុន្មានយ៉ាង ព្រះតថាគតត្រាស់ថា ម្នាលអានន្ទ មាន ៣ យ៉ាង ព្រះអានន្ទទូលសួរថា បពិត្រព្រះអង្គ ៣ យ៉ាងនោះអ្វីខ្លះ ព្រះសាស្ដាត្រាស់ថា ម្នាលអានន្ទ ៣ នោះ គឺធាតុចេតិយ ១ បរិភោគចេតិយ ១ ឧទ្ទេសិកចេតិយ ១ ។ ព្រះអានន្ទទូលថា បពិត្រព្រះអង្គ កាលទ្រង់ចារិកទៅ

ខ្ញុំព្រះអង្គអាចធ្វើចេតិយបានដែរឬ ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ សម្រាប់ធាតុចេតិយមិនអាចធ្វើបាន ព្រោះធាតុចេតិយនោះ មានក្នុងកាលដែលព្រះពុទ្ធបរិនិព្វានហើយ សម្រាប់ឧទ្ទេសិកចេតិយ ក៏មិនមានវត្ថុប្រាកដ ព្រោះជាប់ជាមួយតថាគតប៉ុណ្ណោះ ឯមហាពោធិ៍ដែលអាស្រ័យទីត្រាស់ដឹង សូម្បីព្រះពុទ្ធគង់ព្រះជន្មនៅក្តី បរិនិព្វានក្តី ជាចេតិយបានដូចគ្នា ព្រះអានន្ទទូលថា បពិត្រព្រះអង្គ កាលទ្រង់ចៀសចេញទៅ ព្រះវិហារជេតពនអស់ទីពឹង ទីអាស្រ័យមនុស្សទាំងឡាយមិនបានទីដែលគួរបូជា ខ្ញុំព្រះអង្គនឹងនាំពូជអំពីមហាពោធិ៍មកដាំត្រង់ខ្លោងទ្វារវត្តជេតពន ។ ព្រះសាស្តាត្រាស់ថា សាធុ អានន្ទ ចូរអ្នកដាំចុះ កាលបើដូច្នោះ ក្នុងវត្តជេតពន ក៏ដូចតថាគតនៅជានិច្ច ។ ព្រះអានន្ទត្ថេរ បានប្រាប់ដល់ព្រះបាទកោសល អនាថបិណ្ឌិកសេដ្ឋី និងនាងវិសាខាមហាឧបាសិកាជាដើម ឲ្យជីករណ្តៅក្នុងទីសម្រាប់ដាំដើមពោធិ៍ ត្រង់ទ្វារវត្តជេតពន ហើយពោលនឹងព្រះមហាមោគ្គល្លានត្ថេរថា បពិត្រលោកម្ចាស់ខ្ញុំនឹងដាំដើមពោធិ៍ត្រង់ទ្វារវត្តជេតពន សូមលោកជួយនាំយកកូនពោធិ៍អំពីមហាពោធិ៍ ឲ្យខ្ញុំផងចុះ ។

ព្រះមហាមោគ្គល្លានត្ថេរទទួលថា សាធុ ហើយហោះទៅកាន់ពោធិមណ្ឌលយកចីវរទទួលផ្លែពោធិ៍ ដែលជ្រុះអំពីមែក មិនទាន់ដល់ផែនដីបានហើយ នាំមកប្រគេនព្រះអានន្ទត្ថេរ ។ ព្រះអានន្ទបានប្រាប់សេចក្តីដល់ព្រះបាទកោសលជាដើមថា ថ្ងៃនេះ អាត្មានឹងដាំដើមពោធិ៍ក្នុងទីនេះ ។ ព្រះបាទកោសល ឲ្យរាជបុរសកាន់គ្រឿងឧបករណ៍គ្រប់យ៉ាងយាងមក មួយអន្លើដោយបរិវារធំក្នុង

ពេលល្ងាច ។ អនាថបិណ្ឌិកសេដ្ឋី មហាឧបាសិកាវិសាខា និងអ្នកមានសទ្ធាដទៃៗ ក៏បានធ្វើដូច្នោះ ។

ព្រះអានន្ទត្ថេរ តម្កល់ផើងមាសធំក្នុងទីដែលដាំដើមពោធិ៍ ឲ្យចោះបាតផើង ហើយឲ្យផ្លែពោធិ៍ទុំដល់ព្រះបាទកោសល ទូលថា មហាបពិត្រ សូមទ្រង់ដាំផ្លែពោធិ៍នេះចុះ ព្រះបាទកោសលទ្រង់ព្រះតម្រិះថា ភាពជាព្រះរាជាមិនបានតាំងនៅរហូតទៅ អញគួរឲ្យអនាថបិណ្ឌិកមហាសេដ្ឋី ដាំដើមពោធិ៍នេះ ទ្រង់ព្រះតម្រិះដូច្នេះហើយ បានដាក់ផ្លែពោធិ៍ទុំនោះ ក្នុងដៃរបស់មហាសេដ្ឋី ។ អនាថបិណ្ឌិកមហាសេដ្ឋី ប្រមូលភក់ដែលមានក្លិនក្រអូបហើយ កប់ផ្លែពោធិ៍ទុំក្នុងភក់នោះ ។ គ្រាន់តែផ្លែពោធិ៍ផុតអំពីដៃមហាសេដ្ឋី កាលជនទាំងឡាយកំពុងមើលនោះឯង បានប្រាកដដើមពោធិ៍ប្រមាណប៉ុនយាមនង្គ័ល កម្ពស់ ៥០ ហត្ថ បែក ៥ មែក មែកនីមួយៗ ប្រវែង ៥០ ហត្ថ ចេញទៅក្នុងទិសទាំង ៤ និងទៅលើ ។ ដើមពោធិ៍នោះ ជាដើមឈើធំជាងដើមឈើក្នុងព្រៃតាំងឡើងក្នុងរំពេចនោះឯង ដោយប្រការដូច្នេះ ។

ព្រះរាជាត្រាស់ឲ្យយកក្អមមាស និងក្អមប្រាក់ ៨០០ ដាក់ទឹកក្រអូបពេញ ប្រដាប់ដោយផ្កាឈូកខៀវដែលមានកម្ពស់ ១ ហត្ថជាដើម តម្រៀបជាជួរព័ទ្ធជុំវិញដើមមហាពោធិ៍ ហើយត្រាស់ឲ្យធ្វើព្រះវេទន សម្រេចដោយកែវ ៧ ប្រការ រោយដោយមាស ធ្វើកំពែងព័ទ្ធជុំវិញ ធ្វើខ្លោងទ្វារសម្រេចដោយរតនៈ ៧ គ្រឿងសក្ការៈកើតឡើងជាច្រើន ដោយប្រការដូច្នេះ ។ ព្រះអានន្ទត្ថេរចូលទៅគាល់ព្រះតថាគត ក្រាបទូលថា បពិត្រព្រះអង្គ សូមទ្រង់ប្រថាប់គន់

ចូលសមាបត្តិដែលទ្រង់ធ្លាប់ចូលនាមណ្ឌលពោធិព្រឹក្ស ត្រង់គល់ពោធិ៍ដែលខ្ញុំព្រះអង្គដាំ ដើម្បីប្រយោជន៍ដល់មហាជន ។ ព្រះសាស្ដាត្រាស់ថា ម្នាលអានន្ទ អ្នកនិយាយថ្វី បើតថាគតអង្គុយចូលសមាបត្តិដែលបានចូលហើយ ត្រង់មហាពោធិមណ្ឌល ប្រទេសដទៃ ក៏មិនអាចទ្រទ្រង់នៅបាន ។ ព្រះអានន្ទត្ថេរក្រាបទូលថា បពិត្រព្រះអង្គ ដើម្បីប្រយោជន៍ដល់មហាជន សូមទ្រង់ប្រើប្រាស់គល់ពោធិ៍នោះដោយសេចក្ដីសុខ ដែលកើតអំពីសមាបត្តិ ដោយកំណត់ថា ជិតភូមិប្រទេសនេះចុះ ។ ព្រះសាស្ដា ទ្រង់ប្រើប្រាស់គល់ពោធិ៍នោះដោយសេចក្ដីសុខ ដែលកើតអំពីសមាបត្តិអស់មួយរាត្រី ។

ព្រះអានន្ទត្ថេរ ថ្វាយព្រះពរដល់ព្រះបាទកោសលជាដើម ឲ្យធ្វើការឆ្លងដើមពោធិ៍ ។ ដើមពោធិ៍នោះក៏ប្រាកដថា អានន្ទពោធិ៍នោះឯង ព្រោះជាដើមឈើដែលព្រះអានន្ទដាំ ។ កាលនោះ ភិក្ខុទាំងឡាយអង្គុយសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ ព្រះអានន្ទកាលព្រះតថាគតគង់នៅ បានដាំដើមពោធិ៍ ហើយបូជាសន្ធឹកសន្ធាប់ ព្រះថេរៈមានគុណច្រើន គួរអស្ចារ្យពិត ។ ព្រះសាស្ដាយាងមកហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អំបាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន អានន្ទក៏បាននាំមនុស្សក្នុងទ្វីបទាំង ៤ មួយអន្លើដោយទ្វីបជាបរិវារ ឲ្យនាំគ្រឿងក្រអូប និងផ្កាជាច្រើន ទៅធ្វើការឆ្លងដើមពោធិ៍ ក្នុងមហាពោធិមណ្ឌលដូចគ្នា ដូច្នេះ

ហើយ ទើបទ្រង់នាំអតីតនិទានមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទកាលិង្គរាជ សោយរាជសម្បត្តិក្នុងទន្តបុរនគរ ដែនកាលិង្គ ទ្រង់មានព្រះរាជឱរសពីរអង្គ គឺមហាកាលិង្គមួយអង្គ និងចុល្ល-កាលិង្គមួយអង្គ ។ ក្នុងព្រះរាជបុត្រពីរអង្គនោះ បុត្រច្បង ហោរាទាយថា នឹងបានគ្រងរាជសម្បត្តិ អំណឹះឥតពីបិតាទៅ តែបុត្រប្អូន ពួកហោរាទាយថា នឹងបួសជាឥសី ត្រាច់ភិក្ខាចារ តែឱរសរបស់ព្រះរាជបុត្រប្អូន នឹងបានជាស្តេចចក្រពត្តិ ។

ក្រោយមក កាលព្រះរាជបិតាសោយទិវង្គតទៅ ឱរសច្បងបានជាព្រះរាជា ឱរសពៅបានជាឧបរាជ ។ ឧបរាជនោះ ក៏កើតមានះ ព្រោះបុត្រជាហេតុ ព្រោះបានឮថា កូនរបស់អញនឹងបានជាស្តេចចក្រពត្តិ ។ ព្រះរាជានោះ ទ្រង់អត់ធន់មិនបាន ទើបបញ្ជាអមាត្យម្នាក់ថា ចូរឯងចាប់ចុល្លកាលិង្គ ។ អមាត្យនោះទៅក្រាបទូលថា បពិត្រព្រះរាជកុមារ ព្រះរាជាបំណងនឹងចាប់ទ្រង់ សូមទ្រង់រក្សាជីវិតទ្រង់ចុះ ឧបរាជបានយករបស់ ៣ យ៉ាង របស់ទ្រង់ គឺព្រះរាជលញ្ឆករ គឺព្រះទម្រង់[១] ១ សំពត់កម្ពលសាច់ម៉ដ្ឋ ១ និងព្រះខ័ន ១ បង្ហាញដល់អមាត្យអ្នកបម្រើ ហើយត្រាស់ថា អ្នកទាំងឡាយគប្បីឲ្យរាជ-សម្បត្តិដល់កូនរបស់យើងដោយសញ្ញានេះ ហើយយាងចូលព្រៃ សាងអាស្រម ក្នុងភូមិប្រទេសគួរជាទីរីករាយ បួសជាឥសីគ្រង់ឆ្នេរស្ទឹង ។ ក្នុងដែនរបស់ស្តេចមទ្ទរាជ អគ្គមហេសីរបស់ព្រះបាទមទ្ទរាជក្នុងសាគលនគរ ប្រសូត

១- ក្នុងទីខ្លះព្រះរាជលញ្ឆករលោកប្រែថា ត្រា តែក្នុងទីនេះសំដៅដល់ព្រះទម្រង់ ។

ព្រះរាជធីតា ពួកហោរាទាយព្រះរាជធីតានោះថា ព្រះរាជធីតានេះ នឹងត្រាច់ភិក្ខាចារចិញ្ចឹមជីវិត តែឱរសរបស់ព្រះនាង នឹងបានជាស្តេចចក្រពត្តិ ។ ព្រះរាជាក្នុងជម្ពូទ្វីបបានស្តាប់ហេតុនោះ ទើបមកព័ទ្ធព្រះនគរព្រមគ្នា ព្រះបាទមទ្ទរាជទ្រង់ព្រះតម្រាស់ថា បើអញឲ្យធីតានេះដល់ព្រះរាជាមួយអង្គ ព្រះរាជាដ៏សេសនឹងពិរោធ អញនឹងរក្សាធីតារបស់អញ ទើបនាំព្រះរាជធីតា និងអគ្គ-មហេសី ក្លែងភេទគេចចូលទៅព្រៃ សាងអាស្រមអំពីខាងលើអាស្រមកាលិង្គកុមារ ចិញ្ចឹមជីវិតដោយមូលផលាហារក្នុងទីនោះ ។ ព្រះជនក ព្រះជននីទ្រង់ព្រះតម្រិះថា អញនឹងរក្សាព្រះរាជធីតា ហើយឲ្យនាងនៅក្នុងអាស្រមហើយទៅរកផលាហារ ក្នុងពេលដែលព្រះជនកព្រះជននីយាងទៅ ព្រះរាជធីតាបានយកផ្កាផ្សេងៗ ធ្វើជាមកុដផ្កា ។ ក្នុងទីនោះ មានដើមស្វាយត្រសាយត្រសុំមួយដើម ដូចគ្នានឹងកាំជណ្តើរ តាំងនៅត្រង់ឆ្នេរស្ទឹងគង្គា ។ ព្រះរាជធីតាក៏ឡើងលេងលើដើមស្វាយនោះ ហើយបោះមកុដផ្កាទៅក្នុងទឹក ។

ថ្ងៃមួយ មកុដផ្កាបានជាប់ត្រង់សីសៈរបស់កាលិង្គកុមារ ដែលកំពុងស្រង់ទឹកក្នុងស្ទឹងគង្គា កាលិង្គកុមារសម្លឹងហើយ ទ្រង់ព្រះតម្រិះថា មកុដផ្កានេះ ស្រីម្នាក់ធ្វើ តែមិនមែនជាស្រីចាស់ ជាស្រីក្មេង អញនឹងសង្កេតមើល ទើបទៅខាងលើទឹកដោយអំណាចកិលេស បានស្តាប់សំឡេងព្រះរាជធីតាដែលអង្គុយច្រៀងដោយសំឡេងដ៏ពីរោះ លើដើមស្វាយ ទើបយាងទៅត្រង់គល់ស្វាយ ទតឃើញព្រះរាជធីតា ទើបត្រាស់សួរថា នែនាងមានមុខដ៏ចម្រើន នាងជានរណា ព្រះរាជធីតាឆ្លើយថា យើងជាមនុស្ស ព្រះរាជកុមារត្រាស់

ថា បើដូច្នោះ ចូរនាងចុះមក ព្រះរាជធីតាត្រាស់ថា នែលោក ខ្ញុំជាក្សត្រ មិនអាចចុះទៅបានទេ ព្រះរាជកុមារត្រាស់ថា នែនាង ខ្ញុំក៏ជាក្សត្រដូចគ្នា ចូរនាងចុះមកចុះ ព្រះរាជធីតាត្រាស់ថា នែអ្នក មនុស្សមិនមែនជាក្សត្រដោយគ្រាន់តែពាក្យប៉ុណ្ណោះឡើយ បើលោកជាក្សត្រ សូមលោកពោលមាយារបស់ក្សត្រចុះ ។ ជនទាំងពីរ ក៏នាំគ្នាពោលមាយាក្សត្រដល់គ្នានិងគ្នា កាលជនទាំងពីរនៅដោយសេចក្ដីស្រឡាញ់ ព្រះរាជធីតាក៏តាំងគភ៌ គ្រប់ ១០ ខែ ក៏ប្រសូតព្រះរាជឱរស ដែលសម្បូរដោយបុញ្ញលក្ខណៈដ៏ឧត្ដម ។ ព្រះជនក ព្រះជននីថ្វាយនាមថា កាលិង្គ ។ កាលិង្គកុមារនោះ ចម្រើនវ័យ សម្រេចការសិក្សានូវសិប្បវិជ្ជាគ្រប់យ៉ាង ក្នុងសម្នាក់របស់ព្រះជនក និងព្រះអយ្យកា ។ លំដាប់នោះ ព្រះជនករបស់កាលិង្គកុមារនោះ សម្លឹងមើលផ្កាយក៏ជ្រាបថា បងប្រុសសោយទិវង្គតហើយ ទើបប្រាប់ព្រះរាជបុត្រថា នែបា កូនកុំនៅក្នុងព្រៃឡើយ ស្ដេចមហាកាលិង្គ ជាម្ចាស់អំរបស់ឯងសោយទិវង្គតហើយ ចូរបាទៅកាន់ទន្តបុរនគរ គ្រងរាជសម្បត្តិបន្តសន្តតិវង្សចុះ ហើយប្រគល់ព្រះលញ្ចករ សំពត់កម្ពល និងព្រះខ័នដែលទ្រង់នាំមក ឲ្យហើយប្រាប់ថា នែបា ក្នុងទន្តបុរនគរ អមាត្យអ្នកធ្វើប្រយោជន៍របស់យើងមាននៅត្រង់ផ្លូវឈ្មោះនោះ ចូរបាហោះទៅចុះត្រង់ផ្លូវក្នុងផ្ទះរបស់អមាត្យនោះ ហើយបង្ហាញរតនៈ ៣ ប្រការនេះ ប្រាប់ភាពដែលឯងជារាជបុត្ររបស់យើងដល់អមាត្យនោះ គេនឹងជួយឯងឲ្យបានគ្រងរាជសម្បត្តិ ។

ព្រះរាជកុមារ ថ្វាយបង្គំលាព្រះជនក ព្រះជននី និងព្រះអយ្យកាហើយ

ហោះទៅដោយបុញ្ញឫទ្ធិ ចុះទៅអង្គុយលើទីដេករបស់អមាត្យៗ សួរថា ឯង ជាអ្នកណា ទើបប្រាប់ថា យើងជាកូនរបស់ចុល្លកាលិង្គ ហើយបង្ហាញរតនៈ ទាំង ៣ ប្រការនោះ ។ អាមាត្យក៏ប្រកាសដល់រាជបរិស័ទ ។ អមាត្យ និង រាជបរិស័ទទាំងឡាយ នាំគ្នាប្រដាប់តាក់តែងព្រះនគរ អភិសេកកាលិង្គកុមារ ឲ្យគ្រងរាជសម្បត្តិ ។

លំដាប់នោះ បុរោហិតឈ្មោះភារទ្វាជៈរបស់ព្រះបាទកាលិង្គ បានក្រាប ទូលចក្កវត្តិឲ្យព្រះរាជាកាលិង្គទ្រង់ជ្រាបវត្ត សម្រាប់ឲ្យបានជាស្ដេចចក្កវត្តិ ឲ្យព្រះបាទកាលិង្គទ្រង់ជ្រាប ។ ព្រះបាទកាលិង្គនោះ ទ្រង់បំពេញចក្កវត្តិ វត្ត នោះឲ្យបរិបូណ៌ហើយ ។ កាលដល់ថ្ងៃឧបោសថ ១៥ កើត ចក្ករ័តន៍ក៏មក អំពីលំនៅរបស់ចក្ករ័តន៍ ដំរីកែវក៏មកអំពីត្រកូលឧបោសថ សេះកែវក៏មក អំពីត្រកូលអស្សរាជវលាហកៈ កែវមណីមកអំពីបាតភ្នំវេបុលបព៌ត ស្រីកែវ គហបតិកែវ និងបរិណាយកកែវ ក៏កើតប្រាកដដល់ព្រះបាទកាលិង្គនោះ ។

ព្រះបាទចក្រពត្តិកាលិង្គរាជ ទ្រង់គ្រងរាជសម្បត្តិពេញផ្ទៃចក្កវាឡ ថ្ងៃ មួយ មានសេនាចោមរោមប្រមាណ ៣៦ យោជន៍ ទ្រង់ឡើងដំរីកែវពណ៌ស ដែលប្រៀបដូចកំពូលភ្នំកៃលាស ទៅកាន់សម្នាក់ព្រះជនក ព្រះជននីដោយ មហាសិរីវិលាស ។

ចំណែកដំរីព្រះទីនាំងស្ដេចចក្រពត្តិនោះ មិនអាចហោះរំលងមហាពោធិ-មណ្ឌល ដែលកើតត្រង់ផ្ចិតផែនដី ជាជ័យមង្គលរបស់ព្រះពុទ្ធទាំងពួងបាន ។ ព្រះបាទចក្រពត្តិរាជ ទ្រង់បញ្ជាដំរីនោះរឿយៗ តែដំរីនោះមិនអាចទៅបាន ។

ព្រះសាស្តា កាលប្រកាសសេចក្តីនោះ ទើបត្រាស់គាថាទី ១ ថា

ព្រះបាទកាលិង្គជាស្តេចចក្រពត្តិ គ្រប់គ្រងមនុស្សលើផែនដីដោយធម៌ ស្តេចបានមកដល់ទីជិតពោធិព្រឹក្ស ដោយដំរីមានអានុភាពធំ ដូច្នេះ ។

លំដាប់នោះ បុរោហិតរបស់ស្តេចចក្រពត្តិដែលតាមព្រះរាជាទៅ គិតថា ធម្មតាក្នុងអាកាសមិនមានអ្វីរាំង ព្រោះហេតុអ្វីហ្ន៎ ទើបព្រះរាជាមិនអាចបញ្ជាដំរីទៅបាន អញនឹងពិនិត្យមើល ហើយចុះអំពីអាកាស ពិនិត្យមើលភូមិភាគដែលជាមណ្ឌល គឺផ្ចិតផែនដី មានជ័យបល្ល័ង្ករបស់ព្រះពុទ្ធទាំងពួង ។

បានឮថា ក្នុងកាលនោះ ឈ្មោះថា ដើមស្មៅ សូម្បីប៉ុនពុកមាត់ទន្សាយក៏មិនមានក្នុងទីប្រមាណ ៨ ករីសៈនោះឡើយ មានតែខ្សាច់ដែលមានពណ៌ដូចប្រាក់រាយរាយ ។ ស្មៅវល្លិ និងឈើធំដោយជុំវិញ មានចុងវិលប្រទក្សិណពោធិមណ្ឌល ហើយតាំងនៅចំពោះមុខពោធិមណ្ឌល ។

បុរោហិតពិនិត្យមើលភូមិភាគនោះហើយ គិតថា ពិតហើយ ទីនេះ គឺជាទីកម្ចាត់កិលេសទាំងពួងរបស់ព្រះពុទ្ធទាំងឡាយ សូម្បីបុគ្គលណាម្នាក់ មានសក្កទេវរាជជាដើម ក៏មិនអាចហោះរំលងទីនេះទៅបាន ទើបទៅគាល់ព្រះបាទកាលិង្គរាជ សម្តែងគុណរបស់ពោធិមណ្ឌល ហើយក្រាបទូលព្រះរាជាថា សូមទ្រង់ចុះមក ។

ព្រះសាស្តា កាលប្រកាសសេចក្តីនោះ ទើបត្រាស់ព្រះគាថាទាំងនេះថា

ការទ្វាជព្រាហ្មណបុរោហិត នៅក្នុងដែនកាលិង្គ លើកកម្បង់អញ្ជលីចំពោះព្រះរាជាចក្រពត្តិ ដែលទ្រង់ប្រសូតចាកត្រកូលសមណៈព្រះនាមចុល្លកាលិង្គ ក្រាបទូលពាក្យនេះថា ។

បពិត្រមហារាជ សូមព្រះអង្គស្តេចចុះមក ចំណែកនៃផែនដីនេះជាប្រទេសដែលសមណៈសរសើរហើយ ព្រះពុទ្ធទាំងឡាយ មានគុណច្រើនមិនបាន តែងត្រាស់ដឹងហើយ រុងរឿងក្នុងទីនេះ ។

បពិត្រមហារាជ តាមដែលខ្ញុំព្រះអង្គឮមកថា ស្មៅ និងវល្លិទាំងឡាយ ក្នុងចំណែកនៃផែនដីនេះ វិលក្បួចទៅខាងស្តាំ នេះជាផ្ចិតនៃផែនដី ។

ផ្ចិតនៃផែនដីនេះ ដែលមានសមុទ្រសាគរជាទីបំផុត ជាទីទ្រទ្រង់នូវសត្វទាំងពួង សូមព្រះអង្គស្តេចចុះមកធ្វើនមស្ការ ។

ពួកដំរីណាដែលកើតក្នុងឧបោសថត្រកូល ជាដំរីដ៏ប្រសើរ ដំរីទាំងនោះ រមែងមិនហ៊ានចូលទៅកាន់ប្រទេស មានប្រមាណប៉ុណ្ណោះទេ ។

ដំរីកើតក្នុងឧបោសថត្រកូលក៏ពិតហើយ តែប្រទេសប៉ុណ្ណោះនេះដំរីនុ៎ះមិនហ៊ានចូលទៅជិតទេ សូមព្រះអង្គយកកង្វេរ ពេជ្រ ( កាប់ ) បញ្ជូនដំរីដ៏ប្រសើរ ដែលគេបានបង្ហឹកហើយ ( ឲ្យចូលទៅលមើល ) ។

ព្រះបាទកាលិង្គ ទ្រង់ព្រះសណ្តាប់ពាក្យព្រាហ្មណបុរោហិតនោះ

ហើយ ទ្រង់ពិចារណាតាមពាក្យបុរោហិត ជាអ្នកមើលលក្ខណៈ ទើបបន្ទំដំរីដ៏ប្រសើរដែលកើតក្នុងឧបោសថត្រកូល ដោយគិតថា យើងនឹងបរ ( ដំរី ) ចូលទៅតាមពាក្យរបស់បុរោហិតនេះ លមើល ។

ឯដំរីដែលស្តេចបរចូលទៅ ក៏មិនអាចទទួលភារៈដ៏ធ្ងន់បាន ហើយ ស្រែកដូចជាសត្វក្រៀល ថយក្រោយអន្ទុយ ( លើអាកាស ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សមណកោលញ្ញំ** បានដល់ បុត្រនៃតាបស ។ បទថា **ចក្កវត្តយតោ** សេចក្តីថា ដែលញ៉ាំងចក្រឲ្យប្រព្រឹត្តទៅ អធិប្បាយ ថា ជាស្តេចចក្រពត្តិ ។ បទថា **បរិគ្គហេត្វា** សេចក្តីថា ពិនិត្យមើលភូមិភាគ ។ បទថា **សមណុគីតោ** សេចក្តីថា ដែលព្រះពុទ្ធទាំងពួងសរសើរហើយ ។ បទថា **អនធិវរា** បានដល់ ជាអ្នកមានគុណថ្លឹងមិនបាន ប្រមាណមិនកើត ។ បទថា **វិភោចន្តិ** សេចក្តីថា កម្ចាត់នូវងងឹត គឺកិលេសទាំងពួងបានហើយ រមែងអន្ទុយរុងរឿងក្នុងភូមិភាគចំណែកនេះ ដូចព្រះសុរិយោទ័យបញ្ចេញពន្លឺ ស្រទន់ ដូច្នោះ ។ បទថា **តិណលតា** បានដល់ ស្មៅ និងវល្លិ ។ បទថា **មណ្ឌោ** សេចក្តីថា ជាមណ្ឌលនៃផែនដីដ៏ក្រាស់ មានកម្រាស់ដល់ទៅ ២ សែន ៤ ម៉ឺនយោជន៍ជាសារៈ មិនត្រូវអ្វីមួយគ្របសង្កត់បាន ជាទីមិន ញាប់ញ័រ កាលកប្បកើតឡើង ក៏កើតឡើងមុន កាលកប្បវិនាស ក៏វិនាសក្រោយ គេ ។ បទថា **ឥតិ មេ សុតំ** សេចក្តីថា ទូលបង្គំបានស្តាប់មកហើយដោយ

លក្ខណមន្តយ៉ាងនេះ ។ បទថា **ឱរោហិត្វា** សេចក្តីថា សូមទ្រង់ចុះអំពីអាកាស ហើយនមស្ការ គឺធ្វើសក្ការបូជាចំពោះស្ថានទីដែលជាទីកម្ចាត់កិលេសរបស់ព្រះពុទ្ធគ្រប់អង្គនេះ ។ បទថា **យេ តេ** សេចក្តីថា ដំរីដ៏ប្រសើរកើតក្នុងត្រកូលឧបោសថ ពោល គឺដំរីកែវរបស់ស្តេចចក្រពត្តិ ។ បទថា **ឯត្តាវតា** សេចក្តីថា ដំរីដ៏ប្រសើរទាំងអស់នោះរមែងមិនទៅជិតប្រទេសដែលមានប្រមាណប៉ុណ្ណោះបានឡើយ សូម្បីបន្តិចក៏មិនចូលទៅ ។ បទថា **អភិជាតោ** សេចក្តីថា ដំរីដ៏ប្រសើរនេះកើតក្នុងត្រកូលឧបោសថ គ្របសង្កត់ ឈានកន្លងនូវត្រកូលដំរីទាំង ៨ មានដំរីត្រកូលគោចរិយាជាដើម ។ បទថា **កុញ្ជរំ** បានដល់ ជាប្រភេទសត្វដ៏ឧត្តម ។ បទថា **ឯត្តាវតា** សេចក្តីថា ដំរីដ៏ប្រសើរនេះ មិនអាចចូលទៅទីប្រមាណប៉ុណ្ណោះបាន គឺមិនអាចចូលទៅក្រៃលែងជាងនោះបាន កាលទ្រង់បំណងចំពោះ ចូរឲ្យសញ្ញាដោយកន្ទ្រេវពេជ្រហើយបរ ទៅ ។ បទថា **វេយ្យញ្ជនិកវចោ និសាមេត្វា** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ព្រះរាជាអង្គនោះ ពិចារណាពាក្យសម្តីរបស់កាលិង្គភារទ្វាជបុរោហិតនោះ ដែលជាអ្នកជំនាញក្នុងការព្យាករណ៍លក្ខណៈ ហើយពិចារណាថា អញនឹងដឹងពាក្យរបស់បុគ្គលនេះថា ពិត ឬមិនពិត ដូច្នេះ ទើបបរដំរីព្រះទីនាំងទៅ ។ បទថា **កោញ្ចោវ អភិនទិត្វាន** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើរនោះ កាលព្រះរាជាតឿនដោយកន្ទ្រេវពេជ្រ ហើយបរទៅ ទើបបន្លឺសំឡេងដូចសត្វក្រៀលថយទៅ លើកប្រមោយឡើង លើកកឡើង អង្គុយនៅលើអាកាសនោះឯង ហាក់ដូចជាមិនអាចនាំភារៈធ្ងន់ទៅបាន ។

ដំរីនោះ កាលស្តេចចក្រពត្តិតឿនដោយកង្វេរពេជ្ររឿយៗ មិនអាចអត់ធន់នឹងទុក្ខវេទនាបាន ក៏ធ្វើកាលកិរិយាហើយ ។

ចំណែកព្រះបាទកាលិង្គ កាលមិនជ្រាបថា ដំរីទ្រង់ដល់នូវការស្លាប់ ក៏ប្រថាប់នៅក្នុងទីនោះ បុរោហិតភារទ្វាជកាលិង្គក៏ក្រាបទូលថា បពិត្រមហារាជ ដំរីព្រះទីនាំងរបស់ទ្រង់អស់ជីវិតហើយ សូមទ្រង់ចុះយានឡើងដំរីដទៃចុះ ។

ព្រះសាស្តា កាលទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់គាថាទី ១០ ថា

ភារទ្វាជព្រាហ្មណ៍ក្នុងដែនកាលិង្គដឹងថា ដំរីនោះអស់អាយុហើយ
ក៏ប្រញាប់ក្រាបទូលព្រះបាទកាលិង្គថា បពិត្រមហារាជ សូម
ព្រះអង្គគង់ដំរីដទៃវិញ ព្រោះដំរីនេះ អស់អាយុហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **នាគោ ខីណាយុកោ** សេចក្តីថា ដំរីដ៏ប្រសើររបស់ទ្រង់ ដល់នូវការអស់ជីវិតហើយ ព្រោះកាលព្រះរាជាទ្រង់ធ្វើនូវរាជកិច្ចឯណានីមួយ មិនអាចប្រថាប់គង់លើខ្នងដំរី មិនអាចយានទៅក្នុងទីបំផុតនៃពោធិមណ្ឌលបាន សូមទ្រង់យានឡើងដំរីដ៏ប្រសើរដទៃចុះ ។

ដោយកម្លាំងឫទ្ធិរបស់ព្រះបាទកាលិង្គ ដំរីដ៏ប្រសើរដទៃក៏មកអំពីត្រកូលឧបោសថ ហើយបង្អោនខ្នងចូលទៅជិតព្រះបាទកាលិង្គ ។ ព្រះបាទកាលិង្គៈប្រថាប់គង់លើខ្នងដំរីនោះ ។ ខណៈនោះ ដំរីដែលស្លាប់ក៏ធ្លាក់ចុះលើផែនដី ។

ព្រះសាស្តា កាលប្រកាសសេចក្តីនោះ ទើបត្រាស់ព្រះគាថាទៀតថា

ព្រះបាទកាលិង្គបានឮពាក្យនោះហើយ ក៏ទ្រង់ប្រញាប់ទៅកាន់ដំរី
( ដទៃ ) កាលបើស្តេចទ្រង់ឈានផុតទៅហើយ ដំរីក៏ដួលធ្លាក់មក

លើផែនដី ក្នុងទីនោះឯង ពាក្យព្រាហ្មណបុរោហិតអ្នកទាយ
លក្ខណៈយ៉ាងណា ដីក៏យ៉ាងនោះ ដូច្នេះ ។

លំដាប់នោះ ព្រះបាទកាលិង្គរាជក៏ចុះអំពីអាកាស ហើយបានទតមើលពោធិមណ្ឌល ឃើញបាដិហារ្យ កាលទ្រង់សរសើរបុរោហិតការិង្គៈ ទើបត្រាស់ថា

ព្រះបាទកាលិង្គ មានព្រះរាជឱង្ការនេះ នឹងកាលិង្គការទ្វាជ-
ព្រាហ្មណ៍ថា អ្នកឯងជាមនុស្សចេះដឹងដោយប្រពៃ ជាសព្វញ្ញូ
ឃើញការសព្វគ្រប់ ដូច្នេះ ។

ព្រាហ្មណបុរោហិត មិនបានទទួលយកពាក្យសរសើរនោះ តាំងខ្លួនក្នុងឋានៈថោកថយ ហើយពោលសរសើរព្រះពុទ្ធគុណប៉ុណ្ណោះ ។

ព្រះសាស្តាកាលទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់ព្រះគាថាទាំងនេះថា

កាលិង្គការទ្វាជព្រាហ្មណ៍ មិនទទួលការសរសើរនោះ ក៏ក្រាប
បង្គំទូលដូច្នេះថា បពិត្រមហារាជ ទូលព្រះបង្គំជាខ្ញុំ គ្រាន់តែជា
អ្នកទាយលក្ខណៈ ព្រះពុទ្ធទាំងឡាយ ទើបព្រះអង្គជាសព្វញ្ញូ ។
ព្រះពុទ្ធទាំងឡាយ ព្រះអង្គដឹងសព្វ ជ្រាបសព្វ តែងដឹងដោយ
លក្ខណៈ ចំណែកយើងខ្ញុំ ( ចេះដឹង ) ដោយសារកម្លាំង
សិល្បសាស្ត្រ ព្រះពុទ្ធទាំងឡាយ ទើបព្រះអង្គទ្រង់ជ្រាបសព្វ
ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វេយ្យញ្ជនិកា** សេចក្តីថា បពិត្រមហារាជ

ទូលបង្គំឃើញព្យញ្ជនៈហើយ ជាអ្នកអាចព្យាករបាន ឈ្មោះថា ដឹង ព្រោះព្រះសុគត បពិត្រមហារាជ ឯព្រះពុទ្ធដែលជាអ្នកដឹងហេតុទាំងពួង ជាអ្នកដឹងធម៌ទាំងពួង សេចក្ដីពិត ព្រះពុទ្ធទាំងឡាយទ្រង់ជ្រាប និងទ្រង់ដឹងហេតុទាំងពួង មានអតីតហេតុជាដើម គឺព្រះពុទ្ធទាំងនោះ រមែងដឹងវត្ថុទាំងពួង ដោយសព្វញ្ញុតញ្ញាណមិនមែនដឹងដោយលក្ខណៈ ចំណែកទូលបង្គំជាអ្នកអាចក្នុងអាគម ( និកាយដែលជាទីមក ) ដឹងដោយកម្លាំងសិប្បៈប៉ុណ្ណោះ និងដឹងត្រឹមតែឯកទេសប៉ុណ្ណោះ ចំណែកព្រះពុទ្ធទាំងឡាយ ទើបដឹងហេតុទាំងពួង ។ ព្រះបាទកាលិង្គបានស្ដាប់ព្រះពុទ្ធគុណហើយកើតសោមនស្ស ទើបឲ្យជននៅក្នុងសកលចក្កវាឡ នាំគ្រឿងក្រអូប និងផ្កាកម្រងដ៏ច្រើន មកធ្វើការបូជាមហាពោធិមណ្ឌលអស់ ៧ ថ្ងៃ ។

ព្រះសាស្ដា កាលទ្រង់ប្រកាសសេចក្ដីនោះ ទើបត្រាស់គាថាថា

ព្រះបាទកាលិង្គជ្រះថ្លានឹងពោធិមណ្ឌល ហើយនាំយកផ្កាកម្រង
និងគ្រឿងក្រអូប គ្រឿងលាប ព្រមទាំងតូរ្យតន្ត្រីទាំងឡាយផ្សេងៗ
ទ្រង់ឲ្យធ្វើកំពែងព័ទ្ធជុំវិញ ហើយទើបទ្រង់យាងចេញទៅ ដូច្នេះ ។

លំដាប់នោះ ព្រះរាជាយាងទៅហើយ ព្រះសាស្ដាក៏ត្រាស់គាថាចុងក្រោយថា

ព្រះបាទកាលិង្គបានឲ្យរាជបុរស បេះផ្កាឈើទាំងឡាយ ចំនួនប្រាំមួយម៉ឺនរទេះ មកបូជាកន្លែងដាំពោធិព្រឹក្សដ៏ប្រសើរបំផុត ( នោះ ) ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឆាយាសិ** សេចក្ដីថា ព្រះរាជាបានយាង ទៅកាន់សម្នាក់ព្រះជនក ព្រះជននីហើយ ទ្រង់ត្រាស់ឲ្យលើកសសរមាសកម្ពស់ ប្រមាណ ១៨ ហត្ថក្នុងមហាពោធិមណ្ឌល ហើយសាងវេទិការសម្រេចហើយ ដោយកែវ ៧ ប្រការថ្វាយមហាពោធិ៍នោះ រោយខ្សាច់ដែលលាយដោយកែវ ឲ្យសាងកំពែងព័ទ្ធជុំវិញ ឲ្យសាងខ្លោងទ្វារ ដែលសម្រេចដោយកែវ ៧ ប្រការ ឲ្យប្រមូលផ្កាប្រមាណ ៦ ម៉ឺនរទេះ រាល់ៗ ថ្ងៃ បូជាពោធិមណ្ឌល ដោយ ប្រការដូច្នេះ តែក្នុងបាលីមកត្រឹមប៉ុណ្ណោះថា **សដ្ឋិវាហសហស្សានិ បុប្ផានិ** ផ្កាប្រមាណ ៦ ម៉ឺនរទេះ ដូច្នេះ ។

ព្រះបាទកាលិង្គ កាលទ្រង់ធ្វើការបូជាមហាពោធិ៍យ៉ាងនេះហើយ ទ្រង់ ទៅរកព្រះជនក ព្រះជននីមកកាន់នគរទន្តបុរៈ ហើយបំពេញកុសលទាំងឡាយ មានទានជាដើម កាលអស់ព្រះជន្ម ក៏ទៅកើតក្នុងតាវត្តិង្សពិភព ។

ព្រះសាស្ដា កាលទ្រង់នាំយកព្រះធម្មទេសនានេះ មកសម្ដែងហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អានន្ទបានធ្វើការបូជាពោធិមណ្ឌល តែ ក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុន អានន្ទក៏បានធ្វើការ បូជាពោធិមណ្ឌលដូចគ្នា ហើយទ្រង់ប្រជុំជាតកថា ព្រះបាទកាលិង្គក្នុងកាល នោះ បានមកជាអានន្ទក្នុងកាលឥឡូវនេះ ចំណែកបុរោហិត ឈ្មោះភារទ្វាជកាលិង្គក្នុងកាលនោះ គឺតថាគតនេះឯង ។៚

**អដ្ឋកថា កាលិង្គពោធិជាតក ចប់**

# សុត្តន្តបិដក

## អកិត្តិជាតក

[ ១១០៤ ] ( អកិសម្ពុទ្ធគាថា ) សក្កទេវរាជជាម្ចាស់នៃសត្វ លុះឃើញអកិត្តិបណ្ឌិតកំពុងគង់នៅទើបសួរថា បពិត្រមហាព្រហ្ម លោកប្រាថ្នាចង់បានអ្វី បានជាមកអង្គុយនៅក្នុងទីក្តៅម្នាក់ឯង ។

[ ១១០៥ ] ( អកិត្តិតាបសឆ្លើយថា ) បពិត្រសក្កៈ ការកើតក្នុងភពថ្មីទៀតនាំមកនូវសេចក្តីទុក្ខ ការបែកធ្លាយនៃសរីរៈនាំមកនូវសេចក្តីទុក្ខ ការស្លាប់ព្រោះតែវង្វេង ក៏នាំមកនូវសេចក្តីទុក្ខ បពិត្រវាសវៈ ហេតុនោះបានជាអាត្មា ( អង្គុយប្រាថ្នាព្រះនិព្វាន ) ។

[ ១១០៦ ] ( សក្កៈ ... ) សុភាសិតដ៏សមគួរនេះ លោកបានពោលល្អហើយ បពិត្រកស្សបៈ លោកមានចិត្តប្រាថ្នាចង់បានពរណា ខ្ញុំប្រគេនពរនោះដល់លោក ។

[ ១១០៧ ] ( អកិត្តិ ... ) បពិត្រសក្កៈជាធំជាងសត្វទាំងពួង បើព្រះអង្គប្រទានពរដល់អាត្មា នរជនបានកូន ប្រពន្ធ ទ្រព្យ ស្រូវ និងវត្ថុដទៃជាទីស្រឡាញ់ រមែងមិនឆ្អែតស្កប់ស្កល់ដោយលោភៈណា សូមកុំឲ្យលោភៈនោះ នៅក្នុងសន្តានរបស់អាត្មាបានឡើយ ។

[ ១១០៨ ] ( សក្កៈ ... ) សុភាសិតដ៏សមគួរនេះ លោកបានពោលល្អហើយ បពិត្រកស្សបៈ លោកមានចិត្តប្រាថ្នាពរណា ខ្ញុំប្រគេនពរនោះដល់លោក ។

[ ១១០៩ ] ( អកិត្តិ ... ) បពិត្រសក្កៈជាធំជាងសត្វទាំងពួង បើព្រះអង្គប្រទានពរដល់អាត្មា ពួកជនរមែងញុំាងស្រែចម្ការប្រាក់ មាស គោ សេះ និងទាសបុរសឲ្យសាបសូន្យដោយទោសៈណា ដែលកើតហើយ សូមកុំឲ្យទោសៈនោះ នៅក្នុងសន្តានអាត្មាបានឡើយ ។

[ ១១១០ ] ( សក្កៈ ... ) សុភាសិតដ៏សមគួរនេះ លោកបានពោលល្អហើយ បពិត្រកស្សបៈ លោកមានចិត្តប្រាថ្នាពរណា ខ្ញុំប្រគេនពរនោះដល់លោក ។

[ ១១១១ ] ( អកិត្តិ ... ) បពិត្រសក្កៈជាធំជាងសត្វទាំងពួង បើព្រះអង្គប្រទានពរដល់អាត្មា អាត្មាសូមកុំឲ្យជួបនឹងមនុស្សពាល សូមកុំឲ្យឮដំណឹងមនុស្សពាល សូមកុំឲ្យនៅរួមនឹងមនុស្សពាល សូមកុំឲ្យបានធ្វើ ទាំងកុំឲ្យពេញចិត្តនឹងការចរចាទៅមកនឹងមនុស្សពាល ។

[ ១១១២ ] ( សក្កៈ ... ) មនុស្សពាលបានធ្វើអ្វីដល់លោក បពិត្រកស្សបៈ សូមលោកប្រាប់ហេតុ បពិត្រកស្សបៈ ហេតុអ្វីបានជាលោកមិនប្រាថ្នាជួបមនុស្សពាល ។

[ ១១១៣ ] ( អកិត្តិ ... ) បុគ្គលពាល រមែងណែនាំនូវអំពើមិនគួរណែនាំ រមែងប្រកបក្នុងកិច្ចមិនមែនជាធុរៈ ការណែនាំទៅរកអាក្រក់ជាការប្រសើរ ( របស់បុគ្គលពាលនោះ ) បុគ្គលពាល

បើទុកជាគេនិយាយត្រូវ ក៏នៅតែខឹង បុគ្គលពាល រមែងមិនដឹងច្បាប់អ្វីទេ ការមិនជួបប្រទះនឹងបុគ្គលពាលនោះ ជាការប្រពៃ ។

[ ១១១៤ ] ( សក្កៈ ... ) សុភាសិតដ៏សមគួរនេះ លោកបានពោលល្អហើយ បពិត្រកស្សបៈ លោកមានចិត្តប្រាថ្នាពរណា ខ្ញុំប្រគេនពរនោះដល់លោក ។

[ ១១១៥ ] ( អកិត្តិ ... ) បពិត្រសក្កៈជាធំជាងសត្វទាំងពួង បើព្រះអង្គនឹងប្រទានពរដល់អាត្មា អាត្មាសូមឲ្យជួបប្រទះអ្នកប្រាជ្ញ សូមឲ្យស្តាប់អ្នកប្រាជ្ញ សូមឲ្យនៅរួមជាមួយនឹងអ្នកប្រាជ្ញ សូមឲ្យបានធ្វើ ទាំងសូមឲ្យបានចូលចិត្តនឹងការចរចាទៅមក ជាមួយនឹងអ្នកប្រាជ្ញនោះ ។

[ ១១១៦ ] ( សក្កៈ ... ) អ្នកប្រាជ្ញបានធ្វើប្រយោជន៍អ្វីដល់លោក បពិត្រកស្សបៈ សូមលោកប្រាប់ហេតុ បពិត្រកស្សបៈ ហេតុអ្វីបានជាលោកចង់ជួបប្រទះអ្នកប្រាជ្ញ ។

[ ១១១៧ ] ( អកិត្តិ ... ) អ្នកប្រាជ្ញរមែងណែនាំនូវហេតុ ដែលគួរដឹកនាំ រមែងមិនប្រកបក្នុងកិច្ចដែលមិនមែនជាធុរៈ ការដឹកនាំល្អ ជាការប្រសើរ ( របស់អ្នកប្រាជ្ញនោះ ) អ្នកប្រាជ្ញ បើគេនិយាយត្រូវហើយ រមែងមិនក្រោធ អ្នកប្រាជ្ញនោះ រមែងចេះដឹងច្បាប់ ការសេពគប់ជាមួយនឹងអ្នកប្រាជ្ញនោះ ជាការប្រពៃ ។

[ ១១១៨ ] ( សក្កៈ ... ) សុភាសិតដ៏សមគួរនេះ លោកបាន

ពោលល្អហើយ បពិត្រកស្សបៈ លោកមានចិត្តប្រាថ្នាពរណា ខ្ញុំនឹងប្រគេតពរនោះដល់លោក ។

[ ១១១៩ ] ( អកិត្តិ ... ) បពិត្រសក្កៈជាធំជាងសត្វទាំងពួង បើព្រះអង្គប្រទានពរដល់អាត្មា នាកាលរាត្រីនោះអស់ហើយ ព្រះអាទិត្យក៏រះឡើង សូមឲ្យទិព្វភោជនកើតប្រាកដ ទាំងពួកយាចកអ្នកមានសីល ( ក៏ឲ្យមក ) កាលបើអាត្មាឲ្យ សូមទិព្វភោជនកុំឲ្យអស់ លុះឲ្យហើយ សូមកុំឲ្យក្ដៅក្រហាយក្រោយ កាលបើកំពុងឲ្យ គប្បីឲ្យមានចិត្តជ្រះថ្លា បពិត្រសក្កៈ សូមព្រះអង្គប្រទានពរទ៊ី៎ចុះ ។

[ ១១២០ ] ( សក្កៈ ... ) សុភាសិតដ៏សមគួរនេះ លោកបានពោលល្អហើយ បពិត្រកស្សបៈ លោកមានចិត្តប្រាថ្នាពរណា ខ្ញុំនឹងប្រគេនពរនោះដល់លោក ។

[ ១១២១ ] ( អកិត្តិ ... ) បពិត្រសក្កៈជាធំជាងសត្វទាំងពួង បើព្រះអង្គប្រទានពរដល់អាត្មា ព្រះអង្គកុំចូលមករកអាត្មាទៀតឡើយ បពិត្រសក្កៈ សូមព្រះអង្គប្រទានពរទ៊ី៎ចុះ ។

[ ១១២២ ] ( សក្កៈ ... ) ពួកជនប្រុសស្រីតែងចង់ឃើញ ( ខ្ញុំ ) ដោយការប្រព្រឹត្តវត្តដ៏ច្រើន ចុះភ័យ ( អ្វី ) ក្នុងការឃើញខ្ញុំ ( មានដល់លោក ) ។

[ ១១២៣ ] ( អកិត្តិ ... ) អាត្មាឃើញព្រះអង្គមានភេទជាទេវតា ប្រាកដដូច្នោះ មានសេចក្តីប្រាថ្នាទាំងពួងសម្រេចហើយ គប្បីប្រហែសក្នុងតបធម៌ ភ័យក្នុងការឃើញព្រះអង្គនុ៎ះ មានដល់ ( អាត្មា ) ។

## អកិត្តិជាតកទី ៧ ចប់

# អដ្ឋកថា

## អកិត្តិជាតក

[ ១១០៤-១១២៣ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធឧបាសកដែលជាទានបតី អ្នកក្រុងសាវត្ថីម្នាក់ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អកិត្តឹ ទិស្វាន សម្មន្តំ** ដូច្នេះជាដើម ។

បានឮថា ឧបាសកនោះ និមន្តព្រះសាស្តា ថ្វាយមហាទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានអស់ ៧ ថ្ងៃ ក្នុងថ្ងៃចុងក្រោយ បានថ្វាយបរិក្ខារទាំងពួង ដល់ព្រះអរិយសង្ឃ ។ លំដាប់នោះ ព្រះសាស្តាប្រថាប់កណ្តាលបរិស័ទនោះឯង កាលទ្រង់ធ្វើអនុមោទនា ត្រាស់ថា ឧបាសក ការបរិច្ចាគរបស់អ្នកធំក្រៃពេក កម្មដែលធ្វើបានដោយលំបាកអ្នកធ្វើហើយ ធម្មតាទានវង្សនេះជាវង្សរបស់ពួកបណ្ឌិតក្នុងកាលមុនពិត ដែលឈ្មោះថា ទាន ទោះជាគ្រហស្ថ ឬបព្វជិតគួរតែឲ្យទាំងអស់ បោរាណកបណ្ឌិតបួសក្នុងព្រៃ សូម្បីឆាន់តែស្លឹកតង្កៀបក្តាម និងវត្ថុត្រឹមតែទឹកមិនប្រៃ គ្មានក្លិន ក៏គង់ឲ្យទានដល់យាចកក្នុងកាលសមគួរ ខ្លួនឯងញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយបីតិ និងសុខ ។ ឧបាសកនោះក្រាបទូលអារាធនាថា បពិត្រព្រះអង្គ ការថ្វាយបរិក្ខារទាំងពួងនេះប្រាកដដល់មហាជនហើយនោះឯង សេចក្តីដែលទ្រង់ត្រាស់មិនទាន់ប្រាកដ សូមទ្រង់ត្រាស់នូវពាក្យនោះដល់ខ្ញុំព្រះអង្គចុះ ដូច្នេះហើយ ទើបទ្រង់នាំអតីតនិទានមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណមហាសាល មានសម្បត្តិ ៨០ កោដិ

ឪពុកម្ដាយដាក់ឈ្មោះថាអកិត្តិ ។ កាលលោកចម្រើនវ័យហើយ មាតាក៏ប្រសូតប្អូនស្រីម្នាក់ មាតាបិតាដាក់ឈ្មោះថាយសវតី ។ មហាសត្វអាយុបាន ១៦ ឆ្នាំ ក៏ទៅកាន់នគរតក្កសិលា រៀនសិល្បសាស្ត្រទាំងពួងហើយត្រឡប់មក ។ លំដាប់នោះ មាតាបិតារបស់លោកក៏ធ្វើកាលកិរិយា លោកបានរៀបចំបេត-កិច្ចដល់មាតាបិតាហើយ ធ្វើនូវការពិនិត្យនូវទ្រព្យ បានឮថា បុគ្គលនោះ រកសម្បត្តិបានប៉ុណ្ណេះស្លាប់ទៅហើយ បុគ្គលនោះ រកសម្បត្តិបានប្រមាណប៉ុណ្ណោះស្លាប់ទៅហើយ ក៏មានចិត្តតក់ស្លុតត្រិះរិះថា ទ្រព្យនេះ ប្រាកដដល់អញ អ្នកប្រមូលទ្រព្យមិនប្រាកដ មនុស្សទាំងអស់ បោលទ្រព្យនេះទៅ អញក៏គង់ជញ្ជូនវាទៅមិនបាន ទើបហៅប្អូនស្រីមកប្រាប់ថា ចូរនាងមើលថែទ្រព្យនេះចុះ ប្អូនស្រីសួរថា បងមានអធ្យាស្រ័យដូចម្ដេច ក៏ពោលថា អញចង់បួស ប្អូនស្រីពោលថា នែបង ខ្ញុំមិនឱនក្បាលទទួលទឹកមាត់ដែលបងស្ដោះចោលឡើយ ខ្ញុំមិនត្រូវការទ្រព្យនេះទេ ខ្ញុំនឹងបួសដែរ ។

ព្រះពោធិសត្វលាព្រះរាជា ហើយឲ្យមនុស្សវាយស្គរប្រកាសថា អ្នកណាត្រូវការទ្រព្យ ចូរនាំគ្នាទៅកាន់ផ្ទះរបស់អកិត្តិបណ្ឌិតចុះ ។ ព្រះពោធិសត្វបំពេញមហាទានអស់ ៧ ថ្ងៃ ទ្រព្យក៏មិនទាន់អស់ ទើបគិតថា អាយុសង្ខាររបស់អញរមែងវិនាសទៅ បើអញរង់ចាំឲ្យទ្រព្យអស់ នឹងធ្វើអ្វីកើត បុគ្គលត្រូវការ ចូរនាំគ្នាជញ្ជូនយកទៅ ហើយបើកទ្វារនិវេសន៍ប្រកាសថា យើងឲ្យទាំងអស់អញ្ជើញជញ្ជូនយកចុះ លះបង់ផ្ទះសម្បែង ប្រាក់មាស នាំប្អូនស្រីចេញអំពីនគរពារាណសីទៅ ទាំងដែលពួកញាតិនាំគ្នាយំ លោកចេញតាម

ទ្វារណា ទ្វារនោះ បានឈ្មោះថា អកិត្តិទ្វារ លោកឆ្លងស៊ីងណា កំពង់នោះ បានឈ្មោះថា កំពង់អកិត្តិ លោកដើរទៅបាន ២-៣ យោជន៍ ក៏សាងបណ្ណ-សាលាក្នុងទីដែលគួរត្រេកអរ ហើយបួសជាមួយប្អូនស្រី ។ តាំងអំពីលោកបួសហើយ មហាជនអ្នកដែនអ្នកតំបន់ និងអ្នករាជធានីក៏នាំគ្នាមកបួស ទើបមានបរិវារច្រើន កើតនូវលាភសក្ការៈច្រើន ដូចក្នុងពុទ្ធុប្បាទកាល ។ លំដាប់នោះ ព្រះមហាសត្វត្រិះរិះថា លាភសក្ការៈនេះមានច្រើន ទាំងបរិវាររបស់អញក៏មានច្រើន តែអញគួរនៅម្នាក់ឯងប៉ុណ្ណោះ លុះដល់ពេលស្ងាត់ សូម្បីតែប្អូនស្រីក៏មិនប្រាប់ឲ្យដឹង ចេញទៅម្នាក់ឯងប៉ុណ្ណោះ ដល់ដែនពួកទមិឡស្នាក់នៅក្នុងឧទ្យានក្បែរកំពង់កាចិរៈ ញុំាងឈាន និងអភិញ្ញាឲ្យកើតហើយ ។ ក្នុងទីនោះ លាភ និងសក្ការៈជាច្រើន កើតឡើងដល់លោក លោករង្កៀសនឹងលាភសក្ការៈនោះ ក៏ហោះទៅតាមអាកាស ចុះត្រង់កោះដែលមានដើមតង្កៀបក្តាម ក្បែរកោះនាគ[1] ។ កាលនោះ កោះដើមតង្កៀបក្តាមបានឈ្មោះថា កោះពស់ ។ លោកសាងបណ្ណសាលាជិតដើមតង្កៀបក្តាមធំ ស្នាក់នៅក្នុងកោះពស់នោះ ការដែលលោកនៅក្នុងកោះនោះ មិនមានអ្នកណាដឹងឡើយ ។ លំដាប់នោះ ប្អូនស្រីរបស់លោកតាមរកបងប្រុស រហូតដល់ដែនទមិឡដោយលំដាប់ មិនបានជួប ទើបនៅក្នុងទីដែលបងធ្លាប់នៅនោះឯង តែមិនអាចធ្វើឈានឲ្យកើតបាន ព្រះមហាសត្វមិនបានទៅទីដទៃ ព្រោះលោក

---

១- ក្នុងទីខ្លះ ពាក្យថា នាគ សំដៅដល់ ដើមខ្ទឹង កោះនេះ បច្ចុប្បន្នជាទឹកដីរបស់ប្រទេសស្រីលង្កា មានឈ្មោះថា នាគទីបៈ ។

ប្រាថ្នាតិច ក្នុងពេលដែលដើមតង្កៀបក្តាមនោះមានផ្លែ ក៏ឆាន់ផ្លែ ក្នុងពេលដែលមានតែស្លឹក ក៏បេះស្លឹកមកស្ងោរឆាន់ ។

ដោយតេជះនៃសីលរបស់តាបស បណ្ឌុកម្ពលសិលាអាសនៈរបស់សក្កទេវរាជសម្តែងអាការក្តៅហើយ សក្កទេវរាជទ្រង់ត្រិះរិះថា អ្នកណាបំណងនឹងឲ្យអញឃ្លាតចាកទី ទ្រង់ឃើញអកិត្តិបណ្ឌិត ក៏ទ្រង់ត្រិះរិះថា តាបសនេះ រក្សាសីលដើម្បីអ្វីហ្ន៎ ត្រូវការធ្វើសក្កទេវរាជ ឬប្រាថ្នាអ្វីដទៃ អញត្រូវសាកល្បងលោកមើល ហើយទ្រង់ត្រិះរិះបន្តថា តាបសនេះចិញ្ចឹមជីវិតដោយលំបាក ឆាន់ត្រឹមតែស្លឹកតង្កៀបក្តាមស្ងោរជាមួយទឹក បើប្រាថ្នាភាពជាសក្កៈគង់ឲ្យស្លឹកតង្កៀបក្តាមស្ងោរដល់អញ បើមិនប្រាថ្នា គង់មិនឲ្យ ហើយកាឡាខ្លួនជាព្រាហ្មណ៍ទៅកាន់សម្នាក់របស់ព្រះពោធិសត្វ ។ ព្រះពោធិសត្វស្ងោរស្លឹកតង្កៀបក្តាម ហើយលើកចុះ គិតថា អញទុកឲ្យត្រជាក់ហើយសឹមបរិភោគ បានអង្គុយត្រង់ទ្វារបណ្ណសាលា ។ លំដាប់នោះ សក្កទេវរាជបានទៅឈរចំពោះមុខដើម្បីសូមភិក្ខា ។ ព្រះមហាសត្វ ឃើញសក្កទេវរាជហើយ មានសេចក្តីសោមនស្សត្រិះរិះថា ជាលាភពន់ពេករបស់អញ អញឃើញយាចកក្នុងថ្ងៃនេះ អញត្រូវឲ្យទាន ធ្វើមនោរថរបស់អញឲ្យដល់ទីបំផុត កាន់ស្លឹកតង្កៀបក្តាមស្ងោរ ទៅដាក់ក្នុងភាជនៈរបស់សក្កៈ មិនបានបន្សល់ដើម្បីខ្លួនឡើយ គិតថា សូមទានរបស់អាត្មាអញនេះ បានជាបច្ច័យធ្វើឲ្យជាក់ច្បាស់នូវសព្វញ្ញុតញ្ញាណ ដូច្នេះ ។ ព្រាហ្មណ៍បានទទួលស្លឹកតង្កៀបក្តាមស្ងោរនោះ ដើរទៅបន្តិចក៏អន្តរធានទៅ ។ ចំណែកព្រះពោធិសត្វ

កាលឲ្យដល់សក្កទេវរាជហើយ ក៏មិនបានស្ងោរជាថ្មី សម្ងំនៅដោយបីតិនោះឯងស្អែកឡើង ស្ងោរស្រេច ក៏អង្គុយត្រង់ទ្វារបណ្ណសាលានោះឯង សក្កទេវរាជ ក៏កាឡាខ្លួនជាព្រាហ្មណ៍មកទៀត ។ ព្រះមហាសត្វ ក៏ឲ្យដល់ទ្រង់ទៀតហើយសម្ងំនៅដោយអាការដដែល ។ ក្នុងថ្ងៃជាគម្រប់ ៣ ព្រះមហាសត្វអង្គុយយ៉ាងនោះឯង ដល់នូវសោមនស្សថា ឱ ជាលាភច្រើនរបស់អញហ្ន៎ អញអាស្រ័យស្លឹកតង្កៀបក្តាម ជួបនូវបុណ្យធំ ទោះបីចុករោយព្រោះមិនមានអាហារ ៣ ថ្ងៃ ក៏នៅតែចេញអំពីបណ្ណសាលាក្នុងពេលយប់បាន អង្គុយត្រង់ទ្វារបណ្ណសាលាពិចារណាដល់ទាន សក្កទេវរាជទ្រង់ត្រិះរិះថា ព្រាហ្មណ៍នេះដាច់អាហារ ៣ ថ្ងៃស្រេកឃ្លានបែបនោះ ក៏នៅតែឲ្យទានបាន គួរត្រេកអរសូម្បីការប្រែចិត្តក៏មិនមានឡើយ អញមិនបានដឹងថាសេចក្តីប្រាថ្នាឈ្មោះនេះហើយឲ្យទាន អញត្រូវសួរ ទើបនឹងជ្រាបអធ្យាស្រ័យរបស់លោក ។ សក្កទេវរាជយាងមកក្នុងពេលយប់ ឈរអំពីខាងមុខព្រះមហាសត្វត្រាស់ថា បពិត្រលោកម្ចាស់ ក្នុងកាលខ្យល់ក្តៅបែបនេះកំពុងបក់ លោកម្ចាស់ក៏នៅតែធ្វើតបកម្មក្នុងព្រៃ ដែលមានទឹកព្រៃព័ទ្ធជុំវិញ បែបនេះដើម្បីប្រយោជន៍អ្វីហ្ន៎ ។

ព្រះសាស្តា កាលប្រកាសសេចក្តីនោះ ទើបត្រាស់គាថាទី ១ ថា

សក្កទេវរាជជាម្ចាស់នៃសត្វ លុះឃើញអកិត្តិបណ្ឌិត កំពុងគង់នៅ

ទើបសួរថា បពិត្រមហាព្រហ្ម លោកប្រាថ្នាចង់បានអ្វី បានជា

មកអង្គុយនៅក្នុងទីក្តៅម្នាក់ឯង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កឹ បត្ថយំ** សេចក្តីថា លោកប្រាថ្នាមនុស្ស-

សម្បត្តិឬ ឬប្រាថ្នាសគ្គសម្បត្តិជាដើមណាមួយ ។

ព្រះមហាសត្វបានស្តាប់ដូច្នោះជ្រាបថា ព្រាហ្មណ៍នោះជាសក្កៈ ដើម្បីប្រកាសថា អាត្មាមិនមែនប្រាថ្នាសម្បត្តិទាំងនោះឡើយ តែប្រាថ្នាសព្វញ្ញុតញ្ញាណ ទើបបំពេញតបៈដូច្នេះ ទើបពោលគាថាទី ២ ថា

បពិត្រសក្កៈ ការកើតក្នុងភពថ្មីទៀត នាំមកនូវសេចក្តីទុក្ខ ការបែកធ្លាយនៃសរីរៈ នាំមកនូវសេចក្តីទុក្ខ ការស្លាប់ព្រោះតែវង្វេង ក៏នាំមកនូវសេចក្តីទុក្ខ បពិត្រវាសវៈ ហេតុនោះ បានជាអាត្មា ( អង្គុយប្រាថ្នាព្រះនិព្វាន ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តស្មា** សេចក្តីថា ព្រះមហាសត្វសម្តែងភាពដែលលោកមានអធ្យាស្រ័យក្នុងព្រះនិព្វានយ៉ាងនេះថា ការបែកធ្លាយខន្ធរឿយៗ និងការស្លាប់ជាទុក្ខ ព្រោះហេតុនោះ ទើបអាត្មាប្រាថ្នាព្រះនិព្វាន ដែលជាធម្មជាតមិនមានរឿងទាំងនេះ ទើបសម្ងំនៅក្នុងទីនេះ ។

សក្កទេវរាជស្តាប់ពាក្យនោះហើយ ទ្រង់មានព្រះហឫទ័យត្រេកអរពោលថា លោកម្ចាស់រូបនេះ កាលនឿយណាយក្នុងភពទាំងពួងហើយ នៅក្នុងព្រៃដើម្បីព្រះនិព្វាន អញត្រូវថ្វាយព្រះពរដល់លោក កាលនឹងអញ្ជើញលោកឲ្យទទួលពរ ទើបពោលគាថាទី ៣ ថា

សុភាសិតដ៏សមគួរនេះ លោកបានពោលល្អហើយ បពិត្រកស្សបៈ លោកមានចិត្តប្រាថ្នាចង់បានពរណា ខ្ញុំប្រគេនពរនោះដល់លោក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យំកិញ្ចិ មនសិច្ឆសិ** សេចក្តីថា ខ្ញុំសូមថ្វាយពរដ៏ប្រសើរដល់លោកម្ចាស់ ទោះលោកម្ចាស់ប្រាថ្នាវត្ថុណា សូមលោកម្ចាស់ទទួលពរចុះ ។

ព្រះមហាសត្វ កាលនឹងទទួលពរ ទើបពោលគាថាទី ៤ ថា

បពិត្រសក្កៈជាធំជាងសត្វទាំងពួង បើព្រះអង្គប្រទានពរដល់អាត្មា
នរជនបានកូន ប្រពន្ធ ទ្រព្យ ស្រូវ និងវត្ថុដទៃជាទីស្រឡាញ់
រមែងមិនឆ្អែតស្កប់ស្កល់ដោយលោភៈណា សូមកុំឲ្យលោភៈនោះ
នៅក្នុងសន្តានរបស់អាត្មាបានឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វរញ្ចេ មេ អទោ** សេចក្តីថា បើមហាបពិត្រទ្រង់ប្រទានពរដល់អាត្មាសោត ។ បទថា **បិយានិ ច** សេចក្តីថា វត្ថុដទៃណាដែលជាទីស្រឡាញ់ ។ បទថា **ន តប្បន្តិ** សេចក្តីថា ជនទាំងឡាយរមែងប្រាថ្នាសម្បត្តិ មានកូនជាដើមរឿយៗ ក៏គង់មិនឆ្អែត ។ បទថា **ន មយីវសេ** សេចក្តីថា សូមលោភៈកុំនៅ គឺកុំកើតក្នុងអាត្មាឡើយ ។

លំដាប់នោះ សក្កទេវរាជទ្រង់ត្រេកអរ កាលនឹងឲ្យពរក្រៃលែងឡើង ហើយព្រះមហាសត្វ កាលទទួលពរ ក៏ពោលគាថាទាំងឡាយតាមលំដាប់ថា

សុភាសិតដ៏សមគួរនេះ លោកបានពោលល្អហើយ បពិត្រ
កស្សបៈ លោកមានចិត្តប្រាថ្នាពរណា ខ្ញុំប្រគេនពរនោះដល់
លោក ។

អកិត្តិតាបសពោលថា

បពិត្រសក្កៈជាធំជាងសត្វទាំងពួង បើព្រះអង្គប្រទានពរដល់អាត្មា ពួកជនរមែងញុំាងស្រែ ចម្ការ ប្រាក់ មាស គោសេះ និងទាស-បុរសឲ្យសាបសូន្យដោយទោសៈណា ដែលកើតហើយ សូមកុំឲ្យទោសៈនោះ នៅក្នុងសន្ដានអាត្មាបានឡើយ ។

សក្កៈពោលថា

សុភាសិតដ៏សមគួរនេះ លោកបានពោលល្អហើយ បពិត្រកស្សបៈ លោកមានចិត្តប្រាថ្នាពរណា ខ្ញុំប្រគេនពរនោះដល់លោក ។

អកិត្តិតាបសពោលថា

បពិត្រសក្កៈជាធំជាងសត្វទាំងពួង បើព្រះអង្គប្រទានពរដល់អាត្មា អាត្មាសូមកុំឲ្យជួបនឹងមនុស្សពាល សូមកុំឲ្យឮដំណឹងមនុស្សពាល សូមកុំឲ្យនៅរួមនឹងមនុស្សពាល សូមកុំឲ្យបានធ្វើ ទាំងកុំឲ្យពេញចិត្តនឹងការចរចាទៅមក នឹងមនុស្សពាល ។

សក្កៈពោលថា

មនុស្សពាលបានធ្វើអ្វីដល់លោក បពិត្រកស្សបៈ សូមលោកប្រាប់ហេតុ បពិត្រកស្សបៈ ហេតុអ្វី បានជាលោកមិនប្រាថ្នាជួបមនុស្សពាល ។

អកិត្តិតាបសពោលថា

បុគ្គលពាល រមែងណែនាំនូវអំពើមិនគួរណែនាំ រមែងប្រកបក្នុង

កិច្ចមិនមែនជាធុរៈ ការណែនាំទៅរកអាក្រក់ ជាការប្រសើរ ( របស់បុគ្គលពាលនោះ ) បុគ្គលពាល បើទុកជាគេនិយាយត្រូវ ក៏នៅតែខឹង បុគ្គលពាល រមែងមិនដឹងច្បាប់អ្វីទេ ការមិនជួបប្រទះនឹងបុគ្គលពាលនោះ ជាការប្រពៃ ។

សក្កៈពោលថា

សុភាសិតដ៏សមគួរនេះ លោកបានពោលល្អហើយ បពិត្រកស្សបៈ លោកមានចិត្តប្រាថ្នាពរណា ខ្ញុំប្រគេនពរនោះដល់លោក ។

អកិត្តិតាបសពោលថា

បពិត្រសក្កៈជាធំជាងសត្វទាំងពួង បើព្រះអង្គនឹងប្រទានពរដល់អាត្មា អាត្មាសូមឲ្យជួបប្រទះអ្នកប្រាជ្ញ សូមឲ្យស្តាប់អ្នកប្រាជ្ញ សូមឲ្យនៅរួមជាមួយនឹងអ្នកប្រាជ្ញ សូមឲ្យបានធ្វើ ទាំងសូមឲ្យបានចូលចិត្តនឹងការចរចាទៅមក ជាមួយនឹងអ្នកប្រាជ្ញនោះ ។

សក្កៈពោលថា

អ្នកប្រាជ្ញបានធ្វើប្រយោជន៍អ្វីដល់លោក បពិត្រកស្សបៈ សូមលោកប្រាប់ហេតុ បពិត្រកស្សបៈ ហេតុអ្វីបានជាលោកចង់ជួបប្រទះអ្នកប្រាជ្ញ ។

អកិត្តិតាបសពោលថា

អ្នកប្រាជ្ញ រមែងណែនាំនូវហេតុ ដែលគួរដឹកនាំ រមែងមិនប្រកប

ក្នុងកិច្ចដែលមិនមែនជាធុរៈ ការដឹកនាំល្អជាការប្រសើរ ( របស់អ្នកប្រាជ្ញនោះ ) អ្នកប្រាជ្ញ បើគេនិយាយត្រូវហើយ រមែងមិនក្រោធ អ្នកប្រាជ្ញនោះ រមែងចេះដឹងច្បាប់ ការសេពគប់ជាមួយនឹងអ្នកប្រាជ្ញនោះ ជាការប្រពៃ ។

សក្កៈពោលថា

សុភាសិតដ៏សមគួរនេះ លោកបានពោលល្អហើយ បពិត្រកស្សបៈ លោកមានចិត្តប្រាថ្នាពរណា ខ្ញុំនឹងប្រគេពរនោះដល់លោក ។

អកិត្តិតាបសពោលថា

បពិត្រសក្កៈជាធំជាងសត្វទាំងពួង បើព្រះអង្គប្រទានពរដល់អាត្មា នាកាលរាត្រីនោះអស់ហើយ ព្រះអាទិត្យក៏រះឡើង សូមឲ្យទិព្វភោជនកើតប្រាកដ ទាំងពួកយាចក អ្នកមានសីល ( ក៏ឲ្យមក ) កាលបើអាត្មាឲ្យ សូមទិព្វភោជន កុំឲ្យអស់ លុះឲ្យហើយ សូមកុំឲ្យក្តៅក្រហាយក្រោយ កាលបើកំពុងឲ្យ គប្បីឲ្យមានចិត្តជ្រះថ្លា បពិត្រសក្កៈ សូមព្រះអង្គប្រទានពរនុ៎ះចុះ ។

សក្កៈពោលថា

សុភាសិតដ៏សមគួរនេះ លោកបានពោលល្អហើយ បពិត្រកស្សបៈ លោកមានចិត្តប្រាថ្នាពរណា ខ្ញុំនឹងប្រគេនពរនោះដល់លោក ។

អកិត្តិតាបសពោលថា

បពិត្រសក្កៈជាធំជាងសត្វទាំងពួង បើព្រះអង្គប្រទានពរដល់អាត្មា ព្រះអង្គកុំចូលមករកអាត្មាទៀតឡើយ បពិត្រសក្កៈ សូមព្រះអង្គ ប្រទានពរនុ៎ះចុះ ។

សក្កៈពោលថា

ពួកជនប្រុសស្រីតែងចង់ឃើញ ( ខ្ញុំ ) ដោយការប្រព្រឹត្តវត្ត ដ៏ច្រើន ចុះភ័យ ( អ្វី ) ក្នុងការឃើញខ្ញុំ ( មានដល់លោក ) ។

អកិត្តិតាបសពោលថា

អាត្មាឃើញព្រះអង្គមានភេទជាទេវតា ប្រាកដដូច្នោះ មានសេចក្តីប្រាថ្នាទាំងពួងសម្រេចហើយ គប្បីប្រហែសក្នុងតបធម៌ ភ័យក្នុងកាលឃើញព្រះអង្គនុ៎ះ មានដល់ ( អាត្មា ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យេន ជាតេន** សេចក្តីថា ព្រះមហាសត្វសូមថា ពួកសត្វមានចិត្តណាកើតហើយទើបក្រោធ ត្រូវវិនាសចាកស្រែចម្ការជាដើមនេះ ដោយអំណាចរាជទណ្ឌ ព្រោះខ្លួនធ្វើកម្ម មានសម្លាប់សត្វជាដើម ឬដោយការសម្លាប់ខ្លួន ដោយវិធីផ្សេងៗ មានបរិភោគថ្នាំពិសជាដើម ទោសចិត្តនោះ សូមកុំនៅក្នុងអាត្មាឡើយ ។ បទថា **ន សុណេ** សេចក្តីថា អាត្មាមិនគប្បីបានឮដោយហេតុទាំងនេះថា បុគ្គលពាល នៅក្នុងទីឈ្មោះនោះជាដើមឡើយ ។ បទថា **កិន្នុ តេ អករំ** សេចក្តីថា បុគ្គលពាល រមែងសម្លាប់មាតាបិតារបស់លោកម្ចាស់ឬ ឬបុគ្គលពាលធ្វើនូវសេចក្តីវិនាសណា

មួយ ឲ្យដល់លោក ។ បទថា **អនយំ នយតិ** សេចក្តីថា បុគ្គលមានបញ្ញាថោកថយ រមែងកាន់យកវត្ថុដែលមិនមែនហេតុ ថាជាហេតុ គឺរមែងគិតដល់កម្មដែលទារុណបែបនេះថា អញនឹងធ្វើបាណាតិបាតជាដើមចិញ្ចឹមជីវិត ។ បទថា **អធុរាយំ** សេចក្តីថា បុគ្គលមានបញ្ញាថោកថយ មិនដឹកនាំក្នុងសទ្ធាធុរៈ សីលធុរៈ និងបញ្ញាធុរៈ ដឹកនាំក្នុងវត្ថុដែលមិនគួរប្រកប ។ បទថា **ទុន្នយោ សេយ្យសោ ហោតិ** សេចក្តីថា ការដឹកនាំអាក្រក់នោះឯង ជាការល្អសម្រាប់បុគ្គលមានបញ្ញាថោកថយ គឺបុគ្គលរមែងកាន់យកទុស្សីល្យកម្ម ៥ ប្រការ ហើយប្រព្រឹត្តនោះឯងជាការល្អ ម្យ៉ាងទៀត បុគ្គលនោះ ជាបុគ្គលដែលទូន្មានបានដោយក្រក្នុងផ្លូវប្រតិបត្តិដែលជាប្រយោជន៍ ព្រោះបុគ្គលណាម្នាក់ មិនអាចនឹងទូន្មានបាន ។ បទថា **សម្មា វុត្តោ** សេចក្តីថា បុគ្គលនោះ ត្រូវពោលដោយហេតុ ដោយការណ៍ រមែងក្រោធអាក់អន់ ។ បទថា **វិនយំ** សេចក្តីថា បុគ្គលនោះមិនស្គាល់វិន័យ ដែលត្រូវប្រព្រឹត្តដោយអើពើ ដូចជាត្រូវឈានទៅមុខយ៉ាងនេះជាដើម ទាំងមិនទទួលឱវាទនោះ ។ បទថា **សាធុ តស្ស** សេចក្តីថា ព្រោះហេតុទាំងនេះ ការមិនជួប មិនឃើញបុគ្គលពាល នោះឯងជាការល្អ ។ បទថា **សុរិយស្សុគ្គមនំ បតិ** សេចក្តីថា តាំងអំពីពេលព្រះអាទិត្យរះឡើង ។ បទថា **ធិញា ភិក្ខា** បានដល់ ទិព្វភោជន ។ បទថា **យាចកា** បានដល់ បុគ្គលទទួលភោជនដែលជាទិព្វនោះ ។ បទថា **វត្ត-ចរិយា** បានដល់ ដោយទាន សីល និងឧបោសថកម្ម ។ បទថា **ឧស្សន្នំ អភិកន្ទន្តិ** សេចក្តីថា ពួកនរៈ និងនារីនាំគ្នាប្រាថ្នានឹងឃើញខ្ញុំ ។ បទថា **តំ**

**តានិសំ** សេចក្ដីថា ឃើញលោកដែលប្រដាប់ដោយគ្រឿងប្រដាប់បែបនោះ ។ បទថា **បមជ្ជេយ្យុំ** សេចក្ដីថា អាត្មាដល់នូវការប្រមាទ គឺគប្បីប្រាថ្នាសិរីសម្បត្តិរបស់លោក ក្នុងកាលតបកម្មអាត្មាកាពបំពេញដើម្បីព្រះនិព្វានយ៉ាងនេះ អាត្មាមកប្រាថ្នាតំណែងសក្កៈដូចម្ដេចកើត អាត្មានឹងបានឈ្មោះថាជាអ្នកប្រមាទ ការឃើញទ្រង់ ជាភ័យដល់អាត្មាយ៉ាងនេះ ។

សក្កទេវរាជទទួលថា សាធុ តាំងអំពីនេះទៅ ខ្ញុំលែងមកកាន់សម្នាក់លោកម្ចាស់ហើយ ថ្វាយបង្គំសូមខមាទោស ហើយក៏ចៀសចេញទៅ ព្រះមហាសត្វនៅក្នុងទីនោះឯង ដរាបដល់អស់ជីវិត ចម្រើនព្រហ្មវិហារធម៌ កើតក្នុងព្រហ្មលោកហើយ ។

ព្រះសាស្ដា កាលទ្រង់នាំយកព្រះធម្មទេសនានេះ មកសម្ដែងហើយ ទ្រង់ប្រជុំជាតកថា សក្កទេវរាជក្នុងកាលនោះ បានមកជាអនុរុទ្ធ ក្នុងកាលឥឡូវនេះ ចំណែកអកិត្តិបណ្ឌិតក្នុងកាលនោះ គឺតថាគតនេះឯង ៕៚

## អដ្ឋកថា អកិត្តិជាតក ចប់

# សុត្តន្តបិដក

## តក្ការិយជាតក

[ ១១២៤ ] ( ព្រាហ្មណបុរោហិតនិយាយថា ) ខ្ញុំឯងជាមនុស្សល្ងង់ និយាយសម្តីទាស់ ដូចជាកង្កែបហៅពស់ក្នុងព្រៃ ម្នាលតក្ការិយៈ ខ្ញុំធ្លាក់ក្នុងរណ្តៅនេះ ព្រោះពួថា បុគ្គលនិយាយហួសប្រមាណ មិនប្រពៃឡើយ ។

[ ១១២៥ ] ( តក្ការិយពោធិសត្វតបថា ) បុគ្គលអ្នកនិយាយហួសប្រមាណ តែងដល់នូវការចង ការសម្លាប់ សោក និងខ្សឹកខ្សួល លោកតិះដៀលខ្លួនលោក ព្រោះតែហេតុនោះ បពិត្រលោកអាចារ្យ ពួកជនកប់លោកក្នុងរណ្តៅឥឡូវនេះ ។

[ ១១២៦ ] ( មហាសត្វតំណាលពីសេដ្ឋីបុត្រនិយាយថា ) ថ្វីបានជាអញសួរ អញយកអាសាតុណ្ឌិលៈជាបងនាងកាលី បានជាអញត្រូវគេដណ្តើមយកសំពត់ទាំងគូ ហើយជាមនុស្សអាក្រាត ដំណើរនេះឯង ប្រហែលគ្នានឹងលោកច្រើនប្រការ ។

[ ១១២៧ ] ( តំណាលរឿងកុកសថា ) កាលពពែទាំងពីរកំពុងតែជល់គ្នា កុកសណាចូលទៅត្រង់ចន្លោះពពែ កុកសនោះត្រូវក្បាលពពែទាំងពីរ ទង្គិចខ្ទេចក្នុងទីនោះ ដំណើរនេះប្រហែលគ្នានឹងលោក ច្រើនយ៉ាង ។

[ ១១២៨ ] ( តំណាលរឿងជន ៤ នាក់ថា ) ជន ៤ នាក់កាន់ជាយក្រមា ចាំត្រង់បុរសម្នាក់ ( ដែលលោតពីចុងត្នោត ) ជន

ទាំង ៤ នាក់នោះ បែកក្បាលដួលស្លាប់ ដំណើរនេះប្រហែលគ្នានឹងលោក ច្រើនយ៉ាង ។

[ ១១២៩ ] ( តំណាលរឿងពពែថា ) ដូចជាមេពពែដែលចោរចងទុកក្បែរគុម្ពឫស្សី ទធាក់ជើងក្រោយលេង បានជាន់កាំបិត ហេតុនោះ បានជាចោរអារបំពង់កមេពពែនោះ ដំណើរនេះឯងប្រហែលគ្នានឹងលោក ច្រើនយ៉ាង ។

[ ១១៣០ ] ( តំណាលរឿងព្រះរាជាពារាណសី ត្រាស់ថា ) កិន្នរទាំងពីរនេះ មិនមែនជាទេវតា មិនមែនជាគន្ធព្វបុត្រទេ កិន្នរទាំងនេះជាម្រឹគទេ កិន្នរទាំងនេះ ព្រានព្រៃបាននាំមកដោយអំណាចប្រយោជន៍ ពួកអ្នកធ្វើក្រយាស្ងោយ ចូរចម្អិនកិន្នរមួយនោះក្នុងពេលបាយល្ងាច ចូរចម្អិនកិន្នរមួយទៀត ក្នុងពេលបាយព្រឹក ។

[ ១១៣១ ] ( រឿងកិន្នរីទូលព្រះរាជាថា ) ពាក្យជាទុព្ភាសិតមួយសែនមាត់ ក៏មិនដល់មួយចំណិតនៃពាក្យជាសុភាសិតឡើយ បុគ្គលកាលវង្វៀសនឹងពាក្យជាទុព្ភាសិត រមែងលំបាក ព្រោះហេតុនោះ កិន្នរនៅស្ងៀម មិនមែនព្រោះល្ងង់ទេ ។

[ ១១៣២ ] ( ព្រះរាជាត្រាស់ថា ) កិន្នរីណាបានដោះសានឹងអញ អ្នកទាំងឡាយ ចូរលែងកិន្នរីនុ៎ះចុះ ចូរនាំកិន្នរនោះទៅភ្នំហិមពាន្ត អ្នកទាំងឡាយ ចូរប្រគល់កិន្នរនេះ ដើម្បីរោងគ្រួ ចូរចម្អិនវាក្នុងពេលបាយព្រឹកអំពីព្រលឹម ។

[ ១១៣៣ ] ( កិន្នរក្រាបទូលថា ) ពួកសត្វចិញ្ចឹម មានមេឃជាទីពឹង ពួកមនុស្សមានសត្វចិញ្ចឹមជាទីពឹង បពិត្រមហារាជ ខ្ញុំមានព្រះអង្គជាទីពឹង ឯភរិយារបស់ខ្ញុំ មានខ្លួនខ្ញុំជាទីពឹង ក្នុងវាងយើងខ្ញុំទាំងពីរនាក់ សូមឲ្យអ្នកដែលរួច ( អំពីសេចក្តីស្លាប់ ) ដឹងថា អ្នកណាមួយ ( ស្លាប់ ) ហើយសឹមទៅក្តី ។

[ ១១៣៤ ] បុគ្គលមិនងាយចៀសនិន្ទាទេ បពិត្រព្រះជនិន្ទ ព្រះអង្គគប្បីសេពគប់ រាប់រកនូវពួកជន អ្នកមានសេចក្តីប្រាថ្នាផ្សេងៗ គ្នា ( លមើល ) បុគ្គលពួកមួយបាននូវសេចក្តីសរសើរដោយគុណ មានសីលគុណជាដើមណា បុគ្គលឯទៀត បាននូវពាក្យនិន្ទាដោយគុណ មានសីលគុណជាដើមនោះទៅវិញ ។

[ ១១៣៥ ] សត្វលោកទាំងអស់ មានចិត្តក្បៀវក្លា ដោយចិត្តផ្សេងគ្នា សត្វលោកទាំងអស់ មានចិត្តប្រព្រឹត្តទៅក្នុងចិត្តរបស់ខ្លួន ពួកសត្វទាំងអស់ មានចិត្តផ្សេងៗ គ្នា មានប្រភេទដ៏ច្រើនឯក្នុងលោកនេះ បុគ្គលមិនលុះអំណាចចិត្តរបស់បុគ្គលណាបានឡើយ ។

[ ១១៣៦ ] ( ព្រះរាជា ... ) កិន្នរណា ព្រមទាំងភរិយានៅស្ងៀមឥឡូវនេះ ភ័យហើយ បានដោះសា កិន្នរនោះ ចូររួចអំពីភ័យដល់នូវសេចក្តីសុខ មិនមានរោគក្នុងកាលឥឡូវនេះចុះ វាចារបស់ជន ទាំងឡាយ ជាវាចាមានប្រយោជន៍ ។

**តក្ការិយជាតកទី ៨ ចប់**

# អដ្ឋកថា

## តក្ការិយជាតក

[ ១១២៤-១១៣៦ ] ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុឈ្មោះកោកាលិកៈ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **អហមេវ ទុព្ភាសិតំ ភាសិ ពាលោ** ដូច្នេះជាដើម ។

សេចក្ដីពិស្ដារថា ខាងក្នុងវស្សាមួយ អគ្គសាវកទាំងពីរ បំណងនឹងលះបង់ពួកគណៈនៅស្ងប់ស្ងាត់ ទូលលាព្រះសាស្ដាទៅដល់លំនៅរបស់កោកាលិកភិក្ខុ ក្នុងកោកាលិករដ្ឋ ពោលជាមួយលោកយ៉ាងនេះថា អាវុសោ កោកាលិកៈ ខ្ញុំ និងលោកអាស្រ័យគ្នាទៅវិញទៅមក នឹងនៅជាសុខ ខ្ញុំសូមនៅចាំវស្សាក្នុងទីនេះឯង អស់ ៣ ខែនេះ ។ កោកាលិកភិក្ខុតបថា អាវុសោ លោកម្ចាស់អាស្រ័យខ្ញុំហើយ នឹងនៅជាសុខបានដូចម្ដេច ។ អគ្គសាវកឆ្លើយថា អាវុសោ អ្នកកុំប្រាប់ដល់អ្នកណាថា អគ្គសាវកនៅចាំវស្សាក្នុងទីនេះ ខ្ញុំគប្បីនៅសប្បាយ នេះ ឈ្មោះថា ខ្ញុំអាស្រ័យលោកនៅជាសុខ កោកាលិកៈសួរថា កាលបើដូច្នេះ ខ្ញុំអាស្រ័យលោក គប្បីនៅជាសុខដូចម្ដេច ព្រះថេរៈពោលថា ខ្ញុំនឹងប្រាប់ នឹងពោលនូវធម្មកថាដល់លោកអស់ត្រៃមាស នេះលោកអាស្រ័យខ្ញុំនៅជាសុខ កោកាលិកភិក្ខុពោលថា អាវុសោ សូមលោកនៅតាមអធ្យាស្រ័យចុះ ហើយបានប្រគេនសេនាសនៈដែលសមគួរដល់លោកទាំងពីរ ។ អគ្គសាវកទាំងពីរ នាំគ្នានៅសប្បាយដោយសេចក្ដីសុខក្នុងផលសមាបត្តិ ។ បុគ្គលណាម្នាក់មិនដឹងថា លោកមកគង់នៅក្នុងទីនេះ ។ លោកទាំងពីរចាំវស្សាហើយ បវារណាស្រេច ក៏នាំគ្នាប្រាប់កោកាលិកភិក្ខុនោះថា

អាវុសោ ខ្ញុំអាស្រ័យលោកនៅសប្បាយហើយ នឹងនាំគ្នាទៅថ្វាយបង្គំព្រះសាស្តា លោកទទួលថា សាធុ ហើយនាំអគ្គសាវកទាំងពីរត្រាច់បិណ្ឌបាតក្នុងស្រុកក្បែរៗ ។ ព្រះថេរៈទាំងឡាយធ្វើភត្តកិច្ចស្រេចហើយ ក៏នាំគ្នាចេញអំពីស្រុក ។

កោកាលិកភិក្ខុ បញ្ជូនព្រះថេរៈទាំងនោះ ហើយត្រឡប់ទៅប្រាប់មនុស្សទាំងឡាយថា ឧបាសកឧបាសិកាទាំងឡាយ ពួកអ្នកដូចសត្វតិរច្ឆាន ប្រហែលមិនស្គាល់សោះទេថា អគ្គសាវកទាំងគូនៅក្នុងវិហារអស់ ៣ ខែ ឥឡូវនេះលោកក៏ត្រឡប់ទៅហើយ ។ មនុស្សទាំងឡាយក៏នាំគ្នាពោលថា ហេតុអ្វី ក៏លោកម្ចាស់មិនប្រាប់ដល់ពួកខ្ញុំឲ្យដឹង ហើយនាំគ្នាកាន់យកភេសជ្ជៈ មានសប្បិនិងប្រេងជាដើម និងគ្រឿងស្លៀកដណ្តប់ គឺសំពត់ជាច្រើន ចូលទៅរកព្រះថេរៈ ថ្វាយបង្គំហើយ ពិតថា បពិត្រលោកម្ចាស់ សូមអភ័យទោសដល់ពួកខ្ញុំចុះ ខ្ញុំមិនដឹងថា លោកម្ចាស់ជាអគ្គសាវក ថ្ងៃនេះ ពួកខ្ញុំដឹងដោយការប្រាប់របស់លោកម្ចាស់ឈ្មោះកោកាលិកៈ សូមលោកម្ចាស់ទទួលយកភេសជ្ជៈ និងគ្រឿងស្លៀកដណ្តប់ គឺសំពត់ទាំងនេះ ដើម្បីអនុគ្រោះដល់ពួកខ្ញុំផងចុះ ។

កោកាលិកភិក្ខុត្រិះរិះថា ព្រះថេរៈទាំងពីរជាអ្នកប្រាថ្នាតិច ជាអ្នកសន្តោស គង់មិនទទួលសំពត់ទាំងនេះដោយខ្លួន គង់ឲ្យដល់អញ ទើបទៅកាន់សម្នាក់របស់ព្រះថេរៈទាំងឡាយ ជាមួយពួកឧបាសកនោះឯង ។ ព្រះថេរៈទាំងពីរមិនបានទទួលរបស់អ្វីដើម្បីខ្លួន ទាំងមិនឲ្យគេប្រគេនដល់កោកា-លិកភិក្ខុព្រោះលោកប្រាថ្នាអប់រំភិក្ខុ ។ ពួកឧបាសកនាំគ្នាអង្វរថា បពិត្រលោក

ម្ចាស់ បើលោកម្ចាស់មិនទទួលពេលនេះ ក៏សូមនិមន្តមកទីនេះទៀត ដើម្បីអនុគ្រោះពួកខ្ញុំ ។ ព្រះថេរៈទទួលពាក្យហើយ នាំគ្នាទៅកាន់សម្នាក់របស់ព្រះសាស្ដា ។ កោកាលិកភិក្ខុចងអាឃាតថា ព្រះថេរៈទាំងនេះ បើខ្លួនមិនទទួល ក៏មិនប្រាប់ឲ្យគេឲ្យដល់អញ ចំណែកព្រះថេរៈទាំងពីរ ស្នាក់នៅក្នុងសម្នាក់របស់ព្រះសាស្ដាបន្តិច ក៏នាំភិក្ខុ ៥០០ រូបដែលជាបរិវាររៀងៗ ខ្លួន ត្រាច់ចារិកទៅជាមួយភិក្ខុមួយពាន់រូប រហូតដល់កោកាលិករដ្ឋ ។ ពួកឧបាសកទាំងនោះ ក៏នាំគ្នាទទួលនាំព្រះថេរៈទៅកាន់វិហារនោះឯង ធ្វើសក្ការៈធំៗ រាល់ថ្ងៃ ។ ភេសជ្ជៈ និងគ្រឿងស្លៀកដណ្ដប់ គឺសំពត់កើតឡើងសន្ធឹកសន្ធាប់ ។ ពួកភិក្ខុដែលមកជាមួយព្រះថេរៈ នាំគ្នាជ្រើសរើសចីវរឲ្យដល់ពួកភិក្ខុ ដែលមកជាមួយគ្នាប៉ុណ្ណោះ មិនបានឲ្យដល់កោកាលិកភិក្ខុ ។ សូម្បីព្រះថេរៈក៏មិនប្រាប់ឲ្យគេឲ្យដល់លោក ។ កោកាលិកភិក្ខុមិនបានចីវរ ក៏ជេរព្រះថេរៈថា សារីបុត្ត និងមោគ្គល្លានប្រាថ្នាលាមក កាលមុនគេឲ្យលោកមិនទទួល ឥឡូវនេះ ទទួលរហូតពោរពាស មិនសម្លឹងមើលអ្នកដទៃឡើយ ។ ព្រះថេរៈទាំងឡាយត្រិះរិះថា កោកាលិកៈជួបនូវអកុសល ព្រោះអាស្រ័យពួកយើង មួយអន្ទើដោយបរិវារ ក៏នាំគ្នាចេញទៅ សូម្បីត្រូវពួកមហាជននាំគ្នាអារាធនាថា សូមលោកម្ចាស់នៅក្នុងទីនេះ ២-៣ ថ្ងៃចុះ ក៏មិនប្រាថ្នានឹងត្រឡប់ ។

លំដាប់នោះ ភិក្ខុកំលោះមួយរូបពោលថា ឧបាសកទាំងឡាយ ព្រះថេរៈទាំងឡាយនឹងនៅបានដូចម្ដេច ព្រះថេរៈដែលជិតស្និទ្ធរបស់ពួកអ្នកអត់ធន់ក្នុងការនៅរបស់ភិក្ខុទាំងនេះមិនបាន ។ ឧបាសកទាំងនោះ នាំគ្នាទៅកាន់

សម្នាក់របស់កោកាលិកភិក្ខុនោះ ពោលថា បពិត្រលោកម្ចាស់ បានឮថា លោកម្ចាស់អត់ធន់ក្នុងការនៅក្នុងសម្នាក់របស់ព្រះថេរៈមិនបាន និមន្តទៅចុះ សូមឲ្យព្រះថេរៈទាំងពីរ សូមខមាទោសហើយនិមន្តត្រឡប់មក បើមិនដូច្នោះទេ លោកម្ចាស់គេចទៅទីដទៃចុះ ។ កោកាលិកភិក្ខុ ចាំបាច់ត្រូវអង្វរព្រះថេរៈទាំងឡាយ ព្រោះខ្លាចពួកឧបាសក ។ ព្រះថេរៈទាំងឡាយក៏ពោលថា អាវុសោ ចូរអ្នកទៅចុះ ពួកយើងនឹងមិនត្រឡប់ឡើយ ។ លោកមិនអាចនិមន្តព្រះថេរៈឲ្យត្រឡប់បាន ក៏ត្រឡប់ទៅកាន់វិហារនោះឯង ។ លំដាប់នោះ ពួកឧបាសកនាំគ្នាសួរថា បពិត្រលោកម្ចាស់ៗ និមន្តព្រះថេរៈត្រឡប់មកឬ ក៏ពោលថា នែអ្នកទាំងឡាយ អាត្មាមិនអាចនិមន្តឲ្យលោកត្រឡប់បានឡើយ ។ លំដាប់នោះ ពួកឧបាសកគិតថា បើភិក្ខុមានបាបកម្មនេះ នៅក្នុងវិហារនេះ ពួកភិក្ខុដែលមានសីលជាទីស្រឡាញ់ នឹងមិនរស់នៅក្នុងទីនេះ ពួកយើងត្រូវបណ្តេញលោកចេញ ហើយនាំគ្នាពោលនឹងព្រះថេរៈថា បពិត្រលោកម្ចាស់ៗ កុំនៅទីនេះឡើយ លោកម្ចាស់អាស្រ័យពួកខ្ញុំមិនបានឡើយ កោកាលិកភិក្ខុ ត្រូវជនទាំងនោះបណ្តេញចេញហើយ ក៏កាន់បាត្រ និងចីវរទៅកាន់វត្តជេតពន គាល់ព្រះសាស្តា ក្រាបទូលថា បពិត្រព្រះអង្គ ព្រះសារីបុត្ត និងព្រះមោគ្គល្លាន មានការប្រាថ្នាលាមក លុះក្នុងអំណាចនៃសេចក្តីប្រាថ្នាលាមក ។ លំដាប់នោះ ព្រះមានព្រះភាគត្រាស់សួរថា ម្នាលកោកាលិកៈ អ្នកកុំពោលយ៉ាងនេះឡើយ ចូរធ្វើចិត្តឲ្យជ្រះថ្លាក្នុងសារីបុត្ត និងមោគ្គល្លានចុះ ចូរអ្នកចាំទុកថា ភិក្ខុទាំងនោះ ជាអ្នកមានសីល ។ កោកាលិកភិក្ខុក្រាបទូលថា បពិត្រព្រះអង្គ ទ្រង់

ជឿតែអគ្គសាវ័ករបស់ទ្រង់ ខ្ញុំព្រះអង្គបានឃើញច្បាស់ហើយថា ជនទាំងនេះជាមនុស្សអាក្រក់ មានកម្មបិទបាំង ទ្រុស្តសីលនោះឯង សូម្បីព្រះសាស្ដាត្រាស់ហាមអស់វារៈ ៣ ដង ក៏នៅតែពោលយ៉ាងនេះ ហើយក្រោកចាកអាសនៈចៀសចេញទៅ ។

គ្រាន់តែលោកត្រឡប់ទៅប៉ុណ្ណោះ រាងកាយទាំងមូលក៏កើតជាបូសប៉ុនៗ គ្រាប់ស្ពៃ ហើយធំឡើងជាលំដាប់ រហូតដល់ប៉ុនផ្លែព្នៅទុំ ហើយបែកខ្ទុះ និងឈាម ហូរជោករាងកាយ ។ លោកត្រូវអត់ធន់នឹងការឈឺចាប់ ហើយដេកត្រង់ខ្លោងទ្វារវត្តជេតពន ។ មានរឿងដែលចោទសួរគ្នាជាសំឡេងតែមួយរហូតដល់ព្រហ្មលោកថា អគ្គសាវ័កទាំងពីរត្រូវកោកាលិកភិក្ខុជេរ ។

លំដាប់នោះ តុទិព្រហ្មដែលជាឧបជ្ឈាយ៍របស់លោក ដឹងរឿងនោះក៏ត្រិះរិះថា អញនឹងឲ្យលោកសូមខមាទោសព្រះថេរៈទាំងឡាយ ឈរក្នុងអាកាសពោលថា កោកាលិកៈ លោកម្ចាស់ធ្វើកម្មគ្រោតគ្រាតណាស់ សូមលោកម្ចាស់ឲ្យអគ្គសាវ័កជ្រះថ្លាចុះ ។ កោកាលិកភិក្ខុសួរថា អាវុសោ លោកជានរណា តុទិព្រហ្មពោលថា ខ្ញុំឈ្មោះតុទិព្រហ្ម កោកាលិកភិក្ខុ ត្រឡប់ជាមើលងាយមហាព្រហ្មថា អាវុសោ លោកជាបុគ្គលដែលព្រះមានព្រះភាគទ្រង់ព្យាករហើយថា ជាព្រះអនាគាមីមិនមែនឬ ព្រះដ៏មានព្រះភាគត្រាស់ហើយថា ធម្មតាព្រះអនាគាមីមិនត្រឡប់មកអំពីលោកនោះជាសភាវៈ លោកប្រហែលជាយក្ខត្រង់គំនរសំរាមពិត មហាព្រហ្ម កាលមិនអាចឲ្យលោកកាន់យកពាក្យបាន ក៏ពោលថា លោកនោះឯង នឹងប្រាកដតាមពាក្យរបស់លោក

ហើយក៏ទៅកាន់ព្រហ្មលោកជាន់សុទ្ធាវាសមួយរំពេច ចំណែកកោកាលិកភិក្ខុ ក៏ស្លាប់ទៅកើតក្នុងបទុមនរក ។ សហម្បតីព្រហ្ម ដឹងភាពដែលកោកាលិក-ភិក្ខុ ទៅកើតក្នុងទីនោះហើយ ទើបក្រាបទូលដល់ព្រះតថាគត ។ ព្រះសាស្ដា ត្រាស់រឿងនោះដល់ពួកភិក្ខុ ។ ពួកភិក្ខុកាលពោលដល់ទោសរបស់លោក នាំគ្នាសន្ទនាក្នុងធម្មសភាថា អាវុសោទាំងឡាយ បានឮថា កោកាលិកភិក្ខុជេរព្រះសារីបុត្ត និងព្រះមហាមោគ្គល្លាន កើតក្នុងបទុមនរក ព្រោះអាស្រ័យមាត់របស់ខ្លួន ។ ព្រះសាស្ដាយាងមកហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អំបាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយ ក្រាបទូលថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលកោកាលិកៈត្រូវពាក្យសម្ដីបំផ្លាញហើយ សោយទុក្ខព្រោះមាត់របស់ខ្លួន សូម្បីក្នុងកាលមុន ក៏សោយទុក្ខព្រោះមាត់របស់ខ្លួនដូចគ្នា ដូច្នេះហើយ ទើបទ្រង់នាំអតីតនិទានមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី បុរោហិតរបស់ព្រះរាជា ជាមនុស្សភ្នែកក្រហម មានចង្កូមដុះចេញមកក្រៅ ។ ព្រាហ្មណីរបស់បុរោហិត បានសហាយស្មន់ជាមួយព្រាហ្មណ៍ដទៃ ។ ព្រាហ្មណ៍សហាយនោះ ក៏មានលក្ខណៈបែបនោះដូចគ្នា ។ បុរោហិតបានហាមប្រាមព្រាហ្មណីរឿយៗ តែមិនអាចហាមបាន ក៏គិតថា អញមិនអាចសម្លាប់សត្រូវនេះដោយដៃរបស់ខ្លួនបាន ត្រូវរកឧបាយសម្លាប់វាឲ្យបាន ។ គាត់ក៏ចូលគាល់

ព្រះរាជាក្រាបទូលថា បពិត្រមហារាជ នគររបស់ទ្រង់ ជានគរដែលប្រសើរ ក្រៃលែងក្នុងជម្ពូទ្វីប ទ្រង់សោតក៏ជាអគ្គរាជា ទ្វារនគរទិសទក្សិណរបស់ទ្រង់ ឈ្មោះថា អគ្គរាជ ដូច្នេះ សាងទុកអាក្រក់ មិនជាមង្គលឡើយ ។ ព្រះរាជា ត្រាស់ថា នែអាចារ្យ ឥឡូវនេះ គួរធ្វើដូចម្តេច បុរោហិតក៏ក្រាបទូលថា គួរ ប្រកបមង្គល ព្រះរាជាត្រាស់ថា គួរបានអ្វី បុរោហិតក្រាបទូលថា គួររើទ្វារ ចាស់ រកឈើដែលប្រកបដោយមង្គល ធ្វើពលីដល់ពួកកូត ដែលរក្សា ព្រះនគរ ហើយតាំង ( ឈ្មោះ ) ទ្វារថ្មីតាមមង្គលឫក្ស ព្រះរាជាត្រាស់ថា បើដូច្នោះ សូមលោកធ្វើយ៉ាងនោះចុះ ។

លំដាប់នោះ ព្រះពោធិសត្វសោយព្រះជាតិជាមាណព ឈ្មោះតក្ការិយៈ រៀនសិប្បៈក្នុងសម្នាក់របស់បុរោហិតនោះ បុរោហិតឲ្យរើទ្វារចាស់ធ្វើជាថ្មី ហើយក្រាបទូលព្រះរាជាថា បពិត្រព្រះសម្មតិទេព ទ្វារសម្រេចហើយ ស្អែក នេះ ជាថ្ងៃឫក្សល្អ ត្រូវធ្វើពលីកម្ម លើកនូវទ្វារ កុំឲ្យរំលងនូវឫក្សនោះ ព្រះរាជាត្រាស់ថា បើដូច្នោះ លោកគួរបានអ្វីដើម្បីប្រកបពលីកម្ម បុរោហិត ទូលថា បពិត្រព្រះសម្មតិទេព ទ្វារមានសក្តិធំ ត្រូវអញ្ជើញទេវតា ដែលមាន សក្តិឲ្យចូលគ្រប់គ្រង ចាំបាច់សម្លាប់ព្រាហ្មណ៍ដែលបរិសុទ្ធទាំងពីរចំណែក ម្នាក់ដែលមានភ្នែកក្រហម មានចង្កូមដុះចេញមកក្រៅ យកសាច់ និងឈាម ធ្វើពលីកម្ម ហើយយកទៅកប់ខាងក្រោមទ្វារ តម្កល់ទ្វារលើនោះ យ៉ាងនេះ នឹងកើតសួស្តីដល់ទ្រង់ និងដល់ព្រះនគរ ។ ព្រះរាជាត្រាស់ថា សាធុ លោក អាចារ្យ សូមលោកសម្លាប់ព្រាហ្មណ៍បែបនោះហើយ លើកទ្វារព្រះនគរចុះ ។

បុរោហិតនោះសប្បាយចិត្ត ក្អេងក្អាងថា ថ្ងៃស្អែកនេះ អញនឹងបានឃើញខ្នង បច្ចាមិត្ត កាលទៅដល់ផ្ទះរបស់ខ្លួន ក៏មិនអាចរក្សាមាត់របស់ខ្លួន បានធ្លោយមាត់ប្រាប់ប្រពន្ធថា មនុស្សអាក្រក់ មនុស្សចណ្ឌាល តាំងអំពីនេះទៅ ហាងនឹងត្រេកអរជាមួយអ្នកណា ស្អែកនេះ អញនឹងសម្លាប់សហាយរបស់ហាង ធ្វើពលីកម្ម ។ ករិយាប្រកែកថា គេមិនខុសទេឡើយ តើសម្លាប់ព្រោះហេតុអ្វី បុរោហិតឆ្លើយថា ព្រះរាជាទ្រង់ត្រាស់ឲ្យអញធ្វើពលីកម្មដោយសាច់ និងឈាមរបស់ព្រាហ្មណ៍ដែលមានចង្កូម និងភ្នែកក្រហម ដើម្បីលើកទ្វារនគរឡើង ឯសហាយរបស់ហាងមានចង្កូម និងភ្នែកក្រហម អញនឹងសម្លាប់វាធ្វើពលីកម្ម ។

នាងបញ្ជូនដំណឹងទៅដល់សម្នាក់របស់សហាយនោះថា បានឮថា ព្រះរាជាទ្រង់បំណងនឹងសម្លាប់ពួកព្រាហ្មណ៍ ដែលមានចង្កូម និងភ្នែកក្រហមធ្វើពលីកម្ម បើអ្នកចង់បានជីវិត ក៏ចូរនាំពួកព្រាហ្មណ៍ដែលមានលក្ខណៈដូចគ្នានឹងអ្នក គេចទៅឲ្យទាន់ពេលវេលាចុះ ។ បុរសនោះបានធ្វើតាមនោះ ដំណឹងនោះបានល្បីពេញព្រះនគរ ។ ពួកព្រាហ្មណ៍ដែលមានចង្កូម និងភ្នែកក្រហមគ្រប់គ្នា នាំគ្នាចៀសចេញអំពីព្រះនគរគ្រប់កន្លែង ។ បុរោហិតមិនបានដឹងថាសត្រូវគេចទៅឡើយ គាត់ចូលគាល់ព្រះរាជាអំពីព្រលឹមក្រាបទូលថា បពិត្រព្រះសម្មតិទេព ទីនោះមានពួកព្រាហ្មណ៍ដែលមានចង្កូម និងភ្នែកក្រហម សូមត្រាស់ឲ្យចាប់គេចុះ ។ ព្រះរាជាបញ្ជូនអមាត្យទៅ អមាត្យទាំងនោះមិនឃើញក៏នាំគ្នាមកក្រាបទូលថា បានឮថា ជនទាំងនោះគេចទៅអស់ហើយ ។ ព្រះរាជាទ្រង់ត្រាស់ថា ចូររកមើលក្នុងទីដទៃចុះ ។ លុះនាំគ្នាដើររកគ្រប់កន្លែង ក៏មិន

ជួប កាលព្រះរាជាត្រាស់ថា ចូររកអ្នកដទៃក្រៅអំពីនេះចុះ ក៏នាំគ្នាក្រាបទូលថា បពិត្រព្រះសម្មតិទេព វៀរបុរោហិតនេះចេញហើយ អ្នកដទៃដែលមានរូបយ៉ាងនោះមិនមាន ព្រះរាជាត្រាស់ថា យើងមិនអាចសម្លាប់បុរោហិតបាន ជនទាំងនោះនាំគ្នាក្រាបទូលថា បពិត្រព្រះសម្មតិទេព ទ្រង់បំណាងអ្វីដូច្នោះ ព្រោះថា បុរោហិតនោះជាអ្នកផ្ដើមគំនិត បើមិនលើកទ្វារក្នុងថ្ងៃនេះ ព្រះនគរនឹងមិនបានទទួលការរក្សា សូម្បីលោកអាចារ្យក៏ប្រាប់ថា ផុតអំពីថ្ងៃនេះទៅហើយត្រូវរង់ចាំមួយឆ្នាំទៀត ទើបបានឫក្សល្អ បើព្រះនគរមិនមានទ្វាររាប់ឆ្នាំ ក៏នឹងបើកឱកាសដល់ពួកសត្រូវ ពួកយើងនឹងសម្លាប់ព្រាហ្មណ៍នេះ ឲ្យព្រាហ្មណ៍ដទៃដែលឈ្លាសធ្វើពលីកម្ម លើកទ្វារចុះ ។

ព្រះរាជាត្រាស់ថា ពួកព្រាហ្មណ៍ដទៃដែលឈ្លាសដូចលោកអាចារ្យនេះមានឬ ជនទាំងនោះនាំគ្នាក្រាបទូលថា មានព្រះអង្គ អន្តេវាសិករបស់បុរោហិតនោះឈ្មោះតក្ការិយមាណព សូមប្រទានតំណែងបុរោហិតដល់គេ ហើយទ្រង់ធ្វើនូវមង្គលចុះ ។ ព្រះរាជាត្រាស់ហៅមាណពមក ឲ្យធ្វើសម្មានាការៈហើយប្រទានតំណែងបុរោហិត ទ្រង់បញ្ជាឲ្យធ្វើយ៉ាងនោះ ។ បុរោហិតបានទៅកាន់ទ្វារនគរ មួយអន្លើដោយបរិវារច្រើន រាជបុរសទាំងឡាយ នាំគ្នាចងបុរោហិត នាំមកដោយអានុភាពនៃព្រះរាជា ។ ព្រះមហាសត្វ បានឲ្យគេជីករណ្ដៅក្នុងទីដែលនឹងត្រូវធ្វើទ្វារ ឲ្យបាំងរាំងននជុំវិញ ចូលក្នុងរាំងននជាមួយអាចារ្យ ។ អាចារ្យសម្លឹងមើលរណ្ដៅអស់នូវអាល័យ មិនបានអ្នកណាជាទីពឹងដល់ខ្លួន ទើបគិតថា អញជាអ្នកចាត់ចែងនូវភាពវិនាសទាំងអស់

ព្រោះអញល្ងង់ មិនអាចគ្រប់គ្រងមាត់របស់ខ្លួនបាន ប្រញាប់ប្រាប់ដល់ស្រីអាក្រក់ ខ្លួនរបស់អញនាំការសម្លាប់មកឲ្យខ្លួន កាលនឹងសន្ទនាជាមួយព្រះមហាសត្វ ក៏ពោលគាថាទី ១ ថា

ខ្ញុំឯងជាមនុស្សល្ងង់ និយាយសម្ដីទាស់ ដូចជាកង្កែបហៅពស់ក្នុងព្រៃ ម្នាលតក្ការិយៈ ខ្ញុំធ្លាក់ក្នុងរណ្ដៅនេះ ព្រោះឮថា បុគ្គលនិយាយហួសប្រមាណ មិនប្រពៃឡើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ទុព្ភាសិតំ ភាសិ** កែជា **ទុព្ភាសិតំ ភាសី** សេចក្ដីថា ខ្ញុំបានពោលពាក្យដែលជាទុព្ភាសិត ។ បទថា **ភេកោវ** សេចក្ដីថា ខ្ញុំនោះឯងរមែងពោលតែពាក្យអាក្រក់ៗ ដូចកង្កែបនៅក្នុងព្រៃ ហៅពស់មកដើម្បីស៊ីខ្លួន ដូច្នោះ ។ កង្កែបដែលយំនោះ ឈ្មោះថា យំមិនល្អ ។ បទថា **តក្ការិយេ** សេចក្ដីថា ជាឈ្មោះរបស់ព្រះមហាសត្វ ដែលជាឈ្មោះជាឥត្ថិលិង្គ បុរោហិតកាលហៅព្រះមហាសត្វ ទើបពោលយ៉ាងនេះ ។ ព្រះមហាសត្វបានស្ដាប់ពាក្យនោះហើយ ពោលគាថាទី ២ ថា

បុគ្គលអ្នកនិយាយហួសប្រមាណ តែងដល់នូវការចង ការសម្លាប់ សោក និងខ្សឹកខ្សួល លោកតិះដៀលខ្លួនលោក ព្រោះតែហេតុនោះ បពិត្រលោកអាចារ្យ ពួកជនកប់លោកក្នុងរណ្ដៅឥឡូវនេះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អតិវេលភាណី** សេចក្ដីថា ការពោលកន្លងនូវព្រំដែន ពោលកន្លងប្រមាណ ឈ្មោះថា មិនល្អ អធិប្បាយថា បុរស

ដែលពោលហួសព្រំដែនរាប់ថា ជាមនុស្សមិនល្អ ។ បទថា **សោកបរិទ្ទវញ្ច** សេចក្ដីថា នែអាចារ្យ បុគ្គលដែលពោលហួសកាលយ៉ាងនេះឯង រមែងត្រូវសម្លាប់ និងត្រូវចង ដល់នូវសេចក្ដីសោក យំដោយសំឡេងខ្លាំង ។ បទថា **គរហាសិ** សេចក្ដីថា លោកមិនត្រូវតិះដៀលអ្នកដទៃឡើយ គប្បីតិះដៀលខ្លួនឯងតែម្យ៉ាង ។ បទថា **ឯត្ថ** បានដល់ ព្រោះហេតុនេះ ។ បទថា **អាចរិយ តំ** សេចក្ដីថា ព្រះមហាសត្វពោលថា លោកអាចារ្យ ជនទាំងឡាយកំពុងកប់លោកក្នុងរណ្ដៅដែលជីកនោះឯង ព្រោះហេតុនោះ លោកគប្បីតិះដៀលខ្លួនឯងប៉ុណ្ណោះ ។

ព្រះមហាសត្វកាលពោលហើយយ៉ាងនេះ ទើបពោលបន្តទៅថា លោកអាចារ្យ លោកមិនរក្សាវាចា ដល់នូវសេចក្ដីទុក្ខម្នាក់ឯងប៉ុណ្ណោះ ក៏មិនមែនសូម្បីអ្នកដទៃ ក៏ដល់នូវសេចក្ដីទុក្ខដូចគ្នា ហើយនាំអតីតនិទាន មកសម្ដែងដូចតទៅ

បានឮថា ក្នុងកាលមុន ក្នុងនគរពារាណសីមានស្រីពេស្យាម្នាក់ ឈ្មោះកាលី បងប្រុសរបស់នាងឈ្មោះតុណ្ឌិលៈ ។ ថ្ងៃមួយ នាងកាលីទទួលប្រាក់ ១ ពាន់កហាបណៈ ។ តែតុណ្ឌិលៈដែលជាអ្នកលេងស្រី លេងស្រា និងជាអ្នកលេងល្បែង ។ នាងឲ្យទ្រព្យដល់តុណ្ឌិលៈនោះ គេយកទ្រព្យដែលបានហើយទៅបំផ្លាញឲ្យវិនាសអស់ សូម្បីនាងហាមតុណ្ឌិលៈនោះ ក៏មិនអាចហាមបាន ។ ថ្ងៃមួយ តុណ្ឌិលៈនោះ លេងល្បែងចាញ់ បញ្ចាំសំពត់ យកកន្ទេលផែង ស្លៀកមកកាន់ផ្ទះរបស់ខ្លួន ។ ឯពួកស្រីបម្រើរបស់នាង ក៏បានដាក់បទ

បញ្ហាថា ក្នុងពេលតុណ្ឌិលៈមកដល់ មិនត្រូវឲ្យរបស់ណាមួយ ចាប់កគេអូស ចេញទៅ ។ ជនទាំងនោះក៏នាំគ្នាធ្វើយ៉ាងនោះ តុណ្ឌិលៈទៅឈរយំក្បែរទ្វារ ។ លំដាប់នោះ កូនប្រុសរបស់សេដ្ឋីម្នាក់ នាំទ្រព្យមកឲ្យនាងកាលីម្តង ១ ពាន់ កហាបណៈជានិច្ច ថ្ងៃនោះ ឃើញតុណ្ឌិលៈនោះក៏សួរថា នែតុណ្ឌិលៈ អ្នក យំអ្វី តុណ្ឌិលៈពោលថា នែអ្នក ខ្ញុំចាញ់ល្បែង មករកប្អូនស្រីរបស់ខ្ញុំ ពួក អ្នកបម្រើទាំងនោះ នាំគ្នាចាប់កខ្ញុំដេញចេញមក ។ បុរសនោះប្រាប់ថា បើ ដូច្នោះសូមបង្អង់សិន ខ្ញុំនឹងជួយប្រាប់ប្អូនស្រីរបស់អ្នកឲ្យ ហើយក៏ទៅប្រាប់ នាងថា បងប្រុសរបស់នាងស្លៀកកន្ទេលផែង ឈរត្រង់ទ្វារ ហេតុអ្វីនាងមិន ឲ្យសំពត់ដល់គេខ្លះ ។ នាងឆ្លើយថា ខ្ញុំមិនឲ្យគេ បើអ្នកមានចិត្ត សូមឲ្យខ្លួន ឯងចុះ ។ ក្នុងផ្ទះរបស់ស្រីពេស្យានោះ មានទំនៀមប្រព្រឹត្តជាប់តគ្នាមកដូច្នេះ ថា ក្នុងប្រាក់ ១ ពាន់កហាបណៈ ៥០០ កហាបណៈជារបស់ស្រីពេស្យា ៥០០ កហាបណៈជាតម្លៃរបស់សំពត់ គ្រឿងក្រអូប និងកម្រងផ្កា ។ បុរសដែលនាំ គ្នាមក ស្លៀកសំពត់ដែលបានក្នុងផ្ទះនោះរហូតមួយយប់ ស្អែកឡើង កាលនឹង ទៅ ក៏ផ្លាស់សំពត់នោះ ស្លៀកសំពត់ដែលខ្លួននាំមកនោះឯងត្រឡប់ទៅ ហេតុ នោះ ទើបសេដ្ឋីបុត្រស្លៀកសំពត់ដែលនាងឲ្យហើយ ឲ្យសំពត់របស់ខ្លួនដល់ តុណ្ឌិលៈ បុរសនោះស្លៀកសំពត់ហើយ បញ្ចូនសំឡេងផ្ទាសាដើរទៅកាន់ រោងស្រា ។ ចំណែកនាងកាលីក៏ផ្តាំអ្នកបម្រើថា ស្អែកនេះ កូនប្រុសសេដ្ឋី នេះនឹងទៅ ពួកនាងចូរនាំគ្នាដណ្តើមយកសំពត់ កាលសេដ្ឋីបុត្រនោះចេញមក ក៏ស្ទុះចូលទៅដូចចោរប្លន់ នាំគ្នាទាញសំពត់ រហូតដល់គេអាក្រាតកាយ ទើប

លែង ហើយពោលថា ឥឡូវនេះ អ្នកអាចទៅបានហើយ សេដ្ឋីបុត្រត្រូវដើរ ចេញមកទាំងអាក្រាតកាយ ដូច្នោះ ពួកមនុស្សនាំគ្នាសើចទាំងអស់ បុរស នោះខ្មាសពោលថា អញជាអ្នកធ្វើខ្លួនឯង អញមិនអាចរក្សាមាត់របស់ខ្លួន បាន កាលសម្តែងសេចក្តីនេះ ទើបពោលគាថាទី ៣ ថា

ថ្វី បានជាអញសួរ អញយកអាសាតុណ្ឋិលៈជាបងនាងកាលី បានជាអញត្រូវគេដណ្តើមយកសំពត់ទាំងគូ ហើយជាមនុស្ស អាក្រាត ដំណើរនេះឯង ប្រហែលគ្មានឹងលោក ច្រើនប្រការ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ពហុ តាតិសោវ** សេចក្តីថា ពិតហើយ សូម្បីសេដ្ឋីបុត្រ បានទទួលទុក្ខព្រោះកម្មដែលខ្លួនធ្វើនោះឯង ព្រោះហេតុនោះ សូម្បីលោក ក៏ដូចគ្មានឹងហេតុដែលកើតឡើងនៃទុក្ខនេះ ព្រោះហេតុជាច្រើន ។

មានរឿងមួយទៀតក្នុងក្រុងពារាណសី ដោយការប្រហែសធ្វេសរបស់ អ្នកឃ្វាលពពែទាំងឡាយ កាលពពែពីរជល់គ្នាក្នុងទីរកស៊ី សត្វកុកមួយគិត ថា ឥឡូវនេះឯង សត្វទាំងពីរនេះទង្គិចក្បាលគ្នា នឹងបែកក្បាលស្លាប់ អញ ត្រូវហាមឃាត់ ហើយឃាត់ថា បពិត្រឱពុកធំ អ្នកកុំជល់គ្នាឡើយ កាល សត្វទាំងពីរមិនស្តាប់ពាក្យកុកនោះ នៅតែជល់គ្នានោះឯង ក៏លោតទំត្រង់ខ្នង ខ្លះ ត្រង់មុខខ្លះ អង្វរឿយៗ ទៅ កាលមិនអាចឃាត់បាន ក៏ពោលថា បើយ៉ាងនោះ ក៏ចូរសម្លាប់ខ្ញុំជាមុន ហើយសឹមជល់គ្នា លោតចូលទៅត្រង់ រវាងក្បាលរបស់សត្វទាំងពីរ សត្វទាំងពីរជល់គ្នា កុកនោះ ដូចត្រូវបុកដោយ

ក្បាល ដល់នូវសេចក្តីវិនាសដោយរឿងដែលខ្លួនធ្វើនោះឯង កាលព្រះមហា-សត្វសម្តែងហេតុដទៃទៀត ទើបពោលគាថាទី ៤ ថា

កាលពពែទាំងពីរ កំពុងតែដល់គ្នា កុកសណា ចូលទៅត្រង់
ចន្លោះពពែ កុកសនោះ ត្រូវក្បាលពពែទាំងពីរទង្គិចខ្ទេច ក្នុង
ទីនោះ ដំណើរនេះប្រហែលគ្នានឹងលោក ច្រើនយ៉ាង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មេណ្ឌន្តរំ** បានដល់ ក្នុងចន្លោះពពែទាំងពីរ ។ បទថា **អច្ចុបតី** សេចក្តីថា លោតចូលទៅ គឺតាំងនៅក្នុងចន្លោះត្រង់កណ្តាលនៃក្បាលពពែទាំងពីរ ។ បទថា **បីសិតោ** បានដល់ ត្រូវពពែជល់ហើយ ។

ចំណែកពួកនាយគោបាល អ្នកក្រុងពារាណសីមួយពួកទៀត ឃើញដើមត្នោតចេញផ្លែ ក៏ស្រវាឡើងដើមត្នោតមួយដើម្បីបេះផ្លែ ។ កាលកំពុងកាន់ផ្លែត្នោតចុះមក ពស់វែកមួយលូនចេញអំពីដំបូកឡើងដើមត្នោត បុរសដែលឈរខាងក្រោម នាំគ្នាយកឈើជាដើមវាយ ក៏មិនអាចឃាត់ពស់នោះបាន ទើបជនទាំងនោះ ស្រែកប្រាប់អ្នកនៅលើដើមត្នោតថា ពស់លូនឡើងដើមត្នោត បុរសនោះខ្លាច ស្រែកដោយសំឡេងខ្លាំង ពួកមនុស្សដែលនៅខាងក្រោម យកសំពត់ដែលស្វិតមួយផ្ទាំង កាន់ត្រង់ជ្រុងទាំង ៤ ហើយស្រែកថា សូមលោតចូលក្នុងសំពត់នេះ បុរសដែលនៅខាងលើដើមនោះ កាត់ចិត្តលោតចុះមក ទ្រង់កណ្តាលសំពត់រវាងជនទាំង ៤ ដោយអំណាចការធ្លាក់នោះឯង មនុស្សទាំង ៤ មិនអាចទប់ខ្លួនបាន ក៏ទង្គិចក្បាលគ្នាស្លាប់ទាំងអស់ ។

ព្រះមហាសត្វ កាលសម្តែងហេតុនេះ ទើបពោលគាថាទី ៥ ថា

ជន ៤ នាក់ កាន់ជាយក្រមា ចាំត្រងបុរសម្នាក់ ( ដែលលោត ពីចុងត្នោត ) ជន ទាំង ៤ នាក់នោះបែកក្បាលដួលស្លាប់ ដំណើរ នេះ ប្រហែលគ្នានឹងលោក ច្រើនយ៉ាង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ចោត្ថកំ** បានដល់ សំពត់ ។ បទថា **សព្វេ តេ** សេចក្តីថា មនុស្សទាំង ៤ នាក់នោះ នាំគ្នាកាន់យកសំពត់ នាំគ្នាទង្គិច ក្បាលបែកដេកស្លាប់ហើយ ។

រឿងមួយទៀត ពួកចោរលួចពពែក្នុងក្រុងពារាណសី រួមគ្នាលួចពពែ បានមួយក្នុងពេលរាត្រី គិតគ្នាថា នឹងបរិភោគក្នុងព្រៃ ដូច្នេះហើយ ក្នុង ពេលថ្ងៃ នាំគ្នាចងមាត់ពពែកុំឲ្យស្រែក ហើយយកទៅលាក់ក្នុងគុម្ពឫស្សី ស្អេកឡើង នាំគ្នាទៅដើម្បីស៊ីពពែនោះ ភ្លេចអាវុធ ក៏នាំគ្នាទៅ ។ ចោរទាំង នោះពោលថា នឹងសម្លាប់ពពែអាំងស៊ីសាច់ យកអាវុធមកចុះ មិនឃើញ អាវុធក្នុងដៃសូម្បីត្រឹមតែម្នាក់ នាំគ្នាពោលថា សូម្បីគ្មានអាវុធ ក៏សម្លាប់ពពែ នេះបាន តែមិនអាចពន្លះសាច់វាបាន ណ្ហើយលែងវាទៅចុះ បុណ្យរបស់វានៅ មាន ហើយក៏លែងទៅ ។ គ្រានោះ ជាងផែងម្នាក់ កាន់យកឫស្សីហើយ គិតថា នឹងត្រឡប់មកយកឫស្សីទៀត ទើបលាក់កាំបិតកាប់ឫស្សីក្នុងគំនរ ស្លឹកឫស្សី ចៀសចេញទៅ ។ ពពែត្រេកអរថា អញរួចផុតសេចក្តីស្លាប់ ហើយ ត្លាំត្លង លេងត្រង់គុម្ពឫស្សី ធាក់ដោយជើង ធ្វើឲ្យកាំបិតនោះធ្លាក់ចុះ មក ។ ពួកចោរបានឮសំឡេងកាំបិត ក៏នាំគ្នាដើររកកាំបិត ឃើញកាំបិតហើយ ត្រេកអរថា យើងនឹងសម្លាប់ពពែស៊ីសាច់ពពែនោះ ក៏ស្លាប់ព្រោះរឿងដែល

ខ្លួនធ្វើ ដោយប្រការដូច្នេះ ។ កាលនឹងសម្តែងហេតុនេះ ទើបព្រះមហាសត្វ ពោលគាថាទី ៦ ថា

ដូចជាមេពពៃ ដែលចោរចងទុកក្បែរគុម្ពឫស្សី ទធាក់ជើងក្រោយលេង បានដាន់កាំបិត ហេតុនោះ បានជាចោរអារបំពង់ក មេពពែនោះ ដំណើរនេះឯង ប្រហែលគ្នានឹងលោក ច្រើនយ៉ាងដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អវេក្ខិបន្តី** សេចក្តីថា ពពែត្រូវចងត្រង់គុម្ពឫស្សី ឃ្នើសឃ្នង គឺរពិស ទធាក់នូវជើងក្រោយ ។

កាលពោលយ៉ាងនេះហើយ ព្រះពោធិសត្វសម្តែងថា ធម្មតាបុគ្គលដែលរក្សាពាក្យរបស់ខ្លួន ពោលសមគួរ រមែងផុតទុក្ខ គឺសេចក្តីស្លាប់បាន ហើយនាំរឿងកិន្នរមកពោលជាបន្ត

បានឮថា កូនព្រានព្រៃអ្នកក្រុងសាវត្ថីម្នាក់ ទៅកាន់ព្រៃហិមពាន្ត ប្រើឧបាយមួយ ចាប់កិន្នរឈ្មោលញីមកបាន ហើយថ្វាយដល់ព្រះរាជាៗ ទតឃើញកិន្នរដែលមិនធ្លាប់ទត ទ្រង់ពេញព្រះរាជហឫទ័យ ត្រាស់សួរថា នែព្រាហ្មណ៍ សត្វនេះមានគុណដូចម្តេច នាយព្រានក្រាបទូលថា បពិត្រព្រះសម្មតិទេព សត្វនេះ ច្រៀងពីរោះ រាំល្អ ពួកមនុស្សមិនអាចរាំដូចឡើយ ។ ព្រះរាជាប្រទានទ្រព្យជាច្រើនដល់នាយព្រាន ហើយត្រាស់នឹងកិន្នរទាំងគូថា ចូរអ្នកច្រៀងរាំចុះ កិន្នរទាំងពីរគិតគ្នាថា បើយើងច្រៀង មិនអាចធ្វើព្យញ្ជនៈឲ្យបរិបូណ៌បាន ការចាប់កំហុសក៏នឹងមាន ពួកមនុស្សនឹងត្រូវតិះដៀលថា

ត្រូវសម្លាប់យើង ម្យ៉ាងទៀត កាលយើងពោលច្រើន ក៏ជាមុសាវាទ ព្រោះខ្លាចមុសាវាទ សូម្បីត្រូវព្រះរាជាពោលហើយពោលទៀត ក៏មិនព្រមច្រៀងរាំ ព្រះរាជាកាលទ្រង់ពិរោធ កាលទ្រង់ត្រាស់ថា ចូរពួកអ្នកសម្លាប់កិន្នរទាំងនេះអាំងសាច់ ហើយនាំមកចុះ ទើបត្រាស់គាថាទី ៧ ថា

កិន្នរទាំងពីរនេះ មិនមែនជាទេវតា មិនមែនជាគន្ធព្វបុត្រទេ កិន្នរទាំងនេះជាម្រឹគទេ កិន្នរទាំងនេះ ព្រានព្រៃបាននាំមកដោយអំណាចប្រយោជន៍ ពួកអ្នកធ្វើក្រយាស្ងោយ ចូរចម្អិនកិន្នរមួយនោះក្នុងពេលបាយល្ងាច ចូរចម្អិនកិន្នរមួយទៀត ក្នុងពេលបាយព្រឹក ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **មិគា ឥមេ** សេចក្ដីថា បើសត្វទាំងនេះជាទេវតា ឬគន្ធព្វសោត គប្បីរាំ និងច្រៀងបាន តែសត្វទាំងនេះជាម្រឹគ ជាសត្វតិរច្ឆាន ។ បទថា **អត្ថវសាភតា ឥមេ** សេចក្ដីថា សត្វទាំងនេះ ត្រូវនាំមកកាន់កណ្ដាប់ដៃរបស់យើង ដោយអំណាចនៃប្រយោជន៍ ព្រោះត្រូវព្រានប្រាថ្នាប្រយោជន៍នាំមក ក្នុងបណ្ដាសត្វទាំងនោះ ចូរអ្នកទាំងឡាយអាំងមួយសម្រាប់អាហារពេលល្ងាច មួយទៀត សម្រាប់អាហារពេលព្រឹកចុះ ។

កិន្នរញីត្រិះរិះថា ព្រះរាជាក្រោធហើយ គង់នឹងសម្លាប់អញដោយឥតសង្ស័យ ឥឡូវនេះ ជាពេលដែលអញត្រូវនិយាយ ទើបពោលគាថាបន្ទថា

ពាក្យជាទុព្ភាសិត មួយសែនមាត់ ក៏មិនដល់មួយចំណិតនៃពាក្យជាសុភាសិតឡើយ បុគ្គលកាលវង្វៀសនឹងពាក្យជាទុព្ភាសិត រមែង

លំបាក ព្រោះហេតុនោះ កិន្នរនៅស្ងៀម មិនមែនព្រោះល្ងង់ទេ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សង្កមានោ កិលេសោ** សេចក្ដីថា ដូនកាល ខ្ញុំកាលពោល ក៏ពោលពាក្យដែលជាទុព្ភាសិត កិន្នរកាលរង្កៀសពាក្យជាទុព្ភាសិត រមែងសៅហ្មង គឺរមែងលំបាកដោយប្រការដូច្នេះ ។ បទថា **តស្មា** សេចក្ដីថា ព្រោះហេតុនោះ ទើបខ្ញុំមិនប្រៀនដល់អ្នក មិនមែនព្រោះសេចក្ដីល្ងង់ឡើយ ។ ព្រះរាជាពេញព្រះហឫទ័យនឹងកិន្នរញី ទើបត្រាស់គាថាបន្ដថា

កិន្នរីណាបានដោះសានឹងអញ អ្នកទាំងឡាយ ចូរលែងកិន្នរីនុ៎ះចុះ ចូរនាំកិន្នរនោះទៅក្នុំហិមពាន្ត អ្នកទាំងឡាយ ចូរប្រគល់កិន្នរនេះដើម្បីរោងគ្រួ ចូរចម្អិនវាក្នុងពេលបាយព្រឹកអំពីព្រលឹម ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យា មេសា** កែជា **យា មេឃសា** ។ បទថា **ទេន្តុ** សេចក្ដីថា ចូរឲ្យដើម្បីប្រយោជន៍ដល់រោងចុងភៅ ។

កិន្នរលុះស្ដាប់ព្រះតម្រាស់របស់ព្រះរាជាហើយ គិតថា ព្រះរាជាគង់នឹងសម្លាប់អញដែលមិនពោលពិត ឥឡូវនេះ អញគួរនិយាយ ដូច្នេះហើយពោលគាថាបន្ដថា

ពួកសត្វចិញ្ចឹម មានមេឃជាទីពឹង ពួកមនុស្សមានសត្វចិញ្ចឹមជាទីពឹង បពិត្រមហារាជ ខ្ញុំមានព្រះអង្គជាទីពឹង ឯភរិយារបស់ខ្ញុំមានខ្លួនខ្ញុំជាទីពឹង ក្នុងរវាងយើងខ្ញុំទាំងពីរនាក់ សូមឲ្យអ្នកដែលរួច ( អំពីសេចក្ដីស្លាប់ ) ដឹងថា អ្នកណាមួយ ( ស្លាប់ )

ហើយ សឹមទៅក្នុំ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បជ្ជុន្នធាថា** សេចក្ដីថា សត្វចិញ្ចឹមមានស្មៅជាអាហារ ឈ្មោះថា មានមេឃ គឺភ្លៀងជាទីពឹង ។ បទថា **បសុធាថា អយំ បជា** សេចក្ដីថា ប្រជា គឺមនុស្សនេះ អាស្រ័យគោរស ៥ ឈ្មោះថា ជាអ្នកមានបសុសត្វជាទីពឹងអាស្រ័យ ។ បទថា **ត្វំ ធាថោសិ** សេចក្ដីថា ទ្រង់ជាទីពឹងអាស្រ័យរបស់ខ្ញុំ ។ បទថា **អម្ហធាថា មម ភរិយា** សេចក្ដីថា ខ្ញុំក៏ជាទីពឹងរបស់ករិយានោះ ។ បទថា **ទ្វិន្នមញ្ញតរំ ញត្វា មុត្តោ គច្ឆេយ្យ បព្វតំ** សេចក្ដីថា ក្នុងរវាងខ្ញុំទាំងគូ សត្វមួយដឹងថា សត្វមួយស្លាប់ហើយ ខ្លួនឯងរួចពីស្លាប់ហើយ ទើបទៅកាន់ព្រៃហិមពាន្តជាខាងក្រោយ គឺកាលខ្ញុំទាំងគូនៅមានជីវិត រមែងមិនលះបង់គ្នា ព្រោះដូច្នោះ បើទ្រង់បំណងនឹងបញ្ជូនកិន្នរញីទៅកាន់ហិមពាន្ត សូមសម្លាប់ខ្ញុំជាមុន សឹមបញ្ជូននាងទៅ ក្នុងកាលជាក្រោយ ។

កាលកិន្នរក្រាបទូលយ៉ាងនេះហើយ កាលនឹងសម្ដែងថា បពិត្រមហារាជ ខ្ញុំទាំងពីរមិនមែនស្ងៀម ព្រោះប្រាថ្នានឹងជំទាស់ព្រះតម្រាស់របស់ទ្រង់ទេ តែព្រោះឃើញទោសនៃការនិយាយច្រើន ទើបមិនបានក្រាបទូលស្នងព្រះបញ្ជា ហើយពោល ២ គាថានេះថា

បុគ្គលមិនងាយចៀសនិន្ទាទេ បពិត្រព្រះជនិន្ទ ព្រះអង្គគប្បីសេពគប់ រាប់រកនូវពួកជន អ្នកមានសេចក្ដីប្រាថ្នាផ្សេងៗ គ្នា (លមើល) បុគ្គលពួកមួយ បាននូវសេចក្ដីសរសើរដោយគុណ

មានសីលគុណជាដើមណា បុគ្គលឯទៀត បានទូវពាក្យនិន្ទា ដោយគុណ មានសីលគុណជាដើមនោះទៅវិញ ។

សត្វលោកទាំងអស់ មានចិត្តក្លៀវក្លា ដោយចិត្តផ្សេងគ្នា សត្វលោកទាំងអស់ មានចិត្តប្រព្រឹត្តទៅក្នុងចិត្តរបស់ខ្លួន ពួកសត្វទាំងអស់ មានចិត្តផ្សេងៗ គ្នា មានប្រភេទដ៏ច្រើន ឯក្នុងលោកនេះ បុគ្គលមិនលុះអំណាចចិត្តរបស់បុគ្គលណាបានឡើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សុបរិវជ្ជយាជ** សេចក្ដីថា បពិត្រមហារាជ ឈ្មោះថា និន្ទា បុគ្គលមិនអាចចៀសបានងាយឡើយ ។ បទថា **ឆានា ជនា** សេចក្ដីថា ពួកជនមានការពេញចិត្តផ្សេងៗ គ្នា ។ បទថា **យេនេវ** សេចក្ដីថា បុគ្គលម្នាក់បានទទួលនូវការសរសើរដោយគុណ មានសីលជាដើមយ៉ាងណា ដោយគុណនោះឯង អ្នកដទៃបានទទួលការនិន្ទា សេចក្ដីពិត ព្រោះពោលក្នុងហ្វូងកិន្នរ ខ្ញុំព្រះអង្គរមែងបាននូវការសរសើរ ព្រោះមិនពោលក្នុងពួកមនុស្ស រមែងបាននូវការនិន្ទាដោយអាការយ៉ាងនេះ ឈ្មោះថា និន្ទា ជាវត្ថុដែលចៀសវាងបានដោយលំបាក ខ្ញុំគិតថា យើងបាននូវការសរសើរអំពីសម្នាក់ព្រះអង្គបានដូចម្ដេច ។ បទថា **សព្វោ លោកោ បរចិត្តេន អតិចិត្តោ** សេចក្ដីថា បពិត្រមហារាជ ធម្មតាអសប្បុរស មានការគិតខាងក្នុងដោយគិតសម្លាប់សត្វជាដើម សប្បុរស មានការគិតខាងក្នុង ដោយគិតវៀរចាកការសម្លាប់សត្វជាដើម សត្វលោកទាំងពួង រមែងមានការគិតផ្សេងចាកការគិតរបស់បុគ្គលដទៃ ដោយប្រការដូច្នេះ ។ បទថា **ចិត្តវាសម្ហិ ចិត្តេ** សេចក្ដីថា សត្វ

លោកទាំងមូល ឈ្មោះថា មានការគិតដោយការគិតរបស់ខ្លួន ទាំងថោកទាប ឬប្រណីត ។ បទថា **បច្ចេកចិត្តា** សេចក្ដីថា កិន្នរសម្ដែងធម៌ដល់ព្រះរាជាថា សត្វទាំងអស់ ច្រើនប្រភេទ តែងមានចិត្តចំពោះខ្លួន ក្នុងបណ្ដាសព្វសត្វទាំងនោះ កិន្នរញីក្ដី ខ្ញុំក្ដី អ្នកដទៃក្ដី មិនគួរប្រព្រឹត្តទៅក្នុងការគិតរបស់បុគ្គលណាមួយត្រឹមតែម្នាក់ ទោះជារបស់ទ្រង់ ឬរបស់អ្នកដទៃក៏ដោយ ព្រោះហេតុនោះ ទ្រង់កុំពិរោធខ្ញុំថា បុគ្គលនេះ មិនប្រព្រឹត្តទៅក្នុងអំណាចចិត្តរបស់អញ ព្រោះសព្វសត្វ រមែងមិនលុះអំណាចចិត្តរបស់ខ្លួនទៅបាន ។

ព្រះរាជាទ្រង់សោមនស្សថា កិន្នរនេះជាបណ្ឌិត ពោលត្រឹមត្រូវ ទើបត្រាស់គាថាចុងក្រោយថា

កិន្នរណា ព្រមទាំងភរិយា នៅស្ងៀម ឥឡូវនេះភ័យហើយ បានដោះសា កិន្នរនោះចូររួចអំពីភ័យ ដល់នូវសេចក្ដីសុខ មិនមានរោគក្នុងកាលឥឡូវនេះចុះ វាចារបស់ជនទាំងឡាយ ជាវាចាមានប្រយោជន៍ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វាចា គិរេវត្ថវតី នរានំ** សេចក្ដីថា វាចាគឺពាក្យដែលគួរបន្លឺ រមែងមានប្រយោជន៍ គឺនាំមកនូវប្រយោជន៍ដល់សត្វទាំងនេះ ។

ព្រះរាជាត្រាស់ឲ្យកិន្នរទាំងគូទំក្នុងទ្រុងមាស ត្រាស់ឲ្យហៅព្រាហ្មណ៍ម្នាក់នោះ និងឲ្យលែងដោយព្រះតម្រាស់ថា ចូរឯងទៅ លែងកិន្នរទាំងគូនេះ ក្នុងទីដែលចាប់បាននោះចុះ ។

ចំណែកព្រះមហាសត្វពោលថា លោកអាចារ្យមើលចុះ កិន្នរទាំងគូរក្សាវាចាយ៉ាងនេះ កាលដល់នូវការស្លាប់ ក៏រួចផុតអំពីសេចក្តីស្លាប់បានដោយសុភាសិតដែលខ្លួនពោលនោះឯង ចំណែកលោកដល់នូវសេចក្តីទុក្ខធំ ព្រោះវាចាអាក្រក់ កាលសម្តែងឧទាហរណ៍នេះហើយក៏លួងលោមថា លោកអាចារ្យកុំខ្លាចឡើយ ខ្ញុំនឹងឲ្យជីវិតដល់លោក កាលអាចារ្យពោលថា ម្យ៉ាងទៀត ចូរអ្នកជួយរក្សាខ្ញុំចុះ ក៏ប្រាប់ថា មិនទាន់បានឫក្ស រង់ចាំអស់ថ្ងៃនោះក្នុងចន្លោះមជ្ឈិមយាម ទើបឲ្យមនុស្សយកពពែស្លាប់មកហើយ ពោលថា នែព្រាហ្មណ៍ សូមលោកទៅធ្វើការរកស៊ីចិញ្ចឹមជីវិតក្នុងទីដទៃចុះ កុំឲ្យអ្នកណាដឹងឡើយ លែងព្រាហ្មណ៍នោះទៅ យកសាច់ពពែធ្វើពលីកម្ម ហើយសាងខ្លោងទ្វារឡើង ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះ មកសម្តែងហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលកោកាលិកៈត្រូវវាចាធ្វើខ្លួនឲ្យវិនាស សូម្បីក្នុងកាលមុន ក៏ត្រូវទម្លាយហើយដូចគ្នា ហើយទ្រង់ប្រជុំជាតកថា ព្រាហ្មណ៍មានចង្កូម ក្អែកក្រហម ក្នុងកាលនោះ បានមកជាកោកាលិកភិក្ខុ ក្នុងកាលឥឡូវនេះ ចំណែកតក្ការិយបណ្ឌិតក្នុងកាលនោះ គឺតថាគតនេះឯង ។ល។

## អដ្ឋកថា តក្ការិយជាតក ចប់

# សុត្តន្តបិដក

## រុរុមិគជាតក

[ ១១៣៧ ] ( ព្រះបាទព្រហ្មទត្តប្រកាសថា ) នរណាប្រាប់ម្រឹគនោះ ជាម្រឹគដ៏ឧត្តមជាងម្រឹគទាំងឡាយដល់យើង យើងនឹងឲ្យស្រុកសួយ និងនាងនារីដែលស្អិតស្អាងហើយដល់អ្នកនោះ ។

[ ១១៣៨ ] ( សេដ្ឋីបុត្រក្រាបទូលថា ) សូមព្រះអង្គប្រទានស្រុកសួយ និងពួកនាងនារីដែលស្អិតស្អាងដល់ទូលព្រះបង្គំជាខ្ញុំចុះ ទូលព្រះបង្គំជាខ្ញុំ នឹងក្រាបទូលម្រឹគនោះ ជាម្រឹគដ៏ឧត្តមជាងម្រឹគទាំងឡាយដល់ព្រះអង្គ ។

[ ១១៣៩ ] ដើមស្វាយ និងដើមសាលព្រឹក្ស ក្នុងដងព្រៃទុំ៌ះ មានផ្ការីក ( ផែនដី ) ដ៏ដេរដាសដោយស្មៅ មានសម្ផស្សស្រួល មានពណ៌ក្រហម ដូចជាសម្បុរនៃសត្វមេភ្លៀង ម្រឹគទុំ៌ះ ឋិតនៅក្នុងដងព្រៃនោះ ។

[ ១១៤០ ] ( អភិសម្ពុទ្ធគាថា ) ព្រះបាទព្រហ្មទត្តទ្រង់យឹតព្រះទម្រង់កៅទណ្ឌ ផ្ទាប់កាំសរ ហើយស្តេចចូលតម្រង់ទៅ ឯម្រឹគក្រឡេកឃើញព្រះរាជាហើយ ក៏ទូលអង្វរពីចម្ងាយថា បពិត្រមហារាជ សូមព្រះអង្គឈប់សិន បពិត្រព្រះអង្គប្រសើរក្នុងរថ សូមព្រះអង្គកុំបាញ់ទូលព្រះបង្គំជាខ្ញុំឡើយ នរណាអេះ បានក្រាបទូលដំណើរនេះដល់ព្រះអង្គថា ម្រឹគទុំ៌ះ ឋិតនៅក្នុងដងព្រៃទុំ៌ះ ។

[ ១១៨១ ] ( ព្រះរាជា ... ) នែសម្លាញ់ បុរសជាអ្នកប្រព្រឹត្ត អំពើលាមកនុ៎ះ ឋិតនៅអំពីចម្ងាយ បុរសនោះបានប្រាប់ដំណើរ នេះដល់យើងថា ម្រឹគនុ៎ះ ឋិតនៅក្នុងទីនុ៎ះ ។

[ ១១៨២ ] ( ប្រើសមាសពោធិសត្វ ... ) បានឮមកថា នរជន ពួកខ្លះ ក្នុងលោកនេះ បានពោលពាក្យពិតយ៉ាងនេះថា កំណាត់ ឈើដែលគេស្រង់ឡើង ប្រសើរជាង ឯនរជនពួកខ្លះ ដែលគេ ស្រង់ឡើង មិនប្រសើរទេ ។

[ ១១៨៣ ] ( ព្រះរាជា ... ) ម្នាលម្រឹគ អ្នកតិះដៀលម្រឹគទាំង ឡាយ ឬបក្សីទាំងឡាយ ឬក៏មនុស្សទាំងឡាយ យើងមានភ័យ ច្រើនព្រោះតែឮអ្នកនិយាយ ជាភាសាមនុស្ស ។

[ ១១៨៤ ] ( ប្រើសមាស ... ) ខ្ញុំបានស្រង់មនុស្សណាដែល រសាត់ទៅក្នុងផ្លូវទឹក មានទឹកច្រើន ទឹកជ្រៅ មានខ្សែទឹកហូរ រហ័ស ( ឥឡូវ ) ភ័យមានមកដល់ទូលព្រះបង្គំជាខ្ញុំហើយ ព្រោះហេតុតែស្រង់មនុស្សនោះ បពិត្រមហារាជ ការរួបរួមនឹង អសប្បុរស តែងនាំមកនូវសេចក្តីទុក្ខ ។

[ ១១៨៥ ] ( ព្រះរាជា ... ) យើងនឹងបាញ់ព្រួញនេះទៅតាម អាកាស ជាព្រួញមានស្លាបកន្ទុយ ៤ ផ្តាច់នូវសរីរៈ ( បុរស នោះ ) ចំដើមទ្រូង យើងនឹងសម្លាប់មនុស្សនោះ ជាមនុស្សទ្រុស្ត- មិត្ត ជាអ្នកធ្វើកិច្ចដែលមិនគួរធ្វើ មិនដឹងនូវឧបការគុណ ដែល

ធ្វើហើយប្រាកដ ដូច្នោះ ។

[ ១១៤៦ ] ( ប្រើសមាស ) បពិត្រព្រះជនិន្ទ សប្បុរសទាំងឡាយ រមែងមិនសរសើរនូវការសម្លាប់របស់អ្នកប្រាជ្ញ ឬមនុស្សពាលដោយពិតសូមឲ្យមនុស្សអ្នកមានបាបធម៌ទៅផ្ទះតាមសេចក្តីប្រាថ្នាចុះ កត្តណា ( ដែលព្រះអង្គត្រូវប្រទាន ) ដល់បុរសនុ៎ះ សូមព្រះអង្គប្រទានកត្តនោះ ដល់បុរសនុ៎ះចុះ ចំណែកខ្ញុំសូមធ្វើតាមសេចក្តីប្រាថ្នារបស់ព្រះអង្គចុះ ។

[ ១១៤៧ ] ( ព្រះរាជា ... ) ម្នាលប្រើសមាស បណ្តាសប្បុរសទាំងឡាយ អ្នកដែលមិនប្រទូស្តចំពោះមនុស្ស ដែលប្រទូស្តនោះ ក៏ចាត់ថាជាសប្បុរសមួយដោយពិត មនុស្សមានបាបធម៌ ចូរទៅផ្ទះរបស់ខ្លួនតាមសេចក្តីប្រាថ្នាចុះ កត្តណា ( ដែលយើងត្រូវឲ្យ ) ដល់បុរសនុ៎ះ យើងនឹងឲ្យកត្តនោះ ដល់បុរសនុ៎ះ មួយទៀត យើងនឹងឲ្យស្រុកសួយដល់អ្នក ។

[ ១១៤៨ ] ( ប្រើសមាស ... ) បពិត្រមហារាជ សំឡេងរបស់ចចក និងក្រៀល គេដឹងបានដោយងាយ ឯសម្តីរបស់មនុស្ស គេដឹងបានដោយកម្រ ជាងសម្តីសត្វនោះទៅទៀត បុរសណាមានចិត្តល្អ គេសម្គាល់ថាជាញាតិ ជាមិត្ត ជាសម្លាញ់ក្នុងកាលមុន បុរសនោះ រមែងជាសត្រូវវិញ ក្នុងកាលជាខាងក្រោយ ។

[ ១១៤៩ ] ( អភិសម្ពុទ្ធគាថា ) ពួកអ្នកជនបទ ក៏មកប្រជុំគ្នា

ពួកអ្នកនិគម ក៏មកប្រជុំគ្នា ( ហើយក្រាបទូលស្តេច ) ថា ពួកម្រឹគស៊ីស្រូវអស់ហើយ សូមព្រះសម្មតិទេព កម្ចាត់ពួកម្រឹគនោះចេញ ។

[ ១១៥០ ] ( ព្រះរាជា ... ) ចូរកុំឲ្យមានជនបទ ទាំងដែន ក៏ចូរវិនាសទៅ ដោយពិតចុះ យើងឲ្យអភ័យដល់ពួកបក្សីហើយ មិនប្រទូស្តប្រើសមាសទេ ។

[ ១១៥១ ] យើងមិនមានជនបទក្តី ជនបទមិនមានដល់យើងក្តី យើងឲ្យពរដល់មិគរាជហើយ មិននិយាយពាក្យកុហកទេ ។

រុរុមិគជាតកទី ៩ ចប់

# អដ្ឋកថា

## រុរុមិគជាតក

[ ១១៣៧-១១៥១ ] ព្រះសាស្តា កាលគង់នៅក្នុងវេឡុវនវិហារ ទ្រង់ប្រារព្ធទេវទត្ត ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **តស្ស គាមវរំ ឧម្មិ** ដូច្នេះជាដើម ។

បានឮថា ទេវទត្តនោះ កាលពួកភិក្ខុនាំគ្នាពោលថា អាវុសោទេវទត្ត ព្រះសាស្តាទ្រង់មានឧបការៈច្រើនដល់លោក ហើយលោកក៏បានបួស បានរៀនព្រះត្រៃបិដក សម្បូរនូវលាភសក្ការៈ ព្រោះអាស្រ័យព្រះតថាគត ត្រឡប់ជាពោលថា អាវុសោទាំងឡាយ ព្រះសាស្តាទ្រង់មិនបានធ្វើឧបការៈដល់ខ្ញុំ ត្រឹមតែចុងសក់ ខ្ញុំបួសឯង រៀនព្រះត្រៃបិដកក៏រៀនឯង មានលាភសក្ការៈក៏ខ្លួនឯង ភិក្ខុទាំងឡាយអង្គុយសន្ទនាគ្នាក្នុងធម្មសភា ពោលទោសរបស់ទេវទត្តថា អាវុសោទាំងឡាយ ទេវទត្តជាអកតញ្ញូតកវេទីបុគ្គល ។ ព្រះសាស្តាយាងមកហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អំបាញ់មិញនេះពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលទេវទត្តជាអកតញ្ញូ សូម្បីក្នុងកាលមុន ក៏ជាអតកញ្ញូដូចគ្នា ហើយត្រាស់ថា ក្នុងកាលមុន ទេវទត្តនេះ កាលតថាគតឲ្យជីវិតហើយ ក៏គង់មិនដឹងត្រឹមតែគុណរបស់តថាគត ដូច្នេះហើយ ទើបទ្រង់នាំអតីតនិទានមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី សេដ្ឋីមានសម្បត្តិ ៨០ កោដិ បានកូនប្រុសម្នាក់ ឈ្មោះមហាធនកៈ គិតថា កាលកូនយើងរៀនសិប្បៈនឹងត្រូវលំបាក ទើបមិនព្រមឲ្យរៀនសិប្បៈណាមួយឡើយ បុរសនោះមិនចេះអ្វីសោះក្រៅពីការរាំច្រៀង ប្រគំ ត្រាច់ស៊ី ត្រាច់បរិភោគ ។ កាលបុរសនោះ ចម្រើនវ័យហើយ មាតាបិតា ក៏ចាត់ចែងឲ្យមានកិរិយាតាមសមគួរ ហើយក៏អនិច្ចកម្មទៅ ។ លុះលោកទាំងពីរអនិច្ចកម្មទៅហើយ មហាធនកៈនោះក៏ចោមរោមទៅដោយពួកអ្នកលេងស្រី និងអ្នកលេងល្បែងជាដើម បំផ្លាញទ្រព្យទាំងអស់ដោយអបាយមុខផ្សេងៗ ជាប់បំណុល កាលមិនអាចសងបំណុលទាំងអស់នោះបាន ក៏ត្រូវម្ចាស់បំណុលចោមរោមតឹងទារ ត្រិះរិះថា អញរស់នៅធ្វើអ្វី អញកើតមកដោយរាងកាយមួយ ដូចអ្នកដទៃៗ ស្លាប់វិញល្អជាង កាលត្រូវម្ចាស់បំណុលតឹងទារ ក៏ពោលថា ទ្រព្យរបស់ត្រកូលយើងកប់ត្រង់ស្ទឹងគង្គានៅមាន ខ្ញុំនឹងប្រើទ្រព្យនោះសងលោក ។ ម្ចាស់បំណុលនោះ ក៏ទៅជាមួយបុរសនោះ ។ គាត់ធ្វើដូចជាប្រាប់ហេណ្ឌាកប់ទ្រព្យថា ទ្រព្យមានទីនេះ ហើយគេចទៅ ដោយគិតថា អញនឹងលោតចុះក្នុងស្ទឹងគង្គាឲ្យស្លាប់ ហើយក៏លោតចូលក្នុងស្ទឹងគង្គា ត្រូវក្រសែទឹកខ្ពួលខ្ទាញ់នាំទៅ ក៏ស្រែកយំគួរឲ្យអាណោច ។

កាលនោះ ព្រះមហាសត្វកើតក្នុងកំណើតរុរុម្រឹគ ( ប្រើសមាស ) លះបរិវារស្នាក់នៅត្រង់ព្រៃស្វាយ ដែលមានឱកាសល្អលាយចម្រុះដោយព្រៃរាំង ដែលគួរត្រេកអរ ត្រង់កន្លែងទឹកវិលក្នុងស្ទឹងគង្គា នៅតែម្នាក់ឯងប៉ុណ្ណោះ

បំណងនឹងរក្សាឧបោសថ ពណ៌នៃសរីរៈរបស់ស្តេចម្រឹគនោះ មានពណ៌ដូចដំបារមាស ដែលគេខាត់រលីងល្អ ជើងទាំង ៤ មានពណ៌ដូចជ្រលក់ដោយទឹកល័ក្ត កន្ទុយដូចកន្ទុយចាមរី ស្នែងទាំងឡាយ ដូចគ្នានឹងកម្រងប្រាក់ ភ្នែកទាំងគូដូចត្បូងទទឹមដែលធ្វៃហើយ មាត់ប្រៀបដូចរូវដែលស្រោបដោយសំពត់កម្ពលពណ៌ក្រហម រូបរាងរបស់ស្តេចរុរុម្រឹគនោះ មានសភាពដូច្នេះ ៗ ក្នុងពេលយប់ ស្តេចរុរុម្រឹគនោះ បានឮសំឡេងគួរអាណិតរបស់បុរសនោះ ត្រិះរិះថា អញបានឮសំឡេងមនុស្ស កាលអញនៅមានជីវិត សត្វនេះកុំស្លាប់ឡើយ អញត្រូវជួយជីវិតគេឲ្យបាន ហើយក្រោកចាកដំណេក ដើរទៅកាន់មាត់ស្ទឹង លួងលោមថា បុរសដ៏ចម្រើន អ្នកកុំខ្លាចឡើយ ខ្ញុំនឹងជួយជីវិតអ្នក ហើយហែលកាត់ក្រសែទឹកទៅ ឲ្យបុរសឡើងលើខ្នង នាំដល់ត្រើយ ទៅកាន់លំនៅរបស់ខ្លួន ធ្វើឲ្យគេស្រាកស្រាន្តចិត្ត ៗ លុះកន្លងមកបាន ២-៣ ថ្ងៃ ក៏ពោលថា នែបុរស ខ្ញុំនឹងនាំអ្នកចេញអំពីព្រៃនេះ បញ្ជូនទៅឲ្យដល់ផ្លូវទៅកាន់នគរពារាណសី អ្នកនឹងទៅដោយសួស្តី តែខ្ញុំសូមត្រឹមតែម្យ៉ាង អ្នកកុំប្រាប់ខ្ញុំដល់ព្រះរាជា ឬមហាមាត្យរបស់ព្រះរាជា ព្រោះហេតុនៃទ្រព្យថា ក្នុងទីឈ្មោះនោះ ម្រឹគមាសស្នាក់នៅដូច្នេះឡើយ ៗ បុរសនោះទទួលថា សាធុ ៗ ព្រះមហាសត្វទទួលបដិញ្ញារបស់បុរសនោះហើយ ក៏ឲ្យបុរសនោះឡើងជិះលើខ្នង នាំទៅកាន់ក្រុងពារាណសី ហើយត្រឡប់ ៗ ក្នុងថ្ងៃដែលបុរសនោះទៅដល់ក្រុងពារាណសីនោះឯង អគ្គមហេសីរបស់ព្រះរាជាព្រះនាមខេមាទេវី ព្រះនាងយល់សប្តិឃើញម្រឹគមាស សម្តែងធម្មកថាថ្វាយ ក្នុងពេលទៀបភ្លឺ

ព្រះនាងទ្រង់ព្រះតម្រិះថា បើម្រឹគបែបនេះមិនមានសោត អញមិនអាចយល់សប្តិឃើញបានឡើយ ម្រឹគនេះគង់មានពិត អញនឹងក្រាបទូលដល់ព្រះរាជា ។ ព្រះនាងចូលគាល់ព្រះរាជាក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំម្ចាស់ប្រាថ្នានឹងឃើញប្រើសមាស បំណងនឹងស្តាប់ធម្មកថារបស់ប្រើសមាសនោះ បើបានខ្ញុំម្ចាស់មានជីវិត បើមិនបាន ជីវិតខ្ញុំម្ចាស់មិនមានឡើយ ។ ព្រះរាជាទ្រង់លួងលោមព្រះនាង ត្រាស់ថា បើសត្វនោះមានក្នុងមនុស្សលោក នាងនឹងបានពិតដូច្នេះហើយ ត្រាស់ឲ្យហៅពួកព្រាហ្មណ៍មកគាល់ ត្រាស់សួរថា ធម្មតាម្រឹគដែលមានពណ៌ដូចមាសមានឬ ទ្រង់បានឮថា បពិត្រព្រះសម្មតិទេព មាន ក៏ត្រាស់ឲ្យដាក់ថង់ប្រាក់ ១ ពាន់កហាបណៈក្នុងប្រអប់មាស ដាក់លើកដីរដែលប្រដាប់ស្រេចហើយ មានបំណងនឹងប្រទានដីរនោះ ព្រមទាំងប្រអប់មាស និងថង់ប្រាក់មួយពាន់កហាបណៈ និងទ្រព្យដែលក្រៃលែងជាងនេះដល់អ្នកដែលប្រាប់រឿងប្រើសមាសបាន ហើយឲ្យរចនាគាថាក្នុងផែនមាស ឲ្យរកអមាត្យម្នាក់មកគាល់ មានព្រះតម្រាស់ថា ចូរបាប្រាប់គាថានេះតាមពាក្យរបស់យើងដល់អ្នកនគរ ហើយត្រាស់គាថាទី ១ ក្នុងជាតកនេះថា

នរណាប្រាប់ម្រឹគនោះ ជាម្រឹគដ៏ឧត្តមជាងម្រឹគទាំងឡាយដល់
យើង យើងនឹងឲ្យស្រុកស្អួយ និងនាងនារីដែលស្អិតស្អាងហើយ
ដល់អ្នកនោះ ដូច្នេះ ។

អមាត្យកាន់បន្ទះមាស ហើយដើរប្រកាសក្នុងព្រះនគរគ្រប់កន្លែង លំដាប់នោះ សេដ្ឋីបុត្រក៏ចូលទៅកាន់ក្រុងពារាណសី ស្តាប់ពាក្យនោះហើយ ចូលទៅ

កាន់សម្នាក់អមាត្យពោលថា ខ្ញុំនឹងទូលអំពីម្រឹគនោះដល់ព្រះរាជាបាន សូមអ្នកនាំខ្ញុំចូលគាល់ព្រះរាជាចុះ ។ អមាត្យចុះអំពីដំរី នាំបុរសនោះទៅកាន់សម្នាក់របស់ព្រះរាជា ក្រាបទូលថា បពិត្រព្រះសម្មតិទេព បានឮថា បុរសនេះពោលថា នឹងក្រាបទូលដល់ម្រឹគនោះបាន ។ ព្រះរាជាត្រាស់សួរថា នែបុរស ពិតឬ កាលបុរសនោះក្រាបទូលថា បពិត្រមហារាជ ជាការពិត សូមទ្រង់ប្រទានយសនោះដល់ទូលបង្គំចុះ ហើយពោលគាថាទី ២ ថា

សូមព្រះអង្គប្រទានស្រុកសួយ និងពួកនាងនារីដែលស្អិតស្អាង
ដល់ទូលព្រះបង្គំជាខ្ញុំចុះ ទូលព្រះបង្គំជាខ្ញុំ នឹងក្រាបទូលម្រឹគនោះ
ជាម្រឹគដ៏ឧត្តមជាងម្រឹគទាំងឡាយ ដល់ព្រះអង្គ ដូច្នេះ ។

ព្រះរាជាទ្រង់ស្តាប់ពាក្យនោះហើយ ប្រោសប្រាណដល់បុរសទ្រុស្តមិត្តនោះ ទើបត្រាស់សួរថា នែបា ម្រឹគនោះ នៅឯណា កាលបុរសនោះក្រាបទូលថា ក្នុងទីឈ្មោះនោះ ទ្រង់ក៏ធ្វើបុរសនោះឲ្យជាមគ្គុទ្ទេស ចូលទៅកាន់ទីនោះដោយរាជបរិវារធំ ។ លំដាប់នោះ បុរសទ្រុស្តមិត្តក្រាបទូលព្រះរាជាថា បពិត្រព្រះសម្មតិទេព សូមទ្រង់ឲ្យសេនាឈប់ កាលសេនាឈប់ស្រេចបាច់ហើយ ក៏ក្រាបទូលយាងព្រះរាជា ហើយលើកដៃចង្អុលថា បពិត្រព្រះអង្គ សុវណ្ណម្រឹគនោះ នៅក្នុងទីនោះ ហើយពោលគាថាទី ៣ ថា

ដើមស្វាយ និងដើមសាលព្រឹក្ស ក្នុងដងព្រៃទុំះ មានផ្ការីក
( ផែនដី ) ដ៏ដេរដាសដោយស្មៅ មានសម្ផស្សស្រួល មាន
ពណ៌ក្រហម ដូចជាសម្បុរនៃសត្វមេភ្លៀង ម្រឹគទុំះ ឋិតនៅក្នុង

ដងព្រៃនោះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឥន្ទគោបកសញ្ញា** សេចក្ដីថា បុគ្គលទ្រុស្តមិត្តនោះ ក្រាបទូលថា ដងព្រៃនោះ ដេរដាសដោយតិណជាតិ មានសម្ផស្សជាសុខ មានពណ៌ក្រហម ដូចពណ៌នៃមេក្ទៀង ខៀវស្រងាត់ដូចសម្ទូង ក្នុងដងព្រៃគួរជាទីត្រេកអរនោះ ប្រើសមាសនោះ នៅក្នុងទីនោះ ។

ព្រះរាជា ទ្រង់ទទួលពាក្យរបស់បុរសនោះហើយ កាលត្រាស់បញ្ជាពួកអមាត្យថា អ្នកទាំងឡាយ និងអ្នកដែលកាន់អាវុធ ចូរនាំគ្នាព័ទ្ធដងព្រៃនោះដោយរហ័ស កុំឲ្យម្រឹគនោះគេចទៅបាន ជនទាំងនោះបានធ្វើតាមព្រះតម្រាស់នោះ ហើយនាំគ្នាស្រែកឡើង ព្រះរាជាទ្រង់ប្រថាប់ឈរក្នុងចំណែកម្ខាង ជាមួយមនុស្សទាំង ២-៣ នាក់ ។ បុរសនោះ ក៏ឈរមិនឆ្ងាយ ។ ព្រះមហាសត្វស្ដាប់សំឡេងនោះហើយ ត្រិះរិះថា សំឡេងរបស់ពួកពលព្រះរាជា ភ័យរបស់អញកើតអំពីបុរសនោះ ។ ព្រះមហាសត្វក្រោកឡើង ឃើញពួកបរិស័ទក្នុងទីដែលប្រថាប់ឈរនៃព្រះរាជានោះ គិតថា សួស្ដីគង់នឹងមានដល់អញ អញគួរទៅក្នុងទីនោះឯង ហើយដើរសំដៅព្រះរាជា ។ ព្រះរាជាទ្រង់ទតឃើញប្រើសមាសនោះកំពុងដើរមក ទ្រង់ព្រះតម្រិះថា ម្រឹគមានកម្លាំងដូចស្ដេចដំរី គួរស្ទុះចូលមកវៃអញបាន អញត្រូវផ្ទាប់ព្រួញសម្ទុតឲ្យម្រឹគនោះខ្លាច បើម្រឹគនេះគេចទៅ អញនឹងបាញ់ធ្វើឲ្យខ្សោយកម្លាំង ហើយសឹមចាប់យក ទ្រង់លើកព្រួញឡើងតម្រង់ព្រះពោធិសត្វ ។

ព្រះសាស្ដា កាលទ្រង់ប្រកាសសេចក្ដីនោះ ទើបត្រាស់គាថា ២ ថា

ព្រះបាទព្រហ្មទត្ត ទ្រង់យឺតព្រះទម្រង់កៅទណ្ឌ ផ្ទាប់កាំសរ ហើយស្តេចចូលតម្រង់ទៅ ឯម្រឹគក្រឡេកឃើញព្រះរាជាហើយ ក៏ទូលអង្វរពីចម្ងាយថា បពិត្រមហារាជ សូមព្រះអង្គឈប់សិន បពិត្រព្រះអង្គប្រសើរក្នុងរថ សូមព្រះអង្គកុំបាញ់ទូលព្រះបង្គំជាខ្ញុំឡើយ នរណាអេះ បានក្រាបទូលដំណើរនេះដល់ព្រះអង្គថា ម្រឹគនុ៎ះ ឋិតនៅក្នុងដងព្រៃនុ៎ះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អាទេជ្ជំ** សេចក្តីថា ទ្រង់យឺតធ្នូ មួយអន្ទើដោយព្រួញ ។ បទថា **សន្ធយ្ហ** បានដល់ ផ្ទាប់ព្រួញហើយ ។ បទថា **អាគមេហិ** សេចក្តីថា ស្តេចម្រឹគពោលដោយវាចាដ៏ពីរោះថា បពិត្រមហារាជ សូមទ្រង់បង្អង់សិន សូមទ្រង់កុំបាញ់ទូលបង្គំឡើយ សូមទុកជីវិតឲ្យទូលបង្គំចុះ ។

ព្រះរាជា ទ្រង់ជាប់ព្រះហឫទ័យក្នុងមធុរកថារបស់ព្រះពោធិសត្វនោះ ទ្រង់ទម្លាក់ព្រួញ ប្រថាប់ឈរដោយព្រះអាការដែលគួរគោរព ។ ព្រះមហាសត្វចូលទៅក្បែរព្រះរាជា ទ្រង់ធ្វើមធុរបដិសណ្ឋារៈ ហើយឈរក្នុងចំណែកម្ខាង ចំណែកមហាជនក៏នាំគ្នាដាក់អាវុធទាំងពួង នាំគ្នាចោមរោមព្រះរាជា ។ ខណៈនោះ ព្រះពោធិសត្វក្រាបទូលសួរព្រះរាជាដោយសំឡេងដ៏ពីរោះ ហាក់បីដូចបុគ្គលអង្រួនកណ្តឹងមាសថា

នរណាអេះ បានក្រាបទូលដំណើរនេះដល់ព្រះអង្គថា ម្រឹគនុ៎ះ ឋិតនៅក្នុងដងព្រៃនុ៎ះ ដូច្នេះ ។

ខណៈនោះ បុរសចិត្តបាបថយទៅបន្តិច ហើយឈរត្រង់នោះឯង ។

ព្រះរាជាត្រាស់ប្រាប់ថា បុគ្គលនេះប្រាប់ដល់យើង ទើបត្រាស់ព្រះគាថាទី ៦ ថា

នែសម្លាញ់ បុរសជាអ្នកប្រព្រឹត្ត អំពើលាមកនុ៎ះ ឋិតនៅអំពី
ចម្ងាយ បុរសនោះបានប្រាប់ដំណើរនេះ ដល់យើងថា ម្រឹគនុ៎ះ
ឋិតនៅក្នុងទីនុ៎ះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ចាបចរោ** បានដល់ ដែលលះបង់ការប្រព្រឹត្តប្រពៃ ។

ព្រះមហាសត្វ កាលស្តាប់ពាក្យនោះហើយ តិះដៀលបុគ្គលទ្រុស្តមិត្តនោះហើយ កាលនឹងចរចាប្រាស្រ័យជាមួយព្រះរាជា ពោលគាថាទី ៧ ថា

បានឮមកថា នរជនពួកខ្លះ ក្នុងលោកនេះ បានពោលពាក្យពិត
យ៉ាងនេះថា កំណាត់ឈើដែលគេស្រង់ឡើង ប្រសើរជាង ឯ
នរជនពួកខ្លះ ដែលគេស្រង់ឡើង មិនប្រសើរទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឋិតាវតំ** បានដល់ អណ្តែតលើទឹក ។ បទថា **ឯកច្ចិយោ** សេចក្តីថា បណ្ឌិតក្នុងកាលមុនពោលថា តែបុគ្គលពួកខ្លះជាអ្នកមានសន្តានបាប ជាអ្នកទ្រុស្តមិត្ត កំពុងជិតស្លាប់ក្នុងទឹក បានទទួលការជួយស្រោចស្រង់ឡើងមកបាន ក៏មិនប្រសើរឡើយ ព្រោះកំណាត់ឈើគង់ប្រព្រឹត្តទៅដើម្បីឧបការៈដោយប្រការផ្សេងៗ ចំណែកបុគ្គលទ្រុស្តមិត្តមានតែបំផ្លាញ ព្រោះហេតុនោះ កំណាត់ឈើប្រសើរ ជាងបុគ្គលនោះពន់ពេកតែទូលបង្គំ មិនបានធ្វើតាមពាក្យរបស់បុរាណបណ្ឌិតទាំងនោះ ។

ព្រះរាជាទ្រង់ស្តាប់ដូច្នោះហើយ ទើបត្រាស់គាថាបន្តថា

ម្នាលម្រឹគ អ្នកតិះដៀលម្រឹគទាំងឡាយ ឬបក្សីទាំងឡាយ ឬក៏មនុស្សទាំងឡាយ យើងមានភ័យច្រើន ព្រោះតែពួកអ្នកនិយាយជាភាសាមនុស្ស ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **មិគានំ** ព្រះរាជាត្រាស់សួរថា អ្នកតិះដៀលពួកម្រឹគណាមួយ ឬពួកបក្សី ឬពួកមនុស្ស ។ បទថា **ភយំ ហិ មំ វន្ទតិ** សេចក្ដីថា យើងខ្លាច គឺមិនជាឥស្សរៈដល់ខ្លួនឯង មានតែសេចក្ដីខ្លាច ( ប៉ុណ្ណោះ ) ។ បទថា **អនប្បរូបំ** បានដល់ ច្រើន ។

លំដាប់នោះ ព្រះមហាសត្វកាលនឹងសម្ដែងថា បពិត្រមហារាជ ទូលបង្គំមិនបានតិះដៀលម្រឹគជាដើម តែតិះដៀលពួកមនុស្ស ទើបពោលគាថាទី ៩ ថា

ខ្ញុំបានស្រង់មនុស្សណា ដែលរសាត់ទៅក្នុងផ្លូវទឹក មានទឹកច្រើន ទឹកជ្រៅ មានខ្សែទឹកហូររហ័ស ( ឥឡូវ ) ភ័យមានមកដល់ទូលព្រះបង្គំជាខ្ញុំហើយ ព្រោះហេតុតែស្រង់មនុស្សនោះ បពិត្រមហារាជ ការរួបរួមនឹងអសប្បុរស តែងនាំមកនូវសេចក្ដីទុក្ខ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វាហនេ** សេចក្ដីថា ក្នុងស្ទឹងគង្គាដែលអាចកួចបុគ្គលដែលធ្លាក់ហើយទៅបាន ។ បទថា **មហោទកេ សលិលេ** សេចក្ដីថា មានទឹកច្រើន គឺមានក្រសែហូរខ្ទួលខ្ទាញ់ ។ ព្រះមហាសត្វសម្ដែងអន្ទង់ទឹកគង្គានោះឯង ថាមានទឹកច្រើនដោយបទទាំងពីរ ។ បទថា **តតោនិទានំ**

សេចក្តីថា បពិត្រមហារាជ បុគ្គលណាដែលទ្រង់ចង្អុលបង្ហាញ ឲ្យទូលបង្គំមើលនោះ កំពុងអណ្តែតទៅក្នុងស្ទឹងគង្គា យំថ្ងូរគួរអាណិតក្នុងពេលយប់ ទូលបង្គំជួយស្រង់ឡើងបាន ថ្ងៃនេះ ភ័យមកដល់ទូលបង្គំ ព្រោះបុរសនេះជាហេតុ បពិត្រមហារាជ ឈ្មោះថា ការសមាគមជាមួយបុគ្គលបាប ជាទុក្ខ ។

ព្រះរាជាទ្រង់ស្តាប់ដូច្នោះហើយ ទ្រង់ព្រះពិរោធ ទ្រង់ត្រិះរិះថា បុរសនេះមិនដឹងគុណរបស់មហាសត្វ ដែលមានឧបការៈច្រើនបែបនេះ ត្រូវបាញ់បុរសនេះឲ្យស្លាប់ ហើយត្រាស់គាថាទី ១០ ថា

យើងនឹងបាញ់ព្រួញនេះទៅតាមអាកាស ជាព្រួញមានស្លាបកន្ទុយ

៤ ផ្តាច់នូវសរីរៈ ( បុរសនោះ ) ចំដើមទ្រូង យើងនឹងសម្លាប់

មនុស្សនោះ ជាមនុស្សទ្រុស្តមិត្ត ជាអ្នកធ្វើកិច្ចដែលមិនគួរធ្វើ

មិនដឹងនូវឧបការគុណ ដែលធ្វើហើយប្រាកដដូច្នោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ចតុប្បត្តំ** សេចក្តីថា ប្រកបដោយព្រួញដែលមានស្លាប ៤ ។ បទថា **វិហាឝ្គមំ** បានដល់ ជ្រែកទៅក្នុងអាកាស ។ បទថា **តនុច្ឆិទំ** បានដល់ ទម្លុះរាងកាយ ។ បទថា **ឱសជ្ជាមិ** សេចក្តីថា យើងនឹងលែងព្រួញទៅត្រង់ដើមទ្រូងបុរសនោះ ។

លំដាប់នោះ ព្រះមហាសត្វត្រិះរិះថា បុរសនេះ ចូរកុំវិនាសព្រោះអញឡើយ ទើបពោលគាថាទី ១១ ថា

បពិត្រព្រះជនិន្ទ សប្បុរសទាំងឡាយ រមែងមិនសរសើរ នូវការ

សម្លាប់របស់អ្នកប្រាជ្ញ ឬមនុស្សពាលដោយពិត សូមឲ្យមនុស្ស

អ្នកមានបាបធម៌ទៅផ្ទះតាមសេចក្ដីប្រាថ្នាចុះ កត្តណា ( ដែលព្រះអង្គត្រូវប្រទាន ) ដល់បុរសទុំះ សូមព្រះអង្គប្រទានកត្តនោះដល់បុរសទុំះចុះ ចំណែកខ្ញុំ សូមធ្វើតាមសេចក្ដីប្រាថ្នារបស់ព្រះអង្គចុះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កាមំ** សេចក្ដីថា បុរសនោះ ចូរទៅផ្ទះរបស់ខ្លួនតាមប្រាថ្នា តាមគាប់ចិត្តចុះ ។ បទថា **យញ្ចស្ស ភត្តំ តទេតស្ស ទេហិ** សេចក្ដីថា សូមទ្រង់ប្រទានវត្ថុដែលទ្រង់ត្រាស់ថា អញនឹងឲ្យវត្ថុនេះដល់បុរសនោះផងចុះ ។ បទថា **កាមករោ** សេចក្ដីថា សូមទ្រង់ធ្វើតាមបំណង គឺទ្រង់ប្រាថ្នាវត្ថុណា ក៏ចូរធ្វើវត្ថុនោះចុះ ដោយអត្ថថា នឹងសោយសាច់ទូលបង្គំក៏បាន នឹងធ្វើទូលបង្គំឲ្យជាម្រឹគសម្រាប់កីឡាក៏បាន ទូលបង្គំនឹងធ្វើតាមបំណងរបស់ទ្រង់គ្រប់ប្រការ ។

ព្រះរាជា កាលទ្រង់ស្ដាប់ដូច្នោះហើយ ទ្រង់ពេញព្រះហឫទ័យ កាលទ្រង់សរសើរព្រះមហាសត្វ ទើបត្រាស់គាថាជាបន្ទថា

ម្នាលប្រើសមាស បណ្ដាសប្បុរសទាំងឡាយ អ្នកដែលមិនប្រទូស្តចំពោះមនុស្ស ដែលប្រទូស្តនោះ ក៏ចាត់ថា ជាសប្បុរសមួយដោយពិត មនុស្សមានបាបធម៌ ចូរទៅផ្ទះរបស់ខ្លួនតាមសេចក្ដីប្រាថ្នាចុះ កត្តណា ( ដែលយើងត្រូវឲ្យ ) ដល់បុរសទុំះ យើងនឹងឲ្យកត្តនោះ ដល់បុរសទុំះ មួយទៀត យើងនឹងឲ្យស្រុកសួយដល់អ្នក ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សតំ សោ** សេចក្ដីថា អ្នកត្រូវជាបុគ្គលម្នាក់ ក្នុងបណ្ដាសប្បុរស គឺបណ្ឌិតទាំងឡាយពិតប្រាកដ ។ បទថា **តាមវាំ** សេចក្ដីថា ព្រះរាជាទ្រង់ប្រទានពរដល់មហាសត្វថា យើងជ្រះថ្លាក្នុងធម្មកថារបស់អ្នក នឹងឲ្យស្រុកសួយ ឲ្យអភ័យដល់អ្នកតាំងអំពីនេះតទៅ ចូរអ្នកកុំមានភ័យ ទៅតាមគាប់ចិត្តចុះ ។

លំដាប់នោះ ព្រះមហាសត្វ កាលស្ទាបស្ទង់ព្រះរាជាមើលថា បពិត្រមហារាជ ធម្មតាមនុស្ស មាត់និយាយផ្សេង ធ្វើផ្សេង ទើបពោលគាថា ២ ថា

បពិត្រមហារាជ សំឡេងរបស់ចចក និងក្រៀល គេដឹងបានដោយងាយ ឯសម្ដីរបស់មនុស្ស គេដឹងបានដោយកម្រ ជាងសម្ដីសត្វនោះទៅទៀត បុរសណាមានចិត្តល្អ គេសម្គាល់ថាជាញាតិជាមិត្ត ជាសម្លាញ់ ក្នុងកាលមុន បុរសនោះ រមែងជាសត្រូវវិញក្នុងកាលជាខាងក្រោយ ដូច្នេះ ។

ព្រះរាជាទ្រង់ស្ដាប់យ៉ាងនោះហើយត្រាស់ថា នែស្ដេចម្រឹគ អ្នកកុំមើលងាយខ្ញុំយ៉ាងនេះ ខ្ញុំនឹងលះបង់រាជសម្បត្តិ ក៏មិនលះបង់ពរ ដែលឲ្យដល់អ្នកឡើយ ចូរអ្នកជឿចុះ ចូរទទួលពររបស់ខ្ញុំចុះ ។ ព្រះមហាសត្វ កាលទទួលពរអំពីសម្នាក់ព្រះរាជា សូមទទួលពរ គឺអភ័យទានដល់សព្វសត្វតាំងអំពីខ្លួនទៅ ចំណែកព្រះរាជាក៏ប្រទានពរ ហើយនាំព្រះមហាសត្វទៅកាន់ព្រះនគរ ត្រាស់ឲ្យតាក់តែងព្រះនគរ និងព្រះមហាសត្វ អារាធនាព្រះមហាសត្វ ឲ្យសម្ដែងធម៌ដល់ព្រះទេវី ។ ព្រះមហាសត្វសម្ដែងធម៌ដល់ព្រះរាជា

និងព្រះរាជបរិស័ទ តាំងអំពីដើមដល់ព្រះទេវីដោយកាសាមនុស្សយ៉ាងពីរោះ ជាស់តឿនព្រះរាជាដោយទសពិធរាជធម៌ ទូន្មានមហាជនហើយ ចូលព្រៃបោមរោមទៅដោយពួកម្រឹគ ស្នាក់នៅ ។ ព្រះរាជាទ្រង់ត្រាស់ឲ្យវាយស្គរប្រកាសក្នុងព្រះនគរថា យើងឲ្យអភ័យដល់សព្វសត្វ ។ ចាប់តាំងអំពីនោះមក បុគ្គលណាម្នាក់ មិនអាចលូកដៃពាល់ត្រូវម្រឹគ ឬបក្សីទាំងឡាយបានឡើយ ហ្វូងម្រឹគស៊ីសម្ទូងរបស់មនុស្ស បុគ្គលណា ក៏មិនអាចឃាត់បាន មហាជនទាំំគ្នាទៅកាន់លានព្រះរាជវាំង ហើយស្រែកតវ៉ា ។

ព្រះសាស្តា កាលទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់ព្រះគាថានេះថា

ពួកអ្នកជនបទក៏មកប្រជុំគ្នា ពួកអ្នកនិគមក៏មកប្រជុំគ្នា ( ហើយក្រាបទូលស្តេច ) ថា ពួកម្រឹគស៊ីស្រូវអស់ហើយ សូមព្រះសម្មតិទេព កម្ចាត់ពួកម្រឹគនោះចេញ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ធេសោ** សេចក្តីថា សូមទ្រង់ឃាត់ពួកម្រឹគនោះ ព្រះរាជាទ្រង់ស្តាប់ដូច្នោះហើយ ទើបត្រាស់ ២ គាថាថា

ចូរកុំឲ្យមានជនបទ ទាំងដែន ក៏ចូរវិនាសទៅដោយពិតចុះ យើងឲ្យអភ័យដល់ពួកបក្សីហើយ មិនប្រទូស្តប្រើសមាសទេ ។

យើងមិនមានជនបទក្តី ជនបទមិនមានដល់យើងក្តី យើងឲ្យពរដល់មិគរាជហើយ មិននិយាយពាក្យកុហកទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មាសិ** សេចក្តីថា អ្នកជនបទរបស់យើងទោះមិនមានក្តី ។ បទថា **វរំ** សេចក្តីថា យើងបានឲ្យពរដល់ប្រើសមាស

ឈ្មោះរុរុ ដែលមានពណ៌ដូចមាស និងមិនប្រទូស្តចំពោះបក្សីទាំងឡាយ ឡើយ ។

មហាជនបានស្តាប់ព្រះតម្រាស់របស់ព្រះរាជាហើយ កាលមិនអាចពោល ពាក្យណាមួយបាន ទើបនាំគ្នាចៀសចេញទៅ ។ ពាក្យនុ៎ះ បានខ្ចរខ្ចាយទៅ ហើយ ។ ព្រះមហាសត្វបានស្តាប់រឿងនោះហើយ ទើបហៅហ្វូងម្រឹគមកប្រជុំ គ្នា ទូន្មានថា តាំងអំពីនេះទៅ អ្នកទាំងឡាយកុំនាំគ្នាស៊ីសម្ទូងរបស់ពួក មនុស្សឡើយ ហើយប្រាប់ដល់ពួកមនុស្សថា សូមនាំគ្នាចងរូបស្មៅ ( ទីង មោង ) ក្នុងស្រែ ចម្ការរៀងៗ ខ្លួនចុះ ។ មនុស្សទាំងនោះ នាំគ្នាធ្វើតាម នោះ ដោយសញ្ញានោះ ហ្វូងម្រឹគមិនស៊ីសម្ទូងរហូតដល់សព្វថ្ងៃនេះ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះ មកសម្តែងហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បី ក្នុងកាលមុន ទេវទត្តក៏អកតញ្ញូដូចគ្នា ហើយទ្រង់ប្រជុំជាតកថា សេដ្ឋីបុត្រ ក្នុងកាលនោះ បានមកជាទេវទត្ត ក្នុងកាលឥឡូវនេះ ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទ ចំណែករុរុម្រឹគក្នុងកាលនោះ គឺតថាគតនេះឯង ។៚

## អដ្ឋកថា រុរុមិគជាតក ចប់

# សុត្តន្តបិដក

## សរភជាតក

[ ១១៥២ ] ( ព្រះបាទព្រហ្មទត្តបន្លឺឧទានថា ) បុរសជាបណ្ឌិតត្រូវតែប្រាថ្នា មិនគប្បីនឿយណាយទេ អាត្មាអញឃើញខ្លួនសម្រេចដូចសេចក្តីប្រាថ្នា ។

[ ១១៥៣ ] បុរសជាបណ្ឌិតត្រូវតែប្រាថ្នា មិនគប្បីនឿយណាយទេ អាត្មាអញឃើញខ្លួនដែលគេស្រង់អំពីទឹក មកលើគោក ។

[ ១១៥៤ ] បុរសជាបណ្ឌិតត្រូវតែព្យាយាម មិនគប្បីនឿយណាយទេ អាត្មាអញឃើញខ្លួន សម្រេចដូចសេចក្តីប្រាថ្នា ។

[ ១១៥៥ ] បុរសជាបណ្ឌិតត្រូវតែព្យាយាម មិនគប្បីនឿយណាយទេ អាត្មាអញឃើញខ្លួន ដែលសរភម្រឹគស្រង់អំពីទឹកមកលើគោក ។

[ ១១៥៦ ] នរជនដែលប្រកបដោយប្រាជ្ញា សូម្បីដល់សេចក្តីទុក្ខ ក៏មិនកាត់បង់សេចក្តីប៉ុនប៉ង ដើម្បីឲ្យបានសុខ ព្រោះថាផស្សៈទាំងឡាយមានច្រើន មិនជាប្រយោជន៍ក៏មាន ជាប្រយោជន៍ក៏មាន ពួកជនអ្នកមិនត្រិះរិះ រមែងចូលទៅរកសេចក្តីស្លាប់ ។

[ ១១៥៧ ] ហេតុដែលយើងមិនបានគិត ក៏ប្រែជាមានហេតុដែលយើងបានគិតហើយ ក៏ប្រែជាវិនាសទៅវិញ ភោគៈទាំងឡាយរបស់ស្ត្រីក្តី របស់បុរសក្តី មិនមែនសម្រេចមកពីការគិតឡើយ ។

[ ១១៥៨ ] ( បុរោហិតក្រាបបង្គំទូលថា ) ពីដើមព្រះអង្គជាប់តាមសរភម្រឹគក្នុងជង្គុំ ព្រះអង្គបានរស់រួចព្រះជន្មដោយសារសេចក្តីព្យាយាមរបស់សរភម្រឹគ ដែលមានចិត្តមិនរួញរា ។

[ ១១៥៩ ] សរភម្រឹគណា ធ្វើនូវការប្រពោងថ្ម បានស្រង់ព្រះអង្គឡើងអំពីរណ្តៅដែលមិនងាយឡើងរួច ហើយបានដោះព្រះអង្គដែលដល់នូវសេចក្តីទុក្ខ ឲ្យរួចពីមាត់សេចក្តីស្លាប់ ព្រះអង្គពណ៌នាសរសើរសរភម្រឹគ ដែលជាសត្វមានចិត្តមិនរួញរានោះឯង ។

[ ១១៦០ ] ( ព្រះរាជា ... ) ក្នុងពេលនោះ អ្នកឯងបានទៅក្នុងទីនោះដែរឬ ឬនរណាមួយប្រាប់ដំណើរនោះដល់អ្នក ឬក៏អ្នកជាបុគ្គលមានដំបូល គឺកិលេសបើកហើយ ជាអ្នកឃើញហេតុសព្វ ម្នាលព្រាហ្មណ៍ អ្នកមានញាណដ៏មានកម្លាំងក្លៀវក្លាឬ ។

[ ១១៦១ ] ( បុរោហិត ... ) ក្នុងពេលនោះ ទូលព្រះបង្គំជាខ្ញុំមិនបានទៅក្នុងព្រៃនោះទេ ទាំងគ្មាននរណាមួយប្រាប់ដំណើរនោះដល់ទូលបង្គំជាខ្ញុំឡើយ បពិត្រព្រះជនិន្ទ អ្នកប្រាជ្ញទាំងឡាយតែងពិចារណាសេចក្តីនៃបទ នៃគាថា និងសុភាសិតទាំងឡាយនោះ ។

[ ១១៦២ ] ( ព្រះឥន្ទ្រជ្រែកចូលក្នុងសរីរៈបុរោហិត ហើយនិយាយថា ) ព្រះអង្គផ្ទាប់ព្រះទម្រង់កាំសរ មានស្នាបកន្ទុយជាគ្រឿងសម្លាប់បុគ្គលដទៃដោយសេចក្តីព្យាយាម ពួដ៏ព្រះទម្រង់

កៅទណ្ឌហើយ នៅអល់អែកអ្វីទៀត ចូរឲ្យព្រះទម្រង់កាំសរ ដែលព្រះអង្គបាញ់ទៅហើយ សម្លាប់សរភម្រឹគឲ្យធ្លាប់ទៅ បពិត្រមហារាជ មានប្រាជ្ញាដ៏ប្រសើរ ព្រោះសរភម្រឹគនុ៎ះ នឹងបានជាក្រយាស្ងោយរបស់ព្រះរាជា ។

[ ១១៦៣ ] ( ព្រះរាជា ... ) ម្នាលព្រាហ្មណ៍ យើងដឹងថា សរភម្រឹគនោះ ជាក្រយាស្ងោយរបស់ក្សត្រិយ៍ពិតមែនហើយ តែយើងគោរពគុណដែលសរភម្រឹគធ្វើហើយក្នុងកាលមុន ហេតុនោះ យើងមិនសម្លាប់សរភម្រឹគទេ ។

[ ១១៦៤ ] ( សក្កៈ ... ) បពិត្រមហារាជ នុ៎ះមិនមែនជាសរភម្រឹគទេ នុ៎ះជាព្រះឥន្ទជាធំជាងអសុរ បពិត្រព្រះអង្គជាធំជាងមនុស្ស ព្រះអង្គសម្លាប់ព្រះឥន្ទនោះហើយ ចូរបានជាស្តេចទេវតា ។

[ ១១៦៥ ] បពិត្រមហារាជ បើព្រះអង្គនៅអល់អែកនឹងការសម្លាប់សរភម្រឹគ ដែលជាសម្លាញ់ហើយ បពិត្រព្រះអង្គប្រសើរដោយការព្យាយាមជាងនរជន ព្រះអង្គ ព្រមទាំងព្រះរាជបុត្រ ព្រះរាជទេពី នឹងធ្លាក់ទៅក្នុងវេតរណីនរកនៃព្រះយមរាជ ។

[ ១១៦៦ ] ( ព្រះរាជា ... ) យើងផង ពួកអ្នកជនបទទាំងអស់ផង បុត្រាបុត្រីផង អគ្គមហេសីផង ពួកសម្លាញ់ផង ចូរធ្លាក់ទៅក្នុងវេតរណីនរកនៃព្រះយមរាជដោយពិតចុះ យើងមិនត្រូវសម្លាប់សត្វដែលឲ្យជីវិតយើងឡើយ ។

[ ១១៦៧ ] សរភម្រឹគនេះ ជាអ្នកឲ្យជីវិតដល់យើងដែលដល់នូវសេចក្ដីលំបាកម្នាក់ឯងក្នុងព្រៃដ៏ពន្លឹក បពិត្រមហាព្រហ្ម យើងវញកដឹងនូវកិច្ចការខាងដើមបែបនោះហើយ គប្បីសម្លាប់ដូចម្ដេចបាន ។

[ ១១៦៨ ] ( សក្កៈ... ) សូមព្រះអង្គជាអ្នកញ៉ាំងមិត្រឲ្យត្រេកអរគង់ព្រះជន្មអស់កាលយូរអង្វែង សូមព្រះអង្គសោយរាជសម្បត្តិនេះក្នុងធម្មគុណ សូមឲ្យមានពួកនាងនារីចោមរោម ហើយត្រេកអរក្នុងដែនរបស់ព្រះអង្គចុះ ដូចជាវាសវៈត្រេកអរក្នុងឋានត្រៃត្រឹង្ស ។

[ ១១៦៩ ] ព្រះអង្គជាបុគ្គលមិនក្រោធ មានព្រះហឫទ័យជ្រះថ្លាជានិច្ច យកសមណព្រាហ្មណ៍ ប្រកបដោយធម៌ទាំងអស់ជាភ្ញៀវ ព្រះអង្គគួរគេសូមបាន ឲ្យទាន និងប្រើប្រាស់ខ្លួនឯងតាមសមគួរ សត្វលោកមិនតិះដៀលបាន សូមព្រះអង្គទៅកើតក្នុងឋានសួគ៌ចុះ ។

### សរភជាតកទី ១០ ចប់

## ឧទ្ទាននៃតេរសនិបាតនោះ គឺ

និយាយអំពីស្វាយដ៏ប្រសើរ ១ ដីង ១ ហង្សដ៏ប្រសើរ ១ ការនៅក្នុងព្រៃ ១ ទូតជាគម្រប់ ៥ កាលិង្គពោធិព្រឹក្ស ១ អកិត្តិតាបស ១ តក្ការិយបុរោហិត ១ ម្រឹគមាស ១ សរភម្រឹគ ១ ។

# អដ្ឋកថា

## សរភជាតក

[ ១១៥២-១១៦៩ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការព្យាករណបញ្ហា ដែលទ្រង់ត្រាស់សួរដោយសង្ខេប ព្រះធម្មសេនាបតីឆ្លើយបានយ៉ាងពិស្តារ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អាសីសេថេវ បុរិសោ** ដូច្នេះជាដើម ។

ព្រះសាស្តា ត្រាស់សួរបញ្ហានឹងព្រះថេរៈដោយសង្ខេប ក្នុងកាលណា ឆ្លើយថា ក្នុងកាលដែលទ្រង់ចុះអំពីទេវលោក ក្នុងសេចក្តីនោះ មានកថាពោលដោយសង្ខេបដូចតទៅ

ចាប់តាំងពីព្រះបិណ្ឌោលភារទ្វាជៈ កាន់យកបាត្រឈើចន្ទន៍ក្រហមក្នុងសម្នាក់របស់រាជគហសេដ្ឋីបានដោយឫទ្ធិហើយ ព្រះសាស្តាត្រាស់ហាមការធ្វើឥទ្ធិប្បាដិហារ្យដល់ភិក្ខុទាំងឡាយ ។ កាលនោះ ពួកតិរ្ថិយគិតគ្នាថា ព្រះគោតម ទ្រង់ឃាត់នូវការធ្វើឥទ្ធិប្បាដិហារ្យហើយ ឥឡូវនេះ សូម្បីខ្លួនឯងក៏ទ្រង់ធ្វើមិនបាន កាលត្រូវពួកសាវករបស់ខ្លួន ដែលមិនពេញចិត្តពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់ទាំងឡាយ កាន់យកបាត្រដោយឫទ្ធិមិនបានហើយឬ ក៏នាំគ្នាប្រាប់ថា អាវុសោទាំងឡាយ នុ៎ះមិនមែនជាការដែលពួកយើងធ្វើបានលំបាកឡើយ តែដែលពួកយើងមិនកាន់យក ព្រោះគិតថា អ្នកណានឹងប្រកាសគុណ ដែលល្អិតសុខុមរបស់ខ្លួនដល់ពួកគ្រហស្ថដើម្បីបាត្រឈើ ដែលដូចជាសាកសព ចំណែកពួកសមណសក្យបុត្ត នាំគ្នាសម្តែងកាន់យកទៅ ព្រោះជាបុគ្គលល្ងង់ ឡេះឡោះ ពួកអ្នកកុំគិតឡើយថា

ការសម្តែងឫទ្ធិជារឿងលំបាកសម្រាប់ពួកយើងឡើយ ពួកសាវករបស់សមណគោតមចូរស្ងេះទុកចុះ តែពួកយើងចង់សម្តែងឫទ្ធិជាមួយសមណគោតម បើសមណគោតមធ្វើបាដិហារ្យណាមួយ ចំណែកពួកយើងនឹងធ្វើបានទ្វេគុណ ។ ពួកភិក្ខុស្តាប់រឿងនោះហើយ នាំគ្នាក្រាបទូលថា បពិត្រព្រះមានព្រះភាគ បានឮថា ពួកតិរ្ថិយ នឹងនាំគ្នាធ្វើបាដិហារ្យ ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកតិរ្ថិយចូរនាំគ្នាធ្វើចុះ សូម្បីតថាគតក៏នឹងធ្វើដែរ ។ ព្រះបាទពិម្ពិសារទ្រង់ស្តាប់រឿងនោះ យាងមកក្រាបទូលសួរព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គ បានឮថា ទ្រង់នឹងធ្វើបាដិហារ្យឬ ព្រះសាស្តាត្រាស់ថា ពិតហើយមហារាជ ។ ព្រះរាជាទូលសួរថា បពិត្រព្រះអង្គ ទ្រង់បញ្ញត្តិសិក្ខាបទហើយមិនមែនឬ ព្រះសាស្តា ត្រាស់ថា មហាបពិត្រ ទុំះតថាគតបញ្ញត្តិដល់ពួកសាវក តែសិក្ខាបទរបស់ព្រះពុទ្ធទាំងឡាយមិនមាន ឧបមាដូចផ្កា និងផ្លែឈើក្នុងព្រះរាជឧទ្យានរបស់មហាបពិត្រ ទ្រង់ហាមដល់ជនដទៃ មិនបានហាមដល់មហាបពិត្រ យ៉ាងណា សេចក្តីនេះគប្បីឃើញ ដូច្នោះ ។ ព្រះរាជាទូលសួរបន្តថា បពិត្រព្រះអង្គ ទ្រង់ធ្វើបាដិហារ្យក្នុងទីណា ព្រះសាស្តាត្រាស់ថា ត្រង់គល់គណ្ឌម្ពព្រឹក្ស ក្បែរទ្វារក្រុងសាវត្ថី ។ ព្រះរាជាទូលសួរថា ក្នុងរឿងនោះ ពួកទូលបង្គំនឹងធ្វើអ្វីខ្លះ ព្រះសាស្តាត្រាស់ថា មិនមានអ្វីឡើយ ។

ស្អែកឡើង ព្រះសាស្តាទ្រង់ធ្វើកត្តកិច្ចស្រេច ក៏ទ្រង់ចារិកទៅ ពួកមនុស្សនាំគ្នាសួរថា បពិត្រលោកម្ចាស់ទាំងឡាយ ព្រះសាស្តាទ្រង់យាងទៅក្នុងទីណា ពួកភិក្ខុប្រាប់ថា ទៅធ្វើយមកបាដិហារ្យបង្ក្រាបតិរ្ថិយ ត្រង់គល់គណ្ឌម្ពព្រឹក្ស

ក្បែរទ្វារនគរសាវត្ថី ។ មហាជនស្តាប់ពាក្យរបស់ភិក្ខុទាំងនោះហើយ គិតថា បាដិហារ្យនឹងមានភាពអស្ចារ្យដូចម្តេច ពួកយើងត្រូវទៅមើលបាដិហារ្យនោះ ហើយបិទទ្វារផ្ទះទៅជាមួយព្រះសាស្តា ។ ពួកតិរ្ថិយនាំគ្នាប្រាប់ថា សូម្បីពួកយើង ក៏នឹងនាំគ្នាធ្វើបាដិហារ្យក្នុងទីដែលសមណគោតមធ្វើបាដិហារ្យ នាំគ្នាជាប់តាមព្រះសាស្តាទៅ ជាមួយពួកឧបដ្ឋាកដូចគ្នា ។ ព្រះសាស្តាយាងដល់នគរសាវត្ថីដោយលំដាប់ ព្រះរាជាទូលសួរថា បពិត្រព្រះអង្គ បានឮថា ទ្រង់ធ្វើបាដិហារ្យឬ ព្រះសាស្តាត្រាស់ថា នឹងធ្វើ ព្រះរាជាទូលសួរថា បពិត្រព្រះអង្គ ធ្វើក្នុងកាលណា ព្រះសាស្តាត្រាស់ថា ធ្វើក្នុងថ្ងៃទី ៧ បន្ទាប់អំពីថ្ងៃនេះ គឺក្នុងថ្ងៃ ១៥ កើត ខែអាសាឍ ។ ព្រះរាជាក្រាបទូលថា ទូលបង្គំនឹងធ្វើមណ្ឌបថ្វាយ ព្រះសាស្តាត្រាស់ថា កុំឡើយមហាបពិត្រ សក្កទេវរាជនឹងធ្វើមណ្ឌបរតនៈទំហំ ១២ យោជន៍ ក្នុងទីធ្វើបាដិហារ្យរបស់តថាគត ព្រះរាជាក្រាបទូលថា បពិត្រព្រះអង្គ ទូលបង្គំសូមប្រកាសរឿងនេះក្នុងព្រះនគរ ។ ព្រះសាស្តាត្រាស់ថា មហាបពិត្រ សូមទ្រង់ប្រកាសចុះ ។

ព្រះរាជាត្រាស់បញ្ជាធម្មឃោសកៈ ឡើងលើខ្នងដំរីដែលប្រដាប់តាក់តែងហើយ ធ្វើការឃោសនារាល់ៗ ថ្ងៃ រហូតដល់ថ្ងៃទី ៦ ថា បានឮថា ព្រះដ៏មានព្រះភាគទ្រង់ធ្វើបាដិហារ្យបង្ក្រាបពួកតិរ្ថិយ ត្រង់គល់គណ្ឌម្ពព្រឹក្ស ក្បែរនគរសាវត្ថី ក្នុងថ្ងៃទី ៧ បន្ទាប់អំពីថ្ងៃនេះ ។ ពួកតិរ្ថិយដឹងថា ទ្រង់ធ្វើបាដិហារ្យត្រង់គល់គណ្ឌម្ពព្រឹក្ស នាំគ្នាឲ្យទ្រព្យដល់ម្ចាស់ទ្រព្យ ឲ្យកាប់ដើមស្វាយដែលនៅជិតនគរសាវត្ថីចោល ។ លុះដល់ព្រឹកថ្ងៃពេញបូណ៌មី ធម្ម-

ឃោសកៈដែលប្រកាសថា ព្រះបាដិហារ្យរបស់ព្រះដ៏មានព្រះភាគ ប្រាកដក្នុងថ្ងៃនេះ ដោយអានុភាពនៃទេវតា ធម្មឃោសកៈហាក់បីដូចជាឈរប្រកាសត្រង់ទ្វារជម្ពូទ្វីបទាំងមូល ។ ជនណាម្នាក់គិតនឹងទៅ ជនទាំងនោះ ក៏ឃើញខ្លួនដល់នគរសាវត្ថីនោះឯង ។ ប្រជុំជនមានបរិមណ្ឌល ១២ យោជន៍ ។ ព្រះសាស្តាទ្រង់ចូលកាន់នគរសាវត្ថីអំពីព្រលឹម កាលប្រោសសត្វហើយ ទ្រង់យាងចេញ ។ អ្នកយាមឧទ្យានឈ្មោះគណ្ឌៈ កំពុងនាំផ្លែស្វាយទុំដែលមានផ្លែធំ ទំហំប៉ុនឆ្នាំងមកថ្វាយព្រះរាជា ជួបព្រះសាស្តាត្រង់ទ្វារព្រះនគរ គិតថា ផ្លែស្វាយទុំសមគួរដល់ព្រះតថាគតពិត ទើបបានថ្វាយ ។ ព្រះសាស្តាទ្រង់គង់ក្នុងចំណែកម្ខាង ក្បែរទ្វារនគរនោះឯង ទ្រង់សោយស្រេចហើយ ត្រាស់ថា ម្នាលអានន្ទ ចូរអ្នកឲ្យគ្រាប់ស្វាយនេះ ដល់ឧទ្យានបាលដើម្បីដាំត្រង់នេះ ដើមស្វាយនេះ នឹងមានឈ្មោះថាគណ្ឌម្ពៈ ។ ព្រះថេរៈបានធ្វើតាមនោះ ។ អ្នកយាមឧទ្យានកាយដីហើយដាំ រំពេចនោះឯង ឫសទាំងឡាយ បានជ្រែកគ្រាប់ចាក់ចូលទៅក្នុងដី ពន្លកពណ៌ក្រហមប៉ុនចន្ទោលនង្គ័លក៏តាំងឡើង កាលមហាជនកំពុងមើលនោះឯង ដើមស្វាយវាស់ដោយជុំវិញ ៥០ហត្ថ មានមែកប្រវែង ៥០ ហត្ថ ដោយកម្ពស់សោត ក៏មានប្រមាណ ១០០ ហត្ថ រំពេចនោះ ដើមស្វាយនោះក៏ចេញសំណុំផ្កា មានផ្លែច្រើន ដើមស្វាយនោះរយោនរយានដោយផ្កា និងផ្លែ មានពណ៌ដូចមាស មានរសឆ្ងាញ់ ប្រាកដដូចពេញអាកាស ពេលត្រូវខ្យល់បក់ ផ្លែក៏ជ្រុះរោយចុះ ពួកភិក្ខុដែលនាំគ្នាមកឯក្រោយ ក៏នាំគ្នាឆាន់ ។ លុះដល់ពេលល្ងាច សក្កទេវរាជទ្រង់ពិចារណា

ជ្រាបថា ការសាងវេតនមណ្ឌបដើម្បីព្រះសាស្តា ជាភារៈរបស់ពួកយើង ទ្រង់បញ្ជូនវិស្សុកម្មទេវបុត្រទៅ សាងមណ្ឌបកែវ ៧ ប្រការ មានប្រមាណ ១២ យោជន៍ ដេរដាសដោយឧប្បលខៀវ ទេវតាក្នុងម៉ឺនចក្កវាឡ នាំគ្នាមកប្រជុំដោយប្រការដូច្នេះ ។

ព្រះសាស្តា ទ្រង់ធ្វើយមកប្បាដិហារ្យ បង្ក្រាបពួកតិរ្ថិយ មិនមែនជារឿងដែលទូទៅដល់សាវ័ក ទ្រង់ជ្រាបភាពដែលជនជាច្រើននាំគ្នាជ្រះថ្លា ទ្រង់គង់លើពុទ្ធាសនៈ ទ្រង់សម្តែងធម៌ ហូងបាណជាតិ ២០ កោដិ នាំគ្នាផឹកនូវទឹកអម្រឹត ។ បន្ទាប់អំពីនោះ ទ្រង់ព្រះតម្រិះថា ព្រះពុទ្ធក្នុងកាលមុនទ្រង់ធ្វើបាដិហារ្យហើយយាងទៅក្នុងទីណា ទ្រង់ជ្រាបថា ទៅកាន់តាវត្តិង្សពិភព ទើបក្រោកចាកពុទ្ធាសនៈ ឈានព្រះបាទស្តាំជាន់ភ្នំយុគន្ធរ ព្រះបាទឆ្វេងជាន់កំពូលភ្នំសិនេរុ ហើយចាំវស្សាលើបណ្ឌុកម្ពលសិលា ត្រង់គល់បារិច្ឆត្តកព្រឹក្ស ទ្រង់សម្តែងធម្មកថាដល់ពួកទេវតាអស់កាល ៣ ខែ ។ ឯបរិស័ទ កាលមិនជ្រាបទីដែលព្រះសាស្តាយាងទៅ គិតថា ពួកយើងឃើញព្រះសាស្តាហើយសឹមនាំគ្នាទៅ នាំគ្នានៅក្នុងទីនោះអស់ត្រៃមាស ។ កាលជិតដល់ថ្ងៃបវារណា ព្រះមហាមោគ្គល្លានត្ថេរ ក៏ទៅក្រាបទូលដល់ព្រះសាស្តា ។ លំដាប់នោះ ព្រះសាស្តាត្រាស់សួរថា ឥឡូវនេះ សារីបុត្តនៅឯណា ព្រះថេរៈក្រាបទូលថា បពិត្រព្រះអង្គ លោកនៅត្រង់សង្កស្សនគរជាមួយពួកភិក្ខុ ៥០០ រូប ដែលនាំគ្នាបួស ព្រោះជ្រះថ្លាក្នុងយមកប្បាដិហារ្យ ។ ព្រះសាស្តាទ្រង់ត្រាស់ថា ម្នាលមោគ្គល្លាន ក្នុងថ្ងៃទី ៧ បន្ទាប់អំពីថ្ងៃនេះ តថាគតនឹងចុះត្រង់ទ្វារនគរ

សង្កស្សៈ ។ ពួកជនដែលត្រូវការឃើញតថាគត ចូរជំនុំគ្នាត្រង់នគរសង្កស្សៈចុះ ។ ព្រះថេរៈទទួលថា សាធុ ហើយមកប្រាប់ដល់បរិស័ទ ជួយឲ្យបរិស័ទទាំងអស់ មកដល់នគរសង្កស្សៈដែលនៅឆ្ងាយអំពីនគរសាវត្ថី ៣០ យោជន៍ ដោយកាលត្រឹមតែមួយរំពេចប៉ុណ្ណោះឯង ។ ព្រះសាស្តា ទ្រង់ចេញវស្សាបវារណាហើយ ត្រាស់ប្រាប់ដល់សក្កទេវរាជថា មហាបពិត្រ តថាគតនឹងទៅកាន់មនុស្សលោក ។

សក្កទេវរាជត្រាស់ហៅវិស្សកម្មទេវបុត្រមកត្រាស់ថា ចូរអ្នកធ្វើជណ្តើរដើម្បីព្រះទសពល យាងទៅកាន់មនុស្សលោកចុះ ។ វិស្សកម្មទេវបុត្រនោះសាងជណ្តើរ ៣ គឺជណ្តើរកណ្តាល ជាជណ្តើរកែវមណី ជណ្តើរមួយជាជណ្តើរប្រាក់ ជណ្តើរមួយជាជណ្តើរមាស ជណ្តើរទាំងអស់មានក្បាលនៅលើភ្នំសិនេរុ ជើងជណ្តើរនៅត្រង់ទ្វារសង្កស្សនគរ ចោមរោមដោយវេទិការ ដែលសម្រេចហើយដោយកែវ ៧ ប្រការ ។ ព្រះសាស្តាទ្រង់ធ្វើបាដិហារ្យបើកលោក យាងចុះតាមជណ្តើរកែវមណី ដែលមានត្រង់កណ្តាល ។ សក្កៈទ្រង់កាន់បាត្រ និងចីវរ ស្តេចសុយាម កាន់ផ្លិតវាលវីជនី សហម្បតីព្រហ្មកាន់ឆត្រ ។ ទេវតាក្នុងម៉ឺនចក្កវាឡនាំគ្នាបូជាដោយគ្រឿងក្រអូប និងមាលាដែលជាទិព្វ លុះព្រះសាស្តាយាងប្រថាប់ត្រង់ជើងជណ្តើរ ព្រះសារីបុត្តបានថ្វាយបង្គំជាបឋមនោះឯង ។ បរិស័ទដ៏សេស នាំគ្នាថ្វាយបង្គំឯក្រោយ ។ ក្នុងសមាគមនោះ ព្រះសាស្តាទ្រង់ព្រះតម្រិះថា មោគ្គល្លានប្រាកដខាងឫទ្ធិ ឧបាលិប្រាកដខាងព្រះវិន័យ តែបញ្ញាគុណរបស់សារីបុត្ត មិនទាន់ប្រាកដឡើយ ។ បានឮថា វៀរ

តថាគតដែលជាសម្មាសម្ពុទ្ធហើយ អ្នកដទៃដែលឈ្មោះថា មានបញ្ញាស្មើសារីបុត្ត មិនមានឡើយ តថាគតនឹងធ្វើបញ្ញាគុណរបស់លោកឲ្យប្រាកដ ហើយទ្រង់ចាប់ផ្ដើមសួរបញ្ហារបស់បុថុជ្ជនមុន បុថុជ្ជនពួកខ្លះ នាំគ្នាឆ្លើយបញ្ហានោះ បន្ទាប់អំពីនោះ ទ្រង់សួរបញ្ហាក្នុងវិស័យនៃពួកព្រះសោតាបន្ន ពួកព្រះសោតាបន្នប៉ុណ្ណោះ នាំគ្នាក្រាបទូលឆ្លើយនូវបញ្ហានោះ ពួកបុថុជ្ជនពុំដឹងឡើយ ។ បន្ទាប់អំពីនោះ ទ្រង់សួរបញ្ហាក្នុងវិស័យរបស់ព្រះសកទាគាមី ព្រះអនាគាមី ព្រះខីណាស្រព និងមហាសាវកដោយលំដាប់ ។ បុគ្គលដែលតាំងនៅក្នុងលំដាប់ក្រោមៗ មិនជ្រាបបញ្ហានោះឡើយ បុគ្គលដែលតាំងនៅក្នុងភូមិខាងលើប៉ុណ្ណោះ នាំគ្នាក្រាបទូលឆ្លើយនូវបញ្ហានោះ ក្នុងវិស័យនៃអគ្គ-សាវក ទើបអគ្គសាវកក្រាបទូលឆ្លើយបាន ពួកជនដទៃមិនដឹងឡើយ បន្ទាប់អំពីនោះ ត្រាស់សួរបញ្ហាក្នុងវិស័យនៃព្រះសារីបុត្តត្ថេរ ព្រះថេរៈមួយអង្គប៉ុណ្ណោះដែលអាចឆ្លើយបាន ពួកជនដទៃមិនដឹងឡើយ ពួកមនុស្សនាំគ្នាសួរថា ព្រះថេរៈដែលក្រាបទូលជាមួយព្រះដ៏មានព្រះភាគនោះមានឈ្មោះអ្វី លុះស្ដាប់ថា លោកជាធម្មសេនាបតី ដែលមានឈ្មោះថាសារីបុត្តត្ថេរ ក៏នាំគ្នាពោលថា ឱហ្ន៎ ព្រះថេរៈមានបញ្ញាច្រើនហ្ន៎ ។ ចាប់តាំងអំពីនោះ គុណ គឺបញ្ញារបស់ព្រះថេរៈក៏បានប្រាកដទៅក្នុងពពួកទេវតា និងមនុស្ស ។ គ្រានោះព្រះសាស្ដា ទ្រង់ត្រាស់សួរបញ្ហាក្នុងពុទ្ធវិស័យ ( ក្នុងខុទ្ទកនិកាយ សុត្ត-និបាត ) ជាមួយព្រះថេរៈថា

ពួកអសេក្ខបុគ្គល អ្នកមានធម៌ពិចារណាហើយ និងពួកសេក្ខ-បុគ្គលជាច្រើនណា ក្នុងសាសនានេះ បពិត្រព្រះអង្គនិទុក្ខ[១] ខ្ញុំព្រះអង្គសួរនូវសេចក្ដីប្រព្រឹត្តទៅនៃបុគ្គលទាំងនោះ ព្រះអង្គមានបញ្ញាចាស់ក្លា សូមសម្ដែងប្រាប់ដល់ខ្ញុំព្រះអង្គ ដូច្នេះ ។

ហើយព្រះសាស្ដាត្រាស់ថា ម្នាលសារីបុត្ត អ្នកគប្បីឃើញអត្ថនៃភាសិតដោយសង្ខេបនេះ បានដោយពិស្ដារដូចម្ដេចហ្ន៎ ។ ព្រះថេរៈពិនិត្យមើលបញ្ហាហើយ ឃើញថា ព្រះសាស្ដាត្រាស់សួរបដិបទា ដែលជាផ្លូវនាំឲ្យសម្រេចនៃព្រះសេក្ខៈ និងអសេក្ខៈជាមួយអាត្មាអញ អស់នូវសេចក្ដីសង្ស័យ គង់សង្ស័យក្នុងអធ្យាស្រ័យថា បដិបទាដែលជាផ្លូវនាំឲ្យសម្រេច ពោលដោះស្រាយបានដោយមុខដ៏ច្រើន ដោយអំណាចខន្ធជាដើម កាលអាត្មាអញក្រាបទូលឆ្លើយដោយអាការណា ទោះបីជាអាចទាញយកព្រះអធ្យាស្រ័យរបស់ព្រះសាស្ដាបាន ។ ព្រះសាស្ដាទ្រង់ជ្រាបថា សារីបុត្តអស់សង្ស័យក្នុងបញ្ហា តែសង្ស័យក្នុងអធ្យាស្រ័យរបស់តថាគត បើតថាគតមិនឲ្យន័យ សារីបុត្តមិនអាចឆ្លើយបាន តថាគតត្រូវឲ្យន័យដល់សារីបុត្ត កាលប្រទានន័យ ទើបត្រាស់ថា ម្នាលសារីបុត្ត អ្នកពិចារណាឃើញភូតនេះ ។ បានឮថា ព្រះសាស្ដា ទ្រង់មានបរិវិតក្កយ៉ាងនេះថា កាលសារីបុត្តកាន់យកអធ្យាស្រ័យរបស់តថាគតហើយឆ្លើយ ត្រូវឆ្លើយដោយអំណាចខន្ធ ។ លុះព្រះសាស្ដា ទ្រង់ប្រទានន័យ

---

១- បានជាលោកប្រើពាក្យថា បពិត្រព្រះអង្គនិទុក្ខ ព្រោះបញ្ហានេះ ព្រះសាស្ដាទ្រង់និម្មិតជាព្រះពុទ្ធ ហើយទ្រង់ត្រាស់សួរព្រះពុទ្ធនិម្មិតដោយព្រះអង្គឯង ។

បញ្ហានោះ ក៏ច្បាស់ដល់ព្រះថេរៈរាប់រយរាប់ពាន់ន័យ ។ ព្រះថេរៈកាន់យក តាមន័យដែលព្រះសាស្តាទ្រង់ប្រទាន ក្រាបទូលឆ្លើយបញ្ហាក្នុងពុទ្ធវិស័យបាន ព្រះសាស្តាទ្រង់សម្តែងធម៌ដល់បរិស័ទប្រមាណ ១២ យោជន៍ ។ បាណជាតិ ៣០ កោដិ បានផឹកនូវអមតៈហើយ ។ ព្រះសាស្តាទ្រង់បញ្ជូនបរិស័ទ ហើយ យាងដល់នគរសាវត្ថីដោយលំដាប់ ។ ស្អែកឡើង ទ្រង់យាងទៅប្រោសសត្វ ក្នុងនគរសាវត្ថី ទ្រង់ត្រឡប់អំពីបិណ្ឌបាតហើយ ពួកភិក្ខុនាំគ្នាសម្តែងវត្ត ស្រេចហើយ ទ្រង់ក៏យាងចូលក្នុងព្រះគន្ធកុដិ លុះដល់ពេលល្ងាច ពួកភិក្ខុនាំ គ្នាអង្គុយក្នុងធម្មសភា ហើយពោលដល់គុណកថារបស់ព្រះថេរៈថា អាវុសោ ទាំងឡាយ ព្រះសារីបុត្តប្រកបដោយបុថុប្បញ្ញា ជវនប្បញ្ញា តិក្ខប្បញ្ញា និព្វេធិកប្បញ្ញា ក្រាបទូលឆ្លើយនូវបញ្ហា ដែលព្រះទសពលត្រាស់សួរដោយ សង្ខេប បានយ៉ាងពិស្តារ ។ ព្រះសាស្តាយាងមក ហើយត្រាស់សួរថា ម្នាល ភិក្ខុទាំងឡាយ អំបាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំគ្នាដោយរឿងអ្វី កាលភិក្ខុ ទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន សារីបុត្តធ្លាប់ពោលឆ្លើយអត្ថនៃភាសិតដោយសង្ខេប បាន យ៉ាងពិស្តារដូចគ្នា ហើយទ្រង់នាំអតីតនិទានមកសាធកៈដូចតទៅ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងកំណើតរមាំង ( សត្វសរកម្រឹគ ) អាស្រ័យនៅក្នុង ព្រៃ ។ ព្រះរាជាទ្រង់សព្វព្រះរាជហឫទ័យក្នុងការបាញ់ម្រឹគ ទ្រង់សម្បូរដោយ

កម្លាំង រហូតដល់ទ្រង់មិនឲ្យតម្លៃមនុស្សដទៃ ថាជាមនុស្សឡើយ ។ ថ្ងៃមួយ ទ្រង់យាងទៅប្រមាញ់ម្រឹគ ត្រាស់ជាមួយពួកអមាត្យថា បើម្រឹគរត់ទៅតាមមុខអ្នកណា យើងនឹងដាក់អាជ្ញាដល់អ្នកនោះ ព្រោះហេតុនោះឯង ។ ជនទាំងនោះគិតគ្នាថា ជូនកាល ម្រឹគនៅក្នុងការឡោមព័ទ្ធហើយ គង់រត់ប្រជ្រៀតទៅបាន ពួកយើងត្រូវនាំគ្នាកៀងម្រឹគដែលប្រាកដខ្លួនហើយ ឲ្យរត់ទៅផ្លូវដែលព្រះរាជាទ្រង់ប្រថាប់ ដោយឧបាយណាមួយឲ្យបាន កាលគិតគ្នាហើយ ក៏ធ្វើកតិកាឲ្យឱកាសផ្លូវត្រង់ចន្លោះអំពីព្រះរាជា ជនទាំងនោះនាំគ្នាព័ទ្ធព្រៃល្បោះ វាយផែនដីដោយដំបងជាដើម ។ ជាបឋម រមាំងក្រោកឡើងរត់ទ្ធេទ្ធាបីជុំ កាលនឹងគេច ក៏សម្លឹងមើលឱកាសដែលត្រូវគេច ឃើញមនុស្សដទៃកាន់ធ្នូតម្រៀបគ្នា ដៃទល់ដៃ ធ្នូទល់ធ្នូ ក្នុងទិសដ៏សេស ទីដែលព្រះរាជាប្រថាប់ឈរប៉ុណ្ណោះ ដែលឃើញចន្លោះ ។ រមាំងនោះ កាលរត់ទៅតម្រង់ព្រះរាជា ដូចគ្នានឹងបាចខ្សាច់ដាក់ភ្នែកដែលកំពុងបើក ។ ព្រះរាជាឃើញរមាំងនោះមានកម្លាំង ក៏លែងព្រួញទៅ ព្រួញក៏រត់ខុសទិសដៅ ធម្មតារមាំងជាសត្វឈ្លាសក្នុងមាយាម្រឹគ កាលព្រួញមកចំពោះមុខ ក៏ក្រាបដោយរហ័ស ហើយឈប់ស្ងៀម កាលព្រួញមកពីក្រោយ ក៏ទៅដោយរហ័ស កាលព្រួញមកអំពីលើក៏បែរខ្នង កាលព្រួញមកពីចំហៀង ក៏គេចបន្តិច កាលព្រួញបាញ់មកត្រង់ពោះ ក៏ផ្តួលខ្លួនរមៀលទៅ កាលព្រួញហួសទៅហើយ ក៏រត់ដោយកម្លាំងដ៏រហ័ស ដូចវលាហកៈត្រូវខ្យល់បក់ទៅ ដូច្នោះ ។

ព្រះរាជាអង្គនោះ កាលរមាំងផ្តួលខ្លួនរមៀលទៅ ទ្រង់បន្លឺសីហនាទថា

យើងបាញ់រមាំងបានហើយ រមាំងស្ទុះក្រោកឡើងរត់ទៅដោយរហ័ស ដូចខ្យល់ទម្លាយវង្វង់ទៅបាន ។ ពួកអមាត្យដែលឈរក្នុងទិសទាំងពីរ ឃើញរមាំងគេចទៅហើយ ក៏នាំគ្នាសួរដោយសំឡេងដូចគ្នាថា ម្រឹគចេញទៅតាមផ្លូវអ្នកណាហ្ន៎ ហើយក៏នាំគ្នាឆ្លើយថា តាមផ្លូវដែលព្រះរាជាទ្រង់ប្រថាប់ឈរ ។ ព្រះរាជាក៏ត្រាស់ថា យើងបាញ់បានហើយ ជនទាំងនោះក៏ទូលសួរថា អ្វីដែលទ្រង់បាញ់បាន ជនទាំងនោះក៏នាំគ្នាសើចចំអកព្រះរាជា ដោយប្រការផ្សេងៗថា ម្នាលគ្នាយើង ព្រះរាជានៃយើងទាំងឡាយទ្រង់បាញ់មិនខុសសោះ ទ្រង់បាញ់ផែនដីបានហើយ ។ ព្រះរាជាទ្រង់ព្រះតម្រិះថា ជនទាំងនេះចំអកឲ្យអញប្រហែលជាមិនដឹងថ្វីដៃអញឡើយ អញត្រូវចងក្បិនដើរទៅនោះឯង ប្រើព្រះខ័នចាប់រមាំងឲ្យបាន ហើយទ្រង់រត់ទៅដោយរហ័ស កាលទ្រង់ឃើញរមាំងនោះហើយ ក៏ទ្រង់ដេញតាមទៅអស់ ៣ យោជន៍ ។ រមាំងចូលទៅកាន់ព្រៃហើយ ព្រះរាជាក៏ចូលទៅកាន់ព្រៃដូចគ្នា ។ ក្នុងព្រៃនោះ ក្នុងផ្លូវដែលរមាំងរត់ទៅមានអណ្ដូង ជម្រៅប្រមាណ ៦០ ហត្ថ កើតអំពីឈើធំដែលពុកផុយ អណ្ដូងនោះមានទឹកប្រមាណ ៣០ ហត្ថ ត្រូវស្មៅបិទបាំងជុំជិត រមាំងបានក្លិនទឹក ក៏ដឹងថា មានអណ្ដូង ទើបវាងបន្តិចហើយ លោតឆ្លងទៅ ។ ចំណែកព្រះរាជាទ្រង់យាងទៅត្រង់ ក៏ជ្រុលធ្លាក់ក្នុងអណ្ដូងនោះ ។ រមាំងមិនបានឮសំឡេងសន្ទឹកព្រះបាទរបស់ព្រះរាជា សម្លឹងមើលមិនឃើញ ជ្រាបថាប្រហែលជាធ្លាក់ក្នុងអណ្ដូងហើយ ដើរមកសម្លឹងមើល ឃើញព្រះរាជាមិនមានទីទំ លំបាកនៅក្នុងទឹកជ្រៅ មិនបានដាក់ចិត្តដល់កំហុសដែលព្រះរាជាធ្វើ

ឡើយ កើតសេចក្ដីករុណា គិតថា ព្រះរាជាកុំវិនាសចំពោះមុខអញឡើយ អញនឹងជួយទ្រង់ឲ្យផុតចាកទុក្ខនេះ ហើយឈរត្រង់មាត់អណ្ដូងពោលថា មហារាជទ្រង់កុំខ្លាចឡើយ ខ្ញុំនឹងជួយទ្រង់ឲ្យផុតទុក្ខ ហើយទម្លាក់ដុំថ្ម ( ឲ្យទឹកឡើង ) ដើម្បីជួយព្រះរាជាឲ្យឡើងពីអណ្ដូង ដូចបុគ្គលធ្វើឧស្សាហ៍ទម្លាក់ដុំថ្ម ដើម្បីជួយកូនជាទីស្រឡាញ់របស់ខ្លួនឲ្យឡើងអំពីអណ្ដូង ដូច្នោះ ជួយព្រះរាជាដែលយាងមក ដោយគិតថា អញនឹងបាញ់ឲ្យឡើងអំពីជ្រោះជម្រៅ ៦០ ហត្ថ បានលួងលោមព្រះរាជាឲ្យឡើងលើខ្នង នាំចេញអំពីព្រៃ ដាក់ចុះក្នុងទីមិនឆ្ងាយអំពីសេនា ឲ្យឱវាទដល់ព្រះរាជា ឲ្យទ្រង់រក្សាសីល ៥ ។

ព្រះរាជាផុតអំពីទីដែលទ្រង់ព្រាត់ប្រាសចាកមហាសត្វ ទើបត្រាស់ថា នែស្ដេចរមាំងសម្លាញ់ ចូរអ្នកមកកាន់នគរពារាណសីជាមួយយើង យើងនឹងឲ្យរាជសម្បត្តិក្នុងនគរពារាណសីដែលមានប្រមាណ ១២ យោជន៍ ឲ្យដល់អ្នក ចូរអ្នកគ្រប់គ្រងរាជសម្បត្តិនោះចុះ ស្ដេចរមាំងក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំជាសត្វតិរច្ឆាន មិនត្រូវការដោយរាជសម្បត្តិ ទោះបីទ្រង់មានបំណងល្អចំពោះខ្ញុំសោត សូមទ្រង់រក្សាសីលដែលខ្ញុំបានទូល សូមទ្រង់ឲ្យអ្នកដែនរក្សាសីលផងចុះ ឲ្យឱវាទហើយ ចូលទៅកាន់ព្រៃ ។ ព្រះរាជា មានព្រះនេត្រពោរពេញដោយព្រះអស្សុជល ទ្រង់រឭកដល់គុណរបស់រមាំងនោះរឿយៗមក កាលសេនារៀបចំក្បួនហើយ ទ្រង់ចោមរោមដោយសេនាទៅកាន់ព្រះនគរ ត្រាស់ឲ្យនាំយកជម្មភេរីទៅវាយប្រកាសថា តាំងអំពីនេះទៅ អ្នកដែនទាំងអស់ ចូរនាំគ្នារក្សាសីល ៥ ចុះ តែត្រង់មិនពោលគុណដែលព្រះមហា-

សត្វបានធ្វើដល់ទ្រង់ ឲ្យអ្នកណាម្នាក់ស្តាប់ឡើយ សោយព្រះក្រយាមានរសផ្សេងៗ ក្នុងពេលល្ងាចស្រេច ទ្រង់ផ្ទំលើព្រះទែនដែលជាព្រះបន្ទំ លុះពេលទៀបភ្លឺ ទ្រង់រឭកដល់គុណរបស់ព្រះមហាសត្វ ទ្រង់ក្រោកឡើងប្រថាប់គន់ពត់ភ្នែនលើកម្រាល មានព្រះហឫទ័យពេញដោយបីតិ ទ្រង់បន្លឺព្រះឧទាន ៦ គាថាថា

បុរសជាបណ្ឌិត ត្រូវតែប្រាថ្នា មិនគប្បីនឿយណាយទេ អាត្មាអញ ឃើញខ្លួនសម្រេចដូចសេចក្តីប្រាថ្នា ។

បុរសជាបណ្ឌិតត្រូវតែប្រាថ្នា មិនគប្បីនឿយណាយទេ អាត្មាអញឃើញខ្លួនដែលគេស្រង់អំពីទឹកមកលើគោក ។

បុរសជាបណ្ឌិតត្រូវតែព្យាយាម មិនគប្បីនឿយណាយទេ អាត្មាអញឃើញខ្លួន សម្រេចដូចសេចក្តីប្រាថ្នា ។

បុរសជាបណ្ឌិតត្រូវតែព្យាយាម មិនគប្បីនឿយណាយទេ អាត្មាអញឃើញខ្លួន ដែលសរភម្រឹគស្រង់អំពីទឹកមកលើគោក ។

នរជនដែលប្រកបដោយប្រាជ្ញា សូម្បីដល់សេចក្តីទុក្ខ ក៏មិនកាត់បង់សេចក្តីប៉ុនប៉ង ដើម្បីឲ្យបានសុខ ព្រោះថា ផស្សៈទាំងឡាយមានច្រើន មិនជាប្រយោជន៍ក៏មាន ជាប្រយោជន៍ក៏មាន ពួកជនអ្នកមិនត្រិះរិះ រមែងចូលទៅរកសេចក្តីស្លាប់ ។

ហេតុដែលយើងមិនបានគិត ក៏ប្រែជាមាន ហេតុដែលយើងបានគិតហើយ ក៏ប្រែជាវិនាសទៅវិញ ភោគៈទាំងឡាយរបស់ស្ត្រីក្តី

របស់បុរសក្តី មិនមែនសម្រេចមកពីការគិតឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អាសីសេថេវ** សេចក្តីថា បុគ្គលមិនគប្បី ធ្វើការកាត់នូវការប្រាថ្នាចោល ហើយធ្វើនូវការប្រាថ្នាក្នុងកម្មរបស់ខ្លួនប៉ុណ្ណោះ មិនគប្បីនឿយណាយឡើយ ។ បទថា **យថា ឥច្ឆឹ** សេចក្តីថា ព្រះបាទព្រហ្មទត្តទ្រង់សម្តែងថា ពិតហើយ ខ្ញុំប្រាថ្នានឹងឡើងអំពីជ្រោះ ដែលមានជម្រៅ ៦០ ហត្ថ ខ្ញុំនោះឡើងមកបាន គឺឡើងអំពីជ្រោះបាននោះឯង ។ បទថា **អហិតា ហិតា ច** សេចក្តីថា ផស្សៈដែលជាទុក្ខក៏មាន ដែលជាសុខក៏មាន ដោយអត្ថថា ផស្សៈដើម្បីសេចក្តីស្លាប់ ផស្សៈដើម្បីរស់នៅដូច្នោះក៏មាន ។ ព្រះរាជាទ្រង់សម្តែងថា ពិតហើយ ផស្សៈដើម្បីការស្លាប់ ឈ្មោះថា មិនឧបការៈដល់ពួកសត្វ ផស្សៈដើម្បីការរស់នៅ ឈ្មោះថា ឧបការៈ ផស្សៈដើម្បីការស្លាប់ សូម្បីពួកសត្វនោះ មិនដាក់ចិត្ត គឺមិនចង់គិតក៏មកដល់បាន ។ បទថា **អចិន្តិតម្បិ** សេចក្តីថា ខ្ញុំមិនធ្លាប់គិតថានឹងធ្លាក់អណ្តូង ដូច្នេះ វត្ថុដែលខ្ញុំគិត គឺនឹងសម្លាប់រមាំង តែឥឡូវនេះ វត្ថុដែលខ្ញុំគិត ក៏រលាយទៅ វត្ថុដែលមិនគិត ក៏កើតបាន ។ បទថា **ភោគា** បានដល់ បរិវារយសៗ ទាំងនេះ មិនមែនជាវត្ថុដែលសម្រេចអំពីការគិត ព្រោះហេតុនោះ បុគ្គលអ្នកមានប្រាជ្ញា គប្បីធ្វើព្យាយាមនោះឯង ដ្បិតថា បុគ្គលអ្នកមានសេចក្តីព្យាយាម រមែងធ្វើវត្ថុដែលមិនធ្លាប់គិតនោះឯង ។

កាលព្រះរាជាកំពុងបន្លឺឧទាននោះឯង អរុណក៏រះឡើង បុរោហិតមកគាល់ដើម្បីទូលសួរសេចក្តីសុខក្នុងការផ្ទុំអំពីព្រលឹម ឈរត្រង់ទ្វារ បានឮ

សំឡេងឧទានរបស់ព្រះរាជា ត្រិះរិះថា មឭលមិញ ព្រះរាជាទៅបាញ់ម្រឹគ គង់បាញ់រមាំងនោះខុស កាលត្រូវពួកអមាត្យចំអក ក៏ទ្រង់ដេញតាមរមាំង នោះដោយខត្តិយមានះថា អញនឹងសម្លាប់យួរសត្វនោះមក ក៏ជ្រុលធ្លាក់ជ្រោះ ជម្រៅ ៦០ ហត្ថ ស្តេចរមាំងមានចិត្តអាណិត មិនបានគិតដល់ទោសរបស់ ព្រះរាជា គង់នឹងជួយព្រះរាជាឡើងមកបាន ប្រហែលជាដោយហេតុនោះ ទើបទ្រង់បន្លឺឧទាន ព្រោះបានឮឧទាន ដែលមានព្យញ្ជនៈបរិបូណ៌របស់ព្រះ រាជា ហេតុការណ៍ដែលព្រះរាជា និងស្តេចរមាំងធ្វើ បានប្រាកដដល់ព្រាហ្មណ៍ ដូចស្រមោលប្រាកដដល់អ្នកឆ្លុះមុខត្រង់កញ្ចក់ដែលថ្លៃល្អ ដូច្នោះ ។ ទើប គោះទ្វារ ។ ព្រះរាជាត្រាស់សួរថា នរណា ក៏ក្រាបទូលថា ទូលបង្គំបុរោហិត ។ លំដាប់នោះ ព្រះរាជាបើកទ្វារ ហើយត្រាស់ថា ចូរមកតាមផ្លូវនេះចុះលោក អាចារ្យ បុរោហិតចូលទៅថ្វាយបង្គំព្រះរាជាហើយ ឈរក្នុងទីសមគួរ នា ចំណែកម្ខាង ក្រាបទូលថា បពិត្រមហារាជ ទូលបង្គំជ្រាបហេតុការណ៍ដែល ទ្រង់ធ្វើក្នុងព្រៃ ទ្រង់ដេញរមាំងមួយទៅធ្លាក់ជ្រោះ ហើយរមាំងនោះ ធ្វើការ ទម្លាក់ដុំថ្មជួយទ្រង់ឡើងអំពីជ្រោះបាន ទ្រង់រឭកដល់គុណរបស់រមាំងនោះ ទ្រង់ បន្លឺឧទានហើយ ទើបក្រាបទូល ២ គាថាថា

> ពីដើម ព្រះអង្គជាប់តាមសរភម្រឹគក្នុងដងភ្នំ ព្រះអង្គបានរស់រួច
> ព្រះជន្ម ដោយសារសេចក្តីព្យាយាមរបស់សរភម្រឹគ ដែលមាន
> ចិត្តមិនរួញរា ។
>
> សរភម្រឹគណា ធ្វើនូវការប្រតោងថ្ម បានស្រង់ព្រះអង្គឡើងអំពី

រណ្ដៅដែលមិនងាយឡើងរួច ហើយបានដោះព្រះអង្គ ដែលដល់នូវសេចក្ដីទុក្ខ ឲ្យរួចពីមាត់សេចក្ដីស្លាប់ ព្រះអង្គពណ៌នាសរសើរសរភម្រឹគ ដែលជាសត្វមានចិត្តមិនរួញរានោះឯង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អនុស្សរិ** បានដល់ ដេញតាមទៅ ។ បទថា **វិក្កន្តំ** សេចក្ដីថា បានធ្វើនូវព្យាយាមដើម្បីជួយឲ្យឡើង ។ បទថា **អនុជីវសិ** សេចក្ដីថា ទ្រង់មានជីវិតបាន អធិប្បាយថា ទ្រង់បានជីវិត ព្រោះអានុភាពរបស់រមាំងនោះ ។ បទថា **សមុទ្ធរិ** បានដល់ ជួយលើកឡើងហើយ ។ បទថា **ឥមេវ វណ្ណេសិ** សេចក្ដីថា ទ្រង់គង់សរសើររមាំងមាសលើទីបន្ទំដ៏មានសិរី ។

ព្រះរាជាកាលទ្រង់ស្ដាប់ដូច្នោះហើយ ទ្រង់ព្រះតម្រិះថា ព្រាហ្មណ៍នេះមិនបានទៅបាញ់ម្រឹគជាមួយអញដឹងរឿងទាំងអស់ ដឹងបានដូចម្ដេចហ្ន៎ អញត្រូវសាកសួរមើល ទើបត្រាស់គាថាទី ៩ ថា

ក្នុងពេលនោះ អ្នកឯងបាននៅក្នុងទីនោះដែរឬ ឬនរណាមួយប្រាប់ដំណើរនោះដល់អ្នក ឬក៏អ្នកជាបុគ្គលមានដំបូល គឺកិលេសបើកហើយ ជាអ្នកឃើញហេតុសព្វ ម្នាលព្រាហ្មណ៍ អ្នកមានញាណដ៏មានកម្លាំងក្លៀវក្លាឬ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ភីស្សរូបំ** សេចក្ដីថា ញាណរបស់លោកគួរមានកម្លាំងទេដឹង ព្រោះហេតុនោះ ទើបលោកដឹងសេចក្ដីនោះ ។

ព្រាហ្មណ៍កាលសម្ដែងថា ទូលបង្គំមិនមែនសព្វញ្ញុតញ្ញូ តែសេចក្ដីនៃ

ព្រះគាថា ដែលទ្រង់ញ៉ាំងព្យញ្ជនៈឲ្យក្បោះក្បាយត្រាស់ហើយ ប្រាកដដល់ទូលបង្គំបាន ទើបពោលគាថាទី ១០ ថា

ក្នុងពេលនោះ ទូលព្រះបង្គំជាខ្ញុំ មិនបាននៅក្នុងព្រៃនោះទេ ទាំងគ្មាននរណាមួយប្រាប់ដំណើរនោះ ដល់ទូលបង្គំជាខ្ញុំឡើយ បពិត្រព្រះជនិន្ទ អ្នកប្រាជ្ញទាំងឡាយ តែងពិចារណាសេចក្តីនៃបទ នៃគាថា និងសុភាសិតទាំងឡាយនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សុភាសិតានំ** សេចក្តីថា បទនៃគាថាដែលទ្រង់ត្រាស់ល្អហើយ មិនរលុបព្យញ្ជនៈ ។ បទថា **អត្ថំ តធានេន្តិ** សេចក្តីថា រមែងនាំអត្ថនៃបទរបស់គាថានោះមកពិចារណា ។

ព្រះរាជាទ្រង់ប្រោសប្រទានបុរោហិត ព្រះរាជទានទ្រព្យជាច្រើន ។ តាំងអំពីនោះ ទ្រង់ក៏ត្រេកអរតែក្នុងបុណ្យកុសល មានទានជាដើម ។ ពួកជនក៏នាំគ្នាត្រេកអរក្នុងបុណ្យ កាលស្លាប់ទៅហើយ ក៏កុះករក្នុងស្ថានសួគ៌ ។ ថ្ងៃមួយ ព្រះរាជាទ្រង់ព្រះតម្រិះថា ទ្រង់នឹងបាញ់ក្តារបន្ទោង ត្រាស់បបួលបុរោហិតហើយយាងទៅកាន់ព្រះរាជឧទ្យាន ។ កាលនោះ សក្កទេវរាជទតឃើញទេវតា និងទេវកញ្ញាថ្មីៗ ជាច្រើន ទ្រង់ពិចារណាថា ហេតុអ្វីហ្ន៎ ក៏បានជ្រាបរឿងដែលព្រះរាជាឡើងអំពីជ្រោះបានព្រោះសត្វរមាំង ហើយទ្រង់ដឹកនាំឲ្យមហាជនតាំងនៅក្នុងសីល ទ្រង់ព្រះតម្រិះថា មហាជននាំគ្នាធ្វើបុណ្យ ដោយអានុភាពរបស់ព្រះរាជា ហេតុនោះឯង ទើបទេវលោកបរិបូណ៌ ឥឡូវនេះព្រះរាជាចូលកាន់ព្រះរាជឧទ្យាន ដើម្បីបាញ់ក្តារបន្ទោង អញត្រូវសាកល្បង

ព្រះរាជាមើល ឲ្យទ្រង់បន្លឺសីហនាទ ប្រកាសគុណរបស់ខ្លួន ហើយឲ្យទ្រង់ជ្រាបភាពដែលអាត្មាអញជាសក្កៈ ហើយឈរក្នុងអាកាសសម្តែងធម៌ ពោលដល់គុណរបស់មេត្តា និងបញ្ចសីល ហើយត្រឡប់មក ដូច្នេះហើយ បានទៅកាន់ព្រះរាជឧទ្យាន ។ ចំណែកព្រះរាជាទ្រង់ព្រះតម្រិះថា នឹងបាញ់ក្ការចន្ទោង ក៏ទ្រង់យឹតធ្នូផ្ទាប់កាំសរ ។ វេលានោះ សក្កទេវរាជ បង្ហាញរូបរបស់ខ្លួនឲ្យប្រាកដក្នុងរវាងព្រះរាជា និងក្ការចន្ទោង ដោយអានុភាពរបស់ទ្រង់ ។ ព្រះរាជាទ្រង់ឃើញហើយ មិនលែងព្រួញ ពេលនោះ សក្កទេវរាជ ក៏ចូលក្នុងសរីរៈរបស់បុរោហិត បានពោលគាថាថា

ព្រះអង្គផ្ទាប់ព្រះទម្រង់កាំសរ មានស្លាបកន្ទុយ ជាគ្រឿងសម្លាប់បុគ្គលដទៃដោយសេចក្តីព្យាយាម ឱ្យដ៏ព្រះទម្រង់កៅទណ្ឌហើយ នៅអល់អែកអ្វីទៀត ចូរឲ្យព្រះទម្រង់កាំសរ ដែលព្រះអង្គបាញ់ទៅហើយ សម្លាប់សរកម្រឹគឲ្យធ្លាប់ទៅ បពិត្រមហារាជ មានប្រាជ្ញាដ៏ប្រសើរ ព្រោះសរកម្រឹគនុ៎ះ នឹងបានជាក្រយាស្ងោយរបស់ព្រះរាជា ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បត្តំ** បានដល់ ប្រកបដោយព្រួញដែលមានស្លាប ។ បទថា **បរវិរិយឃាតី** សេចក្តីថា នឹងកម្ចាត់សេចក្តីក្លៀវក្លារបស់សត្រូវដទៃ ។ បទថា **ចាបេ សរំ** សេចក្តីថា ទ្រង់យកព្រួញដែលប្រកបដោយស្លាបនោះ សិកចូលទៅក្នុងបន្ទោះហើយ ឥឡូវនេះ ទ្រង់អល់អែកអ្វីទៀត ។ បទថា **ហន្តុ** សេចក្តីថា សូមព្រួញដែលទ្រង់បាញ់ទៅហើយនោះ

សម្លាប់រមាំងនេះភ្លាមចុះ ។ បទថា **អន្នំ ហិ ឃតំ** សេចក្តីថា បពិត្រមហារាជ ទ្រង់មានប្រាជ្ញាដ៏ប្រសើរ ឈ្មោះថា រមាំង ជាព្រះក្រយាហាររបស់ព្រះរាជា លំដាប់នោះ ទើបព្រះរាជាត្រាស់គាថានេះថា

ម្នាលព្រាហ្មណ៍ យើងដឹងថា សរភម្រឹគនោះ ជាក្រយាស្ងោយ របស់ក្សត្រិយ៍ពិតមែនហើយ តែយើងគោរពគុណដែលសរភម្រឹគ ធ្វើហើយក្នុងកាលមុន ហេតុនោះ យើងមិនសម្លាប់សរភម្រឹគទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បុព្វេ កតត្ថំ** សេចក្តីថា ម្នាលព្រាហ្មណ៍ ខ្ញុំក៏ដឹងសេចក្តីនេះជាក់ច្បាស់ថា ម្រឹគជាអាហាររបស់ក្សត្រ តែខ្ញុំបូជាគុណដែលរមាំងធ្វើក្នុងកាលមុន ព្រោះហេតុនោះ ខ្ញុំមិនសម្លាប់រមាំងជាដាច់ខាត ។

លំដាប់នោះ សក្កទេវរាជត្រាស់ ២ គាថាថា

បពិត្រមហារាជ នុ៎ះមិនមែនជាសរភម្រឹគទេ នុ៎ះជាព្រះឥន្ទ ជាធំជាងអសុរ បពិត្រព្រះអង្គជាធំជាងមនុស្ស ព្រះអង្គសម្លាប់ព្រះឥន្ទនោះហើយ ចូរបានជាស្តេចទេវតា ។

បពិត្រមហារាជ បើព្រះអង្គនៅអល់អែក នឹងការសម្លាប់សរភម្រឹគដែលជាសម្លាញ់ហើយ បពិត្រព្រះអង្គប្រសើរ ដោយការព្យាយាមជាងនរជន ព្រះអង្គ ព្រមទាំងព្រះរាជបុត្រ ព្រះរាជទេពី នឹងធ្លាក់ទៅក្នុងវេតរណីនរកនៃព្រះយមរាជ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អសុរេសោ** នេះ សក្កទេវរាជត្រាស់ដោយ

បំណងថា នោះជាអសុរ នោះជាសក្កទេវរាជ ប្រសើរជាងអសុរ ។ ដោយបទថា **អមរាធិបោ** នេះ សក្កៈត្រាស់ថា សូមទ្រង់សម្លាប់សក្កៈនោះ ហើយទ្រង់នឹងបានជាសក្កទេវរាជខ្លួនឯង ។ ដោយបទថា **វេតរណឹ យមស្ស** នេះ សក្កៈធ្វើឲ្យព្រះរាជាទ្រង់តក់ស្លុតថា បើទ្រង់គិតថា ជាសម្លាញ់របស់អញ ហើយទ្រង់មិនសម្លាប់ម្រឹគនោះសោត ទ្រង់ក្តី បុត្រក្តី ព្រះជាយាក្តី នឹងត្រូវធ្លាក់ទៅវេតរណីនរករបស់ស្តេចយម ។

លំដាប់នោះ ព្រះរាជាបានត្រាស់ ២ គាថាថា

*យើងផង ពួកអ្នកជនបទទាំងអស់ផង បុត្រាបុត្រីផង អគ្គមហេសីផង ពួកសម្លាញ់ផង ចូរធ្លាក់ទៅក្នុងវេតរណីនរកនៃព្រះយមរាជដោយពិតចុះ យើងមិនត្រូវសម្លាប់សត្វដែលឲ្យជីវិតយើងឡើយ ។ សរភម្រឹគនេះ ជាអ្នកឲ្យជីវិតដល់យើង ដែលដល់នូវសេចក្តីលំបាកម្នាក់ឯង ក្នុងព្រៃដ៏ពន្លឹក បពិត្រមហាព្រហ្ម យើងរឭកដឹងនូវកិច្ចការខាងដើមបែបនោះហើយ គប្បីសម្លាប់ដូចម្តេចបានដូច្នេះ ។*

បណ្តាបទទាំងនោះ បទថា **មម ចាណទស្ស** នេះ ព្រះរាជាត្រាស់ថា នៃព្រាហ្មណ៍ បុគ្គលណាឲ្យជីវិតដល់យើង បុគ្គលណាបានឲ្យជីវិតដែលជាទីស្រឡាញ់ដល់យើងហើយ ទោះយើងទៅកាន់នរក ក៏មិនគប្បីប្រហារ មិនគប្បីសម្លាប់បុគ្គលនោះឡើយ បុគ្គលនោះមិនគប្បីត្រូវសម្លាប់ ។ បទថា **ឯកស្ស កត្តា វិវនស្មឹ ឃោរេ** សេចក្តីថា ម្រឹគនេះ ជាសត្វធ្វើគុណដល់ខ្ញុំ កាលមិន

មានសម្លាញ់ម្នាក់ចូលទៅក្នុងព្រៃជ្រៅ បានឲ្យជីវិតដល់ខ្ញុំ ខ្ញុំនោះ រម្លឹកដល់បុព្វកិច្ចបែបនោះ ដែលម្រឹគនេះធ្វើ កាលដឹងដល់គុណនោះ គប្បីសម្លាប់ដូចម្តេចកើត ។

លំដាប់នោះ សក្កទេវរាជចេញអំពីសរីរៈបុរោហិត និម្មិតអត្តភាពជាសក្កៈឈរលើអាកាស កាលទ្រង់សម្តែងគុណរបស់ព្រះរាជា ទើបត្រាស់ ២ គាថាថា

សូមព្រះអង្គជាអ្នកញ៉ាំងមិត្រឲ្យត្រេកអរ គង់ព្រះជន្មអស់កាលយូរអង្វែង សូមព្រះអង្គសោយរាជសម្បត្តិនេះ ក្នុងធម្មគុណ សូមឲ្យមានពួកនាងនារីចោមរោម ហើយត្រេកអរក្នុងដែនរបស់ព្រះអង្គចុះ ដូចជាវាសវៈត្រេកអរក្នុងឋានត្រៃត្រឹង្ស ។

ព្រះអង្គជាបុគ្គលមិនក្រោធ មានព្រះហឫទ័យជ្រះថ្លាជានិច្ច យកសមណព្រាហ្មណ៍ ប្រកបដោយធម៌ទាំងអស់ជាភ្ញៀវ ព្រះអង្គគួរគេសូមបាន ឲ្យទាន និងប្រើប្រាស់ខ្លួនឯងតាមសមគួរ សត្វលោកមិនតិះដៀលបាន សូមព្រះអង្គទៅកើតក្នុងឋានសួគ៌ចុះដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មិត្តាភិរាធី** សេចក្តីថា ទ្រង់ជាអ្នកប្រោសប្រាណមិត្ត គឺមិនទ្រុស្តមិត្ត ។ បទថា **សញ្ញាតិជី** សេចក្តីថា ទ្រង់បំពេញខ្លួនគួរដល់អ្នកសូម ទ្រង់ធ្វើសមណព្រាហ្មណ៍ដែលទ្រទ្រង់នូវធម៌ទាំងពួង ឲ្យជាភ្ញៀវគួរទទួល ។ បទថា **អនិន្ទិតោ** សេចក្តីថា ទ្រង់ជាអ្នកត្រេកអរក្នុងព្រះហឫទ័យ ព្រោះបានបំពេញបុណ្យ មានទានជាដើម នឹងមិនត្រូវសត្វលោក

និទ្ទា សូមចូលដល់នូវស្ថានសួគ៌ចុះ ។

សក្កទេវរាជា កាលត្រាស់យ៉ាងនេះហើយ ទ្រង់ជាស់តឿនព្រះរាជាថា មហារាជ ខ្ញុំមកដើម្បីចាប់កំហុសទ្រង់ ទ្រង់មិនឲ្យខ្ញុំចាប់កំហុសបាន សូមទ្រង់កុំប្រមាទ ហើយទ្រង់យាងទៅកាន់និវាស្ថានរបស់ខ្លួន ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះ មកសម្តែងហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន សារីបុត្តក៏រមែងដឹងអត្ថនៃភាសិតដោយសង្ខេប យ៉ាងពិស្តារដូចគ្នា ហើយប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទក្នុងកាលឥឡូវនេះ បុរោហិតក្នុងកាលនោះ បានមកជាសារីបុត្ត ចំណែកសរភម្រឹគក្នុងកាលនោះ គឺតថាគតដែលជាសម្មាសម្ពុទ្ធនេះឯង ។៚

**អដ្ឋកថា សរភមិគជាតក ចប់**

**តេរសនិបាត ចប់**

# ក្បាលទី ៤៨

# សុត្តន្តបិដក បាលីប្រែ -៥៩

## សន្ទឹកចង្អុលប្រាប់មាតិកា

### កច្ចានិវគ្គ


| | | |
|---|---|---|
| កច្ចានិជាតក | ...... ...... ...... ...... | ២ |
| អដ្ឋកថាកច្ចានិជាតក | ...... ...... ...... ...... | ៥ |
| អដ្ឋសទ្ទជាតក | ...... ...... ...... ...... | ១៦ |
| អដ្ឋកថាអដ្ឋសទ្ទជាតក | ...... ...... ...... ...... | ១៨ |
| សុលសាជាតក | ...... ...... ...... ...... | ៣០ |
| អដ្ឋកថាសុលសាជាតក | ...... ...... ...... ...... | ៣២ |
| សុមង្គលជាតក | ...... ...... ...... ...... | ៤០ |
| អដ្ឋកថាសុមង្គលជាតក | ...... ...... ...... ...... | ៤៣ |
| គង្គមាលជាតក...... ៥៣ | | |
| អដ្ឋកថាគង្គមាលជាតក | ...... ...... ...... ...... | ៥៥ |
| ចេតិយរាជជាតក | ...... ...... ...... ...... | ៧៣ |
| អដ្ឋកថា ចេតិយរាជជាតក | ...... ...... ...... ...... | ៧៦ |
| ឥន្ទ្រិយជាតក | ...... ...... ...... ...... | ៩០ |
| អដ្ឋកថាឥន្ទ្រិយជាតក | ...... ...... ...... ...... | ៩២ |
| អាទិត្តជាតក | ...... ...... ...... ...... | ១០៩ |
| អដ្ឋកថាអាទិត្តជាតក | ...... ...... ...... ...... | ១១១ |
| អដ្ឋានជាតក | ...... ...... ...... ...... | ១២១ |
| អដ្ឋកថាអដ្ឋានជាតក | ...... ...... ...... ...... | ១២៤ |

ទីបិជាតក ...... ...... ...... ...... ១៣២

អដ្ឋកថាទីបិជាតក ...... ...... ...... ...... ១៣៥

## នវកនិបាត

គិជ្ឈជាតក ...... ...... ...... ...... ១៤១

អដ្ឋកថាគិជ្ឈជាតក ...... ...... ...... ...... ១៤៣

កោសម្ពិយជាតក ...... ...... ...... ...... ១៤៩

អដ្ឋកថាកោសម្ពិយជាតក ...... ...... ...... ...... ១៥២

មហាសុវរាជជាតក ...... ...... ...... ...... ១៦២

អដ្ឋកថាមហាសុវរាជជាតក ...... ...... ...... ...... ១៦៥

ចុល្លសុវកករាជជាតក ...... ...... ...... ...... ១៧៣

អដ្ឋកថា ចុល្លសុវកករាជជាតក ...... ...... ...... ...... ១៧៦

ហរិតចជាតក ...... ...... ...... ...... ១៨១

អដ្ឋកថាហរិតចជាតក ...... ...... ...... ...... ១៨៣

បទកុសលមាណវកជាតក ...... ...... ...... ...... ១៩២

អដ្ឋកថាបទកុសលមាណវកជាតក ...... ...... ...... ...... ១៩៥

លោមសកស្សបជាតក ...... ...... ...... ...... ២១៧

អដ្ឋកថាលោមសកស្សបជាតក ...... ...... ...... ...... ២១៩

ចក្កវាកជាតក ...... ...... ...... ...... ២២៩

អដ្ឋកថាចក្កវាកជាតក ...... ...... ...... ...... ២៣២

ហលិទ្ទរាគជាតក ...... ...... ...... ...... ២៤១

អដ្ឋកថាហលិទ្ទរាគជាតក ...... ...... ...... ...... ២៤៣

សមុគ្គជាតក ...... ...... ...... ...... ២៤៩

អដ្ឋកថាសមុគ្គជាតក ...... ...... ...... ...... ២៥២

បូតិមំសជាតក ...... ...... ...... ...... ២៦១
អដ្ឋកថាបូតិមំសជាតក ...... ...... ...... ...... ២៦៣
ទទ្ទរជាតក ...... ...... ...... ...... ២៧២
អដ្ឋកថា ទទ្ទរជាតក ...... ...... ...... ...... ២៧៥

## ឧសកនិបាត

ចតុទ្វារជាតក ...... ...... ...... ...... ២៨៦
អដ្ឋកថាចតុទ្វារជាតក ...... ...... ...... ...... ២៨៩
កណ្ហជាតក ...... ...... ...... ...... ៣០០
អដ្ឋកថាកណ្ហជាតក ...... ...... ...... ...... ៣០៣
ចតុប្បោសថជាតក ...... ...... ...... ...... ៣២០
អដ្ឋកថា ចតុប្បោសថកជាតក ...... ...... ...... ...... ៣២៤
សង្ខជាតក ...... ...... ...... ...... ៣២៥
អដ្ឋកថាសង្ខជាតក ...... ...... ...... ...... ៣២៨
ចុល្លពោធិជាតក ...... ...... ...... ...... ៣៤១
អដ្ឋកថាចុល្លពោធិជាតក ...... ...... ...... ...... ៣៤៤
មណ្ឌព្យជាតក ...... ...... ...... ...... ៣៥៥
អដ្ឋកថា មណ្ឌព្យជាតក ...... ...... ...... ...... ៣៥៩
និគ្រោធជាតក ...... ...... ...... ...... ៣៧៥
អដ្ឋកថានិគ្រោធជាតក ...... ...... ...... ...... ៣៧៧
តក្កលជាតក ...... ...... ...... ...... ៣៨៩
អដ្ឋកថាតក្កលជាតក ...... ...... ...... ...... ៣៩២
មហាធម្មបាលជាតក ...... ...... ...... ...... ៤០៣
អដ្ឋកថាមហាធម្មបាលជាតក ...... ...... ...... ...... ៤០៦

កុក្កុដជាតក ...... ...... ...... ...... ៤១៧
អដ្ឋកថាកុក្កុដជាតក ...... ...... ...... ...... ៤២០
មដ្ឋកុណ្ឌលិជាតក ...... ...... ...... ...... ៤២៨
អដ្ឋកថាមដ្ឋកុណ្ឌលិជាតក ...... ...... ...... ...... ៤៣១
ពិលារកោសិយជាតក ...... ...... ...... ...... ៤៣៨
អដ្ឋកថាពិលារកោសិយជាតក ...... ...... ...... ...... ៤៤១
ចក្កវាកជាតក ...... ...... ...... ...... ៤៥៦
អដ្ឋកថាចក្កវាកជាតក ...... ...... ...... ...... ៤៥៨
ភូរិបញ្ហាជាតក ...... ...... ...... ...... ៤៦៤
អដ្ឋកថាភូរិបញ្ហាជាតក ...... ...... ...... ...... ៤៦៧
មហាមង្គលជាតក ...... ...... ...... ...... ៤៦៨
អដ្ឋកថាមហាមង្គលជាតក ...... ...... ...... ...... ៤៧១
ឃតបណ្ឌិតជាតក ...... ...... ...... ...... ៤៨៥
អដ្ឋកថាឃតបណ្ឌិតជាតក ...... ...... ...... ...... ៤៨៩

## ឯកាទសកនិបាត

មាតុបោសកជាតក ...... ...... ...... ...... ៥០៩
អដ្ឋកថាមាតុបោសកជាតក ...... ...... ...... ...... ៥១២
ជុណ្ហជាតក ...... ...... ...... ...... ៥២២
អដ្ឋកថាជុណ្ហជាតក ...... ...... ...... ...... ៥២៥
ធម្មទេវបុត្តជាតក ...... ...... ...... ...... ៥៣៥
អដ្ឋកថាធម្មទេវបុត្តជាតក ...... ...... ...... ...... ៥៣៨
ឧទយជាតក ...... ...... ...... ...... ៥៤៥
អដ្ឋកថាឧទយជាតក ...... ...... ...... ...... ៥៥០

បានីយជាតក ...... ...... ...... ...... ៥៦៩

អដ្ឋកថាបានីយជាតក ...... ...... ...... ...... ៥៧២

យុធញ្ជយជាតក ...... ...... ...... ...... ៥៨៣

អដ្ឋកថាយុធញ្ជយជាតក ...... ...... ...... ...... ៥៨៦

ទសរថជាតក ...... ...... ...... ...... ៥៩៥

អដ្ឋកថាទសរថជាតក ...... ...... ...... ...... ៥៩៨

សំវរជាតក ...... ...... ...... ...... ៦១៣

អដ្ឋកថាសំវរជាតក ...... ...... ...... ...... ៦១៦

សុប្បារកជាតក ...... ...... ...... ...... ៦២៩

អដ្ឋកថាសុប្បារកជាតក ...... ...... ...... ...... ៦៣២


## ទ្វាទសកនិបាត


ចុល្លកុណាលជាតក ...... ...... ...... ...... ៦៤៤

អដ្ឋកថាចុល្លកុណាលជាតក ...... ...... ...... ...... ៦៤៧

ភទ្ទសាលជាតក ...... ...... ...... ...... ៦៤៨

អដ្ឋកថាភទ្ទសាលជាតក ...... ...... ...... ...... ៦៥១

សមុទ្ទវាណិជជាតក ...... ...... ...... ...... ៦៧៦

អដ្ឋកថាសមុទ្ទវាណិជជាតក ...... ...... ...... ...... ៦៧៩

កាមជាតក ...... ...... ...... ...... ៦៩៤

អដ្ឋកថាកាមជាតក ...... ...... ...... ...... ៦៩៧

ជនសន្ធជាតក ...... ...... ...... ...... ៧១៤

អដ្ឋកថាជនសន្ធជាតក ...... ...... ...... ...... ៧១៧

មហាកណ្ហជាតក ...... ...... ...... ...... ៧២៦

អដ្ឋកថាមហាកណ្ហជាតក ...... ...... ...... ...... ៧២៩

កោសិយជាតក ...... ...... ...... ...... ៧៤១
អដ្ឋកថាកោសិយជាតក ...... ...... ...... ...... ៧៤៥
មេណ្ឌកប្បញ្ហាជាតក ...... ...... ...... ...... ៧៤៦
អដ្ឋកថាមេណ្ឌកបញ្ហាជាតក ...... ...... ...... ...... ៧៤៩
មហាបទុមជាតក ...... ...... ...... ...... ៧៥០
អដ្ឋកថាមហាបទុមជាតក ...... ...... ...... ...... ៧៥៣
មិត្តាមិត្តជាតក ...... ...... ...... ...... ៧៧១
អដ្ឋកថាមិត្តាមិត្តជាតក ...... ...... ...... ...... ៧៧៤

## តេរសនិបាត

អម្ពជាតក ...... ...... ...... ...... ៧៨០
អដ្ឋកថាអម្ពជាតក ...... ...... ...... ...... ៧៨៤
ផន្ទនជាតក ...... ...... ...... ...... ៧៩៦
អដ្ឋកថាផន្ទនជាតក ...... ...... ...... ...... ៧៩៩
ជវនហំសជាតក ...... ...... ...... ...... ៨០៦
អដ្ឋកថាជវនហំសជាតក ...... ...... ...... ...... ៨០៩
ចុល្លនារទកស្សបជាតក ...... ...... ...... ...... ៨២៣
អដ្ឋកថាចុល្លនារទកស្សបជាតក ...... ...... ...... ...... ៨២៦
ទូតជាតក ...... ...... ...... ...... ៨៣៦
អដ្ឋកថាទូតជាតក ...... ...... ...... ...... ៨៣៩
កាលិង្គពោធិជាតក ...... ...... ...... ...... ៨៤៧
អដ្ឋកថាកាលិង្គពោធិជាតក ...... ...... ...... ...... ៨៥០
អកិត្តិជាតក ...... ...... ...... ...... ៨៦៦
អដ្ឋកថាអកិត្តិជាតក ...... ...... ...... ...... ៨៧១

តក្ការិយជាតក ...... ...... ...... ...... ៨៨៤

អដ្ឋកថាតក្ការិយជាតក ...... ...... ...... ...... ៨៨៧

រុរុមិគជាតក ...... ...... ...... ...... ៩០៩

អដ្ឋកថា រុរុមិគជាតក ...... ...... ...... ...... ៩១៣

សរភជាតក ...... ...... ...... ...... ៩២៧

អដ្ឋកថា សរភជាតក ...... ...... ...... ...... ៩៣១